00605247

លេខ / N° : D427

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 09 / 2010
ម៉ោង (Time/Heure) : 08 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក--ក.ស.ច.ស.

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០

ភាសា ៖ ខ្មែរ/បារាំង

ចំណាត់ថ្នាក់ឯកសារ ៖ [សាធារណៈ]

# ដីកាដំណោះស្រាយ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក ANDREW CAYLEY

**ជនត្រូវចោទ**

នួន ជា
ខៀវ សំផន
អៀង សារី
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
ជេត វណ្ណលី
ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Philippe CANONNE
Elizabeth RABESANDRATANA
Mahdev MOHAN
Olivier BAHOUGNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy NGUYEN
Marie GUIRAUD
Laure DESFORGES
Christine MARTINEAU
Pascal AUBOIN
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
Ferdinand DJAMMEN-NZEPA

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
ស សុវាន Jacques VERGÈS
Philippe GRÉCIANO

00605248

# មាតិកាសង្ខេប


**សេចក្តីផ្តើម** ........................................................ ៤

ផ្នែកទី ១- ការបង្កើត អ.វ.ត.ក ........................................ ៤

ផ្នែកទី ២- ការរំលឹកឡើងវិញពីនីតិវិធី ................................ ៤

**ជំពូក ១ - ការកត់សម្គាល់ឃើញអំពីអង្គហេតុ** ......................... ៨

ផ្នែកទី ១- ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ............................ ៨

ផ្នែកទី ២- រចនាសម្ព័ន្ធរដ្ឋបាល (មជ្ឈិម) ............................ ១៥

ផ្នែកទី ៣- រចនាសម្ព័ន្ធរដ្ឋបាល (មូលដ្ឋាន) ........................... ១៥

ផ្នែកទី ៤- ប្រព័ន្ធទំនាក់ទំនង ........................................ ២៥

ផ្នែកទី ៥- រចនាសម្ព័ន្ធយោធា ......................................... ៣៥

ផ្នែកទី ៦- ជម្លោះប្រដាប់អាវុធ ........................................ ៤៥

ផ្នែកទី ៧- ការកត់សម្គាល់អំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម ............... ៤៧

ផ្នែកទី ៨- ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម ..................... ៧៣

ផ្នែកទី ៩- តួនាទីរបស់ជនត្រូវចោទ .................................... ២៨៧

**ជំពូក ២- ច្បាប់ដែលត្រូវអនុវត្ត** ..................................... ៤៣១

**ជំពូក៣- ការកំណត់ប្រភេទបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ** ......... ៤៤០

**ជំពូក ៤- ព័ត៌មាន និងបុគ្គលិកលក្ខណៈ** ................................ ៥២៧

**ជំពូក ៥- សេចក្តីសម្រេចបញ្ចប់** ....................................... ៥៣៦

**ជំពូក ៦- ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន** ............................ ៥៣៨

00605249

# មាតិកាលម្អិត

សេចក្ដីផ្ដើម

**ផ្នែកទី ១- ការបង្កើត អ.វ.ត.ក ............ ៤**

**ផ្នែកទី ២- ការរំលឹកឡើងវិញពីនីតិវិធី ............ ៤**

**ជំពូក ១- ការកត់សំគាល់ឃើញអំពីអង្គហេតុ ............ ១៣**

ផ្នែកទី ១- ប្រវត្តិបក្សកុម្មុយនីស្ដកម្ពុជា ............ ១៣

ផ្នែកទី ២- រចនាសម្ព័ន្ធរដ្ឋបាល (មជ្ឈិម) ............ ១៤

ក. បក្សកុម្មុយនីស្ដកម្ពុជា (ប.ក.ក) ............ ១៤

ខ. គណៈមជ្ឈិម ............ ១៥

គ. គណៈអចិន្ត្រៃយ៍ ............ ១៦

ឃ. មន្ទីរ ៨៧០ ............ ១៨

ង. ក្រសួងនានា (រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ) ............ ២២

ផ្នែកទី ៣- រចនាសម្ព័ន្ធរដ្ឋបាល (មូលដ្ឋាន) ............ ២៣

ផ្នែកទី ៤- ប្រព័ន្ធទំនាក់ទំនង ............ ២៥

ក. បណ្ដាញទំនាក់ទំនង ............ ២៥

ទំនាក់ទំនងនៅមជ្ឈិម ............ ២៦

ទំនាក់ទំនងពីភូមិភាគ ទៅមជ្ឈិម ............ ២៦

ទំនាក់ទំនងពីភូមិភាគ ទៅតំបន់ និងស្រុក ............ ២៧

ទំនាក់ទំនងខាងក្រៅប្រទេស ............ ២៨

ការប្រជុំ "រៀនសូត្រនៅមជ្ឈិម" ............ ២៩

ខ. មធ្យោបាយនៃទំនាក់ទំនង ............ ២៩

សំបុត្រ ............ ៣០

នីរសារ ............ ៣០

ទូរលេខ ............ ៣០

00605250


ឯកសារនយោបាយ និងឯកសារអប់រំ ..................................... ៣២

**ផ្នែកទី ៥- រចនាសម្ព័ន្ធយោធា** ..................................... ៣៥

ក. ការបង្កើត "កងទ័ពបដិវត្តកម្ពុជា" ..................................... ៣៥

ខ. តួនាទី "កងទ័ពបដិវត្តកម្ពុជា" ..................................... ៣៦

គ. អង្គភាពយោធារបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ..................................... ៣៨

គណៈកម្មាធិការយោធានៃគណៈមជ្ឈិម ..................................... ៣៧

អគ្គសេនាធិការ ..................................... ៣៩

ឃ. សមាសភាពកងទ័ពបដិវត្តកម្ពុជា ..................................... ៣៩

កងទ័ពស្រួច ..................................... ៤០

កងពលមជ្ឈិម ..................................... ៤០

កងទ័ពភូមិភាគ ..................................... ៤១

កងឈ្លប ..................................... ៤១

ង. ទំនាក់ទំនង / ព័ត៌មាន ..................................... ៤២

ទំនាក់ទំនងរវាងកងពល និងមជ្ឈិម ..................................... ៤៣

ទំនាក់ទំនងនៅតាមកងពល ..................................... ៤៣

ច. វិន័យ ..................................... ៤៣

ឆ. ការចូលរួមរបស់កងទ័ពបដិវត្តកម្ពុជានៅក្នុង "ការបោសសម្អាត" ..................................... ៤៤

**ផ្នែកទី ៦- ផ្នែកជម្លោះប្រដាប់អាវុធ** ..................................... ៤៥

**ផ្នែកទី ៧- ការកត់សម្គាល់អំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម** ..................................... ៤៧

ក. ការផ្លាស់ទីលំនៅប្រជាជន ..................................... ៤៩

កាលបរិច្ឆេទ និងការចូលរួម ..................................... ៤៩

ខ. សហករណ៍ និងការដ្ឋាន ..................................... ៥១

កាលបរិច្ឆេទ និងការចូលរួម ..................................... ៥២

គ. មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ..................................... ៥៥

កាលបរិច្ឆេទ និងការចូលរួម ..................................... ៥៨

"សីលធម៌" ..................................... ៦១

"ការបោសសម្អាត" ..................................... ៦២

00605251


ឃ. វិធានការប្រឆាំងនឹងក្រុមមនុស្សជាក់លាក់នានា ..... ៦៦

កាលបរិច្ឆេទ និងការចូលរួម ..... ៦៧

ង. ការរៀបអាពាហ៍ពិពាហ៍ ..... ៧១

កាលបរិច្ឆេទ និងការចូលរួម ..... ៧១

**ផ្នែកទី ៧- ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម** ..... ៧៣

ក. ការផ្លាស់ទីលំនៅប្រជាជន ..... ៧៣

ការជម្លៀសប្រជាជនពីភ្នំពេញ៖ ដំណាក់កាលទី១ ..... ៧៣

ការផ្លាស់ទីលំនៅប្រជាជន ពីភូមិភាគកណ្តាល (ឧត្តរចាស់), និរតី, បស្ចិម និងបូព៌ា៖ ដំណាក់កាលទី២ ..... ៨៥

ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា៖ ដំណាក់កាលទី៣ ..... ៩៣

ខ. ការដ្ឋានការងារ និងសហករណ៍ ..... ៩៩

សហករណ៍ត្រាំកក់ ..... ៩៩

ការដ្ឋានទំនប់ត្រពាំងថ្ម ..... ១០៧

ការដ្ឋានទំនប់ ១-មករា ..... ១១៤

ការដ្ឋានស្រែអំបិល ..... ១២០

ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ..... ១២៥

ការដ្ឋានព្រៃស (ស-២៤) ..... ១៣២

គ. មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ..... ១៣៧

មន្ទីរសន្តិសុខ ស-២១ ..... ១៣៧

មន្ទីរសន្តិសុខ សង់ ..... ១៥៦

មន្ទីរសន្តិសុខ ក្រាំងតាចាន់ ..... ១៦១

មន្ទីរសន្តិសុខ កោះខ្យង ..... ១៧១

មន្ទីរសន្តិសុខ ព្រៃដំរីស្រុត ..... ១៧៦

មន្ទីរសន្តិសុខ វត្តគីរីរម្យ ..... ១៨២

មន្ទីរសន្តិសុខភូមិភាគឧត្តរ ..... ១៨៨

មន្ទីរសន្តិសុខ អូរកន្សែង ..... ១៩៣

មន្ទីរសន្តិសុខ ភ្នំក្រោល ..... ២០៣

មន្ទីរសន្តិសុខ វត្តផ្លក ..... ២០៨

00605252

មន្ទីរសន្តិសុខ គោកក្ដួច ..........................................................................................២១៦
កន្លែងសម្លាប់មនុស្សក្នុងស្រុក ១២ (ភូមិភាគបស្ចឹម) .................................... ២២១
កន្លែងសម្លាប់មនុស្ស ព្រៃត្រពាំងអំពិល ........................................................ ២២១
អ្នកដែលត្រូវបានជម្លៀសក្នុងស្រុក ១២ ក្រោយថ្ងៃ១៧ មេសា........................... ២២៣
កន្លែងសម្លាប់មនុស្ស ទួលពោធិជ្រៃ ..................................................................២២៥
កន្លែងសម្លាប់មនុស្ស ស្ទឹងតូច.......................................................................... ២២៩
ឃ. ការប្រព្រឹត្តលើក្រុមមនុស្សជាក់លាក់នានា ..................................................២៣៨
ការប្រព្រឹត្តលើពុទ្ធសាសនិក............................................................................២៣៨
ការប្រព្រឹត្តលើជនជាតិចាម .............................................................................២៣៩
ការប្រព្រឹត្តលើជនជាតិវៀតណាម .....................................................................២៥៣
ង. ការរៀបអាពាហ៍ពិពាហ៍.................................................................................. ២៧១

ផ្នែកទី ៩- តួនាទីរបស់ជនត្រូវចោទ ................................................................២៨៧
ក. នួន ជា ......................................................................................................២៧៨
សាវតារ .........................................................................................................២៧៨
តួនាទី និងមុខងារ...........................................................................................២៧៨
ការចូលរួមក្នុងផែនការរួម.................................................................................. ២៨៩
ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ...........................................៣២៨
ខ. អៀង សារី ................................................................................................. ២២៩
សាវតារ ......................................................................................................... ២២៩
តួនាទី និងមុខងារ...........................................................................................៣៣០
ការចូលរួមក្នុងផែនការរួម..................................................................................៣៣៦
ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ...........................................៣៧៦
គ. ខៀវ សំផន.................................................................................................៣៧៨
សាវតារ .........................................................................................................៣៧៨
តួនាទី និងមុខងារ...........................................................................................៣៧៩
ការចូលរួមក្នុងផែនការរួម..................................................................................៣៨៧
ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ........................................... ៤០៤
ឃ. អៀង ធីរិទ្ធ ................................................................................................. ៤០៤

00605253


សាវតារ .................................................................................... ៤០៤

តួនាទី និងមុខងារ.......................................................................... ៤០៤

ការចូលរួមក្នុងផែនការរួម.................................................................. ៤១២

ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ...................................... ៤៣១

**ជំពូក ២- ច្បាប់ដែលត្រូវអនុវត្ត**............................................................... ៤៣១

**ផ្នែកទី ១- សមត្ថកិច្ចយុត្តាធិការ អ.វ.ត.ក**................................................... ៤៣១

**ផ្នែកទី ២- និយមន័យបទល្មើស**................................................................ ៤៣៥

ក. ប្រល័យពូជសាសន៍...................................................................... ៤៣៥

ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ......................................................... ៤៣៦

គ. ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ.......................................... ៤៣៧

**ផ្នែកទី ៣- ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល** ................................. ៤៣៧

**ផ្នែកទី ៤- សញ្ញាណនៃភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់**................................................. ៤៣៨

**ជំពូក ៣- ការកំណត់ប្រភេទបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ**................................. ៤៤០

**ផ្នែកទី១- យុត្តាធិការលើបុគ្គល**................................................................. ៤៤០

**ផ្នែកទី២- ការអនុគ្រោះទោស ការលើកលែងទោស និងគោលការណ៍ Ne Bis in idem** ........ ៤៤១

**ផ្នែកទី៣- បទល្មើសប្រល័យពូជសាសន៍**.......................................................... ៤៤៣

ក- បទល្មើសប្រល័យពូជសាសន៍ ដោយការធ្វើមនុស្សឃាតលើក្រុមចាម........................ ៤៤៤

ខ- បទល្មើសប្រល័យពូជសាសន៍ ដោយការធ្វើមនុស្សឃាតលើក្រុមវៀតណាម ................. ៤៤៦

**ផ្នែកទី៤- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ......................................................... ៣៤៨

ក-ធាតុផ្សំរួម ..................................................................................... ៤៤៨

អត្ថិភាពនៃការវាយប្រហារ ................................................................ ៤៤៨

លក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ............................................................... ៤៤៨

ធ្វើឡើងប្រឆាំងជនស៊ីវិល .................................................................. ៤៥២

ដោយមូលហេតុជាតិ នយោបាយ ជាតិសាសន៍ ពូជសាសន៍ ឬសាសនា ............................ ៤៥៣

ប្រព្រឹត្តឡើង "ក្នុងក្របខណ្ឌនៃការវាយប្រហារ" .................................................. ៤៥៤

ខ-បទល្មើសជាក់លាក់នានា នៃបទល្មើសប្រឆាំងមនុស្សជាតិ ......................................... ៤៥៥
ការធ្វើមនុស្សឃាត ........................................................................................ ៤៥៥
ការសម្លាប់រង្គាល ....................................................................................... ៤៥៧
ការធ្វើឱ្យទៅជាទាសករ ................................................................................ ៤៦០
ការធ្វើទារុណកម្ម ....................................................................................... ៤៦៤
ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា ........................ ៤៦៦
ការរំលោភផ្លូវភេទ ....................................................................................... ៤៧០
អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស .... ៤៧២
អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយអាពាហ៍ពិពាហ៍ដោយបង្ខំ ... ៤៧៥
អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ .............................. ៤៧៧
អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ .............................. ៤៨៣
**ផ្នែកទី៥- ការបំពារពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ** ................................. ៤៨៥
ក- ធាតុផ្សំរួម ............................................................................................. ៤៨៥
អត្ថិភាពនៃជម្រោះប្រដាប់អាវុធអន្តរជាតិ ............................................................. ៤៨៥
ជនដែលទទួលបានការការពារ ........................................................................... ៤៨៥
ទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធ និង បទឧក្រិដ្ឋ ............................................... ៤៨៦
ការដឹងឮរបស់ចារី ........................................................................................ ៤៨៧
ខ- បទល្មើសជាក់លាក់នៃការបំពារបំពានយ៉ាងធ្ងនធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ............ ៤៨៨
អំពើមនុស្សឃាតដោយចេតនា........................................................................... ៤៨៨
ការធ្វើទារុណកម្ម ....................................................................................... ៤៨៩
ការធ្វើបាបដោយអមនុស្សធម៌ ........................................................................... ៤៩០
ការបង្កឱ្យមានការឈឺចាប់ ឬ របួសខ្លាំង ដល់រាងកាយ និងសុខភាព ............................ ៤៩១
ការដកហូតដោយចេតនាពីឈ្លើយសឹក និង ជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្ដី
ប្រកបដោយយុត្តិធម៌ និង ទៀងទាត់ ................................................................... ៤៩១
ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ................................................................ ៤៩៣
ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ................................................................. ៤៩៤
**ផ្នែកទី ៦- ការកំណត់ទម្រង់នៃការទទួលខុសត្រូវ** .................................................. ៤៩៥
ក- សហឧក្រិដ្ឋកម្មរួម ................................................................................... ៤៩៥
ការទទួលខុសត្រូវតាមការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម........................................... ៤៩៦

00605255


នួន ជា ....................................................................................................៥០០

អៀង សារី ................................................................................................... ៥០១

ខៀវ សំផន ..................................................................................................៥០២

អៀង ធីរិទ្ធិ .................................................................................................៥០៣

សេចក្តីសន្និដ្ឋានទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ...................................................... ៥០៤

ខ- ទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវព្រហ្មទណ្ឌ........................................... ៥០៥

ការរៀបចំផែនការ ........................................................................................ ៥០៥

ការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ..........................................................................៥០៨

ការជួយ និងជម្រុញ........................................................................................៥១១

ការបញ្ជា ..................................................................................................... ៥១៤

ការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ....................................................................... ៥១៧

**ផ្នែកទី ៧- បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយក្រមឆ្នាំ ១៩៥៦..........................៥២២**

**ជំពូកទី ៤- ព័ត៌មាន និង បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ..................................៥២៧**

**ផ្នែកទី ១- នួន ជា** ..........................................................................................៥២៧

**ផ្នែកទី ២-អៀង សារី** ......................................................................................  ៥២៩

**ផ្នែកទី ៣-ខៀវ សំផន**...................................................................................... ៥៣២

**ផ្នែកទី ៤- អៀង ធីរិទ្ធ** .......................................................................................៥៣៤

**ជំពូកទី ៥- សេចក្តីសម្រេចបញ្ចប់**...................................................................... ៥៣៦

**ជំពូកទី ៦- ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន** ......................................................៥៣៨

**ផ្នែកទី ១- អំពីសំណើសុំនៅក្រៅឃុំរបស់ នួន ជា** ................................................ ៥៣៨

ក- ការរំលឹកឡើងវិញពីនីតិវិធី............................................................................៥៣៨

ខ- សំអាងហេតុនៃសេចក្តីសម្រេច ...................................................................... ៥៣៩

**ផ្នែកទី ២- ការរក្សាបន្តការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ** ..................................... ៥៤០

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ៥៥ វិធាន ៦៦ វិធាន ៦៧ និង វិធាន ៦៨ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញការស៊ើបសួរពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦លើឈ្មោះ៖

**- នួន ជា ភេទប្រុស កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ១៩២៦**

ជាប់ឃុំ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៧ (C9) ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨ (C9/3) និងចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៩ (C9/6)

**- អៀង សារី ភេទប្រុស កើតនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩២៥**

ជាប់ឃុំ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ (C22) ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៨ (C22/4) និងចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៩ (C22/8)

**-អៀង ធីរិទ្ធ ភេទស្រី កើតនៅថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៣២**

ជាប់ឃុំ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ (C20) ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៨ (C20/4) និងចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៩ (C20/8)



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

**-ខៀវ សំផន** ភេទប្រុស កើតនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៣១

ជាប់ឃុំ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ (C26) ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨ (C26/4) និងចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៩ (C26/8)

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ (D3)

បានឃើញដីកាសម្រេចបំបែកសំណុំរឿងរបស់យើង ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ (D18)

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៨ (D83) ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ (D៩៨/I) ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ (D146/3) ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ (D196) ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ (D146/4) ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ (D146/5) និង "សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀប រាប់នៅក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ" ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៩ (D202)

បានឃើញសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួររបស់យើង ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១០ (D317)

បានឃើញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យរបស់យើង ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១០ (D385)

បានឃើញដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១០ (D390)

**បានឃើញ**សារណារបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០ ឆ្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពរ (D390/1/2/1.3)

បានឃើញដីកាលើកលែងការចោទប្រកាន់ចំពោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១០ (D៤២០)

យល់ឃើញថា ការស៊ើបសួរបង្ហាញចេញជាលទ្ធផលនូវអង្គហេតុដូចតទៅ៖

# សេចក្តីផ្តើម

## ផ្នែកទី ១- ការបង្កើត អ.វ.ត.ក

១. បន្ទាប់ពីមានសំណើសុំជំនួយផ្លូវការពីព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧[1] កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ("កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក")[2]។

២. អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា បន្ទាប់ពីមានការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពី អ.វ.ត.ក")[3]។ អង្គជំនុំជម្រះនេះ ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០០៦។

## ផ្នែកទី ២- ការរំលឹកឡើងវិញពីនីតិវិធី

៣. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតបឋមលើបទឧក្រិដ្ឋដែលអាចប្រព្រឹត្តឡើងដោយមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៧ ស្របតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា

00605259



បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយបានចោទប្រកាន់ជនសង្ស័យចំនួនប្រាំរូប (នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផននិង កាំង ហ្គេកអ៊ាវ ហៅ ឌុច)[4] ពីអំពើឧក្រិដ្ឋកម្មដែលត្រូវចោទថា បានប្រព្រឹត្តនៅតាមទីតាំងជាច្រើន។ ហេតុនេះ សំណុំរឿងត្រូវបានបញ្ជូនមកការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ក្នុងគោលបំណងឱ្យបើកការស៊ើបសួរ ដូចមានចែងនៅក្នុងវិធាន៥៥ នៃវិធានផ្ទៃក្នុង។

៤. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឌុច ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួន និងបានបញ្ជូនទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩[5]។

៥. នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបំបែកសំណុំរឿងទាក់ទិននឹងការទទួលខុសត្រូវរបស់ ឌុច ក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់គាត់នៅមន្ទីរ ស-២១[6]។

៦. ជាមួយគ្នានេះដែរ នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ ដដែល នួន ជា ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួន និងបានបញ្ជូនទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[7]។

៧. នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ អៀង សារី ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួន និងបានបញ្ជូនទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦[8]។

៨. នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ អៀង ធីរិទ្ធ ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួន និងបានបញ្ជូនទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ គាត់ត្រូវបាន

ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦[9]។

៩. នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ **ខៀវ សំផន** ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួន និងបានបញ្ជូនទៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទប្រល័យពូជសាសន៍ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦[10]។

១០. ក្នុងអំឡុងពេលនៃការស៊ើបសួរ អង្គភាពគាំពារជនរងគ្រោះបានបញ្ជូនមកសហចៅក្រមស៊ើបអង្កេតនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤១២៨។ ក្រោយមកទៀត អ្នកដាក់ពាក្យសុំចំនួន ១០៤ នាក់ បានប្រាប់ឱ្យដឹងថា ខ្លួនចង់ផ្លាស់ប្តូររបៀបនៃការចូលរួមរបស់ខ្លួន និងឱ្យចាត់ទុកថាជាអ្នកដាក់ពាក្យបណ្តឹងធម្មតាប៉ុណ្ណោះ។ អ្នកដាក់ពាក្យចំនួន ១១ នាក់ បានដកពាក្យសុំរបស់ខ្លួនចេញ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ១៩ ត្រូវបានកត់សំគាល់ឃើញថាបានដាក់ពាក្យជាន់គ្នា និងពាក្យសុំចំនួន ៦ ត្រូវបានដាក់ឡើងវិញទៅតាមសំណើរបស់អ្នកដាក់ពាក្យសុំ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ ៩៨៨ ស្របតាមវិធាន ២៣ និង ២៣ ស្ទួន នៃវិធានផ្ទៃក្នុង[11]។ នៅពេលនេះ សហចៅក្រមស៊ើបអង្កេតបានកត់សំគាល់ឃើញថា អ្នកដាក់ពាក្យចំនួន១៨ នាក់ បានស្លាប់ បន្ទាប់ពីបានដាក់ពាក្យសុំ។

១១. អ្នកដាក់ពាក្យសុំប្រមាណជា ៤០% រស់នៅក្នុងខេត្តកំពត ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។ អ្នកដាក់ពាក្យសុំចំនួន ១៣៣ នាក់ រស់នៅបរទេស ជាពិសេសនៅសហរដ្ឋអាមេរិក និងប្រទេសបារាំង។ នៅក្នុងចំណោមអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មានស្ត្រីលើសពីចំនួន ៦០%។ ចំនួនពាក់កណ្តាលនៃអ្នកដាក់ពាក្យសុំ មានអាយុចន្លោះពី ១៨ ដល់ ៣៥ ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លើសពីមួយភាគបី គឺជាអនីតិជន និងមាន ២៤ នាក់ បានកើតបន្ទាប់ពីការបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[12]។ ការដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៨២% បានធ្វើឡើងដោយមានជំនួយពី អន្តរការី សមាគម ឬអង្គការមិនមែន

រដ្ឋាភិបាល ហើយលើសពីពាក់កណ្ដាលតាមរយៈ សមាគមអាដហុកការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា[13]។

១២. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២១២៣ ត្រូវបានសម្រេចទទួលយកដោយសហចៅក្រមស៊ើបអង្កេត[14]។ ពាក្យសុំមួយចំនួន ត្រូវបានសម្រេចមិនទទួលយក ដោយមូលហេតុចម្បងគឺ ជនរងគ្រោះបានទទួលរងនូវព្យសនកម្មដោយប្រយោលពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ប៉ុន្តែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលមិនទទួលយក ត្រូវបានរក្សាទុកនៅក្នុងសំណុំរឿងដូចជាពាក្យបណ្ដឹង រួមជាមួយនឹងពាក្យបណ្ដឹងចំនួន ៤១៥១ ទៀត ដែល បានដាក់ចូលក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញា។ ដូច្នេះ វាគឺជាពាក្យបណ្ដឹងចំនួន ៦២៧៤ ដែលភាគីនានាអាចប្រើប្រាស់ជាព័ត៌មានបាន។ ចំនួននេះមានលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយហេតុថាសេចក្ដីសម្រេចមួយចំនួនកំពុងជាប់បណ្ដឹងឧទ្ធរណ៍។

១៣. នៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងភាគីនានាថាការស៊ើបអង្កេត ត្រូវបានបញ្ចប់ហើយ[15]។ ដូច្នេះ ភាគីនានាបានធ្វើសំណើសុំមួយចំនួន ស្របតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេត បានបំពេញកិច្ចស៊ើបសួរ ឬបដិសេធសំណើសុំ តាមរយៈដីកាសម្រេច ស្របតាមវិធាន ៦៦(២)។ នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានជូនដំណឹងថា ខ្លួននឹងសម្រេចលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ដែលបានប្ដឹងបន្ទាប់ពីការចេញដីការបស់សហចៅក្រមស៊ើបអង្កេត[16]។ តាមរយៈដីកាចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១០ សំណុំរឿងត្រូវបានបញ្ជូនទៅការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ដូចមានចែងនៅក្នុងវិធាន ៦៦[17]។

១៤. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរ ដែលនៅក្នុងដីកានោះ ខ្លួនបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ទៅលើ **នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន** និងធ្វើការបញ្ជូនទៅជំនុំជម្រះពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦[18]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៥. នៅក្នុងដីកាសន្និដ្ឋានបន្ថែមដែលធ្វើឡើងនៅថ្ងៃតែមួយ សហព្រះរាជអាជ្ញា បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាលើកលែងការចោទប្រកាន់ចំពោះ ឌុច[19]។ លើចំនុចនេះ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចមួយដោយឡែក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១០[20]។

១៦. ជាចុងក្រោយ នៅថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១០ **អៀង សារី** បានដាក់សារណា ឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា[21]។ សារណានេះត្រូវបានបដិសេធចោលដោយសហចៅក្រមស៊ើបអង្កេត ដោយសារវាមានចំនួនទំព័រលើសពីការអនុញ្ញាត ស្របតាមមាត្រា ៥(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក[22]។ ហេតុនេះ **អៀង សារី** បានប្តឹងឧទ្ធរណ៍[23]។ អង្គបុរេជំនុំជម្រះបានសម្រេចបណ្តឹងឧទ្ធរណ៍នេះ តាមរយៈសាលដីកាចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១០ ដោយបង្គាប់ឱ្យដាក់សារណានេះទៅក្នុងសំណុំរឿង និងបញ្ជាក់ថា *"សេចក្តីសម្រេចដោយមានសំអាងហេតុ លើបណ្តឹងឧទ្ធរណ៍នេះ នឹងត្រូវចេញប្រកាសនាពេលសមស្របខាងមុខ"*[24]។

១៧. ក្រៅពីឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ដើម្បីគាំទ្រដល់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនភស្តុតាងដែលបានដាក់ចូលក្នុងសំណុំរឿងមាន ៖ កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទចំនួន ៥៦, កំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីលើសពី ១.០០០, របាយការណ៍កំណត់ទីតាំងចំនួន ៣៦, របាយការណ៍របស់អ្នកជំនាញខាងប្រជាសាស្ត្រចំនួនមួយ, ព្រមទាំងរបាយការណ៍របស់អ្នកជំនាញខាងវេជ្ជសាស្ត្រជាច្រើន, និងឯកសារលើសពី ១១.៦០០ បានដាក់ចូលក្នុងសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងដោយមេធាវីរបស់ពួកគេ ដែលសរុបទាំងអស់មានចំនួនលើសពី ៣៥០០០០ ទំព័រ ដែលក្នុងនោះមានលើសពី ២២៣ ០០០ ទំព័រ ទាក់ទិននឹងអង្គហេតុ។

# ជំពូក ១- ការកត់សម្គាល់ឃើញអំពីអង្គហេតុ

## ផ្នែកទី ១- ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

១៨. អត្ថិភាពរបស់បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ត្រូវបានប្រកាសជាផ្លូវការ នាខែកញ្ញា ឆ្នាំ ១៩៧៧

ខណៈដែលបក្សកុម្មុយនីស្តកម្ពុជានេះកាន់អំណាចបានជាងពីរឆ្នាំមកហើយ (ពីដើមឡើយពាក្យ "អង្គការ" ត្រូវបានប្រើប្រាស់តាំងពីទស្សវត្សន៍ឆ្នាំ១៩៤០ និង មានន័យថា "អង្គការចាត់តាំង" ដោយសំដៅដល់បក្សទាំងមូលផង និងសំដៅដល់ថ្នាក់ដឹកនាំនៅកំរិតផ្សេងៗទៀតផង ដោយមិនបានបញ្ជាក់ច្បាស់លាស់ពីអ្វីផ្សេងពីនេះទៀតឡើយ)។ នៅក្នុងប្រទេសកម្ពុជា ក្រុមដែលបានប្រកាន់យកមនោគមវិជ្ជាកុម្មុយនីស្តមានអត្ថិភាព ចាប់តាំងតែពីមុនកាលបរិច្ឆេទនេះមកម្ល៉េះ។ ទោះបីជា ប.ក.ក មាននិន្នាការតាក់តែងប្រវត្តិសាស្ត្រខ្លួនឡើងវិញក៏ដោយ[២៥] ក៏គេនៅអាចកំណត់បាននូវការវិវឌ្ឍរបស់បក្សនេះតាមរយៈកាលបរិច្ឆេទសំខាន់ៗជាច្រើនដែលមានសារសំខាន់ដល់ការស៊ើបសួរ[២៦]។

**១៩.** អង្គការចាត់តាំងមួយក្នុងចំណោមអង្គការចាត់តាំងកុម្មុយនីស្តដំបូងនៅក្នុងតំបន់នេះ គឺបក្សកុម្មុយនីស្តឥណ្ឌូចិន (ប.ក.ឥ) ដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៣០ ដោយមានការទទួលឥទ្ធិពលយ៉ាងខ្លាំងពីជនកុម្មុយនីស្តវៀតណាម។ បក្សកុម្មុយនីស្តកម្ពុជាឥណ្ឌូចិនត្រូវបានរំលាយជាផ្លូវការនៅក្នុងឆ្នាំ១៩៥១ ហើយអតីតសមាជិករបស់បក្សនេះក៏បានបង្កើតអង្គការបដិវត្តដាច់ដោយឡែកពីគ្នានៅក្នុងប្រទេសនីមួយៗ។ បក្សថ្មីមួយដែលត្រូវបានបង្កើតឡើងនៅកម្ពុជា មានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ" (ប.ជ.ប.ខ)។ ប.ជ.ប.ខ មានឥទ្ធិពលខ្លាំងនៅក្នុងបណ្តាក្រុម*ឥស្សរៈ* ដែលបានតតាំងទាមទារយកឯករាជ្យ[២៧] ហើយទីបំផុតការទាមទារនេះបានទទួលជោគជ័យ និងបានទទួលស្គាល់ នៅឯសន្និសីទនាទីក្រុងហ្សឺណែវ ក្នុងឆ្នាំ១៩៥៤។

**២០.** ឯកសារ និងសេចក្តីថ្លែងការណ៍ផ្លូវការនានារបស់ ប.ក.ក ក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ បង្ហាញថា មហាសមាជនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដែលពេលនោះ ប.ជ.ប.ខ ត្រូវប្តូរឈ្មោះទៅជា "បក្សពលករខ្មែរ" (ប.ព.ខ) គឺជាចំណុចចាប់ផ្តើមពិតប្រាកដនៃការបង្កើតចលនាកុម្មុយនីស្តខ្មែរ[២៨]។ មានមនុស្សចំនួនប្រមាណ ២០នាក់បានចូលរួមក្នុងសមាជនេះ ដែលក្នុងនោះមាន **នួន ជា** (អនុលេខាបក្សដែលបានទទួលការបោះឆ្នោតតែងតាំង), សាឡុត ស ហៅ ប៉ុល ពត (សមាជិកគណៈអចិន្ត្រៃយ៍), **អៀង សារី** និង សោ ភឹម (សមាជិកបម្រុងនៃគណៈអចិន្ត្រៃយ៍) និង វន វ៉េត[29]។ ការចេញផ្សាយទស្សនាវដ្តីទង់បដិវត្ត (ជាទស្សនាវដ្តីមួយក្នុងចំណោមទស្សនាវដ្តីផ្លូវការរបស់បក្ស) នៅខែសីហា ឆ្នាំ១៩៧៥ បានលើកឡើងថា "*មាគ៌ាជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា បានធ្វើឡើងច្បាស់លាស់ និងត្រឹមត្រូវជាមូលដ្ឋាននៅឆ្នាំ១៩៦០ ក្នុងមហាសន្និបាត បក្សលើកទី I (ពិតមែនតែបក្សយើងកកើតតាំង ពីឆ្នាំ១៩៥១ម្ល៉េះ)*"[៣០]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

នៅថ្ងៃ ទី៣០ ខែមីនា ឆ្នាំ ១៩៧៦ គណៈមជ្ឈិមបានសម្រេចថា *"កំណត់ កំណើតបក្ស ពីឆ្នាំ១៩៦០វិញ មិនយកឆ្នាំ ១៩៥១ ទេ ដើម្បីកុំឱ្យជាប់ជាមួយគេឯង-ឱ្យដាច់ស្រឡះ"*[៣១]។ នួន ជា បានលើកឡើងថា បើគ្មានរូបលោកផ្ទាល់ និង ប៉ុល ពត ទេ ប.ក.ក នឹងត្រូវបានវៀតណាម ក្ដោបក្ដាប់ទៅហើយ[៣២]។

**២១.** បន្ទាប់ពីសន្និសីទទនាឆ្នាំ ១៩៥៤ ចលនាកុម្មុយនីស្តបានបង្កើតក្រុមមួយជាសាធារណៈ គឺក្រុមប្រជាជន និង ព្យាយាមកែទម្រង់ឱ្យទៅជារបបសង្គមនិយម តាមរយៈដំណើរការប្រជាធិបតេយ្យ។ ប៉ុន្តែ ក្រោមការបង្ក្រាបខ្លាំងក្លារបស់រដ្ឋាភិបាល មេដឹកនាំ ប.ព.ខ បានពិចារណាអំពីការតស៊ូចាំបាច់ដោយអាវុធដើម្បីយកជ័យជំនះ ហើយបានចាប់ផ្ដើមរៀបចំការតស៊ូនេះដើម្បីដណ្ដើមយកអំណាចរបស់រដ្ឋ[៣៣]។ នាដើមទស្សវត្សន៍ឆ្នាំ១៩៦០ ប.ព.ខ បានបង្កើតកងការពារសម្ងាត់[៣៤] ដើម្បីការពារកម្មាភិបាល និងសកម្មភាពនយោបាយរបស់ខ្លួន រួមទាំងដើម្បី "កម្ទេចខ្មាំង"។ ឌុច បានបញ្ជាក់ថា គោលនយោបាយនេះ បានអនុម័តនៅក្នុងពេលមហាសន្និបាតលើកទីមួយ *"ដើម្បីអូសទាញកម្លាំងដែលស្ទាក់ស្ទើរ អព្យាក្រឹត្យ កម្លាំងមិនយោរយៅ ឯកោ ហើយកម្ទេចកម្លាំងដែលសេសសល់"*[35]។

**២២.** បន្ទាប់ពីការបាត់ខ្លួន លេខាបក្សពលករកម្ពុជាឈ្មោះ ទូ សាមុត នៅឆ្នាំ១៩៦២ (មិនដែលមានការបំភ្លឺច្បាស់លាស់អំពីរឿងនេះ) សមាជលើកទី២របស់បក្សត្រូវបានធ្វើឡើងនៅចុងខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលពេលនោះ សាឡុត ស បានក្លាយខ្លួនជាលេខាបក្សថ្មី ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែល[36]។ សមាជនេះ ត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយមានកម្រិតចំនួនអ្នកចូលរួមត្រឹមមនុស្សសំខាន់ៗ ដូចជា **អៀង សារី** និង សោ ភឹម (អ្នកទាំងពីរត្រូវបានបោះឆ្នោតជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍), តា ម៉ុក, វន វេត, សុន សេន, រស់ ញឹម និង គង់ សុផល[37]។ ប៉ុន្មានខែក្រោយមក បន្ទាប់ពីរដ្ឋាភិបាលបានចេញផ្សាយនូវបញ្ជីឈ្មោះមនុស្សដែល គេស្គាល់ថាជា "អ្នកឆ្វេងនិយម" ចំនួន ៣៤ រូប[38] ប៉ុល ពត និង មេដឹកនាំ បក្សពលករកម្ពុជាមួយចំនួនដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង **អៀង សារី** និង សុន សេន ក៏បានភៀសខ្លួនពីទីក្រុង។ អ្នកទាំងនោះបានទៅជ្រកកោននៅឯបន្ទាយវៀតណាមមួយនៅតាមបណ្ដោយព្រំដែនដែលនៅ ទីនោះពួកគេបានបង្កើតមន្ទីរមួយ ឈ្មោះថា មន្ទីរ ១០០[39]។ មកដល់ឆ្នាំ១៩៦៥ ប្រពន្ធរបស់ អ្នកទាំងនោះ ដូចជា ខៀវ ប៉ុណ្ណារី, **អៀង ធីរិទ្ធ**, និង យុន យ៉ាត បានចូលរួមជាមួយពួកគេនៅមន្ទីរ ១០០ នោះ[40]។ ដោយសារអត្តសញ្ញាណរបស់ នួន ជា មិនត្រូវបានគេស្គាល់ ហើយឈ្មោះ របស់គាត់ពុំស្ថិតនៅ

00605265



ក្នុងបញ្ជីឈ្មោះមនុស្សទាំង៣៤នាក់នោះ គាត់បានបន្តស្នាក់នៅភ្នំពេញ និង ទទួលបន្ទុករាល់ប្រតិបត្តិការនានារបស់បក្សពលករកម្ពុជាក្នុងទីក្រុង និងតំបន់ជាច្រើន[41]។

២៣. នៅខែមករា ឆ្នាំ១៩៦៥ ប.ព.ខ បានអនុម័តសេចក្តីសម្រេចមួយដែលបានទាត់ចោលនូវលទ្ធភាពនៃការ "*ការផ្លាស់ប្តូរដោយសន្តិវិធី*" ទៅកាន់លទ្ធិសង្គមនិយម និងបានបញ្ជាក់អះអាងថា "*ជាការចាំបាច់ដែលត្រូវប្រើប្រាស់ហិង្សាបដិវត្តន៍*" ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិ[42]។ ក្នុងអង្គប្រជុំគណៈមជ្ឈិមកាលពីខែកញ្ញា ឬខែតុលា ឆ្នាំ១៩៦៦ មេដឹកនាំបក្សពលករកម្ពុជាបាន សម្រេចប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា (ទោះជាគេរក្សាសេចក្តីសម្រេចនោះទុកជាការសម្ងាត់រហូតដល់សមាជបក្សលើកក្រោយក្តី) និងប្តូរទីតាំងមន្ទីរ១០០ ទៅខេត្តរតនគិរី និងបានចាប់ផ្តើមរៀបចំការតស៊ូប្រដាប់អាវុធនៅតាមតំបន់នីមួយៗ[43]។ នៅអំឡុងឆ្នាំ១៩៦៧ មេដឹកនាំមួយចំនួនរបស់បក្សបានឯកភាពធ្វើការបះបោរប្រដាប់អាវុធមួយនៅឆ្នាំ១៩៦៨[44]។ មិនយូរប៉ុន្មាន ទីស្នាក់ការគណៈមជ្ឈិមថ្មីមួយ (ឈ្មោះ មន្ទីរ ១០០ ដែរ) ត្រូវបានបង្កើតឡើងក្នុងខេត្តរតនគិរី ចម្ងាយប្រហែលប៉ុន្មានគីឡូម៉ែត្រពី "មន្ទីរ ១០២" ដែលជាមន្ទីរភូមិភាគឦសានដែលត្រូវបាន ប្រើប្រាស់ដោយ **អៀង សារី** (គាត់ត្រូវបានតែងតាំងជាលេខាភូមិភាគ) [45]។

២៤. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ តាមបញ្ជារបស់ នួន ជា កងកម្លាំងរបស់ ប.ក.ក បានវាយប្រហារបន្ទាយកងទ័ពរបស់រដ្ឋាភិបាលនៅភូមិបាយដំរាំ, ភាគខាងត្បូងក្រុងបាត់ដំបង ដោយរឹបអូសបានអាវុធមួយចំនួន[46]។ បន្ទាប់មក កាលបរិច្ឆេទខាងលើនេះត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាថ្ងៃកំណើតរបស់កងទ័ពបដិវត្តកម្ពុជា[47]។ នៅប៉ុន្មានខែបន្ទាប់ កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជាបានបន្តការវាយប្រហាររបស់ខ្លួននៅទូទាំងប្រទេស[48]។

២៥. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចនរោត្តមសីហនុត្រូវបានឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរីមតៈ ទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយឈ្មោះថា "សាធារណរដ្ឋខ្មែរ"[49]។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចសីហនុបានប្រកាសអំពីការបង្កើត "រណសិរ្សរួបរួមជាតិកម្ពុជា" (FUNK) និងបានអំពាវនាវឲ្យអ្នកស្នេហាជាតិធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលថ្មី[50]។ សម្តេចសីហនុ និងបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតសម្ព័ន្ធភាពមួយ និងរដ្ឋាភិបាលនិរទេសមួយដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង មានឈ្មោះថា "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" (GRUNK)។

រដ្ឋាភិបាលនេះត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០[51]។ [លុប] [លុប] ជាអតីតប្រធាន "រណសិរ្សរួបរួមជាតិកម្ពុជា" ហើយលោក ប៉ែន នុត ដែលមិនមែនជាជនកុម្មុយនីស្ត ជានាយករដ្ឋមន្ត្រីនៃ "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" [52] រីឯ **ខៀវ សំផន** ជាអតីតឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ខែសីហា ឆ្នាំ១៩៧០ **អៀង ធីរិទ្ធ** ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រី ក្រសួងវប្បធម៌ អប់រំ និង យុវជន[53]។

**២៦.** នាពេលនោះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចាកចេញពីខេត្តរតនគិរី និងបានចាប់ផ្តើមធ្វើដំណើរអស់រយៈពេលប៉ុន្មានខែ ទៅភាគខាងត្បូងស្ទឹងជីនិត តាមបណ្តោយព្រំប្រទល់ខេត្តកំពង់ចាម និងកំពង់ធំ ដែលជាទីតាំងទីស្នាក់ការលេខាភូមិភាគឧត្តរឈ្មោះ កុយ ធួន[54]។ ដំបូង ប៉ុល ពត និង នួន ជា បានស្នាក់នៅឯបន្ទាយមួយឈ្មោះ ក-១ ស្ថិតនៅភូមិដងក្តារ ប៉ែកឦសាននៃឃុំស្ទឹ[55] បន្ទាប់មកនៅចុងឆ្នាំ១៩៧០ ពួកគេបានប្តូរទៅកាន់ទីតាំងធំក្បែរនោះ និងត្រូវបានគេឱ្យឈ្មោះថា មន្ទីរ ស-៧១[56]។ ក្នុងចំណោមមេដឹកនាំបក្សដែលបោះមូលដ្ឋាននៅទីកន្លែងនេះមានដូចជា ប៉ុល ពត, នួន ជា, **ខៀវ សំផន** និង ឈឹម សំអោក ហៅ ប៉ង់[57]។

**២៧.** នៅខែធ្នូ ឆ្នាំ១៩៧០ **អៀង សារី** បានធ្វើដំណើរទៅហាណូយ ដើម្បីរៀបចំឡើងវិញនូវ "វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា" ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងរបស់ **អៀង ធីរិទ្ធ** រហូតដល់ខែឧសភា ឆ្នាំ ១៩៧៥[58]។ បន្ទាប់មក នៅក្នុងខែមេសា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំងដើម្បីស្នាក់នៅជាមួយ [លុប] និងធ្វើជា "បេសកជនពិសេសនៃចលនាតស៊ូ"[59]។ នៅឯភូមិគ្រឹះរបស់គាត់នៅទីក្រុងប៉េកាំង **អៀង សារី** មានទំនាក់ទំនងតាមរយៈទូរលេខផ្ទាល់ជាមួយមន្ទីរ ស-៧១[60]។

**២៨.** នៅខែមករា ឆ្នាំ១៩៧១ គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នាជាលើកទីមួយចាប់តាំងពីខែតុលា ឆ្នាំ១៩៦៦ រយៈពេល៣ថ្ងៃ នៅមន្ទីរ ស-៧១ ដោយមានសមាជិកចូលរួមចំនួន២៧រូប ក្នុងនោះមាន ប៉ុល ពត, នួន ជា, សោ ភឹម, វន វេត, តា ម៉ុក, រស់ ញឹម, គង់ សុផល, ជូ ជេត, កង ចាប, កុយ ធួន, កែ ពក, សឿ វ៉ាស៊ី ហៅ ឌឿន និង ប៉ង់[61]។

**២៩.** តាមរយៈវគ្គរៀនសូត្រដែលដឹកនាំដោយ ប៉ុល ពត ឆ្នាំ១៩៧១ នៅឯទីស្នាក់ការភូមិភាគឧត្តរ ចំពោះ

កម្មាភិបាលស្រុក តំបន់ និងភូមិភាគចំនួន២០០នាក់ ចូលរួម ត្រូវបានជ្រើសរើស និងត្រូវបាននាំចេញទៅប៉ុន្មានគីឡូម៉ែត្រពីទីនោះឆ្ពោះទៅកាន់ជំរំមួយនៅក្នុងព្រៃ ដែលជាកន្លែងប្រារព្ធសមាជបក្សលើកទី៣[62]។ សមាជលើកនេះមានប្រតិភូចូលរួមប្រហែល៦០នាក់ ក្នុងនោះមាន **ខៀវ សំផន**, លេខាភូមិភាគទាំងអស់, និងមេបញ្ជាការយោធា ដូចជា កែ ពក ជាដើម[63]។ សមាជនេះ បាន អនុម័តលក្ខន្តិកៈបក្សថ្មី ទទួលយកជាផ្លូវការនូវឈ្មោះ "បក្សកុម្មុយនីស្តកម្ពុជា" ដែលត្រូវបានប្រើប្រាស់អស់រយៈពេល៥ឆ្នាំរួចមកហើយ និងបានបោះឆ្នោតតែងតាំងគណៈមជ្ឈិមថ្មី ដែលបានដាក់បញ្ចូល ខៀវ សំផន ជាសមាជិក "បម្រុង" ឬ សមាជិក "ត្រៀម" [64]។

៣០. នៅខែឧសភា ឆ្នាំ១៩៧២ គណៈមជ្ឈិមថ្មីបានជួបប្រជុំគ្នា។ នៅក្នុងឱកាសនេះ គណៈមជ្ឈិមថ្មីបានចេញសេចក្តីណែនាំទៅកាន់សមាជិកបក្សឲ្យខំពង្រឹងការតស៊ូប្រឆាំងនឹង "វណ្ណៈជិះជាន់ផ្សេងៗ" និងបានឯកភាពលើផែនការសមូហភាវូនីយកម្មវិស័យកសិកម្ម[65]។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងជាផ្លូវការនូវសហករណ៍ នៅតាមបណ្តាតំបន់នានា ដែលពួកគេបានចូលកាន់កាប់មួយឆ្នាំក្រោយមក ពោលគឺនៅថ្ងៃទី២០ខែឧសភា ឆ្នាំ១៩៧៣[66]។

៣១. បន្ទាប់មកទៀតនៅឆ្នាំ១៩៧៣ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតមូលដ្ឋានជួរមុខថ្មីមួយនៅក្បែរភូមិច្រកស្តេច ខាងលិចឧត្តុង្គ ក្នុងស្រុកកំពង់ត្រឡាចលើ ជិតនឹងទីតាំងទីស្នាក់ការភូមិភាគពិសេសរបស់ វន វេត និងបន្ទាយបញ្ជាការរបស់ សុន សេន[67]។ កងវរៈសេនាតូចចំនួន២៥ របស់បក្សកុម្មុយនីស្តកម្ពុជា បានកាន់កាប់ទីតាំងនានាជុំវិញតំបន់ឧត្តុង្គ និងបានបើកការវាយប្រហារទៅលើទីតាំងអតីតរាជធានីមួយនេះ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៤[68]។

៣២. នៅខែមិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិមបានជួបប្រជុំគ្នានៅឃុំ ព្រែកកោក នៅជិតអតីតទីតាំងមន្ទីរ ក-១ និង "បានសម្រេចបើកការវាយលុកផ្តាច់ព្រ័ត្រ ដើម្បីរំដោះភ្នំពេញ និងប្រទេសទាំងមូល"[69]។ ការវាយប្រហារផ្តាច់ព្រ័ត្រយកទីក្រុងភ្នំពេញត្រូវបានចាប់ផ្តើមអនុវត្តនៅខែមករា ឆ្នាំ១៩៧៥[70]។ នៅដើមខែមីនា ឆ្នាំ១៩៧៥ ប៉ុល ពត បានបង្កើតមូលដ្ឋានបញ្ជាការមួយនៅភូមិស្តុកទាល់ ស្រុកឧត្តុង្គ ឬពញាឮ ចម្ងាយប្រហែល៣០គីឡូម៉ែត្រប៉ុណ្ណោះពីភ្នំពេញ[71]។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា "បានរំដោះយកបានអ្នកលឿង" លន់ នល់ បានចុះពីតំណែង និងនិរទេសខ្លួនទៅរដ្ឋហាវ៉ៃ[72]។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានចូលមកដល់ទីក្រុងភ្នំពេញ[73]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

# ផ្នែកទី ២- រចនាសម្ព័ន្ធរដ្ឋបាល (មជ្ឈិម)

## ក. បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក)

៣៣. មកទល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈ ដែលដំបូងឡើយត្រូវបានអនុម័តក្នុងឱកាសសមាជលើកទី១របស់បក្សនៅខែកញ្ញា ឆ្នាំ១៩៦០[74]។ លក្ខន្តិកៈថ្មីនៃបក្សកុម្មុយនីស្តកម្ពុជា[75]ត្រូវបានអនុម័តដោយសមាជបក្សលើកទី៤[76] នៅក្នុងខែមករា ឆ្នាំ១៩៧៦។ លក្ខន្តិកៈថ្មីនេះបានរៀបរាប់អំពីមនោគមវិជ្ជា លក្ខខណ្ឌនៃការចូលជាសមាជិក រចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃបក្សកុម្មុយនីស្តកម្ពុជា និងមានចែងផងដែរអំពីស្ថាប័នរដ្ឋមួយចំនួនដូចជា៖ កងទ័ពបដិវត្តន៍កម្ពុជា[77] ប្រព័ន្ធគណៈកម្មាធិការបក្សថ្នាក់ជាតិ[78] គណៈមជ្ឈិមបក្ស[79] រួមទាំងមន្ទីរ និងក្រសួងផ្សេងៗជុំវិញគណៈមជ្ឈិម[80]។ បក្សត្រូវបានគ្រប់គ្រងដោយគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម[81]។

៣៤. លក្ខន្តិកៈនេះក៏បានគូសបញ្ជាក់ទៀតថា បក្សកុម្មុយនីស្តកម្ពុជាត្រូវដើរតាមប្រព័ន្ធ "*របបដឹកនាំសមូហភាព*"[82] ដែលផ្អែកលើគោលការណ៍ "*ប្រជាធិបតេយ្យប្រមូលផ្តុំ*"[83]។ នៅពេលគេយកគោលការណ៍នេះមកអនុវត្តចំពោះប្រព័ន្ធគណៈកម្មាធិការនេះ មានន័យថាសមាជិកត្រូវធ្វើសេចក្តីសម្រេចរួមជាមួយសមាជិកផ្សេងទៀត និងពុំអាចសម្រេចជាលក្ខណៈបុគ្គលបានឡើយ[84] ដោយបញ្ជាក់ថាសមាជិកត្រូវបានចាត់ឱ្យទទួលខុសត្រូវតាមផ្នែកជាក់លាក់តាមការកំណត់។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ មានសរសេរថា "*តាំងពីទូរលេខ ឡើងទៅពេលទទួលបានភ្នាមមន្ទីរត្រូវប្រគល់ឱ្យផ្នែកទទួលខុសត្រូវភ្លាម ឱ្យគេពិនិត្យពិចារណា ហើយស្នើអចិន្ត្រៃយ៍បញ្ហាខ្លះ*"[85]។

៣៥. គណៈមជ្ឈិម ក៏ដូចជាគណៈអចិន្ត្រៃយ៍មានសមាសភាពសមាជិក "ពេញសិទ្ធិ" និង សមាជិក "ត្រៀម" (ឬ "បម្រុង") ។ សមាជិក "ត្រៀម" មានឋានៈទាបជាងសមាជិក "ពេញសិទ្ធិ"[86]៖ សមាជិក "ពេញសិទ្ធិ" មានសិទ្ធិ "*ពិគ្រោះពិភាក្សា និងរួមមតិសម្រេច*" ក្នុងគ្រប់វិស័យទាំងអស់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័ននេះ[87] ចំណែកឯសមាជិក "ត្រៀម" ត្រូវបានអនុញ្ញាតឱ្យចូលរួមប្រជុំតែប៉ុណ្ណោះ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតសម្រេចនោះទេ[88]។ នៅថ្នាក់គណៈមជ្ឈិម អ្នកដែលមិនមែនជាសមាជិក "ពេញសិទ្ធិ" ពុំមាន "*អំណាចសម្រេចលើការកម្ទេចនរណាម្នាក់នោះទេ*"[89]។ យោងតាមសក្ខីកម្មរបស់ ឌុច មានតែសមាជិកគណៈមជ្ឈិមប៉ុន្មាននាក់ប៉ុណ្ណោះ ដែលមានជាផ្លូវការនូវអំណាចមួយនេះ[90]។ "ជំនួយការ" របស់គណៈមជ្ឈិម ដែលទោះបីជាមិនមានឋានៈជាសមាជិកក៏ដោយ

ក៏នៅលើទិដ្ឋភាពមួយចំនួន ពួកគេមាន ឋានៈមួយដែលស្រដៀងគ្នាទៅនឹងសមាជិកផងដែរ ព្រោះពួកគេត្រូវបានអនុញ្ញាតឲ្យចូលរួមជាមួយសមាជិក "ពេញសិទ្ធិ" និងសមាជិក "ត្រៀម" ក្នុងវគ្គបណ្តុះបណ្តាលនយោបាយដែលត្រូវបានរៀបចំសម្រាប់ថ្នាក់មជ្ឈិមបក្ស[91]។

៣៦. យោងតាមការបង្ហាញជាផ្លូវការ ស្ថាប័នផ្សេងៗទៀតដែលចំណុះឲ្យបក្សមានដូចជា សភាតំណាងប្រជាជន (ដែលគេបាននិយាយថាត្រូវបានបោះឆ្នោតជ្រើសរើសនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦[92] សូមមើលផ្នែកនៃដីកាដំណោះស្រាយដែលនិយាយអំពីតួនាទី និងមុខងាររបស់ នួន ជា) គណៈប្រធានរដ្ឋ (សូមមើលផ្នែកនៃដីកាដំណោះស្រាយដែលនិយាយអំពីតួនាទី និងមុខងាររបស់ ខៀវ សំផន) ព្រមទាំង គណៈចាត់តាំងនៃគណៈមជ្ឈិមបក្ស (ដែលដឹកនាំដោយ នួន ជា) ដែលត្រូវបានប្រគល់សិទ្ធិក្នុងការតាមដាន និងត្រួតពិនិត្យសមាជិកបក្ស និងចាត់ចែងការបញ្ជូលពួកគេទៅតាមមន្ទីរ និងក្រសួងនានា[93]។

## ខ. គណៈកម្មាធិការមជ្ឈិម

៣៧. អនុលោមតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គណៈកម្មាធិការមជ្ឈិមមានតួនាទីក្នុងការ "*អនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល*" ព្រមទាំង "*ណែនាំអង្គការភូមិភាគតំបន់*" ក៏ដូចជា "*គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល*"[94]។

៣៨. សមាជិកគណៈមជ្ឈិម[95] រួមមាន ប៉ុល ពត (ដែលនៅក្នុងប្រព័ន្ធផ្សព្វផ្សាយផ្លូវការត្រូវបានគេស្គាល់ថា ជា "*លេខាគណៈមជ្ឈិម*"[96]) នួន ជា (អនុលេខាគណៈមជ្ឈិម[97]) អៀង សារី ខៀវ សំផន កុយ ធួន (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[98]) តា ម៉ុក, ណៃ សារ៉ាន់ ហៅ យ៉ា (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[99]) សឿង និង កែ ពក។ លើសពីនេះ ស៊ើ វ៉ាស៊ី ហៅ ឌឿន ដែលជាប្រធានមន្ទីរនយោបាយ ៨៧០ (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[100]) ក៏ជាសមាជិកមួយរូបនៃគណៈមជ្ឈិមផងដែរ[101]។ ឈឹម សំអោក ហៅ ប៉ង់ ពេលខ្លះត្រូវបានចាត់ទុកថាជា "សមាជិក" នៃគណៈមជ្ឈិម ឯពេលខ្លះទៀតជា "ជំនួយការ" នៃគណៈកម្មាធិការនេះ[102]។ ជាងនេះទៀត លេខាភូមិភាគដទៃទៀត និងយ៉ាងហោចណាស់លេខាតំបន់មួយចំនួន ក៏ជាសមាជិកគណៈមជ្ឈិមផងដែរ ហើយកម្មាភិបាលយោធាមួយចំនួនក៏ជាសមាជិកផងដែរ[103]។ សាក្សីមួយចំនួនក៏បានបញ្ជាក់ដែរថា អៀង ធីរិទ្ធ បានចូលប្រជុំគណៈមជ្ឈិមផងដែរ[104]។

00605270



៣៩. បន្ថែមលើនេះ នៅក្នុងគណៈមជ្ឈិម ក៏មានគណៈយោធាពិសេសមួយ[105] ឬគណៈយោធាជាន់ខ្ពស់[106] ដែលសមាសភាពដើមដំបូងមានដូចជា ប៉ុល ពត នួន ជា សុន សេន[107] សោ ភឹម និង តា ម៉ុក[108] ហើយ វ៉ន វេត[109] និង កែ ពក បានក្លាយជាសមាជិកគណៈយោធានៅពេលក្រោយមក[110] ។ ឌុច បានអះអាងថា [លុប] សំ ប៊ិត និង សឿង[111] ដែលភ្ជាប់ទៅនឹងគណៈមជ្ឈិមផងដែរនោះ គឺជាជំនួយការដែលទទួលខុសត្រូវផ្នែកយោធា។ ជួនកាល គណៈមជ្ឈិម និង គណៈយោធាធ្វើការ ជួបប្រជុំរួមគ្នា ដើម្បីពិភាក្សាអំពីបញ្ហាយោធា[112]។ កងទ័ពបដិវត្តកម្ពុជា និង អង្គភាពយោធាមូលដ្ឋានទាំងអស់ ត្រូវស្ថិតនៅក្រោមចំណុះរបស់គណៈយោធា និងគណៈមជ្ឈិម។ កងទ័ពត្រូវបាន "ទស្សនាវដ្ដីទង់បដិវត្ត" មួយលេខចុះផ្សាយថាជា "*ឧបករណ៍ផ្ដាច់ការរបស់បក្សដ៏បរិសុទ្ធ*"[113]។

៤០. ជារួម ទោះបីជាចំនួនសមាជិកភាពមានការប្រែប្រួលក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យក្ដី ក៏គណៈមជ្ឈិមមានសមាជិកលើសពី៣០រូប ដែលយោងតាមលក្ខន្តិកៈបក្សពួកគេមានកាតព្វកិច្ចដឹកនាំការអនុវត្តដោយខ្ជាប់ខ្ជួននូវគោលនយោបាយបក្សនៅក្នុងសង្គមគ្រប់ជាន់ថ្នាក់ និងធ្វើការផ្សព្វផ្សាយអំពីនយោបាយទាំងនេះ ទៅតាមលំដាប់ឋានានុក្រម។ អនុលោមតាមលក្ខន្តិកៈនេះដដែល ពួកគេជួបប្រជុំគ្នាប្រហែលជារៀងរាល់៦ខែ[114]។

### គ. គណៈកម្មាធិការអចិន្ត្រៃយ៍

៤១. គណៈអចិន្ត្រៃយ៍ គឺជាអង្គការមួយដែលមានសមាជិកតិចជាងគណៈកម្មាធិការមជ្ឈិម។ អង្គការនេះមានសមាសភាព ដែលសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា។ យោងតាមការអះអាងរបស់ ខៀវ សំផន បើទោះបីជាយោងតាមលក្ខន្តិកៈ ជាគោលការណ៍គណៈមជ្ឈិមមានអំណាចសម្រេចធំបំផុតក្ដី ក៏ជាក់ស្ដែង អំណាចនេះត្រូវបានអនុវត្តដោយគណៈអចិន្ត្រៃយ៍ ដែលមានភារកិច្ចគ្រប់គ្រងការងារប្រចាំថ្ងៃ[115]។ ឧត្ដមានុភាពរបស់គណៈអចិន្ត្រៃយ៍ ត្រូវបានបង្ហាញឡើងជាពិសេសតាមរយៈសិទ្ធិអំណាចរបស់អង្គការនេះក្នុងការបញ្ជាឱ្យមានការចាប់ខ្លួនសមាជិកគណៈមជ្ឈិម[116]។

៤២. នៅក្នុងការសួរយកចម្លើយមួយ ខៀវ សំផន បានបញ្ជាក់ថា ក្នុងនាមជាលេខាគណៈអចិន្ត្រៃយ៍ ប៉ុល

ពត គឺជាអ្នកដែលមានអំណាចខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា៖ “ (...) *និយាយជាមួយប៉ុល ពត ក៏ដូចជានិយាយនៅក្នុងអង្គប្រជុំដែរ ពីព្រោះគាត់ជាលេខាបក្ស*”[117]។ ខៀវ សំផន ក៏បានបន្ថែមទៀតថា “ *ចំពោះការចេញសេចក្តីសម្រេច អ្វីៗត្រូវបានធ្វើនិងសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយគឺនាពេលបន្ទាប់មកប៉ុណ្ណោះដែលព័ត៌មានត្រូវបានផ្សព្វផ្សាយបន្តទៅគណៈកម្មាធិការមជ្ឈិម ដែលនឹងណែនាំ បន្តទៀតទៅមូលដ្ឋាន*”[118]។

៤៣. ឧត្តមានុភាពរបស់គណៈអចិន្ត្រៃយ៍ក៏ត្រូវបានបញ្ជាក់ផងដែរដោយ ឌុច ដែលបានអះអាងថា នួន ជា គឺជាមនុស្សទីពីរ បន្ទាប់ពី ប៉ុល ពត នៅក្នុងឋានានុក្រមគណៈអចិន្ត្រៃយ៍ ហើយបន្ទាប់មកគឺ អ៊ុង ជឿន ហៅ តា ម៉ុក[119]។ កំណត់ហេតុអង្គប្រជុំបង្ហាញថា នៅពេល ប៉ុល ពត អវត្តមាន នួន ជា ជាអធិបតីនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍[120]។ សមាជិកផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍រួមមាន សោ យ៉ាន់ ហៅ សោ ភឹម (ដែលបានធ្វើអត្តឃាតនៅក្នុងឆ្នាំ ១៩៧៨[121]) អៀង សារី វន វេត (ដែលក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[122]) រស់ ញឹម (ដែលក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[123]) និង សុន សេន[124]។ ក្នុងចំណោមសមាជិកទាំង៧រូបនេះ មានសមាជិកចំនួន៥រូបដែលរស់នៅជាអចិន្ត្រៃយ៍នៅភ្នំពេញ មានដូចជា៖ ប៉ុល ពត នួន ជា អៀង សារី វន វេត និង សុន សេន (រហូតដល់ពេលដែលគាត់ផ្លាស់ទៅភូមិភាគបូព៌ា នៅខែសីហា ឆ្នាំ១៩៧៧ ដើម្បីពិនិត្យមើលជម្លោះជាមួយវៀតណាម)[125]។

៤៤. ក្រៅពី ប៉ុល ពត សមាជិក “ពេញសិទ្ធិ” នៃ គណៈអចិន្ត្រៃយ៍[126] មានដូចជា នួន ជា តាម៉ុក និង អៀង សារី។ វន វេត និង សុន សេន ទំនងអាចជាសមាជិក “ពេញសិទ្ធិ” ឬ អាចជាសមាជិក “ត្រៀម”[127]។

៤៥. ទោះជាមានភស្តុតាងបញ្ជាក់ច្បាស់ថា ខៀវ សំផន ពុំមែនជាសមាជិកផ្លូវការនៃគណៈអចិន្ត្រៃយ៍ក្នុងពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាចក្តី ក៏វាទំនងជាថា ខៀវ សំផន បានជួយ ឬចូលរួមចំណែកដល់ការងាររបស់គណៈអចិន្ត្រៃយ៍ ដូចដែលមានរៀបរាប់នៅក្នុងផ្នែកដែលនិយាយអំពី ខៀវ សំផន ក្នុងដីកាដំណោះស្រាយនេះ[128]។

៤៦. ក្នុងអង្គប្រជុំមួយនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានប្រគល់ដល់កម្មាភិបាលជាន់ខ្ពស់បក្ស ដែលក្នុងចំណោមនោះក៏មានសមាជិកគណៈអចិន្ត្រៃយ៍ផងដែរ នូវការទទួលខុសត្រូវ

00605272



ប្រតិបត្តិលើវិស័យផ្សេងៗក្នុងសកម្មភាពរបស់រដ្ឋាភិបាល ដូចជា យោធា សេដ្ឋកិច្ច សន្តិសុខ កិច្ចការបរទេស និងសង្គមកិច្ច[129]។ កម្មាភិបាលទាំងនោះត្រូវរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ ដែលជាស្ថាប័នមានអំណាចក្នុងការសម្រេច។ ដូច្នេះហើយ បានជានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះមានសរសេរថា *"ក្នុងការលើកគំរោងត្រូវសួរយោបល់អចិន្ត្រៃយ៍ ដើម្បីសម្រេច និងអនុម័ត"*[130]។ កំណត់ហេតុអង្គប្រជុំដែលនេះ ដែលមានបញ្ជាក់អំពីការតម្រូវឱ្យមានការរក្សាទុកនូវរាល់សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ បានសរសេរថា *"សំណួមពរសំខាន់ គឺកំណត់ហេតុត្រូវឱ្យច្បាស់ សួរអីដឹងហ្នឹង ពីការសម្រេចរបស់មជ្ឈិម របស់អចិន្ត្រៃយ៍ ឯកសារប្រជុំមជ្ឈិម ថ្ងៃណា ខែណា ត្រូវធ្វើយ៉ាងណាឱ្យច្បាស់"*។

៤៧. គណៈអចិន្ត្រៃយ៍បានជួបប្រជុំគ្នាជាញឹកញាប់ ប្រហែលជារៀងរាល់ប្រាំពីរ ទៅដប់ថ្ងៃ បើយោងតាមការអះអាងរបស់ **ខៀវ សំផន**[131]។ បន្ថែមលើនេះ សាក្សីម្នាក់បញ្ជាក់ថា គណៈអចិន្ត្រៃយ៍នឹងកោះប្រជុំនៅពេលដែលមានកិច្ចការសំខាន់ណាមួយត្រូវពិភាក្សាដើម្បីសម្រេច[132]។

### ឃ. មន្ទីរ ៨៧០

៤៨. នៅថ្នាក់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អង្គភាពទាំងអស់ពាក់ព័ន្ធនឹងលេខ "៨៧០" ជាលេខកូដមួយដែលគេសំដៅទៅលើថ្នាក់ខ្ពស់បំផុតរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[133] ហើយនៅក្នុងករណីខ្លះ គឺ ប៉ុល ពត តែម្តង[134]។ ស្ថាប័នទាំងនោះបំពេញការងារពាក់ព័ន្ធនឹងវិស័យនយោបាយ រដ្ឋបាល យោធា ទំនាក់ទំនង និងសន្តិសុខ ក្នុងនាមគណៈអចិន្ត្រៃយ៍ ឬជួយគណៈអចិន្ត្រៃយ៍ក្នុងការអនុវត្តការងារទាំងអស់នេះ។ ស្ថាប័នទាំងនេះ ត្រូវរាយការណ៍ជូនសមាជិកគណៈអចិន្ត្រៃយ៍ ដែលនៅទីក្រុងភ្នំពេញ[135]។

៤៩. ឈ្មោះផ្លូវការរបស់ស្ថាប័នពីរដែលសំខាន់បំផុតនៅក្នុងនោះ គឺ៖ "មន្ទីរនយោបាយ៨៧០"[136] និង "មន្ទីររដ្ឋបាល"[137] ដែលគណៈអចិន្ត្រៃយ៍ផ្តល់ឈ្មោះថា "មន្ទីរស-៧១" ឬ "ក្រសួងស-៧១"[138]។ កំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ក៏មានបង្ហាញអំពីស្ថាប័នមួយ ដែលគេហៅថា "ការិយាល័យ៨៧០" ដែលដឹកនាំដោយ ស៊ឹម សុន ហៅ យ៉ែម ។ កំណត់ហេតុទាំងនោះបានបង្ហាញថា គាត់គឺជាអ្នកទទួលភារកិច្ចក្នុងការធ្វើកំណត់ហេតុនៃកិច្ចប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម[139]។

៥០. ប្រធានមន្ទីរនយោបាយ៨៧០ ដំបូងគេ គឺ សឿ វ៉ាស៊ី ហៅ ឌឿន ដែលបានកាន់មុខតំណែងនេះរហូតដល់មានការចាប់ខ្លួនគាត់នៅឆ្នាំ១៩៧៧[140]។ ឌៀវ សំផន ដែលធ្លាប់បានធ្វើការនៅក្នុងមន្ទីរមួយនេះដែរនោះ[141] បានបដិសេធថា មិនមានពេលណាមួយដែលគាត់ធ្លាប់ជាប្រធានមន្ទីរនេះនោះទេ។ មន្ទីររដ្ឋបាល (មន្ទីរស-៧១) ត្រូវបានគ្រប់គ្រងដោយ ឈឹម សំអោក ហៅ ប៉ង់[142] ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៨[143] គាត់បានត្រូវជំនួសដោយ ឈ្មោះ កែន ហៅ លឹន[144] ដែលបានកាន់កាប់តួនាទីនេះរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ទោះបីជាសាក្សីមួយរូបបានអះអាងថា មន្ទីររបស់ ប៉ង់ ត្រូវបានគ្រប់គ្រងដោយ ប៉ុល ពត ខ្លួនឯងផ្ទាល់ដោយមាន ប៉ង់ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ប៉ុល ពត ផ្ទាល់[145] ក៏ប៉ុន្តែសក្ខីកម្មផ្សេងទៀតបានបង្ហាញថា មន្ទីររបស់ ប៉ង់ ជាទូទៅក៏បាន "*រាយការណ៍ទៅមជ្ឈិម*" ផងដែរ[146]។

៥១. ភាពខុសគ្នារវាងមន្ទីរទាំងពីរនេះគឺ មន្ទីរនយោបាយ៨៧០ដែលដឹកនាំដោយ ឌឿន មានភារកិច្ចទទួលបន្ទុកផ្នែកនយោបាយ រីឯមន្ទីរស-៧១ ដែលដឹកនាំដោយ ប៉ង់ ត្រូវទទួលខុសត្រូវលើកិច្ចការរដ្ឋបាល និងការងារជំនួយការផ្សេងៗទៀត[147]។ មន្ទីរនយោបាយ៨៧០ និងមន្ទីរស-៧១ ក៏ដូចជាស្ថាប័នពាក់ព័ន្ធដទៃទៀត ជារឿយៗត្រូវបានគេផ្តល់ឈ្មោះឲ្យថា "មន្ទីរ៨៧០" ឬ "មន្ទីររបស់អង្គការ" ដោយមិនមានការយល់ច្បាស់ទេថា តើគេសំដៅដល់មន្ទីរមួយណានោះឡើយ។

៥២. មន្ទីរនយោបាយ ៨៧០ មានតួនាទីសំខាន់ក្នុងការធានាការធ្វើទំនាក់ទំនងរវាងបុគ្គលនានាដែលមានអំណាចសម្រេចរបស់មជ្ឈិម ព្រមទាំងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានាតាមរយៈប្រព័ន្ធទំនាក់ទំនងព័ត៌មានមួយដែលមានលក្ខណៈទៀតទាត់ និងផ្ទាល់ទៅកាន់មន្ទីរនយោបាយ៨៧០[148]។ ទាក់ទងនឹងមន្ទីរដែលដឹកនាំដោយ ឌឿន កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥បានបង្ហាញថា "*មន្ទីរគណៈអចិន្ត្រៃយ៍ទាក់ទងពីផ្នែកមួយទៅផ្នែកមួយ។ គណៈអចិន្ត្រៃយ៍តាមដានផ្នែកនីមួយៗក្នុងការអនុវត្តមាគ៌ា។ ខាងមន្ទីរមានភារៈកិច្ចតាមដានការអនុវត្ត*"[149]។

៥៣. យោងតាមការរៀបរាប់របស់ ឌុច មុខងារផ្សេងៗរបស់មន្ទីរ ស-៧១ មានដូចជា៖ "*ការពារមន្ទីរមជ្ឈិម និងកម្មាភិបាលនៃមន្ទីរនេះ ទទួលភ្ញៀវ ទូរគមនាគមន៍ (ដែលមានទាំងនីរសារ និងសារទូរលេខ) ភស្តុភារ ស្បៀង ការដឹកជញ្ជូន*"[150]។ ប៉ុន្តែមន្ទីរ ស-៧១ ក្នុងនាមគណៈអចិន្ត្រៃយ៍ ក៏មាន


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ភារកិច្ចក្នុងការតាមដានលើសមាជិករបស់បក្ស ក្រសួងនានា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ខ្លួនឯងផង ដែលខ្លួនមានការសង្ស័យ ព្រមទាំងធ្វើការចាប់ខ្លួនអ្នកដែលត្រូវបានចាត់ទុកថាជាជនក្បត់ និងបញ្ជូនពួកគេទាំងនោះទៅកាន់មន្ទីរស-២១[151]។

៩៤. នៅក្នុងរចនាសម្ព័ន្ធរបស់មន្ទីរស-៧១ មានមន្ទីរចំណុះមួយចំនួន ដែលមានឈ្មោះសម្គាល់សម្ងាត់ ផ្ដើមជាមួយនឹងព្យញ្ជនៈ “ក” នៅខាងមុខ ហើយដែលទទួលខុសត្រូវលើការងាររដ្ឋបាល ឬភស្តុភារ ដើម្បីជួយដល់គណៈមជ្ឈិមក្នុងការបំពេញការងារ។ “មន្ទីរ-ក” ទាំងនេះ ស្ថិតនៅក្រោមការគ្រប់គ្រង ផ្ទាល់របស់ប៉ង់[152]។ ក្នុងចំណោមមន្ទីរទាំងនោះ មន្ទីរដែលសំខាន់ៗរួមមាន៖ មន្ទីរ ក-១ មន្ទីរ ក-៣ មន្ទីរ ក-៧ និងមន្ទីរ ក-១៨។

៩៥. ភស្តុតាងបង្ហាញថា មន្ទីរក-១ គឺជាបរិវេណស្នាក់អាស្រ័យ និងធ្វើការរបស់ ប៉ុល ពត[153] (ខណៈដែលសាក្សីមួយចំនួនបានអះអាងថា មន្ទីរក-១ គឺគ្រាន់តែជាកន្លែងធ្វើការរបស់ ប៉ុល ពត តែប៉ុណ្ណោះ[154]។ ម្យ៉ាងវិញទៀត សាក្សីមួយចំនួនបានលើកឡើងថា មានពេលខ្លះ នួន ជា និង/ឬ ខៀវ សំផន បានស្នាក់នៅ និង/ឬ ធ្វើការជាមួយ ប៉ុល ពត នៅមន្ទីរក១ ផងដែរ[155]។

៩៦. មានភស្តុតាងបញ្ជាក់ទៀតថា ទីតាំងដែលគេស្គាល់ថាជាមន្ទីរ ក-៣ ពេលខ្លះត្រូវបានប្រើប្រាស់ជា កន្លែងស្នាក់នៅ និងកន្លែងធ្វើការរបស់ នួន ជា និង/ឬ ខៀវ សំផន, អៀង សារី, សុន សេន ឬ វន វេត ផងដែរ[156]។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមួយចំនួនបានបញ្ជាក់ថា បានឃើញ ប៉ុល ពត ទៅដល់មន្ទីរក១ ឬ មន្ទីរក៣ ដើម្បីប្រជុំជាមួយ នួន ជា អៀង សារី សុន សេន វន វេត និង ខៀវ សំផន[157] ក៏ដូចជាពេលខ្លះ ជាមួយ អៀង ធីរិទ្ធ ប្រសិនបើមានអង្គប្រជុំពាក់ព័ន្ធនឹងការងារ សង្គមកិច្ច[158]។

៩៧. មន្ទីរក៧ គឺជាអង្គភាពនីរសារ ដែលជាកន្លែងឆ្លងកាត់ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ នានា ដែលផ្ញើទៅកាន់ *“គណៈ៨៧០”* ឬ *“មន្ទីរ៨៧០”* មុននឹងបញ្ជូនទៅឱ្យ ប៉ុល ពត នៅមន្ទីរ ក១ ក៏ដូចជាទៅឱ្យសមាជិកគណៈ៨៧០ ឬសមាជិកពាក់ព័ន្ធរបស់គណៈ៨៧០ អាស្រ័យលើការទទួល ខុសត្រូវតាមផ្នែករបស់ខ្លួន[159]។ មន្ទីរក១៨ គឺជាអង្គភាពទូរលេខ ដែលមានភារកិច្ចទទួល ការទាក់ទងតាមវិទ្យុ រួចបញ្ជូនទៅកាន់មន្ទីរក១[160]។

៥៨. ភស្តុតាងដែលទទួលបាននៅមិនទាន់បង្ហាញឱ្យបានច្បាស់លាស់នៅឡើយទេថា បុគ្គលណាឱ្យពិតប្រាកដ ដែលជាអ្នកត្រូវទទួលលិខិតទំនាក់ទំនងទាំងឡាយ ដែលផ្ញើទៅកាន់ *"គណៈ៨៧០"* ឬ *"មន្ទីរ៨៧០"*។ សាក្សីមួយចំនួនបានលើកឡើងថា ពាក្យទាំងនេះត្រូវបានប្រើសំដៅដោយផ្ទាល់ទៅគណៈមជ្ឈិម[161] ខណៈដែល សាក្សីផ្សេងៗទៀតបានលើកឡើងថា សំដៅទៅគណៈអចិន្ត្រៃយ៍ទៅវិញ[162] ឬទៅ ប៉ុល ពត តែម្តង[163]។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមួយចំនួន និងរួមទាំង ឌុច ផងដែរ បានលើកឡើងអំពីការយល់ឃើញរបស់ខ្លួនថា *"គណៈ៨៧០"* ឬ *"មន្ទីរ៨៧០"* អាចនិយាយសំដៅដូចគ្នាចំពោះ ប៉ុល ពត នួន ជា អៀង សារី វន វេត សុន សេន និង ថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត[164] ដោយរួមទាំង ខៀវ សំផន ផងដែរ គឺអាស្រ័យទៅលើខ្លឹមសារនៃលិខិតទំនាក់ទំនងនោះ[165]។

៥៩. ភស្តុតាងផ្សេងៗទៀតដែលទទួលបានពាក់ព័ន្ធនឹង "មន្ទីរក" ដទៃទៀត បានបង្ហាញថា មន្ទីរ ក៦ គឺជាកន្លែងជួបប្រជុំ ដែលគេស្គាល់ឈ្មោះថា *"បុរីកីឡា"*[166] មន្ទីរក៨ ទទួលបន្ទុកដាំដុះបន្លែ[167] មន្ទីរ ក១១ ជាមន្ទីរពេទ្យ[168] និងមន្ទីរក១២ គឺជាអង្គភាពរៀបចំយានជំនិះ និងអ្នកបើកបរសម្រាប់មជ្ឈិមបក្ស[169]។

៦០. ទោះបីជាអង្គហេតុនានាបានបង្ហាញយ៉ាងច្បាស់ថា ខៀវ សំផន មានតួនាទីនៅក្នុងមន្ទីរ៨៧០ក្តី ក៏ចម្លើយដែលទទួលបានទាក់ទងនឹងតួនាទីនេះ នៅមិនមានលក្ខណៈច្បាស់លាស់នៅឡើយ។ ឌុច និងសាក្សីពីររូបទៀត បានបញ្ជាក់ថាប្រហែលឆ្នាំ១៩៧៧ ខៀវ សំផន បានក្លាយជាប្រធានមន្ទីរនយោបាយ៨៧០ ដែលពីមុនស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់ ឌឿន[170] ខណៈដែលសាក្សីផ្សេងទៀតបានបញ្ជាក់ត្រឹមថា ខៀវ សំផន បានជួបជាមួយ ប៉ង់ នៅមន្ទីរស-៧១ ដើម្បីត្រួតពិនិត្យស្ថានការណ៍ជាមួយគាត់ ហើយថា ប៉ង់ បានទទួលបញ្ជាពី ខៀវ សំផន ក៏ដូចជាពីថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀតផងដែរ[171]។ ចំពោះ ខៀវ សំផន ផ្ទាល់ គាត់បានបដិសេធចំពោះការទទួលតំណែងជាប្រធានមន្ទីរបន្តពី ឌឿន ដោយបានលើកឡើងថា នៅក្នុងស្ថាប័ននោះ គាត់គ្រាន់តែទទួលបន្ទុកចម្បងលើបញ្ហាពាក់ព័ន្ធនឹងភស្តុភារជាតិប៉ុណ្ណោះ ដូចជា ការចែកចាយអំបិល អង្ករ ស្រូវពូជ សម្លៀកបំពាក់ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ដល់បណ្តាភូមិភាគនានា និងរួមទាំងបញ្ហាដែលពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយ [លុប] ប៉ុណ្ណោះ[172]។ សាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មស្របតាមកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍[173] ផងដែរនោះ បានអះអាងថា សារទូរលេខ ដែល ពាក់ព័ន្ធនឹងសំភារៈ និងភស្តុភារ ដែលបានផ្ញើទៅមន្ទីរ៨៧០ ឬលិខិតដែល

00605276



មន្ទីរនេះបានធ្វើចេញ គឺមានសរសេរឈ្មោះថា ខៀវ សំផន ដែលធ្វើសកម្មភាពក្នុងនាម និង ការទទួលខុសត្រូវរបស់មន្ទីរនេះ[174]។ ទោះបីជាយ៉ាងណាក៏ដោយ ខៀវ សំផន បានធ្វើការអះអាង នៅក្នុងឆ្នាំ ១៩៨០ ដោយបានទទួល ស្គាល់នូវការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយនឹងការតាមដាន និង ការអង្កេតលើការចោទប្រកាន់ទៅលើកម្មាភិបាលភូមិភាគ ដែលនេះជាតួនាទីរបស់ ខៀវ បានធ្វើកាល ពីពេលមុន[175] ។

៦១. ជាចុងក្រោយ ខៀវ សំផន និង ឌុច ក៏ដូចជាសាក្សីជាច្រើនទៀត បានបញ្ជាក់ថា ពាក្យថា "*មន្ទីរ៨៧០*" "*អង្គការ៨៧០*" "*គណៈ៨៧០*" ឬ "*អង្គការ*" ត្រូវបានប្រើប្រាស់ដោយមិនមានការ បែងចែកដើម្បីសំដៅដល់ស្ថាប័នដឹកនាំនានារបស់មជ្ឈិមបក្ស[176]។ ឌុច បានលើកឡើងទាក់ទងនឹង មន្ទីរ៨៧០ នេះថា "*អ្វីដែលខ្ញុំអាចនិយាយបាននោះ គឺជាទីស្នាក់ការមេដឹកនាំរបស់បក្ស*"[177]។

## ខ. ក្រសួងនានា (រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ)

៦២. តាមរយៈសេចក្ដីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានធ្វើការកំណត់សមាសភាព របស់ស្ថាប័នរដ្ឋ ដើម្បីបង្កើតរដ្ឋាភិបាលផ្លូវការជំនួសឱ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)[178]។ មានការប្រកាសថា៖ រដ្ឋាភិបាល "*ត្រូវជាអង្គការរបស់បក្សសុទ្ធសាធ។ ជារដ្ឋ របស់យើងផ្ទាល់*"។ ឈ្មោះរបស់រដ្ឋមន្ត្រីទាំងអស់ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦[179]។

៦៣. ទោះបីជាសមាសភាពនេះអាចត្រូវបានផ្លាស់ប្ដូរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ជា គោលការណ៍ រដ្ឋាភិបាលត្រូវបានរៀបចំឡើងក្នុងបែបផែនដូចតទៅ[180]៖ ប៉ុល ពត ជានាយករដ្ឋមន្ត្រី ទទួលបន្ទុកទូទៅលើផ្នែកយោធា និងផ្នែកសេដ្ឋកិច្ច អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក កិច្ចការបរទេស សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ វន វេត ជា ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច នួន ជា ជាប្រធានសភាតំណាងប្រជាជន[181] ហ៊ូ នឹម ជា រដ្ឋមន្ត្រីក្រសួងឃោសនាការ យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងអប់រំ តូច ភឿន ជារដ្ឋមន្ត្រីក្រសួង សារធារណការ ដឹកជញ្ជូន និងប្រៃសណីយ៍ កុយ ធួន ជារដ្ឋមន្ត្រីពាណិជ្ជកម្ម ចេង អន ជារដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម[182] អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច [លុប] ជារដ្ឋមន្ត្រី ទទួលបន្ទុកសុខាភិបាល និង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ដែលធ្លាប់ទទួលបន្ទុក

ផ្នែកពាណិជ្ជកម្ម ទាក់ទងទៅនឹងគណនេយ្យ និងការកំណត់តម្លៃ[183]។

## ផ្នែកទី ៣- រចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់មូលដ្ឋាន)

៦៤. តាមការកំណត់ទីតាំង របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាផ្នែកតូចៗទៅជាអង្គភាពរដ្ឋបាលដែលមានឋានានុក្រមបន្តគ្នា ដែលទាក់ទងទៅនឹងសង្វាក់នៃការបញ្ជាតាមខ្សែបណ្តោយ (ខ្សែឈរ) ដែលគ្រប់គ្រងដោយមជ្ឈិម។ "ភូមិភាគ" ធំៗមួយចំនួនគឺស្ថិតនៅក្រោមមជ្ឈិមដោយផ្ទាល់។ "ភូមិភាគ" ទាំងនេះត្រូវបានបែងចែកទៅជា "តំបន់" ដែលតំបន់នីមួយៗមានបែងចែកជា "ស្រុក" មួយចំនួន ដែលនៅក្នុងស្រុកនីមួយៗមាន "ឃុំ" និង "សហករណ៍"[184]។ នៅគ្រប់កម្រិតនីមួយៗនៃ ភូមិភាគ តំបន់ ស្រុក និង ឃុំ ត្រូវបានគ្រប់គ្រងដោយ "គណៈ" ដែលគណៈនីមួយៗត្រូវបានដឹកនាំដោយលេខា[185]។

៦៥. ភ្លាមៗបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ មាន ៦ ភូមិភាគ ៖ ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគឦសាន ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា[186]។ នៅឆ្នាំ១៩៧៧ ភូមិភាគឧត្តរត្រូវបានដាក់ឈ្មោះសារជាថ្មីថា ជាភូមិភាគកណ្តាល[187] និងភូមិភាគឧត្តរថ្មីមួយទៀតត្រូវបានបង្កើត។

៦៦. បន្ថែមពីលើភូមិភាគនានាដែលបានរាយការណ៍ផ្ទាល់ទៅថ្នាក់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានបង្កើត "តំបន់ស្វយ័ត" មួយចំនួនដែលរំលងថ្នាក់ភូមិភាគក្នុងការរាយការណ៍ផ្ទាល់ទៅ ថ្នាក់មជ្ឈិម។ តំបន់ទាំងអស់នេះគឺតំបន់ស្វយ័ត១០៣ (ព្រះវិហារ) តំបន់ស្វយ័ត ១០៥ (មណ្ឌលគីរី) តំបន់ស្វយ័ត ១០៦ (សៀមរាប) តំបន់ស្វយ័ត៥០៥ (ក្រចេះ) និងតំបន់ស្វយ័តទីក្រុងកំពង់សោម (កំពង់ផែសំខាន់បំផុតរបស់ប្រទេសកម្ពុជា)[188]។ លើសពីនេះទៀត ភ្នំពេញត្រូវបានចាត់ថ្នាក់ជាទឹកដីផ្សេងពីគេ ដោយមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានជាផ្លូវការនោះទេ ដោយធ្វើសេចក្តីរាយការណ៍ ផ្ទាល់ទៅថ្នាក់មជ្ឈិមតែម្តង[189]។ នៅឆ្នាំ១៩៧៧ តំបន់ស្វយ័ត១០៦ (សៀមរាប) ត្រូវបានបញ្ចូលគ្នាជាមួយនឹង តំបន់ស្វយ័ត១០៣ (ព្រះវិហារ) ដើម្បីបង្កើតជាភូមិភាគឧត្តរថ្មី[190]។

៦៧. អង្គហេតុដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹង ស្ថិតនៅគ្រប់ភូមិភាគនីមួយៗនៃរចនាសម្ព័ន្ធថ្នាក់មូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ដូចជានៅតំបន់ពីរក្នុងចំណោមតំបន់ស្វយ័តនានា។ មន្ទីរ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605278



សន្តិសុខសង់ និង ក្រាំងតាចាន់ សហករណ៍ត្រាំកក់ និងការដ្ឋានស្រែអំបិល និង ការដ្ឋានព្រៃស (ស-២៤) មានទីតាំងនៅភូមិភាគនិរតី។ មន្ទីរសន្តិសុខវត្តគីរីរម្យ កន្លែងសម្លាប់មនុស្សទួលពោធិជ្រៃ និងការដ្ឋានត្រពាំងថ្ម ស្ថិតនៅក្នុងភូមិភាគពាយ័ព្យ។ កន្លែងសម្លាប់មនុស្សស្ទឹងតូច និងមន្ទីរសន្តិសុខវត្តធ្លក ស្ថិតនៅក្នុងភូមិភាគបូព៌ា។ មន្ទីរសន្តិសុខភូមិភាគឧត្តរស្ថិតនៅក្នុងភូមិភាគឧត្តរថ្មី។ ការដ្ឋានទំនប់-១មករា ស្ថិតនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)។ មន្ទីរសន្តិសុខអូរកន្សែងស្ថិតនៅក្នុងភូមិភាគឦសាន។ មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខកោះខ្យង កន្លែងសម្លាប់មនុស្សក្នុងស្រុក១២ និងការដ្ឋានសាងសង់វាលយន្តហោះកំពង់ឆ្នាំងស្ថិតនៅក្នុងភូមិភាគបស្ចឹម។ មន្ទីរសន្តិសុខ ស-២១ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ ជាចុងក្រោយ មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅក្នុងតំបន់ស្វយ័ត ១០៥ រីឯ មន្ទីរសន្តិសុខគោកក្ដួចស្ថិតនៅក្នុងតំបន់ស្វយ័ត ៥០៥។

**៦៨.** លេខាភូមិភាគត្រូវបានតែងតាំងជាទូទៅដោយគណៈមជ្ឈិម[191]។ ការអនុវត្តសេចក្តីសម្រេចរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ត្រូវបានធ្វើឡើងដោយលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត[192]។ គោលនយោបាយ និងសេចក្តីណែនាំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ត្រូវបានផ្សព្វផ្សាយដល់លេខាភូមិភាគ និងលេខាតំបន់ស្វយ័តដែលនឹងផ្សព្វផ្សាយគោលនយោបាយ និងសេចក្តីណែនាំទាំងនោះបន្តទៀតក្នុងចំណោមលេខាតំបន់ និងលេខាស្រុក ដើម្បីអនុវត្ត[193]។ ផ្ទុយទៅវិញ ឃុំនានាបានរាយការណ៍ត្រឡប់ទៅគណៈស្រុកវិញ ដែលគណៈស្រុកត្រូវរាយការណ៍បន្តទៅគណៈតំបន់ដែលគណៈតំបន់ត្រូវរាយការណ៍បន្តទៅគណៈភូមិភាគ។

**៦៩.** លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាចែងថា ភារកិច្ច និង មុខងាររបស់គណៈភូមិភាគ គឺដើម្បី "*ដឹកនាំអនុវត្តភារកិច្ច*" យោងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈ "*ចុះជាប់*" ជាមួយតំបន់ ស្រុក និងឃុំ នានា។ នៅក្នុងការធ្វើការងារនេះ គណៈភូមិភាគ ត្រូវបានផ្តល់អំណាចឲ្យធ្វើការ "*កំណត់ការងារថ្មីតាមមាគ៌ានយោបាយរបស់បក្ស*"[194] ដែលមានន័យថាមាគ៌ាបក្សត្រូវតែអនុវត្ត "*តាមមាគ៌ានយោបាយ ការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ*"[195] ដែលមានន័យម្យ៉ាងវិញទៀតថា ភូមិភាគទាំងឡាយត្រូវទទួលខុសត្រូវចំពោះស្ថានភាពសន្តិសុខផ្ទៃក្នុងដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ ដោយហេតុយ៉ាងនេះហើយ គណៈភូមិភាគត្រូវបានអនុញ្ញាតឲ្យ "*អនុវត្តវិន័យក្នុងក្របខណ្ឌភូមិភាគ*"[196]។ ម្យ៉ាងវិញទៀត គណៈភូមិភាគត្រូវបានផ្តល់អំណាចឲ្យធ្វើការជ្រើសរើសសមាជិកថ្មីសម្រាប់ការដឹកនាំថ្នាក់ភូមិភាគ ដែលត្រូវអនុម័តយល់ព្រមពីគណៈមជ្ឈិម[197]។ គណៈភូមិភាគក៏ត្រូវបានតម្រូវតាមលក្ខន្តិកៈឲ្យរក្សា

00605279



*"របាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគជូនគណៈកម្មាធិការមជ្ឈិម"* [198]។

៧០. នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ភារកិច្ច និងមុខងារស្រដៀងគ្នានេះ ត្រូវបានផ្តល់ឲ្យ ទៅគណៈតំបន់[199] គណៈស្រុក[200] និងគណៈឃុំ[201] ដោយតម្រូវឲ្យអនុវត្តសេចក្តីណែនាំ និងធ្វើសេចក្តីរាយការណ៍ត្រឡប់ទៅរដ្ឋបាលថ្នាក់លើវិញ។

៧១. បន្ថែមពីលើការប្រជុំរាល់ប្រាំមួយខែម្តងរបស់គណៈអចិន្ត្រៃយ៍[202] មានកិច្ចប្រជុំប្រចាំឆ្នាំនៅទីក្រុងភ្នំពេញរវាងលេខាភូមិភាគ និងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា[203] ក៏ដូចជាមានកិច្ចប្រជុំជាញឹកញាប់ថែមទៀតនៅទីក្រុងភ្នំពេញរវាងថ្នាក់មជ្ឈិមជាមួយនឹងសមាជិកភូមិភាគ តំបន់ និងស្រុក[204]។ បន្ថែមពីលើនេះទៀត ការប្រជុំគ្នាផ្ទាល់នឹងធ្វើឡើងរវាងភូមិភាគ និងតំបន់។ បន្ទាប់មកតំបន់នានា នឹងធ្វើការអញ្ជើញលេខាស្រុក និងលេខាឃុំ ឲ្យចូលរួមប្រជុំដែលនឹងត្រូវផ្សព្វផ្សាយសេចក្តីណែនាំបន្តទៀតដល់អង្គភាពរបស់គេរៀងៗខ្លួន[205]។

## ផ្នែកទី ៤- ប្រព័ន្ធទំនាក់ទំនងការងារ

៧២. គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា គឺជាក្បាលម៉ាស៊ីននៃប្រព័ន្ធទំនាក់ទំនងការងាររបស់បក្សនៅទូទាំងប្រទេស។ គណៈអចិន្ត្រៃយ៍ជាចំណុចប្រមូលផ្តុំប្រព័ន្ធព័ត៌មានជាប់លាប់រវាងផ្នែកនីមួយៗនៃឋានានុក្រមរដ្ឋបាល។ គណៈអចិន្ត្រៃយ៍ចេញសេចក្តីណែនាំថា: *"រាយការណ៍ជាទិដ្ឋភាពរួមតាមរយៈមុខព្រួញនានា។ ស្នើរាយការណ៍ខ្លីៗតាមទូរលេខ (ការធ្វើដូចនេះ) គណៈអចិន្ត្រៃយ៍ដឹងសភាពការណ៍ ដើម្បីណែនាំបានទាន់ពេលវេលា"*[206]។

### ក. បណ្តាញទំនាក់ទំនង

៧៣. បណ្តាញទំនាក់ទំនងជាច្រើនត្រូវបានរៀបចំឡើងយ៉ាងម៉ត់ចត់នៅថ្នាក់មជ្ឈិម (រវាងក្រសួងនានា និងមន្ទីរនានាដែលនៅជុំវិញមជ្ឈិម ក្នុងចំណោមកងទ័ពរបស់មជ្ឈិម និងនៅក្នុងមន្ទីរសន្តិសុខរបស់មជ្ឈិម ៖ មន្ទីរ ស- ២១), រវាងមជ្ឈិមនិងភូមិភាគ (គ្មានការទាក់ទងផ្ទាល់រវាងភូមិភាគនិងភូមិភាគណាត្រូវបានអនុញ្ញាតឡើយ) និងរវាងភូមិភាគនិងតំបន់។

## ទំនាក់ទំនងទៅមជ្ឈិម

៧៤. ការបែងចែកសារដែលមកដល់មជ្ឈិមពីអង្គភាពខាងក្រៅ ត្រូវបានសម្របសម្រួលដោយមន្ទីរ-១ ដែលជាកន្លែងត្រូវសម្រេចថាតើ មេដឹកនាំមួយណាដែលត្រូវទទួលការចម្លងជូន[207]។ សេចក្តីសម្រេច នេះត្រូវធ្វើឡើងដោយប៉ុលពត និងសហការីរបស់គាត់ ដែលហេតុនេះហើយបានជាអ្នកទាំងនោះបានទទួលសារចូលមកជាច្រើនដងក្នុងមួយថ្ងៃៗ[208]។ តាមសាក្សីម្នាក់បញ្ជាក់ថានួនជាតែងតែបានទទួលបានការចម្លងជូននូវសារដែលប៉ុលពតបានអាន[209]។

៧៥. មានការទាក់ទងគ្នាញឹកញាប់ជាលាយលក្ខអក្សរណ៍ផងដែររវាងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាម្នាក់ ៗ ជាពិសេសរវាងប៉ុលពត និងនួនជា ដែលធ្វើការឆ្លើយឆ្លងសំបុត្រទៅវិញទៅមកជារៀងរាល់ថ្ងៃឬពីរថ្ងៃម្តង[210]។

## ទំនាក់ទំនងពីភូមិភាគទៅមជ្ឈិម

៧៦. ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ ជាពិសេសទៅលើស្ថានភាពកសិកម្ម ដូចជាការធ្វើស្រែ និងទៅលើប្រព័ន្ធធារាសាស្ត្រ ជីវភាពប្រជាជន និងស្ថានភាពខ្មាំង និងស្ថានភាពយោធា[211]។ សាក្សីម្នាក់ (ជាលេខាតំបន់ស្វយ័ត១០៥) បានបញ្ជាក់ថា គាត់បានបញ្ជូនសារទូរលេខទៅមជ្ឈិម ហើយប៉ុល ពត បានបញ្ជូនត្រឡប់មកវិញ នូវមតិយោបល់លើការចាប់ខ្លួនកម្មាភិបាល និងលើចម្លើយសារភាពរបស់ពួកគេ[212]។

៧៧. សារទូរលេខនានាដែលបានរកឃើញ បានបង្ហាញពីបញ្ហានានាដែលជាប់ទាក់ទងនឹងការរត់ចោល ជួរ និងការគ្មានវិន័យ[213]ជម្លោះជាមួយវៀតណាម (មានការរាយការណ៍លម្អិតពីចំនួនខ្មាំងដែលត្រូវបានសម្លាប់ និងសម្ភារៈដែលត្រូវបានរឹបអូស និងបានរាយការណ៍ប្រាប់មន្ទីរ ៨៧០ ពីផែនការប្រយុទ្ធ និងចលនារបស់ខ្មាំង)[214] បញ្ហាសន្តិសុខផ្ទៃក្នុង (ជាទូទៅ[215]ឬ ដោយលម្អិត៖ ជូនកាលសំដៅដល់បុគ្គលដែលត្រូវបានសង្ស័យ)[216] គិញវៀតណាម និងការសួរចម្លើយគិញវៀតណាមនោះ (ដែលបញ្ជាក់ពីការប្រើប្រាស់ទារុណកម្ម)[217] ឬ "ជនក្បត់" (ដោយមានបញ្ជាក់ឈ្មោះ)[218]។

៧៨. ភូមិភាគបានឆ្លើយឆ្លងសារទូរលេខមួយ ឬច្រើនក្នុងមួយថ្ងៃ ជាមួយនឹងតំបន់នីមួយៗ ដោយមិនមានលក្ខណៈទៀងទាត់ទេ[219]។ មានតែទំនាក់ទំនងរវាងមជ្ឈិម និងតំបន់ប៉ុណ្ណោះ មិនដែលមានទំនាក់ទំនងរវាងមជ្ឈិមនឹងថ្នាក់ស្រុកទេ[220]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៧៩. លេខាភូមិភាគម្នាក់មានតារាងពេលវេលាសម្រាប់ទំនាក់ទំនង ដែលត្រូវកំណត់ដោយមជ្ឈិម ដោយបញ្ជាក់ពីពេលវេលាដែលត្រូវទាក់ទងជាមួយនឹងមជ្ឈិម[221]។ សារទូរលេខជាច្រើនត្រូវបានផ្ញើចេញពីភូមិភាគយ៉ាងហោចណាស់មួយដងដែរក្នុងមួយថ្ងៃ[222] ជួនកាលពីរដងក្នុងមួយថ្ងៃ (នៅពេលព្រឹក និងនៅពេលល្ងាច)[223]។ នៅក្នុងកាលៈទេសៈពិសេស សារទូរលេខអាចត្រូវបានផ្ញើនៅម៉ោងផ្សេងក៏បាន[224]។ អ្នកប្រតិបត្តិការសារទូរលេខម្នាក់នៅក្នុងចំណោមអ្នកប្រតិបត្តិការសារទូរលេខជាច្រើននៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) បានបញ្ជាក់ថា គាត់បានទទួលសារបានប្រហែលបួនទៅប្រាំសារក្នុងមួយថ្ងៃពីមជ្ឈិម (៨៧០)[225]។

៨០. តារាងពេលវេលាសម្រាប់ទំនាក់ទំនងដោយសារទូលេខដែលត្រូវបានផ្ញើពីភូមិភាគទៅតំបន់នានាត្រូវកំណត់ដោយភូមិភាគ ដោយធ្វើយ៉ាងណា ឲ្យមានលក្ខណៈងាយស្រួលធ្វើការបែងចែករវាងសារទូរលេខនានាដែលផ្ញើមកពីមជ្ឈិមនិងសារទូរលេខនានាដែលបានទទួលពីតំបន់នានា[226] ។ ការទទួលសារទូរលេខនីមួយៗ ត្រូវបានបញ្ជាក់ថាបានទទួលតាមរយៈពាក្យសម្ងាត់ដោយអ្នកដែល ត្រូវទទួលសារទូរលេខ[227]។ ក្នុងអំឡុងឆ្នាំ១៩៧៨ ទំនាក់ទំនងរវាងមជ្ឈិម និងភូមិភាគមានការកើនឡើងដោយសារមានការរីកចម្រើនផ្នែកបច្ចេកទេស[228]។

៨១. សាក្សីជាច្រើនបង្ហាញថា មានគោលការណ៍ដ៏តឹងរ៉ឹងមួយដែលហាមមិនឲ្យមានទំនាក់ទំនងដោយផ្ទាល់រវាងភូមិភាគនិងភូមិភាគទេ។ ទំនាក់ទំនងការងាររវាងភូមិភាគនិងភូមិភាគត្រូវឆ្លងកាត់តាមមជ្ឈិម[229]។ គ្មានតារាងពេលវេលាសម្រាប់ទាក់ទងតាមសារទូរលេខ ឬតារាងសម្រាប់បកប្រែលេខសម្ងាត់សម្រាប់ទំនាក់ទំនងសារទូរលេខពីភូមិភាគទៅភូមិភាគទេ ដូច្នេះហើយទំនាក់ទំនងផ្ទាល់រវាងភូមិភាគបែបនេះមិនអាចកើតមានទេ[230]។ ប៉ុន្តែមានអ្នកប្រតិបត្តិការសារទូរលេខម្នាក់បញ្ជាក់ថាទំនាក់ទំនងផ្ទាល់រវាងភូមិភាគទៅភូមិភាគត្រូវបានធ្វើឡើងតាមរយៈសំបុត្រ ដែលត្រូវបានផ្ញើតាមនីរសារ ហើយសំបុត្រនោះត្រូវមានបោះត្រារបស់ភូមិភាគ[231]។

## ទំនាក់ទំនងការងារពីភូមិភាគទៅតំបន់ និងស្រុក

៨២. តំបន់នីមួយៗមានអង្គភាពសារទូរលេខផ្ទាល់របស់ខ្លួន ប៉ុន្តែរាល់ការបញ្ជូនសារទូរលេខរបស់តំបន់ត្រូវឆ្លងតាមរយៈភូមិភាគ”[232]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៨៣. មានតែតំបន់ស្វយ័តទេ ដែលទាក់ទងដោយផ្ទាល់ជាមួយមជ្ឈិម[233]។ សាក្សីម្នាក់ដែលបានធ្វើការជាអ្នកប្រតិបត្តិការសារទូរលេខនៅក្នុងតំបន់ស្វយ័ត ១០៥ បញ្ជាក់ថាមន្ទីរស្រុកភាគច្រើនបានរាយការណ៍ពីគម្រោងសាងសង់ទំនប់និងប្រឡាយទឹក សុខភាព ការត្រួតពិនិត្យកងកម្លាំង និងពី៖ *"សមាសភាពល្អ និងមិនល្អ សមាសភាពក្បត់ ឬសន្តិសម្ព័ន្ធ"*[234] ។ លេខាតំបន់ជាអ្នករៀបចំរបាយការណ៍អំពីការងាររបស់ស្រុក ហើយផ្ញើរបាយការណ៍នោះទៅមជ្ឈិមជាប្រចាំថ្ងៃ[235] ។

៨៤. នីរសារជាច្រើនត្រូវបានគេប្រើប្រាស់ជាចម្បងនៅក្នុងទំនាក់ទំនងការងាររវាងស្រុក និងតំបន់ដូចដែលបានចង្អុលបង្ហាញដោយប្រភពអាមេរិកាំង (របាយការណ៍ stony beach)៖ *"ស្រុកនីមួយៗ និងតំបន់ នៅក្នុងភូមិភាគបូព៌ាមានបណ្ដាញនីរសារមួយ ។ បណ្ដាញនេះធ្វើតាមរចនាសម្ព័ន្ធដ៏តឹងរ៉ឹងមួយ ដែលឆ្លុះបញ្ចាំងពីខ្សែសង្វាក់បញ្ជារបស់ភូមិភាគ។ ឧទាហរណ៍ ទោះបីមានអង្គភាពនីរសារថ្នាក់ស្រុក ដែលមានទីតាំងនៅជិតនឹងអង្គភាពភូមិភាគក៏ដោយ ក៏អង្គភាពថ្នាក់ស្រុកដំបូងត្រូវផ្ញើសារទៅបញ្ជាការកណ្ដាលរបស់ពួកគេ រួចផ្ញើទៅមន្ទីរនីរសារភូមិភាគ។ បន្ទាប់មកសារបានចូលដល់បណ្ដាញភូមិភាគ។ នីរសារបញ្ជូនសារសំខាន់ៗទាក់ទងការងារសន្តិសុខ ការងារបក្ស ការងារយោធា ព្រមទាំងធ្វើទំនាក់ទំនងផ្ទាល់ខ្លួនឱ្យបុគ្គលដែលនៅតាមទីតាំងនីមួយៗ"*[236] ។

<u>**ទំនាក់ទំនងក្រៅប្រទេស**</u>

៨៥. កម្ពុជាប្រជាធិបតេយ្យមានមធ្យោបាយបច្ចេកទេសដើម្បីទំនាក់ទំនងជាមួយនឹងប្រទេសក្រៅ ហើយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បញ្ជូនសារទូរលេខទៅប្រទេសផ្សេងទៀតភាគច្រើនគឺរដ្ឋដែលជាមិត្តសង្គមនិយម ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីផ្ដល់យោបល់ និងអបអរសាទរលើព្រឹត្តិការណ៍នានា[237] *ឬដើម្បីពន្យល់ថា អ្វីៗប្រព្រឹត្តទៅបានល្អប្រសើរ"*[238] ។

៨៦. យោងតាម [លុប] ព័ត៌មានក្រៅប្រទេស ត្រូវបានផ្សព្វផ្សាយតាមរយៈស្ថានទូតនៅទីក្រុងប៉េកាំង ហើយការទាក់ទងអាចមកពីបក្ស ឬពីរដ្ឋាភិបាល ឬដោយផ្ទាល់ពីប៉ុល ពត ទៅកាន់ទីស្នាក់ការបក្សនៅទីក្រុងប៉េកាំង[239]។ នៅក្នុងប្រទេស ប្រជាជនមិនមានលទ្ធភាពទទួលសេវាព័ត៌មានបរទេសណាមួយទេ[240]។ ក្រសួងឃោសនាការ ត្រូវបានណែនាំឱ្យជម្រាបជូនដល់មេដឹកនាំជាន់ខ្ពស់ជាប្រចាំថ្ងៃដោយសង្ខេបអំពីអ្វីដែលកើតមាននៅលើពិភពលោក[241]។ លើសពីនេះទៀត [លុប] បានបញ្ជាក់ថា អៀង សារី បានប្រគល់ភារកិច្ចដល់ [លុប] ឱ្យស្ដាប់ព័ត៌មានដែលផ្សាយដោយសេវាកម្មព័ត៌មានបរទេសនានា[242]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

<u>កិច្ចប្រជុំដើម្បី "សិក្សារៀនសូត្រនៅមជ្ឈិម"</u>

៨៧. កម្មាភិបាលមកពីគណៈភូមិភាគ និងតំបន់ រួមទាំងកងទ័ព ត្រូវបានកោះហៅមកចូលរួម "កិច្ចប្រជុំសិក្សារៀនសូត្រ" នៅទីក្រុងភ្នំពេញ[243] ឬនៅ "មជ្ឈិម"[244]។ សាក្សីជាច្រើនបាននិយាយថា នួន ជា[245] ឬមន្ទីរ ៨៧០[246] ឬ ៨៧០[247] ឬ ប៉ុល ពត[248] ជាអ្នកធ្វើការកោះហៅនេះ។

៨៨. នៅក្នុងករណីជាច្រើន នៅពេលដែលកម្មាភិបាលត្រូវបានហៅមកមជ្ឈិម កម្មាភិបាលនោះត្រូវបានចាប់ខ្លួន ហើយមិនដែលត្រឡប់ទៅភូមិភាគរបស់ខ្លួនវិញឡើយ[249]។

៨៩. កិច្ចប្រជុំប្រចាំខែនៅមជ្ឈិមត្រូវបានធ្វើឡើងនៅ ក-១ ដែលមានការចូលរួមពីសំណាក់គណៈស្រុក គណៈតំបន់ និងគណៈភូមិភាគ[250]។ ជារឿយៗ កិច្ចប្រជុំនេះត្រូវបានដឹកនាំ និងចូលរួមដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស[251]។ កិច្ចប្រជុំផ្នែកយោធា ដែលប្រមូលផ្តុំមេបញ្ជាការយោធានានា ត្រូវបានធ្វើឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ហើយត្រូវបានដឹកនាំប្រជុំដោយ ប៉ុល ពត និង សុន សេន[252] ។ ជួនកាល កិច្ចប្រជុំពិសេសនានាត្រូវបានធ្វើឡើងដោយអ្នកចូលរួមតែពីរបីនាក់ប៉ុណ្ណោះ។ កិច្ចប្រជុំនោះធ្វើឡើងមិនទៀងទាត់ទេ[253]។

## ខ. មធ្យោបាយនៃទំនាក់ទំនង

៩០. ក្នុងចំណោមភស្តុតាងដទៃទៀត ដោយពិនិត្យរបាយការណ៍ពីកម្មាភិបាលថ្នាក់ក្រោមទៅថ្នាក់លើរបស់ពួកគេ សេចក្តីណែនាំពីថ្នាក់លើទៅថ្នាក់ក្រោមបង្គាប់ និងការស្នើសុំផ្តល់ព័ត៌មាន ដែលអាចត្រូវបានរកឃើញផងដែរនោះ[254] វាទំនងជាបង្ហាញឱ្យឃើញថា ទំនាក់ទំនងជាចំបងរវាងមន្ទីរនិងមន្ទីរ ឬរវាងបុគ្គលនិងបុគ្គល ត្រូវបានធ្វើឡើងតាមសំបុត្រ សារទូរលេខ និងនីរសារ។ ទំនាក់ទំនងការងារជាផ្លូវការត្រូវបានធ្វើឡើងផងដែរ តាមរយៈការប្រជុំនានាដែលរៀបចំឡើងនៅតាមថ្នាក់រដ្ឋបាលនីមួយៗ និងតាមរយៈការប្រមូលផ្តុំប្រជុំគ្នាដ៏ធំនៅភ្នំពេញ[255]។ ជាទូទៅ ការអញ្ជើញឱ្យមកចូលរួមប្រជុំផ្លូវការបែបនេះត្រូវបានធ្វើឡើងតាមរយៈនីរសារ ឬសារទូរលេខ។ លើសពីនេះទៀត បក្សកុម្មុយនីស្តកម្ពុជាបានផ្សព្វផ្សាយនូវសេចក្តីណែនាំនានា និងឯកសារបណ្តុះបណ្តាលមនោគមន៍វិជ្ជានយោបាយនៅទូទាំងប្រទេស។ ឯកសារផ្សព្វផ្សាយបែបនេះ ត្រូវបានបញ្ជូនពីថ្នាក់មជ្ឈិមទៅកម្មាភិបាលរដ្ឋបាលថ្នាក់ក្រោម ដែលជាអ្នកផ្សព្វផ្សាយឯកសារនេះបន្តនៅក្នុងចំណោមប្រជាជននៅ

តាមភូមិភាគនានា និងតំបន់នានា[256]។

## សំបុត្រ

៩១. សំបុត្រនានាត្រូវបានបញ្ជូនមកពីមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដូចជា ប៉ុល ពត នួន ជា ខៀវ សំផន និងអៀង សារី[257]។ សំបុត្រត្រូវបញ្ជូនតាមរយៈនីរសារទៅឱ្យលេខាភូមិភាគ និងលេខាតំបន់នានា[258]។ មានសារទូរលេខមួយនៅក្នុងចំណោមសារទូរលេខជាច្រើន ដែលបានផ្ញើពីភូមិភាគកណ្តាលបង្ហាញថា ពេលខ្លះ សំបុត្រទាំងនោះត្រូវបានបញ្ជូនមកផ្ទាល់ ដោយកម្មាភិបាលជាន់ខ្ពស់នានាខ្លួនឯង ដូចជាលេខាភូមិភាគ កែ ពក ជាដើម[259]។

## នីរសារ

៩២. នីរសារត្រូវបានគេប្រើប្រាស់ជាចម្បងដើម្បីនាំយកសេចក្តីរាយការណ៍ និង/ឬសារទូរលេខ ពីអង្គភាពនាំសារតាមសារទូរលេខ ទៅកាន់ក្រសួងនានា[260] ឬ ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងគ្នាទាក់ទងនឹងបញ្ហាការចាប់ខ្លួន[261]។ *"នីរសារបានធ្វើការទាក់ទងដោយផ្ទាល់តាមរយៈការជិះកង់ និងជិះម៉ូតូ ។ នីរសារមានការរវល់ណាស់ និងបានចំណាយពេលដ៏ខ្លីប៉ុណ្ណោះ នៅតាមកន្លែងនីមួយៗ មុនពេលពួកគេត្រឡប់មកមូលដ្ឋានរបស់គេវិញ។ នីរសារមិនមានកាតព្វកិច្ចធ្វើការចំពោះតែខ្សែបណ្តាញតែមួយគត់ប៉ុណ្ណោះទេ ប៉ុន្តែធ្វើការឱ្យគ្រប់ខ្សែបណ្តាញទាំងអស់ដែលបម្រើឱ្យដោយអង្គភាពនីរសាររបស់ពួកគេ"*[262]។ មានសាក្សីម្នាក់បញ្ជាក់ថា នីរសារពីមជ្ឈិមបានប្រើប្រាស់ទូកល្បឿនដើម្បីទៅកាន់តំបន់ស្វយ័ត ៥០៥ នៃខេត្តក្រចេះ[263]។

## សារទូរលេខ

៩៣. ក្រោយពេលដួលរលំរបបភ្នំពេញក្នុងឆ្នាំ១៩៧៥ អង្គភាពសារទូរលេខមជ្ឈិមដែលបានប្រតិបត្តិការតាំងពីនៅក្នុង "តំបន់រំដោះ" ត្រូវបានផ្លាស់មកភ្នំពេញដែរ[264]។ មានកុមារប្រហែលជា៤០នាក់ត្រូវបានគេជ្រើសរើសមកពីបណ្តាខេត្តនានា និងត្រូវបានគេបង្រៀនពីបច្ចេកទេសការងារជាមូលដ្ឋាននៃទំនាក់ទំនងការងារតាមសារទូរលេខ (របៀបដាក់លេខកូដសម្ងាត់សារទូរលេខ វាយអត្ថបទ...។ល។) និងជួនកាលមានរៀនភាសាបារាំង និងអង់គ្លេស[265] ផងដែរ។ គណៈអចិន្ត្រៃយ៍បានសម្រេចនាថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥អំពីរបៀបដំណើរការនៃអង្គភាពសារទូរលេខ[266] ។

៩៤. អង្គភាពសារទូរលេខ ដែលត្រូវបានបែងចែកជាពីរផ្នែក (មួយផ្នែកទទួលខុសត្រូវសម្រាប់ការបញ្ជូនសារនិងទទួលសារទូរលេខ និងមួយផ្នែកទៀតទទួលខុសត្រូវសម្រាប់ការដាក់លេខសម្ងាត់និងបកប្រែខ្លឹមសារសារទូរលេខ)[267] ត្រូវបានដាក់លេខសម្ងាត់ថាជា "ក-១៨"។ មន្ទីរនេះមានទីតាំងនៅទីក្រុងភ្នំពេញនៅឯអតីតស្ថានទូតសហរដ្ឋអាមេរិក (បច្ចុប្បន្នជារដ្ឋបាលជលផល)[268]។ មន្ទីរ ក-១៨ រួមមានផ្នែកទំនាក់ទំនងក្នុងប្រទេស ដែលមាន [លុប] ជាអ្នកទទួលខុសត្រូវ និងផ្នែកទំនាក់ទំនងក្រៅប្រទេសដែលមានឈ្មោះ [លុប] ជាអ្នកទទួលខុសត្រូវ[269]។ មានមនុស្សប្រហែលពី ២០ទៅ ៣០នាក់បានធ្វើការនៅក្នុងផ្នែកនីមួយៗ[270] ។ ប្រធានផ្នែកសារទូរលេខក្រោយៗមកទៀត មានឈ្មោះ[លុប][271] (យសត្រូវបានគេស្គាល់ថាជាអនុប្រធាន[272]) និង [លុប] នាឆ្នាំ១៩៧៩ [273] ។

៩៥. នៅតាមភូមិភាគនានា អង្គភាពសារទូរលេខរួមមាន ៖ អ្នកបកប្រែនិងដាក់លេខសម្ងាត់សារទូរលេខ អ្នកបញ្ជូនសារទូរលេខឬអ្នកប្រតិបត្តិការ និងម្នាក់ផ្សេងទៀតជាលេខាឬវាយអត្ថបទ[274] ។

៩៦. សារទូរលេខដែលផ្ញើចេញពីមជ្ឈិម ជាដំបូងត្រូវផ្ញើមកផ្នែកបកប្រែសារទូរលេខ ដែលមានទីតាំងនៅមន្ទីរមជ្ឈិមបក្ស ក-១ ដើម្បីបកប្រែទៅជាលេខកូដសម្ងាត់[275] ។ បន្ទាប់មក សារដែលមានលេខកូដសម្ងាត់នោះត្រូវបញ្ជូនបន្តទៅក្រុមប្រតិបត្តការនៅ ក-១៨ ដែលជាអ្នកត្រូវបញ្ជូនសារនោះជាលេខកូដសម្ងាត់ទៅអ្នកទទួលដែលជាអ្នកបកប្រែទៅជាខ្លឹមសារអត្ថបទធម្មតា[276]។ សារទូរលេខដែលផ្ញើចូលពីភូមិភាគនានាដំបូងត្រូវចូលទៅក.១៨ដើម្បីឱ្យក្រុមអ្នកវាយអត្ថបទ បំប្លែងជាលាយលក្ខណ៍អក្សរ។ ហើយបន្ទាប់មកសារជាលេខកូដសម្ងាត់នោះត្រូវបានបញ្ជូនទៅក-១ ដើម្បីបកប្រែសារទូរលេខហើយត្រូវបញ្ជូនទៅកម្មាភិបាលបក្សដែលជាអ្នកទទួល[277] ។ សារទូរលេខទាំងអស់ដែលបានទទួលត្រូវបានបញ្ជូនទៅកម្មាភិបាលផ្សេងទៀតតាមសេចក្ដីសម្រេចរបស់ ប៉ុល ពត និងសហការីរបស់គាត់ ដែលអ្នកទាំងនោះបានទទួលការចម្លងជូនគ្រប់សារ[278]។ ពាក្យថា "*ឯកសារ*" ដែលនៅលើសារទូរលេខ មានន័យថាសារទូរលេខនេះត្រូវតែរក្សាទុកនៅក្នុងបណ្ណាសាររបស់អ្នកបកប្រែសារទូរលេខ[279]។ ឯកសារជាលេខសម្ងាត់ និងឯកសារបកប្រែជាអក្សរនៃសារទូរលេខ ត្រូវបានរក្សាទុករយៈពេល ៦ខែមុនពេលត្រូវបានដុតចោល[280] ។

៩៧. ឈ្មោះសម្ងាត់របស់អ្នកទទួលខាងក្រោមនេះត្រូវបានប្រើញឹកញាប់នៅក្នុងសារទូរលេខ៖ អ៊ំ សំរាប់ ប៉ុល ពត[281] អ៊ំនួន សំរាប់ នួន ជា[282], អ៊ំវ៉ាន់សំរាប់ អៀង សារី[283] បងវ៉នសំរាប់ វន វ៉េត[284] អ៊ំហែមសំរាប់ ខៀវ សំផន[285] បងជាទីគោរពសំរាប់ ប៉ុល ពត[286] ក.៣សំរាប់មន្ទីររបស់

ខៀវ សំផន និង នួន ជា[287] ក.១ សំរាប់មន្ទីររបស់ ប៉ុល ពត[288]។

៩៨. លេខ ៨៧០ ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើនថា ជាលេខសម្ងាត់របស់មជ្ឈិម[289] ។ ទាក់ទងនឹងរឿងនេះ ជនត្រូវចោទ ខៀវ សំផន បានបញ្ជាក់ថា៖ *"ប៉ុល ពត ចុះហត្ថលេខាលើឯកសារដោយដាក់លេខ៨៧០"*[290] ។ ពាក្យ "ម-៨៧០" ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើនថា ជាលេខសម្ងាត់របស់មន្ទីរគណៈមជ្ឈិម[291] ឬ ជូនកាលជារបស់ នួន ជា និងជូនកាលជារបស់ប៉ុល ពត[292] ។ ពាក្យ "គណៈ ៨៧០" សំដៅទៅលើគណៈមជ្ឈិម[293] ។ យោងតាមចម្លើយជនត្រូវចោទ ឌុច ៖ *"សារទូរលេខ ឬក៏សំបុត្រណាដែលមានដាក់ឈ្មោះ "ប៉ុល" "៨៧០" ឬ "មន្ទីរ៨៧០" ទាំងអស់នេះសុទ្ធតែសំដៅទៅលើប៉ុល ពត"*[294] ។

<u>**ឯកសារនយោបាយ និងអប់រំ**</u>

*ការបោះពុម្ពផ្សាយ*

៩៩. ទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ គឺជាទស្សនាវដ្តីដែលមានសារៈសំខាន់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការផ្សព្វផ្សាយ ហើយបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មេដឹកនាំជាន់ខ្ពស់របស់បក្ស ជាពិសេសទស្សនៈរបស់គណៈអចិន្ត្រៃយ៍ ទោះជាក្នុងរបបនោះ មានទស្សនាវដ្តីផ្សេងៗទៀតក៏ដោយ។ ទស្សនាវដ្តីនេះត្រូវបានបោះពុម្ពនៅមន្ទីរ ក-២៥[295] ដោយក្រសួងឃោសនាការ[296]។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ និង រហូតដល់មានការចាប់ខ្លួនគាត់នៅក្នុងឆ្នាំ ១៩៧៧ ហ៊ូ នឹម គឺជារដ្ឋមន្ត្រីក្រសួងឃោសនាការ។[297] បន្ទាប់ពីការចាប់ខ្លួនគាត់មក យុន យ៉ាត បានគ្រប់គ្រងក្រសួងឃោសនាការនេះ[298]។

១០០. នៅខណៈដែលទស្សនាវដ្តីទង់បដិវត្តន៍មានអត្ថិភាពឡើងជា "ទស្សនាវដ្តីសម្ងាត់" ដែលលាក់កំបាំងនាមុនឆ្នាំ១៩៧៥[299] ទស្សនាវដ្តីនេះបានក្លាយជាការបោះពុម្ពផ្សាយផ្លូវការរបស់បក្សដែលត្រូវបានប្រើក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ[300]។

១០១. ទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ គឺជាឧបករណ៍ឃោសនាមួយ ដែលត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងអំពីនយោបាយរបស់បក្ស មួយដងក្នុងមួយខែ[301]។ មានតែបក្ខជនទេដែលមានសិទ្ធិទទួលបាននូវទស្សនាវដ្តីទាំងនោះ[302] ហើយទស្សនាវដ្តីទាំងនោះ ត្រូវបានផ្សព្វផ្សាយដើម្បីបង្រៀនដល់កម្មាភិបាល ទាំងផ្នែកនយោបាយ និង យោធា[303]។ ពួកគេត្រូវសិក្សា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

រៀនសូត្រពីទស្សនាវដ្ដីទាំងនោះ ហើយត្រូវផ្សព្វផ្សាយគោលនយោបាយដែលមាននៅក្នុងទស្សនាវដ្ដីទាំងនោះទៅអ្នកដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួន និងត្រូវអនុវត្តគោលនយោបាយទាំងនោះ[304]។ ពួកគេត្រូវចូលរួមវគ្គសិក្សាស្ដីអំពីទស្សនាវដ្ដីនោះផងដែរ។ ទស្សនាវដ្ដីយុវជនយុវនារីបដិវត្តន៍ត្រូវបានចែកចាយដល់សមាជិកនៃសម្ព័ន្ធយុវជន[305]។

១០២. ទស្សនាវដ្ដីទាំងនោះមានឥទ្ធិពលគ្របដណ្ដប់លើគ្រប់ប្រព័ន្ធទំនាក់ទំនងការងារជាសាធារណៈរបស់រដ្ឋាភិបាល។ ខ្លឹមសារនៃការផ្សព្វផ្សាយតាមវិទ្យុត្រូវបានដកស្រង់ពីអត្ថបទនានាដែលមានក្នុងនោះ[306] ។ ឯកសារទស្សនាវដ្ដីទង់បដិវត្តន៍ជាច្រើនច្បាប់ត្រូវបានប្រទះឃើញផងដែរនៅក្នុងមន្ទីរ ស-២១ និងនៅផ្ទះជុំវិញបរិវេណនោះ[307]។ ឌុច ខ្លួនឯងក៏បានបញ្ជាក់ថា គាត់បានប្រើប្រាស់ទស្សនាវដ្ដីទង់បដិវត្តន៍សម្រាប់ជាព័ត៌មានស្ដីពី *"មាគ៌ានយោបាយទូទៅរបស់បក្ស"*[308]។ ភស្តុតាងបានបង្ហាញផងដែរថា ទស្សនាវដ្ដីត្រូវបានទទួលដោយមន្ទីរ ៨៧០[309] ព្រមទាំងត្រូវបានផ្សព្វផ្សាយទៅបរទេសតាមរយៈស្ថានទូតខ្មែរប្រចាំប្រទេសចិន[310]។

១០៣. ទស្សនាវដ្ដីទាំងនេះក៏ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការបង្រៀន ជាពិសេសបង្រៀនដោយ នួន ជា[311] និង អៀង សារី[312]។ វគ្គសិក្សារៀនសូត្រទូទៅជាច្រើនត្រូវបានធ្វើឡើងដើម្បីប្រមូលផ្ដុំ និងអប់រំ ឱ្យ *"យុវជន និងយុវនារី ដើម្បីចូលរួមបដិវត្តន៍"*[313]។ យោងតាមសាក្សីមួយចំនួន *"គោលការណ៍ណែនាំនៅក្នុងទស្សនាវដ្ដីត្រូវបានបង្ហាញពីរបៀបធ្វើការដ៏ម៉ត់ចត់ ហើយប្រសិនបើមនុស្សណាម្នាក់មិនសម្របខ្លួនតាមខ្លឹមសារទស្សនាវដ្ដីទេនោះ អ្នកនោះនឹងត្រូវចាត់ទុកថាជាខ្មាំងដោយស្វ័យប្រវត្តិ"*[314]។ ហើយសារសំខាន់គឺថាបុគ្គលដែលប្រឆាំងនឹងបក្ស ត្រូវបានចាត់ទុកថាខ្មាំង[315]។

១០៤. សាក្សីម្នាក់បញ្ជាក់ថា នៅក្នុងហេតុការណ៍មួយនោះ ខិត្តប័ណ្ណដែលត្រូវបានបោះពុម្ពនៅឯ ក-២៥ ត្រូវបានទម្លាក់ពីលើយន្តហោះនៅក្នុងភូមិភាគបូព៌ា ហើយមានខ្លឹមសារចោទប្រកាន់ សោ ភឹម ថាជាជនក្បត់ និងអំពាវនាវឱ្យប្រជាជនកុំមានការភ្ញាក់ផ្អើល[316] ។

### *ខ្សែភាពយន្ត និងការថតរូប*

១០៥. បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយច្បាស់លាស់លើវិស័យភាពយន្ត។ គោលបំណងនៃ ខ្សែភាពយន្ត គឺដើម្បីបង្ហាញពីជោគជ័យរបស់វណ្ណៈកសិករ និងផ្សព្វផ្សាយសេចក្ដីណែនាំដ៏ច្បាស់លាស់

00605288



មួយដែលក្នុងនោះ *"តើត្រូវថតអី? យើងត្រូវថតយកចលនានៃការកសាងប្រទេស ការពារប្រទេស ជាពិសេសការកសាងប្រទេសនៅជនបទ។ យើងថតសកម្មភាពធ្វើតាំងពីគេ ចាប់ផ្តើមធ្វើដល់គេធ្វើហើយក៏យើងថតទៀត"*[317]។

១០៦. ការថតខ្សែភាពយន្តត្រូវបានគេមើលឃើញថា ជាមធ្យោបាយមួយដ៏សំខាន់ក្នុងការធ្វើឱ្យមហាជនចូលពាក់ព័ន្ធនៅក្នុងគោលនយោបាយរបស់បក្ស ដូចដែលបានលើកឡើងនៅក្នុងអង្គប្រជុំការងារនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ ៖ *"និយាយជាទូទៅ, ការថតខ្សែភាពយន្តគឺជាបញ្ហាសំខាន់មួយ។ មហាជនទាមទារណាស់។ បើគេមើលឃើញពីបច្ចុប្បន្នភាព ពួកគេរីករាយណាស់ ដោយសារពួកគេបង្ហាញពីស្នាដៃ ហើយពួកគេជាអ្នកតំណាងនូវកិច្ចការរបស់ពួកគេផ្ទាល់"*[318] ។

១០៧. ការថតរូបត្រូវបានគេមើលឃើញថាជាបញ្ហាសំខាន់បន្ទាប់ពីការថតភាពយន្ត ហើយមានការណែនាំតែមួយគត់ថា ត្រូវថតរូបភាពពិធីផ្សេងៗ ឬ ភ្ញៀវបរទេស ដើម្បីទុកជាឯកសារ[319]។ មានផ្នែកថតរូប និងផ្នែកភាពយន្ត នៅសាលាបច្ចេកទេសសូវៀត ដែលស្ថិតនៅក្រោមក្រសួងឃោសនាការ[320]។

*វិទ្យុ*

១០៨. វិទ្យុត្រូវបានមើលឃើញដោយថ្នាក់ដឹកនាំថាជាវិធីសាស្ត្រដ៏ចម្បងដើម្បីផ្សព្វផ្សាយទស្សនៈបដិវត្តន៍ក្នុងចំណោមប្រជាជន[321] ។ ទាក់ទងនឹងរឿងនេះ មានការផ្តល់គោលការណ៍ណែនាំ លើរបៀបធ្វើការសម្ភាសន៍ប្រជាជននៅតាមភូមិភាគនានា និងលើរបៀបផ្សព្វផ្សាយព័ត៌មាន រួមទាំងលើខ្លឹមសារនៃកម្មវិធីផ្សេងៗផង[322]។ អ្នកជំនាញការចិនត្រូវបានពិគ្រោះពិភាក្សាជាមួយ ពីការបង្កើតបច្ចេកទេសក្នុងការផ្សព្វផ្សាយតាមវិទ្យុ[323]។

១០៩. មុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាមានស្ថានីយ៍វិទ្យុចល័តមួយនៅស្រុកស្ទឹងត្រង់[324]។ ចម្រៀងត្រូវបានគេថតនៅស្ទឹងត្រង់ ហើយត្រូវបញ្ជូនទៅស្ថានីយ៍វិទ្យុរួបរួមជាតិកម្ពុជានៅទីក្រុងហាណូយ[325] ដែលត្រូវបានដឹកនាំដោយ អៀង ធីរិទ្ធ[326] នៅខណៈដែលការងារបច្ចេកទេសត្រូវបានផ្តល់ឱ្យដោយជនជាតិវៀតណាម[327] ។ អង្គភាពវិទ្យុចល័តបានដំណើរការ និងផ្សព្វផ្សាយជាធម្មតានៅក្នុងអំឡុងពេលធ្វើការជម្លៀសប្រជាជនពីភ្នំពេញ ហើយក្រោយមកអង្គភាពនេះត្រូវបានផ្ទេរមកកាន់រដ្ឋធានីហើយក្លាយជាអង្គភាពផ្សព្វផ្សាយតែមួយគត់នៅក្នុងប្រទេស[328] ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១១០. ក្រសួងឃោសនាការមានផ្នែកនិពន្ធ ផ្នែកសម្ភាសន៍ ផ្នែកសរសេរអត្ថបទ និងផ្នែកពិនិត្យកែសម្រួល[329] ។ ការផ្សាយវិទ្យុរួមមានដំណឹងអន្តរជាតិដកស្រង់ពីវិទ្យុបរទេស និងមានព័ត៌មានក្នុងស្រុក ដែលត្រូវបានផ្សព្វផ្សាយដោយក្រសួង ដែលផ្សាយជាចម្បងជុំវិញរឿងការសរសើរសហករណ៍ជនបទ និងសមិទ្ធផលរបស់របប ពន្យល់ពីមាគ៌ារបស់បក្ស និងសុន្ទរកថាថ្នាក់ដឹកនាំនានា ការការពារប្រទេស និងការអប់រំប្រជាជនផងដែរ[330] ។

១១១. ព័ត៌មានត្រូវបានដកស្រង់ពីប៉ុស្តិ៍វិទ្យុវៀតណាម ចិន ឡាវ និងប្រទេសថៃ ប៉ុន្តែមិនមានព័ត៌មានណាដែលមានលក្ខណៈទិតៀនដល់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សាយនោះទេ[331]។ មានការផ្សាយជាភាសាអង់គ្លេស និងភាសាវៀតណាម។ កម្មវិធីផ្សាយជាភាសាថៃត្រូវបានគ្រោងទុកផងដែរ[332]។ កម្មវិធីវិទ្យុពិសេសសម្រាប់ជនជាតិខ្មែរដែលរស់នៅវៀតណាម (ដែលប.ក.ក ហៅថាកម្ពុជាក្រោម) បានផ្សព្វផ្សាយព័ត៌មានស្តីអំពីជម្លោះព្រំដែនខ្មែរវៀតណាម និងការផ្លាស់ទីលំនៅរបស់ខ្មែរកម្ពុជាក្រោមមកភូមិនិរបស់កម្ពុជា ព្រមទាំងការធ្វើទុក្ខបុកម្នេញ ដែលត្រូវបានសន្មតថាវៀតណាមបានប្រព្រឹត្តមកលើខ្មែរក្រោមទាំងនោះ[333]។

១១២. ចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមជាច្រើន ដែលត្រូវបានគេសួរចម្លើយនៅមន្ទីរ ស២១ ត្រូវបានគេចាក់ផ្សាយតាមវិទ្យុ[334] ដើម្បីបង្ហាញថាជនជាតិវៀតណាមបានឈ្លានពានយកទឹកដីកម្ពុជា[335]។ សាក្សីបញ្ជាក់ថា ឈ្លើយសឹកវៀតណាមត្រូវបានសួរចម្លើយនៅសមរភូមិ និងថាការថតសំឡេងការសួរចម្លើយនោះត្រូវបានផ្ញើមកវិទ្យុដើម្បីចាក់ផ្សាយ[336]។

## ផ្នែកទី ៥- រចនាសម្ព័ន្ធយោធា

### ក. ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក)

១១៣. កងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក) គឺជាស្ថាប័នសំខាន់របស់កម្ពុជាប្រជាធិបតេយ្យ[337]។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាពឹងផ្អែកជាសំខាន់ទៅលើកងកម្លាំងដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់ខ្លួន ដោយធ្វើឲ្យកងទ័ពជាផ្នែកមួយសំខាន់នៃឧបករណ៍រដ្ឋបាលរបស់ខ្លួន។ តាំងពី

00605290



ដើមដំបូងមក ប.ក.ក បានគិតថា *"ដើម្បីការពារខ្លួន និងដើម្បីរំដោះខ្លួន គឺត្រូវប្រើហិង្សាដាច់ខាត ទោះជាហិង្សានយោបាយ ឬជាហិង្សាប្រដាប់អាវុធក្តី។ វាចាំបាច់ដាច់ខាតដែលប្រជាជនត្រូវបំពាក់អាវុធ គឺមានន័យថា ត្រូវតែមានកងទ័ព... ដើម្បីការពារប្រជាជន ដើម្បីការពារបដិវត្តន៍ និងដើម្បីបន្តវាយសម្រុកតបតខ្លាំងវិញ"*[338]។

១១៤. ប្រវត្តិផ្លូវការនៃប.ក.ក បង្ហាញថា កម្លាំងប្រដាប់អាវុធរបស់ខ្លួនមានដើមកំណើតចេញពី "*កងការពារសម្ងាត់*"[339]។ នៅឆ្នាំ១៩៦៨ កងកម្លាំងទាំងនេះត្រូវបានប្រែក្លាយទៅជា "*កងឈ្លបប្រដាប់អាវុធ*"[340]។ នៅថ្ងៃ១៧ ខែមករា ឆ្នាំ១៩៦៨ ជាថ្ងៃនៃការចាប់ផ្តើមធ្វើការតស៊ូជាផ្លូវការដោយអាវុធ និងជាថ្ងៃកំណើត "កងទ័ពបដិវត្តន៍" របស់បក្សកុម្មុយនីស្តកម្ពុជា[341]។ ក្រោយមក បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា ចាប់ពីឆ្នាំ១៩៦៩មក *"ការបង្កើតលក្ខខណ្ឌដែលអនុគ្រោះសម្រាប់កងទ័ព មានរួចជាស្រេចហើយនៅទីនោះ... នៅកន្លែងខ្លះ នៅភូមិភាគសំខាន់ៗនានា មានកងអនុសេនាធំមានកងជាច្រើនរួចទៅហើយ។ នៅកន្លែងផ្សេងទៀត មានត្រឹមតែអនុសេនាតូច ក្រុម និងពួក។ ប៉ុន្តែកងកម្លាំងទាំងនោះ គឺនៅក្នុងជួរកងទ័ពបដិវត្តន៍"*[342]។ នៅក្នុងខែមីនា ឆ្នាំ១៩៧០ កងកម្លាំងទាំងនោះត្រូវបានកំណត់ឈ្មោះជាផ្លូវការថា "កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា"។

១១៥. ការរៀបចំចាត់តាំងជាផ្លូវការឡើងវិញនៃកងកម្លាំងប្រដាប់អាវុធនេះត្រូវបានប្រកាសជាសាធារណៈ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ នៅឯការជួបជុំគ្នាមួយ ដែលត្រូវបានគេហៅការជួបជុំនោះជាផ្លូវការថា "សន្និសីទនយោបាយដ៏សំខាន់នៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានតំណាងមកពីអង្គភាពនានានៃកងទ័ពបដិវត្តន៍ចូលរួមប្រហែល ៣០០០នាក់" និងដែលនៅពេលនោះ "*សមមិត្តប្រធានគណៈយោធាកំពូលរបស់បក្ស*"[343] បានថ្លែងទៅកាន់អ្នកចូលរួម។ កងទ័ពបដិវត្តន៍កម្ពុជាបានទទួលជំនួយពីអ្នកជំនាញការ[344] និងទទួលជំនួយជាសម្ភារៈយោធាមកពីប្រទេសនានា[345] ជាពិសេសប្រទេសចិន។

## ខ. តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា

១១៦. តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានកំណត់នៅក្នុងឯកសារមូលដ្ឋានចំនួនពីរស្តីពីអង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ មាត្រា១៩ នៃរដ្ឋធម្មនុញ្ញប្រគល់ភារកិច្ចចំបងពីរដល់កងទ័ព

00605291



បដិវត្តន៍កម្ពុជា ៖ *"ការពាររដ្ឋអំណាចរបស់ប្រជាជនកម្ពុជា(...) ហើយនៅជាមួយគ្នានេះដែរ ជួយកសាងប្រទេស"*[346]។ យោងតាមមាត្រា ២៧ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍កម្ពុជាទទួលខុសត្រូវសន្តិសុខទាំងក្នុង និងក្រៅប្រទេស។ កងទ័ពបដិវត្តន៍មានកាតព្វកិច្ចចូលរួមជាទូទៅក្នុងការ "កសាងប្រទេស"[347]។ តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានលើកយកមកនិយាយដដែលៗ និងអះអាងជាថ្មីនៅក្នុងឯកសារបោះពុម្ពផ្សាយនានារបស់ ប.ក.ក និងនៅក្នុងការប្រជុំនានាជាច្រើនរាប់មិនអស់ដែលរៀបចំដោយបក្ស[348]។

**១១៧.** ការធានា"សន្តិសុខខាងក្រៅ" ឬ ការពារជាតិ គឺជាភារកិច្ចដ៏សំខាន់របស់ ក.ប.ក ជាពិសេសនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងនៅក្នុងបញ្ហាជម្លោះព្រំដែន[349]។ "សន្តិសុខខាងក្នុង" រួមមានការការពាររបបនេះប្រឆាំងនឹងខ្មាំងសត្រូវ និងបុគ្គលដែលត្រូវបានសន្មត់ថាជាគិញ ដែលមាននៅក្នុងកងកម្លាំងប្រដាប់អាវុធ នៅក្នុងបក្ស និងនៅក្នុងប្រទេសទាំងមូល។

**១១៨.** ជាមួយនឹងភារកិច្ច "កសាងប្រទេស" បក្សបានដាក់ការទទួលខុសត្រូវទៅលើកងទ័ពបដិវត្តន៍កម្ពុជាក្នុងការធានាឲ្យមានភាពថ្កុំថ្កើងរុងរឿង និងជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន[350] និងជួយជម្រុញការសម្រេចភារកិច្ចផែនការបួនឆ្នាំ ក្នុងការធ្វើស្រែឲ្យបានបីតោនក្នុងមួយហិកតា[351]។ លើសពីនេះទៀត អង្គភាពកងទ័ពនីមួយៗត្រូវមានភារកិច្ចឧបត្ថម្ភគាំទ្រខ្លួនឯង លើកលែងកងទ័ពនៅឯព្រំដែន[352]។

### ឥ. ស្ថាប័នឥ័ពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា

<u>គណៈកម្មាធិការយោធា នៃគណៈកម្មាធិការមជ្ឈិម</u>

**១១៩.** គណៈកម្មាធិការយោធា[353] ឬគណៈកម្មាធិការយោធាជាន់ខ្ពស់[354] គឺជាស្ថាប័នរបស់គណៈមជ្ឈិមដែលត្រូវបង្កើតឡើងយ៉ាងហោចណាស់ចាប់តាំងពីនៅឆ្នាំ១៩៧០ ហើយអត្ថិភាពនៃគណៈកម្មាធិការនេះត្រូវបានបញ្ជាក់អះអាងជាថ្មីនៅមហាសន្និបាតបក្សលើកទីបួន[355]។ ដោយសារតែតួនាទីដើមរបស់កងទ័ពបក្សកុម្មុយនីស្តកម្ពុជារួមមាន បញ្ហាសន្តិសុខ និងតួនាទីយោធាសុទ្ធសាធ គណៈកម្មាធិការយោធាត្រូវបានគេហៅថា "គណៈកម្មាធិការសន្តិសុខ"[356] ឬ "គណៈកម្មាធិការយោធានិងសន្តិសុខ"[357]។ នៅអមគណៈមជ្ឈិមមានក្រុមជំនួយការទទួលបន្ទុកខាងផ្នែកយោធាផងដែរ[358]។

១២០. គណៈកម្មាធិការយោធាដើរតួនាទីជាអង្គការមជ្ឈិមបក្ស ហើយដូច្នេះគណៈកម្មាធិការយោធាធានាលើការគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជាតាមរយៈមជ្ឈិម[359]។ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធាជួនកាលប្រជុំរួមគ្នា ដើម្បីសម្រេចលើបញ្ហាយោធានានា[360] ដែលត្រូវអនុវត្តបទបញ្ជាយុទ្ធសាស្ត្រជារួមទៅលើកងកម្លាំងប្រដាប់អាវុធ[361]។

១២១. នៅក្នុងបទសម្ភាសន៍មួយ អៀងសារីអះអាងថា គណៈកម្មាធិការសន្តិសុខនិងយោធារួមមានប៉ុល ពត, នួន ជា និងសុន សេន[362]។ សមាជិកដទៃទៀតនៃគណៈកម្មាធិការយោធារួមមាន សោ ភឹម និងតាម៉ុក[363] បើទោះបីជាការទទួលខុសត្រូវជាផ្លូវការរបស់ពួកគេអាចមានលក្ខណៈតូចជាងនេះក៏ដោយ[364]។ សាក្សីជាច្រើនបានប្រាប់ពីឈ្មោះ វន វើត[365] និង កែ ពក ដែរថាជាសមាជិកនៃគណៈកម្មាធិការយោធា[366]។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប៉ុល ពត បន្តធ្វើជាប្រធានគណៈកម្មាធិការយោធា[367]។ ទោះបី នួន ជា បានទទួលស្គាល់អំពីអត្ថិភាពនៃអង្គការបែបនេះ និងអំពីតួនាទីរបស់គាត់ក្នុងវិស័យការពារជាតិ និងក្នុងការកម្ទេចខ្មាំងខាងក្នុងក៏ដោយ ក៏គាត់បដិសេធថា គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការនេះទេ[368]។ ប៉ុន្តែសាក្សីជាច្រើនបាននិយាយថា គាត់ជាសមាជិកនៃគណៈកម្មាធិការនេះ[369]។

១២២. គណៈកម្មាធិការសន្តិសុខនិងយោធា បានសម្រេចលើបញ្ហាសន្តិសុខ និងយោធានានា ជាពិសេសលើ *"ការសម្លាប់"* *"ការប្រតិបត្តិការរបស់ ស-២១"* *"កន្លែងសម្លាប់ផ្សេងទៀត"* *"ភ្នាក់ងារសម្លាប់"* និង *"បញ្ហាទូទៅ"*។ អៀង សារី ក៏និយាយផងដែរថា គណៈកម្មាធិការនេះរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ បន្ទាប់ពីបានទទួលរបាយការណ៍ពីភូមិភាគនានា និងនិយាយថា គាត់ខ្លួនឯងផ្ទាល់ក៏បានឮសេចក្តីរាយការណ៍ពីសន្តិសុខដែរ[370]។

១២៣. ដោយពិនិត្យមើលលើតួនាទីរបស់ពួកគេនៅក្នុងគណៈកម្មាធិការយោធា[371] ប៉ុល ពត, នួន ជា និង សុន សេន ទំនងជាទទួលខុសត្រូវរួមលើមន្ទីរ ស-២១ និងនយោបាយសន្តិសុខ ជាទូទៅ[372]។ សុន សេន បានជួប និងសម្របសម្រួលការងាររបស់គាត់ជាប្រចាំជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត ដោយធានាថា មេដឹកនាំរបស់ ប.ក.ក អាចគ្រប់គ្រង និងដឹងជាប្រចាំអំពីសកម្មភាពរបស់ ក.ប.ក។[373]

<u>សេនាធិការ</u>

១២៤. អង្គការកណ្តាលរបស់កងទ័ពបដិវត្តន៍កម្ពុជា គឺសេនាធិការ។ នៅក្នុងអំឡុងពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាកាលពីថ្ងៃទី ៩ តុលា ឆ្នាំ១៩៧៥ សុន សេន ជា "អ្នកទទួលខុសត្រូវលើសេនាធិការ និងសន្តិសុខ"[374] ខណៈដែល ប៉ុល ពត ទទួលខុសត្រូវទូទៅទៅលើយោធា[375]។ ក្នុងឋានៈជានាយសេនាធិការ សុន សេន ជាអ្នកទទួលសេចក្តីរាយការណ៍ ហើយគឺគាត់ក៏ជាអ្នកចេញបញ្ជា[376]។

១២៥. សេនាធិការត្រូវទទួលខុសត្រូវលើបញ្ជាការ និងការគ្រប់គ្រងរដ្ឋបាលរបស់កងកម្លាំងប្រដាប់អាវុធ។ ជារួម សេនាធិការធានាសម្របសម្រួលភារកិច្ចផ្សេងៗ នៅថ្នាក់មជ្ឈិម ដូចជាការរៀបចំកងពលបញ្ជាការងារចាត់តាំង ភ្នាក់ងារស៊ើបការណ៍ ការរៀបចំទីតាំងកងទ័ព ការរៀបចំផែនការ និងការដឹកនាំប្រតិបត្តិការយោធា ភ័ស្តុភារ អាវុធ គ្រាប់រំសេវ ការផ្គត់ផ្គង់ស្បៀងអាហារ សម្លៀកបំពាក់ ការដឹកជញ្ជូន និងថ្នាំពេទ្យ[377] ហើយចេញបញ្ជាចល័តកងទ័ពទៅកាន់កងពលនានា[378]។ សេនាធិការក៏មានអំណាចផងដែរក្នុងការដកមុខតំណែងពីលេខា និងកម្មាភិបាលផ្សេងទៀតនៅកងពលមជ្ឈិម[379] នៅខណៈដែលការតែងតាំងមុខតំណែងដឹកនាំនៅក្នុងកងពលមជ្ឈិមនានា ត្រូវបានធ្វើឡើងក្នុងនាមគណៈមជ្ឈិម ដោយ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន[380]។ ដើម្បីអនុវត្តគោលនយោបាយ និងមាគ៌ាបក្ស សេនាធិការបានរៀបចំនូវវគ្គសិក្សាសម្រាប់កម្មាភិបាលដែលត្រូវបានជ្រើសរើសមក[381] ព្រមទាំងការប្រជុំជាទៀងទាត់សម្រាប់មេដឹកនាំកងពលមជ្ឈិមនានា និងវរៈសេនាធំឯករាជ្យសម្រាប់ការធ្វើសេចក្តីរាយការណ៍ដល់សេនាធិការ ដែលនឹងចេញបទបញ្ជាទៅវិញលើបញ្ហានានា[382]។

### ឃ. សមាសភាពកងទ័ពបដិវត្តន៍កម្ពុជា

១២៦. តាមខ្លឹមសារមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តន៍កម្ពុជាមានបីប្រភេទ គឺ កងទ័ពស្រួច កងទ័ពតំបន់ និងកងឈ្លប[383]។ កងកម្លាំងទាំងបីប្រភេទនេះស្ថិតនៅ *"ក្រោមការដឹកនាំផ្ទាល់មុខ និងផ្តាច់ការរបស់បក្សកុម្មុយនីស្តកម្ពុជា"*[384]។ កងកម្លាំងបដិវត្តន៍រួមមាន "កងទ័ពស្រួចរបស់មជ្ឈិម" និងអង្គភាពយោធាមូលដ្ឋានទាំងអស់[385] ដែលចុងក្រោយស្ថិតនៅក្រោមការបញ្ជារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធារបស់មជ្ឈិម[386]។ ដូចគ្នាទៅនឹងអង្គការរដ្ឋដែរ កងទ័ពបដិវត្តន៍ត្រូវបានគេនិយាយថា *"ជាឧបករណ៍ផ្តាច់ការរបស់បក្ស"*[387]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

<u>កងទ័ពស្រួច</u>

១២៧. កងទ័ព "ស្រួច" រួមមានកងពលនានា[388] និងវរៈសេនាធំឯករាជ្យ។ កងពលនានាត្រូវបានបែងចែកជាកងពល ដែលរាយការណ៍ផ្ទាល់ទៅមជ្ឈិម[389] និងកងពលតំបន់នានា។ ក្នុងករណីភាគច្រើន កងពលរួមមានបីវរៈសេនាធំ[390] ដែលវរៈសេនាធំនីមួយៗមានបីវរៈសេនាតូច ហើយវរៈសេនាតូចនីមួយៗមានបីអនុសេនាធំ[391]។

<u>កងពលនានារបស់មជ្ឈិម</u>

១២៨. កងពលនានារបស់មជ្ឈិមត្រូវបានបញ្ជាផ្ទាល់ដោយមជ្ឈិម ហើយវរៈសេនាធំឯករាជ្យក៏ទទួលបញ្ជាតាមរបៀបដូចគ្នានេះដែរ។ កងពលមជ្ឈិម គឺជាកងកម្លាំងយោធាដ៏ចម្បងរបស់កងទ័ពបដិវត្តន៍កម្ពុជា។ ដូចនេះហើយ កងពលមជ្ឈិមបានធ្វើប្រតិបត្តិការយោធាជាចំបងប្រឆាំងទៅនឹងខ្មាំងខាងក្រៅ។

១២៩. កងពលមជ្ឈិមនានា ជារឿយៗ ត្រូវបានគេរៀបចំចាត់តាំងឡើងវិញ ត្រូវបានរំលាយ ឬត្រូវបានបញ្ចូលគ្នាទៅវិញទៅមកនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចាប់តាំងពីខែមីនាឆ្នាំ១៩៧៧ កងកម្លាំងមជ្ឈិមរួមមាន កងពល៨០១ កងពល៧០៣ កងពល៣១០ កងពល៤៥០ កងពល១៧០ កងពល២៩០ កងពល៥០២ កងពល៩២០ និងកងពល១៦៤ និងកងវរៈសេនាធំឯករាជ្យ ១៥២ ៣៧៧ និង ៤៨៨[392]។

១៣០. កងទ័ពបដិវត្តន៍កម្ពុជា បានបង្កើតផងដែរនូវបញ្ជាការដ្ឋានសមរភូមិពីរ ដែលបញ្ជាការដ្ឋានសមរភូមិនីមួយៗត្រួតពិនិត្យដោយផ្ទាល់លើប្រតិបត្តការនានារបស់កងពលជាច្រើន។ បញ្ជាការសមរភូមិទាំងពីរនេះត្រូវបានបង្កើតឡើងនៅភូមិភាគបូព៌ា។ បញ្ជាការសមរភូមិទីមួយមានទីតាំងនៅតាមផ្លូវជាតិលេខ១ ក្នុងតំបន់២៣។ បញ្ជាការដ្ឋាននេះត្រូវបានបញ្ជាដោយ សុន សេន[393] ហើយរួមមានកងពល៧០៣, កងពល៣៤០, ២២១, ៤៦០ និង ៨០៥, ២១០, ២៣០, ២៥០ និង ២៧០[394]។ បញ្ជាការដ្ឋានសមរភូមិទីពីរ មានទីតាំងនៅតាមបណ្ដោយផ្លូវជាតិលេខ៧ ហើយស្ថិតនៅក្នុងភូមិភាគបូព៌ាផងដែរ។ បញ្ជាការដ្ឋាននេះរួមមាន កងពល២០៧ (អតីតកងពល៣១០) កងពល ៦០៣ (អតីតកងពល៤៥០[395]) កងពល២៨០[396] និង កងពល១៧៥[397] រួមបញ្ចូលសមាសភាពមកពីកងពល៥០២[398] និងកងកម្លាំងនៃភូមិភាគកណ្ដាល (ភូមិភាគឧត្ដរចាស់)[399]។ ពីដើមឡើយបញ្ជាការសមរភូមិផ្លូវជាតិលេខ៧ ស្ថិតនៅក្រោមបញ្ជារបស់ សោ ភឹម ជាមួយនឹង កែ ពក ដែលជា

អនុប្រធាន។ សោ ភឹម ត្រូវបានជំនួសដោយ សុន សេន បន្ទាប់ពីការបោសសម្អាត និងការធ្វើអត្តឃាដរបស់គាត់។

១៣១. កងពលមជ្ឈិមត្រូវបានបោសសម្អាតយ៉ាងធ្ងន់ធ្ងរ ដែលនាំទៅដល់ការរៀបចំចាត់តាំងឡើងវិញជាបន្តបន្ទាប់ និងបញ្ចូលគ្នាទៅជាមួយនឹងកងពលផ្សេងៗ។ ករណីនេះមានជាពិសេសចំពោះ កងពល ៣១០, ៤៥០ និង កងពល៩២០ នៅក្នុងក្របខ័ណ្ឌនៃការបោសសម្អាតក្នុងភូមិភាគឧត្តរ ដែលអង្គភាពទាំងនេះ មានដើមកំណើតចេញមកពីភូមិភាគឧត្តរ។ បន្ទាប់ពីដំណើរការបោសសម្អាតនេះ កងពល៣១០ និង កងពល៤៥០ ត្រូវបានរៀបចំចាត់តាំងឡើងវិញជាកងពល២០៧[400] និង កងពល៦០៣[401]។

១៣២. ការរៀបចំឡើងវិញនូវកងពលនានាបានកើតឡើងផងដែរ ក្រោយពីមានភាពតានតឹងនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាមពីចុងឆ្នាំ១៩៧៧មក[402]។ ការណ៍នេះកើតឡើងរួមជាមួយនឹងការបង្កើតកងពលមជ្ឈិមថ្មីមួយចំនួន ដែលកើតចេញមកពីការពង្រីក និងរៀបចំឡើងវិញនូវអង្គភាពនានារបស់ភូមិភាគនិរតី។ កងពលទាំងនេះរួមមាន កងពល៣៤០, កងពល២២១, កងពល៤៤០, កងពល៤៦០, កងពល២១០, កងពល២៣០, កងពល២៥០ និង កងពល២៧០[403]។

## កងទ័ពរបស់ភូមិភាគ

១៣៣. នៅក្នុង ក.ប.ក សាខាធំទីពីរគឺកងទ័ពរបស់ភូមិភាគ ដែលជាទូទៅត្រូវបានរៀបចំជាកងពល[404]។ ទោះបីជាកងពលទាំងនោះត្រូវរាយការណ៍ជាចុងក្រោយទៅមជ្ឈិមក៏ដោយ ក៏កងពលទាំងនេះគឺជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលភូមិភាគដែរ[405]។ ភារកិច្ចរបស់កងពលទាំងនេះមានការទាក់ទងយ៉ាងជិតស្និទទៅនឹងសកម្មភាពរបស់ភូមិភាគដែលខ្លួនឈរជើង និងរួមមានជាអាទិ៍ ការការពារទឹកដី និងសន្តិសុខផ្ទៃក្នុង។ កងទ័ពរបស់ភូមិភាគនៅតាមព្រំដែនថៃ និង វៀតណាម មានការជាប់ពាក់ព័ន្ធខ្លាំងនៅក្នុងការប្រយុទ្ធនានា ដែលបានកើតឡើងនៅតាមបណ្ដោយព្រំដែនទាំងនេះ[406]។ នៅថ្នាក់ក្រោមកងពល ស្រុកនានាក៏មានកងកម្លាំងមូលដ្ឋានរបស់ខ្លួនដែរ ដែលចំណុះឲ្យថ្នាក់កងវរៈសេនាតូច។

## កងឈ្លប

១៣៤. កងកម្លាំងទីបី គឺយោធានៅតាមមូលដ្ឋាន ដែលត្រូវបានគេនិយាយសំដៅថាជា "កងឈ្លប"។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៣៥. កងឈ្លបបានរស់នៅក្នុងចំណោមប្រជាពលរដ្ឋនៅតាមភូមិនានា ដោយបំពេញភារកិច្ចទាក់ទងទៅនឹងសន្តិសុខនៅតាមមូលដ្ឋាន[407]។ ក្នុងចំណោមភារៈកិច្ចទាំងនេះ រួមមាន ការចាប់ខ្លួន[408] ការសម្លាប់[409] ព្រមទាំងភារៈកិច្ចដែលទាក់ទងទៅនឹងការងារយោធាបន្ថែមទៀតផងដែរ ដូចជា ការងារត្រៀមការពារភូមិ និងសហករណ៍[410]។ កងឈ្លបរាយការណ៍ផ្ទាល់ទៅ ភូមិគណៈឃុំ និងគណៈស្រុក[411] ហើយត្រូវបានគេហៅឱ្យបំពេញការងារសន្តិសុខរដ្ឋបាលស៊ីវិល[412]។

## ឃ. ទំនាក់ទំនង/ការរាយការណ៍

១៣៦. កងទ័ពបដិវត្តន៍កម្ពុជាមានរចនាសម្ព័ន្ធបញ្ជាតាមឋានានុក្រម ដែលត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈរចនាសម្ព័ន្ធទំនាក់ទំនងការងាររបស់ខ្លួន។ ការរាយការណ៍ត្រូវបានប្រមូលនៅក្នុងកងពល ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅអង្គការបញ្ជាការថ្នាក់មជ្ឈិម គឺ**សេនាធិការ**។ បញ្ជាត្រូវបានចេញតាមរយៈបណ្តាញទំនាក់ទំនងបញ្ច្រាសមកវិញ។ បញ្ជាការថ្នាក់មជ្ឈិមបញ្ជូនបញ្ជារបស់ខ្លួនទៅកាន់កងពលនានា ដែលបញ្ជាទាំងនោះត្រូវបានបញ្ជូនបន្តទៀតទៅកាន់មេបញ្ជាការថ្នាក់ទាបជាង ដែលជាអ្នកអនុវត្តនូវបញ្ជាទាំងនោះ។

### <u>ទំនាក់ទំនងរវាងកងពល និងមជ្ឈិម</u>

១៣៧. ទំនាក់ទំនងការងាររវាងកងពល និងមជ្ឈិមត្រូវបានធ្វើជាប្រចាំ ដោយមានទំនាក់ទំនងច្រើនដងក្នុងមួយថ្ងៃ[413]។ បញ្ជាការថ្នាក់មជ្ឈិមបានធ្វើទំនាក់ទំនងការងារជាទៀងទាត់ជាមួយនឹងកងពលនានា[414] ហើយផ្អែកទៅលើកងពលទាំងនេះ ដើម្បីបញ្ជូនបន្តនូវបញ្ជារបស់ខ្លួនទៅកាន់អង្គភាពនានាដែលមានថ្នាក់ទាបជាង។ សេចក្តីសម្រេចសំខាន់នានារបស់ថ្នាក់កងពលត្រូវបានទុកឱ្យអង្គភាពបញ្ជាការមជ្ឈិមធ្វើការសម្រេច[415]។ កងពលនានាផ្ញើសេចក្តីរាយការណ៍ទៅអង្គភាពបញ្ជាការមជ្ឈិមជាទៀងទាត់។ ជាទូទៅសេចក្តីរាយការណ៍ទាំងនេះស្តីអំពីការប្រយុទ្ធគ្នា ពីការរកឃើញខ្មាំងផ្ទៃក្នុង រួមជាមួយនឹងបញ្ហាផ្សេងៗទៀតផង[416]។

១៣៨. ទំនាក់ទំនងការងារត្រូវបានសម្របសម្រួលតាមមធ្យោបាយផ្សេងៗជាច្រើន។ បណ្តាញទំនាក់ទំនងដែលប្រើប្រាស់ជាញឹកញាប់គឺ តាមរយៈវិទ្យុទាក់ទង និងតាមទូរលេខ[417]។ ដើម្បីសម្រេចគោលបំណងនេះ សេនាធិការ[418] ក៏ដូចជាកងពលនីមួយៗ[419] មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពទូរលេខ។ សារនានាត្រូវបានផ្ញើ និងទទួលដោយកងទ័ពបដិវត្តន៍កម្ពុជាជាលេខសម្ងាត់[420]។

១៣៩. នីរសារត្រូវបានប្រើប្រាស់ជាញឹកញាប់ផងដែរដើម្បីបញ្ជូនសារ[421]។ កងពលនីមួយៗមានអង្គភាពនីរសារដើម្បីផ្តល់នូវសេវាកម្មទាំងនេះ[422]។

១៤០. សាររវាងសេនាធិការ ឬគណៈកម្មាធិការយោធា និងសាររវាងកងពលផ្សេងៗ ត្រូវបានបញ្ជូនជាញឹកញាប់ទៅឲ្យសមាជិកនៃគណៈមជ្ឈិម[423]។

១៤១. មធ្យោបាយផ្សេងទៀតដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីទំនាក់ទំនងការងាររវាងអង្គភាពបញ្ជាការថ្នាក់មជ្ឈិម និងកងពលនានា គឺតាមរយៈកិច្ចប្រជុំផ្ទាល់[424]។ ការប្រជុំទាំងនេះអាចមានការប្រជុំទ្រង់ទ្រាយតូច[425] ឬអាចជាការការប្រជុំទ្រង់ទ្រាយធំ[426]។ ឧទាហរណ៍ ការប្រជុំធំសំខាន់ៗមានដូចជាការប្រជុំដែលធ្វើឡើងនៅមុនពេលវាយប្រហារផ្តាច់ព្រ័ត្រយកភ្នំពេញ[427] ឬមុនពេលបោសសម្អាតភូមិភាគបូព៌ា[428]។ នៅក្នុងការប្រមូលផ្តុំប្រជុំទ្រង់ទ្រាយធំជាញឹកញាប់ មានការធ្វើសុន្ទរកថាដោយមេដឹកនាំបក្ស[429]។ សាក្សីខ្លះបានរាយការណ៍ថាមានការប្រជុំធំផ្នែកយោធា ដែលធ្វើឡើងនៅពហុកីឡដ្ឋានជាតិអូឡាំពិកនៅភ្នំពេញសម្រាប់មេបញ្ជាការអង្គភាពនានាពីថ្នាក់វរៈសេនាតូចឡើងទៅ ដែលដឹកនាំប្រជុំដោយ សុន សេន[430]។

__ទំនាក់ទំនងនៅក្នុងកងពល__

១៤២. នៅក្នុងកងពលនានា ទំនាក់ទំនងការងារធ្វើតាមរចនាសម្ព័ន្ធបញ្ជា ដោយមានមេបញ្ជាការដែលជាធម្មតាធ្វើការទំនាក់ទំនងជាមួយថ្នាក់លើ និងថ្នាក់ក្រោមបង្គាប់របស់ពួកគេផ្ទាល់[431]។ ទំនាក់ទំនងការងារប្រចាំថ្ងៃ ជារឿយៗត្រូវបានធ្វើឡើងតាមវិទ្យុទាក់ទងចល័ត[432] ប៉ុន្តែមធ្យោបាយនីរសារ[433] ទូរលេខ[434] និងការប្រជុំនានា[435] ត្រូវបានគេប្រើប្រាស់ផងដែរ។

### ច. វិន័យ

១៤៣. កងទ័ពបដិវត្តន៍កម្ពុជាបានដាក់របបវិន័យដ៏តឹងរ៉ឹងទៅលើមេបញ្ជាការ និងកងទ័ពរបស់ខ្លួន ដែលរបបវិន័យបានចែងពីមធ្យោបាយនានានៃការតាមដានត្រួតពិនិត្យ និងការដាក់ទណ្ឌកម្ម។

១៤៤. ការប្រជុំទិតៀន និងស្វ័យទិតៀន ត្រូវបានធ្វើឡើងនៅក្នុងអង្គភាពយោធា ដែលកងទ័ពត្រូវបានគេរំពឹងឲ្យធ្វើការទិតៀនពីកំហុសរបស់ពួកគេនិងទិតៀនពីកម្មាភិបាលរបស់ពួកគេ[436]។ បច្ចេកទេស


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

នៃការត្រួតពិនិត្យនិងការដាក់វិន័យនេះ ត្រូវបានប្រើប្រាស់ផងដែរនៅក្នុងការប្រជុំដែលត្រូវបានរៀបចំដោយសេនាធិការ[437]។

១៤៥. មានទម្រង់ផ្សេងៗនៃទណ្ឌកម្មដើម្បីដាក់វិន័យទៅលើកងទ័ព នៅពេលណាដែលមានការប្រព្រឹត្តិខុស។ មានការដាក់ទណ្ឌកម្មនៅក្នុងអង្គភាពនានា[438] ដែលរួមមានការបញ្ជូនទៅអប់រំកែប្រែ[439] ឬទៅការដ្ឋានការងារ[440] ឬត្រូវបានគេសម្លាប់[441]។ មេបញ្ជាការដែលមិនគោរពបញ្ជា ឬត្រូវបានគេចាត់ទុកថាក្បត់ ត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានគេសម្លាប់[442]។ ចំពោះការចាប់ខ្លួន និងការសួរចម្លើយជនក្បត់ដែលគេសន្មត់ អង្គភាពនានារបស់ ក.ប.ក បានប្រើប្រាស់នូវទីតាំងរបស់មន្ទីរផ្សេងៗ ដូចជារបស់មន្ទីរ ស-២១[443] ឬ មន្ទីរសន្តិសុខផ្ទាល់ខ្លួនរបស់អង្គភាពនោះ[444]។

## ឆ. ការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការបោសសម្អាត

១៤៦. ក្នុងឋានៈជាអ្នកទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុងកងទ័ព ក.ប.ក បានអនុវត្តន៍ការបោសសម្អាតតាមបញ្ជារបស់មជ្ឈិមបក្ស។

១៤៧. នៅក្នុងការប្រជុំជាផ្លូវការរបស់ ក.ប.ក នាខែកក្កដា ឆ្នាំ១៩៧៥ ប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស បានប្រកាសថា កងទ័ពបដិវត្តន៍ត្រូវការពារប្រទេសប្រឆាំងនឹង *"ខ្មាំងស៊ីរូងផ្ទៃក្នុង"* និង ថា កាតព្វកិច្ចកងទ័ពបដិវត្តន៍គឺ "បន្តការកម្ទេច"[445]។ នៅក្នុងពេលប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ្យ វិធានការនានាត្រូវបានលើកយកមកពិភាក្សាផងដែរ រួមទាំងការបោសសម្អាតសមាសភាពមិនល្អ[446]។

១៤៨. ឌុច បានពន្យល់ថា នៅក្នុងរយៈពេលក្រោយ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាម ក្នុងពេលដែលមិនទាន់មានអង្គភាពសន្តិសុខមជ្ឈិមណាមួយនោះ បទបញ្ជាទាក់ទងការសម្លាប់អ្នករដ្ឋការរបស់អតីតរបបសាធារណៈរដ្ឋខ្មែរ និងអ្នកផ្សេងទៀត ដែលត្រូវបានគេចាត់ទុកថាជាសត្រូវត្រូវបានសម្លាប់ដោយកម្មាភិបាលយោធាចំណុះឱ្យលេខាភូមិភាគដែលជាអ្នកទទួលបញ្ជាពីគណៈកម្មាធិការអចិន្ត្រៃយ៍[447]។ អង្គភាពយោធាភូមិភាគដែលចូលភ្នំពេញ[448] ព្រមទាំងអង្គភាពភូមិភាគ និងអង្គភាពក្រោមចំណុះដែលចូលដល់ទីក្រុងផ្សេងៗ ដូចជាខេត្តពោធិសាត់ នៅក្នុងភូមិភាគពាយ័ព្យ[449] បានអនុវត្តការសម្លាប់មនុស្សតែម្តង[450]។ កងកម្លាំងយោធាថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងស្រុក បានបន្តចូលរួម

ក្នុងការសម្លាប់មនុស្សនានានៅតាមតំបន់ និងក្នុងផ្នែកមួយចំនួននៃប្រទេស ក្នុងអំឡុងពេលពេញមួយរបបនោះ។ ឧទាហរណ៍ករណីនៅភូមិភាគបស្ចិម តំបន់៣៧ និងនៅមន្ទីរសន្តិសុខកោះខ្យង (ក្នុងស្រុកព្រៃនប់)[451] នៅមន្ទីរសន្តិសុខភ្នំក្រោល (ក្នុងស្រុកកោះញែក តំបន់ស្វ័យត១០៥)[452] និងនៅមន្ទីរសន្តិសុខស្រុកព្រៃដំរីស្រុត (ក្នុងស្រុកកំពង់ត្រឡាចលើ តំបន់៣១ នៃភូមិភាគបស្ចិម)[453]។

១៤៩. យោងតាមសាក្សីថា សេចក្ដីសម្រេចឱ្យអនុវត្តការបោសសម្អាតនៅក្នុងជួរយោធាត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមាន សុន សេន ជាអ្នកធ្វើតាមបញ្ជានានា របស់ ប៉ុល ពត, នួន ជា និង តាម៉ុក[454]។ សាក្សីរូបនោះក៏បាននិយាយផងដែរពីអត្ថិភាពនៃការបោសសម្អាត "*ការប្រជុំរៀបចំផែនការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានប៉ុល ពត, នួន ជា និងអៀង សារី*"[455]។ សាក្សីដដែលនេះរៀបរាប់ថា ការបញ្ជាឱ្យបោសសម្អាតត្រូវបានទទួលនៅក្នុងការប្រជុំនៃមេបញ្ជាការយោធានានា ដែលកោះប្រជុំដោយ ប៉ុល ពត, នួន ជា, តាម៉ុក និង សុន សេន[456]។

## ផ្នែកទី ៦- អត្ថិភាពនៃជម្លោះប្រដាប់អាវុធ

១៥០. ជម្លោះប្រដាប់អាវុធជាអន្តរជាតិមួយដែលជាការប្រឈមមុខដាក់គ្នារវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ បានផ្ទុះឡើងសឹងតែភ្លាមៗ បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ("FAPLNC") បានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជម្លោះប្រដាប់អាវុធនេះបានអូសបន្លាយយ៉ាងហោចណាស់រហូតដល់ពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញនាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងនៅពេលក្រោយៗមកទៀត។

១៥១. ទោះបីជាកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានទទួលស្គាល់ជាផ្លូវការថា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ជម្លោះប្រដាប់អាវុធជាអន្តរជាតិរវាងប្រទេសទាំងពីរបានកើតឡើង ដែលពត៌មាននេះបានបង្ហាញឱ្យដឹងតាមរយៈសេចក្ដីថ្លែងការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ដែលបានបញ្ជាក់ពីការផ្ដាច់រាល់ទំនាក់ទំនងការទូតរវាងរដ្ឋទាំងពីរក៏ដោយ[457] ក៏គេអាចចាត់ទុកបានថា ជម្លោះប្រដាប់អាវុធនេះបានកើតមានឡើងតាំងតែពីពាក់កណ្ដាលខែមេសា ឆ្នាំ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៩៧៥ មកម្ល៉េះ ហើយជម្លោះនេះចេះតែឆាបឆេះសន្ធោសន្ធៅ ខ្លាំងឡើងៗនៅគ្រប់កម្រិតរហូតដល់ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។

១៩២. ជាក់ស្តែង មានតម្រុយជាច្រើនដែលបង្ហាញឱ្យឃើញថា កម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាមបានធ្លាក់ទៅក្នុងជម្លោះប្រដាប់អាវុធជាមួយគ្នា ក្នុងឆ្នាំ១៩៧៥[458] ១៩៧៦[459] ១៩៧៧[460] និងពីឆ្នាំ១៩៧៨ ដល់ ខែមករា ឆ្នាំ១៩៧៩[461]។ ទោះបីជាការវាយប្រយុទ្ធគ្នាត្រូវបានផ្អាកជាច្រើនលើកច្រើនសារក៏ដោយ (ជាពិសេស មុនឆ្នាំ១៩៧៧) ក៏មិនដែលមានពេលណាមួយដែលរដ្ឋទាំងពីរអាចឈានទៅរកការចុះសន្ធិសញ្ញាសន្តិភាពជាទូទៅមួយរវាងគ្នានិងគ្នា ដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធជាអន្តរជាតិនេះបានដែរ។

១៩៣. បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដែលក្រោយមកបានក្លាយទៅជា "កងទ័ពបដិវត្តន៍កម្ពុជា"(ARK) និងកងទ័ពប្រជាជនវៀតណាម បានបើកការវាយប្រយុទ្ធប្រដាប់អាវុធក្រោមរូបភាពជាការវាយលុក និងការចូលលុកលុយ ទាំងក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ[462] ក៏ដូចជាក្នុងដែនដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ[463]។ ដោយឡែកការលុកលុយ និងការវាយប្រយុទ្ធគ្នានេះក៏បានកើតឡើងផងដែរនៅតាមកោះនានា ស្ថិតក្នុងឈូងសមុទ្រថៃ ទីដែលប្រទេសទាំងពីរកំពុងមានជម្លោះជាមួយគ្នា[464]។

១៩៤. ជម្លោះប្រដាប់អាវុធនេះកាន់តែឆេះសន្ធោរសន្ធៅខ្លាំងឡើងៗ រហូតបណ្តាលឱ្យកងទ័ពវៀតណាមបានចូលលុកលុយជាទ្រង់ទ្រាយធំចំនួនពីរលើកទៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដោយលើកទី១ នាខែធ្នូ ឆ្នាំ១៩៧៧ និងលើកទីពីរ នាខែធ្នូ ឆ្នាំ១៩៧៨។ ការវាយលុកចូលលើកចុងក្រោយនេះបានជម្រុញឱ្យកម្ពុជាប្រជាធិបតេយ្យប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨[465]។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបដិវត្តន៍កម្ពុជាបានរត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញ ហើយចាប់តាំងពីពេលនោះមក បក្សកុម្មុយនិស្តកម្ពុជាបានបាត់បង់ការគ្រប់គ្រងរបស់ខ្លួន យ៉ាងឆាប់រហ័សទៅលើដែនដីមួយភាគធំនៃប្រទេសកម្ពុជា។

១៩៥. នៅក្នុងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ទាក់ទងនឹងរឿងក្តី ឌុច អង្គជំនុំជម្រះសាលាដំបូងបាន អះអាងថា ជម្លោះប្រដាប់អាវុធជាអន្តរជាតិដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ បានកើតមានឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605301



នៅក្នុងសម័យកាល គិតតាំងពីខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[466]។

## ផ្នែកទី៧- ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម

១៥៦. មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាមានផែនការរួមដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និង ដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ។

១៥៧. ដើម្បីធ្វើឱ្យសម្រេចនូវផែនការរួម មេដឹកនាំនៃរបស់បក្សកុម្មុយនីស្តកម្ពុជាបានឱ្យអត្ថន័យ និង បានអនុវត្តនូវគោលនយោបាយទាំងប្រាំដូចជា ៖

- ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និង ពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ។
- ការបង្កើត និង ការទាញយកផលប្រយោជន៍តាមរយៈសហករណ៍និងតាមការដ្ឋាន។
- ការអប់រំ "សមាសភាពមិនល្អ" និង ការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និង នៅក្រៅបក្ស។
- ការចេញនូវវិធានការណ៍ជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃសាធារណៈរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។
- ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។

១៥៨. ផែនការរួមកើតមានតាំងតែពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ គោលនយោបាយទាំងប្រាំងដែលត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យសម្រេចផែនការរួមនេះ ត្រូវបានអនុវត្តក្នុងរវាងឬមុនកាលបរិច្ឆេទទាំងនេះ។ គោលនយោបាយទាំងនេះបានប្រែប្រួលនៅមួយពេញរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈកាន់តែធំ និងតឹងរឹង។ ផលវិបាកមួយក្នុងចំណោមផលវិបាកនានានៃ គោលនយោបាយទាំងនេះ គឺការធ្វើសមូហភាវូបនីយកម្មសង្គមលើគ្រប់វិស័យទាំងអស់។ សមូហភាវូបនីយកម្មសង្គមនេះ រួមមានការលុបបំបាត់ផ្សារ រូបិយវត្ថុ និងកម្មសិទ្ធិឯកជន[467] ការហាមឃាត់ការធ្វើដំណើរទៅមកដោយសេរីរបស់មនុស្ស និងជាចុងក្រោយគឺការប្រមូលផ្តុំមនុស្សជាអង្គភាពដោយឡែកៗពីគ្នាដោយធ្វើការបែងចែកជាប្រភេទ ដែលក្នុងនោះមនុស្សត្រូវរស់នៅរួមគ្នាជាលក្ខណៈទូទៅ។ ការណ៍នេះ

បានបង្កើតនូវប្រព័ន្ធមួយ ដែលក្រោយមកប្រជាជនកម្ពុជាបានកំណត់ជាទូទៅថា៖ ប្រទេសទាំងមូលបានក្លាយទៅជា "គុកឥតជញ្ជាំង"។

១៥៩. បុគ្គលដែលបានចូលរួមក្នុងផែនការរួមនេះ យ៉ាងហោចណាស់មានសមាជិកនៃគណៈកម្មាការអចិន្ត្រៃយ៍ ដូចជា នួន ជា និង **អៀង សារី** អ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ដូចជា **ខៀវ សំផន** រដ្ឋមន្ត្រីនានាដូចជា **អៀង ធីរិទ្ធ** លេខាភូមិភាគ និងតំបន់ស្វយ័ត និង មេដឹកនាំកងពលយោធាមជ្ឈិម។

## ក. ការផ្លាស់ទីលំនៅរបស់ប្រជាជន

១៦០. គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និង ការពារបដិវត្តន៍សង្គមនិយម គឺការផ្លាស់ទីលំនៅរបស់ប្រជាជនពីទីប្រជុំជនទៅកាន់តំបន់ជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត តាមមធ្យោបាយចាំបាច់ណាក៏ដោយ។ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមផ្លាស់ទីលំនៅរបស់ប្រជាជន មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីការផ្លាស់ទីលំនៅប្រជាជនជាក់លាក់ទាំងបីដំណាក់កាល៖ ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ (ដំណាក់កាលទី១) ពីភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (ដំណាក់កាលទី២) និង ពីភូមិភាគបូព៌ា (ដំណាក់កាលទី៣)។

១៦១. គោលដៅមួយក្នុងចំណោមគោលដៅទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជន គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកម្លាំងពលកម្មសំរាប់សហករណ៍ និងការដ្ឋានទាំងឡាយ[468]។ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការប្រកាសថែមទៀតថា គឺដើម្បីធានានូវស្បៀងអាហារ និង ការពារសន្តិសុខរបស់ប្រជាជន។ ឯកសារមួយរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះខែកញ្ញា ឆ្នាំ១៩៧៥ បានឆ្លុះបញ្ចាំងពីគោលដៅសំខាន់មួយផ្សេងទៀតគឺ ៖ ការដកហូតសិទ្ធិគោលនយោបាយ និង សេដ្ឋកិច្ចពីអ្នករស់នៅទីក្រុង និងពីអតីតអ្នករដ្ឋការ ដើម្បីប្រែក្លាយពួកគេឱ្យទៅជាកសិករ[469] និងដើម្បី "*រក្សាលទ្ធផលបដិវត្តន៍*"[470]។ ហេតុដូច្នេះ ការផ្លាស់កន្លែងប្រជាជន គឺត្រូវបានយកចិត្តទុកដាក់ជាពិសេស

ក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលថា "យើងខំធ្វើយ៉ាងម៉េច ឱ្យតែចំណេញដល់បដិវត្តន៍"[471]។

*កាលបរិច្ឆេទ និងការចូលរួម*

១៦២. ចាប់តាំងពីមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយជម្លៀសប្រជាជនពីទីក្រុងនានាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេ៖ ប្រជាជនត្រូវបានផ្លាស់កន្លែងមួយផ្នែក ឬ ទាំងស្រុងពីទីរួមខេត្តស្ទឹងត្រែង ខេត្តក្រចេះ ស្រុកបាណន់ និង ឧត្តុង រហូតដល់ភូមិភាគឧត្តរ បូព៌ា ពៀសាន និង នៅតំបន់៥០៥[472]។ ការបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្តន៍បានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ទីលំនៅប្រជាជនពីទីប្រជុំជនទៅជនបទដោយមានការគិតទុកជាមុន[473]។

១៦៣. គោលនយោបាយនេះត្រូវបានអនុវត្តដំបូងនៅថ្ងៃ ឬនៅអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ដំណាក់កាលទី១) បន្ទាប់មកចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ (ដំណាក់កាលទី២) និង នៅចុងឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ ១៩៧៨ (ដំណាក់កាល ទី៣)។

១៦៤. ទាក់ទងនឹងដំណាក់កាលទីមួយ ប៉ុល ពត បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចដើម្បីជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ[474]។ ផែនការរៀបចំទទួលអ្នកជម្លៀសពីទីក្រុងភ្នំពេញ ត្រូវបានផ្សព្វផ្សាយមុននឹងធ្វើការជម្លៀស[475]។ សមាជិកមជ្ឈិមបក្សផ្សេងទៀតក៏មានការពាក់ព័ន្ធនៅក្នុងការរៀបចំផែនការនៃការជម្លៀសនេះដែរ[476] ក្នុងអំឡុងពេលប្រជុំកាលពីចុងខែមីនា និងដើមខែមេសា ឆ្នាំ១៩៧៥[477]។ កិច្ចប្រជុំផ្សេងៗទៀតត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយដល់កម្មាភិបាលថ្នាក់ក្រោមអំពីសេចក្តីសម្រេច[478]។ ក៏ប៉ុន្តែ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនត្រូវបានជូនដំណឹងជាមុនអំពីការវាយប្រហារលើទីក្រុងភ្នំពេញជាទូទៅ តាមរយៈថ្នាក់លើរបស់ពួកគេ និងយោងតាមឋានានុក្រម[479] ឯកងទ័ពផ្សេងទៀតបានទទួលត្រឹមតែបទបញ្ជាឱ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្លាមៗបន្ទាប់ពីពួកគេមកដល់ទីក្រុងភ្នំពេញប៉ុណ្ណោះ[480]។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមិនមែនជាព្រឹត្តិការណ៍មួយដាច់ដោយឡែកតែឯងនោះទេ ប៉ុន្តែវាជាផ្នែកមួយនៃផែនការរួមក្នុងការផ្លាស់ទីលំនៅរបស់ប្រជាជនចេញពីទីក្រុងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[481]។

00605304



១៦៥. ទាក់ទងនឹងដំណាក់កាលទី២ ផែនការបញ្ជូនប្រជាជនទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ បានបង្ហាញឱ្យឃើញច្បាស់តាមរយៈដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាទៅភូមិភាគទាំងនេះ មុន ឬ ប្រហែលជាខែសីហា ឆ្នាំ១៩៧៥[482]។ ការធ្វើទស្សនកិច្ចនេះបានធ្វើឱ្យលេចចេញនូវបញ្ហាដែលថា *"កំលាំងមនុស្សមិនគ្រប់។ ត្រូវបន្ថែមកម្លាំងពលកម្ម។ ៣ ឬ៤ សែនទៀត ក៏មិនគ្រប់។ កម្លាំង ១លាននាក់បច្ចុប្បន្ន ធ្វើមិនបាន ៥០ភាគរយទេ។ ត្រូវថែម ៤ ឬ៥ សែនទៀត"*[483]។ ឯកសាររបស់បក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ បានលើកឡើងថា "ប្រជាជនថ្មី" ត្រូវធ្វើបំលាស់ទីចេញពីភូមិភាគដែលជាកន្លែងប្រមូលផ្តុំបណ្តោះអាសន្នរបស់ពួកគេដោយសារជួបបញ្ហាកង្វះស្បៀងអាហារ។ ឯកសារនោះបានគូសបញ្ជាក់ថា ដំណោះស្រាយទៅលើបញ្ហានេះដែលមានលក្ខណៈអចិន្ត្រៃយ៍ និង ស្របទៅតាមតម្រូវការផលិតកម្ម គឺត្រូវតែអនុវត្តចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៧៥[484]។ សាក្សីផ្សេងៗ[485] និងឯកសារទាំងឡាយ[486] ផ្តល់នូវភស្តុតាងថែមទៀតទាក់ទិននឹងមធ្យោបាយ ដែលមជ្ឈិមបក្សមានការពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅទាំងអស់នេះ។ សារទូរលេខ លេខ១៥ ចុះខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលបានផ្ញើទៅ ប៉ុល ពត[487] ដោយរៀបរាប់អំពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជននៅដំណាក់កាលទី២[488]។ យោងតាមអតីតប្រធានអង្គភាពផ្នែកសារទូរលេខនៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ភូមិភាគបូព៌ា *"ត្រូវបញ្ជូនរបាយការណ៍ ពីភូមិភាគទៅ ប៉ុល ពត ថ្នាក់មជ្ឈិមសិន រួចហើយរង់ចាំការណែនាំពី ប៉ុល ពត។ តែ ពក ទទួលសារទូរលេខរឿងនេះមកពីមជ្ឈិម គឺមិនមែនទទួលផ្ទាល់មកពីខាងបូព៌ានោះទេ"*[489]។

១៦៦. ទាក់ទងនឹងដំណាក់កាលទីបី ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ទីលំនៅប្រជាជនមួយផ្នែកពីភូមិភាគបូព៌ាទៅកន្លែងផ្សេងៗនៅក្នុងភូមិភាគនេះ ឬទៅភូមិភាគផ្សេងទៀតដោយមូលហេតុទាក់ទិននឹងការផលិតស្បៀងអាហារ[490] ឬជម្លោះជាមួយប្រទេសវៀតណាមក៏ដោយ[491] ក៏មានភស្តុតាងដែលអាចបញ្ជាក់ថា មានការផ្លាស់ទីលំនៅប្រជាជនជាច្រើនក្នុងពេលបោសសម្អាតភូមិភាគបូព៌ាដែលត្រូវបានរៀបរាប់ដូចខាងក្រោម[492]។

១៦៧. ចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ បន្ទាប់ពីការផ្លាស់ទីលំនៅរបស់ប្រជាជនដំណាក់កាលទី២ និង ទី៣ នៅភូមិភាគនិរតីមានការប្រឈមមុខនឹងបញ្ហាប្រជាជនលើសចំណុះ និង ភាពអត់ឃ្លាន ដែលចំណុចនេះមានបង្ហាញនូវក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម នៃដីកាដំណោះស្រាយនេះ។ មជ្ឈិមត្រូវបានគេផ្តល់ដំណឹងអំពីបញ្ហាទាំងអស់នេះតាមរយៈការធ្វើទស្សនកិច្ចទៅដល់

00605305



ទីកន្លែងផ្ទាល់ដោយតំណាងរបស់ខ្លួន[493] និង តាមរយៈរបាយការណ៍របស់លេខាភូមិភាគ ដែលបាន លើកឡើងអំពីបញ្ហាទាំងនេះ[494]។

## ខ. សហករណ៍ និងការដ្ឋាន

១៦៨. គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និង ការពារបដិវត្តន៍សង្គមនិយម គឺការបង្កើត និង ការទាញយកផលប្រយោជន៍ពីសហករណ៍ និង ពីការដ្ឋានតាមរយៈគ្រប់មធ្យោបាយចាំបាច់។ សហករណ៍ និង ការដ្ឋាននានា ត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីមុនឆ្នាំ១៩៧៥ ដោយបក្សកុម្មុយនីស្តកម្ពុជាមកម្លេះ ពោលគឺ ដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាលើដែនដីមួយចំនួនរបស់ប្រទេស។ ការបង្កើតនេះបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងអំពីទីតាំងជាក់លាក់នៃការដ្ឋាន និង សហករណ៍ចំនួនប្រាំមួយកន្លែងដែលរួមមាន ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង ទំនប់១មករា ការដ្ឋានស្រែអំបិល សហករណ៍ត្រាំកក់ និងការដ្ឋាន ស២៤។

១៦៩. គោលដៅមួយក្នុងចំណោមគោលដៅទាំងឡាយក្នុងការបង្កើតសហករណ៍និងការដ្ឋាន គឺដើម្បីដាក់ប្រជាជនឱ្យធ្វើការដើម្បីផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និងសម្រាប់ការនាំចេញ[495]។ ចំណុចនេះពាក់ព័ន្ធផងដែរជាមួយនឹងការបង្កើនផលិតផលស្រូវយ៉ាងឆាប់រហ័ស ៣ តោនក្នុងមួយហិកតា[496] ការបង្កើតឱ្យមានប្រព័ន្ធស្រោចស្រពទឹកបញ្ចូលស្រែទូទាំងផ្ទៃប្រទេស[497] ការបង្កើននូវផលិតផលកសិកម្មផ្សេងទៀតដូចជា ដំណាំកៅស៊ូ[498] និងអំបិល[499] និងការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ព្រលានយន្តហោះ ឬ ទំនប់ទឹក[500]។ លទ្ធផលទាំងអស់នេះត្រូវតែធ្វើឱ្យបានសម្រេចទោះបីជាមានផលប៉ះពាល់ដែលអាចកើតមានឡើងចំពោះប្រជាជនយ៉ាងណាក៏ដោយ។ នៅក្នុងករណីខ្លះ ការធ្វើដោយកម្លាំងពលកម្មមិនអាចសម្រេចបានទេ ឧទាហរណ៍ នៅកន្លែងខ្លះ ដីមិនមានជីវជាតិគ្រប់គ្រាន់ដើម្បីផលិតស្រូវឱ្យបាន៣តោនក្នុងមួយហិកតា[501]។ គោលនយោបាយនេះ គឺដើម្បីស្រាវជ្រាវរកខ្មាំង ការពារទប់ទល់នឹងខ្មាំង អប់រំខ្មាំង និងកម្ទេចខ្មាំង[502]។ គោលដៅនេះត្រូវបានឆ្លុះបញ្ចាំងដោយការផ្សាយតាមវិទ្យុនាខែកុម្ភៈ ឆ្នាំ១៩៧៦ នៅក្នុងនោះបានរៀបរាប់អំពីមុខងារយោធាថា ជាភារកិច្ចមួយក្នុងចំណោមភារកិច្ចចំនួនប្រាំមួយរបស់សហករណ៍[503]។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ខែមករា ឆ្នាំ១៩៧៦ បានចែងជាផ្លូវការថា ប្រជាជននៅក្នុង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

សហករណ៍នានា មានកាតព្វកិច្ចការពារប្រទេសជាតិ[504]។ ចាប់ពីឆ្នាំ១៩៧៨មក សហករណ៍ត្រូវបានដាក់ការងារបន្ថែមទៀតគឺឲ្យ "កម្ទេចខ្មាំង" ដែលបក្សកុម្មុយនីស្តកម្ពុជាបានជឿថាបានលាក់ខ្លួននៅក្នុងចំណោមពួកគេ[505]។ សហករណ៍និងការដ្ឋាន មានគោលដៅមួយទៀតដើម្បីលុបបំបាត់របបឯកជន[506] ដោយបំផ្លាញ ចោលរចនាសម្ព័ន្ធសង្គមដែលមានស្រាប់ ហើយជំនួសមកវិញដោយរបបសមូហភាព[507] ដែលក្នុងនោះលែងមានផលប្រយោជន៍បុគ្គល និង គ្រួសារទៀតហើយ[508]។ សហករណ៍ និងការដ្ឋាន គឺត្រូវបានយកចិត្តទុកដាក់ជាពិសេសក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា "យើងខំធ្វើយ៉ាងម៉េច ឲ្យតែចំណេញដល់បដិវត្តន៍" [509]។

## *<u>កាលបរិច្ឆេទ និងការចូលរួម</u>*

១៧០. បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយសមូហភាពលើផលិតផលកសិកម្មក្នុងអំឡុងឆ្នាំ ១៩៧០ និងបានបង្កើនការអនុវត្តន៍នេះតាមរយៈមធ្យោបាយដែលបក្សកុម្មុយនីស្តកម្ពុជាបានពង្រឹងការកាន់កាប់លើទឹកដីទាំងមូលនៃប្រទេសកម្ពុជា[510]។ សហករណ៍មួយចំនួនត្រូវបានបង្កើតឡើង តាំងពីឆ្នាំ១៩៧៣ មកម្លេះ[511]។ នៅខែឧសភា ឆ្នាំ១៩៧៥ សន្និបាតមួយត្រូវបានប្រារព្ធធ្វើឡើងដោយមានការចូលរួមពីតំណាងបក្សកុម្មុយនីស្តកម្ពុជាមកពីទូទាំងប្រទេសកម្ពុជាដែលនៅក្នុងនោះ ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតបានសម្រេចថា បដិវត្តន៍សង្គមនិយមកម្ពុជាត្រូវយកចិត្តទុកដាក់លើវិស័យកសិកម្ម និងវិស័យឧស្សាហកម្មតាមរយៈការបន្តបង្កើតសហករណ៍ ក៏ដូចជាការកសាងទំនប់និងប្រឡាយ។ ផែនការនេះត្រូវបានដាក់ឲ្យអនុវត្តនៅឆ្នាំ១៩៧៦[512]។

១៧១. គោលនយោបាយដូចដែលបានបង្កើតដោយគណៈអចិន្ត្រៃយ៍នេះ បានឆ្លុះបញ្ចាំងតាមរយៈកិច្ចប្រជុំនានា ដែលនៅពេលនោះពួកគេបានផ្តល់ការណែនាំលើបញ្ហាទាំងឡាយ ដូចជា របបអង្ករ[513] ទិសដៅដើម្បីឲ្យសម្រេចបានក្នុងការផលិតអង្ករ និងផលិតផលកសិកម្មផ្សេងទៀត[514] និងការកសាងប្រព័ន្ធស្រោចស្រពទឹកជាដើម[515]។ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានធ្វើសេចក្តីរាយការណ៍អំពីដំណើរទស្សនៈកិច្ចទៅកាន់ភូមិភាគពាយ័ព្យដែលជាកន្លែងគណៈអចិន្ត្រៃយ៍ អាចបានដឹងអំពីស្ថានភាពលំបាកនៃការរស់នៅនិងការងារ រួមទាំងកង្វះស្បៀងអាហារ ភាពអត់ឃ្លាន[516] និងកង្វះថ្នាំពេទ្យ[517] ដោយធ្វើការសន្និដ្ឋានថា "*ដាក់ស្តែងគឺត្រូវពង្រឹង ពង្រីកសហករណ៍*"[518] និងថាភូមិភាគនិរតីមាន "*សង្ឃឹមតិច (ដីតិច ទឹកតិច ស្រូវមិន*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

"*ជំងឺមនុស្ស*" ប៉ុន្តែ បានបញ្ជាក់ថា ពួកគេនឹងអាចដោះស្រាយបញ្ហានេះបាន[៥៣៩]។

១៧៣. សភាតំណាងប្រជាជនបានគាំទ្រគោលនយោបាយនេះនៅក្នុងសន្និបាតមួយធ្វើឡើងនៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ដែលអំពាវនាវឱ្យ "*ប្រជាជនទាំងមូលថែមទៀតដើម្បីវាយសម្រុកនៅគ្រប់សមរភូមិបង្កបង្កើនផលលើគ្រប់ផ្នែកទាំងអស់ ជាពិសេសលើផ្នែកកសិកម្ម សំដៅផលិតស្រូវឱ្យបានច្រើនជាអតិបរមា...សម្រាប់ជម្រុញកសាងប្រទេសយើងឱ្យបានឆាប់របស់តាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ ...*"[៥៤០]។ អ្នកដែលត្រូវបានអះអាងថា ជាតំណាងកម្មករ[៥៤១] កសិករ[៥៤២] និងកងទ័ព[៥៤៣] បានសម្តែងនូវការតាំងចិត្តរបស់ពួកគេក្នុងការគាំទ្រដល់គោលនយោបាយនេះ។ ទាក់ទិនទៅនឹងទិសដៅ "*បីតោនក្នុងមួយហិចតា*" ដែលបង្កើតឡើងដោយការជួបប្រជុំបក្សដ៏ធំមួយនៅក្នុងដើមខែវិច្ឆិកា ឆ្នាំ១៩៧៥ គឺបានក្លាយទៅជា "*សេចក្តីសម្រេច របស់បក្សទាំងមូល ប្រជាជនទាំងមូល និងកងទ័ពបដិវត្តទាំងមូល*"[៥៤៤]។ អង្គភាពយោធាបានបើកអង្គប្រជុំយ៉ាងទៀតទាត់ ដែលនៅក្នុងអង្គប្រជុំនោះ គោលនយោបាយនេះត្រូវបានលើកយកមកពិភាក្សា និងរាល់ព័ត៌មានលម្អិតនៃការអនុវត្តទស្សនៈនេះត្រូវបានរាយការណ៍[៥៤៥]។

១៧៤. សេចក្តីណែនាំ[៥៤៦] និងកិច្ចប្រជុំនានារបស់បក្សកុម្មុយនីស្តកម្ពុជា ក៏បានលើកឡើងអំពីគោលនយោបាយនេះផងដែរ[៥៤៧] រួមមានការប្រជុំមួយនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងនោះមានការកត់សម្គាល់ថា ដោយយោងតាមសេចក្តីណែនាំទាក់ទិននឹងស្ថានភាពកសិកម្មនៅក្នុងតំបន់ ១០៦ និង ១០៣ ក្នុងភូមិភាគឧត្តរ និងទិសដៅដើម្បីនាំអង្ករចេញពីតំបន់ ១០៦ នៅឆ្នាំ១៩៧៧[៥៤៨] របាយការណ៍ ត្រូវបានតម្រូវឱ្យធ្វើជាទៀងទាត់នូវរាល់ទស្សនៈនៃគោលនយោបាយនេះ[៥៤៩]។ កង្វះខាតអង្ករ និងជំងឺ និងឥទ្ធិពលអាក្រក់របស់វាលើកម្លាំងពលកម្មរបស់ប្រជាជននៅតាមការដ្ឋានក៏ត្រូវបានលើកឡើងផងដែរនៅក្នុងអង្គប្រជុំនេះ[៥៥០]។ មានការចេញសេចក្តីណែនាំថា ប្រជាជនត្រូវទទួលបានរបបអង្ករពីរកំប៉ុងក្នុងមួយថ្ងៃ ប៉ុន្តែគេបានកត់សម្គាល់ថា "*នៅចុងរដូវ ច្រើនខ្វះខាត។ បើខ្វះខាតនឹងប៉ះពាល់ដល់សុខភាព ខាតកម្លាំងពលកម្ម*"[៥៥១]។ មានការបញ្ជូនទូរលេខផងដែរទៅមជ្ឈិមបក្ស ដោយរាយការណ៍អំពីគោលនយោបាយទាក់ទិនទៅនឹងសហករណ៍ និងការដ្ឋាននានា រួមមាន លក្ខខណ្ឌបំពេញការងារដូចជាការខ្វះខាតម្ហូបអាហារ និងការអត់ឃ្លាន[៥៥២]។

១៧៥. បញ្ហាជាក់លាក់មួយចំនួនដែលទាក់ទងនឹងសុខភាព និង ផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើគោលនយោបាយនេះត្រូវបានគេលើកឡើងនៅក្នុងពេលប្រជុំដោយមិនបានព្រាងទុករបស់បក្សកុម្មុយនីស្តកម្ពុជានាថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦។ កម្រិតនៃជីវភាពរស់នៅរបស់ប្រជាជន ជំងឺផ្សេងៗដែលបណ្តាលមកកម្រិតទាបនៃជីវភាពរស់នៅ និង កង្វះខាតថ្នាំសង្កូវយ៉ាងធ្ងន់ធ្ងរនៅទូទាំង

*ល្អ)"*[519]។ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានពិចារណាអំពីការបណ្តុះបណ្តាលទាក់ទងនឹងគ្រឿងយន្តកសិកម្ម[520] និងការផលិតអំបិល[521]។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បានផ្តល់ការណែនាំ ពីការដឹកជញ្ជូន ការចែកចាយស្រូវអង្ករ ការបង្កើនផលិតផលអំបិល ការកសាងផ្លូវរថភ្លើង ការកសាងទំនប់វារីអគ្គិសនី[522] និងការកសាងព្រលានយន្តហោះកំពង់ឆ្នាំង[523]។ នៅក្នុងពេលប្រជុំ ពីថ្ងៃទី១៩ ដល់ថ្ងៃ ទី២១ ខែមេសា ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បានលើកឡើងថា ខ្លួននឹងចុះទៅតាមមូលដ្ឋាន នៅខែឧសភា ឆ្នាំ១៩៧៦[524] និងបានសង្កត់ធ្ងន់ថា គណៈអចិន្ត្រៃយ៍ត្រូវធ្វើការងារជាមួយក្រសួងនានាដើម្បី *"បញ្ជាក់ពីជំហររួមរបស់បក្ស និងណែនាំទាន់ពេលវេលា"*[525]។ នៅឯកិច្ចប្រជុំដដែល គណៈអចិន្ត្រៃយ៍បានបង្កើតគណៈកម្មាធិការដែលនៅជុំវិញមន្ទីរ ៨៧០[526] ដោយមានការទទួលខុសត្រូវពាក់ព័ន្ធនឹងកសិកម្ម ពាណិជ្ជកម្ម និងសេដ្ឋកិច្ច[527] និងបានផ្តល់ការណែនាំលើបញ្ហាទាំងឡាយ ដូចជាការចចារទាក់ទងនឹងវិស័យពាណិជ្ជកម្មក្រៅប្រទេស ជាមួយប្រទេសកូរ៉េខាងជើង និងប្រទេសចិន[528] ការអភិវឌ្ឍន៍លើផលិតកម្មកៅស៊ូ ការបង្កើនទិន្នផលស្រូវដើមរដូវ[529] ហើយនឹងការផលិត និងការចែកចាយម៉ាស៊ីនបូមទឹក[530]។ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានដាក់ចេញនូវការណែនាំទាក់ទងនឹងតួនាទីដែលថា កងទ័ពដែលបានចូលរួមក្នុងផលិតកម្មកសិកម្មដោយស្របទៅតាម*"ភារកិច្ចរួម កសាងប្រទេស"* ដែលជាតួនាទីរបស់ពួកគេផងដែរ[531]។ ចុងក្រោយ នៅខែសីហា ឆ្នាំ១៩៧៦ គណៈកម្មាការអចិន្ត្រៃយ៍បានបង្កើតផែនការ ៤ឆ្នាំ ដើម្បីកសាងរបបសង្គមនិយមនៅគ្រប់វិស័យ និងព្យាករណ៍ទៅលើបញ្ហាដូចជាការអភិវឌ្ឍន៍វិស័យកសិកម្មឱ្យបានឆាប់រហ័សផងដែរ[532]។

**១៧២.** គណៈរដ្ឋមន្ត្រីបានអះអាងជាថ្មីអំពីតម្រូវការដើម្បី*"ធ្វើយ៉ាងណាឱ្យបានផលស្រូវ ៣តោន ក្នុងមួយហិចតា"*[៥៣៣] ហើយជាលទ្ធផល*"អចិន្ត្រៃយ៍ត្រូវចុះខាងស្រែឱ្យបានញឹកញាប់ យ៉ាងតិចឱ្យបាន១៥ថ្ងៃក្នុងមួយខែ"*[៥៣៤]។ នៅក្នុងការប្រជុំគណៈរដ្ឋមន្ត្រីធ្វើឡើងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ មានការកត់សម្គាល់ថា ភារកិច្ចរបស់រដ្ឋាភិបាលកម្ពុជាគឺ *"កសាងប្រទេសគ្រប់ផ្នែកសេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សង្គមកិច្ច សុខាភិបាល។ល។ តាមសង្វាក់ និងតាមសំណូមពររបស់បក្ស ធ្វើយ៉ាងម៉េចឱ្យក្រសួងមួយៗ មន្ទីរមួយៗ អង្គភាពមួយៗបំពេញភារកិច្ចបានល្អបានច្រើន តាមសន្ទុះមហាលោតផ្លោះមហាអស្ចារ្យ"*[៥៣៥]។ នៅកិច្ចប្រជុំមួយថ្ងៃទី៣១ ខែឧសភា ឆ្នាំ ១៩៧៦ របាយការណ៍លម្អិតក្នុងការចុះទៅពិនិត្យ*"មូលដ្ឋានជាច្រើន"* ត្រូវបានគេរាយការណ៍ ដូចជា ស្ថានភាពនៃការវិវត្តន៍នូវប្រព័ន្ធទំនប់ទឹក[៥៣៦] ការបង្កបង្កើនផលស្រូវ នៅតាមបណ្តាស្រុកមួយចំនួន[៥៣៧] និង បញ្ហានានាទាក់ទិននឹងប្រឡាយទឹក និងដី[៥៣៨]។ នៅក្នុងកិច្ចប្រជុំនេះ គណៈរដ្ឋមន្ត្រីបានកត់សម្គាល់ នូវកង្វះខាតរបបអង្ករ និង ការលេចចេញនូវ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605309



ប្រទេសត្រូវបានគេកត់សម្គាល់ទុក ខណៈដែលក្រសួងសុខាភិបាល និង សង្គមកិច្ច បានធ្វើការក្រើនរំលឹកនូវកាតព្វកិច្ចនានាទាក់ទងនឹងគោលនយោបាយនេះ និង បានផ្តល់ការណែនាំផ្សេងៗដើម្បីស្តារនូវបញ្ហាទាំងនេះ[553]។ បញ្ហាទាំងឡាយទាក់ទងនឹងសុខាភិបាលត្រូវបានត្រួតពិនិត្យបន្ទាប់មកទៀតដោយ ប៉ុល ពត និង ក្រុមគ្រូពេទ្យប្រចាំភូមិភាគ និង តំបន់ ព្រមទាំងបុគ្គលិកពេទ្យយោធា ដែលបានចូលរួមនៅក្នុងសន្និសិទ្ទសុខាភិបាលថ្នាក់ជាតិលើកទីមួយនាខែតុលា ឆ្នាំ១៩៧៨[554]។

**១៧៦.** គោលនយោបាយនៃការបង្កើតសហករណ៍ និងការដ្ឋាននានា ក៏ត្រូវបានផ្សព្វផ្សាយផងដែរតាមវិទ្យុ[៥៥៥] និងតាមទស្សនាវដ្តីទង់បដិវត្តន៍[៥៥៦]។ ការចេញផ្សាយមួយរបស់ទង់បដិវត្តន៍ក្នុងឆ្នាំ១៩៧៥ បានបញ្ជាក់ថា "*បក្សត្រូវកសាងសេដ្ឋកិច្ចថ្មីឱ្យបានឆាប់រហ័សបំផុតដោយផ្អែកលើកសិកម្មជាមូលដ្ឋាន*"[៥៥៧] និងពួកគេត្រូវតែ "*រៀបចំកម្លាំងវាយសម្រុកជាបន្តបន្ទាប់*"[៥៥៨]។ ក្នុងឆ្នាំ១៩៧៦ មានការបញ្ជាក់ថា បក្សបានធ្វើការវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ចជារៀងរាល់ខែ[៥៥៩] ហើយថា កង្វះខាតម្ហូបអាហារ និងជំងឺបានបន្តកើតមានក្នុងឆ្នាំ១៩៧៦ ប៉ុន្តែបញ្ហានោះ ត្រូវបានដោះស្រាយហើយ "ស្រុកភាគច្រើន" មានម្ហូបអាហារបរិភោគគ្រប់គ្រាន់[៥៦០]។ ប៉ុន្តែក្នុងឆ្នាំ១៩៧៨ មានការធ្វើកំណត់ហេតុថា ការអះអាងកាលពីលើកមុនៗអំពីជោគជ័យផ្នែកកសិកម្មគឺត្រូវបានគេបំផ្លើស ហើយការបរាជ័យ ដែលមានគឺបណ្តាលមកពីខ្មាំងផ្ទៃក្នុង[៥៦១]។

**១៧៧.** ទោះបីជាការបង្កើតរបបនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងប្រទេសកម្ពុជាបានបង្កឱ្យមានបញ្ហាសុខភាព[៥៦២] និងបញ្ហាម្ហូបអាហារយ៉ាងធ្ងន់ធ្ងរយ៉ាងណាក៏ដោយ[៥៦៣] ក៏មេដឹកនាំបក្សមិនបានគិតគូរដល់ប្រព័ន្ធដែលត្រឹមត្រូវដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះដែរ[៥៦៤] និងមិនព្រមទទួលជំនួយអន្តរជាតិឡើយ[៥៦៥] លើកលែងតែជំនួយមានកម្រិតដែលផ្តល់មកពីប្រទេសចិន[៥៦៦]។ ផ្ទុយទៅវិញ គោលនយោបាយរបស់បក្សកម្មុយនីស្តកម្ពុជា ត្រូវបានផ្តោតទៅលើភាពផ្តាច់ខ្លួនចេញពីគេ និងភាពម្ចាស់ការដោយខ្លួនឯងលើផ្នែកសេដ្ឋកិច្ចជាតិ[៥៦៧]។

## គ. មន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្ស

**១៧៨.** គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការលត់ដំនូវ "*សមាសភាពមិនល្អ*" និងការសម្លាប់ "*ខ្មាំង*" ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស[568]។ នៅពេលដែលពួកគេឡើងកាន់អំណាច បក្សកុម្មុយនីស្តកម្ពុជាបានបំផ្លាញរចនាសម្ព័ន្ធច្បាប់ និងតុលាការដែលមានស្រាប់[៥៦៩]។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ជំនួសរចនាសម្ព័ន្ធទាំងនេះដោយបណ្តាញមន្ទីរសន្តិសុខ និងកន្លែង

00605310



សម្លាប់មនុស្សនៅតាមតំបន់ដែលពួកគេបានកាន់កាប់ ដើម្បីឃុំខ្លួន និងលត់ដំ ឬសម្លាប់អ្នកទាំងឡាយណាដែលត្រូវបានសង្ស័យថា ជាប់ពាក់ព័ន្ធក្នុងសកម្មភាពប្រឆាំងនឹងរដ្ឋ[៥៧០]។ គិតមកត្រឹមពេលដែលរបបនេះដួលរលំ មន្ទីរសន្តិសុខប្រហែល ២០០កន្លែង និងកន្លែងសម្លាប់មនុស្សយ៉ាងច្រើនរាប់មិនអស់ ត្រូវបានបង្កើតឡើង ហើយដែលអាចប្រទះឃើញនៅគ្រប់ភូមិភាគទូទាំងប្រទេសកម្ពុជា និងនៅគ្រប់ថ្នាក់ទាំងអស់នៃរចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា រួមទាំងនៅកម្រិតមជ្ឈិមបក្សផងដែរ[៥៧១]។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីមន្ទីរសន្តិសុខចំនួន ១១ កន្លែងដែលរួមមាន មន្ទីរសន្តិសុខស២១ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខកោះខ្យង មន្ទីរសន្តិសុខគោកក្ដួច មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខសង់ មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខវត្តធ្លក និងកន្លែងសម្លាប់មនុស្សចំនួនបី ទៀតគឺ (ក្រៅពី ជើងឯក ដែលភ្ជាប់ជាមួយនឹង ស-២១)៖ កន្លែងសម្លាប់មនុស្សក្នុងស្រុក ១២ កន្លែងសម្លាប់មនុស្សស្ទឹងតូច កន្លែងសម្លាប់មនុស្សទួលពោធិជ្រៃ។

១៧៩. គោលដៅសំខាន់ពីរនៃមន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្សទាំងនោះ គឺដើម្បីអប់រំកសាងសមាសភាពមិនល្អ និង “*កម្ទេច*” ខ្មាំង។ នៅក្នុងការប្រើប្រាស់ទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា ពាក្យថា “កម្ទេច” មានន័យថា “សម្លាប់”[៥៧២]។ ក៏ប៉ុន្តែ នៅក្នុងបរិបទនៃមន្ទីរសន្តិសុខ សញ្ញាណនេះគឺសំដៅដល់ការចាប់ខ្លួនដោយសម្ងាត់ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់[573]។ ដូចគ្នាដែរ ពាក្យថា “បោសសម្អាត”[574] ត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការចាប់ខ្លួន ដែលជាទូទៅត្រូវបានគេសម្លាប់បន្ទាប់មកទៀត[575]។ ជំពូក៧ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា “*អំពីតុលាការ*” បង្ហាញអំពីក្តីកង្វល់របស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការការពាររដ្ឋពីអំពើវិទ្ធង្សនា[៥៧៦]។ មាត្រា ១០ នៃជំពូក ៧ សំដៅទៅលើប្រភេទពីរនៃសកម្មភាពដែលបានបង្កនូវការគំរាមកំហែងដល់រដ្ឋ និងទោសទណ្ឌឆ្លើយតបទៅនឹងអំពើទាំងនោះ ៖ ប្រភេទទីមួយគឺ “*ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត*” និងប្រភេទមួយទៀតគឺ “*ចំពោះប្រភេទបទល្មើស ក្រៅប្រភេទខាងលើ ត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬ ក្នុងក្របខ័ណ្ឌអង្គការប្រជាជន*”[៥៧៧]។ ជនណាដែលត្រូវបានសង្ស័យនៅក្នុងប្រភេទទីមួយ ត្រូវបានចាត់ទុកថាជា “ខ្មាំង” ដែលត្រូវតែ “កម្ទេច” [578] រីឯ ជនដែលស្ថិតនៅក្នុងប្រភេទទីពីរ ត្រូវបានចាត់ទុកថាជា “សមាសភាពមិនល្អ” ដែលនឹងត្រូវយកទៅអប់រំដូចដែលមានចែងដោយរដ្ឋធម្មនុញ្ញ[៥៧៩]។ មន្ទីរសន្តិសុខ

00605311



ត្រូវបានប្រើប្រាស់សំរាប់ឃុំខ្លួនទាំងពួក "ខ្មាំង" និងពួក "សមាសភាពមិនល្អ" ដែលអ្នកទាំងនោះត្រូវបានគេហៅតាមលំដាប់ថាជាអ្នកទោស "*ធ្ងន់*" និងអ្នកទោស "*ស្រាល*"[580]។

១៨០. បក្សកុម្មុយនីស្តកម្ពុជា បានប្រើប្រាស់វិធីសាស្ត្រជាច្រើន ដើម្បីកំណត់អត្តសញ្ញាណអ្នកទាំងឡាយណាដែលបានអនុវត្ត "សកម្មភាពប្រឆាំងនឹងរដ្ឋ" ដូចជា តម្រូវឱ្យប្រជាជនសរសេរប្រវត្តិរូប និងរៀបចំការប្រជុំស្វ័យទិតៀន។ បុគ្គលដែលត្រូវបានចាប់ខ្លួន ហើយត្រូវបានយកទៅសួរចម្លើយនៅមន្ទីរសន្តិសុខមួយ ត្រូវតែប្រាប់ឈ្មោះសមាជិកដទៃទៀតនៃ "ខ្សែ" របស់ពួកគេដែលត្រូវបានចោទប្រកាន់ ដែលជាទូទៅគឺស្ថិតក្រោមការធ្វើទារុណកម្មដែលត្រូវបានប្រើប្រាស់នៅក្នុងមន្ទីរសន្តិសុខទូទាំងប្រទេស និងត្រូវបានគេអនុវត្តតាំងតែមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[៥៨១]។ វិធីសាស្ត្រទាំងឡាយដែលបានយកមកប្រើប្រាស់ក្នុងការសួរចម្លើយត្រូវបានកំណត់ថា ជាវិធីសាស្ត្រ "*ត្រជាក់*" "*អង្កៀម*" ឬ "*ក្ដៅ*"[៥៨២]។ វិធីសាស្ត្រទាំងនេះ ទំនងជាត្រូវបានបង្រៀនដល់កម្មាភិបាលមន្ទីរសន្តិសុខពីសំណាក់កម្មាភិបាលស្រុក និងតំបន់ ហើយពាក្យទាំងនេះត្រូវបានគេយល់ជាទៅទាំងអស់គ្នា[៥៨៣]។ លើសពីនេះទៀត ពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយផ្សេងទៀត អ្នកសួរចម្លើយបានចោទនូវសំណួរដូចៗគ្នាដែលមានលក្ខណៈជាប្រព័ន្ធដូចជា ថាតើពួកគេគឺជាភ្នាក់ងារ សេអ៊ីអា។ បទបញ្ជាឱ្យសួរចម្លើយតាមរបៀបទាំងនេះបានចេញមកពីថ្នាក់មជ្ឈិម និងថ្នាក់ភូមិភាគ[៥៨៤] និងបានឆ្លុះបញ្ចាំងការណ៍ដែលថាថ្នាក់ដឹកនាំមានការសង្ស័យថា ពួកសេអ៊ីអា កំពុងតែរួមដៃជាមួយវៀតណាម ដើម្បីផ្ដួលរំលំរបបបក្សកម្ពុជាប្រជាធិបតេយ្យ[៥៨៥]។ ការបង្កើតមន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្សគឺជាមធ្យោបាយដ៏សំខាន់មួយសំរាប់បក្សកុម្មុយនីស្តកម្ពុជាក្នុងការ "*...ធ្វើម៉េចឱ្យវណ្ណៈត្រូវគេជិះជាន់ ឈ្នះវណ្ណៈជិះជាន់*"[586]។

១៨១. ដូចដែលបានលើកឡើងនៅខាងលើ បញ្ជីឈ្មោះអ្នកទាំងឡាយដែលបក្សសង្ស័យថា ជាប់ពាក់ព័ន្ធក្នុងសកម្មភាពប្រឆាំងនឹងរដ្ឋកាន់តែរីកធំឡើង និងវិវឌ្ឍន៍ជាលំដាប់អាស្រ័យទៅតាមស្ថានភាពក្នុងស្រុក និងជម្លោះប្រដាប់អាវុធអន្តរជាតិប្រឆាំងជាមួយនឹងវៀតណាម។ ចំពោះចំណុចនេះ បក្សកុម្មុយនីស្តកម្ពុជាដែលបានជឿថាខ្លួនស្ថិតនៅក្រោមការគម្រាមកំហែងជាប្រចាំដោយការឈ្លានពាន និង ការលេបយកទឹកដីពីសំណាក់កងទ័ពវៀតណាម បានចាប់ផ្ដើមនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាមដោយបានបញ្ចូលទៅក្នុងនយោបាយការពារប្រទេសរបស់ខ្លួនប្រឆាំងនឹងសត្រូវខាងក្រៅ។

<u>កាលបរិច្ឆេទ និងការចូលរួម</u>

១៨២. គោលនយោបាយនេះត្រូវបានអនុវត្តជាចំបងដោយសមាជិកនៃកងកម្លាំងសន្តិសុខ និងយោធានៃបក្សកុម្មុយនីស្តកម្ពុជា "សន្តិបាល"[៥៨៧] ហើយបានវិវឌ្ឍន៍ទាំងមុន និងក្នុងអំឡុងពេលនៃរបបនោះ។ នៅត្រឹមទសវត្សរ៍ ឆ្នាំ១៩៧០ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សត្រូវបានបង្កើតឡើងនៅតាម "តំបន់រំដោះ" និងត្រូវបានគេប្រើប្រាស់ដើម្បីលត់ដំ និងសម្លាប់ខ្មាំង[៥៨៨]។ គោលនយោបាយនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយចាប់ពីឆ្នាំ១៩៧១ ហើយចម្រៀងលើកទឹកចិត្តជម្រុញឱ្យកម្ទេចមនុស្ស ត្រូវបានគេប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តរបស់ខ្លួន[៥៨៩]។

១៨៣. នៅខែកក្កដា ឆ្នាំ១៩៧៥ ក្នុងការជួបប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជា "ប្រធានគណៈកម្មាធិការយោធាថ្នាក់ខ្ពស់របស់បក្ស" បានប្រកាសថា កងទ័ពបដិវត្តន៍កម្ពុជាត្រូវតែការពារប្រទេសប្រឆាំងនឹង "*ខ្មាំងផ្ទៃក្នុង*" ដោយនិយាយថា វាគឺជាកាតព្វកិច្ចរបស់កងទ័ពបដិវត្តន៍ "*ក្នុងការបន្តកម្ទេច*"[៥៩០]។ ក្នុងអំឡុងកិច្ចប្រជុំផ្សេងៗទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា គេបានលើកយកមកពិភាក្សាអំពីវិធីសាស្ត្រដែលត្រូវអនុវត្តប្រឆាំងនឹងសមាសភាពមិនល្អ[៥៩១]។

១៨៤. គណៈអចិន្ត្រៃយ៍បានលើកអំពីគោលនយោបាយនេះក្នុងអំឡុងកិច្ចប្រជុំមួយចំនួនដែលធ្វើឡើងនៅចន្លោះខែសីហា ឆ្នាំ១៩៧៥ និងខែសីហា ឆ្នាំ១៩៧៦[៥៩២] រួមមានជាអាទិ៍ វិធីសាស្ត្រនៃការឃ្លាំមើល[៥៩៣] ទៅលើស្ថានភាពរបស់បុគ្គលមួយចំនួនដូចជា [លុប] ឬ កម្មាភិបាលដែលត្រូវបានកំណត់ថាជា "*ជនក្បត់*" ដែលមានឥទ្ធិពល[៥៩៤] និងទៅលើស្ថានភាពការពារជាតិ[៥៩៥] និងស្ថានភាពរបស់ខ្មាំង[596]។

១៨៥. មានឯកសារចំនួនពីររបស់បក្សកុម្មុយនីស្តកម្ពុជាចុះខែកញ្ញា ឆ្នាំ១៩៧៥ ស្តីអំពីបុគ្គលដែលបក្សកុម្មុយនីស្តកម្ពុជាសង្ស័យថាជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពប្រឆាំងនឹងរដ្ឋ ទាំងខាងក្នុង និងខាងក្រៅប្រទេសកម្ពុជា និងក្នុងករណីខ្លះ ពួកគេបានស្នើឱ្យមានការដាក់ទណ្ឌកម្មមួយដ៏សមស្រប[៥៩៧]។ ឧទាហរណ៍ទាក់ទិនទៅនឹងបញ្ញវន្តដែលរស់នៅបរទេស ត្រូវបានគេសម្រេចថា អ្នកទាំងនោះនឹងត្រូវលត់ដំតាមរយៈការធ្វើពលកម្មនៅពេលពួកគេវិលត្រឡប់មកក្នុងប្រទេសវិញ[៥៩៨]។

១៨៦. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានរាយការណ៍អំពី "*ការកម្ទេចក្នុងជួរ និងក្រៅជួរ*" ថា ត្រូវអនុវត្តដូចខាងក្រោមនេះ ៖ "*បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវគណៈអចិន្ត្រៃយ៍ភូមិភាគសម្រេច។ នៅជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ នៅតំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍*

*សម្រេច។ នៅកងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច*"[៥៩៩]។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ឯកសារផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា បានតម្រូវឱ្យមានការលើកកម្ពស់នូវ "*ការប្រុងប្រយ័ត្នបដិវត្តន៍*" ដើម្បីទប់ស្កាត់ខ្មាំង "*មិនអាចស៊ើបរកឃើញក្នុង*" បក្ស និង កងទ័ពបានឡើយ[៦០០]។ នៅក្នុងការអនុវត្តន៍ មានការលេចឡើងដែលថាតំបន់ចេញសេចក្តីសម្រេច "កម្ទេច"[601] ឬត្រួតពិនិត្យសេចក្តីសម្រេចកម្ទេចនៅតាមថ្នាក់ស្រុក[602]។ នៅកន្លែងផ្សេងទៀត ស្រុកហាក់បីដូចជាធ្វើការសម្រេចរបៀបនេះ ដោយកម្មាភិបាលរបស់ខ្លួនដោយផ្ទាល់[603]។ម្យ៉ាងវិញទៀត គណៈមជ្ឈិម យ៉ាងហោចណាស់បានផ្ទេរអំណាចនេះទៅសហករណ៍មួយចំនួន។ ការដែលថាសហករណ៍មួយចំនួនមានអំណាច "កម្ទេច" ត្រូវបានបង្ហាញភស្តុតាងដោយសក្ខីកម្មរបស់សាក្សីនានា[604] របាយការណ៍សារព័ត៌មានផ្លូវការ[605] និងសារទូរលេខ[606]។ បន្ថែមពីនេះទៀត កម្មាភិបាលនៅតាមសហករណ៍មួយចំនួនបានបញ្ជូនអ្នកទោសទៅមន្ទីរសន្តិសុខថ្នាក់ស្រុកដើម្បីសម្លាប់ ដូចជាករណីនៅក្នុងស្រុកត្រាំកក់ជាឧទាហរណ៍ ដូចដែលមានរៀបរាប់ក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុទាក់ទិនទៅនឹងសហករណ៍ស្រុកត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ ។

**១៨៧.** សភាតំណាងប្រជាជនបានបញ្ជាក់យ៉ាងច្បាស់អំពី គោលនយោបាយនេះ នៅក្នុងកិច្ចប្រជុំធ្វើឡើងចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ដោយបានទទួលស្គាល់អំពីសារៈសំខាន់ដើម្បី "*លើកកម្ពស់ការប្រុងប្រយ័ត្នបដិវត្តន៍ឱ្យខ្ពស់ជានិច្ច*"[៦០៧]។

**១៨៨.** នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦[៦០៨] ប៉ុល ពត បានបញ្ជាក់ថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវនៅគ្រប់តំបន់ និងក្រសួងទាំងអស់ ដោយបញ្ជាក់ថា "*ខ្មាំងសត្រូវក៏គោរពញញើតយើងដែរ*"[៦០៩]។ ជាពិសេសចំពោះគ្រោះថ្នាក់នៃពួកចក្រពត្តិ និងសេអ៊ីអា ពួកគេបានបញ្ជាក់ថា "*យើងធ្វើល្អយ៉ាងណាក៏ដោយ បើចក្រពត្តិវានៅ សេអ៊ីអាវានៅ ពួកប្រតិកិរិយាវានៅមិនទាន់អស់ពីសកលលោក វានៅតែបន្តប្រឆាំងបដិវត្តប្រឆាំងយើងទៀត ប្រឆាំងនឹងអ្វីដែលចំរើន ទាំងចំហ ទាំងសម្ងាត់*"[៦១០]។ គាត់ក៏បានបញ្ជាក់ផងដែរអំពីសារៈសំខាន់នៃ "*ការប្រុងប្រយ័ត្នបដិវត្តន៍*" ប្រឆាំងនឹង "*គ្រប់ទម្រង់ទាំងអស់នៃសកម្មភាពខ្មាំង*" និង អំពីការលត់ដំមហាជន "*នៅគ្រប់ក្រសួងមន្ទីរ នៅក្នុងកងទ័ព នៅក្នុងសហករណ៍ សហជីព។ល។*[៦១១]"។ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ប៉ុល ពត បានថ្លែងទៅគណៈរដ្ឋមន្ត្រីអំពីការលំបាកដែលបណ្តាលមកពីព្រំដែនខាងកើតតាមរយៈ "*ទីមួយគឺពួកទាហាន និងទីពីរពួកខ្មែរសេអ៊ីអា ជាសិស្សដែលវាចាត់តាំង តែមួយចំនួនតិចទេ*"[៦១២]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៨៩. គោលនយោបាយនេះបានពិនិត្យផងដែរ នៅក្នុងការប្រជុំជាពិសេសចំនួនបួនរបស់បក្សកុម្មុយនីស្ត កម្ពុជានាឆ្នាំ១៩៧៦ ៖ ការប្រជុំពីរលើកទាក់ទងនឹងការឃោសនា ការប្រជុំមួយលើកទាក់ទងនឹងការងារមូលដ្ឋាន និង ទាក់ទងនឹងផ្នែកសុខាភិបាល និងការងារសង្គមកិច្ច[613]។ កំណត់ហេតុនៃការប្រជុំលើកទីមួយទាក់ទងនឹងការឃោសនាដែលធ្វើឡើងនាខែមីនា ឆ្នាំ១៩៧៦ បានជម្រុញលើសារៈសំខាន់នៃការផ្សព្វផ្សាយតាមវិទ្យុដើម្បី "កុំឱ្យខ្មាំងវាយយើង" ឬ ដើម្បីធានានូវការរៀនសូត្រ និង "អប់រំអំពីរដ្ឋធម្មនុញ្ញ"[614]។ ក្នុងពេលប្រជុំលើកទីពីរស្តីអំពីការឃោសនានាខែមិថុនា ឆ្នាំ១៩៧៦ មានការលើកឡើងអំពីការណែនាំជាក់លាក់មួយចំនួនរបស់គណៈអចិន្ត្រៃយ៍លើបញ្ហានេះ ដោយគូសបញ្ជាក់អំពីភាពចាំបាច់ "យើងប្រុងប្រយ័ត្នបដិវត្តថែមទៀត ពិសេសខ្មាំងបង្កប់"[615]។ ស្ថានភាពខ្មាំងនៅតាមមូលដ្ឋានត្រូវបានគេយកមកពិនិត្យផងដែរនៅពេលប្រជុំលើកទីបី នាខែមីនា ឆ្នាំ១៩៧៦ ដែលពេលនោះមានការលើកឡើងអំពីភាពចាំបាច់ "ផ្តាច់ការវណ្ណៈអធន *(...)* ដើម្បីកុំឱ្យខ្មាំងវាឆ្លៀតវាយយើង"[616]។ នៅពេលកិច្ចប្រជុំលើកទីបួន នាខែមិថុនា ឆ្នាំ១៩៧៦ ការងារគោលនយោបាយសតិអារម្មណ៍ និងការបណ្តុះមនោគមន៍វិជ្ជាត្រូវបានគេពិភាក្សាផងដែរជាមួយនឹងក្រសួងសង្គមកិច្ច[617]។

១៩០. នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ មាគ៌ាបក្សចំពោះខ្មាំង និងសមាសភាពមិនល្អទំនងជាបានផ្លាស់ប្តូរបន្ទាប់ពីគណៈមជ្ឈិមបានចេញផ្សាយសេចក្តីណែនាំមានចំណងជើងថា *"សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភ្លាំភ្លាត់ច្រឡំចូល សេអ៊ីអា ឬធ្វើភ្នាក់ងារយួន ឬចូលកាហ្សែបេ ប្រឆាំងបក្ស ប្រឆាំងបដិវត្តន៍ ប្រឆាំងប្រជាជន និងប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ"*[៦១៨]។ សេចក្តីណែនាំនេះបានបញ្ជាក់អំពីការលត់ដំបុគ្គលណាដែលបានចូលរួមជាមួយ សេអ៊ីអា កាហ្សែបេ និងវៀតណាម មុនខែកក្កដា ឆ្នាំ១៩៧៨ ដោយបង្គាប់ឱ្យបក្ស និងប្រជាជនទូទៅលុបបំបាត់ចោលបណ្តាញដែលប្រឆាំងនឹងបក្ស[៦១៩]។ សាក្សីម្នាក់បានគូសបញ្ជាក់ថា សេចក្តីណែនាំនាខែមិថុនា ឆ្នាំ១៩៧៨ បានផ្តល់ឱ្យគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានូវអំណាចដើម្បីកម្ទេចខ្មាំង ដែលកាលពីមុនអំណាចនេះ ត្រូវបានផ្ទេរពីមជ្ឈិមទៅមូលដ្ឋានតាមសេចក្តីណែនាំចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[620]។ សេចក្តីណែនាំខែមិថុនា ឆ្នាំ១៩៧៨នេះត្រូវបានបោះពុម្ពផ្សាយនៅក្រោមទម្រង់ជាសារាចរ នៅក្នុងទស្សនាវដ្តី*ទង់បដិវត្តមួយ*[៦២១]។ ការចេញផ្សាយមួយទៀតនៃទស្សនាវដ្តីទង់បដិវត្ត ចុះខែកក្កដា ឆ្នាំ១៩៧៨ បានប្រកាសទៀតថា ការបែងចែកពីមុនរវាង "ប្រជាជនពេញសិទ្ធិ" "ប្រជាជនត្រៀម" និង "ប្រជាជនជម្លៀស" នៅក្នុងសហករណ៍ត្រូវបានលុបបំបាត់ចោល[៦២២]។ ទង់បដិវត្ត ចេញនាខែកក្កដា ឆ្នាំ១៩៧៨ បានជម្រុញ

សមាជិកបក្សឲ្យបន្ត "បំផុសចលនាមហាជនបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងតទៅទៀតឲ្យខ្លាំងក្លាជាប់ជានិច្ច"[623] ។ នាខែកញ្ញា ឆ្នាំ១៩៧៨ ប៉ុល ពត បានផ្សព្វផ្សាយគោលនយោបាយថ្មីនេះនាកិច្ចប្រជុំធំមួយ ជាមួយកម្មាភិបាលបក្សនៅទូទាំងផ្ទៃប្រទេស[624]។ ប៉ុន្តែ ឌុច បានផ្តល់ភស្តុតាងថា ការផ្លាស់ប្តូរដែលគេអះអាងនេះនៅក្នុង គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា គឺគ្រាន់តែជាការបោកបញ្ឆោត ដែលគេធ្វើឡើងដើម្បីធ្វើឲ្យប្រជាជនស្ងប់ចិត្តប៉ុណ្ណោះ[៦២៥] ។

__"សីលធម៌"__

១៩១. ទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ ត្រូវបានគេចាត់ទុកថាផ្ទុយទៅនឹងទស្សនៈសមូហភាពរបស់ ប.ក.ក[៦២៦] ហេតុដូច្នេះហើយត្រូវបានចាត់ទុកថាជា "អំពើខុសសីលធម៌"[៦២៧] ហើយជាប់ប្រឡាក់ប្រឡូសនឹងសកម្មភាពនៃរបបចាស់[៦២៨]។ ដោយសារហេតុនេះ ក្រឹត្យក្រម សីលធម៌របស់បក្សចែងថា "*កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ*"[៦២៩] ហើយក្រឹត្យក្រមរបស់កងទ័ពលើកឡើងថា "*យើងមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់ស្ត្រីឡើយ*"[៦៣០]។ ក៏មានរៀបរាប់ផងដែរថា ក្រឹត្យក្រម សីលធម៌ទាំងនេះត្រូវបានយកមកឲ្យ "*យុវជន*"[៦៣១] រៀនសូត្រ។ ប្រជាជនត្រូវបានជម្រុញឲ្យប្រកាន់ខ្ជាប់ទៅនឹងក្រឹត្យក្រមនៅក្នុងនោះ[៦៣២]។ បុគ្គលដែលត្រូវបានគេចោទថាមានឥរិយាបថ "ខុសសីលធម៌" ត្រូវបានគេចាត់ទុកជា "សមាសភាពមិនល្អ" ឬ "ខ្មាំង" និង ជាញឹកញាប់ត្រូវបានយកទៅអប់រំ ឬ សម្លាប់[633]។ លើសពីនេះ អ្នកទោសទំនងជាត្រូវបានគេសួរចម្លើយយ៉ាងទៀងទាត់ចំពោះ "អំពើខុសសីលធម៌" របស់ខ្លួន នៅក្នុងមន្ទីរសន្តិសុខ[634]។ ករណីខុសសីលធម៌ និងទណ្ឌកម្មចំពោះទង្វើនោះត្រូវបានរាយការណ៍ទៅថ្នាក់លើដោយបក្សកុម្មុយនីស្តកម្ពុជា[635]។ ទោះបីជាយ៉ាងនេះក្តី នៅពាក់កណ្តាល ឆ្នាំ១៩៧៨ មន្ទីរ ៨៧០ បានចេញសេចក្តីណែនាំទៅគ្រប់ភូមិភាគ "*មានការចេញសេចក្តីណែនាំ ឲ្យមានការដោះលែងអ្នកទោសកម្រិតមធ្យម និងស្រាល*" ហើយអ្នកទោស "ដែលមានកំហុស សីលធម៌" ត្រូវបានគេដោះលែង[៦៣៦]។

__*"ការបោសសម្អាត"*__

១៩២. "ការបោសសម្អាត" ផ្ទៃក្នុងបានកើនឡើងជាលំដាប់ស្របតាមការវិវឌ្ឍន៍របស់គោលនយោបាយនេះ។ "បោសសម្អាត" មានន័យថាធ្វើឲ្យបរិសុទ្ធផ្នែកគោលនយោបាយ តាមរយៈការដាក់ទណ្ឌកម្មដែលមានចាប់ពីការបញ្ចុះឋានន្តរសក្តិបុគ្គលណាម្នាក់រហូតដល់យកទៅលត់ដំ ឬរហូតដល់កម្រិតធ្ងន់បំផុត គឺ "កម្ទេចចោល"[៦៣៧]។ ទាំងសមាជិកបក្ស និងបុគ្គលដែលមិនមែនជាសមាជិកបក្សក៏មាន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

ជាប់ទាក់ទងផងដែរ។ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សមួយចំនួនដែលស្ថិតនៅក្រោមការស៊ើបសួរ បង្ហាញអំពីស្ថានភាពអង្គហេតុដែលត្រូវបានកំណត់ថា ជាការបោសសម្អាត។ ជាពិសេស សហចៅក្រមស៊ើបអង្កេត ត្រូវបានប្តឹងអំពីព្រឹត្តិការណ៍បោសសម្អាតជាក់លាក់ចំនួនពីរ ដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ៖ ការបោសសម្អាតនៅភូមិភាគឧត្តរចាស់ និងនៅភូមិភាគឧត្តរថ្មី ព្រមទាំងការបោសសម្អាតនៅភូមិភាគបូព៌ា។

## <u>ការបោសសម្អាតនៅភូមិភាគឧត្តរចាស់ និង ភូមិភាគឧត្តរថ្មី</u>

**១៩៣.** ក្រោយពីមានសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនាឆ្នាំ១៩៧៦ឲ្យមានការកម្ទេចនៅក្នុងជួរបដិវត្តន៍[៦៣៨] ការបោសសម្អាតដែលពាក់ព័ន្ធនឹងការកាប់សម្លាប់យ៉ាងច្រើន ត្រូវបានធ្វើឡើងនៅក្នុងភូមិភាគឧត្តរ និងនៅក្នុងតំបន់១០៦ ចាប់តាំងពីចុងឆ្នាំ១៩៧៦។ ការបោសសម្អាតទាំងនេះបានកើនឡើងយ៉ាងគំហុកនៅដើមឆ្នាំ១៩៧៧ និងបន្តរហូតដល់ចុងឆ្នាំ១៩៧៧នេះ។

**១៩៤.** មុនខែមេសា ឆ្នាំ១៩៧៥ ភូមិភាគឧត្តរ (ឬ ភូមិភាគ៣០៤ ដោយយោងតាមលេខកូដរបស់ខ្លួន)[៦៣៩] ត្រូវបានបង្កើតឡើង ហើយត្រូវបានប្រែក្លាយបន្ទាប់មកទៀតទៅជាតំបន់៤១ តំបន់៤២ តំបន់៤៣ និងតំបន់១០៦[៦៤០]។ ភូមិភាគឧត្តរត្រូវបានដឹកនាំដោយលេខា កុយ ធួន និងអនុលេខា កែ ពក[៦៤១] (អ្នកទាំងពីរជាសមាជិកគណៈមជ្ឈិម)[៦៤២]។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ភូមិភាគឧត្តរ (ដោយត្រូវបានដាក់ថាជាភូមិភាគ ៣០៣ វិញ) ដោយរួមមានតំបន់ ៤១ ៤២ និង៤៣ តែប៉ុណ្ណោះ ដោយសារតំបន់ ១០៦ បានក្លាយជាតំបន់ស្វយ័ត[៦៤៣]។ នៅពេលនោះ កុយ ធួន ត្រូវបានគេផ្ទេរទៅគណៈមជ្ឈិម ហើយក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[៦៤៤] ខណៈដែល កែ ពក បានជំនួស កុយ ធួន ជាលេខាភូមិភាគឧត្តរ[៦៤៥]។ ស្ថានភាពនេះនៅដូច្នេះរហូតដល់ពេលការបោសសម្អាតក្នុងឆ្នាំ១៩៧៧ មានការកើនឡើងយ៉ាងខ្លាំង។ នៅក្នុងបរិបទនៃការបោសសម្អាតទាំងនេះ កែ ពក បានក្លាយជាលេខាភូមិភាគឧត្តរ ដែលត្រូវបានពង្រីកដោយរួមបញ្ចូលជាថ្មីនូវតំបន់១០៦[៦៤៦]។ ចាន់ សំ ហៅ កង ចាប ហៅ សែ បានក្លាយជាអនុលេខាភូមិភាគនេះ និងជាលេខាតំបន់១០៦ នៅពេលជាមួយគ្នានោះដែរ[៦៤៧] ដោយត្រូវបានគេផ្ទេរមកពីមុខតំណែងមុនៗរបស់គាត់នៅក្នុងភូមិភាគនិរតី[៦៤៨]។ ក្រោយមកនៅក្នុងឆ្នាំនោះដដែល ភូមិភាគឧត្តរថ្មីមួយ (ដោយមានលេខកូដ ៨០១)[៦៤៩] ត្រូវបានបង្កើតឡើងដោយរួមបញ្ចូលតំបន់១០៦ និងតំបន់១០៣[៦៥០] ដោយមាន សែ ជាលេខា[៦៥១]។ តំបន់៤១ តំបន់៤២ និងតំបន់៤៣ ត្រូវបានផ្លាស់ប្តូរឈ្មោះជាភូមិភាគកណ្តាល ដោយមាន កែ ពក ជាលេខា[៦៥២]។

១៩៥. ក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយពីមានសេចក្ដីសម្រេចនៃគណៈមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ លេខាភូមិភាគឧត្តរ កែ ពក បានជូនដំណឹងដល់ ប៉ុល ពត និង នួន ជា អំពីឆន្ទៈរបស់ខ្លួនចង់ចាត់វិធានការនឹងពួកក្បត់នៅក្នុងជួរបដិវត្តន៍[៦៥៣]។ ក្រោយមកតែបន្តិច អតីតលេខាភូមិភាគឧត្តរ និង អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[៦៥៤] កុយ ធួន ត្រូវបានគេដាក់ឃុំឲ្យនៅក្នុងផ្ទះ[៦៥៥] ដោយកំហុសជាច្រើនដែលគេចោទប្រកាន់ (ដែលនាំឲ្យគេចោទគាត់ថាជាគិញរបស់ខ្មាំង)[៦៥៦] ដូច្នេះហើយទំនងជាត្រូវបានគេចាត់ទុកដូចជាសមាសភាពមួយដែលត្រូវការអប់រំផ្នែកគោលនយោបាយ ទៅតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ[៦៥៧]។ កុយ ធួន ក៏ត្រូវបានគេបណ្ដេញចេញពីបក្ស ដោយយោងតាមលក្ខន្តិកៈរបស់បក្សដែរ[៦៥៨]។

១៩៦. នៅក្នុងភូមិភាគឧត្តរ ការអនុវត្តសេចក្ដីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បាននាំឲ្យមានការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ជាលើកដំបូង នៅចុងឆ្នាំ១៩៧៦ នៅពេល ឈឹម មាស ហៅ ហោះ (លេខាកងវរៈសេនាធំនៃកងពល ១១៧ របស់ភូមិភាគឧត្តរ) ត្រូវបានគេបញ្ជូនទៅ ស-២១[៦៥៩] ហើយចម្លើយសារភាពរបស់គាត់បានឆ្លើយដាក់ កុយ ធួន[៦៦០]។ នៅក្នុងពេលជាមួយគ្នានោះដែរ ស-២១ បានចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់មួយរូបមកពីក្រសួងពាណិជ្ជកម្មជាលើកដំបូង។ កម្មាភិបាលនេះជិតស្និទ្ធនឹង កុយ ធួន ណាស់ គឺកម្មាភិបាល ទិត សុន ហៅ ញ៉ែម[៦៦១] ដែលជាសមាជិកទីពីរនៅក្នុងជួរគណៈពាណិជ្ជកម្មនៃមជ្ឈិម[៦៦២] ហើយដែលបានចាប់ផ្ដើមឆ្លើយសារភាពក្រោមការធ្វើទារុណកម្មនៅអំឡុងខែវិច្ឆិកា ឆ្នាំ១៩៧៦[៦៦៣]។

១៩៧. ក្រោយពីមានការឆ្លើយដាក់ជាលើកដំបូងពីកម្មាភិបាលរូបនេះ កុយ ធួន ត្រូវបានគេចាត់ទុកថាជាជនក្បត់ ហើយត្រូវបានចាប់ខ្លួនដោយសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍[664] និងត្រូវបានបញ្ជូនទៅ ស-២១ ដែលការសួរចម្លើយរបស់គាត់មួយផ្នែកត្រូវបានធ្វើឡើងដោយ ឌុច ផ្ទាល់[៦៦៥]។ កុយ ធួន បានឆ្លើយសារភាពថាជាសមាជិករបស់ខ្សែក្បត់ដ៏ធំមួយ ដែលរួមមានកម្មាភិបាលរដ្ឋបាល និង យោធានៅក្នុងភូមិភាគឧត្តរជាច្រើន[៦៦៦]។ ការឆ្លើយសារភាពនេះបានបណ្ដាលឲ្យមានការបោសសម្អាតរីករាលដាលគួរឲ្យកត់សម្គាល់ដោយមានមនុស្សជាច្រើនត្រូវបានគេចាប់ខ្លួន និង ដឹកទាំងឡានៗបញ្ជូនទៅ ស-២១[៦៦៧]។ យោងតាម ឌុច ចម្លើយសារភាពដំបូងរបស់ កុយ ធួន បណ្ដាលឲ្យមានការបោសសម្អាតជាទ្រង់ទ្រាយធំ តាមរយៈការចាប់ខ្លួនកម្មាភិបាលភូមិភាគឧត្តរជាច្រើននាក់[668]។ កែ ពក បានត្រួតពិនិត្យមើលដោយផ្ទាល់លើការបោសសម្អាតតំបន់១០៦

ហើយបានរាយការណ៍លើស្ថានភាពនេះទៅគណៈ ៨៧០[៦៦៩]។ ជនក្បត់ជាច្រើនមកពីតំបន់១០៦ ដែលត្រូវបានគេចោទប្រកាន់ បានទៅដល់ ស-២១ ចាប់តាំងពីដើមឆ្នាំ១៩៧៧ មកម្លេះ[៦៧០]។ ជនរងគ្រោះនៃការបោសសម្អាតដែលមានឋានៈតូចតាច ត្រូវបានគេសម្លាប់ចោលនៅក្នុងមូលដ្ឋាន ហើយដាក់ជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី[671] និងដោយសាច់ញាតិរបស់ កែ ពក ដើម្បីជួយបង្កើនកម្លាំងក្នុងការបោសសម្អាត[៦៧២]។

១៩៨. ការបោសសម្អាតភូមិភាគឧត្តរបានបន្តរហូតដល់ឆ្នាំ១៩៧៨។ ក្រៅពីតំបន់១០៦ ការបោសសម្អាតបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កងពល១៧៤ របស់ភូមិភាគ[៦៧៣] តំបន់១០៣[៦៧៤] កងពល៩២០ របស់មជ្ឈិម និងតំបន់១០៥[៦៧៥] រួមទាំងកងពល៣១០ និង ៤៥០ របស់មជ្ឈិម[៦៧៦] មន្ទីរ ៨៧០ របស់មជ្ឈិម[៦៧៧] ព្រមទាំងអតីតកម្មាភិបាលភូមិភាគឧត្តរដែលកំពុងបម្រើការងារនៅក្នុងក្រសួងពាណិជ្ជកម្ម[៦៧៨]។ ព័ត៌មានបន្ថែមស្ដីពីការបោសសម្អាតភូមិភាគឧត្តរថ្មី មានរៀបរាប់នៅក្នុងផ្នែកស្ដីអំពីមន្ទីរសន្តិសុខនៅភូមិភាគឧត្តរនៃដីកាដំណោះស្រាយនេះ។

## ការបោសសម្អាតនៅភូមិភាគបូព៌ា

១៩៩. ការបោសសម្អាតនៅភូមិភាគបូព៌ាត្រូវបានចាប់ផ្ដើមនៅពាក់កណ្ដាលឆ្នាំ១៩៧៦ ដោយមានការចាប់ខ្លួន សួស នៅ ហៅ ឈូក អតីតលេខាតំបន់២៤ និង ចាន់ ចក្រី ហៅ នៅ មាន អតីតកម្មាភិបាលកងពល១៧០ នៃភូមិភាគបូព៌ា[៦៧៩]។ អ្នកទាំងពីរត្រូវបានចាប់ខ្លួន តាមសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍[៦៨០]។ ឈូក និង ចក្រី ត្រូវបានគេសួរចម្លើយ ធ្វើទារុណកម្ម និងទាញយកចម្លើយសារភាព ដែលក្នុងនោះបានឆ្លើយដាក់កម្មាភិបាលនៅតំបន់២៤ មួយចំនួនទៀត[៦៨១]។ ចម្លើយសារភាពទាំងនេះត្រូវបានគេវិភាគ ហើយនៅត្រឹមពាក់កណ្ដាលខែកញ្ញា ឆ្នាំ១៩៧៦ សុន សេន និងបុគ្គលិក ស-២១ បានបង្កើនការដេញតាមចាប់អ្នកដែលត្រូវបានគេចោទថាជាជនក្បត់ដែលជាកម្មាភិបាល និងអតីតកម្មាភិបាលភូមិភាគបូព៌ា ដែលត្រូវបានគេឆ្លើយដាក់ថាជាភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងវៀតណាម[៦៨២] ហើយនាំឱ្យមានការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ាជាហូរហែ ដែលភាគច្រើនត្រូវបានគេបញ្ជូនទៅ ស-២១ រហូតដល់ឆ្នាំ១៩៧៧[៦៨៣]។ ឧទាហរណ៍ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ស៊ាត ឆែ ហៅ ទុំ អតីតលេខាតំបន់២២ ត្រូវបានគេចាប់ខ្លួន។ ចម្លើយសារភាពដែលទាញចេញពី ទុំ នៅ ស-២១ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៧ បាននាំឱ្យមានការបោសសម្អាតធំមួយនៅតំបន់២២[៦៨៤]។

២០០. ចាប់ពីពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ ការចាប់ខ្លួន និងការបញ្ជូនខ្លួននៅក្នុងភូមិភាគបូព៌ាបានរៀបចំឡើងយ៉ាងហ្មត់ចត់ដោយ សុន សេន និង កែ ពក[៦៨៥] តាមរយៈការប្រើប្រាស់កងកម្លាំងអចិន្ត្រៃយ៍របស់គណៈមជ្ឈិម អង្គភាពមកពីភូមិភាគកណ្តាល និងកងទ័ពរបស់អតីតភូមិភាគនិរតីដែលស្ថិតនៅក្រោមបញ្ជារបស់គណៈមជ្ឈិម[៦៨៦]។ នៅក្នុងខែមីនា ឆ្នាំ១៩៧៨ ការបោសសម្អាតដែលកើនឡើងយ៉ាងធំមួយលើកម្មាភិបាល និងយុទ្ធជននៅភូមិភាគបូព៌ា បានកើតឡើងនៅស្វាយរៀង (តំបន់២៣)[៦៨៧] ដោយក្រោយមកមានការចាប់ខ្លួន និងសម្លាប់ចោលកាន់តែច្រើនឡើងៗចាប់ពីខែឧសភា ដល់ ខែមិថុនា ឆ្នាំ១៩៧៨ នៅតាមបណ្តាទីកន្លែងដទៃៗទៀតនៅក្នុងភូមិភាគបូព៌ា[៦៨៨] ដែលក្នុងអំឡុងពេលនោះ លេខាភូមិភាគបូព៌ា សោ ភឹម បានធ្វើអត្តឃាដដោយមិនចង់ឲ្យគេចាប់ខ្លួន[៦៨៩]។

២០១. ដូចបានគូសបញ្ជាក់ខាងលើការបោសសម្អាតភូមិភាគបូព៌ាមិនមែនកំណត់តាមភូមិសាស្ត្រត្រឹមកម្មាភិបាលរបស់ភូមិភាគបូព៌ាប៉ុណ្ណោះទេ ពោលគឺ កម្មាភិបាលដែលមានប្រភពមកពីភូមិភាគបូព៌ាដែលត្រូវបានគេឲ្យទៅធ្វើការនៅទីកន្លែងដទៃៗទៀត ដោយរួមទាំងនៅក្នុងបណ្តាក្រសួងនានាដូចជា ក្រសួងសង្គមកិច្ចជាដើម[៦៩០]ក៏ត្រូវបានគេកំណត់មុខសញ្ញារហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ[691]។ កម្មាភិបាលរាប់រយនាក់ត្រូវបានបញ្ជូនពីភូមិភាគបូព៌ាទៅមន្ទីរ ស-២១[692] ខណៈពេលដែលអ្នកផ្សេងទៀតត្រូវបានសម្លាប់នៅនឹងកន្លែង[693] ឬត្រូវបានផ្លាស់កន្លែងទៅកាន់តំបន់ផ្សេងទៀតនៃប្រទេស[694]។ កម្មាភិបាលមួយចំនួន ដែលរួមមានអតីតកម្មាភិបាល និងយុទ្ធជនរបស់ភូមិភាគបូព៌ាត្រូវបានដាក់ឲ្យធ្វើការនៅតាមការដ្ឋានដើម្បី "ការលត់ដំ" ដូចជានៅទីកន្លែងសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[695]។

២០២. ចំពោះការបោសសម្អាតនៅភូមិភាគឧត្តរ និងភូមិភាគដែលពាក់ព័ន្ធ មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក បានប្រើប្រាស់ឯកសារចេញផ្សាយរបស់បក្សគឺ *ទង់បដិវត្ត* ដើម្បីផ្តល់យុត្តិកម្មដល់ការបោសសម្អាតរបស់ខ្លួនដែលកំពុងកើតមាន ដើម្បីឲ្យកម្មាភិបាលទាំងឡាយជឿថា ខ្មាំងផ្ទៃក្នុងបានជ្រៀតចូលបក្ស និងដើម្បីជម្រុញកម្មាភិបាលទាំងនេះឲ្យវែកមុខ និងកម្ទេចខ្មាំងបែបនេះចោល[៦៩៦]។

២០៣. អង្គហេតុបន្ថែមទាក់ទិននឹងការបោសសម្អាតភូមិភាគបូព៌ាមានរៀបរាប់ផងដែរ នៅក្នុងផ្នែកនៃដីកាដំណោះស្រាយស្តីអំពី មន្ទីរ ស-២១ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង កន្លែងសម្លាប់មនុស្សស្ទឹងតូច និងការផ្លាស់ទីលំនៅរបស់ប្រជាជនពីភូមិភាគបូព៌ា (ដំណាក់កាលទី៣)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

***

២០៤. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៦នាក់ (មួយរយដប់ប្រាំមួយនាក់) ត្រូវបានប្រកាសទទួលស្គាល់នៅក្នុង បរិបទនៃការ*បោសសម្អាតខ្មាំង*[697] ។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរអោយជឿជាក់ បានស្របទៅនិងវិធាន ២៣ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃ ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃការ*បោសសម្អាតខ្មាំង* ។

## ឃ. វិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា

២០៥. គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចបាននិង ការពារបដិវត្តន៍សង្គមនិយម គឺដាក់ចេញរាល់វិធានការជាពិសេសប្រឆាំងនឹងក្រុមជាក់លាក់នានា។ សកម្មភាពនេះបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ក្រុមមនុស្សជាច្រើន នៅក្នុងប្រទេសកម្ពុជានាសម័យនោះ។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអំពើទាក់ទងនឹងក្រុមជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ (ដូចជាមន្ត្រី យោធា និងក្រុមគ្រួសាររបស់ពួកគេ)។ អំពើទាំងនេះត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជានៅទីកន្លែងផ្សេងគ្នានៃប្រទេសកម្ពុជាចាប់ពីមុនឆ្នាំ១៩៧៥ ដែលជាដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើទឹកដីមួយផ្នែក និងបន្តយ៉ាងហោចណាស់រហូតដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

២០៦. សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអំពើនានា ដែលបានប្រព្រឹត្តិប្រឆាំងនឹងជនជាតិចាមនៅក្នុងភូមិភាគកណ្តាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងក្នុងអំឡុងពេលនៃការចូលលុកលុយនៅប្រទេសវៀតណាម ការប្រឆាំងចំពោះពុទ្ធសាសនិកនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ និងការប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ព្រឹត្តិការណ៍ចុងក្រោយនេះបង្កើតបានជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍យ៉ាងច្រើននៃអំពើប្រឆាំងទៅនឹងអតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ[698]។

២០៧. គោលដៅមួយក្នុងចំណោមគោលដៅផ្សេងទៀតនៃគោលនយោបាយនេះ គឺការបង្កើតឡើងនូវសង្គម

មួយដែលមិនមានសាសនា រួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់ចោលភាពខុសគ្នារវាងជនជាតិ ជាតិ សាសនា សង្គម និងវប្បធម៌។ គោលដៅនេះត្រូវបានបញ្ជាក់ដោយឯកសាររបស់បក្សទាក់ទិននឹងវណ្ណៈ។ ក្នុងឆ្នាំ១៩៧៤ អត្ថបទមួយនិពន្ធដោយ ប៉ុល ពត ដែលបានផ្សព្វផ្សាយនៅក្នុងទស្សនាវដ្ដីទង់បដិវត្តបានបង្ហាញថា មាន *"វណ្ណៈពិសេស"* មួយនៅក្នុងសង្គមកម្ពុជាដែលរួមមាន *"ទាហាន ប៉ូលីស និងលោកសង្ឃ"*[៦៩៩]។ តាមរយៈសៀវភៅកំណត់ហេតុរបស់កម្មាភិបាល និង ដោយបានយោងទៅតាមអត្ថបទខាងលើនេះ បញ្ជាក់ថាជនជាតិភាគតិចទាំងអស់ ក៏ត្រូវបានចាត់ទុកថាជាផ្នែកនៃ *"ប្រភេទវណ្ណៈដោយឡែកពិសេស" នេះផងដែរ*[៧០០]។ វណ្ណៈផ្សេងៗទៀតដូចជា ពួកសក្ដិភូមិ ពួកនាយទុន និងពួកអភិជន ក៏ត្រូវបានគេហាមឃាត់ផងដែរ[៧០១]។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ការអនុវត្តគោលដៅនេះមានការវិវឌ្ឍន៍ទៅមុខ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រកាសពីការលុបបំបាត់វណ្ណៈទាំងនេះ និង វណ្ណៈដោយឡែកពិសេស ដោយបានបញ្ជាក់ថា គឺមានតែវណ្ណៈកម្មករ និងកសិករប៉ុណ្ណោះដែលមានអត្ថិភាព ហើយថាវណ្ណៈទាំងអស់ដទៃទៀត ត្រូវបានរំលាយបញ្ចូលក្នុងវណ្ណៈទាំងពីរនេះ[៧០២]។ នៅពេលនោះ ឬភ្លាមៗបន្ទាប់ពីនោះមក វិទ្យុផ្សាយចេញពីទីក្រុងភ្នំពេញបានធ្វើការបញ្ជាក់ចុងក្រោយអំពីព្រះសង្ឃ[៧០៣] ជនជាតិចាម[៧០៤] និងជនជាតិភាគតិចដទៃទៀត[៧០៥]។ ទោះបីជារដ្ឋអំណាចបក្សជាន់ខ្ពស់បន្តនិយាយរហូតដល់ឆ្នាំ១៩៧៦ អំពីចំនួនប្រជាជនកម្ពុជា ដែលរួមបញ្ចូលនូវអ្នកដែលមិនមែនជាសញ្ជាតិខ្មែរយ៉ាងណាក៏ដោយ[៧០៦] បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសជាផ្លូវការនៅខែសីហា ឆ្នាំ១៩៧៧ ថាការលុបបំបាត់ និងការដាក់បញ្ចូលគ្នានៃជនជាតិភាគតិចគឺដូចដែលយើងអាចនិយាយថាជាប្រទេសមួយដែលមាន "៩៩ភាគរយ"ខ្មែរ[៧០៧]។ គោលដៅមួយទៀតនៃគោលនយោបាយនេះ គឺដើម្បីលុបបំបាត់ខ្លាំង និងដើម្បីបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមទាំងនោះតែម្ដង។ វិធានការដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា គឺត្រូវបានយកចិត្តទុកដាក់ជាពិសេសក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា "យើងខំធ្វើយ៉ាងម៉េចឲ្យតែចំណេញដល់បដិវត្តន៍"[៧០៨]។

*កាលបរិច្ឆេទ និងការចូលរួម*

**២០៨.** វិធានការដែលបានធ្វើឡើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺកើតចេញមកពីគោលនយោបាយដែលមានមុនឆ្នាំ១៩៧៥មកម្លេះ ហើយបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នាខែកុម្ភៈ ឆ្នាំ១៩៧៥ ការប្រកាសជាសាធារណៈអំពីចេតនាក្នុងការសម្លាប់

00605322



ឥស្សរៈជនជាន់ខ្ពស់នៃរបបសាធារណៈរដ្ឋខ្មែរបន្ទាប់ពីបានទទួលជ័យជំនះ ត្រូវបានបន្តធ្វើបន្ទាប់ពីមានសេចក្តីសម្រេចសម្ងាត់មួយឱ្យសម្លាប់មន្ត្រីជាន់ខ្ពស់របស់របបសាធារណៈរដ្ឋខ្មែរ[៧០៩] ដោយផ្អែកលើមូលដ្ឋានថា "*គឺសម្រេច ធ្វើម៉េច កុំឱ្យពួកហ្នឹងវាងើបឡើងប្រឆាំងបដិវត្តបាន*"[៧១០]។

**២០៩.** ក្នុងពេលមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជាពិសេសមន្ត្រីជាន់ខ្ពស់[៧១១] ត្រូវបានគេកំណត់មុខសញ្ញាដើម្បីចាប់ខ្លួន និងសម្លាប់ចោល[៧១២]។ ភស្តុតាងក៏បានបង្ហាញថា ក្រុមនេះត្រូវបានគេកំណត់មុខសញ្ញាផងដែរនៅពេលផ្លាស់ទីលំនៅរបស់ប្រជាជនពីទីប្រជុំជន ផ្សេងៗ (និងជាបន្តបន្ទាប់នៅទូទាំងប្រទេស) ជាពិសេសនៅក្នុងភូមិភាគពាយ័ព្យ[៧១៣] និងភូមិភាគនិរតី[៧១៤] ដូចដែលបានលើកឡើងនៅក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្មក្នុងដីកាដំណោះស្រាយនេះ។

**២១០.** ចំពោះវិធានការប្រឆាំងនឹងពុទ្ធសាសនិកជនវិញ គឺកើតចេញមកពីគោលនយោបាយដែលបានចាប់ផ្តើមនាមុន ឬនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបន្តយ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ឌុច បានឱ្យដឹងថា បុគ្គលសំខាន់ៗនៅក្នុងឋានានុក្រមរបស់ពុទ្ធសាសនិកត្រូវបានសម្លាប់នៅពេលជម្លៀសចេញពីភ្នំពេញដែលអ្នកសម្លាប់ទាំងនោះបានប្រាប់គាត់អំពីបញ្ហាទាំងនេះ[715]។ មាត្រា ២០ នៅក្នុងជំពូក ១៥ នៃរដ្ឋធម្មនុញ្ញរបស់ កម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេគិតថាជាដំណោះស្រាយទាក់ទងនឹងបញ្ហាលើជំនឿសាសនា ដែលចែងថា "*ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិ មិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត*"[៧១៦]។ ក៏ប៉ុន្តែវាហាក់ដូចជាមានការលេចឡើងថា សេរីភាពលើជំនឿសាសនាដូចដែលបានអះអាងនៅក្នុងមាត្រានេះគឺជាការបោកបញ្ឆោត នៅពេលដែលរាល់សាសនាទាំងអស់ត្រូវបានគេចាត់ទុកថាជាប្រតិកិរិយា[៧១៧]។ រាល់ សាសនាទាំងអស់ ត្រូវបានហាមឃាត់ដោយបក្ស[៧១៨] ដោយក្នុងនោះរួមមានពុទ្ធសាសនាផងដែរ[៧១៩]។ វត្តអារាមត្រូវបានកម្ទេច[៧២០] ដែលតាមជាក់ស្តែងរាល់ព្រះសង្ឃ និងដូនជីត្រូវបានចាប់ផ្សឹក[៧២១] ព្រះសង្ឃខ្លះត្រូវគេគំរាមសម្លាប់ ឬត្រូវគេសម្លាប់តែម្តង ប្រសិនបើមិនគោរពតាម[៧២២]។ ប្រជាជនត្រូវបានប្រាប់ឱ្យដើរតាមនិងធ្វើវាសនាលើអង្គការ ដោយមិនត្រូវជឿលើសាសនាទេ[៧២៣]។ ការលុបបំបាត់ពុទ្ធសាសនា និងបំបាត់ព្រះសង្ឃ ត្រូវបានបញ្ជាក់ហេតុផលនៅថ្នាក់មូលដ្ឋានដោយការសន្មតថាព្រះសង្ឃទាំងនេះជាសមាជិករបស់ "*វណ្ណៈពិសេស*" ដែលកម្មាភិបាលនៅតាមមូលដ្ឋានបាននិយាយ

ថា ជាវណ្ណៈកេងប្រវ័ញ្ច និងជិះជាន់គេ[៧២៤]។ នយោបាយនេះត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**២១១.** ទាក់ទិននឹងវិធានការប្រឆាំងនឹងជនជាតិចាមគឺ កើតចេញមកពីគោលនយោបាយដែលចាប់ផ្តើមនៅដើមឆ្នាំ១៩៧០ នៅតាមតំបន់មួយចំនួន[៧២៥] និងដែលមានសន្ទុះកើនឡើងនៅពេញមួយរបបរបស់កម្ពុជា ប្រជាធិបតេយ្យ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ការជម្លៀសភូមិទាំងឡាយរបស់ជនជាតិចាមបានចាប់ផ្តើមប្រហែលជាក្នុងឆ្នាំ១៩៧៣[៧២៦] និងកាន់តែខ្លាំងឡើងបន្ទាប់ពីឆ្នាំ១៩៧៥[៧២៧] ដោយសមាជិកនៃក្រុមនោះមួយចំនួនត្រូវបានគេបំបែកឱ្យទៅរស់នៅតាមភូមិខ្មែរ[៧២៨]។ សារទូរលេខលេខ១៥ ចុះខែវិច្ឆិកា ឆ្នាំ១៩៧៥ រៀបរាប់អំពីគោលនយោបាយក្នុង "ការបំបែក"[៧២៩] ជនជាតិចាម ដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់តាមរយៈមធ្យោបាយនៃការជម្លៀសដោយបង្ខំ[៧៣០]។ នៅក្នុងរបបនោះ បក្សកុម្មុយនីស្តកម្ពុជាបានហាមឃាត់ជនជាតិចាមមិនឱ្យគោរពសាសនារបស់ពួកគេ[៧៣១]។ មេដឹកនាំសាសនា និង ចាស់ព្រឹទ្ធាចារ្យរបស់ជនជាតិចាមត្រូវបានគេឃុំឃាំង ឬ សម្លាប់[៧៣២] ដូចគ្នាដែរចំពោះសមាជិកនៃក្រុមនេះដែលបានតវ៉ា ឬ បន្តគោរពសាសនារបស់ពួកគេ[៧៣៣]។ បក្សកុម្មុយនីស្តកម្ពុជាក៏បានហាមឃាត់ផងដែរនូវវប្បធម៌ ភាសា និងសម្លៀកបំពាក់ប្រពៃណីរបស់ជនជាតិចាម[៧៣៤]។

**២១២.** ចាប់ពីឆ្នាំ១៩៧៧ និងជាទូទៅ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨ បក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តហួសពីការធ្វើទុក្ខបុកម្នេញសាសនា ដោយអនុវត្តគោលនយោបាយនេះ តាមរយៈការអនុម័តនូវគោលនយោបាយសំដៅកម្ទេចជនជាតិចាមក្នុងនាមជាក្រុមនោះ នៅផ្នែកមួយចំនួននៃប្រទេសកម្ពុជាដែលជនជាតិចាមរស់នៅ។ ការសម្លាប់ជនជាតិចាមជាលក្ខណៈទ្រង់ទ្រាយធំ ត្រូវបានប្រព្រឹត្តនាឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨[៧៣៥] នៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងភូមិភាគបូព៌ា។ សាក្សីនានាបានផ្តល់ភស្តុតាងថា ជនជាតិចាមត្រូវបានគេចាត់ទុកថាជាខ្មាំងរបស់បដិវត្តន៍[៧៣៦] ហើយបក្សកុម្មុយនីស្តកម្ពុជាមានចេតនាកម្ទេចក្រុមនេះចោល[៧៣៧] ត្រឹមឆ្នាំ១៩៨០[៧៣៨]។ ភស្តុតាងបានបង្ហាញថា កែ ពក ជាលេខាភូមិភាគកណ្តាល[៧៣៩] ជាសមាជិកគណៈមជ្ឈិម និងជាគណៈយោធាមជ្ឈិម[៧៤០] ព្រមទាំងលេខាស្រុកនៃភូមិភាគបូព៌ានិងកណ្តាល បានចូលរួមដោយផ្ទាល់ក្នុងការកម្ទេចជនជាតិចាម រួមជាមួយអង្គភាពយោធារបស់មជ្ឈិម និងអង្គភាពយោធាផ្សេងទៀត[៧៤១]។

**២១៣.** ពាក់ព័ន្ធនឹងវិធានការប្រឆាំងនឹងជនជាតិវៀតណាម គឺកើតចេញមកពីគោលនយោបាយ ដែលមាន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

អត្ថិភាពមុនឆ្នាំ ១៩៧៥ ហើយបន្តកើនឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ចាប់ពីអំឡុងឆ្នាំ១៩៧៣[៧៤២] បក្សកុម្មុយនីស្តកម្ពុជាបាន ចាប់ផ្តើមបណ្តេញប្រជាជនវៀតណាមពីទឹកដីកម្ពុជា ហើយបញ្ជូនពួកគេត្រឡប់ទៅវៀតណាមវិញ ដែលគោលគោលនយោបាយមួយនេះធ្លាប់ត្រូវបានអនុវត្តរួចមកហើយ ដោយរដ្ឋាភិបាល លន់ នល់ នាឆ្នាំ១៩៧០។ ការបណ្តេញនេះត្រូវបានបន្តអនុវត្តនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦[៧៤៣]។ ការចេញផ្សាយនៃទស្សនាវដ្តីទង់បដិវត្តនាខែមេសា ឆ្នាំ១៩៧៦ បានលើកឡើងអំពីការបណ្តេញជនជាតិវៀតណាមចេញពីទឹកដីកម្ពុជា ដោយបានបញ្ជាក់ថា *"មហាព្យុះសង្ក្រានៃបដិវត្តប្រជាធិបតេយ្យរបស់យើង បានបោសសម្អាតជនបរទេសទាំងនេះរាប់សែននាក់ ឲ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ"*[៧៤៤]។

**២១៤.** ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា គឺជម្រុញគោលនយោបាយនេះឲ្យបានកាន់តែឆ្ងាយ តាមរយៈការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃក្រុមជនជាតិវៀតណាម ដោយសារពួកគេជាក្រុមនេះ។ ចេតនានេះត្រូវបានបង្ហាញតាមរយៈការចេញផ្សាយនៃទស្សនាវដ្តីទង់បដិវត្តចេញលេខខែមេសា ឆ្នាំ១៩៧៧ ដែលបានអំពាវនាវដោយផ្ទាល់ឲ្យសម្លាប់សមាជិកទាំងអស់នៅក្នុងសហគមន៍វៀតណាម ដែលបន្តរស់នៅក្នុងប្រទេសកម្ពុជា។ ទស្សនាវដ្តីនេះតម្រូវឲ្យ *"វាយខ្មាំង"* ដែលជាជនជាតិវៀតណាម និង *"កម្ទេចខ្មាំង"*[៧៤៥] ដោយបានលើកឡើងថា *"ឫសចាស់របស់វាដែលនៅសេសសល់ខ្លះ ក្រោយពីយើងកម្ចាត់ឲ្យវាខ្ទេចខ្ទីរនេះ គឺត្រូវបំផុសមហាជនឲ្យគេបោសសម្អាតវាថែមទៀត ឲ្យស្អាតជាស្ថាពរ"*[៧៤៦]។ ភស្តុតាងនៃការអនុវត្តគោលនយោបាយនេះត្រូវបានបង្ហាញនៅក្នុងលិខិតឆ្លើយឆ្លងរវាងភូមិភាគ និង មជ្ឈិម[៧៤៧]។ អតីតកម្មាភិបាលមួយរូបក៏បានបញ្ជាក់អំពីគោលនយោបាយនេះផងដែរ ដោយលើកឡើងថា នៅទីកន្លែងណាដែលមានជនជាតិវៀតណាម *"គ្រប់រូបត្រូវប្រុងប្រយ័ត្នដើម្បីរកឲ្យឃើញ និងកំចាត់ចោលសត្រូវផ្ទៃក្នុងទាំងនេះ"*[៧៤៨]។ តាមការពិត ចាប់ពីឆ្នាំ១៩៧៧មក[៧៤៩] ការកាប់សម្លាប់ជាទ្រង់ទ្រាយធំលើជនស៊ីវិលវៀតណាមត្រូវបានប្រព្រឹត្តនៅទូទាំងខេត្តព្រៃវែង[៧៥០] និងខេត្តស្វាយរៀង[៧៥១] នៅក្នុងភូមិភាគបូព៌ា។ ភស្តុតាងក៏បានបង្ហាញផងដែរថា ជនស៊ីវិលវៀតណាមត្រូវបានគេកំណត់មុខសញ្ញា និងត្រូវបានសម្លាប់នៅទូទាំងប្រទេសកម្ពុជា ដូចបានរៀបរាប់ក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម នៃដីកាដំណោះស្រាយនេះ ជាពិសេសនៅក្នុងភូមិភាគពាយ័ព្យ[៧៥២] និងភូមិភាគឧត្តរ[៧៥៣]។

**២១៥.** បក្សកុម្មុយនីស្តកម្ពុជាបានសំអាងលើគោលនយោបាយរបស់ខ្លួនក្នុងការកម្ទេចក្រុមជនជាតិវៀត

ណាម តាមរយៈទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ដែលឲ្យដឹងថាបុរសវៀតណាមរៀបការជាមួយស្ត្រីខ្មែរ គឺសម្លាប់តែបុរសនោះប៉ុណ្ណោះ ហើយភរិយា និងកូនៗត្រូវបានគេទុកជីវិតឲ្យ ចំណែកឯនារីវៀតណាមរៀបការជាមួយនឹងបុរសខ្មែរ នារី និង កូនៗនឹងត្រូវបានគេសម្លាប់ ដោយទុកជីវិតឲ្យបុរសនោះប៉ុណ្ណោះ។ ការអនុវត្តបែបនេះទំនងត្រូវបានអនុវត្តនៅទូទាំងខេត្តព្រៃវែង[៧៥៤] និងខេត្តស្វាយរៀង[៧៥៥] ក៏ដូចជានៅតាមបណ្តាតំបន់នានានៅក្នុងប្រទេស[៧៥៦]។

## ខ. ការរៀបអាពាហ៍ពិពាហ៍

**២១៦.** គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំដែលត្រូវបានអនុវត្តដើម្បីសម្រេចឲ្យបាន និង ការពារបដិវត្តន៍សង្គមនិយម តាមរយៈមធ្យោបាយចាំបាច់ណាក៏ដោយ គឺដើម្បីដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍។ បក្សបានបង្ខំឲ្យសហព័ទ្ធរៀបការនឹងគ្នាតាំងពីមុនឆ្នាំ១៩៧៥ នៅពេលខ្លួនកាន់កាប់លើតំបន់មួយចំនួននៅក្នុងទឹកដីប្រទេសកម្ពុជា និងបានបន្តធ្វើដូច្នេះរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអង្គហេតុបែបនេះដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា។

**២១៧.** គោលដៅមួយក្នុងចំណោមគោលដៅនានានៃគោលនយោបាយនេះ គឺដើម្បីគ្រប់គ្រងលើទំនាក់ទំនងរវាងបុគ្គល ដោយអនុញ្ញាតឲ្យពួកគេរៀបការ និងមានទំនាក់ទំនងផ្លូវភេទទៅតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។ ទស្សនៈនៃការរៀបការនេះ បានបង្កើតឡើងវិញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីអនុញ្ញាតឲ្យបក្សកុម្មុយនីស្តកម្ពុជាជំនួសតួនាទីជាឪពុកម្តាយ[៧៥៧] ហើយអនុញ្ញាតឲ្យម្តាយទៅធ្វើការ[758]។ បក្សបានកំណត់ទិសដៅបង្កើនកំណើនប្រជាជន[៧៥៩] និង "*កសាងគ្រួសារ*"[៧៦០]។ គោលដៅនេះ អាចសម្រេចទៅបានតាមរយៈការផ្សំផ្គុំប្រជាជន ដែលមានឋានៈនយោបាយដូចគ្នា[៧៦១] និងឲ្យរៀបការជាមួយនឹងកងទ័ព[៧៦២]។ ដូច្នេះ ការរៀបការគឺត្រូវបានយកចិត្តទុកដាក់ជាពិសេសក្នុងកិច្ចប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា "យើងខំធ្វើយ៉ាងម៉េច ឲ្យតែចំណេញដល់បដិវត្តន៍"[៧៦៣]។

*<u>កាលបរិច្ឆេទ និងការចូលរួម</u>*

**២១៨.** ភស្តុតាងបានបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជា បានបង្ខំឲ្យបុគ្គលរៀបការជាមួយគ្នា ចាប់តាំងពីឆ្នាំ១៩៧៤[៧៦៤]។ នៅខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត បានប្រកាសគោលបំណង ក្នុងការបង្កើនចំនួន

ប្រជាជនកម្ពុជាឱ្យបានចំនួន ២០ លាននាក់ ក្នុងរយៈពេល១០ ទៅ ១៥ ឆ្នាំ[៧៦៥]។ គាត់ក៏បានលើកឡើងផងដែរថា ពិធីរៀបការត្រូវតែរៀបចំឡើងជាក្រុមក្នុងពេលតែមួយ[៧៦៦]។ គោលនយោបាយនេះទាក់ទងនឹងការបង្កើនចំនួនប្រជាជន ត្រូវបានបញ្ជាក់សារជាថ្មីនាពេលសន្និសិទ្ធថ្នាក់ជាតិផ្នែកសុខាភិបាល ដែល ប៉ុល ពត ជាអ្នកសម្ភោធ និងមានការចូលរួមពីតំណាងរបស់ក្រសួង មន្ទីរ ភូមិភាគ និងតំបន់ ព្រមទាំងកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា[៧៦៧]។ ការអនុវត្តប្រព័ន្ធរៀបការដែលកម្មាភិបាលបក្សបានរៀបចំឡើងនៅក្នុងចំណោមប្រជាជន និងបក្សខ្លួនឯង ត្រូវបានគេរៀបរាប់នៅក្នុងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា[៧៦៨] និងបានរាយការណ៍តាមរយៈសារទូរលេខដែលត្រូវបានផ្ញើរទៅថ្នាក់លើរបស់បក្ស[៧៦៩]។ របាយការណ៍មួយរបស់ភូមិភាគបស្ចិមបានរាយការណ៍ទៅកាន់មជ្ឈិមអំពីអាត្រាកំណើត និងអត្រានៃការរៀបការដែលត្រូវបានគេចុះក្នុងបញ្ជី[៧៧០]។

**២១៩.** ឯកសារជាផ្លូវការ និងសេចក្តីថ្លែងការណ៍ផ្សេងៗ ដែលបង្ហាញពីលក្ខណៈដែលសន្មតថាការរៀបការទាំងនេះត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត ៖ ប៉ុល ពត បានប្រកាសថា “*យុវជន និងយុវនារី [នឹង] កសាងគ្រួសារតាមការស្ម័គ្រចិត្ត*”[៧៧១] ហើយថាការរៀបការត្រូវបានធ្វើឡើងដោយផ្អែកលើសំណើរបស់បុគ្គលដែលពាក់ព័ន្ធ បន្ទាប់មកទទួលការយល់ព្រមពីគណៈដែលទទួលបន្ទុក[៧៧២]។ ចម្លើយរបស់សាក្សីជាច្រើន បានអះអាងថា ពួកគេត្រូវបានចាប់បង្ខំឱ្យរៀបការ[៧៧៣]។ ដូចគ្នាដែរ សូម្បីតែអតីតកម្មាភិបាលក៏បាន លើកឡើងថា ការរៀបការធ្វើឡើងដោយស្ម័គ្រចិត្ត តែតាមការអនុវត្តជាក់ស្តែងប្រជាជនមិនអាចជំទាស់ តវ៉ាបានឡើយ ដោយសារពួកគេភ័យខ្លាចនូវអំពើហិង្សា ឬ ការស្លាប់[៧៧៤]។

**២២០.** ដើម្បីសម្រេចនូវគោលនយោបាយនេះ អ្នកដែលនៅលីវក្នុងវ័យម្ភៃ ឬសាមសិបឆ្នាំ[៧៧៥] ត្រូវបានកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា[៧៧៦] បង្ខំឱ្យរៀបការ[៧៧៧] ហើយការប្រារព្ធពិធីត្រូវបានធ្វើជាទូទៅ នៅតាមអគារជាផ្លូវការ ឬតាមទីកន្លែងសាធារណៈនានា[៧៧៨]។ ក្រោយពីបង្ខំឱ្យនៅជាមួយគ្នាអស់មួយរយៈពេលខ្លីមក គេក៏តម្រូវឱ្យប្តីប្រពន្ធត្រឡប់ទៅធ្វើការប្រចាំថ្ងៃរបស់ខ្លួនវិញ ហើយឱ្យត្រឡប់មកជួបគ្នាវិញទៅតាមការសម្រេចរបស់របបនេះ[៧៧៩] នៅក្នុងករណីមួយចំនួនដើម្បីឱ្យមករួមដំណេក[៧៨០]។ ប្រជាជនមួយចំនួនដែលមិនព្រមរៀបការទៅតាមមាគ៌ាបក្សត្រូវបានគេចាត់ទុកជា “ខ្មាំង”[៧៨១] ប៉ុន្តែ ប្រជាជនមួយចំនួនទៀតមិនធ្លាប់ជួបប្រទះនូវបញ្ហាទាំងនេះឡើយ[៧៨២]។

# ផ្នែកទី ៨- ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម

## ក - ការផ្លាស់ទីលំនៅរបស់ប្រជាជន

### ការជម្លៀសប្រជាជនពីភ្នំពេញ - ដំណាក់កាលទី១[783]

ស្ថានភាពមុនឆ្នាំ១៩៧៥

២២១. ចន្លោះពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ ប្រជាជននៅទីក្រុងភ្នំពេញបានកើនឡើងយ៉ាងខ្លាំងដល់ចំនួនច្រើនលាននាក់ ដោយសារតែប្រជាជនផ្លាស់ទីលំនៅពីទីជនបទចូលទីក្រុង ដើម្បីគេចពីសង្គ្រាម[784]។

២២២. បុគ្គលិក[785] និងគ្រឿងបរិធាន[786] នៃសេវាកម្មសុខាភិបាលបានថយចុះនូវសមត្ថភាព នៅអំឡុងពេលនោះ ហើយសេវាកម្មនានានៅទីជនបទមានកាន់តែតិចជាងនៅតាមទីក្រុង ដោយសារមូលហេតុសំខាន់ បណ្តាលមកពីសង្គ្រាម ដែលចេះតែបន្តរវាងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា និងកម្លាំងរបបលន់ នល់ [787]។ មន្ទីរពេទ្យនានានៅក្នុងរដ្ឋធានីកាន់តែមានភាពណែនតាន់តាប់ឡើង[788] និងគុណភាពមានការប្រែប្រួល[789]។ វិស័យសុខាភិបាលមានចំណែកអត្រាតិចជាង៣ភាគរយនៃថវិកាជាតិ នៅចុងឆ្នាំ១៩៧៤ បើប្រៀបធៀប នឹងអត្រា ៥.៧ ភាគរយ នៅឆ្នាំ១៩៦៨[790]។

២២៣. ទោះបីជាភាពអត់ឃ្លាន និងកង្វះជីវជាតិជាបញ្ហាគួរឲ្យព្រួយបារម្ភនៅអំឡុងពេលសង្គ្រាមមុនឆ្នាំ១៩៧៥ក៏ដោយ[791] ក៏មិនមានរបាយការណ៍ណាមួយនិយាយ អំពីការរាលដាលនៃគ្រោះទុរ្ភិក្ស ឬហានិភ័យនៃជម្ងឺ ឆ្លងនៅក្នុងអំឡុងពេលនោះឡើយ[792] បញ្ហានេះដោយសារតែមួយផ្នែកធំមានអង្គការបរទេសជួយឧបត្ថម្ភដល់ប្រជាជន[793] ទោះបីជាសមត្ថភាពរបស់អង្គការបរទេសទាំងនោះដែលទទួលបន្ទុកជួយសហគមន៍ដែលត្រូវបានទទួលរងផលប៉ះពាល់ថយចុះ ខណៈពេលដែលអសន្តិសុខកើនឡើងជាបន្តបន្ទាប់[794]។

ការចាកចេញ

២២៤. នៅពេលដែលកងទ័ពបក្សកុម្មុយនីស្តកម្ពុជាចូលដល់រដ្ឋធានី[795] ប្រជាជនភ្នំពេញត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង[796] ចាប់តាំងពីព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[797] ហើយការចាកចេញនេះបានបន្ត

អស់ជាច្រើនសប្តាហ៍[798] ទាំងយប់ទាំងថ្ងៃ[799]។ ជាទូទៅ ប្រជាជនបានចាកចេញពីលំនៅដ្ឋានរបស់ខ្លួន ទូទាំងរដ្ឋធានី[800]។

ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ

២២៥. ប្រជាជនដែលត្រូវបានបង្ខំឱ្យចាកចេញពីភ្នំពេញភាគច្រើនជាជនស៊ីវិល[801]រួមមាន៖ បុរស ស្ត្រី មនុស្ស-ចាស់ កុមារ[802] ព្រះសង្ឃ[803]។ល។ វេជ្ជបណ្ឌិត និងគិលានុបដ្ឋាក[804] ក៏ត្រូវបានប្រាប់ឱ្យចេញដែរ ព្រមទាំងអ្នកជម្ងឺនៅមន្ទីរពេទ្យ អ្នករបួស និងអ្នកជម្ងឺ[805] រួមទាំងស្ត្រីដែលទើបសម្រាលកូនផងដែរ[806]។ គ្រប់គ្រួសារទាំងអស់ត្រូវបានបង្ខំឱ្យចេញពីភ្នំពេញ[807] ជារឿយៗ សមាជិកគ្រួសារត្រូវបានបំបែកពីគ្នាក៏ដោយ[808]។

២២៦. ចំនួនប្រជាជនជាក់លាក់ដែលត្រូវបានបង្ខំឱ្យចេញពីភ្នំពេញ មិនមានភាពច្បាស់លាស់ទេ ទោះបីជាប្រជាជនសរុបទាំងអស់ទំនងជាមានចំនួនពី ១.៥ ទៅ ២.៦ លាននាក់ក៏ដោយ[809]។ សាក្សីជាច្រើនបាននិយាយថា បានឃើញមនុស្សយ៉ាងច្រើនកកកុញធ្វើដំណើរនៅតាមផ្លូវនានា[810] ហើយថា ទីក្រុងទាំងមូលមិនមានប្រជាជនទេ[811]។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា ប្រជាជនក្រុងភ្នំពេញ និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយខ្មាំង មានចំនួនប្រហែលមួយលាននាក់[812]។ ក្រោយថ្ងៃទី១៧ ខែមេសា បក្សកុម្មុយនីស្តកម្ពុជាបានប៉ាន់ប្រមាណចំនួនអ្នកដែលត្រូវបានជម្លៀសសរុបជាផ្លូវការមានចំនួនពីរលាននាក់[813]។ បន្ទាប់មក បក្សកុម្មុយនីស្តកម្ពុជាបានកំណត់តួលេខអ្នកដែលត្រូវបានជម្លៀសពីភ្នំពេញ និងទីរួមខេត្តនានាថា មានប្រមាណបីលាននាក់[814]។ (ទោះបីជាពេលខ្លះចំនួនបីលាននាក់នេះសំដៅតែទីក្រុងភ្នំពេញតែមួយគត់ ជាពិសេសលើកឡើងដោយ អៀង សារី ក៏ដោយ)[815]។ ក្នុងឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ប្តូរការប៉ាន់ប្រមាណរបស់ខ្លួន ចំពោះចំនួនប្រជាជនសរុបដែលត្រូវបានជម្លៀសថា មានចំនួនដល់បួនលាននាក់[816]។

គោលដៅដំបូង

២២៧. ប្រជាជនស៊ីវិលដែលចាកចេញពីភ្នំពេញ បានចាកចេញតាមគ្រប់ទិសដៅ តាមផ្លូវជាតិនៅគ្រប់ទិសទៅទិសខាងជើង ខាងត្បូង ខាងកើត និងខាងលិចទីក្រុង[817]។ ជាទូទៅ ប្រជាជនមិនត្រូវបានប្រាប់ពីទិសដៅ[818] ឬពីគោលដៅចុងក្រោយទេ[819] លើកលែងតែថា ត្រូវទៅទីជនបទ[820] ឬទីកន្លែងកំណើត ឬភូមិកំណើតរបស់ខ្លួន[821]។ មានពេលខ្លះ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានឱ្យប្រជាជនផ្លាស់ប្តូរទិសដៅ[822]។ សក្ខីកម្មបង្ហាញថា ប្រជាជនបានទៅកាន់តំបន់នានានៃប្រទេសកម្ពុជា[823]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ជារឿយៗ សហគមន៍មូលដ្ឋានត្រូវបានណែនាំឱ្យទទួលយកប្រជាជនដែលទើបមកដល់ថ្មី ហើយផ្តល់អាហារ និងជម្រក ទោះបីជាទូទៅ វាមិនគ្រប់គ្រាន់ទៅនឹងចំនួនអ្នកមកដល់ក៏ដោយ[824]។ ក្នុងករណីខ្លះ ប្រជាជនស៊ីវិលមកពីភ្នំពេញត្រូវបានផ្តល់ជម្រកនៅក្នុងរោងធំៗ[825] ឬត្រូវសង់ជម្រកដោយខ្លួនឯង[826]។ ប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺ ដោយសារការធ្វើដំណើរពីភ្នំពេញ ឬដោយសារស្ថានភាពរស់នៅផ្សេងៗនៅពេលមកដល់[827]។ ប្រជាជនដែលមកពីភ្នំពេញត្រូវបានផ្តល់អត្តសញ្ញាណថា ជា"ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ឬក៏"ប្រជាជនបញ្ញើ" ហើយជារឿយៗត្រូវបានកំណត់ជាមុខសញ្ញានៅពេលមកដល់ដោយផ្អែកលើអត្តសញ្ញាណនេះ[828]។

## <u>មធ្យោបាយ និងវិធីសាស្ត្រនៃការផ្លាស់ទីលំនៅ</u>

### *មធ្យោបាយ*

២២៨. អ្នកដែលដែលរៀបចំការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សីថា ជាកងទ័ព"ខ្មែរក្រហម"[829]។ កងទ័ពទាំងនោះត្រូវបានពណ៌នាថា មានសំលៀកបំពាក់ពណ៌ខ្មៅ[830] ឬពណ៌កាគី[831] មួយចំនួនមានកន្សែង[832] ឬក្រមាបង់ក[833]។ ជារឿយៗ កងទ័ព "ខ្មែរក្រហម"មានបំពាក់ដោយអាវុធ។[834]

២២៩. កងទ័ពបានធ្វើការប្រកាសនានា[835] ជាទូទៅតាមឧឃោសនសព្ទ ឬប្រដាប់បំពងសំលេងធំៗ[836] ថាប្រជាជនមានពេលវេលាកំណត់ដើម្បីចាកចេញពីភ្នំពេញ[837]។ ក្នុងករណីខ្លះ មានសេចក្តីរាយការណ៍ថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមានបញ្ជីឈ្មោះ[838] ហើយពួកគេត្រូវបានបែងចែកទៅតាមទីតាំងជាក់លាក់នានាក្នុងរដ្ឋធានី ដើម្បីពិនិត្យមើលការផ្លាស់ទីលំនៅរបស់ប្រជាជន[839]។

២៣០. កងទ័ពបក្សកុម្មុយនីស្តកម្ពុជាដែលមកពីអង្គភាពផ្សេងៗ ត្រូវបានឃើញថា បានចូលរួម ដើម្បីអនុវត្តការផ្លាស់ទីលំនៅរបស់ប្រជាជនភ្នំពេញ[840]។ ក្រុមកងទ័ពទាំងនោះមានដូចជា៖ កងទ័ពភូមិភាគឧត្តរ[841] (រួមមាន៖ កងពលធំលេខ១ នៅក្រោមមេបញ្ជាការឈ្មោះ [លុប])[842] កងទ័ពភូមិភាគនិរតី[843] កងទ័ពភូមិភាគពិសេស[844] និងកងទ័ពភូមិភាគបូព៌ា[845] ហើយពេលខ្លះសាក្សីនានារៀបរាប់ថាក្រុមកងទ័ពទាំងនោះមានឥរិយាបថផ្សេងៗគ្នាចំពោះប្រជាជន[846]។

២៣១. ប្រជាជនមិនបានរឹងទទឹងនឹងការប្រាប់ឱ្យចាកចេញពីភ្នំពេញឡើយ[847]។ សាក្សីមួយចំនួនបានបង្ហាញសក្ខីកម្មថា មិនបានឃើញអំពើហិង្សាជាក់លាក់ណាមួយ ប្រព្រឹត្តដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជា

នោះទេ[848]។ ទោះបីយ៉ាងណាក៏ដោយ សាក្សីភាគច្រើននិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានជាប់ពាក់ព័ន្ធក្នុងការគំរាមកំហែង[849] និងការប្រើប្រាស់កម្លាំង ដើម្បីធ្វើឱ្យប្រាកដថា ប្រជាជនចាកចេញពីផ្ទះរបស់ខ្លួន[850]។ សាក្សីនានាបានរាយការណ៍ថា បានឮស្នូរកាំភ្លើង[851]។

២៣២. សាក្សីដទៃទៀតនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានបាញ់សម្លាប់ប្រជាជន ប្រសិនបើពួកគេបដិសេធមិនចាកចេញពីផ្ទះ[852]។ ជនស៊ីវិលក៏ត្រូវបានសម្លាប់ផងដែរ នៅក្នុងការបាញ់តបតគ្នាដែលមានគោលដៅចំពោះទាហាន លន់ នល់ [853]។ សាក្សីមួយចំនួនបានប្រាប់ថា បានឃើញសាកសពនៅតាមផ្លូវនានានៅទីក្រុងភ្នំពេញ[854]។ សាក្សីដទៃទៀតនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានទទួលបញ្ជាឱ្យប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដើម្បីឱ្យប្រាកដថា ប្រជាជនចាកចេញពីភ្នំពេញ[855]។

២៣៣. មានការលើកឡើងផងដែរ អំពីការធ្វើបាប និងអំពើហិង្សាផ្សេងៗប្រឆាំងនឹងប្រជាជនស៊ីវិលដូចជា វាយ និងបាញ់ឡើងលើ[856]។ មានសេចក្តីរាយការណ៍ថា ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រជាជនទីក្រុងភ្នំពេញត្រូវបានរឹបអូសយកដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជា[857]។

២៣៤. ទាក់ទងនឹងទាហាន លន់ នល់ ថា ពួកគេខ្លះត្រូវបានដកអាវុធដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជា[858] ហើយត្រូវបានឱ្យចាកចេញពីទីក្រុងជាមួយនឹងប្រជាជនស៊ីវិល[859]។ ទាហាន លន់ នល់ ខ្លះទៀតត្រូវបានកំណត់អត្តសញ្ញាណដោយការសួរចម្លើយ ហើយបំបែកចេញពីប្រជាជនដែលចាកចេញពីទីក្រុង[860]។ មានការប្រកាសជាមុនថា *"អង្គការ"*អាចលើកលែងទោសដល់ប្រជាជនទាំងឡាយ ដែលមកពីរបបមុន លើកលែងតែមន្ត្រីថ្នាក់ខ្ពស់ប្រាំពីរនាក់ប៉ុណ្ណោះ[861] ហើយថា នៅពេលជម្លៀសកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានស្នើអតីតទាហាន លន់ នល់ មន្ត្រីរដ្ឋាភិបាល និងមន្ត្រីប៉ូលីសឱ្យណែនាំខ្លួនដើម្បីធ្វើការបំរើបក្ស ហើយបន្ទាប់មក បុគ្គលទាំងនេះត្រូវបានយកទៅកន្លែងដែលគ្មាននរណាដឹង មុននឹងបាត់ខ្លួន[862]។

២៣៥. ទាហាន លន់ នល់ មួយចំនួនត្រូវបានបាញ់ ប្រសិនបើពួកគេបដិសេធមិនទម្លាក់អាវុធរបស់ខ្លួន ឬបានបង្ហាញពីការរឹងទទឹងណាមួយ[863]។ ជាពិសេស មានបញ្ជាជាលាយលក្ខណ៍អក្សរមួយដែលចុះហត្ថលេខាដោយសមមិត្ត [លុប] ដែលបានបញ្ជាឱ្យ "កំទេច"[864] អ្នករដ្ឋការ លន់ នល់ ដែលមានឈ្មោះក្នុងបញ្ជីមួយ ហើយសាក្សីមួយរូបនិយាយថា សុន សេន បានបញ្ជាឱ្យចាប់ខ្លួនមន្ត្រីរដ្ឋការ

ស៊ីវិលថ្នាក់ខ្ពស់នៃរបប លន់ នល់ រួមទាំងអ្នកនៅក្នុងមន្ទីរពេទ្យផងដែរ។ ក្រោយមក ពួកគេត្រូវបាន សម្លាប់ និងបោះចូលទៅក្នុងអណ្តូងមួយនៅតំបន់ទួលគោក[865]។ សាក្សីខ្លះនិយាយថា បានមើល ឃើញការសម្លាប់ទាហាន លន់ នល់[866] ហើយនិងបានឃើញសាកសពទាហាន លន់ នល់ នៅ តាមផ្លូវ[867]។

*វិធីសាស្ត្រ*

**២៣៦.** មិនមានសក្ខីកម្មណាបង្ហាញថា មានការផ្តល់នូវការដឹកជញ្ជូនណាមួយទេ[868] ក្រៅពីការនិយាយខ្លះ អំពីការប្រើប្រាស់ឡានយោធា[869]។ ប្រជាជនភាគច្រើនបានធ្វើដំណើរដោយថ្មើរជើង[870] អ្នកផ្សេង ទៀតបានបើក ឬយានជំនិះផ្សេងទៀត ឬរុញយានជំនិះទាំងនោះ[871]រួមមាន៖ កង់ម៉ាស៊ីន ឬទោចក្រ យានយន្ត[872] និងទោចក្រយាន ឬស៊ីក្លូ [873]។ នៅក្នុងករណីខ្លះ ទូក[874] ក៏ត្រូវបានប្រើប្រាស់ផងដែរ។

**២៣៧.** កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនកុំឱ្យយករបស់របរផ្ទាល់ខ្លួនច្រើនពេក[875] ដោយ នៅក្នុងករណីមួយចំនួនបានគូសបញ្ជាក់ថា មិនមានការចាំបាច់[876] ព្រោះថាពួកគេចាកចេញសម្រាប់ រយៈពេលខ្លីតែប៉ុណ្ណោះ ហើយថា ប្រជាជនមិនអាចយករបស់របរទៅជាមួយខ្លួនបាន ដោយសារ ពួកគេត្រូវចាកចេញជាប្រញាប់[877]។ ដូច្នេះ ប្រជាជនភាគច្រើនបានទុករបស់របរផ្ទាល់ខ្លួននៅក្នុង ផ្ទះ[878]។ ចំពោះប្រជាជនដែលយករបស់របរតាមខ្លួន មិនមានភស្តុតាងបង្ហាញ អំពីការជួយដឹកជញ្ជូន របស់របរឱ្យពួកគេទេ [879]។ ប្រជាជនយកឥវ៉ាន់តាមខ្លួន ដោយទូលលើក្បាល ឬលីនៅនឹងស្មា ដឹក តាមរទេះ ឬតាមយានជំនិះរបស់ខ្លួន[880]។ ប្រជាជនបានយកតាមខ្លួននូវរបស់របរដូចជា៖ អង្ករ[881] លុយ ថ្នាំសង្កូវ សៀវភៅ ឬសំលៀកបំពាក់[882]។ ប្រជាជនក៏បានជួយអសារដល់អ្នកដែលឈឺ និងមនុស្សចាស់ផងដែរ[883]។

**២៣៨.** មានសក្ខីកម្មមួយចំនួនបង្ហាញថា ម្ហូបអាហារ ឬទម្រង់ដទៃទៀតនៃការឧបត្ថម្ភ ត្រូវបានផ្តល់ឱ្យ ប្រជាជនអំឡុងពេលធ្វើដំណើរចេញពីភ្នំពេញ[884]។ ទោះបីជាសក្ខីកម្មខ្លះបង្ហាញថា កងទ័ពបក្ស កុម្មុយនីស្តកម្ពុជាមួយចំនួនបានផ្តល់អង្ករដល់ប្រជាជនបរិភោគក៏ដោយ[885] ក៏សាក្សីភាគច្រើន រាយការណ៍ថា ពួកគេបានផឹកទឹកកខ្វក់ពីស្រះទឹកនៅតាមផ្លូវ[886] ហើយថា កម្មាភិបាលបក្ស កុម្មុយនីស្តកម្ពុជាបានកត់ឈ្មោះអ្នកដែលបានទទួលអាហារ និងឈ្មោះអ្នកដែលមិនចង់បន្តដំណើរ ទៅមុខទៀត[887]។ សាក្សីពីររូបនិយាយថា ពួកគេមិនបានឃើញប្រជាជនអត់ឃ្លាន អំឡុងពេលផ្លាស់ ទីលំនៅចេញពីភ្នំពេញទេ[888]។

២៣៩. មិនមានភស្តុតាងដែលថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់សន្តិសុខ ឬការការពារដល់ប្រជាជននៅតាមផ្លូវឡើយ[889]។ ប្រជាជនមិនមានជម្រកនៅតាមផ្លូវ[890] ហើយបានដេកលើកន្ទេលនៅតាមផ្លូវ[891] ដេកនៅក្នុងផ្ទះគ្មានមនុស្ស ឬដេកនៅក្រោមដើមឈើ[892]។ ប្រជាជនមិនត្រូវបានផ្តល់អាហារ ឬទឹកទេ[893]។ សាក្សីមួយរូបនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមិនអនុញ្ញាតឱ្យយកអាហារឡើយ[894]។ ហើយអាហារដែលមានតែមួយមុខគត់នោះគឺ បាយ[895]។ ប្រជាជនមួយចំនួនត្រូវធ្វើដំណើរទាំងពេលយប់ដោយមិនសម្រាក[896]អស់ជាច្រើនថ្ងៃ[897]។ ប្រជាជនខ្លះបានហើមជើងដោយសារធ្វើដំណើរផ្លូវឆ្ងាយ[898] ហើយមានសេចក្តីរាយការណ៍ អំពីការស្លាប់ដោយស្ថានភាពដូចនេះ[899]។ មិនមានភស្តុតាងបង្ហាញថា ប្រជាជនបានទទួលថ្នាំសង្កូវឡើយ[900]។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនបានយកទ្រព្យសម្បត្តិពីប្រជាជននៅអំឡុងពេលធ្វើដំណើរ[901]។

២៤០. សាក្សីជាច្រើនបាននិយាយថា បានឃើញសាកសពមនុស្ស ដែលត្រូវបានបាញ់សម្លាប់[902] នៅតាមផ្លូវ[903]។ ប្រជាជនត្រូវបានសម្លាប់នៅតាមផ្លូវដោយសារបញ្ហាតូចតាចដូចជា៖ មិនចង់បោះបង់ចោលកង់របស់ខ្លួន[904]។ ទោះបីជាសាក្សីមួយចំនួនផ្តល់ចម្លើយថា ពួកគេមិនបានឃើញការធ្វើទុក្ខទោសណាមួយពីសំណាក់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ចំពោះជនស៊ីវិល[905] ឬក៏ថា ពួកគេមិនបានឃើញនរណាម្នាក់ស្លាប់នៅតាមផ្លូវទេក៏ដោយ[906] ក៏ **អៀង សារី** ខ្លួនឯងផ្ទាល់បាននិយាយថា ប្រជាជនពី ២.០០០ ទៅ ៣.០០០នាក់ បានស្លាប់នៅអំឡុងការជម្លៀសចេញពីភ្នំពេញ[907]។

<u>ការវិលត្រឡប់ទៅភ្នំពេញវិញ</u>

២៤១. សាក្សីមួយរូបនិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានគំរាមកំហែងថា នឹងបាញ់សម្លាប់ប្រសិនបើនរណាវិលត្រលប់ទៅទីក្រុងភ្នំពេញវិញ[908]។ **នួន ជា** បាននិយាយអំពីចេតនានៃការអនុញ្ញាតឱ្យប្រជាជនវិលត្រឡប់ទៅភ្នំពេញ[909] ហើយ **អៀង សារី** បាននិយាយនៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ថា ទីក្រុងនានាត្រូវបានបំពេញដោយប្រជាជនវិញ បន្ទាប់ពីការផ្លាស់ទីលំនៅប្រជាជនជាដំបូងទៅជនបទ[910] ហើយថា ប្រជាជនអាចមានជម្រើសត្រឡប់ទៅទីក្រុងវិញប្រសិនបើពួកគេចង់ ឬអាចបន្តនៅជនបទ[911]។ ប៉ុន្តែ ទោះបីជាក្នុងកាលៈទេសៈកម្រខ្លះ ប្រជាជនមួយចំនួនទំនងជាត្រូវបានបញ្ជូនត្រឡប់មកភ្នំពេញវិញដើម្បីធ្វើការក៏ដោយ[912] ក៏ជាទូទៅទីក្រុងមានសភាពស្ងប់ស្ងាត់គ្មានប្រជាជន ហើយមានតែកងទ័ព និងកម្មាភិបាលមួយចំនួនតែប៉ុណ្ណោះ[913] រហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[914]។ យោងតាមសេចក្តីថ្លែងការណ៍មួយដោយ ប៉ុល ពត នៅឯការប្រជុំ

មួយនាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៧៦ ប្រជាជននៅភ្នំពេញ *"មានមនុស្សជាងមួយសែន"*[915]។ នាខែមេសា ឆ្នាំ១៩៧៧ តួលេខនេះរួមបញ្ចូលទាំងរបបអាហារចំនួន ៤៣.៨១០នាក់ ដែលត្រូវបានផ្ដល់ដោយអគ្គសេនាធិការដ្ឋាន[916]។

## មូលហេតុដែលលើកឡើងដើម្បីផ្លាស់ទីលំនៅប្រជាជន

២៤២. នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនឲ្យចេញពីផ្ទះរបស់ខ្លួនតែរយៈពេលខ្លីគឺ តែពីរ[917] ឬបីថ្ងៃ[918] ឬមួយឬពីរសប្តាហ៍ប៉ុណ្ណោះយ៉ាងយូរ[919]។

២៤៣. សាក្សីមួយចំនួននិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ប្រជាជនថា ជាការចាំបាច់ក្នុងការចាកចេញពីភ្នំពេញដើម្បីសន្តិសុខផ្ទាល់ខ្លួន[920] ហើយកងទ័ពទាំងនោះអាចកំណត់អត្តសញ្ញាណ[921] ឬកម្ចាត់[922] ទាហាន លន់ នល់ ឬបើមិនដូច្នេះទេ គឺដើម្បីស្វែងរកខ្មាំង[923]។ មានការលើកឡើងផងដែរអំពីការទម្លាក់គ្រាប់បែកដែលបានគ្រោងទុកលើទីក្រុង[924] ដោយកងទ័ពសហរដ្ឋអាមេរិក ទោះបីជា មានសញ្ញាបង្ហាញឲ្យឃើញផងដែរថា ប្រជាជនមួយចំនួនមិនជឿលើការពន្យល់លើហេតុការណ៍នេះក៏ដោយ[925]។ ក្នុងចំណោមយុត្តិកម្មនានាដែលបានលើកឡើង មានការលើកឡើងផងដែរអំពីការដាក់បណ្ដាញគិញរបស់ភ្នាក់ងារ សេ.អ៊ី.អា ដើម្បីបើកការប្រយុទ្ធតបវិញ[926]។

២៤៤. សាក្សីខ្លះបានបង្ហាញផងដែរថា មានការចាំបាច់នឹងបង្ខំឲ្យប្រជាជនចេញពីភ្នំពេញ ដើម្បីរៀបចំ[927] និងបោសសម្អាតទីក្រុង[928] ដូចជាការបោសសម្អាតអាវុធយុទ្ធភណ្ឌជាដើម[929]។

២៤៥. មានការផ្ដល់យុត្តិកម្មពាក់ព័ន្ធនឹងនយោបាយផងដែរ: សាក្សីមួយចំនួននិយាយថា ពួកគេត្រូវបានប្រាប់ថា អង្គការកំពុងរង់ចាំទទួល[930]ពួកគាត់ ហើយថា ពួកគេត្រូវការពួកគាត់ដើម្បីកសាងសេដ្ឋកិច្ចជនបទ[931] កសាងទំនប់ទឹក ព្រែកជីក និងការងារនៅតាមវាលស្រែ[932] ហើយថា អ្នកដែលត្រូវបានអនុញ្ញាតឲ្យនៅទីក្រុងគឺមានតែសមាជិកកងទ័ពប៉ុណ្ណោះដែលត្រូវធ្វើការងាររបស់ខ្លួន[933]។ មានការលើកឡើងផងដែរអំពីកង្វះម្ហូបអាហារនៅភ្នំពេញដែលជាមូលហេតុនៃការផ្លាស់ទីលំនៅប្រជាជន ហើយថាដោយសារ ម្ហូបអាហារមានបរិបូរណ៍នៅជនបទ[934]។

២៤៦. យុត្តិកម្មទាំងនេះបានបង្ហាញពីសក្ខីកម្មដែលត្រូវបានរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍របស់ជនត្រូវ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605334



ចោទ។ នៅក្នុងកិច្ចសម្ភាសន៍មួយដែលបានធ្វើជាមួយអ្នកកាសែតមួយរូបក្នុងឆ្នាំ១៩៨០ **អៀង សារី** បាននិយាយយោងជាទូទៅដល់មូលហេតុសេដ្ឋកិច្ច នយោបាយ និងយោធាដែលជាយុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនចេញ[935]។

**២៤៧.** អៀង សារី បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកកាសែតមួយរូបក្នុងឆ្នាំ១៩៧៥ ដូចដែលបាននិយាយម្តងទៀតនៅឯសន្និសីទមួយក្នុងឆ្នាំ១៩៧៨ថា មូលហេតុចម្បងចំពោះការផ្លាស់ទីលំនៅប្រជាជន គឺម្ហូបអាហារ។ គាត់និយាយថា ពីដំបូងគេគិតថា ប្រជាជននៅទីក្រុងភ្នំពេញមានពីរលាននាក់ ប៉ុន្តែក្រោយមករកឃើញថា មានចំនួន៣លាននាក់។ **អៀង សារី** បានគូសបញ្ជាក់ថា មុនរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាបានទទួលជំនួយជាអាហារចំនួនរវាងពី ៣ម៉ឺន ទៅ៤ម៉ឺនតោនក្នុងមួយខែ ពីសហរដ្ឋអាមេរិក។ ហើយថា បក្សកុម្មុយនីស្តកម្ពុជាមិនមានបំណងស្នើសុំជំនួយពីសហគមន៍អន្តរជាតិឡើយ ហើយក៏មិនមានមធ្យោបាយគ្រប់គ្រាន់ក្នុងការដឹកជញ្ជូនម្ហូបអាហារពីជនបទចូលទីក្រុងដែរ[936]។ ខៀវ សំផន បាននិយាយផងដែរនៅក្នុងការសម្ភាសន៍តាមវិទ្យុមួយក្នុងឆ្នាំ២០០៧ ថា ប្រជាជនមានការអត់ឃ្លាននៅពេលនោះ ប៉ុន្តែគាត់បានយល់ស្របថា នៅជនបទក៏មិនមានអាហារគ្រប់គ្រាន់ដែរ ដូច្នេះប្រជាជនបរិភោគផ្លែចេកជាមួយបាយ ឬដំឡូង ហើយជំនួយស្បៀងអាហារដ៏មានកំណត់ត្រូវបានបញ្ជូនមកតែពីប្រទេសសម្ព័ន្ធមិត្តនឹងបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ[937]។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងចម្លើយពីមុនមួយ **ខៀវ សំផន** បាននិយាយថា រដ្ឋាភិបាលណាមួយដែលទើបងើបចេញពីសង្គ្រាមអាចប្រឈមនឹងបញ្ហាគ្រោះអត់ឃ្លាន ហើយគាត់បានបន្ថែមថា បន្ទាប់ពីផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ប្រជាជនមានអាហារគ្រប់គ្រាន់នៅតាមសហករណ៍[938]។

**២៤៨.** ជនត្រូវចោទទាំងនាក់ក៏បាននិយាយយោងទៅដល់មនោគមវិជ្ជានៃរបបនោះ ជាយុត្តិកម្មមួយចំពោះការផ្លាស់ទីលំនៅប្រជាជនផងដែរ។ នៅក្នុងការប្រឈមនឹងវិបត្តិម្ហូបអាហារនោះ នួន ជា បាននិយាយថា ទិសដៅនៃរបបនោះគឺត្រូវរក្សាឯករាជ្យភាព និងអធិបតេយ្យភាព[939]។ ខៀវ សំផន ក៏បាននិយាយដែរថា ប៉ុល ពត មិនចង់រស់នៅក្រោមការគ្រប់គ្រងរបស់ជនបរទេស[940]។ ការផ្លាស់កន្លែងប្រជាជនពីទីក្រុងទៅជនបទក៏ត្រូវបាននិយាយដោយជនត្រូវចោទ នួន ជា ថាជាសមាសធាតុមួយនៃបដិវត្តន៍សង្គមនិយម[941]។ អៀង សារី បាននិយាយថា គោលបំណងគឺដើម្បីប្រែក្លាយទីកន្លែងនៅក្នុងក្រុងដែលមិនមានមនុស្សរស់នៅឲ្យទៅជាទីតាំងឧស្សាហកម្ម[942]។ អៀង សារី បាននិយាយដែរថា វាមានការចាំបាច់ ដើម្បីនឹងលត់ដំប្រជាជនដែលមកពីទីក្រុងឲ្យស៊ូទ្រាំនឹងការលំបាក ទាំងផ្លូវកាយ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605335



និងផ្លូវចិត្ត តាមរយៈពលកម្មធ្ងន់ធ្ងរ[943]។ តាមសាក្សីមួយរូបបាននិយាយ តាម៉ុក ប្រកាសថា មិនមានការចាំបាច់នឹងមានទីផ្សារ ឬទីក្រុង ហើយប្រជាជននៅទីក្រុងទាំងអស់ត្រូវទៅទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ[944]។ ឌុច បានពន្យល់ថា គោលបំណងរបស់បក្សកុម្មុយនីស្តគឺត្រូវប្រែក្លាយប្រទេសទាំងមូលឲ្យទៅជាប្រទេស របស់កសិករ លុបបំបាត់ឯកជនភាវូបនីយកម្ម និងដើម្បីបង្ខំអ្នកបច្ចេកទេសឲ្យធ្វើស្រែចម្ការដើម្បីធ្វើឲ្យពួកគេរស់នៅស្មើភាពគ្នា ហើយពឹងផ្អែកលើកសិករ[945]។ ឯកសារកាលពីសម័យនោះឲ្យដឹងថា ការអប់រំកែប្រែមិនអាចធ្វើទៅបានក្នុងទ្រង់ទ្រាយធំឡើយ ហេតុដូច្នេះ ជាការចាំបាច់នឹងធ្វើការ *"ជម្លៀស"* ប្រជាជនទៅតាមទីជនបទ[946] ដើម្បីបញ្ឈប់ *"ការចម្លងមនោគមវិជ្ជាដែលមិនអាចគ្រប់គ្រងបានក្នុងផ្លូវបដិវត្តន៍"*[947] ហើយដើម្បីចូលរួមនៅក្នុងចលនាបង្កបង្កើនផល និងចូលរួមចំណែកការពារ និងកសាងប្រទេស[948]។

២៤៩. ជាចុងក្រោយ ទាក់ទងនឹងបញ្ហាសន្តិសុខ នួន ជា បាននិយាយថា ជាការចាំបាច់ក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ដើម្បីសម្រួលដល់ការការពារប្រទេសតាមបែបយោធាដែលប្រឈមមុខនឹងប្រទេសវៀតណាម[949] និងការពារប្រជាជនពីសង្គ្រាម[950]។ អៀង សារី បានលើកឡើងពីឯកសារសម្ងាត់មួយរបស់ សេ.អ៊ី.អា ពាក់ព័ន្ធនឹងផែនការជ្រៀតចូលទីក្រុង[951]។ ខៀវ សំផន បានលើកឡើងពីតម្រូវការក្នុងការធ្វើឲ្យប្រទេសខ្លាំង ដើម្បីវាយខ្មាំង[952]។ តាមឯកសារបក្សកុម្មុយនីស្តកម្ពុជាបានឲ្យដឹងថា ប្រសិនបើប្រជាជនមិនបានចាកចេញពីទីក្រុងនានាទេ ខ្មាំងអាចមានលទ្ធភាពបើកការវាយប្រហារដ៏ភ្ញាក់ផ្អើលពីក្រោយខ្នង[953]។

## ការរៀបចំផែនការ

២៥០. ចាប់តាំងពីមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយជម្លៀសប្រជាជនពីទីក្រុងនានាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេ៖ ប្រជាជនត្រូវបានផ្លាស់ទីលំនៅ មួយផ្នែក ឬ ទាំងស្រុងពីទីរួមខេត្តស្ទឹងត្រែង ខេត្តក្រចេះ ស្រុកបាណន់ និង ឧត្តុង[954]។

២៥១. មានសក្ខីកម្មខ្លះបង្ហាញថា ការសម្រេចចិត្តផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ប្រហែលជាធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥[955] ហើយគឺជាផែនការដែលបានគិតទុកជាមុនរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា[956]។ អតីតកម្មាភិបាលភូមិភាគបូព៌ាមួយរូបបញ្ជាក់ថា ការសម្រេចនេះបានបន្តធ្វើតាមបញ្ជារបស់ ប៉ុល ពត នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ឲ្យគ្រប់ស្រុក និងគ្រប់តំបន់គួរប្រុងប្រៀបរៀបចំ សង់ទីលំនៅដើម្បីទទួលប្រជាជនពីភ្នំពេញ[957]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

២៥២. សាក្សីមួយរូបបានរៀបរាប់ថា នៅដើមខែមេសា ឆ្នាំ១៩៧៥ មានការប្រជុំមួយបានធ្វើឡើងនៅមន្ទីររបស់ ប៉ុល ពត នៅភូមិតាំងពន ស្រុកកំពង់ត្រឡាច(លើ) ខេត្តកំពង់ឆ្នាំង ដែលផ្តោតជាសំខាន់ទៅលើផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ[958]។ សាក្សីរូបនេះបញ្ជាក់ថា ទោះបីជាមិនមានការកត់ត្រាជាផ្លូវការអំពីការប្រជុំនោះក៏ដោយទាំង នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងការប្រជុំនោះ[959] ហើយបានកត់ត្រារៀងៗខ្លួន[960]។ យោងតាមសាក្សីនេះមេបញ្ជាការនានាត្រូវបានប្រាប់ឲ្យ *"រៀបចំការប្រជុំ នៅពេលដែលគេត្រឡប់ទៅតំបន់របស់គេវិញ ហើយធ្វើផែនការដើម្បីជម្លៀសប្រជាជននៅក្នុងទីក្រុងដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គេ។ ក្រោយមកព័ត៌មាននេះត្រូវបានបោះផ្សាយក្នុងទង់បដិវត្តន៍និងទង់រណសិរ្ស ហើយបានចែកទៅឲ្យគ្រប់សមាជិកបក្សទាំងអស់* (ទោះបីជាគ្មានដាមស្នាមអំពីការបោះពុម្ពទាំងនេះក៏ដោយ)[961]។

២៥៣. សាក្សីម្នាក់ទៀតនិយាយអំពីការប្រជុំសម្របសម្រួលមួយនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះ មេបញ្ជាការកងទ័ពបក្សកុម្មុយនីស្តកម្ពុជាទាំងអស់នៃអង្គភាពរបស់គាត់ (កងពលធំលេខ១នៃភូមិភាគឧត្តរនៅពេលនោះ ក្រោយមកជាកងពលធំលេខ៣១០របស់មជ្ឈិម) ត្រូវបានអញ្ជើញឲ្យចូលរួមប្រជុំ ដូចដែលបានរាយការណ៍ទៅឲ្យសាក្សីរូបនោះ ដោយឈ្មោះ [លុប] ដែលជាមេបញ្ជាការកងវរៈសេនាតូចរបស់គាត់[962]។ សាក្សីម្នាក់ទៀតនិយាយថា ប្រមាណមួយខែមុនពេលចូលមកទីក្រុងភ្នំពេញ ការប្រជុំមួយត្រូវបានធ្វើឡើងនៅភ្នំសរ (បញ្ជាការដ្ឋានកងទ័ពបក្សកុម្មុយនីស្តកម្ពុជាតំបន់ខេត្តកំពត)។ ប្រធានសេនាធិការឈ្មោះ [លុប] តំបន់៣៥នៃភូមិភាគនិរតីបានធ្វើជាប្រធានអង្គប្រជុំ ដែលនៅក្នុងនោះលេខាភូមិភាគនិរតីឈ្មោះ តាម៉ុក បាននិយាយថា មិនចាំបាច់នឹងមានផ្សារ ឬទីក្រុងឡើយ ហើយថា ប្រជាជនទាំងអស់ត្រូវតែជម្លៀសចេញពីទីក្រុងនានាទៅតំបន់ជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទក្នុងរយៈពេលពីរថ្ងៃ បន្ទាប់ពីកាន់កាប់បានទីក្រុង[963]។

២៥៤. មានភស្តុតាងថា សំ ប៊ិត អតីតមេបញ្ជាការកងពលធំលេខ២ នៃភូមិភាគនិរតី បានចូលរួមការប្រជុំមួយជាមួយនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ ដែលនៅក្នុងការប្រជុំនោះមាននិយាយថា ប្រជាជនភ្នំពេញត្រូវតែជម្លៀសចេញដើម្បីស្វែងរកសមាសភាព លន់ នល់[964]។ បន្ទាប់មក ព័ត៌មាននេះត្រូវបានផ្សព្វផ្សាយចេញពីការប្រជុំនេះទៅថ្នាក់កងវរសេនាធំ និងកងវរសេនាតូច[965]។

២៥៥. អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ទាបក៏និយាយដែរថា ពួកគេត្រូវបានប្រាប់ជាមុនអំពីផែនការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយរូបបានលឺគេនិយាយ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ថា *អង្គការ* មានផែនការជម្លៀសប្រជាជនទៅកាន់ស្រុកកំណើតរបស់ពួកគេវិញ[966]។ សាក្សីម្នាក់ទៀតនិយាយថា លេខាកងពលធំលេខ១ភូមិភាគឧត្តរ ឈ្មោះ [លុប] បានដាក់បញ្ជាដល់ក្រុមរបស់គាត់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនប្រហែលបីថ្ងៃមុន *"រំដោះ"*[967] រីឯអតីតកងទ័ពម្នាក់ទៀតក៏បាននិយាយដែរថា គាត់បានទទួលព័ត៌មាននេះពីឈ្មោះ [លុប] បីថ្ងៃមុនការវាយចូលទីក្រុងភ្នំពេញ[968]។

២៥៦. ទោះបីជាយ៉ាងណាក៏ដោយ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ក្រោមផ្សេងទៀត បាននិយាយថា មិនមានការណែនាំមុនព្រឹត្តិការណ៍ទាំងនោះទេ[969]។ លើសពីនេះទៀត កងទ័ពមួយចំនួនបានគូសបញ្ជាក់ថា ខ្លួនគ្រាន់តែបានទទួលបញ្ជាឲ្យផ្លាស់ទីលំនៅប្រជាជនតែប៉ុណ្ណោះ បន្ទាប់ពីបានចូលដល់ភ្នំពេញបានប៉ុន្មានថ្ងៃ[970]។

២៥៧. កងទ័ពបក្សកុម្មុយនីស្តកម្ពុជាក៏បានទទួលការណែនាំពីថ្នាក់លើរបស់ខ្លួនឲ្យផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ ស្របតាមខ្សែរយៈបញ្ជាផ្នែកយោធា[971]។ កងវរៈសេនាធំលេខ ២ (ក្រោយមកលេខ៧២៣) នៃកងពលធំលេខ៣១០(កងពលធំលេខ១នៃភូមិភាគឧត្តរ) បានទទួលបញ្ជាឲ្យជម្លៀសប្រជាជនពីមេបញ្ជាការឈ្មោះ [លុប][972] និងមេបញ្ជាការឈ្មោះ [លុប][973]។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាក៏បាននិយាយអំពី *"ថ្នាក់លើ"* ឬ *"អង្គការ"* ថាបានចេញបញ្ជាឲ្យប្រជាជនចាកចេញពីទីក្រុង[974]។

២៥៨. ពាក់ព័ន្ធនឹងការចូលរួមរបស់ជនត្រូវចោទនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច នួន ជា បានចូលរួមក្នុងការរៀបចំផែនការកងទ័ពបក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការវាយប្រហារលើទីក្រុងភ្នំពេញ ដូចដែលបានបង្ហាញជាសក្ខីកម្ម អំពីវត្តមានរបស់គាត់នៅក្នុងការប្រជុំជាមួយមេដឹកនាំយោធា[975]។ នៅក្នុង សេចក្តីថ្លែងការណ៍មួយទៅកាន់អ្នកសារព័ត៌មានមួយរូប នួន ជា បានថ្លែងថា ការសម្រេចជម្លៀសប្រជាជនពីទីក្រុងនានាត្រូវបានធ្វើឡើងដោយ *"គណៈមជ្ឈិមបក្ស។...កាលហ្នឹងផ្តើមគំនិតម្នាក់បន្តិចៗ។ ផ្សំពីនេះពីនោះ"*[976]។ នួន ជា បានថ្លែងទៀតថា *"ដូច្នេះទៅវាយយកអាបន្ទាយខាងក្នុងៗយក។ ដល់អញ្ចឹង ១៧ មេសា ១៩៧៥ រំដោះ កងទ័ពចូលរំដោះយកភ្នំពេញទាំងស្រុង"*[977]។ អៀង សារី បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ជាលាយលក្ខអក្សរមួយក្នុងឆ្នាំ ១៩៩៦ ថា ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយ ប៉ុល ពត ដោយគាត់មិនបានដឹង[978] ប៉ុន្តែគាត់ក៏បានគូសបញ្ជាក់ផងដែរថា គាត់បានព្យាយាមរារាំង ប៉ុល ពត ដោយបាននិយាយថា *"ក្នុងឆ្នាំ១៩៧៤*

*ខ្ញុំបាននិយាយជាមួយ ប៉ុល ពត ថា យកមនុស្សចេញពីស្ទឹងត្រែង និងក្រចេះគឺការងាយ ពីព្រោះមិនមានប្រជាជនច្រើន ប៉ុន្តែជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺមិនមែនជាការងាយទេ។ គ្រប់យ៉ាងត្រូវតែរៀបចំឲ្យបានសព្វគ្រប់ពីព្រោះមានប្រជាជនរាប់លាននាក់"*[979]។ អៀង សារី ក៏បាននិយាយដែរថា *"រាល់សេចក្តីសម្រេចទាំងអស់ត្រូវធ្វើឡើងដោយ គណៈកម្មាធិការបួនរូបនោះឯង* [រួមទាំងរូបគាត់ និង នួន ជា]។ *ការជម្លៀសប្រជាជនចេញពីទីក្រុងនានាមិនពាក់ព័ន្ធនឹងការចូលរួមធ្វើសេចក្តីសម្រេចរបស់ខ្ញុំទេ...* [នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចុះពីយន្តហោះមកពីទីក្រុងប៉េកាំង] [ខ្ញុំ]*បានឃើញទីក្រុងក្លាយជាទីរហោឋានរួចទៅហើយ"*[980]។ យោងតាម អៀង សារី ការសម្រេចដាច់ណាត់ក្នុងការ *"ជម្លៀស"*ភ្នំពេញត្រូវបានធ្វើឡើងចុងខែមីនា ឬដើមខែមេសា ឆ្នាំ១៩៧៥[981]។ នៅក្នុងបទសម្ភាសន៍តាមវិទ្យុមួយ ខៀវ សំផន បាននិយាយថា គាត់បានប្រឆាំងនឹងការជម្លៀស ប៉ុន្តែគាត់ថា ការជម្លៀសនោះត្រូវតែធ្វើដើម្បីជាប្រយោជន៍ដល់អ្នកទីក្រុង[982] ហើយនៅក្នុងការសម្ភាសន៍មួយទៀត គាត់ថា វិធានការនេះ *"ត្រូវបានគិតគូរ និងរៀបចំផែនការដោយគណៈកម្មាធិការអចិន្ត្រៃយ៍"*[983]។ ចំណែកឯ អៀង ធីរិទ្ធ បាននិយាយនៅក្នុងកិច្ចសម្ភាសន៍ជាមួយ [លុប] [លុប] (Elizabeth BECKER) ក្នុងឆ្នាំ១៩៨០ ថា គាត់មិនបានដឹងពេលណាដែលការសម្រេចចិត្តជម្លៀសប្រជាជនភ្នំពេញត្រូវបានធ្វើទេ ពីព្រោះគាត់នៅកន្លែងផ្សេងនៅពេលនោះ[984]។

**២៥៩.** ទាក់ទិននឹងវត្តមានរបស់ជនត្រូវចោទនៅភ្នំពេញ នួន ជា បានចាកចេញពីអតីតមូលដ្ឋានកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១៧ ខែមេសា ហើយបានមកដល់ភ្នំពេញនៅប្រហែលថ្ងៃទី២០ ខែមេសា[985]។ អៀង សារី បាននិយាយថា គាត់បានមកដល់ភ្នំពេញនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ពីប៉េកាំង[986]។ អៀង ធីរិទ្ធ បាននិយាយថា គាត់បានមកដល់ភ្នំពេញអំឡុងខែមិថុនា ប៉ុន្តែថា គាត់បានដឹងអំពីការជម្លៀសនៅមុនពេលគាត់បានមកដល់ភ្នំពេញ[987]។ ខៀវ សំផន បានថ្លែងថា គាត់បានចូលភ្នំពេញពី ៧ ទៅ ១០ថ្ងៃក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[988] ។

**២៦០.** ផ្អែកលើភស្តុតាងខាងលើមកនេះ ការសម្រេចផ្លាស់ទីលំនៅប្រជាជនពីភ្នំពេញត្រូវបានធ្វើឡើងជាសំខាន់ដោយ ប៉ុល ពត ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥[989] ជាមួយនឹងផែនការដែលត្រូវបានផ្សព្វផ្សាយរួចហើយ ដើម្បីរៀបចំទទួលប្រជាជនពីភ្នំពេញក្នុងខែជាមួយគ្នានោះដែរ[990]។ ការចូលពាក់ព័ន្ធរបស់សមាជិកមជ្ឈិមបក្ស[991] ទំនងត្រូវបានធ្វើឡើង ក្រោមរូបភាពជាការប្រជុំមួយចំនួននៅចុងខែមីនា ឬដើមខែមេសា ឆ្នាំ១៩៧៥[992] ដោយមានការចូលរួមពី នួន ជា ខៀវ សំផន និង អៀង សារី[993]។ ទោះបីជា អៀង សារី នៅក្រៅប្រទេសនាពេលនោះ មានភស្តុតាងបង្ហាញថា អៀង សារីបានទទួល

00605339



ការទាក់ទងអំពីការសម្រេចនានា ហើយថា អៀង សារី បានពិភាក្សាគ្នារួចហើយអំពីបញ្ហានេះជាមួយនឹង ប៉ុល ពត ក្នុងឆ្នាំ១៩៧៤[994]។ ខណៈនោះក៏មានការប្រជុំជាមួយនឹងកម្មាភិបាលថ្នាក់ក្រោម ដើម្បីផ្សព្វផ្សាយការសម្រេចនេះ[995] ហើយ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនបានទទួលបញ្ជាជាមុន មុនការវាយប្រហារលើទីក្រុងភ្នំពេញ[996] ទោះបីជាអ្នកដទៃទៀតមិនត្រូវបានប្រាប់ឱ្យដឹងមុនពេលទទួលបញ្ជាឱ្យផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងក៏ដោយ[997]។

***

**២៦១.** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៤នាក់ (ប្រាំមួយរយហុកសិបបួននាក់) ត្រូវបានប្រកាសទទួលស្គាល់នៅក្នុងបរិបទនៃការ*ផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី១)* [998]។ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរអោយជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤)។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃការជម្លៀសទីលំនៅប្រជាជនចេញពីភ្នំពេញ-ដំណាក់កាលទី១ ។

## ការផ្លាស់ទីលំនៅប្រជាជន ពីភូមិភាគឧត្តរចាស់/កណ្តាល និរតី បស្ចិម និងបូព៌ា[999]

**<u>ពេលវេលា និងទីកន្លែង</u>**[1000]

**២៦២.** អំឡុងខែកញ្ញា ឆ្នាំ១៩៧៥[1001] និងបន្តដល់ឆ្នាំ១៩៧៦[1002] និងឆ្នាំ១៩៧៧[1003] ប្រជាជនមួយចំនួនធំត្រូវបានផ្លាស់ទីលំនៅពីផ្នែកកណ្តាល និង ផ្នែកនិរតីនៃប្រទេស(បើយោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលនៃបក្សកុម្មុយនីស្តកម្ពុជា)រួមមាន ភូមិភាគកណ្តាល និងភូមិភាគនិរតី និងផ្នែកខ្លះនៃភូមិភាគបស្ចិម និងភូមិភាគបូព៌ាដែលគេស្គាល់ថាមានខេត្ត៖ កណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងកំពង់ចាម[1004]។ ភាគច្រើនក្នុងចំណោមប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅតំបន់ដែលបក្សកុម្មុយនីស្តកម្ពុជាហៅថា តំបន់១០៦(តំបន់សៀមរាប) តំបន់១០៣(ព្រះវិហារ) និងភូមិភាគពាយ័ព្យ (ដែលរួមមានទីតាំងនៅតាមខេត្តបច្ចុប្បន្ននេះដូចជា៖ ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ)[1005] ឬត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់) (ខេត្តកំពង់ធំ និងផ្នែកខ្លះនៃខេត្តកំពង់ចាមបច្ចុប្បន្ន)[1006]។

២៦៣. លើសពីនេះទៀត សក្ខីកម្មខ្លះបង្ហាញអំពីការផ្លាស់ទីលំនៅនៅក្នុងអំឡុងពេលជាមួយគ្នានេះដែរ ដូចជាពីភូមិភាគបូព៌ា[1007] ឬនៅក្នុងភូមិភាគបូព៌ា[1008](ខេត្តព្រៃវែង និងស្វាយរៀង) ទៅកាន់ខេត្តក្រចេះ (តំបន់៥០៥)[1009] នៅក្នុងភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់)[1010] ឬនៅក្នុងខេត្តបាត់ដំបង[1011]។ សាក្សីភាគច្រើននិយាយថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅជាច្រើនលើក[1012] មុននឹងទៅដល់គោលដៅចុងក្រោយរបស់ខ្លួន។ ប្រជាជនទាំងនោះ ជាពិសេសគឺប្រជាជនមួយចំនួនដែលត្រូវបានជម្លៀសពីដំបូងមកពីភ្នំពេញផងដែរ[1013]។

<u>ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ</u>

២៦៤. មានការលំបាកនឹងធ្វើការប៉ាន់ស្មានអំពីចំនួនប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីផ្នែកនីរតី និងផ្នែកកណ្តាលនៃប្រទេសកម្ពុជា ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ រវាងចុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦។ កំណត់ហេតុមួយរបស់គណៈអចិន្ត្រៃយ៍នាខែសីហា ឆ្នាំ១៩៧៥ បានលើកអំពីតម្រូវការបន្ថែមប្រជាជន ៤០០.០០០ ឬ៥០០.០០០ នាក់ ទៅលើចំនួនប្រជាជនដែលមានស្រាប់នៅភូមិភាគពាយ័ព្យ រួមទាំងការបញ្ជូនផងដែរនូវចំនួនប្រជាជនដែលមិនមានកំណត់ចំនួនច្បាស់លាស់ទៅភូមិភាគឧត្តរនៅពេលនោះ[1014]។ យោងតាមឯកសារមួយរបស់ ប.ក.ក នាខែកញ្ញា ឆ្នាំ១៩៧៥ ប្រជាជនចំនួន ៥០០.០០០ នាក់ នឹងត្រូវបានផ្លាស់ទីលំនៅទៅភូមិភាគពាយ័ព្យ ហើយចំនួន ២០.០០០ នាក់ ទៅខេត្តព្រះវិហារ និង អ្នកផ្សេងទៀតទៅខេត្តកំពង់ធំក្នុងភូមិភាគឧត្តរ និងតំបន់មួយចំនួននៃភូមិភាគបូព៌ា[1015]។ ទូរលេខមួយនាខែវិច្ឆិកា ឆ្នាំ១៩៧៥ ("ទូរលេខ១៥") បង្ហាញថា ប្រជាជនចំនួន ៥០.០០០នាក់នឹងត្រូវបានផ្លាស់ទីលំនៅពីភូមិភាគបូព៌ា និងប្រជាជនចាមចំនួន ១០០.០០០ នាក់ នៅសល់ក្នុងភូមិភាគនេះ[1016]។ យោងតាមសក្ខីកម្មរបស់អតីតកម្មករផ្លូវរថភ្លើងបញ្ជាក់ថា ប្រជាជនជាច្រើនពាន់នាក់ទំនងជាត្រូវបានបញ្ជូនតាមរថភ្លើងដោយកាត់តាមភ្នំពេញ ឆ្ពោះទៅគោលដៅនានាក្នុងខេត្តពោធិ៍សាត់ និង បាត់ដំបងនៅក្នុងភូមិភាគពាយ័ព្យ[1017]។

២៦៥. តាមសាក្សីភាគច្រើន(ដែលខ្លះជាអតីតអ្នកត្រូវបានផ្លាស់ទីលំនៅ)[1018] បានឲ្យដឹងថា អ្នកដែលត្រូវបានផ្លាស់ទីលំនៅរួមមាន កុមារ ស្ត្រី មនុស្សចាស់ គ្រួសារទាំងមូល[1019]។ ប្រជាជនមួយចំនួនមានជាប់ទាក់ទងទៅនឹងរបប លន់ នល់[1020]។ ប្រជាជនខ្លះទៀតត្រូវបានចាត់ទុកថាជាប្រជាជន"ថ្មី"[1021] ដូចជាប្រជាជនដែលត្រូវបានជម្លៀសពីដំបូងចេញពីភ្នំពេញជាដើម[1022]។ សាក្សីមួយចំនួននិយាយថាមានតែ"ប្រជាជនថ្មី"តែប៉ុណ្ណោះ ដែលត្រូវបានប្រាប់ឲ្យចាកចេញ[1023]។ សាក្សីម្នាក់ក៏បាននិយាយ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605341



អំពីការផ្លាស់ទីលំនៅរបស់ជនភាគតិចកម្ពុជាក្រោម និងប្រជាជនចិនផងដែរ[1024]។

២៦៦. ជនជាតិចាមមួយចំនួនក៏ស្ថិតក្នុងចំណោមមនុស្សដែលត្រូវបានផ្លាស់ទីលំនៅដែរ[1025] ដោយការផ្លាស់ទីលំនៅប្រជាជនចាមទាំងនេះកើតឡើងនៅចុងឆ្នាំ ១៩៧៥[1026] បន្ទាប់ពីមានការបះបោររបស់ជនជាតិចាមនៅទីតាំងពីរកន្លែងក្នុងភូមិភាគបូព៌ា[1027]។ ជនជាតិចាមជាច្រើនត្រូវបានផ្លាស់ទីលំនៅពីភូមិកំណើតរបស់ខ្លួននៅក្នុងខេត្តកំពង់ចាម[1028] ហើយត្រូវបានបញ្ជូនទៅភូមិផ្សេងៗទៀតនៅក្នុងខេត្តដដែលនេះ[1029]។ អ្នកខ្លះទៀតត្រូវបានបញ្ជូនទៅឆ្ងាយទៅភូមិនានាទូទាំងខេត្តក្រចេះ[1030] កំពង់ធំ[1031] និង បាត់ដំបង[1032]។ ទូរលេខ១៥[1033] និងភស្តុតាងផ្សេងទៀតដែលបានបន្សល់ទុក[1034] បានឱ្យដឹងថា ការសម្រេចមួយត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ហើយក្រោយមកត្រូវបានអនុវត្តដើម្បីផ្លាស់ទីលំនៅប្រជាជនចាមរាប់ពាន់នាក់ទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។

<u>មធ្យោបាយ និងវិធីសាស្ត្រនៃការផ្លាស់ទីលំនៅប្រជាជន</u>

២៦៧. ប្រជាជនត្រូវបានផ្លាស់កន្លែងតាមរថយន្តយោធា ឬរថយន្តស៊ីវិល[1035] រថភ្លើង[1036] ទូក[1037] រទេះគោ[1038] ត្រាក់ទ័រ[1039] និង/ឬ ដោយថ្មើរជើង[1040] ។ នៅក្នុងករណីជាច្រើន ការធ្វើដំណើរត្រូវធ្វើឡើងតាមមធ្យោបាយច្រើនរួមគ្នា អាស្រ័យតាមគោលដៅ[1041]។ សាក្សីភាគច្រើនមានអារម្មណ៍ទទួលរងការគំរាមកំហែង ឬត្រូវបានបង្ខំឱ្យចាកចេញ[1042]។ ប្រជាជនដែលបានគិតថាពួកគេមានជំរើស ក៏នៅតែត្រូវចាកចេញដែរ ដោយភ័យខ្លាចថានឹងត្រូវចាប់ខ្លួន[1043] ឬ សម្លាប់[1044]។ មានសក្ខីកម្មបង្ហាញថា ប្រជាជនមួយចំនួនត្រូវបានចង[1045] ឬ ត្រូវបានភ្ជង់នឹងកាំភ្លើង[1046] ខណៈដែលអ្នកដទៃទៀតបាននិយាយថា ពួកគេមិនត្រូវបានចង[1047] ឬ ទទួលការធ្វើបាប ឬការវាយដំទេ[1048]។ សាក្សីមួយចំនួននិយាយថា ពួកគេត្រូវបានអនុញ្ញាតឱ្យវេចរបស់របរមួយចំនួន ឬចំណីអាហារបន្តិចបន្តួចមុននឹងចាកចេញ[1049]។

២៦៨. ប្រជាជនដែលត្រូវបានផ្លាស់កន្លែង[1050] រួមទាំងជនជាតិចាម[1051] ត្រូវបានចាត់តាំងជាក្រុម។ ប្រជាជនមួយចំនួនត្រូវបានបំបែកពីគ្នានៅពេលចាកចេញ[1052] ឬអំឡុងពេលធ្វើដំណើរ[1053] ឬពេលមកដល់[1054]។ អតីតកម្មាភិបាលមូលដ្ឋានមួយរូបនិយាយថា *"យើងមិនមានគោលការណ៍ហាមមិនឱ្យប្រជាជនថ្មីរស់នៅជាមួយសាច់ញាតិដែលជាអ្នកមូលដ្ឋាននោះទេ"* [1055]។ សាក្សីមួយចំនួនបានរៀបរាប់ថា ប្រជាជនចាមត្រូវបានបំបែកទៅតាមភូមិខ្មែរ[1056] ដោយមានតែប្រជាជន

00605342



ចាមមួយចំនួនតូចប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យរស់នៅតាមភូមិនីមួយៗ[1057]។ សក្ខីកម្មនានាបង្ហាញថា ជនជាតិចាមជា បុរស ស្ត្រី និងកុមារ ត្រូវបានបំបែកពីគ្នា ហើយផ្លាស់ទីលំនៅទៅទីផ្សេងពីគ្នា[1058]។ សាក្សីមួយចំនួននិយាយថា ពួកគេនៅជាមួយគ្រួសាររបស់ខ្លួនគ្រប់ពេលនៃការផ្លាស់ទីលំនៅ[1059] ឬក៏ថា ពួកគេត្រូវបានអនុញ្ញាតឱ្យទៅជួបគ្រួសារវិញនាពេលក្រោយមក[1060]។ សាក្សីមួយចំនួននិយាយថា ខណៈពេលដែលប្រជាជនចាមភាគច្រើនត្រូវបានផ្លាស់ទីលំនៅ ជនជាតិចាមមួយចំនួនតូច ត្រូវបានតម្រូវឱ្យរស់នៅក្នុងភូមិរបស់ខ្លួន ដដែល[1061]។ សាក្សីបីរូបបាននិយាយថា ពួកគេត្រូវបានតម្រូវឱ្យរស់នៅខាងក្រោមផ្ទះប្រជាជនខ្មែរ[1062]។ សាក្សីពីររូបនិយាយថា មនុស្សចាស់ជាជនជាតិចាម និងមេដឹកនាំសាសនានៅក្នុងភូមិរបស់ខ្លួន ត្រូវបានចាប់ខ្លួន និងសម្លាប់មុនពេលការផ្លាស់ទីលំនៅរបស់ប្រជាជនបានចាប់ផ្តើម[1063]។

**២៦៩.** ការធ្វើដំណើរអាចចំណាយពេលមួយថ្ងៃ[1064] ឬច្រើនថ្ងៃ[1065] ដោយមានឈប់នៅតាមផ្លូវ។ ប្រជាជនអាចសម្រាកមួយភ្លែត[1066] មួយយប់[1067] ឬពីរបីថ្ងៃ ឬដល់ទៅមួយសប្តាហ៍[1068] អាស្រ័យតាមចម្ងាយ និងការធ្វើដំណើរ។ ប្រជាជនធ្វើដំណើរទាំងពេលថ្ងៃ និង/ឬពេលយប់[1069] ហើយប្រជាជនភាគច្រើនស្ថិតក្នុងសភាពលំបាកផ្នែករូបកាយយ៉ាងខ្លាំង[1070]។ សាក្សីជាច្រើនបង្ហាញថា ប្រជាជនត្រូវបានដាក់បញ្ជៀតចូលទៅក្នុងទូររថភ្លើង ឡាន ឬទូកដ៏ចង្អៀត[1071]។ ប្រជាជនបានទទួលរបស់តែបន្តិចបន្តួចសម្រាប់ហូប និង ផឹកទឹកតែប៉ុណ្ណោះ[1072] អំឡុងពេលផ្លាស់ទីលំនៅ[1073] ឬពេលដល់គោលដៅ[1074] ខណៈដែលសាក្សីមួយរូបបាននិយាយថា កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានឱ្យនំប៉័ងមុនពេលប្រជាជនត្រូវឱ្យចុះទូក[1075]។ ថ្នាំពេទ្យក៏មានការខ្វះខាតដែរ[1076]។ ប្រជាជនបានស្លាប់មុនពេលធ្វើដំណើរ ឬនៅតាមផ្លូវ[1077] ឬបន្ទាប់ពីការធ្វើដំណើរដោយសារភាពអត់ឃ្លាន[1078] ដោយសារតែប្រជាជនទាំងនោះចាស់ពេក ឬខ្សោយខ្លាំងពេក[1079] ឬក៏ដោយសារជម្ងឺ[1080]។ សាក្សីនានាក៏បាននិយាយដែរថា ការចាប់ខ្លួន[1081] បានកើតឡើងផងដែរនៅអំឡុងពេលនៃការផ្លាស់ទីលំនៅទាំងនេះ។

**២៧០.** ប្រជាជនមួយចំនួនបានបាត់ខ្លួននៅអំឡុងនៃការផ្លាស់ទីលំនៅនេះ[1082]។ សាក្សីម្នាក់ពន្យល់ថា គាត់ត្រូវបានគេប្រាប់នៅក្នុងអង្គប្រជុំមួយថា អ្នកដែលមិនព្រមចាកចេញនឹងត្រូវគេបញ្ជូនទៅអប់រំ ហើយអ្នកទាំងនោះមិនដែលឃើញត្រឡប់មកវិញឡើយ[1083]។

**២៧១.** មានសក្ខីកម្មស៊ីសង្វាក់គ្នាបង្ហាញថា កម្មាភិបាលដឹកនាំបក្សនៅតាមមូលដ្ឋាន ជាអ្នកទទួលបន្ទុក

00605343



អនុវត្តការផ្លាស់ទីលំនៅ ទាំងនៅដំណាក់កាលចាកចេញ និងដំណាក់កាលមកដល់[1084]។ នៅពេលចាប់ផ្ដើមចាកចេញ កម្មាភិបាលទាំងនោះបានទទួលការណែនាំពីថ្នាក់លើ[1085] ទោះបីជាយ៉ាងណា មានសាក្សីមួយរូបនិយាយថា ការសម្រេចជ្រើសរើសអ្នកភូមិដែលត្រូវផ្លាស់ទីលំនៅ ត្រូវបានធ្វើឡើងដោយសម្ងាត់ ដោយប្រធានកងអនុសេនាតូច[1086]។ ប្រជាជនដែលសួរនាំច្រើនអាចត្រូវបានគំរាម[1087]។ យោងតាមសាក្សីមួយចំនួន កម្មាភិបាលបក្សនៅតាមមូលដ្ឋានបានទទួលនូវបញ្ជីឈ្មោះ[1088] ហើយបានរៀបចំកិច្ចប្រជុំដើម្បីហៅឈ្មោះទាំងនោះដោយសំឡេងខ្លាំងៗ[1089] និងដើម្បីកំណត់អំពីរបៀបដឹកជញ្ជូនប្រជាជនផងដែរ[1090] ។

**២៧២.** កងទ័ព កងឈ្លប ឬកងសន្តិសុខបានឃ្លាំមើលការផ្លាស់ទីលំនៅទាំងនេះ។ សាក្សីភាគច្រើនបានលើកឡើងអំពីវត្តមានរបស់កងកម្លាំងទាំងនេះនៅគ្រប់ដំណាក់កាលនៃការផ្លាស់ទីលំនៅ៖ ដោយឃ្លាំមើលតាំងពីពេលចាប់ផ្ដើមចេញដំណើរ[1091] អំឡុងពេលធ្វើដំណើរ[1092] ដើម្បីយាមប្រជាជននៅលើទូក[1093] នៅតាមរថយន្ត[1094] តាមរថភ្លើង[1095] ឬរទេះគោ[1096] និងរហូតដល់គោលដៅ[1097]។ ផ្ទុយទៅវិញ សាក្សីពីរបីនាក់បានប្រាប់ថា ពួកគេមិនត្រូវបានអមដំណើរជានិច្ចកាលដោយកម្លាំងប្រដាប់អាវុធឡើយ[1098]។

**២៧៣.** នៅខេត្តបាត់ដំបង ឬពោធិ៍សាត់ អ្នកដែលត្រូវបានផ្លាស់ទីលំនៅភាគច្រើនបានមកដល់តាមរថភ្លើង។ មានអង្គភាពចាត់តាំងនៃបណ្ដាញផ្លូវរថភ្លើងច្បាស់លាស់តាមឋានានុក្រម ដោយមានអង្គភាពរថភ្លើងនៅភ្នំពេញ[1099]ជាអ្នកមើលការខុសត្រូវពីលើ។ អតីតកម្មករផ្លូវរថភ្លើងមួយរូបនៅខេត្តបាត់ដំបងប្រាប់ថា រថភ្លើងទាំងនោះត្រូវបានអមដោយកងទ័ពប្រដាប់អាវុធ ហើយថា កងឈ្លបជាអ្នកទទួលបន្ទុកបន្ទាប់ពីរថភ្លើងបានមកដល់។ តាមការយល់ឃើញរបស់គាត់គឺថា *"ការដឹកជញ្ជូនទាំងអស់ហ្នឹង រៀបចំដោយថ្នាក់លើ"*[1100]។ អតីតកម្មករផ្លូវរថភ្លើងពីររូបផ្សេងទៀតបានពន្យល់ថា កងទ័ពបីនាក់ ជាអ្នកគ្រប់គ្រងបណ្ដាញទំនាក់ទំនងរបស់ស្ថានីយរថភ្លើងខេត្តពោធិ៍សាត់[1101] និងខេត្តបាត់ដំបង[1102]។ យោងតាមសាក្សីនានាដែលបានធ្វើការនៅស្ថានីយរថភ្លើងនៅខេត្តបាត់ដំបង[1103] និងខេត្តពោធិ៍សាត់[1104] កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលទទួលបន្ទុកតាមស្ថានីយរថភ្លើងរាយការណ៍ផ្ទាល់ទៅអង្គភាពរថភ្លើងនៅភ្នំពេញ។ លើសពីនេះទៀត សាក្សីមួយរូបក្នុងចំណោមសាក្សីទាំងនោះពន្យល់ថា ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តមួយរូប កម្មាភិបាលទទួលបន្ទុកនៅស្ថានីយខេត្តពោធិ៍សាត់បានចូលរួមវគ្គរៀនសូត្រនៅភ្នំពេញ[1105] ហើយសាក្សីរូបនេះអះអាងបញ្ជាក់ថា ដូច្នេះ មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាត្រូវបានជូនដំណឹងអំពីការផ្លាស់ទីលំនៅ

ទាំងនេះជាប្រចាំ។

២៧៤. កម្មាភិបាលដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅមូលដ្ឋានបានទទួលប្រជាជនដែលផ្លាស់ទីលំនៅ[1106] ហើយរៀបចំអ្នកទាំងនោះឱ្យទៅតាមសហករណ៍[1107]។ សាក្សីមួយចំនួននិយាយថា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានសួរអំពីជីវប្រវត្តិរបស់ពួកគេពេលទៅដល់គោលដៅ[1108]។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបាននិយាយថា មានពេលមួយគាត់ត្រូវបានផ្តល់ឱកាសឱ្យជ្រើសរើសសហករណ៍ដែលគាត់ចង់ទៅ[1109] ដោយគូសបញ្ជាក់ផងដែរថា ក្រោយមក គាត់ត្រូវបានបញ្ជូនឱ្យទៅរៀនសូត្របន្ទាប់ពីការចាប់ខ្លួនប្តី របស់គាត់[1110]។ ចំពោះប្រជាជនដែលត្រូវបានបញ្ជូនទៅផ្ទៃកណ្តាលនៃប្រទេស[1111] ឬទៅខេត្តក្រចេះ[1112] សាក្សីដែលពាក់ព័ន្ធបានផ្តល់សក្ខីកម្មប្រហាក់ប្រហែលគ្នា។

## ការវិលត្រឡប់មកវិញ

២៧៥. ប្រជាជនភាគច្រើនដែលត្រូវបានផ្លាស់ទីលំនៅ ហើយនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ បានត្រឡប់ទៅផ្ទះ ឬភូមិកំណើតរបស់ខ្លួនវិញភ្លាមៗតាមដែលពួកគេអាចធ្វើបាន[1113]។ សាក្សីមួយចំនួនបានឃើញភូមិពីមុនរបស់ខ្លួនស្ងាត់ជ្រងំ[1114] ផ្ទះបាក់បែក និងរណ្តៅសាកសពជាច្រើន[1115]។ សក្ខីកម្មនានាបង្ហាញថា នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានករណីដែលគេអនុញ្ញាតឱ្យប្រជាជនត្រឡប់មកភូមិកំណើតរបស់ខ្លួនឡើយ[1116]។

## មូលហេតុដែលលើកឡើងដើម្បីផ្លាស់ទីលំនៅប្រជាជន

២៧៦. កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍នាខែសីហា ឆ្នាំ១៩៧៥ បានលើកឡើងអំពីដំណើរទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅភូមិភាគពាយ័ព្យ[1117]។ កំណត់ហេតុនេះបញ្ជាក់អំពីតម្រូវការដើម្បីបង្កើនផលិតកម្មស្រូវនៅក្នុងភូមិភាគពាយ័ព្យទាំងមូលដោយ *"អង្គការ"* បានផ្តល់ការណែនាំ ហើយក្នុងនោះមានការណែនាំអំពីបញ្ហាសេដ្ឋកិច្ច និងការបង្កបង្កើនផលដោយឱ្យដឹងថា ភូមិភាគឧត្តរនិងពាយ័ព្យមាន *"លក្ខណៈសម្បត្តិល្អច្រើនជាងគេ"*មានដូចជា ដីស្រែ និងស្រូវមានគុណភាពល្អ អាចចិញ្ចឹម *"ប្រជាជន-ថ្មី"*បាន[1118]។ កំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍នាខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៦ និងឯកសារផែនការ៤ឆ្នាំបក្សកុម្មុយនីស្តកម្ពុជា[1119] ជំរុញឱ្យមានការផ្តោតលើកិច្ចប្រឹងប្រែងស្តីពីផលិតកម្មស្រូវ។

**២៧៧.** សាក្សីមួយចំនួនដែលជាអតីតអ្នកផ្លាស់ទីលំនៅបាននិយាយថា ពួកគេត្រូវបានប្រាប់ និងត្រូវបញ្ជូនទៅតំបន់មួយដែលមានអាហារសម្បូរជាង[1120] និងដីមានជីជាតិជាងសម្រាប់ការដាំដុះ[1121] ឬជាទីកន្លែងដែលខ្វះកម្លាំង[1122]។ សាក្សីមួយរូបនិយាយថា ប្រជាជនត្រូវបានប្រាប់ថា ពួកគេត្រូវតែធ្វើការឲ្យរបបសង្គមនិយម[1123]។ នៅពេលមកដល់គោលដៅ ប្រជាជនត្រូវបានបញ្ជូនទៅធ្វើការក្នុងសហករណ៍[1124] កសាងទំនប់ និងព្រែកជីក[1125] ឬធ្វើស្រែ[1126]។

**២៧៨.** អតីតកម្មាភិបាលមូលដ្ឋានបក្សកុម្មុយនីស្តកម្ពុជាមួយរូបបានពន្យល់ថា *"គោលការណ៍មជ្ឈិមត្រូវដកប្រជាជនថ្មីចេញពីបូព៌ានៅពេលដែលមានសង្គ្រាមជាមួយវៀតណាមនៅចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ (...) ដោយសារមានសង្គ្រាមព្រំដែនទើបប្រជាជនថ្មីត្រូវជម្លៀសចេញ"*[1127]។

## ការរៀបចំផែនការ

**២៧៩.** សក្ខីកម្មរបស់សាក្សី[1128] និងឯកសារ[1129] ចង្អុលបង្ហាញភស្តុតាងអំពីរបៀបដែលមជ្ឈិមជាប់ពាក់ព័ន្ធនៅក្នុងការផ្លាស់ទីលំនៅទាំងនេះ។ ការសម្រេចបញ្ជូនប្រជាជនទៅភូមិភាគឧត្តរ និងពាយ័ព្យនៃប្រទេស ទំនងជាត្រូវបានធ្វើឡើង បន្ទាប់ពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាទៅតំបន់នោះ ក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៥[1130] ហើយឯកសារមួយរបស់ ប.ក.ក នាខែកញ្ញា ឆ្នាំ១៩៧៥[1131] បានលើកឡើងអំពីការអនុវត្តសេចក្តីសម្រេចនោះ។

**២៨០.** ទូរលេខ១៥ នាខែវិច្ឆិកា ឆ្នាំ១៩៧៥[1132] រៀបរាប់អំពីសេចក្តីសម្រេចមួយដែលចេញដោយថ្នាក់លើរបស់ ប.ក.ក ទាក់ទងនឹងការផ្លាស់ទីលំនៅទាំងនេះ ហើយបើយោងតាមសក្ខីកម្មរបស់សាក្សីជាច្រើនដែលស៊ីសង្វាក់គ្នា សេចក្តីសម្រេចនេះត្រូវបានអនុវត្តតាមនាពេលបន្ទាប់មក។ ទូរលេខនេះត្រូវបានបញ្ជូនដោយ ឆុន ទៅ ប៉ុល ពត ហើយចម្លងជូន នួន ជា, បងឌឿន [លេខាមន្ទីរនយោបាយ៨៧០] និងបង [លុប] [មន្ទីរ៨៧០]។ សាក្សីមួយរូបដែលធ្លាប់បានបកប្រែទូរលេខនានាឲ្យមន្ទីរ ក-១ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និយាយថា ប្រធានក្រុមទូរលេខបានសម្រេចចម្លងទូរលេខនេះជូន នួន ជា ដោយបញ្ជាក់ថា *"ជាដំបូងសារទូរលេខនេះ គឺបញ្ជូនទៅតែ ប៉ុល ពត ម្នាក់គត់ ប៉ុន្តែដោយសារអ្នកគ្រប់គ្រងសារទូរលេខ គាត់ដឹងថា បញ្ហានេះគឺត្រូវបញ្ជូនទៅអ្នកទទួលខុសត្រូវខាងប្រជាជនដើម្បីដោះស្រាយ ដូចជា នួន ជា ជាដើមនេះ"*[1133]។ សាក្សីរូបនេះនិយាយដែរថា គណៈអចិន្ត្រៃយ៍អាចមានជាប់ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហានេះដែរ[1134]។ សាក្សីមួយរូបទៀតដែលជាអតីតប្រធានក្រុមទូរលេខ ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) បាន

00605346



ពន្យល់ថា “ [ភូមិភាគបូព៌ា] *ត្រូវបញ្ជូនរបាយការណ៍ពីភូមិភាគទៅ ប៉ុល ពត ផ្ទាក់មជ្ឈិមសិន និងរង់ចាំ ប៉ុល ពត ណែនាំ។ កែ ពក* [លេខាភូមិភាគឧត្តរចាស់/កណ្ដាល] *ទទួលសារទូរលេខរឿងនេះមកពីមជ្ឈិម គឺមិនមែនទទួលផ្ទាល់មកពីខាងបូព៌ានោះទេ”*[1135] ។

**២៨១.** ទូរលេខ១៥ បង្ហាញជាសំខាន់អំពីបញ្ហាមួយដែលកើតឡើងពីការផ្លាស់ទីលំនៅប្រជាជនចាម ដោយឱ្យ ដឹងថា *“ដូច្នេះប្រ.ជអ៊ីស្លាមនៅសល់ក្នុងភ.ភបូព៌ាជាង១សែននាក់ទៀត។ (...) ដកនេះជាគោលការណ៍ បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ។ តែបើឧត្តរមិនព្រមទទួល យើងខ្ញុំក៏ស៊ូទ្រាំក្ដោបក្ដាប់ប្រ.ជអ៊ីស្លាមតទៅទៀតដែរ គ្មានបញ្ហាអ្វីទេ”*[1136] ។ ហេតុការណ៍នេះកើតឡើងប៉ុន្មានសប្ដាហ៍បន្ទាប់ពីការបះបោររបស់ប្រជាជនចាមនៅកោះផល និងស្វាយឃ្លាំង[1137]។ នៅក្នុងបរិបទដូច្នេះ ភស្ដុតាងនេះអាចបង្ហាញថា មូលហេតុចម្បងចំពោះការផ្លាស់កន្លែង និងការបំបែកប្រជាជនចាមតាមការគ្រោងទុក គឺជាការដោះស្រាយបញ្ហាគំរាមកំហែងផ្នែកសន្ដិសុខដែលមានជាមួយប្រជាជនចាមព្រមទាំងជាការឆ្លុះបញ្ចាំងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ដើម្បី *“បំបែក”* ប្រជាជនចាម។

***

**២៨២.** ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣៥៤នាក់ (បីរយហាសិបបួននាក់) ត្រូវបានប្រកាសទទួលស្គាល់នៅក្នុងបរិបទនៃ *ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្ដាល និងភូមិភាគនិរតីនៃប្រទេសទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ (ដំណាក់កាលទី២)* ។[1138] ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្ដុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤)។ ដើមបណ្ដឹងរប្បវេណីទាំងនេះបានផ្ដល់ភស្ដុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃ *ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្ដាល និងភូមិភាគនិរតីនៃប្រទេសទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ-ដំណាក់កាលទី២* ។

00605347



## ការផ្លាស់ទីកន្លែងប្រជាជនពីភូមិភាគបូព៌ា - ដំណាក់កាលទី៣[1139]

### ពេលវេលា និងទីកន្លែង

២៨៣. ចាប់ពីចុងឆ្នាំ១៩៧៧[1140] និងបន្តរហូតដល់ឆ្នាំ១៩៧៨[1141] ប្រជាជនជាច្រើនដែលរស់នៅភូមិភាគបូព៌ាដែលជាភូមិភាគកំណត់ដោយប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់ ប.ក.ក ត្រូវបានផ្លាស់ទីលំនៅពីភូមិភាគនេះ។ តាមការបំភ្លឺរបស់សាក្សីជាច្រើន បង្ហាញថាដំណើរការផ្លាស់ទីលំនៅបានចាប់ផ្តើមនៅក្នុងបរិបទនៃការបោសសំអាតដែលកើនឡើង នៅក្នុងភូមិភាគបូព៌ា[1142]។

២៨៤. សក្ខីកម្មរបស់សាក្សី និងឯកសារភស្តុតាងបង្ហាញឱ្យឃើញជាពិសេសទាក់ទងនឹងការផ្លាស់ទីលំនៅមនុស្សពីបណ្តាខេត្តនៃភូមិភាគបូព៌ាមានដូចជា៖ ខេត្តព្រៃវែង[1143] ខេត្តស្វាយរៀង[1144] និងខេត្តកំពង់ចាម (ស្រុកក្រូចឆ្មារ[1145]និងស្រុកពញាក្រែក[1146])។ ចំនួនដ៏ច្រើននៃប្រជាជនទាំងនោះដែលត្រូវបានផ្លាស់ទីលំនៅ មកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ត្រូវបានគេបញ្ជូនទៅកាន់ខេត្តពោធិសាត់[1147] ឬក៏ខេត្តបាត់ដំបង ដែលខេត្តទាំងពីរនេះស្ថិតនៅភូមិភាគពាយ័ព្យ[1148] នៅខណៈពេលដែលអ្នកត្រូវផ្លាស់ទីលំនៅមកពីខេត្តកំពង់ចាមមួយចំនួនទំនងជាត្រូវបានបញ្ជូនទៅកាន់ខេត្តកំពង់ធំ ស្ថិតនៅភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់)[1149]។ នៅក្នុងកំឡុងពេលដូចគ្នានេះមានភស្តុតាងផងដែរបង្ហាញអំពីការផ្លាស់កងទ័ពពីភូមិភាគ-បូព៌ាទៅកាន់ខេត្តកំពង់ឆ្នាំង នៅក្នុងភូមិភាគបស្ចិម[1150]។ នៅក្នុងថ្ងៃចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ មានភស្តុតាងបង្ហាញអំពីការផ្លាស់ទីលំនៅប្រជាជនស៊ីវិលដែលនៅសេសសល់ យ៉ាងហោចណាស់ពីកន្លែងផ្សេងៗនៅក្នុងភូមិភាគបូព៌ា ទៅកាន់កន្លែងដ៏ទៃទៀត រាប់បញ្ចូលទាំងភូមិភាគពាយ័ព្យ[1151]។

### ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ

២៨៥. ពាក់ព័ន្ធនឹងប្រភេទមនុស្សដែលត្រូវបានផ្លាស់ទីលំនៅ ភស្តុតាងដ៏ច្រើនបានបង្ហាញថាអ្នកដែលត្រូវផ្លាស់ទីលំនៅគឺមានទាំងកម្មាភិបាល និងកងទ័ព ប.ក.ក[1152] ឬប្រជាជនដែលត្រូវបានគេចោទប្រកាន់ថាក្បត់ ឬសមាសភាពមិនល្អ[1153] ឬខ្មែរយៈវៀតណាម ("យួន")[1154] ឬពាក់ព័ន្ធជាមួយលេខាភូមិភាគបូព៌ាដែលត្រូវបានគេបោសសម្អាតឈ្មោះ សោ ភឹម[1155]។ មានភស្តុតាងផងដែរទាក់ទិននឹងប្រជាជនដែលមានទំនាក់ទំនងនឹងអតីតរបបសីហនុ[1156] ឬរបបសាធារណៈរដ្ឋខ្មែរ[1157] និង/ឬ អ្នកទាំងឡាយណាដែលគេចាត់ទុកថាជា"ប្រជាជនថ្មី"[1158] ដែលពីមុនមកធ្លាប់ជម្លៀសមកពីទីក្រុងភ្នំពេញ និងបណ្តាទីប្រជុំជននានា ដូចជាពីខេត្តស្វាយរៀង[1159] ព្រមទាំងព្រះសង្ឃ[1160] ជនជាតិចាម[1161] កូនកាត់ចិន[1162] និងប្រជាជនដើមកំណើតវៀតណាម[1163]។ ក្នុងចំណោមអ្នក

ត្រូវបានគេជម្លៀសទាំងនោះមានទាំងយុវជន មនុស្សចាស់ ស្ត្រី បុរស និងក្មេង[1164]។

## មធ្យោបាយ និង វិធីសាស្ត្រនៃការផ្លាស់ទីលំនៅ

**២៨៦.** ជាទូទៅ ដំបូងប្រជាជនត្រូវបានគេហៅទៅប្រជុំ (ជាញឹកញាប់ការប្រជុំត្រូវបានកោះហៅដោយកម្មាភិបាលមូលដ្ឋានដែលទើបបានតែងតាំងថ្មីៗ[1165]) ដែលនៅពេលប្រជុំនោះប្រជាជនត្រូវបានគេនិយាយប្រាប់ថាពួកគេត្រូវតែចាកចេញ ឬថា *"អង្គការ"* បានសម្រេចផ្លាស់ទីលំនៅទៅកាន់កន្លែងផ្សេង[1166]។ លើកលែងតែករណីខ្លះ[1167] សាក្សីបញ្ជាក់ថា ជាទូទៅប្រជាជនមិនត្រូវបានគេចងទេ[1168]។ សាក្សីខ្លះទៀតប្រាប់ថាពួកគាត់អាចវេចខ្ចប់របស់របរផ្ទាល់ខ្លួនមុនពេលចេញដំណើរ[1169]។ សាក្សីភាគច្រើនពិពណ៌នាថាពួកគាត់ត្រូវបានគេបង្ខំឱ្យចាកចេញ[1170] និងសាក្សីផ្សេងទៀតរៀបរាប់ថា អ្នកទាំងឡាយណាដែលព្យាយាមគេចវេស នឹងត្រូវបាញ់សម្លាប់ចោល[1171]។

**២៨៧.** សាក្សីបានគូសបញ្ជាក់ថា មិនមែនប្រជាជនគ្រប់រូបត្រូវតែផ្លាស់ទីលំនៅនោះទេ បន្ទាប់ពីការតែងតាំងអ្នកថ្មីជំនួសកម្មាភិបាលភូមិភាគបូព៌ា៖ សាក្សីមួយចំនួនទៀតបានរៀបរាប់អំពីដំណាក់កាលនៃការផ្លាស់ទីលំនៅជាបន្តបន្ទាប់[1172] សាក្សីផ្សេងទៀតបានប្រាប់ថាមានប្រជាជនខ្លះអាចបន្តរស់នៅក្នុងភូមិ ឬសហករណ៍នានា។ ក្នុងចំណោមប្រជាជនទាំងនោះមានដូចជា៖ ប្រជាជនមូលដ្ឋាន ឬសមាជិកកងចល័ត[1173] ព្រមទាំង*"អ្នកជាប់សាច់ញាតិជាមួយឈ្លបភូមិឃុំ"*[1174] និងយ៉ាងហោចណាស់ក៏មានគ្រួសារចាមមួយគ្រួសារនៅស្រុកក្រូចឆ្មាផងដែរ[1175]។

**២៨៨.** ក្នុងករណីភាគច្រើន មានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនចម្រុះ អាស្រ័យទៅតាមចម្ងាយផ្លូវដែលត្រូវធ្វើដំណើរទៅកាន់គោលដៅចុងក្រោយ៖ មធ្យោបាយទាំងនោះរួមមាន ការដឹកជញ្ជូនតាមរថយន្តយោធា ឬស៊ីវិល[1176] រទេះគោ[1177] កប៉ាល់[1178] រថភ្លើង[1179] ឬធ្វើរដើង[1180]។ មធ្យោបាយដឹកជញ្ជូនជាទូទៅគឺត្រូវបានរៀបចំជាមុន និងជាស្រេចចាំទទួលអ្នកត្រូវផ្លាស់ទីលំនៅ[1181]។

**២៨៩.** ភស្តុតាងបានបង្ហាញថាប្រជាជនដែលបានផ្លាស់ទីលំនៅមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀងបានធ្វើដំណើរតាមផ្លូវជាទូទៅតែមួយ។ ជាដំបូង អ្នកទាំងនោះត្រូវដើរ[1182] ឬ ដឹកតាមរទេះគោ[1183] ចេញពីភូមិរបស់ខ្លួនមកកាន់អ្នកលឿង[1184] (ដែលជាកន្លែងដែលផ្លូវជាតិលេខ១ ប្រសព្វនឹងទន្លេមេគង្គ នៅក្នុងខេត្តព្រៃវែង ក្នុងតំបន់២៤) បន្ទាប់មកពួកគេឡើងកប៉ាល់[1185] ដែលកប៉ាល់

បានដឹកពួកគេតាមទន្លេមេគង្គមកកាន់ភ្នំពេញ។ អ្នកដែលត្រូវគេផ្លាស់ទីលំនៅភាគច្រើនបានចុះកប៉ាល់នៅច្បារអំពៅ ឬតំបន់ជិតនោះ ដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ[1186]។ សាក្សីមួយចំនួនបានគូសបញ្ជាក់ថា នៅពេលមកដល់ភ្នំពេញ ពួកគាត់ត្រូវបានគេផ្តល់ម្ហូបអាហារ[1187] និង/ឬ ក្រមាឆ្នូតពណ៌ខៀវស[1188]។ អតីតកម្មាភិបាល ប.ក.ក ម្នាក់របស់ក្រសួងឃោសនាការ និងសិក្សាអប់រំ បានរៀបរាប់ថា នៅពេលសម្រាករងចាំនៅក្នុងទីក្រុងភ្នំពេញ ប្រជាជនមកពីខេត្តស្វាយរៀង និងខេត្តព្រៃវែងគេឱ្យមើលកុន *“កុនទាំងនោះភាគច្រើនទាក់ទងនឹងសមរភូមិ និងកុនចិនទាក់ទងនឹងការតស៊ូ”* [1189]”។ ការបញ្ចាំងកុនឱ្យមើលនេះ បានអះអាងបញ្ជាក់ដោយសាក្សីម្នាក់ដែលគាត់ត្រូវបានជម្លៀសមកពីខេត្តព្រៃវែង ទៅកាន់ខេត្តពោធិសាត់ ដែលគាត់បានប្រាប់ថា គាត់បានមើលកុនឃោសនាគេបញ្ចាំងឱ្យមើល នៅពេលដែលគាត់នៅភ្នំពេញ[1190]។ បន្ទាប់មកប្រជាជនដែលត្រូវបានគេផ្លាស់ទីលំនៅត្រូវបានដឹកតាមរថយន្ត[1191] ទៅកាន់ស្ថានីយ៍រថភ្លើងភ្នំពេញ ដែលជាកន្លែងពួកគេត្រូវឡើងជិះរថភ្លើង ដើម្បីចាកចេញទៅកាន់ខេត្តពោធិសាត់ និងខេត្តបាត់ដំបង[1192] ដែលនៅតាមផ្លូវបានឈប់សម្រាកជាច្រើនកន្លែង។

**២៩០.** ស្របពេលជាមួយគ្នានោះ នៅក្នុងអំឡុងពេលដូចគ្នា មានភស្តុតាងបង្ហាញថាកងទ័ពភូមិភាគបូព៌ាជាច្រើនត្រូវបានផ្លាស់៖ តួយ៉ាងកងទ័ពគ្មានអាវុធចំនួន ៥០០០ នាក់ ត្រូវបានដឹកមកពីខេត្តស្វាយរៀងតាមឡានកងទ័ពឆ្ពោះទៅកាន់ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដោយឆ្លងកាត់តាមភ្នំពេញ[1193]។

**២៩១.** អ្នកដែលត្រូវបានគេផ្លាស់ទីលំនៅពីភូមិភាគបូព៌ាមានចំនួនដ៏ច្រើនបានបាត់ខ្លួន[1194] ឬ ស្លាប់ក្នុងអំឡុងពេលផ្លាស់ទីលំនៅដោយសារស្ថានភាពនៃការធ្វើដំណើរមានការលំបាក[1195]។ សាក្សីម្នាក់បានអះអាងផងដែរថា៖ *“...អ្នករឹងទទឹង (ប្រឆាំងជាមួយទាហានខ្មែរក្រហម) គឺត្រូវបានទាហានខ្មែរក្រហមបាញ់ចោលតែម្តង”*[1196]។ ឯសាក្សីផ្សេងទៀតបានរៀបរាប់ថាអ្នកត្រូវបានគេផ្លាស់ទីលំនៅទាំងនេះមិនបានទទួលទាំងអាហារ និងទឹកក្នុងពេលធ្វើដំណើរទេ[1197]។

**២៩២.** ចំពោះប្រជាជនដែលបានដឹកតាមរថភ្លើងឆ្ពោះទៅកាន់ខេត្តពោធិសាត់ និងខេត្តបាត់ដំបង សាក្សីម្នាក់បានរៀបរាប់ថា *“នៅពេលគេទៅដល់ខេត្ត ពួកគេត្រូវបានធ្វើប្រវត្តិរូប។ តាមប្រវត្តិរូបផ្ទាល់ខ្លួនរបស់ពួកគេ ពួកគេត្រូវបានបញ្ជូនទៅតាមទីតាំងផ្សេងៗ”*[1198]។ ភាគច្រើនប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅតាមសហករណ៍ ឬការដ្ឋាននានា[1199]។ ពួកគេត្រូវបានតម្រូវឱ្យធ្វើការងារដូចជា៖ ដឹក

អាង[1200] និង/ឬជួយធ្វើស្រែ[1201]។ សាក្សីទាំងអស់បានរៀបរាប់ប្រាប់អំពីការងារ និងលក្ខខណ្ឌរស់នៅលំបាក[1202]។ អ្នកត្រូវបានគេផ្លាស់ទីលំនៅភាគច្រើនបានរំលឹកឡើងវិញថា ពួកគាត់ត្រូវបានគេឱ្យរស់នៅ និងធ្វើការងារដោយឡែកពីប្រជាជនមូលដ្ឋាន[1203] (ទោះបីជាមាន សាក្សីម្នាក់នៅខេត្តពោធិ៍សាត់បានរៀបរាប់ថា អ្នកត្រូវបានជម្លៀស *"...រស់នៅ ធ្វើការងារ និងហូប ចុកដូចប្រជាជននៅមូលដ្ឋាននេះដែរ")* [1204]។ ជាចុងក្រោយ នៅមុនការចូលមកដល់របស់ វៀតណាម មានភស្តុតាងបង្ហាញថាប្រជាជនដែលត្រូវបានគេផ្លាស់ទីលំនៅមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀងត្រូវបានប្រមូលផ្តុំមកពីការដ្ឋានការងារដែលនៅជិតនោះ និងត្រូវបានបញ្ជូនទៅវត្តរំលេចក្នុងស្រុកបាកានលើ(ក្នុងតំបន់២ របស់ភូមិភាគពាយ័ព្យ[1205]) ដែល នៅកន្លែងនោះហើយដែលពួកគេត្រូវបានបាញ់សម្លាប់[1206]។

២៩៣. អ្នកត្រូវគេផ្លាស់ទីលំនៅខ្លះត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខ[1207] ដែលនៅទីនោះពួកគេត្រូវ បានឃុំឃាំង[1208] ធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរ[1209] ឬយកទៅសម្លាប់នៅទីកន្លែងសម្លាប់មនុស្ស តែម្តង[1210]។ សាក្សីម្នាក់បានពិពណ៌នាអំពីស្ថានភាពដែលឪពុករបស់គាត់ត្រូវបានគេសម្លាប់នៅ ខេត្តពោធិ៍សាត់ និងរឿងដែលគាត់ហៀបនឹងត្រូវបានគេសម្លាប់ផងដែរ ប្រសិនបើម្តាយរបស់គាត់មិន បានតវ៉ា ដោយនិយាយថា *"គាត់មានបងប្អូន ដែលធ្វើការឱ្យកម្មាភិបាលភូមិភាគនិរតី។ គេឈប់ សម្លាប់គ្រួសារខ្ញុំ ហើយពេលនោះ គេបានដោះលែងគ្រួសារដ៏ទៃទៀតប្រហែលជាង ៣០ គ្រួសារ"* [1211]។ សាក្សីម្នាក់ទៀតបានឃើញអ្នកត្រូវបានគេផ្លាស់ទីលំនៅដែលកំពុងសែងឥវ៉ាន់របស់ខ្លួន ត្រូវ បានបាញ់សម្លាប់ដោយកងទ័ព ប.ក.ក ជិតស្ទឹងពោធិ៍សាត់[1212]។

## ការវិលត្រលប់មកវិញ

២៩៤. ប្រជាជនភាគច្រើនដែលនៅរស់រានមានជីវិតពីការផ្លាស់ទីលំនៅមកពីភូមិភាគបូព៌ា បានត្រឡប់មក កាន់ភូមិរបស់ពួកគេវិញតាមលទ្ធភាពដែលអាចធ្វើទៅបាន[1213]។ មានសាក្សីម្នាក់ដែលត្រូវបានឃុំ ខ្លួនពីរខែដោយវៀតណាម មុនពេលគាត់ត្រឡប់ទៅភូមិកំណើតគាត់វិញ[1214]។ សាក្សីខ្លះដែលបាន ត្រឡប់មកវិញបានឃើញសាកសពនៅរាយពាសពេញតាមដងផ្លូវជាតិ[1215] ឬឃើញរណ្តៅសាកសព ដែលពេញទៅដោយសាកសពរលួយ ឆ្អឹង និងលលាដ៏ក្បាល[1216]។

## មូលហេតុនៃការផ្លាស់ទីកន្លែងប្រជាជន

២៩៥. នៅពេលប្រជុំដែលត្រូវបានគេរៀបចំឡើងមុនការផ្លាស់ទីលំនៅ សាក្សីត្រូវបានគេប្រាប់ជាទូទៅថា

00605351



ពួកគេត្រូវបញ្ជូនទៅកាន់តំបន់ដែលមានអាហារច្រើន និង ដីដែលមានជីជាតិសម្រាប់ការដាំដុះ[1217]។ សាក្សីម្នាក់បានបំភ្លឺថា ខ្លួនគាត់ត្រូវបានគេប្រាប់ឲ្យទៅកាន់ខេត្តពោធិ៍សាត់តាមនយោបាយ "*មហាអស្ចារ្យ មហាលោតផ្លោះ*"[1218]។ សាក្សីម្នាក់ទៀតបានរំលឹកប្រាប់អំពីការថ្លែងរបស់គណៈសហករណ៍ ដែលគាត់បាននិយាយថា "*នៅខេត្តបាត់ដំបងត្រូវការឲ្យមនុស្សទៅធ្វើស្រែ ដើម្បីដោះស្រាយផលប្រយោជន៍ប្រទេសជាតិ*"[1219]។

២៩៦. តាម៉ុក បាននិយាយនៅពេលប្រជុំជាមួយកម្មាភិបាលភូមិភាគពាយ័ព្យ នៅក្នុងខេត្តពោធិ៍សាត់ ដោយចង្អុលបញ្ជាក់ថាការផ្លាស់ទីលំនៅគឺដោយសារមូលហេតុការលុកលុយរបស់វៀតណាមចូលប្រទេសកម្ពុជា និងការក្បត់របស់មេដឹកនាំភូមិភាគបូព៌ាឈ្មោះ សោ ភឹម។ សាក្សីម្នាក់ជាអតីតគណៈសហករណ៍ភូមិរំលេច (នៅក្នុងស្រុកបាកានលើ តំបន់២ របស់ភូមិភាគពាយ័ព្យ) ដែលបានចូលរួមកិច្ចប្រជុំនោះដែរ បានអះអាងថា តាម៉ុក និយាយសំដៅដល់ សោ ភឹម ថាជាជនក្បត់ និងបាននិយាយបញ្ជាក់ថា "*អង្គការ*" នឹងផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ាទៅកាន់ភូមិភាគពាយ័ព្យ។ តាម៉ុក បានបន្ថែមថា ចាំបាច់ត្រូវ"*តាមដានប្រយ័ត្នពួកប្រជាជនបូព៌ាទាំងនោះប្រឆាំងមាគ៌ារបស់បក្ស ព្រោះពួកនោះពេលជម្លៀសពីបូព៌ាដាក់នៅរោងចក្រស្ករសនៅភ្នំពេញ គេឆែកមើលឃើញមានកាំភ្លើងដែលពួកនេះមានខ្សែរយៈជាមួយយួនហើយ*"[1220]។

២៩៧. អតីតកម្មាភិបាល ប.ក.ក ពីររូបបានពន្យល់ថា គោលបំណងនៃការផ្លាស់ទីលំនៅគឺដើម្បីជម្លៀសប្រជាជនចេញពីតំបន់ប្រយុទ្ធគ្នាជាមួយពួកវៀតណាម[1221]។ នេះជាមូលហេតុមួយនៃការផ្លាស់ទីលំនៅប្រជាជនស៊ីវិលលើកចុងក្រោយ ក្នុងពេលដ៏ខ្លីមុនការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ នាចុងឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៩[1222]។ អតីតអ្នកដាំស្លម្នាក់នៅក្នុងមន្ទីរពាណិជ្ជនៅក្រូចឆ្មារប្រាប់ថាការផ្លាស់ទីលំនៅប្រជាជនគឺធ្វើឡើងដើម្បីបញ្ចៀស "*ការប្រយុទ្ធគ្នារវាងពួកភូមិភាគឧត្តរ និងភូមិភាគបូព៌ា*" [1223]។ ការផ្លាស់ទីលំនៅនេះ ទំនងជាមានគោលដៅពីរយ៉ាង៖ គឺយកប្រជាជននៅជិតព្រំដែនទៅកាន់កន្លែងសុវត្ថិភាពជាង និងផ្លាស់ទីលំនៅប្រជាជនដែលមានភាពមន្ទិលសង្ស័យផ្នែកនយោបាយចេញពីភូមិភាគនោះ[1224]។

## ការគ្រប់គ្រង និងការឃ្លាំមើល

២៩៨. សាក្សីជាច្រើនបានបញ្ជាក់ថា កម្មាភិបាលមកពីភូមិភាគនិរតី និងភូមិភាគកណ្ដាល(ភូមិភាគឧត្តរចាស់) (ដែលពួកគេបានបោសសម្អាតពួកកម្មាភិបាលមូលដ្ឋានរបស់ភូមិភាគបូព៌ាពីមុន)

បានចាត់ចែង និងពិនិត្យការផ្លាស់ទីលំនៅ[1225]។ សាក្សីផ្សេងទៀតបាននិយាយថា មានកម្មាភិបាលដែលចូលរួមក្នុងការផ្លាស់ទីលំនៅ គឺជាកម្មាភិបាលដែលនិយាយរដឹន[1226] និង/ឬពួកឈ្លប[1227]។ សាក្សីខ្លះទៀតបានអះអាងថា កម្មាភិបាលមូលដ្ឋានបាននាំអ្នកត្រូវគេផ្លាស់ទីលំនៅមកដល់ត្រឹមអ្នកលឿង[1228]។

២៩៩. ចំពោះការចាត់ចែងអ្នកដែលមកដល់ភូមិភាគពាយ័ព្យ សាក្សីម្នាក់រៀបរាប់អំពីការប្រជុំថ្នាក់ស្រុកធ្វើឡើងនៅក្នុងខេត្តពោធិ៍សាត់ ដើម្បីពិភាក្សាអំពីបញ្ហាផ្សេងៗ[1229]។ កិច្ចប្រជុំដឹកនាំដោយ តាម៉ុក (គណៈកម្មាធិការភូមិភាគពាយ័ព្យ) ជាមួយវត្តមានរបស់ [លុប] (គណៈកម្មាធិការតំបន់) និង [លុប] (គណៈកម្មាធិការស្រុក)។

៣០០. អតីតកម្មកររថភ្លើងបានរៀបរាប់ប្រាប់ថា នៅខេត្តពោធិ៍សាត់ មានកងទ័ពកាន់កាំភ្លើងយាមកាមប្រជាជននៅក្នុងរថភ្លើងដោយបានប្រាប់អ្នកទាំងនោះ *"នៅពេលវេលា និងទីកន្លែងត្រូវចាកចេញពីរថភ្លើងក្នុងទីតាំងផ្សេងៗ"* និង/ឬ ដឹកពួកគេតាមឡានទៅកាន់សហករណ៍នានា[1230]។ បន្ទាប់មកកម្មាភិបាលមូលដ្ឋានរបស់ ប.ក.ក បានចាត់តាំងប្រជាជនឱ្យធ្វើការងារនៅតាមសហករណ៍នានានៅក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង[1231]។

***

៣០១. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន**២១៤នាក់ (ពីរយដប់ប្រាំបួននាក់)** ត្រូវបានប្រកាសទទួលស្គាល់នៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគបូព៌ា (ដំណាក់កាលទី៣)[1232]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បានស្របទៅ និងវិធាន ២៣ ស្ទួន (៤)។ ដើមបណ្ដឹងរប្បវេណីទាំងនេះបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថាព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃការ ផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា (ដំណាក់កាលទី៣) ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

## ខ. ការដ្ឋាន និងសហករណ៍

### សហករណ៍ស្រុកត្រាំកក់[1233]

#### ទីតាំង និងការបង្កើត

៣០២. ស្រុកត្រាំកក់ ខេត្តតាកែវមានឃុំចំនួន៨៖ គូស សំរោង ត្រពាំងធំត្បូង ត្រពាំងធំជើង ត្រាំកក់ ញ៉ែងញ៉ង ស្រែរនោង និងតាភេម។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់ ប.ក.ក ឃុំទាំងនេះស្ថិតនៅក្នុងស្រុក១០៥ តំបន់១៣ ភូមិភាគនិរតី[1234]។

៣០៣. មិនយូរប៉ុន្មានក្រោយឆ្នាំ១៩៧០ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំឱ្យមានអ្នកដែលទទួលខុសត្រូវខាងកសិកម្មក្នុងតំបន់ដែលខ្លួនគ្រប់គ្រងជាបណ្តើរៗ ទៅជាក្រុមសហករណ៍តូចៗដែលក្រោយមកត្រូវបានពង្រីកទៅជាសហករណ៍ភូមិ និងបន្ទាប់មកទៀតប្តូរទៅជាសហករណ៍កម្រិតឃុំ[1235]។ នៅក្នុងសហករណ៍នីមួយៗ ទ្រព្យសម្បត្តិឯកជនមានដូចជាដីស្រែត្រូវបានដកហូតដាក់ជាទ្រព្យសម្បត្តិរួមរបស់រដ្ឋ[1236]។ ដំណើរការនេះកើតមានឡើងជាបន្តបន្ទាប់តាំងពីពេលដំបូងមកម្ល៉េះ។ ឧទាហរណ៍ សាក្សីម្នាក់ ដែលរស់នៅក្នុងឃុំសំរោងបានបញ្ជាក់ថា ក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិឯកជន និងបង្កើតជាកន្លែងហូបបាយរួមគ្នា។ ក៏ប៉ុន្តែ ទើបតែមកដល់ឆ្នាំ១៩៧៦ ដែលប្រជាជនត្រូវបានបែងចែកជាកងធ្វើការងារផ្សេងៗគ្នា[1237]។ ទោះបីជាយ៉ាងនេះក្តី ឃុំទាំងអស់ក្នុងស្រុកត្រាំកក់ទំនងជាត្រូវបានប្តូរទៅជាសហករណ៍នៅខែមេសា ឆ្នាំ១៩៧៧ និងបន្តរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1238]។

#### ដំណើរការប្រព្រឹត្តទៅ

<u>រចនាសម្ព័ន្ធគ្រប់គ្រង និង អ្នកធ្វើការ</u>

៣០៤. មុនឆ្នាំ១៩៧៥ ឃុំក្នុងស្រុកត្រាំកក់មានប្រជាជនមួយផ្នែកធំជាអ្នកមូលដ្ឋាន។ ក៏ប៉ុន្តែ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អតីតអ្នករស់នៅក្នុងទីក្រុងជាច្រើនត្រូវបានបញ្ជូនមកនៅក្នុងស្រុកត្រាំកក់។ អតីតលេខាស្រុកត្រាំកក់ [លុប] បានបំភ្លឺឱ្យដឹងថា តំបន់បានណែនាំគាត់ឱ្យរៀបចំទទួលការមកដល់របស់អ្នកដែលត្រូវបានផ្លាស់ទីលំនៅ។ គាត់បានបន្ថែមថា គាត់បានបញ្ជូនគ្រួសារចំនួនប្រហែលជា៣៥០០ ដល់ ៤០០០គ្រួសារទៅកាន់ភូមិ និងឃុំ ដែលពួកគេត្រូវបានរៀបចំបញ្ចូលទៅជាសហករណ៍[1239]។ បន្ទាប់មក អ្នកដែលត្រូវបានផ្លាស់ទីលំនៅ ដែលបានរស់

00605354



នៅក្នុងស្រុកត្រាំកក់ ត្រូវបានផ្លាស់ពីកន្លែងមួយទៅកន្លែងមួយនៅក្នុងស្រុកទាំងមូល[1240]។

៣០៥. ការរៀបចំប្រជាជនដាក់លាក់នៅតាមសហករណ៍នីមួយៗផ្អែកលើការណែនាំ[1241]។ ប៉ុន្តែ យោងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស សមាជិកត្រូវបានគេបែងចែកជាផ្លូវការជាបីប្រភេទ៖ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនបញ្ញើ។ ប្រភេទទាំងនេះកំណត់វិសាលភាពនៃការចូលរួមក្នុងការចាត់ចែងសហករណ៍[1242]។ ប្រភេទប្រជាជនបញ្ញើ ជាទូទៅរួមមានប្រជាជនដែលត្រូវបានជម្លៀសមកពីភ្នំពេញ និងតំបន់ដទៃទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋការ លន់ នល់ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្រុមនេះត្រូវបានគេដឹងជាទូទៅថា ជា"ប្រជាជនថ្មី"[1243] ឬ "ប្រជាជន ១៧ មេសា"[1244]។ ប្រជាជនថ្មីទាំងនេះ មិនមានសិទ្ធិនយោបាយ ដែលអាចឲ្យអ្នកទាំងនោះធ្វើជាប្រធានកងនៅក្នុងសហករណ៍ទេ[1245]។ សមាជិកសហករណ៍ ជា"ប្រជាជនមូលដ្ឋាន"[1246] អាចជាប្រជាជនពេញសិទ្ធិ ឬត្រៀម។ ប្រជាជនត្រៀមគឺជាប្រជាជនដែលមានសមាជិកគ្រួសារពាក់ព័ន្ធ ឬទំនាក់ទំនងផ្សេងទៀត ឬជាខ្សែរយៈខ្លាំង[1247]។ នៅពាក់កណ្ដាលឆ្នាំ១៩៧៨ ការចាត់ជាប្រភេទទាំងបីត្រូវបានអះអាងថា បានត្រូវលុបបំបាត់ចោល[1248] ប៉ុន្តែជាក់ស្ដែងមិនទាន់មានការលុបបំបាត់ទេ[1249]។

៣០៦. អតីតអ្នកធ្វើការជាច្រើនអ្នកបានរៀបរាប់ថា ក្នុងសហករណ៍របស់ពួកគេ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងបញ្ញើ ត្រូវបានបែងចែកទៅតាមកងការងារផ្សេងៗគ្នា ដែលមានកងទី១ កងទី២ និងកងទីបី ទៅតាមលំដាប់លំដោយ[1250]។ មនុស្សត្រូវបានចាត់ជាកងផ្អែកទៅតាមអ្វីដែលគេដឹងតាមរយៈប្រវត្តិរូបរបស់អ្នកទាំងនោះ[1251]។ ប្រជាជនបញ្ញើត្រូវបានគ្រប់គ្រងដោយសមាជិកនៃប្រជាជនត្រៀម និងពេញសិទ្ធ ស្របទៅតាមគោលនយោបាយដំបូងថា ប្រជាជនថ្មីមិនអាចត្រូវបានអនុញ្ញាតឲ្យធ្វើជាប្រធានកងឡើយ[1252]។ ក្នុងឃុំញ៉ែងញ៉ង ប្រជាជនប្រភេទទាំងបីនេះរស់នៅ និងធ្វើការផ្សេងពីគ្នារហូតដល់ឆ្នាំ១៩៧៨ គឺពេលដែលពួកគេត្រូវបានដាក់បញ្ចូលគ្នា[1253] ដែលទំនងជាផ្អែកតាមគោលនយោបាយលុបបំបាត់ប្រភេទទាំងបីនេះនៅទូទាំងប្រទេស[1254]។ កងនីមួយៗមានកងតូចជាច្រើនដូចជា កងជាងឈើ ជីកប្រឡាយ និងបររទេះ[1255]។ ក្នុងកងនីមួយៗ ប្រធានកងរាយការណ៍ឲ្យទៅគណៈឃុំ ដែលត្រូវរាយការណ៍ទៅគណៈស្រុក[1256]។ ជាធម្មតា និរសាជាអ្នកបញ្ជូនឯកសាររវាងអង្គភាពផ្សេងៗ រួមបញ្ចូលការអញ្ជើញចូលរួមប្រជុំ[1257]។

៣០៧. រៀងរាល់ពីរសប្ដាហ៍ គណៈឃុំជួបប្រជុំគ្នាដើម្បីពិភាក្សាពីផែនការការងារ។ អង្គប្រជុំនេះត្រូវបានដឹក

នាំដោយកម្មាភិបាលគណៈស្រុក[1258]។ ក្រោយពីប្រជុំរួច គណៈឃុំផ្សព្វផ្សាយផ្ទាល់មាត់នូវផែនការដល់សមាជិកសហករណ៍ និងរំឭកពួកគេឲ្យខិតខំសម្រេចការងារដាំដុះពី៣ ទៅ ៤តោន ក្នុងមួយហិកតាក្នុង១ឆ្នាំ[1259]។ អតីតសមាជិកម្នាក់បានបញ្ជាក់ឲ្យដឹងថា គាត់បានចូលរួមប្រជុំកងតូចបី ដងក្នុងមួយខែ។ នៅក្នុងអង្គប្រជុំនេះ អ្នកធ្វើការបានទិតៀនគ្នាទៅវិញទៅមកនិងធ្វើ ការស្វ័យទិតៀន[1260]។

៣០៨. ឃុំបានរាយការណ៍ផ្ទាល់មាត់ និងជាលាយលក្ខអក្សរជាទៀងទាត់ ទៅស្រុកទាក់ទិនការអនុវត្តការងារ[1261]។ ស្រដៀងគ្នានេះដែរ ស្រុកបានធ្វើការរាយការណ៍ជាប្រចាំខែ អំពីការអនុវត្តការងារដល់ តំបន់[1262]។ ការធ្វើសេចក្តីរាយការណ៍អំពីការងារដែលត្រូវបានធ្វើនៅតាមមូលដ្ឋាននេះមានរហូតដល់មជ្ឈិមបក្ស[1263]។ យ៉ាងហោចណាស់ សាក្សីចំនួន២ នាក់បានអះអាងថា តាម៉ុកលេខាភូមិភាគធ្លាប់បានមកពិនិត្យមើលសហករណ៍របស់ពួកគេ[1264]។

៣០៩. អតីតសមាជិកម្នាក់របស់គណៈឃុំស្រែរនោងបានចាំថា គាត់បានចូលរួមក្នុងអង្គប្រជុំក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ ដែលក្នុងពេលនោះ គាត់ត្រូវបានគេណែនាំអំពី *"ការបោសសម្អាតខ្មាំងក្នុងជួរ និងខ្មាំងក្រៅជួរ ដែលមាននិន្នាការជាមួយពួក លន់ នល់ ហើយអ្នកដែលនៅក្នុងជួរបក្ស បើមាននិន្នាការមិនល្អក៏មានការបោសសម្អាតដែរ....ខ្មាំងក្នុងជួរគឺកម្មាភិបាល ចំណែកឯខ្មាំងក្រៅជួរគឺជាប្រជាជនធម្មតា"* [1265]។ គាត់បានបញ្ជាក់បន្ថែមថា គាត់បានអានឯកសារទង់បដិវត្តន៍ ដែលត្រូវបានផ្តល់ឲ្យដោយស្រុកទៅមនុស្សមួយចំនួននៅក្នុងឃុំ។ ទង់បដិវត្តន៍លេខ៦ ខែមិថុនា ឆ្នាំ១៩៧៧ មានសំបុត្រពីគណៈកម្មាធិការមជ្ឈិមបក្សផ្ញើឲ្យស្រុកជាច្រើន ក្នុងនោះរួមមានស្រុកត្រាំកក់ផង ដោយផ្តល់ឲ្យនូវរង្វាន់កិត្តិយសជាទង់ក្រហមសម្រាប់*"កិច្ចការពារប្រទេសជាតិ ជំរុញចលនាបដិវត្តសង្គមនិយម នឹងជំរុញចលនាវាយសំរុក កសាងសង្គមនិយម ដោះស្រាយជីវភាពប្រជាជនរបស់បក្ស តាមសង្វាក់មហាលោតផ្លោះមហាអស្ចារ្យ"*[1266]។ ក្នុងសំបុត្រនោះ គណៈកម្មាធិការមជ្ឈិមបក្សបានកំណត់ផែនការលំអិតសម្រាប់ឆមាសទី២ឆ្នាំ១៩៧៧ ហើយដាក់បញ្ចូលនូវការណែនាំស្តីពីការការពារប្រទេសជាតិ ការកសាងសង្គមនិយម និងការសម្រេចបានលទ្ធផលប្រចាំឆ្នាំដាំដុះស្រូវពី ៣ ទៅ ៦ តោនក្នុងមួយហិកតា។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

ស្ថានភាពរស់នៅ និងការងារ

៣១០. សមាជិកសហករណ៍មិនអាចធ្វើដំណើរដោយគ្មានការអនុញ្ញាតឡើយ[1267]។ អតីតសមាជិកម្នាក់បាននិយាយថា គាត់ត្រូវបានអនុញ្ញាតឱ្យជួបជាមួយគ្រួសាររៀងរាល់ដប់ថ្ងៃម្ដង[1268]។ អ្នកដទៃទៀតត្រូវបានអនុញ្ញាតឱ្យជួបគ្រួសារក្នុងរយៈពេល២០ ថ្ងៃម្ដង[1269]។ កុមារដែលធ្វើការនៅក្នុងសហករណ៍ប៉ែន មាស ឃុំសំរោង កម្រអនុញ្ញាតឱ្យជួបឪពុកម្ដាយ និងបងប្អូនរបស់ខ្លួនណាស់[1270]។ ប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យនិយាយដោយសេរីទៅកាន់គ្នាទៅវិញទៅមកបានឡើយ[1271]។ បន្ថែមពីលើនេះ នៅពេលខ្លះ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបញ្ជូនប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីចេញពីផ្ទះឱ្យទៅរស់នៅទីកន្លែងផ្សេងគ្នាក្នុងស្រុកតែមួយ[1272]។

៣១១. សាក្សីបានធ្វើកិច្ចការផ្សេងៗពីគ្នាទៅតាមកងតូចៗ ដែលពួកគេស្ថិតនៅ។ ពេលវេលាធ្វើការងារជាទូទៅចាប់ផ្ដើមប្រហែលពីម៉ោង៧ព្រឹក ដល់ម៉ោង១២ និងម៉ោង១ ដល់ម៉ោង៥ ល្ងាច លើកលែងតែក្នុងរដូវច្រូតកាត់ ប្រជាជនត្រូវធ្វើការងារយូរជាងនេះ។ ក៏ប៉ុន្តែ សាក្សី៣ រូបដែលធ្លាប់ធ្វើការនៅក្នុងឃុំត្រពាំងធំត្បូង ឃុំសំរោង និងឃុំញ៉ែងញ៉ង់បានបញ្ជាក់ផងដែរថា គាត់បានធ្វើការក្នុងវេនទី៣ ចាប់ពីម៉ោង៦ ល្ងាចដល់ម៉ោង ១០យប់[1273]។ ស្ត្រីមានផ្ទៃពោះក៏ត្រូវធ្វើការងារផងដែរ[1274]។ អ្នកធ្វើការក្នុងវាលស្រែត្រូវបានបង្ខំឱ្យសម្រេចតាមចំនួនហិកតាដែលបានកំណត់។ ប្រសិនបើពួកគេធ្វើមិនបានសម្រេចក្នុងពេលវេលាកំណត់ ពួកគេត្រូវបានស្ដីបន្ទោស និងចោទថាជាខ្មាំង[1275]។ អ្នកដែលមិនបានទៅធ្វើការងារត្រូវបានចោទថា ធ្វើពុតជាឈឺ ហើយត្រូវបញ្ជូនទៅរៀនសូត្រ[1276]។ អ្នកដទៃទៀតដែលតវ៉ាត្រូវបានចាប់ខ្លួននិងបាត់ខ្លួន[1277]។ សាក្សីម្នាក់បាននិយាយថា៖ *"គេបង្ខំឱ្យធ្វើការរាល់ថ្ងៃ បើសិនជាយើងអត់ចង់ធ្វើការ គឺមិនបាន ដោយខ្លាចគេយកទៅវ៉ៃចោល"*[1278]។

៣១២. ផលស្រូវដែលប្រមូលបានដោយសហករណ៍មិនត្រូវបានចាត់ចែងដោយផ្ទាល់ទៅឱ្យសមាជិកឃុំនានារបស់ខ្លួនទេ។ ឃុំនីមួយៗត្រូវរាយការណ៍ទៅស្រុកអំពីទិន្នផលស្រូវ។ បន្ទាប់មក ស្រុកនឹងសម្រេចអំពីបរិមាណស្រូវដែលត្រូវប្រមូលពីឃុំនីមួយៗ[1279]។ ស្រូវខ្លះទំនងជាត្រូវបានយកទៅកិន[1280]។ ឃុំខ្លះរាយ-ការណ៍បន្ថយបរិមាណស្រូវដើម្បីទុកចំនួននៅសល់ដើម្បីបែងចែកស្វាត់ៗដល់សមាជិកសហករណ៍[1281]។ សាក្សីស្ទើរតែទាំងអស់រៀបរាប់ឱ្យដឹងថា មានកង្វះខាតអាហារហូបចុកក្នុងសហករណ៍[1282]។ សាក្សីខ្លះបានបញ្ជាក់ថា មានប្រជាជនស្លាប់ដោយសារអត់បាយ[1283] ខណៈដែលអ្នកខ្លះទៀតអះអាងថា មិនបានដឹង ឬគ្មានករណីនេះកើតឡើងឡើយ[1284]។ សាក្សីជាច្រើនអះអាងថា ប្រជាជនមិនហ៊ានត្អូញត្អែរអំពីកង្វះខាតអាហារទេ ដោយសារពួកគេ ខ្លាចត្រូវ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

បានដាក់ទោស ឬសម្លាប់[1285]។ ឯកសាររបស់ស្រុក១០៥ បានកត់ត្រាទុកផងដែរនូវការចាប់ខ្លួនមនុស្សដែលបានត្អូញត្អែរអំពីការងារ និងស្ថានភាពរស់នៅក្នុងសហករណ៍[1286]។

៣១៣. មនុស្សជាច្រើនរស់នៅក្នុងសហករណ៍មានបញ្ហាសុខភាព ជាពិសេសអ្នកដែលត្រូវបានគេជម្លៀសដែលមិនសាំនឹងការរស់នៅតាមទីជនបទ[1287]។ អ្នកមានជំងឺត្រូវបានព្យាបាលដោយពេទ្យឃុំ។ ក៏ប៉ុន្តែការព្យាបាលធ្វើឡើងតាមបែបបុរាណ និងថ្នាំដែលត្រូវផលិតនៅក្នុងស្រុក។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំដែលធ្វើពីឫសឈើ និងថ្នាំអាចម៍ទន្សាយ[1288]។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំចាក់ជាប្រភេទប៉េនីសេលីនលាយជាមួយទឹកដូង[1289]។ គ្រូពេទ្យគឺជាកម្មាភិបាលនារីរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការឡើយ[1290]។ ពួកគេភាគច្រើនមានអាយុចន្លោះពី១២ ទៅ១៣ឆ្នាំ[1291]។ នៅពេលមានមនុស្សស្លាប់ សាកសពត្រូវកប់ និងគ្មានការជូនដំណឹងដល់គ្រួសារទេ[1292]។

៣១៤. ការរៀបការជាក្រុមត្រូវបានរៀបចំក្នុងឃុំដែលម្តងៗមានពី១០ ទៅ២០គូ[1293]។ គូខ្លះបានស្គាល់គ្នា និងគូខ្លះមិនបានស្គាល់គ្នាឡើយ[1294]។ មានតែអ្នកដែលស្ថិតនៅក្នុងប្រភេទប្រជាជនដូចគ្នាប៉ុណ្ណោះ (ពេញសិទ្ធិ ត្រៀម ឬបញ្ញើ) ទើបអាចរៀបការជាមួយគ្នាបាន ដោយមានការយល់ព្រមពីប្រធានកង។ ការរៀបការត្រូវបានធ្វើឡើងនាពេលយប់ ដោយមានការចូលរួមពីគណៈឃុំ ប្រធានសហករណ៍ និងប្រធានកង[1295]។ សាក្សីម្នាក់ឈ្មោះ [លុប] បាននិយាយពីរបៀបដែល [លុប] [លុប] ជាប្រធានកងនារី បានផ្គូរផ្គងគាត់ឲ្យរៀបការក្នុងឃុំញ៉ែងញ៉ង ជាមួយនឹងបុរសដែលខ្លួនស្អប់។ សាក្សីរូបនេះបាននិយាយថា [លុប] បានប្រាប់ថា នាងត្រូវតែរៀបការ ហើយហេតុដូចនេះនាងគ្មានជម្រើសទេ។ នាពេលយប់នៃថ្ងៃរៀបការ នាងរួមបវេណីជាមួយប្តីទាំងមិនពេញចិត្ត។ សាក្សីនៅចាំថា នាយប់នោះ មានឈ្លបបុរសលួចស្តាប់នៅក្រោមផ្ទះ[1296]។ សាក្សីម្នាក់ទៀតបាននិយាយអំពីវត្តមាននៃកងឈ្លបលួចស្តាប់នៅពេលយប់ថ្ងៃរៀបការ ដើម្បីឲ្យដឹងថា៖ "*ពួកគេចុះសម្រុងនឹងគ្នាដែរឬអត់*"[1297]។ ផ្ទុយទៅវិញ សាក្សីពីរនាក់ផ្សេងទៀត រួមមាន [លុប] បានបដិសេធការអនុវត្តរបៀបនេះ ក្នុងពេលស្តាប់យកចម្លើយ[1298]។ សាក្សីផ្សេងទៀតចាំថា ប្រសិនបើនារីណាម្នាក់មិនពេញចិត្តក្នុងការរៀបការ នាងត្រូវបានអប់រំ ឬស្តីបន្ទោសថា៖ "*មនុស្សប្រុសត្រូវតែមានប្រពន្ធ និងនារីត្រូវតែមានប្តី ជារឿងធម្មតា*"[1299]។ [លុប] បានបដិសេធថា មានការរៀបការដោយបង្ខំនៅពេលដែលនាងធ្វើជាអ្នកសម្របសម្រួលការរៀបការនោះ[1300]។ បន្ថែមពីលើនេះ ស្ត្រីមកពីស្រុកត្រាំកក់ ត្រូវបានបញ្ជូនទៅកំពង់សោម ឲ្យរៀបការជាមួយកងទ័ពពិការ តាមសំណើរបស់កងទ័ព[1301]។

00605358



<u>សន្តិសុខ</u>

៣១៥. អតីតលេខាស្រុក [លុប][1302] បានពន្យល់អំពីការណ៍ដែលប្រជាជនត្រូវបានចាត់ថា ជាខ្មាំង និង បន្ទាប់មកគេយកទៅរៀនសូត្រ ឬចាប់ខ្លួន។ គាត់បាននិយាយបន្ថែមថា ពេលមនុស្សក្នុងឃុំត្រូវបាន ចោទ ថាបានប្រព្រឹត្តខុស ជាបឋម ពួកគេត្រូវបានអប់រំនៅនឹងមូលដ្ឋានដោយកម្មាភិបាលភូមិ និងឃុំ។ ក៏ប៉ុន្តែ ប្រសិនបើនៅតែមិនគោរព ឃុំនឹងសុំយោបល់ពីគណៈស្រុក។ គណៈស្រុកនឹង កោះប្រជុំដើម្បីពិភាក្សាបញ្ហានិងធ្វើការសម្រេច។ ឧទាហរណ៍ របាយការណ៍ពីឃុំញ៉ែងញ៉ង ទៅស្រុកបានកំណត់ប្រវត្តិរូបរបស់ "ខ្មាំង" មួយរូប ដោយកត់ត្រានូវប្រភេទកំហុសជាច្រើន ដែលជននោះត្រូវបានចោទថាបានប្រព្រឹត្ត។ ចំណារឆ្លើយតបត្រឡប់មកឃុំវិញពីលេខាស្រុកនៅផ្នែក ខាងក្រោមនៃឯកសារបានបញ្ជាឱ្យមានការចាប់ខ្លួនជននោះ[1303]។ [លុប] បានបញ្ជាក់ថា មុន ពេលចាត់វិធានការដាក់លាក់ណាមួយ ត្រូវសុំយោបល់ពីគណៈតំបន់ជាមុនសិន។ សេចក្តីសម្រេច របស់គណៈតំបន់ត្រូវបានស្រុកយកទៅអនុវត្ត។ ប្រសិនបើសេចក្តីសម្រេចបញ្ជាឱ្យបញ្ជូនទៅ រៀនសូត្រ ទោះបីជា បុគ្គលនោះជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ឬជនស៊ីវិលក៏ដោយ ក៏ត្រូវឈ្លបឃុំចាប់ខ្លួន រួចបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែរ[1304]។

៣១៦. សាក្សីជាច្រើនបានលើកឡើងថា ក្នុងចំណោមកំហុសដែលគេផ្តន្ទាទោស មានការចាប់ខ្លួនចំពោះបទ "ខុសសីលធម៌"ផងដែរ[1305]។ មានភស្តុតាងជាឯកសារបង្ហាញផងដែរអំពីបញ្ហានេះ[1306]។ សាក្សីម្នាក់ ដែលបានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការតំបន់១៣ បានរំឭកថា មានការបង្ហាញអំពីគោលនយោបាយ "ប្តីមួយប្រពន្ធមួយ" ហើយអ្នកប្រព្រឹត្តអំពើខុស សីលធម៌នឹងត្រូវបាន"កម្ទេច" [1307]។

៣១៧. ពួកឈ្លបឃុំមានសិទ្ធិចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយប្រជាជន។ ប៉ុន្តែ សាក្សីខ្លះបញ្ជាក់ថា ឈ្លបមិន មានអំណាចក្នុងការសម្លាប់ឡើយ ដែលនេះត្រូវសម្រេចដោយថ្នាក់ស្រុក[1308]។ សាក្សីម្នាក់ដែល រស់នៅក្នុងឃុំសំរោង បាននិយាយបញ្ជាក់អំពីអង្គប្រជុំដែលពេលនោះ ប្រជាជនត្រូវគេចោទថា បានប្រព្រឹត្តមិនត្រឹមត្រូវ ហើយគាត់បានឃើញកម្មាភិបាលកោសក់បុរស និងស្ត្រី ចេញជាសញ្ញាខ្វែង ជើងក្អែកមុនពេលបណ្តើរពួកគេមកមុខអង្គប្រជុំ។ បន្ទាប់មក ប្រជាជនទាំងនេះត្រូវបានដាក់ក្នុងមន្ទីរ ឃុំឃាំងដោយឈ្លបឃុំ[1309]។ ឯកសារស្រុក១០៥ជាច្រើនបានបញ្ជាក់ថា ឈ្លបឃុំបានសួរចម្លើយ អ្នកទោសដោយប្រើ "វិធីក្តៅ" និង "ត្រជាក់" មុនពេលបញ្ជូនមកថ្នាក់ស្រុក[1310]។ ឧទាហរណ៍

00605359



ឯកសារមួយ ដែលផ្ញើពីឃុំមួយក្នុងស្រុកត្រាំកក់ទៅគណៈស្រុក បានស្នើសុំឲ្យស្រុកផ្តល់យោបល់ អំពីយុវជនមួយរូប ដែលត្រូវបានចោទថា ប្រព្រឹត្តអំពើលួចជាច្រើនដង ថាបាន៖ "*ធ្វើមីទ្ទិងក្នុងកង ឲ្យកាត់ទោសពរដង រហូតបណ្តោយឲ្យយុវជន កងយកមកកុំកៅស៊ូមុខ រឿ្វចសួរចម្លើយ ក៏នៅមិនរាងចាលដែរ*"[1311]។

៣១៨. មុនឆ្នាំ១៩៧៥ សាក្សីម្នាក់ដែលរស់នៅក្នុងឃុំត្រាំកក់បញ្ជាក់ថា កម្មាភិបាលបានចាប់ខ្លួនមនុស្សដែលត្រូវបានចោទថាជាអ្នកមាន ឬអ្នកមានដីស្រែច្រើន។ ពួកគេត្រូវបានប្រាប់ថា បញ្ជូនទៅរៀនសូត្រ។ ក្រោយឆ្នាំ១៩៧៥ មានអ្នកត្រូវបានចាប់ខ្លួនខ្លះក្នុងចំណោមពួកគេបានត្រឡប់មកឃុំវិញ ប៉ុន្តែអ្នកផ្សេងទៀតមិនបានត្រឡប់មកវិញទេ[1312]។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នករស់នៅក្នុងសហករណ៍បានបន្តបាត់ខ្លួនរហូត[1313]។ ជារឿយៗ ប្រជាជនត្រូវបានគេចាប់យកទៅនាពេលយប់[1314]។ អតីតលេខាស្រុក [លុប] បាននិយាយក្នុងពេលស្តាប់យកចម្លើយថា៖ "*មានប្រជាជនខ្លះ មកប្តឹងឲ្យខ្ញុំដែលជាគណៈស្រុកឲ្យជួយពីរឿង បាត់បងប្អូន កូនចៅរបស់ពួកគេ ហើយខ្ញុំបានប្រាប់ទៅគេវិញថា ខ្ញុំជួយមិនបានទេ។ ប្រជាជនដែលមកប្តឹងពីរឿងបាត់បងប្អូនកូនចៅ ដោយសារបងប្អូនកូនចៅរបស់គេនោះ មានទំនាស់ពីរឿងនយោបាយ ដែលគេចោទគ្នាថាក្បត់*"[1315]។

**<u>ការប្រព្រឹត្តិលើក្រុមមនុស្សជាក់លាក់</u>**

៣១៩. ឈ្លបឃុំឃ្លាំមើលអ្នកដែលត្រូវបានផ្លាស់ទីលំនៅមកពីភ្នំពេញយ៉ាងជិតដល់។ ប្រសិនបើពួកគេនិយាយអ្វីប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ពួកគេនឹងត្រូវបានចាប់ខ្លួន និងនាំយកទៅ[1316]។ អតីតជាទាហាន និងប៉ូលិសរបស់របប លន់ នល់ ជាពិសេស អ្នកដែលមានតំណែងជាមន្ត្រីត្រូវបានគេពិនិត្យមើលយ៉ាងល្អិតល្អន់។ បញ្ជីឈ្មោះអតីតទាហាន លន់ នល់ ដែលបានមកដល់ឃុំត្រូវបានគេរៀបចំ និងបញ្ជូនទៅស្រុក។ ឧទាហរណ៍ ឯកសារស្រុក១០៥ ពីឃុំញ៉ែងញ៉ង់បានកត់ត្រានូវឈ្មោះអតីតទាហានចំនួន១១ រូប ដែលត្រូវបានបញ្ជូនទៅក្នុងឃុំញ៉ែងញ៉ង់នេះ[1317]។

៣២០. សាក្សីពីររូបចងចាំថា មានជនជាតិចាមរស់នៅក្នុងស្រុកត្រាំកក់ បានទទួលរងការប្រព្រឹត្តិដូចអ្នកដទៃទៀតដែរ[1318]។ ផ្ទុយទៅវិញ ជនជាតិវៀតណាមហាក់បីដូចជាទទួលរងការប្រព្រឹត្តិខុសពីគេ។ សាក្សីម្នាក់បានរំឭកថា ជនជាតិវៀតណាមទាំងអស់ក្រោយមកបាត់ខ្លួនទាំងអស់ពីភូមិរបស់គាត់[1319]។ អតីតគ្រូបង្រៀនក្នុងកងកុមារក្នុងឃុំញ៉ែងញ៉ង់បាននិយាយថា ក្នុងឆ្នាំ១៩៧៦ ប្រធានឃុំបានប្រកាសថា សមាជិកឃុំជាជនជាតិវៀតណាមនឹងត្រូវបញ្ជូនត្រឡប់ទៅវៀតណាម

វិញ។ គាត់បានចាំថាមានការចាប់ខ្លួន និងការសម្លាប់អ្នកដែលនិយាយកុហកអំពីពូជសាសន៍របស់ខ្លួន ដែលសង្ឃឹមថាអាចបានរួចខ្លួន។ សាក្សីរូបនេះបាននិយាយថា មានពីរដំណាក់កាលពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម។ លើកទីមួយ ប្រជាជនវៀតណាមពិតជាត្រូវបានបញ្ជូនទៅវៀតណាមវិញមែន។ ក៏ប៉ុន្តែក្នុងដំណាក់កាលទី២ ប្រជាជនវៀតណាមត្រូវបានចាប់យកទៅសម្លាប់[1320]។ ឯកសារស្រុក១០៥ជាច្រើន បានកត់ត្រានូវការចាប់ខ្លួនជនជាតិវៀតណាម[1321]។ របាយការណ៍ពីឃុំអង្គតាសោមចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧ ស្នើសុំការណែនាំពីអង្គការ ពាក់ព័ន្ធនឹងការចុះឈ្មោះប្រជាជនកម្ពុជាក្រោម។ ទំនងជាមានគ្រួសារជាច្រើនដែលមានតែប្តី ឬតែប្រពន្ធជាជនជាតិវៀតណាម ប៉ុន្តែអ្នកទាំងពីរស្នើសុំឱ្យគេបញ្ជូនទៅវៀតណាមទាំងអស់គ្នា[1322]។ របាយការណ៍មួយទៀតបានកត់ត្រាថា ផ្អែកតាមសេចក្តីសម្រេចរបស់អង្គការ ខ្មែរកម្ពុជាក្រោមចំនួន៧ នាក់ត្រូវបានបញ្ជូនទៅវៀតណាម[1323]។

**៣២១.** នៅក្នុងផ្នែកខ្លះនៃស្រុកត្រាំកក់ ប.ក.ក បានហាមមិនឱ្យគោរពសាសនា និងបានផ្សឹកព្រះសង្ឃ ចាប់តាំងពីដើមឆ្នាំ១៩៧២ មក[1324]។ មុនខែមេសា ឆ្នាំ១៩៧៥ គោលនយោបាយនេះ គឺត្រូវបានបង្កើតឡើងឱ្យមាននៅទូទាំងស្រុក។ សាក្សីម្នាក់ជាអតីតព្រះសង្ឃបានបញ្ជាក់ថា ក្រោយខែមេសា ឆ្នាំ១៩៧៥ ព្រះសង្ឃទាំងអស់ ដែលមានកំណើតក្នុងខេត្តតាកែវ ឬភ្នំពេញ ត្រូវបានណែនាំឱ្យរស់នៅក្នុងវត្តអង្គរកា ក្នុងស្រុកត្រាំកក់។ ក្រោយមក កម្មាភិបាល ប.ក.ក បានមកបង្គាប់ព្រះសង្ឃទាំងអស់ឱ្យសឹក[1325]។ សាក្សីបានបំភ្លឺពីការបំផ្លាញពុទ្ធបដិមាករ និងប្តូរវត្តអារាមទៅជាកន្លែងប្រជុំ មន្ទីរឃុំឃាំង រោងបាយ កន្លែងចិញ្ចឹមជ្រូក និងឃ្លាំងដាក់សម្ភារៈ[1326]។ ប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឱ្យអុជធូបទេ[1327]។ លោកសង្ឃដែលត្រូវបានផ្សឹកត្រូវបានបញ្ជូនទៅធ្វើកងទ័ព ឬបង្ខំឱ្យធ្វើការងារ[1328]។ បន្ថែមពីលើនេះ សមាជិកគ្រួសារ មិនត្រូវបានអនុញ្ញាតបូជាសាកសព ឬធ្វើពិធីបុណ្យសពឡើយ[1329]។

**៣២២.** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥១នាក់ (ហាសិបមួយនាក់) ត្រូវបានប្រកាសទទួលស្គាល់ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់[1330]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថា មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

## ការដ្ឋានទំនប់ត្រពាំងថ្ម [1331]

### ទីតាំង និងការបង្កើត

៣២៣. ការដ្ឋានទំនប់ត្រពាំងថ្មមានទីតាំងស្ថិតនៅភូមិត្រពាំងថ្មកណ្តាល និងភូមិប៉ោយចារ ឃុំប៉ោយចារ[1332] ស្រុកភ្នំស្រុក[1333] ក្នុងខេត្តបន្ទាយមានជ័យបច្ចុប្បន្ន (ពីមុននៅក្នុងខេត្តបាត់ដំបង)[1334]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់ ប.ក.ក ការដ្ឋានទំនប់ត្រពាំងថ្មមានទីតាំងស្ថិតនៅក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ[1335]។ ផ្នែកសំខាន់នៃទំនប់នេះស្ថិតនៅប្រមាណជា៥០ គីឡូម៉ែត្រភាគពាយ័ព្យ/ភាគឦសាននៃក្រុងស៊ីសុផុន[1336]។

៣២៤. គេមិនស្គាល់ច្បាស់លាស់ទេអំពីកាលបរិច្ឆេទពិតប្រាកដ នៃការចាប់ផ្តើមដំណើរការសាងសង់ការដ្ឋានទំនប់ត្រពាំងថ្ម។ សាក្សីបានផ្តល់ចម្លើយខុសៗគ្នា ដោយសាក្សីខ្លះបាននិយាយថា ការសាងសង់បានចាប់ផ្តើមនៅដើមឆ្នាំ១៩៧៦[1337] ហើយសាក្សីខ្លះទៀតនិយាយថានៅចន្លោះចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧[1338] ប៉ុន្តែសាក្សីមួយចំនួនទៀតបញ្ជាក់ថា ទំនប់ទាំងមូលត្រូវបានសាងសង់នៅក្នុងឆ្នាំ១៩៧៧[1339]។ ទោះជាយ៉ាងនេះក្តី ស្ទើរតែគ្រប់សាក្សីទាំងអស់គាំទ្រថា ទំនប់នេះបានសាងសង់ចប់សព្វគ្រប់នៅចុងឆ្នាំ១៩៧៧[1340] ឬយ៉ាងយូរបំផុតត្រឹមខែឧសភា ឆ្នាំ១៩៧៨[1341]។ ទំនប់នេះត្រូវបានពិព័ណនាជាផ្លូវការដោយបក្សកុម្មុយនីសកម្ពុជា (ប.ក.ក) នៅក្នុងខែតុលាឆ្នាំ១៩៧៧ ថា ជាលទ្ធផលនៃការសម្រុកការងារទូទាំងប្រទេសដើម្បីសម្រេចផែនការសេដ្ឋកិច្ច ឆ្នាំ១៩៧៧ របស់បក្សកុំម្មុយនីសកម្ពុជា ស្របតាមគោលនយោបាយដែលកំណត់ឱ្យអ្នកធ្វើការ *"បូជាអ្វីៗទាំងអស់ដើម្បីផលិតស្រូវឱ្យបានជាអតិបរមា"*[1342]។

៣២៥. ពិធីសម្ពោធត្រូវបានរៀបចំឡើងនៅកន្លែងទំនប់ ក្នុងខែធ្នូ ឆ្នាំ១៩៧៧ ដោយមានការចូលរួមពីកម្មាភិបាលជាន់ខ្ពស់របស់ ប.ក.ក ជាច្រើនរូប ដែលដឹកនាំដោយ ប៉ុល ពត និងអមដំណើរដោយគណៈប្រតិភូចិនមួយក្រុម ដូចមានរាយការណ៍នៅក្នុងសារព័ត៌មានក្រុងប៉េកាំង[1343]។ ហេង រិន ហៅ ម៉ី ហៅ នៅ រិន ជាលេខាតំបន់ និង ជាល[1344] ជាសមាជិកគណៈតំបន់ ក៏បានចូលរួមពិធីនេះផងដែរ។

៣២៦. ក្រោយពេលសាងសង់រួច ទំនប់នេះមានទំហំខ្នងទំនប់ប្រវែងប្រហែល ១០ ម៉ែត្រ ជើងទំនប់មាន

ប្រវែងប្រហែល ១៨ ម៉ែត្រ និងកម្ពស់មានប្រវែងប្រហែលពី ៣ ទៅ ៥ ម៉ែត្រ[1345]។ អាងទំនប់នេះ អាចផ្ទុកទឹកដែលមានផ្ទៃទឹកបណ្តោយប្រមាណជា ១០ គ.ម និងទទឹង ប្រមាណជា ៧ គ.ម[1346]។

**ដំណើរការប្រព្រឹត្តទៅ**

**<u>រចនាសម្ព័ន្ធគ្រប់គ្រង និងអ្នកធ្វើការ</u>**

**៣២៧.** ការសាងសង់ទំនប់ត្រពាំងថ្មត្រូវបានរៀបចំចាត់ចែង និងគ្រប់គ្រងដោយកម្មាភិបាលរបស់ ប.ក.ក ដែលបែងចែកអ្នកលើកទំនប់ដែលខ្លួនដឹកនាំទៅតាមក្រុមការងារតូចៗ ហើយជាអ្នកសម្រេចប្រគល់ភារកិច្ចដល់ក្រុមការងារនិងអ្នកធ្វើការម្នាក់ៗ ចេញផែនការការងារ តែងតាំងប្រធានក្រុម[1347] និងជាអ្នកប្រមូលប្រវត្តិរូបមនុស្សដែលធ្វើការនៅក្នុងការដ្ឋាន[1348]។ នៅក្នុងរចនាសម្ព័ន្ធឋានានុក្រម មានប្រធានក្រុម ប្រធានកងតូច និងប្រធានកងធំ [1349]។

**៣២៨.** ប្រធានកងត្រូវរាយការណ៍ពីភាពជឿនលឿននៃការងារសាងសង់ជាទៀងទាត់ ដើម្បីទទួលបាននូវបញ្ជាពីថ្នាក់លើរបស់ខ្លួន និងដើម្បីរៀបចំផែនការការងារសម្រាប់ពេលខាងមុខ[1350]។ វ៉ាល់, ផេង ថង និង ហង់ គឺជាអ្នកទទួលខុសត្រូវក្នុងការរៀបចំផែនការការងារ[1351]។ របាយការណ៍ត្រូវបានធ្វើជូនអង្គការ៨៧០[1352] ដើម្បីរាយការណ៍ពីភាពជឿនលឿននៃការងារ ដូចជា មានរបាយការណ៍មួយច្បាប់ផ្ញើជូន *"អ៊ំ អ៊ំនួន បងវ៉ាន់ បងវ៉ន មន្ទីរឯកសារ"* ដើម្បីរាយការណ៍អំពីដំណើរទស្សនកិច្ចរបស់អ្នកកាសែតជនជាតិយូហ្គោស្លាវីនៅការដ្ឋានទំនប់ត្រពាំងថ្ម[1353]។

**៣២៩.** ការទទួលខុសត្រូវរួមក្នុងការសាងសង់ទំនប់ត្រពាំងថ្មគឺ វ៉ាល់ ហៅ ឌិក ហួន [1354]ដែលជាកម្មាភិបាលតំបន់៥ នៃភូមិភាគពាយ័ព្យ[1355] ហើយគាត់តែងតែមកការដ្ឋានជាញឹកញាប់ដើម្បីពិនិត្យមើលពីភាពជឿនលឿននៃការងារសាងសង់[1356]។ វ៉ាល់ គឺជាប្រធានកងចល័តតំបន់៥[1357] ដូចដែលសាក្សីម្នាក់បានបញ្ជាក់ថា *"តាវ៉ាល់ ជាអ្នកដាក់ផែនការក្នុងការជ្រើសរើសកម្លាំងពីស្រុក ដើម្បីទៅលើកទំនប់ ត្រពាំងថ្ម"*[1358] ។

**៣៣០.** [លុប] ជាគណៈស្រុកភ្នំស្រុក និងជាអ្នកជួយ វ៉ាល់ ក្នុងការត្រួតពិនិត្យលើការងារសាងសង់ទំនប់[1359] ហើយអ្នកទាំងពីរមានការប្រាស្រ័យទាក់ទងគ្នាក្នុងកិច្ចការនេះ។ វ៉ាល់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧[1360] ហើយ [លុប] ក៏ត្រូវបានចាប់ខ្លួនផងដែរនាខែកញ្ញា ឆ្នាំ១៩៧៧បន្ទាប់ពីអ្នកទាំងពីរត្រូវបានចោទប្រកាន់ថាជាជនក្បត់[1361]មុនពេលបញ្ចប់ការសាងសង់។

៣៣១. លេខាតំបន់៥ នៃភូមិភាគពាយ័ព្យ គឺ ម៉ែន ជុន ហៅ ហ៊ិង្ស[1362] ត្រូវបានចាប់ខ្លួននៅក្នុងខែកញ្ញា ឆ្នាំ ១៩៧៧[1363] ហើយត្រូវបានជំនួសដោយ ហេង រិន ហៅ ម៉ី ហៅ នៅ រិន រហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨[1364] បន្ទាប់មកត្រូវបានសម្លាប់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១៩៧៨[1365]។

៣៣២. អ្នកទទួលខុសត្រូវផ្សេងទៀតក្នុងការត្រួតពិនិត្យលើការងារសាងសង់ទំនប់ត្រពាំងថ្ម គឺ [លុប] [លុប] ជាលេខាគណៈភូមិភាគពាយ័ព្យ ដែលបានទៅពិនិត្យមើលការដ្ឋានសាងសង់ទំនប់ជាច្រើនដងមុនពេលសាងសង់រួច[1366] និង ជាល ជាសមាជិកគណៈតំបន់៥[1367] ហើយអ្នកទាំងពីរក្រោយមកត្រូវបានចាប់ខ្លួននៅឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨[1368]។

៣៣៣. ការដ្ឋានសាងសង់ទំនប់ត្រពាំងថ្មត្រូវបានមេដឹកនាំ ប.ក.ក មកទស្សនកិច្ចជាច្រើនលើកច្រើនសា[1369]។ មានភស្តុតាងបញ្ជាក់ថា ប៉ុល ពត និង ខៀវ សំផន បានមកទស្សនកិច្ចទំនប់ត្រពាំងថ្មជាច្រើនពេលផ្សេងៗគ្នា នាអំឡុងពេលនៃការសាងសង់[1370]។ សាក្សីមួយរូបលើកឡើងពី អៀង សារី ដែលមកទស្សនកិច្ចជាមួយ ប៉ុល ពត ប៉ុន្តែសាក្សីបានដឹងពីរឿងនេះតាមរយៈពាក្យចាមអារាមប៉ុណ្ណោះ គឺខ្លួនមិនបានឃើញជនត្រូវចោទនៅកន្លែងការដ្ឋានទំនប់ត្រពាំងថ្មដោយផ្ទាល់នោះទេ[1371]។

<u>លក្ខខណ្ឌការងារ និងការរស់នៅ</u>

៣៣៤. មនុស្សរាប់ពាន់នាក់ត្រូវបានបង្ខំឲ្យចូលរួមលើកទំនប់ត្រពាំងថ្ម[1372]។ អតីតអ្នកលើកទំនប់មួយរូបបានប៉ាន់ស្មានថាមនុស្សចូលរួមលើកទំនប់មានចំនួនប្រហែលជា១៥.០០០ នាក់[1373] ចំណែកសាក្សីមួយរូបទៀតនិយាយថា *"ខ្ញុំគ្មាប់មិនអស់ទេ គឺតំបន់៥ទាំងមូល ប្លូកជាមួយប្រជាជនតាមសហករណ៍ គឺមនុស្សច្រើនសឹងតែពុល"* [1374]។ សាក្សីផ្សេងទៀតនិយាយថា អ្នកលើកទំនប់មានចំនួន *"រាប់ពាន់នាក់"* ឬ *"រាប់ម៉ឺននាក់"* ដែលបានចូលរួមក្នុងការលើកទំនប់នេះ[1375]។ សារព័ត៌មានចិនដែលរាយការណ៍ពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិនបានផ្តល់តួលេខថា អ្នកលើកទំនប់មានចំនួន ២០.០០០ នាក់[1376] គឺដូចគ្នានឹងសារទូរលេខរបស់ ប.ក.ក ដែលរាយការណ៍ពីដំណើរទស្សនកិច្ចរបស់អ្នកកាសែតជនជាតិយូហ្គោស្លាវីមកកាន់ការដ្ឋានទំនប់ត្រពាំងថ្ម[1377]។

៣៣៥. មនុស្សដែលចូលរួមលើកទំនប់ត្រពាំងថ្ម គឺមកពីភូមិនានានៃបណ្តាស្រុករបស់តំបន់៥ ក្នុងភូមិភាគ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

ពាយ័ព្យ រួមមានស្រុកថ្មពួក ស្រុកភ្នំស្រុក ស្រុកសេរីសោភ័ណ្ឌ និងស្រុកព្រះនេត្រព្រះ[1378] ។ អ្នកលើកទំនប់ទាំងនោះរួមបញ្ចូលទាំងប្រជាជនថ្មីដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ[1379] និងមកពីខេត្តសៀមរាបផងដែរ[1380]។

៣៣៦. អ្នកលើកទំនប់រួមមាន បុរស ស្ត្រី និងកុមារ[1381] ហើយត្រូវបានរៀបចំជាកង។ កងនីមួយៗ ចែកជាក្រុម កងតូច កងធំ កងវរសេនាតូច ដែលមានមនុស្ស ១០ នាក់ ៣០ នាក់ ១០០ នាក់ និង ៣០០ នាក់[1382] ទៅតាមកងនីមួយៗ។ "*កងចល័ត*" រួមមាន"*មនុស្សវ័យកណ្ដាល*" [1383] ។ មានកងចល័តចម្រុះទាំងស្រីទាំងប្រុស ហើយខ្លះមានកងចល័តយុវជនផ្សេង និងកងនារីផ្សេង ប៉ុន្តែមិនមានការបែងចែកការងារខុសគ្នាទេ[1384]។ អ្នកធ្វើការនៅក្នុងកងចល័តតម្រូវឱ្យលើកទំនប់ ជីកប្រឡាយ កសាងប្រព័ន្ធធារាសាស្ត្រ ធ្វើស្រែប្រាំង និងដកស្ទូង[1385]។ "*កងកុមារ*" រួមមានអាយុចាប់ពី ១៣ ដល់ ១៧ ឆ្នាំ[1386]។ កុមារដែលស្ថិតនៅក្នុងកងកុមារត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ និងបង្ខំឱ្យរស់នៅរួមគ្នាជាមួយសមាជិកកងរបស់ពួកគេ[1387]។ ម្យ៉ាងទៀត មាន"*កងករណី*" សម្រាប់មនុស្សដែលចាត់ទុកថា បានគេចវេសពីការងារ ឬមាន"*ជំងឺសតិអារម្មណ៍*" ហើយអ្នកទាំងនោះត្រូវស្ថិតនៅក្រោមការតាមដាន និងអប់រំកែប្រែ[1388]។ កងករណី ត្រូវកំណត់ឱ្យធ្វើការច្រើនជាងគេ[1389] ហើយអ្នកដែលគេចាត់ទុកថាមិនអាចអប់រំកែប្រែបាន អ្នកនោះបាត់ខ្លួនរហូត ហើយមិនដែលឃើញត្រឡប់មកវិញទេ[1390]។

៣៣៧. ទំនប់ត្រពាំងថ្មត្រូវបានកសាងឡើងដោយកម្លាំងមនុស្សស្ទើរតែទាំងស្រុង[1391] ដែលម្នាក់ៗត្រូវលើកដីពី ១ ម៉ែត្រគូបទៅ ៣ ម៉ែត្រគូបកន្លះក្នុង១ ថ្ងៃ[1392]។ គ្រឿងចក្រមួយចំនួនត្រូវបានប្រើ ប៉ុន្តែសម្រាប់ការងារបន្ទាប់បន្សំប៉ុណ្ណោះ ដូចជាប្រើត្រាក់ទ័រ ដើម្បីជួយកិនបង្ហាប់ដីជាដើម[1393]។

៣៣៨. ទោះបីជា មានលក្ខណៈខុសគ្នាពីកងមួយទៅកងមួយទៀតក៏ដោយ ក៏ម៉ោងធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មត្រូវបានចាប់ផ្ដើមពីម៉ោង ៧ ព្រឹក ដល់ម៉ោង ១១ ព្រឹក និងពីម៉ោង ១ រសៀល ដល់ម៉ោង ៥ ល្ងាច[1394]។ សាក្សីមួយចំនួនបានលើកឡើងថា មានធ្វើការនៅពេលយប់ដែរ គឺចាប់ពីម៉ោងប្រហែល ៧ យប់ ដល់ម៉ោង ១០ យប់ ឬយប់ជ្រៅជាងនេះ ជាពិសេសនៅពេលដែលការងារមិនបានសម្រេចតាមផែនការ[1395]។ មានកងខ្លះ បានចាប់ផ្ដើមធ្វើការឆាប់ជាងនេះ នៅពេលព្រឹក ដោយមានសាក្សីមួយរូបបានអះអាងថា ពួកគេបានចាប់ផ្ដើមធ្វើការនៅពេលព្រលឹមស្រាងៗ[1396]។ អ្នកលើកទំនប់មិនត្រូវបាន អនុញ្ញាតឱ្យឈប់សម្រាកទេ ប្រសិនបើពួកគេមិនទាន់បានបញ្ចប់

00605365



ការងារតាមផែនការ[1397]។ អ្នកដែល បានបញ្ចប់ការងាររបស់ខ្លួនហើយ អាចត្រូវបានប្រគល់ការងារបន្ថែមឱ្យធ្វើទៀត[1398]។ ទោះបីជាមានសាក្សីខ្លះនិយាយថា មិនមានការដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនបានសម្រេចការងារតាមផែនការក៏ដោយ[1399] ក៏មានភស្តុតាងរឹងមាំបញ្ជាក់ថា អ្នកទាំងនោះទំនងជាអាចទទួលរងនូវការដាក់ទណ្ឌកម្ម[1400] ទាំងផ្នែកផ្លូវកាយ[1401] ឬតាមរយៈការបន្ថយរបបអាហារ[1402]។ អ្នកដែលមិនបានសម្រេចការងារតាមផែនការអាចត្រូវបានបញ្ជូនទៅកន្លែងអប់រំកែប្រែ ឬកសាង[1403] ឬទៅ"កងករណី"[1404]។

៣៣៩. អ្នកធ្វើការទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកឡើយនៅពេលធ្វើការ[1405]។ សាក្សីភាគច្រើននិយាយថា ពួកគេត្រូវបានហាមឃាត់មិនឱ្យនិយាយរកគ្នាទេនៅពេលកំពុងធ្វើការ[1406]។ ការឈប់សំរាកខ្លីៗដើម្បីផឹកទឹក ជុះនោម ឬបន្ទោរបង់ ត្រូវបានអនុញ្ញាត[1407] ប៉ុន្តែមានអ្នកតាមដាន និងកងឈ្លបឃ្លាំមើល[1408] នៅនឹងកន្លែងធ្វើការ ហើយរាយការណ៍ពីអ្នកដែល"*ខ្ជិល*"ទៅថ្នាក់លើ ដូច្នេះពួកគេមិនហ៊ានសុំឈប់សម្រាកទេ [1409]។ ការសុំឈប់សម្រាកត្រូវបានយល់ព្រមតែក្នុងករណីឪពុកម្តាយឈឺប៉ុណ្ណោះ [1410]។

៣៤០. អ្នកលើកទំនប់ត្រូវរស់នៅជិតនឹងការដ្ឋាន ដោយធ្វើរោងវែងស្នាក់នៅរួមគ្នា រោងខ្លះមានមនុស្សដេករហូតដល់ ៦០០ នាក់[1411]។ ពួកគេមិនទទួលបានកន្ទេលសម្រាប់ដេក ភួយសម្រាប់ដណ្តប់ ខ្នើយ ឬអង្រឹងទេ ដូច្នេះពួកគេត្រូវដោះស្រាយដោយខ្លួនឯង ដោយយកបាវមកក្រាលដេក ហើយភាគច្រើនដេកផ្ទាល់ដី[1412]។ បុរស និងស្ត្រី ដែលមិនទាន់រៀបការ ត្រូវរស់នៅដាច់ដោយឡែកពីគ្នា [1413]។

៣៤១. ទោះបីជាមានសាក្សីមួយចំនួនតូចនិយាយថា មានការហូបចុកគ្រប់គ្រាន់ក៏ដោយ[1414] ជាទូទៅម្ហូបអាហារមិនមានគ្រប់គ្រាន់ទេ[1415] ។ សាក្សីខ្លះនិយាយថា ពួកគេ "*ហូបមិនឆ្អែតទេ គឺផឹកទឹកបំពេញ*" ឬ "*ដើររកបេះស្លឹកឈើហូបជំនួស*" [1416]។ ត្រីងៀត និងសាច់ងៀត ត្រូវបានផ្តល់ឱ្យម្តងម្កាល[1417] ប៉ុន្តែទោះជាមានការផ្តល់ម្ហូបអាហារបែបនេះក្តី ក៏មិនគ្រប់គ្រាន់សម្រាប់អ្នកធ្វើការនៅទីនោះដែរ[1418]។ អ្នកលើកទំនប់ហូបទឹកល្អក់ ដែលដឹកយកមកពីត្រពាំង ឬបឹងនៅជិតៗនោះ[1419]។ គ្មាននរណាម្នាក់ហ៊ានត្អូញត្អែរពីរបបអាហារទេ ដោយភ័យខ្លាចគេសម្លាប់[1420]។ អ្នកលើកទំនប់ខ្លះបានស្លាប់នៅនឹងកន្លែង ដោយសារការអត់ឃ្លាន[1421] និងធ្វើការបាក់កម្លាំង ដែលពេលខ្លះគឺកំពុងតែរែកដីតែម្តង[1422]។

៣៨២. នៅការដ្ឋានលើកទំនប់គ្មានអនាម័យទេ[1423]។ ទឹកល្អក់ដែលដឹកយកមកពីត្រពាំង ឬបឹងជិតៗនោះ មិនបានដាំឱ្យពុះ[1424]។ ការខ្វះអនាម័យបែបនេះ ធ្វើឱ្យអ្នកលើកទំនប់ជាច្រើនធ្លាក់ខ្លួនឈឺ ដោយមានជម្ងឺរាគមួល អាសន្នរោគ និងជម្ងឺគ្រុនចាញ់ ។ល។[1425] អាហារសម្រាប់អ្នកជម្ងឺត្រូវបានកាត់បន្ថយ[1426]។ ពេទ្យមិនបានទទួលការបណ្តុះបណ្តាលទេ ហើយពេទ្យទាំងនោះគឺចាប់ដាក់ គ្មានចំណេះដឹង និងបទពិសោធន៍ទេ [1427]។ បន្ទាប់មក ពេទ្យទាំងនោះដើរមើលតាមរោង និងផ្តល់ថ្នាំឫសឈើ (ថ្នាំអាចម៍ទន្សាយ) ដដែលៗដល់អ្នកជំងឺ[1428]។ កុមារត្រូវបានជ្រើសរើសបញ្ជូនឱ្យទៅរៀននៅសង្គមកិច្ចសម្រាប់រយៈពេលពីរសប្តាហ៍ បន្ទាប់មក ពួកគេក៏វិលត្រឡប់មកទំនប់ត្រពាំងថ្មវិញ ដើម្បីធ្វើជាពេទ្យសម្រាប់កងរបស់គេរៀងៗខ្លួន[1429]។ អាស្រ័យដោយសារស្ថានភាពបែបនេះ មានមនុស្សជាច្រើនបានស្លាប់ដោយសារជម្ងឺ[1430] ហើយមានគ្រួសារខ្លះ ស្លាប់ស្ទើរតែដាច់ពូជតែម្តង[1431]។

៣៨៣. ប្រជាជនថ្មីបានទទួលរងនូវលក្ខខណ្ឌការងារធ្ងន់ធ្ងរជាងដូចជា ម្នាក់ៗត្រូវធ្វើការច្រើនអ្នកដទៃ ឬទទួលរងនូវការដាក់ទណ្ឌកម្មមិនសមហេតុផល[1432]។ កងទ័ព និងកម្មាភិបាលរបស់ ប.ក.ក បានស្រង់ជីវប្រវត្តិរបស់អ្នកលើកទំនប់នៅការដ្ឋាន ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលនឹងត្រូវចាប់ខ្លួន ឬសម្លាប់ នៅពេលខាងមុខ[1433]។

៣៨៤. សាក្សីមួយចំនួនផ្តល់សក្ខីកម្មថា បានឃើញ និងបានចូលរួមពីធីមង្គលការនៅការដ្ឋានទំនប់ត្រពាំងថ្មដែលជារឿយៗមានគូស្រករជាច្រើនសិបគូត្រូវបានរៀបការនៅក្នុងពិធីរួមគ្នា[1434]។ សាក្សីមួយរូបនិយាយថា មានការបង្ខំឱ្យមានគូស្រករ[1435] ទោះបីជាសក្ខីកម្មលើចំណុចនេះមិនមានភាពច្បាស់លាស់ក៏ដោយ ការរៀបការត្រូវតែមានការអនុញ្ញាតពីប្រធានកង ហើយប្រសិនបើគ្មានការអនុញ្ញាតពីប្រធានកងទេ គូស្រករនោះនឹងត្រូវយកទៅសម្លាប់[1436]។

៣៨៥. លើកលែងតែសាក្សីពីររូបដែលបានអះអាងថា មានការបង្រៀនខ្លះដែរដល់កុមារដែលធ្វើការនៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម[1437] ប៉ុន្តែ សក្ខីកម្មភាគច្រើនអះអាងថា មិនមានការអប់រំ ឬការបង្រៀនកុមារទេ[1438] ។

## សន្តិសុខ

៣៨៦. អ្នកលើកទំនប់មួយចំនួន ជាពិសេសប្រជាជនថ្មី[1439] ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលរបស់ ប.ក.ក ដើម្បីយកទៅ"អប់រំរៀនសូត្រ"[1440] បន្ទាប់មកបានបាត់ខ្លួនរហូត ហើយមិនដែលឃើញអ្នកទាំងនោះ

00605367



ត្រឡប់មកវិញទេ[1441]។ មានការបង្កប់គិញសម្ងាត់ចុះតាមដានត្រួតពិនិត្យនៅតាមកងនានា ដើម្បីស៊ើបសួររកពីជីវប្រវត្តិ និងសាវតារបស់អ្នកលើកទំនប់ និងកំណត់ពីអត្តសញ្ញាណរបស់បុគ្គលដែលត្រូវចាប់ខ្លួន ទោះបីជាអ្នកទាំងនោះបានធ្វើការទៅតាមផែនការកំណត់ក៏ដោយ[1442]។ ពួកគេត្រូវបានចោទថាជា *"ពួកសេអ៊ីអារបស់អាមេរិកកាំង"* ឬមានទំនាក់ទំនងជាមួយ*"យួន"*[1443]។ អ្នកទាំងនេះត្រូវបានចង និងបណ្តើរដោយកងទ័ព ឬឈ្លប[1444] ទៅកាន់ទីកន្លែងសម្លាប់។

៣៤៧. អ្នកលើកទំនប់ដែលធ្វើការមិនសម្រេចតាមផែនការកំណត់ ឬអ្នកដែលត្រូវបានចាត់ទុកថាមានជម្ងឺសតិអារម្មណ៍ នឹងត្រូវកំណត់មុខសញ្ញាថាជាជនក្បត់ ហើយត្រូវបញ្ជូនទៅកងករណីដែលត្រូវធ្វើការច្រើនជាងមុន (រែកដីពី ៣ ទៅ ៣,៥ ម៉ែត្រគូប)[1445]។ អ្នកលើកទំនប់ណាម្នាក់ដែលមិនបានសម្រេចតាមផែនការកំណត់ទេ នឹងបាត់ខ្លួននៅពេលយប់ ហើយត្រូវបានសម្លាប់ចោល[1446]។

៣៤៨. មិនមានសាក្សីណាម្នាក់និយាយថា មានមន្ទីរសន្តិសុខស្ថិតនៅនឹងការដ្ឋានទំនប់ត្រពាំងថ្មនោះទេ។ សាក្សីបញ្ជាក់ថា តាមធម្មតាមនុស្សត្រូវបានគេនាំខ្លួនទៅសម្លាប់នៅពេលយប់ ដោយម្តងៗមានចាប់ពីពីរ ឬបីនាក់ រហូតដល់ពីដប់ប្រាំទៅម្ភៃនាក់[1447]។ ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនគ្មាននរណាម្នាក់ ត្រូវបានឃើញវិលត្រឡប់មកវិញទេ[1448]។ មានសាក្សីមួយរូបនិយាយថា ការបាត់ខ្លួននេះគឺកើតចេញមកពីការ *"បញ្ជាពីថ្នាក់លើ"* [1449] ។ ប្រធានកង ត្រូវបានជូនដំណឹងមុនពេលមានការចាប់ខ្លួន [1450]។

៣៤៩. អ្នកលើកទំនប់ជាច្រើនត្រូវបានសម្លាប់ រួចរុញទម្លាក់ចូលក្នុងអាងទំនប់ទឹកនោះ ។ មានអ្នកខ្លះ ត្រូវបានបញ្ជាឲ្យជីករណ្តៅខ្លួនឯង បន្ទាប់មកត្រូវបានវាយសម្លាប់[1451]។ សាក្សីខ្លះនិយាយថា ស្ត្រីមានផ្ទៃពោះ ត្រូវបានវាយសម្លាប់ រួចហើយរុញទម្លាក់ចូលក្នុងអាងទំនប់ទឹកដូចដែលពួកកម្មាភិបាល ប.ក.ក និយាយថា *"ដើម្បីធ្វើស្ពានជាប់លុះត្រាតែយកស្ត្រីមានផ្ទៃពោះ យកទៅសម្លាប់ដាក់ត្រចៀកស្ពាន ទើបស្ពាននោះជាប់"* [1452]។ "ស្ពានទី១" ឬ "ត្រចៀកស្ពានទី១" គឺជាទីកន្លែងសម្រាប់សម្លាប់មនុស្សរួមមួយ[1453]។ ក្រោយការសម្លាប់សាកសពត្រូវបានគេទម្លាក់ទៅក្នុងបាតស្ពាន [1454]។

***

៣៥០. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩៤នាក់ **(កៅសិបប្រាំបួននាក់)** ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធ

00605368



នឹងទំនប់ត្រពាំងថ្ម[1455]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅទំនប់ត្រពាំងថ្ម។

## ការដ្ឋានទំនប់១មករា[1456]

### ទីតាំង និងដំណើរការសាងសង់

៣៥១. ការដ្ឋានទំនប់១មករាត្រូវបានសាងសង់ក្នុងគោលបំណងធ្វើជាប្រព័ន្ធធារាសាស្ត្រ[1457]។ ការសាងសង់ទំនប់នេះគឺ ដើម្បីបង្កើតជាអាងស្តុកទឹកមួយដោយទប់ស្ទឹងជីនិត។ ការដ្ឋានទំនប់១មករា ស្ថិតនៅក្នុងស្រុកបារាយណ៍ និងស្រុកសន្ទុករបស់ខេត្តកំពង់ធំ[1458]បច្ចុប្បន្ន ដោយយោងទៅលើប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីសកម្ពុជា ស្រុកទាំងនោះស្ថិតនៅតំបន់៤២ និងតំបន់៤៣ របស់ភូមិភាគឧត្តរ[1459] ដែលក្រោយមកត្រូវបានប្តូរជាភូមិភាគកណ្តាល ទំនងជាក្នុងអំឡុងពេលដែលទំនប់ និងអាងស្តុកទឹកនេះកំពុងតែសាងសង់[1460]។

៣៥២. ប្រឡាយត្រូវបានជីក ដើម្បីនាំយកទឹកមកស្រោចស្រពដីស្រែ។ ប្រឡាយមេដែលមានទំហំទទឹង២០ ម៉ែត្រ ជាប្រឡាយដែលនាំទឹកទៅកាន់ប្រឡាយតូចៗជាច្រើនដែលមានទំហំពី ២ ទៅ ៣ ម៉ែត្រ[1461]។ ទំនប់១មករា ត្រូវបានតភ្ជាប់ទៅទំនប់មួយទៀតដែលស្គាល់ថាជា“ទំនប់៦មករា”[1462] ជាមួយនឹងប្រឡាយមេដ៏វែងមួយ។ ការសាងសង់ទំនប់១មករា ចាប់ផ្តើមធ្វើនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ [1463] ហើយការសាងសង់បានចប់សព្វគ្រប់ ខណៈពេលដែលការសាងសង់ទំនប់៦មករា ត្រូវបានចាប់ផ្តើមធ្វើនាដើមឆ្នាំ១៩៧៨[1464]។

### ដំណើរការប្រព្រឹត្តទៅ

#### រចនាសម្ព័ន្ធគ្រប់គ្រង និងអ្នកធ្វើការ

៣៥៣. ការសាងសង់ទំនប់១មករា ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ដែលមាន កែ ពក ជាលេខាភូមិភាគ[1465]។ កែ ពក ក៏ជាសមាជិក

គណៈកម្មាធិការមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ[1466]។ ដូចនេះ ទំនាក់ទំនងរវាងភូមិភាគ និងមជ្ឈិមធ្វើឡើងតាមរយៈ កែ ពក ។ ឌុច បានបញ្ជាក់ថា កែ ពក ធ្លាប់ធ្វើដំណើរមកភ្នំពេញដើម្បីចូលរួមប្រជុំប្រចាំឆ្នាំរបស់បណ្តាមេដឹកនាំភូមិភាគ ឬក៏នៅពេលគាត់ត្រូវបានកោះហៅដោយ ប៉ុល ពត[1467]។ សាក្សីមួយចំនួនបានបញ្ជាក់ពីសារៈសំខាន់នៃទំនាក់ទំនងតាមសារទូរលេខ[1468]។

៣៩៤. កែ ពក[1469] បានប្រគល់គំនូសប្លង់ទំនប់១មករា ឲ្យមកសាធារណៈការភូមិភាគ ដែលដំបូងឡើយដឹកនាំដោយឈ្មោះ [លុប][1470]។ [លុប] ត្រូវបានជួយការងារដោយក្រុមអ្នកបច្ចេកទេសដែលមានដូចជា [លុប] និង [លុប][1471]។ មុននេះទាំង [លុប] និង [លុប] អ្នកទាំងពីរធ្លាប់ត្រូវបានបញ្ជូនឲ្យទៅរៀនផ្នែកធារាសាស្ត្រ និងវារីអគ្គីសនី នៅសាលាបច្ចេកទេសឫស្សីកែវនៅទីក្រុងភ្នំពេញ[1472]។ [លុប][1473] ក៏បានក្លាយជាប្រធានមន្ទីរសាធារណៈការរបស់ភូមិភាគ បន្ទាប់ពី សោ បានបាត់ខ្លួន[1474]។ អៀង ឆាំ បានប្រាប់ថា គាត់រាយការណ៍ទៅ កែ ពក ឬកម្លាំងរបស់ កែ ពក នៅពេលពួកគេចុះមកពិនិត្យការដ្ឋានសាងសង់[1475]។ សាក្សីខ្លះបានអះអាងថា ការចុះមកពិនិត្យការដ្ឋាននេះ កើតមានឡើងជាញឹកញាប់[1476]។ អឿន គឺជាកម្មាភិបាលថ្នាក់ខ្ពស់ម្នាក់ ដែលមានតួនាទីសំខាន់ពាក់ព័ន្ធនឹងការសាងសង់[1477] គាត់ត្រូវបានតែងតាំងជាលេខាតំបន់៤២[1478] ជាតំបន់ដែលការដ្ឋានស្ថិតនៅ។

៣៩៥. ការងារសាងសង់ ព្រមទាំងការមើលខុសត្រូវលើការសាងសង់ទំនប់១មករានេះ មានការចូលរួមពីគ្រប់លំដាប់ថ្នាក់ទាំងអស់ តាមឋានានុក្រមនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីសកម្ពុជា។ លំដាប់ថ្នាក់នីមួយៗត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវជាក់លាក់រៀងៗខ្លួន និងកាន់ការងារតាមកន្លែងដោយគោរពតាមខ្សែសង្វាក់បញ្ជាដែលមានចាប់តាំងពីថ្នាក់មេកង កម្មាភិបាលថ្នាក់ឃុំ ស្រុក តំបន់ រហូតដល់កម្មាភិបាលថ្នាក់ភូមិភាគ[1479]។ រៀងរាល់ប្រាំមួយខែម្តង ឬមួយឆ្នាំម្តង មានការរៀបចំប្រជុំនៅភូមិភាគ ដែលអង្គប្រជុំដឹកនាំដោយ កែ ពក និងមានការចូលរួមពីគណៈឃុំ គណៈស្រុក គណៈតំបន់ ដែលនៅក្នុងអង្គប្រជុំនោះអ្នកចូលរួមត្រូវរាយការណ៍អំពីលទ្ធផលការងារ[1480]។

៣៩៦. សមាសភាពនៃគណៈដឹកនាំស្រុក គណៈដឹកនាំតំបន់ និងគណៈកម្មាធិការផ្សេងទៀតរបស់ភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់)មានការផ្លាស់ប្តូរជាបន្តបន្ទាប់ ដោយសមាជិកខ្លះត្រូវបានចាប់ខ្លួន និងខ្លះបានបាត់ខ្លួនក្នុងអំឡុងពេលសាងសង់ទំនប់១មករា[1481]។ លេខាតំបន់៤១ តំបន់៤២ និងតំបន់៤៣

និងកម្មាភិបាលដែលបានមកជំនួសពួកគេ[1482] ខ្លះក៏ត្រូវបានបាត់ខ្លួនផងដែរ។ កម្មាភិបាលមួយចំនួនត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១[1483]។ គណៈតំបន់ទាំងបី៖ តំបន់៤១ តំបន់៤២ និងតំបន់៤៣ ទទួលខុសត្រូវប្រមូលកម្លាំងមកពីបណ្ដាស្រុកនានា ដើម្បីចូលរួមក្នុងការសាងសង់ទំនប់១មករា[1484]។ ថ្នាក់តំបន់ធ្វើទំនាក់ទំនងជាមួយថ្នាក់ស្រុកតាមរយៈកិច្ចប្រជុំ និងតាមរយៈសេចក្ដីរាយការណ៍[1485]។ ដូចគ្នានេះដែរ ចំពោះទំនាក់ទំនងរវាងថ្នាក់ស្រុក និងថ្នាក់ឃុំ ថ្នាក់ស្រុកគឺជាអ្នកធ្វើការបែងចែកការងារនិងដាក់បញ្ជានានាទៅឲ្យថ្នាក់ឃុំក្នុងការអនុវត្តផែនការការងារ[1486]។ អ្នកលើកទំនប់ត្រូវបែងចែកជាក្រុមៗ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេក្រុម[1487] ដែលត្រូវបានតែងតាំងដោយមេភូមិ និងកម្មាភិបាលថ្នាក់ឃុំ[1488]។ ការប្រជុំនានាធ្វើឡើងដើម្បីពិនិត្យថាតើការងារដែលបានដាក់ឲ្យធ្វើគ្រប់ផែនការដែរឬទេ និងថាតើផែនការបញ្ជានានាត្រូវបានគោរពដែរឬទេ ហើយមានករណីខ្លះ ការប្រជុំគឺធ្វើដើម្បីឲ្យមនុស្សសារភាពពីកំហុសរបស់ខ្លួន[1489]។ "ថ្នាក់ក្រោម"ត្រូវរាយការណ៍ជូន"ថ្នាក់លើ" អំពីបញ្ហាផ្សេងៗដូចជា ការខ្វះខាតស្បៀង ឬ ថ្នាំពេទ្យ[1490] ឬអំពីបញ្ហាការងារសាងសង់ និងបញ្ហាសន្តិសុខនៅទំនប់១មករា[1491]។ អតីតប្រធានភូមិម្នាក់បានពន្យល់ថា នៅពេលដែលការងារមិនត្រូវបានធ្វើទៅតាមផែនការ សមាជិក"ថ្នាក់ក្រោម"ត្រូវបានចោទថាក្បត់ ជួនកាលមេក្រុមរបស់ពួកគេជាអ្នកចោទ រួចយកទៅសម្លាប់[1492]។ សាក្សីខ្លះបានប្រាប់ថាមេកង និងមេក្រុមជាអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្ដីសម្រេចដើម្បីឈានទៅចាប់អ្នកលើកទំនប់ខ្លះយកទៅបាត់[1493] ឬក៏ត្រូវទទួលទណ្ឌកម្ម[1494]។ សមាជិកឈ្លបមូលដ្ឋានខ្លះធ្លាប់ត្រូវបានឃើញថា មានកាន់ដំបង ចបកាប់ កាំភ្លើង ឬកាំបិត[1495] ហើយត្រូវបានដឹងថា ជាអ្នកសម្លាប់មនុស្ស[1496]។ សាក្សីខ្លះទៀតរៀបរាប់ថា កងសន្តិសុខ និងកម្មាភិបាលមូលដ្ឋានមួយចំនួន[1497] ជាអ្នកមកពីភូមិភាគនិរតី[1498]។

**៣៩៧.** ប៉ុល ពត ធ្លាប់បានមកការដ្ឋានទំនប់១មករា យ៉ាងហោចណាស់ក៏បានមួយដងដែរ នាឱកាសសម្ពោធន៍ទំនប់១មករា[1499] ដោយរួមមានវត្តមានភ្ញៀវបរទេសជាច្រើន[1500]។ **អៀង សារី**[1501] **ខៀវ សំផន**[1502] **តា ម៉ុក**[1503] និង **សុន សេន**[1504] ត្រូវបានឃើញមានវត្តមាននៅឯការដ្ឋានទំនប់១មករាផងដែរ។ **នួន ជា**[1505] បានទៅមើលការដ្ឋាន ហើយគាត់ "*បាននិយាយឲ្យប្រជាជនខំធ្វើការដើម្បីធ្វើទប់ទឹកសម្រាប់ធ្វើស្រែ*[1506]"។ អៀង ធីរិទ្ធ ធ្លាប់ធ្វើដំណើរទស្សនកិច្ចទំនប់១មករា ជាមួយនឹងគណៈប្រតិភូឡាវនាខែមេសា ឆ្នាំ១៩៧៧[1507]។ តាមការផ្ដល់សក្ខីកម្មរបស់សាក្សីម្នាក់បានឲ្យដឹងថា នៅពេលនោះ អ្នកដែលចូលរួមស្វាគមន៍ អៀង ធីរិទ្ធ ត្រូវបានផ្ដល់អាហារហូបគ្រប់គ្រាន់ ព្រមទាំងសម្លៀកបំពាក់ស្អាតៗ ហើយគាត់ ត្រូវបានជូនដំណឹងអំពីកង្វះខាតថ្នាំ នៅពេលដែលគាត់ចូលមើល

00605371



មន្ទីរពេទ្យមួយ[1508]។

<u>លក្ខខណ្ឌការងារ និងការរស់នៅ</u>

៣៥៨. បើតាមសាក្សីដែលជាអតីតអ្នកលើកទំនប់[1509] និងអតីតកម្មាភិបាលមូលដ្ឋាន[1510]បានឱ្យដឹងថាមានមនុស្សរាប់ម៉ឺននាក់បានចូលរួមលើកទំនប់១មករា[1511]។ ពួកគេភាគច្រើនមកពីបណ្ដាស្រុកជិតៗនោះ[1512] និងបណ្ដាតំបន់នានាដូចជា៖ តំបន់៤១ តំបន់៤២ និងតំបន់៤៣[1513]។ អ្នកលើកទំនប់ភាគច្រើនជាយុវវ័យ និងមនុស្សវ័យកណ្ដាលមានទាំងប្រុស ទាំងស្រី[1514]។ អ្នកលើកទំនប់មួយចំនួនគឺជា "ប្រជាជនថ្មី"[1515] (មួយចំនួននៃពួកគេជាអ្នកដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ)[1516] ជាជនជាតិចាម[1517] ឬយ៉ាងហោចណាស់ តាមការបំភ្លឺរបស់សាក្សីម្នាក់មានទាំងកូនកាត់ចិន និងវៀតណាមផងដែរ[1518]។

៣៥៩. អ្នកលើកទំនប់មិនអាចនិយាយទាក់ទងគ្នាដោយសេរី[1519] ឬគេចវេសដើរហើរតាមទំនើងចិត្តទេ[1520]។ កញ្ចែ ឬមេក្រូ[1521] ត្រូវបានគេប្រើដើម្បីប្រមូលអ្នកលើកទំនប់ ដែលពួកគេធ្វើការទៅតាមម៉ោងកំណត់ដោយពេលខ្លះបានសម្រាកតិចតួច និងពេលខ្លះគ្មានពេលសម្រាកឡើយ[1522]។ ក្រុមលើកទំនប់ភាគច្រើនធ្វើការនាពេលយប់[1523]។ មានការដាក់កំណត់ផែនការពីទំហំដីដែលត្រូវជីក និងលើកក្នុងមួយថ្ងៃៗ ហើយបើអ្នកណាធ្វើមិនបានគ្រប់ផែនការដែលបានកំណត់ត្រូវទទួលទណ្ឌកម្ម[1524]។ សាក្សីបានរៀបរាប់អំពីទំហំដីដែលត្រូវជីក និងលើក គឺរវាងពី ១ ទៅ ៣ ម៉ែត្រគូបក្នុងមួយថ្ងៃ[1525]។ អតីតមេភូមិបាននិយាយថា ពេលខ្លះគាត់កុហកថ្នាក់លើថាក្រុមគាត់បានធ្វើគ្រប់ផែនការហើយ[1526]។ ការងារធ្ងន់ៗភាគច្រើនត្រូវបានធ្វើឡើងដោយដៃ ប៉ុន្តែក៏មានការប្រើប្រាស់គ្រឿងចក្រផងដែរ[1527]។ ចំពោះរបបអាហារវិញភាគច្រើនមិនគ្រប់គ្រាន់ទេ [1528]។ ចំពោះការស្នាក់នៅបុរស និងស្ត្រីស្នាក់នៅដាច់ដោយឡែកពីគ្នា[1529] នៅក្នុងរោង ឬជាកន្លែងជ្រកធម្មតា[1530]។ គ្មានមុង ភួយ ឬកន្ទេលត្រូវបានផ្ដល់ឱ្យឡើយ និងភាគច្រើននាំគ្នាដេកផ្ទាល់ដី[1531]។

៣៦០. អ្នកលើកទំនប់ទទួលរងនូវការប្រព្រឹត្តផ្សេងៗគ្នា អាស្រ័យលើក្រុមរបស់ពួកគេ និង/ឬអាស្រ័យថាតើពួកគេជាប្រជាជនថ្មី ឬជនជាតិចាម[1532]។ ជនជាតិចាម និងពុទ្ធសាសនិកមិនត្រូវបានអនុញ្ញាតិឱ្យប្រតិបត្តិសាសនារបស់ពួកគេឡើយ[1533]។ ម៉ោងធ្វើការ ទំហំការងារ និងវិន័យមានការប្រែប្រួលពីក្រុមមួយទៅក្រុមមួយទៀត[1534]។ សាក្សីពីររូបបានរៀបរាប់ឱ្យដឹងថា មានអ្នកខ្លះមានអាហារហូប



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

គ្រប់គ្រាន់[1535] ខណៈដែលមានសាក្សីផ្សេងទៀតបានប្រាប់ឲ្យដឹងថា ប្រជាជនថ្មីទទួលបានអាហារតិចជាងប្រជាជនដទៃ[1536]។ សាក្សីផ្សេងទៀតបានបញ្ជាក់ថា ប្រជាជនមូលដ្ឋាន និងកម្មាភិបាលរបស់បក្សកុម្មុយនីសកម្ពុជាមានសម្លៀកបំពាក់ល្អជាង[1537] និងមានការរស់នៅប្រសើរជាង[1538]។ តួនាទីមួយចំនួនដូចជាចុងភៅ មេកង និងបុគ្គលិកមន្ទីរគមនាគមន៍គឺ មិនអនុញ្ញាតិឲ្យប្រជាជនថ្មី ឬជនជាតិចាម ឬខ្មែរកាត់ចិនធ្វើទេ[1539]។ បញ្ហាទាំងអស់នោះ(លក្ខខណ្ឌការងារ និងរបបអាហារមិនគ្រាប់គ្រាន់) និងស្ថានភាពគ្មានអនាម័យ[1540] បណ្តាលឲ្យមានមនុស្សឈឺជាច្រើន ដោយសារជំងឺផ្សេងៗ[1541]។ ការព្យាបាលមិនមានលក្ខណៈសមស្រប៖ មន្ទីរពេទ្យភាគច្រើននៅឆ្ងាយ បុគ្គលិកពេទ្យមិនមានការបណ្តុះបណ្តាលបានត្រឹមត្រូវ និងជានិច្ចកាលមិនមានពេទ្យប្រចាំការនៅការដ្ឋានសាងសង់។ ចំណែកឯថ្នាំព្យាបាលក៏មិនមានចំនួនគ្រប់គ្រាន់ និងគ្មានប្រសិទ្ធភាពដែរ[1542]។ ថ្នាំព្យាបាលបែបបុរាណដូចជា*ថ្នាំអាចម៍ទន្សាយ* (ថ្នាំគ្រាប់ស្រដៀងនឹងអាចម៍ទន្សាយ) ឬថ្នាំដបត្រូវបានគេយកមកប្រើប្រាស់[1543]។

**៣៦១.** មេភូមិ[1544] ឬ "អង្គការ"[1545] បានចាត់ចែងឲ្យមានការរៀបអាពាហ៍ពិពាហ៍ដល់អ្នកលើកទំនប់[1546] ឬ កម្មាភិបាលដូចជាករណី [លុប] នាឆ្នាំ១៩៧៦[1547]។ សាក្សីបានរៀបរាប់ថាពួកគេត្រូវបានគេរៀបចំឲ្យមានគ្រួសារជាក្រុមជាមួយនឹងគូស្រករដទៃទៀត[1548] ហើយអតីតមេភូមិម្នាក់បាននិយាយថា *"ខ្ញុំធ្លាប់បានចាត់ចែងរៀបការឲ្យពួកគេ ជួនកាលរៀបការម្តងៗមានប្រហែល ៣០ ទៅ ៤០គូ"* [1549]។ សាក្សីភាគច្រើនបានឆ្លើយបំភ្លឺឲ្យដឹងថា មិនមានការអនុញ្ញាតឲ្យប្រជាជនរៀបអាពាហ៍ពិពាហ៍តាមបំណងដែលសាមីខ្លួនចង់បានទេ ហើយពួកគេក៏មិនហ៊ានបដិសេធ ឬតវ៉ាទៅនឹងអាពាហ៍ពិពាហ៍ដែលបានរៀបចំឡើងនោះដែរ ដោយខ្លាចមានការបញ្ជូនទៅកសាង[1550]។ អតីតកម្មាភិបាលម្នាក់បានពន្យល់ប្រាប់ថា *"ប្រសិនបើមានភាគីណាមួយមិនព្រម គឺគេមិនរៀបការឲ្យទេ គឺទុកគូនោះសិន"* សាក្សីនេះប្រាប់ថែមទៀតថា *"មានគូខ្លះក្រោយរៀបការទៅ គឺមិនចុះសម្រុងនឹងគ្នាទេ តែគេមិនហ៊ានប្រកែកដែរទាំងស្រី ទាំងប្រុស"*[1551]។

**៣៦២.** ការដ្ឋានសាងសង់ទំនប់១មករា ត្រូវបានតាមដានត្រួតពិនិត្យយ៉ាងជិតដល់។ អ្នកត្រួតពិនិត្យបានដើរមើលយ៉ាងល្អិតល្អន់ដើម្បីឲ្យដឹងថា តើផែនការការងារដែលបានដាក់ឲ្យបំពេញបានគ្រប់ជ្រុងជ្រោយដែរឬទេ និងថា តើការងារដែលបានធ្វើនោះគ្រប់ទៅតាមផែនការដែរឬទេ។ ការសាងសង់ត្រូវបានត្រួតពិនិត្យតាមគ្រប់លំដាប់ថ្នាក់ដោយរួមមាន ប្រធានកង ប្រធានក្រុម កម្មាភិបាលឃុំ កម្មាភិបាលស្រុក[1552] និង ជួនកាលមានកម្មាភិបាលថ្នាក់តំបន់ ឬថ្នាក់ភូមិភាគផងដែរ[1553] ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605373



មានកងសន្តិសុខជាអ្នកតាមដានពិនិត្យផងដែរ[1554] និងសាក្សីខ្លះប្រាប់ឱ្យដឹងថា មានគិញនៅក្នុងក្រុម[1555]។ "កំហុស" ឬ"ការប្រព្រឹត្តខុស"ណាមួយត្រូវបានលើកយកមកធ្វើការប្រជុំទិតៀន ឬស្វ័យទិតៀន ដែលធ្វើឡើងនាពេលយប់។ ការអប់រំកែប្រែអនុវត្តផងដែរចំពោះជនណាដែលមិនគោរពតាមបញ្ជា[1556]។ អ្នកខ្លះត្រូវបានវាយ ឬដាក់ទណ្ឌកម្មធ្ងន់ធ្ងរ[1557]។ អ្នកលើកទំនប់ និងកម្មាភិបាលម្នាក់ៗរស់នៅក្នុងស្ថានភាពភ័យខ្លាច ដោយខ្លាចពីការចាប់ចង និងយកទៅសម្លាប់[1558]។

៣៦៣. មានមនុស្សមួយចំនួនបានធ្វើអត្តឃាត អ្នកខ្លះទៀតស្លាប់ដោយសារជម្ងឺ[1559] អត់អាហារ និង/ឬធ្វើការហួសកម្លាំង[1560]។ មានអ្នកផ្សេងទៀតស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗដូចជា រលំថ្មសង្កត់ ឬបាក់ដីលើ[1561]។ ទោះបីជាយ៉ាងណាក៏ដោយ មានសាក្សីម្នាក់បានបញ្ជាក់ថា នៅក្នុងក្រុមគាត់ពុំមានអ្នកស្លាប់ដោយខ្វះអាហារ ឬធ្វើការហួសកម្លាំងទេ[1562]។

## សន្តិសុខ

៣៦៤. ក្នុងឋានៈជាលេខាភូមិភាគ កែ ពក ត្រូវបានផ្តល់អំណាចក្នុងការធ្វើសេចក្តីសម្រេចនានា ពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅក្នុងភូមិភាគដែលគាត់កាន់កាប់ ហើយគាត់ហាក់ធ្លាប់បានប្រើប្រាស់អំណាចនោះទាំងរំលោភបំពាន[1563] យ៉ាងហោចណាស់បានធ្វើទៅលើប្រជាជនសាមញ្ញ ហើយចំពោះការបោសសម្អាត និងការសម្លាប់សមាជិកព្រមទាំងកម្មាភិបាលដទៃទៀត គាត់ទំនងជាត្រូវពិគ្រោះយោបល់ជាមួយថ្នាក់លើរបស់បក្ស[1564]។ តាមសាក្សីពីរនាក់បានអះអាងថា មានការចាត់វិធានការចំពោះអ្នកដែលបានប្រព្រឹត្តខុសសីលធម៌(ទោះបីជាយ៉ាងណាក៏ដោយពួកគេមិនចាំបាច់ថាត្រូវតែសម្លាប់នោះទេ)[1565]។

៣៦៥. មនុស្សម្នាក់ៗដឹងថាពួកគេនឹងត្រូវបានចាប់ខ្លួន ប្រសិនបើធ្វើអ្វីមួយខុស ឬក៏មិនគោរពតាមបញ្ជា[1566] ដូចជា "លួច"ដំឡូង[1567] ធ្វើការមិនគ្រប់ផែនការកំណត់ ឈឺ "ខ្ជិល" ឬត្អូញត្អែរ[1568]។

៣៦៦. សាក្សីភាគច្រើនស្គាល់អ្នកដែលបានបាត់ខ្លួនពីការដ្ឋានទំនប់១មករា ឬបានឮអំពីការបាត់ខ្លួនទាំងនេះ[1569]។ ការបាត់ខ្លួនភាគច្រើនកើតមានឡើងនៅពេលយប់[1570]។ អ្នកលើកទំនប់ត្រូវបានគេហៅទៅប្រជុំ ឬទៅ រៀនសូត្រ[1571] ឬត្រូវបានគេចង[1572] រួចដឹកតាមឡាន ឬរទេះគោយកទៅដោយមិនឃើញត្រលប់មកវិញ[1573]។ មូលហេតុនៃការបាត់ខ្លួនភាគច្រើន មិនត្រូវបានគេដឹងឡើយ[1574] ហើយគេមិនហ៊ានសួរនាំដោយសារពួកគេខ្លាចជាប់ពាក់ព័ន្ធដល់ខ្លួន[1575]។ មេក្រុមត្រូវ

00605374



បានបើកសម្លេងឲ្យឮខ្លាំង នៅពេលដែលគេកំពុងសម្លាប់មនុស្ស ដើម្បីកុំឲ្យឮសម្លេងស្រែករបស់ជនរងគ្រោះ និងដើម្បីលាក់បាំងកុំឲ្យដឹងអំពីវាសនារបស់អ្នកដែលបានបាត់ខ្លួន[1576] មនុស្សភាគច្រើនដែលបានបាត់ខ្លួន គឺអ្នកដែលជាប់និន្នាការរបប លន់ នល់[1577] "ជនជាតិវៀតណាម" ឬអ្នកដែលត្រូវចោទថាជាប់និន្នាការជាមួយវៀតណាម[1578] "ប្រជាជនថ្មី"[1579] ឬចាម[1580]។ "ប្រជាជនមូលដ្ឋាន" ក៏មានបាត់ខ្លួនផងដែរ[1581]។

**៣៦៧.** សាក្សីខ្លះបានឃើញការចាប់ខ្លួន[1582] ឯសាក្សីខ្លះទៀតបានឮថា មានការសម្លាប់មនុស្ស ឬបញ្ជូនទៅកាន់មន្ទីរសន្តិសុខ[1583]។ សាក្សីម្នាក់បានឃើញគេសម្លាប់មនុស្សម្នាក់[1584]។ វត្តបារាយណ៍ជាន់ដែក[1585] ដែលនៅក្បែរការដ្ឋាននោះត្រូវបានដឹងថាជាកន្លែងដែលយកមនុស្សទៅសម្លាប់[1586] ប៉ុន្តែអ្នកខ្លះត្រូវបាននាំយកទៅសម្លាប់នៅកន្លែងដទៃទៀតផងដែរ[1587]។

***

**៣៦៨.** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន**៤៥ នាក់ (សែសិបប្រាំនាក់)** ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងទំនប់១មករា[1588]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្ភ តិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤)។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅទនប់១មករា។

## ការដ្ឋានស្រែអំបិលរបស់រដ្ឋាភិបាល[1589]

### ទីតាំង និងការបង្កើត

**៣៦៩.** ការដ្ឋានស្រែអំបិលគ្របដណ្តប់លើផ្ទៃដីស្រែអំបិល ក្នុងស្រុកកំពត ខេត្តកំពត។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ការដ្ឋាននេះស្ថិតនៅក្នុងតំបន់៣៥ ក្នុងភូមិភាគនិរតី[1590]។ សាក្សីដែលត្រូវបានស្តាប់ចម្លើយទាំងអស់សុទ្ធតែធ្លាប់ធ្វើការនៅកំពង់កណ្តាល (ឥឡូវនេះមានឈ្មោះថា បឹងរូងទី១ និងបឹងរូងទី២ មានផ្ទៃដី១.៤០០ ហិកតា) សេះស(៣១៤ហិកតា) ត្រើយកោះ (៧៩៦ហិកតា) និងបឹងទូក(២០០ហិកតា)[1591]។ កន្លែងផ្សេងៗ

ទំនងជាផ្នែកនៃការដ្ឋានស្រែអំបិលនេះផងដែររួមមាន៖ ជ្រៃយល់, ក្បាលរមាស, កំពង់នង់, កែប, កែបថ្មី, លក, អង្កោលរ៉ី និងស្រែកោះ[1592]។

៣៧០. ការដ្ឋានស្រែអំបិលមានតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1593] ហើយស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់ពីមុនកាលបរិច្ឆេទនេះផងដែរ[1594]។ ទំហំស្រែអំបិលត្រូវបានពង្រីកយ៉ាងទូលាយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1595]។ សាក្សីភាគច្រើនបានមកដល់ស្រែអំបិលនាប៉ុន្មានខែក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1596] ហើយការដ្ឋានស្រែអំបិលនេះមានដំណើរការរហូតដល់ ខែមករា ឆ្នាំ១៩៧៩[1597]។ បច្ចុប្បន្ននេះ ស្រែអំបិលនៅតែអាចប្រើការបានដដែល។

**ដំណើរការប្រព្រឹត្តិទៅ**

**<u>រចនាសម្ព័ន្ធ និងអ្នកធ្វើការ</u>**

៣៧១. ការដ្ឋានស្រែអំបិលត្រូវបានស្គាល់ជាផ្លូវការថាជា ការដ្ឋានស្រែអំបិលរបស់"រដ្ឋ" និងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយជាពិសេសក្រសួង ឬគណៈកម្មាធិការឧស្សាហកម្ម[1598] ដឹកនាំដោយ [លុប] រហូតដល់ការចាប់ខ្លួនគាត់ក្នុងដើមខែវិច្ឆិកា ឆ្នាំ១៩៧៨[1599]។ ក្រសួង ឬគណៈកម្មាធិការឧស្សាហកម្ម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ វន វ៉េត ជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច[1600]។

៣៧២. ការផលិតអំបិលគឺជាការយកចិត្តទុកដាក់ផ្ទាល់របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[1601]។ ក្នុងអំឡុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍របស់ ប.ក.ក នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលចូលរួមដោយ នួន ជា អៀង សារី និង ខៀវ សំផន ការបង្កើនផលិតផលអំបិលចាប់ពី៥០.០០០ ទៅ ៦០.០០០ តោន ត្រូវបានណែនាំដោយ *"អង្គការ"* [1602]។ ការបង្កើនផលិតផលអំបិលសម្រាប់ឆ្នាំ១៩៧៧ ដល់ឆ្នាំ ១៩៨០ ត្រូវបានដាក់ចេញជាផែនការផងដែរ ដោយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ក្នុង"ផែនការ៤ឆ្នាំ ក្នុងការកសាងសង្គមនិយមក្នុងគ្រប់វិស័យ"[1603]។ ផលិតផលអំបិលទំនងជាត្រូវបានដឹក និងចែកចាយនៅទូទាំងប្រទេសកម្ពុជា[1604]។ [លុប] បានពន្យល់ថា ខៀវ សំផន ជាអ្នកទទួលខុសត្រូវក្នុងការ បែងចែកដល់ប្រជាជននូវផលិតផលជាច្រើនប្រភេទដែលផលិតបាន ហើយថា ខៀវ សំផន បានឆ្លើយឆ្លងទូរលេខ និងសារលិខិតជាទៀងទាត់ ជាមួយអង្គភាពផ្សេងៗ ទាក់ទិននឹងការបែងចែកអំបិល ស្រូវ សំលៀកបំពាក់ និងសម្ភារៈផ្សេងទៀត[1605]។

៣៧៣. សមាជិកបក្សជាន់ខ្ពស់បានចុះមកពិនិត្យស្រែអំបិល ដែលនេះសបញ្ជាក់ឲ្យឃើញអំពីសារសំខាន់នៃការដ្ឋាននេះចំពោះកម្មាភិបាលមជ្ឈិមបក្ស។ សាក្សីបាននិយាយថា តា ម៉ុក (លេខាភូមិភាគនិរតី និងជាសមាជិកគណៈអចិន្ត្រៃយ៍(ស្លាប់)) វន វ៉េត(ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច(ស្លាប់)) និង ជូ ជេត ហៅ ស៊ី (លេខាភូមិភាគបស្ចឹម(ស្លាប់)) បានមកមើលការដ្ឋាននេះដែរ[1606]។ អតីតកម្មាភិបាលម្នាក់បាននិយាយថា នួន ជា បានទៅពិនិត្យមើលស្រែអំបិលនៅចុងឆ្នាំ១៩៧៧។ ក្នុងអំឡុងពេលចុះមកពិនិត្យ នួន ជា បានកោះប្រជុំនៅកន្លែងមួយក្នុងការដ្ឋានជាមួយកងវរៈសេនាតូច ហើយណែនាំកម្មករ ថា៖ *"ឲ្យខិតខំប្រឹងធ្វើការ ទៅថ្ងៃមុខប្រទេសនឹងបានជឿនលឿនមហាលោតផ្លោះមហាអស្ចារ្យ"* [1607]។ មានភស្តុតាងផងដែរថា គណៈប្រតិភូបរទេសក៏ធ្លាប់បានទៅទស្សនកិច្ចមើលការដ្ឋានស្រែអំបិលក្នុងឆ្នាំ១៩៧៨ផងដែរ[1608]។

៣៧៤. ការដ្ឋានស្រែអំបិលត្រូវបានចាត់ទុកដោយបក្សកុម្មុយនីស្តកម្ពុជាថា ជាគំរូមួយជោគជ័យរបស់បដិវត្ត ហើយជាទៀងទាត់ត្រូវបានលើកសរសើរដោយសារសម្រេចការងារបានតាមផែនការ[1609]។ កម្មាភិបាល និងកម្មករជាច្រើនត្រូវបានចាត់ទុកថា មានភាពខ្លាំងផ្នែកនយោបាយ ហើយដូចនេះអង្គភាពខាងលើមិនមានកង្វល់អំពីបញ្ហាសន្តិសុខឡើយ[1610]។ ក្នុងសុន្ទរកថានាឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ក្នុងឱកាសអបអរសាទរជ័យជំនះថ្ងៃទី១៧ ខែមេសា ខៀវ សំផន បានសរសើរអង្គភាពផលិតអំបិលដោយលើកឡើងថា ជាអង្គភាពគំរូជឿនលឿន សម្រាប់ទូទាំងប្រទេសយកតម្រាប់តាម[1611]។

៣៧៥. ទោះជាភស្តុតាងមិនបានបង្ហាញច្បាស់ក្តី ប្រធានគ្រប់គ្រងការដ្ឋានស្រែអំបិលមុនគេទំនងជាឈ្មោះ [លុប] រហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៨[1612]។ [លុប] ដែលពីដំបូងជាអនុប្រធានរបស់ [លុប] ក្រោយមកបានឡើងជំនួស [លុប][1613]។ យោងតាមអតីតកម្មាភិបាលម្នាក់និយាយថា ឈ្មោះ [លុប] ជាអ្នកគ្រប់គ្រងនៅកំពង់កណ្តាល ឈ្មោះ រី (ស្រី) ដឹកនាំកងវរៈសេនាតូចនៅសេះស និង [លុប] គ្រប់គ្រងការដ្ឋានត្រើយកោះ[1614]ក្រោយពី [លុប] ត្រូវបានចាប់ខ្លួន[1615]។ កម្មករត្រូវបានបែងចែកជាក្រុម កងហា និងកងរយ[1616]។ អ្នកបច្ចេកទេសនៅការដ្ឋានបានពន្យល់ថា ពួកគេគ្មានសិទ្ធិក្នុងការបញ្ជាដល់កម្មករទេ ហើយពួកគេត្រូវបានគ្រប់គ្រង និងដឹកនាំយ៉ាងជិតដល់ដោយប្រធានក្រុម ឬប្រធានកង[1617]។ កម្មករ និងអ្នកបច្ចេកទេសត្រូវបានប្រាប់នៅក្នុងអង្គប្រជុំដោយប្រធានការដ្ឋានថា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ត្រូវប្ដេជ្ញាប្រឹងប្រែងធ្វើការបង្កើនផលិតផលអំបិលឱ្យបានច្រើន ដើម្បីសម្រេចតាមផែនការ[1618]។

**ជីវភាពរស់នៅ និងលក្ខខណ្ឌការងារ**

៣៧៦. ប្រភពផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ថា មាននារីចំនួនប្រហែល ៥.០០០នាក់ និង អតីតយុទ្ធជនចំនួន៥០០នាក់ (ភាគច្រើនជាអ្នកបច្ចេកទេស) ធ្វើការនៅការដ្ឋានស្រែអំបិល។ ចំនួន នេះត្រូវបានបញ្ជាក់ដោយសាក្សី[1619]។ ក្នុងការដ្ឋានកំពង់កណ្ដាល មានកម្មករជាស្ត្រីប្រហែល ៣.០០០នាក់[1620] និង នៅការដ្ឋានត្រើយកោះប្រមាណ ១.០០០នាក់ [1621]។ មានសាក្សី១២ រូប ជាស្ត្រីដែលធ្លាប់ធ្វើការ នៅ ការដ្ឋានស្រែអំបិល[1622]។ ភាគច្រើននៃកម្មករគឺជាប្រជាជនមូលដ្ឋានមក ពីខេត្តកំពត[1623] និងតាកែវ[1624]។ កម្មករខ្លះមកពីខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ស្វាយរៀង កំពង់ធំ និងកោះកុង[1625]។ មានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយចំនួននៃភូមិភាគបូព៌ា ទំនងត្រូវបាន បញ្ជូនទៅការដ្ឋានស្រែអំបិល នៅពេលដែល សោ ភឹម ត្រូវបានចោទប្រកាន់ថា ក្បត់ និងចាប់ខ្លួន។ កម្មាភិបាលភូមិភាគបូព៌ាទាំងនេះធ្លាប់បានធ្វើការនៅតាមមន្ទីរពេទ្យក្នុងក្រុងភ្នំពេញរហូតដល់ពេល បញ្ជូនមកការដ្ឋាន[1626]។ លើសពីនេះ សាក្សីបានអះអាងថា មានការបញ្ជូនកម្មករជាទៀងទាត់ ពីការដ្ឋានស្រែអំបិល ទៅមន្ទីរ ក-២ របស់ក្រសួងសង្គមកិច្ច ឬមន្ទីរពេទ្យចំណុះក្រសួងនេះ ជាពិសេសមន្ទីរពេទ្យ០៦-មករា មន្ទីរពេទ្យព-១ និងមន្ទីរពិសោធន៍ ហើយការបញ្ជូននេះធ្វើឡើង ពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ [1627]។

៣៧៧. កម្មកររស់នៅរួមគ្នាក្នុងផ្ទះ ហើយពេលយប់មានការឃ្លាំមើលដោយអ្នកយាម ដែលគ្មានកាន់អាវុធ [1628]។ នៅក្នុងរដូវប្រាំង កម្មករធ្វើកិច្ចការជាក់លាក់ដូចជា លើកភ្លឺស្រែអំបិល កៀរសម្អាតអំបិល បង្ហាប់ដីដោយប្រើអង្គប់ជើងដំរី អូសរនាស់ក្នុងទឹកអំបិល និងរែកអំបិលដាក់ចូលទៅក្នុងឃ្លាំង ឬ លីបាវអំបិលដាក់ក្នុងឡាន[1629]។ ក្នុងរដូវវស្សា កម្មករត្រូវធ្វើសម្ភារៈទុកសម្រាប់ផលិតអំបិល នាពេលខាងមុខ និងត្រូវបានបញ្ជូនទៅធ្វើស្រែនៅតាមសហករណ៍ទូទាំងខេត្តកំពត[1630]។ កម្មករ ចាប់ផ្ដើមការងារនៅម៉ោង៤ព្រឹក ឬម៉ោង៦ ព្រឹក [1631]។ ពេលខ្លះ កម្មករត្រូវបានបង្ខំឱ្យធ្វើ ការងារទាំងយប់ ប្រសិនបើបរិមាណអំបិលមិនបានសម្រេចតាមផែនការកំណត់ទេ ឬដើម្បីជៀស វាងការរលាយអំបិល[1632]។ កម្មករធ្វើការងារយ៉ាងលំបាកធ្ងន់ធ្ងរដោយមិនហ៊ានត្អូញត្អែរ ដើម្បីកុំឱ្យចោទប្រកាន់ថា ខ្ជិលច្រអូស[1633]។ ដោយសារមូលហេតុនេះ កម្មករត្រូវតែខិតខំ ប្រឹងប្រែងធ្វើការ ទោះបីពួកគេមានជំងឺធ្ងន់ធ្ងរក៏ដោយ[1634]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៣៧៨. កម្មករខ្លះធ្វើអត្តឃាតដោយសារតែ មានជំងឺ កង្វះអាហារ និង ត្រូវបានចោទប្រកាន់ថាខ្ជិលច្រអូស ឬជាជនក្បត់[1635]។ កម្មករមិនអាចទៅណាមកណាបានដោយគ្មានការអនុញ្ញាតទេ។ កម្មកររស់នៅ និងធ្វើការងារក្រោមការគ្រប់គ្រងដ៏តឹងរឹងរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា[1636]។ ស្រែអំបិល ត្រើយកោះពទ្ធ័ជុំវិញដោយទឹកសមុទ្រ ដែលកម្មករមិនអាចរត់គេចខ្លួនបាន[1637]។ មានការប្រជុំ ទិតៀន ឬស្វ័យទិតៀនជាទៀងទាត់[1638] និងមានការធ្វើប្រវត្តិរូបរបស់កម្មករផងដែរ[1639]។

៣៧៩. កងសន្តិសុខ និងអ្នកបច្ចេកទេសទទួលបានរបបអាហារប្រសើរជាងកម្មករធម្មតា[1640]។ សាក្សីមួយចំនួនបាននិយាយថា ប្រសិនបើអ្នកណាម្នាក់មកធ្វើការងារយឺត ឬ ឈឺ របបអាហាររបស់អ្នកនោះត្រូវបានកាត់បន្ថយ ឬដកយកសម្រាប់ជាទណ្ឌកម្ម[1641]។ សាក្សីម្នាក់ក្នុងចំណោមនោះបាននិយាយថា កម្មករខ្លះបានលួចអាហារ ហើយត្រូវបានបង្អត់អាហារ សម្រាប់រយៈពេល០២ ថ្ងៃ ក្រោយពីចាប់បាន[1642]។ កម្មករត្រូវបាននាំទៅមុជទឹកមួយដង ឬពីរដងក្នុងមួយសប្តាហ៍ ដោយសារមូលហេតុនេះ បណ្តាលឱ្យកម្មករជាច្រើនកើតរោគរមាស់ និងខ្វះអនាម័យ[1643]។ កម្មករត្រូវបានព្យាបាលដោយថ្នាំផលិតនៅក្នុងស្រុកដែលគ្មានប្រសិទ្ធភាព។ កម្មករឈឺ ឬរងរបួសធ្ងន់ធ្ងរ ត្រូវបានដឹកទៅព្យាបាលនៅវត្តជុំគ្រៀល ស្ថិតនៅឃុំជុំគ្រៀល ក្បែរកំពង់កណ្តាល ចំណែកឯអ្នកជំងឺស្រាលត្រូវបានព្យាបាលនៅការដ្ឋាន[1644]។ សាក្សីជាច្រើនបានឃើញកម្មករស្លាប់ដោយបាក់កម្លាំង និងដោយសារជម្ងឺ នៅវត្តជុំគ្រៀល ឬនៅ ការដ្ឋានផលិតអំបិល[1645]។ ក្នុងអំឡុងពេលនោះ វិទ្យុភ្នំពេញបានផ្សាយថា បក្សកុម្មុយនីស្តកម្ពុជាបានយកចិត្តទុកដាក់ដល់ការរស់នៅ និងសុខភាពរបស់កម្មករស្រែអំបិល[1646]។

__សន្តិសុខ__

៣៨០. សាក្សីបានរៀបរាប់ថា កម្មករមួយចំនួនត្រូវបានចាប់ខ្លួន ឬនាំយកទៅ ប៉ុន្តែមិនឃើញដែលត្រឡប់មកវិញឡើយ[1647]។ សាក្សីភាគច្រើនមិនបានដឹងថា កម្មករទាំងនោះត្រូវបានបញ្ជូនទៅកន្លែងណាទេ ចំណែកអ្នកផ្សេងទៀតជឿថា កម្មករខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំសន្លុង ស្ថិតនៅក្នុងស្រុកទ្រាំង ខេត្តតាកែវ ភូមិភាគនិរតី[1648]។ សាក្សីម្នាក់បានបញ្ជាក់ថា កម្មករបានបាត់ខ្លួន ក្រោយពេលដែលកម្មករបានស្នើឱ្យទៅយក"បង្គី"[1649]។ ជារឿយៗ មានការចាប់ខ្លួនត្រូវបានធ្វើឡើងនាពេលយប់[1650]។ សាក្សីមិនស្គាល់អ្នកដែលមកចាប់នោះទេ[1651]។ ប៉ុន្តែ អ្នកខ្លះយល់ថា កម្មករដែលត្រូវបានចាប់ខ្លួន ដោយសារមានជាប់ពាក់ព័ន្ធជាមួយអតីតរបប លន់ នល់[1652] ឬដោយសារអំពើខុសសីលធម៌[1653]។ កម្មករមានការភ័យខ្លាច អំពីការនាំយកទៅ[1654]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605379



៣៨១. ជាចុងក្រោយ កម្មករខ្លះបានព្យាយាមរត់គេចខ្លួនដោយហែលឆ្លងដែលសមុទ្រ ឬឆ្លៀតរត់គេចពេលទៅធ្វើការខណៈដែលមានពួកសន្តិសុខតិចតួចឃ្លាំមើល ដូចជាពេលទៅកាប់អុសជាដើម។ កម្មករខ្លះក្នុងចំណោមអ្នកទាំងនោះត្រូវបានចាប់ខ្លួន នាំត្រឡប់មកវិញ ហើយបង្ហាញនៅក្នុងអង្គប្រជុំកុំឱ្យកម្មករដទៃទៀតយកតម្រាប់តាម ឬត្រូវបានបញ្ជូនទៅអប់រំរៀនសូត្រនៅទីកន្លែងដទៃទៀត ឬក៏បាត់ខ្លួនតែម្តង[1655]។ មានកម្មករខ្លះបានស្លាប់ក្នុងពេលព្យាយាមរត់គេចផងដែរ[1656]។

***

៣៨២. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៧នាក់ (ដប់ប្រាំពីរនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងការដ្ឋានស្រែអំបិល[1657]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅការដ្ឋានស្រែអំបិល។

## ការដ្ឋានកសាងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[1658]

### ទីតាំង និងការបង្កើត

៣៨៣. ការដ្ឋានកសាងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មានទីតាំងស្ថិតនៅក្នុងភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មានទីតាំងស្ថិតនៅក្នុងស្រុក២០ តំបន់៣១ នៃភូមិភាគបស្ចិម(ភូមិភាគ៤០១)។ ព្រលានយន្តហោះនេះនៅមានរូបរាងនៅឡើយ ដែលគ្របដណ្តប់លើផ្ទៃដីចំនួន ៣០០ ហិកតា រួមមាន ផ្លូវយន្តហោះរត់ពីរខ្សែ មានបណ្តោយប្រវែង ២.៤០០ ម៉ែត្រ ប៉មត្រួតពិនិត្យការហោះហើរ និងអគាររដ្ឋបាលផ្សេងៗទៀត។ ទីតាំងនេះមានបណ្តោយសរុបចំនួន ៧ គីឡូម៉ែត្រ ដែលនៅក្នុងទីតាំងនោះមានផ្ទះរបស់ប្រធានគ្រប់គ្រងការដ្ឋាន និងរោងបាយរួមមួយ(ផ្ទះ និងរោងបាយនោះស្ថិតនៅចម្ងាយ០២ គីឡូម៉ែត្រប៉ែកអាគ្នេយ៍នៃផ្លូវយន្តហោះរត់) ព្រមទាំងមានរូងក្រោមដីមួយដែលសាងសង់មិនទាន់រួចរាល់ស្ថិតនៅក្បែរច្រកភ្នំជិតទីតាំង

នោះ[1659]។

៣៨៤. តម្រូវការក្នុងការកសាងព្រលានយន្តហោះយោធាថ្មីមួយត្រូវបានយកមកពិនិត្យ និងពិភាក្សាដោយគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងកិច្ចប្រជុំរបស់ខ្លួននាចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ហើយជម្រើសនៃការជ្រើសរើសខេត្តកំពង់ឆ្នាំង បានប្រកាសជាផ្លូវការនៅក្នុងអង្គប្រជុំពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦[1660]។ សាក្សីជាច្រើនបានបញ្ជាក់ថា ការសាងសង់ការដ្ឋាននេះបានចាប់ផ្តើមនៅដើមឆ្នាំ១៩៧៦[1661]។ ប៉ុន្តែ តាមកំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍បានបង្ហាញថា ការដ្ឋាននេះ បានចាប់ផ្តើមរួចទៅហើយក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៦[1662]។ ការដ្ឋាននេះបានដំណើរការរហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែលពេលនោះនៅមិនទាន់បានរួចរាល់ជាស្ថាពរនៅឡើយ[1663]។

**ដំណើរការប្រព្រឹត្តទៅ**

**<u>រចនាសម្ព័ន្ធគ្រប់គ្រង និងអ្នកធ្វើការ</u>**

៣៨៥. គណៈអចិន្ត្រៃយ៍ បានសម្រេចកសាងព្រលានយន្តហោះមួយនៅខេត្តកំពង់ឆ្នាំង។ កំណត់ហេតុមួយក្នុងចំណោមហេតុជាច្រើនរបស់អង្គប្រជុំបានបង្ហាញថា នួន ជា ខៀវ សំផន និង អៀង សារី បានចូលរួមនៅក្នុងអង្គប្រជុំនោះ[1664]។ នៅក្នុងកិច្ចប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា នាខែឧសភា ឆ្នាំ១៩៧៦ អគ្គសេនាធិការ សុន សេន បានរាយការណ៍អំពីដំណើរការវិវឌ្ឍនៃការកសាងព្រលានយន្តហោះនេះ ដែលមានការចូលរួមពី នួន ជា និង ខៀវ សំផន[1665] ។

៣៨៦. ការកសាងព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានធ្វើឡើងក្រោមការគ្រប់គ្រងរបស់កងពលមជ្ឈិម ៥០២[1666]។ កងពលនេះត្រូវបានបង្កើតឡើងភ្លាមក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយបញ្ចូលកងទ័ពមកពីអង្គភាពដែលមានពីមុន[1667]។ កងពលមជ្ឈិម៥០២ ក៏ដូចគ្នានឹងកងពលមជ្ឈិមដទៃទៀតដែរ ធ្វើការរាយការណ៍ដោយផ្ទាល់ទៅសេនាធិការដ្ឋាន និងអគ្គសេនាធិការ សុន សេន[1668] ។ កងពល៥០២ ទទួលបន្ទុកកងទ័ពអាកាសរបស់កងទ័ពបដិវត្តកម្ពុជា ព្រមទាំងទទួលខុសត្រូវលើព្រលានយន្តហោះកងទ័ពទាំងអស់នៅកម្ពុជា[1669]។ [លុប] ជាលេខានៃគណៈកងពល ៥០២ [1670] ដែលបានទៅពិនិត្យមើលការដ្ឋាននោះជាទៀងទាត់[1671]។ ទោះបីជាមានការបដិសេធពីតួនាទី នៅពេលស្តាប់ចម្លើយរបស់ [លុប] ក៏ដោយ គាត់ទំនងជាកម្មាភិបាលដឹកនាំម្នាក់នៃកងពល៥០២[1672]។ សាក្សីជាច្រើនបានបង្ហាញថា ក្នុងអំឡុងពេលណាមួយនៃការសាងសង់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ព្រលានយន្តហោះនោះឈ្មោះ លៃ (ស្លាប់) គឺជាអនុប្រធានរបស់ [លុប] និងជាអ្នកទទួលខុសត្រូវមើលការដ្ឋាននេះដោយផ្ទាល់[1673]។ លៃ បានដឹកនាំអង្គប្រជុំប្រចាំថ្ងៃនិយាយអំពីការកសាងព្រលានយន្តហោះ ហើយគាត់បានទៅពិនិត្យមើលការដ្ឋានជារៀងរាល់ថ្ងៃ និងបានដាក់បញ្ហានានាដល់ជំនួយការរបស់គាត់។ បន្ថែមពីនេះ ក៏មានអង្គប្រជុំទិតៀន ឬស្វ័យទិតៀនកម្មាភិបាលផងដែរ[1674]។ មានការប្រជុំជាទៀងទាត់រវាងអគ្គសេនាធិការ និងកម្មាភិបាលជាន់ខ្ពស់ពីកងពលផ្សេងៗរបស់មជ្ឈិម និងកងវរៈសេនាធំឯករាជ្យ ដែលមានការចូលរួមពីលេខានៃគណៈកងពល ៥០២ផងដែរ ។ ក្នុងអំឡុងពេលប្រជុំនោះ កម្មាភិបាលទាំងនេះបានរាយការណ៍ឲ្យ **សុន សេន** អំពីរឿងរ៉ាវផ្សេងៗដូចជា ស្ថានការខ្មាំងខាងក្នុង និងខាងក្រៅ និងបានស្នើសុំការណែនាំអំពីចំណាត់ការនៅក្នុងថ្នាក់កងពល។[1675]

**៣៨៧.** ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងនេះ ត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃដំណើរការបោសសម្អាតសមាជិកកងទ័ពបដិវត្តន៍កម្ពុជា ដើម្បីធ្វើអប់រំកែប្រែ ពួកគេក្នុងចំណោមនោះដែលត្រូវបានចាត់ទុកថាជា“សមាសភាពមិនល្អ” ដែលមកពីកងពល៥០២ ខ្លួនឯងផង[1676] ឬជាសមាជិកកងពល ឬអង្គភាពកងទ័ពផ្សេងៗទៀត។ កំណត់ហេតុនៃអង្គប្រជុំ និងសំបុត្រព្រមទាំងរបាយការណ៍ ដែលផ្ញើឆ្លើយឆ្លងគ្នារវាងកងពល៥០២ និងមន្ទីរស-២១[1677] បានបង្ហាញថាកងពល៥០២ បានចូលរួមយ៉ាងសកម្មក្នុងការបោសសម្អាតសមាជិកកងទ័ពបដិវត្តន៍កម្ពុជា។ ជាឧទាហរណ៍ ក្នុងអង្គប្រជុំមួយរបស់កងទ័ពនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ លេខាគណៈកងពល ៥០២បាននិយាយថា៖ “*បញ្ហានេះកំណត់ថា យើងកំចាត់ខ្មាំងបានជាមូលដ្ឋានហើយ តែត្រូវមានវិធានការបន្តទៀត។ កុំឲ្យមានទី២,ទី៣, ទី៤, អ្វីបន្តទៀត។ខ្មាំងធ្វើអីយើងទៀតមិនបានទេ ឲ្យតែយោធាយើងរឹង ស្អាតខាងនយោបាយ។ ត្រូវពង្រឹងបក្សខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង។ ត្រូវបិទសំរិតសំរាំងជាដាច់ខាត*”[1678]។ នៅអង្គប្រជុំផ្សេងមួយទៀតក្នុងខែមីនា ឆ្នាំ១៩៧៧ គាត់បាននិយាយថា៖ “*សមាសភាពមួយចំនួន ដែលយើងចាប់កន្លងមក ច្បាស់ជាសមាសភាពខ្មាំងមែន។ ពួកមិនល្អ បានបញ្ជូនទៅ ស.២១ ជាង ៥០ នាក់។ លេខាអនុសេនាធំត្រូវដក៥នាក់ចេញទៀត ទើបអាចធានាបាន*”[1679]។

**៣៨៨.** សាក្សីជាច្រើនបានអះអាងថា ជនត្រូវចោទបានមកពិនិត្យមើលការដ្ឋាន កសាងព្រលានយន្តហោះកំពង់ឆ្នាំង។ អតីតកម្មាភិបាលម្នាក់បានពន្យល់ថា នៅដើមឆ្នាំ១៩៧៧ **អៀង សារី** និង **ខៀវ សំផន** បានមកពិនិត្យមើលការដ្ឋាននេះ និងបានជួបជាមួយថ្នាក់ដឹកនាំគ្រប់គ្រងការដ្ឋាន[1680]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605382



កម្មករម្នាក់បាននិយាយថា គាត់បានឃើញ **អៀង សារី, នួន ជា** និង **កែ ពក** មកពិនិត្យមើលការដ្ឋានមើលកម្មករធ្វើការ និងជួបជាមួយថ្នាក់ដឹកនាំនៅការដ្ឋានជាច្រើនដងក្នុងចន្លោះឆ្នាំ១៩៧៨ និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1681]។ កម្មករម្នាក់ទៀតបានឃើញ **ខៀវ សំផន** មកពិនិត្យមើលការដ្ឋាននៅក្នុងចុងឆ្នាំ១៩៧៧[1682]។ ដូចគ្នាផងដែរ សាក្សីទី៤បានអះអាងថា គាត់បានឃើញ **ខៀវ សំផន** មកកាន់ការដ្ឋាននេះដោយជិះឧទ្ធម្ភាគចក្រមកនៅចុងឆ្នាំ១៩៧៧ ដើម្បីពិនិត្យមើលការងាររបស់កម្មករ[1683]។ អ្នកបើកឡានឱ្យ **ខៀវ សំផន** ពីឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបនេះ បាននិយាយថា **ខៀវ សំផន** មិនដែលមកកាន់ការដ្ឋានកំពង់ឆ្នាំងទេក្នុងអំឡុងពេលនោះ[1684]។ សាក្សីជាច្រើន បានអះអាងផងដែរនូវវត្តមានជាច្រើនដងរបស់ **តា ម៉ុក** នៅការដ្ឋាននោះ[1685]។

<u>ស្ថានភាពរស់នៅ និងលក្ខខណ្ឌការងារ</u>

៣៨៩. ចំនួនកម្មករនៅការដ្ឋានមានច្រើន ឬតិចទៅតាមពេលវេលាចាប់ពីចំនួនរាប់រយក្នុងដើមឆ្នាំ១៩៧៦ រហូតដល់ជាងមួយម៉ឺននាក់ក្នុងឆ្នាំ១៩៧៧[1686]។ ការដ្ឋាននោះគឺជាការដ្ឋានកងទ័ព ដូច្នេះហើយ កម្មករស្ទើរតែទាំងអស់ ទាំងបុរស និងស្ត្រី[1687] សុទ្ធតែជាកងទ័ពរបស់កងទ័ពបដិវត្តន៍កម្ពុជា[1688]។ មានសាក្សីចំនួន១៤នាក់ជាអតីតកម្មករនៅការដ្ឋានកំពង់ឆ្នាំងនោះត្រូវបានស្តាប់ចម្លើយ[1689]។ កងទ័ពទាំងនោះភាគច្រើនត្រូវបានបញ្ជូនទៅការដ្ឋានកំពង់ឆ្នាំងដើម្បីលត់ដំ និងកសាងខ្លួន ដោយសារតែខ្លួនមានប្រវត្តិរូប"មិនល្អ" ឬជាប់ពាក់ព័ន្ធជាមួយខ្មែរក្បត់[1690]។ ក្រៅពី"សមាសភាពមិនល្អ"មកពីកងពល៥០២ ខ្លួនឯងនោះ[1691] ភាគច្រើននៃកម្មករនៅការដ្ឋានកំពង់ឆ្នាំងត្រូវបានបញ្ជូនទៅទីនោះ ដោយសារពួកគេត្រូវបានចាត់ទុកថា មានជាប់ពាក់ព័ន្ធជាមួយថ្នាក់ដឹកនាំនៃអង្គភាពផ្សេងៗរបស់កងទ័ពបដិវត្តន៍កម្ពុជាដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ក្នុងនោះរួមមានដូចជា៖ ពួកកងទ័ពមកពីកងពលមជ្ឈិម១៧០ (អតីតកងពលភូមិភាគបូព៌ា[1692]) កងពលមជ្ឈិម៣១០[1693] កងពលមជ្ឈិម៤៥០[1694](អតីតកងពលភូមិភាគឧត្តរ[1695]) និងកងពលមជ្ឈិម៧០៣[1696] ដែលជាអតីតកងពលភូមិភាគពិសេស។ ចាប់ពីឆ្នាំ១៩៧៨ កងទ័ពភាគច្រើនត្រូវបានបញ្ជូនទៅការដ្ឋានខេត្តកំពង់ឆ្នាំងនោះ ដោយសារតែមេដឹកនាំរបស់ខ្លួនមកពីភូមិភាគបូព៌ា ឬ មានការពាក់ព័ន្ធជាមួយនឹងភូមិភាគបូព៌ា។ អ្នកទាំងនោះភាគច្រើនបានមកដល់តាមឡាន មកជាក្រុមៗ ពីអង្គភាពកងទ័ពតែមួយ[1697]។ ម្យ៉ាងទៀត មានកងទ័ពមកពីភូមិភាគនិរតី និងភូមិភាគបស្ចិមនៅក្នុងចំណោមកម្មករទាំងនោះផងដែរ[1698]។ បន្ថែមពីលើនេះ តាមសាក្សីម្នាក់ដែលធ្វើការនៅក្រសួងការបរទេស (មន្ទីរ ប-១)នាសម័យនោះបានឱ្យដឹងថា អ្នកធ្វើការនៅមន្ទីរ ប-១ ក៏ត្រូវបានបញ្ជូនទៅកាន់

ការដ្ឋានកំពង់ឆ្នាំងនោះផងដែរ[1699]។ កម្មករខ្លះត្រូវលត់ដំជាមុនសិន នៅតាមកន្លែងធ្វើការផ្សេងៗ[1700] ដូចជានៅព្រៃស (មន្ទីរ ស-២៤) ជាដើម[1701] មុនពេលយកទៅឲ្យធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។

៣៩០. ស្ថានភាពរស់នៅ និងលក្ខខណ្ឌការងាររបស់កម្មករខុសគ្នាទៅតាមកម្រិតនៃ "ការក្បត់" ដែលគេសន្មតចោទប្រកាន់។ សាក្សីជាច្រើនបានបញ្ជាក់ថា ការងារត្រូវផ្តើមធ្វើនៅម៉ោង៧ព្រឹក ដល់ម៉ោង ១១ព្រឹក និងពីម៉ោង១ ដល់ម៉ោង៥ ល្ងាច តែមានការសម្រាកចន្លោះពីម៉ោង១១ ដល់ម៉ោង១ រសៀល។ កម្មករខ្លះទៀតត្រូវធ្វើការវេនយប់តែប៉ុណ្ណោះ[1702] រីឯកម្មករដែលចោទថាបានក្បត់ធ្ងន់ធ្ងរ ត្រូវបានបង្ខំឲ្យធ្វើការទាំងពេលថ្ងៃ និងពេលយប់[1703]។ កម្មករទាំងអស់ធ្វើការងារ៧ ថ្ងៃក្នុងមួយសប្តាហ៍[1704]។

៣៩១. ដើម្បីរៀបចំកសាងផ្លូវយន្តហោះរត់ កម្មករបានកាប់ដើមឈើ ដកគល់ឈើ និងប្រមូលឬសឈើ ដើម្បីរៀបចំទីលាន ជីកដី ឈូសដីដោយប្រើប៊ុលដូហ្ស៊ែរ វាយបំបែកថ្ម បំបែកនិងបង្ហាប់ដី ដឹកជញ្ជូន និងលាយស៊ីម៉ង់ត៍ លាយបេតុង ចាក់កៅស៊ូក្រាលថ្នល់ ព្រមទាំងពង្រាបផ្ទៃដី[1705]។ កងទ័ពដទៃទៀតត្រូវធ្វើការងារនៅតាមភ្នំ ដែលស្ថិតនៅតាមបណ្តោយផ្លូវយន្តហោះរត់៖ ដោយខ្លះត្រូវធ្វើការកន្លែងយកថ្ម និងខ្លះទៀតត្រូវខួងថ្មភ្នំ[1706]។ សាក្សីជាច្រើនបានអះអាងថា ជាញឹកញាប់ កម្មករបានរងរបួស ឬ ស្លាប់ដោយសារតែថ្មខ្ទាតត្រូវ ឬធ្លាក់លើ[1707]។ សាក្សីម្នាក់បានឃើញកម្មករម្នាក់ស្លាប់ដោយសារបំណែកថ្មដែលបំផ្ទុះធ្លាក់ត្រូវ[1708]។ ទោះជាមានគ្រឿងចក្រដែលផលិតនៅប្រទេសចិនមួយចំនួននៅឯការដ្ឋានក៏ដោយ ការងារភាគច្រើនត្រូវបានធ្វើឡើងដោយដៃ[1709]។ ក្នុងអំឡុងពេលនៃការកសាងព្រលានយន្តហោះនេះ អ្នកបច្ចេកទេសចិនជាច្រើនបានផ្តល់ជាជំនួយបច្ចេកទេស[1710]។ កម្មករបានស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដានមើលដោយអ្នកយាមយ៉ាងតឹងរឹង[1711]។

៣៩២. ក្រុមកម្មករខ្លះទទួលអាហារហូបចុកមិនគ្រប់គ្រាន់ទេ[1712]។ ផ្ទុយទៅវិញ កម្មាភិបាលការដ្ឋាន[1713] ព្រមទាំងក្រុមដទៃទៀត រួមទាំងអ្នកដែលបានធ្វើការងារជាមួយអ្នកជំនាញការចិន ទទួលបានរបបអាហារគ្រប់គ្រាន់ប្រសើរជាង[1714]។ កម្មករដែលមានជម្ងឺត្រូវបានដឹកតាមឡានពេទ្យ យកទៅមន្ទីរពេទ្យខេត្ត កំពង់ឆ្នាំង[1715]។ សាក្សីជាច្រើនបានបញ្ជាក់ថា កម្មករមួយចំនួនបានស្លាប់ដោយសារស្រេកឃ្លាន ជម្ងឺ ធ្វើការងារហួសកម្លាំង និងបាក់កំលាំង[1716]។ កម្មាភិបាលម្នាក់បានបញ្ជាក់ថា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

មានកម្មករធ្វើអត្តឃាតជារៀងរាល់សប្តាហ៍[1717]។ កម្មាភិបាលម្នាក់ទៀតបាននិយាយផងដែរថា សាកសពអ្នកដែលបានស្លាប់នៅឯការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានកប់ក្នុងព្រៃជិតវត្តស្ទឹង[1718]។

## សន្តិសុខ

៣៩៣. សាក្សីជាច្រើន បានឃើញនូវការបាត់ខ្លួនកម្មករមួយចំនួន នៅក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1719]។ កម្មករបានសម្គាល់ឃើញថា មានទំនាក់ទំនងគ្នារវាងការប្រជុំទិតៀន ឬស្វ័យតិទៀនប្រចាំថ្ងៃ ជាមួយនឹងការបាត់ខ្លួនរបស់កម្មករ[1720]។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំទាំងនោះ កម្មករត្រូវបានទិតៀនថា៖ ឈឺ ឬខ្ជិលច្រអូស មានកំហុសក្នុងការងារ ការប្រព្រឹត្តកំហុសតិចតួច ឧទាហរណ៍ដូចជា លួចថ្នាំជក់ ឬរងការចោទប្រកាន់ថាមានទំនាក់ទំនងជាមួយវៀតណាម[1721]។ សាក្សីជាច្រើនបានឃើញឡាននៅក្រៅបរិវេណការដ្ឋានដឹកកម្មករចេញពីបរិវេណព្រលានយន្តហោះ ហើយមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញឡើយ[1722]។ សាក្សីជាច្រើនបាននិយាយថា ពួកគេដឹងមិនច្បាស់អំពីជោគវាសនារបស់កម្មករដែលបាត់ខ្លួនឡើយដោយសារពួកគេមិនដែលឃើញមានការកាប់សម្លាប់នោះទេ[1723]។

៣៩៤. កម្មករម្នាក់បាននិយាយថា គាត់បានឃើញមានការចាប់ខ្លួនមនុស្សនៅពេលគាត់ស្ថិតនៅកន្លែងធ្វើការរបស់ លៀ ដោយបញ្ជាក់ថា លៀ តែងតែមានវត្តមាននៅពេលមានការចាប់ខ្លួនមនុស្ស[1724]។

៣៩៥. សាក្សីជាច្រើនគិតថា អ្នកទោសដែលបានបាត់ខ្លួននោះត្រូវគេសម្លាប់ហើយ ដោយបញ្ជាក់ថា កម្មករភាគច្រើនមកពីភូមិភាគបូព៌ា ឬអ្នកដែលមានជាប់ពាក់ព័ន្ធជាមួយភូមិភាគបូព៌ា[1725]។ សាក្សីម្នាក់បានឮថា គេយកមនុស្សទៅសម្លាប់នៅខាងលិចព្រលានយន្តហោះ[1726]។ សាក្សីម្នាក់ទៀតបាននិយាយថា គាត់បានឃើញសាកសពមនុស្សក្នុងរណ្តៅនៅភ្នំពាមលោក ដែលមានចម្ងាយប្រមាណ៥ គីឡូម៉ែត្រពីការដ្ឋានកសាងព្រលានយន្តហោះ ហើយគាត់បានសន្និដ្ឋានថា សាកសពទាំងនោះជាសាកសពរបស់កម្មករខ្លះមកពីការដ្ឋានកសាងព្រលានយន្តហោះកំពង់ឆ្នាំង តែគាត់មិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់ ឡើយ[1727]។ អតីតកម្មាភិបាលម្នាក់ដែលបានធ្វើការនៅការដ្ឋាន បានបង្ហាញទីតាំងមួយមានចម្ងាយប្រហែលជាបីគីឡូម៉ែត្រ ទិសពាយ័ព្យនៃការដ្ឋានដែលគាត់ជឿថា មានរណ្តៅសពរួមមួយដែលកប់សាកសពកម្មករដែលបានសម្លាប់ក្នុងឆ្នាំ១៩៧៧ ដោយសារតែគាត់បានឃើញឡានដឹកមនុស្សបានឈប់នៅទីនោះ។ គាត់បានរៀបរាប់ថា ក្រោយពីឡានបានឈប់មួយសន្ទុះ គាត់

បានឮសំលេងមនុស្សស្រែកយំចេញពីទីតាំងនោះ ហើយ ៧ ថ្ងៃបន្ទាប់មក មានធុំក្លិនស្អុយសាកសពរលួយ។ ក៏ប៉ុន្តែ មិនមានសំណល់សាកសពមនុស្ស ដែលអាចមើលឃើញនៅទីនោះឡើយនាពេលបច្ចុប្បន្ននេះ[1728]។ មិនមានសាក្សីណាដែលបានឃើញការសម្លាប់កម្មករ ដែលធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះឡើយ[1729] ហើយក៏មិនមានភស្តុតាងបញ្ជាក់ថាមានការសម្លាប់កើតឡើងនៅក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ។

**៣៩៦.** កម្មករទំនងជាត្រូវបានដឹកតាមឡានបញ្ជូនពីកំពង់ឆ្នាំងទៅភ្នំពេញ។ សាក្សីខ្លះគិតថា កម្មករដែលដឹកតាមឡានបញ្ជូនទៅភ្នំពេញ អាចបញ្ជូនមកកាន់ព្រៃស(មន្ទីរ ស-២៤) និងមន្ទីរស-២១ [1730]។ សាក្សីម្នាក់បាននិយាយថា គាត់បានឃើញកម្មករ៣០ នាក់មកពីភូមិភាគបូព៌ាត្រូវបានគេចងនិងដឹកតាមឡានតាមបណ្តោយផ្លូវជាតិលេខ៥[1731]។ អតីតសន្តិសុខម្នាក់នៅមន្ទីរស-២១ បានរៀបរាប់ថា គាត់ជឿថា រូបគាត់ត្រូវបានគេបញ្ជូនទៅមន្ទីរស-២៤ ដើម្បីកសាងខ្លួនដោយសារតែបងប្រុសរបស់គាត់ឈ្មោះ [លុប] ដែលធ្លាប់ធ្វើការងារនៅការដ្ឋានកសាងព្រលានយន្តហោះកំពង់ឆ្នាំងនោះត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ នៅក្នុងចុងឆ្នាំ១៩៧៨[1732]។ សាក្សីផ្សេងទៀតបានអះអាងថា កម្មករដែលធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ហើយកម្មាភិបាលខ្លះក៏ដូចគ្នាផងដែរ[1733]។ **យឹម សំអុល** ហៅ **ញ៉** ដែលជាឈ្មោះស្ថិតក្នុងចំណោមមនុស្សដែលបានបាត់ខ្លួនពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ទំនងជាត្រូវបានបញ្ជូនផងដែរទៅមន្ទីរស-២១ ក្នុងចុងឆ្នាំ១៩៧៨[1734]។ **ឌុច** បានពន្យល់ផងដែរក្នុងសវនាការរបស់គាត់ថា ប្អូនថ្លៃរបស់គាត់ដែលជាកម្មាភិបាលធ្វើការនៅការដ្ឋានកំពង់ឆ្នាំងនោះ ត្រូវបានបញ្ជូនទៅមន្ទីរស-២១[1735]។ ទោះបីជាមានភស្តុតាងដូចបានរៀបរាប់ខាងលើ សាក្សីខ្លះបានអះអាងផ្ទុយពីនេះដោយថា តាមតែខ្លួនបានដឹងមិនមានការបាត់ខ្លួន ការចាប់ខ្លួន ឬការសម្លាប់កម្មករទេ[1736]។

**៣៩៧.** កម្មករជាច្រើន (រួមទាំងសាក្សីមួយចំនួន) បន្ទាប់មកត្រូវបានបញ្ចូលទៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា ហើយត្រូវបានបញ្ជូនឲ្យទៅប្រយុទ្ធនៅក្នុងជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម[1737]។

**៣៩៨.** ការដ្ឋានកសាងព្រលានយន្តហោះកំពង់ឆ្នាំង នៅតែមានដំណើរការនៅឡើយ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ខេត្តកំពង់ឆ្នាំងនៅដើមឆ្នាំ១៩៧៩។ នៅពេលនោះ ការងារត្រូវបានបញ្ឈប់ ហើយកម្មករត្រូវបានជម្លៀសចេញ[1738]។ កម្មករភាគច្រើនបានធ្វើដំណើរឆ្ពោះទៅស្ថានីយរថភ្លើង

00605386



រមាស ស្ថិតនៅចម្ងាយ២០ គីឡូម៉ែត្រភាគខាងត្បូងនៃព្រលានយន្តហោះ នៅក្នុងស្រុកទឹកផុស (ស្រុក១៤)[1739]។ កម្មករត្រូវបានប្រាប់ ឲ្យកាន់អាវុធដើម្បីវាយវៀតណាម ចំណែកឯកម្មករជាកងទ័ពមកពីភូមិភាគបូព៌ាត្រូវបានបំបែកចេញ និងត្រូវបានសម្លាប់នៅវត្តមង្គលខណ្ឌ័ ដែលស្ថិតនៅក្នុងភូមិទួលខ្ពស់ និងនៅឯអតីតបន្ទាយបារាំងក្នុងភូមិក្បាលឡាន(ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស)[1740]។ មានការសម្លាប់រង្គាលលើកងទ័ពភូមិភាគបូព៌ានោះបានកើតមានឡើងក្រោយថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[1741]។

***

៣៩៩. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន០៤នាក់ (ប្រាំបួននាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1742]។ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤) ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។

### ការដ្ឋានព្រៃស (មន្ទីរ ស-២៤)[1743]

### ទីកន្លែង និងការបង្កើត

៤០០.ការដ្ឋានព្រៃស(មន្ទីរស-២៤) ស្ថិតនៅខាងក្រៅទីក្រុងភ្នំពេញ ជិតវត្តក្ដុល ស្រុកដង្កោ ខេត្តកណ្ដាល[1744]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ការដ្ឋាននេះ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ យោងតាមសក្ខីកម្មរបស់សាក្សី ទីតាំងចំបងរបស់មន្ទីរស-២៤ លាតសន្ធឹងពីពន្ធនាគារព្រៃសរហូតដល់ភូមិចេក។ ប៉ុន្តែ មន្ទីរស-២៤ ទាំងមូលទំនងជាមានផ្ទៃដីធំជាងនេះ[1745]។ មន្ទីរស-២៤ បានចាប់ផ្ដើមដំណើរការធ្វើជាការដ្ឋានសម្រាប់មន្ទីរស-២១ នៅពេលដែល **អ៊ិន លន ហៅ ណាត** ធ្វើជាប្រធានមន្ទីរ ស-២១ គឺមុនខែមីនា ឆ្នាំ១៩៧៦[1746] ហើយនៅដំណើរការរហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[1747]។

00605387



## ដំណើរការប្រព្រឹត្តទៅ

### រចនាសម្ព័ន្ធគ្រប់គ្រង និងអ្នកធ្វើការ

៤០១. ការដ្ឋានរបស់មន្ទីរស-២៤ មានមុខងារអប់រំកែប្រែយុទ្ធជន[1748] ព្រមទាំងផ្គត់ផ្គង់ម្ហូបអាហារដល់មន្ទីរស-២១ និងអង្គភាពចំណុះរបស់មន្ទីរស-២១[1749]។ ឌុច បានពន្យល់ថា ព្រៃសជាផ្នែកមួយនៃមន្ទីរស-២១[1750] ហើយនៅពេល ឌុច ត្រូវបានតែងតាំងជាប្រធានមន្ទីរ ស-២១ ព្រៃសស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់[1751]។ នុន ហ៊ុយ ហៅ ហ៊ុយស្រែ (ជាសមាជិកនៃគណៈមន្ទីរស-២១ ផងដែរ) ជាអ្នកទទួលខុសត្រូវលើដំណើការប្រចាំថ្ងៃរបស់មន្ទីរស-២៤[1752] រហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅខែធ្នូ ឆ្នាំ១៩៧៨។ ពេលនោះ [លុប] ត្រូវបានចាត់តាំងជំនួស នុន ហ៊ុយ[1753]។

៤០២. ឌុច ទទួលរបាយការណ៍ដែលរៀបរាប់ប្រាប់គាត់អំពីការប្រព្រឹត្តទៅនៃការដ្ឋាន របបការងាររបស់អ្នកជាប់ឃុំ និងអត្តសញ្ញាណរបស់អ្នកដែលត្រូវបានបញ្ជូនពីមន្ទីរស-២៤ ទៅកាន់មន្ទីរស-២១ ឬទៅកាន់ ជើងឯក។ គាត់ក៏បានបញ្ជាក់ផងដែរថាគាត់បានទៅព្រៃសចំនួនបួនដង[1754]។ ឌុច និយាយថា មេរបស់គាត់ឈ្មោះ សុន សេន និង នួន ជា ជាអ្នកធ្វើសេចក្ដីសម្រេចលើការបញ្ជូនមនុស្សទៅមន្ទីរស-២៤ ក្នុងលក្ខខណ្ឌដូចគ្នានឹងមន្ទីរស-២១ ដែរ ចំណែកឯគណៈមន្ទីរស-២១ ជាអ្នកធ្វើសេចក្ដីសម្រេចជាក់លាក់លើការបញ្ជូនបុគ្គលិកមន្ទីរស-២១ ទៅកាន់មន្ទីរស-២៤ ដើម្បីធ្វើការអប់រំកែប្រែ[1755]។

### ស្ថានភាពការងារ និង ការរស់នៅ

៤០៣. ចំពោះមន្ទីរស-២៤ មានបញ្ជីឈ្មោះតិចតួចណាស់ដែលបានរកឃើញ ជាហេតុមិនអាចកំណត់ឲ្យបានច្បាស់ថា តើមានមនុស្សប៉ុន្មាននាក់ត្រូវបានបញ្ជូនទៅ ។ ប៉ុន្តែ ចំនួនអ្នកជាប់ឃុំនៅខណៈណាមួយ នោះហាក់ដូចជាកើនដល់រាប់រយនាក់[1756] នេះជាតួលេខដែល ឌុច បានបញ្ជាក់អះអាង[1757]។ នៅក្នុងសាលក្រមនៃសំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា៖ *"ឯកសារផ្សេងៗពីគ្នា ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញនូវភាពមិនពេញលេញនៃចំនួនអ្នកជាប់ឃុំដែលត្រូវបានបញ្ជូនទៅសម្លាប់ ឬនៅរស់រានមានជីវិតពីការឃុំខ្លួននៅ ស-២៤។ ផ្អែកលើមូលហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា ចំនួនអ្នកជាប់ឃុំសរុបនៅស-២៤ មានមិនតិចជាង ១.៣០០ នាក់ ឡើយ"*[1758]។

៤០៤.សាក្សីជាច្រើនរូបបានបញ្ជាក់ថា មន្ទីរស-២៤ ទទួលយកទាំងបុរស ស្ត្រី[1759] និងកុមារ[1760]។ បើតាម

ឌុច មានមនុស្សពីរក្រុមជាចម្បង៖ ទីមួយ ជនសង្ស័យដោយសារតែទំនាក់ទំនងសាច់សារលោហិត និងទីពីរ អ្នកនៅក្រោមបង្គាប់របស់កម្មាភិបាលថ្នាក់លើដែលត្រូវបានចាប់ខ្លួន[1761]។ មន្ទីរនេះក៏ទទួលផងដែរនូវយុទ្ធជនមកពីអង្គភាពផ្សេងៗដូចជាអ្នករដ្ឋការមកពីក្រសួង និងស្ថាប័នជាច្រើននៅជុំវិញទីក្រុងភ្នំពេញ ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេ[1762]។ អតីតបុគ្គលិកមន្ទីរស-២១ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២៤ ដើម្បីធ្វើការអប់រំកែប្រែ ក៏បានជាប់ឃុំនៅទីនោះផងដែរ[1763]។ ឌុច បានអះអាងថាគ្មានជនបរទេសណាម្នាក់ (វៀតណាម ឬពួកបស្ចិមប្រទេស) ត្រូវបានបញ្ជូនទៅព្រៃសឡើយ[1764]។

៤០៥. ជាដំបូង អ្នកដែលបញ្ជូនទៅមន្ទីរស-២៤ ត្រូវបានចុះឈ្មោះនៅកន្លែងមួយស្ថិតនៅលើផ្លូវលេខ៣៦០ ជិត មន្ទីរស-២១។ បន្ទាប់មក ពួកគេត្រូវបាននាំទៅកាន់ព្រៃស ដែលនៅទីនោះ ពួកគេត្រូវបានថតរូប ហើយត្រូវផ្តល់ប្រវត្តិរូប[1765]។ មន្ទីរស-២៤ ចែកចេញជាបី “ក្រុម”៖ ទីមួយសម្រាប់ “សមាសភាពល្អ” ទីពីរសម្រាប់សមាសភាពមធ្យម និងទីបី សម្រាប់ “សមាសភាពមិនល្អ” ដែលត្រូវបានចោទថាមានអាកប្ប- កិរិយាឆ្គាំឆ្គងបំផុត ហើយក្រុមនេះទទួលនូវការប្រព្រឹត្តយ៉ាងធ្ងន់ធ្ងរបំផុត[1766]។

៤០៦. នៅមន្ទីរស-២៤ អ្នកជាប់ឃុំត្រូវបានបង្ខំឲ្យធ្វើការដើម្បីកសាងខ្លួន។ ពួកគេគ្មានសេរីភាពទេ ហើយត្រូវបានយាមការពារយ៉ាងតឹងរ៉ឹង ទាំងពេលធ្វើការ[1767] និងទាំងនៅពេលយប់[1768]។ ការបិទសិទ្ធិសេរីភាពមានលក្ខណៈតឹងតែងបំផុតចំពោះអ្នកជាប់ឃុំនៃក្រុមទីបី ពីព្រោះពួកគេត្រូវបានដាក់ខ្នោះនៅពេលយប់ ហើយមិនត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងផ្ទះធម្មតាឡើយ[1769]។ ចំពោះអ្នកដែលរស់នៅក្នុងផ្ទះទាំងអស់នេះ[1770] អ្នកខ្លះត្រូវបានដាក់ក្នុងបន្ទប់បិទជិតនៅពេលយប់[1771]។ ឌុច បានបញ្ជាក់ថា អ្នកនៅទីនោះមិនមែន “ជាប់គុក”ដូចគេហៅអ្នកជាប់ឃុំនៅមន្ទីរស-២១ ទេ[1772] ប៉ុន្តែគាត់ទទួលស្គាល់ថា ពាក្យ“សមាសភាព” សម្រាប់ហៅអ្នកធ្វើការនៅមន្ទីរស-២៤ មានន័យថា “ជាប់ឃុំ ហើយ បង្ខំឲ្យធ្វើការ” ដើម្បីកុំឲ្យអ្នកទាំងនេះប្រឆាំងនឹងបក្សតទៅទៀត[1773]។

៤០៧. អ្នកជាប់ឃុំនៅមន្ទីរស-២៤ រួមទាំងស្ត្រី និងកុមារផង ត្រូវបានឲ្យធ្វើការក្នុងវាលស្រែ នៃសាទត្រី ដាំបន្លែ ស្ទូងស្រូវ លើកទំនប់ ជីកប្រឡាយ និងជីកស្រះ[1774]។ សាក្សីជាច្រើនរូបបានអះអាងថា ពួកគេបានធ្វើការទាំងថ្ងៃទាំងយប់[1775] ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយមិនត្រូវបានអនុញ្ញាតឲ្យសម្រាកក្នុងពេលធ្វើការឡើយ[1776]។ នៅមន្ទីរស-២៤ បែបផែននៃថ្ងៃធ្វើការ គឺចាប់ផ្តើមពីព្រលឹមស្រាងៗនៅចន្លោះពីម៉ោង៤ ទៅម៉ោង៧ព្រឹក និងបញ្ចប់នៅចន្លោះពីម៉ោង១០ ទៅ១២យប់[1777] ដោយមានពេលឈប់សម្រាកពីរម៉ោដើម្បីហូប

អាហារ[1778]។

៤០៨. អតីតអ្នកជាប់ឃុំបានគូសបញ្ជាក់ថា ពួកគេទទួលបានរបបអាហារពីរដងក្នុងមួយថ្ងៃ ម្តងនៅពេលថ្ងៃត្រង់ និងម្តងទៀតនៅពេលល្ងាច[1779]។ លើកលែងតែករណីដីកម្រ[1780] ជាទូទៅអ្នកទោសបានអះអាងថា ការបែងចែករបបអាហារទៅឲ្យមន្ទីរ ស-២១ មិនគ្រប់គ្រាន់ទេ[1781] ខណៈដែល ឌុច បានពន្យល់ថា ស្រូវដែលផលិតបានលើសត្រូវប្រគល់ទៅឲ្យគណៈមជ្ឈិម[1782]។ ឌុច បានអះអាងថាគាត់មិនអាចកែប្រែរបបអាហារដែលបានកំណត់នោះទេ ហើយគាត់គិតថា វិធីបង្អត់អាហារអ្នកទោសគឺជាការឆ្លើយតបទៅនឹងគោលនយោបាយដែលបានដាក់ចេញ[1783]។ អ្នកជាប់ឃុំស្លាប់ដោយសារលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារនៅព្រៃស[1784]។

៤០៩. ការបំពេញការងារស្ថិតនៅក្រោមការឃ្លាំមើលរបស់អ្នកយាម[1785] ដែលតម្រូវឲ្យអ្នកទោសប្រឹងប្រែងធ្វើការ និងមិនមានការអត់ឱនឡើយ ប្រសិនបើពួកគេធ្វើការយឺតយ៉ាវ[1786]។ ពេលអ្នកទោសទាំងនោះឈឺ ឬមកយឺត ឬធ្វើការមិនបានពេញចិត្ត អ្នកទោសត្រូវបានវាយដំ និងជេរប្រមាថ[1787]។ អ្នកទោសក៏ត្រូវបានដាក់ទណ្ឌកម្មផងដែរនៅពេលត្រូវបានគេចោទថា "ខុសសីលធម៌ផ្លូវភេទ" "ធ្វើពុតជាឈឺ" ឬ "លួច"[1788]។ ការភ័យខ្លាចការបញ្ជូនចេញ[1789] ឬសម្លាប់ចោល[1790] មានជាប្រចាំ។

៤១០. វគ្គអប់រំរៀនសូត្រត្រូវបានរៀបចំឡើងនៅមន្ទីរស-២១ជាទៀងទាត់ ហើយក្នុងអំឡុងពេលនោះ អ្នកជាប់ឃុំត្រូវបានបញ្ជាឲ្យធ្វើការឲ្យបានរហ័ស និងមានប្រសិទ្ធភាព[1791]។ អ្នកជាប់ឃុំនោះ ត្រូវបានឲ្យចូលរៀនវគ្គបំពាក់បំប៉ននយោបាយ និងមនោគមន៍វិជ្ជា[1792] និងការប្រជុំស្វ័យទិតៀន[1793]។

<u>ការសួរចម្លើយ</u>

៤១១. សាក្សីជាច្រើនរូបបានរៀបរាប់ថា មានការសួរចម្លើយ ហើយអ្នកជាប់ឃុំខ្លះត្រូវបានបុគ្គលិក វាយធ្វើបាបយ៉ាងខ្លាំងនៅពេលនោះ[1794]។ ឌុច អះអាងថា ជាធម្មតា មន្ទីរស-២១ មិនមែនជាកន្លែងសួរចម្លើយ ឬធ្វើទារុណកម្មអ្នកទោសនោះទេ[1795]។ ទោះជាយ៉ាងណា គាត់ទទួលស្គាល់ថាការសួរចម្លើយអាចត្រូវបានធ្វើឡើង ហើយក្នុងពេលនោះ អ្នកជាប់ឃុំត្រូវបានវាយធ្វើបាប ប៉ុន្តែគាត់បានអះអាងថា គាត់មិនដែលបានទាមទារឲ្យបុគ្គលិកមន្ទីរ ស-២១ ធ្វើការសួរចម្លើយ ដើម្បីទទួលបានចម្លើយសារភាពនោះទេ[1796]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

<u>សន្តិសុខ</u>

៤១២. ការបាត់ខ្លួនអ្នកទោសនៅពេលយប់កើតឡើងជាញឹកញាប់[1797] ហើយអ្នកដែលបាត់ខ្លួនមិនដែលត្រឡប់មកវិញទាល់តែសោះ[1798]។

៤១៣. អ្នកជាប់ឃុំខ្លះនៅមន្ទីរស-២៤ ត្រូវបានបញ្ជូនទៅជើងឯក ដើម្បីសម្លាប់ចោល[1799] ដូចជា កុមារជាដើម[1800]។ អ្នកទោសខ្លះក៏ត្រូវបានបញ្ជូនពីមន្ទីរស-២៤ ទៅកាន់មន្ទីរស-២១ផងដែរ[1801] ហើយ ឌុច បានទទួលស្គាល់ថា ចំនួនអ្នកទោស៥៧១ នាក់យ៉ាងតិចត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ [1802]។ នៅក្នុងសាលក្រមនៃសំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា[1803]៖ *"យោងតាមអ្នកជំនាញ David CHANDLERលក្ខណៈមួយដែលធ្វើឱ្យស-២៤ ខុសពី មន្ទីរស-២១គឺថាអ្នកដែលត្រូវបានឃុំគ្រងនៅស-២៤អាចត្រូវបានដោះលែង។ ទោះបី ជាយ៉ាងនេះក្តី ជនជាប់ចោទបានបញ្ជាក់ថា អ្នកជាប់ឃុំកម្រនឹងត្រូវបានគេដោះលែងណាស់ ហើយពួកគេទាំងអស់ត្រូវបានគេឃុំខ្លួនដើម្បីសម្លាប់ចោលប៉ុណ្ណោះ មិនថាពួកគេត្រូវចាត់ទុកក្នុងក្រុមទី១ ទី២ ឬទី៣នោះទេ។ ជនជាប់ចោទបានផ្តល់សក្ខីកម្មថា គាត់បានដាក់បញ្ជាដល់បុគ្គលិកដែលធ្វើការនៅ ស-២៤ឱ្យសម្លាប់អ្នកជាប់ឃុំ ដោយផ្អែកតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ អ្នកជាប់ឃុំនៅស-២៤ ដែលត្រូវបានកំណត់ថាត្រូវសម្លាប់ ហើយប្រសិនបើត្រូវការចម្លើយសារភាពរបស់អ្នកទាំងនោះ ដំបូងត្រូវតែបញ្ជូនពួកគេទៅមន្ទីរស-២១ (ទួលស្លែង)ជាមុនសិន ចំណែកឯអ្នកដែលគេមិនត្រូវការចម្លើយសារភាពទេ អ្នកទាំងនោះត្រូវបានគេបញ្ជូនទៅជើងឯកផ្ទាល់ដើម្បីសម្លាប់ចោល។ ជាធម្មតា ជនជាប់ចោទជាអ្នកធ្វើសេចក្តីសម្រេចនេះ ទោះបីជាអ្នកនៅក្រោមបង្គាប់របស់គាត់អាចបញ្ជូនអ្នកជាប់ឃុំទៅជើងឯកផ្ទាល់ នៅពេលដែលអ្នកទាំងនោះមិនត្រូវការចម្លើយសារភាពក៏ដោយ ករណីនេះមានដូចជាកុមារជាដើម"*។

***

៤១៤. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១នាក់ (ដប់មួយនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងការដ្ឋានការងារព្រៃស (ស-២៤)[1804] ។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅការដ្ឋានការងារព្រៃស(ស-២៤) ។

## គ. មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស

### មន្ទីរសន្តិសុខ ស-២១[1805]

#### ទីតាំង និងការបង្កើត

៤១៥. មន្ទីរសន្តិសុខ ស-២១ (ស-២១) រួមមានមន្ទីរឃុំឃាំងមួយ នៅក្នុងទីក្រុងភ្នំពេញ និងកន្លែងសម្លាប់មនុស្សមួយនៅជើងឯក ដែលស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រ នៅភាគនិរតីនៃទីក្រុងភ្នំពេញ ក្នុងខេត្តកណ្ដាល[1806]។ ព្រៃស (មន្ទីរស-២៤) ជាជំរុំការងារដែលស្ថិតនៅក្រោមចំណុះមន្ទីរស-២១ ហើយដែលជាកម្មវត្ថុនៃផ្នែកពិសេសមួយនៅក្នុងដីកាដំណោះស្រាយ។

៤១៦. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ សុន សេន បានកោះហៅ ឌុច និង អ៊ិន លន ហៅ ណាត មកពីកងពល ៧០៣ នៃកងទ័ពបដិវត្តន៍កម្ពុជា ឲ្យចូលរួមប្រជុំនៅស្ថានីយ៍រថភ្លើង ក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីរៀបចំផែនការបង្កើតមន្ទីរស-២១[1807]។ មន្ទីរស-២១ បានចាប់ធ្វើប្រតិបត្តិការយ៉ាងពេញលេញនៅខែតុលា ឆ្នាំ១៩៧៥[1808] ហើយបានដំណើរការរហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ថ្ងៃដែល ឌុច បុគ្គលិក និងអ្នកជាប់ឃុំ នៅមន្ទីរស-២១ បានរត់គេចខ្លួន[1809]។

៤១៧. ដំបូងឡើយ មន្ទីរឃុំឃាំងស្ថិតនៅសង្កាត់បឹងកេងកង៣ នៅកាច់ជ្រុងផ្លូវ ១៦៣ និង ៣៦០[1810]។ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ មន្ទីរ ស-២១ ត្រូវបានផ្លាស់ទៅកាន់ទីតាំងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ហើយនៅខែមករា ឆ្នាំ១៩៧៦ ក៏បានរើត្រឡប់មកកាន់ទីតាំងចាស់វិញ[1811]។ ជាចុងក្រោយគឺនៅក្នុងខែមេសា ឆ្នាំ១៩៧៦ តាមការសម្រេចរបស់ ឌុច និងដោយមានការយល់ព្រមពី សុន សេន អ្នកជាប់ឃុំក៏ត្រូវបញ្ជូនយកទៅឃុំឃាំងនៅបរិវេណវិទ្យាល័យពញាយ៉ាត[1812] ដែលបច្ចុប្បន្នជា "សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង"។ អគារកណ្ដាល ("អគារ E") ប្រើសម្រាប់ទទួលកត់ឈ្មោះ និងថតរូបអ្នកទោស[1813]។ នៅក្នុងអគារនោះមានបន្ទប់មួយទៀតប្រើសម្រាប់គូរនិងឆ្លាក់រូបមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។ អគារ B C និង D សម្រាប់ដាក់អ្នកទោសទូទៅជួនកាលនៅតាមបន្ទប់ឃុំឃាំងតូចៗដាច់ដោយឡែក ធ្វើពីឈើ ឬឥដ្ឋ ឬក្នុងបន្ទប់ធំរួមគ្នា[1814]។ ផ្ទះមួយប្លុក នៅខាងត្បូងអតីតវិទ្យាល័យ និងក្រោយមកក៏មានអគារ A ផងដែរ ត្រូវបានគេហៅថាជា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១...។

“គុកពិសេស” សម្រាប់ដាក់អ្នកទោសសំខាន់ៗ[1815]។ អគារទាំងនោះហ៊ុមព័ទ្ធដោយរបង និងត្រូវបានការពារដោយអ្នកយាមប្រដាប់អាវុធ[1816]។ អគារជាច្រើនផ្សេងទៀតនៅក្បែរៗនោះ ក៏ជាផ្នែករបស់មន្ទីរស-២១ ដែរ[1817] និងស្ថិតនៅខាងក្នុងបរិវេណទីពីរផ្នែកខាងក្រៅ ដោយមានអ្នកយាមការពារដែលមានកាន់កាំភ្លើងផងដែរ[1818]។ ជាឧទាហរណ៍ អគារទាំងនោះរួមមាន ផ្ទះសម្រាប់សួរចម្លើយ ទីកន្លែងសម្លាប់មនុស្ស និងរណ្ដៅសាកសពរួម រោងបាយ “មន្ទីរឱសថ” ផ្ទះបុគ្គលិក ការិយាល័យផ្សេងៗ ផ្ទះរបស់ **ឌុច** និងផ្ទះមួយខ្នងសម្រាប់ទទួលអ្នកទោស[1819]។

៤១៨. កាលពីដំបូង អ្នកទោសត្រូវបានគេសម្លាប់នៅក្នុង ឬនៅជុំវិញបរិវេណមន្ទីរ ស-២១[1820]។ នៅពេលមួយមិនដឹងថ្ងៃខែច្បាស់លាស់ ពីចន្លោះឆ្នាំ១៩៧៦ ដល់ពាក់កណ្ដាលឆ្នាំ១៩៧៧ **ឌុច** បានសម្រេចរើសយកជើងឯកធ្វើជាទីកន្លែងសម្រាប់សម្លាប់អ្នកទោស[1821]។ ទោះបីជាជើងឯកបានក្លាយទៅជាកន្លែងសម្លាប់អ្នកទោសក៏ដោយ ក៏នៅមានអ្នកទោសខ្លះនៅតែត្រូវបានគេសម្លាប់ និងកប់នៅក្នុងបរិវេណមន្ទីរ ស-២១ ឬក្បែរបរិវេណនោះដែរ[1822]។

## ការដំណើរប្រព្រឹត្តទៅ

### ការរៀបចំ និងបុគ្គលិក

៤១៩. នៅក្នុងកិច្ចប្រជុំថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ **សុន សេន** បានតែងតាំង **ណាត** ជាប្រធានមន្ទីរ ស-២១ និងជាលេខាគណៈកម្មាធិការរបស់មន្ទីរនេះ[1823] ហើយ **ឌុច** ជាអនុប្រធានទទួលបន្ទុកក្រុមអ្នកសួរចម្លើយ[1824]។ ដោយមានជំនួយពីសមាជិកកងពល៧០៣ អ្នកទោសក៏ត្រូវបានគេបញ្ជូនពីមន្ទីរពេទ្យឆ្កួតតាខ្មៅដែល **អ៊ិន លន** ហៅ **ណាត** បានប្រើធ្វើជាមន្ទីរឃុំឃាំង ទៅអង្គភាពសួរចម្លើយនៃមន្ទីរ ស-២១[1825]។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ ណាតត្រូវបានផ្លាស់ទៅសេនាធិការ ហើយតួនាទីជាប្រធាន និងជាលេខាមន្ទីរស-២១ របស់ **ណាត** ត្រូវបានធ្លាក់ទៅលើ **ឌុច**[1826]។ **ឌុច** បានរក្សាទុកនូវតួនាទីជាអនុប្រធានទទួលបន្ទុកប្រតិបត្តិការប្រចាំថ្ងៃនៃមន្ទីរស-២១ របស់ **ឃឹម វ៉ាត** ហៅ ហ៊ី។ សមាជិកទីបីនៃគណៈកម្មាធិការមន្ទីរស-២១ មានឈ្មោះថា នុន ហ៊ុយ ហៅ ហ៊ុយស្រែ។ ហ៊ុយស្រែ ក៏ជាអ្នកទទួលខុសត្រូវលើមន្ទីរស-២៤ ផងដែរ[1827]។ ក្នុងនាមជាប្រធាន **ឌុច** ទទួលបន្ទុកខាងជ្រើសរើសបុគ្គលិក[1828] និងបណ្ដុះបណ្ដាលជាពិសេសការបណ្ដុះបណ្ដាលនយោបាយបុគ្គលិក[1829]។ **ឌុច** ក៏បានបង្រៀនផងដែរដល់បុគ្គលិកនៃមន្ទីរស-២១ នូវវិធីសួរចម្លើយ និងបច្ចេកទេសក្នុងការសម្លាប់អ្នកទោស[1830]។

៤២០.ឌុច គ្រប់គ្រងមន្ទីរ ស-២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធរាយការណ៍គ្រប់ជាន់ថ្នាក់ ដើម្បីធានាថា រាល់បទបញ្ជារបស់គាត់ត្រូវបានអនុវត្តភ្លាមៗ និងជាក់លាក់[1831]។ មន្ទីរ ស-២១ ត្រូវបានបែងចែកជាច្រើនអង្គភាព[1832] ដែលក្នុងនោះមានអង្គភាពស្សួរចម្លើយ[1833] អង្គភាពរៀបចំឯកសារ[1834](ទទួលបន្ទុកខាងចុះបញ្ជី) និងអង្គភាពការពារ ដែលចែកចេញជាពីរផ្នែកគឺអង្គភាពកងការពារ (ទទួលបន្ទុកខាងត្រួតពិនិត្យអ្នកទោសនៅក្នុងគុក) និងអង្គភាពពិសេស។ អង្គភាពពិសេសនេះមានភារកិច្ចមួយចំនួនដូចជាទទួលអ្នកទោសដែលបញ្ជូនមកមន្ទីរ ស-២១ ឬក្នុងករណីខ្លះធ្វើការចាប់ខ្លួន ឬក៏ធ្វើការបញ្ជូនអ្នកទោស និងធ្វើអន្តរាគមន៍ក្នុងករណីបន្ទាន់ និងចុងក្រោយទទួលបន្ទុកដឹកអ្នកទោសទៅជើងឯក និងធ្វើការសម្លាប់[1835]។

៤២១. មន្ទីរ ស-២១ ជាមន្ទីរនយោបាយផង ជាមន្ទីរកងទ័ពផង។ ឌុច បាននិយាយថាមន្ទីរ ស-២១ គឺជាកងវរសេនាធំឯករាជ្យ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីសេនាធិការ ខាងផ្នែកកិច្ចការរដ្ឋបាល និងកិច្ចការផ្សេងៗទៀតដូចជា ការរកស្បៀងអាហារ បុគ្គលិក ការបណ្តុះបណ្តាល។ ទន្ទឹមនឹងនោះដែរមន្ទីរ ស-២១ ក៏ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់ការងារផ្នែកសន្តិសុខ[1836]។ ឌុច បានបញ្ជាក់ជាច្រើនលើកច្រើនសាថា ពីខែមីនា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ថ្នាក់លើរបស់គាត់គឺ សុន សេន ហើយបន្ទាប់មក គឺ នួន ជា ដែលបានមកជំនួស សុន សេន រហូតដល់ថ្ងៃដែលដួលរលំនៃរបបនេះ ។ ទំនាក់ទំនងរវាង ឌុច និងថ្នាក់លើរបស់គាត់នឹងលើកបរិយាយលម្អិតនៅក្នុងដីកានេះផ្នែកទាក់ទងនឹង នួន ជា។

៤២២. មន្ទីរ ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ។ មន្ទីរ ស-២១ ត្រូវធ្វើរបាយការណ៍ទៅថ្នាក់លើខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញប្រទេស ទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗដែលត្រូវបានចាប់ខ្លួន[1837]។

**<u>ការចាប់ខ្លួន និងការឃុំឃាំង</u>**

**សមាសភាពរបស់អ្នកដែលជាប់ឃុំឃាំង**

៤២៣. ផ្អែកលើបញ្ជីឈ្មោះអ្នកទោសដែលបានកែសម្រួលរួច មនុស្សយ៉ាងតិចណាស់[1838]ចំនួន១២.២៧៣ នាក់ ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរស-២១[1839]។ នៅក្នុងបញ្ជីនោះ អ្នកទោស ៥.៩៩៤ នាក់ ជាបុរស ១.៦៩៨ នាក់ ជានារី និង៨៩ នាក់ ជាកុមារ[1840]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៤២៤. អ្នកទោសភាគច្រើនជាជនជាតិខ្មែរ។ ក្រុមអ្នកទោសដែលសំខាន់ជាងគេ គឺអ្នកទោសដែលជាអតីតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា ( ៥.៦០៩ នាក់ យោងលើបញ្ជីឈ្មោះដែលបានកែប្រែរួច ) ។ ជាញឹកញាប់ ការសម្រិតសម្រាំងផ្ទៃក្នុងជួរកងទ័ព បណ្តាលឲ្យមានការចាប់បញ្ជូនសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជាគ្រប់លំដាប់ថ្នាក់ទៅកាន់មន្ទីរស-២១។ អតីតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជាដែលជាប់ឃុំឃាំងនៅមន្ទីរស-២១ភាគច្រើន ត្រូវបានចាប់ខ្លួនមកពីកងពលនានា (ជាពិសេសកងពល១៦៤, ១៧០, ១៧៤, ២៩០, ៣១០, ៤៥០, ៥០២, ៥០៥, ៧០៣, ៨០១ និង៩២០) និងពីគ្រប់កងវរសេនាធំឯករាជ្យនានា (១៥២, ៣៧៧ និង៤៨៨)។ សមាជិកជាច្រើននៃអគ្គសេនាធិការ ក៏ត្រូវបានចាប់បញ្ជូនខ្លួនទៅកាន់មន្ទីរ ស-២១ ផងដែរ[1841]។ ភស្តុតាងដែលប្រមូលបានក៏បានបង្ហាញផងដែរថា បុគ្គលិកនៃមន្ទីរ ស-២១ ចំនួន១៥៦ នាក់ ក៏ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរនេះផងដែរ។ ដោយឡែក យ៉ាងតិចក៏មាន បុគ្គលិកនៃមន្ទីរ ស-២៤ ចំនួន៤៧ នាក់ ត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរ ស-២១ ដែរ[1842]។

៤២៥. អ្នកទោសក្រុមទីពីរ ដែលមានចំនួនច្រើន គឺជាអ្នកទោសដែលជាអតីតកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា (៤.៣៧១ នាក់ យោងលើបញ្ជីឈ្មោះដែលបានកែប្រែរួច)[1843]។ អ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ រួមមាន៖ លេខាភូមិភាគនានាដូចជា រស់ ញឹម (ខែមិថុនា ឆ្នាំ១៩៧៨)[1844] ម៉ែន សាន ហៅ យ៉ា (ខែកញ្ញា ឆ្នាំ១៩៧៦)[1845] កង ចាប ហៅ សែ (ខែសីហា ឆ្នាំ១៩៧៨) និងសមាជិកទាំងឡាយនៃគណៈអចិន្ត្រៃយ៍ ដូចជា វន វ៉េត (ខែវិច្ឆិកា ឆ្នាំ១៩៧៨)[1846] គង់ សុផល ហៅ កឺ ហៅ កាន (ខែវិច្ឆិកា ឆ្នាំ១៩៧៨)[1847] និងលេខាតំបន់ស្វយ័តនានាដូចជា ប៊ូ ផាត ហៅ ហង់ (ខែមិថុនា ឆ្នាំ១៩៧៨)[1848] បន ណាន ហៅ យី (ខែមិថុនា ឆ្នាំ១៩៧៨)[1849] ប៉ា ផល ហៅ សុត (ខែកុម្ភៈ ឆ្នាំ១៩៧៧)[1850] ព្រមទាំងការឃុំខ្លួនអតីតរដ្ឋមន្ត្រីក្រសួងឃោសនាការ ហ៊ូ នឹម (ខែ មេសា ឆ្នាំ១៩៧៧)[1851]។

៤២៦. នៅក្នុងចំណោមអតីតកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា យ៉ាងហោចណាស់មានអ្នកទោសចំនួន ២០៩ នាក់ ដែលជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ត្រូវបានចាប់ខ្លួនពីមន្ទីរ៨៧០ និងពីមន្ទីរ ស-៧១ ព្រម ទាំងពីអង្គភាពដទៃទៀត ដែលនៅចំណុះមន្ទីរទាំងពីរនេះដូចជា៖ សាលាបណ្តុះបណ្តាលជំនាញទូរលេខ អង្គភាពទាំងឡាយរបស់មន្ទីរ ស-៧១ ដែលមានឈ្មោះជាអក្សរកាត់ ក-១ រហូតដល់ ក-១៨ (និងជាពិសេសភូមិតាលៃ ដែលចំណុះឲ្យ ក-១៣) យ-១០ (កងយោធាដែលមានភារកិច្ចការពារមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា) ស្ទឹងមានជ័យ និងអតីត ប-២០។ ការចាប់ខ្លួន

លើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៦ និងការចាប់ខ្លួនលើកចុងក្រោយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៨[1852]។

៤២៧. មុនពេលត្រូវបានចាប់ខ្លួន អ្នកទោសយ៉ាងហោចណាស់១១៣ នាក់ ធ្លាប់បម្រើការងារក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងការបរទេស ជាពិសេសអ្នកដែលធ្វើការនៅមន្ទីរ ម-១ នៅច្រាំងចំរេះ និងអ្នកដែលធ្លាប់ទៅធ្វើការនៅស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅបរទេស[1853] (ការចាប់ខ្លួនលើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៦ និងការចាប់ខ្លួនលើកចុងក្រោយនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨)។ យ៉ាងហោចណាស់មានអ្នកទោសចំនួន១៦ នាក់ត្រូវបានបញ្ជូនខ្លួនមកពីបឹងត្របែក និងជាពិសេសមកពីមន្ទីរដែលចំណុះឲ្យមន្ទីរនេះគឺ មន្ទីរ ក-១៥ និង មន្ទីរ ក-១៧ (ការចាប់ខ្លួនលើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅក្នុងខែធ្នូ ឆ្នាំ១៩៧៥ និងការចាប់ខ្លួនលើកចុងក្រោយនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨)[1854]។

៤២៨. នៅក្នុងសម័យកាលទាំងមូលនៃកម្ពុជាប្រជាធិបតេយ្យ មានអ្នកជាប់ឃុំឃាំងយ៉ាងហោចណាស់ចំនួន ៤៨២ នាក់ ត្រូវបានចាប់ខ្លួនមកពីក្រសួងពាណិជ្ជកម្ម ឬអង្គភាពពាណិជ្ជកម្មរដ្ឋ នៅតាមមូលដ្ឋាននានា ដែលចំណុះឲ្យក្រសួង ជាពិសេសអង្គភាពខាងនេសាទ ខាងកាត់ដេររដ្ឋ ខាងឃ្លាំងរដ្ឋ ខាងដឹកជញ្ជូនជើងគោក និងខាងកំពង់ផែកំពង់សោម[1855]។ ការចាប់ខ្លួនលើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅក្នុងខែតុលា ឆ្នាំ១៩៧៥ និងការចាប់ខ្លួនលើកចុងក្រោយ នៅក្នុងខែមីនា ឆ្នាំ១៩៧៨។

៤២៩. មានមនុស្សដែលត្រូវបានចាប់ខ្លួនចំនួន ១១៦ នាក់ ជាបុគ្គលិកក្រសួងសង្គមកិច្ច បុគ្គលិកមន្ទីរពេទ្យ ឬអង្គភាពចំណុះដូចជា៖ ផ-១, ផ-២ នៅជ្រោយចង្វារ, ផ-៣ (នៅផ្សារចាស់), ផ-៤ (អតីតរោងចក្រ DUMEX), ព-១៧ (មន្ទីរពេទ្យ១៧ មេសា), ព-១ (កាល់ម៉ែត្រ), ព-២, ព-៣, ព-៤ (ក្រោយមកទៅជា ព-៦), ផ-៥ និងមន្ទីរប្រយុទ្ធប្រឆាំងជម្ងឺគ្រុនចាញ់។ ការចាប់ខ្លួនលើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅក្នុង ខែកញ្ញា ឆ្នាំ១៩៧៦ និងការចាប់ខ្លួនលើកចុងក្រោយនៅចុងខែធ្នូ ឆ្នាំ១៩៧៨ ដែលក្នុងឆ្នាំ១៩៧៨ នេះ តួលេខនៃការចាប់ខ្លួនមនុស្សមានកម្រិតខ្ពស់ជាងគេបំផុត[1856]។

៤៣០. អ្នកជាប់ឃុំឃាំងយ៉ាងហោចណាស់ចំនួន ៨៤ នាក់ ជាបុគ្គលិកក្រសួងអប់រំ និងឃោសនាការ និងអង្គភាពទាំងឡាយដែលនៅចំណុះក្រសួងនេះ ជាពិសេសមន្ទីរនានាដែលមានឈ្មោះ ជាអក្សរកាត់ពី ក-២៥ រហូតដល់ ក-៣៨ ដែលសំដៅទៅលើរោងពុម្ព ស្ថានីយវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា

ក្រុមសិល្បៈ និងក្រុមអ្នកកាសែត។ ការចាប់ខ្លួនលើកទី១ ដែលមានចុះក្នុងបញ្ជីបានធ្វើនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៦ និងការចាប់ខ្លួនលើកចុងក្រោយក្នុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៨ ដោយមានការកើនឡើងនៃចំនួនអ្នកដែលត្រូវបានចាប់ខ្លួននៅចន្លោះខែកុម្ភៈ និងខែឧសភា ឆ្នាំ១៩៧៨[1857]។

៤៣១. កម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា និងសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជាដែលត្រូវបានចាប់ខ្លួនមានប្រភពចេញមកពីភូមិភាគ និងតំបន់ស្វយ័តទាំងឡាយនៅក្នុងប្រទេសកម្ពុជា ហើយចំនួននៃអ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះ បានកើនឡើងទៅតាមចង្វាក់នៃការបោសសម្អាតដែលផ្សារភ្ជាប់ទៅនឹងការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ និងមេបញ្ជាការយោធានានា។ ជាមួយគ្នានេះដែរ ចំនួននៃអ្នកទោសដែលចាប់មកពីអតីតភូមិភាគឧត្តរ(ភូមិភាគកណ្តាល) បានកើនឡើងដល់ ៣៦០ នាក់ ពេញមួយសម័យកាល ហើយការចាប់ខ្លួនមានចំនួនលើសពី៨០ នាក់ តែក្នុងអំឡុងពេលនៃខែកុម្ភៈ ឆ្នាំ១៩៧៧ មួយគត់[1858] (ក្នុងខែបន្ទាប់ពីការចាប់ខ្លួន កុយ ធួន[1859])។ សម្រាប់តំបន់១០៦ មនុស្សដែលចាប់ចូលមកមានចំនួន ៧៥ នាក់ ដែលជាតួលេខខ្ពស់បំផុតសម្រាប់ខែមីនា ឆ្នាំ ១៩៧៧[1860]។ មនុស្សមួយចំនួនដែលត្រូវបានចាប់ខ្លួនគឺជាមនុស្សដែល កុយ ធួន បានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់គាត់ នៅក្នុងបញ្ជីឈ្មោះនៃ"ខ្សែក្បត់"របស់គាត់[1861]។ ចុងក្រោយ សម្រាប់ភូមិភាគបូព៌ា ចំនួននៃអ្នកចាប់ខ្លួនបានកើនឡើងរហូតដល់ ១.១៦៥ នាក់ ដោយមានការចាប់ខ្លួនមនុស្សប្រហែល ៥០០ នាក់ តែក្នុងអំឡុងពេលនៃខែមិថុនា ឆ្នាំ១៩៧៨[1862] ប៉ុណ្ណោះ ដែលស្របទៅនឹងការធ្វើអត្តឃាតរបស់ សោ ភឹម។

៤៣២. ក្រៅអំពីសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា និងអតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក៏មានជនកម្ពុជាផ្សេងទៀតត្រូវបានសង្កេតឃើញថា មានឈ្មោះចូលក្នុងបញ្ជីនៃអ្នកទោសផងដែរ ជាពិសេស អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ឬនៃកងកម្លាំងប្រដាប់អាវុធជាតិខ្មែរ(៣២៨ នាក់ មានឈ្មោះក្នុងបញ្ជីដែលត្រូវបានកែប្រែរួច)[1863] គ្រូបង្រៀន សាស្ត្រាចារ្យ និស្សិត វេជ្ជបណ្ឌិត មេធាវី និងវិស្វករ (មានចំនួន២០៩ នាក់)[1864] ជនជាប់ឃុំឃាំង ដោយមូលហេតុមានទំនាក់ទំនងសាច់ញាតិជាមួយមនុស្សដទៃទៀត (មានចំនួន៨៧៦ នាក់)[1865] និងមនុស្សមួយចំនួនទៀតដែលគេពុំស្គាល់ប្រភពនៃការចាប់ខ្លួន[1866]។

៤៣៣. មានជនបរទេសមួយចំនួន[1867]ក៏ត្រូវបានចាប់បញ្ជូនមកឃុំខ្លួននៅមន្ទីរ ស-២១ ផងដែរ ដែលរួមមានជនជាតិ៖ ថៃ ឡាវ ឥណ្ឌា និងពួក"*បស្ចិមប្រទេស* "[1868]។ នៅក្នុងចំណោមជនបរទេសទាំងនោះ អ្នកទោសជាជនជាតិវៀតណាមមានចំនួនច្រើនជាងគេ។ បញ្ជីឈ្មោះអ្នកទោសដែលត្រូវបាន

00605397



តែប្រែប្រួច បានបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់ក៏មានអ្នកទោសជនជាតិវៀតណាមចំនួន ៣៤៥ នាក់ដែលបានជាប់ឃុំឃាំង ដែលក្នុងចំណោមនោះមាន១២២ នាក់ ត្រូវបានបញ្ជាក់ថាជាយោធា និង១៤៤ នាក់ ជាគិញ(អាចជាជនស៊ីវិល ឬជាយុទ្ធជន)។ ចំណែកឯអ្នកទោសចំនួន៧៩ នាក់ ដែលនៅសេសសល់(រួមបញ្ចូលទាំងស្ត្រី និងកុមារ) ទំនងជាជនស៊ីវិល តែពុំមានព័ត៌មានបញ្ជាក់ឱ្យបានច្បាស់ឡើយ[1869]។ វត្តមានរបស់ពួកគេនៅមន្ទីរ ស-២១ ត្រូវបានបញ្ជាក់បន្ថែមផងដែរ ដោយសាក្សីនានា[1870] ដោយចម្លើយសារភាព[1871] និងរូបថតទាំងឡាយ[1872] ដែលនៅសេសសល់។ ការចាប់ខ្លួនជនជាតិវៀតណាមលើកទីមួយដែលមានចុះក្នុងបញ្ជីអ្នកទោស បានធ្វើឡើងនៅក្នុងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឌុច បានអះអាងថា មានជនជាតិវៀតណាមមួយចំនួន(ក្នុងចំនួនតិចតួច) ត្រូវបានបញ្ជូនមកកាន់មន្ទីរ ស-២១ ចាប់តាំងពីឆ្នាំ១៩៧៥[1873]មក ហើយបានបញ្ជាក់ថា ចំនួននៃអ្នកទោសជនជាតិវៀតណាមនេះ បានកើនឡើងនៅពេលដែលកម្ពុជាប្រជាធិបតេយ្យមានជម្លោះជាមួយប្រទេសវៀតណាម។

**ការចាប់ខ្លួន និងការបញ្ជូនទៅមន្ទីរ ស-២១**

៤៣៤. មានវិធីពីរយ៉ាងដែលត្រូវបានប្រើប្រាស់ សម្រាប់ធ្វើការចាប់ខ្លួននិងបញ្ជូនកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា និងសមាជិកកងទ័ពបដិវត្តន៍កម្ពុជា ដែលមកពីភូមិភាគ ឬតំបន់ស្វយ័ត។ ពេលខ្លះមានសមាជិកនៃបុគ្គលិកមន្ទីរ ស-២១ ចូលមកភូមិភាគ ហើយធ្វើការចាប់ខ្លួន ឬប្រមូលអ្នកទោសដែលបានចាប់ខ្លួនដោយអង្គភាពនានារបស់ភូមិភាគ ហើយបន្ទាប់នាំយកមកទីក្រុងភ្នំពេញ[1874]។ ពេលខ្លះទៀត កម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា និង សមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានមន្ទីរ៨៧០ ជាពិសេស **នួន ជា** បានកោះហៅជាផ្លូវការឱ្យទៅចូលរួមការប្រជុំ ឬរៀនសូត្រ ហើយអ្នកទាំងនោះក៏ទៅបាត់រហូត[1875]។ មានករណីជាច្រើន អ្នកដែលត្រូវចាប់ខ្លួនត្រូវបាននាំយកមកដាក់នៅ ក-៧ មុននឹងត្រូវសមាជិករបស់អង្គភាពចំណុះមន្ទីរ ស-៧១ ចាប់បញ្ជូនទៅមន្ទីរ ស-២១[1876]។ ចំពោះអង្គភាពផ្សេងៗនៅទីក្រុងភ្នំពេញ ជាពិសេសក្រសួង ឬអង្គភាពរបស់មជ្ឈិម មានភស្តុតាងបង្ហាញថា ក្រៅពីមន្ទីរ ស-២១ នៅមានសមាជិករបស់អង្គភាពចំណុះមន្ទីរ ស-៧១ ទទួលបន្ទុកក្នុងការចាប់ខ្លួន[1877]។ មានពេលខ្លះ អ្នកត្រូវចាប់ខ្លួនត្រូវបានយកមកដាក់នៅ ក-៧ ផងដែរ[1878]។ ជួនកាល ក្រសួងនានាក៏អាចទទួលបន្ទុកខាងដឹកអ្នកទោសមកពីក្រសួងរបស់ខ្លួនទៅមន្ទីរ ស-២១ ដែរ[1879]។ ឌុច បានបញ្ជាក់ថា ជាគោលការណ៍ "មន្ទីរស-២១ មិនមានសិទ្ធិចាប់មនុស្ស" នោះទេ។ គាត់បានបន្ថែមទៀតថា ភាគច្រើនគាត់គ្រាន់តែទទួលដំណឹងអំពីការចាប់ខ្លួនពី"ថ្នាក់លើ" ដើម្បីឱ្យគាត់រៀបចំការទទួលអ្នកទោស[1880]។ ក្រៅពីករណីដែល មន្ទីរ ស-២១ ត្រូវធ្វើការចាប់ខ្លួន

ដូចរៀបរាប់ខាងក្រោមនេះ ឌុច បានទទួលនូវការជូនដំណឹងពីអ្នកទោសដែលនឹងត្រូវមកដល់តាមរយៈបញ្ជីឈ្មោះដែលទទួលបានពី សុន សេន នួន ជា ឬពី កែន ហៅ លីន[1881]។

៤៣៥. ក៏ប៉ុន្តែ សំណុំរឿងបានបង្ហាញថា បុគ្គលិកមន្ទីរ ស-២១ ជួនកាលបានធ្វើការចាប់ខ្លួនដោយផ្ទាល់[1882]។ [លុប] បានប្រាប់ឲ្យដឹងថា នៅពេលដែលមន្ទីរ ស-២១ ត្រូវចាប់ខ្លួនមនុស្សនៅខាងក្រៅ តែនៅក្នុងទីក្រុងភ្នំពេញ ការចាប់ខ្លួនអាចធ្វើឡើងក្រោមរូបភាពពីរយ៉ាង៖ ទី១ អង្គភាពមន្ទីរ ស-២១ ត្រូវអនុវត្តការចាប់ខ្លួនដោយខ្លួនឯង ទី២ ប្រសិនបើមនុស្សនោះត្រូវបានគេចាប់ខ្លួនរួចស្រេចហើយ អង្គភាព មន្ទីរ ស-២១ គ្រាន់តែមានភារកិច្ចដឹកអ្នកទាំងនោះមកកាន់មន្ទីរ ស-២១ ប៉ុណ្ណោះ[1883]។ [លុប] និយាយថា គាត់ត្រូវបានចាត់ឲ្យចេញក្រៅក្រុងភ្នំពេញច្រើនដងដើម្បីនាំយកអ្នកទោសមកកាន់មន្ទីរ ស-២១ ហើយម្តងៗគាត់បានទទួលបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនពី ឌុច[1884]។ ឌុច បានទទួលស្គាល់ថា ក្នុងករណីចាំបាច់ កងពិសេសនៃមន្ទីរ ស-២១ ត្រូវចាកចេញពីទីក្រុងភ្នំពេញ ដោយមានបទបញ្ជារបស់គណៈកម្មាធិការមជ្ឈិម ហើយកាន់លិខិតដើរផ្លូវពិសេស ដោយមានចុះហត្ថលេខារបស់ សុន សេន ដែលផ្តល់សិទ្ធិឲ្យពួកគេនាំយកអ្នកទោសមកកាន់មន្ទីរ ស-២១។ ឌុច បាននិយាយថា ពេលក្រោយមក ប្រព័ន្ធនេះត្រូវបានបោះបង់ចោល[1885]។ ជាងនេះទៅទៀត ឌុច បានរៀបរាប់ថា ជួនកាលគាត់ត្រូវបានគេពិគ្រោះយោបល់ ឬត្រូវពាក់ព័ន្ធនឹងការធ្វើគម្រោងចាប់ខ្លួន ជាពិសេសនៅពេលទាក់ទងនឹងការចាប់ខ្លួនមនុស្សចំនួនជាច្រើននាក់នៅក្នុងអង្គភាពតែមួយ ឬក៏សមាជិកសំខាន់ៗរបស់បក្ស[1886]។ ចុងក្រោយ ចំពោះមនុស្សសំខាន់ៗមួយចំនួនដូចជា កុយ ធួន និង ប៉ង់ ពេលខ្លះ ការចាប់ខ្លួនត្រូវធ្វើឡើង នៅផ្ទះរបស់ ឌុច[1887]។

៤៣៦. ឌុច បានបញ្ជាក់ថា នៅពេលដែលមានការសម្រេចពីការចាប់ខ្លួន កលល្បិច និងការសម្ងាត់ គឺជាចំនុចចំបង ដើម្បីធានាមិនឲ្យមានការរត់គេច និងដើម្បីបង្ការការក្រោកឈរប្រឆាំង ជាពិសេសនៅពេលដែលការចាប់ខ្លួនមនុស្សជាច្រើនត្រូវធ្វើនៅក្នុងអង្គភាពតែមួយ[1888]។ ក្នុងករណីទាក់ទិននឹងការចាប់ខ្លួនមនុស្សចំនួនជាច្រើននេះ ឌុច បានប្រកាសថា គាត់បានប្រគល់តួនាទីឲ្យ ហ៊ី ជាអ្នកពិភាក្សាជាមួយអ្នកទទួលខុសត្រូវរបស់អង្គភាពនោះ ដើម្បី“កុំឲ្យបុគ្គលិកមានការរំជើបរំជួល និងដើម្បីសម្រួលដល់ការចាប់ខ្លួន[1889]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

<u>ការចាប់ខ្លួនជនស៊ីវិល ឬទាហានវៀតណាម</u>

៤៣៧. ជាទូទៅ ជនស៊ីវិល ឬទាហានវៀតណាមត្រូវបានចាប់ខ្លួន នៅក្នុងតំបន់ជម្លោះដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយវៀតណាម ឬជិតតំបន់ជម្លោះ[1890]។ អតីតមេបញ្ជាការកងទ័ព [លុប] បានអះអាងថា៖ *"ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននៅព្រំដែនជិតស្វាយរៀង និងព្រៃវែងត្រូវបានបញ្ជូនខ្លួនមកទីក្រុងភ្នំពេញ។ ជាដំបូង ពួកគេឆ្លងកាត់តាមអគ្គបញ្ជាការដ្ឋាននៃកងពលដែលនៅទីនោះ [លុប] ជាអ្នកធ្វើសេចក្តីសម្រេចចាត់វិធានការទាក់ទងនឹងជនជាតិវៀតណាមទាំងអស់នេះ។ (...) ខ្ញុំគិតថាពួកគេត្រូវបានបញ្ជូនទៅឲ្យ ឌុច នៅមន្ទីរស-២១។ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ពីព្រោះថានៅពេលនោះ បើនិយាយឲ្យត្រង់ យើងស្ថិតនៅក្នុងភពងងឹត។ យើងមិនដឹងថាមានអ្វីកើតឡើងដោយពិតប្រាកដនោះទេ ហើយការផ្លាស់ទីត្រូវបានគេរឹតត្បិតខ្លាំងណាស់"*[1891]។

៤៣៨. បើមិនទាំងអស់ទេ ជនស៊ីវិល និងទាហានវៀតណាមមួយចំនួនដែលត្រូវបានចាប់ខ្លួននៅតំបន់ជម្លោះសំខាន់ៗ ពិតជាត្រូវបានបញ្ជូនមកមន្ទីរ ស-២១ ដោយពិតប្រាកដ[1892]។ ឌុច បានរៀបរាប់ថា គាត់ត្រូវបានគេជូនព័ត៌មានទាក់ទងតែការមកដល់របស់ពួកគេ គឺដូចការមកដល់របស់អ្នកទោសដទៃទៀតដែរ គឺផ្តល់បញ្ជីឈ្មោះតែប៉ុណ្ណោះ[1893] ហើយគាត់បានបន្ថែមទៀតថា មន្ទីរ ស-២១ មិនដែលធ្លាប់ទទួលបន្ទុកក្នុងការដឹកជនជាតិវៀតណាមពីតំបន់ប្រតិបត្តិការសឹកទេ[1894]។ ការអះអាងនេះត្រូវបានជំទាស់ដោយ ហ៊ឹម ហ៊ុយ ដែលបានប្រកាសថា នៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ឌុច បានបង្ខំឲ្យគាត់ប្រញាប់ទៅសមរភូមិឯស្វាយរៀង ដើម្បីទៅយកទាហានវៀតណាមមកមន្ទីរ ស-២១[1895]។ លើសពីនេះទៅទៀត [លុប] បានប្រកាសថា គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅព្រំដែននៅឆ្នាំ១៩៧៧ ហើយបានឃើញសមាជិកនៃបុគ្គលិកមន្ទីរ ស-២១ ដឹកឈ្លើយសឹកវៀតណាមតាមឡានរបស់មន្ទីរ ស-២១ ពីតំបន់ប្រតិបត្តិការសឹក[1896]។

*ការចាប់ខ្លួនបុគ្គលិកមន្ទីរ ស-២១*

៤៣៩. បុគ្គលិកមន្ទីរ ស-២១ មួយចំនួនក៏ត្រូវបានគេចាប់ខ្លួនដែរ។ ពួកគាត់ត្រូវបានបញ្ជូនទៅព្រៃស ដើម្បីកសាងខ្លួនឡើងវិញ[1897] ឬក៏ត្រូវជាប់ឃុំខ្លួននៅមន្ទីរ ស-២១[1898]។ កម្មាភិបាលអាចត្រូវបានគេបញ្ជូនទៅព្រៃស ចំពោះកំហុសតូចតាច ដូចជានៅពេលដែលកម្មាភិបាលនោះមានស្គាល់អ្នកទោសណាម្នាក់ដែលជាប់ឃុំឃាំងនៅមន្ទីរ ស-២១[1899] ជាដើម។ ចំពោះកំហុសធ្ងន់ធ្ងរជាង ដូចជាបណ្តាលឲ្យអ្នកទោសរត់គេចខ្លួន ធ្វើអត្តឃាត ឬក៏ស្លាប់មុនពេលបញ្ចប់ការសួរចម្លើយ[1900] អ្នកដែលទទួលខុស

ត្រូវ ត្រូវបានគេចាត់ទុកថាជាជនក្បត់បដិវត្តន៍ និងត្រូវបានគេចាប់ខ្លួន*[1901]*។ ផ្ទុយទៅវិញ សាក្សីខ្លះទៀតបានបង្ហាញថា ភាគច្រើននៃបុគ្គលិកមន្ទីរ ស-២១ និងជាពិសេសបុគ្គលិកដែលមកពីខាងកងពលធំ៧០៣ ត្រូវបានគេចាប់ខ្លួន ទោះបីជាមិនបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរណាមួយក៏ដោយ[1902]។

៤៤០.អតីតកងការពារបានប្រកាសថា មានតែ ឌុច ម្នាក់គត់ដែលអាចបញ្ជាឲ្យចាប់សមាជិកនៃបុគ្គលិកនៃមន្ទីរស-២១[1903]។ ចំណែក ឌុច វិញ គាត់បានគូសបញ្ជាក់ថា ទោះបីជា"*ទម្រង់នៃការបោសសំអាតទីមួយ*(បញ្ជូនបុគ្គលិកទៅមន្ទីរ ស-២៤) *ជាសមត្ថកិច្ចរបស់មន្ទីរ ស-២១ ក៏ដោយ ក៏ផ្ទុយទៅវិញនៅពេលក្រោយមក សម្រាប់ទម្រង់នៃការបោសសំអាតទីពីរ* (ការឃុំខ្លួនសមាជិកបុគ្គលិកនៅមន្ទីរ ស-២១) *សេចក្តីសម្រេចចេញមកពី **សុន សេន** ឬ **នួន ជា** នៅពេលបន្ទាប់*"[1904]។

លក្ខខណ្ឌនៃការឃុំខ្លួន

៤៤១. មានអ្នកទោសមកមន្ទីរ ស-២១ ស្ទើរតែរាល់ថ្ងៃ ជាក្រុមៗ និងរាល់ម៉ោងនាពេលថ្ងៃ និងពេលយប់[1905]។ អង្គភាពពិសេសនាំពួកគេចូលគុក ដោយជាទូទៅ ដាក់ខ្នោះដៃ និងចងមុខពួកគេ[1906]។ នៅពេលនោះ អ្នកទោសទាំងនោះត្រូវបានចុះបញ្ជីដោយអង្គភាពរៀបចំឯកសារ[1907]។ ពួកគេត្រូវផ្តល់ប្រវត្តិរូបរបស់ខ្លួន[1908] បន្ទាប់មក គេសង្ខេបចម្លើយរបស់ពួកគាត់[1909]។ ជាទូទៅ គេមិនបានប្រាប់ពួកគាត់អំពីមូលហេតុនៃការចាប់ខ្លួនទេ។ នៅពេលមកដល់ អ្នកទោសក៏ត្រូវបានគេថតរូបផងដែរ[1910]។ បន្ទាប់មកទៀត អ្នកយាមនាំពួកគាត់ទៅក្នុងបន្ទប់ឃុំឃាំង[1911]។

៤៤២. អ្នកទោសត្រូវបានគេឃុំខ្លួនស្ទើរតែ២៤ម៉ោងលើ២៤ម៉ោង[1912]។ មន្ទីរឃុំខ្លួន ស-២១ មានទាំងបន្ទប់ឃុំខ្លួនតូចៗដាច់ដោយឡែក[1913] និងបន្ទប់ធំឃុំខ្លួនរួមដែលមានអ្នកទោសពី២០ទៅ៣០នាក់។ វាអាចមានច្រើនជាងនេះទៀតផង។ នៅក្នុងបន្ទប់ឃុំខ្លួនរួមនេះ អ្នកទោសត្រូវបានគេដាក់ច្រវាក់ជើងបន្តគ្នា[1914]។ អ្នកទោសស្ត្រីមិនត្រូវបានគេដាក់ខ្នោះទេ[1915] ប្រសិនបើពួកគេមិនបង្កបញ្ហា[1916]។ ប្តីប្រពន្ធ និងក្រុមគ្រួសារ រួមបញ្ចូលទាំងកូន ត្រូវបានគេបំបែកពីគ្នា[1917]។ អ្នកទោសទាំងអស់ស្ថិតនៅក្រោមការយាមកាមរបស់កងសន្តិសុខប្រដាប់ដោយអាវុធជាប្រចាំ[1918] ដែលទទួលការណែនាំយ៉ាងតឹងរ៉ឹងដើម្បីទប់ស្កាត់មិនឲ្យអ្នកទោសប៉ុនប៉ងរត់គេចខ្លួន[1919]។ ទោះបីជាអតីតសន្តិសុខមួយចំនួនបានអះអាងថាពួកគាត់មិនត្រូវបានគេអនុញ្ញាតឲ្យវាយអ្នកទោសក៏ដោយ[1920] ក៏បទបញ្ជានេះមិនត្រូវបានគោរពឲ្យបានពេញលេញនោះដែរ[1921]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៤៤៣. អ្នកទោសមិនអនុញ្ញាតិឲ្យនិយាយគ្នាទេ[1922] និងមិនឲ្យនិយាយទៅកាន់អ្នកយាម[1923]។ នៅពេលទៅដល់មន្ទីរស-២១ ពួកគាត់ត្រូវបានបង្ខំឲ្យដោះសម្លៀកបំពាក់ចេញ ដោយទុកតែខោអាវក្នុងតែប៉ុណ្ណោះ[1924]។ ពួកគាត់ត្រូវបានគេហាមមិនឲ្យហាត់ប្រាណ ឬចេញក្រៅបន្ទប់ឃុំខ្លួន[1925]។ ពុំមានអ្នកទោសណាម្នាក់មានគ្រែដេកឡើយ[1926] ហើយអ្នកទោសភាគច្រើនត្រូវដេកផ្ទាល់នឹងឥដ្ឋតែម្តង[1927]។ អ្នកទោសវេទនាយ៉ាងខ្លាំងដោយសារមូសខាំ[1928]។ អ្នកទោសមិនត្រូវបានគេអនុញ្ញាតឲ្យងូតទឹកសម្អាតខ្លួន ក្នុងលក្ខខណ្ឌអនាម័យគ្រប់គ្រាន់ឡើយ[1929] ហើយ"ការងូតទឹក"ធ្វើឡើងដោយការបាញ់ទឹកស្រោចក្នុងបន្ទប់ពីមាត់ទ្វារ ដោយប្រើទុយោ[1930]។ ដោយឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំង អ្នកទោសពុំមានជម្រើសណាផ្សេងក្រៅពីបត់ជើងតូច និងបត់ជើងធំ ដាក់ប៊ីដុង និងហិបគ្រាប់ ដែលគេទុកសម្រាប់ឲ្យពួកគាត់ប្រើនោះទេ[1931]។

៤៤៤.ចំណីអាហារមិនគ្រប់គ្រាន់ និងមិនសមរម្យ[1932] ហើយអ្នកទោសមិនត្រូវបានផ្តល់អាហារឲ្យបរិភោគគ្រប់គ្រាន់ទេ[1933]។ មានតែអ្នកយាម និងអ្នកទោសសំខាន់ៗប៉ុណ្ណោះដែលទទួលបានរបបអាហារប្រសើរជាងគេ[1934]។ លក្ខខណ្ឌនេះបណ្តាលឲ្យអ្នកទោសភាគច្រើនបាក់កម្លាំងយ៉ាងខ្លាំង[1935] និងបណ្តាលឲ្យអ្នកខ្លះស្លាប់[1936]។ ឌុច បានរៀបរាប់ថា សេចក្តីសម្រេចទាក់ទងនឹងការកម្រិតរបបអាហារចេញមក *"ពីថ្នាក់លើ"* ហើយថាគាត់គ្មានសិទ្ធិកែប្រែរបបអាហារដែលបានកំណត់ហើយនោះទេ។ បើតាមសម្តី ឌុច ការអនុវត្តនៃការបង្អត់អាហារអ្នកទោសនេះ ឆ្លើយតបទៅនឹងនយោបាយគិតទុកជាមុននៃបក្សកុម្មុយនីស្តកម្ពុជា[1937]។

៤៤៥.អ្នកទោសជាច្រើនធ្លាក់ខ្លួនឈឺ និងមានរបួស។ សេវាពេទ្យមូលដ្ឋាន[1938] ត្រូវបានផ្តល់ជូនដោយក្រុម "ពេទ្យ" តូចមួយ[1939] ដែលមិនបានសិក្សាវិជ្ជាពេទ្យ និងធ្វើការដោយគ្មានការត្រួតពិនិត្យអំពីសំណាក់គ្រូពេទ្យ[1940]។ ភាគច្រើននៃអ្នកទោសដែលត្រូវការជំនួយពេទ្យបន្ទាន់ ត្រូវបានទុកចោលដោយគ្មានការមើលថែទាំ ហើយពួកគាត់មិនបានទទួលការព្យាបាលសមស្របនោះទេ[1941]។ ក្នុងឃ្លាំងថ្នាំ មានថ្នាំតិចបំផុត ហើយបើទោះជាមាន ក៏មានតែថ្នាំដែលផលិតនៅក្នុងស្រុក ដោយមនុស្សអត់ជំនាញដែរ[1942]។ បុគ្គលិកនៃមន្ទីរ ស-២១ ក៏បានធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រលើអ្នកទោសដែរ[1943]។

៤៤៦. អ្នកទោសតិចតួចណាស់ដែលត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងបរិវេណនៃមន្ទីរ ស-២១។ ពួកគាត់ធ្វើការនៅក្នុងរោងជាងដែលជាជាងចម្លាក់ និងជាជាងម៉ាស៊ីនដែលធ្វើការជាច្រើនម៉ោង ក្រោមការឃ្លាំមើលជាប្រចាំរបស់អ្នកយាម និងដោយគ្មានសេរីភាពក្នុងការផ្លាស់ទី និងក្រោមការគំរាមកំហែងដាក់

ទណ្ឌកម្ម បើសិនជាគេមិនពេញចិត្តនឹងការងាររបស់ពួកគាត់[1944]។ ពួកគាត់ទាំងអស់បានប្រាប់ថា របបអាហារ ហើយថាជាទូទៅ លក្ខខណ្ឌឃុំខ្លួនរបស់ពួកគាត់បានប្រសើរឡើង នៅពេលដែលពួកគាត់បានចាប់ផ្តើមធ្វើការ[1945]។

៤៤៧. អ្នកទោសទាំងអស់រស់ក្នុងភាពភ័យខ្លាចគេដាក់ទណ្ឌកម្ម យកចេញ វាយដំ សួរចម្លើយ និងសម្លាប់ជាប្រចាំ[1946]។ លក្ខខណ្ឌរស់នៅដែលបានពណ៌នាខាងលើនេះ បានបណ្តាលឱ្យអ្នកទោសស្លាប់ជាច្រើន[1947]។ អ្នកទោសមួយចំនួនព្យាយាមធ្វើអត្តឃាត ដោយសារលក្ខខណ្ឌរស់នៅនេះ[1948]។

### ការសួរចម្លើយ

៤៤៨.ភាគច្រើននៃអ្នកទោសដែលត្រូវជាប់ឃុំខ្លួននៅមន្ទីរស-២១ ត្រូវបានសួរចម្លើយជាលក្ខណៈប្រព័ន្ធ[1949]។ ការសួរចម្លើយទាំងនេះត្រូវធ្វើឡើងដោយបុគ្គលិកនៃមន្ទីរ ស-២១ ដែលបំពេញតួនាទីផ្លូវការរបស់ខ្លួន[1950]។ នៅពេលដែលអ្នកទោសត្រូវបានបញ្ជូនទៅតាមបន្ទប់ឃុំខ្លួនរួចហើយ[1951] អ្នកសួរចម្លើយទៅយកអ្នកទោសតាមបន្ទប់ឃុំខ្លួន ហើយនាំពួកគេទៅបន្ទប់សួរចម្លើយ ដោយដាក់ខ្នោះដៃ និងចងមុខ[1952]។ អ្នកទោសតម្រូវឱ្យសរសេរប្រវត្តិរូបទៅឱ្យអ្នកសួរចម្លើយ និងពន្យល់អំពី ការចោទប្រកាន់ដែលនាំឱ្យគេចាប់ខ្លួនពួកគាត់[1953]។ ការសួរចម្លើយមិនមែនសុទ្ធតែទទួលបានចម្លើយសារភាពទាំងអស់ជាលាយលក្ខណ៍អក្សរនោះទេ[1954] ហើយក៏ពុំមានគោលការណ៍ទូទៅណាមួយចែងថា តើអ្នកទោសម្នាក់ៗត្រូវរងការសួរចម្លើយប៉ុន្មានលើក ឬថាការសួរចម្លើយមួយលើកៗត្រូវមានរយៈពេលប៉ុន្មាននោះដែរ[1955]។ ការសួរចម្លើយត្រូវបញ្ចប់លុះត្រាតែគេទទួលបានចម្លើយសារភាព"គួរជាទីពេញចិត្ត" [1956] ហើយអ្នកទោសអាចត្រូវបានគេសួរចម្លើយជាច្រំដែលៗ និងត្រូវបានគេបញ្ជាឱ្យសរសេរជាច្រើនដងនូវចម្លើយសារភាពរបស់ខ្លួន[1957]។

៤៤៩. ជាទូទៅ ឌុច ឬបុគ្គលិកនៃមន្ទីរស-២១ មានឯករាជ្យភាពក្នុងការសម្រេចប្រើ ឬមិនប្រើអំពើហិង្សា និងការធ្វើទារុណកម្មអ្នកទោស[1958] លើកលែងតែចំពោះអ្នកទោសសំខាន់ៗ ឬអ្នកទោសដែលថ្នាក់លើចាប់អារម្មណ៍ខ្លាំង។ ក្នុងករណីនេះ ថ្នាក់លើផ្តល់សេចក្តីណែនាំដោយឡែក[1959]។

៤៥០.ឌុច បាននិយាយថា គាត់បានបង្កើតវិធីសាស្ត្រសួរចម្លើយបី ដែលបែងចែករវាងក្រុមអ្នកសួរចម្លើយផ្សេងៗគ្នា៖ វិធីសាស្ត្រ"*ត្រជាក់*" វិធីសាស្ត្រ"*ក្តៅ*" និងវិធីសាស្ត្រ"*អង្កៀម*"[1960]។ វិធីសាស្ត្រត្រជាក់គឺជាការសួរអ្នកទោសដោយប្រើការបញ្ចុះបញ្ចូលឃោសនា ដោយមិនធ្វើទារុណកម្ម ឬ

ជេរស្តី។ ដោយលក្ខណៈជាក់ស្តែង វិធីសាស្ត្រក្តៅរួមមាន *"ការជេរប្រមាថ ការវាយដំ ឬការធ្វើទារុណកម្មផ្សេងៗទៀត ដែលអនុញ្ញាតដោយបទបញ្ជា"*[1961]។ វិធីសាស្ត្រ"អង្កៀម" គឺជាបច្ចេកទេសមធ្យមដែល *"តម្រូវឱ្យពន្យល់លួងលោមដើម្បីបង្កើតភាពទុកចិត្តគ្នា និងតម្រូវឱ្យអង្វរអ្នកដែលគេសួរចម្លើយ ដោយទទូចបង្ខំឱ្យសរសេរចម្លើយសារភាព"*[1962] ដោយហេតុថាការធ្វើទារុណកម្ម ក៏ត្រូវបានអនុញ្ញាតឱ្យធ្វើដែរ[1963]។

៤៥១. ការអនុវត្តទារុណកម្ម ក្នុងពេលសួរចម្លើយមានជាញឹកញាប់ ហើយ ឌុច[1964] និងអ្នកសួរចម្លើយទទួលស្គាល់ការប្រព្រឹត្តនេះ[1965]។ ឯកសារនៃមន្ទីរស-២១[1966]បញ្ជាក់អំពីការប្រព្រឹត្តនេះ។ អតីតអ្នកទោសនៅមន្ទីរស-២១ ពីរនាក់ លោក ជុំ ម៉ី និង លោក ប៊ូ ម៉េង បានពន្យល់ថា ពួកគាត់ត្រូវបានគេវាយធ្វើបាប យ៉ាងធ្ងន់ធ្ងរក្នុងពេលគេសួរចម្លើយគាត់។ ពួកគាត់បានពិពណ៌នាយ៉ាងច្បាស់លាស់អំពីអង្គហេតុនេះ នៅក្នុងដំណាក់កាលស៊ើបសួរ ក៏ដូចជានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1967]។ នេះស្តែងឡើងឱ្យឃើញយ៉ាងពិតប្រាកដថា ការធ្វើទារុណកម្មមានលក្ខណៈកាន់តែឃោរឃៅឡើងនៅពេលដែលអ្នកទោសផ្តល់ចម្លើយសារភាពមិនច្បាស់លាស់ និងរាល់ចម្លើយសារភាពណាដែលមានលក្ខណៈច្បាស់លាស់តែមិនគ្រប់គ្រាន់ ឬដែលមិនឆ្លើយដាក់ឈ្មោះរបស់"ជនក្បត់"ម្នាក់ទៀតត្រូវបានគេចាត់ទុកថាមិនអាចទទួលយកបាន[1968]។

៤៥២. អ្នកសួរចម្លើយប្រើទម្រង់នៃការធ្វើទារុណកម្មផ្សេងៗ ដើម្បីយកចម្លើយសារភាពពីអ្នកទោស។ បើតាមឌុច វិធីសាស្ត្របួនត្រូវបានអនុញ្ញាតឱ្យប្រើ៖ ការវាយ ឆក់ខ្សែភ្លើង ការច្រកក្បាលក្នុងថង់ប្លាស្ទិច និងការបន្តក់ទឹកចូលច្រមុះ[1969]។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ក្រៅពីវិធីសាស្ត្រទាំងបួននេះ វាជាការពិតដែលថាទម្រង់នៃការធ្វើទារុណកម្មផ្សេងៗទៀតត្រូវបានអនុវត្ត ហើយទម្រង់ខ្លះនៃទម្រង់ទាំងនេះត្រូវបានហាមឃាត់ បើយោងតាម ឌុច។ អាស្រ័យហេតុនេះ ក្រចកដៃ និងជើងរបស់អ្នកទោសត្រូវបានគេចាក់ទម្លុះ និងដក[1970] យ៉ាងហោចណាស់ មានអ្នកទោសម្នាក់ដែលទំនងជាត្រូវបានបង្ខំឱ្យស៊ីលាមក និងអ្នកដទៃទៀតត្រូវបានបង្ខំឱ្យផឹកទឹកនោម[1971]។ បច្ចេកទេសនៃការប្រើទឹកត្រជាក់ និងកង្ហា[1972] និងបច្ចេកទេសដែលតម្រូវឱ្យដោះខោអាវអ្នកទោស និងឆក់ខ្សែភ្លើងត្រង់ប្រដាប់ភេទ និងត្រចៀក[1973] ក៏ត្រូវបានប្រើដែរ។ ការអនុវត្តដែលបង្ខំឱ្យអ្នកទោសសំពះរូបឆ្កែមានក្បាល ហូជីមិញ ឬ Lyndon B. Johnson[1974] ត្រូវបានអង្គជំនុំជម្រះសាលាដំបូង ក្នុងសាលក្រមរបស់ ឌុច ចាត់ទុកថាធ្វើឱ្យអាម៉ាស់យ៉ាងខ្លាំង និងបង្កឱ្យមានការឈឺចាប់ផ្លូវចិត្តដ៏ធ្ងន់ធ្ងរក្នុងបរិបទវប្បធម៌ខ្មែរ[1975]។

លើសពីនេះទៅទៀត [លុប] ចាំបានថា ធ្លាប់ឃើញអ្នកយាមនាំអ្នកទោសម្នាក់ទៅកន្លែងមួយមានរាងដូចក្ដោងទ្វាររួចព្យួរជើងឡើងលើ និងជ្រមុជក្បាលក្នុងពាងមានទឹកពេញ[1976]។ ឌុច និងអ្នកសួរចម្លើយក៏ធ្លាប់បានប្រើការបញ្ចុះបញ្ចូលឃោសនា ការមាក់ងាយ ការកុហក និងការគំរាមកំហែង ដើម្បីយកចម្លើយសារភាព[1977]។

៤៥៣. ផលវិបាកផ្នែករាងកាយអំពីទារុណកម្មពេលសួរចម្លើយ ដែលមើលឃើញយ៉ាងច្បាស់ (ស្នាមរបួសការហូរឈាម ស្នាមជាំ អ្នកទោសសន្លប់ និងអ្នកខ្លះបាត់ក្រចកដៃ ក្រចកជើង) នាំឲ្យអតីតបុគ្គលិកមន្ទីរ ស-២១ ដែលត្រូវបានសម្ភាសន៍ស្ទើរតែទាំងអស់សុទ្ធតែទទួលស្គាល់ថា ពួកគេដឹងថាមានការធ្វើទារុណ-កម្មបែបនេះមែន ទោះបីជាពួកគេមិនបានចូលរួមដោយផ្ទាល់ក៏ដោយ[1978]។ ក្នុងករណីមួយចំនួន ការធ្វើបាបធ្ងន់ធ្ងរលើរាងកាយដូចបានរៀបរាប់ខាងលើនេះ បានបណ្ដាលឱ្យអ្នកទោសស្លាប់[1979]។ ឌុច បានទទួលស្គាល់ថាមានករណីដូចនេះកើតឡើងមែន ហើយគាត់បានពោលទៀតថា គាត់បានរៀបចំវគ្គរៀនសូត្រមួយដើម្បីដោះស្រាយស្ថានភាពនេះ[1980]។

៤៥៤.ការប្រើប្រាស់ទារុណកម្មនៅក្នុងពេលសួរចម្លើយ គឺដើម្បីទទួលបាននូវចម្លើយដែលមានលក្ខណៈ "ពេញ លេញ" ដែលរួមមានបទល្មើសដែលអ្នកទោសត្រូវគេចោទ និងឈ្មោះជនដែលគេសន្មតថាជាខ្មាំងរបស់ របបនោះ[1981]។ ទាក់ទិននឹងអ្នកទោសវៀតណាម ឌុច បានបញ្ជាក់ថា គោលបំណងនៃការសួរចម្លើយគឺ ដើម្បីទទួលបានការសារភាពថា *"វៀតណាមបានឈ្លានពានប្រទេសកម្ពុជា ដើម្បីបញ្ចូលកម្ពុជាក្នុង សហព័ន្ធឥណ្ឌូចិន"*[1982]។ ខុសពីអ្នកទោសកម្ពុជា ការសួរចម្លើយអ្នកទោសវៀតណាមត្រូវគេថតយក សម្លេង ហើយចម្លើយសារភាពមួយចំនួនរបស់ពួកគេត្រូវបានផ្សព្វផ្សាយតាមវិទ្យុក្នុងគោលដៅធ្វើការ ឃោសនា[1983]។ ការសួរចម្លើយអ្នកទោសវៀតណាមក៏មានគោលបំណងទទួលបានព័ត៌មានផ្នែកកងទ័ព ផងដែរ[1984]។

៤៥៥. មន្ទីរ ស-២១ មានតួនាទីយ៉ាងសំខាន់ក្នុងការយកចម្លើយសារភាពពីអ្នកទោស ដើម្បីរែកមុខបណ្ដាញក្បត់ផ្សេងទៀត ហើយ ឌុច បានអះអាងថា *"អត្ថន័យនៃចម្លើយសារភាពគឺជាការងារចម្បងរបស់មន្ទីរ ស-២១"*[1985]។ ចម្លើយសារភាពភាគច្រើនមានទម្រង់ជាប្រវត្តិនយោបាយដែលសរសេរដោយអ្នកទោសខ្លួនឯង ហើយដោយទទួលរងនូវការបង្ខិតបង្ខំ ចម្លើយសារភាពនេះក្លាយទៅជាការបរិហារអំពីខ្លួនឯង និងការចោទប្រកាន់អ្នកដទៃថាក្បត់ ព្រោះបានបម្រើឲ្យចារកម្មបរទេស ដែលជាសត្រូវរបស់បដិវត្តន៍ កម្ពុជា[1986]។ "ការពិត" ដែលបាននិយាយនៅក្នុងចម្លើយសារភាព គឺត្រូវបានកំណត់ទុកជាមុនរួចទៅហើយ ព្រោះថាអ្នកសួរចម្លើយបានបង្ខំ

ឲ្យអ្នកជាប់ឃុំផ្តល់នូវចម្លើយដែលបានកំណត់ទុកជាមុន ដោយទទួលបានការណែនាំពី ឌុច ឲ្យថាមានទំនាក់ទំនងជាមួយពួកសេអ៊ីអា(CIA) កាហ្សេបេ(KG) និង/ឬពួកវៀតណាម[1987]។

៤៥៦. ចម្លើយសារភាពជាលាយលក្ខណ៍អក្សរ ដែលទទួលបានដោយអ្នកសួរចម្លើយត្រូវបានបញ្ជូនទៅឲ្យ ឌុច ដោយមានរបាយការណ៍សួរចម្លើយភ្ជាប់ទៅជាមួយ[1988]។ ឌុច បានអាន បានវិភាគ ធ្វើចំណារ[1989] និងបានសង្ខេបយ៉ាងល្អិតល្អន់[1990] លើចម្លើយសារភាពភាគច្រើន ដើម្បីរាយការណ៍ជូនថ្នាក់លើ[1991]។

## ការរំលោភសេពសន្ថវៈនៅមន្ទីរ ស-២១

៤៥៧. នៅក្នុងសាលក្រមនៃសំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មានករណីរំលោភផ្លូវភេទមួយដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១[1992]។ បុគ្គលិក មន្ទីរ ស-២១ ម្នាក់ បានយកឈើរុកចូលទៅក្នុងប្រដាប់ភេទរបស់អ្នកទោសស្រីម្នាក់ នៅក្នុងអំឡុងពេល សួរចម្លើយ[1993]។ បើតាមសម្តីរបស់ ឌុច ក្រោយពេលករណីនេះត្រូវបានរាយការណ៍ឲ្យឌុច ឌុចបាន ពិគ្រោះយោបល់ពីរឿងនេះជាមួយ [លុប]។ គាត់បានអះអាងថា គាត់បានឲ្យ [លុប]ស្តីបន្ទោសអ្នកដែលប្រព្រឹត្តអំពើនោះ។ ឌុច បាននិយាយថា គាត់បានរាយការណ៍អំពីហេតុការណ៍នោះទៅថ្នាក់លើ ប៉ុន្តែមិនទទួលបានការឆ្លើយតបទេ។ ហេតុដូច្នេះ ឌុច មិនបានដាក់ទណ្ឌកម្មអ្នកដែលបានប្រព្រឹត្តនោះទេ ដោយគ្រាន់តែប្តូរឲ្យទៅសួរចម្លើយអ្នកផ្សេងប៉ុណ្ណោះ។ ឌុច ក៏បានស្នើផងដែរថា ប្រពន្ធរបស់កម្មាភិបាលត្រូវបានតែងតាំងជាអ្នកសួរចម្លើយអ្នកទោសស្រី ហើយសំណើនេះត្រូវបានយល់ព្រម[1994]។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ ខន បាននិយាយថា នារីជាអ្នកសួរចម្លើយទាំងនេះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ហើយយ៉ាងយូរចាប់ពីឆ្នាំ១៩៧៧មក អ្នកទោសស្ត្រីទាំងអស់ ត្រូវសួរចម្លើយដោយបុរសវិញដដែល[1995]។

៤៥៨. ម្យ៉ាងវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [លុប] បានអះអាងនៅពេលស្តាប់ចម្លើយថា គាត់ត្រូវ បានគេចាប់រំលោភ នៅពេលជាប់ឃុំនៅមន្ទីរ ស-២១ នៅឆ្នាំ១៩៧៧ ដោយសន្តិសុខម្នាក់ដែលគាត់បាន ស្គាល់នៅពេលជំនុំជម្រះក្តីឌុច នៅចំពោះមុខអ.វ.ត.ក។ ការរំលោភផ្លូវភេទត្រូវបានប្រព្រឹត្តនៅក្នុងបន្ទប់ ឃុំឃាំងមួយតែឯង នៅពេលដែលគាត់ជាប់ច្រវាក់ ហើយធ្វើឲ្យគាត់ធ្លាក់ឈាមជាច្រើនថ្ងៃជាប់គ្នា។ សន្តិសុខនោះក៏បានគំរាមថា មិនឲ្យប្រាប់អ្នកណាទេ ប្រយ័ត្នគេសម្លាប់ចោល[1996]។ នៅក្នុងក្របខ័ណ្ឌនៃសាលក្រមរបស់ ឌុច អង្គជំនុំជម្រះសាលាដំបូងបាន

00605406



បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកស្រី [លុប] ដោយយល់ឃើញថា ភស្តុតាងដែលគាត់បានផ្តល់ជូនមិនអាចឱ្យសន្និដ្ឋានថា គាត់ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ទេ[1997]។ បន្ទាប់ពីមាន សេចក្តីសម្រេចបដិសេធបែបនេះ រឿងហេតុដែលបានរៀបរាប់ខាងលើ ដែលខុសពីរឿងហេតុដែលបាន លើកឡើងនៅក្នុងសវនាការ បានលេចឡើង ហើយបានធ្វើឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការ ស្តាប់ចម្លើយសាជាថ្មី នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស។ បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរសាជាថ្មីនេះ សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា សេចក្តីបំភ្លឺដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអាចជឿទុកចិត្តបាន និងមានភាពគ្រប់គ្រាន់ តាមបទដ្ឋានតម្រូវនៅដំណាក់កាលនេះនៃនីតិវិធី។

៤៥៩. ភស្តុតាងមួយចំនួនបង្ហាញថា មានករណីរំលោភផ្លូវភេទផ្សេងទៀត ត្រូវបានប្រព្រឹត្តនៅមន្ទីរ ស-២១ ជាពិសេស ការរំលោភដោយអ្នកសួរចម្លើយម្នាក់ឈ្មោះ [លុប] ទៅលើអ្នកជាប់ឃុំស្រីម្នាក់[1998]។ នៅក្នុងសាលក្រមនៃសំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា *"អង្គហេតុនេះមិនមានភស្តុតាងបញ្ជាក់ទៅតាមបទដ្ឋានតម្រូវ ឡើយ"*[1999] ។

### ការសម្លាប់អ្នកទោស

៤៦០. អ្នកជាប់ឃុំជាង ១២.២៧៣ នាក់ ដែលសមាសភាពត្រូវបានរៀបរាប់ពីខាងលើ ត្រូវបានសម្លាប់ចោល នៅជើងឯក ខាងក្នុង ឬជិតបរិវេណមន្ទីរ ស-២១ ឬស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរ ស-២១[2000]។

៤៦១. នៅក្នុងសាលក្រមនៃសំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា *"ផ្អែកតាមគោលនយោបាយក្នុងការ "កម្ទេច" ខ្មាំងនៃបក្សកុម្មុយនីស្តកម្ពុជា អ្នកជាប់ឃុំទាំងឡាយដែលបានជាប់ឃុំនៅមន្ទីរស-២១ (ទួលស្លែង) ត្រូវតែសម្លាប់ទាំងអស់ គ្មានអ្នក ជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ"*[2001]។ ឌុច បានអះអាងថាការសម្លាប់អ្នកទោសណាម្នាក់អាចធ្វើឡើងតាមការណែនាំពីថ្នាក់លើ ជាពិសេសចំពោះការសម្លាប់ជាទ្រង់ទ្រាយធំ[2002] ឬផ្អែកតាមការសម្រេចចិត្តដោយឯកឯងរបស់គាត់ ដោយអនុវត្តតាមមាគ៌ានយោបាយជាទូទៅរបស់បក្ស ដែលមានគោលដៅសម្លាប់អ្នកទោសចោលទាំងអស់[2003]។

៤៦២. សាក្សីជាច្រើនបានអះអាងថា នៅមន្ទីរ ស-២១ ការសម្រេចលើការសម្លាប់អ្នកទោសត្រូវ

បានធ្វើឡើង ដោយ ឌុច ឬបញ្ជូនបន្តដោយ ឌុច[2004]។ ឌុច បាននិយាយថា ពីដំបូងគាត់បានផ្ទេរការទទួលខុសត្រូវលើការសម្លាប់ឱ្យទៅ [លុប][2005] ប៉ុន្តែបន្ទាប់ពីមានហេតុការណ៍មួយ ដែលមានអ្នកទោសម្នាក់ស្លាប់ មុនបញ្ចប់ការសួរចម្លើយ **សុន សេន** បានតម្រូវឱ្យ ឌុច សម្រេចលើរាល់ការសម្លាប់[2006]។ ជាទូទៅ អ្នកទោសត្រូវបានសម្លាប់ នៅពេល ឌុច សន្និដ្ឋានថាពួកគេបានឆ្លើយសារភាពចប់សព្វគ្រប់[2007]។ ប៉ុន្តែ ឌុច ទទួលស្គាល់ថា គាត់មានអំណាចក្នុងការពន្យារពេលការសម្លាប់អ្នកទោសមួយចំនួនដែលមានជំនាញ[2008]។

<u>ការសម្លាប់នៅជើងឯក</u>

**៤៦៣.** អ្នកទោសត្រូវបានដឹកតាមឡានទៅជើងឯក[2009] ដោយអង្គភាពពិសេស[2010] ជាក្រុមពី៣០ ទៅ៤០នាក់។ ពួកគេត្រូវបានគេដាក់ខ្នោះដៃ ចងមុខ និងបណ្តើរឆ្ពោះទៅរកឡាន[2011] ហើយក្នុងពេលកំពុងធ្វើដំណើរ មានការត្រួតពិនិត្យយ៉ាងតឹងតែងពីកងសន្តិសុខ[2012]។ គេលាក់គោលដៅពិតប្រាកដមិនឱ្យអ្នកទោសដឹង ហើយគេប្រាប់អ្នកទោសទាំងនោះថា ផ្ទេរទៅកាន់មន្ទីរមួយផ្សេងទៀត[2013]។

**៤៦៤.** មានសន្តិសុខមួយចំនួនតូចប្រចាំនៅជើងឯក។ ពួកគេមានភារកិច្ចរក្សាការសម្ងាត់របស់ជើងឯក ជីករណ្តៅ និងកប់សាកសពអ្នកជាប់ឃុំ[2014]។ កងសន្តិសុខទាំងនេះត្រូវបានចូលរួមដោយកងសន្តិសុខដែលនាំអ្នកទោសទៅកន្លែងនោះ[2015]។ នៅពេលដែលរថយន្តមកដល់ជើងឯក[2016] អ្នកទោសត្រូវបានគេបណ្តើរឱ្យចូលទៅក្នុងផ្ទះមួយ[2017]។ បន្ទាប់មកទៀត កងសន្តិសុខបាននាំអ្នកទោសចេញក្រៅម្តងមួយៗ ដោយនិយាយទៅកាន់ពួកគេថានាំទៅផ្ទះផ្សេងមួយទៀត។ **ហ៊ឹម ហ៊ុយ** កត់ត្រាឈ្មោះអ្នកទោសទៅក្នុងបញ្ជី មុនពេលដែលពួកគេត្រូវបានបណ្តើរឆ្ពោះទៅរណ្តៅដើម្បីសម្លាប់[2018]។

**៤៦៥.** សាក្សីជាច្រើនបាននិយាយថា អ្នកទោសត្រូវគេសម្លាប់ដោយប្រើ ដំបងដែក ដែកឆ្កៀលរទេះ និងបំពង់ទីប ដោយវាយត្រង់កញ្ចឹងក[2019]។ កងសន្តិសុខវះពោះ ឬអារក[2020] ហើយបន្ទាប់មកទៀតអ្នកទោសត្រូវបានធាក់ទម្លាក់ទៅក្នុងរណ្តៅ បន្ទាប់ពីដោះខ្នោះដៃ និងក្រណាត់ចងមុខចេញ[2021]។ ក្រោយពីការសម្លាប់បានបញ្ចប់ កងសន្តិសុខបានកាយដីដើម្បីកប់រណ្តៅ[2022]។

**៤៦៦.** ទោះបីជាមានសាក្សីមួយចំនួនបានបដិសេធថា មិនធ្លាប់បានឃើញមានកុមារនៅជើងឯកក៏ដោយ[2023] ប៉ុន្តែ យ៉ាងហោចណាស់ ក៏គេឃើញមានរណ្តៅកប់សាកសពមួយដែលមានឆ្អឹងរបស់កុមារនៅសេសសល់ដែរ[2024]។ ក្នុងអំឡុងពេលនៃការសម្តែងឡើងវិញដែលបានធ្វើឡើងនៅជើងឯក ឌុច បាននិយាយថា គាត់មិនបានដឹងអំពីវិធីដែលសម្លាប់កុមារនៅទីនោះទេ ប៉ុន្តែគាត់មិនបានបដិសេធអំពីការដែលកុមារត្រូវបានសម្លាប់នៅកន្លែងនោះឡើយ[2025]។

៤៦៧. សុន សេន និង នួន ជា បានបញ្ជាឲ្យសម្លាប់អ្នកទោសក្នុងទ្រង់ទ្រាយធំជាច្រើនដង។ ការសម្លាប់ដ៏ច្រើនបែបនេះ ត្រូវបានធ្វើឡើងនៅជើងឯក អស់រយៈពេលជាច្រើនថ្ងៃជាប់ៗគ្នា។ ជាញឹកញាប់បំផុត អ្នកទោសទាំងអស់នេះត្រូវបានសម្លាប់ចោលភ្លាមៗ បន្ទាប់ពីមកដល់មន្ទីរស-២១ ដោយគ្មានការសួរចម្លើយជាមុននោះឡើយ[2026]។ ការសម្លាប់ដ៏ច្រើនបែបនេះខ្លះកើតចេញពីការបោសសម្អាត នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា។ បើតាម ឌុច នៅដើមឆ្នាំ១៩៧៧ កម្មាភិបាលមួយចំនួនធំមកពីអតីតភូមិភាគឧត្តរ ក្រុងភ្នំពេញ និងកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានសម្លាប់ចោលបន្ទាប់ពីមានការចាប់ខ្លួន កុយ ធួន[2027]។ នៅដើមឆ្នាំ១៩៧៨ មានការសម្លាប់កម្មាភិបាលភូមិភាគបស្ចិម បន្ទាប់មក សម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ[2028]។ ក្រោយមកទៀត នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ អ្នកទោសប្រហែល៣០០ នាក់មកពីភូមិភាគបូព៌ា ដែលត្រូវគេចោទថាបានបះបោរប្រឆាំង ត្រូវបានគេបញ្ជូនទៅជើងឯក ហើយត្រូវបានសម្លាប់តែម្តង[2029]។ ឌុច ក៏បានបន្ថែមថា នៅថ្ងៃទី០២ ឬទី០៣ ខែមករា ឆ្នាំ១៩៧៩ នួន ជា បានបញ្ជាគាត់ឲ្យកម្ទេចអ្នកទោសទាំងអស់នៅមន្ទីរស-២១[2030]។ មនុស្សប្រហែល២០០នាក់ (ជនជាតិខ្មែរ និងវៀតណាម) ត្រូវបានបញ្ជូនទៅជើងឯក បន្ទាប់មកសម្លាប់ចោល[2031]។

**ការសម្លាប់នៅខាងក្នុង ឬជិតបរិវេណមន្ទីរ ស-២១**

៤៦៨. ឌុច និងសាក្សីផ្សេងៗទៀតបានប្រាប់ឲ្យដឹងថា ទោះបីជាជើងឯកបានក្លាយជាទីកន្លែងសម្លាប់ដ៏សំខាន់ក៏ដោយ ក៏ការសម្លាប់អ្នកជាប់ឃុំមួយចំនួនជាពិសេស កុមារ អតីតបុគ្គលិកមន្ទីរ ស-២១ អ្នកទោស សំខាន់ៗ និងជនបរទេស នៅតែបន្តក្នុងបរិវេណខាងក្នុងទួលស្លែង ឬនៅជិតនោះដដែល[2032]។

៤៦៩. ជួនកាល ឌុច បានប្រាប់ឲ្យថតរូបសាកសពអ្នកទោសសំខាន់ៗ បន្ទាប់ពីការសម្លាប់។ រូបថតទាំងនេះដែលត្រូវបានបញ្ជាឲ្យថតដោយ សុន សេន ឬ នួន ជា ត្រូវបានយកធ្វើជាភស្តុតាង ដើម្បីបញ្ជាក់ថាអ្នក ទោសទាំងនេះពិតជាត្រូវបានសម្លាប់ចោលប្រាកដមែន[2033]។

៤៧០. អ្នកទោសជាជនបរទេសមួយចំនួនដែលជាប់ឃុំនៅមន្ទីរ ស-២១ ត្រូវបានសម្លាប់នៅជិតបរិវេណមន្ទីរ ស-២១។ ជាក់ស្តែង នៅក្នុងឆ្នាំ១៩៧៨ ជនបរទេសបួននាក់ត្រូវបានគេដុតទាំងរស់ជាមួយនឹងសំបកកង់ ឡាន នៅចន្លោះមហាវិថីម៉ៅសេទុង និងសង្កាត់បឹងទំពុន តាមបញ្ជាជាក់លាក់របស់ នួន ជា ធ្វើយ៉ាង ណាដើម្បីកុំឲ្យគេរកឃើញសាកសពជនទាំងនោះ[2034]។

៤៧១. កុមារមួយចំនួនដែលនាំទៅមន្ទីរ ស-២១ ត្រូវបានសម្លាប់នៅក្នុងបរិវេណនៃមន្ទីរនោះ។ ជាធម្មតា កុមារតូចៗដែលមានអាយុតិចត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ ប៉ុន្តែកុមារខ្លះត្រូវបានគេឃុំខ្លួនមួយរយៈខ្លី មុនពេលយកទៅសម្លាប់។ **ឌុច** បានបញ្ជាក់ថា បុគ្គលិកមន្ទីរ ស-២១ ឈ្មោះ **ប៉េង** ជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់កុមារទាំងនោះ[2035]។

៤៧២. យុទ្ធជនបួននាក់ ដែលមកពីកងយោធាមួយដែល **ឌុច** ចាំបានថាមានឈ្មោះ យ-៨ ក៏ត្រូវបានសម្លាប់ ក្រោយពីការសម្លាប់ជាទ្រង់ទ្រាយធំចុងក្រោយ ដែលធ្វើឡើងកាលពីថ្ងៃទី០២ ឬទី០៣ ខែមករា ឆ្នាំ ១៩៧៩។ **ឌុច** បានបញ្ជាក់ថា យុទ្ធជនទាំងនេះត្រូវបានសម្លាប់ដោយអ្នកសួរចម្លើយម្នាក់ឈ្មោះ [លុប] ដោយប្រើចំពុះទង់កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ សាកសពរបស់ពួកគេនេះហើយ ដែលជាប់ខ្នោះនៅសល់លើគ្រែ ដែលពួកកងទ័ពវៀតណាមបានប្រទះឃើញ នៅពេលមកដល់មន្ទីរ ស-២១[2036]។

<u>ការបូមយកឈាម</u>

៤៧៣. អ្នកទោសមួយចំនួនដែលជាប់ឃុំនៅមន្ទីរ ស-២១ បានស្លាប់ បន្ទាប់ពីគ្រូពេទ្យបានបូមយកឈាមក្នុងចំនួនដ៏ច្រើន[2037] ហើយ **ឌុច** ទទួលស្គាល់ថា មានមនុស្សមិនតិចជាង១០០នាក់ទេ ដែលត្រូវបានសម្លាប់ដោយវិធីនេះ[2038]។ ប្រាក់ **ខន** បានផ្តល់សក្ខីកម្មថា អ្នកជាប់ឃុំត្រូវបានគេដាក់ឱ្យដេកលើគ្រែ ហើយ បន្ទាប់មកគេដោះខ្នោះដៃចេញ ដាក់ខ្នោះជើង និងចងមុខ។ ពេលនោះ គេចាក់ម្ជុលចូលក្នុងសរសៃឈាម ហើយបូមយកឈាមរហូតទាល់តែស្លាប់[2039] ហើយ ឡានដឹកសាកសពទាំងនោះទៅកាន់ជើងឯក[2040]។ បន្ទាប់មកឈាមដែលគេបូមបានពីអ្នកទោស ត្រូវបានបញ្ជូនទៅតាមបណ្តាមន្ទីរពេទ្យនានា ជាពិសេស ដើម្បីចាក់បញ្ចូលឱ្យកងទ័ពនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបានរងរបួសនៅក្នុងអំឡុងពេលដែលមានជម្លោះជាមួយវៀតណាម[2041]។

៤៧៤. ដំបូង **ឌុច** បានបដិសេធថាគាត់មិនបានដើរតួនាទីណាមួយក្នុងសកម្មភាពនៃការបូមឈាមពីអ្នកទោស នោះទេ។ គាត់បាននិយាយថា ប្រសិនបើពិតជាមានការបូមឈាមនៅមន្ទីរ ស-២១ មែន គឺ *"មានតំណ តាំងតែពីពេលដែល ណាត នៅជាប្រធានមកម្ល៉េះ"*[2042]។ ក្នុងអំឡុងពេលនៃការសួរយកចម្លើយក្រោយៗ មកទៀត **ឌុច** នៅតែមិនបដិសេធថាអ្នកទោសនៅមន្ទីរស-២១ មិនត្រូវបានបូមឈាមឡើយ ប៉ុន្តែនៅ តែរក្សាជំហរថាមិនធ្លាប់បានដឹងអំពីទង្វើនេះទេ[2043]។ នៅទីបញ្ចប់ នៅចំពោះមុខអង្គជំនុំជម្រះសាលា ដំបូង **ឌុច** បានបញ្ជាក់ថាការអនុវត្តន៍បែបនេះត្រូវបានផ្តួចផ្តើមឡើងក្រោមបញ្ជារបស់ **សុន សេន** ហើយបានបញ្ចប់នៅពេលដែលបុគ្គលិកនៅអង្គភាពពេទ្យទាំងអស់ត្រូវបានសម្លាប់[2044]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605410



***

៤៧៥. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១២៨ នាក់ (មួយរយម្ភៃប្រាំបីនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរស-២១[2045]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤)។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ។

## មន្ទីរសន្តិសុខសង់[2046]

### ទីតាំង និងការបង្កើត

៤៧៦. សង់ គឺជាមន្ទីរសន្តិសុខកម្រិតស្រុក ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល[2047]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខសង់ មានទីតាំងស្ថិតនៅក្នុងស្រុក១៥៤ (លេខសំគាល់ស្រុកកណ្ដាលស្ទឹង) តំបន់២៥ នៃភូមិភាគនិរតី។ សង់ប្រហែលជាបានចាប់ផ្ដើមដំណើរការជាមន្ទីរសន្តិសុខអំឡុងឆ្នាំ១៩៧៦ ឬ១៩៧៧[2048] ហើយបានដំណើរការរហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[2049]។ មន្ទីរសន្តិសុខនេះដែលដើមឡើយជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវបានរុំព័ទ្ធទៅដោយរបងលួសបន្លានិងមានអគារបេតុងជាច្រើនរួមមានអគារឃុំឃាំងមួយចំនួន រោងជំដែកមួយ ផ្ទះបាយមួយ និងផ្ទះដោយឡែកមួយសម្រាប់ប្រធានមន្ទីរឃុំឃាំងស្នាក់នៅនិងធ្វើការ[2050]។ មានបន្ទប់ឃុំឃាំងពិសេសមួយចំនួនផងដែរ ដែលទុកសម្រាប់ឃុំខ្លួនកម្មាភិបាលខ្មែរក្រហមណា ដែលបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ[2051]។

### ដំណើរការប្រព្រឹត្តទៅ

<u>រចនាសម្ព័ន្ធ និងបុគ្គលិក</u>

៤៧៧. ដោយសារជាមន្ទីរសន្តិសុខកម្រិតស្រុក មន្ទីរសន្តិសុខសង់ត្រូវបានគ្រប់គ្រងដោយគណៈស្រុក១៥៤[2052]។ គណៈកម្មាធិការស្រុកបានជួបប្រជុំគ្នាជាទៀងទាត់ជាមួយប្រធានមន្ទីរសន្តិសុខនេះ

នៅឯទីស្នាក់ការគណៈស្រុក ស្ថិតនៅសៀមរាប-កន្ទួត ហើយលេខាមួយរូបក្នុងចំណោមលេខាស្រុកក្រោយៗ ឈ្មោះ យ៉ាន់ (ស្លាប់) បានទៅពិនិត្យមើលមន្ទីរសន្តិសុខនេះដោយផ្ទាល់រៀងរាល់២ ឬ៣ខែម្តង[2053]។ លេខាភូមិភាគនិរតី តាម៉ុក (ស្លាប់) ក៏បានទៅមើលមន្ទីរសន្តិសុខ សង់ ជាច្រើនដងផងដែរ[2054]។

**៤៧៨.** មានកម្មាភិបាលចំនួនប្រហែល ២០ រូបបានធ្វើការជាប្រចាំនៅមន្ទីរសន្តិសុខសង់នោះ[2055]។ ក្នុងអំឡុងពេលដំណើរការ មន្ទីរសន្តិសុខសង់មានប្រធានជាច្រើន[2056]។ ក្រោយពីប្រធានទី១ ឈ្មោះ ម៉ុង ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ មានកម្មាភិបាលដទៃទៀតបានមកគ្រប់គ្រងមន្ទីរសន្តិសុខសង់នេះ[2057]។ ប្រធានចុងក្រោយគឺ [លុប]ដែលគ្រប់គ្រងបានប្រហែលប៉ុន្មានខែមុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរំលំនៅខែមករា ឆ្នាំ១៩៧៩[2058]។ អតីតកម្មាភិបាលមន្ទីរសន្តិសុខសង់ចំនួនពីររូបបាននិយាយថា ស្ថានភាពក្នុងមន្ទីរឃុំឃាំងនេះ បានប្រសើរឡើងក្រោយពេលដែល [លុប]បានចូលមកគ្រប់គ្រង។ សាក្សីម្នាក់បានបន្ថែមថា ក្នុងរយៈពេល [លុប] គ្រប់គ្រងនោះមិនមានការបញ្ជូនអ្នកទោសថ្មីមកទៀតទេ ហើយការដាក់ខ្នោះ និងការសម្លាប់អ្នកទោសក៏មិនមានទៀតដែរ[2059]។

<u>**ការចាប់ខ្លួន និងការឃុំខ្លួន**</u>

**៤៧៩.** មានសាក្សីចំនួន០៧នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន០២ នាក់ដែលធ្លាប់ជាប់ឃុំនៅឯមន្ទីរសន្តិសុខសង់ ត្រូវបានស្តាប់ចម្លើយ[2060]។ អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខនេះមានទាំងបុរស ស្ត្រី និងកុមារ [2061]។ នៅគ្រប់ពេលទាំងអស់ ចំនួនអ្នកទោសមានប្រមាណពី១០០ ទៅ៣០០ នាក់ [2062] ដោយមានអ្នកទោសថ្មីត្រូវបានគេបញ្ជូនមកជាហូរហែរ ហើយក៏មានអ្នកទោសចាស់ត្រូវបានបញ្ជូនចេញផងដែរ[2063]។ នៅក្រោមការគ្រប់គ្រងរបស់ ម៉ុង ទំនងជាមិនមានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឲ្យត្រឡប់ទៅផ្ទះវិញឡើយ[2064]។ អ្នកទោសដែលត្រូវបានចាប់ខ្លួនភាគច្រើនមកពីស្រុកកណ្តាលស្ទឹង[2065] ។ ជារឿយៗ អ្នកទោសត្រូវបានគេនាំយកមកឃុំទាំងគ្រួសារ[2066]។ អ្នកជាប់ទោសទាំងនោះចម្រុះដោយ ប្រជាជនមូលដ្ឋាន កម្មាភិបាលខ្មែរក្រហម ប្រជាជនថ្មី រួមទាំងទាហាន លន់ នល់ ផង[2067]។ អតីតសន្តិសុខម្នាក់ដែលបានចូលរួមនៅក្នុងការសួរចម្លើយអ្នកទោសបានលើកឡើងថា ភាគច្រើននៃអ្នកទោសគឺជាទាហាន លន់ នល់។ គាត់បានបន្តទៀតថា បើអ្នកណាម្នាក់ត្រូវបានចោទថាជាទាហាន លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានចាប់ខ្លួននិងបញ្ជូនមកទាំងគ្រួសារ ដោយរួមទាំងកូនរបស់ពួកគេផងដែរ[2068]។ ប្រជាជនត្រូវបានចាប់ខ្លួនដោយចោទថា

00605412



ជាខ្មាំងដែលសំដៅដល់អ្នកដែលមានការពាក់ព័ន្ធនឹងរបប លន់ នល់ ទាំងតាមការជាក់ស្តែង ឬតាមការស្មាន ជាខ្មែរស ជាពួកសក្តិភូមិ ជាពួកមូលធន ជាសេអ៊ីអា ឬជាកាហ្សេបេ ឬជាអ្នកដែលមិនគោរពវិន័យ ធ្វើឱ្យបាក់នង្គ័ល ឬលួចអាហាររហូបជា ដើម[2069]។ ជួនកាល ប្រជាជនខ្លះត្រូវបានចាប់ខ្លួន ដោយសារតែអ្នកដទៃបានឆ្លើយដាក់នៅក្នុងពេលសួរចម្លើយ[2070]។

៤៨០. មេក្រុម មេភូមិ និងគណៈឃុំ ជាអ្នកដែលបាននាំអ្នកទោសមកមន្ទីរសន្តិសុខសង់[2071]។ ជារឿយៗ គេមិនប្រាប់ការពិតដល់អ្នកទោសអំពីកន្លែងដែលពួកគេត្រូវបញ្ជូនទៅឡើយ[2072]។ អ្នកទាំងនោះត្រូវនាំមកតាមឡាន កង់ រទេះគោ ឬត្រូវបណ្តើរមក។ នៅពេលទៅដល់មន្ទីរសន្តិសុខសង់ ពួកសន្តិសុខបានភ្ជង់នឹងកាំភ្លើងនិងបញ្ជាឱ្យអង្គុយចុះ បន្ទាប់មកបានចងដៃអ្នកទាំងនោះ។ បន្ទាប់មកទៀត ពួកគេត្រូវបាននាំយកទៅកាន់បន្ទប់ឃុំឃាំង[2073]។ ទំនងជាមានការបែងចែកជាប្រភេទអ្នកទោសស្រាល និងអ្នកទោសធ្ងន់ ដែលផ្អែកតាមការបែងចែកនេះ គេកំណត់អំពីលក្ខខណ្ឌនៃការឃុំខ្លួនរបស់គេ រួមទាំងការកំណត់ និងបែងចែងកន្លែងដែលប្រភេទពួកអ្នកទោសត្រូវធ្វើការផងដែរ[2074]។ អតីតសន្តិសុខម្នាក់ (ក្រោយមកបានក្លាយជាអ្នកទោសកម្រិតស្រាល)បាននិយាយថា អ្នកទោសធ្ងន់គេដាក់ខ្នោះជើងហើយចុងក្រោយត្រូវបានសម្លាប់ រីឯអ្នកទោសស្រាល អាចចេញទៅធ្វើការងារនៅខាងក្រៅបាន[2075]។ អ្នកដែលបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរត្រូវដាក់ឱ្យដេកជាជួរដែលមានគ្នា២០ នាក់ ដោយជើងម្ខាងជាប់សោរទៅនឹងរបាដែកវែង[2076]។ អ្នកទោសទាំងនោះបត់ជើងតូច បន្ទោរបង់ និងដេកនៅហ្នឹងកន្លែងតែ មួយ[2077]។ ក៏ប៉ុន្តែ មិនមែនគ្រប់អ្នកទោសត្រូវបានដាក់ខ្នោះឡើយ ជាពិសេសអ្នកទោសស្ត្រី[2078]។ អ្នកទោសស្ត្រី និងបុរសត្រូវបានឃុំខ្លួនដោយឡែកពីគ្នានៅក្នុងអគារផ្សេងគ្នា[2079]។ ពួកអ្នកទោសត្រូវដេកដោយគ្មានសម្លៀកបំពាក់ ដោយសារប្រធានគុកខ្លាចពួកគេយកសម្លៀកបំពាក់ខ្លួនឯងទៅច្រៀកវិញជាខ្សែចងកសម្លាប់ខ្លួន[2080]។ អតីតអ្នកទោសម្នាក់បាននិយាយថា សន្តិសុខម្នាក់បានមកបន្ទប់ដែលគាត់ជាប់ឃុំ រួចយកញញួរវាយលើជង្គង់របស់គាត់ដោយគ្មានសួរនាំរកហេតុផល[2081]។ អ្នកជាប់ឃុំនៅមន្ទីរសង់មិនមានអាហារគ្រប់គ្រាន់ទេ ដូច្នេះហើយមនុស្សជាច្រើនបានស្លាប់ដោយអត់អាហារ[2082]។ ជាងនេះទៅទៀត អ្នកទោសបានស្លាប់ដោយសារជំងឺ និងរបួសដែលកើតពីការវាយដំផងដែរ[2083]។

៤៨១. អ្នកទោសរួមទាំងកុមារផង ត្រូវបានបង្ខំឱ្យធ្វើការ[2084]។ កងសន្តិសុខ និងអ្នកទោសបាននិយាយថា នៅពេលអ្នកទោសធ្ងន់ត្រូវនាំទៅធ្វើការនៅខាងក្រៅមន្ទីរសង់ ពួកគេត្រូវបានដាក់ច្រវ៉ាក់ជើងជាគូៗ[2085]។ អតីតអ្នកទោសម្នាក់បាននិយាយថា នៅពេលស្ទូងស្រូវជាមួយនឹងច្រវ៉ាក់ដែលជាប់នឹង

ចង្កេះនោះ គាត់ត្រូវខំយួរច្រវ៉ាក់នោះបណ្តើរ ធ្វើការបណ្តើរ[2086]។ អ្នកទោសស្រាល បានធ្វើការងារដោយគ្មានការដាក់ខ្នោះច្រវ៉ាក់[2087]។ ការងារមានដូចជា ដាំបន្លែ ស្ទូងស្រូវ ដងទឹក គាស់គល់ឈើ និងឃ្វាលគោក្របី[2088]។ អតីតសន្តិសុខម្នាក់បាននិយាយថា គាត់បានឃើញអ្នកទោសត្រូវគេវាយនឹងរំពាត់ ឬនឹងដំបង នៅពេលពួកគេត្រូវបណ្តើរទៅធ្វើការ[2089]។ អតីតអ្នកទោសជាច្រើនបានអះអាងថា កងសន្តិសុខបានវាយអ្នកទោសរហូតដល់ស្លាប់ដោយសារតែប្រព្រឹត្តកំហុសតូចតាច[2090]។ អ្នកទោសឈឺដែលអាចនៅធ្វើការ បាន បានទទួលការព្យាបាលដោយប្រើថ្នាំ ចំណែកឯអ្នកទោសឈឺដែលមិនអាចធ្វើការបាន ត្រូវបានគេបោះបង់ចោល ហើយជួនកាលបានស្លាប់ដោយសារជម្ងឺ[2091]។

៤៨២. អតីតកម្មាភិបាលពីរនាក់បាននិយាយថា ប្រហែលជានៅឆ្នាំ ១៩៧៨ អនុប្រធានមន្ទីរសន្តិសុខសង់ឈ្មោះ **ម៉េង** ត្រូវបានគេឃុំខ្លួនដោយសារតែគាត់"ខុសសីលធម៌"ជាមួយនឹងអ្នកទោសស្ត្រី[2092]។ អតីតអ្នកទោសចំនួនពីរនាក់ បានឮអ្នកទោសនៅជាមួយនិយាយថា អ្នកទោសស្ត្រីម្នាក់ត្រូវបានអ្នកសួរចម្លើយរំលោភ ដែលពេលក្រោយមកពួកអ្នកសួរចម្លើយទាំងនោះក៏ត្រូវបានគេឃុំខ្លួនដែរ[2093]។ ក្មួយប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឃើញការរំលោភសេពសន្ថរៈលើបងស្រីរបស់គាត់[2094]។

__ការសួរចម្លើយ__

៤៨៣. មានសាក្សីចំនួនបីនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីពីររូប ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខសង់ ត្រូវបានគេសួរចម្លើយ[2095]។ មានម្នាក់ត្រូវបានវាយដំក្នុងអំឡុងពេលសួរចម្លើយនោះ[2096]។ អតីតកម្មាភិបាលចំនួនពីររូបបានទទួលស្គាល់ថា គាត់បានចូលរួម ឬបានឃើញដោយផ្ទាល់គេសួរចម្លើយ អ្នកទោស។[2097] កម្មាភិបាលម្នាក់ បានទទួលស្គាល់ថា គាត់បានឃើញអ្នកទោសត្រូវគេធ្វើទារុណកម្មធ្ងន់ធ្ងរនៅពេលសួរចម្លើយ[2098]។ គាត់បាននិយាយថា អ្នកទោសត្រូវបានសួរចម្លើយអំពីរឿងខុសសីលធម៌ រឿងពាក់ព័ន្ធជាមួយនឹងទាហាន លន់ នល់ អំពីភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេ។ អ្នកទោសនឹងត្រូវគេវាយនឹងរំពាត់ផ្តៅ ឬច្រកក្បាលនឹងថង់ផ្លាស្ទិករហូតសន្លប់បាត់ស្មារតី ប្រសិនបើមិនឆ្លើយទទួលថាខ្លួនជាខ្មាំងនោះទេ[2099]។ នៅពេលសួរចម្លើយ មានសន្តិសុខជាអ្នកចាំសរសេរកត់ត្រាចម្លើយសារភាពរបស់អ្នកទោស មុនពេលយកទៅឱ្យម្នាក់ទៀតវាយអង្គុលីលេខ[2100]។

៤៨៤. អតីតអ្នកវាយអង្គុលីលេខនៅមន្ទីរសន្តិសុខសង់បានបញ្ជាក់ថា គាត់បានកត់ត្រាចម្លើយសារភាព

របស់អ្នកទោស ដែលជាទូទៅចម្លើយនោះរៀបរាប់ពីការពាក់ព័ន្ធដល់របប លន់ នល់ សក្តិភូមិ នាយទុន សេអ៊ីអា និងកាហ្សេបេ។ នៅពេលចម្លើយអ្នកទោសត្រូវបានកត់ត្រាចប់ គេបានបញ្ជូនទៅឲ្យ ម៉ុង ដែលជាអ្នកចុះហត្ថលេខា[2101]។ អតីតសន្តិសុខម្នាក់ដែលជានិរសាររបស់ ម៉ុង បាននិយាយថា នៅពេលសំណុំឯកសារ អ្នកទោសត្រូវបានបញ្ចប់ គេបានបញ្ជាគាត់ឲ្យដាក់ឯកសារក្នុងស្រោមសំបុត្រ និងយកទៅឲ្យមន្ទីរសន្តិសុខផ្សេងៗទៀត ឬទៅសហករណ៍ ឬកងចល័ត។ គាត់ប្រាប់ថា ការធ្វើបែបនេះដើម្បីជូនដំណឹងដល់អ្នកដែលត្រូវទទួលសំបុត្រទាំងនោះអំពីមនុស្សនៅក្នុងអង្គភាពខ្លួន ដែលត្រូវគេឆ្លើយដាក់ក្នុងចម្លើយសារភាព និងដើម្បីឲ្យពួកគេអាចស្រាវជ្រាវរកបណ្តាញខ្មាំងបាន។ ក្រោយមក គេសង្កេតឃើញថា អ្នកដែលគេឆ្លើយដាក់ទាំងនោះត្រូវចាប់បញ្ជូនមកមន្ទីរសន្តិសុខសង់[2102]។

## ការសម្លាប់

៤៨៥. សាក្សីមួយចំនួនបាននិយាយថា អ្នកទោសត្រូវបានដឹកចេញពីមន្ទីរឃុំឃាំងតាមឡាន ហើយមិនដែលឃើញត្រឡប់មកវិញទេ[2103]។ មានការបាត់ខ្លួនជាច្រើនកើតមានឡើងនាពេលយប់[2104]។ ផ្អែកតាមសាក្សីម្នាក់ ការបាត់ខ្លួនបានកើតមានម្តងក្នុងមួយសប្តាហ៍ ឬម្តងក្នុងមួយខែ[2105]។ អ្នកទោសម្នាក់ទៀតបាននិយាយថា ការបាត់ខ្លួនកើតមានជារៀងរាល់ថ្ងៃ[2106]។

៤៨៦. ឡានទាំងនោះបានដឹកអ្នកទោសទៅកាន់មន្ទីរសន្តិសុខមួយផ្សេងទៀត ដោយសារតែមានអ្នកទោសច្រើនពេកនៅមន្ទីរសន្តិសុខសង់[2107]។ ឡានខ្លះទៀតបានដឹកអ្នកទោសយកទៅសម្លាប់[2108]។ អ្នកដែលត្រូវបានគេដឹកយកទៅសម្លាប់ត្រូវបានប្រាប់ថា ដឹកយកទៅសហករណ៍[2109]។ អ្នកទោសមួយចំនួនត្រូវគេសម្លាប់នៅក្នុងបរិវេណមន្ទីរសន្តិសុខសង់នោះតែម្តង ប៉ុន្តែ កន្លែងសម្រាប់សម្លាប់រួមគឺនៅព្រៃឫស្សីដែលស្ថិតនៅចំងាយប្រហែលមួយគីឡូម៉ែត្រពីមន្ទីរសន្តិសុខនេះ[2110]។ សាក្សីម្នាក់ដែលជាអតីតសន្តិសុខមន្ទីរសង់នោះ បានឃើញការសម្លាប់អ្នកទោសដោយផ្ទាល់ចំនួនបីដង[2111]។ គាត់បានឃើញផ្ទាល់ភ្នែកនូវអ្នកទោសប្រហែលពី៣០ ទៅ៤០ នាក់ ត្រូវបានចងជាប់គ្នា និងចងបិទមុខ មុនពេលដែលកងសន្តិសុខបណ្តើរពួកគេយកទៅសម្លាប់។ កងសន្តិសុខបាន សម្រាតខោអាវអ្នកទោស រួចនាំទៅមាត់រណ្តៅដែលបានជីកស្រាប់ ហើយអ្នកទោសត្រូវបានសម្លាប់ដោយអាវុធបំពងក និងវះពោះដោយជំពុះទុង[2112]។ កុមារត្រូវបានសម្លាប់ ដោយបោកក្បាលនឹងគល់ត្រាច[2113]។ ប្រមាត់ត្រូវបានកាត់ សម្រាប់បរិភោគដោយកម្មាភិបាលរបស់មន្ទីរសន្តិសុខ[2114]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៤៨៧. សាក្សីពីររូបបាននិយាយថា មនុស្សចំនួនប្រហែល៥.០០០នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខសង់[2115]។ សាក្សីមួយចំនួន រាប់បញ្ចូលទាំងអតីតជនរងគ្រោះ និងអ្នកសម្លាប់ បានចូលរួមក្នុងការគាស់រណ្តៅសាកសពនៅក្បែរមន្ទីរសន្តិសុខសង់នោះ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ[2116]។ សាក្សីម្នាក់ដែលជាសមាជិករបស់គណៈកម្មការគាស់រណ្តៅសពរួម បាននិយាយថា ពួកគាត់បានគាស់រណ្តៅបានប្រហែល១១២ រណ្តៅ ដែលក្នុងរណ្តៅនីមួយៗមានសាកសពប្រហែលពី៣០ ទៅ១២០ នាក់។ ជាសរុប លលាដ៍ក្បាលចំនួន២.៦០០ ត្រូវបានរកឃើញ។ ក៏ប៉ុន្តែ គេមិនបានគាស់រណ្តៅទាំងអស់ដែលមាននៅក្នុងទីតាំងនោះទេ[2117]។ ក្រៅពីបានឃើញសាកសព ក៏ឃើញមានសំលៀកបំពាក់ (មានទាំងខោអាវរបស់ស្ត្រីផង) ខ្នោះ និងដែកភ្ជួរទេះ ក៏ត្រូវបានប្រទះឃើញដែរ[2118]។

***

៤៨៨. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន **២៧នាក់ (ម្ភៃប្រាំពីរនាក់)** ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខសង់[2119]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខសង់។

### មន្ទីរសន្តិសុខក្រាំងតាចាន់[2120]

#### ទីតាំង និងការបង្កើត

៤៨៩. មន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ[2121]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងស្រុក១០៥ តំបន់ ១៣ ភូមិភាគនិរតី[2122]។ អតីតប្រធានឃុំគុស ក្នុងស្រុកត្រាំកក់ និងជាអតីតប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ ឈ្មោះ [លុប] បាននិយាយថា ក្រាំងតាចាន់ពីមុនជាកន្លែងប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្រោយមកកន្លែងនេះ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ត្រូវបានប្តូរដោយគណៈកម្មាធិការតំបន់ ទៅជាមន្ទីរឃុំឃាំងក្រោមការគ្រប់គ្រងរបស់គណៈស្រុក១០៥[2123]។ មន្ទីរសន្តិសុខនេះបានដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[2124]។ មានភាពមិនស្រប

00605416



គ្នាខ្លះក្នុងការបំភ្លឺរបស់សាក្សីទាក់ទិនជាមួយនឹងរូបភាពជាក់ស្ដែងរបស់ទីតាំងនេះ។ ប៉ុន្តែ ជារួមមានភាពស្របគ្នាថា បន្ទាប់ពីស្រុកបានគ្រប់គ្រងមន្ទីរក្រាំងតាចាន់ មន្ទីរនេះបានព័ទ្ធដោយរបងជុំវិញ ដែលមានអគារជាច្រើនធ្វើអំពីឈើ ប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោស សម្រាប់កម្មាភិបាលស្នាក់នៅ សម្រាប់សួរយកចម្លើយ និងហូបអាហារ[2125]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក**

៤៩០. សាក្សី និងឯកសាររបស់ស្រុក ១០៥ បង្ហាញថា ទំនាក់ទំនងនៃការបញ្ជា អនុវត្តដោយខ្មែរក្រហមទូទាំងប្រទេស ត្រូវបានអនុវត្តនៅក្នុងតំបន់១៣ តាំងពីមុនខែមេសា ឆ្នាំ១៩៧៥។ ឃុំបានរាយការណ៍ទៅគណៈស្រុក ហើយស្រុករាយការណ៍ទៅគណៈតំបន់ និងតំបន់រាយការណ៍បន្តទៅគណៈភូមិភាគ។ អង្គភាពក្រោមត្រូវតែគោរពតាមបទបញ្ជា ដែលចេញដោយអង្គភាពលើទាំងបី[2126]។ ប្រសិនបើកម្មាភិបាលថ្នាក់ក្រោមធ្វើផ្ទុយពីបទបញ្ជា ឬមិនបានសុំការយល់ព្រមពីអង្គភាពថ្នាក់លើ ពួកគេអាចត្រូវបានចាប់ខ្លួន និងសម្លាប់[2127]។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីពិសេសខ្លះ ទំនងជាការដាក់បញ្ជាអាចត្រូវបានដាក់មកផ្ទាល់ ដោយគ្មានឆ្លងកាត់ខ្សែបញ្ជាធម្មតាឡើយ។ ឧទាហរណ៍ ប្រសិនបើតំបន់ផ្ញើលិខិតមកឃុំដោយផ្ទាល់ ឃុំអាចឆ្លើយតបដោយគ្មានឆ្លងកាត់ស្រុក[2128]។ បទបញ្ជាចេញពីឃុំទៅមជ្ឈិមធ្វើឡើង តាមរយៈមធ្យោបាយជាច្រើន។

៤៩១. ការប្រជុំនានាគឺជាវិធីសាមញ្ញមួយ ដើម្បីផ្តល់បញ្ជា និងទទួលរបាយការណ៍នានា ដោយសារមិនមានក្រដាសប្រើប្រាស់គ្រប់គ្រាន់[2129]។ សាក្សីម្នាក់ដែលធ្វើការនៅអាគារពាណិជ្ជកម្មតំបន់ភូមិភាគនិរតី ប្រចាំនៅទីក្រុងភ្នំពេញបានបញ្ជាក់ថា បានឃើញមេដឹកនាំជាន់ខ្ពស់របស់ភូមិភាគនិរតី រាប់បញ្ចូលទាំងលេខាភូមិភាគ តាម៉ុក និង លេខាតំបន់១៣ [លុប] បានមកភ្នំពេញដើម្បីចូលរួមប្រជុំជាមួយអង្គការ[2130]។ ជារៀងរាល់បីខែ ទៅប្រាំមួយខែម្តង ភូមិភាគបានជួបជាមួយគណៈតំបន់។ ក្រោយពីជួបប្រជុំនេះ តំបន់បានកោះប្រជុំជាមួយស្រុក និងឃុំ ដើម្បីប្រាប់អំពីទិសដៅការងារ និងណែនាំអំពីកិច្ចការពាក់ព័ន្ធការគ្រប់គ្រង និងការអប់រំប្រជាជន ដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន។ នាពេលនោះ មានការបង្ហាញអំពីស្ថានភាពក្នុងប្រទេស និងក្រៅប្រទេសផងដែរ[2131]។ អតីតប្រធានកងយុវជនរបស់ស្រុកឈ្មោះ [លុប] បាននិយាយថា គាត់បានចូលរួមប្រជុំ ដែលក្នុងពេលនោះ [លុប] ដែលជាលេខាតំបន់បានអានឯកសារ ដែលក្នុងនោះមានសេចក្តីណែនាំរបស់មន្ទីរ៨៧០ ([លុប]យល់ថា ជាលេខកូដរបស់ការិយាល័យមជ្ឈិម)រួមមាន៖

ទស្សនាវដ្តីយុវជន និងទង់បដិវត្ត។ [លុប] បាននិយាយថា អង្គប្រជុំប្រភេទនេះ កើតមានបីដងក្នុងមួយខែ នេះមិនរាប់បញ្ចូលកាលៈទេសៈពិសេសដែលមន្ទីរ៨៧០ អាចចេញសេចក្តីណែនាំតម្រូវឲ្យកម្មាភិបាលគ្រប់គ្នា ជួបប្រជុំនៅការិយាល័យតំបន់។ តំបន់កោះហៅលេខាស្រុក មកចូលរួមប្រជុំ ហើយស្រុកផ្សព្វផ្សាយការណែនាំ ដល់អង្គភាពរបស់ខ្លួនជាបន្ត[2132]។

៤៩២. អតីតលេខាស្រុក១០៥ [លុប] បាននិយាយអំពីវត្តមានរបស់គាត់ នៅឯកិច្ចប្រជុំរបស់គណៈតំបន់ ដែលនាពេលនោះ [លុប] បានរាយការណ៍ជូន តា ម៉ុក អំពីបញ្ហានានាទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់[2133]។ ក្រោយពីអង្គប្រជុំត្រូវបានបញ្ចប់ តា ម៉ុក និង [លុប] បានពិភាក្សាអំពីជោគវាសនារបស់ក្រុមមនុស្ស៦០ នាក់ រស់នៅក្នុងស្រុកត្រាំកក់ ដែលមានគេឆ្លើយដាក់ក្នុងចម្លើយសារភាព។ តាម៉ុក បានបញ្ជាឲ្យលេខាស្រុកឲ្យតាមដាន និងពិនិត្យមើលមនុស្សទាំងនេះ[2134]។ [លុប] បាននិយាយថា គាត់បានចូលរួមក្នុងអង្គប្រជុំជាច្រើន រំលឹកខួបបក្សដែលដឹកនាំដោយ តា ម៉ុក។ អង្គប្រជុំទាំងនេះ ពីមុនត្រូវបានធ្វើឡើងនៅទីតាំងសម្ងាត់ តែក្រោយមកបានរៀបចំឡើងនៅមន្ទីរតំបន់។ សមាជិកជាន់ខ្ពស់នៃតំបន់ បានចូលរួមក្នុងអង្គប្រជុំនេះ ដើម្បីពិភាក្សានយោបាយ និងការធ្វើបដិវត្ត។ តាម៉ុក បានបង្ហាញអំពីរបៀបកំណត់ភ្នាក់ងារសេអ៊ីអា និងកាហ្សេបេ និងសកម្មភាពរបស់ពួកអ្នកទាំងនោះ។ [លុប] បានដឹងពី តា ម៉ុក ថា សត្រូវទាំងនេះត្រូវតែរកឲ្យឃើញ និងកម្ទេចចោល[2135]។ [លុប] ក៏បានចូលរួមផងដែរ ក្នុងអង្គប្រជុំថ្នាក់តំបន់ដែលដឹកនាំដោយ [លុប] [លុប]។ គាត់បាននិយាយថា ពាក់ព័ន្ធជាមួយនយោបាយ [លុប] បានណែនាំឲ្យពិនិត្យមើលសត្រូវស៊ីរូងផ្ទៃក្នុង។ [លុប] បានបញ្ជា អ្នកចូលរួមឲ្យរាយការណ៍អំពីខ្មាំងដល់ថ្នាក់លើ ហើយបាននិយាយថា ការតាមដានអាចត្រូវបានធ្វើឡើងដោយសហករណ៍[2136]។

៤៩៣. ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ ជាធម្មតារាយការណ៍ និងផ្ញើចម្លើយសារភាពទៅគណៈស្រុក ដែលជាបន្តនឹងផ្ញើទៅតំបន់។ ក្នុងករណី ដែលបញ្ហានោះទាក់ទងតែជាមួយតំបន់ ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ អាចរាយការណ៍ទៅគណៈតំបន់ដោយផ្ទាល់[2137]។ រៀងរាល់ចុងខែ លេខាស្រុកនឹងផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីសកម្មភាពរបស់ខ្លួនដល់តំបន់[2138]។ សក្ខីកម្មរបស់ ពេជ្រ ជឹម និងឯកសាររបស់ស្រុក១០៥ ចុះកាលបរិច្ឆេទចន្លោះខែកក្កដា និងខែវិច្ឆិកា ឆ្នាំ១៩៧៧ បានបង្ហាញថា ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ អាចនឹងធ្វើរបាយការណ៍ប្រចាំខែបញ្ជូនទៅស្រុក។ របាយការណ៍មានសរសេរអំពីចំនួនអ្នកទោសរួម ចំនួនអ្នកដែលបានស្លាប់ដោយសារជំងឺចំនួនមនុស្ស

00605418



ដែលត្រូវបានសម្លាប់ ប្រជាជនសរុប បញ្ហាសេដ្ឋកិច្ច និងការផលិតស្បៀងអាហារ[2139]។

៤៩៤. សមាសភាពជាក់លាក់របស់គណៈនីមួយៗត្រូវបានផ្លាស់ប្តូរ ដោយសារសមាជិកត្រូវប្តូរកន្លែងធ្វើការ ឬស្លាប់ និងត្រូវបានចាប់ខ្លួន។ យ៉ាងណាក៏ដោយ បុគ្គលទាំងនេះ ទំនងជាលេខាស្រុក១០៥ ក្នុងពេលខុសៗគ្នាដែលមាន៖ [លុប], [លុប], [លុប], [លុប], និង[លុប][2140]។ លេខាតំបន់១៣ រួមមាន [លុប] [លុប]និង[លុប][2141]។ តា ម៉ុក ជាលេខាភូមិភាគនិរតី [2142]។

៤៩៥. សាក្សីខ្លះដោយរួមមាន[លុប] បានបរិយាយថា សាក្សី [លុប] គឺជាប្រធានដំបូងបង្អស់របស់មន្ទីរសន្តិសុខក្រាំងតាចាន់។ ក៏ប៉ុន្តែ [លុប] បដិសេធមិនទទួលស្គាល់ថា គាត់ធ្លាប់កាន់តំណែង ជាផ្លូវការនេះឡើយដោយនិយាយថា គាត់គ្រាន់តែជួយមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងឋានៈជាប្រធានឃុំគុសប៉ុណ្ណោះ[2143]។ ទោះជាយ៉ាងនេះក្តី [លុប] ត្រូវបានគេប្តូរការងារនៅខែមេសា ឆ្នាំ១៩៧៥ ហើយអនុរបស់គាត់ឈ្មោះ [លុប] បានក្លាយជាប្រធានមន្ទីរសន្តិសុខដែលមានកូនចៅជាសន្តិសុខចំនួន១២ រូប ធ្វើការងារជាមួយគាត់[2144]។[លុប]ជាប្រធានយ៉ាងហោចណាស់រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨[2145]។ ទំនងជា [លុប]និងក្រោយមកគឺ[លុប] ដែលស្ថិតនៅក្រោមការបញ្ជាផ្ទាល់របស់[លុប] ដែលជាសមាជិកគណៈស្រុក ហើយ[លុប]ទំនងជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិសុខនេះ[2146]។

៤៩៦. កម្មាភិបាលជាន់ខ្ពស់មួយចំនួន ទំនងជាធ្លាប់បានពិនិត្យមើលមន្ទីរសន្តិសុខក្រាំងតាចាន់។ ភស្តុតាងខ្លះបានបង្ហាញថា តា ម៉ុក បានពិនិត្យអ្នកទោសជាច្រើនដងទោះបីជា [លុប] និង [លុប]និង [លុប] (អតីតប្រធានយុវជនស្រុក១០៥)បានបដិសេធថា មិនបានដឹងអំពីព័ត៌មាននេះ ឬភ្លេចក៏ដោយ[2147]។ តាមការពិតមិនមានសាក្សីណាម្នាក់ ក្នុងចំណោមអ្នកទាំងបីមានវត្តមាននៅមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងអំឡុងពេលនៃដំណើរការរបស់មន្ទីរនេះឡើយ។ បន្ថែមពីលើនេះ សាក្សីម្នាក់បានជឿថា គាត់បានឃើញ នួន ជា មកមើលមន្ទីរសន្តិសុខក្រាំងតាចាន់ និងបាននិយាយជាមួយ [លុប]ប៉ុន្តែ [លុប] បានបដិសេធអំពីហេតុការណ៍នេះ[2148]។ សាក្សីបាននិយាយថា លេខាស្រុកជាបន្តបន្ទាប់រួមមាន៖ [លុប] [លុប] និង[លុប]បានទៅពិនិត្យមើលមន្ទីរសន្តិសុខក្រាំងតាចាន់ជាទៀងទាត់[2149]។

<u>**ការចាប់ខ្លួន និងការឃុំខ្លួន**</u>

៤៩៧. សក្ខីកម្មរបស់ [លុប]និង[លុប]និងឯកសារផ្សេងៗរបស់ស្រុក១០៥ បានបង្ហាញអំពី វិធីនៃ

ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ ឬការដោះលែង ដែលកើតមានឡើងនៅក្នុងតំបន់១៣។ ជាដំបូង ឃុំរាយការណ៍អំពីសមាសភាពសង្ស័យផ្សេងៗ(ប្រជាពលរដ្ឋ ឬកម្មាភិបាលបក្សកុម្មុយនីស្ត កម្ពុជា) ជូនទៅស្រុក។ ឧទាហរណ៍ របាយការណ៍ពីឃុំ ព្រៃញ៉ាង ផ្ញើជូនទៅស្រុក និយាយអំពីប្រវត្តិរូបរបស់"ខ្មាំង" ដោយបានសរសេរអំពីកំហុសផ្សេងៗដែលត្រូវបានចោទប្រកាន់។ កំណត់សម្គាល់ត្រឡប់មកវិញពីលេខាស្រុកមកឃុំ បានសរសេរណែនាំនៅទំព័រខាងក្រោមនៃឯកសារថា អ្នកដែលចោទថាជាខ្មាំងនឹងត្រូវបានចាប់ខ្លួន[2150]។ នៅពេលចាប់ខ្លួនបុគ្គលទាំងនោះ រួចបញ្ជូនទៅស្រុក។ បន្ទាប់មក ស្រុកនឹងពិភាក្សាជាមួយនឹងលេខាស្រុក មុននឹងបញ្ជូនអ្នកដែលពាក់ព័ន្ធទៅមន្ទីរសន្តិសុខក្រាំងតាចាន់ ជាមួយរបាយការណ៍[2151]។ ឧទាហរណ៍ របាយការណ៍ពីឃុំត្រពាំងធំត្បូង ផ្ញើមកប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ និយាយអំពីកំហុសរបស់មនុស្សបីនាក់ដែលបក្សបានសម្រេចចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខនេះ[2152]។ ស្របជាមួយពេលគ្នានោះដែរ មានរបាយការណ៍ត្រូវបានផ្ញើទៅគណៈតំបន់។ របាយការណ៍ទាំងនោះគឺជាមូលដ្ឋានសម្រាប់សួរយកចម្លើយអ្នកទោស[2153]។ ក្រោយមក ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់នឹងផ្ញើចម្លើយសារភាពទៅលេខាស្រុក ដែលជាអ្នកបញ្ជូនទៅគណៈតំបន់[2154]។ លេខាតំបន់នឹងណែនាំគណៈកម្មាធិការស្រុកពីបុគ្គលណាមួយនឹងត្រូវសម្លាប់ និងអ្នកដែលនឹងត្រូវដោះលែង។ ឈ្មោះរបស់មនុស្សទាំងនោះនឹងត្រូវបានបញ្ជូនទៅ មន្ទីរសន្តិសុខក្រាំងតាចាន់ ដើម្បីអនុវត្តបញ្ជា[2155]។ ដូច្នេះ បង្ហាញថាតំបន់បានសម្រេចដោយផ្អែកលើចម្លើយសារភាពជាចម្បង និងផ្អែកតាមព័ត៌មានដទៃទៀតដែលផ្តល់ដោយស្រុក អំពីជោគវាសនារបស់អ្នកជាប់ឃុំនៅក្នុងមន្ទីរក្រាំងតាចាន់។ ស្រុកបានផ្អែកលើព័ត៌មានផ្តល់ដល់ខ្លួនដែលបញ្ជូនមកពីឃុំ រាប់បញ្ចូលទាំងព័ត៌មានរឿងហេតុនៃការចោទប្រកាន់ដោយឈ្លបឃុំ និងសេចក្តីរាយការណ៍មកពីប្រជាជន។

៤៩៨. អ្នករស់នៅស្រុកត្រាំកក់បានបំភ្លឺថា មុនពេលដែលអ្នកត្រូវបានជម្លៀសមកពីភ្នំពេញមកដល់ក្នុងតំបន់នេះ លេខាស្រុក និងឃុំ បានចូលរួមអង្គប្រជុំ ដោយពួកគេត្រូវបានណែនាំថា នឹងមានការសម្រិតសម្រាំងក្នុងចំណោម អ្នកដែលត្រូវបានគេជម្លៀស។ ជនណាមួយធ្លាប់ជាពលបាលទោ ឬខ្ពស់ជាងនេះ ក្នុងរបបលន់ នល់ ហើយអ្នកណាធ្លាប់បម្រើឲ្យរដ្ឋការលន់ នល់ ក្នុងឋានៈជាអនុប្រធានទីមួយ ឬខ្ពស់ជាងនេះ នឹងត្រូវបានសម្រិតសម្រាំង។ ហេតុការណ៍នេះត្រូវបានបញ្ជាក់បន្ថែមដោយសាក្សីបីរូប រួមទាំងអតីតប្រធានយុវជនស្រុកថា នៅពេលដែល"ប្រជាជនថ្មី"មកដល់ត្រាំកក់ ពួកគេត្រូវបានបង្ខំឲ្យធ្វើប្រវត្តិរូបហើយថា អ្នកដែលប្រាប់ថាខ្លួនជាទាហាននឹងត្រូវបានបាត់ខ្លួនបន្ទាប់មក[2156]។ សាក្សីម្នាក់បានរៀបរាប់ថា នៅពេលមកដល់ស្រុកត្រាំកក់ ក្នុងខែមេសា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605420



ឆ្នាំ១៩៧៥ គាត់ត្រូវបានបង្គាប់ឲ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់ដោយប្រាប់យ៉ាងជាក់លាក់អំពីថា តើគាត់ជាទាហាន ឬមន្ត្រីរដ្ឋការនៃរបប លន់ នល់[2157]។ សមាជិកគណៈកម្មាធិការឃុំម្នាក់ក្នុងឃុំត្រាំកក់បញ្ជាក់ថា លេខាឃុំ បានបញ្ជាឲ្យប្រមូលអ្នកជម្លៀសទាំងអស់ដែលមានឋានៈពីស័ក្តិមួយឡើងទៅ។ នៅពេលប្រមូលផ្ដុំរួច ថ្នាក់លើបានបញ្ជូនឡានមកដឹកចេញទៅ។ ប្រជាជនទាំងនោះបាត់ខ្លួនជារៀងរហូត[2158]។ បញ្ជីអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ រួមទាំងការកើនឡើងនៃចំនួនអ្នកទោសនៅមន្ទីរសន្តិសុខនេះក្រោយខែមេសា ឆ្នាំ១៩៧៥ បង្ហាញថា ភាគច្រើននៃអ្នកទាំងនោះ ដែលបានបាត់ខ្លួនត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់[2159]។ មានរបាយ-ការណ៍ជាច្រើនមកពីឃុំជូនទៅស្រុកក្នុងឆ្នាំ១៩៧៧ បង្ហាញថា ការសម្រិតសម្រាំងអតីតទាហាន និងមន្ត្រីរដ្ឋការលន់ នល់ នៅតែបន្តមានក្រោយឆ្នាំ១៩៧៥[2160]។

៤៩៩. ភាគច្រើននៃអ្នកត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានចាប់ខ្លួនដោយឈ្លបឃុំ[2161]។ អតីតសន្តិសុខបានបំភ្លឺថា ឈ្លបឃុំបាននាំមនុស្សមកមន្ទីរសន្តិសុខក្រាំងតាចាន់ទាំងពេលថ្ងៃ និងពេលយប់ ជួនកាលច្រើនរហូតដល់១០ នាក់ ចងភ្ជាប់គ្នា[2162]។ សន្តិសុខផ្សេងទៀតបាននិយាយថា ពេលដែលអ្នកទោសមកដល់ គាត់ឃើញអ្នកទោសត្រូវគេចងដៃជាមួយគ្នា[2163]។ អ្នកដែលបណ្ដើរអ្នកទោសមកមន្ទីរសន្តិសុខក្រាំងតាចាន់ មិនត្រូវបានគេអនុញ្ញាតឲ្យចូលក្នុងបរិវេណមន្ទីរឡើយ[2164]។

៥០០. បុរស ស្ត្រី និងកុមាររួមទាំងគ្រួសារត្រូវបានឃុំខ្លួននៅក្រាំងតាចាន់[2165]។ មានសាក្សីចំនួន៨នាក់ជាអតីតអ្នកជាប់ឃុំឃាំង[2166]។ សាក្សីបានឲ្យដឹងថា ភាគច្រើននៃអ្នកជាប់ឃុំឃាំងជាប្រជាជនថ្មីមកពីភ្នំពេញ[2167]។ ប៉ុន្តែ ក៏មានប្រជាជនមូលដ្ឋាន អតីតទាហានលន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ[2168]។ ទាក់ទិនជាមួយជនជាតិចាម សាក្សីដែលរស់នៅក្នុងស្រុកត្រាំកក់បាននិយាយថា ការប្រព្រឹត្តទៅលើជនជាតិចាមដូចគ្នានឹងប្រជាជនដទៃទៀត[2169]។ ជនជាតិវៀតណាមដែលរស់នៅក្នុងស្រុកត្រាំកក់ពីដំបូងត្រូវបានបញ្ជូនទៅវៀត ណាមវិញ ក៏ប៉ុន្តែអ្នកដែលមិនទាន់បានបញ្ជូន ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់ ប្រហែលជានៅមន្ទីរសន្តិសុខក្រាំងតាចាន់នេះ[2170]។ មានភាពមិនច្បាស់លាស់ថាតើមានអ្នកទោស ប៉ុន្មាននាក់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងចន្លោះពីខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ ឬថាតើគុកនេះអាចដាក់អ្នកទោសបានប៉ុន្មាន។ ក៏ប៉ុន្តែ ការប៉ាន់ប្រមាណអាចត្រូវបានទាញចេញពីប្រភពខុសគ្នា។ របាយការណ៍មួយពីមន្ទីរសន្តិសុខក្រាំងតាចាន់ទៅគណៈស្រុកសម្រាប់ខែកក្កដា ឆ្នាំ១៩៧៧ បានឲ្យដឹងថា អ្នកទោសថ្មីចំនួន១៨ រូប បានមកដល់ក្នុងខែនេះ

ធ្វើឲ្យចំនួនអ្នកទោសមានដល់៨១ នាក់។ ក្នុងចំណោមអ្នកទាំងនោះ មានពីរនាក់បានស្លាប់ដោយសារជម្ងឺ ៣៩ នាក់ត្រូវបានសម្លាប់ និងនៅសល់ចំនួន៤០ នាក់[2171]។ របាយការណ៍ស្រដៀងនេះ សម្រាប់ខែវិច្ឆិកា ឆ្នាំ១៩៧៧ បង្ហាញអ្នកទោសសរុបចំនួន៨៥ នាក់[2172]។ របាយការណ៍មួយទៀតពី [លុប] បញ្ជាក់ទៅគណៈស្រុក (ពុំមានកាលបរិច្ឆេទ)ថា អ្នកទោសចំនួន ១៥.០០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់[2173]។

៥០១. ភស្តុតាងបានបង្ហាញថា អ្នកទោសត្រូវបានបែងចែកជាពីរប្រភេទ មានអ្នកទោសកម្រិតស្រាល និងធ្ងន់[2174]។ ប៉ុន្តែ អតីតសន្តិសុខម្នាក់បាននិយាយថា មិនមានការបែងចែកដូច្នេះទេ[2175]។ អ្នកទោសត្រូវបានដាក់ខ្នោះនាពេលយប់ និងពេលថ្ងៃ ប្រសិនបើមិនធ្វើការងារ[2176]។ នៅពេលអ្នកទោសចង់បន្ទោរបង់ អ្នកទោសប្រើត្រឡោកដូង រួចហើយបញ្ជូនបន្តគ្នា រហូតដល់អ្នកនៅចុងក្រោយ។ ប្រសិនបើអ្នកទោសណាម្នាក់ធ្វើឲ្យកំពប់ទឹកនោម ឬលាមក អ្នកទោសនោះត្រូវបានវាយនឹងដំបងឬស្សី។ នៅក្នុងបន្ទប់ឃុំឃាំងនីមួយៗមានដាក់អ្នកទោសជា២ ជួរ ដែលក្នុងមួយជួរៗ មានអ្នកទោសប្រហែល២០ ទៅ ២៥ នាក់[2177]។ បុរស ស្ត្រី និងកុមារ ត្រូវបានឃុំនៅក្នុងបន្ទប់ជាមួយគ្នា ប៉ុន្តែក្នុងជួរដោយឡែកពីគ្នា[2178]។ កុមារអាយុលើសពី១០ ឆ្នាំត្រូវបានដាក់ខ្នោះ[2179]។ កុមារតូចឲ្យនៅជាមួយម្តាយ[2180]។ អ្នកទោសមិនបានអនុញ្ញាតឲ្យកំរើកខ្លួន ដោយសេរីឡើយ[2181]។

៥០២. មានអ្នកទោសចំនួនប្រហែលពី១ទៅ ៣នាក់បានស្លាប់ជារៀងរាល់ថ្ងៃក្នុងបន្ទប់ឃុំឃាំងនីមួយៗ[2182]។ មូលហេតុនៃការស្លាប់ទាំងនោះរួមមាន ការអត់អាហារ ជម្ងឺ សង្កើចខាំ ឬដោយសារការវាយដំ[2183]។ អតីតសន្តិសុខម្នាក់បានអះអាងថា មិនមានកន្លែងព្យាបាលជម្ងឺឡើយ នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយអ្នកជម្ងឺត្រូវបានទុកឲ្យស្លាប់[2184]។ ឯកសាររបស់ស្រុក១០៥ ជាច្រើន បានកត់ត្រាអំពីការស្លាប់ដោយសារជម្ងឺ[2185]។

៥០៣. មានអ្នកទោសខ្លះបាននិយាយថា អ្នកទោសត្រូវបានបង្ខំឲ្យធ្វើការនៅខាងក្នុងបរិវេណគុក ដោយត្រូវធ្វើការជាច្រើនមុខ[2186]។ អ្នកធ្វើការ មានរបបអាហារច្រើនជាងអ្នកដែលជាប់ខ្នោះនៅក្នុងអគារ[2187]។ អ្នកដែលធ្វើការនៅក្នុងវាលស្រែមិនត្រូវបានដាក់ខ្នោះទេ ប៉ុន្តែស្ថិតនៅក្រោមការយាមកាម។ អ្នកទោសខ្លះដែលត្រឡប់មកពីធ្វើការវិញ ត្រូវបានដាក់ខ្នោះក្នុងបន្ទប់ឃុំឃាំងនៅពេលយប់[2188]។

៩០៤. សាក្សីពីរនាក់បាននិយាយអំពីការរំលោភសេពសន្ថវៈដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់[2189]។ អតីតអ្នកជាប់ឃុំឃាំងម្នាក់បាននិយាយយ៉ាងច្បាស់ពីសន្តិសុខម្នាក់ ដែលតែងតែរំលោភ និងសម្លាប់អ្នកទោស។ ហេតុការណ៍នេះ សាក្សីបានដឹងនៅពេលដែលសន្តិសុខនោះ បានប្រើគាត់ឲ្យកប់សាកសព។ ពេលខ្លះសាក្សី បានឃើញសាកសពមានភាពអាក្រាតដោយមានគ្រាប់កាំភ្លើងស៊កចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ[2190]។ អតីតសន្តិសុខម្នាក់បានបដិសេធហេតុការណ៍នៃការរំលោភសេពសន្ថវៈនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយនិយាយថា ប្រសិនបើមានទាំងជនរងគ្រោះ និងអ្នកប្រព្រឹត្តនឹងត្រូវបានសម្លាប់ ដោយសារបានប្រព្រឹត្តអំពើខុសសីលធម៌[2191]។ អតីតប្រធានយុវជនស្រុកបាននិយាយថា គាត់ត្រូវបានភូមិភាគ ឬតំបន់ បញ្ជាឲ្យស៊ើបអង្កេត នូវការចោទប្រកាន់ អំពីបទរំលោភសេពសន្ថវៈ លើស្ត្រីដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលធ្វើការនៅទីតាំងនេះ[2192]។

៩០៥. សាក្សីដែលជាអតីតអ្នកទោសចំនួន០៦នាក់ ត្រូវបានដោះលែង ពីមន្ទីរសន្តិសុខក្រាំងតាចាន់ក្នុងអំឡុងពេលប្រតិបត្តិការរបស់មន្ទីរនេះ[2193]។ សាក្សីម្នាក់បានបញ្ជាក់ថា ក្រោយពីបានជាប់ឃុំឃាំង២៩ ថ្ងៃ គាត់ត្រូវបានដោះលែងផ្ទាល់ដោយ តា ម៉ុក[2194]។ អតីតសន្តិសុខចំនួនពីររូបបាននិយាយថា ចំនួនប្រជាជនតិចណាស់ ដែលត្រូវបានដោះលែង[2195]។

**<u>ការសួរចម្លើយ</u>**

៩០៦. អតីតអ្នកជាប់ឃុំឃាំងចំនួន៧នាក់បានរៀបរាប់ថា ពួកគេត្រូវបានសួរយកចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់[2196]។ អ្នកទោសខ្លះត្រូវបានសួរយកចម្លើយជាច្រើនម៉ោង នៅពេលមកដល់មន្ទីរសន្តិសុខក្រាំតាចាន់[2197]។ ការសួរយកចម្លើយត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ[2198]។ អ្នកទោសត្រូវបានគេចោទថា ជា"ខ្មាំង" និងត្រូវបានសួរ អំពីអត្តសញ្ញាណរបស់មេដឹកនាំរបស់ពួកគេ[2199]។ អតីតអ្នកជាប់ឃុំឃាំងម្នាក់បានឲ្យដឹងថា គាត់ត្រូវបានគេសួរថា តើគាត់មកពីណា តើគាត់ជាសេអ៊ីអាមេរិកកាំង ឬយួន ហើយមានតួនាទីអ្វីក្នុងសម័យ លន់ នល់[2200]។ អ្នកជាប់ឃុំឃាំងម្នាក់ទៀត ត្រូវបានគេចោទអំពីបទខុសសីលធម៌[2201]។ អ្នកជាប់ឃុំឃាំងដទៃទៀត បានចងចាំថាពួកគេត្រូវបានសួរ ហេតុអ្វីបានជាគ្មានអាហារគ្រប់គ្រាន់ក្នុងសហករណ៍ ឬអំពីកិច្ចការសាមញ្ញដូចជាទំនាស់ក្នុងពេលបរទេះ។[2202] នៅពេលមួយនោះ អ្នកទោសទំនងជាត្រូវបានគេសាកសួរ អំពីចំណងទាក់ទងជាមួយ [លុប] មេដឹកនាំរបស់រណសិរ្សនៅក្នុងព្រៃ[2203]។ នៅពេលសួរយកចម្លើយចម្លើយសារភាពរបស់អ្នកទោសត្រូវបានកត់ត្រាដោយដៃ ហើយក្រោយមកទើបត្រូវបានវាយតាម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ម៉ាស៊ីនអង្គុលីលេខ[2204]។

៥០៧. ពេលខ្លះ អ្នកជាប់ឃុំឃាំងត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងរ ក្នុងពេលសួរចម្លើយ។ បក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ភាសា“ក្តៅ” និង”ត្រជាក់” ជាវិធីសាស្ត្រផ្សេងៗដែលត្រូវបានប្រើនៅពេល សួរចម្លើយអ្នកទោស។ “ក្តៅ” មានន័យថា ការវាយដំ និងវិធីសាស្ត្រផ្សេងទៀតធ្វើឲ្យមានរបួសរាងកាយ។ “ត្រជាក់” មានន័យថា លួងលោម ល្បិច បញ្ចុះបញ្ចូល ។ កម្មាភិបាលរៀនវិធីទាំងនេះពីស្រុក និងតំបន់[2205]។ ឯកសាររបស់ស្រុក១០៥ បានបង្ហាញថា ភាសានេះត្រូវបានប្រើនៅថ្នាក់ឃុំ ពេលរាយការណ៍ទៅបក្សអំពីមនុស្សដែលពួកគេបានសួរចម្លើយ[2206]។ ស្រដៀងគ្នានេះដែរ ក្នុងសំបុត្រដែល [លុប] ផ្ញើទៅកាន់ [លុប] ទាក់ទិននឹងអ្នកទោសដែលបានមកដល់ថ្មីបញ្ជាឲ្យ [លុប] សួរដោយសរសេរថា “សាកសួរនិង ល្អិតល្អី...”[2207]។

៥០៨. អតីតអ្នកជាប់ឃុំឃាំង ដែលធ្លាប់ត្រូវបានសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់ពីរនាក់បានអះអាងថា ពួកគេត្រូវបានវាយដំយ៉ាងដំណំក្នុងពេលសួរចម្លើយ[2208]។ អ្នកដទៃទៀតបាននិយាយថា ទោះបីពួកគេត្រូវបានសួរយកចម្លើយ តែមិនដែលត្រូវបានវាយដំទេ[2209]។ សាក្សី(អតីតអ្នកទោស និងសន្តិសុខ) របស់មន្ទីរសន្តិសុខក្រាំងតាចាន់បានឃើញនូវវិធីជាច្រើន ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើទារុណកម្មអ្នកទោសក្នុងអំឡុងពេលសួរយកចម្លើយរួមមាន៖ ការប្រើប្រាស់ថង់ផ្លាស្ទិកដើម្បីធ្វើឲ្យថប់ដង្ហើម វាយនឹងព្រនង់ ឬរំពាត់ ប្រើប្រាស់ដង្កាប់ទាញច្រមុះ និងស្លឹកត្រចៀក ច្រកទឹកអាស៊ីត ចាក់ទឹកលើជនរងគ្រោះ ចងជើង និងចងរឹតក[2210]។ សាក្សីពីរនាក់បាននិយាយបំភ្លឺថា បានឃើញអ្នកទោសស្លាប់ដោយសាររងរបួសកើតមានពីការសួរយកចម្លើយ[2211]។ បន្ថែមពីលើនេះ អតីតអ្នកជាប់ឃុំឃាំងម្នាក់ទៀតបាននិយាយថា គាត់បានកប់សាកសពដែលបានស្លាប់ ដោយសាររងរបួស ដែលទទួលរងពីការសួរចម្លើយ ដោយកង្វះអាហារ និងជម្ងឺ[2212]។

៥០៩. អតីតអ្នកជាប់ឃុំឃាំងម្នាក់ បានចងចាំថាគាត់ត្រូវបានសួរចម្លើយ បន្ទាប់ពីគាត់បានមកដល់មន្ទីរសន្តិសុខក្រាំងតាចាន់បានចំនួន៣ថ្ងៃ។គាត់និយាយថា៖“*នៅក្នុងពេលសួរចម្លើយនោះគេបានសួរយើងថា អ្នកណាជាមេដឹកនាំក្បត់ នៅពេលដែលយើងឆ្លើយថាមិនដឹងៗ គេយកថ្មោងផ្តៅវាយភ្លៅ ឆ្អឹងខ្នងត្រង់ស្មា ហើយដៃយើងគេចងស្ពាយសេកទៅក្រោយជាប់នឹងបង្គោលកូនឈើ។ នៅពេលខណៈដែលយើងឆ្លើយថាមិនដឹងៗគេយកសំពត់កៅស៊ូមករុំក្បាលត្រចៀកនិងមុខជិត ពេលនោះ ធ្វើឲ្យខ្ញុំថប់*

*ដង្ហើមរហូតដល់សន្លប់បាត់ស្មារតី បន្ទាប់មកគេដោះក្រណាត់ភ្នៀងនេះចេញ ហើយគេម្ដងទៀត រកមេដឹកនាំ។ រួចហើយគេចោទថា បើគ្មាននរណាជាមេដឹកនាំ គឺមានតែហ្វែងណឹងមេ។ រួចហើយគេនិយាយថាទុកបីថ្ងៃទៀត ទើបគេយកមកសួរចំលើយម្ដងទៀត"*[2213]។ អតីតអ្នកជាប់ឃុំឃាំង និងអតីតកម្មាភិបាលមួយចំនួន ធ្លាប់បានឮសម្លេងស្រែក ចេញមកពីកន្លែងសួរយកចម្លើយ[2214]។

<u>ការបាត់ខ្លួន និង ការសម្លាប់</u>

៥១០. បញ្ហានានាទាក់ទងនឹងការសម្លាប់ត្រូវបានផ្ញើពីលេខាតំបន់ទៅលេខាស្រុក ដែលជាអ្នកឲ្យដំណឹងដល់ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់។ បញ្ហា ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរនៅលើចម្លើយសារភាព ដែលត្រូវបានផ្ញើ ជាដំបូងចេញមកពីមន្ទីរសន្តិសុខក្រាំងតាចាន់ទៅលេខាស្រុក[2215]។

៥១១. សាក្សីខ្លះបាននិយាយថា អ្នកទោសត្រូវបានបញ្ជូនចេញនាពេលយប់[2216] តាមឡាន[2217] ហើយបានបាត់ខ្លួន[2218]។ កងសន្តិសុខបានប្រាប់អ្នកទោសថា បញ្ជូនពួកគេទៅសហករណ៍[2219]។ អ្នកទោសផ្សេងទៀត មិនបានឮសម្រែករបស់អ្នកទោសដែលកំពុងត្រូវបានគេសម្លាប់ទេ ដោយសារផ្គង់នឹងសំលេងមេក្រូ[2220]។ អតីតអ្នកទោសម្នាក់ត្រូវបានប្រាប់កុំឲ្យប្រាប់អ្នកទោសដទៃទៀតថា អ្នកទោសត្រូវបានសម្លាប់[2221]។

៥១២. សាក្សីជាច្រើនដែលអ្នកស៊ើបអង្កេតបានស្ដាប់ចម្លើយបានបញ្ជាក់ថា ខ្លួនបានឃើញការសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ឬឃើញសាកសពជនរងគ្រោះ[2222]។ ជនរងគ្រោះត្រូវបានសម្លាប់នៅឯកន្លែងជាច្រើនទាំងក្នុង និងក្រៅមន្ទីរសន្តិសុខក្រាំងតាចាន់រួមទាំង នៅក្នុងអគារឃុំឃាំង កន្លែងសួរយកចម្លើយ និងនៅទីតាំងរណ្ដៅសព ដែលជនរងគ្រោះត្រូវបានបង្ខំឲ្យជីកទុកជាមុន មុនពេលយកទៅសម្លាប់[2223]។ សាក្សីម្នាក់បានឲ្យដឹងថា ពេលដែលគេឲ្យយកដើមដូងទៅដាំ ពេលខ្លះគាត់កាប់ដីប៉ះចំខ្មោចដែលគេកប់[2224]។

៥១៣. សាក្សីបីរូប បានរៀបរាប់យ៉ាងលម្អិតអំពីការបានឃើញការសម្លាប់ដែលកើតមានឡើង។ អ្នកទោសត្រូវបានគេចងមុខ ហើយវាយកញ្ចឹងក នឹងស្នាយកាំភ្លើង ញ្ញាវទេះ ឬចបជីក។ នៅពេលដែលអ្នកទោសដួល គេបានប្រើប្រាស់ដាវ ដើម្បីអារបំពង់កបន្ថែម។ ក្មេងត្រូវបានសម្លាប់ ដោយបោកក្បាល វាយផ្ទប់នឹងគល់ឈើ[2225]។

៥១៤. សាកសពជនរងគ្រោះ ត្រូវបានកប់ក្នុង ឬជុំវិញមន្ទីរសន្តិសុខក្រាំងតាចាន់[2226]។ អ្នកដែលនឹងត្រូវសម្លាប់ ត្រូវរជីករណ្តៅដោយខ្លួនឯង ឬជីកដោយអ្នកទោសដទៃទៀត[2227]។ ពេលខ្លះអ្នកទោសម្នាក់ត្រូវបានបង្ខំឲ្យជីករណ្តៅ១ ឬ២ មានបណ្តោយ៣ ម៉ែត្រ និងជម្រៅ១ ម៉ែត្រកន្លះក្នុងមួយថ្ងៃ។ រណ្តៅនិមួយៗ អាចដាក់សាកសពពី៣០ ទៅ ៦០ នាក់។ សាក្សីម្នាក់ជាអតីតប្រធានឃុំនៅឆ្នាំ១៩៧៩ បានចូលរួមក្នុងការគាស់សាកសពនៅលើទីតាំងនេះ[2228]។ គាត់បានបញ្ជាក់ថារណ្តៅចំនួន៨ ត្រូវបានគាស់ដែលមាន លលាដ៍ក្បាលចំនួន១០.០៤៥ ត្រូវបានរកឃើញ។ គាត់បាននិយាយបន្ថែមថា រណ្តៅសាកសពដទៃជាច្រើនទៀតមិនទាន់ត្រូវបានគាស់នៅឡើយ[2229]។ សាក្សីដទៃទៀតបាននិយាយថា មានលលាដ៍ក្បាលចំនួនប្រហែល១៧.០០០ ត្រូវបានរកឃើញ[2230]។ របាយការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យដែលផ្ញើពីប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់ទៅស្រុកបានរាយការណ៍ថា រហូតមកដល់ថ្ងៃនៃរបាយការណ៍ (មិនមានបញ្ជាក់ពីកាលបរិច្ឆេទ) បានកម្ទេចខ្មាំងចំនួន ១៥.០០០នាក់។តួលេខនេះបង្ហាញថា ចំនួនសរុបនៃអ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់អាចមានច្រើនជាងចំនួនលលាដ៍ក្បាលដែលត្រូវបានរកឃើញ[2231]។

***

៥១៥. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន**១១**នាក់ **(ដប់មួយនាក់)** ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់[2232]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤)។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

### មន្ទីរសន្តិសុខ កោះខ្យង[2233]

### ទីតាំង និង ការបង្កើត

៥១៦. យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខកោះខ្យងមានទីតាំងស្ថិតនៅភូមិកោះខ្យង ស្រុកព្រៃនប់ តំបន់៣៧ នៃភូមិភាគបស្ចិម ដែលបច្ចុប្បន្ន


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

នេះជា ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ[2234]។ មន្ទីរសន្តិសុខកោះខ្យងដំណើរការជាមន្ទីរសន្តិសុខរបស់តំបន់៣៧ ផង[2235] និងភូមិភាគបស្ចិមផង[2236]។ មន្ទីរសន្តិសុខនេះទំនងជាចាប់ដំណើរការនៅក្នុងឆ្នាំ១៩៧៦[2237]។

**៥១៧.** មន្ទីរសន្តិសុខកោះខ្យង ត្រូវបានបែងចែកជាបីកន្លែងខុសៗគ្នា[2238]។ ទីតាំងទីមួយ មានផ្ទះមួយសម្រាប់ដាក់អ្នកទោសដែលមានទំហំសែសិបម៉ែត្រ គុណ ប្រាំមួយម៉ែត្រ ផ្ទះសម្រាប់កងសន្តិសុខមួយ និងមូលដ្ឋានកងទ័ពវរៈសេនាធំនៃតំបន់៣៧[2239]។ ទីតាំងទីពីរ ជាកន្លែងសំរាប់សួរចម្លើយអ្នកទោស[2240]។ រីឯទីតាំងទីបី គឺជាកន្លែងការដ្ឋាន[2241] ដែលរួមមានអាគារអ្នកទោសពីរ និងផ្ទះបាយមួយ[2242]។

### ដំណើរការប្រព្រឹត្តទៅ

**រចនាសម្ព័ន្ធគ្រប់គ្រង និង បុគ្គលិក**

**៥១៨.** នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាម តំបន់៣៧ នៃភូមិភាគបស្ចិមស្ថិតក្រោមការគ្រប់គ្រងរបស់ [លុប] [លុប][2243](ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នាខែធ្នូ ឆ្នាំ១៩៧៦)[2244] ហើយ វ៉ន ជាអនុលេខា[2245]។ ចាប់ពីចុងឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ១៩៧៧ នៅភូមិភាគបស្ចិម ជាពិសេសតំបន់៣៧ មានការបោសសម្អាត "សកម្មភាពក្បត់" ដែលឈានទៅដល់ការចាប់ខ្លួនកម្មាភិបាលជាច្រើនរូប[2246]។ ចំណុចនេះក៏ស៊ីសង្វាក់គ្នាផងដែរ ជាមួយនឹងរបាយការណ៍ស្តីពីសកម្មភាពតាមភូមិភាគនានា[2247]។ ក្រោយមកលេខាថ្មីរបស់តំបន់៣៧ គឺឈ្មោះ [លុប] និងអនុលេខាគឺ [លុប][2248]។ លេខានៃស្រុកព្រៃនប់ឈ្មោះ [លុប] ដែលត្រូវចាប់នាឆ្នាំ១៩៧៧ និងឃុំខ្លួននៅកោះខ្យង[2249]។

**៥១៩.** ក្នុងអំឡុងពេលបោសសំអាតក្នុងឆ្នាំ១៩៧៧ តំបន់៣៧ត្រូវបានគ្រប់គ្រងដោយកងទ័ពមកពីកងពលលេខ១ នៃភូមិភាគបស្ចិម ហើយកងទ័ពមកពីខេត្តកំពង់ឆ្នាំងបានមកគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន និងបានរំសាយអង្គភាពកងទ័ពមូលដ្ឋានចាស់ចោល[2250]។ កោះខ្យង នៅពេលនោះនៅតែជាមន្ទីរសន្តិសុខតំបន់៣៧ ដដែល[2251] និងត្រូវបានគ្រប់គ្រងផ្ទាល់ដោយកងទ័ព[2252] ក្រោមការបញ្ជារបស់ឈ្មោះ **សឿង** (ស្លាប់) ហើយក្រោយមកឈ្មោះ ផល[2253]។

**៥២០.** ប្រធានមន្ទីរសន្តិសុខកោះខ្យងឈ្មោះ **វឿន** ហៅ **សាវឿន**[2254](ស្លាប់)។ [លុប] ជាអនុប្រធាន

ទទួលខុសត្រូវលើកិច្ចប្រតិបត្តិការនានារបស់មន្ទីរសន្តិសុខ[2255]។ នៅពេលដែល វឿន ធ្វើអត្តឃាតសម្លាប់ខ្លួន [លុប]បានឡើងធ្វើជាប្រធាន[2256]។ ដោយសរុបមានកម្មាភិបាលពី២០ ទៅ៣០ នាក់ ដែលធ្វើការនៅមន្ទីរសន្តិសុខកោះខ្យង[2257]។

### ការចាប់ខ្លួន និង ការឃុំខ្លួន

៩២១. អ្នកទោសនៅកោះខ្យងត្រូវបានបញ្ជូនមកពីគ្រប់ទីកន្លែងនៃតំបន់៣៧ ដូចជា៖ កំពង់សោម កោះកុង និងមួយផ្នែកនៃខេត្តកំពត ស្រុកព្រៃនប់ និងភូមិស្រែអំបិល [2258]។

៩២២. ជាទូទៅ អ្នកទោសទាំងនេះត្រូវបានកងទ័ពនៅក្នុងកងពលទី១ជាអ្នកចាប់បញ្ជូនមក[2259]។ លើសពីនោះទៅទៀត នៅក្នុងកងពលនេះមានកងពិសេសមួយជាអ្នកស៊ើបអង្កេតប្រវត្តិរូបនៃកងទ័ពរបស់ខ្លួន[2260]។

៩២៣. "ប្រជាជនចាស់" និង"ប្រជាជនថ្មី" ត្រូវគេដាក់ឃុំនៅកោះខ្យង[2261]។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៧ អ្នកទោសភាគច្រើនដែលបាននាំមកមន្ទីរសន្តិសុខជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង ចំណែកឯអ្នកទោសជាប្រជាជនថ្មី ត្រូវបានសម្លាប់ចោលរួចអស់ទៅហើយ[2262]។

៩២៤. អ្នកទោសមានពីរប្រភេទគឺ អ្នកទោសធ្ងន់ និងអ្នកទោសស្រាល។ អ្នកទោសធ្ងន់ ត្រូវគេឃុំដោយចោទថាក្បត់ មានដូចជា៖ អតីតកម្មាភិបាលបក្ស អតីតទាហាន លន់ នល់ ឬជនដែលបានសារភាពថាខ្លួនមានទំនាក់ទំនងជាមួយសេអ៊ីអា[2263]។ អ្នកទោសស្រាល គឺជាជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថា បានលួចឬប្លន់អាហារ ខ្ជិលធ្វើការ ឬមាន"សីលធម៌មិនល្អ"[2264]។

៩២៥. ជាទូទៅ មានអ្នកទោសពី១០០ ទៅ២០០ នាក់ ដែលបានជាប់ឃុំឃាំងនៅកោះខ្យង[2265]។ អ្នកទោសមានទាំងបុរស ស្ត្រី និងកុមារ ដែលត្រូវបានដាក់ឲ្យនៅផ្ទះដាច់ដោយឡែកពីគ្នា[2266]។ មានកុមារខ្លះកើតនៅក្នុងគុក[2267] ខ្លះទៀតត្រូវបានចាប់បញ្ជូនមកជាមួយឪពុកម្តាយរបស់គេ[2268] ឬមួយចំនួនទៀតត្រូវបានចាប់ខ្លួន នៅពេលដែលលួចស្កាត់មកលេងជាមួយឪពុកម្តាយក្នុងពេលកំពុងជាប់គុក[2269]។

៩២៦. ពេលមកដល់កោះខ្យង អ្នកទោសត្រូវដាក់ខ្នោះតម្រៀបគ្នាជាជួរ[2270]។ អ្នកទោសស្រាលត្រូវបានដោះ

00605428



ខ្នោះចេញ ដើម្បីទៅធ្វើការនៅពេលព្រឹក តែដាក់ខ្នោះវិញនៅពេលល្ងាច[2271]។ អ្នកទោសធ្ងន់ គេដាក់ខ្នោះទាំងថ្ងៃទាំងយប់ រហូតដល់ថ្ងៃដែលគេយកទៅសម្លាប់[2272]។

**៥២៧.** ស្ថានភាពរស់នៅក្នុងមន្ទីរសន្តិសុខកោះខ្សែងមានសភាពវេទនាណាស់៖ សាក្សីជាច្រើនបញ្ជាក់ថា អ្នកទោសគេឱ្យដេកលើលាមកខ្លួនឯង មិនឱ្យងូតទឹក និងដេកគ្មានមុងធ្វើឱ្យមូសខាំសុសខ្លួន ការផ្តល់ម្ហូបអាហារដល់អ្នកទោសមិនគ្រប់គ្រាន់ ។ល។[2273] មានសាក្សីម្នាក់អះអាងថា អ្នកទោសមិនបានទទួលអាហារនិងទឹកទាល់តែសោះ ក្នុងរយៈពេលដប់ថ្ងៃដំបូងនៃការឃុំឃាំង[2274]។ ជារៀងរាល់សប្តាហ៍ អ្នកទោសជាពិសេសស្ត្រី និងកុមារ ស្លាប់ដោយសារអត់អាហារ[2275]។ អ្នកទោសស្រាល តែងតែទទួលរបបអាហារច្រើនជាងអ្នកទោសធ្ងន់[2276]។ អ្នកទោសទាំងអស់ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងគុក និងបរិវេណជុំវិញគុកដូចជា៖ ជីកប្រឡាយ ជីករណ្តៅសាកសព ធ្វើស្រែ និងស្រោចទឹកដំណាំ[2277]។ ការព្យាបាលអ្នកជម្ងឺនៅឯមន្ទីរសន្តិសុខកោះខ្សែងគឺគ្មាន ដែលជាហេតុបណ្តាលឱ្យអ្នកទោសយ៉ាងច្រើនស្លាប់ ដោយជម្ងឺ ហេវហត់អស់កម្លាំង និងធ្វើការហួសកម្លាំង[2278]។

<u>ការសួរចម្លើយ</u>

**៥២៨.** តាមធម្មតា ការសួរចម្លើយអ្នកទោសធ្វើនៅក្រៅគុក ឬនៅកន្លែងសួរចម្លើយណាមួយ ដែលបានបម្រុងទុក[2279]។ អ្នកទោសត្រូវបានយកមកសួរអំពីប្រវត្តិរូប មូលហេតុនៃការចាប់ខ្លួន និងត្រូវបានចោទជាសមាជិកសេអ៊ីអា ឬបានគាំទ្រដល់របប លន់ នល់[2280]។ អតីតអ្នកទោសនៅកោះខ្សែងបានរំលឹកឱ្យដឹងថា ចម្លើយសារភាពត្រូវគេកត់ត្រាទុក[2281]។ សាក្សីម្នាក់បានអះអាងថា *"រៀងរាល់បីឬបួនថ្ងៃម្តង គេយកឯកសារទៅថ្នាក់លើ ហើយឯកសារទាំងនេះត្រូវគេបញ្ជូនត្រឡប់មកវិញ គេយកមនុស្សទៅសម្លាប់ម្តងៗចំនួនដប់ឬម្ភៃ"*[2282]។

**៥២៩.** ការសួរចម្លើយភាគច្រើនមានការធ្វើទារុណកម្មយ៉ាងសាហាវដូចជា៖ វាយដំ យកកៅស៊ូប្លាស្ទិករុំក្បាលរហូតដល់ថប់ដង្ហើម ឬឆក់ខ្សែភ្លើងជាដើម [2283] ដែលជាហេតុបណ្តាលឱ្យអ្នកទោសមួយចំនួនស្លាប់ក្នុងអំឡុងពេលសួរចម្លើយ[2284]។ អ្នកទោសស្រីម្នាក់បាននិយាយថា សន្តិសុខម្នាក់បានស្ទាបដោះ និងប្រដាប់ភេទរបស់គាត់ ស្រាតខោអាវ ដើម្បីពិនិត្យមើលរាងកាយរបស់គាត់ ហើយមានកងទ័ពម្នាក់ទៀតកំពុងឈរមើល[2285]។ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩ គេប្រទះឃើញខ្នោះធ្វើពីដែក និងម៉ាស៊ីនភ្លើងនៅសេសសល់ នៅឯមន្ទីរសន្តិសុខកោះខ្សែង[2286]។

<u>ការសម្លាប់</u>

៩៣០. អ្នកទោសធ្ងន់ត្រូវបានគេយកទៅសម្លាប់បន្ទាប់ពីឃុំឃាំងរយៈពេល២ ឬ៣ ថ្ងៃ ប៉ុណ្ណោះ[2287] ឬដូច ដែលអ្នកទោសម្នាក់និយាយថា *"អ្នកដែលគេត្រូវយកទៅសម្លាប់ គេហៅទៅភ្នាម"*[2288]។ សាក្សីខ្លះ ផ្សេងទៀតបានអះអាងថា មានអ្នកទោសផ្សេងទៀតបានបាត់ខ្លួន ហើយពុំដែលឃើញត្រឡប់ មកវិញនោះឡើយ[2289]។ សាក្សីមួយចំនួនបានរាយការណ៍ថា អ្នកទោសឈឺត្រូវបានបញ្ជូនទៅ "មន្ទីរពេទ្យ" ប៉ុន្តែមិនដែលឃើញត្រឡប់មកវិញនោះទេ គឺត្រូវបានគេសម្លាប់ចោល[2290]។ កម្មាភិបាលរបស់បក្សដែលត្រូវឃុំខ្លួននៅកោះខ្យងជាអាទិ៍មានដូចជា៖ ប្រធានសហករណ៍ និង មេកងដែលសុទ្ធតែត្រូវបានចោទថាក្បត់ ហើយត្រូវយកទៅសម្លាប់ ឬបាត់ខ្លួន[2291]។ សាក្សីម្នាក់បាន បញ្ជាក់ថា ជនជាតិវៀតណាមត្រូវបានចាប់ខ្លួន បញ្ជូនទៅកោះខ្យង និងសម្លាប់ចោល[2292]។

៩៣១. ការសម្លាប់ជារឿយៗ ត្រូវបានធ្វើឡើងនៅចំពោះមុខអ្នកទោសដទៃទៀត ដើម្បីធ្វើឱ្យមានការភ័យ ខ្លាចដល់អ្នកទោស កុំឱ្យលួចរត់ ឬប្រព្រឹត្តអ្វីមួយខុសឆ្គង[2293]។ វិធីសម្លាប់មានដូចជា វាយអ្នកទោស រហូតដល់ស្លាប់ កាប់នឹងពូថៅ ចងអ្នកទោសភ្ជាប់គ្នា (ជួនកាលមានទាំងគ្រួសារ) រួចច្រមុជចូលក្នុង អណ្តូងទឹក ឬបោះទម្លាក់ចូលក្នុងអណ្តូងតែម្តង[2294]។ ជាងនេះទៅទៀត អ្នកទោសខ្លះត្រូវគេវះពោះ យកថ្លើមប្រម៉ាត់ ដើម្បីព្រមានដល់អ្នកទោសផ្សេងៗទៀត[2295]។ សាក្សីមួយចំនួនបានឃើញគេយក ថ្លើម និងប្រម៉ាត់មនុស្សទៅព្យួរហាលនឹងដើមស្នាច់ធំមួយដើម ក្នុងបរិវេណមន្ទីរសន្តិសុខ[2296]។ យោងតាមសាក្សីម្នាក់ គាត់បានឃើញកងទ័ពម្នាក់ យកប្រម៉ាត់មនុស្សទៅត្រាំស្រាជីក និង ស៊ីថ្លើម មនុស្សតែម្តង[2297]។ ចំពោះក្មេងៗក៏ត្រូវបានសម្លាប់ផងដែរ ប្រសិនបើពួកគេចង់លួចរត់ ឬស្កាត់ទៅ លេងជាមួយឪពុកម្តាយ[2298]។

៩៣២. សាក្សីមួយចំនួនដែលបានជាប់ឃុំឃាំង បានឃើញរណ្តៅសាកសពនៅក្នុងបរិវេណគុក មាននៅ ក្រោមដើមដូង និងដើមស្វាយ[2299]។ សាក្សីក៏ឃើញរណ្តៅថ្មីៗដែលគេកប់សាកសពដើម្បីធ្វើជី និង បានចាប់អារម្មណ៍ថា មានធុំក្លិនស្អុយចេញពីដី[2300]។ សាក្សីម្នាក់ដែលជាប់ឃុំ ក្នុងឆ្នាំ១៩៧៧ ត្រូវបានគេបញ្ជាឱ្យគាត់គាស់រណ្តៅសពរួមមួយយកសាកសពទៅកប់នៅក្នុងរណ្តៅមួយផ្សេងទៀត ដោយសារមានការព្រួយបារម្ភថា ទឹកដែលជ្រាបចេញពីសាកសព នឹងហូរចូលទៅក្នុងអណ្តូង ដែលនៅក្បែរនោះ[2301]។ សាក្សីរូបនេះនិងសាក្សីខ្លះទៀត ត្រូវបានប្រើឱ្យជីករណ្តៅចំនួនបី ឬបួនមុន នឹងការសម្លាប់កើតឡើង[2302]។

៩៣៣. សាក្សីម្នាក់ដែលរស់នៅក្បែរមន្ទីរសន្តិសុខកោះខ្សង បានចូលក្នុងបរិវេណគុកកោះខ្សង ក្នុងឆ្នាំ១៩៧៩ ដើម្បីស្រាយចំណងអ្នកទោស និងដើររកឪពុកម្តាយរបស់គាត់ បានអះអាងថា នៅពេលនោះ មានអ្នករកមាសបានគាស់កកាយរណ្តៅសាកសពដើម្បីរកមាស ហើយបានឃើញលលាដ៍ក្បាល និងឆ្អឹងមនុស្សជាច្រើននៅទីនោះ[2303]។ គណៈកម្មាធិការវត្តបានប្រមូលធាតុមនុស្សប្រមាណជាង ២០០នាក់ ចេញពីរណ្តៅសពចំនួន២ ឬ៣ ហើយយកទៅដាក់នៅវត្តអូរជ្រៅ។ គាត់សន្និដ្ឋានថា ចំនួនអ្នកទោសសរុបដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខកោះខ្សងមានចំនួនប្រមាណ ១.០០០នាក់[2304]។

***

៩៣៤. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៣៦នាក់ (សាមសិបប្រាំមួយនាក់)** ត្រូវបានប្រកាសទទួលស្គាល់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខកោះខ្សង[2305]។ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤) ។ ដើម បណ្តឹងរដ្ឋប្បវេណីទាំងនេះបាន ផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមក ពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខកោះខ្សង។

### មន្ទីរសន្តិសុខព្រៃដំរីស្រុត[2306]

#### ទីតាំង និងការបង្កើត

៩៣៥. មន្ទីរសន្តិសុខព្រៃដំរីស្រុតមានទីតាំងស្ថិតនៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ (ជា អតីត ស្រុកកំពង់ត្រឡាចលើ) ខេត្តកំពង់ឆ្នាំង។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាល របស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខនេះជាមន្ទីរសន្តិសុខរបស់ស្រុក១២ ដែលស្ថិតនៅតំបន់៣១ ក្នុងភូមិភាគបស្ចិម (ភូមិភាគ៤០១)។ មន្ទីរសន្តិសុខព្រៃដំរីស្រុត ស្ថិតនៅចម្ងាយប្រហែល ២.៥០ គីឡូម៉ែត្រពីភូមិ ដែលឥឡូវនេះទីតាំងនោះបានក្លាយទៅជាព្រៃទៅហើយ។ កត្តាពេលវេលាបានធ្វើឱ្យ ទីតាំងនេះមិនមានបន្សល់ទុកនូវបំណែកអគារ ដែលអាចឱ្យយើងមើលឃើញបានឡើយ។ បរិវេណ មន្ទីរសន្តិសុខព្រៃដំរីស្រុតមានទទឹងប្រវែងប្រហែល១០០ ម៉ែត្រ និងបណ្តោយប្រហែល១៥០


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605431



ម៉ែត្រ[2307]។ មន្ទីរនេះត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧[2308] និងបានដំណើរការរហូតដល់របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ[2309]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក**

**៩៣៦.** ប្រធានមន្ទីរសន្តិសុខព្រៃដំរីស្រុតឈ្មោះ [លុប] ជាមេបញ្ជាការកងអនុសេនាតូច៤០៣ នៃកងអនុសេនាធំ៣០៨[2310]។ ថ្នាក់ដឹកនាំមន្ទីរសន្តិសុខនេះរួមមាន សួន (ស្លាប់)[2311] សឿន (ស្លាប់)[2312] និង [លុប][2313] (សាក្សីរូបនេះបានបដិសេធនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ថាមិនមានការពាក់ព័ន្ធឡើយ)[2314]។ អ្នកធ្វើការទាំងអស់នៅមន្ទីរសន្តិសុខព្រៃដំរីស្រុតនេះសុទ្ធតែជាកងទ័ពវ័យក្មេងដែលមកពីកងអនុសេនាតូច៤០៣[2315]។ អតីតកងសន្តិសុខមន្ទីរនេះ បាននិយាយប្រាប់ថា ថ្នាក់ដឹកនាំមន្ទីរសន្តិសុខបានពន្យល់ប្រាប់ពួកគេឲ្យអនុវត្តន៍តាមបញ្ជា បើមិនដូច្នោះទេពួកគេនឹងត្រូវបានចោទថា ជាខ្មាំង។ ប្រធានមន្ទីរសន្តិសុខ បានប្រកាសតាមឧឃោសនៈស័ព្ទថា បញ្ជានោះចេញមកពីអង្គការដែលតម្រូវឲ្យកម្ចាត់អ្នកក្បត់ទាំងអស់ដូចជា៖ គិញ សេអ៊ីអា និងអ្នកណាដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម និងខ្មែរស[2316]។ នៅមន្ទីរសន្តិសុខព្រៃដំរីស្រុត [លុប], [លុប] និង [លុប] ជាអ្នកទទួលបន្ទុកគ្រប់គ្រងអ្នកទោស បញ្ជូនរបាយការណ៍ ព្រមទាំងកត់ត្រាចម្លើយសារភាពរបស់អ្នកទោស[2317] ឲ្យប្រធានមន្ទីរសន្តិសុខព្រៃដំរីស្រុត[2318]។

**៩៣៧.** មន្ទីរសន្តិសុខព្រៃដំរីស្រុត ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការស្រុក១២ ដោយត្រូវរាយការណ៍ឲ្យគណៈស្រុកតាមរយៈយោធាស្រុក។ [លុប] ជាលេខាស្រុក ១២ ដែលក្រោយមកគាត់ត្រូវបានតែងតាំងទៅថ្នាក់តំបន់ ហើយ តំណែងគាត់ត្រូវជំនួសដោយ គឿន (ស្លាប់)[2319]។ យោងតាម [លុប] បញ្ជាក់ថា [លុប] ជាមេបញ្ជាការកងអនុសេនាធំ៣០៨ ដែលទទួលបន្ទុកព្រៃដំរីស្រុត ក៏ប៉ុន្តែ យិន ផេង បានបញ្ជាក់ថា គាត់ត្រូវបានដកចេញពីអង្គភាពកងទ័ពដោយលេខាស្រុក១២ មុនពេលបង្កើតមន្ទីរសន្តិសុខព្រៃដំរីស្រុតនេះ[2320]។ សារុន (ស្លាប់) ជាលេខាគណៈតំបន់១៣ ហើយក្រោយមកត្រូវបានជំនួសដោយ [លុប][2321]។ ថ្នាក់ដឹកនាំមន្ទីរសន្តិសុខព្រៃដំរីស្រុត ព្រមទាំងកម្មាភិបាលឯទៀតដែលបានធ្វើការនៅទីនោះបានចូលរួមប្រជុំ និងចូលរួមរៀនសូត្រទាំងនៅថ្នាក់ស្រុកនិងថ្នាក់តំបន់៣១[2322]។ [លុប] បានបញ្ជាក់ថា គាត់បានចូលរួមរៀនសូត្រ នៅថ្នាក់ស្រុកនិងថ្នាក់តំបន់ ដែលវគ្គរៀនសូត្រខ្លះដឹកនាំដោយ [លុប] ជាលេខាតំបន់៣១។ វគ្គរៀនសូត្រទាំងនេះបាននិយាយពីកិច្ចការកងទ័ព ការផលិតស្រូវ និងនិយាយ

អំពីកំហុសរបស់អ្នកទោស[2323]។

៩៣៨. តំបន់៣១ ជាផ្នែកមួយនៃភូមិភាគបស្ចិម(៤០១) ដែលមានលេខាឈ្មោះ ជូ ជេត ហៅ ស៊ី រហូតដល់ការចាប់ខ្លួនគាត់ក្នុងខែមិនា ឆ្នាំ១៩៧៨[2324]។ គណៈភូមិភាគបស្ចិម បានរាយការណ៍ជាទៀងទាត់ជូនមន្ទីរ៨៧០ អំពីស្ថានភាពខ្មាំងខាងក្នុង និងខាងក្រៅ ជាពិសេសស្ថានភាពក្នុងតំបន់៣១[2325]។ មជ្ឈិមបក្សបានណែនាំមេដឹកនាំភូមិភាគ តំបន់ និងស្រុករបស់ភូមិភាគបស្ចិម ជាពិសេសនៅក្នុងសន្និបាតភូមិភាគក្នុងឆ្នាំ១៩៧៧ អំពីគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជា ដែលត្រូវអនុវត្តក្នុងភូមិភាគទាក់ទិនជាមួយខ្មាំង។ ស្រុក១២ ត្រូវបានចាត់ថាជាស្រុកគំរូនៃបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា[2326]។

៩៣៩. [លុប] បានពន្យល់ថា គាត់បានផ្ញើររបាយការណ៍ និងចម្លើយសារភាព ឲ្យមេបញ្ជាការកងទ័ពរបស់គាត់ ព្រមទាំងឲ្យគណៈស្រុកផងដែរ[2327]។ សាក្សីមួយចំនួនបានបញ្ជាក់ថា គណៈស្រុកមានអំណាចគ្រប់គ្រងលើមន្ទីរសន្តិសុខព្រៃដំរីស្រុត[2328]។ គណៈស្រុកមានសិទ្ធិ សម្រេចថាអ្នកណាម្នាក់ត្រូវចាប់ខ្លួនដោយផ្អែកតាមរបាយការណ៍ដែលផ្ញើពីភូមិ និងពីគណៈឃុំ(មានដូចជាឃុំឈូកស, ឃុំស្វាយជុក, ឃុំត្បែងខ្ពស់, ឃុំពាម, និងឃុំផ្កាកវៀន)។ បន្ទាប់មកអ្នកទោសត្រូវបានចាប់ខ្លួនដោយឈ្លបស្រុក និងបញ្ជូនទៅមន្ទីរសន្តិសុខព្រៃដំរីស្រុត ព្រមជាមួយនឹងរបាយការណ៍ដែលបង្ហាញពីកំហុសដែលអ្នកទោសបានប្រព្រឹត្ត[2329]។ ប្រធានមន្ទីរសន្តិសុខព្រៃដំរីស្រុតបានប្រាប់ថា ក្នុងឆ្នាំ១៩៧៧ គាត់បានទទួលសំបុត្រមួយពីលេខាស្រុកឈ្មោះ គឿន បញ្ជាឲ្យសម្លាប់មនុស្សម្នាក់ឈ្មោះ ផាន់ ជាអតីតស្នងការនយោបាយ ដោយសារតែគាត់ត្រូវបានចោទថាជាវៀតណាម[2330]។ អតីតកម្មាភិបាលបានរៀបរាប់ថា ការសម្រេចឲ្យសម្លាប់អ្នកទោសគឺចេញមកពី“អង្គការ” ឬ ពី“ថ្នាក់លើ” ក៏ប៉ុន្តែពួកគាត់មិនបានដឹងថា ការសម្រេចនោះចេញមកពីកម្រិតថ្នាក់ណាពិតប្រាកដទេ[2331]។

៩៤០. កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ថ្នាក់ស្រុក និងថ្នាក់តំបន់ ដូចជា៖ [លុប] លេខាគណៈតំបន់៣១[2332] ព្រមទាំងមេបញ្ជាការយោធាតំបន់៣១ ឈ្មោះ [លុប] បានមកពិនិត្យមន្ទីរសន្តិសុខព្រៃដំរីស្រុត[2333]។ មិនមានភស្តុតាងបញ្ជាក់ថា ជនត្រូវចោទបានមកពិនិត្យមន្ទីរសន្តិសុខព្រៃដំរីស្រុតឡើយ[2334]។

ការចាប់ខ្លួន និង ការឃុំខ្លួន

៥៤១. បុរស ស្ត្រី និងកុមារ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខព្រៃដំរីស្រុត[2335]។ មានសាក្សីចំនួនបួននាក់ដែលយើងបានស្តាប់ចម្លើយ ធ្លាប់ជាប់ឃុំនៅមន្ទីរសន្តិសុខនេះ[2336]។ អ្នកជាប់ឃុំទាំងនោះមានដូចជា៖ ប្រជាជនដែលគេជម្លៀសមកពីភ្នំពេញមកស្រុក១២[2337] អ្នកដែលគេចោទថាជាអតីតទាហានឬអ្នករដ្ឋការរបប លន់ នល់[2338] កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង[2339] ប្រជាជនមូលដ្ឋាន ដែលនៅឃុំក្បែរៗនោះ[2340] ព្រមទាំងអ្នកជាប់ខ្សែជាតិពន្ធុវៀតណាម[2341]។ យោងតាមការបញ្ជាក់របស់ [លុប] ចំនួនអ្នកទោសច្រើនបំផុតមានប្រហែល១០នាក់ប៉ុណ្ណោះ ដែលជាប់ឃុំនៅមន្ទីរសន្តិសុខព្រៃដំរីស្រុតក្នុងមួយពេលៗ[2342] ប៉ុន្តែតាមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីផ្សេងៗបានបង្ហាញថា មានអ្នកទោសពី៣០ ទៅ ៥០ នាក់ត្រូវបានគេឃុំនៅមន្ទីរសន្តិសុខនេះ ក្នុងមួយពេលៗ[2343]។

៥៤២. អ្នកទោសខ្លះត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខនៃឃុំដទៃៗទៀត មកកាន់មន្ទីរសន្តិសុខព្រៃដំរីស្រុត[2344] ខណៈដែលអ្នកទោសខ្លះទៀត ដែលចាប់ខ្លួនដោយកងឈ្លបស្រុក ត្រូវបញ្ជូនមកមន្ទីរសន្តិសុខព្រៃដំរីស្រុតដោយផ្ទាល់តែម្តង[2345]។ អតីតអ្នកជាប់ឃុំ និងកងសន្តិសុខ បាននិយាយថា អ្នកទោសត្រូវបានបណ្តើរមកមន្ទីរសន្តិសុខនេះ ដោយដៃជាប់ចំណងស្ពាយសេក[2346]។ សាក្សីបានឲ្យដឹងថា អ្នកដែលគេចាប់ខ្លួនទាំងនោះ ដោយសារតែគេចោទថា ខុសសីលធម៌[2347] ជាខ្មាំងនយោបាយ[2348] ឬមានកំហុសតូចតាចដូចជា លួចម្ហូបអាហារហូបជាដើម[2349]។ ក្នុងអំឡុងពេលជាប់ឃុំនៅទីនោះ អ្នកទោសត្រូវគេបែងចែកជាអ្នកទោសស្រាល ឬអ្នកទោសធ្ងន់ទៅតាមកំហុសដែលពួកគេបានប្រព្រឹត្ត ហើយលក្ខខណ្ឌនៃការដាក់ទោសក៏អាស្រ័យលើកំហុសស្រាល ឬធ្ងន់នោះដែរ [2350]។

៥៤៣. អគារដែលដាក់អ្នកទោសគឺរោងវែងមួយ ដែលមានដំបូលប្រក់ស្លឹកត្នោត ហើយអ្នកទោសត្រូវដេកលើគ្រែឈើវែងដែលធ្វើជាពីរជួរដោយទុកចន្លោះដើរនៅកណ្តាល[2351]។ បុរស ស្ត្រី និងកុមារ ជាប់ឃុំទាំងអស់គ្នានៅក្នុងរោងតែមួយ[2352]។ អ្នកទោសត្រូវស្ថិតនៅក្រោមការឃាមកាមដ៏តឹងរឹង[2353] ដោយជើងជាប់ខ្នោះ និងមិនអនុញ្ញាតឲ្យដើររហេតរហូតឡើយ[2354]។ សាក្សីបាននិយាយថា មិនមានអាហារហូបគ្រប់គ្រាន់ទេ ដូច្នេះហើយបានជាបណ្តាលឲ្យអ្នកទោសមួយចំនួន មានរូបរាងកាយស្គមស្គាំង[2355]។ អតីតកងសន្តិសុខ និងអតីតអ្នកទោសបានបញ្ជាក់ថា មានអ្នកទោសជាច្រើនបានស្លាប់ដោយសារតែអត់អាហារ មានជម្ងឺដម្កាត់ ឬដោយសារតែធ្វើការហួសកម្លាំង[2356]។ ប៉ុន្តែ

មានពេទ្យកងទ័ពម្នាក់បានមកពិនិត្យមើលអ្នកទោសជាប្រចាំផងដែរ[2357]។

៥៤៤. យោងតាមការបញ្ជាក់របស់ [លុប] ព្រមទាំងសាក្សីម្នាក់ទៀត មានតែអ្នកទោសស្រាលប៉ុណ្ណោះ ដែលត្រូវដោះលែងឲ្យធ្វើការងារនៅពេលថ្ងៃ[2358] ប៉ុន្តែ អតីតកងសន្តិសុខ និងអតីតអ្នកទោសនៅមន្ទីរសន្តិសុខព្រៃដំរីស្រុតបាននិយាយថា អ្នកទោសទាំងអស់ត្រូវបានតម្រូវឲ្យធ្វើការ ដោយអ្នកទោសធ្ងន់ត្រូវធ្វើការទាំងជាប់ច្រវាក់ ចំណែកឯអ្នកទោសស្រាលត្រូវធ្វើការដោយមានកងសន្តិសុខចាំត្រួតពិនិត្យ[2359]។ អ្នកទោសត្រូវធ្វើការទាំងក្នុងនិងក្រៅបរិវេណមន្ទីរសន្តិសុខនេះ ដូចជាលើកទំនប់ និងជីកប្រឡាយ[2360]។ ការងារប្រចាំថ្ងៃរបស់ពួកគេចាប់ផ្តើមពីម៉ោង៦ ដល់ម៉ោង១១ ព្រឹក និងពីម៉ោង ១ ដល់ម៉ោង ៥ ល្ងាច ហើយ ពេលខ្លះត្រូវធ្វើការនៅពេលយប់ផងដែរ[2361]។ កងសន្តិសុខបានវាយ និងធ្វើបាបអ្នកទោស ដែលពេលខ្លះរហូតដល់ស្លាប់នៅពេលកងសន្តិសុខពិនិត្យឃើញថាអ្នកទោសធ្វើការយឺត[2362]។ សាក្សីពីរនាក់បាននិយាយថា កងសន្តិសុខបានសម្លាប់អ្នកទោស ពេលពួកគេកំពុងធ្វើការងារ[2363]។

<u>ការសួរចម្លើយ</u>

៥៤៥. មានអ្នកទោសខ្លះត្រូវបានគេសួរចម្លើយពេលដែលពួកគេជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខព្រៃដំរីស្រុត[2364]។ អ្នកទោសត្រូវគេសួរចម្លើយពាក់ព័ន្ធនឹងការចោទថា ពួកគាត់ជាខ្មាំង ដូចជា សេអ៊ីអា ឬកាហ្សេបេ ជាអតីតមន្ត្រីរបបលន់ នល់ មានកំហុសតូចតាច ឬ បានប្រព្រឹត្តអំពើខុសសីលធម៌ ឬមានការពាក់ព័ន្ធជាមួយវៀតណាម[2365]។ មានអ្នកទោសខ្លះ មិនត្រូវគេធ្វើបាបទេ នៅពេលគេសួរចម្លើយ[2366]។ ប៉ុន្តែ ទាំងអតីតអ្នកទោស ព្រមទាំងអតីតកងសន្តិសុខបានអះអាងថា មានអ្នកទោសខ្លះត្រូវគេធ្វើបាបធ្ងន់ធ្ងរនៅពេលសួរចម្លើយ ដូចជា ការវាយដំនឹងព្រនង់ ឬខ្សែតីច្រកក្បាលនឹងថង់ផ្លាស្ទិករហូតដល់សន្លប់ ដកក្រចក និងកាច់ម្រាមដៃ[2367]។ ជាងនេះទៅទៀត សាក្សីជាច្រើនបាននិយាយថា ពួកអ្នកជាប់ឃុំខ្លះបានស្លាប់ក្នុងពេលសួរចម្លើយ ដោយសារតែការធ្វើបាបដូចបានរៀបរាប់ពីខាងលើ [2368]។

<u>ការបាត់ខ្លួន និងការសម្លាប់</u>

៥៤៦. អ្នកទោសត្រូវបានចងមុខ និងដៃ រួចនាំចេញ និងមិនឃើញត្រឡប់មកវិញឡើយ[2369]។ មានហេតុផលជាច្រើនត្រូវបានផ្តល់ចំពោះការបាត់ខ្លួនអ្នកទោស រួមមាន ការនាំទៅ *"ជួបអង្គការ"*[2370] ទៅរៀនសូត្រ[2371] ឬត្រឡប់ទៅផ្ទះវិញ[2372]។ ផ្អែកតាមសាក្សីម្នាក់ កងសន្តិសុខមិនដែលបាននិយាយ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

អំពីការសម្លាប់នៅចំពោះមុខអ្នកទោសឡើយ ហើយបានបង្គាប់ឱ្យអ្នកទោសជីករណ្តៅដោយគ្មានប្រាប់ថាវាជារណ្តៅសម្រាប់កប់សាកសពទេ[2373]។

៩៤៧. ការបញ្ជាឱ្យសម្លាប់អ្នកទោសគឺចេញមកពីប្រធាន ឬពីកម្មាភិបាល៣នាក់ទៀតដែលជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខព្រៃដំរីស្រុត[2374]។ ពួកអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនេះមិនគ្រាន់ត្រឹមតែបញ្ជាឱ្យសម្លាប់អ្នកទោសតែប៉ុណ្ណោះទេ ថែមទាំងបានចូលរួមសម្លាប់អ្នកទោសដោយផ្ទាល់មួយចំនួនទៀតផង[2375]។ អតីតសន្តិសុខម្នាក់ដែលបានចូលរួមសម្លាប់អ្នកទោសនៅព្រៃដំរីស្រុតបានអះអាងថា អ្នកទោសធ្ងន់ត្រូវតែសម្លាប់ចោល រីឯអ្នកទោសស្រាលក៏អាចត្រូវសម្លាប់ដែរ ប្រសិនបើពួកគេមិនអាចអប់រំបាន[2376]។

៩៤៨. សាក្សីខ្លះបាននិយាយថា ខ្លួនបានឃើញការសម្លាប់ និងបានឃើញសាកសពមនុស្សនៅក្នុងរណ្តៅ[2377]។ អ្នកទោសត្រូវគេវាយនឹងដំបងឫស្សី ហើយនៅពេលស្លាប់ភ្លាមគេធាក់ទម្លាក់សាកសពចូលទៅក្នុងរណ្តៅ[2378]។ ការសម្លាប់នេះប្រព្រឹត្តឡើងនៅក្បែរមន្ទីរឃុំឃាំងនៅក្នុងចម្ការដែលមានដើមដូងនិងដើមចេក ហើយទម្លាក់សាកសពចូលទៅក្នុងរណ្តៅដែលអ្នកទោសបានជីកនៅពេលថ្ងៃ។ ក្រោយពីសម្លាប់ហើយ សាកសពមួយចំនួនត្រូវគេកាត់ជាពីរ ឬបីកំណាត់មុនពេលគេទម្លាក់ចូលក្នុងរណ្តៅ ដើម្បីទុកធ្វើជាជីសម្រាប់ដាំដំណាំ[2379]។ អតីតកងសន្តិសុខម្នាក់ដែលបានចូលរួមក្នុងការសម្លាប់បាននិយាយថា *"ក្នុងកំឡុងឆ្នាំ ១៩៧៨ ដែលខ្ញុំនៅគុកដំរីស្រុត ខ្ញុំធ្លាប់បានចូលរួមជីករណ្តៅនិងកប់ សាកសពជាច្រើនដង ដោយបានជីករណ្តៅដោយខ្លួនឯងផ្ទាល់ចំនួន ៣ រណ្តៅ។ ក្នុងមួយរណ្តៅមាន សាកសពប្រហែលពី ១០ ទៅ ១៥នាក់ ។ តាមការស្មានមានរណ្តៅទាំងអស់ ៨ ទៅ ១០ រណ្តៅ "*[2380]។ អ្នកភូមិម្នាក់ ដែលបានជីកគាស់ដើមដូង១០ដើម នៅឆ្នាំ១៩៧៩ បាននិយាយថាគាត់បានឃើញ សាកសពមនុស្សនៅខាងក្រោម។ គាត់បានអះអាងថា "*មានដើមដូងរាប់រយដើម ហើយមានខ្មោច នៅគ្រប់គល់ដូងទាំងអស់*"[2381]។ តាមការប្រាប់ពី [លុប] [លុប] មានអ្នកទោសចំនួនតែ២០ នាក់ប៉ុណ្ណោះ ត្រូវគេសម្លាប់នៅមន្ទីរសន្តិសុខព្រៃដំរីស្រុត[2382] ក៏ប៉ុន្តែ ភស្តុតាងទាំងមូលដូចបានរៀបរាប់ពីខាងលើបានបង្ហាញច្បាស់ថាចំនួនអ្នកទោសដែលគេសម្លាប់នៅទីនោះមានច្រើន។

៩៤៩. អតីតកងសន្តិសុខម្នាក់បានអះអាងថា គាត់បានឮកងទ័ពនិយាយថា អ្នកទោសភេទស្ត្រីត្រូវបានពួកកម្មា-ភិបាលនៅទីនោះរំលោភមុនពេលគេសម្លាប់[2383]។ ម៉ុល ឯម បានបដិសេធការចោទប្រកាន់នេះ

នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់[2384] ហើយនៅពេលដែលគេសួរសំណួរនេះទៅអ្នកទោស ពួកគេបានឆ្លើយថា គ្មានការរំលោភសេពសន្ថវៈកើតឡើងទេនៅមន្ទីរសន្តិសុខព្រៃដំរីស្រុត[2385]។

***

៩៥០. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៤នាក់ (បួននាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខព្រៃដំរីស្រុត[2386]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខព្រៃដំរីស្រុត ។

## មន្ទីរសន្តិសុខវត្តគីរីរម្យ[2387]

### ទីតាំង និងការបង្កើត

៩៥១. មន្ទីរសន្តិសុខវត្តគីរីរម្យស្ថិតនៅលើភ្នំសំពៅ[2388] ក្នុងឃុំភ្នំសំពៅ ខេត្តបាត់ដំបង[2389]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខវត្តគីរីរម្យស្ថិតនៅក្នុងស្រុក ភ្នំសំពៅ តំបន់ ៣ ភូមិភាគពាយ័ព្យ[2390]។

៩៥២. មន្ទីរសន្តិសុខវត្តគីរីរម្យរាប់បញ្ចូលកន្លែងផ្សេងៗមួយចំនួនទៀតដូចជា៖ គុកចន្លោះក្តោង ដែលត្រូវបាន គេស្គាល់ថាជា "កន្លែងនគរបាល"[2391] ឬ "គុកឃ្លាំង"[2392] ដែលជាកន្លែងឃុំឃាំងអ្នកទោសវត្តនៅលើ កំពូលភ្នំ (អាចឡើងទៅដល់តាម"ជណ្តើរស") ដែលនៅទីនោះអ្នកជាប់ឃុំឃាំងត្រូវបានសម្លាប់[2393] និងរួមទាំង ល្អាងតែងខ្លួន ល្អាងល្ខោន និងល្អាងកង្កែប ដែលសុទ្ធតែជារូងនៅលើភ្នំដែលនៅកន្លែងទាំងនោះជនរងគ្រោះត្រូវបានសម្លាប់ ហើយសាកសពរបស់ពួកគេត្រូវបានទុកចោលនៅ ទីនោះ[2394]។

៩៥៣. គុកចន្លោះក្តោងស្ថិតនៅចម្ងាយប្រហែលជា ២០០ម៉ែត្រ ខាងលិចជណ្តើរសឡើងទៅកាន់វត្ត[2395]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

គុកនេះ មានទំហំប្រហែលជា ២០០ម៉ែត្រ គុណនឹង ៥០០ម៉ែត្រ ហើយអាចឃុំឃាំងមនុស្សម្តងៗ បានពី ៥០នាក់ទៅ ២០០នាក់[2396]។ គុកនេះត្រូវបានព័ទ្ធជុំវិញដោយជញ្ជាំងឥដ្ឋ ដោយមានរបងខ្សែលួស បន្លាព័ទ្ធជុំវិញនៅផ្នែកខាងលើរបងឥដ្ឋនោះ[2397]។

៥៥៤. មានភស្តុតាងមួយចំនួនបានបង្ហាញថា គុកនេះត្រូវបានសាងសង់ឡើងប្រហែលជានៅក្នុងឆ្នាំ១៩៧៦[2398] និង មានភស្តុតាងផ្សេងទៀតបង្ហាញថា ប្រហែលជានៅចន្លោះឆ្នាំ ១៩៧៧ និង ១៩៧៨[2399]។ នៅមុនការសាងសង់មន្ទីរចន្លោះក្តោងនេះ អ្នកទោសត្រូវបានចាប់ខ្លួន និងដាក់ឃុំនៅក្នុងអគារឃុំឃាំងបណ្តោះអាសន្នមួយនៅភូមិអណ្តូងព្រីង[2400] ឬនៅសាលាបឋមសិក្សាសម្តេចឪសម្តេចម៉ែ[2401] ហើយពេលនោះចន្លោះក្តោងគ្រាន់តែជាកន្លែងសម្លាប់មនុស្សតែប៉ុណ្ណោះ[2402]។

៥៥៥. នៅក្នុងឆ្នាំ១៩៧៥ ព្រះសង្ឃ និងដូនជីដែលស្នាក់នៅក្នុងវត្តត្រូវបានចាប់ផ្សឹក និងបញ្ជូនឲ្យទៅរស់នៅតាមភូមិនានា[2403]។ ក្រោយមក វត្តនេះបានប្រែក្លាយទៅជាផ្នែកមួយនៃមន្ទីរសន្តិសុខវត្តគីរីរម្យ[2404]។ មន្ទីរសន្តិសុខនេះទំនងជាបានចាប់ផ្តើមដំណើរការពេញលេញ នៅក្នុងឆ្នាំ១៩៧៦ ហើយបានបន្តដំណើរ ការរហូតដល់ការមកដល់របស់ពួកទាហានវៀតណាម នៅក្នុងខែមករា ឆ្នាំ១៩៧៩[2405]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធគ្រប់គ្រង និង បុគ្គលិក**

៥៥៦. ក្នុងកំឡុងពេលទាំងមូលនៃដំណើរការរបស់មន្ទីរសន្តិសុខវត្តគីរីរម្យ លេខាឃុំមានឈ្មោះថា [លុប] [លុប][2406]។ អនុលេខារបស់ [លុប] មានឈ្មោះ [លុប] និង [លុប][2407]។

៥៥៧. [លុប] ទទួលបញ្ជាផ្ទាល់ពី [លុប][2408] ទោះបីជាមានភាពមិនស៊ីសង្វាក់មួយចំនួនអំពីភស្តុតាងដែលអាចបញ្ជាក់អំពីឋានៈពិតប្រាកដរបស់ [លុប] ថានៅកំរិតឃុំ តំបន់ ឬភូមិភាគ ក៏ដោយ[2409]។ ថ្វីបើមានភាពមិនស៊ីសង្វាក់ក៏ដោយ ក៏មានភស្តុតាងដែលអាចបញ្ជាក់យ៉ាងច្បាស់ថា [លុប] ជាកម្មាភិបាលជាន់ខ្ពស់ ប.ក.ក. នៅក្នុងតំបន់ភ្នំសំពៅ ចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតមកដែលគាត់បានចូលរួមពាក់ព័ន្ធយ៉ាងសកម្ម នៅក្នុងការគ្រប់គ្រងត្រួតពិនិត្យការងារនៅតាមសហករណ៍ និងការដ្ឋាន នានា ក៏ដូចជាការអនុវត្តគោលនយោបាយរបស់ ប.ក.ក. ក្នុងការចាប់ខ្លួន និងសម្លាប់អ្នកដែលត្រូវបានកំណត់ថាជាខ្មាំង។ [លុប] ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១

00605438



នៅក្នុងខែមករា ឆ្នាំ១៩៧៨[2410]។

៩៥៨. លេខាគណៈភូមិភាគពាយ័ព្យ គឺឈ្មោះ [លុប] [លុប] [លុប] គាត់បានកាន់តំណែងនេះ រហូតដល់មានការចាប់ខ្លួនគាត់នៅក្នុងខែឧសភា ឆ្នាំ១៩៧៨[2411] ដោយកម្មាភិបាលមកពីភូមិភាគនិរតី និងការឡើងកាន់តំណែងជំនួសគាត់ក្នុងឋានៈជាលេខាភូមិភាគពាយ័ព្យ ដោយ [លុប][2412]។ សក្ខីកម្មរបស់សាក្សីបានបញ្ជាក់ថា [លុប] [លុប] ធ្លាប់បានចុះមកទស្សនកិច្ច នៅភ្នំសំពៅជាច្រើនដង ដែលពេលនោះគាត់បាននិយាយជាមួយកម្មាភិបាលឃុំ និងធ្វើការប្រជុំអប់រំរៀនសូត្រដល់ប្រជាជននៅក្នុងមូលដ្ឋាន[2413]។

**ការចាប់ខ្លួន និង ការឃុំឃាំង**

៩៥៩. ទាំងបុរស ស្ត្រី និងកុមារត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខវត្តគីរីរម្យ[2414]។ ជនរងគ្រោះភាគច្រើនដែលត្រូវបានចាប់ខ្លួន សុទ្ធតែជាប្រជាជនដែលធ្វើការនៅតាមសហករណ៍មូលដ្ឋាន ឬជាកម្មាភិបាលមូលដ្ឋានរបស់ ប.ក.ក ដែលត្រូវបានចាត់ទុកថាថាជាជនក្បត់[2415]។ កម្មាភិបាលជាន់ខ្ពស់របស់ ប.ក.ក ប្រហែលជាធ្លាប់ចុះពិនិត្យការងារនៅតាមសហករណ៍ ដូចជា [លុប][2416]។ របាយការណ៍ស្តីអំពី សកម្មភាពរបស់ប្រជាជននៅតាមសហករណ៍ត្រូវបានធ្វើជាលាយលក្ខណ៍អក្សរដោយថ្នាក់ឃុំ និង បញ្ជូនទៅឱ្យ [លុប][2417] ដែលប្រហែលជាគាត់អាចបានជួបជាមួយនឹងតំណាងមកពីតាមភូមិនានា រៀងរាល់ដប់ថ្ងៃម្តង[2418]។ ប្រវត្តិរូបត្រូវបានគេស្រង់ (ដោយមានបញ្ជាក់ផងដែរអំពីឈ្មោះ និង សកម្មភាពនានារបស់អតីតទាហាន លន់ នល់) ហើយ ដែលទិន្នន័យនេះបន្ទាប់មកត្រូវបានបញ្ជូនទៅ ប្រធានវរៈដើម្បីបញ្ជូនបន្តទៅ *"ថ្នាក់លើ"*[2419]។ [លុប] មានអំណាចក្នុងការចាប់ខ្លួនមនុស្សនៅតាមសហករណ៍ ឬនៅក្បែរការដ្ឋានកំពីងពួយ ដែលត្រូវបានកំណត់ថាជាខ្មាំង និងរួមទាំងមានអំណាច ក្នុងការសម្រេចថាតើបុគ្គលណាម្នាក់ ត្រូវសម្លាប់ ឬមិនសម្លាប់ផងដែរ[2420]។

៩៦០. ប្រជាជនត្រូវបានចាប់ខ្លួនដោយចោទថាខ្ជិលច្រអូស[2421] ជារឿយៗត្រូវបានគំរាមថានឹងត្រូវ *"បញ្ជូនទៅវត្តគីរីរម្យតាមជណ្តើរស"*[2422]។ មនុស្សដែលត្រូវបានចាប់ខ្លួនដោយផ្អែកលើមូលដ្ឋានចោទប្រកាន់ទាំងនេះ ត្រូវបានបញ្ជូនទៅកែប្រែ[2423]។ មានប្រជាជនខ្លះក៏ត្រូវបានគេចាប់ខ្លួនផងដែរ ដោយសារគេគិតថាប្រជាជនមូលដ្ឋានមានផែនការចង់ផ្តួលរំលំអង្គការ និង *"ដោយមានការស្ម័គ្រចិត្តប្រមូលផ្តុំកម្លាំង"*[2424]។ ជាករណីឧទាហរណ៍ សាក្សីមួយរូបបានរំលឹក

ថាមនុស្សចំនួន ២០នាក់ដែលរស់នៅក្នុងសហករណ៍នៅភ្នំសំពៅលិចត្រូវបានចាប់ខ្លួនដោយ [លុប] ដែលនៅពេលដោះលែងពួកគេវិញ គាត់បាននិយាយថា *"កុំភ័យ បើខ្ញុំមិនចាប់ទាំងអស់ ខ្ញុំរកខ្មាំងមិនឃើញ"*[2425]។ មានហេតុផលផ្សេងទៀតដែលអាចនាំឲ្យមានការចាប់ខ្លួនមនុស្ស ដូចជាខុសសីលធម៌[2426] ការលួចផ្លែឈើ[2427] ឬការលួចសត្វ[2428]។

៥៦១. តាមសាក្សីមួយចំនួន អ្នកទោសនៅគុកចន្លោះក្តោងត្រូវបានគេបង្ខំឲ្យធ្វើការងារនៅទីកន្លែងជុំវិញគុក ដោយឲ្យវាយថ្ម ធ្វើសំណង់ផ្សេងៗ[2429] ជីកប្រឡាយ ធ្វើរបង ចិញ្ចឹមជ្រូក ចិញ្ចឹមគោ[2430] ដាំបន្លែ[2431] កាត់ស្មៅ និងកាប់ឈើ[2432] ឬសែងរបស់ធ្ងន់ៗ[2433]។ ជាងនេះទៅទៀត កូនៗរបស់កម្មាភិបាល ប.ក.ក ដែលជាសន្តិសុខគុកនោះ ទាត់ក្បាលអ្នកទោស និងវាយអ្នកទោសនឹងស្វាយកាំភ្លើង នៅពេលដែលពួកគេកំពុងធ្វើការងារ[2434]។

៥៦២. ការប្រជុំរិះគន់ទិតៀនត្រូវបានធ្វើឡើងនៅភូមិភ្នំសំពៅ ដែលពេលនោះកម្មាភិបាលនិយាយអំពី *"ការកំទេចចោលមនុស្ស"* ដែលខូចសីលធម៌ ខ្ជិលច្រអូសមិនទៅធ្វើការ ឈឺច្រើន និងជាជនក្បត់នឹងរបបនេះ ហើយនិយាយថាបក្ស ឬ*អង្គការ*បានបញ្ជាឲ្យពួកគេកំទេច អ្នកដែលខុសសីលធម៌ ខ្ជិលច្រអូសពេលធ្វើការ ឬឈឺច្រើន[2435]។ ជារឿយៗ កិច្ចប្រជុំទាំងនេះត្រូវបានដឹកនាំដោយ [លុប] ឬ [លុប] ហើយអ្នកដែលត្រូវបានគេកំណត់ថាជាខ្មាំងនឹងត្រូវចាប់ខ្លួន និងសម្លាប់នៅនឹងកន្លែង[2436]។ សាក្សីម្នាក់មានវត្តមាននៅពេលដែល [លុប] បានប្រកាសថា *"កុំយកតម្រាប់តាមខ្មាំង បង្កើតក្រុមបះបោរ បើហ៊ានធ្វើបែបនោះគឺត្រូវកំទេច"*[2437]។

## ការសួរចម្លើយ

៥៦៣. ប្រវត្តិរូបរបស់អ្នកទោសត្រូវបានស្រាវជ្រាវនៅគុកចន្លោះក្តោង។ អ្នកទោសដែលត្រូវបានកំណត់ថាជាអ្នកទោសកំរិតធ្ងន់ប្រហែលជាត្រូវបានយកឡើងតាមជណ្តើរសទៅកាន់វត្តគីរីរម្យ[2438] និងអ្នកទោសកំរិតស្រាលនឹងត្រូវទុកឲ្យនៅគុកចន្លោះក្តោងដដែល[2439]។

៥៦៤. ទោះបីជាមុនការសាងសង់គុកចន្លោះក្តោង មានសាក្សីមួយរូបបានលើកឡើងថា ខ្លួនគាត់ធ្លាប់ត្រូវបានគេឃុំឃាំងនៅក្នុងអគារឃុំឃាំងបណ្តោះអាសន្ននៅអណ្តូងព្រីង ដែលនៅទីនោះគាត់ត្រូវបានគេធ្វើបាបយ៉ាងធ្ងន់ធ្ងរ (គេយកចំពុះទុងមកឆ្កូតបាតជើងរបស់គាត់ ដោយគេចោទថាគាត់បានលួចអាវុធ) ប៉ុន្តែមិនមានសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែកណាផ្សេងទៀត ដែលបានបញ្ជាក់អំពី

00605440



ការសួរចម្លើយលើអ្នកជាប់ឃុំផ្សេងទៀត នៅមន្ទីរសន្តិសុខវត្តគិរីរម្យនោះឡើយ ហើយក៏គ្មានភស្តុតាងដូចគ្នាចំពោះការសួរចម្លើយនៅគុកចន្លោះក្តោង ឬ វត្តគីរីរម្យ[2440] ។

## ការសម្លាប់ និងការបាត់ខ្លួន

៥៦៥. មន្ទីរសន្តិសុខវត្តគីរីរម្យជា *"កន្លែងសម្លាប់"* ដែលប្រជាជនមិនហ៊ានធ្វើដំណើរទៅជិតកន្លែងនោះទេ[2441]។ សាក្សីមួយចំនួនបានបញ្ជាក់ថា ក្រុមអ្នកទោស (មានចាប់ពី ២ ទៅ ៣នាក់ រហូតដល់ប្រហែលជា ២០នាក់) ត្រូវបានបណ្តើរដោយមានជាប់ច្រវាក់ដោយពួកកងទ័ព ពីគុកឡើងតាមជណ្តើរសទៅកាន់វត្តនៅលើកំពូលភ្នំ[2442]។ ទោះបីជាសាក្សីពីររូបបានលើកឡើងថាបានឃើញអ្នកទោសមួយចំនួនត្រូវបាននាំត្រឡប់មកពីលើភ្នំវិញ[2443] ក៏មានភស្តុតាងដ៏ច្រើនលើសលប់បានបង្ហាញថា ក្រុមអ្នកទោសដែលត្រូវបានយកឡើងទៅលើកំពូលភ្នំ មិនដែលឃើញត្រឡប់មកវិញនោះទេ[2444]។ ដូចសាក្សីមួយរូបបានលើកឡើងថា *"ខ្ញុំឃើញតែយោធាដែលបណ្តើរអ្នកទោសនោះចុះមកវិញ ប៉ុន្តែគ្មានអ្នកទោសណាម្នាក់ត្រលប់មកវិញទេ"*[2445]។ កម្មាភិបាល ប.ក.ក. ធ្វើការប្រកាសជាចំហថា *"កាលណាទៅដល់វត្តគីរីរម្យនោះស្រួល គឺមិនត្រូវធ្វើការងារអ្វីទៀតទេ*[2446]*"*។

៥៦៦. តាមការបំភ្លឺរបស់សាក្សីម្នាក់ មនុស្សទាំងអស់ដែលរស់នៅតាមភូមិជុំវិញនោះបានដឹងគ្រប់ៗគ្នាថា គេបានយកមនុស្សទៅសម្លាប់[2447] នៅលើភ្នំសំពៅ។ សាក្សីដែលត្រូវបានស្តាប់យកចម្លើយមិនបានឃើញការសម្លាប់ទាំងនោះ ដោយផ្ទាល់ភ្នែកនោះទេ (ព្រោះត្រូវបានហាមឃាត់មិនឱ្យឡើងជណ្តើរ) ប៉ុន្តែបានឃើញសាកសពរបស់ជនរងគ្រោះពេលឡើងទៅលើភ្នំ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ពេលនោះបានប្រទះឃើញមានសាកសពជាច្រើន នៅតាមកន្លែងមួយចំនួន កន្លែងទាំងនេះរួមមាន តាមល្អាងនានាដែលនៅលើកំពូលភ្នំសំពៅ[2448] នៅខាងក្នុងវត្តជាកន្លែង (ដែលសាកសពនៅមានជាប់ខ្នោះទៅនឹងជញ្ជាំងនៅឡើយ)[2449] សាកសព (ដែលរួមមានទាំងកូនក្មេងផង) ទើរលើដើមឈើតាមផ្លូវចុះទៅល្អាង[2450] នៅក្នុងព្រៃ[2451] និងនៅតាមវាលស្រែត្រង់ចន្លោះភ្នំក្តោង និងភ្នំសំពៅ[2452]។ សាក្សីមួយចំនួនបានបញ្ជាក់អំពីការប្រទះឃើញសាកសព ដែលនៅជាប់ចំណង[2453]។

៥៦៧. សាក្សីបានលើកឡើងថា នៅក្នុងល្អាងនានា ពួកគេឃើញ *"សាកសពរាប់រយ"* [2454] ហើយសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនោះបាននិយាយថា *"សាកសពជាច្រើនរាប់មិនអស់ដែលអាចសម្គាល់ថាជាសពមនុស្សប្រុស ស្ត្រី និងក្មេង"*[2455]។ នៅខាងក្នុងវត្តគីរីរម្យ និងរាយពាយតាមផ្លូវទៅល្អាង

សាក្សីបានឃើញឧបករណ៍សម្លាប់មនុស្ស ដែលឧបករណ៍ខ្លះប្រឡាក់ឈាមដូចជា ដំបងឈើ កាំបិត ពូថៅ ដែកវែង ដែកស្បែងមូលប្រវែងប្រហែល៦០-៧០សង់ទីម៉ែត្រ គល់ឫស្សី ឈើជ្រុង ខ្នោះដែ ខ្នោះឈើ និងខ្សែពួរ[2456]។

៥៦៨. សាកសពរបស់ជនរងគ្រោះមាននៅក្នុងល្អាងទាំងបីនៅលើភ្នំសំពៅ។ ល្អាងទាំងនោះមានដូចជា ល្អាងតែងខ្លួន ឬ "*បន្ទប់តែងខ្លួន*"[2457] ល្អាងល្ខោនដែលនៅជិតនោះ[2458] និងល្អាងកង្កែប[2459]។ តួយ៉ាង សាកសពដែលរកឃើញនៅក្នុងល្អាងសុទ្ធតែផ្កាប់មុខចុះ និងមានស្នាមបែកក្បាលពីក្រោយ[2460]។

៥៦៩. ជាងនេះទៀត សាក្សីបានចាំថាធ្លាប់ប្រទះឃើញ នៅកំពស់ត្រឹមប្រមាណមនុស្សលត់ជង្គង់ មានដាក់ចានដែក ឬក៏ចានតម្រងមានភ្ជាប់ទបង្ហូរតាមប្រហោងជញ្ជាំងព្រះវិហារដែលបានចោះ សម្រាប់បង្ហូរឈាមចេញមកក្រៅ និងឲ្យឆ្ងាយពីវត្ត[2461] ហើយឲ្យហូរទៅក្នុងអាងដែលមានឈាមកក នៅខាងក្រៅ[2462]។ ឧបករណ៍នេះប្រើសម្រាប់ត្រងឈាមអ្នកទោសដែលត្រូវបានគេអារក[2463] ហើយត្រូវបានយកចេញ តាំងពីពេលនោះមក[2464]។ នៅក្នុងវត្ត គេឃើញមានច្រវាក់ដែលអាចត្រូវបានគេប្រើប្រាស់ដើម្បីការពារកុំឲ្យអ្នកទោសរត់គេច[2465]។

៥៧០. ទោះបីជាមិនមានភស្តុតាងច្បាស់លាស់ ដែលអាចកំណត់អំពីចំនួនជនរងគ្រោះពិតប្រាកដ ដែលត្រូវបានសម្លាប់នៅវត្តគីរីរម្យក៏ដោយ ចំនួនតួលេខជនរងគ្រោះទំនងជាខ្ពស់ណាស់ ប្រសិនបើយើងពិនិត្យមើទីកន្លែងជាច្រើនដែលមានសាកសព និងសក្ខីកម្មដែលផ្តល់ឡើងដោយសាក្សី គឺជនរងគ្រោះអាចមានប្រហែលចំនួនដល់រាប់ពាន់នាក់។

***

៥៧១. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន០១នាក់ (**មួយនាក់**) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តគិរីរម្យ[2466]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តគិរីរម្យ។

## មន្ទីរសន្តិសុខភូមិភាគឧត្តរ[2467]

### ទីតាំង និង ការបង្កើត

៩៧២. មន្ទីរសន្តិសុខភូមិភាគឧត្តរ ស្ថិតនៅក្នុងទីក្រុងសៀមរាប ខេត្តសៀមរាប។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងតំបន់ ១០៦ ក្នុងភូមិភាគឧត្តរថ្មី (៨០១)[2468]។ ក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧ កម្មាភិបាលមកពីភូមិភាគនិរតីបានមកភូមិភាគឧត្តរ ហើយបានមកជំនួសមេដឹកនាំតំបន់១០៦ ដែលរួមមាន លេខាតំបន់ឈ្មោះ [លុប] និងប្រធានសន្តិសុខតំបន់ឈ្មោះ យង់ ពៅ[2469] ដែលពេលនោះហើយដែលគេបានបង្កើតនូវភូមិភាគឧត្តរថ្មី[2470]។ នួន ជា បានប្រកាសបង្កើតភូមិភាគឧត្តរថ្មីក្នុងអង្គប្រជុំ តំបន់១០៣ ក្នុងចុងឆ្នាំ១៩៧៧[2471]។ ចាប់តាំងពីពេលបង្កើតក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខនេះជារបស់អតីតតំបន់ស្វយ័ត ១០៦ ប៉ុន្តែនៅពេលភូមិភាគត្រូវបានបង្កើតឡើង មន្ទីរនេះដើរតួនាទីជាមន្ទីរសន្តិសុខរបស់ភូមិភាគទាំងមូល ដោយរួមបញ្ចូលអតីតតំបន់ស្វយ័ត ១០៦ និង តំបន់១០៣ ផងដែរ[2472]។ មន្ទីរសន្តិសុខនេះបានដំណើរការយ៉ាងហោចណាស់រហូតដល់ខែធ្នូ ឆ្នាំ១៩៧៨[2473]។

៩៧៣. មន្ទីរសន្តិសុខភូមិភាគឧត្តរ ស្ថិតនៅចំទីតាំងអតីតពន្ធនាគារ នាសម័យអាណានិគមនិយមបារាំងចាស់ ដែលបច្ចុប្បន្នជាទីតាំងសណ្ឋាគារសុខាអង្គរ។ ការសួរចម្លើយត្រូវបានធ្វើឡើងនៅក្នុងវត្តកេសរារាម (ដែលគេស្គាល់ថាជា វត្តធម្មយុត្តិ) ដែលនៅជាប់ខាងលិចនៃទីតាំងគុក។ កន្លែងសម្លាប់អ្នកទោសស្ថិតនៅចំការទ្រិញវ៉ាញ ដែលមានចម្ងាយប្រហែល៥០០ម៉ែត្រ ខាងជើងកន្លែងបង់លុយចូលប្រាសាទអង្គរវត្ត។ អ្នកទោសមួយចំនួនដែលបានស្លាប់ នៅក្នុងមន្ទីរសន្តិសុខ ត្រូវបានកប់នៅក្នុងសាលាបឋមសិក្សាវត្តកេសរារាម ដែលនៅជាប់នឹងរបងវត្តកេសរារាម[2474]។

### ដំណើរការប្រព្រឹត្តទៅ

#### រចនាសម្ព័ន្ធគ្រប់គ្រង និង បុគ្គលិក

៩៧៤. សមាសភាពថ្នាក់ដឹកនាំរបស់មន្ទីរសន្តិសុខបានផ្លាស់ប្តូរក្នុងអំឡុងពេលដំណើរការ។ ប្រធានមន្ទីរសន្តិសុខ គឺ រុន ហៅ ស្រ៊ុន (ស្លាប់) មកពីភូមិភាគនិរតី[2475]។ ពីខែមិថុនា ឆ្នាំ១៩៧៨ រុន ត្រូវបានជំនួសដោយ [លុប] ដែលមកពីភូមិភាគបស្ចិម[2476]។ អនុប្រធានមន្ទីរសន្តិសុខឈ្មោះ ប្រុញ (ស្លាប់)[2477]។ ប្រុញ ទទួលបន្ទុកចាត់ចែងដំណើរការការងារប្រចាំថ្ងៃរបស់មន្ទីរសន្តិសុខ រាប់បញ្ចូល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ការមកដល់របស់អ្នកទោស ការសួរយកចម្លើយ ការសម្លាប់ និងកប់សាកសពអ្នកទោស[2478]។ មិនមានភស្តុតាងបង្ហាញថាជនត្រូវចោទណាមួយទៅពិនិត្យមើលមន្ទីរសន្តិសុខនេះឡើយ[2479]។

**៩៧៥.** កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរថ្មី ត្រូវបានចាប់បញ្ជូនទៅមន្ទីរ ស-២១ ក្នុងខែសីហា ឆ្នាំ១៩៧៨ ហើយត្រូវបានជំនួសដោយ [លុប][2480] បានរាយការណ៍ជាទៀងទាត់ ជាពិសេសទាក់ទងជាមួយនឹងស្ថានភាពខ្មាំងផ្ទៃក្នុង និងការចាប់ខ្លួនខ្មាំងនៅក្នុងតំបន់១០៣ និង១០៦ ទៅមន្ទីរ៨៧០ តាមរយៈទូរលេខ (ទូរលេខខ្លះ ត្រូវបានចម្លងជូន **នួន ជា** និង **អៀង សារី**)[2481]។ កង ចាប អាចបញ្ជូនដោយផ្ទាល់ នូវចម្លើយសារភាពទៅមជ្ឈិមបក្ស ជាពិសេសចម្លើយសារភាពរបស់ [លុប] ដែលជាសមាជិកគណៈកម្មាធិការពាណិជ្ជកម្មរបស់តំបន់១០៣ ប្រចាំនៅភ្នំពេញ។ កង ចាប បានសរសេរក្នុងសំបុត្រភ្ជាប់ជាមួយចម្លើយសារភាពនេះថា គាត់បានបញ្ជូនចម្លើយសារភាពនេះ និងចម្លើយសារភាពរបស់ [លុប] ពីសន្តិសុខតំបន់ ១០៣ ដើម្បីឲ្យគណៈកម្មាធិការ ៨៧០ ពិនិត្យមើល និងដើម្បីស្វែងរកបណ្តាញក្បត់ផ្ទៃក្នុងផ្សេងទៀត។ មានភស្តុតាងបង្ហាញថា **នួន ជា** បានចារលើចម្លើយសារភាពនេះ ជាមួយពាក្យ *"១៩ មេសា១៩៧៨ តាមដាន"*[2482]។

**ការចាប់ និងឃុំខ្លួន**

**៩៧៦.** សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩ រូប ដែលធ្លាប់បានជាប់ឃុំនៅមន្ទីរសន្តិសុខនេះ[2483] ត្រូវបានស្តាប់យកចម្លើយ ហើយអ្នកទាំងនោះបានចង្អុលបង្ហាញពីបុគ្គលដទៃទៀតដែលពួកគេបានស្គាល់ថា បានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះផងដែរ[2484]។ ទាំងបុរស ទាំងស្ត្រី (ពេលខ្លះស្ត្រីមានផ្ទៃពោះ)[2485] ទាំងកុមារ និងទារក[2486] ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខនេះ។ អ្នកជាប់ឃុំឃាំងទាំងអស់គឺជាប្រជាជនកម្ពុជា ដែលមានប្រជាជនថ្មី[2487] ប្រជាជនមូលដ្ឋាន[2488] កម្មាភិបាល និងកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជាមកពីតំបន់១០៦ និង១០៣[2489] ប្រជាជនដែលជាប់ខ្សែនឹងរបប លន់ នល់[2490]។ មន្ទីរឃុំឃាំងព័ទ្ធជុំវិញដោយរបងបេតុង និងមានអាគារឃុំឃាំងធំចំនួនពីរ ដែលអាគារនីមួយៗអាចដាក់អ្នកទោសបានចំនួនប្រហែល ២០០ នាក់។ នៅជ្រុងខាងជើងនៃមន្ទីរឃុំឃាំង មានបន្ទប់ដោយឡែក និងបន្ទប់ឃុំឃាំងចំនួនពីរផ្សេងទៀតដែលអាចដាក់អ្នកទោសប្រហែលពី ៥០ ទៅ ៧០នាក់ ដោយរួមទាំងកន្លែងឃុំឃាំងអ្នកទោសស្រីផងដែរ។ មន្ទីរឃុំឃាំងនេះអាចដាក់អ្នកទោសបានច្រើនជាង ៥០០នាក់[2491]។

00605444



**៥៧៧.** មនុស្សដែលត្រូវបានចាប់ខ្លួនអាចត្រូវបានបញ្ជូនផ្ទាល់មកមន្ទីរសន្តិសុខនេះ ឬអាចដាក់នៅមន្ទីរសន្តិសុខថ្នាក់ស្រុកណាមួយជាមុនសិនមុននឹងបញ្ជូនមក[2492]។ ជាទូទៅមនុស្សត្រូវបានចាប់ខ្លួនជាក្រុមមកពីកន្លែងតែមួយ ឬមកពីអង្គភាពទ័ពជាមួយគ្នា ដែលការចាប់ខ្លួននោះត្រូវបានសម្រេចដោយប្រធានអង្គភាព[2493]។ អតីតអ្នកទោសម្នាក់ជាកម្មាភិបាលមកពីតំបន់ ១០៣ បានបំភ្លឺថា គាត់ត្រូវបានចាប់ខ្លួនក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ផ្អែកតាមបញ្ជាផ្ទាល់របស់ កង ចាប ហៅ សែ លេខារបស់ភូមិភាគឧត្តរថ្មី[2494]។ អ្នកទោសត្រូវបានចងដៃ បិទមុខ និងដឹកតាមឡានមកកាន់មន្ទីរសន្តិសុខ[2495]។ សាក្សីម្នាក់បានអះអាងថា គាត់ និងបងថ្លៃប្រុសរបស់គាត់ត្រូវបានគេវាយដំយ៉ាងដំណំនៅពេលចាប់ខ្លួន[2496]។ អ្នកដែលត្រូវបានចាប់ខ្លួនខ្លះមិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនទេ។ អ្នកខ្លះត្រូវបានគេប្រាប់ថា ចាប់ខ្លួនដោយសារពួកគាត់ក្បត់នយោបាយ ឬដោយសារប្រព្រឹត្តអំពើខុសសីលធម៌[2497]។

**៥៧៨.** នៅមន្ទីរឃុំឃាំង អ្នកទោសប្រុស និងស្រី ត្រូវបានឃុំខ្លួនដាច់ដោយឡែកពីគ្នា និងដាក់តាមប្រភេទអ្នកទោសស្រាល និងអ្នកទោសធ្ងន់។ អ្នកទោសធ្ងន់ត្រូវបានស្ថិតនៅក្នុងលក្ខខណ្ឌឃុំឃាំងលំបាកជាងគេ ដោយមានដាក់ខ្នោះជើង ទាំងយប់ ទាំងថ្ងៃ ចំណែកឯអ្នកទោសស្រាលត្រូវបានដាក់ឲ្យធ្វើការងារ ប៉ុន្តែដាក់ខ្នោះនៅពេលយប់ ហើយដេកនៅកន្លែងដោយឡែក[2498]។ អ្នកទោសស្ថិតនៅក្រោមការឃាមកាមយ៉ាងតឹងរឹង និងជារឿយៗកងសន្តិសុខគុកតែងតែធ្វើបាបអ្នកទោសរាប់បញ្ចូលទាំងកុមារផង ដោយធ្វើការគំរាម មាក់ងាយ និងវាយដំ (ជួនកាលរហូតដល់ស្លាប់)[2499]។ សាក្សីមួយចំនួនបានឃើញអ្នកទោសដែលព្យាយាមរត់គេចខ្លួនចេញពីមន្ទីរឃុំឃាំង ឬលួចអាហារ ត្រូវបានកងសន្តិសុខសម្លាប់នៅក្នុងបរិវេណនៃមន្ទីរសន្តិសុខ[2500]។ សាក្សីម្នាក់បានបញ្ជាក់ពីករណីរំលោភសេពសន្ថវៈ និងការសម្លាប់ចុងភៅស្ត្រីម្នាក់ ដោយកងសន្តិសុខដោយសារតែនាងបានលួចអាហារ[2501]។

**៥៧៩.** អ្នកទោសមានសភាពស្គមស្គាំង និងមានជំងឺ ដោយសារខ្វះខាតអាហារ[2502]។ មិនមានការព្យាបាលណាមួយត្រូវបានផ្តល់ដល់អ្នកជាប់ឃុំឃាំង នៅពេលដែលពួកគេឈឺថ្កាត់ឡើយ[2503] ហើយសាក្សីបានរៀបរាប់ផងដែរថាមានកង្វះខាតផ្នែកអនាម័យយ៉ាងធ្ងន់ធ្ងរ[2504]។ ក្នុងមួយថ្ងៃៗ អ្នកទោសចន្លោះពីម្នាក់ទៅ ១០នាក់បានស្លាប់ដោយសារខ្វះអាហារ ឬជំងឺ ហើយសាកសពរបស់ពួកគេត្រូវបានកប់នៅក្នុងបរិវេណនៃវត្តកេសរារាម[2505]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានពន្យល់ថាកូនរបស់គាត់បានស្លាប់នៅក្នុងមន្ទីរសន្តិសុខមួយខែក្រោយពីពេលមកដល់មន្ទីរសន្តិសុខដោយសារការវាយដំ

គ្មានអាហារគ្រប់គ្រាន់ និងថ្នាំសម្រាប់ព្យាបាល[2506]។ កងសន្តិសុខ និងអ្នកទោសកម្រិតស្រាលទទួលបានរបបអាហារប្រសើរជាង[2507]។

៥៨០. អ្នកទោសខ្លះត្រូវបានដោះលែង ឬបញ្ជូនទៅសហករណ៍ ការដ្ឋានការងារ ឬបញ្ជូនទៅមន្ទីរសន្តិសុខផ្សេងទៀត[2508]។

## ការសួរយកចម្លើយ

៥៨១. អ្នកទោសភាគច្រើនត្រូវបានសួរយកចម្លើយនៅឯមន្ទីរសន្តិសុខភូមិភាគឧត្តរ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥រូប បានផ្តល់សក្ខីកម្មអំពីការសួរយកចម្លើយនៅក្នុងមន្ទីរសន្តិសុខនេះ[2509]។ ផ្អែកតាមសក្ខីកម្មរបស់ពួកគេ នៅពេលសួរចម្លើយ អ្នកទោសត្រូវបានចោទសួរអំពីការគាំទ្រវៀតណាម និងតួនាទីរបស់គេនៅក្នុងភ្នាក់ងារសេអ៊ីអា។ ការសួរចម្លើយធ្វើនៅផ្នែកខាងត្បូងនៃមន្ទីរឃុំឃាំងនៅក្នុងវត្តកេសរារាម[2510]។ អ្នកទោស (ចំនួនពី ៨ ទៅ ១០នាក់ ក្នុងមួយដង) ត្រូវបានគេដោះខ្នោះ នាំឲ្យចេញពីបន្ទប់ រួចដាក់ខ្នោះដៃ និងបណ្តើរឲ្យទៅកាន់វត្ត។ ការសួរយកចម្លើយម្តងចំណាយពេលប្រហែលជាបីម៉ោង[2511]។

៥៨២. ក្នុងអំឡុងពេលនៃការសួរចម្លើយ អ្នកទោសខ្លះទទួលរងនូវការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ តាមមធ្យោបាយខុសៗគ្នាដូចជា ការវាយអ្នកទោសនឹងព្រនង់ (ពេលខ្លះមានរហូតដល់សន្លប់បាត់ស្មារតី) ឆក់ខ្សែភ្លើង ដោយដាក់ខ្សែភ្លើងដែលមានចរន្តលើត្រចៀករបស់អ្នកទោស គ្របក្បាលអ្នកទោសធ្វើឲ្យថប់ដង្ហើម ដកក្រចកដៃ និងក្រចកជើង និងបោះអ្នកទោសចូលក្នុងពំនូកភ្លើង[2512]។ អតីតអ្នកជាប់ឃុំឃាំងម្នាក់បញ្ជាក់ថាគាត់បានឃើញស្ត្រីម្នាក់ត្រូវបាននាំយកទៅសួរចម្លើយពីរ ឬបីថ្ងៃ ក្រោយពីគាត់ សំរាលកូន ហើយកងសន្តិសុខបានសែងគាត់ត្រឡប់មកវិញដោយសារគាត់មិនអាចដើរបាន[2513]។ ទោះបីជាអតីតអ្នកជាប់ឃុំឃាំងបីនាក់បាននិយាយថាពួកគេមិនបានទទួលរងនូវវិធីសួរចម្លើយណាមួយក្នុងចំណោមវិធីទាំងនេះក្នុងអំឡុងពេលសួរយកចម្លើយក៏ដោយ[2514] ក៏នេះគឺជាករណីលើកលែងដ៏កម្រមួយ។

៥៨៣. ក្នុងករណីខ្លះ នៅពេលការសួរយកចម្លើយត្រូវបានបញ្ចប់ អ្នកទោសត្រូវបានដឹកចេញតាមឡាន។ អតីតអ្នកទោសម្នាក់បានពន្យល់ថាគាត់ត្រូវបានគេនាំយកទៅសួរចម្លើយជាមួយអ្នកទោសចំនួន១៧រូបផ្សេងទៀត ហើយបន្ទាប់ពីសួរយកចម្លើយ មានតែគាត់ម្នាក់ឯងគត់ដែលមិនត្រូវគេដឹកចេញ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

តាមឡានតាមផ្លូវអង្គរវត្ត[2515]។

**ការសម្លាប់ និងការបាត់ខ្លួន**

**៥៨៤.** នៅក្នុងមន្ទីរសន្តិសុខនេះ អ្នកទោសភាគច្រើនរួមទាំងកុមារផង[2516] ត្រូវបានសម្លាប់។ អ្នកទោសត្រូវដឹកតាមឡានយកទៅសម្លាប់នៅក្នុងចំការទ្រិញវ៉ាញ ស្ថិតនៅខាងត្បូងនៃប្រាសាទអង្គរវត្ត[2517]។ ការសម្លាប់កើតមានឡើងជាទៀងទាត់។ អតីតកងសន្តិសុខម្នាក់បានពន្យល់ថា ក្នុងមួយលើកៗមានអ្នកទោសប្រហែល ១០ នាក់ ដែលត្រូវដឹកយកទៅសម្លាប់[2518] ក៏ប៉ុន្តែអតីតអ្នកទោសខ្លះបានឃើញអ្នកទោសរហូតដល់ ៦០ នាក់ត្រូវបានដឹកចេញតាមឡាន[2519]។ អតីតអ្នកទោសបានពន្យល់បន្ថែមថាអ្នកទោសត្រូវដឹកតាមឡានរៀងរាល់សប្តាហ៍ ឬរាល់ ១៥ ថ្ងៃម្តង[2520]។ អតីតអ្នកទោសម្នាក់ បានមើលឃើញការសម្លាប់អ្នកទោសប្រហែល ៦០នាក់។ សាក្សីរូបនេះបានរៀបរាប់ថា អ្នកទោសចំនួន ៦០នាក់ទាំងស្រី ទាំងប្រុសដែលជាប់ខ្នោះដៃ ត្រូវបាននាំចេញពីឡាន និងថាពួកគេត្រូវបានសម្លាប់ *"ដោយកាប់សម្លាប់ម្តងមួយៗទំលាក់ទៅក្នុងត្រពាំងសេ ឬអណ្តូង"*[2521]។ ហេតុការណ៍នេះត្រូវបានបញ្ជាក់ផងដែរ ដោយអតីតកងសន្តិសុខម្នាក់ដែលតែងតែចូលរួមក្នុងការសម្លាប់អ្នកទោស[2522]។

**៥៨៥.** សាក្សី (ដែលមិនបានឃើញការសម្លាប់) បានបញ្ជាក់ថាបានឃើញគេដឹកអ្នកទោសតាមឡានចេញពីមន្ទីរសន្តិសុខ និងមិនឃើញអ្នកទោសទាំងនោះត្រឡប់មកវិញឡើយ។ សាក្សីខ្លះបានឃើញឡានត្រឡប់មកវិញដោយគ្មានមនុស្ស[2523]។ ជាទូទៅ មិនមានអ្នកទោសណាដឹងថា អ្នកទោសត្រូវបាននាំទៅទីណាឡើយ[2524] ហើយគេក៏ព្យាយាមធ្វើមិនដឹង ដោយបញ្ជាឱ្យបិទទ្វា និងបង្អួច ដើម្បីមិនឱ្យអ្នកណាម្នាក់មើលឃើញឡានចាកចេញទៅ[2525]។ អ្នកទោសត្រូវបានគេប្រាប់ថា អ្នកទោសទាំងនោះនឹងត្រូវបានគេដោះលែង[2526]។ សាក្សីម្នាក់ត្រូវបានកងសន្តិសុខគំរាមសម្លាប់បើគាត់និយាយប្រាប់គេអំពីជោគវាសនារបស់អ្នកបាត់ខ្លួន[2527]។

**៥៨៦.** ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបំភ្លឺថា នៅក្នុងឆ្នាំ១៩៧៨ នៅពេលដែល [លុប] ត្រូវបានចាត់តាំងមកជំនួស [លុប] ហើយការសម្លាប់អ្នកទោសមានការថយចុះ[2528]។ ការអះអាងនេះ ស៊ីសង្វាក់គ្នាជាមួយនឹងសក្ខីកម្មដែលពន្យល់ថា ក្នុងចុងឆ្នាំ ១៩៧៨ អ្នកទោសខ្លះត្រូវបានដោះលែងចេញពីមន្ទីរសន្តិសុខភូមិភាគឧត្តរដើម្បីយកទៅអប់រំនៅទីកន្លែងផ្សេងទៀត[2529]។

**៥៨៧.** ទោះបីជាមានការលំបាកក្នុងការប៉ាន់ប្រមាណអំពីចំនួនអ្នកទោសនៃមន្ទីរសន្តិសុខនេះ ដែលត្រូវបាន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605447



សម្លាប់ ប៉ុន្តែសក្ខីកម្មនានាបង្ហាញថាអាចមានចំនួនច្រើនពាន់នាក់។ ការស៊ើបសួរបានបង្ហាញថា ទីតាំង ចំការទ្រឹញវ៉ាញត្រូវបានគាស់កាយមួយផ្នែក ហើយថាឆ្អឹងសាកសពត្រូវបានរកឃើញ និង ត្រូវបានដាក់តម្កល់នៅក្នុងបូជនីយដ្ឋានក្នុងវត្តថ្មី[2530]។ ប្រធានក្រុមការងារដែលបង្កើតឡើងដោយក្រសួងវប្បធម៌នាដើមទសវត្សរ៍ឆ្នាំ១៩៨០ ដើម្បីប្រមូលឆ្អឹងសាកសពនៅខេត្តសៀមរាប បានពន្យល់ថា៖ *"ក្រុមរបស់ខ្ញុំបានមើលជុំវិញទីតាំង ដើម្បីប្រមូលឆ្អឹងដែលមានសល់ ដាក់ក្នុងថង់អំបិល ហើយនាំយកទៅទុកក្នុងវត្តថ្មី ដែលត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៨៣។ រហូតដើមឆ្នាំ ១៩៨៤ ដែលបូជនីយដ្ឋានត្រូវបានកសាងដើម្បីដំកល់ឆ្អឹងដែលនៅសល់។ ទីតាំងដែលយើងខ្ញុំប្រមូលមកនោះ គឺ យកមកពីវត្តធម្មយុត្តិផង វត្តថ្មីផង និងផ្លូវទៅសួនសត្វផង។ សាកសពប្រមូលមិនទាន់អស់នៅឡើយ។ សរុបចំនួនសាកសពទាំងបីកន្លែង ប្រហែលជា ៥.០០០ទៅ ៦.០០០នាក់។ ជនរងគ្រោះស្លៀកពាក់ខ្មៅ ហើយមួយចំនួនមានស្លាបព្រាចងភ្ជាប់នៅចង្កេះ។ មានសញ្ញាស្លាកស្នាមនៅលើលលាដ៍ក្បាល ដែលទំនងជាស្នាមវាយ ដៃរបស់គេត្រូវបានចងទៅខាងក្រោយជាមួយខ្សែនីឡុង ឬខ្សែអង្រឹង ហើយមានលលាដ៍ក្បាលក្មេងតូច"*[2531]។

***

៥៨៨. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់ (សាមសិបមួយនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភូមិ ភាគឧត្តរ[2532]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភូមិភាគឧត្តរ។

## មន្ទីរសន្តិសុខអូរកន្សែង[2533]

### ទីតាំង និងការបង្កើត

៥៨៩. មន្ទីរសន្តិសុខដែលមានឈ្មោះហៅថា "មន្ទីរអប់រំកែប្រែអូរកន្សែង"[2534] (ត្រូវបានគេហៅឈ្មោះខុសៗគ្នាថាជាមន្ទីរសន្តិសុខអូរកន្សែង[2535] ឬសាលាកែប្រែកងពល៨០១[2536] ឬគុកកងពល

៨០១[2537]) មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងនៅចន្លោះចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧[2538] ចំណុះឱ្យកងពល៨០១[2539] នៃកងទ័ពបដិវត្តន៍កម្ពុជា និងបានដំណើរការមករហូតដល់ការមកដល់របស់កងទ័ពវៀតណាម[2540]។ មន្ទីរសន្តិសុខអូរកន្សែង ស្ថិតនៅភូមិ៦ (មិនមែនភូមិ៣ ដូចដែលបានលើកដោយភាន់ច្រឡំនោះទេ) ក្នុងឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី នៅជិតអូរមួយដែលមានឈ្មោះហៅថាអូរកន្សែង[2541] ក្បែរមន្ទីរពេទ្យបច្ចុប្បន្នរបស់ខេត្តរតនគិរី[2542]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីសកម្ពុជា មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងតំបន់១០២ របស់ភូមិភាគឦសាន្ត[2543]។

**៥៩០.** កងពល៨០១របស់មជ្ឈិម[2544] ត្រូវបានបង្កើតឡើងដោយការបញ្ចូលគ្នានូវកងពលលេខ១១ និងកងពលលេខ១៤ ដែលជាកងពលពីរក្នុងចំណោមកងពលទាំងបីរបស់ភូមិភាគពិសេស[2545] ដោយស្ថិតនៅក្រោមបញ្ជារបស់គណៈកម្មាធិការយោធាមជ្ឈិមបក្ស ប.ក.ក តាមរយៈ **សុន សេន**[2546] ដែលជាប្រធានអគ្គសេនាធិការ ក.ប.ក[2547]។ កងពល៨០១នេះមាន [លុប] ហៅ [លុប] ជាមេបញ្ជាការកងពល[2548] និង **សាន** ហៅ ០៦ ជាមេបញ្ជាការរង[2549] ហើយនៅឆ្នាំ១៩៧៦ **តាសាន** ត្រូវបានជំនួសដោយ **កែវ សារឿន**[2550]។ នៅចុងឆ្នាំ១៩៧៥ កងពល៨០១ ត្រូវបានបញ្ជូនឱ្យមកឈរជើងនៅខេត្តរតនគិរី របស់ភូមិភាគឦសាន្ត[2551]។ គោលនយោបាយសម្រាប់អនុវត្តនៅកងពល៨០១ ត្រូវបានសម្រេចឡើងដោយមជ្ឈិម[2552] នាពេលប្រជុំអគ្គសេនាធិការ ដោយមានការចូលរួមប្រជុំរបស់ [លុប] ដែលនៅក្នុងកិច្ចប្រជុំនោះ គាត់បានរាយការណ៍អំពីការងារផ្សេងៗជូន **សុន សេន**[2553]។ [លុប] បានឆ្លើយឆ្លងទូរលេខជាមួយអគ្គសេនាធិការនៅភ្នំពេញ[2554] ដោយផ្ញើទូរលេខពីអង្គភាពសារទូរលេខនៃទីបញ្ជាការកងពល៨០១ និងត្រឡប់មកវិញ **សុន សេន** បានណែនាំរាល់សកម្មភាពការងាររបស់កងពល៨០១[2555]។

**៥៩១.** ការបង្កើតមន្ទីរសន្តិសុខអូរកន្សែងធ្វើឡើងស្របពេល ឬក៏បន្ទាប់ពីមានការចាប់ និងការសម្លាប់ **ម៉ែន** សាន ហៅ **យ៉ា** ដែលគាត់ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦[2556]។ ការបង្កើតមន្ទីរសន្តិសុខនេះបង្ហាញឱ្យឃើញ តាមរយៈទំនាក់ទំនងរវាង **សុន សេន** និងកងពល៨០១។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ **សារឿន** បានចូលរួមប្រជុំថ្នាក់កងពលមជ្ឈិម និងកងវរៈសេនាធំឯករាជ្យ តាមការកោះហៅរបស់ **សុន សេន** ដែលនៅក្នុងកិច្ចប្រជុំនោះ **សុន សេន** បានបញ្ជាថា “*ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អតទៅទៀត*” ដោយក្នុងនោះឱ្យប្រមូលសមាសភាពមិនល្អដាក់មួយកន្លែងជាពិសេសដើម្បីធ្វើការអប់រំ[2557]។ នៅឯកិច្ចប្រជុំមួយទៀតនាថ្ងៃទី១៩

ខែកញ្ញា ឆ្នាំ១៩៧៦ **សុន សេន** បានបញ្ជាក់អំពីការគំរាមកំហែងរបស់ *"ខ្មាំងលើផ្ទៃក្នុងប្រទេស និងក្នុងជួរយើង"* ដោយប្រកាសចាត់វិធានការថា *"ត្រូវមានជំហរដាច់ខាត សម្រិតសម្រាំងសមាសភាពប្រឆាំងបដិវត្តន៍ កុំស្ទាក់ស្ទើរ"*[2558]។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ **សុន សេន** បានផ្ញើ "មតិណែនាំ មកកងពល៨០១" មកឲ្យ **សារឿន** ដោយបង្គាប់ឲ្យចាត់វិធានការប្រឆាំងនឹងពួកខ្មាំងដែលចង់ *"បង្កប់ស៊ីរូងផ្ទៃក្នុង កងទ័ពយើង និងមូលដ្ឋាន"*[2559]។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ **សារឿន** បានរាយការណ៍ត្រលប់ទៅ **សុន សេន** វិញថា *"ចំពោះអ្នកដែលខ្មាំងឆ្លើយដាក់ត្រូវពិនិត្យឯកសារ ហើយស្នើចាប់ខ្លួនបណ្ដោះអាសន្ន"* នៅខណៈពេលដែល *"អ្នកសេរីដើរហើរ ឬល្មើសវិន័យ អំប៉ំរំហើយមិនស្ដាប់ ត្រូវមានវិធានការដកទុកមួយជុំ តាមដាន"* **សារឿន** បានបន្ថែមថាគាត់ *"វង់ចាំមតិណែនាំរបស់បក្ស"* [2560]។

**៩៩២.** បរិវេណមន្ទីរសន្តិសុខ គ្មានរបងព័ទ្ធជុំវិញទេ[2561] មានទំហំប្រហែល២០០ ម៉ែត្របួនជ្រុង[2562] និងបែងចែកចេញជាអគារមួយចំនួនស្ថិតនៅដាច់ពីគ្នា[2563] ក្នុងនោះមានអគារសម្រាប់ដាក់អ្នកទោសពី ៤ ទៅ ៥ អគារ ដែលក្នុងចំណោមអគារទាំងនោះ មានអគារពីរសម្រាប់ដាក់អ្នកទោសកម្រិតធ្ងន់[2564]។ មន្ទីរសន្តិសុខនេះត្រូវបានប្រើប្រាស់ជាកន្លែងសម្លាប់មនុស្សផងដែរ ដោយនៅខាងក្នុងបរិវេណមន្ទីរសន្តិសុខ ចម្ងាយប្រហែល១៥០ម៉ែត្រពីគុក មានរណ្ដៅសាកសពចំនួនប្រហែល១០ រណ្ដៅ[2565] ប៉ុន្តែសាកសពភាគច្រើនត្រូវបានយកទៅកប់នៅក្នុងរណ្ដៅគ្រាប់បែកបេ៥២[2566] ដែលស្ថិតនៅក្រៅបរិវេណគុក[2567]។

## ដំណើរការប្រព្រឹត្តទៅ

### រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក

**៩៩៣.** កម្មាភិបាលមកពីទីបញ្ជាការកងពល៨០១ នៅវ៉ឺនសៃ ត្រូវបានបញ្ជូនឲ្យមកធ្វើការនៅអូរកន្សែង[2568]។ [លប់] ត្រូវបានតែងតាំងដោយមេបញ្ជាការកងពល៨០១ ឈ្មោះ តា **សារឿន**[2569] ឲ្យធ្វើជាប្រធានមន្ទីរសន្តិសុខអូរកន្សែង[2570]។ [លប់] ជាអនុប្រធាន[2571] ទទួលបន្ទុកសួរចម្លើយ និងរៀបចំឯកសារអ្នកទោស។ [លុប][2572] ទទួលបន្ទុកចាត់ចែង និងគ្រប់គ្រងការងារសន្តិសុខ និងយាមកាម រួមមានកងសន្តិសុខ និងអ្នកយាមមួយចំនួនទៀតផងដែរ[2573]។

**៩៩៤.** មន្ទីរសន្តិសុខអូរកន្សែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គភាពទ័ព៨០៦[2574] ចំណុះឲ្យកងពល៨០១ ដែលអង្គភាពនោះមាននាទីទទួលខុសត្រូវខាងឃ្លាំង ខាងភស្តុភារ និងខាងដឹកជញ្ជូន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

រួមទាំងផ្នែកផ្សេងៗទៀតនៃមន្ទីរសន្តិសុខនេះផង[2575]។ អង្គភាព ៨០៦ មាន តា ស្មៀន ជាប្រធាន និង [លុប] ជាអនុប្រធាន ហើយ [លុប] ទទួលបន្ទុកភស្តុភារ[2576]។ នៅចុងឆ្នាំ១៩៧៨ តា ស្មៀន ត្រូវបានចាប់ខ្លួន និងបញ្ជូនមកកាន់ភ្នំពេញ[2577] តំណែង របស់ តា ស្មៀន ត្រូវបានជំនួសដោយ តា ម៉ុន[2578]។

៩៩៥. ថ្នាក់ដឹកនាំរបស់មន្ទីរសន្តិសុខអូរកន្សែងមានកិច្ចប្រជុំការងារជាមួយ សូ សារឿន រៀងរាល់ បី ឬបួន ខែម្តង ប៉ុន្តែអាចមានការប្រជុំបន្ទាន់ផងដែរក្នុងករណីចាំបាច់។ មានសន្និបាតភូមិភាគប្រចាំឆ្នាំផងដែរ[2579]។ ទំនាក់ទំនងការងាររវាងមន្ទីរសន្តិសុខអូរកន្សែង និងមេដឹកនាំកងពល៨០១ គឺចេញពី [លុប] តាមរយៈប្រធានអង្គភាព៨០៦[2580] ប៉ុន្តែចំពោះការងារសំខាន់ មន្ទីរសន្តិសុខអាចរាយការណ៍ដោយផ្ទាល់ទៅកងពល[2581]។ ក្នុងឋានៈជាលេខាកងវរៈសេនាតូច ស្មៀន ធ្លាប់ចូលរួមប្រជុំរៀនសូត្រវគ្គសេនាធិការដែលធ្វើឡើងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ ដែលមានកម្មាភិបាលមកពីកងពល៨០១ សរុបចំនួន៣១នាក់ចូលរួម[2582]។

៩៩៦. ផ្ទុយមកវិញ ការទទួលបញ្ជាណែនាំផ្សេងៗពីថ្នាក់លើ គឺធ្វើតាមខ្សែសង្វាក់បញ្ជាដូចរៀបរាប់ខាងលើ[2583] លើកលែងតែ ក្នុងពេលមួយឆ្នាំចុងក្រោយ ប្រធានមន្ទីរសន្តិសុខអូរកន្សែងត្រូវបានណែនាំឲ្យរាយការណ៍ការងារទាំងអស់ទៅកងពល៨០១ផ្ទាល់ តាមការណែនាំរបស់ តា សុន (កម្មាភិបាលថ្នាក់ដឹកនាំដែលជាមនុស្សទីបីក្នុងគណៈកម្មាធិការកងពល៨០១) ដោយមិនឲ្យរាយការណ៍ឆ្លងកាត់អង្គភាព៨០៦ ទៀតទេ[2584]។

៩៩៧. [លុប] មិនសូវបានមកពិនិត្យមន្ទីរសន្តិសុខអូរកន្សែងទេ[2585] ប៉ុន្តែ [លុប] ជាប្រធានអង្គភាព៨០៦ បានមកពិនិត្យមន្ទីរសន្តិសុខអូរកន្សែងញឹកញាប់[2586] និងទទួលសេចក្តីរាយការណ៍ពីមន្ទីរសន្តិសុខនេះទៅឲ្យកងពល[2587]។ មិនមានភស្តុតាងបង្ហាញថាមានជនត្រូវចោទណាម្នាក់ធ្លាប់មកពិនិត្យមើលមន្ទីរសន្តិសុខអូរកន្សែងនោះទេ[2588]។

### ការចាប់ខ្លួន

៩៩៨. ថ្នាក់ដឹកនាំមន្ទីរសន្តិសុខអូរកន្សែងគ្មានអំណាចចាប់[2589] ឬក៏ដោះលែងអ្នកទោសទេ ប៉ុន្តែគ្រាន់តែចាំទទួលយកអ្នកទោសដែលគេចាប់បញ្ជូនមកឃុំឃាំង[2590] និងពិនិត្យរបាយការណ៍ដែលគេបានរាយការណ៍មក ព្រមទាំងតាមដានសកម្មភាពអ្នកទោសនោះនៅក្នុងគុក[2591]។

៥៩៩. អ្នកទោសដែលបាននាំចូលនិងបញ្ជូនចេញត្រូវបានកត់ត្រាជាឯកសារ[2592]។ នៅចន្លោះចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ មន្ទីរសន្តិសុខមានអ្នកទោសប្រហែលពី ១០ ទៅ៤០ នាក់[2593] (អ្នកទោសទាំងអស់សុទ្ធតែជាយុទ្ធជនបញ្ជូនមកពីអង្គភាពចំណុះកងពល៨០១[2594])។ នៅឆ្នាំ១៩៧៨ ចំនួនអ្នកទោសបានកើនឡើងជាង ១០០នាក់[2595]។ សាក្សីម្នាក់បានបំភ្លឺថាមានអ្នកទោសចំនួន ៤០០ ទៅ ៦០០ នាក់នៅក្នុងមន្ទីរសន្តិសុខនោះ[2596]។ នៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខអូរកន្សែងមានដាក់អ្នកទោសចម្រុះ ដូចជា ប្រជាជន និងកងទ័ព[2597] ដែលអ្នកទោសជាប្រជាជនមកពីសហករណ៍[2598] កម្មករចំការកៅស៊ូ និងប្រជាជនធម្មតាមកពីតំបន់១០១[2599]។

៦០០. អ្នកទោសជាកងទ័ពត្រូវបានចាប់មកពីវរៈសេនាធំ ៨១ ៨២ និង៨៣[2600] ចំណុះឲ្យកងពល៨០១ តាមបញ្ជារបស់ **សូ សារឿន**[2601]។ យុទ្ធជនរបស់កងពល៨០១ ដែលត្រូវបានចាប់គឺយុទ្ធជនដែលចាត់ទុកថាជាសមាសភាពសេរី ដោយសារមិនគោរពវិន័យយោធា[2602] ប្រើពាក្យរិះគន់បក្ស[2603] ឬមានការឆ្លើយដាក់នៅក្នុងចម្លើយសារភាពមកពីភ្នំពេញ[2604]។ ចម្លើយសារភាពអាចដំបូងផ្ញើមកឲ្យ **សូ សារឿន** ហើយបន្ទាប់មកបញ្ជូនទៅកាន់អង្គភាពយោធាសាមី ដើម្បីធ្វើការចាប់ខ្លួន និងបញ្ជូនអ្នកដែលមានចម្លើយឆ្លើយដាក់មកកាន់មន្ទីរសន្តិសុខអូរកន្សែង[2605]។ អ្នកទោសមកដល់មន្ទីរសន្តិសុខ ដោយមានចម្លើយសារភាពរបស់ពួកគេជាប់មកជាមួយផងដែរ។

៦០១. នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ លេខាភូមិភាគឦសាន្ត ឈ្មោះ **វី** បានផ្ញើទូរលេខ ដោយសរសេរថា "*សូមរាយការណ៍ជូនបងជាទីគោរព*" មានចម្លងជូន ដូចជា **នួន ជា, អៀង សារី** និង **សុន សេន**[2606] ដោយជូនដំណឹងថា "*ពួកអាបង្កប់នៅចំការកៅស៊ូ-កញ្ចាស់ និងអង្គភាពកងចល័តដែលដកពីយោធាឆ្នាំ៧៤ បានសំរេចឲ្យ* [លុប] (ជាកម្មាភិបាលកងពល៨០១[2607]) *រកវិធីយកដោយស្ងាត់*"។ តាមរយៈនេះ កម្មករសហដីពចំការកៅស៊ូត្រូវបានចាប់ខ្លួន តាមបញ្ជារបស់ ឈ្មោះ [លុប] ហៅ [លុប] ហៅ [លុប] ប្រធានសហដីពចំការកៅស៊ូភូមិភាគឦសាន្ត[2608] និងជាសមាជិកគណៈភូមិភាគផងដែរ[2609]។ កម្មករសហដីពត្រូវបានចាប់ខ្លួន ដោយសារមូលហេតុផ្សេងៗមួយចំនួន ដូចជាខុសវិន័យក្នុងការរស់នៅប្រចាំថ្ងៃ និយាយការពារប្រពន្ធមានផ្ទៃពោះដែលត្រូវបានគេចាប់[2610] រិះគន់បក្ស[2611] ឬត្រូវបានចោទប្រកាន់ថាបានប្រើប្រាស់ "*បច្ចេកទេសរបស់វណ្ណៈសក្តិភូមិ មិនមែនបច្ចេកទេសកសិករទេ*"[2612]។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ទូរលេខរបស់លេខាភូមិភាគឦសាន្ត ឈ្មោះ **វី** បានសរសេរបន្ថែមថា "*ទាំងអស់ក្រោយបានចម្លើយក៏ផុតសំឡេងច្បាស់*

00605452



*និងសុំសម្រេចកម្រិតខ្ពស់ទាំងអស់*'[2613]។

៦០២. អ្នកទោសដែលចាប់មកពីសហករណ៍នានា ត្រូវបានបញ្ជូនមកដោយប្រធានសហករណ៍ ជាមួយនឹងរបាយការណ៍អំពីកំហុសរបស់អ្នកទោស[2614]។ អ្នកទោសភាគច្រើនត្រូវបានចាប់ខ្លួនដោយសារតែបទល្មើសតូចតាច ដូចជាលួចរបស់ហូបជាដើម[2615]។

៦០៣. អតីតអ្នកទោសនៅមន្ទីរសន្តិសុខស្រុកស្ទៀងបានអះអាងបន្ថែមថា មានអ្នកទោសជាជនជាតិភាគតិចចារ៉ាយប្រហែល ១០០[2616] ទៅ២៥០ នាក់[2617]ត្រូវបានចាប់ខ្លួនផងដែរ។

៦០៤. អ្នកទោសត្រូវបានដឹកតាមរថយន្តមកកាន់មន្ទីរសន្តិសុខជាញឹកញាប់[2618]។ អ្នកទោសខ្លះ នៅពេលចាប់ខ្លួនមិនមានដាក់ខ្នោះទេ[2619] អ្នកខ្លះទៀតត្រូវបានភ្ជង់កាំភ្លើង ហើយបណ្ដើរទៅកាន់បន្ទប់រៀងៗខ្លួន[2620]។ ការចាប់ខ្លួនកម្មករសហជីពគឺធ្វើឡើងជាក្រុម[2621]។

## ការឃុំឃាំង

៦០៥. អ្នកទោសខ្លះត្រូវបានដាក់ខ្នោះដោយខ្សែក ឬ ដាក់ខ្នោះជើងរួមគ្នាមួយខ្សែធ្វើពីសរសៃដែកដែលមួយខ្សែមានអ្នកទោសពី ៥ ទៅ ១០នាក់[2622]។ ប្រជាជនធម្មតា ស្ត្រី និងក្មេងមិនត្រូវបានដាក់ច្រវ៉ាក់ ខ្នោះទេ[2623]។ អ្នកទោសស្រី និងប្រុសដាក់នៅដាច់ពីគ្នា[2624]។ អ្នកទោសភាគច្រើនត្រូវបាននាំចេញទៅធ្វើការនៅពេលថ្ងៃ និងនៅពេលយប់ត្រូវបានចាក់សោរឲ្យនៅក្នុងបន្ទប់ឃុំឃាំងដោយមានសន្តិសុខយាមនៅខាងក្រៅ[2625] អ្នកទោសខ្លះទៀតត្រូវបានដាក់ខ្នោះឲ្យនៅតែក្នុងបន្ទប់ឃុំឃាំងរហូត[2626]។ អ្នកទោសគេឲ្យធ្វើការងារដោយមានការតាមមើលពីកងសន្តិសុខ[2627]។ ពួកគេធ្វើការងារផ្សេងៗ ឧទាហរណ៍ដូចជា បោចស្មៅ ធ្វើស្រែ ដាំបន្លែ កាប់ដី និងលើកទំនប់ ភ្លឺស្រែ[2628] ជាដើម។ ការប្រជុំអប់រំកែប្រែមានទៀងទាត់សម្រាប់អ្នកទោស ដែលការប្រជុំនោះដឹកនាំដោយប្រធានមន្ទីរសន្តិសុខ បន្ទាប់ពីគាត់បានទៅប្រជុំជាមួយប្រធានកងពល ឈ្មោះ តា **សារឿន**[2629]។

៦០៦. ស្ថានភាពរស់នៅមានលក្ខណៈលំបាកខ្លាំងណាស់ ជាពិសេសចំពោះអ្នកទោសដែលជាប់ច្រវ៉ាក់ ឬជាប់ខ្នោះ[2630]។ នៅពេលដែលអ្នកទោសមិនត្រូវបានដាក់ខ្នោះ ពួកគេអាចងូតទឹកនៅក្នុងស្រះក្បែរនោះដោយមានការការពារពីកងសន្តិសុខ[2631]។

៦០៧. តាមការបំភ្លឺរបស់អតីតអនុប្រធានមន្ទីរសន្តិសុខថា អ្នកទោសដែលមិនជាប់ច្រវាក់មានអាហារហូបគ្រប់គ្រាន់[2632]។ ប៉ុន្តែ សាក្សីភាគច្រើនបានប្រាប់ឲ្យដឹងថាការហូបចុកមិនគ្រប់គ្រាន់ទេ[2633] លើកលែងតែសាក្សីម្នាក់ (ដែលធ្វើការនៅរោងបាយ)។ អតីតអ្នកជាប់ឃុំឃាំងម្នាក់បានផ្ដល់សក្ខីកម្មថា បានឃើញមានករណីស៊ីសាច់មនុស្ស[2634]។

៦០៨. សុខភាពរបស់អ្នកទោសបានចុះទ្រុឌទ្រោម ទៅតាមពេលវេលានៃការឃុំឃាំងនៅក្នុងគុក[2635]។ តាមការបំភ្លឺរបស់សាក្សីខ្លះឲ្យដឹងថា គ្មានថ្នាំព្យាបាលជម្ងឺទេ[2636] ខណៈពេលដែលមានសាក្សីផ្សេងទៀតបានប្រាប់ថា ពេលខ្លះ មានពេទ្យកងពលម្នាក់ឈ្មោះ [លុប] ព្យាបាលដោយស្ពាវថ្នាំឲ្យអ្នកជំងឺលេប[2637] ហើយមានពេលមួយនោះ អ្នកទោសម្នាក់ត្រូវបានគេឲ្យទៅបេះស្លឹកចំបក់យកមកស្ងោរជាមួយកន្ទក់ឲ្យអ្នកទោស ដែលមានជម្ងឺម្នាក់ទៀតហូប[2638]។ អ្នកទោសជាច្រើនបានស្លាប់ដោយសារជម្ងឺ និងអាហារមិនគ្រប់គ្រាន់[2639]។

៦០៩. **សូ សារឿន** បានបង្ហាប់ថា បើមានអ្នកទោសណាប្រព្រឹត្តបទល្មើសតូចតាច ឬបានកែប្រែខ្លួនល្អហើយនោះ អាចបញ្ជូនពីមន្ទីរសន្តិសុខអូរកន្សែង ទៅមន្ទីរអប់រំកែប្រែ៨០៩[2640] នៅភ្នំកាច់ចង្កេះ[2641] ជិតអូរតាង ដែលមន្ទីរនេះរាយការណ៍ផ្ទាល់ទៅកងពល៨០១ តែម្ដង[2642]។

**ការសួរចម្លើយ**

៦១០. នៅក្នុងបរិវេណមន្ទីរសន្តិសុខ មានអគារសួរចម្លើយដោយឡែក[2643]។ ការសួរចម្លើយធ្វើឡើងដោយអនុប្រធានមន្ទីរសន្តិសុខ ឈ្មោះ [លប់][2644]។ អ្នកទោសភាគច្រើនមិនត្រូវបានសួរចម្លើយនៅពេលមកដល់មន្ទីរសន្តិសុខភ្លាមៗនោះទេ[2645] ដោយត្រូវទុកនៅក្នុងបន្ទប់ឃុំឃាំងសិន ដើម្បីឲ្យខាងមន្ទីរសន្តិសុខមានពេលអានឯកសារពាក់ព័ន្ធនឹងសកម្មភាពរបស់អ្នកទោសនោះ[2646] ឬអ្នកទោសត្រូវបានគេហៅសួរពីប្រវត្តិរូប និងពីមូលហេតុនៃការចាប់ខ្លួនរបស់ពួកគេ[2647]។

៦១១. [លប់] អនុប្រធានមន្ទីរសន្តិសុខបានពន្យល់ថា គាត់ "*មិនដែលធ្វើទារុណកម្មអ្នកទោសទេ ប៉ុន្តែ អាចមានការធ្វើទារុណកម្មអ្នកទោសដោយកងសន្តិសុខ*"[2648]។ ចំណែក [លប់] បានរៀបរាប់ថា "*ការធ្វើទារុណកម្មមានខ្លះដែរ ប៉ុន្តែមិនមានទាំងអស់នោះទេ*"[2649]។ [លប់] បំភ្លឺថា អ្នកទោសខ្លះត្រូវបានវាយនឹងរំពាត់ ឆក់ដោយចរន្តអគ្គីសនី ដោយសារតែពួកគេត្រូវបានសង្ស័យថាលាក់លៀមមិនព្រមឆ្លើយការពិត[2650]។ តាមការបំភ្លឺឲ្យដឹងរបស់អ្នកធ្លាប់ជាប់ឃុំឃាំងថា មិនមានការប្រព្រឹត្ត



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

អាក្រក់ណាមួយធ្វើឡើងចំពោះពួកគេទេ នៅក្នុងពេលស្សួរចម្លើយ[2651] ប៉ុន្តែ មានអ្នកខ្លះថាមានការប្រព្រឹត្តិយ៉ាងធ្ងន់ធ្ងរទៅលើអ្នកទោសក្នុងពេលស្សួរចម្លើយ[2652]។ ភាគច្រើនមានការធ្វើទារុណកម្មផ្លូវចិត្ត ដោយឲ្យហូបតិច ធ្វើការងារច្រើន ហើយគ្មានសេរីភាពក្នុងការដើរហើរទេ[2653]។

**៦១២.** [លប់] ជាអ្នកធ្វើរបាយការណ៍អំពីការស្សួរចម្លើយ ហើយបញ្ជូន ទៅឲ្យ [លប់][2654] ដែលជាអ្នកផ្ញើចម្លើយសារភាព និងលទ្ធផលនៃការស្សួរចម្លើយបន្ថែម តាមរយៈមេបញ្ជាការអង្គភាព ៨០៦ ទៅឲ្យ **សូ សារឿន** នៅថ្នាក់កងពល[2655] ដើម្បីសុំមតិណែនាំ[2656]។

**៦១៣.** អ្នកស្សួរចម្លើយម្នាក់ឈ្មោះ [លុប] មកពីភ្នំពេញមកធ្វើការនៅគុកអូរកន្សែងប្រហែលជាពីរ ឬ បីខែ នាពាក់កណ្តាលឆ្នាំ១៩៧៧[2657]។ **សូ សារឿន** ធ្លាប់និយាយប្រាប់ [លប់] ដោយផ្ទាល់ថា [លុប] មកពីសេនាធិការ នៅក្នុងកងអង្គភាព៧០៣ ដែលនៅក្រោមបញ្ជាការរបស់ **ពីន**[2658] ហើយមក "*ធ្វើការងារជាមួយ* [លប់] *ដើម្បីតាមដានប្រវត្តិសកម្មភាពអ្នកទោសដែលមានចម្លើយផ្ញើយដាក់មកពីភ្នំពេញ*"[2659]។ [លុប] ក៏ធ្លាប់ប្រាប់ [លប់] ដោយផ្ទាល់ដែរថា នឹងមានមនុស្សមកពីភ្នំពេញមកធ្វើការនៅ គុកអូរកន្សែង[2660]។ [លុប] បានលិខិតឧទ្ទេសនាមមកពីភ្នំពេញ[2661] និងមកដល់អូរកន្សែងដោយនាំមកជាមួយនូវចម្លើយសារភាពមានចំណារប៊ិចពណ៌ក្រហម ដោយសរសេរថា អ្នកទោសឈ្មោះនេះត្រូវស្សួររកបណ្តាញ និង សកម្មភាពរបស់ពួកគេ[2662]។ ណូ ខ្លួនឯងផ្ទាល់ធ្លាប់ប្រាប់ [លប់] ថាមុនមកគុកអូរកន្សែង គាត់ធ្វើការនៅកងពលលេខ១២[2663] ហើយ "*អង្គភាពរបស់គាត់ គឺនៅកន្លែងស្សួរចម្លើយ ឬកន្លែងសន្តិសុខ ស្ថិតនៅអតីតសាលាទួលស្វាយព្រៃ*"[2664]។ អនុប្រធានមន្ទីរសន្តិសុខនេះយល់ថា ណូ ប្រហែលជាមកពីមន្ទីរ ស-២១[2665] ទោះបីជា **ឌុច** បានបញ្ជាក់ថា តាមគាត់ចាំគឺគ្មានមនុស្សឈ្មោះនេះទេ[2666]។

**៦១៤.** តាមការរៀបរាប់របស់ [លប់] បានឲ្យដឹងថា [លុប] បានមកដល់មន្ទីរសន្តិសុខអូរកន្សែង ប្រហែលជា ពីរ ឬបីខែ បន្ទាប់ពីការចាប់កម្មាភិបាល និងបញ្ជាជនមួយក្រុមរបស់កងពល៨០១[2667]។ ចាប់ពីខែធ្នូ ឆ្នាំ១៩៧៦ មានការពិភាក្សាគ្នារវាង **សុន សេន** ជាមួយ **សារឿន** និងកម្មាភិបាលផ្សេងទៀតរបស់កងពល៨០១ អំពីការសម្រិតសម្រាំងកម្មាភិបាលថ្នាក់ដឹកនាំកងពល៨០១ និងកម្មាភិបាលថ្នាក់ស្រុកនៅក្នុងអង្គការចាត់តាំងនយោបាយរបស់ភូមិភាគឦសាន្ត[2668]។ នៅឆ្នាំ ១៩៧៧ កងពល៨០១ បានក្លាយជាកម្មវត្ថុនៃការសម្រិតសម្រាំងយ៉ាងធ្ងន់ធ្ងរ ដោយកម្មាភិបាលកងពល និងកងវរៈសេនាធំមួយចំនួនត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១[2669] ចំណែក

ឯកម្មាភិបាលថ្នាក់ក្រោម និងយុទ្ធជនធម្មតាត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង។

៦១៥. បន្ទាប់ពីការមកដល់របស់ [លុប] កម្មាភិបាលជាច្រើនដែលនៅក្នុងអង្គភាពរបស់ **ឡាយ សារីម** ត្រូវបានចាប់ខ្លួន ហើយនាំមកកាន់មន្ទីរសន្តិសុខអូរកន្សែង[2670]។ [លុប] បានចូលរួមសួរចម្លើយអ្នកទោសបួននាក់ ដែលជាកម្មាភិបាលឋានៈធំៗរបស់កងពល៨០១[2671] រាប់បញ្ចូលទាំងកម្មាភិបាលនៃអតីតកងពលលេខ ១១ ដែលនៅក្នុងកងពលនោះ **ឡាយ សារីម**[2672] (ដែលត្រូវបានគេចាប់ខ្លួនមកកាន់មន្ទីរ ស-២១ នាខែមករា ឆ្នាំ១៩៧៧[2673]) ជាប្រធាន មុនពេល **ឡាយ សារីម** ក្លាយមកជាប្រធានមន្ទីរពេទ្យលេខ៨០៥ របស់កងពល៨០១។ [លុប] បានរៀបចំការសួរចម្លើយជាមួយ [លប់] [2674] ដោយសួរកម្មាភិបាលថ្នាក់អនុសេនាធំ ឈ្មោះ **ផេង ផយ** ក្នុងកងវរសេនាធំរបស់ **ឡាយ សារីម** ក្នុងកងពលចាស់លេខ១១ របស់ **តា** ទាញ[2675] និងកម្មាភិបាលថ្នាក់អនុសេនាតូចបីរូប មានឈ្មោះ **ពត** ឈ្មោះ **សំរិន** និងឈ្មោះ **ធា**[2676]។ នៅក្នុងពេលសួរចម្លើយ [លុប] អាចយោងទៅលើចម្លើយសារភាពដែលគាត់យកមកពីភ្នំពេញដែលមានការឆ្លើយដាក់អ្នកទាំងនោះ[2677]។ [លុប] ខ្លួនគាត់ផ្ទាល់បានធ្វើរបាយការណ៍ដោយខ្លួនឯងផ្ទាល់ ហើយនាំយករបាយការណ៍ទៅអគ្គសេនាធិការ នៅឯភ្នំពេញ[2678]។

**ការសម្លាប់មនុស្ស និងការបាត់ខ្លួន**

៦១៦. មេដឹកនាំមន្ទីរសន្តិសុខអូរកន្សែងមិនមានសិទ្ធិអំណាចធ្វើការសម្រេចសម្លាប់អ្នកទោសទេ[2679]។ កាលបរិច្ឆេទនៃការយកអ្នកទោសទៅសម្លាប់ត្រូវបានកត់ត្រាទុក និងធ្វើស្ថិតិរាយការណ៍ជូនទៅកងពលក្នុងករណីចាំបាច់[2680]។

៦១៧. ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៧៦ **សារឿន** បានចាប់ផ្តើមរាយការណ៍ពីការចាប់ខ្លួន "យួន" ដោយអង្គភាពរបស់កងពល៨០១[2681] និងលេខាភូមិភាគឦសាន្ត ឈ្មោះ **វី** ក៏បានរាយការណ៍ផងដែរពីការចាប់ខ្លួនវៀតណាមដោយកងពល[2682]។

៦១៨. ទូរលេខចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ធ្វើដោយ **វី** ហៅ "**អ៊ុំ នាង**" ក្នុងឋានៈគាត់ជា លេខាភូមិភាគឦសាន្ត ជូន "បងជាទីគោរព" ចម្លងជូនដូចជា **នួន ជា** និង **អៀង សារី** បានរាយការណ៍អំពីការចាប់ខ្លួនកងទ័ពយួនជាជនជាតិចារ៉ាយចំនួន ២០៩នាក់ ធ្វើឡើងដោយកងពល៨០១ តាមពាក្យពេចន៍ដូចតទៅ *"...នៅម៉ោង០៩ ព្រឹកថ្ងៃទី១៤ ខែមិថុនា នេះ កងផលិត៨០១ ប្រចាំ១០៧*

*ល្បាតចាប់បានកងពលទ័ពយួនចំនួន២០៩ នាក់ក្នុងនោះមាននារី ៩នាក់ នៅម្តុំអូរល្អក់ខាងត្បូង ផ្លូវលេខ១៩ [?] ចំងាយ៤គីឡូ សឹងទាំងអស់ជាជនជាតិចារ៉ាយ និយាយខ្មែរប៉ែឡាំ។ បានបញ្ជូនមកទុកដាក់ហើយ [...] តាមកងផលិត៨០១ ស្នើសម្រេចកម្រិតខ្ពស់តែម្តង។ ខ្ញុំរង់ចាំចម្លើយយល់ព្រមសម្រេចរបៀបនេះ*"[2683]។

**៦១៩.** សូ សារឿន បានកោះហៅ [លប់] ឲ្យទៅជួប រួចប្រាប់ថាឲ្យពួកគាត់ "*ដោះស្រាយជនជាតិចារ៉ាយនោះទៅ*" [...] *ពាក្យ "ដោះស្រាយ" [មានន័យថា] "សម្លាប់ចោល*"[2684]។

**៦២០.** តាមការឲ្យដឹងរបស់ [លប់] "*មានការចាប់ជនជាតិចារ៉ាយពីព្រំដែនវៀតណាមមក ដោយសារតែជនជាតិចារ៉ាយទាំងនោះ វៀតណាមបានកៀរទៅនៅទឹកដីវៀតណាម*"[2685]។ [លប់] បានបញ្ជាក់ថា ជនជាតិចារ៉ាយទាំងនោះត្រូវបានចោទប្រកាន់ថា ជាទាហានធីរគី[2686] ហើយត្រូវបានគេហៅថា "*ជនជាតិហ្វូរ៉ូ*"[2687]។

**៦២១.** ការសម្លាប់ជានជាតិចារ៉ាយបានធ្វើឡើងជាបន្តបន្ទាប់។ ជនជាតិចារ៉ាយទាំងប្រុស ស្រី និងក្មេង[2688] ត្រូវបាននាំមកមន្ទីរសន្តិសុខអូរកន្សែង[2689] អ្នកទាំងនោះត្រូវបានចាប់ចងជាខ្សែ និងបញ្ជូនចេញតាមឡាន[2690] ដោយមានកងសន្តិសុខដែលមកពីតំបន់ មកពីកងកាំភ្លើងធំ៨០៣[2691] និងកងសន្តិសុខរបស់មន្ទីរសន្តិសុខអូរកន្សែង[2692] ចូលរួមយកទៅសម្លាប់នៅរណ្តៅគ្រាប់បែកបេ៥២ ចម្ងាយ ប្រហែលមួយគីឡូម៉ែត្រពីមន្ទីរសន្តិសុខ[2693]។

**៦២២.** នៅចុងឆ្នាំ១៩៧៨[2694] នៅក្នុងតំបន់អូរយ៉ាដាវ មានអ្នកទោសជនជាតិវៀតណាមមួយក្រុមចំនួន ៦នាក់[2695] ក្នុងនោះមានស្រីម្នាក់ផងត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ តាមបញ្ជារបស់ សូ សារឿន[2696] ដោយមានយោធាដែលបានចាប់អ្នកទាំងនោះជាអ្នកបណ្តើរយកទៅសម្លាប់[2697]។

**៦២៣.** តាមការបំភ្លឺរបស់អនុប្រធានមន្ទីរសន្តិសុខថា ការសម្លាប់មនុស្សដ៏ច្រើនក្នុងពេលតែមួយប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខអូរកន្សែងមានតែម្តងគត់[2698]៖ គឺការសម្លាប់ពួកជនជាតិចារ៉ាយ។ ប៉ុន្តែ ថ្នាក់ដឹកនាំមន្ទីរសន្តិសុខ បានផ្តល់តួលេខចំនួនអ្នកស្លាប់ប្រហែលរាប់រយនាក់ ភាគច្រើនកម្មករសហជីព ឬប្រជាជនមកពីសហករណ៍បានស្លាប់ដោយសារជំងឺ មិនមែនដោយសារការសម្លាប់ទេ[2699]។ ទោះ

បីជាយ៉ាងណាក៏ដោយ សាក្សីខ្លះបានបំភ្លឺថាមានការសម្លាប់មនុស្សជាលក្ខណៈបុគ្គលក៏កើតមានឡើងផងដែរ[2700] ជាពិសេសនាចុងឆ្នាំ១៩៧៨។ ជាឧទាហរណ៍ **សូ សារឿន** បានបញ្ជា [លប់] ដោយផ្ទាល់ឲ្យយកអ្នកទោសទៅសម្លាប់ ចំពោះអ្នកទោសទាំងឡាយណាដែលមិនកែខ្លួន បន្ទាប់ពីអប់រំកែប្រែ[2701]។ ចំពោះអ្នកទោសណាដែលលួចរត់ ហើយត្រូវគេចាប់បានមកវិញ ត្រូវបានបាញ់សម្លាប់ចោល[2702]។ សាក្សីពីរនាក់បានផ្តល់សក្ខីកម្មថា មានអ្នកទោសស្រីម្នាក់ត្រូវបានចោទប្រកាន់ថាខុសសីលធម៌ ត្រូវបានពុះខ្នងយកប្រម៉ាត់ ហើយយកទៅព្យួរនៅចង្ក្រានបាយ[2703]។ ប៉ុន្តែ បញ្ហាសម្លាប់នេះត្រូវបានបដិសេធដោយប្រធានមន្ទីរសន្តិសុខអូរកន្សែងថា មិនមានហេតុការណ៍នេះកើតឡើងទេ[2704]។ សាក្សីមួយចំនួនទៀតអះអាងថា មិនបានឃើញ និងមិនបានឮ អំពីការសម្លាប់នេះទេ[2705]។ ចុងក្រោយមានការបំភ្លឺប្រាប់ឲ្យដឹងថា មានអ្នកទោសបីនាក់បានចងកសម្លាប់ខ្លួន[2706]។

***

៦២៤. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន **0៥ នាក់ (ប្រាំនាក់)** ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង[2707]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឲ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខអូរកន្សែង។

## មន្ទីរសន្តិសុខ "ភ្នំក្រោល" [2708]

### ទីតាំង និងការបង្កើត

៦២៥. មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅក្នុងឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី[2709]។ មន្ទីរសន្តិសុខនេះមានទំនាក់ទំនងជាមួយនឹងមន្ទីរ ក-១១[2710] នៃតំបន់១០៥ ដែលនៅជិតនោះ និងលេខាតំបន់១០៥ ដែលមានមន្ទីរ ក-១៧[2711] ជាទីបញ្ជាការ។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅក្នុងតំបន់ ១០៥ ដែលត្រូវបានគេស្គាល់ថា "តំបន់មណ្ឌលគិរី"[2712]។ មន្ទីរសន្តិសុខភ្នំក្រោល បានកើតមានរួចទៅហើយនៅក្នុងឆ្នាំ១៩៧៥[2713]។ មណ្ឌលគិរីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគឦសានរហូតដល់ចុង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605458



ឆ្នាំ១៩៧៦[2714] ជាពេលដែលមណ្ឌលគិរីបានក្លាយទៅជាតំបន់ស្វយ័ត ដែលឋិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មជ្ឈិម[2715] ។

៦២៦. គុកភ្នំក្រោលធ្វើពីឈើ ក្រាលរនាបឬស្សី មានដំបូលប្រក់ស្បូវ[2716]។ មន្ទីរ ក-១៧ ជាអគារមានកម្ពស់ពីរជាន់ ជញ្ជាំងក្ដារ ប្រក់ស័ង្កសី។ មន្ទីរនេះដំណើរការជាកន្លែងធ្វើការរបស់លេខាតំបន់ ១០៥ និងធ្លាប់ជាកន្លែងឃុំខ្លួនបណ្ដោះអាសន្នមួយរយៈពេលផងដែរ[2717]។ មន្ទីរ ក-១១ ស្ថិតនៅចម្ងាយប្រហែល ១ គីឡូម៉ែត្រភាគឦសានពីគុកភ្នំក្រោល[2718] ដែលដំណើរការជាមន្ទីរឃុំឃាំង និងជាកន្លែងធ្វើការរបស់កងទ័ព[2719]។ មន្ទីរនេះធ្វើអំពីឈើ មានដំបូលប្រក់ស្បូវ ជញ្ជាំងឬស្សី និងក្រាលរនាបក្ដារ[2720]។

៦២៧. ត្រពាំងព្រីង (ដែលគេស្គាល់ថាជាទួលខ្មោច) គឺជាកន្លែងសម្លាប់មនុស្សរបស់មន្ទីរសន្តិសុខនេះ។ ត្រពាំងព្រីងមានទីតាំងចម្ងាយប្រមាណ ៤ គីឡូម៉ែត្រ ពីកោះញែក តាមបណ្ដោយផ្លូវឆ្ពោះទៅខេត្តក្រចេះ[2721]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក**

៦២៨. លេខាតំបន់១០៥ ដែលធ្លាប់ធ្វើការនៅមន្ទីរ ក-១៧ រួមមានឈ្មោះ **ហម ហៅ ឡាំង** ហើយក្រោយមកហៅ **ឆាន**[2722] (ស្លាប់ដោយស្ថានភាពមិនច្បាស់លាស់នៅឆ្នាំ១៩៧៧)[2723] ហើយចុងក្រោយមានឈ្មោះ [លប់] ដែលបានក្លាយជាលេខាតំបន់នៅខែកញ្ញា ឆ្នាំ១៩៧៨[2724]។ បន្ទាប់ពីការស្លាប់របស់ **ឡាំង** នៅតំបន់ ១០៥ ត្រូវបានធ្វើការបោសសំអាតយ៉ាងសំបើម ហើយមនុស្សមួយចំនួនត្រូវបានចាប់ខ្លួនបញ្ជូនទៅភ្នំក្រោល[2725] ។ អនុលេខាតំបន់មានឈ្មោះ **សូ គឹមអាន ហៅ ម៉ី**[2726] (ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ១៩៧៧)[2727] ឈ្មោះ **ចាំ**[2728] ឈ្មោះ **ផាក់**[2729] និងឈ្មោះ **លក**[2730]។ សមាជិកដែលទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចមានឈ្មោះ **ខាំ ភួន** (ស្លាប់ដោយស្ថានភាពមិនច្បាស់លាស់នៅឆ្នាំ១៩៧៧)[2731]។ **សូភា** គឺជាសមាជិកគណៈតំបន់ ១០៥ ទទួលបន្ទុកផ្នែកយោធា និង សន្តិសុខ[2732] រហូតដល់ត្រូវបានចាប់ខ្លួននៅខែ វិច្ឆិកា ឬ ខែធ្នូ ឆ្នាំ១៩៧៨ [2733]។

៦២៩. កងពលធំលេខ៩២០ របស់មជ្ឈិមដែលត្រូវបានដាក់ពង្រាយនៅខេត្តមណ្ឌលគិរីនៅចុងឆ្នាំ១៩៧៥[2734] ហើយត្រូវបានណែនាំឲ្យមានការសហការឲ្យបានជិតស្និទ្ធជាមួយកម្មាភិបាលមូលដ្ឋាន

នៅទីនោះ ហើយត្រូវរាយការណ៍ក្នុងពេលជាមួយគ្នាទៅឲ្យមូលដ្ឋាន និងអគ្គសេនាធិការផងដែរ[2735]។ កងពលធំលេខ៩២០ ត្រូវបានធ្វើការបោសសំអាតនៅក្នុងឆ្នាំ១៩៧៦[2736] ហើយកម្មាភិបាលត្រូវបញ្ជូនទៅឲ្យមជ្ឈិម រីឯមជ្ឈិមក៏បានផ្ញើរាល់ចម្លើយសារភាពត្រឡប់មកកងពលលេខ៩២០ វិញដែរ ហើយមជ្ឈិមក៏ផ្ញើទៅថ្នាក់តំបន់ផងដែរនូវ ចម្លើយសារភាពរបស់បុគ្គលិកកងពល៩២០ ដែលទាក់ទិនជាមួយកម្មាភិបាលមូលដ្ឋាន[2737]។

**៦៣០.** មន្ទីរសន្តិសុខភ្នំក្រោល ស្ថិតក្រោមការគ្រប់គ្រងរបស់កងទ័ព។ កងទ័ពតំបន់មានពីរកងវរៈសេនាតូច គឺកងវរៈសេនាតូចលេខ១ និងកងវរៈសេនាតូចលេខ២[2738]។ កងវរៈសេនាតូចលេខ២ មានទីតាំងឈរជើងនៅភ្នំក្រោល[2739] ដែលមានឈ្មោះ **ឡេង** ជាមេបញ្ជាការកងវរៈសេនាតូចនេះរហូតដល់ពេលត្រូវចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៨[2740]។ មេបញ្ជាការកងអនុសេនាធំឈ្មោះ **វឿង** ហៅ **ខាំ**[2741] និងឈ្មោះ **ម៉ុង** ហៅ **សៅ ចាំពី** ជាសមាជិក[2742]។

**៦៣១.** ប្រធានមន្ទីរសន្តិសុខភ្នំក្រោលគឺមានឈ្មោះ **ឡេង**[2743] រីឯឈ្មោះ [លុប] ជាអនុប្រធាន[2744] ហើយឈ្មោះ [លុប] ជាសមាជិកគណៈ[2745]។ គណៈតំបន់ និងកងទ័ពត្រូវរាយការណ៍ផ្ទាល់ទៅឲ្យគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[2746]។

**៦៣២.** មានទំនាក់ទំនងព័ត៌មានជាប្រចាំរវាងគណៈមជ្ឈិម និងតំបន់១០៥ ហើយឯកសារអង្គលីលេខសម្ងាត់ត្រូវបានផ្ញើពីថ្នាក់ស្រុកទៅមជ្ឈិម រួចពីមជ្ឈិមមកស្រុកតាមរយៈមន្ទីរ ក-១៧[2747]។ មន្ទីរក-១៧ចេញការណែនាំត្រឡប់ទៅថ្នាក់ស្រុក ហើយធ្វើរបាយការណ៍បូកសរុបការងារប្រចាំថ្ងៃនៅថ្នាក់ស្រុកផងដែរ[2748]។ លេខាតំបន់ ១០៥ រាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិម ដើម្បីសុំយោបល់ ជាពិសេសទៅលើជនសង្ស័យ[2749]។ ការសួរចម្លើយគិញ "វៀតណាម" ក៏ត្រូវធ្វើជារបាយការណ៍ទៅឲ្យមជ្ឈិមដែរ[2750]។ ឯកសារដែលវាយដោយអង្គលីលេខ ភាគច្រើនផ្ញើទៅមន្ទីរមជ្ឈិម ៨៧០ និង មន្ទីរ ក-៣[2751]។ ចំពោះសារពាក់ពន្ធ័កិច្ចការសុខាភិបាល ឬសង្គមកិច្ច គឺពុំមានវាយជាអក្សរសម្ងាត់ទេ គឺវាយជាអក្សរធម្មតា ហើយផ្ញើរទៅឲ្យ **ខៀវ សំផន** រួច **ខៀវ សំផន** ផ្តល់ការណែនាំត្រលប់មកវិញ[2752]។ ចំពោះសារទាក់ទិននឹងបញ្ហាសន្តិសុខត្រូវផ្ញើទៅឲ្យ **នួន ជា** ។ សាក្សីមួយរូបបាននិយាយថា" *... នួន ជា បានណែនាំមកជា ប្រចាំអំពីការងារសន្តិសុខ ការប្រយ័ត្នប្រយែងខ្មាំងមានខ្មាំងវៀតណាម ឬខ្មាំងបង្កប់ អំពីមហិច្ឆតារបស់វៀតណាម ការងារសតិអារម្មណ៍ដែលត្រូវណែនាំបន្តដល់ថ្នាក់ស្រុក*"[2753]។

៦៣៣. សាក្សីម្នាក់បាននិយាយថា ការប្រជុំប្រចាំខែគឺធ្វើនៅមន្ទីរ ក-១១ ដែលមានអ្នកចូលរួមពីគណៈតំបន់ កងទ័ពតំបន់ និងគណៈស្រុក[2754]។ សាក្សីផ្សេងបាននិយាយថាការប្រជុំត្រូវបានធ្វើឡើងនៅក្នុងមន្ទីរអប់រំថ្នាក់តំបន់ និងមន្ទីរអប់រំថ្នាក់ស្រុក[2755] ហើយថា *"គណៈតំបន់បាននាំពាក្យរបស់ថ្នាក់មជ្ឈិមមកពន្យល់(យើង)"* ដោយគូសបញ្ជាក់ថា *"...ឲ្យតាមដានខ្មាំងបង្កប់ (ដែលទាក់ទងជាមួយវៀតណាម)... និងខ្មាំងក្បត់"*[2756]។

**ការចាប់ខ្លួន និងការឃុំឃាំង**

៦៣៤. អតីតអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោលដែលត្រូវបានស្ដាប់ចម្លើយ បាននិយាយថា ពួកគេត្រូវបានចាប់ខ្លួន ដោយសារត្រូវបានគេសង្ស័យថាជាជនក្បត់បដិវត្តន៍ អាចជាការជាប់ពាក់ព័ន្ធជាមួយវៀតណាម[2757] ឬអាចត្រូវបានចោទថាជាខ្មែរយៈសេរីអា[2758]។ ជាទូទៅ ការចោទប្រកាន់ត្រូវបានធ្វើឡើងនៅពេលប្រជុំទិតៀន ឬស្វ័យទិតៀន[2759]៖ *"រៀងរាល់ពេលល្ងាច បន្ទាប់ពីហូបបាយរួច ពួកវាតែងតែប្រជុំ ដោយនិយាយចោទថា ពួកខ្ញុំទាំងអស់គ្នា ជាសេរីអា"*[2760]។ បន្ទាប់ពីចាប់ខ្លួន អ្នកទោសត្រូវតែសរសេរប្រវត្តិរូបរបស់ខ្លួន[2761]។

៦៣៥. អ្នកទោសត្រូវបានចាប់ដោយកម្មាភិបាល ប.ក.ក ហើយនាំទៅមន្ទីរសន្តិសុខភ្នំក្រោល[2762] រីឯអ្នកខ្លះត្រូវចាប់ខ្លួននៅមន្ទីរ ក-១១ ក្រោយពីបានកោះហៅឲ្យមកប្រជុំ[2763]។ ការចាប់ខ្លួនមួយចំនួន ត្រូវបានចេញបញ្ជាពីលេខាតំបន់ ហើយអ្នកអនុវត្តបទបញ្ជាគឺ សមាជិកតំបន់ទទួលបន្ទុកកិច្ចការកងទ័ព ដោយមានការជួយពីកម្មាភិបាលកងទ័ពតំបន់ និងកម្មាភិបាលសន្តិសុខ ចំពោះកងពលធំលេខ៩២០ គឺមានសិទ្ធិធ្វើការចាប់ខ្លួនទាំង កម្មាភិបាលតំបន់ ប្រជាជន និងកងទ័ព ដោយលេខាតំបន់ឈ្មោះ [លុប] មានបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ឃុំ[2764] ដំបូងអ្នកទោសខ្លះត្រូវឃុំនៅថ្នាក់ស្រុក ឬនៅសហករណ៍ រួចផ្ទេរទៅភ្នំក្រោល[2765]។

៦៣៦. សាក្សីម្នាក់បាននិយាយថា ពេលមកដល់មន្ទីរសន្តិសុខភ្នំក្រោល គាត់ត្រូវគេដាក់ខ្នោះជើងព្យួរឡើងលើ អស់រយៈពេល ២៤ ម៉ោង[2766]។ សាក្សីម្នាក់ទៀតបាននិយាយថា គេចងជើងគាត់ជាប់នឹងកៅអី និងចងស្លាបសេក[2767] ខណៈដែលអ្នកជាប់ទោសផ្សេងទៀតត្រូវគេដាក់ខ្នោះជើងជាប់រហូតដល់មន្ទីរសន្តិសុខភ្នំក្រោល[2768]។ ខ្នោះខ្លះដាក់អ្នកទោសបានម្នាក់ ខ្លះអាចដាក់អ្នកទោសបានពី ៤ ឬ ៥ នាក់[2769] ហើយខ្នោះខ្លះអាចដាក់អ្នកទោសរហូតដល់ទៅ ២០នាក់[2770]។ អ្នកទោសត្រូវបាន

គេដាក់ខ្នោះពេលយប់[2771] ប៉ុន្តែយោងតាមសក្ខីកម្មមួយចំនួន អ្នកទោសស្រាលមិនត្រូវបានគេដាក់ខ្នោះទេ ដោយពេលថ្ងៃគេឱ្យអ្នកទោសទាំងនោះធ្វើការ[2772]។

៦៣៧. នៅមន្ទីរ ក-១១ អ្នកទោសត្រូវបានឃុំឃាំងបណ្តោះអាសន្នក្នុងស្ថានភាពដូចៗគ្នា[2773]។ នៅអំឡុងខែវិច្ឆិកា ឆ្នាំ១៩៧៧ មានអ្នកទោសប្រហែល ៤០នាក់ ត្រូវឃុំខ្លួនដោយចងឱ្យដេកនៅជាន់ក្រោមផ្ទាល់ដីនៅមន្ទីរ ក-១៧ ហើយមានអ្នកទោសប្រហែល ៥នាក់ ត្រូវគេឃុំនៅជាន់ទីមួយ[2774]។ ពាក់ពន្ធ័នឹងចំនួនអ្នកទោសដែលបានជាប់ឃុំនៅមន្ទីរសន្តិសុខភ្នំក្រោល មានសាក្សីមួយរូបបាននិយាយថា មានអ្នកទោស ៨០នាក់[2775] រីឯ សាក្សីម្នាក់ទៀតបាននិយាយថា អាចមានអ្នកជាប់ឃុំរហូតដល់ ៣៨៥ នាក់ [2776] ។

៦៣៨. អ្នកទោសស្រាលនៅមន្ទីរសន្តិសុខភ្នំក្រោលត្រូវគេបង្ខំឱ្យធ្វើការនៅពេលថ្ងៃ[2777] ដោយដៃមានជាប់ចំណង[2778]។ អ្នកទោសត្រូវបានយាមកាមគ្រប់ពេលវេលា[2779]។ ការហូបចុកនៅមន្ទីរសន្តិសុខភ្នំក្រោលមិនគ្រប់គ្រាន់ទេ ហើយជាក់ស្តែងអ្នកទោសទាំងអស់មានសភាពទ្រុឌទ្រោម និងស្គមស្គាំង[2780]។

## ការសួរចម្លើយ

៦៣៩. សាក្សីជាច្រើនបាននិយាយថា អ្នកជាប់ទោសត្រូវគេធ្វើបាបយ៉ាងខ្លាំងក្នុងពេលសួរចម្លើយនៅមន្ទីរសន្តិសុខភ្នំក្រោល។ សាក្សីម្នាក់បានរៀបរាប់ថាគាត់ត្រូវបានគេចងជើងឡើងលើ ក្បាលចុះក្រោម រួចសួរចម្លើយ[2781]។ សាក្សីម្នាក់ទៀតជាអតីតអ្នកទោសបានផ្តល់សក្ខីកម្មថា មានក្មេងប្រុសម្នាក់អាយុ ៨ ឆ្នាំជាកូនរបស់ស្ត្រីអ្នកជាប់គុកត្រូវពួកនារីយាមគុកចងព្យួរជើងឡើងទៅលើ ទុកទាល់តែស្រក់ឈាមពេញភ្នែក[2782]។ ផ្ទុយទៅវិញសាក្សីផ្សេងទៀតបាននិយាយថា ការធ្វើបាបធ្ងន់ធ្ងរមិនមានញឹកញាប់ទេ ឬគ្មានតែម្តង[2783] សាក្សីមួយរូបបាននិយាយថា *"ការសួរចម្លើយមិនមានការធ្វើទារុណកម្មទេ តែមានការសំឡុតគំរាមខ្លាំងៗ"*[2784]។ ចំណុចនេះមានការអះអាងដូចគ្នានឹងសំដីអតីតកងទ័ពម្នាក់ដែលធ្លាប់ធ្វើការនៅមន្ទីរសន្តិសុខភ្នំក្រោល[2785]។

៦៤០. ក្នុងពេលសួរចម្លើយ អ្នកទោសត្រូវបានគេសួរចម្លើយអំពីខ្សែបណ្តាញសេអ៊ីអា និង/ឬខ្សែរៀតណាមរបស់ពួកគេ[2786]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605462



ការសម្លាប់ និងការបាត់ខ្លួន

៦៤១. សាក្សីមួយរូបបាននិយាយថា អ្នកទោសដែលនាំយកទៅមន្ទីរសន្តិសុខភ្នំក្រោលមានឱកាសរស់តិចតួចណាស់[2787] អតីតអ្នកទោសជាច្រើនបានរៀបរាប់អំពីរបៀបដែលអ្នកទោសដូចគ្នាត្រូវគេវាយរហូតដល់ស្លាប់[2788] ហើយបានផ្តល់សក្ខីកម្មបន្ថែមទៀតថា បានឃើញអ្នកទោសត្រូវបានគេដឹកចេញនៅពេលយប់ ហើយមិនដែលឃើញត្រឡប់មកវិញទេ[2789]។ ចំពោះមន្ទីរ ក-១១ សាក្សីម្នាក់បាននិយាយថា " *កាលខ្ញុំនៅការដ្ឋាន ខ្ញុំបានឃើញមនុស្សប្រហែល ៣០នាក់ ត្រូវបានគេដឹកចេញចូលពីរ បីថ្ងៃម្តង។ អ្នកដែលដឹកចេញគឺយកទៅសម្លាប់*"[2790]។ សាក្សីម្នាក់បាននិយាយថា កងសន្តិសុខម្នាក់នៅមន្ទីរ ក-១១ បានប្រាប់គាត់ថា "*អ្នកដែលគេចាប់យកមកដាក់នៅក្នុងគុកនេះបានតែពីរឬបីថ្ងៃ ក្រោយមកត្រូវបានគេនាំយកទៅសម្លាប់*"[2791]។

៦៤២. ជាទូទៅ ការសម្លាប់ត្រូវបានធ្វើឡើងនៅត្រពាំងព្រីង[2792] ដែលជាកន្លែងសម្លាប់មនុស្សនោះស្ថិតនៅចម្ងាយប្រហែល ៤ គីឡូម៉ែត្រ តាមផ្លូវចេញពីមន្ទីរសន្តិសុខភ្នំក្រោល ឆ្ពោះទៅខេត្តក្រចេះ[2793]។ អ្នកទោសត្រូវបានគេដឹកចេញជាក្រុមៗទៅសម្លាប់[2794]។ សាក្សីម្នាក់ដែលធ្លាប់រស់នៅជិតកន្លែងសម្លាប់បាននិយាយថាជនរងគ្រោះមានប្រុសមានស្រីប្រហែល ២០០នាក់ ត្រូវបានកប់ក្នុងរណ្តៅតែមួយនៅត្រពាំងព្រីង[2795]។ ពេលខ្លះអ្នកទោសត្រូវបានគេសម្លាប់នៅក្បែរគុកភ្នំក្រោល[2796]។

***

៦៤៣. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៨នាក់ (ប្រាំបីនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល[2797]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំក្រោល។

**មន្ទីរសន្តិសុខវត្តធ្លក**[2798]

**ទីតាំង និងការបង្កើត**

៦៤៤. មន្ទីរសន្តិសុខវត្តធ្លកស្ថិតនៅប្រមាណ២៨ គីឡូម៉ែត្រ ភាគពាយ័ព្យក្រុងស្វាយរៀង នៅភូមិធ្លក ឃុំធ្លក

ស្រុកមានជ័យថ្មី (បច្ចុប្បន្នមានឈ្មោះថា ស្រុកស្វាយជ្រុំ)[2799] ខេត្តស្វាយរៀង[2800]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងតំបន់២៣[2801] ភូមិភាគបូព៌ា (២០៣)[2802]។ មន្ទីរសន្តិសុខវត្តធ្លករួមមានមន្ទីរមួយដែលតាំងនៅក្នុងភូមិធ្លក[2803] មន្ទីរឃុំឃាំងមួយមានទីតាំងនៅក្បែរវត្តធ្លក[2804] និងរណ្ដៅសាកសពមួយចំនួន[2805]។ ចេតិយរំឭកវិញ្ញាណក្ខន្ធមួយ ដែលដាក់ឆ្អឹងគាស់ចេញពីរណ្ដៅសាកសព មានទីតាំងនៅក្នុងភូមិនេះ[2806]។ ដើម្បីជាការឆ្លើយតបនឹងសំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណី មានការរកឃើញថា នៅពេល មន្ទីរសន្តិសុខវត្តធ្លកត្រូវបានបិទ អ្នកទោសដែលនៅសេសសល់ក្នុងមន្ទីរនេះត្រូវបានផ្ទេរទៅមន្ទីរសន្តិសុខផ្សេងទៀតនៅស្រុកមានជ័យថ្មី ដែលមានទីតាំងនៅភូមិបឹងរ៉ៃ ឃុំក្រោលគោ ចម្ងាយ១០គីឡូម៉ែត្រភាគខាងលិច[2807]។

៦៤៥. ប.ក.ក បានបណ្តេញព្រះសង្ឃចេញពីវត្តធ្លកមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[2808]។ សាក្សីនិយាយថាមន្ទីរសន្តិសុខវត្តធ្លកត្រូវបានបង្កើតឡើងក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីកាលបរិច្ឆេទនេះ[2809] តាមរយៈការផ្លាស់ទីលំនៅប្រជាជន និងអ្នកធ្វើការនៃមន្ទីរសន្តិសុខមុនឆ្នាំ១៩៧៥ នៅភូមិម៉ឺនសាយ (ឃុំអង្គតាសូ) ដែលមានចម្ងាយ៦គីឡូម៉ែត្រភាគពាយ័ព្យនៃភូមិធ្លក[2810]។ មន្ទីរសន្តិសុខវត្តធ្លកទំនងជាបានបន្តដំណើរការ[2811]ជាមន្ទីរសន្តិសុខស្រុកមានជ័យថ្មី[2812] រហូតដល់ តួនាទីជាមន្ទីរសន្តិសុខនេះ[2813] និងអ្នកទោសដែលនៅសល់ចុងក្រោយ[2814] ត្រូវបានផ្ទេរទៅបឹងរ៉ៃនៅដើមឆ្នាំ១៩៧៨ បន្ទាប់ពីមានការវាយចូលរបស់វៀតណាមក្នុងតំបន់នោះ[2815]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក**

៦៤៦. សាក្សីបានឱ្យដឹងថាខ្សែរយៈបញ្ជាដែលអនុវត្តដោយបក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេសបានដំណើរការនៅតំបន់ ២៣ អំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ ថ្នាក់ឃុំរាយការណ៍ទៅគណៈស្រុក ហើយគណៈស្រុករាយការណ៍បន្តទៅគណៈតំបន់[2816]។ សមាសភាពនៃគណៈឃុំ គណៈស្រុក និងគណៈតំបន់ទាំងនេះបានប្រែប្រួលតាមពេលវេលា ជាពិសេស បន្ទាប់ពីការបោសសម្អាតនៅស្រុកមានជ័យថ្មីនៅចុងឆ្នាំ១៩៧៧ និងពាក់កណ្តាលឆ្នាំ១៩៧៨។ **អ៊ុក សារ៉ាន ហៅ សូ** ទំនងជាលេខាតំបន់ ២៣ (ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៨) និងត្រូវបានជំនួសដោយ **ចាន់ ហៅ សេង ហុង**[2817]។ ទំនងជាមានផងដែរមន្ទីរសន្តិសុខតំបន់មួយដែលមានកម្មាភិបាលដឹកនាំក៏ត្រូវបានបោសសម្អាតផងដែរនៅពាក់កណ្តាលឆ្នាំ១៩៧៨[2818]។

៦៤៧. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្រុកស្វាយរៀងត្រូវបានបំបែក ហើយមន្ទីរសន្តិសុខវត្តធ្លកបាន ស្ថិតនៅក្នុងស្រុកថ្មី ឈ្មោះស្រុកមានជ័យថ្មី (ដែលក្រោយមកដាក់ឈ្មោះថា ស្រុកស្វាយជ្រុំ)[2819]។ សក្ខីកម្ម[2820] និងឯកសារ[2821] បានកំណត់អត្តសញ្ញាណលេខាស្រុកមានជ័យថ្មីចំនួនពីរនាក់បន្តបន្ទាប់គ្នា គឺ **ខៀវ** សាមិត និង **ផឹង** **សុន** ហៅ **សយ**)។ អ្នកទាំងពីរត្រូវបានបោសសម្អាត (**ផឹង** **សុន** ហៅ **សយ** បានចូលមន្ទីរស-២១ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨)។ **អាត** ទំនងជាលេខាឃុំធ្លក។

៦៤៨. សាក្សីនិយាយថា ប្រធានមន្ទីរសន្តិសុខវត្តធ្លកបានគ្រប់គ្រងលើលេខាមន្ទីរសន្តិសុខថ្នាក់ឃុំធ្លក ហើយធ្វើសេចក្តីសម្រេចចិត្តលើការចាប់ខ្លួននានា[2822]។ សាក្សីមួយរូបបាននិយាយថាទំនាក់ទំនងត្រូវបានធ្វើឡើងតាមនីរសារ[2823] ហើយនៅថ្នាក់ក្រោម ការទទួលបញ្ជាត្រូវបានធ្វើឡើងដោយផ្ទាល់មាត់[2824]។

៦៤៩. មន្ទីរសន្តិសុខវត្តធ្លកបានដំណើរការពីដំបូង ក្រោមការបញ្ជារបស់កម្មាភិបាលមកពីភូមិភាគបូព៌ា។ សមាសភាពច្បាស់លាស់នៃគណៈមន្ទីរសន្តិសុខនេះបានផ្លាស់ប្តូរតាមពេលវេលា ហើយពេលវេលានៃការផ្លាស់ប្តូរទាំងនេះមិនច្បាស់លាស់ទេ។[2825] ទោះយ៉ាងណាក៏ដោយ កម្មាភិបាលមួយរូបឈ្មោះ **វង់** **អោ** ដែលត្រូវបានគេស្គាល់ច្បាស់ថា បានគ្រប់គ្រងមន្ទីរសន្តិសុខវត្តធ្លក[2826]។ **អោ** ទំនងជាបានបន្តធ្វើជាប្រធានមន្ទីរនៅពេលមន្ទីរសន្តិសុខនេះត្រូវបានប្តូរទីតាំងទៅបឹងរ៉ៃ ជាទីកន្លែងដែលកម្មាភិបាលថ្នាក់ស្រុកផ្សេងទៀតតាំងនៅ[2827]។ អ្នកជាប់ឃុំម្នាក់នៅវត្តធ្លកចងចាំយ៉ាងច្បាស់ថា **អោ** ទើបត្រូវបានផ្ទេរទៅបឹងរ៉ៃនៅដើមឆ្នាំ១៩៧៨ ប៉ុណ្ណោះ គឺដំណាលគ្នាជាមួយនឹងអ្នកធ្វើការទាំងអស់នៅមន្ទីរសន្តិសុខ និងអ្នកទោសសេសសល់ចំនួន ៣០នាក់ នៅពេលដែលមន្ទីរសន្តិសុខវត្តធ្លកត្រូវបានបិទជាស្ថាពរ[2828]។

៦៥០. សាក្សីមួយចំនួន[2829]អះអាង ដោយស៊ីសង្វាក់គ្នាក្នុងករណីមួយចំនួនទៅនឹងបញ្ជីចាប់ខ្លួន និងឃុំឃាំងរបស់មន្ទីរ ស-២១[2830] ថា ក្នុងខែឧសភា ឆ្នាំ១៩៧៨ កម្មាភិបាលស្រុកមានជ័យថ្មី (រួមទាំងប្រធានមន្ទីរសន្តិសុខស្រុក **វង់** **អោ** និងកម្មាភិបាលដឹកនាំឃុំធ្លក **សុខ** **សារ៉េត**) ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលមជ្ឈិមនៅក្រោមការបញ្ជារបស់ **សុន** **សេន**[2831] ហើយថា យ៉ាងហោចណាស់មនុស្សមួយចំនួនត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ (ទួលស្លែង) ប្រហែលជាតាមរយៈវត្តធ្លក។ សាក្សីមួយរូបនិយាយថា បន្ទាប់ពីនោះមក ស្រុក រួមទាំងមន្ទីរសន្តិសុខវត្តធ្លក និងបឹងរ៉ៃ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ័ពមជ្ឈិម[2832]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៦៥១. សាក្សីអះអាងថា កងសន្តិសុខនៅក្រោមបង្គាប់ប្រមាណពី២០ ទៅ៣០ នាក់ បានធ្វើការនៅមន្ទីរ និងមន្ទីរឃុំឃាំងនៃមន្ទីរសន្តិសុខវត្តធ្លក ដោយពួកគេស្នាក់នៅក្នុងមន្ទីរដែលស្ថិតនៅក្នុងភូមិ ឬនៅវត្ត[2833]។ យ៉ាងណាក៏ដោយ ចំនួននេះអាចបានធ្លាក់ចុះមកនៅតិចជាង ១០ នាក់នាឆ្នាំ១៩៧៨ [2834]។

៦៥២. គ្មានភស្តុតាងណាមួយបញ្ជាក់ថា ជនត្រូវចោទណាម្នាក់បានធ្វើទស្សនកិច្ចដោយផ្ទាល់ នៅមន្ទីរសន្តិសុខវត្តធ្លកឡើយ[2835]។

## ការចាប់ខ្លួន និងការឃុំឃាំង

៦៥៣. សាក្សីមួយរូបដែលត្រូវបានស្តាប់ចម្លើយ ធ្លាប់ជាប់ឃុំនៅមន្ទីរសន្តិសុខវត្តធ្លក (ជាមួយនឹងគ្រួសាររបស់គាត់) ចាប់តាំងពីចុងឆ្នាំ១៩៧៧[2836]។ ការថ្លែងរបស់សាក្សីនានាបញ្ជាក់ថាប្រជាជនដែលជាប់ឃុំនៅមន្ទីរសន្តិសុខវត្តធ្លកភាគច្រើនគឺជាជនស៊ីវិលកម្ពុជា ភាគច្រើនជាជនជាតិខ្មែរ (មិនមែនជនជាតិបរទេស ឬនិគមជនជាតិភាគតិច)[2837] ដែលត្រូវបានចាប់ខ្លួនដោយសារមូលហេតុផ្សេងៗរួមទាំងការលួចចំណីអាហារ និងអាកប្បកិរិយាខុសសីលធម៌[2838]។ ប្រជាជនដែលត្រូវបានជម្លៀសចេញពីភ្នំពេញក្នុងឆ្នាំ១៩៧៥ និងអតីតបុគ្គលិកស៊ីវិល និងទាហាននៃរបបលន់ នល់ ទំនងជាត្រូវបានឃុំឃាំងនៅតាមបណ្តាគុកថ្នាក់ឃុំ ដូចជានៅវត្តបឹងរាំងជាដើម ជាជាងនៅមន្ទីរសន្តិសុខវត្តធ្លក[2839]។ ទោះជាយ៉ាងណាក៏ដោយ សាក្សីមួយរូបដែលធ្លាប់បានជាប់ឃុំឃាំងយល់ថា គ្រួសាររបស់គាត់ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៧ ដោយគាត់បញ្ជាក់ថា *"ដោយសារឪពុកខ្ញុំជានាយទាហាននៅក្នុងកងទ័ពលន់ នល់ ឬក៏ម្តាយខ្ញុំជាកូនចៅចិន ឬដោយសារតែយើងត្រូវចាត់ជាប្រជាជនថ្មី"*។ សាក្សីរូបនោះបានកត់សម្គាល់ថាប្រជាជនផ្សេងទៀតដែលនាំមកពីជុំវិញស្រុកត្រូវបានឃុំ បន្ទាប់ពីការវាយលុករបស់វៀតណាមនៅឆ្នាំ១៩៧៧[2840]។ សាក្សីនានានិយាយថាអ្នកទោសត្រូវបានបញ្ជូនមក មន្ទីរសន្តិសុខវត្តធ្លកពីមន្ទីរសន្តិសុខផ្សេងទៀតនៅក្នុងស្រុក[2841] ឬត្រូវបាននាំផ្ទាល់ទៅមន្ទីរសន្តិសុខវត្តធ្លកពីភូមិនៅជុំវិញនោះ និងឃុំនានានៃស្រុកមានជ័យថ្មី[2842]។ ទាំងបុរស ស្ត្រី និងកុមារត្រូវបានឃុំនៅមន្ទីរសន្តិសុខវត្តធ្លក[2843] ប៉ុន្តែសាក្សីមួយរូបដែលធ្លាប់ចេញចូលមន្ទីរឃុំឃាំងនោះជាទៀងទាត់បាននិយាយថា មន្ទីរឃុំឃាំងនេះបានដាក់ឃុំអ្នកទោសភាគច្រើនជាបុរស[2844]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605466



៦៥៤. អ្នកទោសមួយចំនួនត្រូវបាននាំជាដំបូងមកមន្ទីរនៅក្នុងភូមិផ្លកដើម្បីសួរចម្លើយ[2845]។ សាក្សីមួយរូបបានសង្កេតឃើញកងសន្តិសុខ *"បណ្តើរមនុស្សដែលជាប់ចំណង ដោយសន្តិសុខជិះកង់វាយអ្នកទោសដោយប្រើខ្សែតី ឆ្ពោះមកមន្ទីរសន្តិសុខ"*[2846]។ ក្រោយមក ពួកគេត្រូវបាននាំដោយថ្មើរជើងពីមន្ទីរនៅក្នុងភូមិផ្លកទៅមន្ទីរឃុំឃាំង ហើយជួនកាលអ្នកទោសត្រូវបានវាយដំនៅតាមផ្លូវ[2847]។ នៅក្នុងករណីផ្សេងទៀត អ្នកទោសខ្លះត្រូវបាននាំទៅដាក់នៅមន្ទីរឃុំឃាំងតែម្តង[2848]។

៦៥៥. មន្ទីរឃុំឃាំងនៅក្បែរវត្តត្រូវបានរុំព័ទ្ធដោយលួសបន្លា ហើយកងសន្តិសុខបានយាមអាគារគុកទាំងបីដែលធ្វើពីឈើ[2849]។ មានការអនុវត្តន៍វិន័យតឹងតែង[2850]។ សាក្សីបានឱ្យដឹងថាអ្នកទោសខ្លះត្រូវបានដាក់ខ្នោះ ឬចងដៃទៅក្រោយខ្នង ហើយអ្នកទោសដែលត្រូវបានចាត់ជាអ្នកទោស "ធ្ងន់" មិនត្រូវបានអនុញ្ញាតឱ្យធ្វើការនៅក្រៅបរិវេណគុកទេ[2851]។ អតីតអ្នកទោសមួយរូបនិយាយថាអ្នកទោសទាំងអស់លើកលែងតែកុមារតូចៗត្រូវបានដាក់ខ្នោះពេលមកដល់មន្ទីរឃុំឃាំង និងនៅពេលល្ងាច[2852]។

៦៥៦. អតីតអ្នកទោសរូបនោះបន្ថែមថា មិនមានអាហារគ្រប់គ្រាន់ឡើយ[2853] ហើយសាក្សីម្នាក់ទៀតសង្កេតឃើញថាអ្នកទោសស្ថិតក្នុងសភាពទ្រុឌទ្រោម និងស្លេកស្លាំង[2854]។ ឱសថតែមួយមុខដែលមាននោះត្រូវបានផលិតនៅក្នុងស្រុក និងមិនមានប្រសិទ្ធភាពឡើយ[2855]។ អ្នកទោសត្រូវបានបង្ខំឱ្យធ្វើការ នៅក្នុងមន្ទីរឃុំឃាំង។ អ្នកទោស "ស្រាល" រួមទាំងកុមារ[2856] ត្រូវឱ្យទៅធ្វើការនៅក្រៅមន្ទីរឃុំឃាំងនៅក្រោមការយាមកាម ដូចជា អូសអួន ឃ្វាលគោ រើសអាចម៍ក្របី និងអូសរទេះ លើកភ្លឺស្រែ។ ពួកគេធ្វើការធ្ងន់ជាងអ្នកមិនជាប់ទោស ហើយជើងទាំងពីរជាប់ខ្នោះឈើ[2857]។ សាក្សីមួយរូបបានឃើញអ្នកទោសត្រូវបានវាយនៅកន្លែងធ្វើការខាងក្រៅបរិវេណមន្ទីរឃុំឃាំង ដោយសារពួកគេធ្វើការមិនបានល្អ[2858]។

៦៥៧. ដោយសារមិនមានឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាណាមួយពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តផ្លក មានការលំបាក ក្នុងការប៉ាន់ប្រមាណចំនួនអ្នកទោសសរុបដែលជាប់ឃុំនៅ ទីនោះរវាងពីឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៨។ មន្ទីរឃុំឃាំងអាចដាក់អ្នកទោសប្រមាណពីរទៅបីរយនាក់ក្នុងមួយពេល[2859] ហើយសាក្សីមួយរូប ដែលបានសង្កេតមើលសកម្មភាពប្រចាំថ្ងៃក្នុងអំឡុងពេលខាងលើនេះអះអាងថាអ្នកទោសត្រូវបាននាំមកដោយថ្មើរជើង *"ក្នុងមួយថ្ងៃមានការបណ្តើរចូលមក ២ ឬ ៣ដងដែលសរុបមានមនុស្សចំនួន ៥ ទៅ ៦នាក់ ត្រូវបានគេចាប់បញ្ជូនមក"*[2860]។

ការសួរចម្លើយ

៦៥៨. សាក្សីមួយចំនួននិយាយយោងទៅដល់អ្នកជាប់ឃុំឃាំង ដែលត្រូវបាននាំមកសួរចម្លើយនៅមន្ទីរក្នុងភូមិធ្លក ប៉ុន្តែមិនមានពួកគេណាម្នាក់និយាយថាធ្លាប់មានវត្តមានក្នុងអំឡុងពេលសួរចម្លើយនោះទេ[2861]។ សាក្សីមួយរូបនិយាយថា អ្នកដែលត្រូវបានសួរចម្លើយមានជើងជាប់ខ្នោះ ហើយថាគាត់ *"បានឮសំឡេងស្រែកនៅពេលសួរចម្លើយ"* ខណៈដែលគាត់កំពុងឃ្វាលគោនៅជិតទីតាំងសួរចម្លើយនោះ[2862]។ សាក្សីមួយរូបអះអាងថា អគារវត្តធ្លកត្រូវបានប្រើដើម្បីសួរចម្លើយផងដែរ[2863]។ សាក្សីមួយរូបទៀតនិយាយថា នៅចុងឆ្នាំ១៩៧៧ គាត់ត្រូវបានចាប់ខ្លួន ហើយត្រូវបានចងបិទមុខ និងសួរចម្លើយ និងចោទថាបានពាក់ព័ន្ធនឹង លន់ នល់ (ក្បាលស) ប៉ុន្តែគាត់មិនបានបញ្ជាក់ទេថាតើព្រឹត្តិការណ៍នេះបានកើតឡើងនៅមន្ទីរសន្តិសុខវត្តធ្លក[2864]។

ការសម្លាប់

៦៥៩. សាក្សីមួយរូបនិយាយថាមិនមានការសម្លាប់ នៅមន្ទីរក្នុងភូមិទេ ប៉ុន្តែមានតែបន្ទាប់ពីការផ្ទេរទៅមន្ទីរឃុំឃាំងដែលនៅក្បែរនោះគាត់បានឃើញរណ្តៅថ្មីៗជាបន្តបន្ទាប់[2865]។ អតីតអ្នកជាប់ឃុំមួយរូបនិយាយថាអ្នកទោសដែលបានជួយកងសន្តិសុខ នៅពេលមានការសម្លាប់បានប្រាប់គាត់ថា *"ធ្លកគឺជាកន្លែងសម្លាប់មនុស្សដែលគេចាប់មកពីភូមិ និងឃុំផ្សេងៗ"*[2866]។ សាក្សីនានាក៏បានផ្តល់នូវសក្ខីកម្មអំពីហេតុការណ៍នៃការសម្លាប់អ្នកជាប់ឃុំឃាំង ដែលធ្វើការនៅខាងក្រោមមន្ទីរឃុំឃាំងដែលត្រូវបានកប់ទាំងរស់[2867] ឬដោយវាយឲ្យស្លាប់ដោយកងសន្តិសុខ[2868]។

៦៦០. សាក្សីមួយរូបបានឃើញបងប្រុសធម៌របស់គាត់ដែលជាអ្នកជាប់ឃុំឃាំងកំពុងជីករណ្តៅ និងបានប្រាប់គាត់ថា *"គេបានឲ្យខ្ញុំជីករណ្តៅដើម្បីកប់ខ្ញុំធ្វើជី"*។ នៅក្នុងឱកាសមួយផ្សេងទៀត គាត់បានឃើញកងសន្តិសុខបីនាក់លាងឈាមពីដៃ និងកាំបិតរបស់ពួកគេ ដែលក្នុងនោះ មានម្នាក់ប្រាប់គាត់ថា *"បងកុំភ័យអី ខ្ញុំសម្លាប់តែអ្នកអាក្រក់ទេ អ្នកល្អមិនអីទេ"*[2869]។ អ្នកជាប់ឃុំឃាំងម្នាក់បានឃើញអ្នកជម្ងឺផ្នែកស្មារតីមួយរូបត្រូវបានគេវាយ ហើយយកចេញទៅសម្លាប់ ដោយសារមិនបានដាក់រនុកដែកឲ្យបានត្រឹមត្រូវចូលទៅក្នុងខ្នោះជើងអ្នកទោសនៅពេលល្ងាចនោះ[2870]។

៦៦១. សាក្សីមួយរូបបានឃើញការសម្លាប់រង្គាលនូវ *"អ្នកទោសដែលត្រូវបានគេសម្លាប់ប្រហែលពី ៣០ ទៅ ៤០នាក់"* ខាងកើតវត្តធ្លក ចំនួនបីថ្ងៃបន្តបន្ទាប់គ្នានៅចុងឆ្នាំ១៩៧៥ ហើយគាត់អាចកំណត់

00605468



បង្ហាញរណ្តៅកប់សាកសពទាំងនោះបាន[2871]។ សាក្សីរូបនោះនិយាយថា *"ភាគច្រើនជាបុរសដែលមានចាប់ពីអាយុចាប់ពី២០ឆ្នាំឡើង"*។ ការសម្លាប់ត្រូវបានធ្វើឡើងដោយ *"កងសន្តិសុខ"* មួយក្រុម ស្លៀកពាក់ខ្មៅ និងមានកាំភ្លើងវែង ដែលបានបញ្ជាឲ្យអ្នកទោសផ្សេងទៀតជីករណ្តៅមុននឹងយកអ្នកទោសដែលជាប់ចំណង និងត្រូវបិទមុខចេញមកដើម្បីសម្លាប់។ កងសន្តិសុខបានប្រើ *"ត្បូងចប និងរនុកដែកសម្រាប់គាស់ដែកគោលប្រវែងប្រហែលកន្លះម៉ែត្រ វាយពីរ ឬ បីដង ជួនកាលលើកញ្ចឹងក ឬលលាដ៍ក្បាលផ្នែកខាងក្រោយ មុនពេលដែលពួកវាធាក់ទម្លាក់រណ្តៅ។"* សាក្សីរូបនោះបានសន្និដ្ឋានថា *"អ្នកទោសខ្លះមិនទាន់ស្លាប់ទេ"*។ អ្នកទោសមួយចំនួនចង់រត់គេច ហើយនៅពេលមួយនោះ អ្នកទោសពីរនាក់បានរត់គេច *"តែត្រូវបានសន្តិសុខព័ទ្ធបាញ់ប្រហារស្លាប់នៅក្បែរបរិវេណនោះ"*។ សាក្សីដដែលនេះកត់សម្គាល់ថា បន្ទាប់ពីការសម្លាប់បានបញ្ចប់ កងសន្តិសុខបានដើរត្រឡប់មកមន្ទីរឃុំឃាំងវិញ ហើយអ្នកទោសបានមកលប់រណ្តៅទាំងនោះ[2872]។

៦៦២. សាក្សីមួយរូបនិយាយថា គាត់បានឃើញអ្នកទោសស្ត្រីប្រាំមួយនាក់ជាប់ឃុំនៅក្នុងមន្ទីរក្នុងភូមិផ្គកជាទីកន្លែងដែលកងសន្តិសុខរស់នៅ[2873]។ សាក្សីម្នាក់ផ្សេងទៀតនិយាយជាពាក្យចចាមអារាមថា ស្ត្រីក្មេងៗសម្រស់ទាក់ទាញ ដែលឪពុកម្តាយរបស់ពួកគេជានិគមជនផ្សេងៗគ្នាជា *"កូនកាត់ចិន វៀតណាម ខ្មែរ ត្រូវបានកងសន្តិសុខប្រមូលមកធ្វើការនៅមន្ទីររបស់កងសន្តិសុខស្នាក់នៅ ហើយទ័ពខ្មែរក្រហមចាប់រំលោភស្ត្រីទាំងនោះ ហើយកាត់ប្រដាប់ភេទយកទៅហាលក្រោមដើមក្រសាំង និងសម្លាប់ចោល"*[2874]។ អតីតអ្នកជាប់ឃុំម្នាក់បានឆ្លើយស៊ីសង្វាក់ទៅនឹងសក្ខីកម្មនេះ និងបានបង្ហាញដើម*ក្រសាំង*នៅក្បែរមន្ទីរឃុំឃាំង ទីដែលគាត់បានឃើញប្រដាប់ភេទរបស់មនុស្សព្យួរនៅទីនោះនៅក្នុងឆ្នាំ១៩៧៨[2875]។

៦៦៣. អ្នកជាប់ឃុំម្នាក់ ដែលបានមកដល់មន្ទីរសន្តិសុខវត្តផ្គក នៅចុងឆ្នាំ១៩៧៧ បានឃើញមន្ទីរឃុំឃាំងគ្មានមនុស្ស ហើយឃើញ *"រណ្តៅសាកសពជាច្រើន ដែលចំហ និងមានសាកសពស្អុយរលួយ"* ចំនួន ៣០ ទៅ ៤០ រណ្តៅ នៅក្បែរអាគារមន្ទីរឃុំឃាំងនោះ។ បន្ទាប់មក គាត់បានឃើញរណ្តៅសាកសពច្រើនថែមទៀតនៅពេលធ្វើការខាងក្រៅបរិវេណនោះ[2876]។ សាក្សីជាច្រើនដែលបានត្រឡប់មកភូមិផ្គកវិញក្រោយឆ្នាំ១៩៧៩ បានរកឃើញទីតាំងកប់សពនានានៅពាសពេញតំបន់ជុំវិញវត្តផ្គក ប៉ុន្តែមិនមានសាកសពនៅក្នុងមន្ទីរឃុំឃាំងទេ[2877]។ ឯកសារពាក់ព័ន្ធនឹងគម្រោងគាស់សាកសពនៅឆ្នាំ១៩៨២ បញ្ជាក់បន្ថែមពីអត្ថិភាពនៃរណ្តៅសាកសពយ៉ាងហោចណាស់ចំនួន៤១ ទាក់ទងនឹងមន្ទីរឃុំឃាំងនេះ[2878]។ យោងតាមសាក្សីមួយរូប ដែលបានចូលរួមគម្រោងគាស់

00605469



សាកសពនៅវត្តធ្លកនេះ មានរណ្តៅសាកសពចំនួនច្រើនដល់២០០ រណ្តៅ នៅទីតាំងនោះ ប៉ុន្តែភាគច្រើននៃរណ្តៅមានទំហំតូចៗ ដែលមានសាកសពមិនលើសពីពីរ ឬបី[2879]។

៦៦៤. សក្ខីកម្មភាគច្រើនរបស់សាក្សីបង្ហាញឱ្យឃើញថា ចំនួនអ្នកស្លាប់មានពី ៧៤៥នាក់ ដល់ ១.៥០០ នាក់[2880]។ ចំនួននេះមានបញ្ជាក់ផងដែរ តាមភស្តុតាងជាឯកសារស្តីពីស្ថិតិគាស់សាកសពនៅឆ្នាំ១៩៨២[2881]។ សាក្សីមួយរូបដែលបានសម្របសម្រួលគម្រោងគាស់សាកសពនេះបានអះអាងបញ្ជាក់ពីសុក្រិតភាពនៃស្ថិតិទាំងនេះសម្រាប់ខេត្តទាំងមូល រួមទាំងមន្ទីរសន្តិសុខវត្តធ្លក[2882]។ សាក្សីមួយរូបដែលជាមេឃុំតាំងពីឆ្នាំ១៩៨៣ ហើយបានចូលរួមក្នុងការសាងសង់ចេតិយរំឭកវិញ្ញាណក្ខន្ធនៅក្នុងភូមិធ្លកបញ្ជាក់ថា មានតែឆ្អឹងយកពីរណ្តៅនៅជុំវិញវត្តធ្លកតែប៉ុណ្ណោះ ត្រូវបានដាក់នៅក្នុងចេតិយនោះ[2883] ដែលមានចំនួនសរុបមិនលើសពី ១.៥០០នាក់[2884]។

៦៦៥. ពាក់ព័ន្ធនឹងការសម្លាប់នៅបឹងរ៉ៃ ការស៊ើបសួរ(ដែលត្រូវបានកម្រិតត្រឹមទំនាក់ទំនងជាមួយនឹងមន្ទីរសន្តិសុខវត្តធ្លក) មិនអាចបញ្ជាក់អំពីចំនួនជនរងគ្រោះទាំងអស់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីមួយរូបដែលត្រូវបានផ្ទេរមកពីមន្ទីរសន្តិសុខវត្តធ្លកកត់សម្គាល់ថា នៅអំឡុងពេលប៉ុន្មានខែដែលគាត់ត្រូវបានឃុំខ្លួននៅទីនោះក្នុងឆ្នាំ១៩៧៨ *"មានអ្នកទោសនាំចូលមក ហើយយកចេញទៅសម្លាប់"* រួមទាំងម្តាយរបស់គាត់ផ្ទាល់ និងអ្នកជាប់ឃុំផ្សេងទៀត ដែលត្រូវបានបញ្ជូនមកពីមន្ទីរសន្តិសុខវត្តធ្លក ហើយមានតែអ្នកជាប់ទោសចំនួនប្រាំនាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅពេលដែលគាត់ត្រូវបានដោះលែង[2885]។

៦៦៦. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៣ (បីនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តធ្លក[2886]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តធ្លក។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១។

**មន្ទីរសន្តិសុខគោកក្តួច (គោកក្តួច)[2887]**

**ទីតាំង និងការបង្កើត**

**៦៦៧.** មន្ទីរសន្តិសុខគោកក្តួចមានទីតាំងនៅភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ[2888]។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា គោកក្តួចស្ថិតនៅក្នុងតំបន់ ៥០៥ ភូមិភាគឦសាន[2889]។ នៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ ១៩៧៧ តំបន់ ៥០៥ ត្រូវបានដកចេញពីភូមិភាគឦសាន ហើយក្លាយជាតំបន់ស្វយ័ត[2890]។ គោកក្តួចត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧០[2891] ហើយទំនងជាបានដំណើរការនៅដើមឆ្នាំ ១៩៧១ ឬ ឆ្នាំ១៩៧២[2892] និងបានដំណើរការពេញលេញពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[2893]។ មន្ទីរសន្តិសុខគោកក្តួចមានទំនាក់ទំនងនឹងការដ្ឋានប្រាស្រាល។ អ្នកទោសដែលត្រូវបានគិតថាជាជនមានកំហុសស្រាលបានបញ្ជូនទៅការដ្ឋានប្រាស្រាល[2894]។ មន្ទីរសន្តិសុខកោះសំតួចដែលមានទីតាំងនៅលើកោះមួយនៅកណ្តាលទន្លេមេគង្គ[2895] និងគុកស្ត្រីស្រែគ្នោតដែលមានទីតាំងនៅខាងលិចគោកក្តួច[2896] ក៏មានការពាក់ព័ន្ធនឹងគោកក្តួចដែរ។ មុននឹងទៅដល់គោកក្តួច ជួនកាល អ្នកទោសត្រូវបាននាំទៅមន្ទីរអាហារដែលមានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីគោកក្តួច ដើម្បីសួរចម្លើយសិន[2897]។

**៦៦៨.** មន្ទីរសន្តិសុខគោកក្តួចរួមមានអគារវែងពីរធ្វើពីឫស្សី មានដំបូលប្រក់សង្ក័សី ដាក់អ្នកទោសប្រមាណពី ២០ ទៅ ៣០នាក់ក្នុងមួយអគារ[2898]។ នៅការដ្ឋានប្រាស្រាល អ្នកទោសត្រូវបានដាក់នៅក្នុងខ្ទមច្រើនជាង ១០ ជាមួយនឹងទីជម្រកវែងពីរប្រវែងពី ៣០ ទៅ ៣៥ ម៉ែត្រ និងទីជម្រកតូចៗមួយចំនួនទៀត[2899]។

**ដំណើរការប្រព្រឹត្តទៅ**

**រចនាសម្ព័ន្ធ និងបុគ្គលិក**

**៦៦៩.** តា **យែម** គឺជាលេខាតំបន់៥០៥ ពីឆ្នាំ១៩៧១។ នៅពេលមួយមិនយូរប៉ុន្មានបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តា **យែម** ត្រូវបានបញ្ជូនទៅកាន់តំណែងមួយទៀតនៅទីក្រុងភ្នំពេញ[2900]។ **យី** ហៅ **ប៊ិន ណាន** បានបន្តជាលេខាតំបន់នេះរហូតដល់ឆ្នាំ១៩៧៨ ជាពេលដែលត្រូវគេចាប់ខ្លួនគាត់[2901]។ លេខាតំបន់បន្ទាប់ គឺ **មឿន**[2902]។ លេខាតំបន់ចុងក្រោយគឺ [លុប][2903]។ អនុលេខាតំបន់៥០៥ ជាបន្តបន្ទាប់ រួមមាន **កង** (ដែលត្រូវបានចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧)[2904] **គួន** (ត្រូវបានចាប់ខ្លួនថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៨) [2905] និង **ខុន**[2906]។

៦៧០. ស្រុកសំបូរត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមួយ ដែលមានលេខាស្រុកមួយរូប អនុលេខាស្រុកមួយរូប និងសមាជិកដទៃទៀតដែលទទួលបន្ទុកលើផ្នែកសេដ្ឋកិច្ច សន្តិសុខ នយោបាយ និងយោធា[2907]។ ផ្នែកសន្តិសុខស្រុកសំបូរត្រូវចាត់ចែងដោយគណៈកម្មាធិការដែលមានសមាជិកបីរូប ត្រួតពិនិត្យលើកិច្ចការនៅគោកក្ដួច និងការដ្ឋានប្រាស្រាល[2908] ហើយជួនកាលត្រូវបានគេហៅថា កងសន្តិសុខ៣២[2909]។

៦៧១. បុគ្គលមួយចំនួនត្រូវបានផ្ដល់អត្តសញ្ញាណថាជាលេខាស្រុកសំបូរជាបន្តបន្ទាប់គ្នា ដែលរួមមាន **ផាន**, **នី**, និង [លុប][2910]។ លើសពីនេះទៀត សាក្សីមួយរូប[2911]បាននិយាយថា ចែត្រ ហៅ **ឈុន**, **យោង** ហៅ **ឈឹម យ៉ុង** ដែលជាសមាជិកមួយរូបនៃគណៈតំបន់៥០៥ ទទួលបន្ទុកស្រុកសំបូរ[2912] ហើយដែលក្រោយមក ត្រូវបានចាប់ខ្លួនដោយគណៈតំបន់ដោយត្រូវបានចោទប្រកាន់ពីបទរំលោភស្ត្រីម្នាក់នៅប្រហែលឆ្នាំ១៩៧៦[2913] និងបានគ្រប់គ្រងលើគណៈស្រុកសំបូរ ក្នុងនាមជាលេខាស្រុកផងដែរ។ កម្មាភិបាលទទួលបន្ទុកសន្តិសុខស្រុកដែលគ្រប់គ្រងស្ថានភាពសន្តិសុខនៅក្នុងស្រុក និងមន្ទីរឃុំឃាំង រួមមាន **អ៊ុង សាម៉ុន**[2914] (ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៧) [2915] **ផង់ នី** (ត្រូវបានចាប់ខ្លួនថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៧៨) [2916] និង [លុប][2917]។ [លុប] ដែលបានកាន់តំណែងរហូតដល់ចុងឆ្នាំ ១៩៧៨ គឺជាអ្នកដឹកនាំចុងក្រោយនៃគណៈសន្តិសុខស្រុក ហើយជាប្រធានគុកគោកក្ដួច យោងតាមសក្ខីកម្មរបស់អតីតកងសន្តិសុខ និងអ្នកទោសមួយចំនួន[2918]។ ការបោសសម្អាតនៅក្នុងតំបន់៥០៥ ត្រូវបានធ្វើឡើងដោយកងទ័ពដែលត្រូវបានបញ្ជូនមកពីភូមិភាគបស្ចិម ហើយកម្មាភិបាលដែលជាកម្មវត្ថុនៃការបោសសម្អាតត្រូវបានជំនួសដោយកម្មាភិបាលដែលមកពីភូមិភាគបស្ចិម និងនិរតីផងដែរ[2919]។

៦៧២. **នួន ជា** ត្រូវបានគេឃើញជារឿយៗនៅពេលធ្វើទស្សនកិច្ចតំបន់ក្រចេះ[2920]។ បន្ទាប់ពីកម្មាភិបាលតំបន់បានទទួលបញ្ជាពីមជ្ឈិមនៅភ្នំពេញ ពួកគេអាចកោះហៅប្រជុំនៅថ្នាក់ក្រោម ដើម្បីអនុវត្តបញ្ជាទាំងនោះ[2921]។ ការប្រជុំប្រចាំសប្ដាហ៍អំពីស្ថានភាពខ្មាំង ផលិតកម្ម និងសុខភាពរបស់ប្រជាជនត្រូវបានធ្វើឡើងនៅថ្នាក់ស្រុក[2922]។ លើសពីនេះទៀត ការប្រជុំប្រចាំសប្ដាហ៍រវាងថ្នាក់ឃុំ និងថ្នាក់ស្រុក និងរវាងថ្នាក់ស្រុក និងថ្នាក់ខេត្តត្រូវបានរៀបចំធ្វើឡើងផងដែរ[2923]។ ប្រសិនបើមនុស្សណាម្នាក់នៅក្នុងភូមិត្រូវបានកំណត់មុខសញ្ញាថាជាខ្មាំង ថ្នាក់ស្រុកនឹងអាចចាប់អ្នកនោះនៅថ្នាក់ឃុំ[2924]។ ទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានចែកចាយជាទូទៅក្នុងចំណោមយុវជន

00605472



នៅក្នុងតំបន់ ទោះបីជាមិនមានការស្តាប់ចម្លើយណាមួយទំនងជាបង្ហាញថា គ្រប់ការណែនាំទាំងអស់ដែលមានបរិយាយនៅក្នុងទស្សនាវដ្តីនោះត្រូវបានអនុវត្តតាមក៏ដោយ[2925]។

## ការចាប់ខ្លួន និងការឃុំខ្លួន

**៦៧៣.** ទោះជាអ្នកទោសទាំងអស់សុទ្ធតែមិនត្រូវបានប្រាប់ពីមូលហេតុនៃការចាប់ខ្លួនរបស់ពួកគេក៏ដោយ[2926] ក៏ពួកគេភាគច្រើនត្រូវបានចោទថាជាខ្មាំង[2927] ឬជាទាហាន លន់ នល់[2928] ឬពាក់ព័ន្ធនឹងវៀតណាម ឬជាសមាសភាពអាក្រក់ រួមទាំង *"ខ្មែរ ស"*[2929]។ អ្នកទោសគឺជាប្រជាជនថ្មី[2930] ឬជានិគមជនជាតិភាគតិច ដូចជា ក្រោល ព្នង ចាម ខ្មួន និងមីល[2931]។ នៅឆ្នាំ១៩៧៧–១៩៧៨ អ្នកជាប់ទោសបានកើនឡើង ដោយសារមានការចាប់ខ្លួនកងទ័ពភូមិភាគបូព៌ាជាច្រើន[2932]។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាពីថ្នាក់ឃុំត្រូវបានចាប់នៅពេលចូលរួមប្រជុំនៅមន្ទីរស្រុក[2933]។ អតីតសន្តិសុខម្នាក់នៅគោកក្ដួចនិយាយថា គាត់បានឃើញផ្ទាល់ភ្នែកពីរបៀបដែលជនជាតិវៀតណាមត្រូវបានជ្រើសរើសយកចេញ៖ *"ពេលនោះគេបានប្រមូលក្រុមគ្រួសារវៀតណាមសុទ្ធ (ប្ដី–ប្រពន្ធ ជាជនជាតិវៀតណាម) មកដាក់ក្នុងអាគារ (...)។ រួចគេប្រមូលយកទៅដាក់ឡាន ហើយដឹកយកទៅក្រោមអស់ តែមិនដឹងទៅណាទេ"*[2934]។

**៦៧៤.** មានសក្ខីកម្មផ្សេងៗគ្នាអំពីចំនួនអ្នកទោស ប៉ុន្តែទំនងជា មានអ្នកទោសប្រមាណពី ៤០ ទៅ ១០០ នាក់ នៅគោកក្ដួច ទៅតាមពេលវេលា រួមទាំងបុរស ស្ត្រី និងកុមារ[2935]។ យោងតាមសន្តិសុខម្នាក់នៅឆ្នាំ១៩៧៧–១៩៧៨ ចំនួនអ្នកទោសបានកើនឡើងដល់ប្រមាណ២០០ ទៅ ៣០០នាក់ នៅគ្រប់ពេលវេលាទាំងអស់ ក្នុងនោះមានអ្នកទោសកម្រិតធ្ងន់ប្រមាណ៥០នាក់[2936]។ អ្នកទោសប្រមាណ១០០–២០០នាក់ ត្រូវបានឃុំនៅការដ្ឋានប្រាស្រាល ហើយភាគច្រើននៃពួកគេត្រូវបានបញ្ជូនមកពីគោកក្ដួច[2937]។

**៦៧៥.** អ្នកទោសនៅគោកក្ដួចត្រូវបានបែងចែកតាមអ្នកទោសធ្ងន់ និងអ្នកទោសស្រាល[2938]។ អ្នកទោសធ្ងន់ (អ្នកទោសនយោបាយ ឬជាជនក្បត់របស់របបនេះ) ត្រូវបានគេដាក់ខ្នោះ[2939]។ បទល្មើសស្រាលរួមមាន៖ មិនធ្វើការឲ្យបានត្រឹមត្រូវ និយាយមិនត្រឹមត្រូវ ខុសសីលធម៌ ឬបរិភោគអាហារដែលត្រូវបានហាមឃាត់[2940]។ អ្នកទោសស្រាលមិនត្រូវបានដាក់ខ្នោះទេ ហើយអនុញ្ញាតឲ្យដើរដោយសេរីនៅក្នុងទីធ្លាគុក[2941]។ សាក្សីមួយចំនួនរៀបរាប់ថា អ្នកប្រព្រឹត្តកំហុស"មធ្យម" ត្រូវបានឃុំដោយដាក់ខ្នោះតែម្ខាង[2942]។ នៅការដ្ឋានប្រាស្រាល អ្នកទោសស្រាល ដែលបានបញ្ជូនមកពីគោកក្ដួច និង

00605473



មន្ទីរអាហារ បន្ទាប់ពីការសួរចម្លើយមិនត្រូវបានដាក់ខ្នោះទេ[2943]។

៦៧៦. សាក្សីជាច្រើននិយាយថា លក្ខខណ្ឌរស់នៅក្នុងគោកក្ដួច និងការដ្ឋានប្រាស្រាលមានលក្ខណៈលំបាកណាស់[2944] ហើយថាចំណីអាហារមិនគ្រប់គ្រាន់[2945]។ អតីតអ្នកទោសប្រាប់ថាមិនមានការព្យាបាលផ្នែកវេជ្ជសាស្ត្រទេ[2946] ហើយថាមានអ្នកទោសជាច្រើនបានស្លាប់ដោយសារជម្ងឺ ភាពហេវហត់ និងភាពអត់ឃ្លាន។[2947]

៦៧៧. ជួនកាល អ្នកទោសនៅគោកក្ដួច និងការដ្ឋានប្រាស្រាលត្រូវបានប្រមូលផ្ដុំឱ្យធ្វើការជាមួយគ្នា ហើយធ្វើដំណើរទៅវិញទៅមករវាងទីកន្លែងទាំងពីរនេះ[2948]។ អ្នកទោសនៅគោកក្ដួច និងការដ្ឋានប្រាស្រាលត្រូវបានបញ្ជាឱ្យធ្វើចំការ ធ្វើស្រែ ដាំដំឡូង ឬពោត ឬធ្វើទំនប់ ឬប្រឡាយទឹក[2949]។ អ្នកទោសត្រូវបានឃាមកាមគ្រប់ពេលកំពុងធ្វើការ[2950]។ អ្នកទោសដែលរត់គេច លួចចំណីអាហារ ឬមិនគោរពតាមវិន័យ ត្រូវបានវាយ ឬដាក់ខ្នោះ ឬត្រូវបង្អត់អាហារ។[2951] អ្នកទោសត្រូវធ្វើការពេញមួយថ្ងៃ ដោយឱ្យឈប់សម្រាកនៅពេលថ្ងៃត្រង់ ហើយជួនកាលត្រូវធ្វើការនៅពេលយប់។[2952]

៦៧៨. សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅមន្ទីរសន្តិសុខគោកក្ដួចអះអាងថា នៅតំបន់៥០៥ អ្នកខុស "*សីលធម៌*"ដែលជាពោះម៉ាយ ឬនៅលីវ ត្រូវបានបង្ខំឱ្យរៀបការតាមគោលនយោបាយ "ថ្នាក់លើ"[2953]។

៦៧៩. អ្នកទទួលបន្ទុកចុងក្រោយគេមួយរូបក្នុងចំណោមអ្នកដទៃទៀតនៃគណៈស្រុកសំបូរបាននិយាយថា គាត់បានដោះលែងអ្នកទោស ដែលជាប់ឃុំដោយសារកំហុសតូចតាចនៅគោកក្ដួចបន្ទាប់ពីគាត់បានមកដល់ ប៉ុន្តែការអះអាងនេះមិនមានការបញ្ជាក់ពីសាក្សីណាម្នាក់ឡើយ[2954]។

### ការសួរចម្លើយ

៦៨០. ការសួរចម្លើយនៅគោកក្ដួចត្រូវបានធ្វើឡើងដោយអ្នកសួរចម្លើយបីនាក់ និងអ្នកកត់ត្រាម្នាក់ ហើយមានរយៈពេលប្រមាណ ១ម៉ោង ទៅ១ម៉ោង៣០នាទី[2955]។ អ្នកទោសត្រូវបានសួរអំពីជីវប្រវត្តិ និងការពាក់ព័ន្ធដែលត្រូវជាប់ចោទជាមួយនឹងខ្សែរយៈវៀតណាម[2956]។ ចម្លើយសារភាពអំឡុងពេលសួរចម្លើយធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយផ្ញើទៅគណៈស្រុកដោយរក្សាមួយច្បាប់នៅគោកក្ដួច[2957]។ សមាជិកមកពីមន្ទីរស្រុកត្រូវបានគេឃើញម្ដងម្កាលអំឡុងពេលសួរចម្លើយ[2958]។

00605474



នៅការដ្ឋានប្រាស្រាល សាក្សីបាននិយាយថា ជាទូទៅអ្នកទោសមិនត្រូវបានសួរចម្លើយទេ ដោយសារពួកគេជាច្រើនមកពីគោកក្ដួច ជាទីកន្លែងដែលពួកគេត្រូវបានសួរចម្លើយរួចហើយ[2959]។

៦៨១. អតីតអ្នកទោស និងអតីតកងសន្តិសុខនៅគោកក្ដួច និយាយថា អំឡុងពេលសួរចម្លើយ ការធ្វើទុក្ខទោសធ្ងន់ធ្ងរ[2960]ត្រូវបានប្រើជាទៀងទាត់ រួមមាន ការវាយដំ ការប្រើខ្សែភ្លើង និងរំពាត់ផ្ដៅ[2961]។ សាក្សីមួយរូបនិយាយថា អំឡុងពេលសួរចម្លើយ អ្នកទោសលេចនោម ឬលេចលាមក ហើយនិងបែកឈាម ឬក៏រហូតដល់បាត់បង់ស្មារតី[2962]។

## ការសម្លាប់

៦៨២. សាក្សីនិយាយថាអ្នកទោសត្រូវបាននាំចេញទៅ ហើយបន្ទាប់មកមិនត្រូវបានគេឃើញទៀតឡើយ[2963]។ អ្នកទោសដែលត្រូវបាននាំចេញទៅ គឺជាអ្នកទោសកម្រិតធ្ងន់[2964]។ សាក្សីមួយរូបនិយាយថាសមាជិកគណៈស្រុកសំបូរដែលត្រូវបានចោទថាក្បត់ ត្រូវបានសម្លាប់នៅគោកក្ដួច[2965]។ យោងតាមសក្ខីកម្មស៊ីសង្វាក់គ្នាបានឱ្យដឹងថា អ្នកទោសត្រូវបាននាំចេញទៅដោយកងសន្តិសុខនៅពេលយប់[2966] ហើយជួនកាលមានប្រើប្រាស់ឡានដើម្បីដឹកដោយមានកងសន្តិសុខអមផង[2967]។

៦៨៣. សាក្សីអះអាងថា មានទីតាំងពិឃាតមួយនៅក្នុងទីធ្លាគោកក្ដួច[2968]។ សាក្សីមួយរូបបានឃើញសាកសពមនុស្សដែលត្រូវបានសម្លាប់ ហើយបន្ទាប់មក គាត់ត្រូវកប់សាកសពទាំងនោះនៅទីតាំងមួយចម្ងាយ៥០០ម៉ែត្រពីមន្ទីរសន្តិសុខ[2969]។ សាក្សីដដែលនោះក្រោយមកត្រូវបានផ្ទេរទៅការដ្ឋានប្រាស្រាលជាកន្លែងដែលគាត់ត្រូវកប់សាកសពចំនួន ៨៩ ផ្សេងទៀត ដែលជាប្រជាជនថ្មី ហើយថានិងដែលត្រូវគេបាញ់សម្លាប់ ឬត្រូវបានវាយឱ្យស្លាប់[2970]។

៦៨៤. រណ្ដៅចំនួន ៣ ត្រូវបានរកឃើញនៅឆ្នាំ១៩៧៩ នៅទីតាំងគោកក្ដួច។ រណ្ដៅនីមួយៗមានទំហំប្រមាណ ២ ម៉ែត្រគុណនឹង ៥ម៉ែត្រ[2971]។ សំលៀកបំពាក់ត្រូវបានប្រទះឃើញនៅក្រោមដើមឈើនៅក្បែរចុងរណ្ដៅប៉ែកខាងជើង ព្រមទាំងដំបងចំនួនពីរ និងចបកាប់ចំនួនពីរ នៅក្រោមដើមឈើនៅក្បែររណ្ដៅពីរនៅចុងប៉ែកខាងត្បូងនៃគោកក្ដួច[2972]។

***

00605475



៦៨៥. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន០៦ (ប្រាំមួយនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខគោកក្ដួច[2973]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤)។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខគោកក្ដួច។

## កន្លែងសម្លាប់មនុស្សក្នុងស្រុក ១២ (ភូមិភាគបស្ចឹម)
## កន្លែងសម្លាប់មនុស្សព្រៃត្រពាំងអំពិល[2974]

### ទីតាំង និងការបង្កើត

៦៨៦. ព្រៃត្រពាំងអំពិលនិងព្រៃត្រពាំងព្រីង គឺជាទីតាំងពិឃាតពីរនៅក្បែរគ្នា និងមានការពាក់ព័ន្ធគ្នា ដែលទីតាំងទាំងនេះស្ថិតនៅក្នុងតំបន់ព្រៃ។ ទីតាំងទាំងពីរនេះស្ថិតនៅចម្ងាយប្រហែល ៣គីឡូម៉ែត្រខាងត្បូងភូមិក្រាំងល្វា ក្នុងឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ (ជាអតីតស្រុកកំពង់ត្រឡាចលើរហូតដល់ឆ្នាំ១៩៨៥) នៃខេត្តកំពង់ឆ្នាំង[2975]។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ទីតាំងទាំងនេះស្ថិតនៅក្នុងស្រុក១២ តំបន់៣១ នៃភូមិភាគបស្ចឹម (ភូមិភាគ ៤០១)។

### ដំណើរការប្រព្រឹត្តទៅ

### រចនាសម្ព័ន្ធគ្រប់គ្រង និង បុគ្គលិក

៦៨៧. បក្សកុម្មុយនីស្តកម្ពុជាបានកាន់កាប់ស្រុកកំពង់ត្រឡាចលើ ក្នុងឆ្នាំ១៩៧២ ឬ ឆ្នាំ១៩៧៣[2976]។ នៅពេលនោះពួកគេបានបង្កើតឱ្យមានមន្ទីរសន្តិសុខជំទាវជ្រេង ដែលមានទីតាំងស្ថិតនៅភូមិជំទាវជ្រេង (បច្ចុប្បន្ននេះមន្ទីរសន្តិសុខនេះត្រូវបានគេបោះបង់ចោល)[2977] ហើយទីតាំងនេះគឺជាទីបញ្ជាការមួយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ១៩៧៥[2978]។ មន្ទីរសន្តិសុខនេះបានដំណើរការរហូតដល់ពេលដែលប្រធានឈ្មោះ **សារិន**[2979] បានស្លាប់នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[2980]។ ក្រោយមកមន្ទីរសន្តិសុខនេះត្រូវបានជំនួសដោយមន្ទីរសន្តិសុខស្រុក១២ ដែលគេស្គាល់ថា មន្ទីរសន្តិសុខព្រៃដំរីស្រុត[2981]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605476



៦៨៨. នៅក្រោយឆ្នាំ១៩៧៥ មាស យឹម ហៅ តា យឹម គឺជាលេខានៃគណៈស្រុក១២ ដែលក្រោយមក គាត់ត្រូវគេតម្លើងឋានៈទៅកម្រិតថ្នាក់តំបន់ ហើយតំណែងគាត់ត្រូវបានជំនួសដោយ គឿន (ស្លាប់)[2982]។ សារុន គឺជាលេខាគណៈតំបន់ ៣១ (ស្លាប់ ហើយក្រោយមកត្រូវបានជំនួសដោយ តា យឹម)[2983]។

## ការបាត់ខ្លួន និងការសម្លាប់

៦៨៩. សាក្សីបាននិយាយថា ប្រជាជនខ្លះដែលរស់នៅក្នុងភូមិជំទាវជ្រែង ឬអ្នកដែលត្រូវបានបញ្ជូនទៅទីនោះ បានបាត់ខ្លួន[2984] ដោយអ្នកខ្លះត្រូវបានប្រាប់ថា ហៅទៅ "រៀនសូត្រ"[2985] ឬខ្លះត្រូវចាប់យកទៅដោយសារពួកគេបាន "ធ្វើខុស"[2986] ឬត្រូវបានចាប់ដោយគ្មានប្រាប់អំពីមូលហេតុ[2987]។

៦៩០. សាក្សីជាច្រើនបានអះអាងដូចៗគ្នាថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខជំទាវជ្រែងត្រូវបាននាំយកទៅសម្លាប់នៅព្រៃត្រពាំងអំពិល និងត្រពាំងព្រីង[2988]។ មានសាក្សីពីរនាក់ ដែលម្នាក់ធ្វើការនៅទំនប់ដែលស្ថិតនៅចន្លោះមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ហើយម្នាក់ទៀតជាអ្នកភូមិ បានអះអាងថា ពួកគាត់បានឃើញជាច្រើនដង ឈ្លបឃុំបណ្តើរអ្នកជាប់ឃុំចេញពីមន្ទីរសន្តិសុខដោយដៃជាប់ចំណងស្ពាយសេកសំដៅទៅកន្លែងសម្លាប់ ហើយមានតែពួកឈ្លបនោះទេដែលបានត្រឡប់មកវិញដោយបាននាំយកមកជាមួយនូវខ្សែចំណងនិងឥវ៉ាន់ផ្សេងៗ[2989]។ មានសាក្សីផ្សេងៗទៀតដែលត្រូវបានស្តាប់ចម្លើយ បានរៀបរាប់ពីហេតុការណ៍នានា ដែលបានកើតឡើងនាមុនអំឡុងពេលនៃយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)[2990]។

៦៩១. ដោយសារតែមន្ទីរសន្តិសុខជំទាវជ្រែងបានបិទនៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានហេតុផលដែលអាចសន្និដ្ឋានបានថា ការសម្លាប់មនុស្សដែលជាប់ពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខជំទាវជ្រែងទំនងជាមិនស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ។ ប៉ុន្តែ មានសាក្សីជាច្រើនបានអះអាងថា បន្ទាប់ពីមន្ទីរសន្តិសុខជំទាវជ្រែងបានបិទ មានមនុស្សខ្លះនៅតែត្រូវបាននាំយកទៅសម្លាប់នៅព្រៃត្រពាំងព្រីង និងព្រៃត្រពាំងអំពិលដដែល[2991]។ អនុប្រធានឈ្លបឃុំក្រាំងល្វាបាននិយាយថា នៅពេលដែលប្រជាជនត្រូវបានជម្លៀសចេញពីភ្នំពេញមកដល់ឃុំនេះ អង្គប្រជុំជាច្រើនត្រូវបានរៀបចំឡើង ហើយអ្នកដែលជម្លៀសមកនោះ ដែលគេស្គាល់អត្តសញ្ញាណថាជាអតីតទាហាន លន់ នល់ ត្រូវបានយកទៅសម្លាប់ចោលនៅព្រៃត្រពាំងអំពិល និងព្រៃត្រពាំងព្រីង។ សាក្សីរូបនេះបានបញ្ជាក់ថា អ្នកដែលជម្លៀសមកនោះត្រូវបានវាយសម្លាប់នឹងដំបង ហើយគាត់

00605477



បានឃើញដំបងឬស្សីបន្សល់ទុកនៅកន្លែងសម្លាប់នោះ[2992]។ សាក្សីម្នាក់ទៀតដែលបានធ្វើការងារនៅក្នុងភូមិជំទាវជ្រែង ក្នុងឆ្នាំ១៩៧៨ បានអះអាងថា គាត់បានឃើញមនុស្សចំនួន ៧ ទៅ ៨នាក់ត្រូវបានបណ្តើរទៅកាន់ទីតាំងនោះចំនួនពីរដង ហើយបន្ទាប់មកកងសន្តិសុខទាំងនោះបានត្រឡប់មកវិញ ដោយគ្មានមនុស្សទាំងនោះមកជាមួយទេ[2993]។

៦៩២. របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងបានបង្ហាញថា សព្វថ្ងៃនេះមិនមានស្លាកស្នាមអ្វីបន្សល់ទុកនៅទេ ក្រៅតែពីស្នាមរណ្តៅជាពំនូកៗមួយចំនួនដែលអាចមើលឃើញនៅក្នុងព្រៃនោះ។ ក៏ប៉ុន្តែគេនៅតែអាចកំណត់បានថា ស្នាមទាំងនោះគឺជារណ្តៅ។ ខាងលើផ្ទៃដីនៅកន្លែងដែលមានស្នាមរណ្តៅទាំងនោះ គេឃើញមានបន្សល់ទុកនូវកំទេចកំទីឆ្អឹងមនុស្ស ដែលបង្ហាញថាពិតជាមានសាកសពមនុស្សបានស្លាប់នៅទីនោះ។ គេរកឃើញនៅទីនោះផងដែរនូវធ្មេញមនុស្សដែលមានស្នាមធ្មេញធ្វើដោយពេទ្យធ្មេញ បំណែកខោអាវផ្សេងៗដូចជាខ្សែរ ខ្សែរូត របស់របរតែងខ្លួនដូចជាគ្រឿងអលង្ការ និងខ្សែកថា ជាដើម។ល។[2994] សាក្សីជាច្រើននាក់ដែលធ្លាប់បានមកមើលព្រៃត្រពាំងអំពិលនិងត្រពាំងព្រីងក្រោយឆ្នាំ១៩៧៩ បានឃើញរណ្តៅជាច្រើនព្រមទាំងឆ្អឹងមនុស្សផងដែរ[2995]។ ក្រៅពីការសន្និដ្ឋានដែលដកស្រង់ចេញពីកំណត់ហេតុស្តាប់ចម្លើយសាក្សី និង របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង គេមិនអាចកំណត់បានច្បាស់លាស់អំពីចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅទីតាំងទាំងនោះនិងដែលស្ថិតក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ ក៏ប៉ុន្តែបើពិនិត្យទៅលើរណ្តៅដែលគេឃើញ និង ទំហំរបស់វាពិតជាមានសាកសពមនុស្សជាច្រើននាក់ដែលត្រូវបានកប់នៅទីនោះ[2996] ។

## ប្រជាជនដែលត្រូវបានជម្លៀសនៅកាន់ស្រុក ១២ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា[2997]

៦៩៣. នៅក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងពីទីរួមខេត្តកំពង់ឆ្នាំង បានមកដល់ស្រុកសាមគ្គីមានជ័យ (ដែលមុនឆ្នាំ ១៩៨៥ មានឈ្មោះថា ស្រុកកំពង់ត្រឡាចលើ) ខេត្តកំពង់ឆ្នាំង[2998]។

៦៩៤. បន្ទាប់ពីការដួលរលំទីរួមខេត្តកំពង់ឆ្នាំង[2999] "ប្រជាជនថ្មី" ជាច្រើន (រួមមាន បុរស ស្ត្រី និងកុមារ)[3000] ត្រូវបានជម្លៀសចេញ[3001] និងបញ្ជូនទៅប្រមូលផ្តុំក្នុងវត្ត ក្នុងភូមិត្រពាំងម្ទេស ឃុំស្វាយជុក។ សាក្សីពីររូបបានបញ្ជាក់ថា ពួកគេបានឃើញមនុស្សមួយចំនួនត្រូវបានគេនាំចេញពីវត្ត ពីរថ្ងៃបន្ទាប់ពីគេបានមកដល់។ សាក្សីម្នាក់ក្នុងចំណោមពីររូបបានបញ្ជាក់ទៀតថា បាន

ឃើញមនុស្សទាំងនោះត្រូវបានចងនៅទំនប់ជ្រលងតាពុជ ក្នុងព្រៃតាគុច ហើយឈ្លបម្នាក់បាន និយាយប្រាប់គាត់ថាគេបានចូលរួមនៅក្នុងការសម្លាប់មនុស្សទាំងនោះដោយប្រើដំបងនិងពូថៅ[3002]។ សាក្សីម្នាក់ទៀតបានឃើញរណ្តៅសាកសព និងឆ្អឹងលលាដ៍ក្បាលនៅកន្លែងក្នុងឆ្នាំ១៩៧៦[3003]។

**៦៥៥.** អតីតឈ្លបម្នាក់បានបញ្ជាក់ថា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយនៅក្នុងភូមិច្រកសង្កែ ឃុំស្វាយជុក ដែលពេលនោះប្រធានគណៈឃុំស្វាយជុក ឈ្មោះ [លុប] បានស្នើឲ្យមេភូមិទាំងអស់ធ្វើការប្រមូលប្រវត្តិរូបរបស់ប្រជាជនទាំងអស់ ដែលជម្លៀសមកពីភ្នំពេញ។ ប្រជាជនទាំងនោះត្រូវបានបែងចែកជាពីរប្រភេទ៖ *"មនុស្សធម្មតា កសិករ" និងទាហាន ឬវណ្ណការរបប លន់ នល់ ពួកសក្តិភូមិ"* ។ ពួកប្រជាជនដែលថិតនៅក្នុងប្រភេទទីពីរ (ប្រហែលជា ៧០០នាក់) ត្រូវបានគេចង វាយកញ្ចឹងកដោយប្រើដំបងឬស្សី និងបន្ទាប់មកកប់ក្នុងដីនៅកន្លែងមួយ ហៅថា ព្រៃទទឹង ដែលថិតនៅចម្ងាយប្រហែល ១គីឡូម៉ែត្រខាងលិចព្រៃដំរីស្រុត។ សាក្សីបានបញ្ជាក់ថាកាលនោះគាត់ទទួលបន្ទុកនាំមនុស្សទៅកាន់កន្លែងសម្លាប់[3004]។ មិនមានសំណល់ឆ្អឹងមនុស្សត្រូវបានរកឃើញនៅទីនោះឡើយ ប៉ុន្តែការស៊ើបអង្កេតនៅនឹងកន្លែងបានបង្ហាញថាស្ថានភាពដីនៅផ្ទៃខាងលើក្នុងបរិវេណប្រហែល រាប់រយម៉ែត្រការ៉េ មានសភាពមិនប្រក្រតី ដែលបង្ហាញអំពីសកម្មភាពគាស់កកាយ និងស្នាមរណ្តៅចាស់នៅទីកន្លែងនោះ[3005]។

**៦៥៦.** នៅចុងខែមេសា ឆ្នាំ១៩៧៥ ឬដើមខែឧសភា ឆ្នាំ១៩៧៥[3006] ក្រុមគ្រួសារដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ដែលបានមកដល់ក្នុងភូមិថ្មីខ្មែរ ឃុំត្បែងខ្ពស់[3007] ត្រូវបាននាំទៅកាន់ព្រៃស្រែវ៉ាល់[3008] និងសម្លាប់ដោយកម្មាភិបាលឃុំ តាមបញ្ជារបស់ថ្នាក់លើដែលទទួលបានក្នុងពេលប្រជុំជាមួយគណៈឃុំស្វាយជុក[3009]។ សាក្សីបានបញ្ជាក់ថាប្រុសៗត្រូវបានគេចង។ ទាំងប្រុស ទាំងស្រី និងកុមារផងត្រូវបានគេសម្លាប់ដោយប្រើដំបងឈើ និងដែកគ្នៀរទេះ[3010]។ ការសម្លាប់ត្រូវបានធ្វើឡើងក្នុងរយៈពេលពីបីទៅប្រាំថ្ងៃ[3011]។ សាក្សីមួយរូបបានធ្វើការប៉ាន់ប្រមាណថាមានមនុស្សប្រហែលជា ២០០នាក់ ត្រូវបានសម្លាប់នៅព្រៃស្រែវ៉ាល់[3012]។ ទីកន្លែងដែលសាក្សីបានពណ៌នាថាជាព្រៃស្រែវ៉ាល់នោះ ទំនងជា ត្រូវបានគេជីកគាស់កកាយ ក្រោយឆ្នាំ១៩៧៩ ហើយឥឡូវនេះមិនមានស្លាកស្នាមដែលអាចបង្ហាញថា ធ្លាប់ជាទីកន្លែងសម្លាប់មនុស្សទៀតឡើយ[3013]។

**៦៥៧.** សាក្សីនានាបានរៀបរាប់អំពីការសម្លាប់ស្រដៀងគ្នានេះ ដែលប្រហែលជាកើតឡើងនៅចុងខែមេសា ឬដើមខែឧសភា ឆ្នាំ១៩៧៥ នៅក្នុងស្រុក១២ និងរួមទាំងទីកន្លែងផ្សេងទៀតដែលស្ថិតនៅក្នុង

00605479



ឃុំត្បែងខ្ពស់ ឃុំពាម និងឃុំក្រាំងល្វា ហើយដែលការសម្លាប់ទាំងនោះប្រព្រឹត្តឡើងចំពោះ "ប្រជាជនថ្មី" ដែលត្រូវបានគេកំណត់ថា ជាអ្នករដ្ឋការ និងទាហាន **លន់ នល់**[3014] ។ សាក្សីម្នាក់រូប បានពណ៌នាថា រយៈពេលក្រោយមក "*អង្គការ*" បានបញ្ឈប់សកម្មភាពសម្លាប់មនុស្សដែលត្រូវបាន ជម្លៀសមកពីទីក្រុង ហើយប្រជាជនដែលមកដល់ប៉ុន្មានខែដំបូង ក្រោយការបង្កើតរបប កម្ពុជាប្រជាធិបតេយ្យ បានរួចផុតពីការសម្លាប់[3015] ។

## កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[3016]

### ទីតាំង និងការបង្កើត

៦៩៨. កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបានចាប់ផ្តើមដំណើរការនៅចុងខែមេសា ឆ្នាំ១៩៧៥ រហូតដល់ អំឡុងឆ្នាំ១៩៧៧ តែពុំជាប់ជាប្រចាំទេ ហើយដែលអំឡុងពេលនោះ[3017] មានការសម្លាប់ជា ទ្រង់ទ្រាយធំលើអតីតទាហាន និងប្រជាជនស៊ីវិលជាច្រើននាក់[3018]។

៦៩៩. ទួលពោធិ៍ជ្រៃមានទីតាំងស្ថិតនៅលើដីទួលមួយ[3019] នៅជិតត្រើយខាងលិចបឹងទន្លេសាប[3020] ក្បែរ ភូមិក្តុលឈ្មិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់[3021]។ យោងតាមប្រព័ន្ធកំណត់ទីតាំង ភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ទួលពោធិ៍ជ្រៃស្ថិតនៅក្នុងស្រុកកណ្តៀង តំបន់៧ នៃភូមិភាគពាយ័ព្យ[3022]។

៧០០. កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃជាអតីតបន្ទាយទាហាន លន់ នល់ (ហៅថាបន្ទាយ ភូមិពោធិ៍)[3023]។ នៅចម្ងាយប្រមាណប្រហែលជាបួនគីឡូម៉ែត្រពីទួលពោធិ៍ជ្រៃ មានបឹងមួយដែល ជាទីកន្លែងសម្លាប់មនុស្សផងដែរ ដោយគេបានឃើញសាកសពត្រូវបានបោះចូលទៅក្នុងនោះ[3024]។

### ដំណើរការប្រព្រឹត្តទៅ

### រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក

៧០១. **មូល សម្បត្តិ** (ហៅ **តា ញឹម** ហៅ **រស់ ញឹម** ហៅ **មូល អុន**) ជាលេខាគណៈភូមិភាគពាយ័ព្យ រហូត ដល់មានការចាប់ខ្លួនគាត់ ដោយពួកកម្មាភិបាលមកពីភូមិភាគនិរតី នៅពាក់កណ្តាលឆ្នាំ១៩៧៨[3025] នៅពេលនោះ **តា ម៉ុក** ឡើងធ្វើជាលេខាភូមិភាគពាយ័ព្យជំនួសគាត់[3026]។ **គង់ សុផល** ហៅ **តា គី**

[3027] ជាអនុលេខាភូមិភាគពាយ័ព្យនេះ ហើយគាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ នៅក្នុងខែ វិច្ឆិកា ឆ្នាំ១៩៧៨ [3028]។

៧០២. **តាខ្លែង** គឺជាមេបញ្ជាការកងពលភូមិភាគពាយ័ព្យដែលបានវាយយកខេត្តពោធិ៍សាត់[3029]។ **យី** ជាលេខាស្រុកកណ្តៀង និង សាន ជាអនុលេខា[3030]។ **ម៉ៅ** ជាសមាជិកគណៈស្រុកកណ្តៀង[3031]។ **សុត** ហៅ កែ **គីមហួត** ជាលេខាតំបន់៧ និង **តួយ** ជាអនុលេខា[3032]។ **សុត** ទំនងជាត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧[3033] ហើយ **តួយ** ក៏ដូចគ្នាផងដែរ [3034]។

៧០៣. យោងតាមសក្ខីកម្មជាច្រើន នៅក្នុងឆ្នាំ១៩៧៦ មានការប្រជុំជាទៀងទាត់រវាងកម្មាភិបាលជាន់ខ្ពស់ ប.ក.ក. ដែលក្នុងនោះមានលេខាគណៈភូមិភាគ គណៈតំបន់ គណៈស្រុក ព្រមទាំងមេកងតាមឃុំ និងប្រធានសហករណ៍ផងដែរ[3035]។ មានសាក្សីលើកឡើងថា **នួន ជា** បានកោះប្រជុំ ពីរ ឬ បីលើក និងបានរៀបចំផែនការបោសសម្អាតខ្មាំងផ្ទៃក្នុង[3036] ដែលរួមមានការដាក់ឈ្លបនៅតាមស្រុក ដើម្បីឲ្យ រាយការណ៍មកគណៈស្រុក និងគណៈតំបន់ជាដើម[3037]។ ផ្អែកលើរបាយការណ៍ទាំងនេះ គណៈតំបន់នឹងធ្វើការចាប់ខ្លួនមនុស្សនៅតាមស្រុក និងតាមឃុំ[3038]។ សក្ខីកម្មរបស់សាក្សីនោះក៏បានបញ្ជាក់ឡើងផងដែរអំពីការចូលរួមដោយផ្ទាល់របស់ **នួន ជា** ក្នុងកិច្ចប្រជុំទាំងនោះ[3039]។

**ការចាប់ ការបញ្ជូនខ្លួន និងការសម្លាប់នៅទួលពោធិ៍ជ្រៃ**

៧០៤. កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបានដំណើរការចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៧ ហើយទំនងជាមានការសម្លាប់ចំនួនយ៉ាងច្រើនក្នុងអំឡុងពេលនោះ[3040]។

**អតីតមន្ត្រី និងអ្នករដ្ឋការនៃរបប លន់ នល់**

៧០៥. បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញភ្លាម កម្មាភិបាលនិងកងទ័ព ប.ក.ក បានវាយចូល និងកាន់កាប់ខេត្តពោធិ៍សាត់ និងតំបន់ជុំវិញទួលពោធិ៍ជ្រៃ[3041]។ ខេត្តពោធិ៍សាត់ត្រូវបានកាន់កាប់ទាំងស្រុងដោយកម្មាភិបាល និងកងទ័ព ប.ក.ក នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ហើយក្នុងប៉ុន្មានថ្ងៃភ្លាមៗបន្ទាប់ពីនោះក៏មានការកោះប្រជុំអភិបាលខេត្តពោធិ៍សាត់ ទាហាន អ្នករដ្ឋការនៃអតីតរដ្ឋាភិបាល **លន់ នល់** នៅសាលាខេត្តពោធិ៍សាត់។ កម្មវត្ថុនៃកិច្ចប្រជុំនោះគឺ *"ការអញ្ជើញមកទទួលអង្គការនៅទួលពោធិ៍ជ្រៃ"* [3042]។ កងទ័ព ប.ក.ក ត្រូវបានដាក់ពង្រាយនៅជុំវិញសាលាខេត្ត ដើម្បីកុំឲ្យអ្នកចូលរួមលួច

00605481



រត់គេច[3043]។

៧០៦. សាក្សីបានបញ្ជាក់ថា *"អតីតមន្ត្រីរដ្ឋការ"* ទាំងអស់របស់របប លន់ នល់ ត្រូវបានកោះហៅឱ្យទៅប្រជុំ[3044]។

៧០៧. អ្នកមានវត្តមាននៅក្នុងកិច្ចប្រជុំនោះមាន តា ញឹម និង តា កន (គណៈភូមិភាគពាយ័ព្យ) និង តា សុត (គណៈតំបន់ ៧)[3045]។ ក្រៅពីនេះ តា តួយ (ដែលជាអនុលេខាតំបន់៧) [លុប] (ដែលជាអនុលេខាស្រុកកណ្ដៀង) និង តា ម៉ៅ (ដែលមកពីគណៈស្រុកកណ្ដៀង) ក៏មានវត្តមានក្នុងពេលនោះដែរ[3046]។ អតីតកម្មាភិបាល ប.ក.ក ម្នាក់បានលើកឡើងថា តា ញឹម និង តា សុត បានដាក់បញ្ជាថា៖ *"ពួកទាហាន និង ប៉ូលីសជំនាន់ លន់ នល់ ឲ្យតែអ្នកណាមានពាក់ស័ក្តិ ត្រូវតែយកទៅសម្លាប់ចោលទាំងអស់ បើទុកពួកអ្នកទាំងនេះអាចនឹងមានការរើបម្រាស់ នៅថ្ងៃក្រោយ ដូច្នេះត្រូវតែសម្លាប់ចោលឲ្យអស់ ។ កងទ័ព ដែលនាំយកទាហាននិងប៉ូលីសទាំងនោះទៅសម្លាប់មានតែកងទ័ពភូមិភាគ និងកងទ័ពតំបន់ទេ"*[3047]។

៧០៨. ជនរងគ្រោះគ្រប់គ្នា បានមកដល់សាលាខេត្តពោធិ៍សាត់ ដោយស្ម័គ្រចិត្ត[3048]។ មានការប៉ាន់ប្រមាណថាមានមនុស្សប្រហែល ៣០០០នាក់បានមកក្នុងបរិវេណសាលាខេត្តដើម្បីចូលរួមនៅក្នុងការប្រជុំ[3049]។

៧០៩. ជនរងគ្រោះត្រូវបានកម្មាភិបាល ប.ក.ក បំភ័ន្តដោយប្រាប់ថា ពួកគេនឹងត្រូវយកទៅរៀនសូត្របន្ទាប់មកទើបអាចធ្វើសមាហរណកម្មចូលក្នុងជួរកងទ័ពជាមួយឋានន្តរស័ក្តិដដែល ឬខ្ពស់ជាង[3050]។ ដំណឹងនេះបានផ្សាយទៅកាន់ហ្វូងមនុស្សតាមរយៈឧឃោសនស័ព្ទ[3051]។ ហេតុដូចនេះហើយ បានជាអតីតទាហាន និងអ្នករដ្ឋការ លន់ នល់ បានចាកចេញពីអង្គប្រជុំដោយក្ដីរីករាយ និងគ្មានការព្រួយបារម្ភ បន្ទាប់ពីស្ដាប់ឮការសន្យានេះ ហើយពួកគេក៏ត្រូវបានប្រាប់ផងដែរថា ពួកគេនឹងបានចូលគាល់សម្ដេចព្រះ **នរោត្តម សីហនុ**[3052]។ បន្ទាប់មក ជនរងគ្រោះត្រូវបានដឹកជញ្ជូនតាមឡានធំៗទៅកាន់បន្ទាយទាហាន នៅទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ[3053]។ ឡាននីមួយៗមានផ្ទុកមនុស្សប្រហែលពី ៣០ ទៅ ៤០នាក់[3054]។ ពេលនោះមិនមានឡានគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនជនរងគ្រោះតែមួយជើងនោះទេ ដូច្នេះគេត្រូវធ្វើការដឹកជញ្ជូនជាច្រើនជើង[3055]។ ប្រតិបត្តិការខាងលើត្រូវបានធ្វើដោយកងទ័ពវរៈតំបន់ ២០១ និងទាហានវរៈ២៤ របស់ភូមិភាគពាយ័ព្យ។ មានការលើកឡើងផងដែរថា តា

ខ្លែង ក៏បានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការនេះ[3056]។

៧១០. ជនរងគ្រោះត្រូវបានសម្លាប់ភ្លាមៗ នៅពេលទៅដល់[3057]។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានចំណាយពេលពេញមួយថ្ងៃក្នុងការបាញ់សម្លាប់ជនរងគ្រោះ គឺតាំងពីពេលព្រឹករហូតដល់ពេលល្ងាច[3058]។

៧១១. សាកសពជនរងគ្រោះត្រូវបានគេកប់នៅក្នុងរណ្តៅរួមជាច្រើន[3059] ហើយរណ្តៅនីមួយៗមានសាកសពជាច្រើន និងមានទំហំប្រហែលជា១០ ម៉ែត្របួនជ្រុង។[3060]គេបានប្រើប៊ុលដូស័រដើម្បីកប់សាកសពជនរងគ្រោះ ដែលគរជាគំនរលើគ្នា[3061]។ ឯកសណ្ឋានទាហាន លន់ នល់ ត្រូវបានគេរកឃើញនៅជិតរណ្តៅសាកសពនោះ[3062]។ ជនរងគ្រោះត្រូវបានគេចងស្លាបសេកដាក់ដៃទៅក្រោយ និងចងភ្ជាប់គ្នាជាជួរ[3063]។ សាកសពជនរងគ្រោះប្រឡាក់ទៅដោយឈាម និងមានស្នាមគ្រាប់ដែលខ្លះត្រូវបាញ់ចំក្បាល និង ខ្លះទៀតចំដើមទ្រូង[3064]។ សាក្សីបានប៉ាន់ប្រមាណថា មានសាកសពជនរងគ្រោះប្រមាណជា ២០០០[3065] ទៅ ៣០០០ នាក់ ។

<u>ប្រជាជនមូលដ្ឋាន និង ប្រជាជនថ្មីមកពីសហករណ៍</u>

៧១២. សាក្សីបានបញ្ជាក់បន្ថែមទៀតថា ក្រៅពីការសម្លាប់ជាទ្រង់ទ្រាយធំដែលប្រព្រឹត្តលើអតីតអ្នករដ្ឋការ និងទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ក៏មានការសម្លាប់ជាទ្រង់ទ្រាយតូចផងដែរនៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ចំពោះមនុស្សដែលមកពីសហករណ៍មូលដ្ឋាន ដែលត្រូវបានគេយល់ឃើញថាមានប្រវត្តិរូបមិនល្អ ឬខ្ជិលច្រអូស[3066]។ សាក្សីមួយរូបបញ្ជាក់ថា មានការចាប់មនុស្សជាបន្តបន្ទាប់ ហើយនៅពេលដែលចំនួនអ្នកចាប់ខ្លួនកើនដល់ ១០០ ទើបពួកគេបញ្ជូនអ្នកទោសទាំងនោះទៅទួលពោធិ៍ជ្រៃដើម្បីសម្លាប់ [3067]។

៧១៣. អ្នកទោសត្រូវបានគេដឹកយកទៅសម្លាប់នៅបឹងមួយ ដែលមានចម្ងាយបួនគីឡូម៉ែតពីទួលពោធិ៍ជ្រៃផងដែរ។ សាក្សីមួយរូបបាននិយាយថា ក្នុងបឹងពោរពេញទៅដោយសាកសព ដែលសាក្សីបានប៉ាន់ប្រមាណថា មានប្រហែល ៥០០០ នាក់ ដែលត្រូវបានទម្លាក់ទៅក្នុងបឹងមួយនេះ [3068]។

***



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៧១៤. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០នាក់ (ម្ភៃនាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[3069]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ។

### កន្លែងសម្លាប់មនុស្សស្ទឹងតូច[3070]

### ទីតាំង និងការបង្កើត

៧១៥. កន្លែងសម្លាប់មនុស្សស្ទឹងតូច[3071] មានទីតាំងភូមិសាស្ត្រស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ ដែលមានចំងាយប្រហែល៧ គីឡូម៉ែត្រ នៅខាងត្បូងភូមិមួយនៅលើផ្លូវជាតិលេខ៧ ឈ្មោះថា ភូមិតាហៀវក្រោម និងមានចំងាយ១០ គីឡូម៉ែត្រនៅខាងជើងព្រំដែនវៀតណាម[3072] ដែលនាពេលនោះទីកន្លែងនេះសុទ្ធតែជាព្រៃ[3073] ដែលមានទីតាំងស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម (ដែលបច្ចុប្បន្ននេះស្ថិតនៅភូមិស្ទឹងតូច[3074])។ យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីសកម្ពុជាកន្លែងសម្លាប់មនុស្សស្ទឹងតូចស្ថិតនៅក្នុងតំបន់២០ ភូមិភាគបូព៌ា (តំបន់២០៣)[3075]។

៧១៦. ការស៊ើបសួរកន្លងមកមិនបានរកឃើញថា កន្លែងសម្លាប់មនុស្សស្ទឹងតូចមានទំនាក់ទំនងណាមួយជាមួយនឹងការសម្លាប់មនុស្សធ្វើឡើងដោយមន្ទីរសន្តិសុខក្នុងតំបន់នោះ មុនការបោសសម្អាតភូមិភាគបូព៌ាឡើយ[3076]។ សក្ខីកម្មជាសំខាន់ដែលប្រមូលបានពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋនេះ បង្ហាញឱ្យ ឃើញថា អង្គហេតុបានកើតឡើងក្នុងកំឡុងពេលមួយដ៏ខ្លី ខណៈពេលដែលមានការមកឈរជើងកាន់កាប់ស្រុកពញាក្រែកនាចុងខែឧសភា ឆ្នាំ១៩៧៨[3077] ក្នុងក្របខណ្ឌនៃការបោសសម្អាតភូមិភាគបូព៌ា៖ ការចាប់ខ្លួន និងការសម្លាប់មនុស្សមួយចំនួននៅស្ទឹងតូច និងនៅតំបន់ក្បែរៗនោះអាចត្រូវធ្វើឡើងនៅពេលបន្ទាប់ពីការមកឈរជើងកាន់កាប់តំបន់នោះ[3078]។ សាក្សីម្នាក់បានបញ្ជាក់ថា ការសម្លាប់ប្រជាជនភូមិបុស្ស (ដែលនឹងរៀបរាប់ខាងក្រោម) បានកើតឡើងបន្ទាប់ពីការចូលមកកាន់កាប់ត្រួតត្រាស្រុកនោះក្នុងពេលមួយដ៏ខ្លី[3079]។ ការសម្លាប់ហាក់

ដូចជាបានបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ដោយសារតែអ្នកស្រុកត្រឡប់មករស់នៅតំបន់នោះនាឆ្នាំ១៩៧៩ បានប្រទះឃើញរណ្តៅជាច្រើន“*ពោរពេញដោយសាកសពហើមថ្មីៗ*”[3080]។ ទោះបីជាយ៉ាងនេះក៏ដោយ គេមិនអាចបដិសេធចោលករណីដែលថា សាកសពខ្លះដែលប្រទះឃើញនៅកន្លែងសម្លាប់មនុស្សស្ទឹងតូច អាចជាសាកសពជនរងគ្រោះ ដែលត្រូវបានសម្លាប់ធ្វើឡើងមុនខែឧសភាឆ្នាំ១៩៧៨ ឬ សាកសពដែលស្លាប់បណ្តាលមកពីការវាយប្រយុទ្ធគ្នាឡើយ[3081]។

**ដំណើរការប្រព្រឹត្តទៅ**

**<u>រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក</u>**

**៧១៧.** ទីតាំងដែលសុទ្ធតែព្រៃនៃកន្លែងសម្លាប់មនុស្សស្ទឹងតូច ដែលជាតំបន់ប្រឈមមុខផ្នែកយោធាតាំងពីយូរយារណាស់មកហើយនោះ និងដែលបន្សល់ទុកនូវរណ្តៅគ្រាប់បែក៥២ជាច្រើន[3082] គឺជាទីតាំងមួយដ៏ល្អប្រសើរ សម្រាប់ការសម្លាប់រង្គាលដោយលាក់កំបាំង[3083]។ ទីកន្លែងសម្លាប់មនុស្សស្ទឹងតូចនេះមានរណ្តៅសាកសពច្រើនកន្លែងដែលមិនអាចកំណត់បាននូវចំនួនច្បាស់លាស់ ដែលត្រូវបានប្រទះឃើញជាបន្តបន្ទាប់ ដោយអ្នកស្រុកដែលបានត្រឡប់មករស់នៅស្រុកនោះវិញ បន្ទាប់ពីឆ្នាំ១៩៧៩[3084]។ ក្រុមអ្នកស៊ើបអង្កេតបានកំណត់អត្តសញ្ញាណទីតាំងរណ្តៅសាកសព៤កន្លែងផ្សេងៗគ្នា[3085]។

**៧១៨.** មានសក្ខីកម្មស៊ីសង្វាក់ដែលបង្ហាញថា ការសម្លាប់មនុស្សនៅក្នុងស្រុកពញាក្រែកត្រូវបានធ្វើឡើងដោយកងកម្លាំងដែលស្ថិតនៅក្រោមបញ្ជាការផ្ទាល់របស់ **កែ ពក** ដែលមានឋានៈជាលេខាភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់) និងចាប់ពីឆ្នាំ១៩៧៧មក គាត់ជាមេបញ្ជាការរងទទួលបន្ទុកសមរភូមិតាមបណ្តោយផ្លូវជាតិលេខ៧ ប្រឆាំងទៅនឹងវៀតណាម (ដែលពីដំបូងកម្លាំងនោះនៅក្រោមបញ្ជារបស់ **សោ ភឹម**)[3086]។ នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍សម្លាប់មនុស្សនៅស្ទឹងតូច មានសក្ខីកម្មខ្លះបង្ហាញផងដែរថា **កែ ពក** ធ្លាប់បានធ្វើការក្រោមការបញ្ជារបស់ **សុន សេន** (ដែលពេលនោះគាត់ឈរជើងនៅភូមិភាគបូព៌ាផងដែរ[3087]) និងក្រោមបញ្ជារបស់ **នួន ជា**[3088]។ សាក្សីម្នាក់ទៀតបានបំភ្លឺថា មេបញ្ជាការយោធាភូមិភាគកណ្តាល ដែលទទួលខុសត្រូវប្រមូលប្រជាជនយកទៅសម្លាប់មានឈ្មោះថា[លុប][3089]។

**៧១៩.** មានសាក្សីមួយចំនួនបានរៀបរាប់ អំពីដំណើរការបោសសំអាត ដែលក្នុងនោះមានសាក្សីមួយរូបបានរៀបរាប់ថា គេបានចោទ **សោ ភឹម** ថា “ក្បត់ជាតិ” ហើយគេបានយកអ្នកដែលធ្វើការនៅក្រោម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605485



សោ ភឹម ទៅសម្លាប់ទាំងអស់។ ចំណែកឯសាក្សីមួយរូបទៀតបានបញ្ជាក់ថា បន្ទាប់ពីដំណាក់កាលដំបូងនៃការចាប់ខ្លួនកម្មាភិបាលយោធាភូមិភាគបូព៌ា ពួកកងទ័ពបានចាប់ផ្តើមធ្វើ "រដ្ឋប្រហារ" ជាទូទៅ ដោយមានការចាប់ខ្លួនកម្មាភិបាលភូមិភាគ តំបន់ គណៈស្រុក គណៈឃុំ គណៈតំបន់ ប្រធានសហករណ៍ជាបន្តបន្ទាប់[3090]។

៧២០. "កម្លាំងមកបោសសំអាត" ទាំងនោះរួមមាន កងពលរបស់មជ្ឈិម (ដោយមានសមាសភាពខ្លះមកពីភូមិភាគនិរតី[3091]) និងកងពលរបស់ភូមិភាគកណ្តាល[3092]។ សាក្សីដែលនៅរស់រានមានជីវិតពីការសម្លាប់រង្គាលប្រជាជនភូមិបុស្សបានរំលឹកប្រាប់ថា កងទ័ពដែលមកយកប្រជាជនទៅសម្លាប់បាននិយាយប្រាប់ថា ពួកគេត្រូវបានជំនួសដោយទាហានមួយក្រុមទៀតក្នុងឯកសណ្ឋានព៌ណបៃតងដែលទាហានមួយក្រុមនេះនឹងសម្លាប់ចោលទាំងអស់ "ដោយមិនឱ្យនរណាម្នាក់រួចខ្លួនឡើយ"[3093]។

៧២១. មានភស្តុតាងបង្ហាញថា កំលាំងទ័ពរបស់ **សុន សេន** និង **កែ ពក** បានពង្រាយទ័ពជាច្រើនកន្លែងតាមបណ្តោយផ្លូវជាតិលេខ៧ នៅខាងលិចស្ទឹងតូច ចាប់ពីទីបញ្ជាការដ្ឋានប្រតិបត្តិការរបស់ភូមិភាគបូព៌ានៅសួង រហូតទៅដល់ភាគខាងលិច[3094] នៅទីបញ្ជាការប្រតិបត្តិការរួមនៅភូមិស្ទឹង[3095] នៅវត្តស្រះ[3096] នៅខាងលិចផ្លូវបំបែកស្ទឹងតូច។ មន្ទីរមួយដែលស្ថិតនៅអតីតទីបញ្ជាការដ្ឋានកងពលលេខ៤ នៅ "ព្រៃម៉ៃសាក់" នៅខាងត្បូងផ្លូវជាតិលេខ៧ និងខាងកើតផ្លូវបំបែកស្ទឹងតូច[3097] ទំនងត្រូវបានគេប្រើប្រាស់ធ្វើជាទីកន្លែងឈរជើងរបស់កងទ័ព ដែលបានសម្លាប់មនុស្សនៅស្ទឹងតូច ដោយហេតុថា សាក្សីដែលត្រូវបានគេដោះលែងឱ្យរួចខ្លួនពីការសម្លាប់ ត្រូវបានគេនាំយកពីទីកន្លែងសម្លាប់ស្ទឹងតូចទៅកាន់ទីនោះ[3098]។ មានសាក្សីមួយចំនួនបានប្រាប់ថា ពួកគេបានប្រើប្រាស់ឡានទាហានផលិតនៅប្រទេសចិន ដើម្បីដឹកនៅពេលចាប់ខ្លួន[3099]។

<u>ប្រភេទជនរងគ្រោះ</u>

៧២២. ជនរងគ្រោះដែលត្រូវបានសម្លាប់នៅស្ទឹងតូច អាចត្រូវបានធ្វើការបែងចែកជាច្រើនប្រភេទដូចជា៖ កម្មាភិបាលថ្នាក់ក្រោម ប្រជាជនស៊ីវិលដែលមានការពាក់ព័ន្ធនឹងកម្មាភិបាលថ្នាក់ក្រោមនេះ ឬកម្មាភិបាលយោធា ។ ប៉ុន្តែ ចំពោះករណីពិសេស ទាក់ទងនឹងប្រជាជនភូមិព្រៃទំនប់("ភូមិបុស្ស") ចាំបាច់ត្រូវមានការរៀបរាប់ដោយឡែកមួយ។

<u>កម្មាភិបាលថ្នាក់ក្រោម និងប្រជាជនពាក់ព័ន្ធនឹងកម្មាភិបាលទាំងនោះ</u>

៧២៣. បន្ទាប់ពីការបោសសម្អាតកម្មាភិបាលជាន់ខ្ពស់ទាំងផ្នែកយោធា និងនយោបាយរបស់ភូមិភាគបូព៌ាមក[3100] ដោយលើកលែងករណីពិសេសរបស់ភូមិបុស្ស (ដែលនឹងត្រូវរៀបរាប់ខាងក្រោម) ការចាប់ខ្លួនជាបន្តបន្ទាប់ជុំវិញតំបន់ស្ទឹងត្រូចហាក់ដូចជាកំរិតត្រឹមកម្មាភិបាលថ្នាក់ក្រោមដូចជា មេភូមិ ឬមេឃុំ[3101] ព្រមទាំងអ្នកដែលមានជាប់ពាក់ព័ន្ធនឹងពួកគេដូចជា សមាជិកគ្រួសាររបស់ពួកគេ[3102] (ថែមទាំងអាចរាប់បញ្ចូលការចាប់ខ្លួន ប្រជាជនថ្មី[3103] ផងដែរ)។ សាក្សីម្នាក់បានផ្តល់មកឱ្យអ្នកស៊ើបអង្កេតនូវបញ្ជីឈ្មោះកម្មាភិបាលឃុំកក់ និងកម្មាភិបាលសហករណ៍របស់ឃុំនោះចំនួន១០៥ រូបដែលបានបាត់ខ្លួននាសម័យនោះ[3104]។ ដើម្បីបំបែកជនរងគ្រោះដែលគេដៅទុកចេញពីចំណោមប្រជាជន ពួកគេទំនងជាបានប្រើប្រាស់វិធីមួយចំនួនដូចជា៖ កោះហៅទៅប្រជុំ ឬទៅរៀនសូត្រ ជាឧទាហរណ៍ ហៅទៅកាន់មន្ទីរស្រុកនៅកណ្តោលជ្រុំ[3105] បន្ទាប់មកពួកគេត្រូវបានចាប់ខ្លួន ឬបាត់ខ្លួន[3106] ឬក៏មានបាចខិតប័ណ្ណអំពាវនាវឱ្យពួកកម្មករប្រមូលផ្តុំគ្នានៅវត្តក្នុងភូមិដែលជាកន្លែង "*ប្រធានក្រុម ប្រធានកង គេប្រាប់ថាឱ្យទៅរៀនទទួលផែនការថ្មី ក្រោយមកក៏បាត់រហូត*[3107]"។

៧២៤. មានសក្ខីកម្មយ៉ាងស៊ីសង្វាក់បង្ហាញថា "ប្រជាជនធម្មតា"ដែលមានសម្លៀកបំពាក់ជាស៊ីវិលត្រូវបានសម្លាប់នៅស្ទឹងត្រូច[3108]។ សាក្សីម្នាក់បានបញ្ជាក់ថា ប្អូនប្រុសរបស់គាត់(ដែលនៅរស់ដល់សព្វថ្ងៃ) និងប្រជាជនមួយចំនួនរស់នៅភូមិបុស្សរកា(ឃុំដូនតី) ត្រូវបានឡានដឹកនៅកណ្តោលជ្រុំ ហើយត្រូវបានគេចាប់ និងបញ្ជូនយកមកសម្លាប់នៅស្ទឹងត្រូច[3109]។ សាក្សីផ្សេងទៀតបានរៀបរាប់ថា កម្មាភិបាលមូលដ្ឋាន ព្រមទាំងប្រជាជនស៊ីវិលដែលពាក់ព័ន្ធនឹងកម្មាភិបាលទាំងនោះត្រូវបានចាប់មកពីភូមិក្បែរនោះ(មានដូចជា៖ ភូមិរកាធំ ភូមិពន្លៃ ភូមិទឹកយង់) និងត្រូវបានសម្លាប់[3110]។ ប៉ុន្តែសាក្សីខ្លះបានបញ្ជាក់ថាកម្មាភិបាលថ្នាក់ក្រោមខ្លះ និងប្រជាជនស៊ីវិលផ្សេងទៀតត្រូវបានគេយកទៅសម្លាប់នៅកន្លែងដ៏ទៃទៀតនៅក្នុងស្រុកនេះផងដែរ[3111]។

<u>កម្មាភិបាលយោធា</u>

៧២៥. មានភស្តុតាងមួយចំនួនបានបង្ហាញពីសាកសពទាហានដែលមានកប់នៅស្ទឹងត្រូច[3112]។ សាក្សីម្នាក់បានរៀបរាប់ថា រណ្តៅសាកសពមួយចំនួនមានសាកសពមនុស្សប្រុសជាច្រើន"*ប្រហែលជាយោធាច្រើនជាង ពីព្រោះឃើញមានបន្សល់ទុកក្បែររណ្តៅនូវទូសៀគ្រាប់ ខោអាវគគី ដែលជាខោអាវយោធា និងឃើញស្បែកជើងពុម្ពដែលផលិតនៅប្រទេសចិន*" [3113]។ សាក្សីផ្សេងទៀតបានបញ្ជាក់ផងដែរនូវសំណល់សាកសពដែលអាចធ្វើឱ្យគេសន្និដ្ឋានថា សាកសពមួយចំនួនដែលគេបាន

ប្រទះឃើញគឺជាសាកសពរបស់ទាហានខ្មែរ[3114]។

៧២៦. ទោះបីជាយ៉ាងណាក៏ដោយ ភាពស្រពិចស្រពិលខ្លះនៅតែមាន។ ទោះបីជាសាក្សីមួយចំនួនបានបញ្ជាក់ថា កងទ័ពរបស់ភូមិភាគបូព៌ាត្រូវបានចាប់ខ្លួននិងបាត់ខ្លួន ក្នុងកំឡុងពេលព្រឹត្តិការណ៍នៅស្ទឹងតូចក៏ដោយ[3115] ប៉ុន្តែ គ្មានភស្តុតាងដែលអាចបង្ហាញឲ្យឃើញពីទំនាក់ទំនងដែលថាសាកសពដែលគេប្រទះឃើញនោះ[3116] ពិតជាសាកសពរបស់កងទ័ពទាំងនោះទេ។ ជាងនេះទៅទៀត គេត្រូវធ្វើការកត់សំគាល់ថា អាចមានកងទ័ពដែលបានស្លាប់នៅពេលមានការប្រយុទ្ធគ្នា ខណៈពេលដែលមានការចូលមកឈរជើងកាន់កាប់ភូមិភាគបូព៌ានេះ[3117] និងថាមានកងទ័ពខ្លះបានរួចជីវិតពីការបោសសម្អាត ហើយបានចូលរួមកម្លាំងតស៊ូនៅក្នុងព្រៃ[3118] ហើយថាអាចមានកងទ័ពខ្មែរ ឬកងទ័ពវៀតណាម[3119] ខ្លះបានស្លាប់នៅស្ទឹងតូច នៅក្នុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម[3120]។

<u>ករណីពិសេសចំពោះប្រជាជនភូមិព្រៃទំនប់ ("ភូមិបុស្ស")</u>

៧២៧. មានសក្ខីកម្មនានាបង្ហាញយ៉ាងច្បាស់ អំពីការសម្លាប់ប្រជាជនភូមិព្រៃទំនប់ ក្នុងចំនួនដ៏ច្រើន(ដែលត្រូវបានគេស្គាល់ផងដែរថាជាភូមិ "បុស្ស" នៃឃុំដូនតីរបស់ស្រុកពញាក្រែក) នៅកន្លែងសម្លាប់មនុស្សស្ទឹងតូចនាខែមិថុនា ឆ្នាំ១៩៧៨[3121]។ សាក្សីមួយចំនួនដែលរស់រានមានជីវិតពីការសម្លាប់បញ្ជាក់ប្រាប់ថា អ្នកភូមិត្រូវបានគេនាំយកទៅកន្លែងនោះ ហើយសម្លាប់ចោលក្នុងពេលតែមួយយប់[3122]។ អ្នកនៅរស់រានមានជីវិតម្នាក់បានប្រាប់អ្នកស៊ើបអង្កេតនូវរឿងហេតុដែលគាត់បានចាំ និងបានផ្ដល់នូវបញ្ជីឈ្មោះមានបញ្ជាក់អាយុ និងមុខរបររបស់អ្នកភូមិចំនួន១៤០នាក់ ដែលពួកគេត្រូវបានដឹកតាមឡានយកទៅសម្លាប់ ដែលអ្នកទាំងអស់នោះ "*គឺមានចម្រុះ មានទាំងកម្មាភិបាលសហករណ៍ ប្រជាជនធម្មតា កូនក្មេង មនុស្សចាស់ គណៈឃុំ [លុប] (...) ប៉ុន្តែគ្មានយោធាទេ*" [3123]។

៧២៨. បើប្រៀបធៀបទៅនឹងការប្រព្រឹត្តដែលបានធ្វើទៅលើអ្នកភូមិដទៃទៀតនៅក្នុងតំបន់នោះ សកម្មភាពប្រព្រឹត្តនេះមានលក្ខណៈធ្ងន់ធ្ងរជាង ដោយសារតែ **សោ ភឹម** មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងភូមិព្រៃទំនប់[3124]។ អ្នកនៅរស់រានមានជីវិតពីការសម្លាប់ម្នាក់ ដែលសក្ខីកម្មរបស់គាត់ស៊ីសង្វាក់ជាមួយនឹងសក្ខីកម្មរបស់សាក្សីផ្សេងទៀត បានរៀបរាប់ប្រាប់ថា នៅពេលចុះពីឡាន កងទ័ពបាននិយាយទៅកាន់ពួកគេថា "*ពួកអ្នកឯងសុទ្ធតែកូនចៅ អា ភឹម*"[3125]។

៧២៩. តាមការបំភ្លឺរបស់សាក្សី អង្គហេតុនោះបានកើតឡើងដូចតទៅ៖ នៅថ្ងៃមួយ មានកងទ័ពមួយក្រុម ប្រហែលជាងដប់នាក់ស្លៀកឯកសណ្ឋានខ្មៅ ក្រម៉ាស្លូត្រ និងពាក់មួកកន្ទិបក្រណាត់[3126] បានចូលមកក្នុងភូមិបុស្ស ដោយមានឡានកងទ័ពធំបី ឬបួន។ គណៈភូមិបុស្សបានរៀបចំការប្រជុំនៅក្នុងបរិវេណសាលា[3127]។ ពួកគេបាននិយាយប្រាប់ប្រជាជនថា *អង្គការ*ថ្នាក់លើ[3128] ចង់ឱ្យផ្លាស់កន្លែងទៅរស់នៅស្នួងនៅលើផ្លូវជាតិលេខ៧ នៅខាងលិចស្រុកពញាក្រែក ដែលនៅទីនោះមានផ្ទះធ្វើអំពីថ្មច្រើន ដើម្បីធ្វើការនៅក្នុងចំការកៅស៊ូ[3129]។ ពួកគេគ្រាន់តែប្រាប់ឱ្យប្រជាជនយកតែសម្លៀកបំពាក់បន្តិចបន្តួចដែលជាប់នឹងខ្លួន ហើយមិនចាំបាច់យកចានឆ្នាំង ឬកន្ទេលឡើយ[3130]។

៧៣០. បន្ទាប់មកប្រជាជនបានត្រលប់មកផ្ទះរៀងៗខ្លួនវិញ ដើម្បីប្រមូលក្រុមគ្រួសាររបស់ពួកគេ ហើយក្មេងៗដែលកំពុងធ្វើការនៅវាលស្រែត្រូវបានកងទ័ពហៅឱ្យមកជុំគ្នាក្នុងភូមិ[3131]។ នៅប្រហែលជាម៉ោង៤ ល្ងាច ប្រជាជនទាំងស្រី ប្រុស ក្មេង ចាស់ ត្រូវបានគេប្រមូលឱ្យឡើងឡានក្រោមការយាមកាមរបស់កងទ័ពប្រដាប់ដោយអាវុធ ដែលក្នុងមួយឡានអាចដាក់មនុស្សពី៣០ ទៅ៤០នាក់ (ដោយនៅពេលនោះគ្មានកន្លែងគ្រប់គ្រាន់សំរាប់ប្រជាជនទាំងអស់ទេ)[3132]។ ប៉ុន្តែ ឡានទាំងនោះមិនបានធ្វើដំណើរទៅកាន់កន្លែងដែលបានប្រកាសប្រាប់នោះទេ បែរជាបត់ទៅខាងកើតតាមផ្លូវជាតិលេខ៧ ដោយឆ្លងកាត់ភូមិកណ្តោលជ្រុំ និងភូមិតាហៀវក្រោម[3133]។

៧៣១. នៅក្នុងឡានទាំងនោះមានកងទ័ពយាមកាម ដោយមានកងទ័ពម្នាក់កាន់កាំភ្លើងអង្គុយនៅខាងក្រោយឡាន ដើម្បីយាមមនុស្សជិះក្នុងឡាន ចំណែកឯកងទ័ពផ្សេងទៀត អង្គុយនៅក្នុងកាប៊ីនឡាន។ សាក្សីបានប្រាប់ថា មិនមានការចង ឬគំរាមកំហែងទេនៅក្នុងអំឡុងពេលដឹកជញ្ជូនមនុស្សនោះ[3134]។

៧៣២. នៅប្រហែលម៉ោង៦ល្ងាច ពេលដែលឡានដឹកមនុស្សមកដល់ស្ទឹងតូច ឡានក៏បានឈប់នៅក្បែរផ្លូវស្រាប់តែមានកងទ័ពមួយក្រុមបានចេញមកពីក្នុងព្រៃ[3135]។ កងទ័ពទាំងនោះបានភ្ជង់កាំភ្លើង ហើយបានបញ្ជាឱ្យប្រជាជនចុះពីឡាន យកក្រមាចងដៃទៅក្រោយរួចយក*ខ្សែអង្រឹង*[3136]ចងម្តងប្រាំនាក់ ដោយមនុស្សប្រុសត្រូវបានចងដោយឡែកពីមនុស្សស្រី និងក្មេងៗ[3137]។ មានមនុស្សចាស់ម្នាក់ដែលមានជម្ងឺ ស្មារតីបានតដៃជាមួយកងទ័ព ក៏កងទ័ពវាយគាត់ចំថ្ងាស់មួយស្វ័យកាំភ្លើងស្លាប់ទៅ[3138]។

៧៣៣. មនុស្សប្រុសត្រូវបានគេនាំយកទៅសម្លាប់មុន[3139] ប្រហែលជាចម្ងាយ៥០ ទៅ៦០ម៉ែត្រពីផ្លូវខាងត្បូងប៉ុស្តិ៍នគរបាលឃុំកក់បច្ចុប្បន្ន[3140]។ អ្នករស់រានមានជីវិតពីរនាក់ ក្នុងចំណោមអ្នករស់រានមានជីវិតទាំងអស់ ១១រូប ដែលជាសាក្សីឃើញផ្ទាល់ភ្នែកអំពីការសម្លាប់[3141]បានឱ្យដឹងថា នៅពេលចូលដល់ក្នុងព្រៃ ពួកកងទ័ពបានបញ្ជាឱ្យពួកប្រុសៗឈប់ បន្ទាប់មកពួកគេត្រូវបានគេយកចេញពីខ្សែម្តងម្នាក់ៗ ហើយនាំទៅកាន់រណ្តៅដែលបានជីករួចស្រេច អាចជារណ្តៅបេ-៥២ចាស់ក៏ថាបាន[3142]។ អ្នកនៅរស់រានមានជីវិតពីការស្លាប់ម្នាក់បានរៀបរាប់ថា *"ពួកយោធាបានបណ្តើរប្រជាជនម្តងម្នាក់ៗ សំដៅទៅរករណ្តៅក្នុងព្រៃ ដោយមានក្រម៉ាចងដៃ រួចហើយបណ្តើរទៅឈប់មាត់រណ្តៅ ដោយមានពួកយោធា២នាក់នាំយកទៅរួចយកកាំភ្លើងខ្លីភ្ជង់នឹងគុម្ពត្រចៀក ដោយវាប្រាប់ថា កុំឱ្យស្រែក និងកុំឱ្យរត់។ ពួកវាបានយកព្រនង់ឈើម្នាក់មួយៗ វាយព្រមគ្នាទៅលើប្រជាជនទំលាក់រណ្តៅ"*[3143]។ ឯសាក្សីនៅរស់រានមានជីវិតម្នាក់ទៀត ដែលពេលនោះស្ថិតនៅក្នុងជួររង់ចាំការសម្លាប់ និងបានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់មនុស្សជាច្រើនអ្នកនៅក្នុងយប់នោះបានបញ្ជាក់ស៊ីសង្វាក់ទៅនឹងសក្ខីកម្មនៃអង្គហេតុនេះ ព្រមទាំងអះអាងបន្ថែមថា *"បើអ្នករងគ្រោះ* [បន្ទាប់ពីបានវាយទម្លាក់ចូលរណ្តៅ] *នៅកំរើកគេនឹងចាក់បន្ថែមជាមួយ បាយ៉ូណែតកាំភ្លើងសេកាសេ"*[3144]។ សាក្សីផ្សេងទៀត ដែលមិនអាចមើលឃើញរណ្តៅសម្លាប់ពីទីកន្លែងដែលខ្លួនស្ថិតនៅ បានរលឹកថាពួកគាត់បានឮសម្លេងវាយសម្លាប់ និងសម្លេងស្រែករបស់ជនរងគ្រោះ[3145] និងបញ្ជាក់ថាពួកកងទ័ពថែមទាំងបានប្រមូលសម្លៀកបំពាក់ របស់អ្នកដែលត្រូវបានសម្លាប់ផងដែរ[3146]។

៧៣៤. អ្នកនៅរស់រានមានជីវិតម្នាក់រៀបរាប់ថា នៅពេលដែលដល់វេនគេយកគាត់ទៅសម្លាប់ គាត់ត្រូវបានគេវាយក្បាលពីក្រោយ និងត្រង់ត្របកភ្នែកខាងឆ្វេង មុននឹងធ្លាក់ទៅលើសាកសពចំនួនប្រហែល៨ទៅ ១០នាក់ដែលគេបានសម្លាប់ទៅក្នុងរណ្តៅ[3147]។ ដោយគិតថាជនរងគ្រោះបានស្លាប់ហើយកងទ័ពបានចុះទៅក្នុងរណ្តៅស្រាយយកក្រមាដែលចងនឹងដៃ[3148]។ មួយសន្ទុះក្រោយមក ពេលដែលរណ្តៅរបស់គាត់ពេញ សាក្សីបានរើខ្លួនពីគំនរសាកសពដែលនៅពីលើគាត់ ហើយបានសម្ងំលាក់ខ្លួន[3149]។ រួចព្រលឹមឡើងគាត់បានរត់ចូលព្រៃដោយឆ្លងកាត់ភូមិជាច្រើន ដើម្បីលាក់ខ្លួន។ ក្នុងពេលគេចខ្លួន គាត់ក៏បានប្រាប់អំពីការសម្លាប់នេះដល់មេដឹកនាំមូលដ្ឋានមួយចំនួន។ គាត់បានដឹងពីប្រជាជនក្នុងភូមិទាំងនោះថា កងទ័ពនឹងមកយកប្រជាជននៅភូមិពន្លៃឱ្យផ្លាស់ទីលំនៅ ដែលភូមិពន្លៃគឺជាភូមិគំរូមួយទៀតរបស់ **សោ ភឹម** នៅក្នុងឃុំកក់ ហើយគាត់ក៏បានរត់ទៅប្រាប់ប្រជាជនឱ្យគេចខ្លួន មុនពេលដែលគាត់រត់ចូលព្រៃ ហើយជាច្រើនខែក្រោយមកក៏រត់ទៅដល់ប្រទេសវៀត

ណាម[3150]។ សាក្សីមួយចំនួននៅភូមិពន្លៃបានបញ្ជាក់អះអាងថា ពួកគេពិតជាបានជួបអ្នករស់រានមានជីវិតមួយនេះ នៅពេលដែលគាត់បានមកប្រាប់អំពីរឿងសម្លាប់ ហើយប្រាប់ឱ្យរត់គេចខ្លួនផងដែរ[3151]។

៧៣៥. ចំពោះស្ត្រី និងកូនក្មេងដែលរង់ចាំនៅលើថ្នល់ពេញមួយយប់ ពួកគេក៏ត្រូវបានគេចងរួមគ្នាផងដែរ ដើម្បីនាំចូលទៅក្នុងព្រៃសម្លាប់នៅពេលដល់វេនពួកគេ[3152]។ ប៉ុន្តែ មានស្ត្រីម្នាក់ ព្រមទាំងគ្រួសាររបស់គាត់(ដែលមានចំនួនសរុប១០នាក់ ដោយក្នុងនោះមានចំនួន៥ នាក់ត្រូវបានស្លាប់យកចម្លើយនៅក្នុងអំឡុងពេលស៊ើបសួរ[3153]) ត្រូវបានគេទុកជីវិត ដោយសារស្ត្រីនោះបានបញ្ចុះបញ្ចូលកងទ័ពទាំងនោះថា កូនប្រុសគាត់គឺ ជាកងទ័ពរបស់"មជ្ឈិម"។ នៅពេលព្រឹកឡើង គ្រួសាររបស់គាត់ត្រូវបានដឹកតាមឡានទៅកាន់មន្ទីរ"ម៉ៃសាក់" (ក្បែរផ្លូវបំបែកផ្លូវជាតិលេខ៧) ហើយត្រូវបានឃុំនៅទីនោះចំនួន៥ថ្ងៃ ជារយៈពេលដែលគេធ្វើការបញ្ជាក់អំពីអ្វី ដែលគេបាននិយាយប្រាប់ជាមួយនឹងមេបញ្ជាការមជ្ឈិម (ដែលប្រហែលជាមនុស្សម្នាក់ឈ្មោះ "ពក") មុនបញ្ជូនពួកគេទៅកាន់សហករណ៍វិញ[3154]។

៧៣៦. សាក្សីខ្លះបានវាយតំលៃថា មនុស្សប្រហែល១៦០ ទៅ៣០០ នាក់ត្រូវបានដឹកពីព្រៃទំនប់ទៅកាន់ស្ទឹងតូចនាថ្ងៃនោះ[3155]។ សក្ខីកម្មរបស់សាក្សីទាំងនោះ មានភាពស៊ីសង្វាក់គ្នាទៅនឹងអ្វី ដែលបានបំភ្លឺថាមានអ្នករស់រានមានជីវិតប្រហែលតែ១០ ឬ១១ នាក់ ប៉ុណ្ណោះ[3156]។ សាក្សីម្នាក់គិតថា នៅពេលដែលគេដឹងថា ប្រជាជនមិនត្រូវបានគេដឹកទៅកាន់ស្លូងទេនោះ ប្រជាជនខ្លះដែលនៅក្នុងភូមិបុស្សបានភៀសខ្លួនទៅក្នុងព្រៃ៖ ជាក់ស្តែងឡានដើងទីពីរដែលបានត្រលប់ទៅដឹកមនុស្សមកពីស្ទឹងតូចវិញនៅពេលព្រឹកគឺស្ទើរតែទទេទៅហើយ[3157]។

**<u>ចំនួនអ្នកស្លាប់</u>**

៧៣៧. ក្រៅពីករណីភូមិបុស្ស ដោយគ្មានការធ្វើកំណាយសាកសពជាផ្លូវការ គេមិនអាចកំណត់ចំនួនពិតប្រាកដនៃមនុស្សដែលត្រូវបានសម្លាប់ និងត្រូវបានកប់នៅទីកន្លែងនោះទេ។ នៅក្នុងឆ្នាំ១៩៧៥ ឃុំកក់ (ដែលមានជនរងគ្រោះភាគច្រើនត្រូវបានសម្លាប់នៅស្ទឹងតូច ជាមួយនឹងឃុំដូនតី) មាន១០ភូមិ ឬសហករណ៍ដោយមានប្រជាជនសរុបប្រហែលជា ១០០០ នាក់[3158]។ សាក្សីម្នាក់បានផ្តល់មកឱ្យអ្នកស៊ើបអង្កេតនូវបញ្ជីឈ្មោះកម្មាភិបាលឃុំកក់ ឬកម្មាភិបាលសហករណ៍របស់ឃុំនេះ ចំនួន១០៥ រូបដែលបានបាត់ខ្លួន ប៉ុន្តែគាត់មិនមានលទ្ធភាពបញ្ជាក់អះអាងថា ពួកគេទាំងនោះពិតជាត្រូវបាន

00605491



សម្លាប់នៅស្ទឹងតូចនោះទេ[3159]។ សាក្សីម្នាក់ទៀតដែលបញ្ជាក់អះអាងថា មានអ្នកភូមិបុស្សរកា ត្រូវបានគេយកទៅសម្លាប់នៅទីកន្លែងនោះ (ស្ទឹងតូច) មិនបានផ្ដល់ចំនួនតួលេខពិតប្រាកដទេ[3160]។

៧៣៨. ការិយាល័យវប្បធម៌ស្រុកពញាក្រែក បានធ្វើការស្រាវជ្រាវដល់ទីកន្លែង តាមរយៈសាកសព ដែលបានប្រទះឃើញនៅក្នុងរណ្តៅមួយចំនួននាឆ្នាំ១៩៨១ និងទំនងជាបានប្រមូលចំនួនស្ថិតិដែល ពាក់ព័ន្ធនឹងការបាត់ខ្លួននៅស្ទឹងតូច[3161] ប៉ុន្តែសាក្សីម្នាក់បានបង្ហាញនូវភាពមន្ទិលសង្ស័យ ទៅលើ ភាពត្រឹមត្រូវរបស់ការស្រាវជ្រាវនេះ[3162] ហើយគ្មានឯកសារណាមួយត្រូវបានរកឃើញនៅក្នុង អំឡុងពេលស៊ើបសួរឡើយ។ នៅក្នុងឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការគូសប្លង់ ផែនទីព្រៃស្ទឹងតូច ដោយបានកំណត់អត្តសញ្ញាណរណ្តៅសាកសពចំនួន៣ កន្លែង និង បានកំណត់ ដោយមិនមានបញ្ជាក់អំពីប្រភពសំអាងនូវចំនួនអ្នកស្លាប់ថា មានចំនួន១៨០៣នាក់ដែលបានស្លាប់ នៅកន្លែងសម្លាប់ស្ទឹងតូច[3163]ដែលចំនួនតួលេខនេះទំនងជាតួលេខស្ថិតិរបស់រដ្ឋាភិបាល។ ទោះបីជា មានការចុះអង្កេតផ្នែកនីតិវេជ្ជវិទ្យាបានធ្វើឡើងនៅកន្លែងនោះនាឆ្នាំ២០០៤ ក៏ដោយ[3164] ក៏គ្មាន ភស្តុតាងណាមួយបង្ហាញថា ទីកន្លែងនោះត្រូវបានគេធ្វើកំណាយសាកសពជាផ្លូវការឡើយ ហើយក៏ មិនមានបូជនីយដ្ឋានសំរាប់តំកល់អដ្ឋធាតុនោះដែរ[3165]។ ចាប់តាំងពីឆ្នាំ១៩៧៩មក គេឃើញ ពេលខ្លះមានអ្នកធ្វើកំណាយគាស់រកសាកសព[3166] មានការកាប់ឆ្ការ-រានព្រៃ ការរាន និងភ្ជួររាស់ ដីដើម្បីធ្វើស្រែ-ចំការ នៅទីកន្លែងនោះ[3167]។

***

៧៣៩. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៤នាក់ (បួននាក់) ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងកន្លែង សម្លាប់មនុស្សស្ទឹងតូច[3168]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវ បានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែល គួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្ដល់ភស្តុ តាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្ដាលមកពី ផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅកន្លែងសម្លាប់មនុស្សស្ទឹងតូច។

00605492



## ឃ. ការប្រព្រឹត្តចំពោះក្រុមមនុស្សជាក់លាក់

### ការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនិកជន[3169]

**៧៤០.** បក្សកុម្មុយនីសកម្ពុជា បានអនុម័តនូវគោលការណ៍ ហាមឃាត់មិនឱ្យមាន និង គោរពព្រះពុទ្ធសាសនា[3170]។ វត្តអារាម និងព្រះវិហារជាច្រើនត្រូវបានបំផ្លាញចោល[3171] ឬត្រូវបានផ្លាស់ប្តូរសម្រាប់គោលដៅផ្សេងៗដូចជា មន្ទីរសន្តិសុខ ទ្រុងជ្រូក រោងបាយរួម មន្ទីរពេទ្យ ឬឃ្លាំងស្តុកសំភារៈ[3172]។ ព្រះពុទ្ធរូបមាករត្រូវបានគេបំផ្លាញចោល[3173] ហើយសូម្បីតែការអុចទៀនធូបក៏ត្រូវបានហាមឃាត់ផងដែរ[3174]។ បក្សកុម្មុយនីស្តកម្ពុជា បានជំរុញឱ្យមានការស្អប់ខ្ពើមព្រះសង្ឃ និងដូនជី ដោយបានផ្សព្វផ្សាយថា ព្រះសង្ឃ គឺជាប៉ារាស៊ីត ឈ្លើងជញ្ជក់ឈាម គេនញ៉ា[3175]។ សាក្សីម្នាក់បានរៀបរាប់ថា *"នៅពេលដែលខ្មែរក្រហមកាន់កាប់ទីនេះភ្លាម គេហាមមិនឱ្យមានសាសនា។ គេមិនអនុញ្ញាតិឱ្យធ្វើបុណ្យធ្វើទានទេ លោកត្រូវគេផ្សឹកអស់។ មេកង មេភូមិ មេឃុំ គេប្រកាសថាមិនឱ្យមានអបិយជំនឿ។ គេថាលោក អាពាក់អាវធំ សក្តិភូមិ ជញ្ជក់ឈាមរាស្ត្រ"* [3176]។

**៧៤១.** ព្រះសង្ឃ និងដូនជី ស្ទើរទាំងអស់ត្រូវបានគេផ្សឹក[3177]។ ព្រះសង្ឃមួយចំនួន ត្រូវបានគំរាមកំហែងដល់អាយុជីវិត ឬត្រូវសម្លាប់បើសិនជាមិនព្រមធ្វើតាម[3178]។ បន្ទាប់ពីត្រូវផ្សឹកហើយ ព្រះសង្ឃទាំងនោះត្រូវបង្ខំឱ្យធ្វើពលកម្ម និងធ្វើស្រែចំការ[3179]។ អតីតសង្ឃមួយអង្គ បានរៀបរាប់ថា ខ្លួនត្រូវបានបង្ខំឱ្យរៀបការ ហើយបើជំទាស់ គាត់នឹងត្រូវបានគេយកទៅ"*រណ្តៅ*"[3180]។

**៧៤២.** សក្ខីកម្មជាច្រើនបានបញ្ជាក់ខុសៗគ្នា អំពីប្រភពនៃការចេញបញ្ជាឱ្យធ្វើទុក្ខបុកម្នេញលើព្រះសង្ឃខាងពុទ្ធសាសនា ។ សាក្សីខ្លះទៀតបានបំភ្លឺថា មានបញ្ជាមកពី"*ថ្នាក់លើ*"[3181] ឬពី"*មជ្ឈិមបក្ស*"[3182]។ សាក្សីផ្សេងទៀតបានរៀបរាប់ អំពីការប្រជុំរបស់គណៈស្រុក នៅក្នុងតំបន់របស់ពួកគេ[3183] ឬ បានឱ្យដឹងថា បញ្ជាត្រូវបានទទួលដោយផ្ទាល់ពីគណៈស្រុក និងគណៈឃុំ[3184]។

**៧៤៣.** ការលុបបំបាត់សាសនា ការបំផ្លិចបំផ្លាញវត្តអារាម និងការប្រើប្រាស់វត្តអារាម ក្នុងគោលបំណងផ្សេងទៀត ។ល។ បានកើតជាទូទៅនៅគ្រប់ខេត្តទាំងអស់នៃប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា៖ នៅភូមិភាគនិរតី[3185](ជាអាទិ៍ វត្តដំណាក់ត្រយឹង នៅក្នុងស្រុកទូកមាស ខេត្តកំពត[3186]) ភូមិភាគពាយ័ព្យ[3187] (ជាអាទិ៍ វត្តសំរោង នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង[3188] និងវត្តគីរីរម្យ នៅ

00605493



ស្រុកភ្នំសំពៅ ខេត្តបាត់ដំបង[3189]) ភូមិភាគកណ្តាល(ឧត្តរចាស់)[3190] ភូមិភាគឧត្តរ(ថ្មី)[3191] ភូមិភាគបូព៌ា[3192] (ជាអាទិ៍ វត្តចំបក់ នៅក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង[3193] វត្តតាគត់ និងវត្តមេ ដែលស្ថិតនៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល[3194] និង វត្តធ្លក នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង[3195]) ភូមិភាគបស្ចិម[3196] ភូមិភាគឦសាន[3197] (ជាអាទិ៍ វត្តជ័យមង្គល នៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង[3198]) និង នៅក្នុងតំបន់ស្វយ័តនៃខេត្តក្រចេះ(តំបន់៥០៥[3199] ជាអាទិ៍ វត្តអន្ទង់វៀន នៅស្រុកក្រចេះ ខេត្តក្រចេះ[3200])។

***

**៧៤៤.** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៨៧នាក់ (ប៉ែតសិបប្រាំពីរនាក់)** ត្រូវបានប្រកាសទទួលស្គាល់ នៅក្នុងបរិបទនៃ "ប្រព្រឹត្តកម្មលើពុទ្ធសាសនិក"[3201]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរអោយជឿជាក់បាន ស្របទៅនិងវិធាន ២៣ស្ទួន (៤)។ ដើមបណ្តឹងរប្បវេណីទាំងនេះ បានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថាព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃប្រពឹត្តកម្មលើពុទ្ធសាសនិក។

**ការប្រព្រឹត្តិនៅលើជនជាតចាម**[3202]

**៧៤៥.** ចាម គឺជាជនជាតិភាគតិចមួយ ដែលមានភាសាដូចគ្នា វប្បធម៌ដូចគ្នា និងសាសនាដូចគ្នា គឺសាសនាអ៊ីស្លាម[3203]។ ប្រជាជនចាមបានកំណត់អត្តសញ្ញាណខ្លួនឯងជាចាមអញ្ចឹងតែម្តង និង ត្រូវបានគេស្គាល់ថា ជាចាមអញ្ចឹងដោយអ្នកផ្សេងទៀត ដែលមិនស្ថិតនៅក្នុងក្រុមជនជាតិភាគតិចនេះ[3204]។

**៧៤៦.** មុនឆ្នាំ១៩៧៥ ជនជាតិចាមមួយចំនួនធំ រស់នៅតាមដងទន្លេមេគង្គ នៅក្នុងខេត្តកំពង់ចាម។ ពួកគេមានចំនួនច្រើន ជាពិសេសនៅស្រុកក្រូចឆ្មារ និង ស្រុកកងមាស[3205]។

**៧៤៧.** យោងតាមរបាយការណ៍របស់អ្នកបច្ចេកទេសខាងប្រជាសាស្ត្រ៖ *"ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាចាប់ពីខែមេសា ១៩៧៥ ដល់ខែមករា ១៩៧៩ ការសិក្សាប៉ាន់ប្រមាណ លើទំហំនៃមហន្តរាយ"* គេបានធ្វើការសន្និដ្ឋានថា ៣៦% នៃប្រជាជនចាមនៅប្រទេស

កម្ពុជាត្រូវបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ចំណែកឯប្រជាជនខ្មែរអត្រានៃការស្លាប់ ១៨,៧%)[3206]។

## គោលនយោបាយទាក់ទងនឹងជនជាតិចាមមុនឆ្នាំ១៩៧៥

៧៤៨. នៅអំឡុងឆ្នាំ១៩៧០ បក្សកុម្មុនីសកម្ពុជា បានចូលកាន់កាប់មួយផ្នែកធំនៃខេត្តកំពង់ចាម ដូចជាតំបន់ភាគច្រើនដែលមានចាមរស់នៅ[3207]។

៧៤៩. នៅពេលដំបូង បក្សហាក់បីដូចជា មានការយោគយល់ចំពោះឥស្លាម[3208]។ ដូចគ្នាដែរមុនឆ្នាំ១៩៧៥ មានចាមមួយចំនួនបានចូលរួមនៅក្នុងបក្សកុម្មុយនីសកម្ពុជា ឧទាហរណ៍ [លុប] ជាជនជាតិចាម ម្នាក់ ដែលធ្លាប់ជាសមាជិកគណៈស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម[3209] និងធ្លាប់ជាសមាជិករបស់គណៈកម្មាការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា[3210] (បន្ទាប់មកគាត់បានរត់ចេញពីកម្ពុជា និងឆ្លងដែនទៅប្រទេសវៀតណាមនៅខែឧសភា ឆ្នាំ១៩៧៨[3211])។ មានជនជាតិចាមផ្សេងទៀតក៏ធ្លាប់ជាកម្មាភិបាលនៅមន្ទីរ ស-២១ ដែរ (ប៉ុន្តែពួកគេទាំងអស់ក៏ត្រូវបានសម្លាប់ អ្នកខ្លះនៅឆ្នាំ១៩៧៧ អ្នកផ្សេងទៀតនៅឆ្នាំ១៩៧៨)[3212]។

៧៥០. ប៉ុន្តែក្រោយមក បក្សកុម្មុយនីស្តកម្ពុជាបានដាក់បញ្ចូលជនជាតិចាម ឲ្យស្ថិតនៅក្រោមការឃោសនាតឹងតែងប្រឆាំងនឹងការអនុវត្តន៍សាសនាជាទូទៅ និង ឃាត់ឃាំងនូវសេរីភាពរបស់ពួកគេ ជាពិសេសក្នុងការប្រតិបត្តិឥស្លាម[3213]។ សាក្សីម្នាក់បានអះអាងថា នៅឆ្នាំ១៩៧៤ បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសថា ចាម គឺជា"ខ្មាំងទីមួយ"[3214]។

៧៥១. បក្សកុម្មុនីសកម្ពុជាបានចាប់ផ្តើមកំណត់មុខសញ្ញា ក្នុងការជម្លៀសអ្នករស់នៅក្នុងភូមិចាម នៅអំឡុងឆ្នាំ១៩៧៣។ មានពេលខ្លះគឺ មានតែអ្នកដឹកនាំសាសនា និង អ្នកចេះដឹងសាសនាឥស្លាមប៉ុណ្ណោះ ដែលត្រូវគេជម្លៀស[3215] នៅក្នុងករណីផ្សេងទៀត អ្នកភូមិភាគច្រើនត្រូវបានគេជម្លៀស ហើយបានទុកតែគ្រួសារចាមមួយចំនួនប៉ុណ្ណោះនៅក្នុងភូមិនីមួយៗ[3216]។ ចាមត្រូវបានជម្លៀសទៅកាន់ខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជា[3217]។

00605495



៧៩២. មុនឆ្នាំ១៩៧៥ ចាមមួយចំនួនត្រូវបានគេចាប់ឃុំខ្លួន ធ្វើទារុណកម្ម និង សម្លាប់[3218] ។ ចាប់ពីឆ្នាំ១៩៧០ ឬឆ្នាំ១៩៧១ មន្ទីរសន្តិសុខមួយ(ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចាប់ ធ្វើទារុណកម្ម និងសម្លាប់ ដូចដែលបានរៀបរាប់ដូចខាងក្រោម) ត្រូវបានបង្កើតឡើងនៅក្រូចឆ្មារ[3219]។ បក្សកុម្មុយនីស្តកម្ពុជា បានកំណត់មុខសញ្ញាចំពោះអ្នកដឹកនាំសាសនា[3220] និងចាមដែលធ្វើការតវ៉ាប្រឆាំងនឹងការរារាំងនូវសេរីភាពក្នុងការប្រតិបត្តិនូវជំនឿសាសនារបស់ពួកគេ[3221]។ យោងតាមសាក្សីមួយចំនួន ប្រជាជនចំនួនប្រមាណ១០០នាក់[3222] ទៅ២០០ នាក់[3223] ជាជនជាតិភាគតិចចាមនៅក្នុងស្រុកក្រូចឆ្មារ និងស្រុកនានាក្នុងខេត្តកំពង់ចាម ត្រូវបានចាប់ខ្លួន និងត្រូវបានបាត់ខ្លួនពីក្នុងភូមិរបស់ពួកគេ នៅអំឡុងឆ្នាំ១៩៧៥។ សេចក្តីសម្រេចចាប់ខ្លួនត្រូវបានធ្វើឡើងនៅថ្នាក់ខេត្ត ឬខ្ពស់ជាងនេះ[3224]។

## ការប្រព្រឹត្តិលើជនជាតចាមពីឆ្នាំ១៩៧៥ ដល់ ១៩៧៧

៧៩៣. នៅក្នុងសន្និសីទដែលរៀបចំឡើងនាខែឧសភា ឆ្នាំ១៩៧៥ ដែលមានការចូលរួម ពីកម្មាភិបាលនយោបាយ និងកងទ័ពរបស់មជ្ឈិម និងថ្នាក់ក្រោម(រហូតដល់ថ្នាក់ស្រុក) **ប៉ុល ពត** និង **នួន ជា** ទំនងជាបានលើកឡើងនូវបញ្ហាទាក់ទងនឹង"ការលុបបំបាត់" ជនជាតិរបស់ចាម ដោយបានបង្ហាញនៅពេលនោះអំពីគោលនយោបាយរបស់ពួកគេ ក្នុងការលុបបំបាត់រាល់សាសនាទាំងអស់ ដែលត្រូវបានចាត់ទុកថាជាប្រតិកិរិយា[3225]។ ការផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ នៅតែបន្តចាត់ទុកជនជាតិចាមថាជា "មូស្លីមកម្ពុជា" និងប្រកាសទទួលស្គាល់សេរីភាពសាសនារបស់ពួកគេ[3226]។ ប៉ុន្តែ បន្ទាប់ខែតុលា ឆ្នាំ១៩៧៥ នៅតាមវិទ្យុ រាល់ការផ្សព្វផ្សាយជាសាធារណៈ ទាក់ទងនឹងការទទួលស្គាល់ជនជាតិចាម ត្រូវបានបញ្ឈប់នៅក្នុងបរិបទមួយដែលមានការបដិសេធ ជាទូទៅអំពីអត្តិភាពរបស់ជនជាតិភាគតិចនានានៅក្នុងប្រទេសកម្ពុជា។ ទោះបីមេដឹកនាំជាន់ខ្ពស់បក្ស[3227] និងការផ្សព្វផ្សាយជាផ្លូវការផ្សេងទៀតបានបន្ត[3228] និយាយអំពីប្រជាជនកម្ពុជាថា *"ជាតិយើងគឺសំដៅជាតិកម្ពុជា ប្រជាជនកម្ពុជាដែលមានទាំងជនជាតិខ្មែរ និងជនជាតិផ្សេងៗ។"* ក៏ដោយ ក៏គេត្រូវកត់សម្គាល់ថា ការផ្សព្វផ្សាយនេះត្រូវបានបញ្ឈប់ជាស្ថាពរនៅអំឡុងឆ្នាំ១៩៧៦។ ការផ្លាស់ប្តូរនេះបានកើតឡើង បន្ទាប់ពីការការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ របស់កម្ពុជាប្រជាធិបតេយ្យ នាខែមករា ឆ្នាំ១៩៧៦ ដែលមិនបានលើកឡើង អំពីអត្តិភាពរបស់ជនជាតិភាគតិចផ្សេងៗឡើយ[3229]។

៧៩៤. ជំពូកទី១៥ មាត្រា២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងថា៖ *"ប្រជាជនគ្រប់រូបមានសិទ្ធិជឿជំនឿ ឬ សាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជន*

*កម្ពុជាដាច់ខាត*"[3230]។ ឌុច ផ្ដល់សក្ខីកម្មដល់សហចៅក្រមស៊ើបអង្កេតថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ គឺ*"សរសេរសម្រាប់បិទបាំង"* ហើយមាត្រានេះ គឺជា *"ពាក្យភូតភរ"*[3231]។ ទាំងនេះស្របទៅនឹង [លប់] ដែលបានអះអាងថា *"ដល់ពេលចេញរដ្ឋធម្មនុញ្ញវាថាសាសនាណាក៏ប្រតិកិរិយាដែរ"*[3232]។

**៧៥៥.** ពេលខ្លះជនជាតិចាមបានធ្វើការតវ៉ា អំពីការហាមឃាត់សាសនារបស់ពួកគេ ដោយលើកយករដ្ឋធម្ម-នុញ្ញមកសំអាង។ នៅក្នុងរបាយការណ៍ប្រចាំសប្ដាហ៍មួយរបស់តំបន់៥ ភូមិភាគពាយ័ព្យដែលបានផ្ញើរទៅលេខាភូមិភាគ"ម"-៥៦០ និងបណ្ណសាររដ្ឋានមានសរសេរថា *"មានសមាសភាព ១៧ មេសាដែលមកពីភ្នំពេញដែលជាជនជាតិចាម"* បានធ្វើសកម្មភាពតវ៉ានៅក្នុងរោងបាយរួមរបស់សហករណ៍អំពីការហូបចុករបស់ពួកគេ ដោយបានសំអាងលើរដ្ឋធម្មនុញ្ញ។ អ្នករាយការណ៍បានបញ្ជាក់ថា៖ *"ចំពោះសភាពការណ៍នេះ យើងមានវិធានការហើយពិសេសគឺរកខ្សែរបស់វារកមេចលនារបស់វាដើម្បីបោសសំអាត"*[3233]។

**៧៥៦.** សាក្សីជាច្រើន (ជាជនជាតិចាម និងក្រៅពីជនជាតិចាម) ដែលរស់នៅទូទាំងប្រទេសកម្ពុជា បានបញ្ជាក់ដូចៗគ្នាថា ប.ក.ក មិនអនុញ្ញាតឱ្យមានការគោរពប្រតិបត្តិសាសនាឥស្លាម និងហាមឃាត់មិនឱ្យថ្វាយបង្គំព្រះ[3234] បានរឹបអូសយក និងដុតចោលនូវគម្ពីរកូរ៉ាន់ (កូរ៉អាន/Coran)[3235] វិហារចាមត្រូវបានបិទទ្វារ និងបំផ្លាញ[3236] ឬត្រូវបានគេប្រើប្រាស់ ក្នុងគោលបំណងផ្សេងៗទៀតដូចជា៖ រោង-បាយរបស់សហករណ៍[3237] ឃ្លាំងដាក់សម្ភារៈ[3238] ឬជាទីកន្លែងសម្រាប់ចិញ្ចឹមជ្រូក[3239]។ សាក្សីជាច្រើន(លើកលែងបីនាក់ក្នុងចំណោមពួកគេ[3240]) បានលើកឡើងថា ជនជាតិចាម ត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក[3241]។ អ្នកដឹកនាំសាសនា និងអ្នករៀនចេះដឹងសាសនាឥស្លាមជ្រៅជ្រះត្រូវបានចាប់ខ្លួន និងសម្លាប់[3242]។ ស្ត្រីជនជាតិចាមត្រូវបានគេបង្ខំឱ្យកាត់សក់ និងហាមឃាត់មិនឱ្យយកក្រមាគ្របក្បាល[3243]។ ភាសាចាម ត្រូវបានគេហាមឃាត់[3244]។ ចំពោះសម្លៀកបំពាក់ប្រពៃណីចាម ក៏ត្រូវបានហាមឃាត់ដែរ[3245]។

**៧៥៧.** យោងតាមសាក្សីមួយចំនួន បទបញ្ជាបំផ្លិចបំផ្លាញវប្បធម៌របស់ជនជាតិចាម ចេញមកពី*"អង្គការ"*[3246] មកពី*"អង្គការថាក់តាំងជាន់ខ្ពស់"*[3247] ពី *"ប្រធានភូមិ ឬប្រធានផ្នែក"*[3248] ឬពី *"មេបញ្ជាការដ្ឋាន"*[3249] ហើយ អ្នកដែលបដិសេធមិនដើរតាមការណែនាំរបស់បក្សនឹងត្រូវបានវាយធ្វើបាប[3250] ចាប់ខ្លួន ឬសម្លាប់[3251]។

00605497



៧៥៨. នាខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ មានការបះបោររបស់ជនជាតិចាមពីរដង នៅក្នុងសប្តាហ៍បន្តបន្ទាប់គ្នានៅក្នុងភូមិពីរក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម៖ កោះផល(ជាកោះមួយនៅកណ្តាលទន្លេមេគង្គ ក្នុងឃុំប៉ើសទី១) និង ស្វាយឃ្លាំង(ឃុំស្វាយឃ្លាំង)[3252]។ សាក្សីបានរៀបរាប់ថា បន្ទាប់ពីមានការបះបោរទាំងនោះ អំពើក្នុងការធ្វើទុក្ខបុកម្នេញលើជនជាតិចាម មានការកើនឡើងគួរឱ្យកត់សម្គាល់[3253]។ បុគ្គលជាច្រើនត្រូវបានចាប់ខ្លួន[3254] អ្នកភូមិស្ទើរតែទាំងអស់ ត្រូវបានបញ្ជូនចេញពីភូមិដ្ឋាន[3255] បំបែកឱ្យទៅរស់នៅលាយឡំជាមួយអ្នកភូមិខ្មែរ[3256] និងបុរសមេគ្រួសារភាគច្រើនត្រូវបានគេសម្លាប់[3257]។ សាក្សីម្នាក់ផ្សេងទៀត ដែលជាអតីតប្រធានភូមិកោះផល បានរៀបរាប់ថាមនុស្សដែលនៅសល់ពីស្លាប់មានចំនួន១៨៣នាក់ ដែលមុនបះបោរមានចំនួន ១.៨៦៤នាក់[3258] (សាក្សីម្នាក់ទៀតបានបង្ហាញថា មានអ្នករស់រានមានជីវិត ២៦៧នាក់ ក្នុងចំណោមចំនួនសរុប ១.៣០៦នាក់ដែលបានរស់នៅកោះផលពេលនោះ)[3259]។

៧៥៩. សាក្សីម្នាក់បានបញ្ជាក់ថា ក្នុងឆ្នាំ១៩៧២ គាត់ត្រូវបានប្រើឱ្យជួយធ្វើស្ថិតិប្រជាជនភូមិ៥ និងភូមិ៦ ឃុំស្វាយឃ្លាំង។ គាត់ពន្យល់ថា ស្ថិតិប្រជាជនចាមកាលពីឆ្នាំ១៩៧២ នោះមានចំនួន១.២៤២គ្រួសារ ប៉ុន្តែនៅសល់ត្រឹមតែ១៧០គ្រួសារ ប៉ុណ្ណោះក្នុងឆ្នាំ១៩៧៩[3260]។

៧៦០. កម្មាភិបាលស្រុក និងឃុំរបស់បក្សកុម្មុយនីស្តកម្ពុជាទំនងជា មានជាប់ពាក់ព័ន្ធនឹងការបង្ក្រាបអ្នកបះបោរ[3261]។

៧៦១. ឯកសារផ្សេងទៀតក្នុងសម័យនោះបានឱ្យដឹងថា មានបណ្តាញទំនាក់ទំនងក្នុងការបញ្ជូនដំណឹងពីថ្នាក់ក្រោមទៅថ្នាក់លើ ហើយថាថ្នាក់លើ មានជាអាទិ៍ នួន ជា[3262] បានដឹងអំពីរាល់សកម្មភាពរបស់ប្រជាជនចាមនៅមូលដ្ឋាន។ សារទូរលេខដែលមានចំណងជើងថា "ទូរលេខ ១៥ - សូមគោរពជូនស.មបងប៉ុលជាទីស្នេហា" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ បានឆ្លុះបញ្ចាំងឱ្យឃើញនូវគោលនយោបាយអនុវត្តដោយមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងគោលបំណង "បំបែក" ចាម និងការជម្លៀសពួកគេដោយបង្ខំពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគឧត្តរ[3263]។ សារទូរលេខនេះបានផ្ញើទៅ ប៉ុល ពត និងចម្លងជូនអ្នកផ្សេងទៀតដែលក្នុងនោះមាន នួន ជា ផងដែរ។ ភាពត្រឹមត្រូវនៃសារទូរលេខ១៥ នេះត្រូវបានបញ្ជាក់ដោយសាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅក្នុងរបបនោះ ជាអ្នកបកប្រែទូរលេខនៅមន្ទីរមជ្ឈិម ក-១ ដែលបានបញ្ជាក់ថា ប្រធានអង្គភាពសារទូរលេខបាន


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

សម្រេចចិត្តចម្លងជូន នួន ជា ហើយគាត់ក៏បានបន្ថែមថា គណៈកម្មាធិការអចិន្ត្រៃយ៍ប្រហែលជាអាចពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហានេះ[3264]។

## ***ការប្រព្រឹត្តិលើជនជាតិចាមពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៩***

**៧៦២.** សាក្សីមួយចំនួនបាននិយាយថា ប្រជាជនចាមក៏ទទួលបាននូវការប្រព្រឹត្តស្រដៀងគ្នាទៅនឹងប្រជាជនផ្សេងទៀតដែរ[3265] ហើយថាពួកគេមិនត្រូវបានចាប់ខ្លួន ឬសម្លាប់ទេ[3266] ឬក៏ថាមានការធ្វើបាបតែមួយគត់ទៅលើជនជាតិចាម គឺការហាមឃាត់មិនឲ្យប្រតិបត្តិសាសនា[3267]។ ជាពិសេសដូចជានៅទំនប់១មករា សាក្សីបីនាក់បានរៀបរាប់ថាចាមត្រូវបានរស់នៅក្នុងលក្ខខណ្ឌដូចគ្នានឹងអ្នកលើកទំនប់ខ្មែរផ្សេងទៀតដែរ[3268]។ យ៉ាងណាក៏ដោយ សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងបីខាងលើបានអះអាងថា បើឃើញនរណាម្នាក់កំពុងប្រតិបត្តិសាសនាឥស្លាម *"គេនឹងយកទៅសម្លាប់ចោល"* ហើយថាភាគច្រើននៃប្រជាជនដែលត្រូវបានគេសម្លាប់គឺជា *"ប្រជាជនថ្មី និងចាម"*[3269]។ សាក្សីម្នាក់ផ្សេងទៀតក្នុងចំណោមសាក្សីទាំងបី ដែលធ្លាប់បានធ្វើការនៅការដ្ឋាននេះ បានលើកអំណះអំណាងថា ជនជាតិចាមក៏ត្រូវបានចាត់ទុកថាមានថ្នាក់ទាបដូចប្រជាជន១៧មេសាដែរ[3270]។ សាក្សីទាំងបីនាក់ដែលធ្លាប់ធ្វើការនៅទីកន្លែងនោះបានបញ្ជាក់ថាសាសនារបស់ជនជាតិចាមត្រូវបានហាមឃាត់[3271]។

**៧៦៣.** អំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មានសាក្សីជាច្រើនបានសង្កេតឃើញថាមានការសម្លាប់រង្គាលលើប្រជាជនចាមនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងភូមិភាគបូព៌ា[3272]។

**៧៦៤.** ព្រឹត្តិការណ៍ទាំងអស់នេះហាក់ដូចជាត្រូវបានសម្របសម្រួលដោយមជ្ឈិម។ អតីតលេខាភូមិភាគកណ្តាល កែ ពក[3273] គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម[3274]។ ពាក់ពន្ធ័និងបញ្ហាសន្តិសុខគឺស្ថិតនៅក្រោមអំណាចរបស់ **សុន សេន**, **នួន ជា** និង **ប៉ុល ពត**[3275]។ ឌុច បានផ្តល់ភស្តុតាងថា កែ ពក បានមក "ភ្នំពេញជាច្រើនដង" នៅឆ្នាំ១៩៧៧[3276]។ សាក្សីម្នាក់ដែលធ្លាប់ធ្វើជាអ្នកផ្ញើទូរលេខឲ្យ កែ ពក បានផ្តល់ភស្តុតាងថាទំនាក់ទំនងរវាង កែ ពក និងមជ្ឈិម បានកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងឆ្នាំ១៩៧៨ ដោយបញ្ជាក់ថា ជាអាទិ៍នៅចុងឆ្នាំ១៩៧៨ គាត់បានទទួលសារទូរលេខច្រើនជាងចំនួនដែលគាត់បានទទួលពីមុនមក[3277]។ សាក្សីនេះក៏បានរំលឹកថា នៅពេលនោះមជ្ឈិមបានតំឡើងនូវម៉ាស៊ីនសារទូរលេខពិសេសថ្មីមួយ ដែលបង្កភាពងាយស្រួលដល់ភូមិភាគកណ្តាល

00605499



ធ្វើការបញ្ជូនដំណឹង ទៅមជ្ឈិមចាប់ពីម៉ោង៦ព្រឹករហូត ដល់ពេលអាធ្រាត្រ[3278]។ គាត់និយាយទៀតថា នៅពេលនោះដែរមានសារទូរលេខកាន់តែច្រើនជាងសព្វដងដែលត្រូវបានផ្ញើពីតំបន់ ទៅកាន់ភូមិភាគ[3279]។

**៧៦៥.** សាក្សីម្នាក់ទៀតបានរៀបរាប់ថា គាត់ត្រូវបានហៅឲ្យទៅប្រជុំនៅឆ្នាំ១៩៧៧ នៅភូមិបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម តំបន់៤១ ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)។ គាត់បានរៀបរាប់អំពីរបៀបវារៈនៃកិច្ចប្រជុំគឺដើម្បីរៀបចំផែនការដែលគេហៅថា "ផែនការកម្ទេចខ្មាំង" ដោយប្រធានអង្គប្រជុំប្រកាសថា *"ខ្មាំងរបស់បដិវត្តន៍មានច្រើន ប៉ុន្តែខ្មាំងដែលធំជាងគេរបស់យើងគឺ ចាម។ ដូច្នេះ ផែនការនេះអំពាវនាវឲ្យមានការកម្ទេចជនជាតិចាមឲ្យអស់មុនឆ្នាំ១៩៨០"*[3280]។ សាក្សីដដែលនេះក៏បានរៀបរាប់បន្ថែមទៀតថា ក្រោយមក គាត់ត្រូវបានចាត់ឲ្យទៅជួបលេខាឃុំអូរនុង ស្រុកចំការលើ។ ខណៈដែលគាត់កំពុងរង់ចាំការមកដល់របស់ប្រធានអង្គប្រជុំ គាត់បានឃើញសៀវភៅមួយដែលមានក្របពណ៌លឿងថ្លាមានចំណងជើងថា "ផែនការសម្រាប់សហករណ៍ជឿនលឿន" ដែលក្នុងនោះមានសរសេរថា *"ចាមគឺជាខ្មាំងធំជាងគេ ហើយត្រូវកម្ទេចឲ្យអស់មុនឆ្នាំ១៩៨០"*[3281]។

**៧៦៦.** សាក្សីម្នាក់ទៀតបានបង្ហាញថា នៅក្នុងឆ្នាំ១៩៧៧ កម្មាភិបាលសន្តិសុខមកពីតំបន់២១ នៃភូមិភាគបូព៌ា បានប្រាប់គាត់ថា *"ទៅថ្ងៃមុខពួកចាមដែលនៅសេសសល់នឹងត្រូវសម្លាប់ទាំងអស់"*[3282]។ សាក្សីផ្សេងទៀតបានសង្កេតឃើញថាមានការ *"ចាត់ការប្រឆាំង នឹងអ្នកណាដែលមិនមែនជាខ្មែរ ជាពិសេសជនជាតិចាម [...]"*[3283] ឬមានបញ្ជា *"ប្រមែប្រមូលអ្នកកាន់ជំនឿអ៊ីស្លាមទាំងអស់មកជួបជុំគ្នា"*[3284]។ សាក្សីម្នាក់ទៀតបានបញ្ជាក់ថា ថ្ងៃមួយនៅពេលដែលគាត់ភ្ញាក់ពីដេកស្រាប់តែ *"បាត់អស់រលីងជនជាតិចាមនៅក្នុងភូមិរបស់ខ្ញុំ"*។ ក្នុងចំណោមជនជាតិចាមចំនួនដប់គ្រួសារនៅក្នុងភូមិរបស់គាត់ មានតែម្នាក់ប៉ុណ្ណោះ ដែលនៅរស់ ដោយសារពេលសម្លាប់ គាត់ធ្វើការនៅក្រៅភូមិនៅក្នុងកងចល័តស្រុក[3285]។

**៧៦៧.** [លុប] អតីតលេខាស្រុកក្រូចឆ្មារ ចាប់ពីឆ្នាំ១៩៧៨ (ដែលតាមរយៈឋានៈនេះ គាត់ត្រូវបានចាត់ទុកថាជាបុគ្គលម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវចំពោះការសម្លាប់រង្គាលលើប្រជាជនចាមនៅស្រុកក្រូចឆ្មារ[3286]) បានពន្យល់ថាមានការបះបោរដោយជនជាតិចាមនិងខ្មែរនៅស្រុកក្រូចឆ្មារ នៅឆ្នាំ១៩៧៨។ គណៈឃុំបានរាយការណ៍ទៅគណៈស្រុកអំពីការបះបោរនេះ ហើយគណៈស្រុករាយការណ៍បន្តទៅគណៈតំបន់។ រួចគណៈតំបន់បានបញ្ជាឲ្យចាប់និងឃុំខ្លួន *"ពួក*

*បះបោរ*"។ [លប់] បានបន្ថែមទៀតថា បន្ទាប់មកថ្នាក់លើបានសរសេរចំណារមួយមកថ្នាក់ស្រុកដោយចារប៊ិចក្រហមថា ៖ *"អ្នកដែលបះបោរទាំងអស់ ត្រូវកម្ទេចចោលទាំងអស់"*[3287]។ សាក្សីបានបន្ថែមទៀតថា គាត់បានធ្វើដំណើរតាមកាណូតទៅកាន់កន្លែងឃុំឃាំងអ្នកបះបោរ រួចដាក់បញ្ជាពីថ្នាក់លើទៅឱ្យមេបញ្ជាការកងទ័ពដែលមើលការខុសត្រូវនៅទីនោះ ហើយថាអ្នកបះបោរត្រូវបានវាយសម្លាប់នឹងដំបង ហើយកប់នៅក្នុងរណ្តៅរួម ដែលរណ្តៅនីមួយៗកប់មនុស្សប្រហែលពីម្ភៃ ទៅសាមសិបនាក់[3288]។

**៧៦៨.** សាក្សីម្នាក់បានបញ្ជាក់ថា៖ *"ក្រុមនេះ(ខ្មែរក្រហមដែលមកពីភូមិភាគនិរតី) បានស្រាវជ្រាវយកតែជនជាតិចាម ដើម្បីសម្លាប់ចោលគ្មានទុកឱ្យសល់ម្នាក់។ សមាជិកគ្រួសារខ្ញុំដែលមានគ្នា៨នាក់ត្រូវបានយកទៅសម្លាប់ទាំងអស់ លើកលែងតែខ្ញុំម្នាក់បានរួចខ្លួន ដោយសារតែខ្ញុំបន្លំខ្លួនធ្វើជាជនជាតិដទៃ"*[3289]។ សាក្សីម្នាក់ទៀតបានឱ្យដឹងអំពីស្ថានភាពគ្រួសារចាមប្រហែល១០០គ្រួសារនៅក្នុងឃុំដែលគាត់ធ្លាប់រស់នៅថា *"ខ្ញុំមិនបានឃើញការសម្លាប់ទេ គ្រាន់តែឃើញខ្មែរក្រហមចូលមកហៅមួយគ្រួសារម្តងៗចេញទៅ ហើយប្រជាជនចាមកាន់តែតិចទៅៗ ក្រោយមកគេប្រមូលទាំងអស់។ គេចាប់ប្រជាជនចាមនៅឆ្នាំ១៩៧៨"*[3290]។

**៧៦៩.** សាក្សីម្នាក់ទៀតបានអះអាងថា គាត់មានការភ្ញាក់ផ្អើលដោយនៅចុងឆ្នាំ១៩៧៨ មានការប្រជុំមួយដែលធ្វើឡើងនៅស្រុកសណ្តាន់ ខេត្តកំពង់ធំ រវាង កែ ពក និង លេខាស្រុកនៃភូមិភាគបូព៌ា និងភូមិភាគកណ្តាល មួយចំនួនចូលរួម។ សាក្សីដដែលនេះបានបញ្ជាក់ថា គាត់បានឮខ្លឹមសារដែលបាននិយាយនៅក្នុងអង្គប្រជុំនោះដោយសារតែពួកគេបានប្រើឧឃោសនៈស័ព្ទនៅខាងក្នុង។ ក្នុងកំឡុងពេលនៃការប្រជុំ នោះគឺ កែ ពក បានសួរទៅលេខាស្រុកក្រូចឆ្មារថា *"គម្រោងដែលបានដាក់ជូនដោយបក្ស តើបានបញ្ចប់ ប៉ុន្មានភាគរយហើយ? ...សមមិត្តត្រូវតែកម្ទេចពួកចាមដែលស្ថិតក្នុងកងចល័តមុន ព្រោះពួកគេទាំង នោះសុទ្ធតែជាជនក្បត់ជាតិ"*[3291]។

**៧៧០.** [លប់] បានអះអាងថា ជនជាតិចាមត្រូវបានចាត់ទុកជាមុខសញ្ញានៃការសម្លាប់រង្គាលនៅឆ្នាំ១៩៧៨ ប៉ុន្តែ បានបដិសេធថាកម្មាភិបាលភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) មានពាក់ព័ន្ធទៅនឹងការសម្លាប់នោះទេ[3292]។ ការអះអាងរបស់សាក្សីនេះមានលក្ខណៈខុសគ្នាពីសាក្សីផ្សេងទៀត ដែលបានកត់សម្គាល់ឃើញថាកម្មាភិបាលភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់រង្គាលជនជាតិចាម នៅស្រុកក្រូច

ឆ្នារ[3293]។

## មន្ទីរសន្តិសុខ ស្រុកក្រូចឆ្មារ ភូមិភាគបូព៌ា

៧៧១. មន្ទីរសន្តិសុខក្រូចឆ្មារ គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុក[3294]។ មន្ទីរនេះមានទីតាំងនៅជិតភូមិព្រែកតាដួង ក្នុងឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម[3295]។ យោងទៅលើប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ រដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរឃុំឃាំងនេះស្ថិតនៅក្នុងតំបន់២១ នៃភូមិភាគបូព៌ា។ មន្ទីសន្តិសុខក្រូចឆ្មារមានទំហំបណ្តោយប្រមាណ ១៥ម៉ែត្រ និងទទឹង ១០ម៉ែត្រ[3296] កម្ពស់ពីរជាន់[3297] និងព័ទ្ធជុំវិញដោយរបងលួស[3298]។ មន្ទីរនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ ១៩៧០ ឬឆ្នាំ១៩៧១[3299] ហើយដំណើរការយ៉ាងហោចណាស់រហូតដល់ឆ្នាំ១៩៧៨[3300]។

៧៧២. យោងតាមសាក្សីដែលជាអ្នកធ្លាប់ធ្វើការនៅក្នុងមន្ទីរសន្តិសុខនេះមានការអះអាងខុសៗគ្នា[3301]។ [លុប] [លុប] ប្រធានសន្តិសុខតំបន់២១ បានទៅត្រួតពិនិត្យមន្ទីរសន្តិសុខនៅស្រុកក្រូចឆ្មារយ៉ាងទៀតទាត់ *"រៀងរាល់មួយខែ ឬពីរខែ"*[3302]។ ប្រព័ន្ធរាយការណ៍ត្រូវបានធ្វើជាទៀងទាត់ពីមន្ទីរសន្តិសុខក្រូចឆ្មារទៅកាន់ថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា។ សាក្សីម្នាក់ដែលជាអតីតប្រធានក្រុមសួរចម្លើយនៅក្រូចឆ្មារបានអះអាងថា *"ចម្លើយសារភាពទាំងនេះ ត្រូវបញ្ជូនទៅឲ្យប្រធានសន្តិសុខ ហើយប្រធានសន្តិសុខបញ្ជូនបន្តទៅឲ្យគណៈស្រុក និងជាបន្តបន្ទាប់ដល់ថ្នាក់តំបន់ និងភូមិភាគ"*[3303]។ ប្រព័ន្ធទំនាក់ទំនងក៏មានធ្វើរវាងថ្នាក់ភូមិភាគនិងមន្ទីរឃុំឃាំងផងដែរ។ នៅពេលដែលចម្លើយសារភាពមួយត្រូវបញ្ជូនទៅថ្នាក់លើរហូតដល់ភូមិភាគ អ្នកទោសដែលបានសួរចម្លើយរួចត្រូវឃុំខ្លួនរហូតដល់មាន *"សេចក្តីសម្រេច"*[3304]។ អ្នកទោសមួយចំនួនត្រូវដោះលែង និងខ្លះទៀតត្រូវសម្លាប់[3305]។ ការអនុវត្តន៍របៀបនេះគឺធ្វើតាមសេចក្តីសម្រេចនាខែមីនា ឆ្នាំ១៩៧៦ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលបានផ្តល់អំណាចឲ្យភូមិភាគកម្ទេចខ្មាំង[3306]។

៧៧៣. ការប៉ាន់ប្រមាណចំនួនអ្នកទោសនៅមន្ទីរសន្តិសុខក្រូចឆ្មារមានចំនួន ៣០ ឬ ៤០នាក់[3307] ពេលខ្លះ ១២០នាក់[3308] ឬរាប់រយនាក់[3309] តាមពេលវេលាខុសៗគ្នា។ អ្នកទោសភាគច្រើនដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស្រុកក្រូចឆ្មារ គឺជាជនជាតិចាមមកពីភូមិផ្សេងៗដែលនៅជុំវិញនោះ[3310] ដែលរួមមានទាំងស្ត្រី និង កុមារ[3311]។ ការចាប់ និងការឃុំខ្លួនជនជាតិចាមមានការកើនឡើង បន្ទាប់ពីមានការបះបោរនៅឆ្នាំ១៩៧៥[3312]។ អ្នកដែលត្រូវចាប់ខ្លួនត្រូវបានចាត់ទុកថា មានទំនាក់ទំនង

ជាមួយអ្នកដឹកនាំចលនាបះបោរ[3313]។ ការចាប់ខ្លួនជនជាតិចាម ជាញឹកញាប់មានធ្វើនៅថ្ងៃសុក្រ គឺពេលដែលប្រុសៗទៅថ្វាយបង្គំនៅវិហារចាម[3314]។

៧៧៤. ទាំងអតីតអ្នកជាប់ឃុំឃាំង និងអ្នកសួរចម្លើយបានផ្ដល់ភស្តុតាងអំពីវិធីសាស្ត្រក្នុងការសួរចម្លើយ ដែលត្រូវបានប្រើប្រាស់នៅក្នុងមន្ទីរសន្តិសុខក្រូចឆ្មារ។ រាល់ការសួរចម្លើយ មានកម្មាភិបាលចំនួន បីនាក់ចូលរួម៖ *"ប្រធានជាអ្នកសួរសំណួរទូទៅ អនុប្រធានសម្រាប់ជំនួយការ និងសមាជិកជាអ្នក កត់ត្រា"*[3315]។ បន្ទាប់ពីការសួរចម្លើយច្រើនដង ចម្លើយសារភាពស្ពាពរ នឹងត្រូវសរសេរ ហើយ រាយការណ៍ទៅថ្នាក់លើ[3316]។ អ្នកទោសត្រូវបានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅអំឡុងពេល សួរចម្លើយ ដូចជា៖ ការវាយដំ ការដកក្រចកដៃ និងក្រចកជើង ឬការដកធ្មេញរបូតទាំងឫស[3317]។ ដំបូងឡើយការសួរចម្លើយអ្នកទោសធ្វើនៅខាងក្រោយអាគារ ហើយសួរចម្លើយនៅទីលំហ[3318]។ ក្រោយមក អ្នកសួរចម្លើយទទួលបញ្ជាពីថ្នាក់លើឱ្យជីករណ្ដៅជម្រៅប្រមាណជាពីរម៉ែត្រ ដើម្បីយក អ្នកទោសចុះទៅសួរក្នុងរណ្ដៅនោះ[3319]។

៧៧៥. សាក្សីម្នាក់ដែលបានរស់នៅក្បែរមន្ទីរសន្តិសុខបានឃើញការសម្លាប់ផ្ទាល់។ គាត់បាននិយាយថាអ្នក ទោសត្រូវបានចងមុខ និងឱ្យអង្គុយក្បែរមាត់រណ្ដៅ រួចហើយវាយនឹងត្បូងចបពីក្រោយ [3320]។ បន្ទាប់ពីកន្លែងសួរចម្លើយត្រូវប្ដូរទៅសួរនៅតាមរណ្ដៅ សាក្សីនោះលែងបានឃើញការសម្លាប់ ទៀតហើយ ប៉ុន្តែជាញឹកញាប់គាត់បានឃើញកម្មាភិបាល ប.ក.ក សែងសាកសពអ្នកទោស ដាក់តាមរណ្ដៅ រួចកប់នៅក្នុងព្រៃឫស្សីតាមបណ្ដោយព្រែកតាដួង[3321]។ ក្រោយឆ្នាំ១៩៧៩ សាក្សីរូបនោះបានឃើញមានរណ្ដៅសពរួមចំនួន១០នៅទីនោះ[3322]។ សាក្សីម្នាក់ទៀតបានអះអាងថា គាត់ដឹងថា មានសាកសពជាច្រើនត្រូវបានកប់នៅឯព្រែកតាដួង[3323]។

**មន្ទីរសន្តិសុខវត្តអូរត្រកួន ភូមិភាគកណ្ដាល (ភូមិភាគឧត្តរចាស់)**

៧៧៦. មន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្សវត្តអូរត្រកួន គឺស្ថិតនៅភូមិសំបួរមាស ឃុំពាមជីកង ស្រុក កងមាស ខេត្តកំពង់ចាម[3324]។ យោងទៅតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់ បក្សកុម្មុយនីស្តកម្ពុជា មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងតំបន់៤១ នៃភូមិភាគកណ្ដាល (ភូមិភាគឧត្តរ ចាស់)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605503



**៧៧៧.** បរិវេណវត្តនេះមានទំហំប្រហែល ១៧០ម៉ែត្រ គុណនឹង ២០០ម៉ែត្រ ព័ទ្ធដោយរបងឬស្សីបន្លាខ្ពស់ៗ។ ដីមួយកន្លែងទំហំ៣ហិកតា ដែលជាប់បរិវេណខាងកើតវត្តត្រូវបានប្រើប្រាស់ជាកន្លែងសម្លាប់មនុស្សនិងកប់សាកសពអ្នកទោសរបស់មន្ទីរសន្តិសុខនេះ[3325]។ មន្ទីរសន្តិសុខនេះទំនងជាត្រូវបានបង្កើតនៅឆ្នាំ១៩៧៥[3326] ឬឆ្នាំ១៩៧៦[3327] និងយ៉ាងហោចណាស់ដំណើរការរហូតដល់ឆ្នាំ១៩៧៧។

**៧៧៨.** ប្រធានមន្ទីរសន្តិសុខអូរត្រកួនឈ្មោះ [លុប][3328] និង [លុប]ដែល[លុប] ជាសមាជិកគណៈស្រុកកងមាសផងដែរ[3329]។ មានសាក្សីផ្សេងៗទៀតបានកំណត់អត្តសញ្ញាណ [លប់] ថាជាសមាជិកម្នាក់នៃថ្នាក់ដឹកនាំមន្ទីរសន្តិសុខ[3330]។ [លុប] ដែលជាលេខាស្រុក ព្រមទាំងប្រពន្ធគាត់ឈ្មោះ [លុប]ដែលជាអនុលេខាស្រុកដែរនោះ មានការជាប់ពាក់ព័ន្ធការងារនឹងមន្ទីរសន្តិសុខនេះ[3331]។

**៧៧៩.** អ្នកជាប់ឃុំឃាំងមានដូចជាប្រជាជនថ្មី ប្រជាជនមូលដ្ឋាន និងជនជាតិចាម[3332]។ ក្នុងអំឡុងឆ្នាំ១៩៧៧ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានចាប់ខ្លួនប្រជាជនចាមទាំងអស់នៅទូទាំងស្រុកកងមាស ហើយយកអ្នកទាំងនោះទៅវត្តអូរត្រកួន ដែលការចាប់នេះធ្វើឡើងដោយក្រុមឈ្លបដាវវែង។ មានសាក្សីម្នាក់ដែលបានចូលរួមក្នុងសកម្មភាពរបស់ក្រុមឈ្លបដាវវែង (ក្រុមឈ្លបមួយនេះ រៀបចំឡើងដោយកម្មាភិបាលមកពីភូមិភាគនិរតី[3333]) ដែលជាការចាប់ពួកចាមទាំងអស់នៅក្នុងភូមិសំបួរមាស (ក) ភូមិសំបួរមាស (ខ) និងភូមិសាច់ស្វ នៅក្នុងស្រុកកងមាស[3334]។ សាក្សីដដែលនេះបានបញ្ជាក់ថា គាត់ជាមួយនឹងមនុស្សបីនាក់ផ្សេងទៀតជាអ្នកបានជួយក្រុមឈ្លបនោះ ក្នុងការចាប់ប្រជាជនចាមទាំងបុរស ស្ត្រី និងកុមារចំនួនប្រហែល ៣០០នាក់។ បន្ទាប់ពីការចាប់ហើយ ក្រុមឈ្លបបានឱ្យគាត់ (សាក្សី) និងគ្នារបស់គាត់បណ្តើរអ្នកទោសទៅមន្ទីរសន្តិសុខអូរត្រកួន ដែលជាទីកន្លែងដែលចាមទាំងអស់ត្រូវបានសម្លាប់[3335]។ សាក្សីរូបនេះបានបញ្ជាក់ថែមទៀតថា ការចាប់ និងសម្លាប់ចាមទាំងអស់គឺធ្វើឡើងតាមបញ្ជារបស់លេខាស្រុក[3336]។

**៧៨០.** ហេតុការណ៍នេះ ត្រូវបានបញ្ជាក់ដោយសាក្សីពីរនាក់ទៀត ដែលអះអាងថានៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ចាមទាំងអស់នៅភូមិសាច់ស្វ ស្រុកកងមាស ត្រូវបានចាប់ខ្លួន និងនាំយកទៅវត្តអូរត្រកួន[3337]។ សាក្សីទាំងនេះមិនបានឃើញការសម្លាប់ណាមួយទេ[3338] ប៉ុន្តែសាក្សីម្នាក់បានឮកងឈ្លបម្នាក់ដែលចេញពីវត្តនិយាយថាចាមទាំងអស់ត្រូវបានសម្លាប់[3339]។ សាក្សីមួយរូបទៀតបញ្ជាក់ថាមានប្រជាជនចាមពី២០ ទៅ ៣០នាក់ មកពីភូមិសាច់ស្វ នៅក្នុងកងចល័តរបស់គាត់ ប៉ុន្តែនៅ

00605504



ដើមឆ្នាំ១៩៧៧ ពួកគេត្រូវបានចាប់ខ្លួនទាំងអស់ដោយកម្មាភិបាលសន្តិសុខស្រុកអូរត្រកួន ហើយថា គ្មាននរណាម្នាក់នៅរស់ឡើយ[3340]។

៧៨១. សាក្សីម្នាក់ទៀតដែលធ្លាប់ធ្វើជាសមាជិកក្រុមឈ្លបដាវវែង បានឃើញគេចងដៃអ្នកទោសទៅក្រោយ បណ្ដើរទាំងខ្សែៗចេញពីភូមិសំបួរមាស (ក)[3341]។ សាក្សីដដែលនេះបានបន្ថែមថា រាល់ជនជាតិចាមក្នុងភូមិនេះត្រូវបានគេកំណត់ជាមុខសញ្ញា និងត្រូវបានចាប់ខ្លួន[3342]។ ហេតុការណ៍នេះក៏ត្រូវបានបញ្ជាក់ផងដែរដោយសាក្សីម្នាក់ទៀតថា រាល់ជនជាតិចាមនៅភូមិសំបួរមាស ត្រូវបានចាប់ខ្លួន ហើយត្រូវបាននាំទៅវត្តអូរត្រកួន និងសម្លាប់[3343]។

៧៨២. សាក្សីម្នាក់ផ្សេងទៀត បានពាក់ព័ន្ធដោយផ្ទាល់ក្នុងការដឹកជញ្ជូនមនុស្សជាងមួយពាន់នាក់តាមទូកទៅវត្តអូរត្រកួន។ សាក្សីរូបនេះបានអះអាងថាមនុស្សទាំងនោះដែលរួមមានយុវជនប្រមាណ ៦០០នាក់ និងយុវនារីប្រមាណ៤០០នាក់ ដែលមកពីកងចល័តត្រូវបានគេចង រួចនាំទៅកំពង់ផែដែលមានចម្ងាយប្រហែល៥០០ម៉ែត្រពីវត្តអូរត្រកួន ហើយបន្ទាប់មកអ្នកទាំងនោះត្រូវបានបណ្ដើរទាំងក្រុមៗយកទៅសម្លាប់នៅកន្លែងនោះ[3344]។ នៅពេលដែលសាក្សីត្រូវបានសួរថា តើមនុស្សទាំងអស់នោះមានចាមដែរឬទេ គាត់បានឆ្លើយថា *"ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមើលមិនដឹងថា ជាចាម ឬខ្មែរទេ ពីព្រោះគ្មានអ្វីសម្គាល់"* ទោះបីជាសាក្សីខ្លួនឯងក៏ជាជនជាតិចាមក៏ដោយ[3345]។ នៅពេលដែលគេសួរថា តើអ្នកទោសដែលគេយកទៅសម្លាប់នៅអូរត្រកួន យកមកពីកន្លែងណា សាក្សីបានឆ្លើយថា នៅក្នុងភូមិរបស់គាត់ គ្រួសារចាមស្លាប់ទាំងអស់[3346]។

៧៨៣. នៅពេលចាប់ខ្លួន ជនជាតិចាមទំនងជាមិនត្រូវបានយកទៅដាក់ឃុំទេ គឺសម្លាប់ភ្លាមៗតែម្ដង[3347]។ សាក្សីដដែលនេះរៀបរាប់ថា នៅក្នុងវត្តអូរត្រកួនមិនមានគុកសម្រាប់ដាក់អ្នកទោសទេ ពេលយកអ្នកទោសមកដល់ *"គេសម្លាប់ចោលនៅពេលយប់នោះទាំងអស់"*[3348]។ សាក្សីផ្សេងៗទៀតថា ការសម្លាប់ត្រូវបានធ្វើនៅពេលយប់[3349] ហើយគេចាក់មេក្រូបំពងសំឡេងអំពីចំរៀងបដិវត្តន៍ខណៈដែលមានការសម្លាប់មនុស្ស[3350]។ សាក្សីបានឮសំឡេងវាយមនុស្សនឹងដំបង[3351] និងសម្រែកចេញមកពីកន្លែងនោះ[3352]។ នៅឆ្នាំ១៩៧៩ មានសាក្សីបានឃើញសាកសពជាច្រើន[3353] និងរណ្ដៅសពរួមជាច្រើនផងដែរ[3354] នៅទីនោះ។ សាក្សីម្នាក់ដែលបានឃើញរណ្ដៅសពរួមនៅឆ្នាំ១៩៧៩ បានប៉ាន់ប្រមាណថា មានមនុស្សប្រហែល១០.០០០នាក់ ត្រូវបានសម្លាប់នៅទីនោះ[3355]។ សាក្សីម្នាក់ទៀតបានអះអាងថា ធ្លាប់បានឃើញបញ្ជីឈ្មោះអ្នកទោសនៅវត្តអូរត្រកួន និងប៉ាន់

ប្រមាណថា មនុស្សចំនួនប្រហែល ៣០.០០០ នាក់ត្រូវបានសម្លាប់នៅទីនោះ[3356]។

**មន្ទីរសន្តិសុខភូមិទ្រា ស្រុកក្រូចឆ្មារ ភូមិភាគបូព៌ា**

៧៨៤. មន្ទីរសន្តិសុខភូមិទ្រាមានទីតាំងនៅភូមិទ្រា ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងដោយយោងទៅតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរនេះស្ថិតនៅក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា។ ផ្ទះឈើមួយត្រូវបានប្រើជាមន្ទីរឃុំឃាំង និងសម្លាប់អ្នកទោស ហើយកប់សាកសពនៅវាលមួយខាងលិចមន្ទីរសន្តិសុខដែលស្ថិតនៅជាប់នឹងទន្លេមេគង្គ[3357]។

៧៨៥. នៅពាក់កណ្ដាលឆ្នាំ១៩៧៨ ជនជាតិចាមជាច្រើនត្រូវបានប្រមូលពីភូមិនានាក្នុងក្រូចឆ្មារ និងពីកងចល័តផ្សេងៗ បញ្ជូនទៅមន្ទីរសន្តិសុខភូមិទ្រា[3358]។ នៅឯមន្ទីរសន្តិសុខ នាពេលនោះមនុស្សម្នាក់ៗត្រូវបានសួរដើម្បីកំណត់អត្តសញ្ញាណជាចាម ឬក៏ខ្មែរ ឬជា "កូនកាត់"[3359]។ សាក្សីម្នាក់ជាជនជាតិចាម ដែលត្រូវបានចាប់ខ្លួននៅខែកក្កដាឆ្នាំ១៩៧៨[3360] បានរៀបរាប់ពីហេតុការណ៍នោះថា៖ *"បន្ទាប់ពីនោះមក កម្មាភិបាលម្នាក់បានស្រែកបញ្ជាយ៉ាងខ្លាំងថា 'អ្នកណាកូនចាមនៅម្ខាង ខ្មែរនៅម្ខាង ហើយបើកូនកាត់នៅម្ខាង'។ ខ្ញុំនឹងឃើញថា មុននោះបន្តិចខ្ញុំបានឆ្លើយកុហករួចហើយថា ខ្ញុំជាជនជាតិខ្មែរ ដូច្នេះខ្ញុំត្រូវតែទៅខាងខ្មែរ។ មានអ្នកផ្សេងទៀតចំនួន ១៥នាក់ ដែលបានឆ្លើយដូចខ្ញុំដែរ ហើយត្រូវនៅក្រុមជាមួយខ្ញុំ។ ក្រៅពីនេះ មាននារីចំនួន20នាក់ត្រូវបានបំបែកគ្នា ជាពីរក្រុមផ្សេងទៀត គឺក្រុមអ្នកឆ្លើយថាជនជាតិចាម និងមួយក្រុមទៀតដែលឆ្លើយថាកូនកាត់។ ជីដូនមួយរបស់ខ្ញុំម្នាក់ឈ្មោះតីជៅ នៅក្នុងក្រុមកូនកាត់នេះ។ តាមការពិតមនុស្សទាំង៣៦នាក់នេះធ្លាប់ជាមិត្តភក្តិនឹងគ្នាជាជនជាតិចាម ដែលកើតចេញពីម្ដាយឪពុកជាជនជាតិចាមសុទ្ធសាធ។ ប៉ុន្តែការឆ្លើយកុហកដូច្នេះ គឺដើម្បីជាលេសយករួចខ្លួន។ ៤ ឬ ៥ នាទីក្រោយមក ក្រុមអ្នកឆ្លើយថា "ជនជាតិចាម" និង "កូនកាត់" ត្រូវបាននាំចុះពីលើផ្ទះម្ដងម្នាក់។ ខ្មែរក្រហមប្រាប់ថាយកទៅឱ្យហូបបាយ។ ខ្ញុំចេះតែលួចសម្លឹងមើលមិនដាក់ភ្នែកតាមប្រឡោះជញ្ជាំងផ្ទះដើម្បីចង់ដឹងថាខ្មែរក្រហមយកទៅកន្លែងណាមួយ។ ថ្វីត្បិតពេលនោះថ្ងៃលិចបាត់ទៅហើយ ប៉ុន្តែខ្ញុំអាចមើលឃើញដោយសារមានពន្លឺលោកខែ។ ខ្ញុំមើលឃើញកម្មាភិបាលម្នាក់បណ្ដើរនារីម្នាក់សំដៅទៅឯរណ្ដៅមួយដែលស្ថិតនៅចម្ងាយពីផ្ទះប្រហែល៨ម៉ែត្រប៉ុណ្ណោះ។ នៅពីលើមាត់រណ្ដៅ មានបន្ទះក្ដារមួយដាក់កាត់ទទឹង។កម្មាភិបាលនោះចាប់ទាញនារីឱ្យដេកផ្កាប់មុខ គងថ្ពាសលើបន្ទះក្ដារ រួចក៏ទាញកាំបិតស្នាចអារកញ្ចឹងកពីក្រោយ ហើយទម្លាក់សាកសពទៅក្នុងរណ្ដៅ។ រណ្ដៅនោះមិនជាជ្រៅប៉ុន្មានទេ ព្រោះខ្ញុំអាចមើលឃើញដៃជើងរបស់គាត់កំពុងបម្រះចុះឡើងៗ។បន្ទាប់មក កម្មាភិបាល*

*នោះក៏យកនារីម្នាក់ផ្សេងទៀតមកសម្លាប់តាមវិធីតែមួយ។ ការសម្លាប់គឺត្រូវបន្តវេនគ្នាតាមលេខរៀង"*[3361]។ សាក្សីនេះបានបន្ថែមទៀតថា នារីខ្លះប្រហែលជាត្រូវបានរំលោភមុននឹងយកទៅសម្លាប់ ពីព្រោះសាក្សីរូបនេះបានឮសំឡេងនារីខ្លះស្រែកថា *"កុំរំលោភខ្ញុំ"*[3362]។

**៧៨៦.** អង្គហេតុនេះ ក៏បានបញ្ជាក់ដោយសាក្សីផ្សេងទៀត ដែលត្រូវបានយកទៅដាក់មន្ទីរសន្តិសុខនោះដូចគ្នានៅឆ្នាំ១៩៧៨។ ក្នុងនោះមានសាក្សីម្នាក់បញ្ជាក់ពីរឿងហេតុកើតឡើងនោះថា៖ *"[លុប] បានហៅយើងសួរម្តងម្នាក់ៗថា "ជនជាតិអ្វី?" អ្នកដែលឆ្លើយមុនគេបានឆ្លើយតាមត្រង់ថា "ជនជាតិចាម"។ ហើយអ្នកបន្តបន្ទាប់មកទៀតក៏ឆ្លើយតាមក្រោយថា "ចាម"ដូចៗគ្នា។ ជិតអស់មនុស្សទៅហើយក៏ធ្លាក់មកដល់វេនខ្ញុំ។ ខ្ញុំឆ្លើយកុហកទាំងប្រថុយប្រថានថាខ្ញុំជា"ខ្មែរ"។ រួចហើយ [លុប] បានរុញខ្ញុំទៅកៀនជញ្ជាំងម្ខាង។ ឃើញដូច្នោះ អ្នកបន្ទាប់ខ្ញុំប្រហែល ១០នាក់ទៀត ក៏ឆ្លើយថា "ខ្មែរ" ហើយត្រូវបានយកមកដាក់ឱ្យនៅជាមួយខ្ញុំ"*។ សាក្សីនេះបានបន្ថែមទៀតថា អ្នកដែលបានឆ្លើយថា "ចាម" ត្រូវបានគេនាំខ្លួនយកទៅដោយកងឈ្លបដែលប្រដាប់ដោយអាវុធអាកា៤៧ និងកាំបិតកកុកមួយ [3363]។

**៧៨៧.** សាក្សីមួយផ្សេងទៀតដែលត្រូវបានបញ្ជូនទៅភូមិទ្រាជាមួយនឹងគ្រួសារគាត់បានបញ្ជាក់ថា កម្មាភិបាលប.ក.ក ត្រូវការដឹងថា នរណាជាចាម និងនរណាជាខ្មែរ។ *"អ្នកខ្លះលើកដៃ ព្រោះចង់ក្លែងខ្លួនជាខ្មែរក្រែងត្រូវបានលើកលែង ប៉ុន្តែអ្នកដែលលើកដៃទាំងនោះ ត្រូវបានខ្មែរក្រហមវ៉ៃសំពងនឹងស្វាយកាំភ្លើង លុះគ្រាអ្នកទាំងនោះទ្រាំមិនបាន ក៏ឆ្លើយប្រាប់តាមត្រង់វិញថាខ្លួនជាចាម។ ខ្ញុំយល់ថា នោះគ្រាន់តែជាការដេកពិសោធន៍ប៉ុណ្ណោះ ពីព្រោះខ្មែរក្រហមបានស្គាល់ពួកយើងជាជនជាតិចាមតាំងពីដំបូងទីមកម្ល៉េះ"*[3364]។ សាក្សីនេះបានបន្ថែមថា នៅក្បែរមន្ទីរសន្តិសុខ សាក្សីបានមើលឃើញពួកប្រុសៗចាមត្រូវបានកម្មាភិបាល ប.ក.ក អូសទម្លាក់ទៅក្នុងទឹកទន្លេ[3365]។ ក្រុមបុរសចាមចំនួនប្រហែល៣០នាក់ ត្រូវបានចងជាខ្សែជាប់ទៅនឹងកាណូត រួចហើយកាណូតទាញអូសទម្លាក់ទៅក្នុងទន្លេ និងថា *"កាណូតមួយគ្រឿងនោះធ្វើសកម្មភាពនេះចុះឡើងៗពេញមួយថ្ងៃ"*[3366]។

**៧៨៨.** សាក្សីម្នាក់ដែលមានដើមកំណើតនៅភូមិទ្រា នៅពេលដែលសាក្សីរូបនោះត្រលប់មកភូមិទ្រាវិញមួយខែ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានរកឃើញរណ្តៅសពរួមជាច្រើននៅក្បែរៗមាត់ទន្លេ។ សាក្សីបញ្ជាក់ថា គាត់និងអ្នកភូមិជាច្រើនទៀតបានគាស់កាយរណ្តៅសពទាំងនោះ

ដើម្បីស្វែងរកវត្ថុមានតម្លៃ និងថាគាត់ឃើញ *"រណ្តៅចំនួនជាង២០រណ្តៅ។ រណ្តៅធំជាងគេមានទំហំប្រហែលបីម៉ែត្របួនជ្រុង ដែលក្នុងនោះមានសាកសពពី ២០ ទៅ ៣០ រណ្តៅតូចជាងនេះមានសាកសពចំនួនតិចជាង២០សាកសព"*[3367]។ សាក្សីម្នាក់ទៀតបាននិយាយថា *"គេបានឃើញសាកសពរាប់រយនៅក្នុងរណ្តៅទាំងនោះ"* ដែលត្រូវបានគេគាស់នៅឆ្នាំ១៩៧៩[3368]។

**៧៨៩.** សាក្សីពីរនាក់បានផ្តល់ភស្តុតាងថា ការចាប់ និងសម្លាប់នៅភូមិទ្រា គឺធ្វើតាមការបញ្ជារបស់លេខាស្រុកក្រូចឆ្មារ ឈ្មោះ [លប់][3369]។

***

**៧៩០.** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៦នាក់ (នាក់) ត្រូវបានប្រកាសទទួលស្គាល់ នៅក្នុងបរិបទនៃប្រព្រឹត្តកម្មលើជនជាតិភាគតិចចាម[3370]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើ គោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរអោយជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពី ផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃប្រព្រឹត្តកម្មលើជនជាតិភាគតិចចាម។

**ការប្រព្រឹត្តចំពោះប្រជាជនវៀតណាម**[3371]

**សេចក្តីផ្តើម**

**៧៩១.** វៀតណាមអាចត្រូវបានគេចាត់ទុកថាជាក្រុមជនជាតិភាគតិច[3372] ដោយសារពួកគេមានភាសា និងវប្បធម៌រួម ឬ ពីព្រោះពួកគេបានកំណត់អត្តសញ្ញាណ និង បានសម្គាល់ពួកគេថា ជាវៀតណាម ហើយ ត្រូវបានកំនត់អត្តសញ្ញាណ និងត្រូវបានសំគាល់ដោយអ្នកផ្សេងទៀតដូច្នេះដែរ[3373]។ បក្សកុម្មុយនីស្ត-កម្ពុជាក៏បានលើកឡើងថា វៀតណាមជាក្រុមជាតិមួយ[3374] នៅក្នុងសុន្ទរកថាជាសាធារណៈមួយចំនួន[3375]។ បន្ថែមពីនេះទៀតអ្នកទទួលខុសត្រូវនៃបក្សកុម្មុយនីស្តកម្ពុជា ក៏បានចាត់ទុកវៀតណាមថា ជាក្រុមពូជសាសន៍មួយ[3376] ដោយយោងទៅតាមជីវសាស្ត្រ និងជាពិសេសតាមដើមកំណើត "ខ្សែស្រឡាយខាងម្តាយ" ដោយចាត់ទុកពួកគេជាក្រុមមួយ ដោយយោងតាមការកំណត់សំគាល់តាមរយៈរូបសាស្ត្រជាមួយភូមិសាស្ត្រនៃប្រទេសវៀតណាម[3377]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

## និន្ន័យប្រជាសាស្ត្រ

៧៩២. យោងតាមរបាយការណ៍របស់អ្នកជំនាញប្រជាសាស្ត្រ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ បានធ្វើការសន្និដ្ឋានថាមានប្រហែល ៤០០.០០០ នៃប្រជាជនវៀតណាមដែលរស់នៅកម្ពុជាក្នុងឆ្នាំ១៩៧០។ ក្នុងចំណោម៤០០.០០០ នាក់ មានប្រជាជនប្រហែលពាក់កណ្ដាល ត្រូវបានគេបណ្ដេញឱ្យទៅប្រទេសវៀតណាមវិញ ឬត្រូវបានសម្លាប់ដោយរបប លន់ នល់ នៅក្នុងឆ្នាំដដែល ខណៈពេលដែលជនជាតិវៀតណាម១៥០.០០០ ទៅ២០០.០០០ នាក់ ផ្សេងទៀតបានចាកចេញពីកម្ពុជាបន្ទាប់ពីបក្សកុម្មុយនីសកម្ពុជាកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥។ អ្នកជំនាញការដែលសរសេររបាយការណ៍បានសន្និដ្ឋានថា មានជនជាតិវៀតណាមប្រហែលចំនួន ២០.០០០នាក់នៅបន្តរស់នៅលើទឹកដីប្រទេសកម្ពុជានៅឡើយនៅខែមេសា ឆ្នាំ១៩៧៥ ហើយថា *"ពួកគេស្ទើរតែទាំងអស់ត្រូវបានសម្លាប់ក្រោមដៃរបស់ខ្មែរក្រហមក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩"*[3378]។

៧៩៣. ទំនងដូចជាមានចំនួនប្រជាជនវៀតណាម ដែលនៅរស់រានមានជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានចំនួនតិចគួរឱ្យកត់សម្គាល់។ សាក្សីពីរនាក់បានផ្ដល់ភស្តុតាងថា ពួកគេបានដឹងថា មានប្រជាជនវៀតណាម ដែលរួចផុតពីការសម្លាប់ដោយបានលាក់ខ្លួន ឬបានបន្លំខ្លួនជាប្រជាជនខ្មែរ[3379]។ សាក្សីបីនាក់ផ្សេងទៀត បានរៀបរាប់ថា ពួកគេដឹងថាមានប្រជាជនវៀតណាមម្នាក់ ឬពីរនាក់មិនត្រូវបានគេសម្លាប់ ប៉ុន្តែ គាត់មិនបានដឹងអំពីមូលហេតុនោះទេ[3380]។ សាក្សីម្នាក់ដែលមានម្ដាយជាវៀតណាមបាននិយាយថា ទោះបីជាសមាជិកគ្រួសាររបស់គាត់ភាគច្រើន រួមទាំងម្ដាយគាត់ ត្រូវបានសម្លាប់គាត់ត្រូវបានគេទុកឱ្យនៅរស់ពីព្រោះ *"នៅភូមិខ្ញុំមិនសូវមានវៀតណាម ហើយ (...) ប្ដីខ្ញុំចេះកាត់ដេរជាពិសេសគឺម្ហូកប៉ារេ និង ខោអាវរបស់ខ្មែរក្រហម"* [3381]។

### ការផ្លាស់ទីលំនៅប្រជាជនស៊ីវិលវៀតណាមពីប្រទេសកម្ពុជា ទៅប្រទេសវៀតណាម

៧៩៤. ដើមឡើយបក្សកុម្មុយនីស្តកម្ពុជាបានផ្ដោតលើ ការបណ្ដេញចេញរាល់ប្រជាជនវៀតណាមពីទឹកដីកម្ពុជា។ គោលនយោបាយនេះ ចាប់ផ្ដើមអនុវត្តតាំងពីឆ្នាំ១៩៧៣[3382] ហើយត្រូវបានបន្តអនុវត្តនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦[3383]។ គោលនយោបាយនេះ ត្រូវបានអនុវត្តនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[3384] ព្រមទាំងនៅទូទាំងប្រទេសកម្ពុជា[3385]។ ប្រជាជនវៀតណាមត្រូវបានបញ្ជូនដោយ

ថ្មើរជើង ដោយរទេះភ្លើង និងដោយទូក[3386]។ ភស្តុតាងដែលមានក្នុងសំណុំរឿងបង្ហាញថា មានតែប្រជាជនវៀតណាមប៉ុណ្ណោះ ដែលត្រូវបានគេអនុញ្ញាតឱ្យត្រឡប់ទៅកាន់ប្រទេសវៀតណាម[3387] ហើយមានការពិសោធន៍សាកល្បងភាសាវៀតណាម ដើម្បីកំណត់អំពីសញ្ជាតិវៀតណាមរបស់ពួកគេ[3388]។ ទោះបីជាមានសាក្សីមួយចំនួនបាននិយាយថា ពួកគេត្រូវបានបង្ខំឱ្យទៅប្រទេសវៀតណាមវិញក៏ដោយ[3389] ក៏មានសាក្សីខ្លះទៀតបានលើកឡើងថា ប្រជាជនវៀតណាមអាចជ្រើសរើសយល់ព្រមទទួលយកការសំណើឱ្យត្រលប់ទៅកាន់ប្រទេសវៀតណាម[3390]។ ហើយសាក្សីផ្សេងទៀតសង្ស័យថា នេះជាអន្ទាក់ និងតាមការពិតប្រជាជនទាំងនោះត្រូវបានគេយកទៅសម្លាប់[3391]។ ដោយសារ បក្សកុម្មុយនីសកម្ពុជាមិនអនុញ្ញាតឱ្យបុគ្គលដែលមានសហព័ទ្ធ និងបុគ្គលដែលមានឪពុក ឬម្តាយរៀបការជាមួយវៀតណាម ត្រឡប់ទៅប្រទេសវៀតណាមវិញទេ ហេតុនេះហើយជនជាតិវៀតណាម ដែលស្ថិតក្នុងស្ថានភាពទាំងនេះបានជ្រើសរើសស្នាក់នៅប្រទេសកម្ពុជា[3392]។

**៧៩៥.** សាក្សីម្នាក់បានរៀបរាប់ថា របបកម្ពុជាប្រជាធិបតេយ្យ បានប្រមូលជនជាតិវៀតណាម ដាក់តាមកាណូតឱ្យទៅស្រុកវិញ ហើយចំពោះវៀតណាមដែលមិនបានចាកចេញ ត្រូវបានស្រាវជ្រាវនឹងយកទៅសម្លាប់[3393]។ សាក្សីផ្សេងទៀតបានរៀបរាប់ នូវអ្វីដែលបានកើតឡើងថា៖ *"ចំពោះប្រជាជនជនជាតិវៀតណាម ទោះជាអ្នកធ្លាប់តស៊ូធ្វើការក្នុងអង្គភាព ឬ [...]ជាប្រជាជនធម្មតាក៏ដោយ ក៏ត្រូវបញ្ជូនទៅវៀតណាម វិញ។ ក្រោយមកទៀតជនជាតិវៀតណាមណាដែលមិនព្រមទៅ ឬបានបន្លំខ្លួនថាជាខ្មែរ ត្រូវគេចាប់យកទៅសម្លាប់"*[3394]។

**៧៩៦.** ទស្សនាវដ្តីទង់បដិវត្តន៍នៅខែមេសា ឆ្នាំ១៩៧៦ ហាក់បីដូចជា បានលើកឡើងពីការបណ្តេញប្រជាជនវៀតណាមចេញពីទឹកដីកម្ពុជា។ ទស្សនាវដ្តីនេះបានលើកឡើងថា *"ជនបរទេសប្រភេទយ៉ាង មានសភាពពិសពុល គ្រោះថ្នាក់ដល់ប្រជាជនយើងខ្លាំងណាស់។ ជនទាំងនេះមានសភាព ហៅថាពិសពុល ដោយវាមកត្របាក់យើង មកប្របិចយើង មកលេបយើង មករឹបយកគ្រប់បែបគ្រប់យ៉ាងទាំងអស់ ធ្វើឱ្យប្រជាជាតិយើង និងប្រជាជនយើង ត្រូវគ្រោះថ្នាក់អន្តរាយក្នុងពេលកន្លងមកអស់ទឹកដីជាច្រើន។"* ទស្សនាវដ្តីក៏បានបន្តទៀតថា *"ប៉ុន្តែ បដិវត្តរបស់យើងហើយពិសេស ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ បានដោះស្រាយបញ្ហាយ៉ាងស្អាត ហើយដោះស្រាយទាំងមូល។ យើងសន្មតថា ដោះស្រាយបានជាស្ថាពរ។ រាប់ពាន់ឆ្នាំមកហើយ ដោះបញ្ហានេះមិនទាន់បាន ហើយក៏មិនដោះស្រាយទៀត។ វណ្ណៈជិះជាន់ វាមិនត្រឹមតែមិនដោះស្រាយទេ វាលក់ទឹកដីទាំងកំណាត់ៗឱ្យបរទេសនេះទៀត។ ឥឡូវ យើងដោះស្រាយបញ្ហានេះបាន។ កម្មករបដិវត្ត*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

*យើង កសិករបដិវត្តយើង ប្រជាជនយើង កងទ័ពបដិវត្តយើង បានដោះស្រាយបញ្ហានេះទាំងស្រុង និង ជាស្ថាពរ។ ទំហំនៃជ័យជំនះនេះធំធេងណាស់ ជ្រាលជ្រៅណាស់ អស្ចារ្យណាស់...។ គឺមហាចលនាប្រជាធិបតេយ្យ មហាអស្ចារ្យដែលបដិវត្តរបស់យើងបានបោសសំអាត ជនបរទេសទាំងនេះរាប់សែននាក់ ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ"*[3395]។

## ការសម្លាប់ប្រជាជនស៊ីវិលវៀតណាមនៅក្នុងខេត្តព្រៃវែង និង ខេត្តស្វាយរៀង

**៧៩៧.** សាក្សីជាច្រើនបានអះអាងថា មានការសម្លាប់រង្គាលលើប្រជាជនស៊ីវិលវៀតណាម ត្រូវបានប្រព្រឹត្តនៅក្នុងខេត្តព្រៃវែង[3396] និងខេត្តស្វាយរៀង[3397] នាឆ្នាំ១៩៧៧ ឆ្នាំ១៩៧៨ និងឆ្នាំ១៩៧៩[3398]។ យោងទៅតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ជុំវិញតំបន់មួយផ្នែក ឬ ទាំងអស់របស់ខេត្តព្រៃវែង និងស្វាយរៀងរួមមាន៖ តំបន់ ២០, ២២, ២៣ និង ២៤ នៃភូមិភាគបូព៌ាមួយផ្នែក ឬទាំងអស់។

**៧៩៨.** កម្មាភិបាល ប.ក.ក បានធ្វើការចាប់ខ្លួន និង សម្លាប់ប្រជាជនវៀតណាម តាមវិធីសាស្ត្រមួយដោយធ្វើការស្រាវជ្រាវរកពីផ្ទះមួយទៅផ្ទះមួយ ឬរៀបចំការប្រជុំ ដើម្បីធ្វើជំរឿនចំពោះបុគ្គលណាដែលមានដើមកំណើតវៀតណាម[3399]។ បញ្ជីស្រង់ឈ្មោះជនជាតិវៀតណាម ដែលរៀបចំរួចជាស្រេចត្រូវបានប្រើប្រាស់នៅពេលធ្វើការចាប់ខ្លួន[3400] ដែលរឿងនេះសាក្សីម្នាក់បានបំភ្លឺថាជាការអនុវត្តន៍បញ្ជាដែលចេញពីថ្នាក់លើ[3401]។

**៧៩៩.** នៅពេលខ្លះគេបានប្រាប់ទៅប្រជាជនវៀតណាមថា ពួកគេត្រូវបានយកទៅរៀនសូត្រ[3402] ទៅប្រជុំ[3403] ឬទៅកាប់រំពាក់[3404] បន្ទាប់មកពួកគេត្រូវបានដាក់ ក្នុងរទេះសេះហើយយកចេញទៅ។ ជារឿយៗ បន្ទាប់ពីមេគ្រួសារត្រូវបានយកទៅមុន មិនយូរប៉ុន្មានម្តាយ និងកូនក៏ត្រូវបានយកទៅដែរ[3405]។ សាក្សីម្នាក់ដែលម្តាយគាត់ជាជនជាតិវៀតណាម ហើយត្រូវបានចាប់ខ្លួន បានរៀបរាប់ថា ហេតុផលតែមួយគត់ ដែលគាត់អាចនៅរស់រានមានជីវិត ដោយសារអ្នកភូមិជួយយកអាសារហើយបកស្រាយប្រាប់កម្មាភិបាលប.ក.កថា៖"*ខ្ញុំមានឈាមជ័រជាខ្មែរ*"[3406]។សាក្សីភាគច្រើនបានផ្តល់ភស្តុតាងថា វៀតណាម ទាំងអស់នៅក្នុងភូមិរបស់ពួកគាត់ត្រូវបានចាប់យកទៅ ឬពួកគាត់ដឹងថាប្រជាជនវៀតណាមត្រូវបានបាត់ខ្លួនជារៀងរហូត[3407]។ សាក្សីមួយចំនួនបានពណ៌នាយ៉ាងជាក់លាក់ពីការសម្លាប់រង្គាល ដែលត្រូវបានប្រព្រឹត្តនៅវាលតូច ភូមិចំការក្បួយ ស្រុកព្រៃវែង[3408]។

៨០០. សាក្សីបានផ្តល់អត្តសញ្ញាណ អំពីកម្មាភិបាលភូមិ[3409] ឃុំ[3410] និងស្រុក[3411] ដែលបានចូលរួមក្នុងការចាប់ខ្លួនជនជាតិវៀតណាមនៅព្រៃវែង។ សាក្សីមួយចំនួនបានអះអាងថា ការចាប់ខ្លួនត្រូវបានធ្វើឡើងតាមបញ្ជារបស់គណៈតំបន់២០[3412] ឬ"ថ្នាក់លើ"[3413] និងបានរៀបរាប់បញ្ជាក់ថា ការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តទាំងមុន[3414] និងបន្ទាប់[3415] ការបោសសម្អាតពួកបូព៌ា ដែលបានធ្វើឡើងជាពិសេសដោយកម្មាភិបាលភូមិភាគនិរតី។

៨០១. លំនាំនៃការចាប់ខ្លួន និង ការសម្លាប់ស្រដៀងគ្នាទៅលើប្រជាជនវៀតណាម បានកើតឡើងនៅខេត្តស្វាយរៀង[3416]។ នៅឆ្នាំ១៩៧៧[3417] និងឆ្នាំ១៩៧៨[3418] សាក្សីមួយចំនួនបានឃើញប្រជាជនវៀតណាមនៅខេត្តស្វាយរៀងត្រូវបានចាប់ខ្លួន និងនាំយកទៅដោយកម្មាភិបាលឃុំ[3419] និងកម្មាភិបាលស្រុក[3420]។ គ្មានសាក្សីណាម្នាក់អាចបញ្ជាក់ឲ្យបានច្បាស់ថា អ្នកទាំងនោះត្រូវបានយកទៅកន្លែងណាប្រាកដទេ ប៉ុន្តែ ត្រឹមតែដឹងថា អ្នកទាំងនោះត្រូវបានយកទៅសម្លាប់[3421]។ សាក្សីផ្សេងទៀតបានផ្តល់ភស្តុតាងថា "បណ្តាញរបស់វៀតណាម" ត្រូវបានគេចាប់ខ្លួន ដោយគាត់លើកឡើងថា៖ *"អើដឹងគេយកទៅណាបើថា យកទៅបាត់ៗតែម្តងទៅ។ សម្លាប់ណាវាមិនយកទៅណាទេ"*[3422]។

**ការសម្លាប់ប្រជាជនស៊ីវិលវៀតណាមក្រៅពីខេត្តព្រៃវែង និងខេត្តស្វាយរៀង**

៨០២. ការសម្លាប់ប្រជាជនវៀតណាម មិនមែនកើតឡើងត្រឹមតែនៅខេត្តព្រៃវែង និងខេត្តស្វាយរៀងប៉ុណ្ណោះទេ ដែលនេះបង្ហាញឲ្យឃើញថា ជាការរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ។ ការសម្លាប់រង្គាលលើប្រជាជនវៀតណាម ត្រូវបានកើតឡើងនៅពាក់កណ្តាលចុងឆ្នាំ១៩៧៨[3423] នៅវត្តខ្សាច់ ភូមិយាង ឃុំបួស្សីលក ខេត្តសៀមរាប[3424]។ ប្រជាជនវៀតណាមត្រូវបានចាប់ខ្លួនពីស្រុកស្វាយលើ[3425] និងស្រុកជីក្រែង[3426] ក្នុងខេត្តសៀមរាប និងនាំយកទៅវត្តខ្សាច់។ បក្សកុម្មុយនីស្តកម្ពុជាបានចេញវិធានការ ដើម្បីឲ្យច្បាស់ថា មានតែប្រជាជនវៀតណាមប៉ុណ្ណោះដែលត្រូវបានគេកំណត់ជាមុខសញ្ញា។ ការចាប់ខ្លួនត្រូវបានធ្វើឡើង ដោយការប្រើប្រាស់នូវបញ្ជីស្ថិតិដែលបានធ្វើចំពោះប្រជាជនវៀតណាម[3427]។ សាក្សីម្នាក់បានឮកម្មាភិបាល ប.ក.ក សួរទៅប្រជាជនដែលត្រូវបានគេចាប់ខ្លួនថា *"ពួកឯងសុទ្ធតែយួន?"*[3428]។ សាក្សីផ្សេងទៀតបានលឺកម្មាភិបាល ប.ក.ក សួរថា *"អ្នកឯងជាជនជាតិចិន ឬ ជនជាតិវៀតណាម?"* ដោយគាត់បានរៀបរាប់ទៀតថា អ្នកដែលឆ្លើយថា ជាជនជាតិវៀតណាមត្រូវគេសម្លាប់ ចំណែកឯអ្នកណាឆ្លើយថា ជនជាតិចិនត្រូវបានគេដោះលែង[3429]។ សក្ខីកម្មទាំងនេះស្របទៅនឹងសាក្សីផ្សេងទៀត ដែលធ្លាប់បានជួបស្ត្រីម្នាក់ដែលត្រូវបានគេដោះលែងពីវត្តខ្សាច់ពីព្រោះ

00605512



គាត់បានប្រាប់គេថា ជាជនជាតិចិន[3430]។ ប្រជាជនវៀតណាម ដែលត្រូវបានគេនាំយកទៅវត្តខ្សាច់ មិនត្រូវបានគេសួរចម្លើយ ឬឃុំខ្លួនយូរនោះទេ។ ពួកគេត្រូវបានសម្លាប់នៅក្នុងអំឡុងពេល២៤ម៉ោង បន្ទាប់ពីការចាប់ខ្លួនតែម្តង[3431] ដោយគល់ឫស្សី ហើយសាកសពត្រូវបានកប់ក្នុងរណ្តៅ និង អណ្តូង[3432]។ សាក្សីមួយចំនួនបានឃើញការសម្លាប់[3433] ហើយសាក្សីផ្សេងទៀតបានឮសូរ សម្លេងគេវៃមនុស្ស និង ឮសម្លេងស្រែក[3434]។ សាក្សីម្នាក់បាននិយាយថា ក្នុងរយៈពេល ប្រហែលបីម៉ោង គាត់បានឃើញមនុស្សជាង ១០០ នាក់ ត្រូវបានសម្លាប់ ហើយគាត់ស្មានថាមាន ប្រជាជនប្រហែល ៦០០ ទៅ ៧០០ នាក់ត្រូវបានសម្លាប់[3435]។ សាក្សីម្នាក់ទៀតបាននិយាយថា ប្រហែលជា ២៥នាក់ត្រូវបានសម្លាប់ក្នុងអំឡុងពេលប្រហែលមួយម៉ោងដែលគាត់បានលួចមើល ហើយប្រហែលជាង ១០០ នាក់ ត្រូវបានសម្លាប់ជាបន្តបន្ទាប់ប្រហែលជា ២ ទៅ ៣ ដង[3436]។ ប្រជាជនវៀតណាមទាំងប្រុស ទាំងស្រី និងក្មេងត្រូវបានសម្លាប់[3437]។

៨០៣. សាក្សីផ្សេងទៀតបានធ្វើសក្ខីកម្មថា ការសម្លាប់ដែលត្រូវបានកំណត់មុខសញ្ញាចំពោះប្រជាជន ស៊ីវិលវៀតណាមនៅទូទាំងប្រទេសកម្ពុជា ឧទាហរណ៍នៅកន្លែងដូចជា៖ ខេត្តបាត់ដំបង[3438] និងខេត្ត ពោធិ៍សាត់[3439] ក្នុងភូមិភាគពាយ័ព្យ ខេត្តមណ្ឌលគិរី[3440] ក្នុងតំបន់ស្វយ័ត១០៥ ខេត្តកំពត[3441] ខេត្ត តាកែវ[3442] ក្នុងភូមិភាគនិរតី ខេត្តក្រចេះ[3443] ក្នុងតំបន់ស្វយ័ត៥០៥ ខេត្តកោះកុង[3444] ក្នុងភូមិភាគ បស្ចិម និងស្រុកក្រូចឆ្មារ និងស្រុកខ្សាច់កណ្តាល[3445] ក្នុងភូមិភាគបូព៌ា[3446]។

៨០៤. មានភស្តុតាងផងដែរអំពីប្រជាជនវៀតណាមដែលត្រូវបានគេឃុំ និង សម្លាប់នៅមន្ទីរសន្តិសុខ ផ្សេងៗដែលស្ថិតនៅក្រោមវិសាលភាពនៃការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតរួមមាន នៅមន្ទីរស-២១ នៅទីក្រុងភ្នំពេញ[3447] នៅមន្ទីរសន្តិសុខក្រាំងតាចាន់នៅភូមិភាគនិរតី[3448] នៅមន្ទីរ សន្តិសុខព្រៃដំរីស្រុត និងមន្ទីរសន្តិសុខកោះខ្សេង នៅភូមិភាគបស្ចិម[3449] នៅមន្ទីរសន្តិសុខគោកក្តួច ក្នុងតំបន់ស្វយ័ត៥០៥[3450] និងមន្ទីរសន្តិសុខអូរកន្សែងនៅភូមិភាគឦសាន[3451]។ នៅខែមិថុនា ឆ្នាំ១៩៧៧ ក្រុមវៀតណាមដែលជាជនជាតិចារ៉ាយចំនួន ២០៩ នាក់ត្រូវបានឃុំខ្លួន[3452] និងសម្លាប់ ជាក្រុមនៅមន្ទីរសន្តិសុខអូរកន្សែង[3453]។ ការចាប់ខ្លួនប្រជាជនទាំងនេះត្រូវបានរាយការណ៍ពីលេខា ភូមិភាគឦសានទៅ "បងជាទីគោរព" និងបានចំលងជូនការរាយការណ៍នោះទៅឲ្យ នួន ជា និង អៀង សារី[3454]។

**ការប្រព្រឹត្តចំពោះប្រជាជនខ្មែរដែលមានប្ដី ឬប្រពន្ធវៀតណាម និងកូនដែលកើតពីឪពុក ឬម្ដាយវៀតណាម**

៨០៥. យោងតាមគោលនយោបាយមុនដំបូងរបស់បក្សកុម្មុយនីសកម្ពុជា ជនជាតិវៀតណាម ដែលមានប្ដី ឬប្រពន្ធជាខ្មែរ មិនត្រូវអនុញ្ញាតិឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញទេ ជាមួយប្ដី ឬប្រពន្ធរបស់ខ្លួន[3455]។ ហេតុនេះហើយបានជាមាន ជនជាតិវៀតណាមមួយចំនួនបន្តរស់នៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ១៩៧៧ ដែលអ្នកទាំងនោះមានប្ដី ឬប្រពន្ធជាជនជាតិខ្មែរ រួមទាំងកូនផង។

៨០៦. សាក្សីភាគច្រើនបានផ្ដល់សក្ខីកម្ម ទាក់ទងនឹងការប្រព្រឹត្តជាពិសេស ចំពោះបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពនេះ មិនត្រឹមតែស្ថិតនៅក្នុងខេត្តព្រៃវែង[3456] និងខេត្តស្វាយរៀង[3457]ប៉ុណ្ណោះទេ ប៉ុន្តែក៏មានកើតឡើងផងដែរនៅខេត្តកំពង់ចាម (ស្រុកកងមាស នៅភូមិភាគកណ្ដាល តំបន់៤១)[3458] និងនៅខេត្តសៀមរាប[3459]។

៨០៧. ការអនុវត្តន៍មានដូចជា៖ ប្រសិនបើបុរសជាជនជាតិវៀតណាម រៀបការជាមួយស្ត្រីខ្មែរ គឺមានតែបុរសទេ ដែលត្រូវបានយកទៅសម្លាប់ ចំពោះប្រពន្ធ និងកូនត្រូវបានទុកជីវិត ។ ប៉ុន្តែប្រសិនបើស្ត្រីជាជនជាតិវៀតណាមបានរៀបការជាមួយនឹងបុរសខ្មែរ ប្រពន្ធនិងកូននោះនឹងត្រូវយកទៅសម្លាប់ ចំណែកប្ដីត្រូវបានទុកជីវិត[3460]។

៨០៨. ហេតុផលដែលនៅពីក្រោយគោលនយោបាយនេះ ត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើន។ សាក្សីម្នាក់ក្នុងចំណោមនោះបាននិយាយថា៖ *"បើម្ដាយជាវៀតណាម គេយកទាំងម្ដាយ និងកូនទាំងអស់ទៅសម្លាប់ ពីព្រោះថា កូនបៅទឹកដោះម្ដាយ"* [3461]។ អ្នកផ្សេងទៀតបានចង្អុលបង្ហាញថា គាត់ត្រូវបានគេប្រាប់ថាកូនដែលកើតចេញពីម្ដាយដែលជាជនជាតិវៀតណាម ត្រូវបានគេសម្លាប់ពីព្រោះទងសុក ឬឈាមរបស់កូនចេញពីម្ដាយ មិនមែនចេញពីឪពុកទេ[3462] ឬបន្តទៀតថា គោលនយោបាយតម្រូវឲ្យបំផ្លាញពូជ ឬខ្សែលោហិតរបស់វៀតណាម[3463] ហើយថា ពូជវៀតណាមមិនត្រូវមានទៀតទេ និងមិនត្រូវអនុញ្ញាតិឲ្យមានការបង្កបង្កើតឡើយ[3464]។

៨០៩. កូនដែលកើតពីម្ដាយខ្មែរ និងឪពុកវៀតណាម ទំនងជាមិនត្រូវបានគេទុកជីវិតគ្រប់ពេលនោះទេ ព្រោះពេលខ្លះ កូនទាំងនេះក៏ត្រូវបានគេសម្លាប់ផងដែរ[3465] ហើយពេលខ្លះទៀត ប្ដីខ្មែរដែលមានប្រពន្ធជនជាតិវៀតណាមក៏ត្រូវបានគេចាប់ខ្លួន[3466] ឬសម្លាប់ដែរ[3467]។

៨១០. សារទូរលេខមួយ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ របស់ ញឹម បានស្នើសុំយោបល់ពីអង្គការ ៨៧០ អំពីអ្វីដែលត្រូវធ្វើជាមួយ "*សមាសភាពពួកទាហាន និង ពួកយួន ដែលមានប្តីខ្មែរ មានខ្មែរបានប្រពន្ធយួន ហើយកូនកាត់យួន តើឲ្យសំរេចយ៉ាងណា*"[3468]។ ញឹម បានកត់សំគាល់ថា "*មិនទាន់មាន*" សកម្មភាពប្រឆាំងពីប្រជាជនទាំងនោះទេ បើអ្នកណា"*មានសកម្មភាពឲ្យសំរេចចោលដែរ អ្នកខ្លះស្នើឲ្យប្រមូលទុកមួយកន្លែង ការនេះខ្ញុំសំរេចមិនពិបាកប្រមូលទេ តែយើងត្រូវក្តាប់វាឲ្យបានបន្តទៅទៀត បើវាចេញលេចភេទ យើងម្ចាស់ការបានភ្លាម*"។ ទោះបីជាយ៉ាងណាក៏ដោយ ញឹម បានស្នើនូវវិធីសាស្ត្រដើម្បីប្រមូលម្ចាស់ការ និងបើចាំបាច់សម្លាប់ពួកគេទាំងនោះ ហើយគាត់ក៏បានរៀបរាប់ទៀតថា "*ការនេះមតិអង្គប្រជុំ សូមសួរមកអង្គការ ៨៧០ ទៀត។ បើអង្គការសំរេចយ៉ាងណា សូមមានមតិណែនាំមកចុះ*"[3469]។

៨១១. នៅពេលសួរចម្លើយ ឌុច បានរៀបរាប់ពីឯកសារនេះថា "*មិនមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនៅក្នុងឯកសារនេះទេ។ របស់ ញឹម បានសរសេរទៅ ប៉ុល ពត ("អង្គការ ៨៧០") ដើម្បីពន្យល់ថា ទាក់ទងនឹងអតីតទាហានខ្មែរដែលបានរៀបការជាមួយជនជាតិវៀតណាម និង កូនកាត់ខ្មែរវៀតណាម ស្ថានការណ៍ត្រូវបានគ្រប់គ្រងយ៉ាងល្អ ហើយ អ្នកទាំងនោះមិនអាចបង្កបញ្ហាទេ។ គេត្រូវយល់ថារបបនោះ គឺមានការប្រយ័ត្នប្រយ៉ែងណាស់ចំពោះពួកទាំងនោះ ពីព្រោះ មិនមានការទុកចិត្តពួកគេទេ ហើយតាមយោបល់ខ្ញុំគឺ មានហេតុផលនយោបាយជាជាងពូជសាសន៍។ តាមពិតទៅមានការឯកភាពគ្នារវាងថ្នាក់លើ និងថ្នាក់ក្រោម។ អ្នកទាំងនោះមិនអាចធ្វើសកម្មភាពបានទេ។ ខ្ញុំមិនដឹងថាតើមានចម្លើយរបស់ ប៉ុល ពត តបទៅ របស់ ញឹម វិញដែរឬទេ ប៉ុន្តែវាមិនមែនជាការចាំបាច់ទេ*"[3470]។ ឌុច ក៏បាននិយាយទៀតថា គាត់មិនជឿថាមាននយោបាយច្បាស់លាស់ ទាក់ទងនឹងប្រជាជនស៊ីវិលវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា[3471] អ្នកដែលនៅសល់បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ "ត្រូវបានសម្លាប់" [3472]។ គាត់បានបន្ថែមទៀតថា "*ខ្ញុំបានឃើញនៅក្នុងបញ្ជីឈ្មោះចាស់នៅមន្ទីរស-២១ មានជនជាតិវៀតណាមដែលនៅរស់នៅក្នុងប្រទេសកម្ពុជាដែរ។ ជនស៊ីវិល និង ទាហានវៀតណាមត្រូវបានប្រព្រឹត្តកម្មដូចគ្នា។ ពួកគេត្រូវបានសួរចំលើយ បន្ទាប់មកត្រូវបញ្ជូនទៅសម្លាប់*"[3473]។ ចុងបញ្ចប់ ឌុច បាននិយាយបន្ថែមថា ពេលខ្លះគាត់ត្រូវបានប្រាប់ដោយ នួន ជា ពីការមកដល់មន្ទីរ ស-២១ របស់ជនស៊ីវិល និងទាហានវៀតណាម[3474]។

៨១២. ដូចគ្នាដែរ មានសំបុត្រមួយ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧ ផ្ញើទៅកាន់បក្សដោយ លេខាឃុំអង្គ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

តាសោម(ស្រុកត្រាំកក់) រាយការណ៍អំពីប្តី ប្រពន្ធកាត់ខ្មែរ-វៀតណាម ដែលបានស្នើសុំទៅប្រទេសវៀតណាម ហើយបានស្នើយោបល់ទៅអង្គការថា ត្រូវធ្វើយ៉ាងណាចំពោះពួកគេ។ នៅក្នុងសំបុត្រនោះ ក៏បានសរសេរថា ពួកគេទាំងអស់ត្រូវបានគេចុះក្នុងបញ្ជី។ សំបុត្របានបន្ថែមទៀតថា បើទាំងពីរនាក់ប្តីប្រពន្ធជាជនជាតិវៀតណាម ពួកគេត្រូវ“*បញ្ជូនដល់អង្គការ*”[3475]។ របាយការណ៍មួយទៀតមកពី ប្រធានភូមិក្បាលពោធិ៍ បានស្នើសុំទៅអង្គការ អំពីអ្វីដែលត្រូវធ្វើចំពោះ“*កូនកាត់យួន*”ម្នាក់ដែលត្រូវបានចោទថា មានការរអ៊ូរទាំ និងត្រូវបានប្តឹងថា ឈឺច្រើនពេកពេលធ្វើការ[3476]។

៨១៣. សាក្សីមួយចំនួនបានអះអាងថា ការប្រព្រឹត្តិជាពិសេសទៅលើប្តី ឬប្រពន្ធរបស់ជនជាតិវៀតណាម និង បុគ្គលដែលមានឪពុក ឬម្តាយជាជនជាតិវៀតណាម គឺជាលទ្ធផលនៃសេចក្តីសម្រេចដែលចេញដោយថ្នាក់លើ។ សាក្សីខ្លះត្រូវបានគេផ្តល់ដំណឹងដោយកម្មាភិបាលបក្សដូចជា “*ប្រធានភូមិ*”[3477] និងអំឡុងពេលប្រជុំ“*ស្វ័យទិតៀន*”[3478]។ សាក្សីម្នាក់បានពន្យល់ថា “*ខ្ញុំដឹងថាជាការបញ្ជាពីលើដល់ក្រោម ដោយខ្ញុំសំគាល់ឃើញថា មានការប្រជុំពេលព្រឹក ហើយពេលល្ងាចមានការចាប់ខ្លួនតែម្តង*”[3479]។ សាក្សីផ្សេងទៀតបានប្រាប់ថា “*ខ្ញុំដឹងថាអ្នកចាប់គឺខាងឈ្លបឃុំ...តាមបញ្ជារបស់ថ្នាក់លើ*”[3480]។

## គោលបំណងក្នុងការបំផ្លិចបំផ្លាញប្រជាជនវៀតណាម

៨១៤. នៅក្នុងទស្សនាវដ្តី ទង់បដិវត្ត ចេញខែមេសា ឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានប្រើពាក្យជារួមដើម្បី“*វកខ្មាំង[...] ពិនិត្យខ្មាំង[...] វិភាគខ្មាំង[...] តាមដានខ្មាំង [...]កៀបសង្កត់ខ្មាំង [...]ចាប់ខ្មាំង [...]និងកំទេចខ្មាំង*”[3481] និងបានអះអាងថា “*បញ្ហាមួយ ដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរ គឺរែកមុខពួក“ស អ អ” នឹងភ្នាក់ងាររបស់វា ពួក“ក ស ប” នឹងភ្នាក់ងាររបស់វា ពួក“យ” (វៀតណាម) លេបទឹកដី និងផ្តែបំរើរបស់វាឲ្យច្បាស់ និងជាបន្តបន្ទាប់ ក្នុងបក្សទាំងមូល កងទ័ពទាំងមូល និង ប្រជាជនទាំងមូល វាយផ្ចាច់ខ្មាំងខាងនយោបាយ កុំឲ្យវាមកលបចូលបាន នៅក្នុងបក្សយើង កងទ័ពយើង និងប្រជាជនយើងជារៀងរហូត។ ឯឫសចាស់របស់វា ដែលនៅសេសសល់ខ្លះ ក្រោយពីយើងកំចាត់ឲ្យវាខ្ទេចខ្ទីនេះ គឺត្រូវបំផុសមហាជនឲ្យគេបោសសំអាតវាថែមទៀត ឲ្យស្អាតជាស្ថាពរ*”[3482]។ ទាំងនេះ អាចចាត់ទុកជា ការអំពាវនាវដោយផ្ទាល់ ដើម្បីសម្លាប់រាល់សមាជិកនៃសហគមន៍ប្រជាជនវៀតណាម ដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា។

៨១៥. អត្ថិភាពនៃគោលនយោបាយនេះ បានបញ្ជាក់បន្ថែមដោយសៀវភៅសរសេររបស់កម្មាភិបាលរបស់មន្ទីរ ស-២១ ដែលមានផ្នែកខ្លះបង្ហាញថា កម្មាភិបាលបានដឹងថា ពួកគេត្រូវបានស្នើរឲ្យស្វែងរក និងសម្លាប់ប្រជាជនវៀតណាមទាំងអស់នៅក្នុងប្រទេសកម្ពុជា។ សៀវភៅមួយនោះបានសរសេរថា *"រកយួន៖ យើងរកព្រោងព្រាត។ ដឹងថា មានលាក់យួននៅបូព៌ា នៅពាយ័ព្យ នៅភ្នំពេញរកមិនឃើញដែរ។ តែពិតជាមាន"*[3483]។ សៀវភៅមួយទៀតបានលើកឡើងថា *"តើរកយួនឃើញ ឬ មិនឃើញ? ជ័យជំនះអតិបរមា ៖ រកយួនឃើញ។ ជ័យជំនះអប្បបរិមា៖ រកខ្មែរក្បត់ដែលជាភ្នាក់ងារយួនបានថែមទៀត"* [3484] ហើយបានបន្ថែមទៀតថា វៀតណាមទាំងនោះបានលាក់ខ្លួននៅទូទាំងប្រទេសកម្ពុជា[3485]។

៨១៦. ភស្តុតាងទាក់ទងនឹងការអនុវត្តន៍គោលនយោបាយនេះ អាចរកឃើញផងដែរ នៅក្នុងឯកសារឆ្លើយឆ្លងពីភូមិភាគទៅមជ្ឈិម។ សេចក្តីរាយការណ៍មួយចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ មកពីមន្ទីរ ៤០១ នៃភូមិភាគបស្ចិម រាយការណ៍ទៅអង្គការ អំពី*"កំទេចជនជាតិយួន ទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង អស់ចំនួន ១០០ នាក់"*[3486]។ សេចក្តីរាយការណ៍នេះបានបន្ថែមទៀតថា *"វិធានការណ៍យើងលើសកម្មភាពខ្លាំងខាងលើនេះ"* ត្រូវបានធ្វើឡើងដោយ *" បន្តតាមដានស្រាវជ្រាវរកខ្មែរខ្លាំងគ្រប់ប្រភេទ ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ហើយបោសសំអាតវាតទៅទៀត ឲ្យស្អាតដាច់ខាតពីក្នុងមូលដ្ឋាន និង អង្គភាព មន្ទីរ ក្រសួងផ្សេងៗ"*។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ [លុប] (ជាលេខាកងពល១៦៤របស់មជ្ឈិម) បានរាយការណ៍ជាសម្ងាត់តាមទូរស័ព្ទទៅកាន់ នួន ជា និង អៀង សារី ថា វៀតណាម១២០ នាក់ត្រូវបានចាប់ និង បាញ់សម្លាប់នៅក្នុងពេលបីថ្ងៃរវាង ថ្ងៃទី ២៧ ដល់ ៣០ ខែមីនា ឆ្នាំ១៩៧៨[3487]។

៨១៧. អតីតកម្មាភិបាលក៏បានអះអាងពីគោលនយោបាយដែលថា វៀតណាមមាននៅគ្រប់ទីកន្លែង *"គ្រប់ៗរូបត្រូវប្រុងប្រយ័ត្នដើម្បីរកឲ្យឃើញ និង កំចាត់ចោល"*[3488]។

៨១៨. នៅឆ្នាំ២០០៦ ព្រះបាទនរោត្តម សីហនុ បានបោះពុម្ពនូវព្រះរាជសារ ដែលបានធ្វើឡើងដោយព្រះហស្តផ្ទាល់ ដែលនៅក្នុងនោះព្រះអង្គបានប្រទាននូវព័ត៌មានលំអិត ទាក់ទងនឹងការប្រជុំជាមួយ ប៉ុល ពត នៅដំណាក់កាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ[3489]។ ព្រះរាជសារនេះនឹងមានទម្ងន់ជាភស្តុតាងលុះត្រាតែ មានសក្ខីកម្មដែលមានទម្រង់ជាកំណត់ហេតុនៃការស្តាប់ចម្លើយតែប៉ុណ្ណោះ ប៉ុន្តែព្រះរាជ-សារនេះហាក់ដូចជាមានការពាក់ព័ន្ធធ្ងន់ធ្ងរ ដើម្បីបញ្ចូលនៅក្នុងជំពូក

ស្តីពីអង្គហេតុនេះ។ ព្រះរាជសុន្ទរកថានេះបានរៀបរាប់ពី ប៉ុល ពត ដែលបានប្រាប់ទៅព្រះបាទនរោត្តមសីហនុ ដូចតទៅ ៖ *"ប្រទេសកម្ពុជារបស់យើងនឹងមិនបានសុខសាន្តទេ ដរាបណាយើងជាជនជាតិកម្ពុជានៅមិនទាន់បានកំទេចចោលនូវកំពូលជឃ្លនដ៏អាក្រក់នេះ។ ខ្ញុំបានចាប់ផ្តើមបញ្ជូនកងទ័ពយើងទៅកម្ពុជាក្រោម(កូសាំងស៊ីន) ក្នុងបេសកកម្មដើម្បីសំលាប់ឱ្យបានច្រើនជាអតិបរមានូវបុរស ស្ត្រី និង កុមារ របស់កំពូលជឃ្លនដ៏អាក្រក់បំផុតនេះ។ ក៏ប៉ុន្តែថា (យើង) មិនអាចកំទេចពួកវាចោលទាំងស្ត្រី ទាំងបុរស ឱ្យអស់ពីក្នុងប្រទេសរបស់ពួកវាបានទេ។ នៅតំបន់អណ្តាម និងតុងកឹង គឺនៅមានប្រជាជនរាប់សិបលាននាក់នៅឡើយ។ ដូច្នេះ ខ្ញុំក៏បានសំរេចចិត្តផ្លាស់ប្តូរយុទ្ធសាស្ត្រ និង កលល្បិច។ គឺ (ផ្លាស់ប្តូរ) ទាំងស្រុងតែម្តង! ។ (គឺ) ខ្ញុំបញ្ឆោតពួកវាឱ្យចូលមកស្រុកយើង ដោយធ្វើយ៉ាងណាឱ្យពួកវាជឿយ៉ាងស៊ប់ថា ពួកវាពិតជាបានទទួលជ័យជំនះតាមមធ្យោបាយយោធា។ ដល់ពេលណាពួកវាបានចូលមកដល់កម្ពុជាប្រជាធិបតេយ្យហើយ យើងជាប្រជាជនកម្ពុជាទាំងប្រុស ទាំងស្រី នឹងកាប់ពួកវាជាដុំតូចៗ(sic!) នឹងហាន់ពួកវាជាកង់ៗ (sic!) ។ នៅវៀតណាមពួកវាគ្មានផ្លូវថា នឹងបានឃើញទាហានពួកវាត្រឡប់ទៅស្រុកវាវិញឡើយ ហើយពួកវា ពិតជានឹងបញ្ជូន កងពលជាច្រើនមករកយើងទៀត។ ហើយយើងជាប្រជាជនកម្ពុជានឹងបន្តហាន់ពួកវាជាកង់ៗ។ ហើយដល់ដំណាក់កាលចុងក្រោយ បន្ទាប់ពីមានការរំដោះកម្ពុជាក្រោមរបស់យើងរួច យើងនឹងធ្វើដំណើរទៅកាន់ប្រទេសរបស់ពួកវាគឺទៅអណ្តាម និងទៅឱ្យដល់តុងកឹងទៀត ដែលការធ្វើដូច្នេះគឺដើម្បីកាប់សម្លាប់ប្រពន្ធ និងកូនរបស់ពួកវា(ក្មេងប្រុសស្រី និងទារក)។ ហេតុដូចនេះ កំពូលជឃ្លនដ៏អាក្រក់បំផុត នឹងវិនាសបាត់បង់ពីផ្ទៃផែនដីនេះ"*[3490]។

**សង្គ្រាមប្រឆាំងវៀតណាម និងការឃោសនាអំពីការរើសអើង**

៨១៩. ទោះបីជាមិនមានការកំណត់មុខសញ្ញាច្បាស់លាស់ និងជាក់លាក់ ចំពោះសមាជិកនៃសហគមន៍ជនជាតិវៀតណាម ដែលនៅសេសសល់ក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ការឃោសនាប្រឆាំងវៀតណាមដោយសំដៅដល់កងកម្លាំងប្រដាប់អាវុធវៀតណាម ក្នុងបរិបទនៃជំលោះប្រដាប់អាវុធជាមួយវៀតណាម និង ការចោទប្រកាន់ ក្នុងចំណោមប្រជាជនកម្ពុជាថា ជាភ្នាក់ងាររបស់វៀតណាម ភ្នាក់ងាររបស់អាមេរិកសេអ៊ីអា និងរបស់សូវៀត ក.ហ្សេ.បេ[3491] បានលើកទឹកចិត្ត និងបណ្តាលឱ្យមានការសម្លាប់ប្រជាជនស៊ីវិលវៀតណាមជាច្រើន។ ការសម្លាប់នេះ ត្រូវបានប្រព្រឹត្តឡើងទាំងនៅក្នុងប្រទេសវៀតណាម ឬ អ្នកដែលត្រូវបានគេចាប់នៅក្នុងប្រទេសកម្ពុជា។

៨២០. ចាប់ពីឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបាន បង្កើននូវការឃោសនាញុះញង់ឱ្យស្អប់ ប្រជាជនវៀតណាម។ នៅក្នុងការឃោសនារបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា វៀតណាមគឺ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ជាពួកជនវាតទឹកដី ឈ្លានពាន ឃោឃៅ សាហាវ ដណ្តើមទឹកដី លេបទឹកដី[3492] ដែលមានបំណង ត្រួតត្រាកម្ពុជា"*ដើម្បីលេបត្របាក់ប្រជាជាតិ ប្រជាជន និងទឹកដីកម្ពុជាយើងទាំងមូល*" [3493]។ បក្សកុម្មុយនីស្តកម្ពុជាបានញុះញង់"*បញ្ឆេះ ភាពស្អប់ខ្ពើមដែលពោរពេញទៅដោយភាពឈឺចាប់*"ប្រឆាំងទៅនឹងប្រជាជនវៀតណាម និងបានជំរុញឱ្យកម្មាភិបាលបន្តការញុះញង់នូវភាពស្អប់ខ្ពើមនេះនៅក្នុងស្រទាប់ប្រជាជន[3494]។ "*ការសារភាព*"ដោយបង្ខំទៅលើទាហានវៀតណាម ដែលត្រូវចាប់ខ្លួន ត្រូវបានចាក់ផ្សាយតាមវិទ្យុដែលផ្ទុកទៅដោយពាក្យពេចន៍អុចអាល ដើម្បីបង្ហាញថា វៀតណាម មានគម្រោងការលេបត្របាក់ប្រទេសកម្ពុជា និងបំផ្លាញប្រជាជនកម្ពុជា[3495]។ ខៀវ សំផន[3496] អៀង សារី[3497] អៀង ធិរិទ្ធ[3498] និង នួន ជា[3499] អ្នកទាំងអស់នេះ បានចូលរួមក្នុងការផ្សព្វផ្សាយ នូវការឃោសនាទាក់ទងនឹងការប្រឆាំងវៀតណាម។

៨២១. ទស្សនាវដ្តី ទង់បដិវត្ត បក្សកុម្មុយនីស្តកម្ពុជា ចេញផ្សាយនៅខែធ្នូ ឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៨ បានធ្វើការអបអរជាសាធារណៈ ចំពោះប្រទេសក្នុងការបោសសំអាតផ្ទៃក្នុង នៅក្នុងឆ្នាំ ១៩៧៧ ប្រឆាំងនឹងភ្នាក់ងារវៀតណាមដែលលាក់ខ្លួននៅក្នុងប្រទេស។ អត្ថបទនេះបានរៀបរាប់ថា "*យើងដណ្តើមបានជ័យជំនះធំ ហើយជាខ្សែសង្វាក់នៅឆ្នាំ១៩៧៧ ដោយសារយើងបានសំរិតសំរាំង និងបោសសំអាតខ្មាំងបានជាខ្សែសង្វាក់ ដឹកឫសគល់របស់វាធំៗ បានជាមូលដ្ឋាន...ដល់ពេល ឥឡូវនេះ កំលាំងយួន និងកំលាំងសូវៀតដែលបង្កប់ស៊ីរូងអស់ជាមូលដ្ឋាន*"[3500]។ ទស្សនាវដ្តី នេះបានអំពាវនាវឱ្យបន្តការសម្លាប់ដោយបន្ថែមថា "*ខាងផ្នែកចាត់តាំងវិញ គុណសម្បត្តិឆ្នាំនេះ សំខាន់គឺបានសំរិតសំរាំង បោសសំអាតសមាសភាពមិនល្អ សមាសភាពខ្មាំងបង្កប់ស៊ីរូង ធ្វើឱ្យ បក្សស្អាត ជាអតិបរមា...ប៉ុន្តែតទៅមុខទៀត ត្រូវយកចិត្តទុកដាក់សំរិតសំរាំងតទៅទៀត...ត្រូវ សំរិតសំរាំងតទៅទៀត ពីព្រោះសមាសភាពខ្មាំងមិនទាន់អស់រលីងនៅឡើយ*" [3501]។

៨២២. ទស្សនាវដ្តីទង់បដិវត្ត បានបន្តនូវការអំពាវនាវ ដើម្បីសម្លាប់ប្រជាជនវៀតណាម នៅក្នុងលេខចុះ ផ្សាយនៅខែកក្កដា ឆ្នាំ១៩៧៨ ថា៖ "*ខ្មាំងយួន...វាជាសត្រូវប្រចាំជាតិរបស់យើង តាំងពីដើមរហូត ឥឡូវ និងទៅមុខយូរអង្វែងទៀត...។ ករណីកិច្ចប្រចាំជាតិរបស់យើងរាល់គ្នា គឺតស៊ូកំទេចខ្មាំងយួន ឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍របស់យើង។ គ្មានជនកម្ពុជាណាម្នាក់ក្នុងជំនាន់នេះ ហើយក៏គ្មានជនកម្ពុជាណាម្នាក់ក្នុងជំនាន់ក្រោយដាក់អាវុធឈប់វាយខ្មាំងយួន ឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជាជាដាច់ខាត*"[3502]។ ទស្សនាវដ្តីនេះ ក៏បានអបអរសាទរ ចំពោះ សហករណ៍នូវតួនាទីរបស់ពួកគេ ក្នុងការកាប់សម្លាប់ដោយបានលើកឡើងថា "*ជាពិសេសថែមទៀត ក្នុងមហាចលនាមហាជនវាយកំទេចខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ និង ក្នុង*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605519



*មហាចលនាមហាជនបោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារសេអ៊ីអា ភ្នាក់ងារវៀតណាមបម្រើយួន និង ភ្នាក់ងារកាសេបេ សហករណ៍ទូទាំងប្រទេសបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើសកម្មភាពបំពេញភារកិច្ចរបស់ខ្លួន នាំមកនូវជ័យជំនះជាយុទ្ធសាស្ត្រជូនជាតិ ប្រជាជន បក្ស និងបដិវត្ត*[3503]។ ការណែនាំទាំងនេះស្របគ្នានឹងការរៀបរាប់ អំពីការបោសសម្អាតដែលធ្វើឡើងប្រឆាំងនឹងជនក្បត់នៅក្នុងជួរបក្ស និងប្រជាជន[3504]។

៨២៣. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ នៅក្នុងការផ្សព្វផ្សាយ តាមរយៈវិទ្យុជាតិក្នុងក្រុងភ្នំពេញគេអាចដឹងថា ប្រទេសកម្ពុជាមានប្រជាជនតិចជាងប្រទេសវៀតណាម *"គិតជាចំនួន យើងម្នាក់ត្រូវសម្លាប់វៀតណាម ៣០ នាក់"*។ ការផ្សព្វផ្សាយនេះបានរៀបរាប់ថា ៖ *"ដោយប្រើតួលេខទាំងនេះ យោធាកម្ពុជាម្នាក់ ស្មើនឹងទាហានវៀតណាម ៣០ នាក់។ ដូច្នេះ វៀតណាមប៉ុន្មាននាក់ស្មើនឹងយោធាកម្ពុជាចំនួន ១០ នាក់? ចំលើយគឺត្រូវជា ៣០០ នាក់។ យោធាកម្ពុជា ១០០ នាក់ ស្មើនឹងទាហានវៀតណាម ៣.០០០ នាក់។ យោធាកម្ពុជា ១.០០០.០០០ នាក់ស្មើនឹងវៀតណាម ៣០.០០០.០០០នាក់។ យើងត្រូវមានយោធា ២.០០០.០០០ នាក់មានលើសពីតំរូវការក្នុងការវាយវៀតណាម ពីព្រោះវៀតណាមមានតែប្រជាជន ៥០.០០០.០០០នាក់។ យើងមិនចាំបាច់មានមនុស្ស ៨.០០០.០០០នាក់។ យើងត្រូវការតែកងទ័ព ២.០០០.០០០នាក់ ដើម្បីវាយកំទេចវៀតណាម ៥០.០០០.០០០នាក់ ហើយយើងនៅមាននៅសល់មនុស្សចំនួន ៦.០០០.០០០នាក់"* [3505]។

៨២៤. ការផ្សព្វផ្សាយបានបន្តទៀតថា *"បញ្ហានេះមិនទាក់ទងទៅនឹងកំលាំងប្រដាប់អាវុធតែឯងទេ។ បក្ស កងទ័ព និងប្រជាជនទាំងមូលត្រូវដឹងឲ្យបានពេញលេញនៃមាគ៌ា ទស្សនៈ និងជំហរទាំងនេះ"* [3506]។ ជាក់ស្តែង គោលនយោបាយនេះ ត្រូវបានគេផ្សព្វផ្សាយនៅក្នុងវិទ្យុទៅដល់ប្រជាជនកម្ពុជា និង ជាការបន្ថែមព័ត៌មានទៅដល់កម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ ម៉ម ណៃ ហៅ ចាន់ ជាអ្នកសួរចម្លើយសំខាន់ម្នាក់នៅមន្ទីរស-២១ ដែលបានកត់ត្រានូវមេរៀនដែល ឌុច បានបង្រៀន[3507] ដោយបានសរសេរថា *"នយោបាយបក្ស"* កំណត់ជាទូទៅ ១ ទល់ ៣០ ហើយគោលការណ៍នេះអាចមានចំនួនទៅដល់ ១ ទល់ ៩០ នៅខេត្តស្វាយរៀង[3508]។ គាត់បានបញ្ជាក់ទៀតថាគោលនយោបាយនេះ ត្រូវតែអនុវត្តតាមរយៈ*"បោសសំអាតអាខ្មាំងឲ្យអស់ ឲ្យធំ"* [3509]។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ ប៊ុន និង ទុយ ជាអ្នកសួរចំលើយផ្សេងទៀតនៅមន្ទីរ ស-២១ ក៏បានលើកឡើងផងដែរអំពី *"គោលការណ៍បក្ស"* ទាក់ទងនឹង ១ ទល់ ៣០ និង ១ ទល់ ៩០ នៅខេត្តស្វាយរៀង[3510]។

៨២៥. នៅក្នុងការផ្សព្វផ្សាយផ្សេងទៀត តាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា បានទាមទារឱ្យមាន *"ការប្រុងប្រយ័ត្នខ្ពស់"* ដើម្បី"ការពារបក្ស និងការពារការគ្រប់គ្រងបដិវត្តន៍របស់វណ្ណៈកម្មករ កសិករ ដោយការកម្ចាត់ទាំងខ្មាំងដែលនៅបង្កប់សេសសល់ និង ខ្មាំងឈ្លានពានដែលមកពីខាងក្រៅ"[3511]។ គោលបំណងជាក់លាក់មួយ ត្រូវធ្វើឡើងដើម្បីបំពេញតម្រូវការក្នុងការ *"កំទេចឱ្យអស់ពីសហករណ៍ពួកយើង និង ទឹកដីកម្ពុជា ទាំងខ្មាំង ដែលនៅបង្កប់សេសសល់ និងខ្មាំងឈ្លានពានដែលមកពីខាងក្រៅ ដូចគ្នាដែរចំពោះរាល់សកម្មភាពទាំងអស់របស់ពួកគេ"*[3512] ហើយត្រូវធ្វើដូចគ្នាដែរ នៅក្នុងមន្ទីរ និង ក្រសួងនានារបស់រដ្ឋ[3513]។ កងទ័ពបានប្ដេជ្ញា *"ដើម្បីប្រយុទ្ធ និងកំទេចសត្រូវលេបទឹកដី និង សត្រូវផ្សេងទៀតគ្រប់លំដាប់ថ្នាក់ ដូច្នេះពួកគេនឹងត្រូវបានលុបបំបាត់ឱ្យសាបសូន្យពីទឹកដីកម្ពុជាយើង"* [3514]។ ក្រសួងព័ត៌មាន និងឃោសនាការ បានលើកឡើងថា៖ *"បើវៀតណាមមិនព្រមដកកងទ័ពចេញពីទឹកដីកម្ពុជាដ៏ពិសិដ្ឋ គឺមានតែដំណោះស្រាយមួយគត់សំរាប់កងទ័ព និងប្រជាជនបដិវត្តន៍កម្ពុជា គឺថាត្រូវកំទេច និង សម្លាប់ឱ្យអស់នូវសត្រូវឈ្លានពានវៀតណាមដែលមកចង់លេបទឹកដីកម្ពុជា"*[3515]។

៨២៦. តួយ៉ាងផ្សេងទៀតនៃការសម្លាប់ *"ការកម្ទេច"* និង ការវាយប្រហារលើប្រជាជនស៊ីវិលវៀតណាម និង ការបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជនវៀតណាម ត្រូវបានគេជូនដំណឹងទៅមន្ទីរ ៨៧០ ទៅ នួន ជា និង អៀង សារី[3516]។

៨២៧. នួន ជា អៀង សារី និង មន្ទីរ ៨៧០ ក៏ត្រូវបានគេផ្ដល់ដំណឹងលម្អិត ពីកម្មាភិបាលថ្នាក់ក្រោមចំពោះការសម្លាប់រង្គាលលើប្រជាជនស៊ីវិលនៅប្រទេសវៀតណាម តាមរយៈរបាយការណ៍របស់អ្នកទទួលខុសត្រូវថ្នាក់ក្រោម។ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៧ មានសារទូរលេខមួយផ្ញើរទៅកាន់មន្ទីរ៨១ និង បានចម្លងជូន នួន ជា អៀង សារី និង មន្ទីរ៨៧០ ដោយបានរាយការណ៍ថា *"កងទ័ពកម្ពុជាសម្លាប់រង្គាលអស់ប្រជាជនវៀតណាមចំនួន ១.០០០ នាក់"មួយពាន់នាក់" នៅហាទៀន ខេត្តគៀនយ៉ាង"* [3517]។

៨២៨. សេចក្ដីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាចេញពីមន្ទីរ៨៧០ នាថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨ ដោយបានពង្រឹងនូវការដាក់បទបញ្ជា ទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹង *"ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី"*[3518]។ សេចក្ដីណែនាំនេះបានធ្វើឡើងសំដៅដល់ *"ប្រជាជនកម្ពុជាទាំងមូល កងទ័ពបដិវត្តកម្ពុជាទាំងមូល យុទ្ធជន យុទ្ធនារី កម្មាភិបាលគ្រប់ក្រសួងមន្ទីរទាំងអស់"* ដោយបានបង្គាប់ឱ្យប្រជាជន *"ត្រូវលើកកំពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តខ្ពស់ជាប់ជានិច្ច តាមដានរាវរក*


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

*ភ្នាក់ងារខ្មាំងយួន កុំឱ្យវាលាក់បំពួនបាននៅទីកន្លែងណាឱ្យសោះ ហើយកំចាត់វាឱ្យអស់ការនឹងទាន់ពេលវេលា*"[3519]។

**៨២៩.** ពីរថ្ងៃបន្ទាប់មក មន្ទីរ៨៧០ បានផ្តល់នូវការណែនាំបន្ថែមទៀតអំពីថា តើត្រូវធ្វើយ៉ាងណាដើម្បីវាយប្រហារប្រកបដោយប្រសិទ្ធភាពចំពោះ "*យួនឈ្លានពាន*" ទាំងនៅក្នុងសមរភូមិ និងនៅក្នុងជួរបក្ស។ ការណែនាំនេះបានបញ្ជាថា "*ថ្នាក់ភាគ តំបន់ ស្រុក គណៈបញ្ជាការគ្រប់ថ្នាក់ និងកម្មាភិបាលយោធា និងមូលដ្ឋាន យកចិត្តទុកដាក់រៀនសូត្រចុះឡើង អំពីមាគ៌ាវាយដូចចែងខាងលើនេះ ឱ្យសក្តិសិទ្ធិបំផុតបំផុសកម្មាភិបាល និងយុទ្ធជនយើង ប្រឡងប្រណាំងវាយកំទេចក្បាលខ្មាំងយួនឈ្លានពាន ទឹកដីឱ្យអស់រលីង ការពារបក្សបដិវត្តកម្ពុជាប្រជាធិបតេយ្យ ការពារប្រជាជនយើង សហករណ៍យើង ស្រូវអង្ករ ស្រែចំការ និងភោគផលដំណាំរបស់យើងទាំងអស់*"[3520]។ សេចក្តីណែនាំនេះបានបន្តទៀតថា "*គ្រប់ថ្នាក់បក្ស និងអង្គភាពយោធា ក្រសួង-មន្ទីរ ត្រូវមានវិធានការណ៍ម៉ត់ចត់ និងតឹងរឹង កំចាត់ចារកម្ម សន្តិសម្ព័ន្ធ និងសង្គ្រាមចិត្តសាស្ត្រផ្សេងៗរបស់ខ្មាំង ទោះជាវាចេញតាមទិដ្ឋភាពណាក៏ដោយ។ ប្រុងប្រយ័ត្នបំផុតនៅតាមសមរភូមិនីមួយៗ និង ជិតសមរភូមិទាំងក្នុងយោធា ក្នុងប្រជាជន ក្នុងយុទ្ធជន-យុទ្ធនារី ក្រសួង-មន្ទីរ កម្មាភិបាល*"[3521]។

**៨៣០.** គណៈកម្មាធិការ ៨៧០ បានដាក់បញ្ជាថា តើត្រូវធ្វើការវាយប្រហារលើទាហានឈ្លានពានវៀតណាមយ៉ាងណា។ សេចក្តីណែនាំនាថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៩ បានបង្ហាញពីចេតនារបស់សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍៨៧០ ដើម្បី"*ដេញវាយខ្មាំងតាមចិត្ត កំទេចខ្មាំងតាមចិត្ត ហើយច្បាស់ជាពួកអាយួនយំស្វា និងស្រែកចេចចាចពេញតែព្រៃ មុននឹងត្រូវយើងកំទេចវា ឱ្យអស់សាបសូន្យ លើទឹកដី ដ៏ពិសិដ្ឋិរបស់យើង*"[3522]។ សេចក្តីណែនាំនេះក៏បានបង្គាប់ផងដែរថា តើត្រូវធ្វើយ៉ាងណា ដើម្បីផ្សព្វផ្សាយព័ត៌មាននៅគ្រប់ជួរបក្ស "*សេចក្តីណែនាំនេះ ត្រូវចែកចាយ និងសិក្សាក្នុងគណៈបក្សភាគ តំបន់ ស្រុក សហករណ៍ ក្នុងគណៈសមរភូមិ គណៈកងពល វរៈសេនាធំ វរៈសេនាតូច អនុសេនាធំ អនុសេនាតូច ក្រុម និង យុទ្ធជន គណៈបញ្ជាការមុខព្រួញនីមួយៗ ឱ្យជ្រួតជ្រាបសាចុះសាឡើង*"[3523]។

**៨៣១.** ការសម្លាប់ក៏មានពាក់ព័ន្ធផងដែរ ទៅនឹងការបោសសម្អាតដែលធ្វើឡើងនៅភូមិភាគបូព៌ាប្រឆាំងទៅនឹងបុគ្គលដែលត្រូវចោទថាជា ជនក្បត់ ដែល នួន ជា បានកំណត់អត្តសញ្ញាណដូចជា "*ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងខ្មាំងដែលជាដៃជើងយួន*"[3524] ទោះបីជាការសម្លាប់នេះ ត្រូវបានកំណត់មុខសញ្ញាចំពោះជនជាតិវៀតណាមដែលនៅក្រៅពីភូមិភាគបូព៌ាក៏ដោយ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605522



# ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាលើទឹកដីវៀតណាម

៨៣២. សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តប្រឆាំងលើជនស៊ីវិល និងកងទ័ពវៀតណាម ក្នុងអំឡុងពេលនៃការចូលលុកលុយក្នុងទឹកដីវៀតណាមពីសំណាក់កងទ័ពបដិវត្តន៍កម្ពុជា[3525]។

៨៣៣. ក្នុងអំឡុងពេលនៃការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានចេញ ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិមួយទៅកាន់រដ្ឋាភិបាលនៃប្រទេសវៀតណាម ដើម្បីស្នើសុំសហប្រតិបត្តិការ និងការជួយជ្រោមជ្រែងនៅក្នុងដំណើរការស៊ើបសួរនេះ[3526]។ ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិត្រូវបានបញ្ជូនទៅស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ។ ចំនួនភាគច្រើននៃឯកសារដែលបានស្នើសុំ នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិនេះ ទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសវៀតណាម និង/ឬ ការលុកលុយរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងទឹកដីវៀតណាម ក៏ដូចជាឯកសារដែលពាក់ព័ន្ធនឹងបញ្ហាយោធានានា របស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ [3527]។

៨៣៤. សហចៅក្រមស៊ើបអង្កេតមិនបានទទួលនូវចម្លើយតបជាផ្លូវការណាមួយនោះទេពីអាជ្ញាធរវៀតណាម។ រយៈពេលប្រាំមួយខែបន្ទាប់ពីការធ្វើសំណើសុំនេះ សហចៅក្រមស៊ើបអង្កេតបានផ្ញើលិខិតមួយច្បាប់ទៀតទៅកាន់ស្ថានទូតវៀតណាមដើម្បីទទួលបានដំណឹងអំពីសំណើសុំរបស់ខ្លួន ប៉ុន្តែនៅតែមិនមាន ការឆ្លើយតបជាផ្លូវការដដែល[3528]។ ក្នុងអំឡុងពេលនេះ អ្នកស៊ើបអង្កេតកម្ពុជាមួយរូប ដែលត្រូវបានចាត់តាំងដោយដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ ឱ្យធ្វើការទាក់ទងជាមួយនឹងអាជ្ញាធរវៀតណាមបានទាក់ទងជាច្រើនដង ជាមួយនឹងតំណាងរបស់ស្ថានទូត(ទាំងតាមទូរស័ព្ទ និងធ្វើដំណើរទៅផ្ទាល់) ដើម្បីទទួលបាននូវឯកសារដែលបានស្នើសុំនោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមិនមានការឆ្លើយតបជាផ្លូវការណាមួយពីសំណាក់ស្ថានទូតវៀតណាមដដែល។ ខ្លឹមសារលម្អិត អំពីការព្យាយាមធ្វើទំនាក់ទំនងនេះមានរៀបរាប់ នៅក្នុងរបាយការណ៍អនុវត្តបញ្ចប់ដីកាចាត់ឱ្យស៊ើបសួរជំនួស[3529]។

៨៣៥. ដោយសារមិនមានចម្លើយតបជាផ្លូវការណាមួយ ពីស្ថានទូតវៀតណាម ចំពោះការព្យាយាមទំនាក់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ទំនងជាច្រើនលើកច្រើនសា សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា លទ្ធភាពដែលរដ្ឋាភិបាលវៀតណាមនឹងធ្វើការសហការ និងផ្តល់ការអនុញ្ញាតឱ្យធ្វើដំណើរទៅកាន់ទីកន្លែងដែលអាចជាទីកន្លែងឧក្រិដ្ឋកម្ម ដែលឋិតក្នុងទឹកដីវៀតណាមមានកម្រិតទាបណាស់ ។ ដូច្នេះ រាល់ការស៊ើបអង្កេតផ្សេងៗ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិនៅក្នុងទឹកដីវៀតណាម គឺមានព្រំដែនកម្រិតដោយសារតែមិនអាចមានលទ្ធភាពក្នុងអំឡុងពេលស៊ើបសួរ ដើម្បីធ្វើទស្សនកិច្ចដល់ទីកន្លែង ដែលត្រូវបានចោទថាមានការវាយប្រហារ ហើយថែមទាំងមិនអាចធ្វើការសម្ភាសន៍សាក្សីដែលមកពីទីកន្លែងនោះបានដែរ។

**៨៣៦.** ទោះជាមានការលំបាកបែបនេះក៏ដោយ សហចៅក្រមស៊ើបអង្កេតក៏នៅតែបន្តការស៊ើបសួររបស់ខ្លួនដែរ និងបានកត់សម្គាល់ឃើញថា កងទ័ពបដិវត្តកម្ពុជាទំនងជាបានធ្វើការលុកលុយចូលទៅក្នុងទឹកដីនៃប្រទេសវៀតណាមនៅពាក់កណ្តាល និងចុងឆ្នាំ១៩៧៧[3530]។ នៅអំឡុងពេលនៃការចូលលុកលុយនេះកងទ័ពបដិវត្តកម្ពុជាបានសម្លាប់ប្រជាជនស៊ីវិល ដុតផ្ទះសំបែង និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានទទួលយ៉ាងទៀងទាត់ នូវសារទូរលេខយោធាពីមេបញ្ជាការកងទ័ពបដិវត្តកម្ពុជាពីសមរភូមិមុខ គ្រប់ទីកន្លែងដែលរាយការណ៍ អំពីការវិវឌ្ឍន៍នៃប្រតិបត្តិការយោធា និង រង់ចាំទទួលយកបទបញ្ជា។ បន្ថែមពីនេះទៀត រដ្ឋាភិបាលវៀតណាមនៅទីក្រុងហាណូយបានធ្វើពាក្យបណ្តឹងទៅកាន់អគ្គរដ្ឋទូតនៃកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសវៀតណាម ឈ្មោះ ហេង សុខខេង ហៅ ឈាន ទាក់ទងនឹងឧក្រិដ្ឋកម្មដែលកំពុងតែត្រូវបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជាប្រឆាំងនឹងប្រជាជនស៊ីវិលវៀតណាមនៅទីកន្លែងជាច្រើន។ ឈាន បានរាយការណ៍បញ្ហានេះទៅមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងស្នើសុំការណែនាំ។ ភស្តុតាងខាងក្រោមបង្ហាញថា ជនស៊ីវិលត្រូវបានគេសម្លាប់នៅ ហាជៀន ខេត្តគៀនយ៉ាង ខេត្តអានយ៉ាង និងនៅផ្សារក្រដាស់ និង ទីកន្លែងផ្សេងទៀតនៅខេត្តតៃនីញ។

**៨៣៧.** សារទូរលេខមួយចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៧ ត្រូវបានចម្លងជូនឱ្យ **នួន ជា** និង **អៀង សារី** បានរាយការណ៍ថា *"កងទ័ពកម្ពុជាសម្លាប់រង្គាលអស់ប្រជាជនវៀតណាមចំនួន១.០០០នាក់ (មួយពាន់នាក់) នៅហាជៀន ខេត្តគៀនយ៉ាង"*[3531]។ សារទូរលេខមួយទៀតចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ក៏បានចម្លងជូនទៅឱ្យ **នួន ជា** និង **អៀង សារី** ទាក់ទងនឹងការវាយប្រហារដោយកងទ័ពបដិវត្តកម្ពុជានៅហាទៀង *"បានកាប់សម្លាប់ ដុតបំផ្លាញផ្ទះសំបែង បណ្តាលឱ្យខូចខាតយ៉ាងសំបើម"*។ សារទូរលេខនោះបានបន្ថែមទៀតថា *"ការដែលកងទ័ពកម្ពុជាបំពាបំពាន និងកាប់សម្លាប់ ដុតកំទេច*

*គេមិនមែនលើកឡើងដោយតាមតែរាយការណ៍ទេ គឺសុទ្ធតែមានភស្តុតាងច្បាស់ មិនអាចប្រកែកបាន"* [3532]។

៨៣៨. សារទូរលេខផ្សេងទៀតបានរៀបរាប់ថា *"កងទ័ពយើងល្បាតពានទៅតែនិញកំឡុងខែ៩-៧៧ កន្លងមក កាប់សម្លាប់វង្គាលប្រជាជនគេជាង ១.០០០នាក់"* [3533]។ ក្នុងអំឡុងដំណើរការនីតិវិធីនៃសំណុំរឿងខុច(លេខ០០១) ចំពោះមុខអង្គជំនុំជម្រះ លោក [លុប] បានផ្តល់នូវសក្ខីកម្មជាអ្នកជំនាញទាក់ទងនឹងសក្ខីកម្មផ្ទាល់ខ្លួន ចំពោះលទ្ធផលរបស់កងទ័ពបដិវត្តកម្ពុជា ក្នុងការវាយប្រហារនៅតៃនិញ និងហាជៀន និង ការប្រទះឃើញនូវការស្លាប់របស់ជនស៊ីវិល រួមទាំងស្ត្រី និងកុមារ[3534]។

៨៣៩. បន្ថែមពីនេះទៀត ការសម្លាប់ប្រជាជនវៀតណាមនៅ ខេត្តអានយ៉ាង ដោយកាំភ្លើងត្បាល់របស់កងទ័ពបដិវត្តកម្ពុជាត្រូវបានរាយការណ៍ទៅមជ្ឈិមដែលរួមមាន៖ **នួន ជា** និង **អៀង សារី**[3535]។ ម្យ៉ាងទៀត ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់នូវពត៌មានទាក់ទងនឹងការវាយប្រហាររបស់កងទ័ពបដិវត្តកម្ពុជានៅខេត្តអានយ៉ាង[3536]។ ជាចុងបញ្ចប់ អតីតកងទ័ពបដិវត្តកម្ពុជាម្នាក់បានផ្តល់ភស្តុតាងថា អំឡុងពេលនៃការប្រយុទ្ធនៅផ្សារក្រដាសក្នុងខេត្តតៃនីញ នាដើមឆ្នាំ១៩៧៧ គាត់ត្រូវបានគេបញ្ជាឱ្យបាញ់ និងសម្លាប់ជនជាតិវៀតណាមចោលតែម្តង *"ទោះជាលើកដៃក៏ដោយ"* ហើយបានបន្ថែមថា *"ចំណែកកងទ័ពវៀតណាម និងប្រជាជនវៀតណាមស្លាប់អស់ ប្រហែលរាប់រយនាក់"*[3537]។

៨៤០. មានភស្តុតាងដែលបង្ហាញថា កងទ័ពបដិវត្តកម្ពុជាបានដុតផ្ទះសំបែង និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅអំឡុងពេលចូលលុកលុយក្នុងទឹកដីនៃប្រទេសវៀតណាម[3538]។ ការប្រយុទ្ធត្រូវបានគេរាយការណ៍ទៅមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា តាមរយៈសារទូរលេខកងទ័ពធ្វើដោយ មេបញ្ជាការកងទ័ពបដិវត្តកម្ពុជា[3539]។ អតីតកងទ័ពបដិវត្តកម្ពុជាម្នាក់បានរៀបរាប់នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតអំពីការប្រយុទ្ធនៅខេត្តតៃនីញ នាពាក់កណ្តាលឆ្នាំ១៩៧៨។ គាត់បាននិយាយថាក្រុមរបស់គាត់ជាក្រុមវាយឆ្អក់ ដែលមានចំនួនប្រហែល ២០០ នាក់ ត្រូវបានបញ្ជាឱ្យចូលទៅក្នុងភូមិ និង *"បំផ្លាញខ្ទេច ដុតខ្ទេច"* និងដើម្បីឆ្លើយតបទៅនឹងបទបញ្ជា គាត់ *"បានបោះគ្រាប់បែក និងដុតផ្ទះ មន្ទីរពេទ្យកងទ័ព ឃ្លាំងរំសេវ រោងចក្រអារឈើ"*[3540]។ អតីតកងទ័ពបដិវត្តកម្ពុជាម្នាក់ទៀតបាននិយាយថា គាត់ក៏ត្រូវបានគេបញ្ជាឱ្យ *"ដុតបំផ្លាញផ្ទះសម្បែង*

*ទាំងស៊ីវិល ទាំងទាហាន*" អំឡុងពេលប្រយុទ្ធនៅផ្សារក្រដាស[3541]។ ជនស៊ីវិលត្រូវបានគេសម្លាប់ផងដែរ នៅអំឡុងពេលនៃការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនោះ[3542]។

***

៨៤១. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៨នាក់ (ហុកសិបប្រាំបីនាក់) ត្រូវបានប្រកាសទទួលស្គាល់នៅក្នុងបរិបទនៃ "ប្រព្រឹត្តកម្ម លើជនជាតិវៀតណាម"[3543]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់មានភស្តុតាងគ្រប់គ្រាន់ ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរអោយជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្តឹងរប្បវេណីទាំងនេះ បានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តជាបឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃប្រពឹត្តកម្មលើជនជាតិវៀតណាម។

## ខ. ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍[3544]

### ជីវប្រវត្តិរបស់បុគ្គលដែលត្រូវរៀបការ

៨៤២. ទាំងបុរស[3545] និងស្ត្រី[3546] ត្រូវបានរៀបការដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេភាគច្រើនមានអាយុខ្ទង់២០ ឆ្នាំ នៅពេលរៀបការ[3547] ពេលខ្លះគូស្រករមានអាយុទាបជាងនេះ[3548] ពេលខ្លះលើសពីនេះ[3549] ហើយលើសពីនេះទៅទៀត អតីតកម្មាភិបាល ប.ក.ក ខ្លះបានឱ្យដឹងថា បុគ្គលគ្រប់រូបដែលអាចមានសមត្ថភាពរៀបការ និងជាគោលដៅថានឹងត្រូវរៀបការ គឺនៅពេលចាប់ពីអាយុ២០ឆ្នាំឡើងចំពោះស្ត្រី និងចាប់ពីអាយុពី២៥ឆ្នាំឡើងសម្រាប់បុរស[3550]។ សាក្សីមួយចំនួន ដែលត្រូវបានរៀបការដោយបង្ខំមានទាំងអតីតព្រះសង្ឃដែលត្រូវបានគេចាប់ផ្សឹកផងដែរ[3551]។ សាក្សីផ្សេងទៀតដែលធ្លាប់បានរៀបការម្តងហើយ បានរៀបការម្តងទៀតដោយសារតែ ប្តី ឬប្រពន្ធរបស់ពួកគាត់បានបាត់ខ្លួន[3552]។

### ភាពកើតឡើងជាញឹកញាប់នៃការរៀបការ

៨៤៣. ដោយសារការរៀបការធ្វើឡើង មានកាលបរិច្ឆេទកំណត់ច្បាស់លាស់ បង្ហាញឲ្យឃើញថា ទំនងជា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

មានការរៀបការដោយបង្ខំត្រូវបានធ្វើឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា[3553]។ ចំពោះពេលវេលាបន្ទាប់មក សាក្សីជាច្រើនបានបញ្ជាក់ថា ការរៀបការដោយបង្ខំត្រូវបានធ្វើឡើងគ្រប់ពេលនៅក្នុងរបបនោះ[3554] និងនៅស្ទើរតែគ្រប់ភូមិភាគ[3555]។

៨៤៤. នៅទូទាំងប្រទេស ប្រជាជនត្រូវបានរៀបការជាទូទៅដោយរៀបចំពិធីរួមគ្នា[3556] ដែលផ្គុំគ្នាចាប់ពីពីរ[3557] ទៅដល់លើសពីមួយរយគូ[3558] សាក្សីភាគច្រើនបានផ្តល់ភស្តុតាង អំពីការរៀបចំពិធីរួមគ្នារវាង ដប់ទៅហុកសិបគូ[3559]។ ឌុច បានរៀបរាប់ថា ការរៀបការរបស់គាត់ធ្វើឡើងផ្ទុយពីគោលការណ៍ដែលអនុវត្តនៅក្នុងសម័យនោះ ពីព្រោះថា ការរៀបចំពិធីត្រូវបានប្រារព្ធឡើងដោយគ្មានវត្តមានរបស់គូស្រករផ្សេងទៀតឡើយ[3560]។ សាក្សីម្នាក់បានថ្លែងថា នៅពេលរៀបការ គេធ្វើឡើងច្រើនគូដើម្បីកុំឲ្យខាតបង់ធនធាន[3561]។

**តួនាទីរបស់កម្មាភិបាល**

៨៤៥. អតីតលេខាតំបន់ម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យបានពន្យល់ថា នយោបាយនៃការរៀបការជាក្រុមត្រូវបានសម្រេចឡើងដោយថ្នាក់លើ ដោយបញ្ជាក់ថា គាត់ធ្លាប់ចូលរួមកិច្ចប្រជុំមួយ ដែលនៅពេលនោះ ប៉ុល ពត បាននិយាយថា *"ឲ្យរៀបការជាគូៗ ពីរបីគូ ក៏រៀបការបានដែរ កុំឲ្យលំបាកពេក"*[3562]។ សាក្សីម្នាក់បានរៀបរាប់ថា ការរៀបការរបស់គាត់ត្រូវបានរៀបចំដោយថ្នាក់ដឹកនាំផ្ទាល់របស់គាត់នៅក្នុងក្រសួងសង្គមកិច្ច ហើយ អៀង ធីរិទ្ធិ បានប្រាប់សាក្សីថា គាត់ចង់ឲ្យសាក្សីរៀបការជាមួយអ្នកផ្សេងទៀត[3563]។ សាក្សីម្នាក់ដែលធ្លាប់បានធ្វើការនៅមន្ទីរសន្តិសុខគោកក្តួចបានរៀបរាប់ថា នៅក្នុងតំបន់៥០៥ បើអ្នកជាប់ទោសពី "អំពើខុសសីលធម៌" ជាមេម៉ាយឬពោះម៉ាយ ឬនៅលីវ ពួកគេត្រូវបានរៀបការឲ្យតែម្តងដែលជាការអនុវត្តន៍នយោបាយរបស់ថ្នាក់លើ[3564]។ អតីតលេខាស្រុកម្នាក់បានអះអាងថា ពួកគេអាចបដិសេធមិនរៀបការបាន ហើយថាទោះបីជាការរៀបការត្រូវបានធ្វើឡើងទៅតាមសេចក្តីសម្រេចរបស់ថ្នាក់លើក៏ដោយ នេះមិនមែនជាការ"រៀបការដោយបង្ខំទេ"។ ប៉ុន្តែ គាត់បានទទួលស្គាល់ថា ក្នុងការអនុវត្តន៍ជាក់ស្តែងគាត់ជាអ្នកសម្រេចផ្គូរផ្គងគូស្រករតាមរយៈ "ការមើលប្រវត្តិរូប"របស់ពួកគេ។ បន្ទាប់មកសេចក្តីសម្រេចត្រូវបានប្រកាសដោយគណៈស្រុក។ គូស្រករមិនហ៊ានបដិសេធចំពោះការផ្គូរផ្គងរបស់គាត់ឡើយ ដោយខ្លាចត្រូវបានគេសម្លាប់។ ម្យ៉ាងវិញទៀត គាត់បានចង្អុលបន្ថែមថា អ្នកត្រូវ

00605527



រៀបការត្រូវបានគេប្រាប់ថា ពួកគេអាចមានសេរីភាពក្នុងការលែងលះគ្នា ប៉ុន្តែតាមការពិត គូរស្រករដែលបែកផ្លូវគ្នានោះច្បាស់ជា"មានបញ្ហា" ហើយត្រូវបានគេបញ្ជូនទៅការដ្ឋាន[3565]។

៨៤៦. សាក្សីភាគច្រើនបានលើកឡើងថា ការរៀបការត្រូវបានរៀបចំឡើង ដោយបុគ្គលផ្សេងដែលមិនមែនជាសាមីខ្លួនផ្ទាល់ ឬក្រុមគ្រួសាររបស់ពួកគេឡើយ។ សាក្សីមួយចំនួនបានបង្ហាញថា ការរៀបការត្រូវបានរៀបចំឡើងដោយ"អង្គការ"[3566] "ប៉ុល ពត"[3567] ឬ"ខ្មែរក្រហម"[3568]។ សាក្សីមួយចំនួនបានបញ្ជាក់ថា ការរៀបការត្រូវបានរៀបចំឡើងដោយអ្នកតំណាងរបស់កម្មាភិបាលមូលដ្ឋានដូចជា៖ ប្រធានកង លេខាស្រុក គណៈឃុំ ប្រធានភូមិ ប្រធានសហករណ៍។ល។[3569]

### គោលការណ៍អនុវត្តក្នុងការជ្រើសរើសគូស្រករ

៨៤៧. ឌុច បានរៀបរាប់ថា មានគោលនយោបាយក្នុងបំណងចង់ឲ្យការរៀបការគោរពទៅតាមរូបមន្ត "១+១=២"។ មានន័យថា គេត្រូវតែរៀបការជាមួយនឹងបុគ្គលណាដែលមានឋានៈដូចគ្នា ដោយពិចារណាទៅលើសមាជិកភាពបក្សរបស់ពួកគេ និងឋានៈក្នុងសង្គមរបស់ពួកគេ[3570]។ ទាំងនេះគឺស៊ីសង្វាក់គ្នាទៅនឹងសាក្សីផ្សេងៗទៀត ដែលមកពីភូមិភាគផ្សេងៗ[3571]។ សាក្សីម្នាក់ក្នុងចំណោមនោះបានបញ្ជាក់ថា បុគ្គលដែលធ្លាប់បានរៀបការជាមួយនឹងជនបរទេស ត្រូវបានរៀបការម្តងទៀតជាមួយនឹងប្រជាជនខ្មែរ[3572]។

៨៤៨. នៅពេលដែលអង្គភាពទ័ពចង់រៀបការឲ្យកងទ័ពរបស់ខ្លួន ទំនងជាគេរើសស្ត្រីនៅតាមភូមិ[3573] ហើយពិធីរៀបការរបស់កងទ័ពទាំងនោះត្រូវបានរៀបចំឡើងដោយការពាក់លេខ ៖អនាគតគូស្រករដែលពាក់លេខ១ ត្រូវបានសន្មតថា ត្រូវរៀបការជាមួយគូដែលមានពាក់លេខ ១ ។ល។[3574] សាក្សីខ្លះទៀតក៏បានលើកឡើងពីការរៀបការនារីជាមួយនឹងកងទ័ពពិការ[3575]។ សាក្សីម្នាក់បានបន្ថែមទៀតថា បើនារីណាមិនព្រមរៀបការគេគំរាមថា "គេនឹងយកជនពិការដែលជាកងទ័ពឲ្យមករៀបការជាមួយ"[3576]។

### ស្ថានភាពចាប់បង្ខំ

៨៤៩. សាក្សីភាគច្រើនបាននិយាយថា ពួកគេត្រូវបានគេបង្ខំ[3577] និង/ឬ ពួកគេមិនហ៊ានជំទាស់នឹងគោល-បំណងរបស់"អង្គការ"ទេ[3578]។ គេដឹងថា តាមគោលការណ៍ទូទៅ គូស្រករដែលត្រូវបានគេផ្សំផ្គុំមិន

ធ្លាប់បានស្គាល់អនាគតប្តីឬប្រពន្ធរបស់ខ្លួនឡើយមុនពេលរៀបការ[3579] និងមិនមានអំណាចក្នុងការសម្រេចចិត្តជ្រើសរើសគូស្រករដោយខ្លួនឯងឡើយ[3580]។ សាក្សីខ្លះបាននិយាយថា គេបានរៀបការជាមួយបុគ្គលដែលត្រូវបានគេផ្សំផ្គុំឱ្យ ទោះបីជាស្រលាញ់ ឬមិនស្រលាញ់យ៉ាងណាក៏ដោយ[3581] ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបញ្ជាក់ថា គាត់មិនហ៊ានជំទាស់ទេ ពីព្រោះគាត់មិនដឹងថាត្រូវគេចទៅណា[3582]។ សាក្សីម្នាក់ទៀតត្រូវបានគេបញ្ជូនទៅកន្លែងអប់រំ ដោយសារគាត់បដិសេធមិនព្រមរៀបការនាពេលដំបូង ហើយគាត់លែងហ៊ានជំទាស់ហើយនាពេលក្រោយមក ។ល។[3583] ទោះបីជាបុគ្គលមួយចំនួនបានព្យាយាមប្រកែកក៏ដោយ[3584] សាក្សីផ្សេងទៀតបានថ្លែងថា បើសិនជាយើងបដិសេធមិនព្រមរៀបការ "ត្រូវគេបញ្ជូនទៅកងចល័ត[3585]ឬទៅការដ្ឋាន"[3586] "ត្រូវគេដកចេញពីអង្គភាព"[3587] ឬបញ្ជូនទៅជំរុំដើម្បី"កសាង" [3588] ឬ"ត្រូវបាត់ខ្លួន" (មានន័យថា យកទៅសម្លាប់ចោល)[3589] ឬត្រូវបានចោទថា ជា "ជនក្បត់"[3590] ឬត្រូវបានគេ "កម្ទេច ឬសម្លាប់ដោយអង្គការ"[3591]។ សាក្សីផ្សេងទៀតបានប្រាប់ថា ពួកគេមិនហ៊ានជំទាស់ទេ[3592] ដោយបានបញ្ជាក់ថា មានបុគ្គលខ្លះបានធ្វើអត្តឃាត ដោយការលោតទឹកសម្លាប់ខ្លួន ឬផឹកថ្នាំពុល[3593]។

៨៥០. សាក្សីមួយចំនួនបានបញ្ជាក់ពីភាពភ័យខ្លាចត្រូវបានគេសម្លាប់[3594]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានរៀបរាប់ថា បងស្រីទាំងពីររបស់គាត់ត្រូវបានគេបង្ខំឱ្យរៀបការ ជាមួយកម្មាភិបាល ប.ក.ក ទោះបីជាពួកគាត់បានព្យាយាមគេចវេសពីការរៀបការដោយកុហកថាមានជម្ងឺក៏ដោយ។ គាត់បានបន្ថែមថាក្រោយមកបងស្រីគាត់ទាំងពីរត្រូវបានសម្លាប់ដោយកម្មាភិបាល ប.ក.ក ព្រមជាមួយនារីៗដ៏ទៃទៀតដែលបដិសេធមិនព្រមរៀបការ[3595]។ សាក្សីផ្សេងទៀតបានរៀបរាប់ថា បើបុគ្គលណាទាមទារជ្រើសរើសដោយខ្លួនឯងអ្នកដែលត្រូវរៀបការជាមួយ បុគ្គលនោះនឹងត្រូវយកទៅសម្លាប់ចោល[3596]។

៨៥១. ក៏ប៉ុន្តែ មានករណីមួយចំនួនដែលបុគ្គលអាចបដិសេធបានដោយជោគជ័យចំពោះការរៀបការរបស់ពួកគេ[3597]។ សាក្សីម្នាក់បានរៀបរាប់ថា នៅក្នុងកងគាត់ កងនារីបានបដិសេធជាក្រុមចំពោះការរៀបការដែលស្នើដោយកងយុវជន[3598]។ សាក្សីម្នាក់បាននិយាយទៀតថា បើសិនជាពួកនារីមិនព្រមរៀបការ "ទុកឱ្យពួកគេ"នៅក្នុងវរៈនោះទៅ ហើយមិនត្រូវបង្ខំឱ្យពួកគេរៀបការនោះទេ[3599]។ អតីតព្រះសង្ឃមួយអង្គដែលគេចាប់ផ្សឹកបានពន្យល់ថា គាត់បានប្រកែកច្រើនលើកច្រើនសា តែគាត់មិនត្រូវបានគេដាក់ទណ្ឌកម្មចំពោះការបដិសេធនេះឡើយ[3600]។

៨៥២. ដូចគ្នាផងដែរ សាក្សីមួយចំនួនបាននិយាយថា យុវនារី យុវជន អាចមានជម្រើសក្នុងការជ្រើសរើសបុគ្គលដែលជាអនាគតគូស្រករបស់ខ្លួនបាន ដោយធ្វើសំណើទៅកម្មាភិបាល ដើម្បីអាចរៀបការជាមួយបុគ្គលណាម្នាក់បាន[3601]។ សាក្សីម្នាក់បានបញ្ជាក់ថា គាត់សាកល្បងប្រកែកមិនព្រមរៀបការជាមួយអនាគតភរិយាដែលគេជ្រើសរើសឱ្យគាត់ ព្រោះគាត់បានស្រលាញ់នារីម្នាក់ផ្សេងទៀត ក្រោយមកគេអនុញ្ញាតឱ្យរៀបការជាមួយនឹងមនុស្សដែលគាត់ពេញចិត្ត[3602]។

៨៥៣. នៅក្នុងការសួរយកចម្លើយមួយ ឌុច បានចង្អុលបង្ហាញថា ទោះបីជាសំណើសុំរៀបការចេញមកពីកម្មាភិបាលបក្សណាម្នាក់ក៏ដោយ ក៏សំណើនេះត្រូវបានសួរបញ្ជាក់ទៅអនាគតប្ដី ប្រពន្ធទាំងពីរ ដើម្បីឱ្យច្បាស់ថា ពួកគេពិតជាចង់រៀបការមែន[3603]។ សាក្សីម្នាក់ទៀតដែលជាអ្នកផ្សំផ្គុំបាននិយាយថា ពួកគេភាគច្រើនមានការពេញចិត្ត ហើយបញ្ជាក់ថា ចំពោះអ្នកដែលមិនពេញចិត្ត “យើងហៅមកអប់រំសតិ-អារម្មណ៍” ក្រោយមកពួកគេក៏បានព្រមព្រៀងរៀបការ[3604]។ សាក្សីជាច្រើនផ្សេងទៀតបានអះអាងថា បុគ្គលដែលត្រូវបានគេផ្សំផ្គុំឱ្យរៀបការ ក៏មានសេរីភាពមួយចំនួនក្នុងការជ្រើសរើសដែរ[3605]។

**ការប្រារព្ធពិធីរៀបការ**

៨៥៤. សាក្សីភាគច្រើនបានលើកឡើងថា ការរៀបការបានប្រារព្ធធ្វើឡើងនៅកន្លែងផ្សេងៗគ្នាដូចជា៖ នៅក្នុងអគារផ្លូវការ (មន្ទីរស្រុក[3606] មន្ទីរបក្ស[3607] អង្គភាពយោធា[3608] រោងបាយសហករណ៍[3609] មន្ទីរពេទ្យ[3610] កន្លែងប្រជុំ[3611]។ល។) ឬនៅទីកន្លែងសាធារណៈ (បេនឡាន[3612] វាលស្រែ[3613] ការដ្ឋាន[3614] ក្នុងសហករណ៍[3615]។ល។) សាក្សីមួយចំនួនបាននិយាយអំពីពិធីរៀបការដែលបានរៀបចំឡើងនៅក្នុងវត្ត[3616]។

៨៥៥. ការប្រារព្ធពិធីរៀបការត្រូវបានធ្វើឡើង ដោយគោរពទៅតាមពិធីមួយចំនួន។ សាក្សីបាននិយាយថា ពួកគេត្រូវបានគេចែកសំលៀកបំពាក់ខ្មៅ និងក្រមាបង់កថ្មី[3617] ហើយគូស្រករត្រូវបានគេឱ្យធ្វើការទាក់ទងគ្នាដោយអង្គុយ[3618] ឬក៏ឈរ[3619]ទន្ទឹមគ្នា ឬកាន់ដៃគ្នា[3620] និងធ្វើការប្ដេជ្ញាចិត្ត[3621] ថារស់នៅជាមួយគ្នាជាប្ដី ប្រពន្ធ[3622] និង ខិតខំធ្វើការដោយដើរតាមមាគ៌ារបស់“អង្គការ”[3623] និង ខិតខំបម្រើបដិវត្តន៍[3624]។ អ្នកផ្សេងទៀតបានលើកឡើងថា គូស្រករត្រូវដើរក្បួននៅក្រោម ទង់ជាតិ[3625] និងសូត្រប្រវត្តិរូបរបស់ប្ដី ឬប្រពន្ធខ្លួន[3626]។ សាក្សីខ្លះនិយាយថា មិនមានការរៀបចំពិធីរៀបការតាមប្រពៃណីខ្មែរឡើយ[3627] ដូចជាគ្មានការចូលរួមពីព្រះសង្ឃជាដើម[3628]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៨៥៦. ចំពោះបុគ្គលដែលមកចូលរួមពិធីរៀបការ សាក្សីភាគច្រើនបានចង្អុលថា ពេលរៀបការនោះ អ្នកដែលមានវត្តមានគឺមានតែគូស្រករផ្សេងទៀត និងបុគ្គលដែលផ្តួចផ្តើមក្នុងការរៀបចំពិធី ដោយអត់មានវត្តមានរបស់សមាជិកគ្រួសារទេ ហើយជាពិសេសគឺ ឪពុកម្តាយ[3629]។ ប៉ុន្តែ មានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បាននិយាយថា គាត់ត្រូវបានគេអនុញ្ញាតឲ្យសម្រាកបីថ្ងៃ ជាមួយឪពុកម្តាយបន្ទាប់ពីពិធីរៀបការរួច[3630]។ ផ្ទុយពីនេះ សាក្សីម្នាក់ទៀតបានប្រាប់ថា ថ្ងៃរៀបការនោះគ្មានពិធីជប់លៀងអីទេ ហើយថា បន្ទាប់ពីរៀបការរួច ប្តី ប្រពន្ធដើរទៅនៅផ្ទះរបស់គេរៀងៗខ្លួន[3631]។

៨៥៧. សាក្សីម្នាក់ដែលប្រកែកថា មិនដែលឃើញមានការរៀបការដោយបង្ខំ និងការរៀបការជាក្រុមនោះ បានបញ្ជាក់ថា មានការចូលរួមពីក្រុមគ្រួសារនៅក្នុងពិធីរៀបការដែរ[3632]។ យោងតាមសាក្សីម្នាក់ផ្សេងទៀត ប៉ុល ពត ធ្លាប់បានអះអាងថា ក្រុមគ្រួសារត្រូវតែចូលរួមក្នុងការរៀបការ[3633]។ សាក្សីមួយចំនួនបានរៀបរាប់ថា ការរៀបការមានការរៀបចំម្ហូបរួមគ្នា[3634]។ ទោះបីជាយ៉ាងណាក៏ដោយ ឌុច បាននិយាយថា គ្រួសាររបស់គាត់និងគ្រួសាររបស់ប្រពន្ធគាត់ (ដែលគាត់ត្រូវបានគេអនុញ្ញាតិឲ្យជ្រើសរើសដោយខ្លួនឯង) ត្រូវបានគេអនុញ្ញាតឲ្យចូលរួមក្នុងពិធីរៀបការរបស់គាត់។ នេះជាករណីយោគយល់ ដោយសារគាត់ជាកម្មាភិបាលជាន់ខ្ពស់ ប៉ុន្តែគាត់បានទទួលស្គាល់ថា នាពេលនោះ គាត់មិនហ៊ានទាំងនិយាយឲ្យនរណាដឹងផង អំពីបំណងប្រាថ្នារបស់គាត់ ដែលចង់ឲ្យម្តាយឡើងឲ្យពរនៅអំឡុងពិធីរៀបការ[3635]។

**ដំណាក់កាលបន្ទាប់ពីការរៀបការ**

៨៥៨. ទាក់ទងទៅនឹងការផ្សំដំណេក ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បាននិយាយថា គាត់មិនហ៊ានបដិសេធក្នុងការរួមដំណេកជាមួយនឹងប្តីគាត់បានទេ ដោយសារខ្លាចមេកងវាយ ព្រោះគាត់ធ្លាប់បានឃើញអំពើទាំងនេះបានកើតឡើង ចំពោះស្ត្រីផ្សេងទៀតនៅក្នុងកងរបស់គាត់[3636]។ សាក្សីផ្សេងទៀតបាននិយាយថា ការរួមដំណេកត្រូវបានឃ្លាំមើលដោយកងឈ្លប[3637]។ សាក្សីម្នាក់ទៀតបានចង្អុលបង្ហាញថា កម្មាភិ-បាល ប.ក.ក បានប្រាប់ថា អ្នកដែលមិនព្រមរួមដំណេក ក្រោយពីរៀបការនឹងត្រូវបានគេបញ្ជូនយកទៅឃុំឃាំង[3638]។ បុគ្គលមួយចំនួនបានធ្វើអត្តឃាតដោយសារមូលហេតុនេះ[3639]។ សាក្សីផ្សេងទៀតបានរៀបរាប់ថា ក្រោយមកបីថ្ងៃបន្ទាប់ពីរៀបការរួច មេកង

បានប្រាប់គាត់ឱ្យនៅជាមួយប្ដីរបស់គាត់។ គាត់ខ្លាចប្ដីរបស់គាត់ណាស់ ហើយមានពួកឈ្លបនៅលបស្ដាប់នៅក្រោមផ្ទះ ដែលនាំឱ្យគាត់ត្រូវតែបង្ខំចិត្តរួមដំណេកជាមួយនឹងប្ដីគាត់[3640]។ សាក្សីម្នាក់ផ្សេងទៀតនិយាយថា មិនមានឈ្លបចាំស៊ើបការណ៍នៅក្រោមផ្ទះនោះទេ[3641]។ ឌុច បានបន្ថែមទៀតថា៖ "*តាមខ្ញុំដឹង មិនមានវិធានការដាក់លាក់ដើម្បីតាមដាននោះទេ ប៉ុន្តែ មានកម្មាភិបាលខ្លួចមួយចំនួន បានបញ្ជាឱ្យគេទៅតាមដានមើលថា តើប្ដីប្រពន្ធមានបានរួមដំណេកជាមួយគ្នាដែរឬទេ។ ចំនុចនេះ គឺមិនទាក់ទងនឹងបញ្ហានៃការរៀបការដោយបង្ខំនោះទេ។ ខ្ញុំចាំករណីមួយនៃមិត្ត យ៉ាង ដែលជាលេខាកងវរៈសេនាធំ ក្រោយមកជាប្រធានគណៈកម្មាធិការមន្ទីរពេទ្យយោធា ៩៨ ដែលបានបញ្ជាឱ្យកូនចៅគាត់ ទៅតាមដានប្ដីប្រពន្ធ ថាតើពួកគេមានបានរួមដំណេកជាមួយគ្នាដែរ ឬក៏អត់។ គាត់ត្រូវបានគេដាក់ទណ្ឌកម្មដោយសារបានធ្វើបែបនេះ។ ជាដំបូងគាត់ត្រូវសុំទោសប្ដីប្រពន្ធនោះ បន្ទាប់មកដោយសារមានចំនុចផ្សេងទៀតដែលត្រូវស្ដីបន្ទោសគាត់ គាត់ត្រូវបានចាប់ខ្លួន បញ្ជូនទៅស២១ និងសម្លាប់ចោល*"។[3642]

៨៥៩. ទាក់ទងនឹងការដែលប្ដីប្រពន្ធត្រូវស្នាក់នៅជាមួយគ្នាបន្ទាប់ពីរៀបការហើយ សាក្សីមួយចំនួនបានលើកឡើងថា ពួកគេត្រូវបានគេតម្រូវឱ្យរស់នៅជាមួយគ្នាមួយរយៈពេលខ្លីបន្ទាប់ពីពិធីរៀបការ[3643] មុនពេលដែលពួកគេត្រូវឱ្យរស់នៅបែកគ្នា[3644]។ សាក្សីផ្សេងទៀតបានលើកឡើងថា ក្រោយពីរៀបការរួច ប្ដី ប្រពន្ធរស់នៅជាមួយគ្នាក្នុងរយៈពេលខ្លី បន្ទាប់មកគេតម្រូវឱ្យពួកគាត់ជួបគ្នា[3645] ម្ដងម្កាល[3646] (ជួនកាលក្នុងមួយសប្ដាហ៍ម្ដង ឬមួយខែម្ដង)។ សាក្សីផ្សេងទៀតហាក់ដូចជារស់នៅជាមួយគ្នា បន្ទាប់ពីរៀបការរួច[3647]។ សាក្សីមួយចំនួនបាននិយាយថា ពួកគេរស់នៅជាមួយគ្នារហូតមក[3648] ខណៈដែលអ្នកដទៃផ្សេងទៀតនិយាយថា បានលែងលះគ្នា។[3649]

៨៦០. សាក្សីមួយចំនួនទៀតក៏បានលើកឡើងផងដែរថា បន្ទាប់ពីរៀបការ គាត់មានកូន[3650]។

***

៨៦១. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៦៦៤នាក់ (ប្រាំមួយរយហុកសិបបួននាក់) ត្រូវបានប្រកាសទទួលស្គាល់ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ[3651]។ ពោលគឺអង្គហេតុដែលបានរៀបរាប់នៅក្នុងពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថាមានភស្តុតាងគ្រប់គ្រាន់ដោយផ្អែកទៅលើគោលការណ៍សម្មតិកម្មច្បាស់លាស់ដែលគួរឱ្យជឿជាក់បាន ស្របទៅនិងវិធាន ២៣ ស្ទួន (៤) ។ ដើមបណ្ដឹងរប្បវេណីទាំងនេះ

បានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តជា បឋមបានថា ព្យសនកម្មរបស់ពួកគាត់គឺបណ្តាល មកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយនៃការរៀបការដោយបង្ខំ។

## ផ្នែកទី ៩- តួនាទីរបស់ជនត្រូវចោទ

### ក. នួន ជា[3652]

### សាវតារ

៨៦២. នួន ជា បានចាប់ផ្តើមចូលប្រឡូកយ៉ាងសកម្មក្នុងសកម្មភាពនយោបាយ នៅចុងទសវត្សរ៍ឆ្នាំ១៩៤០ នៅពេលដែលគាត់បានធ្វើការនៅក្នុងប្រទេសថៃ។ នួន ជា បានចូលរួមជាមួយអង្គការយុវជនប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមបក្សកុម្មុយនីស្តថៃ ជាបក្សដែលគាត់បានចូលជាសមាជិកផងដែរ[3653]។

៨៦៣. បន្ទាប់មក នួន ជា បានត្រឡប់មកប្រទេសកម្ពុជា ដើម្បីចូលរួមចលនាតស៊ូរបស់បក្សកុម្មុយនីស្តឥណ្ឌូចិននៅតំបន់សំឡូត ដោយគាត់ទទួលបន្ទុកខាងឃោសនានៅក្នុងបក្ស[3654]។ នៅពេលនោះ គាត់ក៏បានទាក់ទងយ៉ាងសកម្មជាមួយពួកកុម្មុយនីស្តវៀតណាម និងសមាសភាពកុម្មុយនីស្តនៃចលនាខ្មែរឥស្សរៈ (ឆ្នាំ១៩៥០-១៩៥៣)[3655]។ គាត់នៅតែជាសមាជិកសកម្មម្នាក់ក្នុងចលនាកុម្មុយនីស្តនេះ បន្ទាប់ពីការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជា នាឆ្នាំ១៩៥១[3656]។ ចាប់ពីឆ្នាំ១៩៥១ ដល់ ឆ្នាំ១៩៥៣ គាត់បានសិក្សាវគ្គនយោបាយនៅភាគខាងត្បូងនិងភាគខាងជើងនៃប្រទេសវៀតណាម។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ជាមួយនឹងមុខរបរជំនួញផងនោះ នួន ជា ជាមេដឹកនាំម្នាក់នៃចលនាកុម្មុយនីស្តសម្ងាត់នៅទីក្រុងភ្នំពេញ[3657]។

៨៦៤. នៅខែកញ្ញា ឆ្នាំ១៩៦០ នួន ជា ត្រូវបានជ្រើសរើសជាអនុលេខាបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលក្រោយមកបានប្តូរឈ្មោះថាជា បក្សពលករកម្ពុជា និងក្រោយមកទៀតប្តូរឈ្មោះទៅជា បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ជាមួយ សាឡុត ស និង ទូ សាមុត[3658]។ នួន ជា នៅតែកាន់តំណែងជាអនុលេខា នៅពេលដែល សាឡុត ស បានក្លាយជាលេខាបក្ស បន្ទាប់ពីការបាត់ខ្លួន ទូ សាមុត នៅឆ្នាំ១៩៦២[3659]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៨៦៥. បន្ទាប់ពីការទម្លាក់សម្តេច នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ **នួន ជា** បានគេចខ្លួនចេញពីភ្នំពេញ ដើម្បីចូលរួមចលនាព្រៃម៉ាគី ជាមួយនឹងមេដឹកនាំដ៏ទៃទៀតដូចជា **សាឡុត ស, សុន សេន, តា ម៉ុក** និង **សោ ភឹម**។ មេដឹកនាំ ប.ក.ក ទាំងនេះបានបង្កើតទីស្នាក់ការកណ្តាលរបស់ពួកគេជាបន្តបន្ទាប់នៅក្នុងខេត្តផ្សេងៗមួយចំនួនដូចជា៖ ខេត្តកំពង់ធំ[3660] ខេត្តកំពង់ចាម[3661] និងខេត្តកំពង់ឆ្នាំង[3662]។

៨៦៦. ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ **នួន ជា** គឺជាអនុបញ្ញាការយោធាជាន់ខ្ពស់កងទ័ពប្រជាជននៃចលនារំដោះជាតិកម្ពុជា និងជាប្រធានផ្នែកនយោបាយរបស់កងទ័ព។ **នួន ជា** ទទួលបន្ទុកជាពិសេសផងដែរក្នុងការធ្វើការទំនាក់ទំនងជាមួយនឹងវៀតណាម[3663]។

៨៦៧. នៅដើមខែមេសាឆ្នាំ១៩៧៥ **នួន ជា** នៅជាមួយ **ប៉ុល ពត** និងមេដឹកនាំយោធា និងនយោបាយសំខាន់ៗ ផ្សេងទៀតរបស់ ប.ក.ក ដូចជា **កុយ ធួន, សោ ភឹម, តា ម៉ុក** និង **សុន សេន** រហូតដល់ការកាន់កាប់ទីក្រុងភ្នំពេញ[3664]។

៨៦៨. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **នួន ជា** ត្រូវបានគេហៅឈ្មោះខុសៗគ្នា ដោយប្រើនាមត្រកូលរបស់គាត់ **នួន** ហៅថា បង **នួន**[3665] ឬ អ៊ំ **នួន**[3666] ឬក៏ប្រើឋានៈនៅក្នុងបក្សរបស់គាត់ហៅថា (សមមិត្ត) អនុលេខា[3667]។ **នួន ជា** ត្រូវបានគេស្គាល់ឈ្មោះហៅក្រៅផងដែរថា បងទី២[3668]។

**តួនាទី និងមុខងារ**

***សមាជិកគណៈមជ្ឈិម និង សមាជិកគណៈអចិន្ត្រៃយ៍***

៨៦៩. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **នួន ជា** គឺជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម[3669]។ **នួន ជា** បានកាន់តួនាទីជាអនុលេខាមជ្ឈិមបក្ស តាំងពី១៩៦០[3670] និងត្រូវបានតែងតាំងជាអនុលេខាដដែលនៅឆ្នាំ១៩៦៣[3671]។ ក្នុងអំឡុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ **នួន ជា** នៅតែមានតួនាទីជាអនុលេខាមជ្ឈិមបក្ស[3672]។ ទោះបីជា គាត់ពិតជាបានកាន់តួនាទីនេះនៅពេញមួយរបបកម្ពុជាប្រជា


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ធិបតេយ្យក៏ដោយ គាត់ត្រូវបានប្រកាសជាសាធារណៈ ថាជាអនុលេខាគណៈមជ្ឈិម នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុណ្ណោះ ដំណាលពេលដែលអត្ថិភាពរបស់បក្សត្រូវបានប្រកាសឲ្យដឹងជាផ្លូវការ[3673]។

**៨៧០.** ក្នុងឋានៈជាអនុលេខាមជ្ឈិមបក្ស **នួន ជា** គឺជាមនុស្សទីពីរនៅក្នុងឋានានុក្រមបក្ស[3674] និង ត្រូវបានស្គាល់ថាជាបងធំទី២[3675] និងជា "*ដៃស្តាំ*" របស់ **ប៉ុល ពត**[3676]។ ក្នុងនាមជាសមាជិកពេញសិទ្ធិ **នួន ជា** អាច "*ពិគ្រោះពិភាក្សា និងរួមមតិសំរេច*" ពាក់ព័ន្ធនឹងបញ្ហាទាំងអស់[3677]។ **ឌុច** យល់ឃើញថា **នួន ជា** ជាអ្នកទទួលខុសត្រូវអនុវត្តរាល់សេចក្តីសម្រេចធ្វើឡើងដោយ **ប៉ុល ពត**[3678] ខណៈដែលកម្មាភិបាលជាន់ខ្ពស់ឈ្មោះ [លុប] ពន្យល់ថា **ប៉ុល ពត** មិនអាចសម្រេចតែម្នាក់ឯងបានទេ[3679]។ **នួន ជា** ប្រាប់នៅក្នុងបទសម្ភាសន៍មួយដែលធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យថា "*រួមគ្នាទាំងអស់ គាត់ [ប៉ុល ពត] ក៏រួមចំណែក យើងខ្ញុំក៏រួមចំណែក*"[3680] ប៉ុន្តែនៅក្នុងបទសម្ភាសន៍មួយទៀត **នួន ជា** បញ្ជាក់ថា "*ប៉ុល ពត ជាលេខាបក្ស។ គឺខ្ញុំជាអនុលេខាទេ ប៉ុន្តែអនុលេខាតាមបញ្ហាគេដែរ*"[3681]។

**៨៧១.** **នួន ជា** ក៏ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិម របស់ ប.ក.ក[3682]។ យោងតាមលក្ខន្តិកៈ ប.ក.ក បានចែងថា ក្នុងឋានៈជាលេខា និងអនុលេខានៃសាខាបក្សដែលមានសមាជិកតិចដូចជា គណៈអចិន្ត្រៃយ៍នេះ **ប៉ុល ពត** និង **នួន ជា** ទទួលខុសត្រូវចាត់ចែងការងារប្រតិបត្តិការ នៅក្នុងចន្លោះពេលពីការប្រជុំមួយទៅមួយទៀតរបស់គណៈអចិន្ត្រៃយ៍[3683]។ នៅក្នុងចំណោមកំណត់ហេតុអង្គប្រជុំចំនួន ១៩ របស់គណៈអចិន្ត្រៃយ៍ ដែលនៅសល់[3684] (មានកំណត់ហេតុចំនួន១៥ ដែលបានបញ្ជាក់ពីវត្តមានអ្នកចូលរួម[3685]) **នួន ជា** ត្រូវបានកត់ត្រាថាមានវត្តមានចំនួន ១៤ ដង[3686]។ ដូចនេះ ហាក់ដូចជាបង្ហាញថា **នួន ជា** បានចូលរួម ប្រជុំជាច្រើន ឬ ស្ទើរតែគ្រប់ពេលប្រជុំទាំងអស់។ តាមការឲ្យដឹងរបស់ **ខៀវ សំផន** គណៈអចិន្ត្រៃយ៍ជួបប្រជុំជាទៀងទាត់ប្រហែលពី ៧ ទៅ ១០ ថ្ងៃម្តង និងអាចញឹកញាប់ជាងនេះក្នុងករណីបន្ទាន់[3687]។ នៅរាល់ពេលប្រជុំនោះ **នួន ជា** ផ្តល់យោបល់ សេចក្តីណែនាំ និងបទបញ្ជាផ្សេងៗ[3688]។ វាទំនងជាថា **នួន ជា** បានដឹកនាំប្រជុំគណៈអចិន្ត្រៃយ៍នៅពេលដែល **ប៉ុល ពត** អវត្តមាន[3689]។

**៨៧២.** នៅក្នុងតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាសមាជិកគណៈមជ្ឈិម **នួន ជា** បានចូលរួម

ប្រជុំកម្រិតខ្ពស់នានារបស់ ប.ក.ក ជាទៀងទាត់ ដែលធ្វើជាប្រចាំនៅមន្ទីរ ក-១ និងមន្ទីរ ក-៣[3690] និងបានជួបប្រជុំប្រចាំខែ នៅមន្ទីរ ក-១ ជាមួយនឹងកម្មាភិបាលថ្នាក់ដឹកនាំមកពីបណ្តាភូមិភាគ តំបន់ ព្រមទាំងគណៈស្រុក ដែលការប្រជុំនេះមានរយៈពេលពី ៥ ទៅ ៦ថ្ងៃ ដោយមានកម្មាភិបាលចូលរួម ប្រហែល២០រូប[3691]។ នួន ជា ក៏បានជួបជាញឹកញាប់ នៅក្រៅទីក្រុងភ្នំពេញ ជាមួយមេដឹកនាំតំបន់ស្វយត និងមេដឹកនាំភូមិភាគ ជាពិសេសនៅពេលសន្និបាតតាមតំបន់ និង ភូមិភាគ[3692]។

### តួនាទីនៅក្នុងផ្នែកសន្តិសុខ ប.ក.ក.

#### <u>សមាជិកគណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម</u>

**៨៧៣.** នួន ជា ធ្លាប់ជាសមាជិកគណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម។ សមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការនេះត្រូវបានបញ្ជាក់ដោយ **អៀង សារី**[3693] [លុប][3694] និង សុន្ទរកថាដែលគាត់បានធ្វើឡើងនាឱកាសបុណ្យខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា ក្នុងនាមគណៈកម្មាធិការយោធារបស់ ប.ក.ក[3695]។ **ឌុច** បានប្រាប់ថា **នួន ជា** ជាសមាជិករបស់គណៈកម្មាធិការនេះ ប៉ុន្តែមិនច្បាស់លាស់ទេថា គាត់បានដឹងរឿងនេះតាំងពីសម័យនោះមក ឬទើបតែដឹងនៅពេលដែលគាត់បានចូលមើលឯកសារនៅក្នុងសំណុំរឿង[3696]។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលនោះ **ឌុច** ដឹងថា **នួន ជា** ទទួលបន្ទុកលើការងារសន្តិសុខ និងយោធា[3697]។ ។ **នួន ជា** ទទួលស្គាល់ថាពិតជាមានអង្គភាពបែបនោះមែននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងថាតួនាទីរបស់អង្គភាពនេះគឺការពារជាតិ និងបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ប៉ុន្តែបានបដិសេធដាច់អហង្ការថា គាត់មិនធ្លាប់ជាសមាជិករបស់គណៈកម្មាធិការនោះឡើយ[3698] ។

**៨៧៤.** មានភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងបានបញ្ជាក់ថា **នួន ជា** ទទួលខុសត្រូវលើកិច្ចការសន្តិសុខ ។ **ឌុច** បានអះអាងថា *"ការងារសន្តិបាលត្រូវបានសម្រេចដោយ ប៉ុល ពត ប៉ុន្តែ នួន ជា ជាអ្នកតំណាងរបស់គាត់"* [3699]។ អ្នកវាយសារទូរលេខ នៅក្នុងតំបន់ស្វយ័ត១០៥ បានពន្យល់ថា "*ចំពោះការងារសន្តិសុខវិញ អង្គលីលេខរបស់ខ្ញុំផ្ញើទៅឈ្មោះ នួន ជា*"។ គាត់បានបញ្ជាក់បន្ថែមថា "*នួន ជា បានណែនាំមកជាប្រចាំអំពីការងារសន្តិសុខ*"[3700]។ សាក្សីផ្សេងទៀតបានបន្ថែមថា **នួន ជា** ទទួលបន្ទុកលើការងារសន្តិសុខនេះ[3701]។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន **នួន ជា** បាន បញ្ជាក់ថា **សុន សេន** ទទួលខុសត្រូវលើក្រសួងការពារជាតិ និងបញ្ជាក់ថា គាត់គ្មានសមត្ថភាព

ជ្រៀតជ្រែក ឬចេញបញ្ជាទាក់ទងនឹងសន្តិសុខផ្ទៃក្នុងនោះទេ វាជាផ្នែកទទួលខុសត្រូវរបស់គណៈកម្មាធិការយោធា[3702]។

៨៧៥. ពាក់ព័ន្ធនឹងបញ្ហាយោធា អង្គភាពមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា គឺជាអគ្គសេនាធិការដែលដឹកនាំដោយ **សុន សេន** ដោយមាន **ប៉ុល ពត** ទទួលខុសត្រូវទូទៅខាងផ្នែកយោធា។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងឋានៈជាអនុលេខាមជ្ឈិមបក្ស និងជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិមបក្ស **នួន ជា** បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការយោធាជាមួយ **ប៉ុល ពត** និង **សុន សេន**។ នៅក្នុងអំឡុងពេលសួរយកចម្លើយ ឌុច បាននិយាយថា *"គ្រប់អ្វីៗទាំងអស់ត្រូវឆ្លង នួន ជា ទោះបីជាស្ថិតនៅក្នុងវិស័យយោធាក៏ដោយ"* [3703]។ នេះបង្ហាញឱ្យឃើញថា **នួន ជា** បានចូលរួមរៀបចំផែនការយោធាក្នុងការវាយប្រយុទ្ធដណ្តើមយកទីក្រុងភ្នំពេញ នាខែមេសា ឆ្នាំ១៩៧៥[3704]។ លើសពីនេះទៀត សាក្សីជាច្រើនបានបញ្ជាក់ថា **នួន ជា** ប្រើប្រាស់អំណាចទទួលខុសត្រូវខ្លះក្នុងផ្នែកយោធា ក្នុងអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យ[3705] ដូចជាឧទ្ទេសនាមវគ្គរៀនសូត្រនយោបាយដល់សមាជិកកងទ័ពបដិវត្តន៍កម្ពុជា[3706] និងតែងតាំងកម្មាភិបាលយោធា[3707]។ អ្នកកាន់ទូរស័ព្ទឱ្យ **សុន សេន** ពន្យល់ថា គ្មានទំនាក់ទំនងសារទូរលេខធ្វើឡើងរវាង **សុន សេន** និង **នួន ជា** ទេ *"ពីព្រោះពួកគេជួបធ្វើការងារជាមួយគ្នារាល់ថ្ងៃជាទូទៅ"*។ សាក្សីដដែលនេះបានរៀបរាប់ថា **នួន ជា** មិនដែលមកអគ្គសេនាធិការដែលជាកន្លែង **សុន សេន** ប្រជុំជាមួយកងពលជាប្រចាំនោះទេ[3708]។ ចំណុចនេះត្រូវបានបញ្ជាក់តាមហេតុដែលថា ពុំឃើញមានកំណត់ហេតុនៃការប្រជុំធ្វើឡើងរវាង អគ្គសេនាធិការ និងកងពលមជ្ឈិម និងកងវរៈសេនាធំឯករាជ្យនានា មានកត់ត្រាអំពីវត្តមានចូលរួមរបស់ **នួន ជា** នោះទេ[3709]។

៨៧៦. ទោះបីជាកិច្ចការនយោបាយការបរទេសមិនឋិតនៅក្នុងការទទួលខុសត្រូវចម្បងរបស់ **នួន ជា** ក៏ដោយ ក៏ **នួន ជា** បានបំពេញមុខងារមួយចំនួនទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិ។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. **នួន ជា** បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច ទាក់ទងនឹងគោលនយោបាយ និងយុទ្ធសាស្ត្រអំពីបញ្ហាព្រំដែនកម្ពុជា ព្រមទាំងស្ថានភាពជម្លោះព្រំដែនជាមួយប្រទេសវៀតណាម[3710]។ គាត់បានចូលរួមផ្តល់ជាយោបល់ និងការណែនាំច្បាស់លាស់អំពីបញ្ហាទាំងនេះ[3711]។ **នួន ជា** ធ្លាប់ចរចាជាមួយនឹង អាជ្ញាធរវៀតណាម[3712] និងបានចូលរួមនៅក្នុងការតាក់តែង "សៀវភៅខ្មៅ" ស្តីអំពីនយោបាយការបរទេសរបស់វៀតណាម[3713]។ **នួន ជា** ត្រូវបានចម្លងជូននូវទូរលេខជាច្រើន ដែលនៅសេសសល់ ដែលរាយការណ៍អំពីស្ថានភាពនៅលើសមរភូមិ និងនៅតាមព្រំដែនជាមួយវៀតណាម (ចលនារបស់ទ័ព ការវាយប្រយុទ្ធគ្នា និង

អ្នករងរបួស)[3714]។ ទូរលេខខ្លះផ្ញើមកស្នើសុំការណែនាំ ឬសុំសម្ភារៈពីមជ្ឈិម ប.ក.ក. ឬដើម្បីបញ្ជាក់ថាបានអនុវត្តការណែនាំ ឬបានទទួលសម្ភារៈ ដែលបានស្នើសុំ[3715]។ មានភស្តុតាងបង្ហាញផងដែរថា នួន ជា មានអំណាចផ្ញើសេចក្តីណែនាំទាក់ទងនឹងបញ្ហាសន្តិសុខអន្តរជាតិ ទៅឲ្យថ្នាក់ក្រោម និងបង្ហាញថា នួន ជា បានផ្ញើសេចក្តីណែនាំនោះតាមរយៈសារទូរលេខ ឬលិខិតនៅក្នុងឱកាសមួយចំនួន[3716]។

<u>មន្ទីរសន្តិសុខ ស-២១ និង ការដ្ឋាន ស-២៤ (ព្រៃស)</u>

**៨៧៧.** ក្នុងកិច្ចសម្ភាសន៍ជាច្រើនក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានពន្យល់ថា មុនឆ្នាំ ១៩៧៩ គាត់មិនបានដឹងពីមន្ទីរស-២១ នោះទេ ហើយប្រសិនបើមានឯកសារណាមួយដែលដាក់បន្ទុកលើរូបគាត់ ឯកសារទាំងនោះគឺជាឯកសារដែលគេរៀបចំឡើងតែប៉ុណ្ណោះ។ នួន ជា បានបន្ថែមទៀតថា ឌុច ធ្លាប់ធ្វើការនៅក្រសួងការពារជាតិ និងសន្តិសុខផ្ទៃក្នុង ដែលមាន សុន សេន ជាអ្នកទទួលខុសត្រូវ[3717]។ ទោះបីជាយ៉ាងណាក៏ដោយ មានភស្តុតាងយ៉ាងច្បាស់បានបង្ហាញថា នួន ជា ទទួលបន្ទុកគ្រប់គ្រងលើមន្ទីរសន្តិសុខ ស-២១ និងការដ្ឋាន ស-២៤ (ព្រៃស) របស់មន្ទីរ ស-២១[3718] ចាប់តាំងពីការបង្កើតមន្ទីរសន្តិសុខ ស-២១ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

**៨៧៨.** នៅមន្ទីរ ស-២១ ចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ដំបូង អ៊ិន លន ហៅ ណាត ជាប្រធាន និងបន្ទាប់មក ឌុច[3719] មាន សុន សេន ជាថ្នាក់លើផ្ទាល់[3720]។ ឌុច យល់ឃើញថា អំណាចរបស់ សុន សេន កើតចេញពីតួនាទីរបស់គាត់ជាសមាជិកភាពរបស់គាត់នៅក្នុងគណៈយោធាមជ្ឈិម ប.ក.ក.[3721] ពីសមាជិកភាពនៅក្នុងគណៈអចិន្ត្រៃយ៍ ប.ក.ក[3722] និងពីមុខតំណែងជានាយអគ្គសេនាធិការ[3723]។ ទោះបីជានៅក្នុងដំណាក់កាលដំបូងនោះ ឌុច មិនមានទំនាក់ទំនងដោយផ្ទាល់ណាមួយជាមួយនឹង នួន ជា ក៏ដោយ ក៏ ឌុច អាចយល់បានតាមរយៈការសន្ទនារបស់គាត់ជាមួយនឹង សុន សេន ថា នួន ជា ក្នុងឋានៈជាអនុលេខា ប.ក.ក. ហើយជាបុគ្គលទីពីរ នៅក្នុងឋានានុក្រមបក្ស ទទួលខុសត្រូវលើមន្ទីរស-២១ ពីលើ សុន សេន[3724]។ ឌុច បានបញ្ជាក់ថា *"...សុន សេន មាន នួន ជា ជាថ្នាក់លើ ហើយ នួន ជា នេះនៅក្រោម ប៉ុល ពត"*[3725] ។ មិនមានភាពច្បាស់លាស់ទេថា តើការដឹងឮ និងការយល់ដឹងរបស់ ឌុច អំពីរចនាសម្ព័ន្ធឋានានុក្រម ដែលនៅពីលើគាត់បានកើនដល់កម្រិតណា បន្ទាប់ពីគាត់បានចូលមើលឯកសារនៅក្នុងសំណុំរឿង[3726] ប៉ុន្តែមានទឡ្ហីករណ៍យ៉ាងច្បាស់ដែលអាចបញ្ជាក់បានថា នៅពេលនោះ ឌុច បានដឹងថា នួន ជា ជាថ្នាក់លើរបស់ សុន សេន ពាក់ព័ន្ធនឹងមន្ទីរ ស-២១[3727]។

៨៧៩. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ សុន សេន បានចាកចេញពីភ្នំពេញទៅកាន់សមរភូមិមុខ នៅក្នុងជម្លោះជាមួយប្រទេសវៀតណាម ហើយ នួន ជា បានហៅ ឌុច ឲ្យមកការិយាល័យរបស់គាត់ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ[3728]។ ចាប់ពីពេលនោះមក ឌុច យល់បានថាគាត់ត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា ដែលក្លាយជាថ្នាក់លើផ្ទាល់របស់គាត់[3729]។ ឌុច បញ្ជាក់ថា នួន ជា បានប្រាប់គាត់ថា *"ប្រធាននៃស-២១មិនមែនខ្ញុំ ឌុច ទេ គឺគាត់ នួន ជា ជាប្រធាន[3730]"* ។ ទោះបីជាត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា, ឌុច នៅតែរក្សាទំនាក់ទំនងជាមួយនឹង សុន សេន តាមរយៈទូរស័ព្ទ ជារៀងរាល់ពីរសប្តាហ៍ម្តង ឬមួយខែម្តង។ ថ្វីបើ ឌុច ឈប់ផ្ញើចម្លើយសារភាពទៅ សុន សេន ទៀត ហើយក៏ដោយ សុន សេន នៅតែចូលរួមតាមដានសកម្មភាពការងាររបស់មន្ទីរ ស-២១ ដដែល។ ឌុច យល់ថា សុន សេន នៅតែចាត់ទុកខ្លួនគាត់ជាថ្នាក់លើរបស់គាត់ (ឌុច)[3731]។

<u>សមាជិកគណៈចាត់តាំងមជ្ឈិម និងការទទួលខុសត្រូវលើការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ</u>

៨៨០. នួន ជា ទទួលខុសត្រូវខាងគណៈចាត់តាំងមជ្ឈិមបក្ស[3732] ដែលមានអំណាចតាមដាន និងត្រួតពិនិត្យសមាជិកបក្សទាំងអស់ និងពិនិត្យការតែងតាំងបុគ្គលិកថ្មីនៅក្នុងមន្ទីរ និងក្រសួងនានា[3733]។ ឌុច យល់ឃើញថា នួន ជា ទទួលខុសត្រូវ *"លើការជ្រើសរើសនិងតែងតាំងសមាជិកថ្មី និងលើការតែងតាំងកម្មាភិបាល និងសមាជិកឲ្យកាន់តួនាទីផ្សេងៗ។ (...) នៅពេលណាដែលមានការតម្លើងថ្នាក់នរណាម្នាក់ គឺអ្នកផ្សេងទៀតត្រូវបានដកចេញ មានន័យថា កំទេច"*[3734]។ នួន ជា បានចូលរួមការតែងតាំងលេខាតំបន់ ឬ ភូមិភាគ ជាពិសេសដូចជា ការតែងតាំង [លុប] ជាលេខាតំបន់ស្វយ័ត ១០៥ ការតែងតាំង កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរថ្មី នួន ជា ប្រកាសបង្កើតភូមិភាគឧត្តរ និងការតែងតាំង [លុប] ជាលេខាតំបន់ ១០៣[3735]។ ក្នុងបទសម្ភាសន៍ធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ឆ្លើយនឹងសំណួរដែលសួរថា *"តើលោកបានដោះស្រាយបែបដូចម្តេចចំពោះសមមិត្តដែលមិនល្អ?"* ដោយនិយាយថា *"ខ្ញុំបានធ្វើការអប់រំកែប្រែពួកគេ ហើយមិនអនុញ្ញាតឱ្យពួកគេឋិតនៅក្នុងមុខតំណែងរបស់ពួកគេទេ"*[3736]។

៨៨១. នៅឯកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នាថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ នួន ជា ត្រូវបានគេឲ្យទទួលខុសត្រូវ *"ការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ"*[3737]។ ឌុច យល់ថា សេចក្តីសម្រេចនេះបានតែងតាំង នួន ជា ជាអ្នកទទួលខុសត្រូវក្រសួងចំនួន ៤ ដូចជា៖ ក្រសួង

00605539



ឃោសនាការ ក្រសួងអប់រំ ក្រសួងសង្គមកិច្ច និងក្រសួងវប្បធម៌។ឌុច ពន្យល់ថាហេតុផលនៃការតែងតាំងនេះដោយសារតែរដ្ឋមន្ត្រីទាំងបួន ដែលដឹកនាំក្រសួងទាំងនោះមិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិម[3738]។

៨៨២. ចំពោះការងារបក្ស ឃោសនាការ និងសិក្សាធិការ សេចក្ដីសម្រេចនេះបានធ្វើឲ្យ នួន ជា ក្លាយជាអ្នកទទួលខុសត្រូវចម្បងក្នុងការផ្សព្វផ្សាយមាគ៌ានយោបាយដែលសម្រេចដោយបក្សទៅដល់សមាជិក ប.ក.ក យោធា និងមហាជន។

៨៨៣. រដ្ឋមន្ត្រីដំបូងនៃក្រសួងព័ត៌មាន និងឃោសនាការ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឈ្មោះ ហ៊ូ នឹម ដែលគាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ នាខែមេសា ឆ្នាំ១៩៧៧[3739] បន្ទាប់មក ក្រសួងនេះត្រូវបានរៀបចំឡើងវិញ និងច្របាច់បញ្ចូលគ្នាជាមួយនឹងក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ ដែល មាន យុន យ៉ាត (ប្រពន្ធរបស់ សុន សេន) ជារដ្ឋមន្ត្រី និងក្រោយមក យុន យ៉ាត បានក្លាយជារដ្ឋមន្ត្រីកាន់ក្រសួងទាំងពីរនេះ[3740]។ លើសពីនេះទៀត នៅខណៈពេលដែលសារព័ត៌មានផ្លូវការបានផ្សាយថា យុន យ៉ាត កាន់ក្រសួងនេះ យ៉ាងហោចណាស់ រហូតដល់ខែមករា ឆ្នាំ១៩៧៩[3741] ប៉ុន្តែមានសាក្សីពីររូបដែលធ្លាប់ធ្វើការនៅក្នុងក្រសួងនោះបានបញ្ជាក់ថា នួន ជា ក្លាយជារដ្ឋមន្ត្រីក្រសួងអប់រំ និងព័ត៌មាន ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ[3742]។

៨៨៤. នួន ជា បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍របស់ ប.ក.ក នាថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៧៦ ដែលនៅពេលប្រជុំនោះ "*គុណសម្បត្តិ*" និង "*ការខ្វះខាត*" កម្មវិធីឃោសនាការអប់រំ ត្រូវបានលើកយកមកពិភាក្សា[3743]។ តាមរយៈកំណត់ហេតុនៃការប្រជុំការងារឃោសនាការដែលបានបន្សល់ទុក មានភស្តុតាងបង្ហាញឲ្យឃើញផងដែរថា មជ្ឈិម ប.ក.ក បានតាមដានយ៉ាងយកចិត្តទុកដាក់អំពីមធ្យោបាយឃោសនា និង បានចេញសេចក្តីសម្រេចផ្សេងៗអំពីបញ្ហានេះ។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងកិច្ចប្រជុំស្តីអំពី "ការងារឃោសនាការ" ដែលមានវត្តមានរបស់ នួន ជា បញ្ហាផ្សាយតាមវិទ្យុអំពីការបោះឆ្នោត ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ត្រូវបានពិភាក្សាយ៉ាងពិស្តារ (រួមមានទាំងខ្លឹមសារផ្សាយ និងពេលវេលាផ្សាយ) ដែលបង្ហាញឲ្យឃើញថា នួន ជា មានពាក់ព័ន្ធក្នុងដំណើរការធ្វើសេចក្តីសម្រេចទាក់ទិននឹងការផ្សព្វផ្សាយទាំងនោះ[3744]។ នៅក្នុងកិច្ចប្រជុំមួយទៀតធ្វើឡើងនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦ ដោយមានវត្តមានផងដែររបស់ នួន ជា រាល់ទិដ្ឋភាព

នៃការងារឃោសនាការរបស់ ប.ក.ក (ការផ្សាយតាមវិទ្យុ ការបោះពុម្ពផ្សព្វផ្សាយ និងភាពយន្តឃោសនា) ត្រូវបានពិភាក្សាជាមួយនឹងកម្មាភិបាលមកពីក្រសួងឃោសនាការ។ នៅក្នុងកិច្ចប្រជុំនោះ នួន ជា បានផ្តល់ការណែនាំ និងយោបល់ទៅលើទិដ្ឋភាពចំៗនៃការងារឃោសនាការ[3745]។ មានភស្តុតាងបង្ហាញផងដែរថា នួន ជា មានអំណាចណែនាំថ្នាក់ក្រោមអំពីបញ្ហាព័ត៌មាន និងឃោសនាការ[3746]។

៨៨៥. នៅក្នុងបទសម្ភាសន៍មួយ នួន ជា ទទួលស្គាល់ថា នៅមុនថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៥ គាត់ពិតជាបានដឹង និងមានការពាក់ព័ន្ធនឹងការបោះពុម្ព និងសរសេរទស្សនាវដ្តី *ទង់បដិវត្ត* ហើយគាត់បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងនោះ[3747]។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានស្នើសុំដោយផ្ទាល់ឲ្យកម្មាភិបាល ប.ក.ក សរសេរអត្ថបទមួយចំនួន សម្រាប់ទស្សនាវដ្តីឃោសនារបស់ ប.ក.ក[3748]។

៨៨៦. នៅពេលបង្ហាញខ្លួនលើកដំបូង ចំពោះមុខសហចៅក្រមស៊ើបអង្កេត នួន ជា អះអាងថា គាត់ទទួលបន្ទុកអប់រំកម្មាភិបាល និងបក្ខជន[3749]។ ឌុច យល់ថា ការទទួលខុសត្រូវរបស់ នួន ជា ក្នុង "ការងារបក្ស"មានន័យជាពិសេសថា នួន ជា ទទួលបន្ទុក *"កិច្ចការប្រចាំថ្ងៃនៅក្នុងបក្ស។ ខ្ញុំនៅចាំថាការងារនយោបាយរបស់បក្ស ផ្តោតជាសំខាន់លើការរៀនសូត្រប្រចាំឆ្នាំ (ការអប់រំនយោបាយសតិអារម្មណ៍ និងចាត់តាំង)"*[3750]។ នៅទីក្រុងភ្នំពេញ នួន ជា បានបង្រៀនវគ្គនយោបាយជាច្រើនដល់មហាជន ដោយបានបង្រៀនមាគ៌ា ឬគោលនយោបាយរបស់ ប.ក.ក។ ប្រជុំរៀនសូត្រនេះជាចម្បងធ្វើឡើងនៅបុរីកីឡា[3751]។ វគ្គរៀនសូត្រទាំងនោះត្រូវបានរៀបចំ សម្រាប់កម្មាភិបាល និងកម្មកររបស់បក្ស នៅភ្នំពេញ[3752] ព្រមទាំងសម្រាប់ កម្មាភិបាលផ្សេងៗមកពីកន្លែងនានាក្នុងប្រទេសកម្ពុជា (ភូមិភាគ តំបន់ និង សមាជិកគណៈស្រុក ប្រធានសហករណ៍ និង លេខាគណៈឃុំមួយចំនួន)[3753]។ នួន ជា បានចូលរួមប្រជុំដូចគ្នានេះជាមួយសមាជិកកងទ័ពបដិវត្តន៍កម្ពុជា[3754]។ វគ្គអប់រំនយោបាយទាំងនេះអាចមានអ្នកចូលរួមរហូតដល់រាប់រយនាក់[3755] សមាជិកបក្សត្រូវចូលរួមវគ្គរៀនសូត្រនេះយ៉ាងហោចណាស់ឲ្យបានម្តងក្នុងមួយឆ្នាំ[3756]។ កម្មាភិបាលយោធា និងយោធាដែលឈរជើងនៅក្រៅទីក្រុងភ្នំពេញត្រូវបានហៅឲ្យចូលរួមវគ្គរៀនសូត្រទាំងនេះ តាមរយៈទូរលេខ និងលិខិតអញ្ជើញដែលផ្ញើចេញដោយ នួន ជា[3757]។ សាក្សីមួយចំនួនបានរៀបរាប់ផងដែរថា នួន ជា បានធ្វើបទឧទ្ទេសនាមផ្សេងៗដល់កម្មាភិបាល ប.ក.ក និងកងទ័ពបដិវត្តន៍កម្ពុជា នៅពេលសន្និបាតភូមិភាគ និងសន្និបាតនៅតំបន់ស្វយ័ត[3758]។ អតីតអនុកងពលលេខ ១

បានប្រាប់ថា *"ជាតម្ណាក្នុងសន្និបាតរបស់ភូមិភាគគឺមាន តា នួន ជា ឬ តា ប៉ុល ពត គាត់បានចូលរួម"*[3759] សាក្សីខ្លះប្រាប់ថា បន្ទាប់មកវគ្គសិក្សារៀនសូត្រស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយសមាជិកបក្ស ដើម្បីណែនាំដល់ប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឱ្យដើរតាមមាគ៌ារបស់បក្ស[3760]។

**៨៨៧.** ចំពោះការងារសង្គមកិច្ច **អៀង ធីរិទ្ធ** ធ្លាប់មកជួបមេដឹកនាំមជ្ឈិមបក្ស និងជាពិសេស ជួបជាមួយ **នួន ជា** នៅ ក-៣ និង/ឬ ក-១ ម្តង ឬពីរដង ក្នុងមួយខែ[3761]។ **នួន ជា** មានវត្តមាននៅក្នុងអង្គប្រជុំស្តីអំពីការងារសង្គមកិច្ច និងសុខាភិបាល ដែលធ្វើឡើងនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដោយនៅក្នុងអង្គប្រជុំនោះ **អៀង ធីរិទ្ធ** និងកម្មាភិបាលថ្នាក់ដឹកនាំរបស់ក្រសួងសង្គមកិច្ចបានរាយការណ៍យ៉ាងលម្អិត អំពីសកម្មភាពរបស់ក្រសួង និងមន្ទីរចំណុះផ្សេងៗរបស់ក្រសួង ហើយ **នួន ជា** បានផ្តល់មតិយោបល់អំពីប្រធានបទផ្សេងៗដែលបានពិភាក្សានៅក្នុងអង្គប្រជុំ[3762]។ **នួន ជា** បានធ្វើទស្សនកិច្ច និងបានមកប្រជុំនៅមន្ទីរពេទ្យមួយចំនួនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច[3763] និងបង្រៀនវគ្គអប់រំនយោបាយដល់បុគ្គលិករបស់ក្រសួង[3764]។

**<u>នាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ</u>**

**៨៨៨.** **នួន ជា** ត្រូវបានតែងតាំងជាផ្លូវការជានាយករដ្ឋមន្ត្រីស្តីទីរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ ដើម្បីជំនួស **ប៉ុល ពត** បន្ទាប់ពីការមានការប្រកាសជាផ្លូវការរបស់បក្សថា **ប៉ុល ពត** សម្រាកជាបណ្តោះអាសន្ន ដើម្បីថែទាំសុខភាព[3765]។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីថ្ងៃនោះ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៦ សេចក្តីសម្រេចនោះហាក់ដូចជាមិនត្រូវបានអនុវត្តពេញលេញទេ ដោយសារក្នុងអំឡុងពេលនោះ សារព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យនៅតែផ្សាយដដែលៗថា **ប៉ុល ពត** ជានាយករដ្ឋមន្ត្រី ហើយ **នួន ជា** មិនបានត្រូវគេផ្សាយថាជានាយករដ្ឋមន្ត្រីស្តីទីទេ[3766] លើកលែងតែនៅក្នុងឱកាសដ៏កម្របុ៉ណ្ណោះ[3767]។ ចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ១៩៧៧ **នួន ជា** ត្រូវបានប្រកាសជាសាធារណៈ និងជាញឹកញាប់ដោយសារព័ត៌មានបក្សកុម្មុយនីស្តកម្ពុជាថា ជានាយករដ្ឋមន្ត្រីស្តីទី[3768] ជាពិសេសនៅក្នុងសុន្ទរកថាដែលគាត់បានធ្វើឡើងនៅក្នុងខួបអនុស្សាវរីយ៍លើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា នាថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧[3769] (នៅឆ្នាំបន្ទាប់ សុន្ទរកថាខួបអនុស្សាវរីយ៍ដូចគ្នានេះត្រូវបានធ្វើឡើងដោយ **ប៉ុល ពត**[3770])។ ស្ទើរតែគ្មាន[3771]ការនិយាយយោងជាសាធារណៈអំពី **ប៉ុល ពត** ក្នុងឋានៈគាត់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ជានាយករដ្ឋមន្ត្រី នៅក្នុងអំឡុងពេលនោះ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលជាថ្ងៃដែលគាត់ត្រូវបានគេដឹងឮជាសាធារណៈ ជាលើកដំបូងថាជាលេខាបក្សកុម្មុយនីស្តកម្ពុជា[3772]។ ឌុច យល់ថាពេលដែល នួន ជា បានធ្វើជានាយករដ្ឋមន្ត្រីស្តីទី មានន័យថា "*លេខាបក្សស្តីទី*"[3773]។

<u>ប្រធានសភាតំណាងប្រជាជន និង ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន</u>

៨៨៩. ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល នួន ជា មានតួនាទីជាប្រធានសភាតំណាងប្រជាជន[3774] និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជននេះ[3775]។ គាត់ត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នេះ នៅក្នុងសម័យប្រជុំសភាពេញអង្គលើកទី១ ដែលប្រារព្ធធ្វើឡើងនាថ្ងៃទី១១ ដល់ ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦[3776]។

៨៩០. ក្នុងឋានៈជាប្រធានសភាតំណាងប្រជាជន និងប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជននេះហើយ ដែល នួន ជា ភាគច្រើនត្រូវបានគេស្គាល់ជាសាធារណៈ។ នៅក្នុងតួនាទីទាំងនោះ នួន ជា បានដឹកនាំប្រតិភូរបស់ ប.ក.ក ទៅធ្វើទស្សនកិច្ចជាផ្លូវការទៅកាន់ប្រទេសចិន និងប្រទេសកូរ៉េខាងជើង ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨[3777] បានធ្វើទំនាក់ទំនងជាមួយមេដឹកនាំបរទេសនានា[3778] ព្រមទាំងបានចេញសេចក្តីថ្លែងការណ៍ជាផ្លូវការនានា[3779]។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង តួនាទីជាប្រធានទាំងពីរនេះ បាននាំមកនូវតែការទទួលខុសតិចតួចប៉ុណ្ណោះ[3780] លើកលែងតែការអនុម័តសេចក្តីសម្រេចមួយចំនួន ដូចជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ស្តីពី "ការកាត់ផ្តាច់ទំនាក់ទំនងបណ្តោះអាសន្នរវាង កម្ពុជា និង វៀតណាម" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧[3781]។

**តួនាទីផ្សេងៗទៀត**

៨៩១. បន្ថែមលើអ្វីដែលបានលើកឡើងខាងលើ នួន ជា បានក្លាយជាលេខាតាមជាក់ស្តែងរបស់ភូមិភាគចំនួនពីរ បន្ទាប់ពីលេខាភូមិភាគទាំងនោះត្រូវបានចាប់ខ្លួន។ បន្ទាប់ពីការចាប់ខ្លួនលេខាភូមិភាគពាយ័ព្យឈ្មោះ ម៉ែន សាន ហៅ យ៉ា[3782] នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ តួនាទីនេះ អាចត្រូវបានជំនួសដោយ អ៊ុំ ណេង ហៅ វី ហៅ វង់ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨[3783] និងបន្ទាប់មកក៏ត្រូវបានជំនួសដោយ នួន ជា ក្នុងរយៈពេលខ្លីមួយ[3784]។ ឌុច និង សាក្សីមួយចំនួនបញ្ជាក់ថា នួន ជា បានក្លាយជាលេខាភូមិភាគបូព៌ា ក្នុងអំឡុងពេលមួយ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ បន្ទាប់ពី សោ ភឹម ធ្វើអត្តឃាត[3785]។

៨៩២. ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ នួន ជា រួមចំណែកទទួលខុសត្រូវ "មន្ទីរនយោបាយ ៨៧០" និង មន្ទីរ "ស-២១"[3786]។

<u>ការចូលរួមជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់ប.ក.ក</u>

៨៩៣. នួន ជា មានទំនាក់ទំនងផ្ទាល់ខ្លួន និងនយោបាយជាមួយនឹងសមាជិកសំខាន់ៗរបស់ប.ក.ក ក្នុងរយៈពេលជាច្រើនឆ្នាំ[3787]។ បន្ថែមពីលើមន្ទីរចំនួនពីររបស់គាត់ ដែលមានទីតាំងស្ថិតនៅបូរីកីឡា និងវិទ្យាល័យព្រះសុរាម្រិត (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ) នោះ[3788] នួន ជា បានរស់នៅ និងធ្វើកិច្ចការប្រចាំថ្ងៃជាមួយ ប៉ុល ពត, ខៀវ សំផន, អៀង សារី និង សុន សេន នៅមន្ទីរក-១ និងមន្ទីរក-៣ ស្ទើរតែពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ[3789]។

៨៩៤. នួន ជា បានចុះត្រួតពិនិត្យនៅឃ្លាំងមួយ ជាមួយនឹង ខៀវ សំផន និង វ៉ាន់ រិទ្ធ[3790] ហើយគាត់បានចុះទៅក្រសួងការបរទេសជាមួយនឹង ប៉ុល ពត និង ខៀវ សំផន[3791]។ នួន ជា ក៏បានធ្វើដំណើរទស្សនកិច្ចនៅមូលដ្ឋានជនបទ ជាមួយនឹងសមាជិកផ្សេងទៀតនៃគណៈមជ្ឈិម ដែលរួមមាន ប៉ុល ពត, ខៀវ សំផន និង អៀង សារី[3792]។ គាត់បានចូលរួមក្នុងការប្រជុំធំៗរបស់បក្ស រួមជាមួយនឹងថ្នាក់ដឹកនាំ ប.ក.ក ផ្សេងៗទៀត រួមមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន អៀង ធីរិទ្ធ ផងដែរ[3793]។ នួន ជា បានទទួលគណៈប្រតិភូបរទេសនៅភ្នំពេញជាមួយនឹងសមាជិកថ្នាក់ដឹកនាំ ប.ក.ក ផ្សេងៗទៀត រួមមាន សុន សេន, ខៀវ សំផន, អៀង សារី និង ប៉ុល ពត[3794]។ ជាចុងក្រោយ នួន ជា ជាមួយថ្នាក់ដឹកនាំ ប.ក.ក. ផ្សេងទៀត បានធ្វើទំនាក់ទំនងជាប្រចាំពីភ្នំពេញទៅកាន់រដ្ឋាភិបាលបរទេសនានា[3795] ។

**ការចូលរួមនៅក្នុងផែនការរួម**

**ការផ្លាស់ទីលំនៅប្រជាជន**

៨៩៥. តាមរយៈតួនាទីរបស់គាត់ជាច្រើននៅក្នុង ប.ក.ក នួន ជា បានចូលរួមនៅក្នុងការជម្លៀសប្រជាជនពីទីក្រុង និងទីប្រជុំជននានាទៅជនបទ ព្រមទាំងពីជនបទមួយទៅកាន់ជនបទមួយទៀត។

៨៩៦. ប.ក.ក បានជម្លៀសប្រជាជនពីទីប្រជុំជននានា មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែល នួន ជា ជាសមាជិកគណៈអចិន្ត្រៃយ៍។ តាមការឲ្យដឹងរបស់ ខៀវ សំផន នៅឆ្នាំ១៩៦០ ក្នុង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605544



សន្និបាតបក្សលើកទី១ ដែលមានវត្តមានរបស់ នួន ជា មានការកំណត់ថាទីក្រុងគឺជាកន្លែងដែលសត្រូវរបស់បដិវត្តប្រមូលផ្តុំកំលាំង[3796]។ នៅក្នុងសុន្ទរកថានាខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បានគាំទ្រគោលជំហរនេះ ដោយនិយាយថា មុនឆ្នាំ១៩៧៥ មានសត្រូវតិចតួចនៅតាមជនបទ ប៉ុន្តែមានសត្រូវច្រើននៅក្នុងទីក្រុង[3797]។ លើសពីនេះទៀត នៅក្នុងសុន្ទរកថា ដែលគាត់បានថ្លែងក្នុងខួបអនុស្សាវរីយ៍លើកទី៩ របស់កងទ័ពបដិវត្តន៍កម្ពុជា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ នួន ជា បានលើកឡើងពីការជម្លៀសប្រជាជន ចេញពីបាណាម ដែលស្ថិតនៅក្នុងភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៣ និងការជម្លៀសប្រជាជនចេញពីឧត្តុង្គ ដែលស្ថិតនៅក្នុងភូមិភាគពិសេស ក្នុងឆ្នាំ១៩៧៤[3798]។

**៨៩៧.** ជាច្រើនដង នៅក្នុងអំឡុងនិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានគាំទ្រ និងការពារគោលនយោបាយនេះ។ ជាបឋម គាត់បានពន្យល់ថា ភ្លាមៗបន្ទាប់ពីការរំដោះ ទីក្រុងនានាត្រូវបានជម្លៀសចេញដោយសារមូលហេតុសន្តិសុខដើម្បី "*កម្ទេច*" ផែនការដែល"*ជាសកម្មភាពរួមគ្នារបស់សហរដ្ឋអាមេរិក កាហ្សេបេ (KGB) និងវៀតណាម*" ដើម្បីដណ្តើមអំណាចពីប.ក.ក[3799]។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានបន្ថែមថា ការជម្លៀសមានសារៈសំខាន់ក្នុងការការពារប្រជាជនពីសង្គ្រាម[3800] ហើយនោះគឺជាវិធានការបណ្តោះអាសន្នសមស្របមួយ ដោយសារតែការខ្វះខាតម្ហូបអាហារ និងប្រេងឥន្ធនៈនៅតាមបណ្តាក្រុងនានា[3801]។ និយាយពីប្រជាជនដែលត្រូវបានជម្លៀសវិញ គាត់បានលើកឡើងថា៖ "*មិនមានប្រជាជនច្រើនស្លាប់ទេ ក្នុងអំឡុងពេលជម្លៀស ក្រោយមកទេមាន ព្រោះប្រជាជននៅមានកម្លាំង*"[3802]។ នួន ជា បានដឹងផងដែរពីការជម្លៀសប្រជាជននាសម័យកម្ពុជាប្រជាធិបតេយ្យ តាមរយៈការទទួលទូរលេខ ដូចជាទូរលេខមួយចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានរាយការណ៍អំពីការបែងចែកប្រជាជនថ្មីពីសៀមរាបទៅកាន់ស្រុកផ្សេងៗ[3803]។

__ដំណាក់កាលទី១__

**៨៩៨.** នួន ជា បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេច ដែលបណ្តាលឱ្យមានការជម្លៀសប្រជាជនចេញពីបណ្តាទីក្រុងមួយចំនួន ជាពិសេសទីក្រុងភ្នំពេញ ទៅកាន់ទីជនបទ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងបទសម្ភាសន៍មួយ ដែលធ្វើឡើងក្រោយរបបនោះ នួន ជា បាននិយាយថា សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយ"*គណៈមជ្ឈិមបក្ស*"[3804]។ ទោះបីជាយ៉ាងណាក៏ដោយ នួន ជា នៅតែលើកឡើងពីការវិភាគ ដែលបណ្តាលឱ្យមានការសម្រេចជម្លៀសប្រជាជនចេញពីបណ្តាទីក្រុង ដែលធ្វើឡើងដោយគណៈយោធា ប.ក.ក ជាគណៈកម្មាធិការមួយ ដែល នួន ជា បាន

បដិសេធថា គាត់មិនមែនជាសមាជិក[3805]។

៨៩៩. នួន ជា បានជាប់ពាក់ព័ន្ធនៅក្នុងការបន្តធ្វើផែនការស្តីពីគោលនយោបាយនេះ តាមរយៈការចូលរួមចំណែករបស់គាត់នៅក្នុងអង្គប្រជុំនានា ដែលប្រព្រឹត្តទៅនៅចុងខែមីនា និងដើមខែមេសា ឆ្នាំ១៩៧៥[3806]។ នៅដើមខែមេសា មានអង្គប្រជុំមួយបានប្រព្រឹត្តទៅនៅឯមន្ទីររបស់ ប៉ុល ពត ស្ថិតក្នុងភូមិតាំងពន ស្រុកកំពង់ត្រឡាច (លើ) ក្នុងខេត្តកំពង់ឆ្នាំង។ គោលបំណងរបស់អង្គប្រជុំ គឺពិភាក្សាទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងរបៀបនៃការអនុវត្តន៍គោលនយោបាយនេះ។ នួន ជា បានចូលរួមនៅក្នុងអង្គប្រជុំ និងបានកត់ត្រាខ្លឹមសារប្រជុំផ្ទាល់ខ្លួន។ សាក្សីបានឲ្យដឹងទៀតថា៖ “*លោក នួន ជា ក៏មានចំណាប់អារម្មណ៍ ហើយនិងយល់ព្រមលើផែនការដូចគ្នាដែរ*[3807]”។

៩០០. នួន ជា មានជាប់ពាក់ព័ន្ធនៅក្នុងការធ្វើផែនការ និងការសម្របសម្រួលផ្នែកយោធាទាក់ទងនឹងការវាយប្រហារលើទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ ដែលបានធ្វើឡើងមុនការជម្លៀសប្រជាជនចេញពីទីក្រុង តាមរយៈអង្គប្រជុំដែលគាត់ធ្វើឡើងជាមួយ សុន សេន និងមេបញ្ជាការយោធាមកពីបណ្តាភូមិភាគទាំងអស់។[3808] នៅក្នុងបទសម្ភាសន៍មួយនៅក្រោយរបបនោះ នួន ជា បាននិយាយថា៖ “*ដូច្នេះទៅវាយយកអាបន្ទាយខាងក្នុងៗយក។ ដល់អញ្ចឹង ១៧ មេសា ឆ្នាំ១៩៧៥ រំដោះ កងទ័ពចូលរំដោះយកភ្នំពេញទាំងស្រុង*”[3809]។ នួន ជា រួមជាមួយថ្នាក់ដឹកនាំ ប.ក.ក ផ្សេងៗទៀត បានចាកចេញពីអតីតទីបញ្ជាការ ប.ក.ក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានចូលមកទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥[3810]។ កាលបរិច្ឆេទនេះមានភាពស៊ីសង្វាក់ជាមួយនឹងអង្គប្រជុំលើកដំបូងរបស់មេដឹកនាំ ប.ក.ក ដែលត្រូវបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ “*គឺនៅពេលក្រោយរំដោះ មិនដល់មួយអាទិត្យ*” នៅឯស្ថានីយ៍រថភ្លើង ហើយដែលនៅទីនោះ នួន ជា ត្រូវបានកត់ត្រាថាមានវត្តមាន[3811]។

<u>ដំណាក់កាលទី២</u>

៩០១. សេចក្តីសម្រេចក្នុងការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្តាល (ឧត្តរចាស់) ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ ត្រូវបានធ្វើឡើងដោយសមាជិកគណៈអចិន្ត្រៃយ៍ បន្ទាប់ពីពួកគេបានធ្វើដំណើរទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅចន្លោះថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥។ នួន ជា ប្រហែលជាបានចូលរួមធ្វើដំណើរទស្សនកិច្ចនេះ និងបានចូលរួមប្រជុំ

00605546



គណៈអចិន្ត្រៃយ៍ជាបន្តបន្ទាប់[3812]។ យ៉ាងហោចណាស់ គាត់ក៏បានដឹងឮផងដែរពីអត្ថិភាពរបស់ឯកសារបក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានបញ្ជាក់ពីភាពចាំបាច់ក្នុងការផ្លាស់ទីលំនៅប្រជាជនថ្មី ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ[3813]។ ឯកសារនេះស្របជាមួយនឹងអង្គប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយមួយក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាការពង្រឹងវិស័យកសិកម្ម និងឧស្សាហកម្ម ដែល នួន ជា បានចូលរួម[3814]។ មានទូរលេខចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៥[3815] ស្តីអំពីបញ្ហាកើតឡើងក្នុងការអនុវត្តន៍សេចក្តីសម្រេចបញ្ជូនជនជាតិចាម និងប្រជាជនដ៏ទៃទៀតចេញពីភូមិភាគបូព៌ាជាលក្ខណៈទ្រង់ទ្រាយធំ ទៅភូមិភាគឧត្តរ ដែលបានផ្ញើដោយ ឆុន ទៅ ប៉ុល ពត និងចម្លងជូន នួន ជា។ សាក្សីមួយរូបដែលធ្លាប់ទទួលបន្ទុកបកប្រែទូរលេខនានាសម្រាប់មន្ទីរមជ្ឈិម ក-១ និយាយថាប្រធានអង្គភាពទូរលេខជាអ្នកសម្រេចឱ្យចម្លងទូរលេខនេះទៅឱ្យ នួន ជា *"ដោយសារទូរលេខនេះទាក់ទងជាមួយប្រជាជន ទើបគេបញ្ជូនមក នួន ជា (...) ដើម្បីដោះស្រាយ[3816]"*។

## ដំណាក់កាលទី៣

៩០២. ការផ្លាស់ទីលំនៅប្រជាជននេះបានកើតឡើងនៅពេលដែល នួន ជា ជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ ជាងនេះទៀត ការផ្លាស់ទីលំនៅប្រជាជននេះមានជាប់ពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគបូព៌ា ដែលបានកើតឡើងដោយសារការភ័យខ្លាចការបង្កប់ខ្លួនរបស់វៀតណាមនៅក្នុងជួរ ប.ក.ក ក្នុងភូមិភាគបូព៌ា ដើម្បីរៀបចំរដ្ឋប្រហារ។ សេចក្តីសម្រេចផ្លាស់ទីលំនៅប្រជាជននេះគឺធ្វើឡើងដោយមជ្ឈិមរបស់ ប.ក.ក។ សាក្សីមួយរូបរៀបរាប់ថា គាត់បានចូលរួមប្រជុំមួយ នៅភូមិភាគពាយ័ព្យ ដែលនៅក្នុងអង្គប្រជុំនោះ តា ម៉ុក បានហៅ សោ ភឹម ថាជាជនក្បត់ ហើយបាននិយាយទៀតថា *"អង្គការ"* នឹងធ្វើការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគពាយ័ព្យ ដើម្បីតាមដានថាតើពួកប្រជាជនភូមិភាគបូព៌ាប្រឆាំងមាគ៌ារបស់បក្ស និង/ឬ ថាតើអ្នកទាំងនោះមានពាក់ព័ន្ធជាប់ខ្សែរយៈជាមួយវៀតណាមឬយ៉ាងណា[3817]។ ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុងផ្នែកផ្សេងៗទៀត នួន ជា បានក្លាយទៅជាលេខាភូមិភាគបូព៌ាតាមជាក់ស្តែង ក្នុងរយៈពេលខ្លីក្រោយពីការធ្វើអត្តឃាតរបស់ សោ ភឹម[3818] ហើយ នួន ជា បានចូលរួមយ៉ាងសកម្មក្នុងការបោសសម្អាតភូមិភាគបូព៌ា ដែលការបោសសម្អាតនេះជាប់ពាក់ព័ន្ធជាមួយនឹងការផ្លាស់ទីលំនៅប្រជាជន[3819]។

## សហករណ៍ និងការដ្ឋាននានា

៩០៣. តាមរយៈតួនាទីផ្សេងៗនៅក្នុង ប.ក.ក នួន ជា បានចូលរួមបង្កើត និងដាក់ឱ្យដំណើរការនូវសហករណ៍ និងការដ្ឋានទាំងឡាយ។

### ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ

៩០៤. ប.ក.ក បានចាប់ផ្ដើមរៀបចំជាបណ្ដើរៗ នូវផលិតកម្មកសិកម្មបែបសមូហភាព តាមរយៈការបង្កើតសហករណ៍ចាប់តាំងពីដើមឆ្នាំ១៩៧០ នៅពេលដែល នួន ជា បានក្លាយជាអនុលេខា និងសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍រួចមក។ តាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នួន ជា បានចូលរួមយ៉ាងសកម្មក្នុងការបង្កើតគោលនយោបាយនេះ។ អតីតលេខាមួយរូបនៃគណៈឃុំមួយចំនួនរបស់ខេត្តក្រចេះ រំឮកឱ្យដឹងថា ក្នុងឆ្នាំ១៩៧៣ ឬឆ្នាំ១៩៧៤ នួន ជា បានថ្លែងសុន្ទរកថាមួយនៅចំពោះមុខកម្មាភិបាល ប.ក.ក ចំនួនប្រមាណ ៥០នាក់ មកពីថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់ ដោយ នួន ជា បានធ្វើការពន្យល់ពីរបៀបនៃការបង្កើតសហករណ៍។ នួន ជា បានបង្ហាញសហករណ៍ពីរប្រភេទគឺ សហករណ៍ "ថ្នាក់ទាប" និង "ថ្នាក់ខ្ពស់" ហើយក៏បានលើកឡើងផងដែរពីទិន្នផលដែលត្រូវបែងចែកដោយផ្អែកលើការរួមវិភាគទានទៅឱ្យសហករណ៍[3820]។

៩០៥. នួន ជា បានចូលរួមបង្កើតគោលនយោបាយ នៅឯសន្និបាតដែលប្រព្រឹត្តនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥[3821]។ ក្នុងឋានៈជាសមាជិកមួយរូបរបស់គណៈអចិន្ត្រៃយ៍ នួន ជា បានចូលរួមចំណែកនៅក្នុងការរៀបចំគោលនយោបាយនេះ តាមរយៈការចូលរួមក្នុងអង្គប្រជុំនានារបស់គណៈអចិន្ត្រៃយ៍[3822] ក៏ដូចជាបានចូលរួមចំណែកក្នុងការចងក្រងផែនការបួនឆ្នាំ ដើម្បីកសាងលទ្ធិសង្គមនិយមលើគ្រប់វិស័យ[3823]។ បញ្ហានេះត្រូវបានលើកយកមកពិភាក្សានៅឯអង្គប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលនៅក្នុងអង្គប្រជុំនោះ ការពង្រឹងវិស័យកសិកម្មឱ្យបានឆាប់ត្រូវបានជជែកពិភាក្សា[3824]។ នួន ជា ចូលរួមផងដែរក្នុងអង្គប្រជុំរបស់មជ្ឈិមបក្ស ប.ក.ក ដែលប្រព្រឹត្តទៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦[3825] ហើយយ៉ាងហោចណាស់ក៏គាត់បានដឹងឮអំពីការតាក់តែងសេចក្ដីណែនាំនានារបស់ ប.ក.ក ស្ដីពីបញ្ហានេះ។ នួន ជា បានបញ្ជាក់ឡើងវិញពីការគាំទ្ររបស់គាត់ចំពោះគោលនយោបាយនេះ នៅក្នុងសន្និបាតរបស់សភាតំណាងប្រជាជនដែលធ្វើនៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

៩០៦. ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ នួន ជា បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍នានា ដែលនៅក្នុងអង្គប្រជុំទាំងនោះ មានការសម្រេចអំពីការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[3826]។

<u>ការគាំទ្រគោលនយោបាយនេះ</u>

៩០៧. នួន ជា បានគាំទ្រគោលនយោបាយនេះយ៉ាងសកម្ម និងជាសាធារណៈ។ ទាំងក្នុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងសុន្ទរកថាជាសាធារណៈ និងសេចក្តីថ្លែងការណ៍នានា នួន ជា បានបញ្ជាក់អះអាងថា បញ្ហាដែលពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ប្រជាជនត្រូវបានដោះស្រាយ និងថាសូម្បីតែជីវភាពរស់នៅបានប្រសើរឡើង តាមរយៈផែនការប្រព័ន្ធធារាសាស្ត្រ ការធ្វើឱ្យទៅជាសមូហភាពនូវផលិតកម្មដែលដាក់ចុះដោយ ប.ក.ក[3827]។ ឧទាហរណ៍ ក្នុងដំណើរទស្សនកិច្ចរបស់បក្សពលករនៃប្រទេសដាណឺម៉ាក នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៨ ជំនួសមុខឱ្យ ប.ក.ក ក្នុងតួនាទីជាអនុលេខានោះ នួន ជា បានថ្លែងសុន្ទរកថា ដោយបាននិយាយថា *"ចំពោះស្ថានភាពរស់នៅវិញ យើងបានដោះស្រាយបញ្ហារបស់យើងជាមូលដ្ឋាន តាមរយៈមធ្យោបាយអភិវឌ្ឍគម្រោងធារាសាស្ត្រជាច្រើន។ យើងកំពុងប្រមូលមូលធន ដើម្បីអភិវឌ្ឍប្រទេសរបស់យើង ដោយឈរលើមូលដ្ឋានឯករាជ្យភាព និងខ្លួនទីពឹងខ្លួន"*[3828]។ នៅក្នុងសុន្ទរកថាដដែលនេះ នួន ជា បានទទួលស្គាល់ផងដែរថា មិនមានការបើកប្រាក់ខែឱ្យកម្មករ ហើយប្រជាជនទាំងអស់ត្រូវរស់នៅតាមបែបសមូហភាព[3829]។

៩០៨. នៅក្នុងបទសម្ភាសន៍មួយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បាននិយាយអំពីប្រជាជនកម្ពុជា ដោយគាត់បាននិយាយថា *"យើងខ្ញុំកសាងសតិអារម្មណ៍គេតាមការអប់រំ។ មួយតាមការអប់រំតាមសាលា ប៉ុន* [ប៉ុន្តែ] *ពីរទៀតតាមការហ្វឹកហ្វឺនឱ្យគេធ្វើការងារខ្លះ។ ដល់យើងលត់ដំបំប៉នគេទៅគេបានយល់ និងមានការជឿជាក់លើយើង ក៏ធ្វើឱ្យបក្សរបស់យើងកាន់តែខ្លាំងឡើង"*[3830]។

<u>ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះ</u>

៩០៩. នួន ជា បានដឹងឮពីមធ្យោបាយផ្សេងៗដែលប្រើប្រាស់ក្នុងការអនុវត្តន៍គោលនយោបាយនេះ និងក៏បានចូលរួមអនុវត្តផងដែរ។

៩១០. តាមរយៈការចូលរួមនៅក្នុងអង្គប្រជុំនានា ក្នុងរវាងថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ និងថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ នួន ជា បានដឹងឮពីស្ថានភាពរស់នៅ និងធ្វើការយ៉ាងលំបាកនៅតាម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605549



បណ្តាការដ្ឋាន និងសហករណ៍ផ្សេងៗ ទោះបីជាស្ថានភាពទាំងនោះ ត្រូវបានចាត់ទុកជាបណ្តោះអាសន្ន ឬងាកចេញពីមាគ៌ាបក្ស។ ស្ថានភាពលំបាកទាំងនោះត្រូវបានរាយការណ៍ឱ្យដឹង ដូចជាកង្វះស្បៀង[3831] កង្វះថ្នាំសង្កូវ[3832] និងការកើតមានជំងឺក្នុងអត្រាមួយខ្ពស់[3833]។

**៩១១.** **នួន ជា** ត្រូវបានគេចម្លងជូនជាទៀងទាត់ផងដែរ នូវទូរលេខផ្សេងៗ ដែលផ្ញើដោយភូមិភាគ និងកងពលមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា មកឱ្យមជ្ឈិម ដែលនៅក្នុងទូរលេខទាំងនោះ មានរាយការណ៍ពីទិដ្ឋភាពផ្សេងៗ ដែលពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាននានា រួមមានស្ថានភាពធ្វើការងាររបស់ប្រជាជន ការដកស្ទូងស្រូវ និងការសាងសង់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រផ្សេងៗទៀត[3834]។ ជាពិសេស **នួន ជា** ត្រូវបានចម្លងជូននូវទូរលេខមួយដែលរាយការណ៍ពីដំណើរទស្សនកិច្ចរបស់អ្នកសារព័ត៌មានយូហ្គោស្លាវីនៅទំនប់ត្រពាំងថ្ម[3835]។ នៅក្នុងបទសម្ភាសន៍ធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **នួន ជា** បានទទួលស្គាល់ថាប្រជាជនកម្ពុជាមួយចំនួនបានស្លាប់ដោយសារជំងឺ និងកង្វះស្បៀងអាហារ[3836] ហើយគាត់បានបន្ថែមថា *"ការដោះស្រាយសេដ្ឋកិច្ចជីវភាពអី វាមិនទាន់បានស្រួល។ មានស្លាប់មានរស់អី"*[3837]។

**៩១២.** **នួន ជា** បានចូលរួមផ្សព្វផ្សាយគោលនយោបាយនេះ តាមរយៈការពាក់ព័ន្ធដោយផ្ទាល់ក្នុងការបង្កើត និងបែងចែកទៅឱ្យកម្មាភិបាល ប.ក.ក នូវ*ទស្សនាវដ្តីទង់បដិវត្ត* និង*យុវជននិងយុវនារីបដិវត្ត* ក៏ដូចជាតាមរយៈការពាក់ព័ន្ធរបស់គាត់នៅក្នុងការផ្សព្វផ្សាយតាមវិទ្យុផ្សេងៗជាដើម។ [លុប] ជាអតីតមេបញ្ជាការយោធា ត្រូវបានអ្នកស៊ើបអង្កេតបង្ហាញ*ទស្សនាវដ្តីទង់បដិវត្ត* លេខ៧ ចេញផ្សាយក្នុងខែកក្កដា ឆ្នាំ១៩៧៦ នៅក្នុងនោះមាននិយាយពីតួនាទីផ្សេងៗរបស់សហករណ៍ ក្នុងការកសាងសង្គមនិយម និងផែនការបង្កើនទិន្នផលស្រូវបីតោនក្នុងមួយហិកតាជាដើម។ សាក្សីរូបនេះបានបកស្រាយថា *"ដើម្បីការងារកសិកម្មឱ្យបានតាមផែនការគេ គឺ ៣តោនក្នុងមួយហិចតា ដែលបណ្តាលឱ្យមានការបាក់កម្លាំង និងហូបមិនគ្រប់គ្រាន់"*។ គាត់បានបន្ថែមទៀតថា *"ខ្ញុំដឹងថាអ្នកសរសេរគឺ គណៈមជ្ឈិមដែលមាន ប៉ុល ពត នួន ជា អៀង សារី (...) គំនិតចម្បង គឺ ពួកគាត់ទាំងនោះតែម្តង ព្រោះក្នុងសន្និបាតត្រូវតែមានការឯកភាពគ្នាក្នុងបក្សជាមុនសិន ទើបគោលការណ៍នេះដាក់ចេញ និងអាចអនុវត្តទូទាំងប្រទេសបាន"*[3838]។

**៩១៣.** ក្នុងវគ្គបំពាក់បំប៉ននយោបាយជាច្រើន ដែលគាត់បង្រៀនដល់កម្មាភិបាល និងបុគ្គលិករបស់បក្ស ព្រមទាំងសមាជិករបស់កងទ័ពបដិវត្តកម្ពុជានៅភ្នំពេញ[3839] និងសម្រាប់ថ្នាក់ដឹកនាំមូលដ្ឋាន នៅតាម

បណ្តាភូមិភាគនានា[3840] នួន ជា បាននិយាយពីផែនការប្រែក្លាយសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ជាងនេះទៅទៀត នួន ជា បានចុះពិនិត្យតាមបណ្តាស្ថាប័នរដ្ឋ ទំនប់ ការដ្ឋានសាងសង់ ឃ្លាំង និងទីតាំងកសិកម្មទូទាំងប្រទេសកម្ពុជា[3841]។ ជាក់ស្តែង នួន ជា បានចុះទៅត្រួតពិនិត្យការដ្ឋាន ចំនួនបីក្នុងចំណោមការដ្ឋានចំនួនប្រាំ ដែលស្ថិតនៅក្រោមការស៊ើបសួរ (ការដ្ឋានស្រែអំបិល[3842] ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[3843] និងការដ្ឋានទំនប់១មករា[3844]) ហើយព្រៃស ស្ថិតនៅក្រោមការត្រួតត្រារបស់គាត់។ ក្នុងអំឡុងពេលនៃការចុះត្រួតពិនិត្យ ទោះបីជាសាក្សីខ្លះបំភ្លឺថា នួន ជា មិនត្រូវបានគេប្រាប់ឲ្យដឹងពេញលេញអំពីស្ថានភាពទាំងនោះ ដោយកម្មាភិបាលដឹកនាំមូលដ្ឋានក៏ដោយ[3845] ក៏ នួន ជា បានឃើញពីស្ថានភាពរស់នៅ និងស្ថានភាពធ្វើការរបស់ប្រជាជន[3846]។ សាក្សីមួយចំនួនរៀបរាប់ថា នៅក្នុងពេលចុះទស្សនកិច្ចត្រួតពិនិត្យទាំងនេះ នួន ជា បានថ្លែងសុន្ទរកថា ជំរុញឲ្យកម្មករខិតខំប្រឹងប្រែងធ្វើការ[3847] (ទោះបីជាយ៉ាងណាក៏ដោយ សាក្សីផ្សេងទៀត បានលើកឡើងថា នួន ជា បានណែនាំឲ្យជួយសាងសង់ជម្រក និង ឲ្យផ្តល់ស្បៀងឲ្យបានគ្រប់គ្រាន់សម្រាប់ប្រជាជន[3848]។

៩១៤. កងការពារមួយរូបរបស់ នួន ជា បានពន្យល់ថា បន្ទាប់ពីចុះទស្សនកិច្ចត្រួតពិនិត្យនៅភូមិភាគពាយ័ព្យ កងការពារនោះ យល់ថា "*ពេលតា នួន ជា ទៅគាត់ឃោសនាប្រជាជនឲ្យខំធ្វើការ តែពេលតា នួន ជា ត្រឡប់មកវិញ មេៗតំបន់បង្ខំឲ្យប្រជាជនធ្វើការធ្ងន់ធ្ងរទៀត។ ខ្ញុំដឹងថា តា នួន ជា ដាក់ផែនការឲ្យប្រជាជនហូបបាយមួយថ្ងៃបីដង ហើយមួយអាទិត្យហូបបបរស្ករមួយដង តែប្រធានសហករណ៍ និងតំបន់មិនធ្វើតាម ដោយសារគាត់ឃើញប្រជាជនស្គមៗ បានជាគាត់ចុះតាមសហករណ៍ដាប់*"។ នៅពេលសួរថា តើ នួន ជា មានស្តីបន្ទោសប្រធានសហករណ៍ ឬតំបន់ ដែលទទួលខុសត្រូវនោះដែរឬទេ សាក្សីរូបនេះ បានឆ្លើយតបថា នួន ជា បានហៅពួកគេមកប្រជុំស្វ័យទិតៀន និងបានបង្គាប់ឲ្យពួកគេ "*ធ្វើស្រែឲ្យបានបីតោនក្នុងមួយហិចតា*[3849]"។

៩១៥. នៅក្នុងបទសម្ភាសន៍មួយធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ទទួលស្គាល់ថា "*មានប្រជាជនមួយចំនួនបានស្លាប់ដោយសារតែការអត់ឃ្លាន ប៉ុន្តែបញ្ហានោះ វាលើសពីសមត្ថភាពរបស់យើងខ្ញុំក្នុងការដោះស្រាយ។ យើងបានព្យាយាមអស់លទ្ធភាព ប៉ុន្តែបក្សរបស់យើងនៅតែមិនអាចគ្រប់គ្រងបាន។ យើងមិនបានសម្លាប់ប្រជាជនទេ។ យើងមិនចង់ឲ្យប្រជាជនស្លាប់ទេ។ យើងបានព្យាយាមស្វែងរកដំណោះស្រាយចំពោះបញ្ហា សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែមានប្រជាជន ប៉ុន្មាននាក់បានស្លាប់នោះ គ្មាននរណាបានដឹងនោះទេ*[3850]"។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

## មន្ទីរសន្តិសុខ និង ទីកន្លែងសម្លាប់មនុស្ស

៩១៦. តាមរយៈតួនាទីផ្សេងៗនៅក្នុង ប.ក.ក នួន ជា បានចូលរួមអប់រំកែប្រែ *"សមាសភាពអាក្រក់"* និងសម្លាប់ *"ខ្មាំង"* ទាំងក្នុងជួរ និងក្រៅជួរបក្ស។

<u>ការចូលរួមចំណែកក្នុងការបង្កើតគោលនយោបាយនេះ</u>

៩១៧. គោលនយោបាយនេះកើតមានមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺនៅក្រោយពេលដែល នួន ជា បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ និងជាអនុលេខាបក្សនៃ ប.ក.ក។ តាមការបំភ្លឺរបស់សាក្សីមួយចំនួន ក្នុងចន្លោះឆ្នាំ១៩៦៨ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នួន ជា ធ្លាប់បានដឹកនាំវគ្គសិក្សាអប់រំនានាពាក់ព័ន្ធនឹងការកសាងបក្ស ស្វ័យទិតៀន និងតម្រូវការក្នុងការ "កំចាត់វណ្ណៈជិះជាន់ផ្សេងៗ"[3851]។

៩១៨. ក្រោយមក នួន ជា ជាប់ពាក់ព័ន្ធក្នុងការបង្កើតគោលនយោបាយនេះ តាមរយៈការចូលរួមក្នុងអង្គប្រជុំនានារបស់គណៈអចិន្ត្រៃយ៍[3852] ក៏ដូចជាបានចូលរួមចំណែកក្នុងការចងក្រងផែនការបួនឆ្នាំដើម្បីកសាងលទ្ធិសង្គមនិយមលើគ្រប់វិស័យ[3853]។ គោលនយោបាយនេះត្រូវបានលើកយកមកពិភាក្សាថែមទៀត នៅក្នុងអង្គប្រជុំផ្សេងទៀតរបស់មជ្ឈិម ដូចជា អង្គប្រជុំជាមួយកម្មាភិបាលស្តីពីឃោសនាការ[3854] និងការងារនៅមូលដ្ឋាន[3855] ដែល នួន ជា បានចូលរួម។ លើសពីនេះ នាខែកក្កដា ឆ្នាំ១៩៧៥ នួន ជា បានចូលរួមការប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលនៅក្នុងការប្រជុំនោះ គោលនយោបាយនេះត្រូវបានលើកយកមកពិភាក្សាគ្នា[3856]។ នួន ជា បានចូលរួមចំណែកក្នុងការគាំទ្រគោលនយោបាយនេះ នៅសន្និបាតនៃសភាតំណាងប្រជាជន ប្រារព្ធធ្វើឡើងពីថ្ងៃទី១១-១៣ ខែមេសាឆ្នាំ១៩៧៦ ដែលគាត់បានចូលរួមក្នុងឋានៈជាប្រធានសភាតំណាងប្រជាជន និងជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជានេះ[3857]។

៩១៩. ក្នុងឋានៈជាអនុលេខានៃគណៈមជ្ឈិមបក្ស នួន ជា បានចូលរួមនៅក្នុងការចងក្រងបង្កើតឯកសារ ប.ក.ក ពាក់ព័ន្ធនឹងគោលនយោបាយនេះ រួមមានសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលបានផ្ទេរអំណាច "កម្ទេច" ទាំងក្នុងជួរ និងក្រៅជួរ ទៅឲ្យគណៈភូមិភាគ និងគណៈតំបន់ស្វយ័ត ព្រមទាំងឯកសារផ្សេងទៀតរបស់ ប.ក.ក[3858]។ នួន ជា បានរួម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

វិភាគទានផងដែរក្នុងការផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស នាខែមិថុនា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា "*សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុនីស្តកម្ពុជាអំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភាន់ច្រឡំចូល សេ អ៊ី អា (CIA) ឬភ្នាក់ងារយួន ឬចូល កា សេ បេ (KGB) ប្រឆាំងបក្សបដិវត្តន៍ ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ* "។ សេចក្តីណែនាំនេះហាក់ចែងអំពីការអប់រំកែប្រែ ចំពោះអ្នកដែលបានចូល សេ.អ៊ី.អា (CIA) កា.ហ្សេ.បេ (KGB) និងភ្នាក់ងារវៀតណាមមុនខែកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែសេចក្តីណែនាំនេះបង្គាប់ឲ្យបក្ស និងប្រជាជនកម្ពុជាលុបបំបាត់ខ្សែបណ្តាញទាំងឡាយដែលបន្តប្រឆាំងបក្ស ចាប់ពីខែកក្កដាឆ្នាំ១៩៧៨ តទៅ[3859]។ ជាងនេះទៅទៀត នាខែកញ្ញា ឆ្នាំ១៩៧៨ នួន ជា បានចូលរួមមហាសន្និបាតបើកទូលាយនៅទីក្រុងភ្នំពេញ ជាមួយមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក ដែលនៅក្នុងមហាសន្និបាតនោះ ប៉ុល ពត បានប្រកាសទៅកាន់អ្នកចូលរួមរាប់រយនាក់ថា យោធា និងកំលាំងមូលដ្ឋានគ្មានសិទ្ធិចាប់ខ្លួនមនុស្សទៀតទេ។ ចាប់ពីពេលនោះមក ពួកគេមានសិទ្ធិត្រឹមតែសួរចម្លើយមនុស្ស និងរាយការណ៍មកមជ្ឈិមតែប៉ុណ្ណោះ[3860]។

<u>ការគាំទ្រគោលនយោបាយនេះ</u>

**៩២០.** នួន ជា បានផ្សព្វផ្សាយ និងគាំទ្រជាសាធារណៈចំពោះគោលនយោបាយនេះ ក្នុងអំឡុងពេល និងបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងអំឡុងពេលទស្សនកិច្ចរបស់បក្សពលករនៃប្រទេសដាណឺម៉ាក[3861] នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៨ ជំនួសមុខឲ្យ ប.ក.ក និងក្នុងឋានៈជាអនុលេខា នួន ជា បាននិយាយ និងឆ្លើយតបទៅនឹងសំណួរ ជាច្រើន។ ដោយនិយាយយ៉ាងពិស្តារអំពីតម្រូវការបោសសម្អាតក្នុងជួររបស់ ប.ក.ក គាត់បាននិយាយថា " *យើងស៊ើបអង្កេតអំពីប្រវត្តិជីវិត និងប្រវត្តិរូបៈ ទាំងមុនពេល និងក្រោយពេលពួកគេចូលរួមធ្វើបដិវត្តន៍។ យើងធ្វើដូចនេះ គឺ ដើម្បីការពារការជ្រៀតចូលពីសំណាក់ ឧទាហរណ៍ ដូចជា ពួកសេអ៊ីអា (CIA) ពួកកាហ្សេបេ (KGB) ឬភ្នាក់ងារ យួន។ តាមរយៈការអនុម័តយកគោលការណ៍ចាត់តាំងទាំងនេះ យើងមានការរួបរួមនៅក្នុងជួរបក្ស ហើយអាចបោស សម្អាតសមាសភាពអាក្រក់ចេញពីបក្សយើងបាន។ យើងមិនទទួលបានជោគជ័យ ១០០ភាគរយនោះទេ។ សត្រូវនៅតែ ព្យាយាមបំផ្លាញបក្ស។ ហេតុដូច្នេះ យើងកំពុងព្យាយាមពង្រឹងការអប់រំផ្នែកមនោគមវិជ្ជា និងការអប់រំផ្នែកនយោបាយ និងព្យាយាមបោសសម្អាតក្នុងជួរបក្ស*"។ គាត់បានបន្ថែមទៀតថា៖ "*ចាប់តាំងពីការរំដោះមក បទពិសោធន៍របស់យើងគឺពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងបក្សដែលបានរៀបចំឡើងនៅក្នុងជួរបក្សយើងតែម្តង។ ពួកគេតែងតែពាក់ព័ន្ធនឹងពួក សេអ៊ីអា (CIA) ភ្នាក់ងារកាហ្សេបេ (KGB) និងភ្នាក់ងារវៀតណាម។*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

*បទពិសោធន៍របស់យើងក្នុងផ្នែកនេះ គឺនៅថ្មី ថ្មោងខ្លាំងណាស់ ប៉ុន្តែវាបានបង្ហាញឱ្យយើងដឹងថា ពួកសេអ៊ីអា (CIA) ភ្នាក់ងារកាហ្សេបេ (KGB) និងភ្នាក់ងារវៀតណាម បានធ្វើការងារនៅក្នុងបក្សអស់រយៈពេលជាយូរមកហើយ។ [...] ទោះមានអ្វីកើតឡើងក៏ដោយ យើងត្រូវតែការពារអ្នកដឹកនាំយើង។ ប្រសិនបើ យើងបាត់បង់សមាជិក ប៉ុន្តែយើងរក្សាអ្នកដឹកនាំបាន យើងអាចបន្តយកជ័យជំនះ។ ការការពារថ្នាក់ដឹកនាំបក្ស គឺជាការងារយុទ្ធសាស្ត្រ។ ឱ្យតែមានថ្នាក់ដឹកនាំ បក្សនឹងមិនស្លាប់ឡើយ។ ការបាត់បង់សមាជិក២០០-៣០០នាក់ មិនអាចប្រៀបធៀបនឹងការបាត់បង់កម្មាភិបាលដឹកនាំពីរទៅបីនាក់បានឡើយ។ ការបាត់បង់សមាជិក២០០-៣០០នាក់ ប្រសើរជាងការបាត់បង់កម្មាភិបាលដឹកនាំពីរទៅបីនាក់។ បើពុំដូច្នោះទេ បក្ស នឹងគ្មានក្បាលម៉ាស៊ីន ហើយមិនអាចដឹកនាំការតស៊ូបានទេ”*[3862]។

**៩២១.** នៅពេលចូលខ្លួនដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត **នួន ជា** បាននិយាយថា “*ភ្នាក់ងារសេអ៊ីអា (CIA) អាមេរិក កាហ្សេបេ (KGB) សូវៀត ខ្មែរសេរី ពួកភ្នាក់ងារសម្ងាត់វៀតណាម ក៏មាន ហើយពួកនេះមានបង្កប់ខ្លួននៅក្នុងបក្ស និងចំណោមប្រជាជន សហករណ៍យើងខ្ញុំ ហើយធ្វើឱ្យមាគ៌ារបស់បក្ស “ឆ្វេង” និង “ខ្លោច” និងបំផ្លាញប្រទេសជាតិឯង បក្ស និងប្រជាជន*[3863]”។

**៩២២.** បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ **នួន ជា** បាននិយាយថា៖ “*មានពួកកាន់កាប់ស្រុក និងខេត្ត ជាពួកក្បត់។ ពួកទាំងនោះបង្កប់ខ្លួននៅក្នុងបក្ស ហើយវាបំផ្លាញស្រែចំការរបស់យើង។ នយោបាយរបស់យើងកំណត់ឱ្យប្រជាជនហូបគ្រប់គ្រាន់ និងស្មើភាពគ្នាទាំងតូចទាំងធំ ប៉ុន្តែពួកក្បត់ទាំងនោះមិនដើរតាមនយោបាយរបស់យើងទេ ហើយយើងក៏មិនអាចគ្រប់គ្រងពួកនោះបានដែរ ពីព្រោះយើងមិនមានកម្មាភិបាលបក្សជាន់ខ្ពស់គ្រប់គ្រាន់ទេ*[3864]”។ នៅក្នុងបទសម្ភាសន៍ជាមួយអ្នកសាព័ត៌មាន **នួន ជា** បាននិយាយថា៖ “*ពេលនោះ ច្របូកច្របល់ណាស់។ ខ្មែរសេរីក៏មាន សេអ៊ីអា (CIA) ក៏មាន កាហ្សេបេ (KGB) យួនក៏មាន យួនសេរី។ ដូច្នេះក្នុងសង្គមស្មុគស្មាញណាស់។ បញ្ហានេះ យើងខ្ញុំមិនមែនបដិសេធមិនទទួលខុសត្រូវទេ។ យើងទទួលខុសត្រូវ ប៉ុន្តែដោយអចេតនា។ យើងខ្ញុំគ្មានចេតនាអីទៅសម្លាប់ប្រជាជនឯងទេ។ គ្រួសារខ្ញុំ បងប្អូនខ្ញុំ អស់៤០នាក់។ ខ្លះធ្វើ Colonel* (ស័ក្តិប្រាំ) *ធ្វើគ្រូបង្រៀន និងធ្វើអីៗច្រើន*”។ ឆ្លើយនឹងសំណួរដែលសួរគាត់ថាតើគាត់គិតថាបដិវត្តន៍គឺ “យុត្តិធម៌” នោះ **នួន ជា** និយាយថា “*ខ្ញុំថាយុត្តិធម៌ ពីព្រោះកម្ទេច កម្លាំងខ្មាំង រក្សាបានកម្ពុជាមួយឯករាជ្យ អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ គឺតស៊ូមកនេះ រក្សាបានប្រជាជាតិមិនធ្លាក់ទៅក្នុងកណ្តាប់ដៃបរទេស*”[3865]។ នៅក្នុងបទសម្ភាសន៍មួយទៀត ឆ្លើយ

តបទៅនឹងសំណួរសួរថា *"មានអតីតកម្មាភិបាលជាច្រើននាក់របស់លោក សមាជិកជាន់ខ្ពស់របស់បក្ស ត្រូវបានកម្ទេច និងបានបាត់បង់ជីវិត"* នួន ជា បាននិយាយថា *"មិនច្រើនទេ។ អ្នកខ្លះមិនព្រមទទួលកំហុសរបស់ខ្លួន ប៉ុន្តែអ្នកខ្លះទៀតបានដឹង ហើយពួកគេព្រមទទួលកំហុសរបស់ខ្លួននៅពេលមានការប្រជុំ ហើយពួកគេក៏បានទទួលការលើកលែងទោស យើងមិនបានសម្លាប់មនុស្សច្រើនទេ យើងសម្លាប់តែមនុស្សដែលអាក្រក់ មិនមែនសម្លាប់មនុស្សល្អទេ"*[3866]។ នៅក្នុងបទសម្ភាសន៍មួយផ្សេងទៀត នួន ជា បានបន្ថែមថា *"ខ្ញុំគោរពនូវវិញ្ញាណក្ខន្ធរបស់ប្រជាពលរដ្ឋខ្ញុំដែលបានលះបង់អាយុជីវិត ហើយក៏ខ្ញុំសំដែងនូវការសោកស្តាយ ហើយជំរាបឲ្យឃើញថាមិនមែនកម្ពុជាប្រជាធិបតេយ្យជាអ្នកសម្លាប់ប្រជាជនកម្ពុជារបស់ឯងទេ គឺប្រទេសដែលគេជាតាំងខ្លួនជាអមិត្រជាមួយកម្ពុជាប្រជាធិបតេយ្យ"*[3867]។

<u>ការដឹងឮ និង ការអនុវត្តន៍គោលនយោបាយនេះជាលក្ខណៈទូទៅ</u>

៩២៣. លើកលែងតែសាក្សីម្នាក់ចេញដែលជឿជាក់ថា នួន ជា បានទៅពិនិត្យមើលមន្ទីរសន្តិសុខក្រាំងតាចាន់ និងបាននិយាយជាមួយសាក្សីម្នាក់ទៀត (ដែលបានបដិសេធថាមិនមានហេតុការណ៍នេះកើតឡើងទេ)[3868] មិនមានភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា នួន ជា បានចុះពិនិត្យមើលមន្ទីរសន្តិសុខ ឬទីតាំងសម្លាប់មនុស្សណាមួយទេ។ ឌុច បានអះអាងថា នួន ជា មិនដែលចូលមកក្នុងបរិវេណមន្ទីរ ស-២១ ឡើយ[3869]។

៩២៤. ទោះបីជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលមានអង្គប្រជុំនយោបាយមហាជន និងវគ្គរៀនសូត្រនយោបាយ ដែលធ្វើឡើងនៅទីក្រុងភ្នំពេញសម្រាប់កម្មាភិបាល ប.ក.ក និងសមាជិកកងទ័ពបដិវត្តន៍កម្ពុជា មកពីភូមិភាគស្ទើរតែទាំងអស់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងអំឡុងពេលគាត់ចុះទស្សនកិច្ចតាមភូមិភាគ នួន ជា បានណែនាំអ្នកចូលរួមទាំងនោះឲ្យរារាំងខ្មាំងបង្កប់នៅក្នុងជួរបក្សពីការបំផ្លាញ ប.ក.ក ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះអ្នកដែលមានខ្សែរយៈជាមួយវៀតណាម ឬសេអ៊ីអា (CIA) ឲ្យមានការប្រយ័ត្នប្រយែងនូវរាល់សកម្មភាពរបស់ពួកអ្នកផ្សេងទៀត ហើយត្រូវ *"បោសសម្អាត"* ខ្មាំងរបស់បក្ស[3870]។ ជាឧទាហរណ៍ អតីតមេកងម្នាក់នៅក្នុងវរៈសេនាតូច បានពន្យល់នៅក្នុងបទសម្ភាសន៍ថា នៅដើមឆ្នាំ១៩៧៦ គាត់បានចូលរួមនៅក្នុងអង្គប្រជុំជាច្រើនដែលគេរៀបចំឡើងសម្រាប់កម្មាភិបាល ប.ក.ក ដែលមកពីភូមិភាគពាយ័ព្យ ដោយពេលនោះ នួន ជា បាននិយាយថា *"ក្នុងផែនការបោសសម្អាតខ្មាំងផ្ទៃក្នុង គឺយកគិញមកដាក់តាមអង្គភាព ស្រុក តំបន់ ក្រុម និងតាមកង [...] គិញស៊ើបការបានមករាយការណ៍ទៅស្រុក និងតំបន់។*

00605555



*ហើយបន្ទាប់ មកខាងតំបន់ ដែលទទួលបានព័ត៌មានពីតិញ ក៏បញ្ជាកងឈ្លបចាប់ខ្លួន [...]*"[3871]។

៩២៥. នួន ជា បានចូលរួមផងដែរ ក្នុងការអនុវត្តន៍នូវគោលនយោបាយនេះ តាមរយៈការចូលរួមក្នុងការសរសេរ និងបែងចែកទស្សនាវដ្តី *ទង់បដិវត្ត* និងទស្សនាវដ្តី*យុវជននិងយុវនារីបដិវត្ត* ដល់កម្មាភិបាល ប.ក.ក[3872] និងតាមរយៈតួនាទីរបស់គាត់ក្នុងការផ្សព្វផ្សាយតាមវិទ្យុផងដែរ។ ជាពិសេស សុន្ទរកថាដែលបានធ្វើឡើងដោយ "តំណាងអង្គការបក្ស" នៅក្នុងឱកាសសន្និបាតភូមិភាគបស្ចិមប្រារព្ធនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ ត្រូវបានបោះពុម្ពក្នុងទស្សនាវដ្តី*ទង់បដិវត្ត* លេខខែសីហា ឆ្នាំ១៩៧៧[3873]។ សាក្សីឈ្មោះ [លុប] អតីតអនុមេបញ្ជាការកងពលលេខ១ និយាយថាគាត់បានចូលរួមការប្រជុំរបស់ភូមិភាគបស្ចិមនេះ ដែលមានអ្នកចូលរួមមកពីគណៈកម្មាធិការ ស្រុក តំបន់ និង ភូមិភាគផ្សេងៗ ព្រមទាំងលេខា និងអនុលេខាកងពលនានារបស់ភូមិភាគបស្ចិម។ សាក្សីមិនបានចងចាំអំពីវត្តមានរបស់ នួន ជា ទេ ប៉ុន្តែគាត់បានទទួលស្គាល់ថា វត្តមានរបស់ នួន ជា មិនអាចបដិសេធបានទេ ដោយសារជាធម្មតា ប៉ុល ពត និង នួន ជា តែងតែមានវត្តមានជានិច្ចនៅក្នុងសន្និបាតភូមិភាគ។ សាក្សីរូបនេះអាចអវត្តមាននៅពេលដែល នួន ជា មានវត្តមាននៅឯសន្និបាត ដោយសារសាក្សីអាចជាប់រវល់ជាមួយកិច្ចការយោធា[3874]។ សុន្ទរកថាដ៏វែងនេះដែលត្រូវបានយកមកបោះពុម្ពនៅក្នុងទស្សនាវដ្តី*ទង់បដិវត្ត* បានរៀបរាប់យ៉ាងលម្អិតអំពីកិច្ចការដែលភូមិភាគបស្ចិមបានធ្វើក្នុង "*ការបោសសម្អាតនូវសមាសភាពមិនល្អ និងជនក្បត់ទាំងឡាយនៅក្នុងភូមិភាគរបស់ខ្លួន*"[3875]។ ជាចុងក្រោយ អត្ថបទនោះបានស្នើឡើងថា "*ថ្នាក់ដឹកនាំបក្សគ្រប់ថ្នាក់យកចិត្តទុកដាក់ពិនិត្យពិចារណាសិក្សារៀនសូត្របទខនេ្ទសនាមនេះឲ្យបានហ្មត់ចត់ ដើម្បីយកទៅអនុវត្តទៅតាមភូមិភាគរបស់ខ្លួនបានលទ្ធផលល្អ*"[3876]។ [លុប] បានបញ្ជាក់ថា នៅក្នុងសន្និបាតនេះ មានការពិភាក្សា "*អំពីការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង*"[3877]។ ទោះបីជាថា នួន ជា បានឬមិនបានថ្លែងសុន្ទរកថានេះក៏ដោយ នួន ជា ពិតជាបានចូលរួមក្នុងការតាក់តែងទស្សនាវដ្តី *ទង់បដិវត្ត* លេខនេះក៏ដូចជាក្នុងការចាប់ខ្លួននៅក្នុងភូមិភាគបស្ចិម ឬយ៉ាងហោចណាស់បានដឹងអំពីការចាប់ខ្លួនទាំងនោះ តាមរយៈតួនាទីរបស់គាត់ក្នុងផ្នែកឃោសនាការរបស់ ប.ក.ក., ទូរលេខផ្ញើពីភូមិភាគបស្ចិមមកមជ្ឈិមបក្សរបស់ ប.ក.ក[3878] និងតួនាទីរបស់គាត់ជាអ្នកគ្រប់គ្រង មន្ទីរស-២១។

៩២៦. ចំពោះបញ្ហា "ខុសសីលធម៌" អ្នកកាន់ទូរលេខឈ្មោះ [លុប] បញ្ជាក់ថា អ្វីៗដែលពាក់ព័ន្ធនឹង "*បញ្ហាខុសសីលធម៌*" ត្រូវបញ្ជូនទៅឲ្យ នួន ជា ហើយថាអំពើរំលោភសន្ថវៈគឺជាទម្រង់មួយនៃអំពើខុសសីលធម៌[3879]។ គាត់ក៏ពន្យល់ផងដែរថា "*អ្នកដឹកនាំទាល់តែមានភាពជាអ្នកដឹកនាំ មាន*

*គុណសីលធម៌ មានឆន្ទៈរឹងប៉ឹង និងសីលធម៌រស់នៅល្អ"* បើមិនដូច្នេះទេ ពួកគេនឹងត្រូវ *"ដកចេញ ឬយកទៅលត់ដំនៅកន្លែងផ្សេង"*[3880]។ បញ្ហានេះត្រូវបាន នួន ជា ខ្លួនឯងផ្ទាល់បានលើកឡើងនៅក្នុងបទសម្ភាសន៍មួយក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យថា "សមមិត្តមិនល្អ" ត្រូវបានធ្វើការអប់រំកែប្រែ និងដកចេញពីតួនាទី និងបានបន្ថែមថា *"នៅក្នុងរយៈពេលដែលខ្ញុំកាន់អំណាច ក្មេងស្រីមិនដេកនៅជាមួយក្មេងប្រុសទេ"*[3881]។ នួន ជា ត្រូវបានចម្លងជូននូវទូរលេខរាយការណ៍អំពីបុរសដែលត្រូវបានចោទប្រកាន់ថា ខុសសីលធម៌ជាមួយស្ត្រីម្នាក់ ហើយពួកគេត្រូវបានចាត់ទុកថាជា "ខ្មាំង"[3882]។

**៩២៧.** នៅក្នុងវគ្គអប់រំរៀនសូត្រជាច្រើន នួន ជា បានណែនាំកម្មាភិបាល ប.ក.ក អំពីក្រមសីលធម៌ បដិវត្តន៍របស់ ប.ក.ក។ [លុប] ដែលជាកងការពារ និងជានីរសាររបស់ នួន ជា បានបញ្ជាក់ថា នៅក្នុងវគ្គអប់រំរៀនសូត្រសម្រាប់កងការពារ នួន ជា បានណែនាំកងការពារទាំងអស់អំពី *"សីលធម៌ ១២ ប្រការគឺ ប្រកាន់ភាពស្មោះត្រង់ កុំឱ្យប៉ះពាល់ស្រី កុំឱ្យលួច កុំនិយាយកុហក"* ហើយប្រការទាំងនេះត្រូវបានសរសេរចូលទៅក្នុងសៀវភៅ ដែលគាត់ធ្លាប់បានអាន។ គាត់យល់ថា *"បើខ្ញុំបំពានសីលធម៌នោះ ខ្ញុំនឹងស្លាប់ហើយ"*[3883]។ នៅរង្វង់ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [លុប] អតីតលេខាឃុំ បានចូលរួមក្នុងវគ្គប្រជុំរៀនសូត្រនៅឯបូរីកីឡាក្នុងទីក្រុងភ្នំពេញជាមួយ នួន ជា។ គាត់បាននិយាយថា *"អ្នកចូលរួមត្រូវបានចែកឯកសារចំនួនប្រហែល ១០ សន្លឹក។ [...] ឯកសារនោះ គឺជាលក្ខន្តិកៈបក្សដែលមានខ្លឹមសារថា "ត្រូវម្ចាស់ការកុំឱ្យងាករេ កុំឱ្យក្បត់ ត្រូវមានសីលធម៌ កុំមានស្រីញី កុំប៉ះពាល់របស់របបររបស់ប្រជាជន កុំអួតអាងថាខ្លួនឯងជាអ្នកធំ ច្រងើងច្រងាង..."*[3884]។ ឌុច ក៏បានលើកឡើងផងដែរថា នួន ជា បានបង្រៀនអំពីគោលការណ៍សីលធម៌ ១២ ប្រការ នៅក្នុងវគ្គរៀនសូត្រ[3885]។

<u>ការដឹងឮ និង ការពាក់ព័ន្ធនឹងការចាប់ "ខ្មាំង"</u>

**៩២៨.** នួន ជា ដឹងឮ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចាប់ខ្លួន "ខ្មាំង" ជាក់ស្ដែង ការចាប់ខ្លួននៅក្នុងជួរបក្ស និងរួមទាំងនៅគ្រប់កម្រិតនៃឋានានុក្រមបក្ស។

**៩២៩.** ពាក់ព័ន្ធនឹងការសម្លាប់ជុំវិញមជ្ឈិម ប.ក.ក ឌុច គ្រាន់តែបានដឹងច្បាស់អំពីឋានានុក្រមនៅពីលើគាត់ផ្ទាល់ប៉ុណ្ណោះ ប៉ុន្តែគាត់មិនបានដឹងព័ត៌មានលម្អិតអំពីដំណើរការធ្វើសេចក្ដីសម្រេចចំពោះការចាប់

ខ្លួនទេ។ គាត់ទើបតែបានដឹងអំពីសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នៅពេលដែលគាត់បានចូលមើលសំណុំរឿងតែប៉ុណ្ណោះ[3886]។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈបទពិសោធន៍នៅមន្ទីរ ស-២១ របស់គាត់ និងជាមួយនឹងការដឹងឮ ដែលគាត់មាននៅពេលនោះ ឌុច មានលទ្ធភាពក្នុងការសន្និដ្ឋានបានថា ផែនការដែលបានដាក់ចុះនៅក្នុងសេចក្ដីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹង *"សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ"* ត្រូវបានយកមក អនុវត្ត[3887]។

៩៣០. ឌុច យល់ថា គណៈភូមិភាគមានអំណាចចាប់ខ្លួន "កម្មាភិបាលថ្នាក់កណ្ដាល" ប៉ុន្តែមិនមានអំណាចចាប់ខ្លួនកម្មាភិបាលថ្នាក់ខ្ពស់ជាងទេ ហើយគាត់ថា គណៈភូមិភាគ ត្រូវរាយការណ៍អំពីការចាប់ខ្លួនដែលបានធ្វើទៅ **នួន ជា**[3888]។ ចំណុចនេះត្រូវបានបញ្ជាក់ដោយករណីឈ្មោះ **សាន់ អ៊ាប** ហៅ **ខុន** និង **ស៊ើយ** ហៅ **ផង់** ដែលជាកម្មាភិបាលពីររូបរបស់តំបន់ ១០៣ នៃភូមិភាគឧត្តរថ្មី ដែលទំនងជាត្រូវបានចាប់ខ្លួនតាមការផ្ដួចផ្ដើមរបស់លេខាភូមិភាគឈ្មោះ **សែ**។ បន្ទាប់មក **សែ** បានធ្វើចម្លើយសារភាពទៅកាន់មជ្ឈិម ប.ក.ក ហើយទំនងជាថា **នួន ជា** បានធ្វើចំណារលើចម្លើយសារភាពទាំងនោះ[3889]។

៩៣១. ទូរលេខជាច្រើន ដែលផ្ញើមកពីភូមិភាគ តំបន់ស្វយ័ត និងកងពលនានារបស់មជ្ឈិម ដែលចម្លងជូន **នួន ជា** រាយការណ៍ពីស្ថានការណ៍របស់ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅជួរ ព្រមទាំងចំណាត់ការនានាប្រឆាំងនឹងខ្មាំងទាំងនោះ[3890]។ ទូរលេខទាំងនេះបានសរសេរថា *"យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត"*[3891] ឬ *"អាខ្លះបញ្ចេញបាន ត្រូវឯកោ និងសម្អាត"*[3892]។ នៅក្នុងទូរលេខទាំងនោះមានការប្រើវាក្យស័ព្ទ ដូចជា*"បោសសម្អាតសម្រិតសម្រាំងវាជាប់"*[3893] *"ពួកក្បត់ផ្ទៃក្នុងបានបោសសម្អាត"*[3894] *"បោសសម្អាតខ្មាំងបង្កប់"*[3895] *"រុករកខ្មាំង"*[3896] *"រកក្បាលម៉ាស៊ីនខ្មាំងតទៅទៀត"*[3897] ព្រមទាំង *"កម្ទេចខ្មាំងគ្រប់បែបយ៉ាង"*[3898]។ [លុប] បានបញ្ជាក់យថាភូតភាពរបស់ទូរលេខទាំងនេះមួយចំនួន ហើយបានពន្យល់ថា៖ អក្សរសរសេរថា *"អ៊ំ នួន"* នៅត្រង់កន្លែង "ចម្លងជូន" សំដៅ **នួន ជា** ហើយមានន័យថាទូរលេខនោះត្រូវប្រគល់ទៅឱ្យ **នួន ជា**[3899]។ [លុប] ជាអតីតមេបញ្ជាការយោធា និងជាលេខាតំបន់១០៥ ត្រូវបានសាកសួរពីបញ្ហាទាក់ទងនឹងទូរលេខមួយចំនួនដែលគាត់បានសរសេរ ហើយមាននៅសេសសល់។ ទូរលេខទាំងនេះ រាយការណ៍ពីស្ថានការណ៍ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ការចាប់ខ្លួននានាដែលត្រូវបានធ្វើឡើង និងបុគ្គលដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាព[3900]។ គាត់បានពន្យល់ថា នៅពេល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ដែលគាត់សរសេរនៅក្នុងទូរលេខដោយដាក់ថា *"គោរពជូនបង ម-៨៧០"* បានសេចក្តីថា *"គណៈមជ្ឈិម"* រួមមាន នួន ជា។ ឆ្លើយតបនឹងសំណួរដែលត្រូវបានសួរថា តើសាក្សីបានទទួលចម្លើយតបមកវិញដែរឬទេនោះ សាក្សីនេះនិយាយថា ទូរលេខតែងតែមានការឆ្លើយតបជានិច្ច ដោយភ្ជាប់មកជាមួយសេចក្តីណែនាំផ្សេងៗពី ប៉ុល ពត ឬ ពី នួន ជា[3901]។ សាក្សីឈ្មោះ [លុប] ដែលធ្លាប់ធ្វើការនៅមន្ទីរ ក-១ បានបញ្ជាក់ថា នៅពេលទូរលេខ ឬលិខិតណាមួយមកដល់មន្ទីររបស់ប៉ង់ គាត់គឺជាអ្នកទទួលបន្ទុកជាញឹកញាប់ក្នុងការទទួលយកទូរលេខ ឬលិខិតទាំងនោះទៅឱ្យ ប៉ុល ពត។ ក្រោយពី ប៉ុល ពត បានអានរួចហើយ គាត់នឹងយកទូរលេខ ឬលិខិតទាំងនោះទៅឱ្យ នួន ជា។ ជាការតបមកវិញ នួន ជា បានសរសេរលិខិតផ្ញើទៅឱ្យ ប៉ុល ពត ជារៀងរាល់ថ្ងៃ ឬ ពីរថ្ងៃម្តង[3902]។

**៩៣២.** ពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្សនៅក្នុងអង្គភាពរដ្ឋបាល ជាពិសេសកម្មាភិបាលជាន់ខ្ពស់មួយចំនួនរបស់ ប.ក.ក នៅភូមិភាគ និងកម្មាភិបាល ប.ក.ក នៅតាមបណ្តាក្រសួង និងមន្ទីរមជ្ឈិម ឌុច ជឿជាក់ថា ការចាប់ខ្លួននេះត្រូវបានសម្រេចដោយបុគ្គលម្នាក់ ដែលស្ថិតនៅពីលើ សុន សេន៖ *"គឺប្រហែលជាអាច ប៉ុល ពត ឬ នួន ជា។ បានវាចុះមកដល់ត្រឹម សុន សេន"*[3903]។ ចំពោះការចាប់ខ្លួននៅក្នុងអង្គភាពយោធា ឌុច សង្កេតឃើញថា ការសម្រេចទាំងនេះអាចត្រូវធ្វើឡើងដោយ សុន សេន ដោយសារគាត់គឺជានាយសេនាធិការ[3904]។ យ៉ាងណាក៏ដោយ គាត់ក៏បានលើកឡើងផងដែរថា ប៉ុល ពត និង នួន ជា បានដើរតួនាទីនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចទាំងនេះ។ ឌុច បានលើកឡើងថា៖ *"សម្រិតសម្រាំងកម្លាំងណាមុន កម្លាំងណាក្រោយ ជាទិសដៅដែលអចិន្ត្រៃយ៍កំណត់ និយាយឱ្យចំ គឺប៉ុល ពត ជាអ្នកកំណត់។ តើដំណើរការយ៉ាងម៉េច គឺ នួន ជា និង សុន សេន ជាអ្នកគិតគូរ"*[3905]។

**៩៣៣.** ឌុច នៅតែលើកឡើងដដែលៗថា សុន សេន នួន ជា និង ប៉ុល ពត គឺជាបុគ្គលសំខាន់ក្នុងការធ្វើសេចក្តីសម្រេច ដែលអាចធ្វើដាច់ដោយឡែក ឬរួមគ្នា ក្នុងការចាប់ខ្លួន។ ឌុច យល់ឃើញថា ប៉ុល ពត មានការពាក់ព័ន្ធយ៉ាងពិតប្រាកដនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ហើយ ឌុច បានពន្យល់ថា ទោះបីជា គាត់មិនបានដឹងឮពីការលម្អិតដោយផ្ទាល់ក៏ដោយ ក៏គាត់បានធ្វើការកត់សម្គាល់ថា នួន ជា ជានិច្ចកាលមិនអាចធ្វើការសម្រេចចិត្តតែឯកឯងបានទេ ហើយ *"ពេលខ្លះគាត់ត្រូវសួរទៅ ប៉ុល ពត សិន"*[3906]។ គាត់ជឿជាក់ថានៅពេល ប៉ុល ពត ធ្វើការសម្រេចចិត្តឱ្យចាប់ខ្លួននោះ នួន ជា គឺជាអ្នកទទួលខុសត្រូវក្នុងការធានាពីការប្រតិបត្តិតាមបញ្ជាឱ្យបានត្រឹមត្រូវ[3907]។ យ៉ាងណាក៏ដោយ ឌុច ពន្យល់ថា នួន ជា នៅមានអំណាចបង្គាប់ឱ្យមានការចាប់ខ្លួនមនុស្សដែលត្រូវបានឆ្លើយដាក់

នៅក្នុងចម្លើយសារភាព ដូចជាគាត់បានសម្រេចឱ្យមានការចាប់ខ្លួនបុគ្គលមួយចំនួនក្នុងពេលកំពុងមានអង្គប្រជុំ ជាក់ស្តែងដូចជាការចាប់ខ្លួនសមាជិកបុគ្គលិកមន្ទីរ ស-២១ ជាដើម[3908]។ ឌុច ក៏បញ្ជាក់ដែរថា នួន ជា មានអំណាចក្នុងការសម្រេចថាអ្វីដែលគួរសរសេរ ឬមិនត្រូវសរសេរនៅក្នុងចម្លើយសារភាព រួមមានលទ្ធភាពក្នុងការលុបឈ្មោះជនមួយចំនួន ដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាព ជាក់ស្តែងនៅពេលដែលមានឈ្មោះ ខៀវ សំផន បានលេចឡើង[3909]។

៩៣៤. ដោយផ្អែកលើបទពិសោធន៍របស់គាត់ផ្ទាល់នៅឯមន្ទីរ ស-២១ ឌុច យល់ឃើញថាមានវិធីពីរយ៉ាងក្នុងការចាប់ខ្លួនមនុស្ស។ ទីមួយ អង្គភាពមួយអាចរាយការណ៍ទៅឱ្យថ្នាក់លើ និងស្នើឱ្យមានការចាប់ខ្លួន[3910]។ វិធីនេះមានបញ្ជាក់តាមរយៈចម្លើយសារភាពរបស់ សាន់ អ៊ាប ហៅ ខុន មកពីគណៈពាណិជ្ជកម្មតំបន់១០៣ នៃសាខាភ្នំពេញ ដែលត្រូវបានលេខាភូមិភាគឧត្តរថ្មីផ្ញើទៅឱ្យ *"គណៈ៨៧០"* នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨។ នៅក្នុងលិខិតអមមួយ កង ចាប ហៅ សែ បានសរសេរថាគាត់បានផ្ញើចម្លើយសារភាពនេះ ជាមួយនឹងចម្លើយសារភាពរបស់អ្នកផ្សេងទៀត ទៅឱ្យគណៈ ៨៧០ ពិនិត្យដើម្បីស្រាវជ្រាវខ្សែ "ក្បត់" បង្កប់ស៊ីរូងផ្ទៃក្នុង[3911]។ ឌុច ក៏ជឿជាក់ថាផងដែរថា ចំណារសរសេរថា *"១៩/៤/១៩៧៨ តាមដាន"* នៅលើទំព័រខាងមុខ ត្រូវបានសរសេរដោយ នួន ជា[3912]។

៩៣៥. ទីពីរ ឌុច ជឿជាក់ថា នៅពេលដែលបុគ្គលម្នាក់ ឬមនុស្សមួយក្រុម គឺជាមនុស្សចាំបាច់ដែលត្រូវចាប់ខ្លួននោះ នួន ជា នឹងទាក់ទងទៅអង្គភាពពាក់ព័ន្ធដើម្បីទទួលបានព័ត៌មាន ដែលបន្ទាប់មកសេចក្តីសម្រេចរួមមួយនឹងត្រូវធ្វើឡើង[3913]។ ដូច្នេះ ឌុច យល់ថាចម្លើយសារភាពនៅមន្ទីរ ស-២១ ត្រូវបានចែកចាយដោយ នួន ជា និង/ឬ ប៉ុល ពត ទៅឱ្យភូមិភាគ មន្ទីរមជ្ឈិម និងតាមបណ្តាក្រសួងដែលពាក់ព័ន្ធផ្សេងៗ[3914]។ ចំណារនៅលើចម្លើយសារភាពបង្ហាញថា មានចម្លើយសារភាពនៅមន្ទីរ ស-២១ មួយចំនួនត្រូវបានបញ្ជូនទៅអង្គភាពពាក់ព័ន្ធផ្សេងៗ[3915]។ ឌុច បានបញ្ជាក់ពីអក្សរសរសេរដោយដៃរបស់ នួន ជា នៅលើចម្លើយសារភាពមួយចំនួននៃចម្លើយសារភាពទាំងនេះ[3916]។ សុន សេន ក៏បានប្រើប្រាស់វិធីស្រដៀងគ្នា ក្នុងការចាប់មនុស្សនៅក្នុងអង្គភាពយោធា[3917]។

## តួនាទីក្នុងការបោសសម្អាតភូមិភាគកណ្តាល (ឧត្តរចាស់) និងតំបន់១០៦

៩៣៦. ប៉ុន្មានថ្ងៃក្រោយពីគណៈមជ្ឈិមបានចេញសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ លេខា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

អតីតភូមិភាគឧត្តរ ឈ្មោះ កែ ពក បានជូនដំណឹងដល់ ប៉ុល ពត និង នួន ជា អំពីការប្តេជ្ញារបស់គាត់ ក្នុងការចេញវិធានការប្រឆាំងនឹងពួកក្បត់នៅក្នុងជួរបដិវត្តន៍[3918] ដូចមានរៀបរាប់នៅក្នុងផ្នែកស្តីពីការបោសសម្អាតនៅភូមិភាគកណ្តាល (ឧត្តរចាស់) ក្នុងរយៈពេលខ្លី បន្ទាប់ពី កុយ ធួន ត្រូវបានឃុំខ្លួននៅក្នុងផ្ទះ និងក្រោយមកត្រូវបានចាប់ខ្លួន។ ខៀវ សំផន បានប្រាប់ថា ការសម្រេចចាប់ខ្លួន កុយ ធួន ធ្វើឡើងដោយគណៈអចិន្ត្រៃយ៍[3919]។ កុយ ធួន ត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ហើយនៅពេលនោះ ឌុច បានទទួលការណែនាំពីសំណាក់ សុន សេន ទាក់ទងនឹងការសួរចម្លើយ និងសម្លាប់ កុយ ធួន[3920]។ ការចាប់ខ្លួន កុយ ធួន បណ្តាលឱ្យមានការចាប់ខ្លួនកម្មាភិបាល ប.ក.ក និងសមាជិកកងទ័ពបដិវត្តន៍កម្ពុជាជាច្រើន ជាពិសេសអ្នកដែលមកពី ឬជាប់ពាក់ព័ន្ធនឹងភូមិភាគកណ្តាល (ឧត្តរចាស់)[3921]។ មុនពេលស្លាប់ កែ ពក លេខាភូមិភាគកណ្តាល (ឧត្តរចាស់) បានលើកឡើងថា គាត់បានជួប ប៉ុល ពត និង នួន ជា នៅភ្នំពេញ ហើយនៅពេលនោះ ប៉ុល ពត និង នួន ជា បានបង្ហាញគាត់នូវឯកសារដែលមានការឆ្លើយដាក់កម្មាភិបាល និងយោធាមកពីភូមិភាគកណ្តាល (ឧត្តរចាស់)។ កែ ពក បានបន្ថែមថា គាត់ជឿថា ប៉ុល ពត និង នួន ជា បានសម្រេចរួចហើយអំពីការចាប់ខ្លួននេះ[3922]។ នួន ជា បានទទួលចម្លើយសារភាពរបស់កម្មាភិបាល និងសមាជិកយោធានានានៃភូមិភាគកណ្តាល (ឧត្តរចាស់) នៅឆ្នាំ១៩៧៧ ពីមន្ទីរ ស-២១[3923] ហើយ នួន ជា បានសួរសុខទុក្ខ កែ ពក នៅខេត្តកំពង់ចាម ក្នុងឆមាសដំបូងនៅឆ្នាំ១៩៧៧[3924]។ សាក្សីមួយចំនួនផ្តល់សក្ខីកម្មបន្ថែមថា ពួកគេបានចូលរួមនៅក្នុងវគ្គរៀនសូត្រនយោបាយ ដែលដឹកនាំបង្រៀនដោយ នួន ជា ដែលពេលនោះ គាត់បានចាក់ខ្សែអាត់សំឡេងសារភាពរបស់ កុយ ធួន និងបាននិយាយថា កុយ ធួន គឺជាជនក្បត់មានទំនាក់ទំនងជាមួយសេ.អ៊ី.អា (CIA) ហើយជនទាំងឡាយដែលមានជាប់ពាក់ព័ន្ធនឹង កុយ ធួន ត្រូវបានចាប់ខ្លួន[3925]។ ក្រោយពីមានការចាប់ខ្លួន កុយ ធួន និងខ្សែរយៈដែលមានជាប់ពាក់ព័ន្ធរបស់គាត់មកតំបន់១០៦ ត្រូវបានបោសសម្អាត និងជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី ដឹកនាំដោយលេខាតំបន់៣៥ ឈ្មោះ ចាន់ សាន ហៅ កង ចាប ហៅ សែ ដែលបានក្លាយជាលេខារបស់ភូមិភាគឧត្តរថ្មី (៨០១) នៅពាក់កណ្តាលឆ្នាំ១៩៧៧[3926]។ សាក្សីមួយរូបលើកឡើងថា នួន ជា បានប្រកាសនៅក្នុងអង្គប្រជុំនៅឯមន្ទីររបស់តំបន់១០៣ នៅខេត្តព្រះវិហារ ពីការបង្កើតភូមិភាគឧត្តរថ្មី និងការចាត់តាំង កង ចាប ហៅ សែ ជាលេខានៃភូមិភាគនោះ[3927]។

<u>**តួនាទីក្នុងការបោសសម្អាតភូមិភាគបូព៌ា**</u>

**៩៣៧.** នួន ជា បានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ដែលឈានទៅដល់

ការចាប់ខ្លួន "ខ្មាំងនៅក្នុងជួរបក្ស" ទាំងនៅក្នុង ប.ក.ក និង កងទ័ពបដិវត្តន៍កម្ពុជា ដែលមកពី និង មានជាប់ពាក់ព័ន្ធនឹងភូមិភាគបូព៌ា ក៏ដូចជាការអនុវត្តន៍សេចក្តីសម្រេចនេះ។

៩៣៨. មានភស្តុតាងបង្ហាញថា នួន ជា ពាក់ព័ន្ធតាំងពីដំបូងទៅនឹងការបោសសម្អាតភូមិភាគបូព៌ា ជាពិសេសការចាប់ខ្លួនលេខាតំបន់២៤ ឈ្មោះ **សួស នៅ** ហៅ ឈូក។[3928]

៩៣៩. [លុប] រំលឹកឲ្យដឹងថា គាត់បានឮជាលើកដំបូងពីផែនការដកកម្លាំងទ័ពមកពីនិរតី ដើម្បីឲ្យចូលរួមក្នុងការបោសសម្អាតពួកដែលត្រូវបានចោទថាចូលដៃជាមួយវៀតណាមនៅភូមិភាគបូព៌ា ក្នុងពេលប្រជុំដែលធ្វើនៅខេត្តតាកែវ នៅផ្ទះ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី ក្នុងឆ្នាំ១៩៧៧។ នៅពេលប្រជុំនោះ កងទ័ពត្រូវបានប្រាប់ថា នឹងត្រូវប្រយុទ្ធជាមួយវៀតណាម[3929]។ [លុប] រួមជាមួយនឹងទាហានប្រមាណជា ២៤០០-២៥០០នាក់ មកពីនិរតី ត្រូវបានហៅឲ្យមកភ្នំពេញ ដែលនៅទីនោះ [លុប] បានជួបជាមួយ **សុន សេន** ដែលចាប់ពីពេលនោះមក កងទ័ពទាំងនោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមបញ្ជារបស់ **សុន សេន**[3930] ដើម្បីរៀបចំអនុវត្តបេសកកម្មនេះ[3931]។ **សុន សេន** បាននិយាយបន្ថែមថា បេសកកម្មនេះរាប់បញ្ចូលនូវការបោសសម្អាតកម្មាភិបាល និងកងទ័ពភូមិភាគបូព៌ា។ ទោះបីជា **ប៉ុល ពត** និង **នួន ជា** មានវត្តមាននាពេលនោះក៏ដោយ ពួកគាត់មិនបានបន្ថែមមតិយោបល់អ្វីទៀតទេ[3932]។ បន្ទាប់ពីព្រឹត្តិការណ៍នេះ [លុប] ត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅខេត្តស្វាយរៀង (តំបន់២៣) ភាគខាងត្បូងនៃភូមិភាគបូព៌ា[3933]។ [លុប] បំភ្លឺថារយៈពេលប្រមាណកន្លះខែក្រោយមក នៅដើមឆ្នាំ១៩៧៨ គាត់បានចូលរួមនៅក្នុងអង្គប្រជុំមួយនៅទីក្រុងភ្នំពេញ ជាមួយមេបញ្ជាការជាន់ខ្ពស់យោធា នៅអគ្គសេនាធិការ។ [លុប] បញ្ជាក់ថា នៅក្នុងអង្គប្រជុំនោះ *"ប៉ុល ពត បាននិយាយពីផែនការ បោសសម្អាត ហើយបន្ទាប់មក* ***នួន ជា*** *បានយល់ស្របទៅនឹងអ្វី ដែល ប៉ុល ពត បាននិយាយ។* ***នួន ជា*** *និង ប៉ុល ពត បានផ្តល់ព័ត៌មានលម្អិតអំពីផែនការចាប់ខ្លួន និងដកកម្មាភិបាល ពីភូមិភាគបូព៌ា។ គាត់បាននិយាយថា ពួកគេទាំងនោះបានសហប្រតិបត្តិការជាមួយវៀតណាម ហើយពួកគេនឹងត្រូវបានចាប់ខ្លួន ដោយកម្មាភិបាលរបស់យើងមកពីភូមិភាគនិរតី"*[3934]។ [លុប] បានបន្ថែមទៀតថា **នួន ជា** បាននិយាយពី *"ការបោសសម្អាតខ្មាំងបង្កប់ស្បែងផ្ទៃក្នុង ខ្មាំងដែលជាដៃជើងយួន។* ***នួន ជា*** *បានបញ្ជាឲ្យចាប់ គឺបោសសម្អាត។ ជំនាន់នោះ ពាក្យ "បោសសម្អាត" បានន័យថា ចាប់និងសម្លាប់*[3935]"។ ទោះបីជា [លុប] លើកឡើងថា មេបញ្ជាការភូមិភាគនិរតីផងទៃទៀតមានវត្តមាននៅក្នុងអង្គប្រជុំនោះក៏ដោយ ក៏មេបញ្ជាការទាំងនេះ បានបដិសេធចំពោះការជួប **នួន ជា** ក្នុងអំឡុងរបបកម្ពុជា

ប្រជាធិបតេយ្យ[3936]។

៩៤០. [លុប] សន្និដ្ឋានថាការសម្រេចឱ្យមានការបោសសម្អាតភូមិភាគបូព៌ាត្រូវបានធ្វើដោយគណៈ អចិន្ត្រៃយ៍ ដែលមាន **សុន សេន** ជាអ្នកប្រតិបត្តិតាមបញ្ជារបស់ **ប៉ុល ពត**, **នួន ជា** និង**តា ម៉ុក**[3937]។ សាក្សីឈ្មោះ [លុប] ដែលធ្លាប់ធ្វើការងារជាមួយ **សុន សេន** នៅឯមន្ទីរវិទ្យុទាក់ទង និងភស្តុភាររបស់អគ្គសេនាធិការ ដំបូងនៅខេត្តស្វាយរៀង បន្ទាប់មកនៅតាមផ្លូវជាតិលេខ៧ នៅភាគខាងជើងនៃភូមិភាគបូព៌ា បានបញ្ជាក់ចំណុចនេះដោយនិយាយថា ការសម្រេចឱ្យមានការបោសសម្អាតភូមិភាគបូព៌ា ត្រូវបានធ្វើឡើង និងអនុវត្តក្រោមការត្រួតពិនិត្យរបស់មជ្ឈិម ប.ក.ក។ [លុប] [លុប] លើកឡើងថា ជាញឹកញាប់ **សុន សេន** *"ឡើងមករាយការណ៍ផ្ទាល់នៅគណៈមជ្ឈិម ហើយករណីតិចតួចធ្វើតាមទូរស័ព្ទសម្ងាត់ ទាំងពីរសមរភូមិនៅស្វាយរៀង និងស្នួល។ ខ្ញុំយល់ថា ការសម្រេចចាប់ខ្លួនកម្មាភិបាលដែលគេឆ្លើយដាក់ មិនមែនជាការសម្រេចត្រឹមតែ សុន សេន តែឯងទេ គឺទាល់តែមានការសម្រេចពីគណៈមជ្ឈិមទៀត"*[3938]។ គាត់បានបន្ថែមថា តាមអ្វីដែលគាត់អាចយល់បាន មានតែ **ប៉ុល ពត** ម្នាក់ប៉ុណ្ណោះ ដែលអាចចេញបញ្ជាឱ្យមានការបោសសម្អាតបែបនេះក្នុងភូមិភាគបូព៌ា[3939]។ ចម្លើយសារភាពមន្ទីរ ស-២១ របស់សមាជិកកងទ័ពបដិវត្តន៍កម្ពុជារបស់ភូមិភាគបូព៌ា ដែល **នួន ជា** បានធ្វើចំណារនៅចុងខែមីនា ឆ្នាំ១៩៧៨[3940] បង្ហាញថា **នួន ជា** ត្រូវបានជូនដំណឹងអំពីការចាប់ខ្លួនកម្មាភិបាល ប.ក.ក និងសមាជិករបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ ហើយ **នួន ជា** បានតាមដានការវិវត្តន៍លើបញ្ហានេះយ៉ាងជិតដល់។

៩៤១. **សោ ភឹម** ដែលជាលេខាភូមិភាគបូព៌ា និងជាសមាជិកគណៈមជ្ឈិម បានធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ១៩៧៨[3941]។ **ឌុច** ធ្វើការបកស្រាយថា ការចាប់ខ្លួន **សោ ភឹម** ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍ ហើយថា **សុន សេន** បានហៅ **សោ ភឹម** ពីសមរភូមិភូមិភាគបូព៌ា ដើម្បីប្រាប់ដំណឹងគាត់ថា មានការព្រមព្រៀងរួចរាល់ហើយ[3942]។ **សោ ភឹម** មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងអស់រយៈពេលជាយូរជាមួយស្រុកពញាក្រែក ហើយជាពិសេសជាមួយភូមិ "បុស្ស" ដែលស្ថិតនៅខាងលិចស្ទឹងតូច ប្រមាណ១០គីឡូម៉ែត្រ។ ថ្នាក់ដឹកនាំ ប.ក.ក រួមទាំង **នួន ជា** ក៏បានដឹងរឿងនេះដែរ[3943] ហើយអ្នកភូមិបុស្សត្រូវបានសម្លាប់បន្ទាប់ពី **សោ ភឹម** បានធ្វើអត្តឃាត[3944]។ បន្ថែមលើនេះទៀត សាក្សីមួយរូបបញ្ជាក់ថា ប្រជាជននៅភូមិបុស្ស ដែលក្រោយមកត្រូវបានបញ្ជូនទៅស្ទឹងតូច ដើម្បីសម្លាប់ ត្រូវបានប្រាប់ថា ពួកគេត្រូវធ្វើដំណើរទៅស្នួល ដើម្បីទៅជួបជាមួយ **នួន ជា**[3945]។

៩៤២. [លុប] ពន្យល់ថា **នួន ជា** បានចូលរួមនៅក្នុងអង្គប្រជុំមួយក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ដើម្បីតាក់តែង "សៀវភៅខ្មៅ" ស្តីពីគោលនយោបាយការបរទេសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចំពោះកម្ពុជាប្រជាធិបតេយ្យ។ សាក្សីរូបនេះបន្ថែមថា ក្នុងពេលប្រជុំ ប៉ុល ពត គឺជាអ្នកនិយាយច្រើនជាងគេ ហើយ *"នួន ជា ធ្វើជាអ្នកអង្កេតការណ៍ និងជាអ្នកចូលរួមអកម្ម"*[3946]។ សៀវភៅខ្មៅនេះមានផ្នែកខ្លះនិយាយពីយុទ្ធសាស្ត្ររបស់វៀតណាម ដែលត្រូវបានចោទប្រកាន់ថាបង្កើត *"បណ្តាញខ្មាំង"* នៅក្នុងជួរបក្ស ប.ក.ក និងបានលើកឡើងថា ពួកវៀតណាម បានជ្រៀតចូលមកក្នុងដែនដីកម្ពុជាជាសម្ងាត់ និងធ្វើការជួបប្រជុំនៅភូមិភាគបូព៌ា ក្នុងរវាងខែកុម្ភៈ និងឧសភា ឆ្នាំ១៩៧៨ *"ជាមួយនិងភ្នាក់ងារដែលវៀតណាមបានឲ្យជ្រៀតចូល និងចាត់តាំង តាំងពីយូរមកហើយ" "ដើម្បីអនុវត្តផែនការរដ្ឋប្រហារ"* ប៉ុន្តែ ផែនការនោះត្រូវបាន ប.ក.ក ធ្វើឲ្យបរាជ័យ[3947]។

<u>**តួនាទីនៅក្នុងការចាប់ខ្លួនកម្មាភិបាលមជ្ឈិមបក្ស និងកម្មាភិបាលមន្ទីរមជ្ឈិមបក្ស (មន្ទីរនយោបាយ ៨៧០ និងមន្ទីរ ស-៧១)**</u>

៩៤៣. **ឌុច** ពន្យល់ថា ចំពោះសមាជិកគណៈមជ្ឈិម ឬកម្មាភិបាលជាន់ខ្ពស់របស់ ប.ក.ក រាល់ការសម្រេចចាប់ខ្លួនទាំងអស់ត្រូវសម្រេចរួមគ្នាដោយគណៈអចិន្ត្រៃយ៍[3948]។ ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាអ្នកទទួលខុសត្រូវលើមន្ទីរស-២១ **នួន ជា** បានចូលរួមនៅក្នុងការចាប់ខ្លួន និងការសម្លាប់ ជាបន្តបន្ទាប់ (ឬករណីខ្លះជំរុញឲ្យមានការធ្វើអត្តឃាត) លេខាភូមិភាគនានា រួមមាន **សោ ភឹម** (ធ្វើអត្តឃាតក្នុងខែមិថុនា ឆ្នាំ១៩៧៨)[3949] និង **រស់ ញឹម** (ខែមិថុនា ឆ្នាំ១៩៧៨)[3950] **ជូ ជេត ហៅ ស៊ុី** (ខែមីនា ឆ្នាំ១៩៧៨)[3951] **ម៉ែន សាន ហៅ យ៉ា** (ខែកញ្ញា ឆ្នាំ១៩៧៦) **អ៊ុំ ណេង ហៅ វី** (ធ្វើអត្តឃាតក្នុងខែមិថុនា ឆ្នាំ១៩៧៨) និង **កង ចាប ហៅ សែ** (ខែសីហា ឆ្នាំ១៩៧៨) សមាជិកគណៈអចិន្ត្រៃយ៍ **វន វេត** (ខែវិច្ឆិកា ឆ្នាំ១៩៧៨) និង **គង់ សុផល ហៅ កឹ ហៅ កាន** (ខែវិច្ឆិកា ឆ្នាំ១៩៧៨) និង លេខាតំបន់ស្វយ័តនានា ដូចជា៖ **ប៊ូ ផាត ហៅ ហង់** (ខែមិថុនា ឆ្នាំ១៩៧៨) **ប៊ិន ណាន ហៅ យី** (ខែមិថុនា ឆ្នាំ១៩៧៨) និង **ប៉ា ផល ហៅ សុត** (ខែកុម្ភៈ ឆ្នាំ១៩៧៧) និង **ហ៊ូ នឹម** ជាអតីតរដ្ឋមន្ត្រីក្រសួងឃោសនាការ (ខែមេសា ឆ្នាំ១៩៧៧)[3952]។

៩៤៤. **នួន ជា** មានជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួនកម្មាភិបាលមកពីមន្ទីរមជ្ឈិមនានា។ សាក្សីមួយរូបបម្រើការងារនៅមន្ទីរក-១ ពន្យល់ថា នៅក្នុងមន្ទីរ ជនទាំងឡាយណាដែលត្រូវបានចោទថាក្បត់ជាតិនោះ គឺសុទ្ធតែជាបុគ្គលដែលមានតួនាទីសំខាន់ៗ ដូចជា **សែម** (អតីតប្រធានមន្ទីរក-១) **ឈឹម សំអោក**

ហៅ ប៉ង់ (ប្រធានមន្ទីរស-៧១) និងមិត្តភក្តិរបស់គាត់ម្នាក់ ឈ្មោះ **យ៉ន** ហើយសាក្សីប្រាប់ទៀតថា មនុស្សទាំងនេះ ត្រូវបានគេនាំខ្លួនយកទៅ ហើយបាត់ខ្លួនតែម្តង។ គាត់បានបន្ថែមថា *"រឿងនេះ ខ្ញុំយល់ថា អ៊ំ១ ពិសេស ប៉ុល ពត នួន ជា ដឹងហើយពីការចាប់ខ្លួន និងក្បត់នេះ"*[3953]។ **នួន ជា** បានទទួល បានធ្វើចំណារ និងបានបញ្ជូនចម្លើយសារភាពពីមន្ទីរ ស-២១ របស់អតីតលេខាមន្ទីរ៨៧០ និងជាអ្នកកត់ត្រាកំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ ឈ្មោះ **ដោគ ឆាយ** ហៅ ទូច ទៅឱ្យ ប៉ុល ពត[3954]។ ចំពោះការចាប់ខ្លួន **ឈឹម សំអោក** ហៅ **ប៉ង់**, ឌុច បកស្រាយថា **វន វេត** បានមកកាន់មន្ទីរ ស-២១ ដោយនាំមកនូវជាមួយលិខិតមួយច្បាប់របស់ **នួន ជា** ដែលផ្តល់ការអនុញ្ញាតជាពិសេសឱ្យគាត់ធ្វើការជាមួយ ឌុច លើបញ្ហាសន្តិសុខ ព្រមទាំងបានប្រាប់គាត់អំពីការសម្រេចរបស់ "បក្ស" ក្នុងការចាប់ខ្លួន **ប៉ង់**។ គាត់បានពិភាក្សាជាមួយ **វន វេត** ពីស្ថានភាពនៃការចាប់ខ្លួន ហើយបានសម្រេចថា នៅពេលដែល **ប៉ង់** មកទទួលយកចម្លើយសារភាព ពីមន្ទីរ ស-២១ លើកក្រោយ **ប៉ង់** នឹងត្រូវចាប់ខ្លួនភ្លាមតែម្តង។ ឌុច ជឿជាក់ថា **នួន ជា** ជាអ្នកចេញបញ្ជាឱ្យចាប់ខ្លួននេះ[3955]។ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មនុស្សចំនួន ២០៩ នាក់ មកពីមន្ទីរនយោបាយ៨៧០ និងមន្ទីរ ស-៧១ និងអង្គភាពក្រោមចំណុះរបស់មន្ទីរទាំងនោះ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ នៅក្នុងបរិបទនៃការបោសសម្អាតទាំងនេះ ដូចមានរៀបរាប់នៅក្នុងផ្នែកអង្គហេតុទាក់ទងនឹងមន្ទីរ ស-២១។

**<u>តួនាទីនៅក្នុងការចាប់ខ្លួននៅក្រសួងសង្គមកិច្ច និងក្រសួងឃោសនាការ និងសិក្សាធិការ</u>**

**៩៤៥.** ដូចដែលបានលើកឡើងខាងលើ នៅខែតុលា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានឱ្យ **នួន ជា** ទទួលបន្ទុកសង្គមកិច្ច ឃោសនាការ និងសិក្សាធិការ។ អនុលោមតាមការប្រគល់អំណាចនេះ ឌុច យល់ឃើញថា **នួន ជា** បានត្រួតត្រាលើសកម្មភាពការងាររបស់ក្រសួងសង្គមកិច្ច ក្រសួងឃោសនាការ និងក្រសួងអប់រំ ដោយសារថា រដ្ឋមន្ត្រីក្រសួងទាំងនោះ *"មិនមានអំណាចសម្រេចលើការកម្ទេចនរណាម្នាក់នោះទេ"*[3956]។

**៩៤៦.** ឌុច ពន្យល់ថា វិធីនៃការចាប់ខ្លួន និងការបញ្ជូនទៅមន្ទីរ ស-២១ ដែលប្រព្រឹត្តលើបុគ្គលិកមកពី ឬនៅក្រោមអំណាចរបស់ក្រសួងសង្គមកិច្ច គឺមិនខុសគ្នាពីវិធីដូចមានរៀបរាប់ខាងលើនោះទេ។ ឌុច បញ្ជាក់ថា គាត់បានផ្ញើចម្លើយសារភាពដែលឆ្លើយដាក់បុគ្គលិកមកពី ឬនៅក្រោមអំណាចរបស់ក្រសួងពាក់ព័ន្ធ ទៅឱ្យ **សុន សេន** (ហើយ ក្រោយថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ផ្ញើទៅឱ្យ **នួន ជា** វិញ) ដែលក្រោយមក *"ផ្ទាក់លើ (សុន សេន និងបន្ទាប់មក នួន ជា) កត់សម្គាល់ឃើញ*

*ឈ្មោះមនុស្សដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព គេកោះហៅប្រធាននៃអង្គភាពរបស់អ្នកនោះ (ក្នុងករណីយើង គឺ អៀង ធីរិទ្ធ ដើម្បីសម្រេច)"*[3957] ។ នួន ជា បានទទួល បាន ផ្ញើចំណារ និងបានបញ្ជូនចម្លើយសារភាពមួយចំនួនពីមន្ទីរ ស-២១ ទៅឱ្យក្រសួងសង្គមកិច្ច ជាពិសេសទៅឱ្យ **អៀង ធីរិទ្ធ**[3958]។ ឌុច ក៏ពន្យល់ដែរថា ឯកសារដែលគាត់បានផ្ញើទៅ **នួន ជា** បានផ្ដល់ជាមូលដ្ឋាន ក្នុងការចាប់ខ្លួនមនុស្សក្នុងក្រសួងសង្គមកិច្ច[3959]។ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មនុស្សចំនួន ១១៦នាក់ មកពីក្រសួងសង្គមកិច្ច និង អង្គភាពផ្សេងៗចំណុះឱ្យក្រសួងនេះ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ នៅក្នុងបរិបទ នៃការបោសសម្អាតទាំងនេះ ដូចមានរៀបរាប់នៅក្នុងផ្នែកអង្គហេតុទាក់ទងនឹងមន្ទីរ ស-២១។

**៩៤៧.** ប្រព័ន្ធនៃការចាប់ខ្លួនដែលបានរៀបរាប់ខាងលើ ទំនងជាត្រូវបានអនុវត្តផងដែរនៅក្នុងក្រសួង ឃោសនាការ និងសិក្សាធិការ នៅពេលដែល **នួន ជា** បានគ្រប់គ្រងក្រសួងឃោសនាការ និង សិក្សាធិការនេះ នៅចុងឆ្នាំ១៩៧៨។ អ្នកខ្លះដែលបម្រើការនៅក្រសួងនេះត្រូវបានគេចាត់ទុកថាជា ពួកក្បត់ ហើយក៏បានបាត់ខ្លួន[3960] ឯរដ្ឋមន្ត្រី និងកម្មាភិបាលដឹកនាំមកពីក្រសួងនេះអាចចូលរួមក្នុង អង្គប្រជុំជាទៀងទាត់ជាមួយ "ថ្នាក់លើ"[3961]។ សាក្សីមួយរូបពន្យល់ថា នៅពេលដែល **នួន ជា** ធ្វើជា រដ្ឋមន្ត្រី *"ក៏នៅមានការបាត់ខ្លួនជាបន្តបន្ទាប់ដដែល។ បើតាមខ្ញុំយល់ខ្លះគឺថា អ្នកខាងនិរតីគឺជា អ្នកបដិវត្តន៍ល្អ ហើយក្រោយពេលពួកបូព៌ា និង ពួកបស្ចិម ត្រូវបានបោសសម្អាត ភាគច្រើនគេ បញ្ជូនពួកនិរតីទៅជំនួស"*[3962]។ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មនុស្សចំនួន ៨៤នាក់ មកពីក្រសួងអប់រំ និងឃោសនាការ និងអង្គភាពផ្សេងៗចំណុះ ឱ្យក្រសួងនេះ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ ដូចមានរៀបរាប់នៅក្នុងផ្នែកអង្គហេតុ ទាក់ទងនឹងមន្ទីរ ស-២១។

**៩៤៨.** បន្ថែមលើអង្គហេតុដែលមានរៀបរាប់ខាងលើ **នួន ជា** បានពាក់ព័ន្ធនៅក្នុងការចាប់ខ្លួនកម្មាភិបាល ប.ក.ក និងសមាជិកកងទ័ពបដិវត្តន៍កម្ពុជា នៅទូទាំងប្រទេសកម្ពុជា ជាពិសេសនៅក្នុងភូមិភាគ ពាយ័ព្យ[3963] ភូមិភាគពាយ័ព្យ[3964] ភូមិភាគនិរតី[3965] ភូមិភាគឧត្តរថ្មី (ជាពិសេសតំបន់១០៣)[3966] និងតំបន់ស្វយ័ត ១០៥[3967]។ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទាក់ទងនឹង **អៀង សារី** និង ស្របតាមប្រព័ន្ធនៃការចាប់ខ្លួន ដូចបានរៀបរាប់ខាងលើ **នួន ជា** ក៏បានដើរតួនាទីក្នុងការចាប់ខ្លួន កម្មាភិបាលនៅក្នុងក្រសួងដទៃទៀត ជាពិសេសនៅក្រសួងការបរទេស និងបានពាក់ព័ន្ធផងដែរនឹង ការអំពាវនាវប្រជាជនខ្មែរដែលនៅបរទេសឱ្យវិលត្រឡប់មកកម្ពុជាវិញ[3968]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605566



## ការដឹងឮនិងការអនុវត្តន៍គោលនយោបាយនេះនៅមន្ទីរ ស-២១

## ការបង្កើតមន្ទីរ ស-២១

៩៤៩. យោងតាមសម្តីរបស់ ឌុច, នួន ជា មិនបានមានវត្តមាននៅក្នុងកិច្ចប្រជុំ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ ១៩៧៥ ដើម្បីបង្កើតមន្ទីរ ស-២១ នោះទេ។ ប៉ុន្តែ នួន ជា ប្រហែលជាពាក់ព័ន្ធ ព្រោះថា ឌុច ទទួលស្គាល់ថា សុន សេន *"មិនសម្រេចម្នាក់ឯងទេ។ ថ្នាក់ទី២ ត្រូវគោរពអ្នកទី១ និងបន្តបន្ទាប់។ ក្នុងបក្សគឺគេគោរពអញ្ចឹង"*[3969] ។

## ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយបញ្ជា

៩៥០. នៅមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ នួន ជា ជាថ្នាក់លើរបស់ សុន សេន ពេលដែល សុន សេន ទទួលខុសត្រូវលើមន្ទីរ ស-២១។ ចាប់តាំងពីការបង្កើតមន្ទីរ ស-២១ រហូតមកដល់ខែមីនា ឆ្នាំ ១៩៧៦ អ៊ិន លន ហៅ ណាត គឺជាលេខាទី ១ នៃមន្ទីរ ស-២១ និងបានរាយការណ៍ទៅ សុន សេន[3970]។ នៅខែមីនា ឆ្នាំ១៩៧៦ ឌុច បានទទួលតំណែងបន្តពី ណាត និងបានរាយការណ៍តាមទូរស័ព្ទរាល់ថ្ងៃទៅ សុន សេន រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧។ ឌុច ពន្យល់ថា មន្ទីរស-២១ ទទួលការណែនាំដោយផ្ទាល់ពី សុន សេន *"ដែលតាំងខ្លួនជាតំណាងអង្គការ"* និងពន្យល់បន្ថែមថា សមាជិកផ្សេងទៀតរបស់គណៈអចិន្ត្រៃយ៍ ឬបណ្តាក្រសួងនានាមិនអាចធ្វើការទាក់ទង ឬផ្តល់ការណែនាំដល់មន្ទីរ ស-២១ ដោយផ្ទាល់នោះទេ គឺត្រូវធ្វើតាមរយៈ សុន សេន[3971]។ ឌុច បានរាយការណ៍តាមទូរស័ព្ទពីការវិវឌ្ឍន៍និងការសួរចម្លើយ និងខ្លឹមសារនៃចម្លើយសារភាព ហើយ សុន សេន បានផ្តល់ការណែនាំមកឱ្យគាត់វិញ[3972]។ ជាឧទាហរណ៍ ឌុច បានទទួលការណែនាំជាច្រើនពី សុន សេន អំពីអ្នកដែលត្រូវបញ្ជូនទៅមន្ទីរ ស-២១[3973]។ គាត់ក៏បានទទួលបញ្ជាពី សុន សេន ទាក់ទងទៅនឹងការចាប់ខ្លួនអ្នកទោសមួយចំនួន[3974] និងការប្រើប្រាស់បច្ចេកទេសសួរចម្លើយ រួមទាំងការធ្វើទារុណកម្ម[3975]។ គាត់បានសួរយោបល់ទៅ សុន សេន នៅពេលបញ្ចប់ការសួរចម្លើយសំខាន់ៗ និងមុននឹងបញ្ជូនអ្នកទោសទៅសម្លាប់[3976]។

៩៥១. បន្ថែមពីលើការទាក់ទងគ្នាតាមទូរស័ព្ទ ឌុច បានទៅរាយការណ៍ជាទៀងទាត់ឱ្យ សុន សេន ដោយផ្ទាល់ នៅឯអគ្គសេនាធិការតាមការកោះហៅរបស់ សុន សេន[3977]។ យូរៗម្តង សុន សេន បានមកជួប ឌុច នៅជិតមន្ទីរ ស-២១ ឬនៅផ្ទះរបស់ ឌុច[3978]។ ទោះបីជា ឌុច និង សុន សេន បាន

ជួបគ្នាជាទៀងទាត់ក៏ដោយ ឌុច បញ្ជាក់ឱ្យដឹងថា ឯកសារទាំងឡាយទាក់ទងទៅនឹងដំណើរការសន្តិសុខនៅមន្ទីរ ស-២១ រួមមានចម្លើយសារភាព លិខិតស្នាម ចំណារ និងរបាយការណ៍ផ្សេងៗ ហើយពេលខ្លះ "ទ្រព្យសម្បត្តិដែលរឹបអូសបាន" ត្រូវបញ្ជូនតាមរយៈនីរសាររបស់ សុន សេន ឈ្មោះ [លុប] និងឈ្មោះ [លុប][3979]។ យូរៗម្តងដោយកម្រ ឌុច បានទទួលលិខិតពី សុន សេន ដែលមានខ្លឹមសារសង្ខេប និងការបញ្ជាជាបន្ទាន់[3980]។

**៩៥២.** បន្ទាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ឌុច បានរាយការណ៍ផ្ទាល់ទៅ នួន ជា ហើយ ឌុច បានរំឭកថា ជាមួយ នួន ជា គឺវាប្លែកពី សុន សេន, នួន ជា មិនចូលចិត្តនិយាយតាមទូរស័ព្ទទេ[3981]។ នួន ជា បានជួបជាមួយ ឌុច រវាងពីបីទៅប្រាំថ្ងៃម្តងនៅមន្ទីររបស់ នួន ជា ហើយជាទូទៅ គឺជួបនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យព្រះសុរាម្រិត ឬនៅបូរីកីឡា ពីរ ឬបីដង[3982]។ នីរសារម្នាក់របស់ នួន ជា ឈ្មោះ [លុប] បានទូរស័ព្ទមក ឌុច ដើម្បីធ្វើការណាត់ជួប[3983]។ នៅក្នុងការជួបប្រជុំនេះ ឌុច បានរាយការណ៍អំពីការរីកចម្រើនក្នុងការសួរចម្លើយ និងខ្លឹមសារនៃចម្លើយសារភាព[3984] ហើយបានទទួលការណែនាំអំពីការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់[3985]។

**៩៥៣.** ចាប់តាំងពីខែសីហា ឆ្នាំ១៩៧៧ រហូតដល់ពេលចេញដំណើររបស់ នួន ជា ដើម្បីធ្វើទស្សនកិច្ចជាផ្លូវការទៅប្រទេសចិន និងកូរ៉េខាងជើង នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៧៨[3986] ឯកសារភាគច្រើនដែលបញ្ជូនទៅវិញទៅមករវាង ឌុច និង នួន ជា ត្រូវបានធ្វើឡើងតាមរយៈនីរសារ។ នីរសាររបស់ នួន ជា ដែលមកកាន់មន្ទីរ ស-២១ មានឈ្មោះ [លុប][3987] និងឈ្មោះ [លុប] [លុប](បានស្លាប់ក្នុងពេលស៊ើបអង្កេត)[3988] ហើយឈ្មោះ ស៊ីន (ស្លាប់) បានមកយូរៗម្តង[3989]។ កាលពីដំបូង [លុប] បានបដិសេធអំពីតួនាទីរបស់គាត់ ថ្វីបើមានការបញ្ជាក់ជាផ្លូវការរបស់ ឌុច អំពីអត្តសញ្ញាណរបស់គាត់ តែទីបំផុត [លុប] បានទទួលស្គាល់ថា គាត់ពិតជានីរសារ និងជាកងការពាររបស់ នួន ជា មែន[3990]។ នីរសាររបស់ នួន ជា មិនដែលបានចូលទៅក្នុងបរិវេណគុកទេ តែបានជួប ឌុច នៅមាត់ទ្វារចូលផ្ទះរបស់ ឌុច[3991]។ មានករណីលើកលែងតែមួយគត់ចំពោះប្រព័ន្ធដែលបានរៀបរាប់ខាងលើ គឺនៅពេលដែល នួន ជា បានបញ្ជាឱ្យ ឌុច ផ្ញើចម្លើយសារភាព ឬលិខិតផ្សេងៗមកគាត់តាមរយៈ ឈឹម សំអោក ហៅ ប៉ង់ ដែលជាអ្នកទទួលខុសត្រូវមន្ទីរ ស-៧១[3992]។ ចុងក្រោយ បន្ទាប់ពីខែកញ្ញា ឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពីការចាប់ខ្លួន ឈឹម សំអោក ហៅ ប៉ង់ នាខែឧសភា ឆ្នាំ១៩៧៨ គឺឱ្យឈ្មោះ កែន ហៅ លឹន ដែលជាអ្នកជំនួស ប៉ង់ នៅមន្ទីរ ស-៧១ ជាអ្នកទទួល និងចែកចាយ

ចម្លើយសារភាពទាំងនោះ[3993]។

៩៥៤. [លុប] បានបញ្ជាក់ថា ការបញ្ជូនឯកសារធ្វើឡើងតាមពីររបៀប គឺពី នួន ជា ទៅ ឌុច និងពី ឌុច ទៅ នួន ជា[3994]។ សំបុត្រត្រូវបានដាក់ស្រោមបិទជិត ដូច្នេះ នីរសារមិនអាចដឹងថាមានអ្វីនៅក្នុងស្រោមសំបុត្រនោះទេ ហើយ ឌុច បានអះអាងថា គាត់មិនត្រូវបានអនុញ្ញាតឱ្យនិយាយពីខ្លឹមសារនៃឯកសារទាំងនោះជាមួយនីរសារឡើយ[3995]។ [លុប] បានបញ្ជាក់ថា តាមបទពិសោធន៍របស់គាត់ ការបញ្ជូនសំបុត្រគឺបានធ្វើឡើងម្តងក្នុងមួយសប្តាហ៍ អាស្រ័យទៅលើភាពចាំបាច់ ហើយគាត់មិនបានដឹងពីកម្មវិធីពេលវេលារបស់នីរសារដទៃទៀតទេ[3996]។ ប៉ុន្តែ ឌុច បានអះអាងថា [លុប] បានមកទទួលឯកសារប្រហែល *"រៀងរាល់បី ឬប្រាំថ្ងៃម្តង"*[3997] ។

៩៥៥. [លុប] បានបន្ថែមថា ពេលខ្លះ នួន ជា បានចាត់តាំងឱ្យគាត់ធ្វើដំណើរទៅមន្ទីរ ស-២១ តែភាគច្រើន កែន គឺជាអ្នកចាត់តាំងឱ្យគាត់ទៅ[3998]។ ឌុច និយាយថា កញ្ចប់សំបុត្រដែលគាត់បានផ្ញើទៅឱ្យ នួន ជា មានចម្លើយសារភាពដែលគាត់បានចារនៅលើនោះ ជាទូទៅជាមួយនឹងសំបុត្រដែលមានស្រោមបិទជិត និងរបាយការណ៍[3999]។ ឌុច បានទទួលលិខិតពី នួន ជា ដែលបានសរសេរខ្លីៗ និងការបញ្ជាជាបន្ទាន់ដោយកម្រ បើទោះបីជាគាត់មិនចាំពីខ្លឹមសារនៃលិខិតទាំងនេះក៏ដោយ។ ឌុច បញ្ជាក់ថា ក្នុងករណីខ្លះ សម្រាប់បញ្ហាសំខាន់ៗ គេមិនប្រើនីរសារទេ ហើយ នួន ជា បានហៅ ឌុច ឱ្យទៅជួបដោយផ្ទាល់[4000]។ ជាករណីលើកលែងបំផុត ឌុច ត្រូវបានទាក់ទងដោយ ប៉ុល ពត ផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់ថា បុគ្គលពិសេសៗមួយចំនួនត្រូវបានបញ្ជូនខ្លួនទៅមន្ទីរ ស-២១[4001]។

៩៥៦. ទោះបីជា ឌុច បានលើកឡើងថា គាត់រាយការណ៍ និងមានទំនាក់ទំនងតែជាមួយនឹង សុន សេន និងបន្ទាប់មក នួន ជា ក៏ដោយ ក៏មានភស្តុតាងមួយចំនួននៅក្នុងសំណុំរឿងបានបង្ហាញថា ឌុច ធ្លាប់បានទទួលសំបុត្រដែលផ្ញើមកពីកងពលមជ្ឈិម ៥០២ ដោយផ្ទាល់[4002] ។ នៅពេលដែលសួរអំពីបញ្ហានេះ ឌុច ពន្យល់ថា វាគឺជាយុទ្ធវិធីរបស់ សុន សេន និង នួន ជា ដើម្បីមិនបញ្ចេញឈ្មោះរបស់ពួកគេ ហើយពន្យល់ថាទោះបីជាឯកសារទាំងនោះបានផ្ញើទៅមកក៏ដោយ ក៏វាមិនត្រូវបានធ្វើឡើងដោយផ្ទាល់រវាងគាត់ និងកងពលមជ្ឈិមដែរ ប៉ុន្តែតាមរយៈ សុន សេន ឬ នួន ជា[4003]។ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណុំរឿង 001/18-07-2007/ECCC/TC អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការពន្យល់នេះខ្វះភាពអាចជឿជាក់បាន ហើយថា លិខិតទាំងនោះផ្ញើទៅ ឌុច ដោយផ្ទាល់ ទោះបីជាមានការយល់ព្រមពីថ្នាក់លើរបស់គាត់

ក៏ដោយ[4004]។

៩៥៧. នៅក្នុងបទសម្ភាសន៍ពីមុនជាមួយអ្នកសារព័ត៌មានជាច្រើន នួន ជា ពន្យល់ថា គាត់មិនដែលទទួលខុសត្រូវលើមន្ទីរ ស-២១ ទេ ប៉ុន្តែគាត់ថា *"ឧបមាថាបើថាមិនទៅផ្ញើឯកសារអីណា ជូនណាតាមខ្ញុំទុកឱ្យ ខ្ញុំហុចឱ្យទៅ សុន សេន ឬ ឱ្យទៅប៉ុល ពត តែប៉ុណ្ណឹងទេ ដែលថាខ្ញុំទាក់ទងជាមួយឌុចណា[4005]"*។

## តួនាទីក្នុងដំណើរការចាប់ខ្លួន និង ការបញ្ជូនទៅមន្ទីរ ស-២១

៩៥៨. ក្រៅពីការពាក់ព័ន្ធរបស់ នួន ជា នៅក្នុងការសម្រេចដើម្បីចាប់ខ្លួន ដូចបានរៀបរាប់ជាទូទៅខាងលើពាក់ព័ន្ធនឹងមន្ទីរ ស-២១ មន្ទីរសន្តិសុខដទៃទៀត និងទីកន្លែងសម្លាប់មនុស្ស ឌុច ក៏បានបញ្ជាក់ផងដែរថា តាមដែលគាត់ដឹង នួន ជា គឺជាអ្នកបញ្ជាឱ្យចាប់ខ្លួន និងបញ្ជូនកម្មាភិបាល ប.ក.ក ជាច្រើនទៅមន្ទីរ ស-២១ រួមមាន សមាជិកតំបន់ស្វ័យត ឈ្មោះ **ហួត កែ** ហៅ **សូភា**[4006] ឈ្មោះ **ព្រុំ ផល** ហៅ **វិន** (ប្រពន្ធរបស់ **វន វេត** និងជាប្រធានមន្ទីរពេទ្យនៃក្រសួងឧស្សាហកម្ម) ឈ្មោះ **យ៉ាង កន** ហៅ **ភាស់**[4007] (ប្រពន្ធរបស់ **ចេង អន** ដែលជាអនុប្រធានរបស់ **វន វេត** ហើយដែលជាប្រធានគណៈឧស្សាហកម្មមជ្ឈិម)[4008] ឈ្មោះ **កែវ លីផុងហួត** ហៅ **ធឿន** (ប្អូនថ្លៃប្រុសរបស់ **ឌុច**)[4009] និងឈ្មោះ **វី** (មកពីក្រសួងឧស្សាហកម្ម)[4010]។ ឌុច ក៏យល់ផងដែរថា នួន ជា ក៏បានពាក់ព័ន្ធក្នុងការចាប់ខ្លួនសមាជិកក្រុមគ្រួសាររបស់ខ្លួនគាត់ផ្ទាល់។ ឌុច បញ្ជាក់ថា *"នួន ជា ក៏បានឱ្យគេចាប់ខ្លួន រស់ ញឹម ដែលជាប្អូនថ្លៃរបស់គាត់ (ជាលេខាភូមិភាគពាយ័ព្យ)។ ខ្ញុំក៏គិតថាគាត់បានឱ្យគេចាប់ខ្លួនក្មួយស្រីទាំងពីរនាក់របស់គាត់ ឈ្មោះ ឡាច តារា និង ឡាច វ៉ារី និងប្ដីរបស់ពួកគេទាំងពីរឈ្មោះ សាត និងប្ដី ឡាច វ៉ារី ខ្ញុំមិនចាំឈ្មោះទេ"[4011]*។

៩៥៩. ក្នុងឋានៈជាអ្នកគ្រប់គ្រងផ្ទាល់លើមន្ទីរស-២១ នួន ជា ទទួលខុសត្រូវដោយផ្ទាល់ និងជាលក្ខណៈបុគ្គល ចំពោះការសម្រេចចាប់ខ្លួនបុគ្គលិកមន្ទីរ ស-២១។ ឌុច ពន្យល់ថា នៅពេលដែលសាច់ញាតិជិតដិតរបស់កម្មាភិបាលណាម្នាក់នៃមន្ទីរ ស-២១ ត្រូវបានចាប់ខ្លួន កម្មាភិបាលនោះនឹងត្រូវបញ្ជូនទៅមន្ទីរ ស-២៤ ដើម្បីធ្វើការអប់រំកែប្រែ ហើយគណៈកម្មាធិការមន្ទីរ ស-២១ អាចសម្រេចធ្វើដូច្នេះ។ ប៉ុន្តែ ចំពោះការចាប់និងឃុំខ្លួនបុគ្គលិកមន្ទីរ ស-២១ នៅមន្ទីរ ស-២១ *"សេចក្ដីសម្រេចត្រូវចេញដោយ សុន សេន ឬ នួន ជា នាពេលបន្ទាប់មក"[4012]*។ ឌុច ទទួលស្គាល់ថា គាត់ជាមនុស្សតែម្នាក់គត់ ដែលមានសិទ្ធិវាយការណ៍ពីកំហុសរបស់បុគ្គលិកមន្ទីរ ស-២១ និងបញ្ជាក់ថា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

*"ប្រសិនបើខ្ញុំចាំច្បាស់ គឺមិនមានករណីលើកលែងទេ៖ ខ្ញុំជានិច្ចកាលរាយការណ៍ទៅថ្នាក់លើ ហើយថ្នាក់លើនេះ តែងតែបញ្ជាឲ្យចាប់ខ្លួនអ្នកដែលត្រូវបានគេឆ្លើយដាក់ទាំងនោះ"*[4013]។ ជាឧទាហរណ៍ ឌុច ផ្តល់នូវការបញ្ជាក់លម្អិតអំពីការចាប់ខ្លួនឈ្មោះ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាកម្មាភិបាលគ្រប់គ្រងមន្ទីរ ស-២៤។ គាត់បានពន្យល់ថា បន្ទាប់ពីអ្នកកាន់តេអូរបស់ ហ៊ុយ ស្រែ បានរត់គេចខ្លួននៅចុងឆ្នាំ ១៩៧៨ ហើ បានធ្វើរបាយកាណ៍ស្នើសុំឲ្យមានការចាប់ខ្លួន ហ៊ុយ ស្រែ។ ឌុច បានបញ្ជូនរបាយការណ៍នោះ *"ទៅគណៈកម្មាធិការអចិន្ត្រៃយ៍បន្ទាប់មក នួន ជា បានបញ្ជាឲ្យចាប់ខ្លួនសួរចម្លើយ និងសម្លាប់ ហ៊ុយ ស្រែ"*[4014]។

៩៦០. នៅពេលមានការសម្រេចឲ្យចាប់ខ្លួនមនុស្ស **នួន ជា** បានដឹងឮយ៉ាងច្បាស់ និងបានពាក់ព័ន្ធក្នុងការចាប់ខ្លួន និងការបញ្ជូនខ្លួនទៅកាន់មន្ទីរ ស-២១។ សាក្សីមួយចំនួនមកពីទូទាំងប្រទេសកម្ពុជា បញ្ជាក់ថា មនុស្សទាំងនោះអាចត្រូវបានហៅទៅចូលរួមប្រជុំ និងចូលរួមវគ្គរៀនសូត្រនៅភ្នំពេញ ដែលជាញឹកញាប់គឺតាមសំណើរបស់ **នួន ជា**[4015]។ ក្នុងករណីខ្លះ ជាការប្រជុំពិតមែន តែក្នុងករណីខ្លះទៀត ប្រជាជនបានបាត់ខ្លួន[4016]។ សាក្សីម្នាក់និយាយថា នៅពេលមានអ្នកណាម្នាក់បាត់ខ្លួន គាត់ជឿថា ពួកគេពិតជាបានទៅរៀនសូត្រ លើកលែងតែរហូតដល់ការប្រជុំជាមួយ **នួន ជា**, **ខៀវ សំផន** និង**វ៉ាន់ រិទ្ធ** (លេខាគណៈកម្មាធិការពាណិជ្ជកម្មមជ្ឈិម) នៅមួយសប្តាហ៍មុនពេលការចូលមកដល់របស់វៀតណាម។ អ្នកទាំងបីនេះបានប្រកាសថា *"ពេលនេះយើងផ្អាកការហៅទៅរៀនសូត្រសិនហើយយើងរួមគ្នាវាយខ្មាំង"*។ ចាប់តាំងពីពេលនោះមក សាក្សីរូបនេះ យល់ឃើញថា គេមិនមែនបញ្ជូនប្រជាជនទាំងនោះទៅរៀនសូត្រនោះទេ ដោយ *"ការហៅទៅរៀនសូត្រ"* មានន័យថា *"បាត់ខ្លួនតែម្តង"*[4017]។ **ឌុច** ក៏បានបញ្ជាក់ផងដែរថា ក្នុងករណីខ្លះ អ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានហៅឲ្យទៅមន្ទីររបស់ **នួន ជា** មុននឹងបញ្ជូនខ្លួនទៅមន្ទីរ ស-២១[4018]។ ក្រោយពេលពួកគេបានមកដល់ភ្នំពេញ ជាញឹកញាប់ ពួកគេខ្លះត្រូវឆ្លងកាត់មន្ទីរ ក-៧ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **នួន ជា** មុនពេលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១។ **ឌុច** ពន្យល់ថា ចំណារដាក់ថា "ស-២១" នៅលើលិខិតផ្ញើដោយអនុលេខាភូមិភាគបស្ចិមឈ្មោះ **ប៉ាល់** នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ មានសរសេរថា **អឹម ណោន** ហៅ **លី** (ប្រពន្ធលេខាភូមិភាគបស្ចិម **ជូ ជេត** ហៅ **ស៊ុ**) ដែលត្រូវផ្ញើទៅឲ្យអង្គការតាមរយៈមន្ទីរ ក-៧ គឺជាចំណាររបស់ **នួន ជា**[4019]។ ការណ៍នេះអាចបញ្ជាក់ថា **នួន ជា** បានបញ្ជាឲ្យមានការចាប់ខ្លួនបុគ្គលនេះដោយផ្ទាល់។

៩៦១. **នួន ជា** ក៏បានរៀបចំការផ្ទេរអ្នកទោសពីមន្ទីរសន្តិសុខនានានៅកម្ពុជាមកកាន់មន្ទីរ ស-២១ ផងដែរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

នៅពេលសាកសួរអំពីចម្លើយសារភាពរបស់កម្មាភិបាលបក្សកុម្មុយនីស្តម្នាក់ឈ្មោះ **ពៅ ហាក់** មកពីមន្ទីរសន្តិសុខ ស-៧៩ (ភូមិភាគបូព៌ា) **ឌុច** អះអាងថា ដំបូងគេបានឃុំខ្លួនមនុស្សនេះនៅឯមន្ទីរសន្តិសុខ ស–៧៩ របស់ភូមិភាគនេះ មុននឹងបញ្ជូនមកមន្ទីរ ស-២១។ **ឌុច** បន្ថែមថា *"មានតែ នួន ជា ទេដែលមានសិទ្ធិរៀបចំការផ្ទេរ សុន សេន មិនមានសមត្ថភាពធ្វើអន្តរាគមន៍ទេ ហើយ ប៉ុល ពត មិនលូកដៃដោយខ្លួនឯង នៅក្នុងការផ្ទេរនោះទេ"* [4020]។

**៩៦២.** ក្រៅពីករណីដែលបុគ្គលិកមន្ទីរ ស-២១ បានធ្វើប្រតិបត្តិការចាប់ខ្លួនដោយខ្លួនឯង **ឌុច** ត្រូវបានជូនដំណឹងឲ្យរង់ចាំទទួលអ្នកទោសតាមរយៈបញ្ជីអ្នកទោសដែលទទួលបានពី **សុន សេន**, **នួន ជា** ឬ **កែន ហៅ លឺន**[4021]។ ចុងក្រោយ **នួន ជា** បានត្រួតពិនិត្យលើការចាប់ខ្លួនអ្នកទោសពីររូប មានឈ្មោះ **វិន** និង ឈ្មោះ **ភាស់** ព្រមទាំងការចាប់ខ្លួនលេខាតំបន់២៤ នៃភូមិភាគបូព៌ា ឈ្មោះ **សួស នៅ** ហៅ **ឈូក**[4022] ។

**ចម្លើយសារភាពនៅមន្ទីរ ស-២១**

**៩៦៣.** **ឌុច** ពន្យល់ថា គាត់បានចារនៅលើចម្លើយសារភាពទាំងនោះ តាមការណែនាំពី **សុន សេន** ប៉ុន្តែថា នៅពេល **នួន ជា** ក្លាយជាថ្នាក់លើរបស់គាត់ផ្ទាល់ គាត់បានកាត់បន្ថយការធ្វើចំណារទាំងនោះ ដោយសារ **នួន ជា** មិនយកចិត្តទុកដាក់ទៅលើចំណារទាំងនោះទេ[4023]។ **ឌុច** បានរក្សាទុកចម្លើយសារភាពរបស់មន្ទីរ ស-២១ មួយច្បាប់ និងបញ្ជូនសំណៅដើមនៃចម្លើយសារភាព តាមរយៈមធ្យោបាយប្រាស្រ័យទាក់ទងគ្នាដូចបានរៀបរាប់ខាងលើ[4024]។ ដោយសារពីដំបូង គាត់មានទំនាក់ទំនងតែជាមួយ **សុន សេន** ហើយក្រោយមកជាមួយ **នួន ជា**, **ឌុច** សន្និដ្ឋានថា គ្រប់ករណីទាំងអស់ត្រូវតែបញ្ជូនទៅឲ្យអ្នកទាំងពីរដោយផ្ទាល់[4025]។ ទោះបីជាប្រព័ន្ធទំនាក់ទំនងនេះមិនច្បាស់លាស់ទាំងស្រុងក៏ដោយ វាទំនងជាថា ចម្លើយសារភាពជួនកាលបានទៅដល់ថ្នាក់លើរបស់ **ឌុច** តាមរយៈមន្ទីរ ក-១។ ជាឧទាហរណ៍ និរសាររបស់ **នួន ជា** ឈ្មោះ [លុប] ពន្យល់ថា *"ពេលខ្លះ ខ្ញុំយក[សំបុត្រ]ទៅឲ្យតា នួន ជា ដោយផ្ទាល់ដៃ ហើយពេលខ្លះខ្ញុំឲ្យទៅគាត់តាមរយៈ កែន។ កែនជាអនុប្រធានមន្ទីរ ក-១"* [4026]។

**៩៦៤.** ហេតុដូច្នេះ ហាក់ដូចជាថា ទោះបីជាអ្នកណាជាថ្នាក់លើរបស់ **ឌុច** នាពេលនោះក៏ដោយ ក៏ចម្លើយសារភាពទាំងនោះបានទៅដល់គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ហើយក្រោយមកត្រូវបានបញ្ជូនទៅ **ប៉ុល ពត** **នួន ជា** និង **សុន សេន**។ ចម្លើយសារភាពបន្សល់នៅមន្ទីរ ស-២១

00605572



ដែលមាននៅក្នុងសំណុំរឿងគាំទ្រដល់ការអះអាងនេះ។ យោងតាមចម្លើយរបស់ **ឌុច** និងចម្លើយសារភាពជាង ៤.០០០ ច្បាប់ដែលបានរកឃើញនៅក្នុង និងជុំវិញបរិវេណមន្ទីរ ស-២១ នៅចុងបញ្ចប់នៃរបបនេះ គេជឿជាក់ថា **នួន ជា** បានទទួលចម្លើយសារភាពពីមន្ទីរ ស-២១ រាប់រយច្បាប់ ឬអាចដល់រាប់ពាន់ច្បាប់។ ទោះបីជាយ៉ាងណាក៏ដោយ មានភស្តុតាងហាក់បង្ហាញថា **នួន ជា** បានដុតចោលឯកសារផ្ទាល់ខ្លួនរបស់គាត់ពីសម័យបក្សកុម្មុនីស្តកម្ពុជា នៅពេលវៀតណាមបានចូលមកដល់ នៅដើមឆ្នាំ១៩៧៩[4027] ហើយមិនមានចម្លើយសារភាពណាមួយក្នុងចំណោមចម្លើយសារភាពពីមន្ទីរ ស-២១ នៅសេសសល់នោះទេ។ ក្រៅពីចម្លើយសារភាពដែលបានរកឃើញនៅក្នុង និងនៅជុំវិញទីតាំងបរិវេណមន្ទីរ ស-២១ ចម្លើយសារភាពពីមន្ទីរ ស-២១ ខ្លះត្រូវបានរកឃើញនៅក្នុងផ្ទះមួយនៅក្នុងទីក្រុងភ្នំពេញ និងត្រូវបានគេជឿជាក់ថា ស្ថិតនៅក្រោមការកាន់កាប់របស់ **សុន សេន** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[4028]។ ក្នុងចំណោមចម្លើយសារភាពទាំងនោះ យ៉ាងហោចណាស់ក៏មានចម្លើយសារភាពចំនួន ២៧ ច្បាប់ មានចំណារ ដែលគេជឿជាក់ថា ជាចំណាររបស់ សុន សេន។ នេះបង្ហាញឲ្យឃើញថា ចម្លើយសារភាពទាំងនោះ ត្រូវបានបញ្ជូនទៅ **នួន ជា**[4029]។ **ឌុច** បញ្ជាក់ថា ចំណារទាំងនេះបង្ហាញថា **សុន សេន** បានបញ្ជូនចម្លើយសារភាពទាំងនេះទៅឲ្យ **នួន ជា** ដោយសារ **សុន សេន** មានឋានៈទាបជាង **នួន ជា**[4030]។ ចម្លើយសារភាពខ្លះក៏មានចំណារដែល **ឌុច** បានបញ្ជាក់អះអាងថា ជាចំណាររបស់ **នួន ជា** ហើយនេះបញ្ជាក់ថា នៅពេលណាមួយនោះ **នួន ជា** ក៏មានចម្លើយសារភាពទាំងនោះដែរ[4031]។

**៩៦៥.** ចំណុចនេះក៏បង្ហាញឲ្យឃើញថា ចម្លើយសារភាពត្រូវបានបញ្ជូនទៅវិញទៅមករវាង **សុន សេន** និង **នួន ជា** នៅមុន និងក្រោយថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧។ ទោះមិនច្បាស់លាស់ទាំងស្រុងថាតើចម្លើយសារភាពទាំងនោះត្រូវបានចែកជូនរវាង **នួន ជា** និង **សុន សេន** ដោយរបៀបណាទេ ដោយសារថា នីរសាររបស់ **នួន ជា** ឈ្មោះ [លុប] មិនដែលដឹកជញ្ជូនឯកសារទាំងនោះទៅមន្ទីរណាក្រៅតែពីមន្ទីរ ស-២១ ឡើយ[4032]។ ទោះជាយ៉ាងណាក៏ដោយ អ្នកកាន់ទូរស័ព្ទរបស់ **សុន សេន** នៅឯទីក្រុងភ្នំពេញនិយាយថា មិនមានការប្រាស្រ័យទាក់ទងគ្នាតាមទូរលេខរវាង **សុន សេន** និង **នួន ជា** ឡើយ "*ព្រោះពួកគេជួបធ្វើការងារជាមួយគ្នារាល់ថ្ងៃជាទូទៅ*"[4033]។ មានភស្តុតាងបង្ហាញផងដែរថា ចម្លើយសារភាពទៅមន្ទីរ ស-២១ ត្រូវបានបញ្ជូនពី **សុន សេន** និង/ឬ **នួន ជា** ទៅឲ្យ **ប៉ុល ពត**[4034]។ **ឌុច** បញ្ជាក់បន្ថែមថា គាត់មិនបានដឹងថា ចម្លើយសារភាពពីមន្ទីរ ស-២១ ត្រូវបានបញ្ជូនទៅឲ្យ **ប៉ុល ពត** ដោយរបៀបណានោះទេ ប៉ុន្តែបានបញ្ជាក់ថា "*វាអាចថា ការបញ្ជូននេះ ធ្វើឡើងតាមរយៈលេខារបស់ នួន ជា។ វាអាចផងដែរថា នួន ជា ប្រគល់ឯកសារ*

*ដោយខ្លួនគាត់ទៅ ប៉ុល ពត*"[4035]។

៩៦៦. ចម្លើយសារភាពទាំងអស់ ជាពិសេសចម្លើយសារភាពពីមន្ទីរ ស-២១ គឺជាឯកសារស្នូលរបស់ប្រព័ន្ធបក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់ "ខ្មាំង" ទាំងក្នុងជួរបក្ស និងក្រៅជួរបក្ស។ ឌុច ពន្យល់ថា ខ្លឹមសារនៃចម្លើយសារភាពទាំងនោះត្រូវបានគេប្រើប្រាស់ជា "*លេសដើម្បីបំបាត់អ្នកដែលបង្កើតជាឧបសគ្គតែប៉ុណ្ណោះ*" និងថា "*សូម្បីតែគណៈកម្មាធិការអចិន្ត្រៃយ៍ បើតាមគំនិតខ្ញុំ ក៏មិនជឿចម្លើយសារភាពនោះទាំងស្រុងដែរ*"[4036]។ ដោយមិនគិតថាតើចម្លើយសារភាពទាំងនោះ មានការចោទប្រកាន់មិនពិត ឬបំផ្លើសយ៉ាងណានោះ ឌុច និយាយថា ចម្លើយសារភាពទាំងនោះមានទម្ងន់ជាផ្លូវការ ក្នុងការសម្រេចពីការចាប់ខ្លួនអ្នកដែលត្រូវបានចោទថាជាខ្មាំង ជាពិសេសដោយ នួន ជា។ ចម្លើយសារភាពមួយចំនួនមានចំណាររបស់ នួន ជា។ ឧទាហរណ៍ នៅពេលត្រូវបានសួរអំពីចំណារនៅលើចម្លើយសារភាពមួយដែលសរសេរថា "*១៩/៤/៧៨ តាមដាន*" ឌុច និយាយថា ចំណារទាំងនោះ គឺជាអក្សររបស់ នួន ជា និងថា នួន ជា បានយកចិត្តទុកដាក់ចំពោះចម្លើយសារភាពនេះ ដោយសារគាត់បានគូសបន្ទាត់ពីក្រោមឈ្មោះ ខាំ មី (ពីមន្ទីរ ស-៧១[4037] និងក្រោយមកបានបាត់ខ្លួន[4038]) ដែលត្រូវបានឆ្លើយដាក់ដោយម្ចាស់ចម្លើយសារភាពនេះ។ នៅពេលសួរអំពីការគូសខ្វែង និងចំណារនៅក្នុងបញ្ជីឈ្មោះ នៅក្នុងចម្លើយសារភាព ឌុច ពន្យល់ថា គាត់ជឿថា ការគូសខ្វែង និងចំណារនៅពីមុខឈ្មោះ គឺធ្វើឡើងដោយ នួន ជា និងគាត់ជឿជាក់ថា ក្រោយមក នួន ជា បានផ្ញើចម្លើយសារភាពមួយច្បាប់ទៅឱ្យឈ្មោះ សេង ហុង ហៅ ចាន់ (អនុលេខាគណៈភូមិភាគបូព៌ា និងជាសមាជិកគណៈមជ្ឈិមផង) ដែលបានចាប់ខ្លួនឈ្មោះ អ៊ុយ សាត ហៅ កិម ហៅ គុន និងបានបញ្ជូនឈ្មោះនេះមកកាន់មន្ទីរ ស-២១ ក្នុងរយៈពេលបួនថ្ងៃក្រោយពីមានចំណារនេះរួចមក[4039]។ ឌុច បញ្ជាក់ថា "*ជាទូទៅ ការដែលឈ្មោះរបស់មនុស្សម្នាក់ ត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពតែមួយដង មិនជាការគ្រប់គ្រាន់ដើម្បីឱ្យមានការចាប់ខ្លួននោះទេ។ គឺត្រូវតែមានច្រើនដង*"[4040]។ គាត់បានបន្ថែមថាថ្នាក់លើរបស់គាត់ "*ដឹងហើយថា ឆ្លើយទៅវាខុសមនុស្សដែលគេឆ្លើយដាក់នោះពាសណាពាសណីចៀសមិនរួច។ នេះជារឿងដែលយើងដឹងក៏ប៉ុន្តែជៀសពីធ្វើវាមិនរួច។ ដល់និយាយៗណាស់ៗទៅ ពូនួន គាត់ថា អ្ហឺ! មិត្តឯងគេ គេចេះធ្វើការរបស់គេដែរណា*[4041]" ។

៩៦៧. នៅក្នុងបទសម្ភាសន៍មួយ អ្នកសារព័ត៌មានមួយរូបបានបង្ហាញដល់ នួន ជា នូវចម្លើយសារភាពមន្ទីរ ស-២១ របស់កម្មាភិបាលកងពលលេខ ១៧៤ របស់ភូមិភាគកណ្តាល ឈ្មោះ ញឹម ស៊ីម ហៅ សួត

ដែលមានចំណារសរសេរថា *"ជូនបង នួន ១ច្បាប់"*។ នួន ជា បានបដិសេធថា គាត់មិនដែលបាន ឃើញឯកសារនេះទេ និងបាននិយាយថា គាត់មិនបានដឹងថាអ្នកណាជាអ្នកសរសេរចំណារនេះទេ ដោយបានបន្ថែមថា *"ជូនណាគេសរសេរអញ្ចឹងតែខ្ញុំមិនដែលឃើញទេ"*[4042]។ នៅពេលត្រូវបាន បង្ហាញពីចម្លើយសារភាពរបស់កម្មាភិបាលកងពល១៧៤ ឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត ដែលមានចំណារសរសេរថា *"ជូនបង នួន (ផ្ទាល់)"* នួន ជា បាននិយាយថា *"ទេអានេះខ្ញុំមិនដឹងទេ ព្រោះឯកសារទាំងនេះអាចធ្វើបាន* (ក្លែង)"[4043]។ នួន ជា ក៏បាននិយាយផងដែរថា មន្ទីរ ស-២១ *"គេបានបង្កើតវាឡើង ដើម្បីស្វែងរកសត្រូវរបស់ប្រទេស"*។ គាត់បានកំណត់ថា "សត្រូវ" គឺជា *"អ្នកដែលធ្វើឱ្យអន្តរាយដល់ប្រជាជន។ គឺស-២១ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហានោះ។ គួរឱ្យសោកស្ដាយ ដោយមានសមមិត្តអាក្រក់នៅទីនោះ"*។ នៅពេលសួរថាតើមន្ទីរ ស-២១ បានរក ឃើញសត្រូវដែរឬអត់នោះ គាត់និយាយថា *"ពួកគេបានរកឃើញ។ ក៏ប៉ុន្តែសមមិត្តទាំងឡាយនៃ ស-២១ បានដើរទៅឆ្ងាយពេក។ ជួនកាល ពួកគេបានមិនធ្វើតាមផែនការ និងជួនកាល ពួកគេធ្វើជ្រុលពេក"*[4044]។

<u>**ការសួរចម្លើយនៅមន្ទីរ ស-២១**</u>

**៩៦៨.** នួន ជា បានដឹងថា អ្នកជាប់ឃុំនៅមន្ទីរ ស–២១ ត្រូវបានធ្វើបាបយ៉ាងធ្ងន់ធ្ងរក្នុងពេលសួរចម្លើយ។ ហាក់ដូចជាថា នួន ជា បានទទួលចម្លើយសារភាពពីមន្ទីរ ស-២១ ដែលមានចំណាររបស់ ឌុច ឬរបស់អ្នកសួរចម្លើយ ដែលសរសេរអំពីការធ្វើទារុណកម្ម[4045]។ ឌុច ក៏និយាយដែរថា គាត់តែងតែ បានរាយការណ៍ជូន នួន ជា អំពីការសួរចម្លើយ[4046]។ ឌុច បញ្ជាក់ថា នៅក្នុងករណីជាច្រើន គាត់បានទទួលការណែនាំទាក់ទងនឹងការស្រង់យកចម្លើយ និងខ្លឹមសារនៃចម្លើយសារភាពជាក់លាក់ មួយចំនួន[4047]។ យោងតាមសម្ដីរបស់ ឌុច, នួន ជា មិនបានផ្ដល់ការណែនាំញឹកញាប់អំពីបច្ចេកទេស សួរចម្លើយដូច សុន សេន បានធ្វើនោះឡើយ[4048]។ មានពេលខ្លះ នួន ជា បានផ្ដល់ ការណែនាំយ៉ាងច្បាស់លាស់កុំឱ្យ ឌុច ធ្វើបាបអ្នកទោសក្នុងពេលសួរចម្លើយ[4049]។

**៩៦៩.** ចំពោះករណីរំលោភសេពសន្ថវៈមួយ ដែលបានកើតឡើងនៅមន្ទីរ ស-២១, ឌុច និយាយថា ពេល នោះគាត់បានរាយការណ៍អំពីរឿងនេះទៅថ្នាក់លើរបស់គាត់នៅពេលនោះ ប៉ុន្តែ ពួកគេនោះមិនបាន និយាយអ្វីឡើយ[4050]។ ប៉ុន្តែ មិនមានអ្វីដែលអះអាងថា នួន ជាបានដឹងអំពីករណីនេះទេ។

<u>ការសម្លាប់អ្នកទោសនៅមន្ទីរ ស-២១</u>

៩៧០. ឌុច និយាយថា *"នួន ជា បានប្រាប់ខ្ញុំឱ្យដឹងច្បាស់ថា គ្រប់ជនដែលបញ្ជូនមក ស-២១ ត្រូវតែសម្លាប់ទាំងអស់។ ខ្ញុំជាអ្នកទទួលខុសត្រូវនៅ ស-២១ ដូច្នេះ ខ្ញុំអនុវត្តតាមបញ្ជារបស់គាត់នោះ"*[4051]។ ឌុច និយាយថា ធម្មតា គាត់ធ្លាប់បានទទួលបញ្ជាច្បាស់លាស់ពី នួន ជា តែចំពោះការសម្លាប់ទ្រង់ទ្រាយធំ និងការសម្លាប់ក្នុងករណីពិសេស ប៉ុន្តែ ចំពោះការសម្លាប់ជាទៀងទាត់ ឬ "ធម្មតា" គាត់អាចសម្រេចដោយមិនចាំបាច់មានការណែនាំពិសេសណាមួយពី នួន ជា នោះទេ[4052]។

៩៧១. ឌុច ពន្យល់ថា គាត់បានដឹងឮពីសេចក្តីសម្រេចនៅខែមិថុនា ឆ្នាំ១៩៧៨ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរមាគ៌ានយោបាយក្នុងការកម្ទេចខ្មាំង តាមរយៈមធ្យោបាយផ្សេងៗមួយចំនួនដូចជា៖ នៅក្នុងទស្សនាវដ្តី *ទង់បដិវត្ត* លេខចេញផ្សាយខែឧសភា-មិថុនា ឆ្នាំ១៩៧៨[4053] តាមរយៈព័ត៌មានដែលមាននៅក្នុងសេចក្តីណែនាំ និងក្នុងអំឡុងពេលចូលរួមវគ្គរៀនសូត្រនយោបាយ ក្នុងឆ្នាំ១៩៧៨ ដែលមាន ប៉ុល ពត ជាអ្នកឧទ្ទេសនាម[4054]។ ឌុច លើកឡើងថា ពីដំបូង គាត់មានការជឿជាក់លើសេចក្តីណែនាំទាំងនេះ ហើយបានផ្សព្វផ្សាយបន្តព័ត៌មានទាំងនោះទៅឱ្យបុគ្គលិកមន្ទីរស-២១ ប៉ុន្តែ បញ្ជាក់ថា *"៣ ឬ៤ថ្ងៃក្រោយមក នួន ជា បានកោះហៅខ្ញុំដូចធម្មតា ហើយខ្ញុំបានប្រាប់គាត់ថា មិនមានអ្វីរាយការណ៍ទេ ដោយសារតែខ្ញុំ ឈប់ធ្វើការសួរចម្លើយទៀតហើយ។ ពេលនោះ គាត់បាន រិះគន់ ដោយនិយាយថា ឥឡូវនេះ មិត្ត ឌុច ចេះមាគ៌ាបក្សច្បាស់ហើយ។ ដូច្នេះ ខ្ញុំដឹងថានេះ គ្រាន់តែជាល្បិចកលប៉ុណ្ណោះ ហើយ ការសួរចម្លើយត្រូវបានបន្តធ្វើឡើងវិញ"* [4055] ។

៩៧២. ជាញឹកញាប់ ឌុច បានទទួលបញ្ជាពី នួន ជា ឱ្យសម្លាប់អ្នកទោសនៅមន្ទីរ ស-២១ រួមមាន សមាជិកពីររូបនៃចលនាហ្វុលរ៉ូ (FULRO)[4056] ប្រពន្ធរបស់ **វន វ៉េត** ឈ្មោះ **រិន** និងប្រពន្ធរបស់ **ចេង អន** ឈ្មោះ **ភាស់**[4057] **នុន ហ៊ុយ** ហៅ **ហ៊ុយ ស្រែ** (កម្មាភិបាលគ្រប់គ្រងមន្ទីរ ស-២៤)[4058] **ផា ថាចាន់** (អ្នកបកប្រែភាសាវៀតណាមនៅមន្ទីរ ស-២១ ដែលត្រូវបាន ឌុច ទុកជីវិត)[4059] **វន វ៉េត** (សមាជិកគណៈអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច)[4060] និង **ចៅ សេង** (អតីតមន្ត្រីរបស់ GRUNK ដែលបានត្រលប់ចូលប្រទេសវិញ)[4061]។ ឌុច ក៏ផ្តល់ការពន្យល់លម្អិតផងដែរអំពីការសម្លាប់ពួកបស្ចិមប្រទេសបួននាក់នៅខាងក្រោយបរិវេណមន្ទីរ ស-២១[4062]។ នៅក្នុងសវនាការជំនុំជម្រះលើរូបគាត់ ឌុច និយាយថា *"ខ្ញុំនៅចាំពាក្យដែលពូ នួន គាត់បញ្ជាមកខ្ញុំ។ គាត់ថា*

*ពួកអាច្រះវែងកម្ទេចទៅ ហើយថតរូបឱ្យផង។ មិត្តត្រូវចាំយើងមិនទុកផ្លឹងសម្រាប់ដូរយក ប៊ូដូហ្សែរ ដូចគុយបាទេ"* [4063]។ យ៉ាងហោចណាស់មានមួយករណីដែល នួន ជា បានបញ្ជាមិនឱ្យសម្លាប់អ្នកទោសម្នាក់ ប៉ុន្តែឱ្យរក្សាទុកអ្នកទោសនេះនៅមន្ទីរ ស-២១[4064]។

**៩៧៣.** ឌុច ពន្យល់ថា គាត់បានទទួលបញ្ជាច្បាស់លាស់ពី នួន ជា ជាច្រើនដង ឱ្យសម្លាប់អ្នកទោសមន្ទីរ ស-២១ ជាទ្រង់ទ្រាយធំ[4065]។ ជាពិសេស ឌុច និយាយថា នៅខែធ្នូ ឆ្នាំ១៩៧៨ "*អ្នកទោសប្រមាណ ៣០០នាក់ត្រូវបានសម្លាប់ នៅពេលដែលពួកគេមកដល់ស-២១ តាមបញ្ជារបស់ នួន ជា ដោយមិនមានការសួរចម្លើយទេ (ភូមិភាគបូព៌ាបានបះបោរ ហើយវាមិនចាំបាច់សួរចម្លើយអ្នកទោសទាំងនោះទេ ពីព្រោះគេច្បាស់លាស់ហើយអំពីអំពើក្បត់របស់ពួកគេ)"* [4066] ។ នៅក្នុងការសម្ភាសន៍ជាមួយអ្នកសារព័ត៌មានម្នាក់ នួន ជា បដិសេធថាគាត់មិនបានផ្តល់បញ្ជានេះទេ នៅពេលសាកសួរអំពីព្រឹត្តិការណ៍ពិសេសនេះ[4067]។ ចុងបញ្ចប់ ឌុច និយាយថា "*នៅថ្ងៃ២ ឬ៣ មករា ១៩៧៩ (ខ្ញុំចាំមិនច្បាស់ទេ) នួន ជា ហៅខ្ញុំទៅទទួលបញ្ជាដាច់ខាត។ គឺតម្រូវឱ្យស-២១ កម្ទេច (សម្លាប់) ជនរងគ្រោះឱ្យអស់"* [4068]។ តាមសម្តីរបស់ ឌុច អ្នកទោសប្រហែល ២០០ នាក់ (លើកលែងតែ ៤នាក់) ត្រូវបានសម្លាប់ចោលភ្លាម ដោយអនុវត្តតាមបញ្ជានេះ ហើយគាត់បន្ថែមថា "*នួន ជា បានសម្រេចកម្ទេចអ្នកទោសទាំងអស់ ប៉ុន្តែ បានអនុញ្ញាតឱ្យខ្ញុំរក្សាទុកអ្នកទោសទាំងបួននាក់នោះ ដោយប្រាប់ខ្ញុំថា " ត្រូវគ្រប់គ្រងស្ថានការដោយម្ចាស់ការខ្លួនឯង" ដែលមានន័យថា កម្ទេចអ្នកទាំងនោះ នៅពេលដែលចាំបាច់។ ខ្ញុំបានផ្តល់បញ្ជានេះទៅឱ្យ ហ៊ី ដែលបានបញ្ជូនបញ្ជានេះបន្តទៅឱ្យអ្នកសួរចម្លើយទាំងឡាយ។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ អ្នកសួរចម្លើយអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ ប្រសិនបើពួកគេមិនបានអនុវត្តតាមបញ្ជាគឺសម្លាប់អ្នកទោសទាំងនោះ"* [4069]។ អ្នកទោសទាំងបួននាក់នោះបន្ទាប់មកត្រូវបាន [លុប] សម្លាប់ចោល នៅពេលដែលកងទ័ពវៀតណាមចូលមកដល់[4070]។

**៩៧៤.** ឌុច ក៏ពន្យល់ផងដែរថា មានពេលខ្លះ នួន ជា និង សុន សេន បានស្នើឱ្យគាត់ថតរូបសាកសពអ្នកទោស ដើម្បីឱ្យថ្នាក់លើជឿជាក់ថា អ្នកទោសទាំងនោះពិតជាត្រូវបានសម្លាប់ចោលមែន[4071]។

### ក្រុមមនុស្សជាក់លាក់ផ្សេងៗ

**៩៧៥.** តាមរយៈតួនាទី និងមុខងារផ្សេងៗនៅក្នុង ប.ក.ក នួន ជា បានចូលរួមក្នុងវិធានការនានា

ដែលកំណត់មុខសញ្ញាក្រុមជាក់លាក់មួយចំនួន។

៩៧៦. ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ នួន ជា បានចូលរួមក្នុងការបង្កើតឯកសាររបស់បក្សចុះនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលកំណត់ថា មានវណ្ណៈតែមួយគត់ គឺវណ្ណៈកម្មករ និងកសិករ ហើយថា វណ្ណៈផ្សេងៗទៀតត្រូវតែបញ្ចូលទៅក្នុងវណ្ណៈទាំងពីរនេះ[4072]។

## ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរ

៩៧៧. ក្រុមមនុស្សនេះត្រូវបានកំណត់ជាគោលដៅជាក់លាក់ នៅពេលដែល នួន ជា ជាអនុលេខាគណៈមជ្ឈិមបក្ស និងជាសមាជិកពេញសិទ្ធិគណៈអចិន្ត្រៃយ៍។ នៅក្នុងមហាសន្និបាតមួយនៅទីក្រុងភ្នំពេញនាខែឧសភា ឆ្នាំ១៩៧៥ នួន ជា បានពន្យល់ថា អតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ មិនឲ្យស្ថិតនៅក្នុងក្របខណ្ឌកម្លាំងរបស់របបថ្មីទេ[4073]។ នៅក្នុងចម្លើយសារភាពមន្ទីរ ស-២១ និងដែលត្រូវបានបញ្ជូនទៅ នួន ជា យ៉ាងហោចណាស់ក៏មានចម្លើយសារភាពរបស់មនុស្សម្នាក់ក្នុងចំណោមនោះត្រូវបានគេជឿជាក់ថាជា "ប្រជាជនថ្មី" ដែលបានបម្រើការឲ្យរបប លន់ នល់[4074]។ យ៉ាងហោចណាស់ នួន ជា បានទទួលទូរលេខមួយ ដែលកំណត់ អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរថាជាខ្មាំង[4075]។

## ការប្រព្រឹត្តលើពុទ្ធសាសនិក

៩៧៨. ក្រុមមនុស្សនេះត្រូវបានកំណត់ជាគោលដៅជាក់លាក់ នៅពេលដែល នួន ជា ជាអនុលេខាគណៈមជ្ឈិម និងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ ក្នុងអំឡុងដំណើរទស្សនកិច្ចរបស់បក្សពលករនៃប្រទេសដាណឺម៉ាក ក្នុងខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បាននិយាយថា ក្នុងអំឡុងពីឆ្នាំ១៩៦០ ដល់ ឆ្នាំ១៩៧៣ "*យើងថែមទាំងបានធ្វើការនៅក្នុងចលនាព្រះសង្ឃ ធ្វើឲ្យសង្ឃដើរតាមយើង ដោយនិយាយថា យើងនឹងការពារប្រទេស និងសាសនារបស់យើង។ ប្រសិនបើប្រទេសជាតិយើងត្រូវបានត្រួតត្រាដោយបរទេសនោះ ប្រទេសយើងនឹងគ្មានសាសនាអ្វីទៀតទេ*" [4076]។ ផ្ទុយទៅវិញ នៅរយៈពេលដំបូងនៃរបបនេះ នួន ជា បានដឹកនាំអង្គប្រជុំសម្រាប់កម្មាភិបាល ប.ក.ក និងសមាជិកនៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ដែលនៅពេលនោះ គាត់បានបង្ហាញជូនពីគោលនយោបាយបក្សក្នុងការហាមឃាត់សាសនាទាំងអស់ រួមទាំង ព្រះពុទ្ធសាសនា ដោយបានផ្សឹកព្រះសង្ឃ បិទមិនឲ្យ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

មានវត្តអារាម និងហាមមិនឲ្យប្រារព្ធពិធីបុណ្យតាមបែបព្រះពុទ្ធសាសនា[4077]។

## ការប្រព្រឹត្តទៅលើជនជាតិចាម

៩៧៩. ក្រុមមនុស្សនេះត្រូវបានកំណត់ជាគោលដៅជាក់លាក់ នៅពេលដែល នួន ជា ជាអនុលេខាគណៈមជ្ឈិម និងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ ក្នុងឋានៈជាអនុលេខាបក្ស ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ និងជាសមាជិកនៃគណៈកម្មាធិការយោធា នួន ជា គឺជាថ្នាក់លើម្នាក់របស់ កែ ពក[4078] ដែលបានអនុវត្តគោលនយោបាយរបស់ ប.ក.ក ប្រឆាំងនឹងសហគមន៍ជនជាតិចាមនៅភូមិភាគកណ្តាល (ឧត្តរចាស់) ក្នុងរវាងឆ្នាំ១៩៧៧ និង១៩៧៨។

៩៨០. នៅក្នុងសន្និបាតមួយ ក្នុងខែឧសភា ឆ្នាំ១៩៧៥ ប៉ុល ពត និង នួន ជា បានបង្ហាញគោលនយោបាយដែលក្នុងនោះរួមមាន ការបំបាត់ចោលសាសនាទាំងអស់ ដែលត្រូវបានចាត់ទុកថាជាសាសនាប្រតិកិរិយា[4079]។ "ទូរលេខ ១៥" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ និយាយពីមាគ៌ានយោបាយធំៗរបស់ថ្នាក់លើ ប.ក.ក ដើម្បី "*បំបែក*" ជនជាតិចាម និងដើម្បីជម្លៀសពួកគេទាំងបង្ខំចេញពីភូមិភាគបូព៌ាឲ្យទៅកាន់ភូមិភាគឧត្តរ។ ដូចដែលបានពន្យល់ខាងលើ ទូរលេខនេះត្រូវបានផ្ញើទៅឲ្យ ប៉ុល ពត និងចម្លងជូន នួន ជា ក្នុងចំណោមអ្នកដទៃផ្សេងទៀត[4080]។ នៅពេលសាកសួរអំពីទូរលេខនេះ សាក្សីម្នាក់ដែលធ្លាប់បានធ្វើការបកប្រែទូរលេខទាំងនេះឲ្យមន្ទីរ ក-១ កាលពីនៅក្នុងរបបនោះពន្យល់ថាហេតុអ្វីបានជាប្រធានអង្គភាពទូរលេខសម្រេចចម្លងជូន នួន ជា គឺដោយសារ"*ទូរលេខនេះទាក់ទងជាមួយប្រជាជនទើបគេបញ្ជូនមក នួន ជា (...)ដើម្បីដោះស្រាយ*"។ សាក្សីរូបនេះក៏និយាយផងដែរថា គណៈអចិន្ត្រៃយ៍អាចចូលរួមពាក់ព័ន្ធក្នុងបញ្ហានេះ[4081]។

៩៨១. នួន ជា ត្រូវបានចម្លងជូននូវទូរលេខមួយទៀតពី កែ ពក នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ដែលមានខ្លឹមសារថា "*ពួកអាខ្មាំងជាទាហានចាស់ រួមផ្សំជាមួយពួកចាម និងពួកអាអតីតប្រធានក្រុមសហករណ៍*"[4082]។

## ការប្រព្រឹត្តលើជនជាតិវៀតណាម

៩៨២. ក្រុមមនុស្សនេះត្រូវបានកំណត់ជាគោលដៅជាក់លាក់ នៅពេលដែល នួន ជា ជាអនុលេខាគណៈ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

មជ្ឈិមបក្ស និងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។

៩៨៣. ពីឆ្នាំ១៩៧៥ ដល់ ១៩៧៦ នួន ជា បានគាំទ្រគោលនយោបាយរបស់ ប.ក.ក ដើម្បីបណ្តេញ ជនជាតិវៀតណាមទាំងអស់ដែលនៅលើទឹកដីកម្ពុជា និងបញ្ជូនពួកគេទៅប្រទេសវៀតណាមវិញ គាត់បានផ្សព្វផ្សាយគោលនយោបាយនេះ យ៉ាងហោចណាស់ក្នុងឱកាសនៃកិច្ចប្រជុំមួយ[4083] ដែលគាត់បានធ្វើឡើងនៅថ្ងៃដំបូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតាមរយៈតួនាទីទូទៅរបស់គាត់ នៅក្នុងការរៀបចំតាក់តែងបង្កើតទស្សនាវដ្តី *ទង់បដិវត្ត* និងទស្សនាវដ្តី *យុវជននិងយុវនារីបដិវត្ត* ។

៩៨៤. នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ តាមរយៈការចូលរួមពាក់ព័ន្ធជាបន្តបន្ទាប់នៅក្នុងការបោះពុម្ពទស្សនាវដ្តី និងការផ្សព្វផ្សាយតាមវិទ្យុឃោសនារបស់ ប.ក.ក នួន ជា បានផ្តល់ព័ត៌មានក្នុងគោលដៅធ្វើឲ្យមានការភ័យខ្លាច និង ឲ្យមានការស្អប់ខ្ពើមជនជាតិវៀតណាម ឬ ក្រៅពីនេះ ប្រមូលការគាំទ្រនានាដើម្បីកំណត់ក្រុមមនុស្សនេះជាគោលដៅជាក់លាក់។ "សៀវភៅខ្មៅ" ដែល នួន ជា បានចូលរួមនៅក្នុងការធ្វើសេចក្តីព្រាង ក៏មានសរសេរផងដែរអំពីយុទ្ធសាស្ត្ររបស់វៀតណាមដែលមានបំណង "ដាក់ឲ្យនៅក្រោមចំណុះ និង លេបត្របាក់ទឹកដីកម្ពុជា" និងអំពីការជំរុញឲ្យស្អប់ខ្ពើមជនជាតិវៀតណាម[4084]។

៩៨៥. ក្នុងអំឡុងទស្សនកិច្ចរបស់បក្សពលកររបស់ប្រទេសដាណឺម៉ាកក្នុងខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បានថ្លែងសុន្ទរកថាមួយដោយបាននិយាយថា *"បដិវាទកម្មមួយទៀតគឺមកពីខាងក្រៅ។ ជាពិសេសវៀតណាមកំពុងព្យាយាមបំផ្លាញបក្សយើង តាមរយៈមធ្យោបាយមនោគមន៍វិជ្ជា សេដ្ឋកិច្ច នយោបាយ យោធា"*[4085] ។ សុន្ទរកថាមួយទៀតនៅក្នុងពិធីជប់លៀង នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧៨ នួន ជា បាននិយាយថា *"បច្ចុប្បន្ននេះ នៅក្រោមការដឹកនាំដ៏ត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា និងសមមិត្ត ប៉ុល ពត ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា បានកម្ទេចសកម្មភាពធ្វើវិទ្ធង្សនាការប៉ុនប៉ងធ្វើរដ្ឋប្រហារ និងសកម្មភាពរំលោភឈ្លានពាន ការវាតទឹកដី ការបញ្ចូលជាឧបសម្ព័ន្ធ និងការលេបទឹកដីដ៏ឃោរឃៅ ព្រៃផ្សៃ ហើយដែលវៀតណាមបានធ្វើម្តងហើយម្តងទៀត ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា ក៏បានកម្ទេចកលល្បិច "សហព័ន្ធឥណ្ឌូចិន" របស់វៀតណាម ដែលមានគោលបំណងលេបទឹកដីកម្ពុជា និងគោលបំណងកម្ទេចចោលឲ្យអស់សូន្យនូវពូជសាសន៍អម្បូរកម្ពុជា។ ដោយហេតុនេះ យុទ្ធសាស្ត្រ "ការវាយលុកដូចផ្លេកបន្ទោរជ័យជំនះបានមកលឿនដូចផ្លេកបន្ទោរ" របស់វៀតណាមបានរងនូវបរាជ័យគួរឲ្យ*

*អាម៉ាស់មុខ”*[4086]។ សុទ្ធរកថានេះធ្វើឡើងនៅក្នុងបរិបទនៃការសម្លាប់រង្គាលជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា ដូចមានបរិយាយលម្អិតនៅក្នុងផ្នែកស្តីពី “ការប្រព្រឹត្តលើជនជាតិវៀតណាម” នៃដីកាដំណោះស្រាយនេះ។

**៩៨៦.** **នួន** ជា បានដឹងអំពីគោលនយោបាយរបស់ ប.ក.ក ក្នុងការសម្លាប់សមាជិកសហគមន៍វៀតណាម និងបានទទួលដំណឹងពីបណ្តាភូមិភាគ និងពីមេបញ្ជាការយោធានានាអំពីការអនុវត្តន៍ គោលនយោបាយនេះ ។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ [លុប] លេខាកងពលមជ្ឈិមលេខ ១៦៤ បានរាយការណ៍តាមទូរលេខសម្ងាត់មក **នួន** ជា និង **អៀង សារី** ថា ប្រជាជនវៀតណាមចំនួន ១២០ នាក់ ត្រូវបានចាប់ខ្លួន និងបាញ់សម្លាប់នៅចន្លោះពីថ្ងៃទី២៧ និង ៣០ ខែមីនា ឆ្នាំ១៩៧៨[4087]។ តាមរយៈកាលៈទេសៈផ្សេងទៀត **នួន** ជា ក៏ត្រូវបានជូនដំណឹងផងដែរអំពីការកាប់សម្លាប់ “ការកម្ទេច” និងការវាយប្រហារទៅលើជនស៊ីវិលវៀតណាម ព្រមទាំងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជាជនវៀតណាម[4088]។ **នួន** ជា ក៏បានគេជូនដំណឹងតាមរយៈសេចក្តីរាយការណ៍លម្អិត ពីសំណាក់កម្មាភិបាលថ្នាក់ក្រោមអំពីការសម្លាប់រង្គាលជនស៊ីវិលវៀតណាមនៅក្នុងប្រទេសវៀតណាម។ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៧ ទូរលេខមួយដែលត្រូវបានផ្ញើទៅ ម.៨១ (មន្ទីរ ៨១) ដោយឯកអគ្គរដ្ឋទូតរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសវៀតណាម និងបានចម្លងជូន **នួន** ជា **អៀង សារី** និងមន្ទីរ ៨៧០ រាយការណ៍អំពីការលេចឮមានព័ត៌មាននៅក្នុងប្រទេសវៀតណាមថា “*កងទ័ពកម្ពុជាសម្លាប់រង្គាលអស់ប្រជាជនវៀតណាមចំនួន ១០០០ នាក់ “មួយពាន់អ្នក” នៅហាជៀន ខេត្តគៀនយ៉ាង”*[4089]។

**៩៨៧.** ការសម្លាប់នេះប្រហែលជាជាប់ពាក់ព័ន្ធនឹង “អំពើក្បត់” របស់មេដឹកនាំភូមិភាគបូព៌ា ជាពិសេស **សោ ភឹម**។ មានភស្តុតាងខ្លះបញ្ជាក់ថា **នួន** ជា បានចូលរួមយ៉ាងសកម្មនៅក្នុងការបោសសម្អាត **សោ ភឹម** និងភូមិភាគបូព៌ា[4090] មុនពេលក្លាយជាលេខាភូមិភាគបូព៌ាតាមជាក់ស្តែងបានមួយរយៈក្រោយពីការធ្វើអត្តឃាតរបស់ **សោ ភឹម**[4091]។

**៩៨៨.** ទាហាន និងជនស៊ីវិលវៀតណាម ដែលត្រូវបានចាប់ខ្លួននៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម ជាទូទៅត្រូវបានចាប់ខ្លួននៅក្នុង ឬក្បែរតំបន់ជម្លោះចម្បងតាមព្រំដែនជាមួយវៀតណាម។ **នួន** ជា បានទទួលព័ត៌មានរាយការណ៍តាមទូរលេខ ពីមេបញ្ជាការយោធា អំពីការចាប់ខ្លួន ការឃុំខ្លួន ការសួរចម្លើយ ឬការសម្លាប់ទាហាន ជនស៊ីវិល ឬគិញវៀតណាមខ្លះ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

នៅក្នុង ឬនៅជិតសមរភូមិ[4092]។ ជាឧទាហរណ៍ ទូរលេខមួយដែលបានផ្ញើដោយ [លុប] (សាក្សី) សរសេរថា “*យើងខ្ញុំសូមរាយការណ៍អំពីស្រុកប្រជាជនយួនវត់មកចំនួនប្រាំបួននាក់ តាមសួរចម្លើយរបស់វា គឺវាថាយួនចាត់ចែងឲ្យវាមកស៊ើបការ នៅក្នុងប្រទេសកម្ពុជា នឹងមករស់នៅនឹងប្រជាជនកម្ពុជា ដើម្បីក្លាប់ប្រជាជនកម្ពុជា ឥឡូវនេះបានបោសសម្អាតវាហើយ*”។ សាក្សីរូបនេះពន្យល់ថា គាត់បានផ្ញើទូរលេខនេះទៅឲ្យមន្ទីរ ៨៧០ ដែលគាត់យល់ថា រួមទាំង នួន ជា ផងដែរ[4093]។ នៅក្នុងទូរលេខ៦០ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ ហើយដែលបានចម្លងជូន នួន ជា សុំយោបល់ណែនាំពីមន្ទីរ ៨៧០ អំពីប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួន៖ “*យើងខ្ញុំសូមស្នើមតិរបស់ ម.៨៧០ ពីបញ្ហាយួនដែលយើងចាប់បាននៅភូមិតាដេវ លើផ្ទះប្រជាជននោះ បើ ម.៨៧០ ត្រូវការយើងខ្ញុំនឹងផ្ញើមកជូន-បច្ចុប្បន្នយើងរក្សាទុកកំពង់យកចម្លើយ*”[4094]។

**៩៨៩.** ភស្តុតាងហាក់បង្ហាញថា ទាហាន និងប្រជាជនវៀតណាមខ្លះ បើមិនទាំងអស់ទេ[4095] ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដូចបានរៀបរាប់នៅក្នុងផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយនេះ។ ទូរលេខមួយច្បាប់ទៀតដែលផ្ញើទៅតែ ប៉ុល ពត និង នួន ជា នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ សរសេរថា “*ខាងសមមិត្ត តាល់ ចាប់បានយួន ២ ក្បាល អាយុ ១៧ និង ២៧ឆ្នាំ។ ឲ្យយកទៅស ២១*”[4096]។ ឌុច ក៏បាននិយាយម្តងហើយម្តងទៀតថា ទាហានវៀតណាម និងជនស៊ីវិលវៀតណាម ត្រូវបានគេប្រព្រឹត្តដូចគ្នានឹងអ្នកជាប់ឃុំឃាំងដទៃទៀតនៅមន្ទីរ ស-២១ អញ្ចឹងដែរ[4097]។ មានការខុសគ្នាតែមួយគត់ គឺចម្លើយសារភាពរបស់វៀតណាម ត្រូវបានថតសម្លេងសម្រាប់គោលបំណងឃោសនា និងផ្សព្វផ្សាយតាមវិទ្យុ[4098]។ ឌុច ពន្យល់ថាសេចក្តីសម្រេច (ថតយកសម្លេង) នេះធ្វើឡើងដោយ នួន ជា[4099]។ ឌុច បានបញ្ជាក់បន្ថែមនៅក្នុងសវនាការជំនុំជម្រះលើរូបគាត់ថា “*ខ្លឹមសារនៃសេចក្តីសារភាពរបស់វៀតណាមនេះ យកផ្ញើទៅឲ្យពូនួន។ ដូច្នេះ ខុសត្រូវយ៉ាងម៉េចគាត់កែលម្អជាបន្តបន្ទាប់។ ខ្ញុំកែតែខាងក្រោមជាបន្តបន្ទាប់ទៀត។ ដូច្នេះ ទិសដៅដែលចង់បាននៅក្នុងការឃោសនានេះ ខាងលើកំណត់ច្បាស់លាស់*”[4100]។

**៩៩០.** ជាចុងក្រោយ ទូរលេខមួយចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ផ្ញើដោយ **អ៊ុំ ណេង ហៅ វី** ក្នុងឋានៈគាត់ពេលនោះជាលេខាភូមិភាគឦសាន្តសរសេរថា “សូមរាយការណ៍ជូនបងជាទីគោរព” និងចម្លងជូន នួន ជា រាយការណ៍អំពីការចាប់ខ្លួនវៀតណាមជាតិចារ៉ាយចំនួន២០៩នាក់ ដោយកងពល៨០១[4101]។ ដូចដែលបានលើកឡើងនៅក្នុងផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង វៀតណាមជាតិចារ៉ាយទាំងនោះត្រូវបានសម្លាប់ នៅពេលក្រោយមក។

00605582



### ការរៀបអាពាហ៍ពិពាហ៍

៩៩១. តាមរយៈតួនាទីផ្សេងៗទៀតរបស់គាត់នៅក្នុង ប.ក.ក នួន ជា បានចូលរួមនៅក្នុងការតាក់តែងបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ នៅក្នុងប្រទេសកម្ពុជា។

៩៩២. នួន ជា បានចូលរួមនៅក្នុងការផ្សព្វផ្សាយនៅទូទាំងប្រទេស អំពីសេចក្តីណែនាំទាក់ទងនឹង ការតាក់តែងបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍។ គាត់បានទទួលស្គាល់ជាច្រើនលើកថា ប.ក.ក មានផែនការប្រាំឆ្នាំ ដើម្បីបង្កើនចំនួនប្រជាជនកម្ពុជាឲ្យបានរហូតដល់ ១៥លាននាក់ ដោយសារ "*ធ្វើបដិវត្តន៍ត្រូវការប្រជាជន ហើយកសាងប្រទេសត្រូវការប្រជាជនដែរ*"[4102]។ នួន ជា បានចូលរួមផងដែរនៅក្នុងគោលនយោបាយនេះតាមរយៈការផ្សព្វផ្សាយគោលការណ៍សីលធម៌បដិវត្តន៍របស់ ប.ក.ក តាមការពាក់ព័ន្ធរបស់គាត់នៅក្នុងការបង្កើត និងការចែកចាយទស្សនាវដ្តី *យុវជននិងយុវនារីបដិវត្ត* និងទស្សនាវដ្តី*ទង់បដិវត្ត* ព្រមទាំងការពាក់ព័ន្ធរបស់គាត់នៅក្នុងការរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ។

### ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ

៩៩៣. យ៉ាងហោចណាស់ ពីខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នួន ជា បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និងវៀតណាម។ នួន ជា បានដឹងតាំងពីដំណាក់កាលដំបូងអំពីជម្លោះជាមួយប្រទេសវៀតណាម ក្នុងរយៈពេលប៉ុន្មានខែ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4103]។ គាត់ក៏ត្រូវបានជូនដំណឹងអំពីស្ថានភាពយោធា និងការចរចាជាមួយប្រទេសវៀតណាម តាមរយៈការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ប.ក.ក មួយចំនួន នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៥, នៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៧៦, នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦, នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦, នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ និងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦[4104]។ មានភស្តុតាងបង្ហាញផងដែរថា នួន ជា បានចរចាជាមួយអាជ្ញាធរវៀតណាម[4105]។ គាត់បានដឹងពីស្ថានភាពនៅសមរភូមិផ្សេងៗ និងនៅតាមព្រំដែនជាមួយប្រទេសវៀតណាម (ការចល័តទ័ព ការប្រយុទ្ធគ្នា និងការខូចខាត) តាមរយៈទូរលេខដែលកងទ័ព ប.ក.ក

នៅឯសមរភូមិបានបញ្ជូនមកគាត់។ ទូរលេខខ្លះបានបន្សល់ទុករហូតដល់បច្ចុប្បន្ន និងបានបង្ហាញថា គាត់ត្រូវបានគេចម្លងជូនជាច្រើនច្បាប់នៅចន្លោះពីថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨។ ការបញ្ជូនទូរលេខនេះបានកើនឡើង ដោយពេលខ្លះ ជួនកាលមានរហូតដល់ច្រើនដងក្នុងមួយថ្ងៃ ពាក់ព័ន្ធទៅនឹងការកើនឡើងនៃជម្លោះប្រដាប់អាវុធនេះ[4106]។ គាត់ក៏បានទទួលទូរលេខទាក់ទងនឹងទំនាក់ទំនងអន្តរជាតិ និង ការទូត ចំពោះជម្លោះប្រដាប់អាវុធដែលលើកឡើងនេះ[4107]។ ចុងក្រោយ **នួន ជា** បានថ្លែងសុន្ទរកថា[4108] និងបានដឹកនាំកិច្ចប្រជុំនយោបាយជាច្រើន ជាពិសេសមួយនឹងសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលគាត់បាននិយាយអំពីជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសវៀតណាម[4109]។

## ខ. អៀង សារី[4110]

### សាវតារ

**៩៩៤.** **អៀង សារី** បានចាប់ផ្តើមចូលរួមក្នុងសកម្មភាពនយោបាយ ក្នុងទសវត្សរ៍ឆ្នាំ១៩៤០ ខណៈគាត់ជានិស្សិតវិទ្យាល័យព្រះស៊ីសុវត្ថិ[4111]។ ក្នុងអំឡុងពេលនោះ គាត់បានជួបជាមួយ **អៀង ធីរិទ្ធ**[4112] និង **សាឡុត ស**[4113]។

**៩៩៥.** ក្នុងឆ្នាំ១៩៥០ **អៀង សារី** បានធ្វើដំណើរទៅទីក្រុងប៉ារីស ដើម្បីសិក្សា[4114]។ នាពេលនោះ **អៀង សារី** បានក្លាយជាសមាជិកបក្សកុម្មុយនីស្តបារាំងជាមួយ **ប៉ុល ពត** និង **ខៀវ សំផន**[4115] ហើយជាសមាជិកស្ថាបនិកម្នាក់នៃក្រុមម៉ាក្សនិយមក្នុងស្រទាប់និស្សិតខ្មែរ[4116]។

**៩៩៦.** ក្រោយពីត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ ក្នុងឆ្នាំ១៩៥៧[4117] **អៀង សារី** បានចូលរួមជាមួយគណបក្សបដិវត្តន៍ប្រជាជនកម្ពុជា[4118]។ **អៀង សារី** គឺជាសាស្ត្រាចារ្យ ប្រវត្តិវិទ្យា និងភូមិវិទ្យា នៅក្នុងអនុវិទ្យាល័យឯកជនមួយឈ្មោះកម្ពុជបុត្រ[4119] រហូតដល់គាត់លាក់ខ្លួនក្នុងឆ្នាំ១៩៦៣[4120]។

**៩៩៧.** ក្នុងឆ្នាំ១៩៦០ **អៀង សារី** បានចូលរួមក្នុងសមាជលើកទី១ របស់បក្សពលករខ្មែរ ដែលជាឈ្មោះថ្មីរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងជាឈ្មោះមុនរបស់បក្សកុម្មុយនីស្តកម្ពុជា[4121]។ គាត់ត្រូវបានជ្រើសរើសជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍ ដូច្នេះបានក្លាយជា


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

មនុស្សលំដាប់ទី៤ របស់បក្ស[4122]។ ក្នុងអំឡុងសមាជលើកទី២ របស់បក្សក្នុងឆ្នាំ១៩៦៣ **អៀង សារី** ត្រូវបានជ្រើសរើសជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍[4123]។

**៩៩៨.** ក្នុងខែមេសា ឆ្នាំ១៩៦៣ ក្រោយពី [លុប] បានចាត់ទុកគាត់ជាអ្នកឆ្វេងនិយមម្នាក់ក្នុងចំណោមអ្នកឆ្វេងនិយមចំនួន ៣៤នាក់ **អៀង សារី** បានភៀសខ្លួនទៅព្រំដែនវៀតណាម ដើម្បីចូលរួមជាមួយ **សុន សេន** និង **ប៉ុល ពត**[4124]។ ក្នុងឆ្នាំ១៩៦៦ **អៀង សារី** និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតបានប្តូរទីតាំងទៅនៅក្នុងខេត្តរតនគីរី ភូមិភាគឦសានជាទីកន្លែងដែលទីស្នាក់ការថ្មីរបស់គណៈមជ្ឈិមបានតាំងនៅ[4125]។ ដូច្នេះ **អៀង សារី** បានក្លាយជាលេខាភូមិភាគឦសាន[4126]។

**៩៩៩.** ក្នុងឆ្នាំ១៩៧០ **អៀង សារី** បានធ្វើដំណើរទៅទីក្រុង ហាណូយ ជាទីកន្លែងដែលគាត់បង្កើតស្ថានីយ៍វិទ្យុ *"សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា"*[4127] ដែលគ្រប់គ្រងដោយ **អៀង ធីរិទ្ធ**។ **អៀង សារី** បានធ្វើដំណើរពី ទីក្រុងហាណូយ ទៅទីក្រុងប៉េកាំង ដើម្បីចងសម្ពន្ធ័ភាពជាមួយបក្សកុម្មុយនីស្តចិន។ នៅឆ្នាំ១៩៧១ **អៀង សារី** បានតាំងមូលដ្ឋានជាអចិន្ត្រៃយ៍នៅទីក្រុងប៉េកាំង[4128]។ ស្របពេលជាមួយគ្នានោះ គាត់បានធ្វើជា៖ *"បេសកជនពិសេសនៃអ្នកតស៊ូផ្ទៃក្នុងនៅប៉េកាំង"* និងទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយ [លុប][4129]។ តួនាទី និងមុខងាររបស់ **អៀង សារី** ក្នុងអំឡុងពេលដែលគាត់ស្នាក់នៅប្រទេសចិន នឹងត្រូវបាននិយាយសម្អិតក្នុងផ្នែកដែលមានចំណងជើងថា៖ "អ្នកធ្វើមាតុភូមិនិវត្តន៍"។ ក្នុងអំឡុងពេលនោះ **អៀង សារី** បានមកកម្ពុជាចំនួនពីរដង៖ ម្តងនៅក្នុងឆ្នាំ១៩៧៣ នាពេលដែល គាត់អមដំណើរ [លុប] [លុប] ទៅពិនិត្យមើល *"តំបន់រំដោះ"*[4130] និង ម្តងទៀតក្នុងឆ្នាំ ១៩៧៤[4131]។ គាត់ត្រឡប់មកកម្ពុជាជាអចិន្ត្រៃយ៍ ក្នុងខែមេសា ឆ្នាំ១៩៧៥[4132]។

**១០០០.** ក្នុងអំឡុងរបបបក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** បានប្រើឈ្មោះបដិវត្តន៍របស់គាត់ គឺ *"វ៉ាន់"*[4133]។

**តួនាទី និង មុខងារ**

**សមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍**

**១០០១.** អៀង សារី ចូលរួមក្នុងគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ១៩៦០[4134] និង គណៈ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605585



អចិន្ត្រៃយ៍នៅឆ្នាំ១៩៦៣។[4135]ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការទាំងពីរ[4136]។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម អៀង សារី អាច *"ពិគ្រោះពិភាក្សា និងរួមមតិសម្រេច"* ទាក់ទងនឹងបញ្ហាទាំងអស់[4137]។

១០០២.ក្នុងចំណោមកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ចំនួន ១៩ លើក ដែលនៅសល់[4138] (មានតែ ១៥ លើកប៉ុណ្ណោះដែលបញ្ជាក់ពីវត្តមានអ្នកចូលរួម[4139]) មានការកត់ត្រាថា **អៀង សារី** ធ្លាប់បានចូលរួមចំនួន ១០ លើក[4140]។ គាត់ត្រូវបានកត់ត្រាថាធ្លាប់បានចូលរួមក្នុងអង្គប្រជុំពិសេសរបស់គណៈអចិន្ត្រៃយ៍ប.ក.ក ចំនួនម្តង[4141]។ តាមការពិត **អៀង សារី** ទំនងជាបានចូលរួមប្រជុំច្រើនជាងនេះ ព្រោះ ខៀវ សំផន និយាយថា គណៈអចិន្ត្រៃយ៍កោះប្រជុំរវាង ៧-១០ ថ្ងៃម្តង ហើយប្រជុំកាន់តែញឹកញាប់ទៅទៀតនៅពេលចាំបាច់[4142]។ ឯកសារដែលនៅសេសសល់ទាំងនោះ បង្ហាញថា **អៀង សារី** ធ្លាប់បានធ្វើបទឧទ្ទេសនាមលើបញ្ហានានាជាច្រើនដូចជា ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម ការដឹកជញ្ជូន ការចូលរួមនៅសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ជំនួយបរទេស ជម្លោះជាមួយប្រទេសវៀតណាម ការអំពាវនាវដល់ប្រជាជនកម្ពុជាដែលនៅបរទេសឱ្យវិលត្រឡប់ និងទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសដទៃទៀត[4143]។ ទាក់ទិនជាមួយនឹងអង្គប្រជុំដែលគាត់មិនបានចូលរួម **អៀង សារី** អាចនឹងទទួលបានកំណត់ហេតុអង្គប្រជុំ ដែលប្រហែលជាត្រូវបានធ្វើឡើងជាប្រចាំ។

១០០៣.ក្នុងតួនាទីជាសមាជិកគណៈមជ្ឈិម និង គណៈអចិន្ត្រៃយ៍, **អៀង សារី** បានចូលរួមការប្រជុំរបស់ ប.ក.ក ជាទៀងទាត់ នៅក-១ និង ក-៣ ជាពិសេស ការប្រជុំប្រចាំខែនៅ ក-១ ដែលមានរយៈពេល ៥-៦ ថ្ងៃ ជាមួយគណៈភូមិភាគ គណៈតំបន់ និង/ឬគណៈស្រុក។ មានកម្មាភិបាលប្រមាណ ២០រូប ចូលរួមនៅក្នុងកិច្ចប្រជុំទាំងនេះ[4144]។ **អៀង សារី** ក៏បានចូលរួមការប្រជុំប្រចាំឆ្នាំរវាងលេខាមជ្ឈិម និងលេខាភូមិភាគផងដែរ[4145]។

១០០៤.**អៀង សារី** មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ពេញមួយរយៈកាលនៃរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា និងនៅពេលដែលថ្នាក់ដឹកនាំបក្សនេះបានភៀសខ្លួនទៅនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ[4146]។

១០០៥. ដំណើរការបង្កើតក្រសួងការបរទេស (ដែលមានឈ្មោះសម្គាល់ ប-១) ស្ទើរតែត្រូវបានធ្វើឡើងភ្លាម បន្ទាប់ពីការចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។[4147] ក្រសួងនេះត្រូវបានសម្ពោធជាផ្លូវការនៅខែធ្នូ ឆ្នាំ១៩៧៥។[4148] ដំបូងឡើយ ប-១ មានទីតាំងស្ថិតនៅអគារចំនួនពីរ លើវិថីព្រះស៊ីសុវត្ថិ តាមមាត់ទន្លេ ក្រុងភ្នំពេញ។ ក៏ប៉ុន្តែ នៅឆ្នាំ១៩៧៦ ប-១ ត្រូវបានរើទៅនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ីវិញ[4149]។ ប-១ មានផ្ទះទទួលភ្ញៀវចំនួនពីរកន្លែងទៀតគឺ ផ្ទះទី១ នៅជិតវត្តភ្នំ និង ផ្ទះទី២ នៅសណ្ឋាគារ *ឡឺរ៉ូយ៉ាល់ (Le Royal)*[4150]។

១០០៦. សាក្សីម្នាក់អះអាងថា មានមនុស្សជាង ១.០០០ នាក់ធ្វើការនៅ ប-១[4151]។ ពីដំបូង គេជ្រើសរើសបុគ្គលិកពីក្រុមមនុស្សដែលមានភាពសក្តិសម "ស្អាតស្អំ" ដែលមន្ទីរ ៨៧០ គ្រប់គ្រងដោយ ប៉ង់ និង ឌឿន ជាអ្នកជ្រើសរើសពីតាមភូមិភាគផ្សេងៗ ដោយផ្អែកលើវណ្ណៈ ឬសមត្ថភាព និងមកពីតាមមូលដ្ឋានបដិវត្តន៍ចាស់ៗដូចជា ខេត្តព្រះវិហារ និង ខេត្តកំពង់ចាម[4152]។ ក្រៅពីបុគ្គលិកដែលជ្រើសរើសពីបណ្តាភូមិភាគផ្សេងៗនោះ បុគ្គលិករបស់ ប-១ ក៏រួមមានផងដែរនូវ *"បញ្ញាជន"* មួយចំនួន ដែលភាគច្រើននៃអ្នកទាំងនោះ បានវិលត្រឡប់ពីបរទេសមកកម្ពុជាវិញ[4153]។ ជាងនេះទៀត អៀង សារី ក៏បានជ្រើសរើស *"កុមារកម្មាភិបាល"* មួយចំនួន ដែលជាកុមារមិនបានទទួលការអប់រំ និងមានអាយុពីប្រាំបី ទៅ ដប់ប្រាំឆ្នាំ[4154]។ មានពេលមួយ ប-១ បានរៀបចំវគ្គរៀនសូត្រ *"កម្មាភិបាលបដិវត្តន៍"* ដល់កុមារ ដែលត្រូវបញ្ជូនទៅឲ្យរៀនសូត្រនៅទីនោះ[4155]។

១០០៧. ពីដំបូង ប-១ មិនមានមន្ទីរផ្សេងៗទេ[4156]។ ប៉ុន្តែ កម្មាភិបាលទាំងនោះបានទទួលឋានៈផ្លូវការ នៅពេលពួកគេជួបជាមួយភ្ញៀវបរទេស។ ឧទាហរណ៍ អតីតកម្មាភិបាល ប-១ [លុប] និយាយថា គាត់ត្រូវបានគេណែនាំទៅអង្គការសហប្រជាជាតិថាជាសមាជិក *"ខាងកិច្ចការទូទៅ"* ដែលតាមពិតមិនមានផ្នែកនេះទេ[4157]។ ក្រោយមក ប-១ ប្រហែលជាមានការរៀបចំជារចនាសម្ព័ន្ធត្រឹមត្រូវ។ អតីតកម្មាភិបាល ប-១ [លុប] និយាយថា ខុសពីក្រសួងផ្សេងៗទៀត មានតែ ប-១ ទេ ដែលមានរចនាសម្ព័ន្ធជាក្រសួង[4158]។ យោងតាមឯកសារមួយ ដែលមានចំនួន ១៥២ ទំព័រ (ប្រហែលជាកំណត់ត្រាសរសេរដោយដៃរបស់កម្មាភិបាលជាន់ខ្ពស់នៅ ប-១ ប៉ុន្តែ មិនអាចកំណត់អត្តសញ្ញាណបាន) ចុះនៅខែកក្កដា ឆ្នាំ១៩៧៦ ប-១ ត្រូវបានបែងចែកជាប្រាំពីរផ្នែកគឺ៖ ការអប់រំ, ដាំដុះ, ការិយាល័យ (រួមមាន *"ផ្នែកសម្ងាត់"*) នយោបាយ ពិធីការ លេខាធិការ និង អាកាសចរ

ស៊ីវិល[4159]។ កំណត់ត្រាទាំងនេះ ដែលមាននៅក្នុងសៀវភៅទិនានុលេខមួយ ត្រូវបានយកទៅបង្ហាញសាក្សីជាច្រើន ហើយពុំមានសាក្សីណាម្នាក់បដិសេធពីយថាភូតភាពរបស់ឯកសារនោះទេ ក្នុងអំឡុងពេលស៊ើបអង្កេត[4160]។

១០០៨. នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៥ វិទ្យុនៅភ្នំពេញបានផ្សាយថា **អៀង សារី** ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស[4161]។ ការតែងតាំងនេះត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ក្នុងផ្នែកស្ដីអំពី *"ការងារបរទេសទាំងបក្ស ទាំងរដ្ឋ"* [4162]។ នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ គណៈមជ្ឈឹមបក្ស បានកត់ត្រាការតែងតាំង ក្នុងឯកសារមួយដែលមានចំណងជើងថា *"សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន"* [4163]។ ការតែងតាំងត្រូវបានគាំទ្រដោយសភាតំណាងប្រជាជនកម្ពុជា នៅខែបន្ទាប់[4164]។ **អៀង សារី** បានទទួលស្គាល់ថា ខ្លួនធ្លាប់ធ្វើជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ក្នុងអំឡុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាមែន ដោយនិយាយថា គាត់ទទួលយកតួនាទីនេះក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៦ ក៏ប៉ុន្តែ គាត់មិនចាំថាថ្ងៃណាពិតប្រាកដទេ[4165]។ នៅក្នុងតួនាទីនេះ គាត់ក៏ជាសមាជិកនៃគណៈរដ្ឋមន្ត្រីដែរ។

១០០៩. សៀវភៅទិនានុលេខដែលរកឃើញ មានខ្លឹមសារទាក់ទងនឹង ប-១ ក្រោមចំណងជើង *"សន្និបាតសាខា (២២-៥-៧៦)"* មានកត់ត្រាថា **អៀង សារី** ជាប្រធានសាខាបក្ស[4166] ហើយចំពោះទិដ្ឋភាពរដ្ឋបាល គាត់ជាគណៈប្រធានដឹកនាំទូទៅ និង ជាប្រធានផ្នែកនយោបាយ[4167]។ បន្ទាប់មកទៀត នៅក្នុងឯកសារដដែលនោះ ក្រោមចំណងជើងថា *"ផែនការសាខា-១៩៧៧"* **អៀង សារី** ត្រូវបានសរសេរថាជាលេខាគណៈសាខាក្រសួងជាមួយ [លុប] ដែលជាអនុរបស់គាត់[4168]។

១០១០. មានទិដ្ឋភាពជាច្រើនទាក់ទិននឹងតួនាទីរបស់ **អៀង សារី** នៅ ប-១។ តួនាទីមួយក្នុងចំណោមតួនាទីជាច្រើន គឺការងារគ្រប់គ្រងស្ថានទូតកម្ពុជានៅក្រៅប្រទេស។ ក្នុងខែឧសភា ឆ្នាំ ១៩៧៦ ប.កុ.ក បានតែងតាំងអ្នកការទូតសម្រាប់ស្ថានទូតកម្ពុជាប្រជាធិបតេយ្យចំនួនបួន៖ ចិន, កូរ៉េខាងជើង, វៀតណាម និង ឡាវ។ អ្នកការទូតដែលតែងតាំងដោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាចុងក្រោយនៅមានងស្ថានទូតកម្ពុជាប្រជាធិបតេយ្យក្នុងប្រទេស អាល់បានី, យូហ្គោស្លាវី និងរូម៉ានី[4169]។ បើតាម [លុប] ដែលជាអ្នកមានតួនាទីជាន់ខ្ពស់ជាច្រើននៅ ប-១ រួមមានតំណែងជាប្រធាននាយកដ្ឋានឃោសនាការ និង ព័ត៌មាន[4170] **អៀង សារី** ជាប្រធានផ្នែកនយោបាយដែលមានបុគ្គលិក

ជាបញ្ញវន្តនានា ដូចជា [លុប][4171] ដឹកនាំអង្គប្រជុំនានាក្នុងកម្រិតក្រសួង[4172] ដឹកនាំអង្គប្រជុំបក្សនៅក្នុងក្រសួង[4173] ដឹកនាំការងារទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងផ្នែកផ្សាយជាភាសាបរទេសនៃវិទ្យុកម្ពុជាប្រជាធិបតេយ្យ[4174] និងផ្តល់ការណែនាំទៅអ្នកក្រោមបង្គាប់ អំពីការរៀបចំវគ្គរៀនសូត្រដល់បុគ្គលិកក្រសួង ដោយផ្អែកលើការផ្សាយប្រចាំថ្ងៃនៃវិទ្យុកម្ពុជាប្រជាធិបតេយ្យ[4175]។

**១០១១.**បើតាម [លុប] ក៏ជាអ្នកមានតួនាទីជាន់ខ្ពស់ជាច្រើនផងដែរនៅ ប-១ រួមមានឋានៈជាប្រធានសន្តិសុខ[4176] អះអាងថា អៀង សារី *"ជាអ្នកដឹកនាំរួម"* នៅ ប-១[4177] ដែលមានន័យថាគាត់ក៏ដឹកនាំសាខាបក្សក្នុងក្រសួង[4178] ទទួលខុសត្រូវកិច្ចការផ្ទៃក្នុងរបស់ក្រសួង[4179] ផ្សព្វផ្សាយបទបញ្ជាពីថ្នាក់លើ ជាពិសេសពី ប៉ុល ពត និង នួន ជា[4180] ជួបប្រជុំជាមួយបញ្ញវន្តដែលជាបុគ្គលិកស្ទើររៀងរាល់ថ្ងៃ[4181] គ្រប់គ្រងមន្ទីរអប់រំកែប្រែដែលជាសាខារបស់ក្រសួងដូចជា ច្រាំងចំរេះ និងព្រែកប្រា[4182] ទទួលភ្ញៀវបរទេស[4183] និងធ្វើដំណើរទស្សនកិច្ចផ្លូវការទៅបរទេស (រួមមានការចូលរួមប្រជុំរបស់អង្គការសហប្រជាជាតិ)[4184] និងអមដំណើរគណៈប្រតិភូបរទេសដែលមកទស្សនកិច្ចទៅទីជនបទ[4185]។ [លុប] បាននិយាយផងដែរថា អៀង សារី ទទួលខុសត្រូវកិច្ចការសន្តិសុខផ្ទៃក្នុងរបស់ ប១ ដោយធ្វើការពិគ្រោះយោបល់ជាមួយមន្ទីរនយោបាយ ៨៧០ និងជាមួយប៉ង់[4186]។ ឌុច ក៏បានថ្លែងបញ្ជាក់ដូចនេះដែរ[4187]។

**១០១២.**ក្នុងតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស, អៀង សារី បានធ្វើដំណើរទៅបរទេសជាទៀងទាត់ ទៅកាន់ប្រទេសនានាដូចជា ស្រីលង្កា, រ៉ូម៉ានី, ចិន[4188], ភូមា, ប៉ាគីស្ថាន, ឡាវ, បារាំង, ម៉ិកស៊ិក្ស, គុយបា, វៀតណាម, សិង្ហបុរី, កូរ៉េខាងជើង, ឥណ្ឌូនេស៊ី, ថៃ, ហ្វីលីពីន, ប៉េរូ, ម៉ាឡេស៊ី, ជប៉ុន, សហរដ្ឋអាមេរិក[4189], ហុងគ្រី, យូហ្គោស្លាវី និង ប៊ុលហ្គារី[4190]។ អតីតបុគ្គលិកប-១ ម្នាក់និយាយថា អៀង សារី ឧស្សាហ៍ធ្វើដំណើរទៅប្រទេសចិន, វៀតណាម និង កូរ៉េខាងជើង ញឹកញាប់ជាងគេ[4191]។ ក្នុងពេលដែលគាត់នៅបរទេស អៀង សារី នៅតែគ្រប់គ្រង ប-១ បាន តាមរយៈមន្ទីរ ៨៧០ ដែលគ្រប់គ្រងដោយ ប៉ង់។ នៅពេល អៀង សារី អវត្តមាន ជាទូទៅ [លុប] [លុប] ត្រូវបានចាត់តាំងជាអ្នកកាន់ការជំនួស។ ក៏ប៉ុន្តែ [លុប] មិនមានអំណាចធ្វើសេចក្តីសម្រេចទេ ហើយបំពេញការងារក្រោមការណែនាំរបស់ *"មជ្ឈិម"*[4192]។ នៅពេលដែល អៀង សារី និង [លុប] អវត្តមាន ប-១ ត្រូវគ្រប់គ្រងដោយសមាជិកជាន់ខ្ពស់ផ្សេងទៀតក្នុងក្រសួង[4193] ឬ ដោយ ខៀវ សំផន ម្តងម្កាលដែរ[4194]។

១០១៣. នៅប្រទេសកម្ពុជា អៀង សារី តែងតែទទួលគណៈប្រតិភូបរទេស, រៀបចំពិធីជប់លៀង, ចូលរួមប្រជុំពិភាក្សាពីទំនាក់ទំនងអន្តរជាតិ និង ពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងអមដំណើរគណៈប្រតិភូទាំងនោះទៅទស្សនកិច្ចនៅទូទាំងប្រទេសកម្ពុជា[4195]។

១០១៤.ច្បាស់ណាស់ថា **អៀង សារី** មានអំណាចលើ ប-១ ទោះបីជាអតីតបុគ្គលិកនៅទីនោះបាននិយាយថា ការសម្រេចលើកិច្ចការសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍តែឯងប៉ុណ្ណោះ[4196]។

## តួនាទីផ្សេងៗទៀត

១០១៥.បន្ថែមលើតួនាទីខាងលើ អៀង សារី មានតួនាទីមួយចំនួនទៀត ក្នុងអំឡុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា។ តួនាទីទាំងនោះរួមមាន អំណាចឧទ្ទេសនាមមនុស្សចូលក្នុងបក្ស[4197] ដឹកនាំគណៈកម្មការកិច្ចការបរទេសនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[4198] សរសេរលិខិតឆ្លើយឆ្លងក្នុងនាម [លុប][4199]។ **អៀង សារី** ក៏ជាសមាជិកគណៈកម្មាធិការនានា ដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានាដូចជា ធនាគារ ការទិញសម្ភារ និង ឃ្លាំងរដ្ឋនៅក្រុងភ្នំពេញ[4200]។ ជាងនេះទៅទៀត គាត់ប្រហែលជាបានចូលរួមរៀបចំទស្សនាវដ្ដីឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា[4201] ទោះបីមានសាក្សីម្នាក់បានបដិសេធពីការអះអាងនេះក៏ដោយ[4202]។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ **អៀង សារី** ចូលរួមទទួលខុសត្រូវលើមន្ទីរនយោបាយ ៨៧០ និងមន្ទីរ ស-៧១ ផងដែរ[4203]។

## ទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់ ប.ក.ក

១០១៦.**អៀង សារី** មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាលក្ខណៈបុគ្គល និងលក្ខណៈនយោបាយ ជាមួយសមាជិកសំខាន់ៗផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំ[4204]។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** បានរស់នៅនិងធ្វើការជាមួយ សុន សេន, ខៀវ សំផន, នួន ជា និង ប៉ុល ពត នៅ ក-១ និង ក-៣[4205]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១០១៧.**អៀង សារី** ក៏មានទំនាក់ទំនងផងដែរជាមួយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា រួមមាន **ប៉ុល ពត**, **អៀង ធីរិទ្ធ**, **ខៀវ សំផន** និង **នួន ជា** ក្នុងឱកាសផ្សេងៗជាច្រើន ដូចជាការជួបជុំ សំខាន់ៗរបស់បក្ស[4206] មុនពេលរៀបចំចេញដំណើរទៅតាមភូមិភាគ[4207] ដោយជួយសរសេរសុន្ទរកថាដល់ពួកគេ[4208] ឬនៅពេលទទួលពួកគេនៅ ប-១[4209]។ **អៀង សារី** និង **ខៀវ សំផន** ទទួលគណៈប្រតិភូបរទេសជាមួយគ្នា[4210] និងធ្វើដំណើរទៅបរទេសរួមគ្នា[4211]។ **អៀង សារី** និង **ខៀវ សំផន** ក៏ធ្លាប់បានធ្វើដំណើរទៅតាមទីជនបទ និង ពិនិត្យតាមសហករណ៍ និង ការដ្ឋានជាមួយគ្នាដែរ[4212]។

## ការចូលរួមក្នុងផែនការរួម

### ការផ្លាស់ទីលំនៅប្រជាជន

១០១៨.តាមរយៈតួនាទីនានារបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** បានចូលរួមក្នុងការផ្លាស់ទីលំនៅប្រជាជនពីតាមទីក្រុងនិងទីប្រជុំជននានាទៅជនបទ រួមទាំងការផ្លាស់ទីលំនៅពីតំបន់ជនបទមួយ ទៅជនបទមួយទៀត។

១០១៩.បក្សកុម្មុយនីស្តកម្ពុជា បានជម្លៀសប្រជាជនពីតាមទីក្រុងមួយចំនួននៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ខណៈដែល **អៀង សារី** ជាសមាជិកគណៈអចិន្ត្រៃយ៍[4213] ជាហេតុការណ៍ដែលគាត់ទទួលស្គាល់ថាបានពិភាក្សាជាមួយ ប៉ុល ពត នាទីកន្លែងជិតទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៤[4214]។ វាទំនងជាថា បញ្ហានេះ ត្រូវបានពិភាក្សាក្នុងអំឡុងពេលប្រជុំរបស់គណៈមជ្ឈិមបក្សខែមិថុនា ឆ្នាំ ១៩៧៤[4215]។

១០២០.ទាំងក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** បានគាំទ្រ និង ការពារជាសាធារណៈ នូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជម្លៀសមនុស្សចេញពីទីក្រុង និង បញ្ជូនប្រជាជនទៅទីជនបទ។ នៅខែកក្កដា ឆ្នាំ១៩៧៨ អៀង សារី បានផ្តល់មូលហេតុបីសម្រាប់បណ្តេញមនុស្សចេញពីទីក្រុងនៅកម្ពុជាគឺ៖ *"កង្វះស្បៀងអាហារ, វត្តមាននៃបណ្តាញខ្មាំង និង បទពិសោធន៍ធ្វើស្រែចម្ការរបស់ប្រជាជន"*[4216]។ ក្នុងខែដដែល គាត់បានពន្យល់ថា នៅពេលផ្នែកឧស្សាហកម្មបានរីកចម្រើន ប្រជាជនអាចវិលត្រឡប់មកទីក្រុងវិញ[4217]។ នៅពេលមានការប្រជុំជាមួយគណៈប្រតិភូបរទេស អៀង សារី បាននិយាយថា ការជម្លៀសប្រជាជន ត្រូវបានរៀបចំផែន


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ការជាមុន និងចាំបាច់ ដោយសារតែអាចមានការទម្លាក់គ្រាប់បែក មានគិញបង្កប់ គ្រោះអត់ឃ្លាន និងការចាំបាច់បញ្ជូនមនុស្សទៅទីជនបទ ដើម្បីបង្កបង្កើនផលកសិកម្ម[4218]។ **អៀង សារី** ក៏បានគាំទ្រដល់គោលនយោបាយ នៅឯកិច្ចប្រជុំជាមួយបុគ្គលិកនៅ ប-១ ដោយនិយាយថា គេធ្វើឡើងដើម្បីសម្រិតសម្រាំងមនុស្សដែលមានទម្លាប់នៅទីក្រុង[4219]។ **អៀង សារី** បានដឹងពីការផ្លាស់ទីលំនៅដោយបង្ខំ ក្នុងសម័យគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការទទួលទូរលេខ ដូចជាទូរលេខមួយចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបង្ហាញពីការបញ្ជូន *"ប្រជាជនថ្មី"* ពីខេត្ត សៀមរាប ទៅស្រុកផ្សេងៗទៀត[4220]។

**១០២១.**ក្រោយថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ **អៀង សារី** នៅបន្តគាំទ្រ និង ការពារការសម្រេចបណ្តេញមនុស្សចេញពីទីក្រុង និងទីប្រជុំជនដដែល។ ឧទាហរណ៍ នៅឆ្នាំ១៩៨០ គាត់បានអះអាងថា ការសម្រេចចិត្តបណ្តេញមនុស្សចេញពីទីក្រុងត្រូវបានធ្វើឡើង ដោយសារបក្សកុម្មុយនីស្តកម្ពុជាខ្លាចវៀតណាមជ្រៀតចូលសម្លាប់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[4221]។ នៅឆ្នាំដដែលនោះ **អៀង សារី** អះអាងថា នៅពេលគាត់ទៅដល់ទីក្រុងភ្នំពេញ ទីក្រុងនោះគ្មានមនុស្សរស់នៅរួចហើយ ហើយថា ប្រសិនបើមនុស្សភាគច្រើនក្នុងបក្សកុម្មុយនីស្តកម្ពុជាគិតដូចគាត់ ប្រាកដជាគេមិនអនុវត្តតាមការសម្រេចនោះទេ[4222]។ នៅឆ្នាំ១៩៩៦ ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យដែលបង្កើតឡើងដោយ អៀង សារី បានប្រកាសថា ការជម្លៀសប្រជាជនចាត់ទុកជាការចាំបាច់ ដើម្បីបង្រៀនអ្នកក្រុងឲ្យចេះអត់ធន់នឹងការរងទុក្ខលំបាកទាំងផ្លូវចិត្ត និងផ្លូវកាយ តាមរយៈការងារធ្ងន់ធ្ងរ[4223]។

<u>ដំណាក់កាលទី១</u>

**១០២២.អៀង សារី** បានចូលរួមក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ ទោះបីគាត់មិនបាននៅទីក្រុង ភ្នំពេញ នៅពេលមានការប្រជុំសម្រេចលើផែនការជម្លៀសប្រជាជនក៏ដោយ[4224] (គាត់វិលត្រលប់មកទីក្រុងភ្នំពេញវិញ ពីទីក្រុងប៉េកាំង ចន្លោះថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ១៩៧៥ ហើយគាត់បានប្រាប់ថា នៅពេលនោះទីក្រុងគ្មានមនុស្សរស់នៅ[4225])។ **អៀង សារី** ទទួលស្គាល់ថា គាត់បានពិភាក្សាផែនការជម្លៀសប្រជាជន ជាមួយ ប៉ុល ពត នៅឆ្នាំ១៩៧៤ ហើយបានផ្តល់ព័ត៌មានប្រាប់ ប៉ុល ពត ថា ពួកចិនចាប់អារម្មណ៍ចង់ដឹងពីផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយព្រឹត្តិការណ៍ជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា[4226]។ ប៉ុល ពត បានឆ្លើយតបថា ផែនការនោះគឺការជម្លៀសចេញពីទីក្រុង ហើយថា ពួកចិនមិនចាំបាច់ព្រួយបារម្ភទេ ព្រោះធ្លាប់មានបទពិសោធន៍នេះពីខេត្តស្ទឹង

00605592



ត្រែង និង ខេត្តក្រចេះ រួចមកហើយ។ នៅដំណាក់កាលនោះ **អៀង សារី** បាននិយាយថា គេមិនដឹងច្បាស់ទេ ថាតើទីក្រុងភ្នំពេញនឹងត្រូវជម្លៀសមនុស្សចេញទាំងស្រុងដែរឬទេ។ **អៀង សារី** និយាយថា ផែនការគឺត្រូវជម្លៀស ហើយបន្ទាប់មក *"យើង"* នឹងចាំមើលថាតើ ប្រជាជនកម្ពុជាទាំងនោះ រួមទាំងសហរដ្ឋអាមេរិកនឹងមានប្រតិកម្មយ៉ាងណា[4227]។ នៅខែកញ្ញា ឆ្នាំ១៩៩៦ អៀង សារី បានទទួលស្គាល់ថែមទៀតថា នៅឆ្នាំ១៩៧៤ គាត់បានព្រមាន ប៉ុល ពត ថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ នឹងមិនងាយស្រួលដូចការជម្លៀសប្រជាជនពីទីប្រជុំជនតូចៗនៅខេត្តស្ទឹងត្រែង និងក្រចេះនោះទេ។ អៀង សារី បានដាស់តឿនថា គ្រប់យ៉ាងត្រូវតែ *"រៀបចំឱ្យបានសព្វគ្រប់ ពីព្រោះមានប្រជាជនរាប់លាននាក់"*[4228]។ គាត់និយាយថា នៅពេលគាត់មកដល់ទីក្រុង អ្វីៗទាំងអស់ត្រូវបានសម្រេចរួចជាស្រេចហើយ វាគ្មានប្រយោជន៍នឹងនិយាយពីបញ្ហានេះទៀតទេ[4229]។

**១០២៣.** ការពន្យល់ជាបន្តបន្ទាប់ដែល **អៀង សារី** បានផ្តល់ឱ្យចំពោះហេតុផល ដែលនាំឱ្យមានការជម្លៀសប្រជាជនចេញពីភ្នំពេញ មានខុសៗគ្នាទៅតាមឆ្នាំ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ **អៀង សារី** បានអះអាងថា មានហេតុផលពីរដែលសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ទីមួយ ដោយសារមានការខ្វះខាតស្បៀងអាហារ ហើយបក្សកុម្មុយនីស្តកម្ពុជាមិនមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនស្បៀងមកទីក្រុងភ្នំពេញ ដូច្នេះ ពួកគេសម្រេចជម្លៀសប្រជាជនទៅទី ជនបទដែលមានស្បៀងអាហារ។ ការធ្វើបែបនេះដើម្បីបញ្ចៀសការសុំជំនួយពីប្រទេសដទៃ។ ទីពីរ ពួកគេបានរកឃើញឯកសារមួយដែលពណ៌នាលម្អិតអំពីផែនការសម្ងាត់របស់សេ.អ៊ី.អា និងរបប លន់ នល់ ដែលដួលរលំ ដើម្បីរំលំនិងតស៊ូប្រឆាំងនឹងជ័យជំនះរបស់បក្សកុម្មុយនីស្តកម្ពុជា នៅទីក្រុងភ្នំពេញ។ **អៀង សារី** បាននិយាយផងដែរថា ប្រជាជនអាចត្រឡប់មកទីក្រុងភ្នំពេញវិញ ប្រសិនបើពួកគេចង់ ហើយជាក់ស្តែង មានប្រជាជនចំនួន ១០០.០០០ នាក់បានត្រឡប់មកវិញ[4230]។ ក្នុងខែតុលា ឆ្នាំ១៩៧៥ **អៀង សារី** បានអះអាងថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ ជាការចាំបាច់ដើម្បីបង្អាក់ផែនការអាមេរិក ក្នុងការធ្វើឱ្យរដ្ឋាភិបាលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាដួលរលំ[4231]។ នៅខែឧសភា ឆ្នាំ១៩៧៧ **អៀង សារី** បានអះអាងថា បន្ទាប់ពី *"ក្រោយពីការជម្លៀសប្រជាជនលើកដំបូងចេញពីទីក្រុង ឥឡូវទីក្រុងកំពុងមានកំណើនប្រជាជនឡើងវិញ"* ហើយថា តំបន់ដែលពុំមានប្រជាជនត្រូវបានប្រើប្រាស់សម្រាប់បង្កបង្កើនផល។ **អៀង សារី** ក៏បានទទួលស្គាល់ផងដែរថា ប្រជាជនពី ២.០០០ នាក់ ទៅ ៣.០០០ នាក់ បានស្លាប់ក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ[4232]។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ អៀង សារី បានពន្យល់យ៉ាងលម្អិតដល់ឯកអគ្គរដ្ឋទូតដាណឺម៉ាក ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ **អៀង សារី**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

បាននិយាយថា ការជម្លៀសនោះគឺដោយសារកង្វះស្បៀងអាហារ បញ្ហាសន្តិសុខ និងភាពចាំបាច់ក្នុងការបង្កើនផលិតផលកសិកម្ម។[4233]

**ដំណាក់កាលទី២**

១០២៤. ការសម្រេចផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្តាល (ឧត្តរចាស់), ភូមិភាគនិរតី, ភូមិភាគបស្ចិម និង ភូមិភាគបូព៌ា ទៅកាន់ភូមិភាគឧត្តរ និង ភូមិភាគពាយ័ព្យ បានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ ក្រោយពេលពួកគេបានទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យ ចន្លោះថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥។ ទោះបី **អៀង សារី** ប្រហែលជាមិននៅក្នុងប្រទេសក្នុងពេលនោះក៏ដោយ[4234] ប៉ុន្តែគាត់បានទទួលស្គាល់ថា គាត់បានចូលរួមក្នុងអង្គប្រជុំបើកទូលាយមួយរបស់គណៈអចិន្ត្រៃយ៍ នៅខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាអំពីបញ្ហានៃការបង្កើតរបបផ្តាច់ការ និងការពង្រឹងវិស័យកសិកម្ម និងឧស្សាហកម្ម[4235]។ ម្យ៉ាងទៀត មានឯកសារមួយរបស់បក្ស មានចុះកាលបរិច្ឆេទដូចគ្នានឹង ការប្រជុំនេះ បញ្ជាក់ពីភាពចាំបាច់ក្នុងការបញ្ជូនប្រជាជនថ្មីទៅក្នុងភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ[4236]។

**ដំណាក់កាលទី៣**

១០២៥. ការផ្លាស់ទីលំនៅប្រជាជននេះកើតឡើងនៅពេល **អៀង សារី** ជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍។ បន្ថែមពីលើនេះ ការផ្លាស់ទីលំនៅប្រជាជននេះជាប់ពាក់ព័ន្ធជាមួយនឹងការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា ដែលកើតមានឡើងដោយសារបក្សកុម្មុយនីស្តកម្ពុជា មានការបារម្ភថាវៀតណាមបានជ្រៀតចូលក្នុងជួរកម្មាភិបាលរបស់ខ្លួន ក្នុងភូមិភាគបូព៌ា ដើម្បីរៀបចំធ្វើរដ្ឋប្រហារ។ **អៀង សារី** បានសម្តែងការបារម្ភតាមរយៈសុន្ទរកថារបស់គាត់[4237] និងតាមរយៈការផ្សព្វផ្សាយ "សៀវភៅខ្មៅ"[4238] ដល់មន្ត្រីបរទេស និងអ្នកសារព័ត៌មាន។[4239] សៀវភៅខ្មៅនោះបានសរសេរថាវៀតណាមបានជ្រៀតចូលក្នុងដែនដីកម្ពុជា ដើម្បីបង្កើតទំនាក់ទំនង និងធ្វើការជួបប្រជុំជាមួយភ្នាក់ងារកម្ពុជា ដើម្បីរៀបចំផែនការធ្វើរដ្ឋប្រហារ។ ឯកសារនេះបានបន្តសរសេរថាផែនការនេះបានទទួល "បរាជ័យយ៉ាងអាម៉ាស់ និងធ្ងន់ធ្ងរ"[4240]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ហាក់បង្ហាញថា អ្នកដែលត្រូវជម្លៀសចេញពីភូមិភាគបូព៌ា បានឆ្លងកាត់តាម

ទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៨។[4241] បន្ថែមពីលើនេះ សាក្សីជាច្រើននិយាយថា **អៀង សារី** បានទៅពិនិត្យភូមិភាគបូព៌ា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[4242]។

**សហករណ៍ និងការដ្ឋាននានា**

**១០២៦.**តាមរយៈតួនាទីផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** បានចូលរួមក្នុងការបង្កើត និងការដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាននានា។

**ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ**

**១០២៧.**ចាប់តាំងពីឆ្នាំ១៩៧០ ប.ក.ក បានចាប់ផ្ដើមរៀបចំជាបណ្ដើរៗ នូវសមូហកម្មផលិតកម្ម កសិកម្ម តាមរយៈការបង្កើតសហករណ៍ នៅពេល **អៀង សារី** ជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍រួចហើយ[4243]។

**១០២៨.**ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** បានចូលរួមក្នុងការបន្តរៀបចំគោលនយោបាយ ដោយចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឬ តាមរយៈការទទួលបានកំណត់ហេតុអង្គប្រជុំទាំងនេះ[4244] និងបានចូលរួមក្នុងការបង្កើត *ផែនការបួនឆ្នាំ* ដើម្បីកសាងសង្គមនិយមនៅគ្រប់វិស័យ[4245]។ គោលនយោបាយនេះក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុងការប្រជុំបើកទូលាយរបស់គណៈអចិន្ត្រៃយ៍ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ទាក់ទងនឹងការពិភាក្សាអំពីការពង្រឹងវិស័យកសិកម្ម[4246]។ ជាងនេះទៀត **អៀង សារី** ក៏បានជួយក្នុងការរៀបចំគោលនយោបាយតាមរយៈ តួនាទីរបស់គាត់នៅក្នុងគណៈរដ្ឋមន្ត្រី[4247]។

**១០២៩.អៀង សារី** បានចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ ដែលក្នុងនោះមានការចេញសេចក្ដីសម្រេចធ្វើការសាងសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង[4248] ឬបានទទួលកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍នេះ ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

<u>ការគាំទ្រដល់គោលនយោបាយ</u>

១០៣០.អៀង សារី បានគាំទ្រយ៉ាងសកម្មចំពោះគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ នៅថ្នាក់ជាតិ គាត់បានផ្សព្វផ្សាយពីគោលនយោបាយនេះ នៅតាមការប្រជុំរៀនសូត្រ ជាមួយបុគ្គលិកក្រសួងការបរទេស[4249] ការជួបជុំជាទ្រង់ទ្រាយធំ[4250] និង តាមវិទ្យុជាតិកម្ពុជា[4251]។ នៅថ្នាក់អន្តរជាតិ អៀង សារី បានពន្យល់ពីគោលនយោបាយនេះដល់អ្នកកាសែតបរទេស[4252] ក្រុម និងគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា[4253] និងនៅអង្គការសហប្រជាជាតិ[4254]។

១០៣១. នៅខែមករា ឆ្នាំ១៩៧៦ អៀង សារី បានថ្លែងថា សហករណ៍មិនត្រឹមតែបំពេញបាននូវមុខងារផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ តែក៏បានបម្រើបុព្វហេតុនយោបាយផងដែរ ដោយចែករំលែកនូវ *"ការខិតខំកម្ទេចខ្មាំង"*[4255]។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អៀង សារី បានពន្យល់ថា សហករណ៍មានភារកិច្ចការពារ *"...តំបន់រំដោះ និងកំលាំងបដិវត្តរដ្ឋ និង ប្រយុទ្ធទល់នឹងសកម្មភាពក្បត់របស់ខ្មាំង និងយុទ្ធនាការសន្តិភាវកម្ម"*[4256]។

១០៣២. នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៦ ក្នុងពិធីជប់លៀងមួយនៅខេត្តសៀមរាប ដោយមានការចូលរួមពីកម្មាភិបាលនៅ ប-១ និងអ្នកការទូតនៅប្រទេសកម្ពុជា អៀង សារី បានប្រកាសថា៖ *"ដូចដែលអ្នកបានឃើញស្រាប់ហើយថា ប្រទេសទាំងមូលបានប្រែក្លាយជាការដ្ឋានដ៏ធំមួយ។ ប្រជាជនកម្ពុជាជាកម្លាំងចលករ ក្នុងការកសាងប្រព័ន្ធស្រោចស្រព់ទឹកថ្មី ដោយមានជំនឿជាក់ដ៏មុតមាំចំពោះអនាគតដ៏ភ្លឺស្វាង"*[4257]។

១០៣៣. នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៦ ក្នុងពិធីជប់លៀងមួយដែលរៀបចំទទួលគណៈប្រតិភូមួយក្រុមមកពីប្រទេសចិន អៀង សារី បានប្រកាសថា ប្រទេសកំពុងតស៊ូសម្រេចឲ្យបាននូវភារកិច្ចចម្បងចំនួនពីរគឺការកសាងសេដ្ឋកិច្ច និង ការពារប្រទេស។ គាត់និយាយថា *"នាពេលបច្ចុប្បន្ននេះចលនាបដិវត្តកសាងប្រព័ន្ធស្រោចស្រព និង បង្ហូរទឹក ដែលក៏តំណាងនូវស្មារតីប្រយុទ្ធ និង ការប្រយុទ្ធបង្កបង្កើនផលផ្នែកឧស្សាហកម្ម និង កសិកម្ម កំពុងបន្តយ៉ាងសស្រាក់សស្រាំនៅទូទាំងប្រទេស។ មានការដ្ឋាននៅគ្រប់ទីកន្លែង"*[4258]។

១០៣៤.នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦ នៅឯមហាសន្និបាតលើកទី៣១ របស់អង្គការសហប្រជាជាតិ អៀង


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

**សារី** បានថ្លែងថា៖ *"គ្រប់ទីកន្លែងនៅក្នុងប្រទេស ប្រជាជនកម្ពុជាយើងបានចូលរួមក្នុងចលនាបដិវត្ត យ៉ាងក្លៀវក្លា ដើម្បីសម្រេចឱ្យបាននូវភារកិច្ចពីរជាមូលដ្ឋានគឺ៖ ការពារ និង កសាងប្រទេស"*[4259]។ **អៀង សារី** ក៏បានថ្លែងផងដែរថា *"បរិវារ"* របស់សហរដ្ឋអាមេរិក និង *"កម្លាំងប្រតិកិរិយាដទៃទៀត"* កំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជានៅឡើយ *"ប្រជាជន និង កងទ័ពបដិវត្តនឹងបន្តប្រយុទ្ធប្រឆាំងពួកទាំងនោះដោយឯករាជ្យ និង បានធ្វើឱ្យពួកវាត្រូវទទួលបរាជ័យយ៉ាងអាម៉ាស់"*[4260]។

**១០៣៥.**នៅខែមករា ឆ្នាំ១៩៧៧ ក្នុងពិធីជប់លៀងមួយដែលរៀបចំទទួលក្រុមអគ្គទូតប្រចាំកម្ពុជាប្រជាធិប-តេយ្យ **អៀង សារី** បានថ្លែងពីសមិទ្ធិផលរបស់ប្រទេស ក្នុងវិស័យកសិកម្ម និង ធារាសាស្ត្រ និង បានប្រកាសថា៖ *"... ឆ្ពោះទៅស្តាបនាសេដ្ឋកិច្ចឡើងវិញ និង ការពារនិងកសាងប្រទេស យ៉ាង ក្លៀវក្លា។ វាក្លាយជាចលនាជាទ្រង់ទ្រាយធំ បដិវត្តន៍មានអត្ថន័យធំធេងនៅទូទាំងប្រទេស មិនធ្លាប់មានក្នុងប្រវត្តិសាស្ត្ររបស់យើង"*[4261]។

**១០៣៦.**នៅក្នុងសុន្ទរកថាដែលប្រកាសតាមវិទ្យុកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ **អៀង សារី** បានថ្លែងពីជោគជ័យ ដែលទទួលបានពីការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា[4262]។

**១០៣៧.** នៅខែឧសភា ឆ្នាំ១៩៧៧ **អៀង សារី** បានប្រាប់អ្នកកាសែតម្នាក់ថា៖ *"បទពិសោធន៍បដិវត្តកម្ពុជាមិនធ្លាប់មានទេពីមុនមក។ អ្វីដែលយើងកំពុងព្យាយាមនាំយកមកនេះ គឺមិនដែលកើតឡើងទេពីមុន...។ យើងកំពុងរៀបចំប្រទេសឡើងវិញ ដោយយកកសិកម្មជាមូលដ្ឋាន...។ កម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងដោយអង្គការ។ អង្គការជាបក្សនិងរដ្ឋតែមួយ។ ប្រជាជនត្រូវបានរៀបចំទៅជាសហករណ៍ ទទួលខុសត្រូវចែកស្បៀងអាហារ សម្លៀកបំពាក់ និងថ្នាំសង្កូវ។ គ្មានការចាយលុយឡើយ។ ទស្សនទាននៃកម្មសិទ្ធិឯកជនត្រូវលុបបំបាត់ចោល។ គ្មានកាសែតទេ មានតែឯកសារប្រចាំសប្តាហ៍ដែលផ្សព្វផ្សាយក្នុងចំណោមថ្នាក់ដឹកនាំ។ ប្រព័ន្ធអប់រំចាស់ត្រូវលុបបំបាត់ចោល...។ ដោយសារយើងមិនមានគំរូណាមួយដើម្បីដើរតាម យើងកំពុងរៀនតាមរយៈបទពិសោធន៍។ យើងចាប់ផ្តើមពីសហករណ៍កសិកម្ម នៅក្នុងតំបន់រំដោះ ក្នុងឆ្នាំ១៩៧៣។ បច្ចុប្បន្ននេះ សហករណ៍បានរីកសាយពេញទូទាំងប្រទេស"*[4263]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១០៣៨.នៅខែសីហា ឆ្នាំ១៩៧៧ ក្នុងពិធីជប់លៀងមួយដែលរៀបចំដើម្បីស្វាគមន៍គណៈប្រតិភូមួយក្រុមមកពីប្រទេសភូមា **អៀង សារី** បានប្រកាសថា គណៈប្រតិភូអាចបានឃើញផ្ទាល់នឹងភ្នែកនូវការខិតខំប្រឹងប្រែងរបស់ប្រជាជន ដើម្បីកសាងប្រព័ន្ធធារាសាស្ត្រ ប្រឡាយទឹក ផ្លូវទឹក និង អាងស្តុកទឹក[4264]។

១០៣៩. នៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ នៅឯមហាសន្និបាតលើកទី៣២ របស់អង្គការសហប្រជាជាតិ **អៀង សារី** បាននិយាយពីការងារកសាងជាតិនៅកម្ពុជា និងបានថ្លែងថា៖ *"យើងពឹងផ្អែកយ៉ាងរឹងប៉ឹងទៅលើការយល់ដឹងពីបដិវត្តយ៉ាងខ្លាំងក្លា, កម្លាំងដ៏មហាស្ចារ្យ, បទពិសោធន៍និងស្មារតីច្នៃប្រឌិតរបស់ប្រជាជនយើង ដែលភាគច្រើនលើសលប់ជាកសិករ។ យើងប្រកាន់យកកសិកម្មជាកត្តាមូលដ្ឋាន ហើយយើងប្រើប្រាស់ធនធានដែលទទួលបានពីកសិកម្ម ដើម្បីកសាងឧស្សាហកម្មឱ្យបានរីកចម្រើន និង ដើម្បីប្រែក្លាយកម្ពុជាដែលធ្លាប់តែមានកសិកម្មខិនថយ តែក្នុងមួយរយៈពេលខ្លី ឱ្យទៅជាប្រទេសដែលមានកសិកម្មទំនើប និង បន្ទាប់មកក្លាយជាប្រទេសឧស្សាហកម្ម ខណៈដែលរក្សាយ៉ាងរឹងប៉ឹងនូវមាគ៌ាឯករាជ្យ និង បូរណភាព និង យកកម្លាំងខ្លួនឯងជាមូលដ្ឋាន"*។ គាត់បានបន្តដោយសរសេរថា អាងផ្ទុកទឹកធំៗ, ប្រឡាយ និង ទំនប់ត្រូវបានសាងសង់ដោយ៖ *"កម្មករកសិករយើង ដែលជាអ្នកពឹងផ្អែកទាំងស្រុងទៅលើកម្លាំងខ្លួនឯង"*។ **អៀង សារី** ក៏បញ្ជាក់ផងដែរថា ការបង្កើតជាសហករណ៍យ៉ាងទូលំទូលាយ ដែលកសិករជាអ្នកកាន់អំណាច និង គ្រប់គ្រងការបង្កបង្កើនផល *"បង្កើតជាកត្តាមូលដ្ឋានដែលកំពុងផ្លាស់ប្តូរជាបន្តបន្ទាប់ នូវការលេចឡើងនូវទីជនបទ ... និងប្រែក្លាយរូបភាពនេះ"*[4265]។

១០៤០. នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ ក្នុងលិខិតមួយផ្ញើជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិ **អៀង សារី** និយាយថា ដោយសារកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាកំពុងធ្វើការជាមួយប្រជាជនដោយអនុវត្តការការពារ និងការកសាងជាតិ ពួកគេមិនអាចតំណាងកម្ពុជានៅអង្គសហប្រជាជាតិបានទេ[4266]។ **អៀង សារី** បាននិយាយបន្តថា អតីតរដ្ឋការរដ្ឋាភិបាលចាស់ ដែលក្លាយជាប្រជាពលរដ្ឋធម្មតាជាថ្មី កំពុងធ្វើការជាមួយប្រជាជននៅតាមសហករណ៍ ហើយថា *"គ្រប់គ្នាមានសិទ្ធិស្មើៗគ្នា"*។ **អៀង សារី** ក៏បានថ្លែងដែរថា ក្នុងដំណើរការស្តារសេដ្ឋកិច្ច និងការកសាងជាតិនេះ ប្រជាជនកម្ពុជាសម្រេចបានសមិទ្ធិផលជាច្រើនទាំងក្នុងវិស័យឧស្សាហកម្ម និង កសិកម្ម ដោយពឹងផ្អែកលើធនធានរបស់ខ្លួនទាំងស្រុង[4267]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១០៤១. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ **អៀង សារី** បានថ្លែងក្នុងកិច្ចសម្ភាសន៍មួយថា បច្ចុប្បន្ននេះប្រជាជនកម្ពុជា *"លើសលុបនៅទីជនបទ"*[4268]។

១០៤២. នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៨ នៅឯមហាសន្និបាតលើកទី៣៣ របស់អង្គការសហប្រជាជាតិ **អៀង សារី** បាននិយាយអំពីលទ្ធផលដែលសម្រេចបានដោយសង្គម *"សម្ភូហភាពនិយម, សង្គមនិយម"* របស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈប្រព័ន្ធធារាសាស្ត្រយ៉ាងទូលំទូលាយ និងការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម បច្ចេកវិទ្យា និង វិទ្យាសាស្ត្រ។ គាត់បានធ្វើការកត់សម្គាល់ថា *"អ្នកដែលមានជីវិតស្រណុកក្នុងសង្គមចាស់ ពោលគឺមានចំនួនជិត ១០% នៃប្រជាជន ស្ថានភាពរស់នៅផ្នែកសម្ភារៈត្រូវបានកាត់បន្ថយតិចឬច្រើនតាមកម្រិតអ្នកគ្រប់គ្នានៅក្នុងប្រទេស"*[4269]។

<u>ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះ</u>

១០៤៣. **អៀង សារី** បានដឹងអំពីមធ្យោបាយជាច្រើន ដែលគោលនយោបាយនេះត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា ហើយបានចូលរួមនៅក្នុងការអនុវត្តន៍គោលនយោបាយនេះ។

១០៤៤. **អៀង សារី** បានទទួលទូរលេខដែលរាយការណ៍ពីការអនុវត្តន៍គោលនយោបាយ និងស្ថានភាព រស់នៅរបស់ប្រជាជននៅទូទាំងប្រទេស[4270]។ មានរបាយការណ៍ខ្លះបានបញ្ជាក់ច្បាស់ថា មានការខ្វះខាតស្បៀងអាហារនៅតាមខេត្ត ហើយថាប្រជាជនកំពុងជួបប្រទះការអត់ឃ្លាន[4271]។ ទូរលេខមួយចំនួនទៀត រាយការណ៍ពីការរីកចម្រើននៅតាមការដ្ឋាននានា ដូចជាទំនប់ទឹកដែលកំពុង សាងសង់ រួមទាំងការដ្ឋានមួយឈ្មោះ ទំនប់ត្រពាំងថ្ម។[4272]

១០៤៥. **អៀង សារី** បានទៅពិនិត្យជាលក្ខណៈបុគ្គលនៅតាមការដ្ឋាន និងសហករណ៍នានា នៅទូទាំងប្រទេសកម្ពុជា[4273]។ **អៀង សារី** បានទៅពិនិត្យតាមតំបន់នានា ដូចជានៅខេត្តសៀមរាប[4274] រួមមានស្រុកសូទ្រនិគម[4275] និង ស្រុកជីក្រែង[4276] និងខេត្តបាត់ដំបង[4277] និង ស្នួង[4278]នៅភូមិភាគបូព៌ា។ **អៀង សារី** ក៏បានទៅធ្វើទស្សនកិច្ចផងដែរនៅតាមការដ្ឋាន ដូចជា៖ ទំនប់១ មករា[4279] ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[4280] និង ទំនប់ត្រពាំងថ្ម[4281]។ [លុប] អតីតបុគ្គលិកនៅ ប-១ ដែលធ្លាប់អមដំណើរ អៀង សារី ទៅធ្វើទស្សនកិច្ចនៅតាមទីជនបទ និយាយថាពួកគេបានឃើញ *"ប្រជាជនមានការលំបាក"* តែមិនហ៊ាននិយាយអ្វីទេ ព្រោះការងាររបស់ពួកគេ

*"ក្រសួងការបរទេស បើនិយាយរឿងរបស់ភូមិភាគរបស់គេ នាំឱ្យប៉ះពាល់សាមគ្គីភាព។ ភាគមួយមានមេមួយដូចស្ដេចក្រាញ់អីចឹង"*[4282]។ [លុប] ក៏និយាយទៀតថា៖ *"ភ្ញៀវបរទេសក៏អាចឃើញដូចខ្ញុំដែរ គេអាចសរសេររបាយការណ៍របស់គេ តែខ្ញុំមិនដឹងថាថ្នាក់លើបានឃើញរបាយការណ៍នេះឬអត់ទេ"* [4283]។ លើសពីនេះទៀត អៀង សារី ទំនងជាបានបញ្ជូនកម្មាភិបាល ប-១ ដែលមិនសកម្មការងារ ទៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង "*ដើម្បីវាយថ្ម*"[4284]។

**១០៤៦.** អ្នកក្រោមបង្គាប់ **អៀង សារី** នៅ ប-១ តែងអមដំណើរគណៈប្រតិភូបរទេសជាទៀងទាត់ ទៅតាមសហករណ៍ និងការដ្ឋាន ក្នុងតំបន់នានាដូចជា ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ កំពង់សោម ខេត្តក្រចេះ និង ខេត្តតាកែវ[4285]។ ក្រោយពីដំណើរទស្សនកិច្ចទាំងនេះ អ្នកក្រោមបង្គាប់ អៀង សារី នឹងរាយការណ៍ម្ដងម្កាលទៅឱ្យគាត់ អំពីជីវភាពរស់នៅដ៏លំបាកលំបិនរបស់ប្រជាជន[4286]។

**១០៤៧.** នៅក្នុងកិច្ចសម្ភាសន៍មួយ **អៀង សារី** អះអាងថា គាត់មិនបានដឹងពីជីវភាពរស់នៅដ៏លំបាកលំបិនរបស់ប្រជាជននៅតាមបណ្ដាខេត្តទេ រហូតទាល់តែកូនស្រីគាត់ប្រាប់គាត់ ដែលក្រោយមក គាត់បានលើកយកបញ្ហានេះប្រាប់ ប៉ុល ពត ដោយនិយាយថា៖ *"ប៉ុល ពត ថាខ្ញុំហ្នឹងមនុស្សបានតែរើរបបខ្លួនឯងទេ គ្មានបានទៅជួយទេ។ ខ្ញុំអត់ហ៊ាននិយាយអីទាំងអស់ព្រោះអំណាចនៅលើគេ។ ខ្ញុំឃើញថាវាទៅមិនរួច។ប្រយុទ្ធមានតែងាប់។"*[4287]។ នៅក្នុងកិច្ចសម្ភាសន៍មួយទៀត **អៀង សារី** រៀបរាប់ពីការពិភាក្សាស្រដៀងគ្នានេះជាមួយកូនស្រីគាត់ ហើយត្រូវបាន ប៉ុល ពត ព្រមាន។ ដូច្នេះ គាត់និយាយថា ចាប់ពីពេលនោះមក គាត់ខ្លាចត្រូវគេចាប់ខ្លួន[4288]។ **អៀង សារី** ទទួលស្គាល់ថា ប្រជាជនគ្មានអ្វីហូបចុក ប៉ុន្តែ គាត់ប្រកែកថា គាត់មិនបានដឹងថាមានមនុស្សស្លាប់ដោយសារបញ្ហានេះទេ[4289]។ នៅពេលផ្សេងទៀត អៀង សារី ប្រកែកថា គាត់មិនបានដឹងពីជីវភាពនៅតាមខេត្តទេ។ ឧទាហរណ៍ នៅក្នុងកិច្ចសម្ភាសន៍មួយក្នុងឆ្នាំ១៩៨១ **អៀង សារី** បាននិយាយថា *"យើងពុំបានដឹងអំពីការរស់នៅឯថ្នាក់មូលដ្ឋានឡើយ។ នោះហើយជារបៀបដែលការកាប់សម្លាប់អាចកើតមាន។ ប៉ុន្តែអ្នកកាប់សម្លាប់ប្រជាជនគឺជាភ្នាក់ងារវៀតណាមឯណោះ។ រឿងនេះវាច្បាស់ដូចថ្ងៃ"*[4290]។

### មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស

**១០៤៨.** តាមរយៈតួនាទីផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** បានចូលរួមក្នុងការអប់រំកែប្រែ *"សមាសភាពមិនល្អ"* និងការសម្លាប់ *"ខ្មាំង"* ទាំងផ្ទៃក្នុង និងខាងក្រៅជួរបក្ស។

<u>ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ</u>

១០៤៩. គោលនយោបាយនេះមានតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេល **អៀង សារី** គឺជាសមាជិកពេញសិទ្ធិគណៈអចិន្ត្រៃយ៍ទៅហើយ។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី បានចូលរួមបន្តរៀបចំផែនការស្តីពីគោលនយោបាយ តាមរយៈការចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ ឬតាមរយៈការទទួលបានកំណត់ហេតុនៃការប្រជុំទាំងនេះ[4291]។ ជាងនេះទៅទៀត ក្នុងឋានៈជាសមាជិកគណៈមជ្ឈិម **អៀង សារី** បានចូលរួមក្នុងការរៀបចំ និងអនុវត្តសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលផ្ទេរអំណាចទៅឱ្យគណៈភូមិភាគ និងគណៈតំបន់ស្វយ័ត ក្នុងការកម្ទេចទាំងក្នុងជួរ និងក្រៅជួរ[4292]។ **អៀង សារី** ក៏បានចូលរួមផងដែរក្នុងគោលនយោបាយនេះ ក្នុងឋានៈជាសមាជិកគណៈរដ្ឋមន្ត្រី[4293]។ បន្ថែមពីលើនេះ ក្នុងខែកក្កដា ឆ្នាំ ១៩៧៥ **អៀង សារី** បានចូលរួមកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍ ដែលនៅពេលនោះ គោលនយោបាយនេះត្រូវបានពិភាក្សា[4294]។

១០៥០. **អៀង សារី** អាចធ្លាប់បានចូលរួមក្នុងការបង្កើត និងផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈមជ្ឈិម ខែមិថុនា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា *"សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភាន់ច្រឡំចូល សេអ៊ីអា ឬធ្វើភ្នាក់ងារយួន ឬចូលកាហ្សេបេ ប្រឆាំងបក្ស បដិវត្ត ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ"* ដែលពណ៌នាពីការអប់រំកែប្រែអ្នកដែលបានចូលរួមជាមួយ សេ.អ៊ី.អា, កា.ហ្សេ.បេ និងវៀតណាម មុនខែកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែបញ្ជាឱ្យបក្ស និងប្រជាជនកម្ពុជាកម្ចាត់ចោលនូវខ្សែបណ្តាញដែលបន្តប្រឆាំងបក្សពី ខែកក្កដា ឆ្នាំ ១៩៧៨ទៅ[4295]។ ជាងនេះទៅទៀត នៅខែកញ្ញា ឆ្នាំ១៩៧៨ **អៀង សារី** បានចូលរួមសន្និបាតធំមួយនៅទីក្រុងភ្នំពេញ ជាមួយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដែលនៅពេលនោះ ប៉ុល ពត បានប្រកាសដល់អ្នកចូលរួមរាប់រយនាក់ថា កងទ័ពនិងមូលដ្ឋានលែងមានសិទ្ធិចាប់មនុស្សទៀតហើយ ចាប់ពីពេលនោះមក ពួកគេត្រឹមតែមានសិទ្ធិសួរចម្លើយ និងរាយការណ៍ទៅមជ្ឈិមប៉ុណ្ណោះ[4296]។

<u>ការគាំទ្រគោលនយោបាយនេះ</u>

១០៥១. **អៀង សារី** បានផ្សព្វផ្សាយ និងគាំទ្រគោលនយោបាយ ទាំងនៅថ្នាក់ជាតិ និងនៅឆាកអន្តរជាតិ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605601



១០៩២.នៅខែមេសា ឆ្នាំ១៩៧៧ រយៈពេលខ្លីបន្ទាប់ពីមានការបោសសម្អាតនៅ ប-១ នៅខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧ **អៀង សារី** បានប្រកាសជាសាធារណៈថា៖ *"...ប្រជាជនកម្ពុជាយើង និងកងទ័ពបដិវត្តយើងបានកម្ទេចរាល់ឧបាយកលរបស់ខ្មាំង ដោយបំបែកខ្សែបណ្តាញគិញ្ចរបស់ពួកគេ និងបានជោគជ័យក្នុងការរក្សាបាននូវឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដី និងសមិទ្ធិផលដ៏ពិសិដ្ឋរបស់បដិវត្ត។ ទោះបីជាយ៉ាងនេះក្តី ប្រជាជនយើង និងកងទ័ពបដិវត្តយើងបាននិងកំពុងបង្កើននូវស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់"*[4297]។

១០៩៣.នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៧ **អៀង សារី** បានថ្លែងសុន្ទរកថាក្នុងពិធីជប់លៀងមួយ ដែលរៀបចំដើម្បីស្វាគមន៍គណៈប្រតិភូមកពីប្រទេសភូមា។ គាត់បាននិយាយថា *"ក្នុងអំឡុងពេល ៨ ខែចុងក្រោយនេះ ប្រជាជនកម្ពុជាយើង និងកងទ័ពបដិវត្តយើង បានពុះពារយ៉ាងខ្លាំងក្លា និងលំបាកលំបិន ដើម្បីបង្កបង្កើនផល និងការពារបានយ៉ាងជោគជ័យ និងការពារឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី រួមទាំងសមិទ្ធិផលបដិវត្ត និងការគ្រប់គ្រងរដ្ឋរបស់ប្រជាជនក្នុងភាពស្មើគ្នា និងយុត្តិធម៌ ដោយបានកម្ទេចចោលនូវរាល់ឧបាយកលគ្រប់រូបភាពរបស់ខ្មាំង"*[4298]។

១០៩៤.នៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ នៅឯមហាសន្និបាតលើកទី៣២ របស់អង្គការសហប្រជាជាតិ **អៀង សារី** បានប្រកាសថា កម្ពុជាបានកម្ចាត់ទាំងខ្មាំងផ្ទៃក្នុង និងខាងក្រៅ ដោយនិយាយថា៖ *"...ទោះបីជាមានការបន្សល់ទុកបញ្ហាក្រោយពេលសង្គ្រាមជាច្រើនដែលត្រូវដោះស្រាយក៏ដោយក៏ប្រជាជនយើង និងកងទ័ពបដិវត្តយើង ដែលមានការប្រុងប្រយ័ត្នចំពោះចរិតពិតនៃពួកក្បត់ចក្រពត្តិអាមេរិកឈ្លានពាន និងសាហាវឃោរឃៅបរិវាររបស់ពួកវា និងពួកប្រតិកិរិយា ដែលជាសត្រូវរបស់ប្រជាជនយើងគ្រប់គ្នា ជានិច្ចកាលមានភាពប្រុងប្រយ័ត្នបដិវត្តន៍ និងបានធ្វើឱ្យខ្ចាត់ខ្ចាយនូវការប៉ុនប៉ងឈ្លានពាន វាតទី ធ្វើវិទ្ធង្សនា និងញុះញុង និងទទួលបានជោគជ័យពេញលេញក្នុងការការពារជាតិ និងបង្រួបបង្រួមជាតិ និងការអភិវឌ្ឍសមិទ្ធិផល និងកំលាំងបដិវត្តន៍ ព្រមទាំងការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី និងព្រំដែនរបស់ប្រទេសដែលមានឯករាជ្យ និងអធិបតេយ្យភាពពេញលេញ ដោយពឹងផ្អែកទាំងស្រុងលើកម្លាំងផ្ទាល់ខ្លួន"*[4299]។

១០៩៥.នៅខែមេសា ឆ្នាំ១៩៧៨ ក្នុងពិធីពិសារអាហារពេលល្ងាចមួយ ដើម្បីស្វាគមន៍គណៈប្រតិភូមកពីបក្សកុម្មុយនីស្តម៉ាក្ស-លេនីន របស់សហរដ្ឋអាមេរិក ក្នុងពេលដែលការបោសសម្អាតនៅក្នុងក្រសួង

ការបរទេសកំពុងបន្ត **អៀង សារី** បាននិយាយថា៖ *"...យើងបានកម្ទេចចោលទាំងស្រុងនូវសកម្មភាពស៊ើបយកការ និងវិទ្ធង្សនាទាំងអស់របស់ខ្មាំងគ្រប់ប្រភេទ រួមទាំងសកម្មភាពរបស់វៀតណាម និងសេអ៊ីអា ដែលកំពុងសហការគ្នា ..."*[4300]។

**១០៥៦.** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ក្នុងពិធីជប់លៀងមួយ ដើម្បីស្វាគមន៍សមាជិកអង្គទូត ដែលទទួលស្គាល់ដោយកម្ពុជា **អៀង សារី** បានថ្លែងថា កាលពីឆ្នាំកន្លងទៅ ប្រជាជន និងកងទ័ពបដិវត្ត *"...បានកម្ទេចនូវរាល់សកម្មភាពចារកិច្ច និងវិទ្ធង្សនារបស់ខ្មាំងគ្រប់ប្រភេទ រួមទាំងការប៉ុនប៉ងផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ តាមរយៈការធ្វើរដ្ឋប្រហារ..."*[4301]។

**១០៥៧.** នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ ក្នុងលិខិតមួយច្បាប់ផ្ញើជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិ **អៀង សារី** បានសរសេរថា ក្នុងរយៈពេលបីឆ្នាំកន្លងទៅ ប្រជាជនកម្ពុជាបាន *"កម្ទេច"* សកម្មភាពចារកិច្ច និងវិទ្ធង្សនា របស់ពួកចក្រពត្តិ ពួកពង្រីកទឹកដី ពួកវាតទីនិយម និងបរិវារវា រួមទាំងការប៉ុនប៉ងរបស់ពួកទាំងនោះក្នុងការផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ[4302]។ គាត់បានបន្តសរសេរថា *"រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមិនធ្វើឃាត...។ ក៏ប៉ុន្តែ នៅពេលដោះស្រាយជាមួយជនក្បត់មួយក្តាប់តូច ភ្នាក់ងារចក្រពត្តិនិយមបរទេស និងពួកប្រតិកិរិយា ដែលស្វែងរកការកម្ទេចប្រជាជាតិរបស់ពួកខ្លួន ប្រជាជនរបស់ខ្លួន និងបដិវត្តរបស់ខ្លួន រដ្ឋាភិបាលអនុវត្តជាដាច់ខាត និងក្លាហាននូវភាពផ្តាច់ការនៃវណ្ណៈពលជីព"*[4303]។

**១០៥៨.** នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៧៨ នៅឯសន្និសីទកាសែតមួយសម្រាប់សមាជិកបេសកកម្មការទូតនៅកម្ពុជា **អៀង សារី** បានប្រកាសថា៖ *"...នៅចុងខែឧសភា ឆ្នាំ១៩៧៨ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា បានកម្ទេចដោយជោគជ័យជាថ្មីម្តងទៀតនូវ ផែនការធ្វើរដ្ឋប្រហារមួយរបស់បក្សកុម្មុយនីស្តវៀតណាម និង រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងគោលបំណងផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ...។ គោលបំណងនៃការធ្វើរដ្ឋប្រហារនៅពេលនេះ គឺដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ។ ប្រសិនបើពួកគេមិនអាចផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យបានទាំងស្រុងទេ ពួកគេមានផែនការព្យាយាមគ្រប់គ្រងភូមិភាគបូព៌ា"*[4304]។ នៅថ្ងៃដដែលនោះ ក្រសួងឃោសនាការបានចេញសេចក្តីប្រកាសព័ត៌មានមួយ ដែលមានខ្លឹមសារថា បក្សកុម្មុយនីស្តកម្ពុជា និង កងទ័ពបដិវត្តន៍កម្ពុជា បានកម្ទេចទាំងស្រុងនូវផែនការធ្វើរដ្ឋប្រហាររបស់ពួកវៀតណាម[4305]។ នៅថ្ងៃទី២៩

ខែមិថុនា ឆ្នាំ១៩៧៨ នៅក្នុងកិច្ចសម្ភាសន៍មួយ **អៀង សារី** បានប្រកាសជាថ្មីថា បក្សកុម្មុយនីស្ត កម្ពុជាបានបំផ្លាញចោលយ៉ាងជោគជ័យចំពោះផែនការធ្វើរដ្ឋប្រហាររបស់ពួកវៀតណាម[4306]។

**១០៥៩.** នៅខែកក្កដា ឆ្នាំ១៩៧៨ ក្នុងកិច្ចសម្ភាសន៍មួយជាមួយកាសែត *Le Monde* **អៀង សារី** បាននិយាយថា *"នៅប្រទេសកម្ពុជា ម្យ៉ាងមានភ្នាក់ងារសេអ៊ីអា និងម្យ៉ាងទៀតមានភ្នាក់ងារវៀតណាម។ គឺពួកគេទាំងនេះហើយដែលបង្កើតការលំបាកជាច្រើនដល់ពួកយើង ដោយបង្កើតពាក្យចចាមអារ៉ាមថារដ្ឋាភិបាលមិនអាចបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជនបានទេ។ ភ្នាក់ងារទាំងនេះបានផ្សព្វផ្សាយដែលបង្កឲ្យមានការភាន់ច្រឡំយ៉ាងធំ អំពីសកម្មភាព និងកម្មាភិបាលនិងមេដឹកនាំដែលត្រូវបានគេលួចធ្វើឃាត។ តែយើងអាចធ្វើឲ្យសភាពការណ៍ទាំងនេះមានស្ថិរភាពបាន ដែលកំពុងតែមានការកែលម្អឡើង"*[4307]។

**១០៦០.** នៅពេលមានសំណួរក្នុងកិច្ចសម្ភាសន៍មួយទាក់ទិននឹងពាក្យថា *"អាទីរ៉េ* (បំផ្លាញចោល)*"* និង *"កម្ទេចចោល"* ដែលគាត់ប្រើនៅអង្គការសហប្រជាជាតិ និងនៅពេលដែលគេសួរគាត់ថា តើទាំងពាក្យទាំងនេះបង្ហាញឲ្យដឹងថាមានការសម្លាប់មនុស្សនៅក្នុងប្រទេសកម្ពុជាដែរឬទេ **អៀង សារី** បានឆ្លើយថា៖ *"អាណឹងហើយដែលយើងប្រើពាក្យពេជន៍ហ្នឹងណា ពីកាលហ្នុង បើមិននិយាយអញ្ចឹងឃើញទេ គឺថាមានទោស ហើយត្រឡប់ម៉ោម្តងៗ នៅតែភ័យខ្លួន។ ប្រែជាភាសាបរទេសហ្នឹងណា សុទ្ធតែពួកគេដែលគេហៅថា* [លុប] *ពួកអីហ្នឹងជួយបកប្រែច្រើនណាស់។ ខ្ញុំមិនសូវចេះទេភាសាបរទេសអីប៉ុន្មានទេ ក៏ប៉ុន្តែកម្ទេចអីៗទាំងអស់ហ្នឹងសុទ្ធតែពាក្យគេហៅថា ក្នុងស្រុកក្នុងអាដែង គេហៅថាគណៈបក្សគេប្រើ បើយើងមិនប្រើអាណឹងខ្លាចគេចោទប្រកាន់ទៀត។"*[4308]។

<u>ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះជាលក្ខណៈទូទៅ</u>

**១០៦១.** ទោះបីមិនមានភស្តុតាងដែលបង្ហាញថា **អៀង សារី** ធ្លាប់បានធ្វើទស្សនកិច្ចជាលក្ខណៈបុគ្គលទៅតាមមន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់ណាក៏ដោយ ប៉ុន្តែ **អៀង សារី** បានដឹងថា ខ្មាំងបក្សកុម្មុយនីស្តកម្ពុជាខាងក្នុង និងខាងក្រៅ ត្រូវបានរកឃើញ និងយកទៅសម្លាប់ តាមរយៈតួនាទីរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍, ការទទួលទូរលេខដែលរាយការណ៍ពី "សភាពការណ៍ខ្មាំង" នៅទូទាំងប្រទេស, ការដឹងនិងការចូលរួមរបស់គាត់នៅ ស-២១ និង តាមរយៈការប្រជុំជាទៀងទាត់ជាមួយសមាជិកគណៈភូមិភាគ និងគណៈតំបន់។

១០៦២.ឌុច ពន្យល់ពីការសម្រេចថា រាល់ការចាប់ខ្លួនសមាជិកគណៈមជ្ឈិម ឬ កម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាត្រូវសម្រេចជាសមូហភាពដោយគណៈអចិន្ត្រៃយ៍[4309]។ ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ **អៀង សារី** ប្រហែលជាបានដឹង និងបានចូលរួមការចាប់ខ្លួន និងការសម្លាប់ ឬការធ្វើអត្តឃាតរបស់សមាជិកគណៈអចិន្ត្រៃយ៍, ភូមិភាគ, លេខាតំបន់ស្វ័យត និងរដ្ឋមន្ត្រី។ វាទំនងផងដែរថា **អៀង សារី** អាចបានទទួលឯកសារថតចម្លងមួយច្បាប់ក្នុងចំណោមឯកសារថតចម្លងទាំងប្រាំពីរ នៃចម្លើយសារភាពរបស់លេខាតំបន់ **សួស នៅ** ហៅ **ឈូក** ដែល **ឌុច** ជឿថាគាត់បានរៀបចំជូនគណៈអចិន្ត្រៃយ៍[4310]។ លើសពីនេះទៀត **អៀង សារី** អាចមានវត្តមានក្នុងអង្គប្រជុំ សម្រេចអំពីការចាប់ខ្លួន **វន វេត និងនៅពេលចាប់ខ្លួននោះ**[4311]។

១០៦៣.**អៀង សារី** បានទទួលទូរលេខពីភូមិភាគនានាដែលរាយការណ៍ពីការអនុវត្តន៍គោលនយោបាយនេះ[4312]។ ឧទាហរណ៍ មានទូរលេខមួយដែលចម្លងជូន **អៀង សារី** និងបានទទួលនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ រាយការណ៍ពីការកម្ចាត់*ពួកចារកម្ម* និង*ពួកក្បត់ផ្ទៃក្នុង* នៅតាមបណ្ដោយព្រំដែនខាងកើត[4313]។ ទូរលេខមួយទៀតដែលចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ផ្ញើដោយ [លុប] ជូន "គណៈ ៨៧០" បានកត់ត្រាថា៖ *"នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់ វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើង នៅតាមការដ្ឋាន។ ពួកខ្មាំងដែលនៅសេសសល់ទាំងនេះ វាទាក់ទងជាមួយពួកប៉ូលីស ទាហាន និងពួករដ្ឋការ ពួកទាំងនេះវាបន្លំធ្វើប្រជាជនថ្មី។ ក្រោយពីវាធ្វើសកម្មភាពប្រឆាំងនឹងយើង ទើបយើងស្គាល់មុខវាច្បាស់ ទន្ទឹមនឹងនេះ យើងក៏បានបោសសម្អាតវាជាខ្សែសង្វាក់។ មកដល់ថ្ងៃនេះ សភាពការណ៍ខ្មាំងបង្កប់ត្រូវស្ងប់ស្ងាត់។ ពួកទាហាន ប៉ូលីស និងរដ្ឋការមួយចំនួនត្រូវរត់បាត់ ក្រោយពីយើងបោសសម្អាតចំនួនប្រមាណ ២០ ក្បាល។ យើងក៏មានវិធានការបន្តរកចាប់ពួកនេះតទៅទៀត។ ឯខ្មាំងបង្កប់នៅតំបន់ព្រះវិហារ ក្រោយពីយើងបានបោសសម្អាត និងកំពុងបោសសម្អាតតទៅទៀត"*[4314]។ ទូរលេខផ្សេងទៀតសរសេរថា *"យើងកំពុងបន្តបោសសំអាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត"* [4315] ឬ *"អាខ្លះបញ្ចេញបាន ត្រូវវាយកោ និងសម្អាត"*[4316] និងរួមមានពាក្យពេចន៍មួយដូចជា *"បោសសម្អាត និងសម្រិតសម្រាំងពួកវាជាប់"*[4317] *"ពួកក្បត់ផ្ទៃក្នុងបានបោសសម្អាត"*[4318] *"បោសសម្អាតខ្មាំងបង្កប់"*[4319] *"រុករកខ្មាំង"* [4320] *"រកក្បាលម៉ាស៊ីនខ្មាំងតទៅទៀត"* [4321] និង *"កម្ទេចខ្មាំងគ្រប់បែបយ៉ាង"*[4322]។ បន្ថែមលើសពីនេះទៀត ទូរលេខផ្ញើពីកងពល ៩២០ ទៅ **សុន សេន** ចម្លងជូន **អៀង សារី** បានរាយការណ៍អំពីសមាសភាពមិនល្អចំនួនប្រាំនាក់ត្រូវបានចាប់ខ្លួន និងសួរយកចម្លើយ។ ទូរលេខបានសរសេរថា "ឯកសារ" នឹងត្រូវបានបញ្ជូន

នៅពេលដែលការសួរយកចម្លើយបានបញ្ចប់[4323]។

**១០៦៤.** នៅពេលខុសៗគ្នា **អៀង សារី** ទទួលស្គាល់ថា គាត់បានដឹងពីការសម្លាប់ខ្មាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងកិច្ចសម្ភាសន៍នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៨១ និង ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ **អៀង សារី** បានអះអាងថា មានគណៈកម្មាធិការយោធានិងសន្តិសុខមួយ ដែលរួមមាន ប៉ុល ពត, នួន ជា, សោ ភឹម និង សុន សេន មានភារកិច្ចសម្រេចលើបញ្ហាយោធា និងសន្តិសុខ ដោយរួមមាន *"សម្លាប់... ស-២១... ទីតាំងសម្លាត់ផ្សេងទៀត... ភ្នាក់ងារសម្ងាត់... និង បញ្ហាយោធា"*។ គាត់និយាយថា គណៈកម្មាធិការនេះត្រូវរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ បន្ទាប់ពីបានទទួលរបាយការណ៍ពីភូមិភាគ ហើយថាគាត់ខ្លួនឯងក៏បានទទួលរបាយការណ៍ស្តីពីបញ្ហាសន្តិសុខពីគណៈកម្មាធិការនេះដែរ[4324]។ **អៀង សារី** ក៏ទទួលស្គាល់ផងដែរថា ជួនកាល ប៉ុល ពត បានផ្តល់ព័ត៌មានឱ្យគាត់អំពីការសម្លាប់[4325]។ ក្នុងកិច្ចសម្ភាសន៍មួយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ **អៀង សារី** បានទទួលស្គាល់ថា គាត់បានដឹងពីការសម្លាប់មនុស្សដែលបានកើតឡើងនៅតាមភូមិភាគនានា ដោយនិយាយថា នៅភូមិភាគបូព៌ា *"ប្រសិន សោ ភឹម ធ្វើចង់សម្លាប់ ចង់អីៗ អត់ចាំបាច់សួរម៉ោខាងពីលើទេ។ ដូច្នេះការចាត់តាំងវាអញ្ចឹង គឺថាភូមិភាគមួយៗហ្នឹងវាឯករាជ្យសឹងតែអាដែងគេហៅថា សម្លាប់អីក៏សម្លាប់ទៅ ធ្វើអីក៏ធ្វើបានដែរ"*[4326]។ ក្នុងកិច្ចសម្ភាសន៍នៅខែមករា ឆ្នាំ១៩៧៩ **អៀង សារី** បានទទួលស្គាល់ថា នៅដើមសម័យរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា មានការសម្លាប់មនុស្សជាច្រើន ប៉ុន្តែថា ចំនួនសរុបក្នុងអំឡុងរបបនេះទាំងមូលគឺមានមិនលើសពីពីរបីពាន់នាក់នោះទេ[4327]។

**១០៦៥.** ដូចមានរៀបរាប់នៅក្នុងផ្នែកស្តីពីអង្គហេតុទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម គោលនយោបាយរបស់ ប.ក.ក ពាក់ព័ន្ធនឹងបញ្ហាសីលធម៌ គឺត្រូវដាក់ទោសអ្នកដែលប្រព្រឹត្តរំលោភសេពសន្ថវៈ។ មិនមានភស្តុតាងដែលបង្ហាញថា **អៀង សារី** បានដឹងថា អ្នកប្រព្រឹត្តអំពើរំលោភសេពសន្ថវៈទាំងនោះមិនត្រូវបានផ្តន្ទាទោសឡើយ។ ឧទាហរណ៍ គាត់បានទទួលទូរលេខ ខែឧសភា ឆ្នាំ ១៩៧៨ ដែលក្នុងនោះ អ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈត្រូវបានចាត់ជា "ខ្មាំងខាងក្នុង"[4328]។

**១០៦៦.** អតីតកម្មាភិបាល ប-១ ម្នាក់ ឈ្មោះ [លុប] និយាយថា **អៀង សារី** បានទទួលស្គាល់ចំពោះមុខគាត់ថា **អៀង សារី** រៀបចំប្រព័ន្ធមន្ទីរសន្តិសុខនៅប្រទេសកម្ពុជាយកគម្រូតាមប្រទេសចិន។ នៅឆ្នាំ១៩៩៦ [លុប] និយាយថា នៅពេលដែល **អៀង សារី** នៅប៉េកាំង គាត់បានទៅទស្សនាគុកលេខ១ ដែលជាកន្លែងឃុំឃាំងពួកប្រឆាំងនឹងបដិវត្តន៍សំខាន់ៗ។ នៅកន្លែងឃុំឃាំងនោះ

អ្នកទោសត្រូវបានតម្រូវឱ្យអានឯកសារមនោគមវិជ្ជា, ចូលរួមវគ្គស្វ័យទិតៀន, ដុសលាងខួរក្បាល និង ត្រូវបានឃុំឃាំងដាច់តែឯង។ [លុប] និយាយថា ពេលក្រោយមកទៀត នៅប្រទេសកម្ពុជា **អៀង សារី** បាននិយាយប្រាប់គាត់ថា *"គាត់អាចធ្វើបានល្អជាងគុកលេខ១ទៀត។ វាត្រូវតែល្អជាង គឺធ្វើនៅទូទាំងប្រទេស និងក្នុងគ្រប់វិស័យទាំងអស់"*[4329]។

## ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះនៅមន្ទីរ ស-២១

**១០៦៧.អៀង សារី** ទទួលស្គាល់ថា គាត់បានដឹងពីអត្ថិភាពនៃស-២១ ក្នុងរបបគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា[4330]។ ក៏ប៉ុន្តែ គាត់មិនដែលបានទៅទស្សនាកន្លែងនោះទេ[4331] ហើយមិនបានជួបប្រធានគុក **កាំង ហ្កេកអ៊ាវ** ហៅ ឌុច ដែរ[4332]។ ក្នុងកិច្ចសម្ភាសន៍មួយនៅខែកក្កដា ឆ្នាំ១៩៨១ អៀង សារី បានអះអាងថា ទោះបីគាត់បានដឹងពីមន្ទីរ ស-២១ ក៏ដោយ តែគាត់មិនបានដឹងថាមានការសម្លាប់អ្នកទោសដែរ ដោយគាត់គ្រាន់តែគិតថា អ្នកដែលត្រូវបានគេចាប់ខ្លួននឹងត្រូវបញ្ជូនទៅសហករណ៍ ដើម្បីអប់រំកែប្រែ[4333]។ នៅខែធ្នូ ឆ្នាំ១៩៩៦ **អៀង សារី** បានអះអាងក្នុងកិច្ចសម្ភាសន៍មួយថា រាល់ពេលដែលគាត់ត្រឡប់មកពីទស្សនកិច្ចនៅបរទេស មកដល់កម្ពុជាវិញ៖ *"ខ្ញុំនឹកខ្លួនខ្ញុំថាតើគេនាំខ្ញុំទៅអាស-២១ ហ្នឹង ឬ មួយខ្ញុំបានទៅគ្រួសារខ្ញុំ"*[4334]។ ក្នុងឆ្នាំ១៩៩៧ **អៀង សារី** បានបង្ហាញអារម្មណ៍ដូចគ្នានេះទៅនឹងអ្នកនិពន្ធម្នាក់ដែលសរសេរទាក់ទងនឹងកម្ពុជា ប៉ុន្តែគាត់នៅតែរក្សាជំហរថា នៅពេលនោះ គាត់បានជឿថា មន្ទីរ ស-២១ គឺជាមន្ទីរអប់រំកែប្រែ ដែលមនុស្សអាចរួចចេញមកវិញបាន។ ទើបតែក្នុងរយៈកាលក្រោយមកប៉ុណ្ណោះ ដែលគាត់កត់សម្គាល់ថា មិនដែលឃើញមាននរណាម្នាក់បានវិលត្រឡប់មកវិញទេ និងបានដឹងដែរថា អ្នកដែលជាប់ឃុំ *"ត្រូវបានជាប់ចោទនៅទីនោះដោយគ្មានសំអាងត្រឹមត្រូវ"*[4335]។

**១០៦៨.ឌុច** បំភ្លឺថា សមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់សុទ្ធតែបានដឹងថា មនុស្សគ្រប់គ្នាដែលបញ្ជូនទៅមន្ទីរ ស-២១ សុទ្ធតែត្រូវគេយកទៅសម្លាប់ ហើយថា ការធ្វើទារុណកម្មត្រូវបានគេអនុវត្តនៅគ្រប់មន្ទីរសន្តិសុខទាំងអស់[4336]។ បន្ថែមពីលើនេះ វាច្បាស់ណាស់ថា **អៀង សារី** បានដឹងថា អ្នកទោសមួយចំនួននៅមន្ទីរ ស-២១ ជាឈ្លើយសឹកវៀតណាម ដោយសារ ប-១ បានបោះពុម្ពឯកសារប្រមូលផ្តុំ "ចម្លើយសារភាព"[4337] របស់កងទ័ព និងគិញវៀតណាម ដែលត្រូវបានសួរយកចម្លើយនៅមន្ទីរ ស-២១[4338]។

**<u>ទំនាក់ទំនងជាមួយមន្ទីរ ស-២១ តាមរយៈ ប-១</u>**

**១០៦៩.** ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ យ៉ាងហោចណាស់ មានមនុស្ស ចំនួន ១១៣ នាក់ ដែលត្រូវបានចាប់ខ្លួនពី ប-១ ជាពិសេសពីមន្ទីរ ម-១ នៅច្រាំងចំរេះ ហើយបញ្ជូន មកមន្ទីរ ស-២១ ដូចដែលបង្ហាញក្នុងផ្នែកនិយាយអំពីអង្គហេតុទាក់ទង ស២១។

**១០៧០.** បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ ប-១ ជាកន្លែងមួយដែលបក្សពិនិត្យតាមដានកម្មាភិបាលមកពី ទូទាំងប្រទេស ដែលគេសង្ស័យពីភាពស្មោះត្រង់ ហើយទីបំផុតមនុស្សជាច្រើនត្រូវបានគេបញ្ជូន ទៅមន្ទីរ ស-២១[4339]។ **អៀង សារី** ក៏ធ្លាប់ទទួលស្គាល់ពីបញ្ហានេះដែរ[4340]។ អ្នកដែលស្ថិតក្រោមការ សង្ស័យ ជារឿយៗត្រូវបានប្រាប់ថា ពួកនោះនឹងត្រូវគេតែងតាំងជាអ្នកការទូត ឬជាអគ្គរដ្ឋទូត[4341]។ [លុប] និយាយថា ប-១ ជាកន្លែងសម្រេចតាមគោលបំណងនេះ ដោយសារវាជាកន្លែងដែលគ្មាន អាវុធ ហើយថា *"ពួកគេ"* មិនដឹងថាត្រូវបញ្ជូនទៅណាទៀត[4342]។ មានម្តងនោះ នួន ជា ធ្លាប់បាន គំរាមដល់ ឌុច ថា ការងារចុងក្រោយដែលសេសសល់សម្រាប់គាត់គឺត្រូវ *"ទៅធ្វើទូត"* ដែលមាន ន័យថា មនុស្សនោះនឹងត្រូវចាប់ខ្លួន និងយកទៅសម្លាប់[4343]។

**១០៧១.** ទាក់ទិននឹងប្រភេទមនុស្សដែលត្រូវបញ្ជូនពី ប-១ ទៅ ស-២១ ឌុច និយាយថា៖ *"ជាបឋម មាន បក្ខជនដែលបម្រើការងារនៅប-១។ បន្ទាប់មក មានបញ្ជាជនដែលត្រូវត្រៀមបញ្ជូនទៅធ្វើឯកអគ្គរដ្ឋ ទូតនៅបរទេស (ឧទាហរណ៍ ណាត, ទាញ, ឆាយ គីមហ៊ី)។ មានផងដែរ បក្ខជនដែលធ្វើការនៅ បរទេស ហើយដែលត្រូវបានហៅត្រឡប់មកវិញ (មាឃ ទូច, ស៊ានអាង) និង ផងដែរ បញ្ជាជន ដែលរស់នៅបរទេស ឧទាហរណ៍ និស្សិតនៅបារាំង និង ចុងក្រោយ អតីតឯកអគ្គរដ្ឋទូតរបស់ GRUNK (អ៊ី សុបគន្ធី, ហួត សម្បត្តិ, ជា សាន ដែលសរុបទាំងអស់ ២៣ នាក់"*[4344]។

**១០៧២.** វាទំនងជាថា រហូតដល់ឆ្នាំ១៩៧៧ នៅក្នុងករណីខ្លះ មន្ទីរ ស-២១ ត្រូវចុះទៅតាមអង្គភាពដែល ពាក់ព័ន្ធដើម្បីចាប់មនុស្ស ប៉ុន្តែថា ក្រោយមក គឺអង្គភាពពាក់ព័ន្ធជាអ្នកទទួលខុសត្រូវក្នុងការបញ្ជូន មនុស្សមក ស-២១។ ទាក់ទិននឹង ប-១ ការបញ្ជូនមនុស្សធ្វើឡើងដោយនីរសារម្នាក់ឈ្មោះ ជាម[4345] ដែលទំនងជាអតីតប្រធានសន្តិសុខនៅ ប-១ គឺ [លុប] នេះ។ នៅពេលដែលសួរអំពី ចំណុចនេះ [លុប] ប្រកែកថាមិនពិតទេ[4346] ហើយនិយាយថា គឺមន្ទីរ៨៧០ ដែលជាអ្នករៀបចំ ( យោងទៅដល់មន្ទីរដែលគ្រប់គ្រងដោយ ប៉ង់) និងបន្ថែមថា កងកម្លាំង យ-១០ ជាអ្នកអនុវត្តការចាប់

ខ្លួនមនុស្ស[4347]។ ក្រៅពីនេះ អាចមានឯកសារផ្សេងទៀត ដែលនាំមនុស្សពី ប-១ ទៅ ស-២១[4348]។ ក្រោយពេល **អៀង សារី** ផ្តល់ព័ត៌មានពីមនុស្សដែលត្រូវចាប់ខ្លួន មនុស្សនោះនឹងត្រូវគេដឹកចេញតាមរថយន្ត[4349]។ [លុប] ក៏និយាយថា ប៉ង់ ខ្លួនឯង ជាអ្នកមកយកមនុស្សទៅ ក្រោយពេលបានទាក់ទងផ្ទាល់ជាមួយ **អៀង សារី**[4350]។ ប៉ង់ បានប្រាប់មនុស្សដែលត្រូវចាប់ខ្លួន ថានាំយកទៅរៀនសូត្រ[4351]។ [លុប] និយាយថា គេដឹកមនុស្សតាមឡានចេញទៅ ហើយថា **អៀង សារី** បានដឹងរឿងនេះដែរ ដោយសារមនុស្សទាំងនោះត្រូវបានបញ្ជូនមកឱ្យគាត់ជាមុន មុនពេលបញ្ជូនចេញទៅ[4352]។ [លុប] និយាយថា មនុស្សដែល "មកពីក្រៅប-១" មកហៅមនុស្សទៅ "រៀនសូត្រ"។ មនុស្សទាំងនោះនឹងជួបផ្ទាល់ជាមួយអ្នកដែលនឹងត្រូវចាប់ខ្លួន ដោយមិនចាំឆ្លងកាត់ [លុប][4353]។ [លុប] រំឭកពីការចាប់ខ្លួនសហការីគាត់ម្នាក់នៅ ប-១ ដែលត្រូវគេ *"ប្រាប់ថាទៅប្រជុំ"* ដោយនីរសារម្នាក់ ហើយមិនឃើញត្រឡប់មកវិញ[4354]។

១០៧៣. ឌុច លើកពីករណីលើកលែងមួយថា៖ *"តាមគោលការណ៍នៃ ទម្លាប់ការងារ មុនមានការចាប់ខ្លួនទៅក្រសួងការបរទេស សេចក្តីសម្រេចពី អៀង សារី ជាការចាំបាច់"*[4355]។ នៅក្នុងការយល់ឃើញរបស់គាត់ **អៀង សារី** អាចត្រូវ *"ទទួលយល់ព្រមតាមសេចក្តីសម្រេច"*[4356]។ [លុប] និយាយថា ករណីកំហុសចោទប្រកាន់ធ្ងន់ធ្ងរដែលកើតមាននានា គឺលេចចេញពីបុគ្គលទាំងឡាយដែលត្រូវបានឆ្លើយដាក់ក្នុងចម្លើយសារភាពដែល ឌុច បានរាយការណ៍ទៅឱ្យមន្ទីរ ប-១ តាមរយៈមន្ទីរ៨៧០។ ឌុច និយាយថា **អៀង សារី** ជាអ្នកស្រាវជ្រាវរកឱ្យឃើញថា បុគ្គលទាំងឡាយដែលមានឈ្មោះនោះជានរណា ហើយពួកគេធ្វើការនៅផ្នែកអ្វី ហើយបន្ទាប់មក ទើបធ្វើការសម្រេច ថានរណាត្រូវបញ្ជូនទៅ ដែលក្រោយមកនឹងមានការចាប់ខ្លួន[4357]។ បន្ថែមលើនេះទៀត **អៀង សារី** បានប្រាប់ [លុប] ថា ចម្លើយសារភាពទាំងឡាយដែលមានចំណារត្រូវបានបញ្ជូនឱ្យគាត់ នៅពេលបរិភោគអាហាររួមគ្នា ឬនៅមន្ទីររបស់គាត់តាមរយៈលិខិតសម្ងាត់[4358]។ អតីតកម្មាភិបាលមន្ទីរ ប-១ [លុប] មិនអាចបញ្ជាក់អំពីរបៀបខាងលើនេះទេ ប៉ុន្តែគាត់និយាយថា សម្តីរបស់[លុប] លើបញ្ហានេះ អាចគួរឱ្យជឿជាក់បាន ដោយសារ [លុប] ទទួលបន្ទុកខាងសន្តិសុខ[4359]។ នៅពេលត្រូវតទល់ជាមួយនឹងសក្ខីកម្មរបស់ [លុប] ពាក់ព័ន្ធនឹងការបញ្ជូនចម្លើយសារភាពនានាតាមរយៈមន្ទីររបស់ ប៉ង់ នោះ [លុប] ដែលជាអតីតកម្មាភិបាលមន្ទីរ ប-១ បានបញ្ជាក់ថា *"ខ្ញុំបានដឹងដែរ លោក អៀង សារី បានប្រជុំថ្នាក់ដឹកនាំក្រសួងបានជ្រាប ប៉ុន្តែខ្ញុំមិនដឹងអំពីការសម្រេចរបស់លោក អៀង សារី ទេ"*[4360]។

**១០៧៤.**មានចម្លើយសារភាពនៅមន្ទីរ ស-២១ ចំនួនពីរ ដែលមានចំណារថា *"មិត្ត វ៉ាន់"* បានគាំទ្រការ អះអាងរបស់ [លុប] ដែលបានលើកឡើងថា **អៀង សារី** បានទទួលចម្លើយសារភាព ក្នុងស្ថានភាពដូចបានរៀបរាប់ពីខាងលើនេះ។ ចម្លើយសារភាពទាំងពីរនោះ គឺ៖ ឈ្មោះ មាយ ទូច ហៅ កែម អតីតកម្មាភិបាលភូមិភាគឧត្តរ (ត្រូវចាប់ខ្លួននៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៧) ត្រូវបានចាត់តាំងជាទូតនៅប្រទេសឡាវ ក្នុងឆ្នាំ១៩៧៦[4361] និងឈ្មោះ សាន ប៉ូ (ត្រូវចាប់ខ្លួននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៨) នៅផ្សាររដ្ឋភ្នំពេញ[4362]។ ឌុច ពន្យល់ថា ចំណារទាំងនេះ គឺជាចំណាររបស់ នួន ជា ហើយបញ្ជាក់ទៀតថា *"តាមគោលការណ៍នៃទម្លាប់ការងារ"*_ចម្លើយសារភាពទាំងនេះ ត្រូវបញ្ជូនទៅ អៀង សារី ដោយសារគាត់គឺជាប្រធានអង្គភាពសាមី របស់អ្នកទោសទាំងនោះ។ ឌុច និយាយថា ការធ្វើរបៀបនេះ គឺដើម្បីជូនដំណឹងដល់ប្រធានអង្គភាព ពីសកម្មភាពនានារបស់ខ្មាំងនៅក្នុងអង្គភាពរបស់ពួកគេ និងដើម្បីទុកលទ្ធភាពឲ្យប្រធានអង្គភាព អាចគិតជាមុនអំពីការចាប់ខ្លួនរបស់ជនណាម្នាក់ ដែលត្រូវបានឆ្លើយដាក់ក្នុងចម្លើយសារភាព[4363]។ **ឌុច** និយាយថា មនុស្សចំនួន៦០នាក់ ដែលត្រូវបានឆ្លើយដាក់ដោយ មាយ ទូច ក្រោយមក គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួនទេ[4364]។ [លុប] និយាយថា គាត់បានដឹងថា មន្ទីរ ប-១ ទទួលចម្លើយសារភាពនានាពីមន្ទីរ ស-២១ ដែលឯកសារទាំងនោះត្រូវបានរក្សាទុកដោយ [លុប][4365]។

**១០៧៥.**ភស្តុតាងក្នុងសំណុំរឿងបង្ហាញថា **អៀង សារី** បានទទួលចម្លើយសារភាពចំនួនពីរផ្សេងទៀត ក្រៅពីចម្លើយសារភាពដែលមានចារឈ្មោះបដិវត្តន៍របស់គាត់។ ជាឧទាហរណ៍ [លុប][4366] រំឭកថា **អៀង សារី** បានប្រកាសនៅក្នុងអង្គប្រជុំមួយ នៅឯបឹងត្របែក គាត់បានអានចម្លើយសារភាពនៅមន្ទីរស-២១ របស់ប្រជាជនខ្មែរដែលបានវិលត្រឡប់ពីបរទេស រួមមាន **វ៉ាន់ ពីនី** (ត្រូវចាប់ខ្លួននៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៧)[4367] និង **លាន សិរីវុធ** (ត្រូវចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧)[4368]។ [លុប] និយាយថា អៀង សារី បានប្រកាសថា ឈ្មោះ **វ៉ាន់ ពីនី** ត្រូវបានលើកឡើងនៅក្នុងចម្លើយសារភាពចំនួនពីរ ដែលនេះគឺជាមូលហេតុ **វ៉ាន់ ពីនី** ត្រូវបានចាប់ខ្លួន[4369]។ ពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ **វ៉ាន់ ពីនី, ឌុច** និយាយថា ក្នុងចំណោមមនុស្សចំនួន១០៦នាក់ ដែល **វ៉ាន់ ពីនី** បានឆ្លើយដាក់ យ៉ាងហោចណាស់មានអតីតសមាជិករបស់បក្សកុម្មុយនីស្ត ឬសមាជិករាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចំនួន១៩នាក់ ដែលត្រូវបានចាប់ខ្លួន។ ស្វាយ បូរី ត្រូវបានចាប់ខ្លួន **២២ថ្ងៃ** បន្ទាប់មកនោះ[4370]។ ទាក់ទងទៅនឹងចម្លើយសារភាពរបស់ លាន សិរីវុធ, ឌុច និយាយថា មនុស្សម្នាក់ក្នុងចំណោមមនុស្សទាំងឡាយ ដែល **លាន សិរីវុធ** បានលើកឡើងនោះ ត្រូវបានចាប់ខ្លួនរួចហើយ ហើយមនុស្សម្នាក់ទៀត ត្រូវបានចាប់ខ្លួននៅពេល

ក្រោយមក[4371]។ [លុប] និយាយថា អត្ថិភាពនៃចម្លើយសារភាពត្រូវបានដឹងឮយ៉ាងច្បាស់ "*អ្នកណាក៏ដឹងដែរថា ជនណាក៏ដោយដែលត្រូវ បានគេឆ្លើយដាក់តាមរយៈចម្លើយសារភាព ចំនួនបីខុសៗគ្នា នឹងត្រូវចាប់ខ្លួន។ ចំពោះសហព័ទ្ធ គឺតម្រូវ ឲ្យមានចម្លើយសារភាពចម្លើយដាក់ខ្លួនចំនួនប្រាំនាក់ ទើបអាចចាប់ខ្លួនបាន*"[4372]។ អៀង សារី បញ្ជាក់ថា ពីដំបូងឡើយ តម្រូវឲ្យមានមនុស្សចំនួនបីនាក់ឆ្លើយដាក់មនុស្សម្នាក់ មុននឹងធ្វើការចាប់ខ្លួនមនុស្សម្នាក់នោះ ប៉ុន្តែក្រោយចុងឆ្នាំ ១៩៧៧ ឬចុងឆ្នាំ១៩៧៨ ចំនួនមនុស្សនេះបានកើនដល់ប្រាំនាក់។ ក្រោយមក មានការសម្រេចថា មានតែបុគ្គលទាំងឡាយដែលត្រូវចោទប្រកាន់ពីសកម្មភាពនានាក្រោយរំដោះ ទើបត្រូវចាប់ខ្លួន[4373]។ [លុប] និយាយថា យូរៗពេលនោះ មានការបាត់ខ្លួនបុគ្គលិកខ្លះពីក្រសួង ដោយសារមាន "*ឯកសារ*" ពាក់ពន្ធ័សាមីខ្លួននោះ[4374]។

**១០៧៦.**[លុប] ក៏និយាយផងដែរថា អៀង សារី បានបង្ហាញចម្លើយសារភាពរបស់ លាន សេរីវុធ ឲ្យគាត់មើល[4375]។ [លុប] និយាយថា គាត់បានដឹងថា លាន សេរីវុធ ត្រូវបានសម្លាប់ ដោយសារការប្រើពាក្យសម្តីរបស់ អៀង សារី នៅពេលពិភាក្សាជាមួយគាត់៖ "*...កម្ទេច បោសសម្អាត*"។ [លុប] ក៏បញ្ជាក់ផងដែរថា អៀង សារី បានប្រកាសនៅក្នុងការប្រជុំមួយនៅមន្ទីរ ប-១ នាចុងឆ្នាំ១៩៧៨ ថា អ្នកទោសទាំងឡាយដែលត្រូវបានចាប់ពីពេលមុន ត្រូវបាន "*កម្ទេចដោយភ័ត្តច្រលំ*" ដោយសារតែជនក្បត់ធំមួយត្រូវបានរកឃើញ ហើយ **អៀង សារី** បានប្រកាសទៀតថា គាត់ពឹងផ្អែកលើបុគ្គលិកផ្សេងៗទៀត ក្នុងការរកមុខជនក្បត់នោះ[4376]។ [លុប] លើកឡើងថា អៀង សារី តែងតែនិយាយថា ជនក្បត់រស់នៅបរទេស ឬបានរៀបការនឹងជនបរទេស ដែលគាត់យល់ឃើញថា អាចជាការនិយាយបញ្ចិតបញ្ចៀងទៅដល់ [លុប] ឬ [លុប][4377]។ ក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា៖ "[លុប]", [លុប] អះអាងថា អៀង សារី បានបង្ហាញគាត់នូវឯកសារមួយ ហើយនិយាយថា វាជាចម្លើយសារភាពរបស់ វ៉ាន់ ពីនី[4378]។

**១០៧៧.**នៅក្នុងបទសម្ភាសន៍មួយក្នុងខែធ្នូ ឆ្នាំ១៩៩៦ អៀង សារី បានទទួលស្គាល់ថា នៅពេលដែល សេង កេងហ៊ុន ដែលជាប្រពន្ធរបស់មិត្តបដិវត្តន៍ចាស់របស់គាត់ម្នាក់បានបាត់ខ្លួនពីមន្ទីរ ប-១ **អៀង សារី** បានសួរថាមានអ្វីបានកើតឡើងចំពោះគាត់។ **អៀង សារី** បានទទួលចម្លើយថា "... *ខាងថ្នាក់លើ ខាងមជ្ឈិម ខាងអចិន្ត្រៃយ៍ឲ្យម៉ោយកទៅចំការ*"[4379]។ ទាំងប្តីនិងប្រពន្ធត្រូវចាប់ខ្លួនក្នុងខែមីនា ឆ្នាំ១៩៧៧ ហើយត្រូវសម្លាប់នៅមន្ទីរស-២១[4380]។ នៅក្នុងបទសម្ភាសន៍ដដែល **អៀង សារី** បាននិយាយថា នៅពេលបញ្ជាជនត្រូវចាប់ខ្លួន គណៈសន្តិសុខ និងគណៈយោធា បានប្រាប់គាត់ថា ពួកគេ

ទាំងនោះ "*នៅចំការ*"[4381]។

១០៧៨. [លុប] និយាយថា មនុស្សគ្រប់ៗគ្នាបានកត់សម្គាល់ពីការបាត់ខ្លួនមនុស្សពីក្រសួង ប៉ុន្តែគ្មាននរណាម្នាក់សួរនាំអ្វីឡើយ - ហើយនៅក្នុងអំឡុងពេលប្រជុំផ្សេងៗ គ្មានការលើកឡើងពីបុគ្គលទាំងនោះទេ ដោយគ្រាន់តែនិយាយថា ពួកគេត្រូវបាន "*ផ្លាស់ប្តូរការងារ*"។ នៅពេលនោះ [លុប] [លុប] គាត់មានការជឿជាក់ថា មនុស្សទាំងនោះ ត្រូវគេឲ្យទៅរៀនសូត្រនៅឯជនបទ[4382]។ [លុប] [លុប] ក៏បាននិយាយផងដែរថា នៅពេលដែលមនុស្សបានចាកចេញពីមន្ទីរ ប-១ គេគ្រាន់តែនិយាយថា អ្នកទាំងនោះត្រូវបានបញ្ជូនទៅធ្វើការនៅតាមកន្លែងផ្សេងៗទៀត[4383]។ [លុប] រំឭកឲ្យដឹងថា មានប្រជាជនជាច្រើនត្រូវបានបាត់ខ្លួនពីក្រសួង ហើយគេមិនបានដឹងទេថា ពួកគេទាំងនោះត្រូវគេយកទៅទីណាទេ[4384]។

១០៧៩. **អៀង សារី** មានចម្លើយសារភាពផ្សេងទៀត ក្រៅពីចម្លើយសារភាពរបស់ប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស ឬរបស់បុគ្គលិកមន្ទីរ ប-១ ដែលបានមកពីមន្ទីរ ស-២១។ ឧទាហរណ៍ នៅអង្គប្រជុំមួយនៃមន្ទីរ ប-១ ដែលមានការចូលរួមពី ស្ងួង ស៊ីគឿន ជាកម្មាភិបាលជាន់ខ្ពស់មន្ទីរ ប-១ អៀង សារី បានអានសេចក្តីដកស្រង់ចេញពីចម្លើយសារភាពរបស់ កុយ ធួន រដ្ឋមន្ត្រីពាណិជ្ជកម្ម និងចម្លើយសារភាពរបស់ **ពឹង គឹមសៀ**[4385] អតីតនាយកទស្សនាវដ្តីបក្សប្រជាធិបតេយ្យ ដែលចម្លើយសារភាពរបស់គាត់មានចារដាក់ថា គាត់បានស្លាប់ក្នុងពេលសួរចម្លើយ[4386]។ [លុប] ក៏បានរំឭកឲ្យដឹងថា នៅក្នុងអង្គប្រជុំមួយ អៀង សារី បាននិយាយអំពីការចាប់ខ្លួន កុយ ធួន[4387]។

១០៨០. អតីតមន្ត្រីការទូតមួយរូប ឈ្មោះ [លុប] ដែលជាមិត្តចាស់របស់ ប៉ុល ពត បានប្រកាសថា នៅក្នុងដំណើរទស្សនកិច្ចមួយនៅអង្គការសហប្រជាជាតិ គាត់បានដឹងថា **អៀង សារី** បានដឹងពីអ្វីដែលបានកើតឡើងទៅលើជនទាំងឡាយ ដែលបានបាត់ខ្លួនពីក្រសួង នៅពេលដែល **អៀង សារី** បាននិយាយថា "*កុំតែបង (ប៉ុល ពត) កុំអីមិត្តមឿនឯងទៅបាត់ហើយ*"[4388]។ [លុប] ជាបុគ្គលិកមួយរូបទៀតបាននិយាយថា នៅឯទីក្រុងប៉េកាំង អៀង សារី បានសួរគាត់ថា គាត់បានចូល សេ.អ៊ី.អា. ពីពេលណា។ ដោយសារគាត់បានឆ្លើយថា គាត់មិនស្គាល់ សេ.អ៊ី.អា **អៀង សារី** បានបង្គាប់ឲ្យ [លុប] [4389] ឲ្យប្រាប់ [លុប] សរសេរប្រវត្តិរូបផ្ទាល់ខ្លួន[4390]។ គាត ឈន់ [លុប] [4391] និង [លុប][4392] និងអ្នកឯទៀត ក៏ត្រូវគេប្រាប់ឲ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួនដែរ នៅពេលដែលពួកគេនៅមន្ទីរ ប-១[4393]។ ក្រោយពីសរសេរបញ្ចប់ប្រវត្តិរូបរួច[4394] [លុប]

ត្រូវបានលត់ដំ ដោយឱ្យធ្វើការកន្លែងដាំដំណាំរបស់ ប-១ និងចិញ្ចឹមសត្វទន្សាយ[4395]។

១០៨១.[លុប] រំឭកអំពីការចាប់ខ្លួនជាទ្រង់ទ្រាយធំមួយនាដើមឆ្នាំ១៩៧៧ ដូចជាការចាប់ខ្លួនប្រពន្ធរបស់ កុយ ធួន សៀន អាន [លុប] និងហ៊ូ នឹម ហើយនៅក្រោយមក អៀង សារី បានប្រកាសតាមរយៈសុន្ទរកថាមួយថា ជនក្បត់ទាំងអស់ត្រូវចាប់ខ្លួន[4396]។ នៅក្នុងកិច្ចសម្ភាសន៍មួយ អៀង សារី បានទទួលស្គាល់ថា បានដឹងឮពីការចាប់ខ្លួនរបស់ ហ៊ូ នឹម នាពេលនោះ ប៉ុន្តែ មិនបានដឹងឮពីអ្វីដែលបានកើតឡើងលើ ហ៊ូ នឹម ទេ[4397]។ នៅក្នុងបទសម្ភាសន៍មួយ ធ្វើឡើងក្នុងខែធ្នូ ឆ្នាំ១៩៩៦ គាត់បានទទួលស្គាល់ថា បានដឹងជាមុនថា ហ៊ូ នឹម នឹងត្រូវចាប់ខ្លួន[4398]។

១០៨២.ឌុច បានដឹងឮពីការចាប់ខ្លួនតែមួយករណីប៉ុណ្ណោះ[4399] គឺការចាប់ខ្លួនកម្មាភិបាលរបស់មន្ទីរ ប-១ ដែល **អៀង សារី** មិនបានដឹង។ គាត់និយាយថា នៅក្នុងខែសីហា ឆ្នាំ១៩៧៧ **សុន សេន** បានទូរស័ព្ទ និងផ្តល់ការទូន្មានដល់គាត់ពីការចាប់ខ្លួនសំខាន់មួយ ដែលជិតកើតមានទៅលើ ថៅ សេង ជាអតីតរដ្ឋមន្ត្រីទទួលបន្ទុកបេសសកម្មពិសេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាមិត្តជិតស្និទរបស់ **អៀង សារី**។ គាត់បានប្រាប់ ឌុច ឱ្យរក្សាទុកព័ត៌មាននេះជាសម្ងាត់ ហើយត្រូវកត់ត្រាជនជាប់ឃុំឃាំងនោះដោយដាក់ឈ្មោះថា ចិន សួន[4400]។ ក្រោយមក នួន ជា បានប្រាប់ ឌុច ថា ទោះបីជានរណាម្នាក់មកពីមន្ទីរ ប-១ សាកសួរព័ត៌មាន ត្រូវឆ្លើយថា "*ទុកឱ្យបងវ៉ាន់ ទៅសួរបងទីពីរទៅ*"។ ឌុច មានការជឿជាក់ថា នេះបានបង្ហាញពីជម្លោះរវាង ប៉ុល ពត និង **អៀង សារី** ហើយការដែល ប៉ុល ពត ត្រូវចាប់ខ្លួន ថៅ សេង គឺជាការប្រមាន[4401] ដោយសារតែ ប៉ុល ពត យល់ឃើញថា បញ្ញាជនទាំងនោះ គឺជាអ្នកយកការណ៍មានសក្តានុពល ហើយ **អៀង សារី** បានតម្លើងឋានៈ ថៅ សេង ពីបឹងត្របែកទៅមន្ទីរ ប-១[4402]។ [លុប] បញ្ជាក់ទ្រឹស្តីរបស់ ឌុច ដែលបានលើកឡើងថា គាត់បានសួរ **អៀង សារី** ម្តង ថាតើគាត់អាចរស់នៅតាមជនបទបានដែរឬទេ ដោយសារតែគាត់មានការនឿយណាយនឹង ការរិះគន់ដែលកើតមានឥតឈប់ឈរ។ **អៀង សារី** បានឆ្លើយតបថា "*មិត្តនឹងត្រូវគេជម្រះបញ្ជីចោលភ្លាម នៅពេលដែលមិត្តចាកចេញ*"។ ក្នុងឆ្នាំ២០០៧ **អៀង សារី** បានពន្យល់ថា ការលើកឡើងនេះ គឺចង់សំដៅដល់ ថៅ សេង ដែលបានចំណាយពេលទាំងនៅច្រាំងចំរេះ[4403] និងនៅបឹងត្របែក[4404] មុនពេលត្រូវបញ្ជូនទៅមន្ទីរ ស-២១[4405]។ [លុប] បានរំឭកថា ថៅ សេង បានត្រឡប់ មកពីជនបទ ហើយឆ្លងកាត់មន្ទីរ ប-១ អស់រយៈពេលពីរបីថ្ងៃមុនពេល "*ចាកចេញទៅ មិនដឹងថាទៅទីណាទេ*"[4406]។ **អៀង សារី** បញ្ជាក់ថា ថៅ សេង ត្រូវចាប់ខ្លួនដោយគាត់មិនបានដឹង។ គាត់និយាយថា "*ពួកគេ*" មិនបានគាំទ្រ

ក្រុមដែលគាត់បានបណ្តុះបណ្តាល និងមានចេតនាយកមកធ្វើការនៅមន្ទីរ ប-១[4407]។

១០៨៣.បន្ថែមពីលើការចាប់ខ្លួនរបស់ ចៅ សេង, [លុប] ជឿជាក់ថា ការចាប់ខ្លួនរបស់ តូច ខាំឿន អាចនឹងមិនកើតមានដោយមានការយល់ព្រមពី **អៀង សារី** ឡើយ ដោយសារតែពួកគេគឺជាមិត្តស្និទ្ធស្នាលនឹងគ្នា។ សួង ស៊ីគឿន និយាយថា វាបានកើតឡើងនៅពេល អៀង សារី ស្ថិតនៅក្រៅប្រទេស[4408] ហើយ **អៀង សារី** បានប្រាប់ [លុប] ថា តូច ខាំឿន ត្រូវចាប់ខ្លួននៅពេលដែលគាត់នៅប្រទេសម៉ាឡេស៊ី[4409]។

១០៨៤.មានភស្តុតាងបង្ហាញថា មានករណីមួយចំនួន **អៀង សារី** បានការពារមនុស្សមួយចំនួនពីការចាប់ខ្លួន។ ឌុច និយាយថា ក្នុងឆ្នាំ១៩៩០ គាត់បានដឹងថា **អៀង សារី** បានជួយសង្គ្រោះជីវិតកូនក្មេងចំនួនបីនាក់ ដែលឪពុកម្តាយរបស់ក្មេងៗទាំងនោះ ត្រូវបានចាប់ខ្លួននៅមន្ទីរ ប-១ ហើយត្រូវបញ្ជូនទៅមន្ទីរ ស-២១ ដូចជា **ណាត**, **ទាញ** និងតូច ខាំឿន[4410]។ [លុប] និយាយថា អៀង សារី មានអំណាចក្នុងការធានាជីវិត យ៉ាងហោចណាស់ អាចធានាជីវិតរបស់បុគ្គលិកជាសមាជិករបស់គាត់មួយចំនួន ដូចជា [លុប] ជាដើម[4411]។ [លុប] នៅនិយាយទៀតថា ទោះបីជា [លុប] និង [លុប] ត្រូវបានឆ្លើយដាក់ក្នុងចម្លើយសារភាពមន្ទីរ ស-២១ ជាច្រើនក៏ដោយ ក៏ពួកគេមិនត្រូវបានចាប់ខ្លួនដែរ ដោយសារ **អៀង សារី** បាននិយាយប្រាប់ ប៉ុល ពត ថា *"បើចាប់ [ពួកគេ] ត្រូវលុបចោលក្រសួងការបរទេសចោលតែម្តងទៅ"*[4412]។ **អៀង សារី** បានអះអាងចំណុចនេះនៅក្នុងកិច្ចសម្ភាសន៍មួយ ដោយគាត់និយាយថា គាត់បានប្រាប់ទៅគណៈសន្តិសុខ និងយោធាថា ប្រសិនបើពួកគេចាប់ខ្លួនបញ្ញាជន ដូចជា [លុប] នោះគាត់នឹងត្រូវ *"បិទទ្វារ"* ក្រសួងគាត់ ហើយគាត់បានគំរាមថានឹងលាលែង។ [លុប] និយាយថា ប៉ុល ពត បានប្រាប់ថា គ្មានការចាំបាច់អ្វី ដែល **អៀង សារី** ត្រូវលាលែងឡើយ ប៉ុន្តែ **អៀង សារី** ត្រូវធានាអះអាងចំពោះពួកអ្នកទាំងនោះ[4413]។ ម្យ៉ាងវិញទៀត [លុប] និយាយថា អៀង សារី បានប្រាប់គាត់ថា សន្តិសុខមានផែនការចាប់ខ្លួន [លុប] ប៉ុន្តែព្រឹត្តិការណ៍ខែមករា ឆ្នាំ១៩៧៩ បានចូលមកបង្អាក់ផែនការនេះ[4414]។ [លុប] ក៏មានការជឿជាក់ផងដែរថា អៀង សារី បានការពាររូបគាត់[4415]។ កម្មាភិបាលជាន់ខ្ពស់នៅមន្ទីរប-១, [លុប] បានប្រាប់ [លុប] ថា នៅក្នុងឆ្នាំ១៩៧៧ អៀង សារី បានកោះហៅចូលក្នុងអង្គប្រជុំមួយនៅមន្ទីរ ប-១ ហើយ *"ចេញបញ្ជាថា ពេល គាត់មិននៅ ទោះជា ប៉ុល ពត ឬអ្នកណាបញ្ជា ឱ្យយកបុគ្គលិករបស់គាត់ ក៏គាត់មិនឱ្យយកដែរ"*[4416]។ [លុប] លើក

ឡើងថា ទោះបីជាគាត់មិនបានដឹងអំពីព័ត៌មានលម្អិតនៃរឿងនេះ វាជាការពិតដែល អៀង សារី "*ការពារ*" បុគ្គលទាំងឡាយនោះអញ្ចឹងមែន[4417]។

១០៨៥. បន្ថែមលើនេះទៀត **អៀង សារី** ទំនងជាបានប៉ុនប៉ងជួយបុគ្គលិកនៅមន្ទីរ ប-១ ឲ្យជៀសផុតពីការសម្លាប់ តាមរយៈការណែនាំដល់ពួកគេពីអ្វីដែលត្រូវនិយាយប្រសិនជាត្រូវគេសួរចម្លើយ។ ឧទាហរណ៍ **ស៊ុន ទី** ហៅ ទាញ អតីតសមាជិកអគ្គសេនាធិការ បានព្យាយាមសរសេរសំបុត្រទៅឲ្យ ប៉ុល ពត ពីមន្ទីរ ស-២១ ដោយសុំឲ្យ ប៉ុល ពត ទុកជីវិតឲ្យខ្លួន។ បន្ទាប់មក **ស៊ុន ទី** បានបញ្ជូនកំណត់ហេតុមួយទៅឲ្យ ឌុច ដោយសរសេរថា៖ "*មតិនេះជាខ្លឹមសារដែលបងវ៉ាន់ បានអប់រំនៅមន្ទីរក្រសួងការបរទេស។ ស្នើសុំ កុំហែកវាចោល នេះជាសំឡេងចុងក្រោយបំផុតរបស់ខ្ញុំ "ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨*"[4418]។ ឧទាហរណ៍មួយទៀត ដែលអាចបង្ហាញពីការប្រឹងប្រែងរបស់ អៀង សារី ក្នុងការការពារជនណាម្នាក់នោះ គឺក្នុងករណីរបស់ **វ៉ាន់ ពីនី**។ ឌុច និយាយថា សុន សេន ធ្លាប់បានសួរគាត់ម្តងថា ហេតុអ្វីបានជាមិនបញ្ជូនចម្លើយសារភាពរបស់ **វ៉ាន់ ពីនី** ទៅមន្ទីរ ស-២១។ ឌុច ប្រហែលជាឆ្លើយថា វ៉ាន់ ពីនី មិនទាន់បានបញ្ជូនមកមន្ទីរ ស-២១ ទេ។ ប៉ុន្មានថ្ងៃក្រោយមក សុន សេន បានសួរសំណួរនេះទៅ ឌុច ម្តងទៀត ដោយបានបញ្ជាក់ថា **វ៉ាន់ ពីនី** ត្រូវចាប់ខ្លួនហើយ។ ដូច្នេះ ឌុច បានហៅអ្នកទោសទាំងអស់នៅមន្ទីរ ប-១ មកជុំគ្នា ដើម្បីស្វែងរក **វ៉ាន់ ពីនី** និងប្រពន្ធ ប៉ុន្តែមិនបានឃើញឡើយ។ បីថ្ងៃបន្ទាប់ពីការផ្ញើលទ្ធផលនៃការស្វែងរករបស់គាត់ទៅឲ្យ សុន សេន, **វ៉ាន់ ពីនី** បានទៅដល់មន្ទីរ ស-២១[4419]។ ហោ ណាំហុង នៅចាំថា **វ៉ាន់ ពីនី** បានចាកចេញពីបឹងត្របែក បន្ទាប់ពីគេប្រាប់ថា គាត់ត្រូវចាត់តាំងឲ្យទៅទីក្រុងញូវយ៉ក។ គាត់នៅចាំសម្តី វ៉ាន់ ពីនី ថា៖ "*ខ្ញុំបានបញ្ចប់ការងារដោយដៃរបស់ខ្ញុំហើយ។ ខ្ញុំអាចប្រើជំនាញការរបស់ខ្ញុំវិញម្តង*"[4420]។

១០៨៦. កិច្ចប្រជុំផ្ទៃក្នុង ត្រូវបានធ្វើជាទៀងទាត់នៅ ប១ រួមមានប្រជុំប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ កិច្ចប្រជុំ "កសាងគ្នា" ឬ"ជីវទស្សន៍" ជាប្រចាំខែ និង "ប្រជុំធ្វើប្រវត្តិរូប" ក្នុងរយៈពេលមួយខែ[4421]។ គោលបំណងមួយរបស់អង្គប្រជុំទាំងនេះគឺដើម្បីរកអ្នកក្បត់ក្នុង ប-១[4422]។ កំណត់ត្រានៃអង្គប្រជុំចូលរួមដោយ **អៀង សារី** ត្រូវបានកត់ត្រាក្នុងសៀវភៅ ប-១[4423]។ ទាក់ទិនជាមួយនឹងអង្គប្រជុំធ្វើប្រវត្តិរូប "មជ្ឈឹម" បានបញ្ជាថា អង្គប្រជុំប្រភេទនេះត្រូវធ្វើនៅក្នុងគ្រប់អង្គភាព ជាផ្នែកនៃ "ការសម្រិតសម្រាំង" សមាជិកបក្ស។[4424] អង្គប្រជុំប្រភេទនេះ របស់ ប១ ត្រូវបានដឹកនាំដោយ **អៀង សារី**[4425]។ [លុប] បញ្ជាក់ថា ធ្លាប់បានចូលរួមនៅក្នុងអង្គប្រជុំនានា ដែល **អៀង សារី** បាននិយាយអំពីបញ្ហាសន្តិសុខ ការការពារជាតិ ការសាងសង់ និងវិធីក្នុងការការពារកុំឲ្យមានខ្មាំង

00605615



ស៊ីរ៉ូងផ្ទៃក្នុង[4426]។ [លុប] និយាយថា យូរៗម្តង អង្គប្រជុំពិសេស ត្រូវបានរៀបចំឡើងដើម្បីពិភាក្សាអំពី "*...ខ្មាំង ដែលបំបែកបំបាក់ផ្ទៃក្នុង*"[4427]។ **អៀង សារី** មានវត្តមាន នៅបណ្តាអង្គប្រជុំទាំងនេះ[4428]។ [លុប] ចងចាំអំពីអង្គប្រជុំស្រដៀងគ្នានេះដែរ ដែលក្នុងនោះមានការនិយាយអំពីសកម្មភាពនានារបស់ខ្មាំង ភ្នាក់ងារគាំទ្រវៀតណាម និងភ្នាក់ងារទាំងឡាយ ដែលប្រឆាំងនឹងអំណាចរបស់ *អង្គការ* និងបដិវត្តន៍[4429]។ [លុប] រំឭកពីអង្គប្រជុំនានាដែល **អៀង សារី** បានលើកឡើងពីការចាប់មនុស្សនៅតាមបណ្តាមូលដ្ឋាន និងកំហុសដែលពួកគេទាំងនោះបានប្រព្រឹត្ត ហើយបាននិយាយបញ្ជិតបញ្ជៀងចំពោះកម្មាភិបាលមន្ទីរប-១[4430]។ [លុប] ដែលមានវត្តមាននៅក្នុងអង្គប្រជុំដែរនោះ មិនបានចងចាំអំពីបញ្ហានានា ដែលត្រូវបានគេលើកយកមកពិភាក្សានោះទេ ប៉ុន្តែគាត់បានទទួលស្គាល់ថា ការរៀបរាប់របស់ [លុប] គឺជាការពិត[4431]។ [លុប] និយាយថា **អៀង សារី** មិនដែលបានបើកអង្គប្រជុំ ដើម្បីនិយាយទៅកាន់បុគ្គលិក អំពីមូលហេតុផ្សេងៗនៃការបាត់ខ្លួននោះទេ[4432]។ [លុប] ដែលជាចុងភៅ និងអ្នកសម្អាតនៅមន្ទីរ ប-១ នោះ ក៏បានឮ **អៀង សារី** និយាយអំពីភាពស្មោះត្រង់ចំពោះបក្ស។ [លុប] ក៏រំឭកផងដែរថា នៅក្នុងអង្គប្រជុំទាំងនោះ បុគ្គលិកមួយចំនួនបានប្តេជ្ញាចិត្តនឹងខិតខំប្រឹងប្រែងធ្វើការ ហើយមិនក្បត់បក្ស[4433]។ [លុប] នៅចាំបានថា "*វត្តមានមន្ត្រីរដ្ឋការចំនួន១៥ នាក់*" ដែលបានចូលរួមក្នុងអង្គប្រជុំស្វ័យទិទៀនជាប្រចាំនោះ យូរៗម្តង មានការចូលរួមពីសំណាក់ អៀង សារី[4434]។ [លុប] បញ្ជាក់ថា បានចូលរួមក្នុងអង្គប្រជុំ ដែល អៀង សារី បានលើកឡើងថា ភូមិភាគបូព៌ាមិនល្អ[4435]។

**១០៨៧.** [លុប] រំឭកថា **អៀង សារី** បានធ្វើជាអធិបតីក្នុងអង្គប្រជុំពេញអង្គនានារបស់ក្រសួង និងរបស់បក្ស ដែលនៅក្នុងអង្គប្រជុំទាំងនោះ មានការអានសារាចរនានាដែលលើកឡើងពី "*ការពិត*" តាមការណែនាំរបស់បក្ស[4436]។ ឯកសារដែលមានចុះកាលបរិច្ឆេទ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧ មានចំណងជើងថា៖ "*ធ្វើការជាមួយនឹងគណៈកម្មាធិការគ្រប់អង្គភាព*" ហាក់បីដូចជាឧទាហរណ៍មួយនៃសារាចរដែលផ្សព្វផ្សាយនៅមន្ទីរ ប-១[4437]។ ក្នុងឯកសារនោះមានការលើកឡើងពីក្រសួងមួយដែលមិនមានបញ្ជាក់ឈ្មោះ ថាក្រសួងនេះបាន "*ទាក់ទងនឹងទូតបរទេសច្រើនណាស់*"[4438] ហើយវារួមមាន "*ផ្នែកនយោបាយ ពិធីការ និងលេខាធិការដ្ឋាន*"[4439] ដែលមានប្រមាណ "*ជា១០ ភាគរយ...ជាអនុជន បញ្ញាជន*"[4440] ហើយ "*រ៉ាប់រងទទួលភ្ញៀវបាន គេមកប៉ុន្មាន ក៏យើងរ៉ាប់រងបាន*"[4441]។ ឯកសារនោះក៏បានផ្តល់ជាឧទាហរណ៍ ពី "*ភារកិច្ចស្ទូល*" របស់មន្ទីរប-១ និងផ្ទះលេខ២ ផងដែរ[4442]។ សារាចរនៃមន្ទីរ ប-១ នេះ ផ្តើមដោយឃ្លាថា "*ក្នុងសន្និបាតក្រសួងយើង យើងបានកត់សម្គាល់ថា យើងបានកម្ទេច នឹង បោសសម្អាតជាមូលដ្ឋានខ្មាំងជា សេអ៊ីអា កាហ្សេបេ*

00605616



*និងយួនលេបទឹកដី។ យើងបានឯកភាពគ្នាលើបញ្ហាបោសសម្អាតខ្មាំងនេះ ទន្ទឹមនេះ យើងក៏បានឯកភាពគ្នាថា ខ្មាំងមិនទាន់ អស់នៅឡើយទេ ក្នុងក្រសួងយើង ក៏ដូចក្នុងអង្គភាពនីមួយៗ ដូច្នេះ យើងត្រូវបន្តបោសសម្អាតឱ្យស្អាត ជ្រះស្រឡះ ក្នុងក្រសួង ក៏ដូចក្នុងអង្គភាពនីមួយៗ"*។ បន្ទាប់មក នៅក្នុងសារាចរដដែលនោះ មានសរសេរថា *"បើយើងមើលក្នុងក្រសួងទាំងមូល យើងឃើញថា ៩៨ភាគរយក្នុងក្រសួងទាំងមូល បានស្អាត ហើយ គឺ ៩៨ភាគរយល្អ យល់ពីបញ្ហាបោសសម្អាតខ្មាំង...ប៉ុន្តែនៅ ២ភាគរយទៀត កំពុងធ្វើសកម្ម ភាព... យើងត្រូវពុះពារ ធ្វើយ៉ាងណាកុំឱ្យ ២ភាគរយនេះ វាពង វាពង្រីកបាន...យើងត្រូវហ៊ុំព័ទ្ធវា បង្រួញក្តោបវាឱ្យមកនៅ ១.៥០ ឬ ១ ឬកន្លះភាគរយ"*[4443]។ នៅក្នុងទស្សនៈរបស់ [លុប] ការលើកឡើងអំពីការកម្ទេចខ្មាំង គឺសំដៅដល់ *"ស្ថានភាពរួមរបស់ប្រទេស និងមិនមែនតែពីស្ថានភាពរបស់មន្ទីរប-១ នោះទេ"*[4444]។

១០៨៨. សៀវភៅទិនានុលេខ ដែលមានកំណត់ត្រាទាក់ទងនឹងមន្ទីរ ប-១ បានបង្ហាញថា ការប្រជុំនៅក្រសួង ប-១ នៅថ្ងៃទី១០ ខែកក្កដាឆ្នាំ ១៩៧៦ ដែលបញ្ជាក់ច្បាស់ពីការចូលរួមរបស់ អៀង សារី បានលើកយកស្ថានការណ៍ការពារជាតិមកពិភាក្សា។ អ្នកធ្វើកំណត់ហេតុបានកត់ត្រាពីវិធីដែលខ្មាំងបានវាយប្រហារទៅលើ ប.ក.ក ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក៖ *"ពិនិត្យឃើញខ្សែតាំងពីសង្គ្រាមមក ដូច្នេះការលំបាកស្មុគស្មាញធំដុំដែរ។ តាមដានរឿងនេះរយៈ៣ខែ ទើបឃើញ។ ដូច្នេះ ត្រូវតាមដាន គ្រប់ក្រសួង ទាំងនារី-បុរស ឱ្យជិតស្និទបំផុត"*។ អ្នកកត់កំណត់ហេតុ បានបន្តកត់ត្រាទៀត នៅក្រោមចំណងជើង *"ការស៊ើបអង្កេតផ្ទៃក្នុង"* ថា *"នៅក្នុងប្រទេសយើង ក្បត់ស៊ើរ៉ូង ពី១% ដល់៥% ។ យើងត្រូវតាមដានប្រវត្តិរូបច្បាស់លាស់ ជីវទស្សនៈច្បាស់លាស់ ពិសេសក្នុងក្រសួងការបរទេស"*[4445]។ [លុប] យល់ឃើញថា ការពិភាក្សាបែបនេះ *"ដូចជាមិនមានទេ"*[4446] ហើយ [លុប] និយាយថា កំណត់ហេតុមួយចំនួន ហាក់បីដូចជាត្រូវបានកត់ត្រាពីអង្គប្រជុំសាខា *"មន្ទីរ"* ប-១[4447]។

១០៨៩. **អៀង សារី** និយាយថា អស់រយៈពេលបីឆ្នាំ ដែល ប.ក.ក បានកាន់អំណាច គាត់មានការភ័យខ្លាចពីជីវិតរបស់គាត់ និងមានការងឿងឆ្ងល់ ថាតើគេអាចយកគាត់ទៅមន្ទីរស-២១ ដែរឬយ៉ាងណា[4448]។ នៅឆ្នាំ១៩៧៨ [លុប] បាននិយាយថា បរិយាកាសនៅក្នុងមន្ទីរ ប-១ បានបាត់បង់ភាពស្ងាត់ស្ងៀមរបស់ខ្លួន និងស្ថិតនៅក្រោមភាពតានតឹងគ្របដណ្តប់ដោយសារការចាប់ខ្លួន និងការបាត់ខ្លួននានា។ គាត់បាននិយាយថា **អៀង សារី** ហាក់បីដូចជាទទួលរង *"នូវការឈឺចាប់ខាងផ្លូវចិត្តដែលពិបាកពណ៌នា"* ដែលមនុស្សគ្រប់ៗរូបមានការភ័យខ្លាច[4449]។ [លុប]

[លុប] ដែលជាអតីតភរិយារបស់គាត់ មានទស្សនៈផ្សេងពីនេះ ហើយនិយាយថា អៀង សារី មានភាពឈ្លាសវៃ ក្នុងការបង្កើតបរិយាកាសភ័យខ្លាចមួយ ដែលមានលក្ខណៈពិសេស បើប្រៀបធៀបទៅនឹងលក្ខណៈដូចគ្នានេះនៅបណ្តាក្រសួងនានា និងទីជនបទ[4450]។

<u>ប្រជាជនកម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍</u>

១០៩០. នៅដើមទសវត្សរ៍៧០ និងក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការហៅប្រជាជនកម្ពុជាដែលនៅឯបរទេស ឱ្យវិលត្រឡប់មកកម្ពុជាវិញ។ អ្នកដែលត្រឡប់មកពីបរទេសមួយចំនួនតូច ត្រូវបានបញ្ជូនផ្ទាល់ទៅតាមបណ្តាក្រសួង រួមទាំងមន្ទីរ ប-១ នៅពេលដែលពួកគេត្រឡប់មកពីបរទេសវិញ។ ប៉ុន្តែមានករណីជាច្រើន ដែលអ្នកត្រឡប់មកពីបរទេសវិញ ត្រូវបញ្ជូនទៅលត់ដំ ជាបឋមគឺនៅតាមបណ្តាទីកន្លែងនានាទូទាំងប្រទេសកម្ពុជា និងនៅភ្នំពេញ និងបន្ទាប់មកទៅទីតាំងចំនួនពីរកន្លែងគឺ ច្រាំងចំរេះ និងបឹងត្របែក។ ពេលខ្លះជនទាំងឡាយដែលត្រូវបញ្ជូនទៅលត់ដំត្រូវស្នាក់នៅទីនោះរហូតដល់របបនោះបានបញ្ចប់ នៅពេលដែលជនដទៃទៀត ត្រូវគេដាក់នៅក្នុងក្រសួងនានា ក្រោយពីតាមដានបានមួយរយៈ។ អ្នកដែលត្រឡប់មកពីបរទេសវិញជាច្រើន បានអស់ជីវិតនៅមន្ទីរ ស-២១។ គិតត្រឹមឆ្នាំ១៩៧៧ យ៉ាង ហោចណាស់ មានមន្ត្រីការទូតមួយរូប ប្រហែលជាត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ ប៉ុន្មានថ្ងៃក្រោយពីគាត់ត្រឡប់មកដល់ប្រទេសកម្ពុជា។ នៅក្នុងកិច្ចសម្ភាសន៍ក្នុងខែកក្កដា ឆ្នាំ១៩៩៦ **អៀង សារី** បាននិយាយថា៖ *ខ្ញុំមានការសោកស្តាយពន់ពេកក្រៃ ចំពោះការស្លាប់ពួកបញ្ញវន្ត ពីព្រោះខ្ញុំគឺជាមនុស្សម្នាក់ ដែលបានប្រមូលពួកគេឱ្យមកជួយកសាងប្រទេស"*[4451]។

១០៩១. ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីការទម្លាក់សម្តេចសីហនុពីប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា ប្រជាជនកម្ពុជាជាច្រើនបានចូលរួមជាមួយសម្តេចក្នុងពេលដែលទ្រង់គង់និរទេសនៅទីក្រុងប៉េកាំង។ សម្តេច សីហនុ បានអំពាវនាវទៅកាន់ប្រជាជនកម្ពុជាឱ្យចូលរួមជាមួយទ្រង់ដើម្បីបង្កើតជារណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីទប់ទល់នឹងរដ្ឋាភិបាលថ្មីនៅទីក្រុងភ្នំពេញ ដែលក្រោយមកបានក្លាយទៅជាសាធារណរដ្ឋខ្មែរ ដែលមាន លន់ នល់ ជាប្រធានាធិបតី។ ប.ក.ក ដែលនៅតែលាក់កំបាំងនៅឡើយ បានចូលរួម និងបង្កប់នៅក្នុង FUNK និង GRUNK[4452]។ [លុប] និយាយថា នៅឆ្នាំ១៩៧១ **អៀង សារី** បានប្រើប្រាស់មនោសញ្ចេតនាស្នេហាជាតិក្នុងការបំពាក់បំប៉នប្រជាជនកម្ពុជា ដែលបាន

ចូលរួមជាមួយ FUNK ហើយបានរៀបចំឱ្យពួកគេធ្វើដំណើរទៅទីក្រុងប៉េកាំង ដែលភាគច្រើនជនទាំងនោះគឺជាបញ្ញាជនដែលមកពីទីក្រុងប៉ារីស។ បន្ទាប់មក **អៀង សារី** បានរកអ្នកស្ម័គ្រចិត្តជាច្រើនចេញពីក្រុមនេះដើម្បីចូលរួម *"វណ្ណៈសិរ្យ"* នៅប្រទេសកម្ពុជា[4453]។ ដូច្នេះហើយ ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៧០មក[4454] ប្រជាជនកម្ពុជាដែលនៅបរទេស បានចាប់ផ្តើមវិលត្រឡប់ មកប្រទេសកម្ពុជាវិញ តាមទីក្រុងប៉េកាំង[4455]។

**១០៩២.** ប.ក.ក បានបន្តគោលនយោបាយ *"អប់រំកែប្រែ"* ចំពោះអ្នកវិលត្រឡប់ពីបរទេស ទាំងមុន និងទាំងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ឯកសារផ្លូវការចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ បានកត់ត្រាថា៖ *"វណ្ណសិរ្សខាងក្រៅត្រូវចូលមកនៅក្នុងប្រទេស។ ពោលគឺយើងបានបញ្ចប់អង្គការដឹកនាំក្រៅប្រទេសនេះហើយ...នៅក្នុងប្រទេស យើងក្តាប់នៅក្នុងដៃបានទាំងអស់ទៀត"*។[4456] ឯកសារនេះបានបញ្ជាក់ថា ប.ក.ក បានស្វាគមន៍ការវិលត្រឡប់មកកម្ពុជាវិញរបស់គ្រប់មនុស្សទាំងអស់ ទោះបីជាពួកគេស្ថិតក្នុងក្រុមណាក៏ដោយ ព្រោះវាមានលក្ខណៈប្រសើរជាង ប្រសិនបើបញ្ញាជនទាំងនោះដែលរស់នៅក្នុងប្រទេសអឺរ៉ុបខាងលិច និងអាមេរិកវិលត្រឡប់មកវិញ ជាជាងការដែលពួកគេអាចធ្វើឱ្យបក្សចុះទន់ខ្សោយផ្នែកនយោបាយ ដោយពួកគេរស់នៅឯបរទេស។ ឯកសារនោះបានឱ្យដឹងផងដែរពីគោលនយោបាយដែលអនុវត្តកាលពីពេលមុន និងបានសរសេរថា នៅពេលដែលបញ្ញាជនទាំងនេះវិលត្រឡប់មកវិញ៖ *"គឺឱ្យធ្វើពលកម្ម ដូចអ្នកមកឆ្នាំ១៩៧២ ១៩៧៣ ១៩៧៤ ក៏ធ្វើពលកម្ម។ បើមកឥឡូវរិតតែធ្វើពលកម្មទៀត។ កម្លាំងនេះ ជាបន្ទាប់បន្សំទេ។ តែក៏ ត្រូវហ្វឹកហ្វឺន កសាងគេក្នុងសង្គមថ្មី ចលនាថ្មី"*[4457]។ នៅក្នុងខែដដែលនេះ នៅក្នុងបេសសកម្មមួយទៅអង្គការសហប្រជាជាតិ គណៈប្រតិភូកម្ពុជា រួមទាំង **អៀង សារី** បានធ្វើដំណើរឆ្លងកាត់ទីក្រុងប៉ារីស ហើយបានរៀបចំអង្គប្រជុំមួយ ដើម្បីហៅបញ្ញាជនទាំងអស់ឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ[4458]។ នៅពេលស្ថិតនៅឯបរទេស អៀង សារី បានប្រាប់ទៅប្រជាជនកម្ពុជាអំពីជីវភាពល្អនៅក្នុងប្រទេសកម្ពុជាក្រោមការដឹកនាំរបស់ ប.ក.ក ហើយបានជំរុញពួកគេឱ្យវិលត្រឡប់[4459]។ [លុប] ប៉ាន់ស្មានថា មានអ្នកស្ម័គ្រចិត្ត និងអ្នកដែលបានជឿតាម យ៉ាងហោចណាស់ ប្រមាណជា ១០០នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ[4460]។ អ្នកឯទៀតបានត្រឡប់មកវិញដោយសារបានទទួលបញ្ជាឱ្យវិលត្រឡប់[4461]។ អ្នកខ្លះទៀតនៅមានការសង្ស័យថា តើជីវភាពនៅក្រោមរបប ប.ក.ក មានស្ថានភាពល្អពិតមែនឬយ៉ាងណា ប៉ុន្តែនៅតែវិលត្រឡប់មកវិញដដែល[4462]។ ជនទាំងឡាយដែលបានវិលត្រឡប់ ត្រូវបានទទួលនៅឯព្រលានយន្តហោះដោយអ្នកទទួលខុសត្រូវមន្ទីរប-១ រួមមាន **អៀង សារី**[4463] និង [លុប][4464]។ លិខិតឆ្លងដែនរបស់ពួកគេត្រូវបានដកហូតនៅឯទីក្រុង

ប៉េកាំង ឬនៅពេលដែលពួកគេធ្វើដំណើរមកដល់ប្រទេសកម្ពុជា[4465]។

១០៩៣.ចាប់ពីឆ្នាំ១៩៧៦ ការហៅឲ្យមន្ត្រីការទូតមួយចំនួនឲ្យត្រឡប់មកវិញ និងការរៀនសូត្ររបស់ពួកគេជាបន្តបន្ទាប់ ទំនងជាត្រូវបានដាក់ឲ្យស្ថិតនៅក្រោមសមត្ថកិច្ចមួយផ្នែករបស់ **អៀង សារី** និងមន្ទីរប-១។ នៅក្នុងកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍មួយ ដែលបានប្រព្រឹត្តនៅថ្ងៃទី១៩-២០-២១ ខែមេសា ឆ្នាំ១៩៧៦ មានការកត់ត្រាថា ក្រសួងការបរទេស គឺជាអ្នករៀបចំបញ្ជីរាយនាមមន្ត្រីការទូតនៅបរទេស ដែលត្រូវហៅឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ។ មានការកត់សម្គាល់ថា មន្ត្រីការទូតទាំងនេះនឹងត្រូវយកទៅលត់ដំ ហើយហាមមិនឲ្យចាកចេញពីប្រទេសកម្ពុជា[4466]។ នៅក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍មួយទៀត ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ **អៀង សារី** បានរាយការណ៍ថា *"យើងមានតែប៉េកាំង, កូរ៉េ, វៀត ណាម និងឡាវ។ ឯទូតចាស់ គ្រួសារអីមកអស់ហើយ នៅតែម្នាក់ៗចាំស្ថានទូត ដូចនៅអាល់បានី, យូហ្គោស្លាវី និងរូម៉ានី"*[4467]។ គាត់រាយការណ៍ផងដែរថា *"សំខាន់គឺស្មោះត្រង់។ ឯពួកទូតចាស់ត្រូវប្រយ័ត្ន។ យើងកុំអាលប្រើ។ បើទៅ ដូចជា* [លុប] *ជាជំនួយយើងម្តងៗដូច្នេះបាន តែឲ្យនៅជាប្រចាំមិនបានទេ។"*។[4468]

១០៩៤. [លុប] ដែលជាឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសគុយបានាពេលនោះ បានពន្យល់នៅដើមឆ្នាំ១៩៧៦ ថា បានទទួលទូរលេខមួយពី **អៀង សារី** ហៅឲ្យឯកអគ្គរដ្ឋទូតទាំងអស់របស់ប្រទេសកម្ពុជា វិលត្រឡប់មកវិញជាបន្ទាន់ ដើម្បីចូលរួមវគ្គសិក្សាដែលមានរយៈពេល១០ថ្ងៃ។ [លុប] [លុប] បាននិយាយថា គាត់ រួមជាមួយមនុស្ស១៣នាក់ផ្សេងទៀតនៅក្នុងវគ្គសិក្សានោះ ត្រូវបង្រៀនដោយកម្មាភិបាលជាន់ខ្ពស់នៅមន្ទីរ ប-១ [លុប]។ ក្រោយពីវគ្គសិក្សាត្រូវបានបញ្ចប់ ជនទាំងឡាយដែលបានចូលរួម ត្រូវបានបញ្ជូនទៅកាន់ការដ្ឋានស្ទើរតែនៅទូទាំងប្រទេសកម្ពុជា។ [លុប] ក៏នៅចាំផងដែរថា ក្រោយពីការវិលត្រឡប់របស់គាត់មកប្រទេសកម្ពុជា **អៀង សារី** បានទាក់ទងជាមួយប្រពន្ធរបស់គាត់ ឲ្យប្រពន្ធ ព្រមទាំងកូនៗរបស់គាត់វិលត្រឡប់ ហើយពួកគេក៏យល់ព្រមវិលត្រឡប់តាមការស្នើសុំរបស់គាត់[4469]។ មនុស្សផ្សេងៗទៀតដែលបានមកដល់កម្ពុជា ក្នុងខែធ្នូ ឆ្នាំ១៩៧៥ អាចទទួលការបណ្តុះបណ្តាលនយោបាយពី **អៀង សារី**[4470]។ [លុប] ដែលត្រូវជាប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ LEFEUVRE Martine[4471] គឺជាមន្ត្រីទូតប្រចាំនៅប្រទេសសេណេហ្កាល់ គាត់បានទទួលសំបុត្រមួយច្បាប់ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ពី **ពេជ ជាង** នៅស្ថានទូតកម្ពុជាប្រចាំនៅប្រទេសចិន

00605620



ស្នើសុំឱ្យគាត់វិលត្រឡប់ទៅប្រទេសកម្ពុជាវិញដើម្បីរៀនសូត្រ[4472]។ ពេជ ជាង បានជួបជនទាំងឡាយដែលបានឆ្លងកាត់តាមទីក្រុងប៉េកាំង នៅពេលដែលពួកគេធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ[4473]។ នៅក្នុងប្រៃសណីយ៍បត្រមួយដែលផ្ញើមកពីទីក្រុងប៉េកាំង ចុះនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៧[4474] [លុប] បានសរសេរប្រាប់ប្រពន្ធរបស់គាត់ថា គាត់នឹងវិលត្រឡប់ទៅប្រទេសកម្ពុជាវិញនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៧។ សំណុំឯកសារបានបង្ហាញថា គាត់បានចូលទៅមន្ទីរ ស-២១ បួនថ្ងៃក្រោយ គឺនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ហើយត្រូវបានសម្លាប់នៅខែធ្នូក្នុងឆ្នាំដដែល[4475]។

**១០៩៥.** ជនទាំងឡាយដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញមានជោគវាសនាខុសៗគ្នា អាស្រ័យលើប្រវត្តិរបស់បុគ្គលនោះ អាស្រ័យលើពេលវេលាដែលពួកគេបានវិលត្រឡប់មកវិញ និងអាស្រ័យលើការវិនិច្ឆ័យដែលធ្វើឡើងបន្ទាប់ពីការសាកល្បង ថាតើពួកគេត្រូវបានចាត់ទុកថាស្មោះត្រង់គ្រប់គ្រាន់សម្រាប់បដិវត្តន៍ ហើយឬនៅ។ អ្នកដែលវិលត្រឡប់មកវិញមួយចំនួន ដែលបានធ្វើការជាមួយ **អៀង សារី** នៅទីក្រុងប៉េកាំង រួមទាំងសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [លុប][4476] [លុប][4477] និង [លុប][4478] ត្រូវបានចាត់តាំងផ្ទាល់ទៅមន្ទីរ ប-១ នៅពេលដែលពួកគាត់ធ្វើដំណើរមកដល់[4479]។ នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ជនឯទៀត រួមមាន សាក្សី [លុប] [លុប][4480] [លុប][4481] [លុប][4482] [លុប][4483] និង [លុប][4484] ត្រូវបានបញ្ជូនទៅកាន់ការដ្ឋាន និងសហករណ៍ផ្សេងៗ នៅក្នុងទីក្រុងភ្នំពេញ និងប្រទេសកម្ពុជា។ ពេលខ្លះ អ្នកដែលវិលត្រឡប់មកពីបរទេសដូចជា [លុប] ត្រូវបានបញ្ជូនទៅមន្ទីរ ប-១ ក្រោយពីរៀនសូត្របានមួយរយៈមក[4485]។

**១០៩៦.** មានពេលខ្លះ ក្នុងឆ្នាំ១៩៧៦ អាចក្នុងខែកក្កដា[4486] មានការសម្រេចចិត្តឱ្យហៅ យ៉ាងហោចណាស់ អតីតមន្ត្រី GRUNK មកពីសហករណ៍ និងការដ្ឋាននានានៅក្នុងប្រទេស ហើយប្រមូលផ្តុំពួកគេនៅឯច្រាំងចំរេះ នាទីក្រុងភ្នំពេញ[4487]។ ឆ្នាំបន្ទាប់មក នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ អ្នកវិលត្រឡប់មកពីបរទេសវិញទាំងនោះ ត្រូវបានកោះហៅឱ្យមកចូលរួមអង្គប្រជុំមួយនៅមន្ទីរប-១ ដែលនៅក្នុងអង្គប្រជុំនោះ **អៀង សារី** បានចេញបញ្ជាឱ្យពួកគេវិលត្រឡប់ទៅច្រាំងចំរេះ ហើយរៀបចំខ្លួនដើម្បីចាកចេញ។ នៅពេលធ្វើដំណើរដល់ច្រាំងចំរេះ ឡានជាច្រើនបានត្រៀមរួចជាស្រេចដើម្បីដឹកពួកគេទាំងនោះជាមួយនឹងឥវ៉ាន់ដែលជាប់មកជាមួយទៅបឹងត្របែក[4488]។ ប្រជាជនកម្ពុជាផ្សេងៗទៀតដែលវិលត្រឡប់ពីបរទេស ដែលត្រូវបានដាក់នៅតាមទីតាំងផ្សេងៗគ្នាក្នុងទីក្រុងភ្នំពេញ ដូចជា មន្ទីរ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ក-១៥ ក៏ត្រូវបញ្ជូនទៅបឹងត្របែកនៅក្នុងពេលជាមួយគ្នានោះដែរ[4489]។ វាប្រហែលជាថា មនុស្សមួយចំនួនដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយពីរយៈពេលនោះ ត្រូវបានបញ្ជូនផ្ទាល់ទៅបឹងត្របែក[4490]។ នៅក្នុងកិច្ចសម្ភាសន៍មួយ **អៀង សារី** បានលើកឡើងថា ការប្រមូលផ្តុំអ្នកវិលត្រឡប់ពីបរទេស អាចជាផែនការដែលបានគិតទុកជាមុនរបស់មជ្ឈិម ដើម្បីអាចត្រួតពិនិត្យពួកគេឱ្យបានកាន់តែជិតដល់ និងដើម្បីធ្វើឱ្យឥទ្ធិពលរបស់ពួកគេចុះទន់ខ្សោយ[4491]។

**<u>ច្រាំងចំរេះ</u>**

**១០៩៧.** ច្រាំងចំរេះ មានឈ្មោះសម្គាល់ថា ម-១ ឬ មន្ទីរ ម-១ (ក្រោយមកប្តូរទៅជាមន្ទីរ ប-៦០)[4492] គឺជាកសិដ្ឋាន ចិញ្ចឹមសត្វ និងមន្ទីរបង្កបង្កើនស្បៀង ដែលមានទីតាំងនៅច្រាំងចំរេះ ស្ថិតនៅតាមផ្លូវជាតិលេខ៥ក្នុងចម្ងាយជិត១០គីឡូម៉ែតពីទីក្រុងភ្នំពេញ[4493]។ ជនទាំងឡាយដែលស្នាក់នៅទីនោះត្រូវមើល ការចិញ្ចឹមសត្វ នេសាទ និងដាំដុះបន្លែបង្ការ[4494]។ សេរីភាពធ្វើដំណើរទៅមករបស់ពួកគេត្រូវបានកម្រិត[4495]។ ពីដើមឡើយមន្ទីរ ម-១ ត្រូវស្ថិតក្រោមការត្រួតត្រារបស់ក្រសួងពាណិជ្ជកម្ម[4496]។ ប៉ុន្តែមួយរយៈពេលក្រោយពីការឃុំខ្លួន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **កុយ ធួន** នៅក្នុងផ្ទះ មន្ទីរ ប-១ បានចាប់ផ្តើមគ្រប់គ្រងមន្ទីរម-១[4497]។ មន្ទីរប-១ បានទទួលបន្តតែផ្នែកខ្លះនៃទីតាំងនោះប៉ុណ្ណោះ រីឯផ្នែកដែលនៅសល់ត្រូវបានចាត់តាំងទៅតាមតំបន់ និងស្រុកផ្សេងៗដូចជា ស្រុកឧត្តុង្គជាដើម[4498]។ កាលបរិច្ឆេទពិតប្រាកដ ដែលមន្ទីរ ម-១ ត្រូវបានដាក់ក្រោមសមត្ថកិច្ចនៃមន្ទីរ ប-១ គឺមិនច្បាស់លាស់ទេ។ ប៉ុន្តែនៅក្នុងសៀវភៅទិនានុលេខដែលមានកំណត់ត្រាផ្សេងៗអំពីមន្ទីរប-១ មានកំណត់ហេតុនៃកិច្ចប្រជុំមួយ ក្រោមចំណងជើងថា៖ "*ទិសតម្រង់ការងារក្រសួងការបរទេសរយៈ៧.៧៦ ដល់៧.៧៧*" ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦ ដែលបានបង្ហាញថា មន្ទីរ ម-១ បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរប-១ នៅពេលនោះ[4499]។ ដោយសារ **កុយ ធួន** ត្រូវបានដាក់ឱ្យស្ថិតក្រោមការឃុំខ្លួនក្នុងផ្ទះនៅមន្ទីរ ក-១ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦[4500]នោះ សមត្ថកិច្ចគ្រប់គ្រងមន្ទីរ ម-១ អាចត្រូវបានផ្ទេរ មុនកាលបរិច្ឆេទនេះ។ [លុប] និយាយថា នៅពេលដែលមន្ទីរ ម-១ ត្រូវបានផ្ទេរទៅមន្ទីរ ប-១ នោះ មានអង្គប្រជុំមួយដែលនៅក្នុងអង្គប្រជុំនោះ **អៀង សារី** បានប្រគល់ការទទួលខុសត្រូវដល់គាត់ និងឱ្យគាត់រាយការណ៍ផ្ទាល់ទៅ **អៀង សារី**[4501]។ [លុប] មិនចាំឱ្យបានច្បាស់លាស់ទេអំពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរនោះ ដោយគ្រាន់តែធ្វើការ ប៉ាន់ស្មានថា "*ប្រហែលជា*" ក្នុង "*ចុងឆ្នាំ១៩៧៦*"[4502]។ **អៀង សារី** បានចុះមកត្រួតពិនិត្យមើលច្រាំងចំរេះម្តងម្កាល[4503]។

១០៩៨. ចំនួនប្រជាជននៅច្រាំងចំរេះ មានរវាងពី៥០ ទៅ២០០នាក់ មានទាំងបុរស និងស្ត្រី ព្រមទាំងកុមារ ដែលមកពីកន្លែងផ្សេងៗគ្នា[4504]។ នៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ បញ្ញាជន មន្ត្រីការទូត និងអតីតសមាជិក GRUNK ជាច្រើន ត្រូវបានគេប្រមូលផ្តុំជាមួយគ្នានៅទីតាំងនោះ[4505]។ [លុប] បានរំឭកថា គាត់ត្រូវបានបញ្ជូនពីភូមិភាគបូព៌ាទៅច្រាំងចំរេះក្នុងខែកក្កដា ឆ្នាំ១៩៧៦[4506]។ អ្នកឯទៀតដែលវិលត្រឡប់មកពីបរទេស ដែលស្នាក់នៅទីនោះជាមួយគាត់ មានអ្នកអង្គម្ចាស់ [លុប] និងអ្នកម្នាង , អ្នកអង្គម្ចាស់ [លុប] និងអ្នកម្នាង, [លុប] និង ប្រពន្ធ, [លុប] និងប្រពន្ធ, [លុប] និងប្រពន្ធ [លុប] , [លុប] កូនទាំងប្រាំ និងប្រពន្ធរបស់គាត់, [លុប] កូនទាំងបី និងប្រពន្ធរបស់គាត់, [លុប] និងប្រពន្ធរបស់គាត់, [លុប] [លុប] កូនទាំងពីរ និងប្រពន្ធរបស់គាត់, [លុប] កូនទាំងបី និងប្រពន្ធរបស់គាត់, [លុប] កូនទាំងពីរ និងប្រពន្ធរបស់គាត់, [លុប] និងប្រពន្ធ, [លុប], [លុប] កូនទាំងពីរ និងប្រពន្ធរបស់គាត់, [លុប] កូនទាំងពីរ និងប្រពន្ធរបស់គាត់ និង [លុប] និងកូនរបស់គាត់ម្នាក់[4507]។

១០៩៩. សាក្សី [លុប] ដែលមានឪពុកជាអតីតអ្នកការទូតរបស់រដ្ឋាភិបាល GRUNK ហើយដែលត្រូវបានគេបញ្ជូនទៅមន្ទីរ ប-១ នោះ ត្រូវបានគេផ្លាស់ចេញពីមន្ទីរប-១ ទៅមន្ទីរច្រាំងចំរេះ[4508] នៅពាក់កណ្តាលឆ្នាំ ១៩៧៦[4509] ហើយគាត់បានឃើញ [លុប][4510] [លុប][4511] [លុប][4512] ព្រះអង្គម្ចាស់ [លុប][4513] ព្រះអង្គម្ចាស់ [លុប][4514] [លុប][4515] [លុប][4516] [លុប][4517] និង [លុប][4518] នៅពេលដែលគាត់បាននៅទីនោះ។ [លុប] បានឃើញមនុស្សទាំងអស់នេះ ត្រូវគេយកទៅទាំងក្រុម នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧[4519] ដូចអ្វីដែលបានរៀបរាប់ដោយលោក [លុប][4520] និង [លុប] ដែលបញ្ជាក់ថា ពួកគាត់ត្រូវបានបញ្ជូនទៅមន្ទីរបឹងត្របែក[4521]។ ក្រោយមកអ្នកដែលបានចេញទៅទីនោះ ត្រូវបានជំនួសដោយអ្នកមកថ្មីពីមន្ទីរ ប-១ ដែលភាគច្រើនជាស្ត្រីដែលប្តីរបស់គេត្រូវបានចាប់ខ្លួន ឬជាមនុស្សដែលត្រូវបានចោទថា "ជាសមាសភាពមិនល្អ"[4522]។ [លុប] បដិសេធថា មិនមានបញ្ញាជនណាត្រូវបានចាប់បញ្ជូនទៅច្រាំងចំរេះទេ។ គាត់ក៏បាននិយាយដែរថា គាត់មិនដឹងថាមានឯកអគ្គរដ្ឋទូតបានរស់នៅទីនោះឡើយ[4523]។

១១០០. ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មនុស្សជាច្រើននាក់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ត្រូវបានចាប់ខ្លួននៅច្រាំងចំរេះ និងបញ្ជូនទៅមន្ទីរ ស-២១ ដូចដែលបានបង្ហាញក្នុងផ្នែកនិយាយពីអង្គហេតុពាក់ពន្ធ័ជាមួយនឹងមន្ទីរ ស-២១។ អ្នកទាំងនោះរួមមាន ហួត សម្បត្តិ ជាអតីតមន្ត្រីការទូតនៃរដ្ឋាភិបាល GRUNK ប្រចាំប្រទេសយូហ្គោស្លាវី និង អ៊ី សុបគន្ធី ជាអតីតតំណាង GRUNK ប្រចាំប្រទេសស៊ីយអែត។ អ្នកទាំងពីរនេះ បានមកដល់មន្ទីរ ស-២១ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ក្នុងអំឡុងពេលដែល ម-១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប-១។ អ្នកទាំងពីរនេះហាក់ដូចជាត្រូវចាប់ខ្លួន ដោយសារតែពួកគាត់បានសរសេរសំបុត្រឱ្យសាច់ញាតិនៅបរទេស ណែនាំពួកគេកុំឱ្យត្រឡប់មកកម្ពុជាវិញ[4524]។ [លុប] និយាយថា នៅពេលណាមានរឿងមិនប្រក្រតីកើតឡើងនៅច្រាំងចំរេះ គាត់ត្រូវតែរាយការណ៍ឱ្យ អៀង សារី។ [លុប] បញ្ជាក់ថា រឿងហេតុមិនប្រក្រតីនោះគឺអ្នកនៅទីនោះត្រូវបានចោទថា ពាក់ព័ន្ធនឹងបណ្តាញខ្មាំង[4525]។ [លុប] និយាយថា នៅពេលមាន "បញ្ហាមិន*ធម្មតា*" កើតឡើង គាត់កោះហៅអ្នកនៅច្រាំងចំរេះឱ្យទៅប្រជុំនៅមន្ទីរ ប-១។ ឧទាហរណ៍ ដូចករណី កុយ ធួន ដែលគេចោទនោះ អ្នកនៅក្រោមបង្គាប់គាត់ ក៏ត្រូវគេសួរចម្លើយដែរ។ បន្ទាប់ពីការកោះប្រជុំនោះមក [លុប] រាយការណ៍ឱ្យ អៀង សារី ថា កូនចៅរបស់ កុយ ធួន ទាំងអស់មិនដឹងរឿងអ្វីទេ[4526]។

<u>បឹងត្របែក</u>

**១១០១.**ពីដំបូង បឹងត្របែកគឺជាអង្គភាពចំណុះរបស់ ស-៧១[4527] ដែលមានទីតាំងនៅភ្នំពេញ[4528]។ ដោយសារជាអង្គភាពចំណុះរបស់ ស-៧១, ក-១៧ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់[4529] ដែលត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា ជាអ្នកទទួលខុសត្រូវរួមលើការរៀនសូត្រ និងបំពាក់បំប៉ន[4530]។ ចាប់តាំងពីដើមឆ្នាំ១៩៧៧[4531] ក្រុមអ្នកវិលត្រឡប់ ដែលបក្សកុម្មុយនីស្តបានបញ្ជូនទៅ "លត់ដំនៅបឹងត្របែក" បានចាប់ផ្តើមជំនួសនិស្សិត ដែលនៅមន្ទីរបឹងត្របែក[4532]។ ក្នុងឆ្នាំ១៩៧៨ ប្រហែលជាក្រោយពេលចាប់ខ្លួន ប៉ង់[4533] (ហេតុការណ៍នេះកើតឡើងនៅក្នុងខែឧសភា ឆ្នាំ១៩៧៨)[4534] ការគ្រប់គ្រងរដ្ឋបាលនៅមន្ទីរបឹងត្របែក ត្រូវបានផ្ទេរទៅមន្ទីរ ប-១ វិញ[4535]។ [លុប] បាននិយាយថា ការផ្លាស់ប្តូរនេះ ដោយសារតែពួកបញ្ញាជន ដែលបានស្នាក់នៅមន្ទីរបឹងត្របែកនោះ ត្រូវគេដាក់ក្រោមមន្ទីរ ប-១វិញ[4536]។ ពាក់ព័ន្ធនឹងហេតុការណ៍នេះ អៀង សារី បាននិយាយថា "*..ពេលនោះឯងគឺថា ខ្ញុំវាឃើញថា បើមិនមានបញ្ញាជន ជួយការងារអីក្នុងការកសាងប្រទេសជាតិហ្នឹងវាទៅមិនរួចទេ*"[4537]។ កាលបរិច្ឆេទពិតប្រាកដក្នុងឆ្នាំ១៩៧៨ ថាពេលដែលមន្ទីរបឹងត្របែកត្រូវផ្ទេរទៅមន្ទីរ ប-១ មិនមានភាពច្បាស់លាស់ទេ។ ទាំង អៀង សារី និង [លុប]

[លុប] បាននិយាយថា ហេតុការណ៍នេះកើតឡើង ប្រហែលមួយខែមុនកងទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញ[4538]។ ប៉ុន្តែ [លុប] បានប្រាប់ពីកាលបរិច្ឆេទពិតប្រាកដ គឺក្នុងខែឧសភា ឆ្នាំ១៩៧៨[4539]។ ទោះបីជាយ៉ាងណាក៏ដោយ [លុប] បញ្ជាក់ពីហេតុការណ៍នោះថា តាំងពីមុនមន្ទីរបឹងត្របែកត្រូវបានដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរប-១ "*មានការសហការគ្នាដែរក្នុងការដឹកនាំ*" ដោយសារតែមានបញ្ជាជនមួយចំនួនដែលស្នាក់នៅមន្ទីរបឹងត្របែកនោះ[4540]។ ក្នុងរយៈពេលខ្លីបន្ទាប់ពីបឹងត្របែកត្រូវបានផ្ទេរទៅមន្ទីរ ប-១ មន្ទីរនេះត្រូវបានបែងចែកជាបីផ្នែកគឺ៖ មន្ទីរ ប-៣០ ដែលមានមនុស្សរស់នៅច្រើនជាងគេ, មន្ទីរ ប-៣១ សម្រាប់អ្នកដែលត្រៀមខ្លួនទៅធ្វើការតាមក្រសួងផ្សេងៗស្នាក់នៅ និងមន្ទីរ ប-៣២ ទុកសម្រាប់ឲ្យអតីតមន្ត្រីការទូតស្នាក់នៅ[4541]។

**១១០២.អៀង សារី** ទទួលស្គាល់ថា គាត់បានទៅពិនិត្យមើលមន្ទីរបឹងត្របែកចំនួនពីរដង បន្ទាប់ពីមន្ទីរនោះត្រូវបានផ្ទេរឲ្យគាត់គ្រប់គ្រង[4542]។ អតីតអ្នករស់នៅមន្ទីរបឹងត្របែកម្នាក់បានបញ្ជាក់ពីវត្តមានរបស់ **អៀង សារី** នៅក្នុងខែមេសា ឆ្នាំ១៩៧៨ ដែលនៅពេលនោះ សាក្សីរូបនេះ បានសួរទៅ **អៀង សារី** អំពីជោគវាសនាឪពុកម្តាយរបស់គាត់[4543]។ [លុប] បញ្ជាក់ថា បន្ទាប់ពីការផ្ទេរការគ្រប់គ្រងមក **អៀង សារី** បានណែនាំប្រាប់អ្នកស្នាក់នៅក្នុងមន្ទីរនោះថា [លុប] គឺជាអ្នកគ្រប់គ្រងថ្មី ជំនួស **ប៉ង់**[4544]។ គាត់បាននិយាយថា **អៀង សារី** បានមកបង្រៀននៅមន្ទីរបឹងត្របែកចំនួនពីរដង ក្នុងឆ្នាំ១៩៧៨ និងឆ្នាំ១៩៧៩ នៅពេលដែលគាត់បានរៀបចំផែនការនៅពេលវៀតណាមវាយចូល[4545]។ [លុប] និង [លុប] រំឭកថា **អៀង សារី** បានមកពិនិត្យកន្លែងនោះ ហើយដែលគាត់បានបង្រៀននយោបាយដល់អ្នកស្នាក់នៅទីនោះ ព្រមទាំងបង្រៀនពីស្ថានភាពទូទៅមុនពេលពួកគេត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរ ប-១ ឬនៅតាមក្រសួងផ្សេងៗ[4546]។ [លុប] និយាយថា គាត់បានឃើញ **អៀង សារី** នៅឯមន្ទីរបឹងត្របែកនោះជាច្រើនដង ដោយគាត់បានមកធ្វើជាអធិបតីក្នុងពិធីប្រជុំផ្សេងៗក្រោយខែតុលា ឆ្នាំ១៩៧៨[4547]។ [លុប] នៅចងចាំថា **អៀង សារី** បាននិយាយ "*បញ្ញោរ*" អ្នកដែលចូលរួមក្នុងអង្គប្រជុំនោះ ដោយថា ឥឡូវនេះគាត់ជាអ្នកទទួលបន្ទុក ហើយពួកគេ "មិនមែនពួកក្បត់" ទេ[4548]។ គាត់និយាយទៀតថា អ្នកស្នាក់នៅទាំងនោះ ត្រូវគេរៀបចំឲ្យទៅធ្វើការនៅតាមក្រសួងផ្សេងៗ ដូចជា មន្ទីរ ប-១ ជាដើម ហើយបណ្តាញខ្មាំងត្រូវបានកម្ចាត់អស់ហើយ[4549]។ ជាងនេះទៅទៀត **អៀង សារី** ក៏បានបន្ថែមថា គាត់បានអានចម្លើយសារភាពអ្នកត្រឡប់មកពីបរទេសចំនួនពីររូបគឺ **វ៉ាន់ ពិនី**[4550] និង **លាន សិរីវុធ**[4551]។

១១០៣. អ្នកស្នាក់នៅបឹងត្របែកធ្វើការងារធម្មតាដោយប្រើកម្លាំង ដូចជា ដាំបន្លែ បេះកំប្លោក[4552]។ ស្ថានភាពរស់នៅឯមន្ទីរបឹងត្របែក យ៉ាប់យឺនណាស់។ អ្នកស្នាក់នៅទីនោះត្រូវបានជំរុញឱ្យរាយការណ៍ពីគ្នាទៅវិញទៅមក ហើយកងសន្តិសុខកាចសាហាវជាងកន្លែងរស់នៅផ្សេងទៀត[4553]។ បន្ទាប់ពីក្រោកពីដំណេកនៅម៉ោង៥.៣០ព្រឹកភ្លាម ពួកគេត្រូវធ្វើ *"ការងារសង្គមនិយម"* ចំនួន២ម៉ោងសិន មុនពេលដើររកអាហារហូបចុក។ បន្ទាប់ពីបាយថ្ងៃត្រង់ ពួកគេត្រូវធ្វើការងារសង្គមនិយមទៀត បន្ទាប់មកត្រឡប់ទៅធ្វើការងារដាំដុះវិញ។ បន្ទាប់ពីអាហារល្ងាចរួច ពួកគេត្រូវចូលរួមប្រជុំស្វ័យទិទៀនទៀត[4554]។ ពួកអ្នកស្នាក់នៅទាំងនោះ ត្រូវបានប្រាប់ឱ្យដើរតែក្នុងទីបរិវេណនោះទេ ហើយហាមមិនឱ្យមានទំនាក់ទំនងជាមួយអ្នកខាងក្រៅឡើយ[4555]។ ទោះបីយ៉ាងណាក៏ដោយ ក៏មានសាក្សីខ្លះនិយាយថា បន្ទាប់ពី មន្ទីរ ប-១ គ្រប់គ្រងមន្ទីរបឹងត្របែក ស្ថានភាពរស់នៅបានប្រសើរឡើង[4556]។

១១០៤. អំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មានមនុស្សយ៉ាងហោចណាស់ ចំនួន ១៦នាក់ ត្រូវចាប់ខ្លួននៅបឹងត្របែក និងបញ្ជូនទៅមន្ទីរ ស-២១ ដូចដែលមានបង្ហាញនៅក្នុងផ្នែកនិយាយអំពីអង្គហេតុពាក់ព័ន្ធជាមួយនឹងមន្ទីរ ស-២១។ [លុប] រៀបរាប់ថា គាត់បានឃើញមនុស្សត្រូវពួកឈ្លបដឹកតាមឡានយកចេញទៅ ហើយ *"មិនដែលត្រឡប់"* មកវិញឡើយ[4557]។ នៅចុងឆ្នាំ១៩៧៨ មានការប្រជុំដ៏ធំមួយ ដែលនៅពេលនោះ គេបានប្រាប់អ្នកស្នាក់នៅទាំងនោះថា មានខ្មាំងនៅក្នុងជំរុំ ដូច្នេះពួកគេត្រូវតែមានស្មារតីប្រុងប្រយ័ត្នខ្ពស់[4558]។

### ក្រុមមនុស្សជាក់លាក់

១១០៥. តាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុង ប.ក.ក **អៀង សារី** បានចូលរួមក្នុងសកម្មភាពដែលកំណត់មុខសញ្ញាក្រុមជាក់លាក់មួយចំនួន។

១១០៦. ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ **អៀង សារី** ប្រហែលជាបានចូលរួមបង្កើតឯកសារបក្សចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែលបង្ហាញថា វណ្ណៈមានតែពីរទេគឺ កម្មករ និងកសិករ ហើយវណ្ណៈផ្សេងទៀតត្រូវបានបញ្ចូលទៅក្នុងវណ្ណៈទាំងពីរនោះ[4559]។

<u>ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ</u>

១១០៧.ក្រុមនេះត្រូវបានកំណត់ជាមុខសញ្ញា ខណៈពេលដែល **អៀង សារី** មានឋានៈជាសមាជិកពេញសិទ្ធនៃគណៈអចិន្ត្រៃយ៍។

១១០៨.វាមិនទំនងជាថា **អៀង សារី** បានចូលរួមដោយផ្ទាល់ក្នុងសមាជជាតិលើកទី២របស់ FUNK នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលដឹកនាំដោយ **ខៀវ សំផន** ហើយនាពេលសមាជនោះ មានការទាមទារឱ្យសម្លាប់ "ជនក្បត់៧រូបក្នុងទីក្រុងភ្នំពេញ"[4560]។ ក៏ប៉ុន្តែ ក្នុងខែបន្ទាប់មក នៅឯពិធីជប់លៀងក្នុងទីក្រុងប៉េកាំង **អៀង សារី** បានពន្យល់អ្នកដែលចូលរួមថា "....*សមាជជាតិលើកទីពីរត្រូវបានរៀបចំឡើងនៅកម្ពុជានាពេលថ្មីៗនេះ*"។ តាមរយៈនេះ **អៀង សារី** បានគាំទ្រការអំពាវនាវឱ្យមានការសម្លាប់ជនក្បត់ទាំង៧រូបខាងលើ[4561]។

១១០៩.តាមរយៈការទទួលទូរលេខ **អៀង សារី** បានដឹងអំពីការប្រហារជីវិតអតីតមន្ត្រី និងយោធារបស់របប លន់ នល់ នៅពាសពេញប្រទេសកម្ពុជា ដែលអ្នកទាំងនោះត្រូវបានចោទថា មាននិន្នាការជាមួយសកម្មភាពខ្មាំង។ ជាឧទាហរណ៍ ក្នុងខែមីនា ឆ្នាំ១៩៧៨ **អៀង សារី** បានទទួលទូរលេខមួយដែលមានខ្លឹមសារថា៖ "*នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់ វាងើបក្បាលឡើងវិញ ហើយធ្វើសកម្មភាពប្រឆាំងយើងនៅតាមបណ្តាការដ្ឋានផ្សេងៗ។ ពួកខ្មាំងនៅសេសសល់ទាំងនេះ វាទាក់ទងជាមួយនឹង ពួកប៉ូលីស ទាហាន និង ពួករដ្ឋការ។ ពួកទាំងនេះ វាបន្លំធ្វើជា "ប្រជាជនថ្មី"។ ក្រោយពីវា ធ្វើសកម្មភាពប្រឆាំងយើងហើយ ទើបយើង ស្គាល់មុខពួកវាច្បាស់ ទន្ទឹមនឹងនេះ យើងក៏បោសសម្អាត វាជាខ្សែសង្វាក់។ មកដល់ថ្ងៃនេះ ពួកប៉ូលីស ទាហាន និងរដ្ឋការមួយចំនួនបានរត់បាត់ ក្រោយពីយើង បោសសម្អាតចំនួនប្រមាណជាង២០ក្បាល និងមានវិធានការបន្ត រកចាប់ខ្លួនពួកនេះតទៅទៀត*"[4562]។

១១១០.ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ **អៀង សារី** បាននិយាយនៅក្នុងបទសម្ភាសន៍ថា មន្ត្រីរបប លន់ នល់ បានចូលរួមក្នុងការបង្កបង្កើនផលកសិកម្ម ហើយពួកគេត្រូវបានប្រើដោយរដ្ឋាភិបាល ប.ក.ក នៅពេលអ្នកទាំងនោះ "*ស្មោះត្រង់*"។ ទាក់ទងនឹងវាសនានៃអតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត, **អៀង សារី** និយាយថា "*ស្លាប់ ឬរស់ គាត់គឺជាជនក្បត់ ហើយត្រូវបានកាត់ទោសដោយប្រជាជន និងសភា*"[4563]។ ពីរខែក្រោយមក ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ គាត់ទទួលស្គាល់នៅចំពោះមុខអ្នកកាសែតបរទេសថា ឡុង បូរ៉េត និង សេរីមតៈ ត្រូវបានសម្លាប់[4564]។

១១១១. ក្នុងខែឧសភា ឆ្នាំ១៩៧៧ **អៀង សារី** បាននិយាយថា អតីតមន្ត្រីរបប លន់ នល់ ដែលជា "*ឧក្រិដ្ឋជន ដ៏គ្រោះថ្នាក់ត្រូវបានយកទៅកាត់ទោស*" ហើយគាត់ឲ្យដឹងថា អ្នកឯទៀតបានចូលរួមក្នុងមហាជនឥឡូវនេះ និងកំពុងធ្វើការតាមសហករណ៍នៅទូទាំងប្រទេសកម្ពុជា។ គាត់បានបដិសេធថា ពួកគេមិនត្រូវបានយកទៅដាក់ទៅតាមមន្ទីរឃុំឃាំងនានាទេ។ គាត់បាននិយាយអំពីព្រឹត្តការណ៍មួយដែលបានជួបនៅពេលគាត់បានទៅពិនិត្យមើលសហករណ៍ថា កសិករម្នាក់ចង់សម្លាប់អតីតវរសេនីយ៍ត្រីម្នាក់ដែលបានធ្វើការនៅក្នុងសហករណ៍នោះដែរ ប៉ុន្តែជននោះត្រូវបានជួយជីវិត ពីព្រោះគាត់បាន "*...កែខ្លួនបានល្អ បន្ទាប់ពីរំដោះរួចមក*"[4565]។

១១១២. ក្នុងខែមេសា ឆ្នាំ១៩៧៨ **អៀង សារី** បានសរសេរសំបុត្រមួយច្បាប់ ផ្ញើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលក្នុងនោះគាត់បាននិយាយថា អតីតមន្ត្រីរដ្ឋការរបស់រដ្ឋាភិបាលមុនកំពុងធ្វើការជាមួយប្រជាជននៅតាមសហករណ៍នានា ហើយ "*គ្រប់គ្នាមានសិទ្ធិស្មើៗគ្នា*"[4566]។

១១១៣. ក្នុងខែធ្នូ ឆ្នាំ១៩៩៦ **អៀង សារី** បាននិយាយនៅក្នុងបទសម្ភាសន៍មួយថា គាត់មិនបានដឹងឮអ្វីទាំងអស់អំពីផែនការសម្លាប់ទាហាន ព្រមទាំងមន្ត្រីរដ្ឋការ លន់ នល់ ទេ ក្នុងអំឡុងពេលមានការជម្លៀសអ្នកទាំងនោះចេញពីភ្នំពេញ[4567]។ គាត់បាននិយាយថា សេចក្តីសម្រេចប្រហារជីវិតមន្ត្រីទាំងនោះត្រូវបាន អនុវត្តក្នុងអំឡុងថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះគាត់មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទេ។ គាត់បាននិយាយផងដែរថា សេចក្តីសម្រេចក្នុងការប្រហារជីវិតក្រុមមនុស្សទាំងនោះ ព្រមទាំងជម្លៀសប្រជាជនចេញពីទីក្រុង គឺដោយសារតែគេបានរកឃើញថា មានអាវុធនៅក្នុងផ្ទះមន្ត្រីយោធាទាំងនោះ ដែលមានការលើកឡើងថា ពួកនោះកំពុងរៀបចំធ្វើរដ្ឋប្រហារ[4568]។

## ការប្រព្រឹត្តចំពោះពុទ្ធសាសនិក

១១១៤. ក្រុមនេះត្រូវបានកំណត់ជាមុខសញ្ញាជាក់លាក់ នៅពេលដែល **អៀង សារី** មានឋានៈជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ ទោះបីជាយ៉ាងណាក៏ដោយ **អៀង សារី** ត្រូវបានសាកសួរនៅក្នុងកិច្ចសម្ភាសន៍ ក្នុងឆ្នាំ១៩៧៥ ថាតើ ប.ក.ក គោរពព្រះពុទ្ធសាសនា ឬអត់ ពេលនោះ គាត់បានឆ្លើយថា "*យើងគោរព ជំនឿសាសនារបស់មនុស្សគ្រប់គ្នា។ ប្រជាជនមានសិទ្ធជឿ ប៉ុន្តែពួកគេត្រូវ*


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

*គោរពច្បាប់រដ្ឋ។ វត្តអារ៉ាម នៅកម្ពុជាពុំមានបិទទេ*"[4569]។

<u>ការប្រព្រឹត្តលើជនជាតិចាម</u>

១១១៥.ជនជាតិចាមត្រូវបានកំណត់ជាមុខសញ្ញាជាក់លាក់ នៅពេលដែល អៀង សារី មានតួនាទីជាសមាជិកពេញសិទ្ធិក្នុងគណៈអចិន្ត្រៃយ៍។ អៀង សារី បានដឹងអំពីគោលនយោបាយនេះចំពោះតែផ្នែកដែលអនុវត្តពាក់ព័ន្ធនឹងគាត់តែប៉ុណ្ណោះ។

<u>ការប្រព្រឹត្តលើជនជាតិវៀតណាម</u>

១១១៦.ក្រុមនេះត្រូវគេកំណត់ជាមុខសញ្ញាជាក់លាក់ នៅពេលដែល អៀង សារី មានតួនាទីជាសមាជិកពេញសិទ្ធក្នុងគណៈអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រីកិច្ចការបរទេស។ អៀង សារី មិនត្រឹមតែបានដឹងពីការប្រព្រឹត្តចំពោះជនជាតិវៀតណាមប៉ុណ្ណោះទេ ថែមទាំងបានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយនេះផងដែរ។

១១១៧. អៀង សារី បានថ្លែងសុន្ទរកថាជាច្រើនតាមវិទ្យុ ដែលក្នុងនោះ គាត់បានផ្សាយព័ត៌មាននានាក្នុងគោលបំណងបង្កើតឱ្យមានការភ័យខ្លាច ឬ ជំរុញឱ្យមានការស្អប់ខ្ពើមវៀតណាម ឬ ធ្វើឱ្យប្រជាជនកំណត់គោលដៅជាក់លាក់លើក្រុមនេះ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ អៀង សារី បានប្រកាសដូច្នេះថា "*ខ្មាំង*" ដូចជា វៀតណាមត្រូវបាន "*បោសសម្អាត*"[4570]។ ក្នុងសុន្ទរកថាចុះថ្ងៃទី៩ ខែកញ្ញាឆ្នាំ១៩៧៨ គាត់បានថ្លែងថា ប្រជាជនកម្ពុជាបាន "*យកជ័យជម្នះក្នុងការវាយកម្ចាត់ការទន្ទ្រាន និងវិទ្ធង្សនា ការប៉ុន ប៉ងធ្វើរដ្ឋប្រហារ ព្រមទាំងការវាយលុកក្នុងទ្រង់ទ្រាយធំដែលបង្កឡើងដោយពួកខ្មាំងយួនឈ្លាន ពានភាគទីនិយមនិងលេបទឹកដី*"[4571]។ ក្នុងសុន្ទរកថា ថ្លែងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ គាត់បាននិយាយថា "*ពួកឈ្លានពាន ពួកភាគទីនិយម លេបទឹកដី*" ត្រូវបាន "*កម្ចាត់តាមយុទ្ធសាស្ត្រ*"[4572]។ ក្នុងសុន្ទរកថា ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ គាត់បានថ្លែងសុន្ទរកថា វៀតណាមបាន "*បង្កើនការឈ្លានពាន ភាគទីនិយម លេបទឹកដីកម្ពុជាប្រជាធិបតេយ្យ*" ហើយ "*ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា*" និង "*បន្តរក្សាម្ចាស់ការ និងវាយកម្ចាត់ ធ្វើឱ្យវាកាន់តែដកថយថែមទៀត*"[4573]។ សុន្ទរកថាទាំងនេះត្រូវបានធ្វើឡើងក្នុងបរិបទនៃការសម្លាប់រង្គាលលើជនស៊ីវិលវៀតណាមក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងក្នុងផ្នែកដទៃទៀតនៃកម្ពុជា


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ដូចដែលមានរៀបរាប់ក្នុងផ្នែកស្តីពីការកត់សម្គាល់ឃើញពីអង្គហេតុនៃឧក្រិដ្ឋកម្មនៃដីកាដំណោះស្រាយនេះ។

**១១១៨.**បន្ថែមពីលើនេះ **អៀង សារី** បានដឹងឮពីការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងការទន្ទ្រានចូលក្នុងដីវៀតណាម តាមរយៈរបាយការណ៍ និងទូរលេខ ដែលត្រូវបានផ្ញើឱ្យគាត់។ ឧទាហរណ៍ **អៀង សារី** បានទទួលទូរលេខជាច្រើន ដែលទូរលេខទាំងនោះនិយាយអំពីអង្គភាពរបស់កងទ័ពបដិវត្តន៍កម្ពុជាថា បានចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម[4574]។ ឧទាហរណ៍ ទូរលេខដែលក្នុងនោះអង្គភាពយោធាបានរាយការណ៍ថាបានប្រយុទ្ធ និងសម្លាប់ជនស៊ីវិល[4575]ជាដើម។ ទូរលេខមួយចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ដោយ អ៊ុំ ណេង ហៅ វី ក្នុងនាមជាលេខាភូមិភាគឦសានជូនចំពោះ បងជាទីស្នេហា ព្រមទាំងបានចម្លងជូន **អៀង សារី** បានរាយការណ៍ អំពីការចាប់ខ្លួនជនជាតិវៀតណាមចាវ៉ាយ ចំនួន ២០៩ នាក់ ដោយកងពល ៨០១[4576]។ ដូចដែលបាននិយាយក្នុងដីកាដំណោះស្រាយនេះ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង អ្នកទាំងនេះក្រោយមកត្រូវបានសម្លាប់។ **អៀង សារី** បានដឹងឮពីការសម្លាប់ជនជាតិវៀតណាម តាមរយៈទូរលេខមួយទៀតចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ ដែលផ្ញើមកពីកងពល១៦៤ បានរាយការណ៍ថា មានជនជាតិវៀតណាម១២០នាក់ត្រូវចាប់ខ្លួន និងបាញ់សម្លាប់[4577]។ មានទូរលេខមួយទៀត ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៧ មានអត្ថន័យថា សារព័ត៌មានខាងវៀតណាមបានរាយការណ៍ពីការសម្លាប់ជនស៊ីវិលវៀតណាមក្នុងទ្រង់ទ្រាយធំ ចំនួន ១.០០០នាក់ ដោយកងទ័ពកម្ពុជា[4578]។ បន្ថែមពីលើនេះ **អៀង សារី** បានចែកចាយតាមរយៈ ប-១ នូវកម្រង *"ចម្លើយសារភាព"*[4579] របស់កងទ័ព និងគិញវៀតណាម ដែលត្រូវបានស្រង់យកនៅមន្ទីរ ស-២១[4580]។

**១១១៩.អៀង សារី** ថែមទាំងបានចែកចាយ "សៀវភៅខ្មៅ"[4581] ដែលមានសរសេរថា *"សារជាតិពិតប្រាកដរបស់ជនជាតិវៀតណាម និងប្រទេសវៀតណាម"* គឺ *"សារជាតិនៃពួកឈ្លានពាន ពួកពង្រីកទឹកដី និងពួកលេបទឹកដីរបស់ប្រទេសដទៃ"*[4582]។

## ការរៀបអាពាហ៍ពិពាហ៍

**១១២០.**តាមរយៈតួនាទីផ្សេងៗគ្នានៅក្នុង ប.ក.ក **អៀង សារី** បានចូលរួមក្នុងការដាក់បទបញ្ញត្តិពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍។

១១២១. ការអនុវត្តន៍ប្រព័ន្ធរៀបអាពាហ៍ពិពាហ៍ដែលរៀបចំដោយបក្សត្រូវបានផ្សព្វផ្សាយតាមរយៈឯកសារបោះពុម្ពផ្សាយដោយ ប.ក.ក[4583] ដែល **អៀង សារី** ប្រហែលជាបានអាន។ គាត់ត្រូវបានគេរាយការណ៍តាមរយៈទូរលេខអំពីការអនុវត្តន៍ប្រព័ន្ធរៀបការនេះ[4584]។ ថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ក្នុងមហាសន្និបាតលើកទី៣២ របស់អង្គការសហប្រជាជាតិ **អៀង សារី** បាននិយាយថា ប្រជាជនកម្ពុជាមានចំនួនតិចនៅឡើយ ដូច្នេះហើយ ប.ក.ក មានគោលបំណងចង់ឱ្យមានការកើនចំនួនប្រជាជនឱ្យបានឆាប់រហ័ស[4585]។ នៅថ្ងៃ២២ ខែមេសា ឆ្នាំ១៩៧៨ ក្នុងសំបុត្រមួយច្បាប់ផ្ញើជូនមហាសន្និបាតអង្គការសហប្រជាជាតិ **អៀង សារី** បាននិយាយថា គោលដៅមួយរបស់ ប.ក.ក គឺបង្កើនចំនួនឱ្យបានច្រើនតាមតែអាចធ្វើបាន[4586]។ នៅក្នុងក្រសួងដែលគាត់គ្រប់គ្រង ជារឿយៗ កម្មាភិបាលត្រូវបានរៀបអាពាហ៍ពិពាហ៍ជាក្រុម ហើយអ្នកទាំងនោះត្រូវបានគេសួរនាំថា តើពួកគេព្រមទទួលយកដៃគូរបស់គេបានដែរឬទេ[4587]។ កម្មាភិបាលដែលមិនបានរៀបការ មិនទទួលបានការទុកចិត្ត ដូច្នេះហើយ ជួនកាលអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឱ្យអ្នកទាំងនោះ ទោះបីជាពួកគេមិនព្រមក៏ដោយ[4588]។ កម្មាភិបាលដែលបានរៀបការជាមួយដៃគូមិនមែនជាជនជាតិខ្មែរ ត្រូវបានជំរុញឱ្យរៀបការជាមួយជនជាតិខ្មែរវិញ[4589]។

## ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ

១១២២. **អៀង សារី** ដឹងថា ជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជា និងវៀតណាម កើតមានគ្រប់ពេលទាំងអស់ ចាប់ពីខែមេសាឆ្នាំ១៩៧៥ យ៉ាងហោចណាស់រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

១១២៣. **អៀង សារី** បានទៅទស្សនកិច្ចដោយផ្ទាល់នៅទីក្រុងហាណូយដើម្បីចរចាអំពីជម្លោះប្រដាប់អាវុធនេះ[4590]។ យ៉ាងហោចណាស់ **អៀង សារី** បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ចំនួនបីដងដែលក្នុងនោះ ស្ថានភាពនៃជម្លោះជាមួយវៀតណាមត្រូវបានយកមកជជែក[4591]។ ការប្រជុំលើកទី១ ប្រព្រឹត្តឡើងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦[4592]។ ជាងនេះទៅទៀត **អៀង សារី** បានទទួលទូរលេខជាច្រើនដង ទាក់ទងនឹងប្រតិបត្តិការយោធារបស់កងទ័ពបដិវត្តន៍កម្ពុជា ប្រឆាំងនឹងកងកម្លាំងវៀតណាម នៅតាមព្រំដែន[4593] និងបានទំនាក់ទំនងជាមួយតំណាងភាគីវៀតណាម[4594] ឡាវ[4595] ថៃ[4596] និងបារាំង[4597] អំពីហេតុការណ៍នោះ។ របាយការណ៍ទីមួយនៃទំនាក់ទំនងនោះ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥[4598]។ មិនមានរបាយការណ៍ដែលនៅសេសសល់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធជាមួយ វៀតណាម ដែលចុះកាលបរិច្ឆេទមុនខែវិច្ឆិកា ឆ្នាំ១៩៧៥ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ មិនត្រូវធ្វើសេចក្ដីសន្និដ្ឋានថា **អៀង សារី** មិនបានដឹងឮអំពីអត្ថិភាពនៃជម្លោះនោះឡើយ។ មានសាក្សីម្នាក់បាននិយាយថា **អៀង សារី** ត្រូវបានរាយការណ៍គ្រប់ពេលវេលាទាំងអស់ ឲ្យដឹងអំពីបញ្ហាពាក់ព័ន្ធនឹងសង្គ្រាម ដោយសារគាត់មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស[4599]។

**១១២៨.**ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស **អៀង សារី** បាននាំយកជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ទៅសហគមន៍អន្តរជាតិ។ គាត់បានរាយការណ៍ជូនក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិអំពីជម្លោះនោះ[4600] និងប្រាប់ពីការផ្ដាច់ទំនាក់ទំនងការទូតជាមួយវៀតណាមដោយសារតែការបន្តប្រយុទ្ធគ្នា[4601]។ **អៀង សារី** ថែមទាំងបានថ្លែងសុន្ទរកថាជាច្រើនក្រោមប្រធានបទជម្លោះនោះ ទៅកាន់អ្នកការទូតបរទេសប្រចាំទីក្រុងភ្នំពេញ[4602] នៅក្នុងសន្និសីទរដ្ឋមន្ត្រីការបរទេសនៃប្រទេសមិនចូលបក្សសម្ព័ន្ធ ដែលធ្វើឡើងនៅទីក្រុងបែលក្រាដ[4603] ក៏ដូចជានៅក្នុងស្ថានទូតចិនប្រចាំទីក្រុងភ្នំពេញ[4604] នៅក្នុងពិធីជប់លៀង ទទួលគណៈប្រតិភូបក្សកុម្មុយនីស្តម៉ាក្ស-លេនីនបារាំង[4605] នៅក្នុងសន្និសីទសារព័ត៌មាននៃដំណើរទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសហ្វីលីពីន[4606] នៅក្នុងសន្និសិទសារព័ត៌មាននៃដំណើរទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសឥណ្ឌូនេស៊ី[4607] នៅឯសន្និសីទសារព័ត៌មានក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣៣[4608] និងជាចុងក្រោយនៅក្នុងពិធីទទួលឯកអគ្គរដ្ឋទូតយូហ្គោស្លាវីប្រចាំនៅកម្ពុជា[4609]។ **អៀង សារី** ក៏បានបញ្ជាក់ផងដែរអំពីជម្លោះនេះនៅក្នុងបទសម្ភាសន៍ជាឯកជនជាមួយអ្នកសារព័ត៌មាន[4610]។

**១១២៩.**ដើម្បីគាំទ្រដល់ការទាមទារថា ជម្លោះនោះបណ្ដាលមកពីការឈ្លានពានរបស់វៀតណាម **អៀង សារី** បានចែកចាយដោយផ្ទាល់ខ្លួន និងតាមរយៈមន្ត្រីក្រសួងរបស់គាត់នូវឯកសារដែលមានចំណងជើងថា "សៀវភៅខ្មៅ"[4611] ទៅឲ្យមន្ត្រីជាជនបរទេសព្រមទាំងអ្នកសារព័ត៌មានផង[4612]។ ជាងនេះទៅទៀត ក្នុងខែកក្កដា ឆ្នាំ១៩៧៨ **អៀង សារី** ត្រូវបានជូនដំណឹងតាមរយៈទូរលេខ[4613] ថាការចងក្រង "*ចម្លើយសារភាព*" របស់ទាហានវៀតណាមដែលចាប់ខ្លួនបាន ត្រូវបានបោះពុម្ពផ្សាយដោយ "*នាយកដ្ឋានផ្សព្វផ្សាយនិងព័ត៌មាន នៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ*"[4614]។ ឯកសារនោះត្រូវបានចែកចាយឲ្យតំណាងទាំងឡាយនៃប្រទេសផ្សេងៗ។ ចម្លើយសារភាពនោះក៏ត្រូវបានចាក់ផ្សាយតាមវិទ្យុផងដែរ[4615]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605632



**គ. ខៀវ សំផន**[4616]

**សាវតារ**

**១១២៦.**ខៀវ សំផន ហៅ "ហែម"[4617],"ខាង"[4618] ឬ "ណន"[4619] ជាសកម្មជនចាស់ទុំមួយរូបនៅក្នុងចលនាកុម្មុយនីស្តកម្ពុជា។ ខណៈដែលកំពុងសិក្សានៅប្រទេសបារាំងក្នុងទសវត្សរ៍ឆ្នាំ៥០ គាត់ចាប់ផ្តើមចូលក្នុងឆាកនយោបាយ[4620]។ **ខៀវ សំផន** គាត់បានចូលរួមជាមួយក្រុមម៉ាក្ស-លេនីននិយម ដែលបានបង្កើតដោយ **អៀង សារី**។ ប៉ុល ពត, សុន សេន និង **អៀង ធីរិទ្ធ** ក៏ជាសមាជិកក្រុមនោះផងដែរ[4621]។ គាត់ក៏បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំងដែរ[4622]។

**១១២៧.** ពេលវិលត្រឡប់មកប្រទេសកម្ពុជាវិញ **ខៀវ សំផន** មានមុខរបរជាគ្រូបង្រៀន[4623]។ នៅឆ្នាំ១៩៥៩ គាត់បង្កើតកាសែតជាភាសាបារាំងឈ្មោះ *L'Observateur* (*អ្នកសង្កេតការណ៍*) ដែលគាំទ្រនិង ផ្តល់ថវិកាដោយសកម្មជនកុម្មុយនីស្តនៃប្រទេសកម្ពុជា[4624]។ ក្នុងឆ្នាំ១៩៦០ **ខៀវ សំផន** ត្រូវបានតាមដានយ៉ាងប្រកិតពីនគរបាល ហើយបានទទួលរងនូវការបំពារបំពាន (ដែលក្នុងពេលនោះគាត់ត្រូវបានប្រមាថជាសាធារណៈ) ដោយសារបានបោះពុម្ពផ្សាយអត្ថបទរិះគន់រដ្ឋាភិបាល នៅលើទំព័រកាសែត *L'Observateur*។ ក្នុងខែសីហា ឆ្នាំ១៩៦០ **ខៀវ សំផន** ត្រូវបានឃុំខ្លួនដោយគ្មានការជំនុំជម្រះអស់រយៈពេលពីរខែ។

**១១២៨.**នៅឆ្នាំ១៩៦២ **ខៀវ សំផន** បានចូលរួមជាមួយចលនាសង្គមរាស្ត្រនិយមរបស់សម្តេចនរោត្តមសីហនុ ហើយបានជាប់ឆ្នោតជាតំណាងរាស្ត្រប្រចាំស្រុកស្អាង ខេត្តកណ្តាល និងត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម[4625]។ ទោះបីយ៉ាងណាក៏ដោយ គាត់ត្រូវបានបង្ខំឱ្យលាលែងពីតំណែងនៅឆ្នាំ១៩៦៣[4626]។ **ខៀវ សំផន** បានជាប់ឆ្នោតជាតំណាងរាស្ត្រជាថ្មីម្តងទៀតនៅឆ្នាំ១៩៦៦ ប៉ុន្តែ តំណែងរបស់គាត់មិនបានស្ថិតស្ថេរទេ ដោយសារមានជម្លោះ និងអស្ថេរភាពនៅក្នុងបក្ស។ ដោយសារត្រូវបានចោទប្រកាន់ថា ជាអ្នកញុះញង់ឱ្យកសិករបះបោរនៅស្រុកសំឡូតនាឆ្នាំ១៩៦៦ **ខៀវ សំផន** ត្រូវបានកោះហៅឱ្យទៅបង្ហាញខ្លួននៅចំពោះមុខតុលាការយោធា។ **ខៀវ សំផន** បានភៀសខ្លួនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧ ដោយការភ័យខ្លាចការគំរាមចាប់ខ្លួន[4627]។ គាត់បានទៅជ្រកកោននៅភូមិជៀងតុង ស្រុកសំរោងទង ខេត្តកំពង់

ស្ពឺ ក្រោមការការពាររបស់តាម៉ុក[4628]។ **ខៀវ សំផន** បានរស់នៅទីនោះរហូតដល់ឆ្នាំ១៩៧០[4629]។

**១១២៩.** ក្រោយពីការផ្តួលរំលំសម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ហើយនៅពេលរណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានបង្កើត **ខៀវ សំផន** បានចូលរួមជាមួយ ប៉ុល ពត, **នួន ជា** និងមេដឹកនាំផ្សេងទៀតនៃបក្សកុម្មុយនីស្ត នៅទីស្នាក់ការកណ្តាលរបស់បក្សនេះនៅក្នុងតំបន់ចន្លោះខេត្តកំពង់ធំ និងខេត្តកំពង់ចាម[4630]។ **ខៀវ សំផន** ត្រូវបានតែងតាំងឱ្យកាន់តំណែងជាន់ខ្ពស់មួយចំនួនរួមមានជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះប្រជាជនកម្ពុជា[4631]។ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ **ខៀវ សំផន** ត្រូវបានតែងតាំងជាផ្លូវការជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)[4632] ហើយក្នុងតួនាទីនេះ **ខៀវ សំផន** បានដឹកនាំគណៈប្រតិភូនានាទៅបរទេស[4633]។ **ខៀវ សំផន** ទទួលបន្ទុកផងដែរក្នុងការធ្វើទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ[4634]។

**១១៣០.** នៅឆ្នាំ១៩៧១ **ខៀវ សំផន** បានក្លាយជាសមាជិកបេក្ខជននៃគណៈមជ្ឈិមប.ក.ក[4635]។ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧២ **ខៀវ សំផន**, ហ៊ូ យន់, ហ៊ូ នឹម បានអំពាវនាវ ឱ្យព្រះសង្ឃ និងប្រជាជនទីក្រុងភ្នំពេញ ព្រមទាំងប្រជាជនតាមខេត្តផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មាំង "*ងើបឡើងកម្ទេចខ្មាំង*" [4636]។ រវាងខែមករា និងខែមេសា ឆ្នាំ១៩៧៥ **ខៀវ សំផន** បានប្រកាសជាសាធារណៈជាច្រើនលើកអំពីជ័យជំនះដ៏ធំសម្បើម និងបានអំពាវនាវឱ្យប្រជាជនទីក្រុងភ្នំពេញក្រោកឡើងតស៊ូ ដើម្បីរំដោះជាតិ[4637] និងបានប្រកាសថា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អាចនឹងកាន់កាប់ក្រុងភ្នំពេញនាពេលឆាប់ៗ[4638]។

### តួនាទី និងមុខងារ

### សមាជិកគណៈមជ្ឈិម និងការចូលរួមក្នុងការងារគណៈអចិន្ត្រៃយ៍

**១១៣១.** **ខៀវ សំផន** ត្រូវបានបញ្ចូលជាសមាជិកត្រៀមនៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧១ និងបានក្លាយជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៧៦[4639]។ ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម **ខៀវ សំផន** អាច "*ពិគ្រោះ ពិភាក្សា និង រួមមតិសម្រេច*" រាល់បញ្ហាដែលពាក់ព័ន្ធ[4640]។

១១៣២. **ខៀវ សំផន** ធ្លាប់បានអះអាងថា គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ[4641] ។ ទោះបីគាត់ធ្លាប់ ឬមិនធ្លាប់ជាសមាជិកផ្លូវការក៏ដោយ ក៏មានឯកសារជាច្រើនបង្ហាញថា គាត់បានចូលរួមប្រជុំក្នុងគណៈអចិន្ត្រៃយ៍ជាច្រើនដងដែរ ។ ក្នុងចំណោមកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ចំនួន ១៩[4642] ដែលនៅសល់ (មានតែ ១៥ ប៉ុណ្ណោះ ដែលកត់ត្រាពីសមាសភាពអ្នកចូលរួម[4643] ) មានការកត់ត្រា ថា គាត់បានចូលរួមប្រជុំចំនួន ១៣ ដង[4644] ព្រមទាំងបានចូលរួមអង្គប្រជុំពិសេសនានារបស់គណៈមជ្ឈិមយ៉ាងតិច ២ ដង[4645]។ **ខៀវ សំផន** បានថ្លែងថា "*នៅពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ "បើកទូលាយ" ក៏ដូចនៅពេលប្រជុំគណៈកម្មាធិការមជ្ឈិមបក្ស ខ្ញុំមិនដែលមានមតិអ្វីទាំងអស់*"[4646]។ ប៉ុន្តែមានឯកសារជាច្រើនបង្ហាញថា គាត់ជាអ្នករាយការណ៍ទៅគណៈអចិន្ត្រៃយ៍ចំនួនពីរដង[4647]។ ចំពោះការប្រជុំដែល **ខៀវ សំផន** មិនបានចូលរួម គាត់ប្រហែលជានៅតែអាចទទួលបាននូវកំណត់ហេតុប្រជុំទាំងនោះ ដែលទំនងជាត្រូវបានគេកត់ត្រាជាប្រចាំ។

១១៣៣. កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ដែលបានដាក់ចូលក្នុងសំណុំរឿង បានចុះកាលបរិច្ឆេទត្រឹមពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ។ ប៉ុន្តែ **ខៀវ សំផន** បានអះអាងនៅពេលសួរចម្លើយថា គណៈអចិន្ត្រៃយ៍បានកោះប្រជុំជារៀងរាល់ ៧ ទៅ ១០ ថ្ងៃ ឬញឹកញាប់ជាងនេះក្នុងករណីបន្ទាន់ [4648]។ សាក្សីម្នាក់ដែលជាអ្នកបើករថយន្តឱ្យ **ខៀវ សំផន** ពីឆ្នាំ ១៩៧៨ បានបញ្ជាក់ថា គាត់បានបើករថយន្តដឹក **ខៀវ សំផន** ពីមន្ទីរ ក-៣ ទៅកាន់មន្ទីរ ក-១ ចំនួន ២ ឬ ៣ លើក ក្នុងមួយសប្តាហ៍ ហើយ **នួន ជា** និង **អៀង សារី** ក៏ត្រូវបានដឹកតាមរថយន្តទៅកាន់មន្ទីរ ក-១ ក្នុងពេលជាមួយគ្នានោះដែរ [4649]។ សាក្សីម្នាក់ទៀតបានអះអាងថា **ខៀវ សំផន អៀង សារី** និង **នួន ជា** បានចូលរួមប្រជុំសម្ងាត់នៅមន្ទីរ ក-១ [4650]។

១១៣៤. **ខៀវ សំផន** មានទំនាក់ទំនងនិងគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោមតាមរយៈការចូលរួមប្រជុំប្រចាំខែនៅមន្ទីរ ក-១ជាមួយ **ប៉ុល ពត, នួន ជា, អៀង សារី**និង**ប៉ង់** ដែលជាប្រធានមន្ទីរ ស-៧១។ ការប្រជុំទាំងនោះ មានរយៈពេលពីប្រាំទៅប្រាំមួយថ្ងៃ ហើយមានកម្មាភិបាលជាថ្នាក់ដឹកនាំប្រហែល ២០នាក់មកពីភូមិភាគ តំបន់ ឬ/និង គណៈស្រុកផ្សេងៗចូលរួម[4651]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

**ប្រធានគណៈប្រធានរដ្ឋ**

**១១៣៥.** ក្នុងសម័យប្រជុំដំបូងនៃសភាតំណាងប្រជាជនកម្ពុជា ដែលបានប្រារព្ធធ្វើឡើងពីថ្ងៃទី១១ ដល់ទី១៣ ខែមេសា ឆ្នាំ១៩៧៦ **ខៀវ សំផន** ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ[4652]។ ក្នុងតួនាទីនេះ គាត់បានទទួលតំណែងជាប្រមុខរដ្ឋបន្តពី [លុប] [4653]។

**១១៣៦.** ជំពូក៨ មាត្រា១១ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងថា៖ *"គណៈប្រធានរដ្ឋ មានភារៈតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេស និង ក្រៅប្រទេស"*[4654]។ **ខៀវ សំផន** បានអះអាងថា *"ទាក់ទងនឹងជំពូក៨ ស្ដីពីប្រធានគណៈប្រធានរដ្ឋ សេចក្ដីសម្រេចចិត្តបង្កើតស្ថាប័ននេះ គឺដើម្បីអនុវត្តគោលការណ៍សម្ពហភាពក្នុងគ្រប់វិស័យ"*[4655]។ ក៏ប៉ុន្តែ **ខៀវ សំផន** បានប្រកាសជាដដែលៗថា តួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ គ្រាន់តែជាតួនាទីកិត្តិយស និងជានិមិត្តរូបប៉ុណ្ណោះ ហើយថាគាត់គ្មានអំណាចជាក់ស្តែងទេ[4656]។ មានសាក្សីជាច្រើនបាននិយាយថា ពួកគេជឿថា **ខៀវ សំផន** មិនមែនជាបុគ្គលដែលមានអំណាចទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[4657]។

**១១៣៧.** លើសពីនេះ **ខៀវ សំផន** បានប្រកាសថា ការងាររបស់គាត់គឺគ្រាន់តែថ្លែងសុន្ទរកថា ទទួលលិខិតសារតាំងពីឯកអគ្គរដ្ឋទូតបរទេសចូលរួមនិងដឹកនាំការទទួលប្រមុខរដ្ឋពីប្រទេសនានាប៉ុណ្ណោះ[4658]។ ទោះបីជាយើងសន្មតថា តួនាទីរបស់គាត់ត្រូវបានកម្រិតត្រឹមនេះក៏ដោយ វាហាក់ដូចជាច្បាស់លាស់ណាស់ថា ការទទួលខុសត្រូវចំបងនានារបស់ **ខៀវ សំផន** ក្នុងតំណែងនេះ គឺដើម្បីជួយលើកស្ទួយគោលនយោបាយផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជាលើឆាកអន្តរជាតិ។ គាត់បានផ្ញើ[4659] និងទទួល[4660] លិខិតឆ្លើយឆ្លង និងសារតាំងពីបណ្ដាមេដឹកនាំ និង ឯកអគ្គរដ្ឋទូតផ្សេងៗលើពិភពលោក ។ គាត់បានធ្វើដំណើរបំពេញទស្សនកិច្ច ជាតំណាងកម្ពុជាប្រជាធិបតេយ្យ ទៅកាន់ប្រទេសនានាដូចជា ចិន[4661] ស្រីលង្កា[4662] សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ[4663] យូហ្គោស្លាវី[4664] រ៉ូម៉ានី[4665] និង បានថ្លែងសុន្ទរកថាម្ដង នៅឯសន្និសីទកំពូលលើកទីប្រាំរបស់បណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងកូឡុំបូ ក្នុងឆ្នាំ១៩៧៦ [4666] (ប៉ុន្តែគាត់បានបញ្ជាក់ថា **អៀង សារី** ជាអ្នកសរសេរសុន្ទរកថានេះឲ្យគាត់)[4667] ។ គាត់ក៏បានទទួលគណៈប្រតិភូ និងឯកអគ្គរដ្ឋទូតបរទេសជាច្រើននៅប្រទេសកម្ពុជា[4668] ជូនកាលគាត់អមដំណើរជាមួយពួកគេ ដើម្បីទៅធ្វើទស្សនកិច្ចនៅជុំវិញប្រទេសកម្ពុជា[4669] និងបានរាយការណ៍ប្រាប់គណៈប្រតិភូទាំងនោះអំពីការកសាងប្រទេសឡើងវិញ

អំពីសហករណ៍ និងបដិវត្តកសិកម្ម[4670] ផងដែរ។

១១៣៨. **ខៀវ សំផន** បានដឹកនាំសកម្មភាពនានាក្នុងនាមជាប្រធានគណៈប្រធានរដ្ឋដូចជា៖ ប្រកាសឲ្យប្រើបទប្បញ្ញត្តិ ដែលកំណត់អំពីការប្រព្រឹត្តិទៅរបស់សភាតំណាងប្រជាជនកម្ពុជា និងគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា[4671] និងបានទទួលព័ត៌មានទាក់ទងតាមទូរលេខអំពីជីវភាពរស់នៅ ការចាប់ខ្លួន និង ការឃុំឃាំងមនុស្សនៅខេត្តព្រះវិហារ [4672]។

**អង្គភាពចំណុះមន្ទីរ៨៧០**

១១៣៩. ចាប់ពីថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** ជាកម្មាភិបាលដឹកនាំមួយរូប នៃអង្គភាពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានឈ្មោះជាផ្លូវការថា "មន្ទីរនយោបាយ៨៧០" ។ **ខៀវ សំផន** បានទទួលស្គាល់ថា គាត់ជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាលតែពីរនាក់ប៉ុណ្ណោះ ដែលត្រូវបានចាត់តាំងឲ្យបំពេញការងារនៅទីនោះ ដែលកម្មាភិបាលម្នាក់ទៀតគឺជាប្រធានមន្ទីរនេះដំបូងឈ្មោះ **សៀ វ៉ាស៊ី** ហៅ **ខឿន**[4673] ជាសមាជិកមួយរូបនៃគណៈមជ្ឈិម ដែលបានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់ ។ **ឌុច** បានអះអាងថា **ខៀវ សំផន** បានកាន់តួនាទីជាប្រធានមន្ទីរនយោបាយ៨៧០ នៅឆ្នាំ១៩៧៦ នៅពេលដែល **ខឿន** ចាកចេញទៅគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្ម[4674]។ លើសពីនេះ **ឌុច** បានអះអាងថា តំណែងរបស់ **ខៀវ សំផន** ជាប្រធានមន្ទីរកាន់តែមានលក្ខណៈរឹងមាំនៅក្នុងឆ្នាំ១៩៧៧ នៅខណៈ **ខឿន** ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១[4675]។ [លុប] ដែលជាអ្នកបានកាន់តំណែងជាន់ខ្ពស់ជាច្រើននៅ ប-១[4676] និងជាអ្នកបញ្ជូនសំបុត្រដោយផ្ទាល់ពី ប-១ និងពី **អៀង សារី** ទៅឲ្យ **ខៀវ សំផន** អះអាងបន្ថែមថា **ខៀវ សំផន** បានជំនួសតំណែង **សៀ វ៉ាស៊ី** ហៅ **ខឿន** ក្នុងឋានៈជាប្រធាននៅចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨[4677]។ សាក្សីម្នាក់ទៀតដែលធ្លាប់ធ្វើការនៅ ប-១ ក៏បានបញ្ជាក់ដូចគ្នាផងដែរ[4678]។ នៅក្នុងកិច្ចសម្ភាសន៍មួយនាឆ្នាំ១៩៩៩ **អៀង សារី** បានបញ្ជាក់ថា **ខៀវ សំផន** ជាប្រធានមន្ទីរនយោបាយ៨៧០[4679] ទោះបីជាថ្មីៗនេះ គាត់បានបដិសេធលើការលើកឡើងនេះក៏ដោយ[4680]។

១១៤០. លើសពីនេះទៀត **ខៀវ សំផន** អាចជាអ្នកទទួលខុសត្រូវនៅក្នុងមន្ទីរ ស-៧១ ។ សាក្សីម្នាក់បាននិយាយថា **ប៉ង់** ជាប្រធានមន្ទីរ ស-៧១ ហើយគាត់ជាអ្នកទទួលបញ្ជាពី **ខៀវ សំផន** និងពីមេដឹកនាំ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ជាន់ខ្ពស់ផ្សេងៗទៀតទៅតាមជំនាញការងារ[4681]។

១១៨១.**ខៀវ សំផន** បានប្រកែកជាបន្តបន្ទាប់ថា គាត់មិនធ្លាប់ធ្វើជាប្រធានមន្ទីរនយោបាយ៨៧០ ទេ[4682]។ គាត់បានអះអាងថា តួនាទីរបស់គាត់នៅក្នុងមន្ទីរចំណុះមន្ទីរ៨៧០ ត្រូវបានកំណត់ត្រឹមតែបញ្ហាសេដ្ឋកិច្ច ការផ្គត់ផ្គង់ស្បៀងអាហារនៅទូទាំងប្រទេសកម្ពុជា និងការទំនាក់ទំនងជាមួយ[លុប] [លុប] តែប៉ុណ្ណោះ[4683]។ សាក្សីម្នាក់ដែលធ្លាប់ធ្វើការជាអ្នកបកប្រែទូរលេខ នៅតំបន់ស្វយ័ត១០៥ និងជានីរសាររបស់មជ្ឈិមបក្ស អះអាងថា គាត់ត្រូវបញ្ជូនទូរលេខទាំងអស់ ដែលទាក់ទិននឹង *"ការងារសម្ភារៈ សុខាភិបាល ឬសង្គមកិច្ច និង ការងារក្រៅពីសន្តិសុខ"* ផ្ទាល់ទៅឱ្យ **ខៀវ សំផន** នៅមន្ទីរ៨៧០ [4684]។

## ក្រសួងពាណិជ្ជកម្ម

១១៨២.**ខៀវ សំផន** ត្រូវបានតែងតាំងឱ្យទទួលខុសត្រូវ *"ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ"* ក្នុងអំឡុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥[4685] ដែលជាក់ស្តែងគឺធ្វើការនៅកៀកនឹងសមាជិកគណៈមជ្ឈិម **កុយ ធួន** ដែលត្រូវចាត់តាំងឱ្យទទួលបន្ទុកខាង*"ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស"*[4686]។ នៅក្នុងតួនាទីនេះ **ខៀវ សំផន** អាចបានចូលរួមប្រជុំក្នុងគណៈរដ្ឋមន្ត្រីផងដែរ។

១១៨៣. **ខៀវ សំផន** បានអះអាងជាសាធារណៈថា ការទទួលខុសត្រូវរបស់គាត់រួមមាន ធ្វើការងារជាមួយនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសសម្រាប់ការនាំចេញនិងនាំចូលទំនិញ អនុវត្តសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទិននឹងការចែកស្បៀងអាហារនៅទូទាំងប្រទេស និងរៀបចំតម្លៃផលិតផលដែលបានទទួលពីតាមសហករណ៍[4687]។ សាក្សីនានាបានបញ្ជាក់ថា គាត់ទទួលខុសត្រូវផ្នែកពាណិជ្ជកម្ម និងចែកទំនិញ និងស្បៀងនៅទូទាំងប្រទេសមែន[4688] ហើយមានសាក្សីជាច្រើននាក់ទៀតអះអាងថា គាត់បានទៅក្រសួងពាណិជ្ជកម្មជាទៀងទាត់[4689]។ លេខាតំបន់១០៥ បាននិយាយ ថា *"ខ្ញុំធ្លាប់ឱ្យបញ្ជីពាណិជ្ជកម្មស្នើសម្ភារៈឱ្យទៅ ខៀវ សំផន ផ្ទាល់ដៃហើយធ្លាប់បាននិយាយជាមួយគាត់ពីការងារសេដ្ឋកិច្ចនៅពេលបាយ ឬ ក្រៅពេលប្រជុំផ្លូវការ"* [4690]។ ក្នុងពេលសួរចម្លើយ **ឌុច** បានផ្តល់សក្ខីកម្មថា **ខៀវ សំផន** ធ្លាប់បានគ្រប់គ្រងរោងចក្រអគ្គិសនីរដ្ឋាករទឹក និងឃ្លាំងរដ្ឋ[4691]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១១៨៤.**ខៀវ សំផន** បានទទួលទូរលេខ និង លិខិតឆ្លើយឆ្លងជាច្រើន ពីគណៈកម្មាធិការពាណិជ្ជកម្ម និងក្រុមហ៊ុន FORTRA ពាណិជ្ជកម្មក្រៅប្រទេសនៅទីក្រុងភ្នំពេញ ទាក់ទងនឹងបញ្ហានានាដូចជា៖ ការនាំចូល-នាំចេញស្បៀងអាហារនិងទំនិញ ទំនាក់ទំនងសេដ្ឋកិច្ចជាមួយបរទេស ក៏ដូចជាការដែលសមាជិកគណៈកម្មាធិការពាណិជ្ជកម្មធ្វើដំណើរទៅតាមទីជនបទនៃប្រទេសកម្ពុជា ដើម្បីប្រមូលភោគផល[4692]។ នៅពេលត្រូវបានសួរអំពីទូរលេខមួយ ដែលផ្ញើទៅឲ្យ **ខៀវ សំផន**[4693] សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅក្រសួងពាណិជ្ជកម្មបានអះអាងថា វ៉ាន់ រិត មិនមានអំណាចសម្រេចទៅលើការទិញទំនិញពីបរទេសទេ ហើយថារាល់លិខិតដែលទាក់ទងនឹងបញ្ហានេះត្រូវតែផ្ញើទៅឲ្យ **ខៀវ សំផន** ដើម្បីសម្រេច[4694]។ ទោះបីជាគណៈកម្មាធិការពាណិជ្ជកម្មដែលនៅក្រោមការគ្រប់គ្រងរបស់ **វ៉ាន់ រិត** ត្រូវទទួលខុសត្រូវចំពោះមុខ **វន វេត**[4695] ក៏ដោយ ក៏ការដែលថា **វ៉ាន់ រិត** ស្ថិតនៅក្រោមបង្គាប់របស់ **ខៀវ សំផន** នោះ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមហេតុការណ៍ដែលថាគាត់បានធ្វើចំណារជាទៀងទាត់លើសេចក្តីចម្លងនៃរបាយការណ៍ពាណិជ្ជកម្ម ដែលត្រូវផ្ញើជូនទៅ "បងហែម" ដោយប្រើពាក្យស្វាគមន៍ជាភាតរភាព។ **ឌុច** បានបញ្ជាក់ថា ជាធម្មតាត្រូវប្រើពាក្យនេះជាមួយថ្នាក់លើ[4696]។ សាក្សីមួយរូប ដែលធ្វើការនៅខាងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេសបានអះអាងថា **ខៀវ សំផន** មានអំណាចលើ **វ៉ាន់ រិត**[4697] ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ **ខៀវ សំផន** បានទទួលគណៈប្រតិភូសេដ្ឋកិច្ចនិងពាណិជ្ជកម្មក្រៅប្រទេសមួយក្រុមមកពីប្រទេសយូហ្គោស្លាវី[4698] ហើយគាត់អះអាងថា គាត់ធ្លាប់បានទៅប្រទេសយូហ្គោស្លាវីពីរដង[4699]។

## តួនាទីផ្សេងទៀត

១១៨៥.បន្ថែមលើការរៀបរាប់ពីខាងលើ **ខៀវ សំផន** ក៏នៅមានតួនាទីមួយចំនួនផ្សេងទៀត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ផ្នែកយោធា

១១៨៦.ទាំងមុននិងក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ខៀវ សំផន មានតួនាទីជាឧបនាយករដ្ឋមន្ត្រី[4700] រដ្ឋមន្ត្រីក្រសួងការពារជាតិ និង ជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិ និងប្រជាជនកម្ពុជា[4701]។ **ឌុច** អះអាងថា **ខៀវ សំផន** គ្រាន់តែជាប្រធានកិត្តិយសគណៈកម្មាធិការយោធា *"ជារូបភាពបង្ហាញសាកលលោកទេ"* រីឯ **ប៉ុល ពត** មានអំណាចពិតប្រាកដនៅក្នុងវិស័យយោធា[4702]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ផ្នែកកិច្ចការបរទេសនិងអ្នកធ្វើមាតុភូមិនិវត្តន៍

១១៤៧.មានភស្តុតាងបញ្ជាក់ថានៅពេល **អៀង សារី** នៅក្រៅប្រទេស **ខៀវ សំផន** ទទួលខុសត្រូវដឹកនាំក្រសួងការបរទេស[4703]។ **ខៀវ សំផន** ពាក់ព័ន្ធនឹងការហៅប្រជាជនដែលរស់នៅបរទេសឲ្យត្រឡប់មកកម្ពុជាវិញ ដោយអប់រំពួកគេពេលពួកគេមកដល់។ សាក្សីបីនាក់បាននិយាយថា **ខៀវ សំផន** មានតួនាទីជាអ្នកបង្រៀនវគ្គរៀនសូត្រនយោបាយដល់ប្រជាជនកម្ពុជាដែលត្រឡប់ចូលស្រុកវិញ[4704]។ មានសាក្សីម្នាក់ដែលវិលត្រឡប់មកកម្ពុជាវិញនៅចុងឆ្នាំ១៩៧៥ជាមួយក្រុមនិស្សិតមួយក្រុមដែលមានគ្នាដប់នាក់បានអះអាងថា **ខៀវ សំផន** ធ្លាប់បានប្រាប់ពួកគាត់ថា បច្ចុប្បន្ននេះមានវណ្ណៈតែពីរប៉ុណ្ណោះ គឺវណ្ណៈកសិករនិងកម្មករ ហើយថា *"ប្រទេសជាតិត្រូវការពួកយើងដើម្បីកសាងប្រទេសឡើងវិញ ប៉ុន្តែមុនដំបូងគឺត្រូវទៅជនបទដើម្បីរៀនធ្វើអ្វីៗ ដែលយើងមិនដែលបានធ្វើពីមុនមកទាល់តែសោះ។ ជាឧទាហរណ៍ ដូចជា រៀនដាំស្រូវ ដើម្បីស្វែងយល់ថាតើមានការលំបាកបែបណា ទម្រាំទទួលបានបាយមួយចានយកមកហូប"*[4705]។ អ្នកត្រឡប់មកវិញភាគច្រើន បានត្រូវបញ្ជូនទៅមន្ទីរ ស-២១ បន្ទាប់ពីការហៅឲ្យទៅរៀនសូត្រ ។

សុន្ទរកថា និងការបង្រៀននយោបាយ

១១៤៨.លើសពីនេះទៀត **ខៀវ សំផន** ជាអ្នកទទួលខុសត្រូវថ្លែងសុន្ទរកថាក្នុងនាមបក្សកុម្មុយនីស្តកម្ពុជា និងដឹកនាំសកម្មភាពបណ្តុះបណ្តាល។ **ខៀវ សំផន** បានថ្លែងសុន្ទរកថាជាច្រើនដង ដើម្បីលើកស្ទួយ និងផ្សព្វផ្សាយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានថ្លែងសុន្ទរកថានៅសន្និបាតធំៗរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីអបអរសាទរខួបកំណើតជ័យជំនះថ្ងៃទី១៧ ខែមេសា[4706] និងដើម្បីអបអរសាទរបុណ្យចូលឆ្នាំខ្មែរ[4707]។ មានសាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅមន្ទីរទូរលេខរបស់មជ្ឈិមបក្សបានអះអាងថា **ខៀវ សំផន** ជាអ្នកណែនាំគាត់ក្នុងការរៀបចំកម្មវិធីបុណ្យជាតិផ្សេងៗ[4708]។ សាក្សីជាច្រើនផ្តល់ភស្តុតាងថា ពួកគេធ្លាប់បានស្តាប់សុន្ទរកថារបស់គាត់នៅក្នុងអង្គមិទ្ទិញ និងការប្រជុំធំៗ ដែលបានប្រារព្ធធ្វើឡើងនៅតាមទីកន្លែងនានាដូចជា ពហុកីឡាដ្ឋានអូឡាំពិក និងបូរីកីឡា[4709]។ សាក្សីនានាបានផ្តល់ភស្តុតាងថា **ខៀវ សំផន** បានថ្លែងសុន្ទរកថាទៅកាន់មនុស្សប្រហែល ២០.០០០ នាក់ ដែលមកពីគ្រប់ទិសទីនៃប្រទេសកម្ពុជា

ក្នុងពេលមានមិទ្ទិញ និងការប្រជុំទាំងនោះ[4710]។

១១៤៩. **ខៀវ សំផន** បានអះអាងថា គាត់ *"ភាគច្រើន"* ឯកភាពទៅនឹងខ្លឹមសារនៅក្នុងសុន្ទរកថាទាំងនោះ ប៉ុន្តែគាត់មិនយល់ស្រប *"ចំពោះចំណុចខ្លះ ... ឧទាហរណ៍ ការលុបបំបាត់លុយ"* តែគាត់មិនហ៊ាន បញ្ចេញការជំទាស់ទេ ព្រោះខ្លាចត្រូវគេសម្លាប់[4711]។ គាត់អះអាងថា សុន្ទរកថារបស់គាត់ *"ពុំមិន មានសារៈសំខាន់ច្រើននោះទេ"* ហើយថា មានតែ ប៉ុល ពត និង នួន ជា ទេ ដែលថ្លែងសុន្ទរកថា សំខាន់ៗ[4712]។ **ខៀវ សំផន** បានទៅ ប-១ ដើម្បីរកឯកសារ និងពិភាក្សាអំពីបញ្ហាណាដែលគាត់គួរ លើកឡើងនៅក្នុងសុន្ទរកថារបស់ខ្លួន[4713]។

១១៥០. **ខៀវ សំផន** ក៏មានការទទួលខុសត្រូវផងដែរ ក្នុងការរៀបចំវគ្គរៀនសូត្រនយោបាយជាទៀងទាត់ ជាមួយកម្មករ និង កម្មាភិបាលគ្រប់ជាន់ថ្នាក់ដែលមកពីទូទាំងប្រទេសកម្ពុជា។ មានសាក្សីជាច្រើនផ្តល់ សក្ខីកម្មថា ពួកគេតម្រូវឱ្យចូលរួមវគ្គរៀនសូត្រទាំងនោះជាមួយ **ខៀវ សំផន**[4714] ។ ខ្លឹមសារនៅក្នុង សុន្ទរកថា និង វគ្គរៀនសូត្រនយោបាយ គ្របដណ្តប់ទៅលើបញ្ហានានាដូចជា៖ ជោគជ័យរបស់ បដិវត្តន៍[4715] ជម្លោះប្រដាប់អាវុធជាមួយវៀតណាម[4716] គោលនយោបាយកសិកម្ម និងសេដ្ឋកិច្ច របស់បក្សកុម្មុយនីស្តកម្ពុជា[4717] បញ្ហាផ្ទៃករដ្ឋបាលដូចជា៖ ការថែទាំសម្ភារៈបរិក្ខារ[4718] តម្រូវការ ក្នុងការកម្ចាត់ពួកសក្តិភូមិ និង ពួកមូលធន[4719] ផ្តួលរំលំពួកក្បត់ លន់ នល់ និងលុបបំបាត់ខ្សែរយៈ លន់ នល់[4720] ឬអំពីសភាពការណ៍នៅក្រុងភ្នំពេញ[4721] ។

## ការចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា

១១៥១. **ខៀវ សំផន** មានទំនាក់ទំនងស្និទ្ធស្នាលជាលក្ខណៈបុគ្គល និងជាលក្ខណៈនយោបាយជាមួយ សមាជិកសំខាន់ៗផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ[4722]។ ក្នុងរបប បក្សកុម្មុយនីស្តកម្ពុជា គាត់បានចូលរួមជាទៀងទាត់ជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃបក្ស កុម្មុយនីស្តកម្ពុជា[4723]។ គាត់បានរស់នៅ និងធ្វើការជាមួយ **សុន សេន អៀង សារី នួន ជា ប៉ុល ពត** និង **វន វេត** (រហូតពេល **វន វេត** ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១) នៅមន្ទីរ ក-១ និងមន្ទីរ ក-៣ អស់រយៈពេលមួយភាគធំនៃរបបនេះ[4724]។ សាក្សីតែងតែបានឃើញ **ខៀវ សំផន** ចូលរួមប្រជុំ និងធ្វើការជាមួយថ្នាក់ដឹកនាំទាំងនោះ និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត[4725] និងបានឮ ការប្រកាសតាមវិទ្យុអំពីការធ្វើការរួមគ្នារបស់ពួកគេ[4726]។ **ឌុច** បានផ្តល់សក្ខីកម្មថា *"ខៀវ សំផន*

*ជាមនុស្សដែល ប៉ុល ពត ទុកចិត្ត*"[4727] ហើយបានទទួលនូវ "*ព័ត៌មានអាទិភាពទាំងឡាយ*"[4728]។

១១៥២.**ខៀវ សំផន** បានធ្វើជាគណៈអធិបតីនៅក្នុងកិច្ចប្រជុំ និងវគ្គរៀនសូត្រសំខាន់ៗរបស់បក្ស ដោយមានវត្តមាន៖ ប៉ុល ពត នួន ជា **អៀង សារី** និង **អៀង ធីរិទ្ធ** ហើយគាត់បានធ្វើបទបង្ហាញផងដែរ [4729] ។ **ខៀវ សំផន** និង **អៀង សារី** បានទទួលគណៈប្រតិភូបរទេសរួមគ្នា[4730] និងបានធ្វើដំណើរទៅក្រៅប្រទេសរួមគ្នា[4731] ។ **ខៀវ សំផន** និង **អៀង សារី** ក៏បានធ្វើដំណើរទៅតាមទីជនបទ និងបានចុះត្រួតពិនិត្យមើលតាមសហករណ៍ និង ការដ្ឋាននានារួមគ្នា[4732] ។ **អៀង សារី** តែងបានប្រាស្រ័យទាក់ទងជាទៀងទាត់ជាមួយ **ខៀវ សំផន** នៅពេលគាត់រៀបចំទទួលភ្ញៀវ និង នៅពេលធ្វើដំណើរទៅតាមបណ្តាភូមិភាគ[4733] ។

## ការចូលរួមនៅក្នុងផែនការរួម

### ការផ្លាស់ទីលំនៅប្រជាជន

១១៥៣. តាមរយៈតួនាទីផ្សេងៗរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួមក្នុងការផ្លាស់ទីលំនៅប្រជាជនពីទីក្រុងទៅកាន់តំបន់ជនបទនានា ហើយព្រមទាំងពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ។

#### ដំណាក់កាលទី១

១១៥៤.[លុប] បានបញ្ជាក់ថា **ខៀវ សំផន** បានចូលរួមប្រជុំសម្រេចអំពីផែនការផ្លាស់ទីលំនៅប្រជាជនទីក្រុងភ្នំពេញនៅដើមខែមេសា ឆ្នាំ១៩៧៥[4734]។ ការប្រជុំនេះគឺនៅមន្ទីរ ប-៥ ដែលជាមន្ទីររបស់ **ប៉ុល ពត** ឋិតនៅភូមិតាំងពន ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង[4735] ។[លុប] បានគូសបញ្ជាក់ថា **ខៀវ សំផន** ជាអ្នកកត់ត្រា និង"*ឡើងមានយោបល់ និងចំណាប់អារម្មណ៍ ហើយឯកភាពតាមផែនការដែលត្រូវជម្លៀសប្រជាជន*"[4736]។

១១៥៥.សាក្សីម្នាក់ទៀតបានផ្តល់សក្ខីកម្មបញ្ជាក់ថា **ខៀវ សំផន** បានចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី២០ ឬរង្វង់ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីម្នាក់នេះបានធ្វើ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605642



ដំណើរទៅកាន់ភ្នំអង្គរស្បូដើម្បីសម្រាក និងរៀបចំខ្លួនចូលទីក្រុងភ្នំពេញជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយក្រុម[4737]។ សាក្សីនេះបានបញ្ជាក់ថា **ខៀវ សំផន ហ៊ូ នឹម** និង **សុន សេន** បានធ្វើដំណើរទៅជួបគ្នានៅឯភ្នំអង្គរស្បូ និងបាន"*ត្រៀមចូលទៅកាន់កាប់*"ក្រុងភ្នំពេញ[4738]។ គាត់បានបញ្ជាក់ថា **ខៀវ សំផន ហ៊ូ នឹម** និង **សុន សេន** បានស្នាក់នៅភ្នំអង្គរស្បូចំនួន ៣ យប់ មុនពេលធ្វើដំណើរចូលភ្នំពេញ[4739]។

**១១៥៦. ខៀវ សំផន** បាន បញ្ជាក់ថា គាត់បានចូលទីក្រុងភ្នំពេញ ៧-១០ ថ្ងៃ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4740]។ គាត់បាននិយាយថា គាត់ពុំបានដឹងអំពីផែនការជម្លៀសប្រជាជនចេញពីភ្នំពេញឡើយ ទើបតែពេលគាត់បានចូលមកភ្នំពេញ និងបានស្តាប់ឮទាហានមួយក្រុមជជែកគ្នាអំពីរឿងនេះប៉ុណ្ណោះ[4741]។ គាត់បានបញ្ជាក់ជាសាធារណៈថា គាត់គិតថា ប្រជាជនពុំគួរត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញឡើយ[4742]។

**១១៥៧. ខៀវ សំផន** បានចេញសេចក្តីថ្លែងការណ៍មួយចំនួនតាមវិទ្យុនៅប៉ុន្មានខែមុន ការជម្លៀសប្រជាជនដែលនិយាយពាក់ព័ន្ធនឹងសភាពការណ៍នៅភ្នំពេញ។ នៅចន្លោះខែមករា និងខែមេសា ឆ្នាំ១៩៧៥ **ខៀវ សំផន** បានលើកឡើងជាច្រើនដង អំពីអ្វីដែលបានកំពុងកើតឡើងនៅភ្នំពេញ ។ គាត់បានអះអាងថា បនក្បត់ លន់ នល់ ជិតដួលរលំហើយ បានបញ្ជានិងអំពាវនាវឲ្យប្រជាជនភ្នំពេញវាយប្រយុទ្ធពួកលន់ នល់ ដើម្បីរំដោះជាតិ[4743]។ គាត់ក៏បានអំពាវនាវឲ្យស្ថានទូតបរទេស និងអង្គការបរទេសទាំងអស់នៅភ្នំពេញជម្លៀសបុគ្គលិករបស់ខ្លួន ដើម្បីជៀសវាងការបាត់បង់អាយុជីវិតបុគ្គលិកទាំងនោះ[4744]។ ផ្អែកតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានជំរុញឲ្យអ្នកទីក្រុងភ្នំពេញទៅរស់នៅជនបទដោយអំពាវនាវថា "*ឲ្យប្រជាជនធ្វើដំណើរទៅកាន់តំបន់រំដោះ*" ដោយប្រកាសថាពុំមានអង្គរទេនៅក្នុងទីក្រុងភ្នំពេញ[4745] ហើយសន្យាប្រាប់ប្រជាជនថាកម្មាភិបាល និងអ្នកតស៊ូដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីជួយពួកគេអោយមាន "*ជីវិតថ្មី*" នៅជនបទ ហើយជាពិសេសពួកគេអាចទទួលបាន"*ការផ្គត់ផ្គង់ និង មធ្យោបាយគ្រប់គ្រាន់*" សម្រាប់ផលិតកម្មកសិកម្ម[4746]។

**១១៥៨.ខៀវ សំផន** បានអំពាវនាវឲ្យកម្មាភិបាលបក្ស និង"*អ្នកតស៊ូ*" ដើម្បី"*បោសសំអាតសត្រូវឲ្យមានសកម្មភាពខ្លាំងក្លានៅទូទាំងតំបន់រំដោះ*"[4747] ហើយជាទូទៅដើម្បីលើកកម្ពស់ការប្រុងប្រយ័ត្ន "*បដិវត្តប្រឆាំងនឹងផែនការរបស់សត្រូវ*"[4748]។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ **ខៀវ សំផន**

00605643



បានចេញសេចក្តីប្រកាសព័ត៌មានមួយតាងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ដោយបានប្រកាសថា *"ពួកក្បត់ទាំង ៧ នៅទីក្រុងភ្នំពេញ ... លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង Sosthene Fernandez"* ត្រូវសម្លាប់ចោល[4749] និងបានអំពាវនាវឲ្យប្រជាជននៅភ្នំពេញរួមចំណែកដល់ការរំដោះជាតិតាមរយៈ *"បង្វែរចុងកាណុងដាក់ពួកវា"*[4750]។ គាត់បានបញ្ជាក់ថា *"បនក្បត់ជាតិទីក្រុងភ្នំពេញបច្ចុប្បន្ន នេះកំពុងភាន់ភាំង ភ័យស្លន់ស្លោ និងជិតដួលរលំទាំងស្រុង"*[4751] និងបានបញ្ជាឲ្យប្រជាជន *"វាយប្រហារខ្លាំងឲ្យបានខ្លាំងក្លា និងច្រើនឡើងថែមទៀត ទាំងនៅខ្សែត្រៀមខាងមុខ និងខ្សែត្រៀមខាងក្រោយ ដើម្បីសម្រេចបាននូវភារកិច្ចរំដោះប្រជាជាតិ និងប្រជាជនយើងទាំងស្រុង និងជាអចិន្ត្រៃយ៍"*[4752]។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ គាត់បានថ្លែងសុន្ទរកថាតាមវិទ្យុថា ទោះបីជា លន់ នល់ និងពួកក្បត់ផ្សេងទៀតដែលបានរៀបរាប់ឈ្មោះក្នុងខែកុម្ភៈ បានគេចចេញពីប្រទេសក៏ដោយ *"ក៏មានការប្រឹងប្រែងបន្តនូវ អំពើក្បត់របស់ក្រុមក្បត់ចុងក្រោយ"* ផងដែរ ហើយបានអំពាវនាវឲ្យផ្តួលរំលំពួកក្បត់ទាំងនោះជាស្ថាពរ[4753]។

១១៥៩. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៥ **ខៀវ សំផន** បានពន្យល់តាមវិទ្យុថា *"ភ្លាមៗក្រោយរំដោះ"* រណសិរ្សរួបរួមជាតិកម្ពុជាបានប្រឈមនឹងការរកវិធីដោះស្រាយបញ្ហាប្រជាជនអត់ឃ្លាននៅភ្នំពេញ ហើយពួកគេ*"បានដោះស្រាយ"*បញ្ហានេះ តាមរយៈការកេណ្ឌកម្លាំងប្រជាជនដើម្បីបង្កើនផលិតកម្មនៅទូទាំងផ្ទៃប្រទេស[4754]។ **ខៀវ សំផន** បានលើកឡើងម្តងទៀតនូវអំណះអំណាងទាំងនេះក្នុងសុន្ទរកថារបស់គាត់នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ក្នុងឱកាសសន្និសីទកំពូលលើកទី ៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅ កូឡុំបូ ដោយបានបញ្ជាក់ថា *"យើងបានដោះស្រាយជាមូលដ្ឋានរួចរាល់ហើយនូវបញ្ហាជីវភាពប្រជាជនកម្ពុជាយើង ចាប់តាំងពីថ្ងៃរំដោះ ពិសេសពាក់ព័ន្ធបញ្ហាស្បៀងអាហារ"*[4755]។ **ខៀវ សំផន** បានចេញសេចក្តីថ្លែងការណ៍មួយចំនួនជាបន្តបន្ទាប់ដោយយល់ស្រប និង ការពារផែនការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញដោយសំអាងថា ប្រជាជនកំពុងអត់ឃ្លាន[4756]។

១១៦០. [លុប] បានបញ្ជាក់ថា **ខៀវ សំផន** បានប្រាប់ព្រះអង្គនៅក្នុងលិខិតមួយ ថាកុំឲ្យយាងត្រឡប់ទៅភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ដោយហេតុថា ប.ក.ក ត្រូវការជម្លៀសប្រជាជនដើម្បីទប់ស្កាត់ការរាលដាលនៃជម្ងឺឆ្លងដែលអាចបណ្តាលឲ្យស្លាប់[4757]។ ក្នុងពេលសួរចម្លើយ **ខៀវ សំផន** បាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់អាចភ្លេច ប៉ុន្តែសារនោះ អាចជាសារមួយដែលអានឲ្យកត់ត្រាដោយ ប៉ុល ពត[4758]។

១១៦១.អត្ថបទសារព័ត៌មានមួយចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ អះអាងថា **ខៀវ សំផន** បានចូលទីក្រុងភ្នំពេញនៅសប្តាហ៍មុន ក្នុងសម្លៀកបំពាក់ខ្មៅនិងក្រមាមួយ និង "*ដោយបានប្រកាសអំពីជ័យជំនះនៃរបបផ្លូវនិយមថ្មីរបស់គាត់*"[4759]។ លើសពីនេះ របាយការណ៍សារព័ត៌មាន ញ៉ូយ៉កថែម ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៨២ បានសរសេរលម្អិត អំពីកិច្ចសម្ភាសន៍មួយជាមួយ **ខៀវ សំផន** នៅឯទីក្រុងកូឡាឡាំពួរ ដែលគេជឿថាគាត់បានទទួលស្គាល់ថាបានចូលរួម ក្នុងការសម្រេចរួមគ្នាអំពីការជម្លៀសប្រជាជនចេញពីភ្នំពេញដោយបង្ខំ[4760]។

<u>ដំណាក់កាលទី ២</u>

១១៦២.ការសម្រេចផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល(ឧត្តរចាស់) និរតី បស្ចិម និងបូព៌ា ត្រូវបានធ្វើដោយគណៈអចិន្ត្រៃយ៍ បន្ទាប់ពីសមាជិកគណៈអចិន្ត្រៃយ៍បានទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យ រវាងថ្ងៃទី២០ ដល់២៤ ខែសីហា ឆ្នាំ១៩៧៥[4761]។ ទោះបីជាមិនមានកំណត់ត្រាអំពីអ្នកដែលបានទៅទស្សនកិច្ចក៏ដោយ ហើយទោះបីជាគាត់ពុំមែនជាសមាជិកនៃបេសកកម្មនេះក្តី ក៏ **អៀង សារី** បានបញ្ជាក់ថា **ខៀវ សំផន** បានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍បើកទូលាយនៅខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីពិភាក្សាអំពីការអនុវត្តន៍លទ្ធិផ្តាច់ការ និងការពង្រឹងវិស័យកសិកម្ម និងឧស្សាហកម្ម[4762]។ ឯកសារមួយរបស់បក្សដែលមានកាលបរិច្ឆេទស្របគ្នានឹងថ្ងៃប្រជុំបានបញ្ជាក់ថា គេត្រូវការផ្លាស់ទីលំនៅ "ប្រជាជនថ្មី" ទៅភូមិភាគឧត្តរ និងពាយ័ព្យ[4763]។

<u>ដំណាក់កាលទី ៣</u>

១១៦៣. មានការបង្ហាញតាមរយៈដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ថា **ខៀវ សំផន** ពាក់ព័ន្ធនឹងផែនការជម្លៀសប្រជាជនពីភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ដូច្នេះវាទំនងជាថា **ខៀវ សំផន** បានសង្កេតមើលការផ្លាស់ទីលំនៅប្រជាជននេះ បានចែកក្រម៉ា និងម្ហូបអាហារឲ្យប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ[4764] ។

**សហករណ៍ និង ការដ្ឋាន**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១១៦៤.តាមរយៈតួនាទីផ្សេងៗរបស់គាត់ក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួមក្នុងការបង្កើត និងការដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាន ។

## ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ

១១៦៥.ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានចូលរួមចំណែក ក្នុងការរៀបចំផែនការនៃគោលនយោបាយបាយនេះ ដោយបានចូលរួមអង្គប្រជុំគណៈអចិន្ត្រៃយ៍ ឬតាមរយៈការទទួលបាននូវកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍[4765] និងក្នុងការបង្កើត *ផែនការបួនឆ្នាំ* ដើម្បីកសាងសង្គមនិយមគ្រប់វិស័យ[4766]។ គោលនយោបាយនេះក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុងកិច្ចប្រជុំបើកទូលាយរបស់គណៈអចិន្ត្រៃយ៍នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានពិភាក្សាលើការងារពង្រឹងវិស័យកសិកម្មឱ្យបានឆាប់រហ័ស[4767]។ ជាងនេះទៅទៀត **ខៀវ សំផន** ប្រហែលជាបានចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយនេះ តាមរយៈតួនាទីគាត់ជាសមាជិករបស់គណៈរដ្ឋមន្ត្រី[4768]។ **ខៀវ សំផន** បានគូសបញ្ជាក់ថា គោលនយោបាយនេះត្រូវបានសម្រេចក្នុងអង្គប្រជុំគណៈមជ្ឈិម[4769]។ **ខៀវ សំផន** បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការធ្វើសេចក្តីសម្រេច ដើម្បីកសាងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[4770]។

## ការគាំទ្រគោលនយោបាយនេះ

១១៦៦.**ខៀវ សំផន** បានថ្លែងសុន្ទរកថាជាច្រើនពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ដែលក្នុងនោះគាត់បានយល់ព្រមគាំទ្រគោលនយោបាយនេះដោយគាត់បានរាយការណ៍អំពីសមិទ្ធិផល និងការរីកចម្រើននៃការផលិតស្រូវ កៅស៊ូ និង អំបិល។ **ខៀវ សំផន** បានរៀបរាប់លម្អិតអំពីស្ថានភាពរស់នៅ និងស្ថានភាពការងារនៅតាមការដ្ឋាន និងសហករណ៍ និងបានលើកទឹកចិត្តអ្នកធ្វើការឱ្យខំប្រឹងធ្វើការឱ្យបានស្វាហាប់[4771]។ ក្នុងសុន្ទរកថាមួយរបស់គាត់នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ **ខៀវ សំផន** បានបញ្ជាក់ថា "*ប្រជាជនយើងកំពុងស្តារសេដ្ឋកិច្ច និងកសាងប្រទេសដោយទឹកចិត្តមោះមុតខ្ពស់នៅគ្រប់ទិសទី ទាំងក្រុង និងជនបទ។ មានការដ្ឋាននៅគ្រប់ទិសទី ដែលនៅទីនោះប្រជាជនយើងកំពុងខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីបង្កើត និងកែលម្អ រោងចក្រ អភិវឌ្ឍឧស្សាហកម្ម និងបង្កើនផលិតកម្មកសិកម្ម ព្រមទាំងកែប្រែមុខមាត់ជនបទ ... គ្រប់គ្នាធ្វើការតាមវាលស្រែ នេះដោយសារកម្មកររបស់យើងអនុវត្តប្រព័ន្ធការងារសមូហភាព*"[4772]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

**១១៦៧.**ក្នុងឱកាសមហាសន្និបាតនៅទីក្រុងភ្នំពេញថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ដើម្បីអបអរខួបលើកទី២ របស់របបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានថ្លែងកោតសរសើរដល់កម្មករកុមារដែលកំពុង "*កសាងទំនប់ទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយទឹក*"[4773]។ ដូចគ្នានេះដែរ នាឱកាសមហាសន្និបាតខួបលើកទី៣ គាត់បានសម្តែងសេចក្តីសាទរទៅកាន់ប្រជាជនដែលបាន "*យើងបំពេញបានតាមផែនការបក្សយើងនិងរដ្ឋាភិបាល*" នៅក្នុងវិស័យកសិកម្ម និងដំណាំស្រូវ[4774]។

<u>ការដឹងឮ និង ការអនុវត្តន៍គោលនយោបាយនេះ</u>

**១១៦៨.ខៀវ សំផន** បានដឹងអំពីមធ្យោបាយផ្សេងៗ ដែលគោលនយោបាយនេះត្រូវបានអនុវត្តន៍នៅទូទាំងប្រទេស ។ **ខៀវ សំផន** បានធ្វើដំណើរជាច្រើនទៅកាន់គ្រប់ទិសទីនៃផ្ទៃប្រទេស ដើម្បីត្រួតពិនិត្យការដ្ឋាន និងសហករណ៍។ គាត់បានបញ្ជាក់ថា គាត់បានអមដំណើរ [លុប] ទៅកាន់ភូមិភាគកណ្តាល និងពាយ័ព្យ និងបាន"*ឃើញដោយផ្ទាល់ភ្នែកនូវការខិតខំរបស់អង្គការនៅតាមជនបទ*"និងបានចុះធ្វើ "*ទស្សនកិច្ចសិក្សា*" មួយទៀតនៅភូមិភាគបស្ចិម និងភូមិភាគនិរតី [4775]។ ក្នុងអំឡុងទស្សនកិច្ចមួយជាមួយ [លុប] នៅចន្លោះថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ **ខៀវ សំផន** បានសង្កេតឃើញកម្មករចំនួនរាប់ម៉ឺននាក់ កំពុងធ្វើការងារប្រើកម្លាំងនៅតាមសហករណ៍[4776]។ អ្នកបើករថយន្តឱ្យ **ខៀវ សំផន** បានបញ្ជាក់ថា គាត់បានដឹក **ខៀវ សំផន** និង [លុប] ចុះទៅពិនិត្យតាមខេត្តនានាដូចជា សៀមរាប បាត់ដំបង កំពត និង កំពង់សោម[4777]។ សាក្សីម្នាក់ទៀតបានបញ្ជាក់ថា គាត់បានឃើញ **ខៀវ សំផន** អមដំណើរ[លុប] [លុប] "*ជាច្រើនដង*" ទៅសម្រាកលំហែរកាយនៅតាមខេត្តនានាដូចជា៖ កណ្តាល តាកែវ កំពង់ចាម និងតំបន់ជុំវិញភ្នំពេញ[4778]។

**១១៦៩.**សាក្សីនានាបានផ្តល់សក្ខីកម្មថា **ខៀវ សំផន** បានធ្វើដំណើរចុះពិនិត្យការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[4779] ការដ្ឋានទំនប់១មករា[4780] ព្រមទាំងការដ្ឋាននិងសហករណ៍[4781] មន្ទីរពេទ្យ[4782] ការដ្ឋានជួសជុលរថយន្ត[4783] រោងចក្រកាត់ដេរ[4784] និងឃ្លាំងនានា[4785]។ សាក្សីទាំងនេះបានបញ្ជាក់ថា គោលបំណងជាក់លាក់នៃការធ្វើដំណើរចុះពិនិត្យតាមទីកន្លែងរបស់ **ខៀវ សំផន** គឺដើម្បីសង្កេតមើលជាក់ស្តែងនូវស្ថានភាពការងារ និងរបបអាហារដែលកម្មករបានទទួល[4786]។ សាក្សីបានបញ្ជាក់ផងដែរថា **ខៀវ សំផន** បានថ្លែងសុន្ទរកថាជម្រុញឱ្យកម្មករខំប្រឹងធ្វើការឱ្យបានលឿន និង


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ស្លាប់ថែមទៀត[4787]។

**១១៧០.ខៀវ សំផន** ក៏បានដឹងផងដែរថា បក្សកុម្មុយនីស្តកម្ពុជាបាននាំចេញ ស្រូវ អង្ករ ខណៈដែលប្រជាជនកម្ពុជាកំពុងអត់ឃ្លាន ។ របាយការណ៍មួយដែល **វ៉ាន់ រិត** ផ្ញើទៅឱ្យ **ខៀវ សំផន** នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៨ បានរាយការណ៍ថា អំឡុងខែមករា ដល់ខែកញ្ញា ឆ្នាំ១៩៧៨ ស្រូវ និងអង្ករ ចំនួន ២៩.៧៥៨ តោន ត្រូវបាននាំចេញ[4788]។ ក្នុងអំឡុងពេលដូចគ្នានេះ ទស្សនាវដ្តីទង់បដិវត្តន៍បានរាយការណ៍ឱ្យសមាជិកបក្សទាំងអស់ដឹងថា មានការខ្វះខាតអង្ករ ហើយបានទទួលស្គាល់ដោយតុណ្ហីភាពថា មានភាពអត់ឃ្លាននៅក្នុងប្រទេស[4789]។

**១១៧១.** ការដឹងឮរបស់ **ខៀវ សំផន** អំពីការបង្កើតសហករណ៍ និងការដ្ឋាន ព្រមទាំងស្ថានភាពការងារនៅតាមទីកន្លែងទាំងនេះ ក៏ត្រូវបានបង្ហាញតាមរយៈលិខិតចំហនានា[4790] និងសៀវភៅទាំងឡាយរបស់គាត់[4791]។

## មន្ទីរសន្តិសុខ និង ទីកន្លែងសម្លាប់មនុស្ស

**១១៧២.** តាមរយៈតួនាទីនានារបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួមក្នុងការអប់រំ "សមាសភាពមិនល្អ" និង ការសម្លាប់ "ខ្មាំង" ទាំងក្នុង និងក្រៅជួរបក្ស។

### <u>ការចូលរួមបង្កើតគោលនយោបាយនេះ</u>

**១១៧៣.** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានចូលរួមចំណែកជាបន្តបន្ទាប់ក្នុងការបង្កើតគោលនយោបាយនេះ តាមរយៈការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬការទទួលបានកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍[4792]។ លើសពីនេះក្នុងនាមជាសមាជិកគណៈមជ្ឈិម **ខៀវ សំផន** ប្រហែលជាបានចូលរួមក្នុងការតាក់តែង និងការអនុវត្តន៍នូវសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលប្រគល់សិទ្ធិអំណាចកម្ទេចខ្មាំងខាងក្នុង និងខាងក្រៅឱ្យទៅគណៈភូមិភាគ និងគណៈតំបន់ស្វយ័ត[4793]។ **ខៀវ សំផន** ប្រហែលជាទទួលខុសត្រូវផងដែរ ចំពោះគោលនយោបាយនេះ ក្នុងនាមជាសមាជិកគណៈរដ្ឋមន្ត្រី[4794]។ លើសពីនេះទៀត នៅខែកក្កដា ឆ្នាំ១៩៧៥ **ខៀវ សំផន** បានចូលរួមក្នុងការជួបជុំកងទ័ពបដិវត្តន៍កម្ពុជាដែលបានពិភាក្សា អំពីគោល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605648



នយោបាយនេះ[4795]។ **ខៀវ សំផន** បានចូលរួមផងដែរក្នុងការបញ្ជាក់ថែមទៀតលើគោលនយោបាយនេះនៅក្នុងអង្គប្រជុំសន្និបាតរបស់សភាតំណាងប្រជាជននៅថ្ងៃទី១១ ដល់១៣ ខែមេសា ឆ្នាំ១៩៧៦ ដែលគាត់បានធ្វើជាអធិបតីក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ[4796]។

**១១៧៤.**សាក្សីមួយរូបលើកឡើងថា **ខៀវ សំផន** បានចេញសេចក្តីថ្លែងការណ៍មួយនៅខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៨ ដោយចេញបញ្ជាលើកលែងទោសដល់ជនទាំងឡាយណាដែលត្រូវបានចាប់ខ្លួន[4797]។ សេចក្តីថ្លែងការណ៍នេះ ធ្វើឡើងក្នុងបរិបទជាសេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សនាខែមិថុនា ឆ្នាំ១៩៧៨ ស្តីពី "*សេចក្តីណែនាំ របស់ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពី គោលនយោបាយ របស់បក្ស ចំពោះ អ្នកភាន់ច្រឡំ ចូល សេអ៊ីអា ឬធ្វើភ្នាក់ងារ យួន ឬចូល ការ សេ បេ ប្រឆាំងបក្ស បដិវត្ត ប្រជាជន និង កម្ពុជាប្រជាធិបតេយ្យ*"។ សេចក្តីណែនាំនេះ ហាក់ដូចជាពណ៌នាអំពីការកសាងខ្លួនឡើងវិញ ចំពោះអ្នកណាដែលបានចូល សេ.អ៊ី.អា កា.ហ្សេ.បេ និង វៀតណាម មុនខែកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែ ក៏បានដាក់បញ្ជាឲ្យបក្ស និងប្រជាជនកម្ពុជាកម្ចាត់ខ្សែបណ្តាញដែលបានបន្តប្រឆាំងបក្សចាប់ពីខែកក្កដា ឆ្នាំ១៩៧៨ ទៅ[4798]។ លើសពីនេះទៀត ក្នុងខែកញ្ញា ឆ្នាំ១៩៧៨ **ខៀវ សំផន** បានចូលរួមមហាសន្និបាតនៅទីក្រុងភ្នំពេញ ជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងនោះ **ប៉ុល ពត** បានថ្លែងចំពោះមុខអ្នកចូលរួមរាប់រយនាក់ថា កងទ័ព និងមូលដ្ឋានលែងមានសិទ្ធិចាប់ខ្លួនមនុស្សទៀតហើយ។ ចាប់ពីពេលនេះតទៅ ពួកគេមានតែសិទ្ធិសួរចម្លើយ និងធ្វើរបាយការណ៍ទៅឲ្យមជ្ឈិម[4799]។

**<u>ការគាំទ្រលើគោលនយោបាយនេះ</u>**

**១១៧៥.**ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានថ្លែងសុន្ទរកថា និងប្រកាសតាមវិទ្យុ ដោយផ្សព្វផ្សាយ និងគាំទ្រគោលនយោបាយនេះ ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ដោយបានអំពាវនាវឲ្យប្រជាជនវាយកម្ចាត់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា[4800]។

**១១៧៦.**នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ មានធ្វើមហាសន្និបាតរឭកខួបលើកទីពីរថ្ងៃ១៧ ខែមេសា **ខៀវ សំផន** បានលើកឡើងពីសមិទ្ធិផលយ៉ាងធំធេងរបស់បដិវត្តន៍ និងបានប្រកាសថា កងទ័ព និង "*ប្រជាជនទៅតាមសហករណ៍*" មិនអនុញ្ញាតិឲ្យមានសត្រូវមកពីក្រៅ ឬខាងក្នុង"*បំផ្លិចបំផ្លាញបដិវត្ត*" ឡើយ។ គាត់បានអំពាវនាវឲ្យការពារប្រទេសជាប្រចាំ "*តាមរយៈការទប់ស្កាត់ជាដាច់ខាត*

00605649



*នូវសត្រូវទាំងអស់ រារាំងពួកវាពីការឈ្លានពានពីការជ្រៀតជ្រែក ឬការធ្វើវិទ្ធង្សនាប្រឆាំងនឹងយើង។ យើងត្រូវបោសសំអាតសត្រូវក្នុងសមត្ថភាពយើងជាម្ចាស់ការណ៍លើស្ថានភាព ដើរតាមមាគ៌ាគោលនយោបាយក្នុងស្រុក គោលនយោបាយបរទេស និងគោលនយោបាយយោធារបស់អង្គការបដិវត្ត យើង...យើងត្រូវតែប្តេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច រក្សាស្មារតីបដិវត្តន៍ឥតងាករេ បន្តវាយប្រយុទ្ធ និងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា*"[4801]។ សុន្ទរកថានេះបានយល់ស្របយ៉ាងច្បាស់ ឱ្យមានការបោសសម្អាតភូមិភាគឧត្តរចាស់ និងឧត្តរថ្មី និងបោសសម្អាតអ្នកដែលពាក់ព័ន្ធនៅតាមក្រសួង និងមន្ទីរនានារបស់មជ្ឈិមបក្ស។ មិនតែប៉ុណ្ណោះ អត្ថបទសុន្ទរកថានេះក៏ត្រូវបានផ្សព្វផ្សាយ ក្នុងទស្សនាវដ្តីទង់បដិវត្តចេញក្នុងខែកក្កដា ឆ្នាំ១៩៧៧ ដែលបានអំពាវនាវឱ្យកម្ចាត់និគមជនវៀតណាមដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ព្រមទាំងខ្មាំងផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា[4802]។

**១១៧៧.** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ នៅឯកិច្ចប្រជុំមហាសន្និបាតរពួកខួបលើកទីបី **ខៀវ សំផន** បានចេញ បញ្ជាថា ភារកិច្ចទីមួយរបស់ប្រជាជន គឺត្រូវការពារប្រទេសប្រឆាំងនឹងពួកវៀតណាមដែលជា "*ចារកម្ម បង្កើតក្រុម និងប៉ុនប៉ងធ្វើរដ្ឋប្រហារ*"[4803] នៅកម្ពុជាតាមរយៈ"*ការអនុវត្តបានត្រឹមត្រូវតាមមាគ៌ាបក្ស ទាំងកិច្ចការពារផ្នែកខាងក្រៅនិងខាងក្នុង*"[4804]។ **ខៀវ សំផន** បានលើកឡើងថា "*សកម្មភាពប្រចាំថ្ងៃរបស់យើងដើម្បីលុបបំបាត់ពួកខ្មាំងសត្រូវឈ្លានពានគ្រប់ប្រភេទឱ្យបានជាស្ថាពរ និងជារៀងរហូតពីលើទឹកដីកម្ពុជា ជាពិសេសពួកសត្រូវឈ្លានពាន វៀតណាម ពួកវាតទីនិយម និងពួកលេបទឹកដី*"[4805]។ សុន្ទរកថានេះបង្ហាញការឱ្យឃើញការយល់ស្របជាមួយបោសសម្អាតដែលបានធ្វើកាលពីពេលមុន និងការបោសសម្អាតដែលកំពុងបន្តនៅទូទាំងប្រទេស ជាពិសេសនៅភូមិភាគបូព៌ា។ លើសពីនេះទៀត ចំណុចនេះត្រូវបានគាំទ្រដោយសុន្ទរកថាមួយទៀតរបស់ ប៉ុល ពត ដែលបានចេញផ្សាយក្នុងខែមេសា ឆ្នាំ១៩៧៨ នៅទស្សនាវដ្តីទង់បដិវត្តដែលបានរៀបរាប់ផ្តោតជាសំខាន់នូវការបោសសម្អាតខ្សែក្បត់ និងសមាសភាពមិនល្អនៅក្នុងជួរបក្ស ជាពិសេសនៅតាមក្រសួង និងមន្ទីរ[4806]។

**ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះ**

**១១៧៨.**បើទោះជាគ្មានភស្តុតាងបញ្ជាក់ថា **ខៀវ សំផន** ពិតជាបានចុះពិនិត្យមន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់ដោយផ្ទាល់ក៏ដោយ[4807] មានភស្តុតាងបង្ហាញថា **ខៀវ សំផន** បានដឹង និងបានជាប់ពាក់ព័ន្ធក្នុងការ

កំណត់អត្តសញ្ញាណ ការចាប់ខ្លួនខ្មាំងពិតប្រាកដនិងខ្មាំងដែលគេបានសន្មតទាំងក្នុង និងទាំងក្រៅជួរបក្សកុម្មុយនីស្តនៅទូទាំងប្រទេសកម្ពុជា។

**១១៧៩.** **ខៀវ សំផន** បញ្ជាក់ថា គាត់បានដឹងឮពីការចាប់ និងការឃុំខ្លួននានានៅខេត្តព្រះវិហារ ដោយសមាជិកគ្រួសាររបស់ភរិយាគាត់ម្នាក់ត្រូវបានចាប់ខ្លួន[4808]។ នៅពេលការចាប់ខ្លួនទាំងនោះត្រូវបានរាយការណ៍ឲ្យ **ខៀវ សំផន** ហើយពួកគេក៏ត្រូវបានដោះលែង[4809]។ **ឌុច** អះអាងថា កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្តរត្រូវបានចាប់ខ្លួន បន្ទាប់ពីគាត់បានចេញបញ្ជាឲ្យចាប់ខ្លួនសាច់ញាតិ **ខៀវ សំផន**[4810]។ សាក្សីមួយរូបលើកឡើងថា គាត់តែងតែបានផ្ញើទូរលេខជាទៀងទាត់ពីតំបន់១០៣ ទៅឲ្យ ខៀវ សំផន រាយការណ៍ពីការចាប់ និងឃុំខ្លួននានានៅក្នុងខេត្តព្រះវិហារ ប៉ុន្តែគាត់មិនដែលទទួលបានការឆ្លើយតបមកវិញទេ[4811] ។

**១១៨០.** ទាក់ទងនឹងការសម្លាប់កងទ័ពវៀតណាម នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៧ **ខៀវ សំផន** បានចេញសេចក្តីថ្លែងការណ៍មួយក្នុងនាមរដ្ឋាភិបាល ទៅកងទ័ព និងប្រជាជន ដោយផ្តល់ព័ត៌មានលម្អិតពីសកម្មភាពឈ្លានពានរបស់វៀតណាមមកលើប្រទេសកម្ពុជា[4812] និងបានប្រកាសថា កងទ័ពបដិវត្តន៍កម្ពុជា "*បានកម្ចាត់ពួកវៀតណាមចោលដោយជោគជ័យតាំងពីឆ្នាំ១៩៧៥*"[4813]។ **ខៀវ សំផន** បានអំពាវនាវឲ្យមានសកម្មភាពបន្ថែមទៀត ដោយគាត់បានលើកឡើងថា "*គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សភាតំណាងប្រជាជនកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ អំពាវនាវដល់បក្សទាំងមូល ដល់កងទ័ពបដិវត្តន៍ទាំងអស់ និងប្រជាជនទូទាំងប្រទេសឲ្យ...ទប់ស្កាត់ខ្មាំងឈ្លានពានវៀតណាមមិនឲ្យ វាតទីនិយម និងលេបយកទឹកដីរបស់យើង។ កងទ័ពបដិវត្តន៍កម្ពុជា និងប្រជាជនកម្ពុជាទាំងអស់ក្រោមការដឹកនាំរបស់ បក្សកុម្មុយនីស្តកម្ពុជា ពិតជាអាចរុញច្រាន ពួកខ្មាំងវៀតណាមឈ្លានពានវាតទីនិយម ដោយជោគជ័យយ៉ាងពិតប្រាកដចេញពីប្រទេសកម្ពុជា*"[4814]។ **ខៀវ សំផន** បានបកស្រាយថា គោលនយោបាយនៃជម្លោះប្រដាប់អាវុធរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបាន"*ប្រកាន់ខ្ជាប់យ៉ាងរឹងមាំក្នុងការធ្វើទាំងយុទ្ធសាស្ត្រសង្គ្រាមទ័ពព្រៃ និងសង្គ្រាមដោយចំពោះ ក្នុងការកម្ទេចកងកម្លាំងខ្មាំង*"[4815]។ **ខៀវ សំផន** បានផ្តល់ស្ថិតិចំនួនជនជាតិវៀតណាមដែលត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៧៥, ១៩៧៦ និង១៩៧៧[4816]។

**១១៨១.** ដូចមានរៀបរាប់នៅក្នុងផ្នែកស្តីពីអង្គហេតុ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម គោលនយោបាយ ប.ក.ក ចំពោះអំពើអសីលធម៌ គឺត្រូវដាក់ទោសលើអ្នកដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ ពុំមាន

ភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា **ខៀវ សំផន** បានដឹងថា អ្នកដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈទាំងនោះមិនត្រូវបានផ្តន្ទាទោស នោះឡើយ។

## ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះនៅមន្ទីរ ស-២១

១១៨២.ខៀវ សំផន លើកឡើងថា គាត់មិនបានដឹងពីអត្ថិភាពនៃមន្ទីរ ស-២១ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ[4817] ហើយរូបគាត់ហាក់ដូចជាមិនដែលបានទៅមន្ទីរ ស-២១ ឡើយ[4818]។ **ខៀវ សំផន** ក៏អះអាងផងដែរថា គាត់មិនដែលបានជួប ឌុច ទេ ក្នុងអំឡុងរបបកម្ពុជាប្រជាធិតេយ្យ[4819]។ ប៉ុន្តែ ឌុច ផ្តល់សក្ខីកម្មក្នុងពេលសួរយកចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត និងនៅក្នុងសវនាការជាច្រើនលើកថា គាត់បានចូលរួមប្រជុំជាមួយ **ខៀវ សំផន** នៅព្រឹកថ្ងៃទី០៦ ខែមករា ឆ្នាំ ១៩៧៩[4820]។ ឌុច និយាយថា ខៀវ សំផន បានផ្តល់ការណែនាំនានាឱ្យគាត់ ពាក់ព័ន្ធនឹងការចូលមកដល់របស់កងកម្លាំងវៀតណាមនៅភ្នំពេញ ដោយបានបញ្ជាក់ថា បុគ្គលិកមន្ទីរ ស-២១ ត្រូវ *"រក្សាភាពស្ងប់ស្ងាត់ កុំភ្ញាក់ផ្អើល"*[4821]។ ឌុច និយាយទៀតថា គាត់បានទទួល ហើយបានផ្សព្វផ្សាយការណែនាំទាំងនោះដល់បុគ្គលិកមន្ទីរ ស-២១[4822]។

១១៨៣. **ឌុច** ក៏បញ្ជាក់ផងដែរថា គណៈអចិន្ត្រៃយ៍បានដឹងថា ការធ្វើទារុណកម្មត្រូវបានគេប្រើនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ហើយថា គ្រប់មនុស្សដែលបញ្ជូនមកមន្ទីរ ស-២១ ត្រូវតែសម្លាប់[4823]។ ក្នុងនាមជាអ្នកដែលបានចូលរួមប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់ វាទំនងជាថា **ខៀវ សំផន** បានដឹងអំពីការធ្វើទារុណកម្ម និងការសម្លាប់នៅមន្ទីរ ស-២១។ មានការបង្ហាញច្បាស់ថា **ខៀវ សំផន** បានឮចម្លើយសារភាពអ្នកទោសជនជាតិវៀតណាម ដែលត្រូវបានថតសម្លេងទុកសម្រាប់គោលបំណងដើម្បីឃោសនានៅមន្ទីរ ស-២១ និងផ្សព្វផ្សាយតាមវិទ្យុ[4824] ។

## ការពាក់ព័ន្ធជាមួយមន្ទីរ ស-២១ តាមរយៈការចាប់ខ្លួន និងការសម្លាប់

១១៨៤.ខៀវ សំផន និយាយថា គាត់មិនដែលបានចូលរួមក្នុងអង្គប្រជុំណាមួយ ដែលបានសម្រេចពីការបោសសម្អាត ឬការចាប់ខ្លួននោះទេ[4825] ហើយក៏មិនបានដឹងពីវិសាលភាពនៃការចាប់ខ្លួន មុនឆ្នាំ ១៩៧៩ ដែរ[4826]។ **ខៀវ សំផន** និយាយថា ប៉ុល ពត បានឱ្យគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធនឹងការសម្រេចចាប់ខ្លួនកម្មាភិបាលសំខាន់ៗនៅក្នុងបក្សនោះទេ[4827]។ ប៉ុន្តែ **ខៀវ សំផន** ហាក់ដូចជាបានដឹង និង

ពាក់ព័ន្ធនឹងការបោសសម្អាតមេដឹកនាំជាន់ខ្ពស់នានាក្នុងបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងមនុស្ស នៅក្នុងមន្ទីរ៨៧០ នៅក្នុងក្រសួងពាណិជ្ជកម្ម និងមន្ទីរដែលចំណុះឱ្យក្រសួងនេះ។

**១១៨៥.**ឌុច ក៏និយាយផងដែរថា **ខៀវ សំផន** គឺជាបុគ្គលមួយរូបក្នុងចំណោមបុគ្គលទាំងឯប់បីរូប ដែល "*មានសិទ្ធិពេញលេញ*" ក្នុងការសម្រេចអំពីការកម្ទេចខ្មាំងទាំងក្នុង និងក្រៅជួរ យោងតាមសេចក្តីសម្រេចដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[4828]។ ចំពោះមេដឹកនាំនានារបស់បក្សកុម្មុយនីស្តកម្ពុជា **ឌុច** ពន្យល់ប្រាប់ថា សេចក្តីសម្រេចដើម្បីចាប់ខ្លួនសមាជិកគណៈមជ្ឈិម ឬ កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវតែធ្វើការសម្រេចរួមគ្នាដោយគណៈអចិន្ត្រៃយ៍[4829]។ ដោយសារគាត់មានវត្តមាន និងបានចូលរួមជាទៀងទាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ **ខៀវ សំផន** ច្បាស់ជាបានដឹង និងបានចូលរួមនៅក្នុងការចាប់ខ្លួន និងការសម្លាប់ដែលកើតមានក្រោយមក ឬការធ្វើអត្តឃាតរបស់សមាជិកគណៈអចិន្ត្រៃយ៍ លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត និងរដ្ឋមន្ត្រី។ ម្យ៉ាងវិញទៀត **ខៀវ សំផន** ទទួលស្គាល់ថា គាត់បានដឹងពីការចាប់ខ្លួន និងការបោសសម្អាតមេដឹកនាំជាន់ខ្ពស់ ហើយគាត់បានផ្តល់យុត្តិកម្មចំពោះការបោសសម្អាតនានា នៅក្នុងជួររបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ **ខៀវ សំផន** លើកឡើងនៅក្នុងបទសម្ភាសន៍មួយនាឆ្នាំ១៩៨០ ថា មាន ភ្នាក់ងារវៀតណាមបង្កប់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជាជាច្រើន "*វាមានទាទីសំខាន់វិញ វាប្រើនាទីសំខាន់ ហើយអ្នកខ្លះកាន់ភាគអំណាចសំខាន់ៗ*"[4830]។ **ខៀវ សំផន** បន្ថែមទៀតថា នៅក្នុងឆ្នាំ១៩៧៥ ប្រហែលជាពាក់កណ្តាលនៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍ និង គណៈមជ្ឈិមគឺជា ភ្នាក់ងាររបស់វៀតណាម[4831]។ នៅក្នុងបទសម្ភាសន៍មួយនៅឆ្នាំ២០០៦ **ខៀវ សំផន** បានលើកឡើងថា វន វ៉េត និង សោ ភឹម ត្រូវចាប់ខ្លួនដោយសារតែពួកគេជាភ្នាក់ងារយួន[4832]។ **ខៀវ សំផន** លើកឡើងថា ការចាប់ខ្លួនរបស់កម្មាភិបាលភូមិភាគបូព៌ា"*ដែលនាំឱ្យមានការបោសសំអាតផ្ទៃក្នុងពីមួយទៅមួយជាប់រដឹក*"[4833]។

**១១៨៦.**លើសពីនេះ នៅមន្ទីរនយោបាយ ៨៧០ ជាទីដែល**ខៀវ សំផន** ធ្វើការ មន្ទីរ៨៧០ "*ទទួលខុសត្រូវធ្វើការស៊ើបអង្កេតលើកម្មាភិបាលដែលគេសង្ស័យ សម្រាប់គណៈកម្មាធិការអចិន្ត្រៃយ៍*"[4834]។ ទោះបីជា **ខៀវ សំផន** បានប្រកែកថា គាត់មិនបានជំនួស **ខឿន** ជាប្រធានមន្ទីរនយោបាយ៨៧០ ក៏ដោយ[4835] ក៏ **ខៀវ សំផន** ទទួលស្គាល់ថា គាត់ជាប់ពាក់ព័ន្ធនឹងការពិនិត្យ និងការស៊ើបអង្កេតការចោទប្រកាន់ដែលថា កម្មាភិបាលចាស់ម្នាក់នៅភូមិភាគបស្ចឹមជាគិញវៀតណាម។ **ខៀវ សំផន** អះអាងដែរថា គេបានទាញសេចក្តីសន្និដ្ឋានថា វាជាការចោទប្រកាន់ក្លែងក្លាយ ដែលធ្វើឡើង

ដោយបុគ្គល ដែលតាមការពិតជាគិញវៀតណាមខ្លួនឯង[4836]។ នេះប្រហែលជាការបំភាន់មួយដល់អនុលេខាភូមិភាគបស្ចិមឈ្មោះ ផល ដែល ជូ ជេត ហៅ ស៊ី ជាលេខាភូមិភាគ បានព្យាយាម *"ដកអំណាច"* ប៉ុន្តែ ឈ្មោះ ផល នេះត្រូវបានទទួលការទុកចិត្តពី ប៉ុល ពត និង នួន ជា ។ ផ្ទុយទៅវិញ ជាលទ្ធផល ស៊ី ត្រូវបានចាប់ខ្លួនក្នុងខែមីនា ឬ ខែមេសា ឆ្នាំ១៩៧៨[4837]។ ឌុច ឱ្យដឹងថា ការចាប់ខ្លួននេះផ្អែកលើសេចក្ដីសម្រេច ដែលបានធ្វើនៅក្នុងកិច្ចប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ ដែលក្នុងនោះ ប៉ុល ពត បានអញ្ជើញ **ខៀវ សំផន** ជាពិសេស ដើម្បីណែនាំគាត់អំពីដំណើរការបោសសម្អាត[4838]។ ឌុច បានផ្ដល់សក្ខីកម្មក្នុងឆ្នាំ១៩៩៩ ហើយក្រោយមកគាត់បញ្ជាក់បន្ថែមទៀត នៅក្នុងការសួរចម្លើយចំនួនពីរដងជាមួយនឹងសហចៅក្រមស៊ើបអង្កេតថា **ឈឹម សំអោក** ហៅ ប៉ង់ បានប្រាប់គាត់ថា **ខៀវ សំផន** បានចូលរួមក្នុងអង្គប្រជុំមួយជាមួយគណៈអចិន្ត្រៃយ៍ដែលជជែកពីការចាប់ខ្លួន ស៊ី[4839]។

**១១៨៧.** តាមសេចក្ដីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ស្ដីពី *"សិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរបក្ស"* មន្ទីរនយោបាយ៨៧០ ដែលកាលនោះដឹកនាំដោយ **ខៀវ** មានសិទ្ធិក្នុងការអនុវត្តន៍អំណាចនេះនៅតាមអង្គភាពផ្សេងៗ *"ជុំវិញមន្ទីរមជ្ឈិម"*[4840] ក្នុងក្របខណ្ឌនៃអំណាចដែលធំជាងមុនរបស់មន្ទីរនេះក្នុងការបោសសម្អាតនៅតាមអង្គភាពដែលពាក់ព័ន្ធ[4841]។ ឌុច រៀបរាប់អំពីជនរងគ្រោះម្នាក់ឈ្មោះ **អោគ ឆាយ** ហៅ **ទូច** *"គឺជាលេខានៃមន្ទីរ៨៧០ ហើយ យើងអាចនិយាយថា គាត់ជាស្មៀនរបស់ ប៉ុល ពត"*[4842]។ ទោះបីជា ឌុច ជឿថាការសម្លាប់នេះត្រូវបានបញ្ជាដោយ ប៉ុល ពត នួន ជា និង សុន សេន[4843] ក៏ដោយ ក៏គាត់អះអាងថា **ខៀវ សំផន** អាចត្រូវបានសន្មតថាបានដឹងអំពីរឿងនេះ[4844]។

**១១៨៨.** មានការបង្ហាញផងដែរថា **ខៀវ សំផន** បានចូលរួមក្នុងការចាប់ខ្លួន វន វេត នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨[4845] ដែលបានកើតឡើង នៅមន្ទីរគណៈអចិន្ត្រៃយ៍ (មន្ទីរ៨៧០)[4846] គឺមន្ទីរនេះហើយដែលក្រោយមក **ខៀវ សំផន** ជាកម្មាភិបាលដឹកនាំ។

**១១៨៩.** ទាក់ទងនឹងអង្គភាពចំណុះមន្ទីរ៨៧០ មានមនុស្សប្រហែល ២០៩ នាក់ ត្រូវបានចាប់ខ្លួននៅមន្ទីរនយោបាយ៨៧០ និងមន្ទីរ ស-៧១ ហើយបានបញ្ជូនទៅមន្ទីរ ស-២១ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨ ដូចដែលបានកំណត់នៅក្នុងការកត់សម្គាល់អំពីអង្គហេតុពាក់ព័ន្ធនឹងមន្ទីរ ស-២១។ សាក្សីមួយរូបដែលធ្លាប់បានបម្រើការនៅអង្គភាពមួយចំណុះមន្ទីរ៨៧០ និយាយថា **ខៀវ សំផន** បានលើកពីបញ្ហា

00605654



ការចាប់ខ្លួន ប៉ង់ នៅក្នុងវគ្គរៀនសូត្រមួយ។ គាត់បន្ថែមថា **ខៀវ សំផន** បាននិយាយទៅកាន់ក្រុមអ្នករៀនសូត្រថា ប៉ង់ *"ត្រូវបានគេចាប់យកទៅបាត់ហើយ ដោយសារតែគាត់ក្បត់ចូលដៃចូលជើងជាមួយយួន"*[4847]។

**១១៩០.** ចំពោះក្រសួងពាណិជ្ជកម្ម មានមនុស្សប្រមាណ ៤៨២ នាក់ ត្រូវបានចាប់ខ្លួនរួចបញ្ជូនទៅមន្ទីរស-២១ ក្នុងអំឡុងពីឆ្នាំ១៩៧៥-១៩៧៩ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកពាក់ព័ន្ធនឹងមន្ទីរ ស-២១។ សាក្សីមួយរូបដែលធ្លាប់ធ្វើការនៅក្រសួងពាណិជ្ជកម្ម និយាយថា ជាងពាក់កណ្តាលនៃមនុស្សនៅក្នុងអង្គភាពរបស់គាត់ ត្រូវគេបោសសម្អាតក្រោមលេសដែលគេប្រាប់ថា ត្រូវគេហៅទៅរៀនសូត្រ[4848]។ សាក្សីរូបនោះនិយាយថា ប្រហែលជាមួយអាទិត្យ មុនពេលដែលវៀតណាមចូលមកដល់ភ្នំពេញក្នុងខែមករា ឆ្នាំ១៩៧៩ **ខៀវ សំផន** និង **នួន ជា** បានមកកាន់ក្រសួងពាណិជ្ជកម្ម ហើយបានប្រាប់ដល់បុគ្គលិកថា៖ *"ពេលនេះយើងផ្អាកការហៅទៅរៀនសូត្រសិន ហើយយើងរួមគ្នាវាយខ្មាំង"*[4849]។ សាក្សីរូបនេះសន្និដ្ឋានថា បុគ្គលិករបស់ក្រសួងពាណិជ្ជកម្មលែងត្រូវបានបោសសម្អាតទៀតហើយ[4850]។ នៅពេលដែលត្រូវគេសាកសួរពីការបោសសម្អាតនៅក្នុងអង្គភាពពាណិជ្ជកម្ម ឌុច និយាយថា *"ខៀវ សំផន ត្រូវតែបានដឹងពីដំណើរនៃការបោសសម្អាត ពីព្រោះគ្រប់ៗគ្នាសុទ្ធតែបានដឹង"* ។ ករណី **យុគ ជួង** ហៅ ជន ជាសមាជិកគណៈឧស្សាហកម្ម ឌុច ក៏លើកឡើងផងដែរថា **ខៀវ សំផន** *"ទៅថ្នាក់លើ ហើយ ដែលថ្នាក់លើនេះ ត្រូវយកវាទៅឱ្យ **ខៀវ សំផន** ដើម្បីឱ្យគាត់ដឹងរឿង ហើយ ផ្តល់យោបល់លើការចាប់ខ្លួនអ្នកផ្សេងទៀត ដែលមានឆ្លើយដាក់នៅក្នុងចម្លើយសារភាពនោះ"*[4851]។

## ក្រុមមនុស្សជាក់លាក់ផ្សេងៗ

**១១៩១.** តាមរយៈតួនាទីផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួមនៅក្នុងសកម្មភាពកំណត់មុខសញ្ញាក្រុមជាក់លាក់ផ្សេងៗ ។

**១១៩២.** ក្នុងនាមជាសមាជិកគណៈមជ្ឈិម **ខៀវ សំផន** អាចបានចូលរួមនៅក្នុងការបង្កើតឯកសារបក្សនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា មាននៅសល់តែវណ្ណៈកម្មករ និងកសិករប៉ុណ្ណោះ ហើយថា វណ្ណៈផ្សេងទៀតត្រូវបានរំលាយចូលទៅក្នុងវណ្ណៈទាំងពីរនេះ។ ដូច្នេះ នៅចុងឆ្នាំ១៩៧៥ **ខៀវ សំផន** បានពន្យល់ទៅកាន់និស្សិតមួយក្រុមដែលវិលត្រឡប់មកប្រទេសកម្ពុជាថា ពេលនេះមាន

វណ្ណៈតែពីរប៉ុណ្ណោះនៅកម្ពុជាគឺ វណ្ណៈកម្មករ និង កសិករ[4852]។ **ខៀវ សំផន** បានលើកឡើងអំពីទ្រឹស្តីនេះ ក្នុងអំឡុងខែធ្នូ ឆ្នាំ១៩៧៥ នៅក្នុងសមាជជាតិដែលពេលនោះ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តជាផ្លូវការ[4853]។ **ខៀវ សំផន** បានថ្លែងខ្លឹមសារជាគន្លឹះនៅក្នុងសុន្ទរកថាចំពោះមុខកម្មករ និងកសិករ ដែលជាអ្នកតំណាងរបស់វណ្ណៈទាំងពីរនេះ ដោយបានសង្កត់ធ្ងន់ថា រដ្ឋធម្មនុញ្ញបានធានាថា ប្រទេសជាតិត្រូវបានដឹកនាំដោយ *"កម្មករ និងកសិករជាអ្នកមើលការខុសត្រូវ"* លើប្រព័ន្ធការងារសមូហភាពក្នុងវិស័យកសិកម្ម និងវិស័យផ្សេងទៀត[4854]។ **ខៀវ សំផន** បានយល់ស្របចំពោះការហាមឃាត់នៅក្នុងរដ្ឋធម្មនុញ្ញប្រឆាំងនឹងសាសនា ដែលត្រូវបានចាត់ទុកថាជាប្រតិកិរិយា ដោយបានអធិប្បាយថា សត្រូវរបស់ប្រទេសជាតិកំពុងព្យាយាមប្រើប្រាស់ *"សាសនាជាខែល"* ដើម្បីប្រឆាំងនឹងប្រទេសជាតិ ហើយត្រូវតែប្រឆាំងតាមគ្រប់មធ្យោបាយ *"ទោះបីជាត្រូវលះបង់អ្វីក៏ដោយ"*[4855]។ ដូច្នេះ **ខៀវ សំផន** បានគាំទ្រជាទូទៅចំពោះការអនុវត្តន៍គោលនយោបាយនេះ និងបានចូលរួមអនុវត្តផងដែរ។ **ខៀវ សំផន** បានធ្វើសេចក្តីថ្លែងការណ៍ទាំងនេះ ស្របពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានអះអាងចេតនារបស់ខ្លួន ក្នុងការលុបបំបាត់រាល់ជនជាតិភាគតិច និងក្រុមផ្សេងៗ។

## <u>ការប្រព្រឹត្តលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ</u>

១១៩៣. ដូចដែលបានរៀបរាប់ខាងលើ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ **ខៀវ សំផន** បានចេញសេចក្តីប្រកាសព័ត៌មានមួយក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា និងក្នុងឋានៈរបស់គាត់ ជាប្រធានសមាជជាតិនៃរណសិរ្សនេះ។ **ខៀវ សំផន** បានរាយការណ៍ថា រណសិរ្សរួបរួមជាតិកម្ពុជា បានធ្វើសមាជរបស់ខ្លួនក្នុងរយៈពេលពីរថ្ងៃ ហើយបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីបញ្ហាផ្សេងៗមួយចំនួន។ **ខៀវ សំផន** លើកឡើងពី*"ពួកក្បត់ទាំង៧នាក់នៅក្នុងទីក្រុងភ្នំពេញ...លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង Sosthene Fernandez"* ដែលត្រូវសម្លាប់ចោល[4856]។ ក្នុងចំណោមឈ្មោះទាំងប្រាំពីរនាក់ខាងលើ មានតែ ឡុង បូរ៉េត និង សិរិមតៈ ទេដែលនៅក្នុងប្រទេស[4857]។ សិរិមតៈ បានប៉ុនប៉ងរត់ភៀសខ្លួនក្នុងស្ថានទូតបារាំង ប៉ុន្តែក្រោយមកត្រូវបានប្រគល់ទៅឱ្យ ប.ក.ក[4858]។ អ្នកទាំងពីរត្រូវបាន ប.ក.ក សម្លាប់[4859] ហើយ **អៀង សារី** ក៏បានអះអាងដូចគ្នានេះដែរ[4860]។ **ខៀវ សំផន** បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនផ្សេងៗទៀត អំពី *"ក្រុមបនក្បត់ លន់ នល់"*[4861]។

ការប្រព្រឹត្តលើពុទ្ធសាសនិក

១១៩៤. ក្រុមនេះត្រូវបានកំណត់ជាមុខសញ្ញាជាក់លាក់ ខណៈដែល **ខៀវ សំផន** គឺជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់បានចូលរួមប្រជុំជាទៀងទាត់ក្នុងគណៈអចិន្ត្រៃយ៍។ តាមរយៈតួនាទីដ៏ច្រើនរបស់គាត់ក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួម និងជួយក្នុងការអនុវត្តន៍គោលនយោបាយនេះ ជាពិសេស តាមរយៈសុន្ទរកថារបស់គាត់ស្តីពីការបង្កើតសង្គមដែលមិនជឿសាសនា និងមានលក្ខណៈតែមួយ ដោយគ្មានការបែងចែកវណ្ណៈ និងស្តីពីការលុបបំបាត់ភាពខុសគ្នារវាងជាតិពន្ធុ, ជាតិ, សាសនា, ពូជសាសន៍, នយោបាយ, វប្បធម៌ និង វណ្ណៈ។

ការប្រព្រឹត្តលើជនជាតិចាម

១១៩៥. ក្រុមនេះត្រូវបានកំណត់ជាមុខសញ្ញាជាក់លាក់ នៅពេលដែល **ខៀវ សំផន** ជាសមាជិកជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ហើយគាត់បានចូលរួមប្រជុំជាទៀងទាត់ក្នុងគណៈអចិន្ត្រៃយ៍។ តាមរយៈតួនាទីដ៏ច្រើនក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួម និងជួយក្នុងការអនុវត្តន៍គោលនយោបាយនេះ ជាពិសេស តាមរយៈសុន្ទរកថារបស់គាត់ ស្តីពីការបង្កើតសង្គមដែលមិនជឿសាសនា និងមានលក្ខណៈតែមួយ ដោយគ្មានការបែងចែកវណ្ណៈ និងស្តីពីការលុបបំបាត់ភាពខុសគ្នារវាងជាតិពន្ធុ, ជាតិ, សាសនា, ពូជសាសន៍, នយោបាយ, វប្បធម៌ និង វណ្ណៈ។

ការប្រព្រឹត្តលើជនជាតិវៀតណាម

១១៩៦. ក្នុងពេលមានជម្លោះ រដ្ឋមានកាតព្វកិច្ចការពារបូរណភាពទឹកដីរបស់ខ្លួន ប៉ុន្តែ **ខៀវ សំផន** បែរជាធ្វើការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជនកម្ពុជា ដោយបានលើកឡើងអំពីការគំរាមកំហែងគាបសង្កត់ពីវៀតណាម ហើយព័ត៌មានទាំងនោះធ្វើឡើងដើម្បីបង្កើតឱ្យមានការភ័ន្តច្រឡំ ការភ័យខ្លាច និងជំរុញឱ្យមានការស្អប់ខ្ពើមប្រជាជនវៀតណាម ឬ នាំឱ្យប្រជាជនចូលរួមកំណត់មុខសញ្ញាលើក្រុមនេះ។ **ខៀវ សំផន** បានថ្លែងសុន្ទរកថាជាច្រើន និងផ្សព្វផ្សាយតាមវិទ្យុដោយចាត់ទុកវៀតណាមថាជា "*ខ្មាំងសត្រូវឈ្លានពាន ពួកវាតទីនិយម និង ពួកនិយមលេបទឹកដី*"[4862] ដែល "*មានមហិច្ឆិតាលេបទឹកដីកម្ពុជា ស្របតាមផែនការសហព័ន្ធឥណ្ឌូចិនរបស់វា*"[4863]។ **ខៀវ សំផន** បានអំពាវនាវឱ្យប្រជាជនប្រយុទ្ធជាមួយពួកវៀតណាម[4864]។

១១៩៧.ជាពិសេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ក្នុងអំឡុងកិច្ចប្រជុំមហាសន្និបាតរឭកខួបជ័យជម្នះលើកទីបី **ខៀវ សំផន** បានបញ្ជាក់ថា កិច្ចការទីមួយរបស់ប្រជាជនគឺត្រូវការពារប្រទេសប្រឆាំងនឹងពួកវៀតណាម ដែលជា *"ចារកម្ម បង្កើតក្រុម និងប៉ុនប៉ងធ្វើរដ្ឋប្រហារ"*[4865] នៅកម្ពុជា តាមរយៈការ *"ការអនុវត្តឱ្យបានត្រឹមត្រូវតាមមាគ៌ាបក្ស ទាំងកិច្ចការពារផ្នែកខាងក្រៅ និងខាងក្នុង"* [4866]។ **ខៀវ សំផន** បានលើកឡើងថា៖ *"សកម្មភាពប្រចាំថ្ងៃរបស់យើងគឺត្រូវលុបបំបាត់ ពួកខ្មាំងសត្រូវឈ្លានពានគ្រប់ប្រភេទឱ្យបានជាស្ថាពរ និង ជារៀងរហូតពីលើទឹកដីកម្ពុជា ជាពិសេស អំពើឧក្រិដ្ឋនៃពួកឈ្លានពានវៀតណាម ពួកវាតទីនិយម និងពួកលេបទឹកដី"*[4867]។ សុន្ទរកថានេះ បានធ្វើនៅក្នុងបរិបទនៃការសម្លាប់រង្គាលលើប្រជាជនវៀតណាមក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង និងនៅកន្លែងផ្សេងៗនៃប្រទេសកម្ពុជា ដូចបានរៀបរាប់នៅក្នុងផ្នែកទាក់ទងទៅនឹងការកត់សម្គាល់អំពីអង្គហេតុនៃដីកាដំណោះស្រាយនេះ ។

១១៩៨.ដូចមានរៀបរាប់ក្នុងផ្នែកស្តីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" និងផ្នែកស្តីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" នៃដីកាដំណោះស្រាយនេះ *ទស្សនាវដ្តីយុវជន* និង*ទង់បដិវត្ត* ដែល **ខៀវ សំផន** អាចបានអាន ត្រូវបានមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ក្នុងការញុះញង់ឱ្យស្អប់ខ្ពើមជនជាតិវៀតណាម ដើម្បីបញ្ជាឱ្យដេញជនជាតិវៀតណាមចេញពីកម្ពុជា ដើម្បីបញ្ជាឱ្យ *"ធ្វើវិស្សុទ្ធកម្ម"* និង*"បោសសំអាត"* លើប្រជាជនវៀតណាម ព្រមទាំងអ្នកពាក់ព័ន្ធនឹងជនជាតិវៀតណាមទាំងអស់ និង ដើម្បីបញ្ជាឱ្យសម្លាប់ជនស៊ីវិលវៀតណាមដែលមាននៅក្នុងប្រទេសកម្ពុជាចាប់ពីខែមេសា ឆ្នាំ១៩៧៧។

## ការរៀបអាពាហ៍ពិពាហ៍

១១៩៩.តាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួមក្នុងការចេញបទប្បញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។ ការអនុវត្តប្រព័ន្ធរៀបអាពាហ៍ពិពាហ៍ ដែលមានការរៀបចំដោយបក្ស ត្រូវបានផ្សព្វផ្សាយតាមរយៈការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា[4868] ដែល **ខៀវ សំផន** អាចបានអាន។ លើសពីនេះទៀត មានភស្តុតាងបង្ហាញថា ការរៀបការដោយបង្ខំបានកើតឡើងនៅតាមអង្គភាពនានាក្រោមចំណុះក្រសួងពាណិជ្ជកម្ម[4869]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

## ការដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ

១២០០.យ៉ាងហោចណាស់ ពីខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **ខៀវ សំផន** បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និងវៀតណាម។ **ខៀវ សំផន** នៅតែត្រូវបានជូនដំណឹងអំពីស្ថានភាពយោធា និងការចរចាទាំងឡាយជាមួយវៀតណាម តាមរយៈការចូលរួមរបស់គាត់នៅក្នុងការប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា និងការទទួលបានកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះ[4870]។ **ខៀវ សំផន** បានថ្លែងសុន្ទរកថា និងធ្វើសេចក្តីថ្លែងការណ៍សាធារណៈនានា អំពីជម្លោះប្រដាប់អាវុធអន្តរជាតិទាំងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[4871] និងទាំងក្រោយពេលរបបនេះបានដួលរលំ[4872]។

### ឃ. អៀង ធីរិទ្ធ[4873]

#### សាវតារ

១២០១.ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ **អៀង ធីរិទ្ធ** បានប្រើប្រាស់ឈ្មោះបដិវត្តន៍ថា *"ភា"* ឬ ត្រូវបានគេស្គាល់ថាជាឈ្មោះ ភា[4874]។

១២០២.**អៀង ធីរិទ្ធ** ហៅ **ភា** បានពន្យល់ថា គាត់បានចាប់ផ្តើមចូលរួមនយោបាយតាំងពីគាត់មានអាយុ១៤ឆ្នាំ ដោយមានការផ្តួចផ្តើមពីសំណាក់សិស្សរួមជំនាន់ និងជាអនាគតស្វាមីរបស់គាត់ គឺ **អៀង សារី** ហៅ **វ៉ាន់**។ គាត់បានចូលរួមនៅក្នុងចលនាមួយ ដែលគាត់ហៅថាជា *"ចលនាបដិវត្ត (...) ដើម្បីរំដោះកម្ពុជាចេញពីអាណានិគមនិយមបារាំង"* ខណៈពេលដែលគាត់រៀននៅវិទ្យាល័យស៊ីសុវត្ថិ។ ចលនានោះត្រូវបានដឹកនាំដោយ **អៀង សារី**[4875]។

១២០៣. បន្ទាប់មក នៅពេលមកដល់ទីក្រុងបារីស (នៅទីនោះគាត់ជាសិស្សចាប់ពីឆ្នាំ ១៩៥២ រហូតដល់ឆ្នាំ១៩៥៧)[4876] គាត់បានចូលរួមក្នុងក្រុមម៉ាក្សឡេនីន ដែលក្នុងនោះមានសមាជិកដូចជាបងស្រីរបស់គាត់ឈ្មោះ **ខៀវ ប៊ុណ្ណារី**, **សាឡុត ស ហៅ ប៉ុល ពត**, **អៀង សារី**, **ខៀវ សំផន**[4877]។

១២០៤.បន្ទាប់ពីគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ **អៀង ធីរិទ្ធ** បានចូលរួមយ៉ាងសកម្មក្នុងចលនាកុម្មុយនីស្ត នៅក្នុងឆ្នាំ១៩៦០ ដែលនៅពេលនោះមានការរៀបចំរចនាសម្ព័ន្ធឡើងវិញនៅក្នុងចលនានេះ ដែលក្នុងនោះ **សាឡុត ស**, **អៀង សារី** និងអតីតសមាជិកក្រុមម៉ាក្សឡេនីន បានដើរតួនាទីយ៉ាងសំខាន់។ **អៀង ធីរិទ្ធ** នៅតែរស់នៅក្នុងទីក្រុងភ្នំពេញដដែល នៅពេលដែល **សាឡុត ស** និង **អៀង សារី** បានរត់ភៀសខ្លួនទៅតាមភូមិភាគ ដែលមូលដ្ឋាននៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម នៅក្នុងឆ្នាំ១៩៦៣។ បន្ទាប់មក **អៀង ធីរិទ្ធ** បានទៅតាមពួកគេទាំងពីរនាក់នេះ នៅក្នុងឆ្នាំ១៩៦៥ ហើយគាត់នៅទីនោះជាមួយពួកគេរហូតដល់ឆ្នាំ១៩៧០[4878]។

១២០៥.ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** ទទួលបន្ទុកគ្រប់គ្រងស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលហៅថា "សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា" នៅទីក្រុងហាណូយ[4879]។ នៅពេលនោះ គាត់បានចូលរួមនៅក្នុងតំណាងការទូតឱ្យរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[4880]។ នៅក្នុងខែមីនា ឆ្នាំ១៩៧៤ គាត់បានបើកកិច្ចប្រជុំមួយនៅទីក្រុងហាណូយ ក្នុងនាមជាបេសកជនពិសេសម្នាក់របស់រណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាមួយនឹង **ខៀវ សំផន**, **អៀង សារី** និងសមាជិកជាន់ខ្ពស់ដទៃទៀតនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[4881]។ នៅក្នុងខែមេសា ឆ្នាំ១៩៧៤ ក្នុងនាមជាសមាជិកមួយរូបនៃគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា **អៀង ធីរិទ្ធ** បានទៅទីក្រុងប៉េកាំង[4882] និងប្រទេសកូរ៉េខាងជើង[4883]។ **អៀង ធីរិទ្ធ** ត្រូវបានគេស្គាល់ថាជា "រដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន" នៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចាប់ពីដើមខែវិច្ឆិកា ឆ្នាំ១៩៧៤ មកម្ល៉េះ[4884] បើទោះបីជាអំណាចរដ្ឋបាលរបស់គាត់ក្នុងនាមជារដ្ឋមន្ត្រីនេះមិនមានភាពច្បាស់លាស់ក៏ដោយ។

១២០៦.មិនមានភាពច្បាស់លាស់នោះទេថាតើ **អៀង ធីរិទ្ធ** បានត្រឡប់មកភ្នំពេញវិញនៅពេលណា ហើយគាត់មកពីណានោះទេ។ យោងតាមសាក្សីម្នាក់ឱ្យដឹងថា គាត់ត្រឡប់មកកម្ពុជាវិញ ពីទីក្រុងប៉េកាំង ជាមួយប្ដីរបស់គាត់ មួយសប្ដាហ៍បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4885]។ **អៀង ធីរិទ្ធ** បាននិយាយនៅក្នុងឆ្នាំ១៩៨០ ថា គាត់ត្រឡប់មកវិញនៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ ឬក៏ពេលក្រោយនេះទៀត ដោយពេលនោះគាត់ថា គាត់ត្រលប់មកពីខេត្តរតនគិរី[4886] ប៉ុន្តែនៅឆ្នាំ២០០៩ **អៀង ធីរិទ្ធ** បាននិយាយថា **ប៉ុល ពត** បានឱ្យគាត់ត្រឡប់មកកម្ពុជាតាមប្រទេសចិន នៅក្នុងឆ្នាំ១៩៧៥[4887]។ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** បានធ្វើទស្សនកិច្ចផ្លូវការមួយទៅសាធារណរដ្ឋ ប្រជា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

មានិតចិន ក្នុងនាមជារដ្ឋមន្ត្រីក្រសួងអប់រំ ដោយរួមដំណើរជាមួយ **ខៀវ សំផន**, **អៀង សារី**, **សារិន ឆាក** និង [លុប][4888]។ ទោះជាក្នុងករណីណាក៏ដោយ ច្បាស់ណាស់ថា **អៀង ធីរិទ្ធ** មានវត្តមាននៅក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥[4889]។

### តួនាទី និងមុខងារ

**១២០៧.** អៀង ធីរិទ្ធ មិនមែនជាសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ទេ ហើយក៏មិនមែនជាសមាជិករបស់គណៈមជ្ឈិមដែរ។ ក្នុងចំណោមកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ចំនួន ១៩ ដែលនៅសេសសល់[4890] មានត្រឹមតែ ១៥ កំណត់ហេតុទេ ដែលមានកត់ត្រាអំពីអ្នកដែលមានវត្តមាន[4891] ហើយមិនដែលឃើញមានឈ្មោះរបស់គាត់ឡើយ។ មិនមានសាក្សីណាបញ្ជាក់ថាគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ឡើយ។ ទោះបីជាសាក្សីមួយរូបឈ្មោះ [លុប] បានកំណត់ថា អៀង ធីរិទ្ធ គឺជាសមាជិកគណៈមជ្ឈិម[4892] ប៉ុន្តែសក្ខីកម្មនេះផ្ទុយនឹងការលើកឡើងដោយ ខៀវ សំផន[4893] និងឌុច[4894]។ ទោះបីជាយ៉ាងណាក៏ដោយ វាទំនងជាថា អៀង ធីរិទ្ធ បានចូលរួមការប្រជុំមួយចំនួនរបស់គណៈមជ្ឈិម[4895]។

**១២០៨.** ផ្ទុយទៅវិញ អៀង ធីរិទ្ធ បានចូលរួមក្នុងអង្គប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដែលពិភាក្សាអំពីការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា ការប្រជុំប្រចាំខែនៅ ក-១ និង ក-៣[4896] ការប្រជុំនៅគណៈរដ្ឋមន្ត្រី[4897] ការប្រជុំស្តីពីសុខាភិបាល និងសង្គមកិច្ច[4898]។

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

**១២០៩.** ក្រសួងសង្គមកិច្ចបានដំណើរការពីខែតុលា ឆ្នាំ១៩៧៥[4899] រហូតដល់ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[4900]។ រចនាសម្ព័ន្ធជាក់ស្តែងនៃក្រសួងនេះមានការប្រែប្រួលទៅតាមពេលវេលាក្នុងរបបនេះ។ កំណត់ហេតុអង្គប្រជុំមួយស្តីពីការងារសង្គមកិច្ច និងសុខាភិបាលបង្ហាញថា រចនាសម្ព័ន្ធរបស់ក្រសួងនេះមានយ៉ាងហោចណាស់ ចាប់ពីខែតុលា ឆ្នាំ១៩៧៥[4901]។ ការបង្កើតក្រសួងនេះត្រូវបានទទួលស្គាល់ជាផ្លូវការក្នុងខែមេសា ឆ្នាំ១៩៧៦ នៅឯការប្រជុំសភាតំណាង ប្រជាជនកម្ពុជា[4902]។

**១២១០.** ក្រសួងសង្គមកិច្ចគ្រប់គ្រងមន្ទីរពេទ្យជាច្រើន រួមទាំងការផលិត និងការចែកចាយថ្នាំពេទ្យនៅក្នុង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ទីក្រុងភ្នំពេញ និងទូទាំងប្រទេសកម្ពុជា[4903]។ នៅទីក្រុងភ្នំពេញ ការគ្រប់គ្រងនេះរួមទាំង ផ-១[4904] ផ-២ នៅជ្រោយចង្វា[4905] ផ-៣ (ផ្សារចាស់)[4906] ផ-៤ (អតីតអគារឌុយម៉ិច DUMEX)[4907] ព-១៧/មន្ទីពេទ្យ ១៧-មេសា[4908] ព-១/កាល់ម៉ែត្រ[4909] ព-២[4910] ព-៣[4911] ព-៤ [ក្រោយមក ព-៦ ឬមន្ទីរពេទ្យ ៦-មករា][4912] ផ-៥[4913] និងមន្ទីរពេទ្យគ្រុនចាញ់[4914]។

**១២១១.** ទីស្តីការក្រសួងរបស់ក្រសួងសង្គមកិច្ច ដែលមានឈ្មោះសម្គាល់ហៅថា ក-២[4915] មានទីតាំងនៅជិតក្រសួងការពារជាតិបច្ចុប្បន្ន ដែលស្ថិតនៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម[4916]។ មន្ទីរ ក-២ មានបុគ្គលិករាប់រយនាក់[4917] និងមានផ្នែកមួយចំនួន រួមមាន ផ្នែកទំនាក់ទំនង[4918] ដែលទទួលខុសត្រូវតែចំពោះការទទួលនិងការបញ្ជូនលិខិត *"ឆ្លងក្រសួង"*[4919]។ មន្ទីរ ក-២ ត្រូវបានដឹកនាំបន្តបន្ទាប់គ្នាដោយអនុប្រធានរបស់ **អៀង ធីរិទ្ធ** ឈ្មោះ **ស៊ីន ផលគុណ** ហៅ **ស៊ូ**[4920] (រហូតដល់ពេលចាប់ខ្លួននៅចុងឆ្នាំ១៩៧៧-ដើមឆ្នាំ១៩៧៨)[4921], ឈុន[4922] និងអាចមានអ្នកផ្សេងទៀត[4923]។ **ឡេង ពិសី** ហៅ **ឡេង ស៊ីមហាក់** ហៅ **ស៊ី** ក៏ជាសមាជិកដំបូងរបស់គណៈក្រសួងសង្គមកិច្ចផងដែរ[4924] និងជាប្រធានមន្ទីរពេទ្យ ១៧-មេសា[4925]។

**១២១២.** ក្រសួងសង្គមកិច្ចរៀបចំការប្រជុំជាទៀងទាត់ ដែលប្រជុំខ្លះត្រូវបានធ្វើឡើងនៅទីស្តីការក្រសួង និងពេលខ្លះធ្វើឡើងនៅតាមមន្ទីរពេទ្យ និងរោងចក្រផលិតឱសថ ជាមួយប្រធានកងដែលនៅក្រោមចំណុះក្រសួងនេះ[4926] ឬ ប្រជុំជាមួយបុគ្គលិកទាំងអស់របស់ក្រសួង[4927]។ ក្រសួងនេះក៏មានរៀបចំវគ្គបណ្តុះបណ្តាលនយោបាយ[4928] និងវេជ្ជសាស្ត្រ ដែលភាគច្រើនធ្វើនៅ ផ-៥ ជិតស្ថានីយ៍អយស្ម័យយាន[4929] ជាពិសេសចំពោះការប្រជុំជាមួយបុគ្គលិកពេទ្យមកពីជនបទ ឬក៏កងទ័ព។[4930] វគ្គបណ្តុះបណ្តាលវេជ្ជសាស្ត្រមានកម្រិតទាប[4931]។

**១២១៣.** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍មួយបានបង្ហាញថា **អៀង ធីរិទ្ធ** ទទួលខុសត្រូវលើការងារសង្គមកិច្ច យ៉ាងហោចណាស់ក៏ចាប់តាំងពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥[4932]។ **អៀង ធីរិទ្ធ** ត្រូវបានតែងតាំងជាផ្លូវការជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដោយសភាតំណាងប្រជាជនកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៦[4933]។ **អៀង ធីរិទ្ធ** បានទទួលស្គាល់ថា គាត់ពិតជាទទួលខុសត្រូវខាងផ្នែកសង្គមកិច្ច *"ចាប់តាំងពីឆ្នាំ១៩៧៦ ក្រោយពីការបោះឆ្នោត"*[4934] ដែលសាក្សីមួយចំនួន[4935] និងឯកសារកំណត់ហេតុប្រជុំដែលនៅសេសសល់[4936] បានបញ្ជាក់ពីការទទួលខុសត្រូវរបស់ **អៀង ធីរិទ្ធ**។ គាត់កាន់តំណែងនេះទាំងក្នុងអំឡុងពេល[4937] និងទាំងក្រោយពេលដែលរបបនេះបានដួលរលំ

[4938]។

**១២១៤.**ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** មានអាសនៈនៅក្នុងគណៈរដ្ឋមន្ត្រី ដែលចេញមាគ៌ានយោបាយរបស់បក្ស សម្រាប់ឲ្យរដ្ឋមន្ត្រីយកទៅអនុវត្ត[4939]។ នៅឯកិច្ចប្រជុំលើកទី១ របស់គណៈរដ្ឋមន្ត្រី ធ្វើនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ ប៉ុល ពត បានពន្យល់ថា រដ្ឋាភិបាលនឹងប្រជុំមួយដងក្នុងមួយខែ រយៈពេលពេញមួយថ្ងៃ ដើម្បីពិនិត្យមើលនយោបាយរបស់បក្ស និងដើម្បីផ្សព្វផ្សាយទៅតាមក្រសួងនីមួយៗ[4940]។ មកទល់នឹងថ្ងៃនោះ ក្រសួងនីមួយៗបានទទួល *"ការងារល្អិត* [លម្អិត] *របស់ក្រសួងនីមួយៗ ក្រសួងមានផែនការរបស់ខ្លួនហើយ"* [4941]។ បន្តមកទៀត នៅក្នុងកិច្ចប្រជុំលើកទីពីរនៃគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ **ប៉ុល ពត** បានកំណត់ភារកិច្ចសម្រាប់ក្រសួងនានា រួមទាំងភារកិច្ចខាងផ្នែកការងារសង្គមកិច្ច និងសុខាភិបាល។ នៅក្នុងកិច្ចប្រជុំនេះ **អៀង ធីរិទ្ធ** បានរាយការណ៍ជូនអង្គការផងដែរ អំពីសកម្មភាពការងាររបស់ក្រសួងសង្គមកិច្ច[4942]។

**១២១៥.អៀង ធីរិទ្ធ** ក៏បានចូលរួមប្រជុំផងដែរពាក់ព័ន្ធនឹងការងារសុខាភិបាល និងសង្គមកិច្ច ដែលក្នុងពេលនោះ **អៀង ធីរិទ្ធ** បានរាយការណ៍ទៅឲ្យ **នួន ជា** និង **ប៉ុល ពត**។ ជាឧទាហរណ៍ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ អៀង ធីរិទ្ធ និងកម្មាភិបាលថ្នាក់ដឹកនាំក្រសួងរបស់គាត់បានរាយការណ៍លម្អិតពីសកម្មភាពរបស់ក្រសួង និងផ្នែកផ្សេងៗរបស់ក្រសួងនេះ ហើយ ប៉ុល ពត និង **នួន** ជា បានបញ្ចេញមតិទៅលើប្រធានបទដែលបានពិភាក្សានោះ[4943]។

**១២១៦.**សាក្សីជាច្រើនលើកឡើងថា **អៀង ធីរិទ្ធ** បានទៅមន្ទីរ ក-៣ និង/ឬ ក-១ ម្តង ឬ ពីរដងក្នុងមួយខែ ដើម្បីជួបប្រជុំជាមួយមេដឹកនាំរបស់មជ្ឈិមបក្ស ជាពិសេស គឺជួបជាមួយ **នួន ជា**[4944]។ ជាក់ស្តែង អតីតអ្នកបើកបរឲ្យ **អៀង ធីរិទ្ធ** ឈ្មោះ [លុប] បានថ្លែងថា *"ការងាររដ្ឋបាលមួយចំនួន ត្រូវតែរាយការណ៍ទៅលោក នួន ជា"* [4945] ហើយ *"រាល់លិខិតស្នាមគឺចេញមកពីក-៣ទាំងអស់។ ឧទាហរណ៍ លិខិតចែកថ្នាំពេទ្យទៅភូមិភាគ ទៅតំបន់ ទៅកងពលជាដើម គឺសុទ្ធសឹងចេញមកពីក-៣ទាំងអស់"* [4946]។ លើសពីនេះទៀត អតីតអ្នកបម្រើនៅផ្ទះរបស់ **អៀង ធីរិទ្ធ** បានពន្យល់ថា គាត់បានយកលិខិតសរសេរដោយ **អៀង ធីរិទ្ធ** មួយចំនួនទៅឲ្យ ប៉ុល ពត, **នួន** ជា និងសុន **សេន** តាមរយៈនីរសាររបស់ពួកគាត់[4947]។

**១២១៧.** យោងតាម **ឌុច**, ទាំង **ប៉ុល ពត** និង **នួន ជា** ជាអ្នកពិនិត្យតាមដាន **អៀង ធីរិទ្ធ** និង ក្រសួង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605663



គាត់។ យោងតាម ឌុច, នួន ជា ទទួលខុសត្រូវតាមការជាក់ស្តែងក្នុងការត្រួតពិនិត្យក្រសួងសង្គមកិច្ច នេះ។ គាត់បានពន្យល់ថា ការងារនេះត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ពីព្រោះ **អៀង ធីរិទ្ធ** មិនមែនជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនោះទេ[4948]។ សាក្សី មួយរូបឈ្មោះ [លុប] ដែលបានរស់នៅក្នុងផ្ទះរបស់ **អៀង ធីរិទ្ធ** ក៏ដឹងដែរថា **នួន ជា** មានអំណាច លើក្រសួងសង្គមកិច្ច[4949]។ **ឌុច** ក៏បានបង្ហាញដែរថា *"ប៉ុល ពត ព្យាយាមអន្តរាគមន៍នៅក្នុង ដំណើការរបស់ក្រសួងសង្គមកិច្ច និង ក្រសួងសុខាភិបាល ជាងក្រសួងផ្សេងទៀត ហើយ ប្រហែលជា ដោយសារគាត់មិនទាន់ពេញចិត្តនឹងការងាររបស់ក្រសួងទាំងនេះ"*[4950]។ ការណ៍នេះ ត្រូវបានបញ្ជាក់ដោយការចូលរួមដ៏សកម្មរបស់ **ប៉ុល ពត** នៅក្នុងសន្និសីទវេជ្ជសាស្ត្រជាតិ នៅឆ្នាំ ១៩៧៨ ដែលនៅពេលនោះដំណោះស្រាយផ្នែកសង្គមកិច្ច និងវេជ្ជសាស្ត្រមួយចំនួនត្រូវបាន អនុម័ត[4951]។

**១២១៨.**នៅក្នុងក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានចូលរួមនៅក្នុងការសម្រេចសំខាន់ៗទាំងមូល។ ទោះបី វាទំនងជាថា អនុប្រធានរបស់ **អៀង ធីរិទ្ធ** ដើរតួនាទីដ៏សំខាន់ក៏ដោយ[4952] **អៀង ធីរិទ្ធ** បានធ្វើការ គ្រប់គ្រងទៅលើក្រសួងរបស់គាត់ និងមន្ទីរ ក-២[4953]។ គាត់បានចូលរួមនៅក្នុងការសម្រេចចិត្ត សំខាន់ៗបំផុត[4954]។ សាក្សី [លុប] ដែលបានធ្វើការនៅមន្ទីរ ក-២ ចាប់ពីខែមេសា ឬឧសភា ឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៩ ពន្យល់ថា *"នៅពេលដែលមន្ទីរពេទ្យណាមួយទូរស័ព្ទ មកស្នើសុំអ្វីមួយ គឺយើងសរសេរសំណើនោះ នៅលើក្រដាសអំពីការស្នើសុំនេះ ហើយយកសំណើ នោះទៅឱ្យឈ្មោះ ឈុន ដែលជាប្រធានមន្ទីរក-២។ ពេលដែលឈ្មោះ ឈុន បានទទួលលិខិតស្នើសុំ នេះហើយ គឺគាត់យកក្រដាសនេះទៅជួបជាមួយ អ៊ំ ភា (អៀង ធីរិទ្ធ) ដើម្បីសុំសេចក្តីសម្រេច។ (...) ក្រោយពីអ៊ំ ភា គាត់សម្រេចហើយ ឈ្មោះ ឈុន យកលិខិតស្នើសុំនោះត្រឡប់មកវិញ ហើយឱ្យពួកយើងយកទៅប្រគល់ឱ្យតាមផ្នែកដែលពាក់ព័ន្ធ។ សម្រាប់ការស្នើសុំណាដែលមិនសូវ សំខាន់ គឺឈ្មោះ ឈុន ជាអ្នកសម្រេចនៅលើសំណើនោះ ប៉ុន្តែប្រសិនបើការស្នើសុំណាមានលក្ខណៈ សំខាន់នោះ គឺអ៊ំ ភា ជាអ្នកសម្រេច"*[4955]។ សាក្សី [លុប] បន្ថែមទៀតថា **អៀង ធីរិទ្ធ** មានបណ្តាញខ្សែទូរស័ព្ទផ្ទាល់ខ្លួនរបស់គាត់ [4956]។

**១២១៩.**មានទិដ្ឋភាពផ្សេងៗគ្នាជាច្រើន ទាក់ទិននឹងតួនាទីរបស់ **អៀង ធីរិទ្ធ** នៅក្រសួងសង្គមកិច្ច។ ក្នុងនាម ជាប្រមុខក្រសួង **អៀង ធីរិទ្ធ** ទទួលខុសត្រូវលើការទិញ ផលិត និងចែកចាយថ្នាំពេទ្យ នៅក្នុង ភ្នំពេញ និងទូទាំងប្រទេស[4957]។ នៅក្នុងការងារនេះ **អៀង ធីរិទ្ធ** ទទួលបានជំនួយពីប្រធាន មន្ទីរ ក-

២[4958]។ គាត់ក៏ត្រូវសហការជាមួយនឹងក្រសួងពាណិជ្ជកម្មផងដែរ[4959]។ គាត់ ត្រូវបានជូនដំណឹងផងដែរអំពីសភាពការណ៍នៅតាមមន្ទីរពេទ្យ និងរោងចក្រផលិតថ្នាំពេទ្យនៅទីក្រុងភ្នំពេញ តាមរយៈការធ្វើទស្សនកិច្ច និងការធ្វើអធិការកិច្ចជាទៀងទាត់[4960]។ យូរៗម្តង គាត់ក៏បានចុះសួរសុខទុក្ខនៅតាមមន្ទីរពេទ្យនានានៅទូទាំងប្រទេស[4961]។

**១២២០.**ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** គ្រប់គ្រងទៅលើផ្នែកបុគ្គលិកនៅតាមមន្ទីរពេទ្យ និងរោងចក្រផលិតថ្នាំពេទ្យ។ អតីតអ្នកបើកបររបស់គាត់ ឈ្មោះ [លុប] អះអាងថា *"គាត់មានសិទ្ធិដក តែងតាំង តាមដាន និង រាយការណ៍"* ទាំងអស់ទៅថ្នាក់លើចំពោះបុគ្គលិកទាំងនេះ[4962]។ អតីតប្រធានមន្ទីរពេទ្យ ព-៤ [ក្រោយមកហៅថា ព-៦] មន្ទីរពេទ្យ ១៧-មេសា និង ផ-២ បាននិយាយថា ពួកគាត់ត្រូវបានតែងតាំងដោយ **អៀង ធីរិទ្ធ**[4963]។ គួរកត់សម្គាល់ថា កូនស្រីមួយចំនួនរបស់ **អៀង ធីរិទ្ធ** និងប្តីរបស់ពួកគេ គឺជាប្រធានមន្ទីរពេទ្យ និងរោងចក្រផលិតថ្នាំពេទ្យរបស់ក្រសួងសង្គមកិច្ច។ [លុប] បានដឹកនាំមន្ទីរពេទ្យមួយចំនួនជាបន្តបន្ទាប់, [លុប] ភេទស្រី គឺជាប្រធាន ផ-១ និង [លុប] ភេទស្រី គឺជាប្រធាន ផ-២[4964]។

**១២២១.** **អៀង ធីរិទ្ធ** បានបើកការប្រជុំ និងរៀបចំវគ្គបណ្តុះបណ្តាលយ៉ាងទៀងទាត់នៅក្នុងក្រសួងសង្គមកិច្ច។ មានការប្រជុំជាមួយនឹងប្រធានមន្ទីរពេទ្យ និងប្រធានរោងចក្រថ្នាំពេទ្យ។ នៅក្នុងពេលប្រជុំទាំងនោះ ប្រធានៗទាំងនោះត្រូវរាយការណ៍ពីស្ថានភាពអង្គភាពរបស់ខ្លួន ហើយ **អៀង ធីរិទ្ធ** ក៏ផ្តល់ការណែនាំទៅពួកគេទាំងនោះផងដែរ[4965]។ **អៀង ធីរិទ្ធ** ក៏ធ្លាប់បានដឹកនាំវគ្គបណ្តុះបណ្តាលនៅ ផ-៥ ដែលមានបុគ្គលិកពីក្រសួងទាំងមូល ឬ ពីអង្គភាពផ្សេងទៀត[4966] រួមទាំងបុគ្គលិកពេទ្យ និងប្រធានមន្ទីរពេទ្យពីតាមបណ្តាខេត្ត[4967]។

**តួនាទីដទៃទៀត**

**១២២២.** បន្ថែមលើការរៀបរាប់ខាងលើ **អៀង ធីរិទ្ធ** មានតួនាទីមួយចំនួនទៀត ក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ។ ពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** ទទួលខុសត្រូវកិច្ចការវប្បធម៌, សង្គមកិច្ច និង កិច្ចការបរទេស[4968] ដែលគាត់ចែករំលែកការងារជាមួយ **អៀង សារី** ចំពោះកិច្ចការបរទេស[4969] និងជាមួយ **នួន ជា** ក្នុងកិច្ចការវប្បធម៌, សង្គមកិច្ច និងអប់រំ[4970]។ **អៀង ធីរិទ្ធ** ត្រូវបានជ្រើសតាំងធ្វើជាតំណាងកម្មកររោងចក្រភ្នំពេញ នៅសភាតំណាង

ប្រជាជនកម្ពុជានៅក្នុងខែមេសា ឆ្នាំ១៩៧៦[4971]។ យ៉ាងហោចណាស់ ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧មក **អៀង ធីរិទ្ធ** ក៏ជាតំណាងសមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យផងដែរ[4972]។

**១២២៣.** ក្នុងសមត្ថភាពផ្សេងៗរបស់គាត់ **អៀង ធីរិទ្ធ** បានទទួលជួបប្រតិភូបរទេសមួយចំនួន ដោយរួមទាំងប្រតិភូប្រទេសឡាវ នៅក្នុងខែមេសា ឆ្នាំ១៩៧៧[4973] អាល់ហ្សេរី នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨[4974] និងកូរ៉េខាងជើង នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨[4975]។ នៅក្នុងឆ្នាំ១៩៧៧ និង ១៩៧៨ **អៀង ធីរិទ្ធ** ក៏បានថ្លែងសុន្ទរកថាមួយចំនួន ដោយមានវត្តមានរបស់អង្គទូតក្នុងប្រទេសមកពីប្រទេសកូរ៉េខាងជើង ឬប្រទេសអេហ្ស៊ីប[4976]។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ, ជួន ជឿន** និងកម្មាភិបាលមកពីក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល បានចូលរួមជាមួយ **ប៉ុល ពត** និង **អៀង សារី** ក្នុងការស្វាគមន៍ និងរួមដំណើរប្រតិភូប្រទេសចិនមួយក្រុម ដើម្បីធ្វើទស្សនកិច្ចនៅរោងចក្រផលិតថ្នាំពេទ្យមួយ[4977]។ សាក្សីមួយចំនួនបញ្ជាក់ថា **អៀង ធីរិទ្ធ** និងពេលខ្លះបុគ្គលិកក្រសួងសង្គមកិច្ច បានចូលរួមនៅក្នុងពិធីទទួលភ្ញៀវបរទេស[4978]។

### ទំនាក់ទំនងផ្សេងទៀតជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

**១២២៤.អៀង ធីរិទ្ធ** មានការពាក់ព័ន្ធជាលក្ខណៈបុគ្គល និងជាលក្ខណៈនយោបាយ យ៉ាងជិតស្និទ្ធិជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ[4979]។ កន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់ **អៀង ធីរិទ្ធ** គឺនៅមន្ទីរក-២ ដែលជាទីស្តីការរបស់ក្រសួងគាត់[4980] ក៏ប៉ុន្តែ ជារឿយៗ គាត់ត្រូវបានឃើញជាមួយស្វាមីគាត់គឺ **អៀង សារី** ឧទាហរណ៍ដូចជានៅពេលធ្វើដំណើរជាមួយស្វាមីគាត់ទៅ សៀមរាប[4981] ឬក៏ទៅចូលរួមការប្រជុំនានា[4982]។

**១២២៥.**ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ** ក៏បានចូលរួមក្នុងការប្រជុំធំៗរបស់បក្ស[4983] ជួនកាលជាមួយនឹងបណ្តាលេខាភូមិភាគ លេខាតំបន់ និងកម្មាភិបាលយោធា[4984]។ **ឌុច** និយាយថា បានឃើញ **អៀង ធីរិទ្ធ** ពីរដងក្នុងមួយឆ្នាំ នៅក្នុងការប្រារព្ធខួបថ្ងៃ១៧ មេសា និងថ្ងៃ៣០ កញ្ញា[4985]។ [លុប] ក៏បានឃើញ **អៀង ធីរិទ្ធ** នៅក្នុងការប្រជុំនៅភ្នំពេញ[4986]។

**១២២៦.**លើសពីនេះទៀត តាមរយៈតួនាទីផ្នែកការទូត **អៀង ធីរិទ្ធ** ក៏មានទំនាក់ទំនងនៅពេញមួយរបបនេះ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ក្នុងសកម្មភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ដែលរួមមាន **អៀង សារី**[4987] នួន ជា[4988] និង **ខៀវ សំផន**[4989]។

**ការចូលរួមនៅក្នុងផែនការរួម**

**ការផ្លាស់ទីលំនៅប្រជាជន**

**១២២៧.** តាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **អៀង ធីរិទ្ធ** បានចូលរួមក្នុងគោលនយោបាយដែលនាំឱ្យមានការផ្លាស់ទីលំនៅប្រជាជនពីទីក្រុង និងទីប្រជុំជន ទៅកាន់តំបន់ជនបទ រួមទាំងពីទីជនបទមួយ ទៅកន្លែងមួយទៀត។

**១២២៨.** ការផ្លាស់ទីលំនៅប្រជាជនពីតាមទីក្រុង និងទីប្រជុំជន ទៅកាន់ទីជនបទ ត្រូវបានលើកឡើងនៅក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា[4990] ដែល **អៀង ធីរិទ្ធ** អាចបានអាន និងចែកចាយនៅក្នុងក្រសួងរបស់គាត់[4991]។

<u>ដំណាក់កាលទី១</u>

**១២២៩.** **អៀង ធីរិទ្ធ** មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទេ នៅពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងនៅពេលធ្វើផែនការ និងអនុវត្តការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលដំបូងៗ[4992]។

**១២៣០.** **អៀង ធីរិទ្ធ** ប្រហែលជាបានដឹងពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មុនគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែមិថុនា ឆ្នាំ១៩៧៥[4993]។ ក្នុងករណីណាក៏ដោយ **អៀង ធីរិទ្ធ** បានទទួលស្គាល់នាពេលក្រោយមកថា គាត់មិនមានការភ្ញាក់ផ្អើលអំពីការជម្លៀសប្រជាជននៅពេលគាត់មកដល់នោះទេ *"ដោយសារមេដឹកនាំបានពន្យល់យើងថាដោយសារមូលហេតុសេដ្ឋកិច្ច នយោបាយ និងយោធា"*[4994]។

**១២៣១.** នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ **អៀង ធីរិទ្ធ** បានចូលរួមការប្រជុំមួយដែលពិភាក្សាពីផលវិបាកមិនល្អនៃការជម្លៀសទីក្រុងភ្នំពេញ ទៅលើប្រជាជន ជាពិសេសពីហេតុការណ៍ដែលថា

ប្រជាជនឆ្លងជម្ងឺអាសន្នរោគ ក្រោយពេលពួកគេត្រូវបានឲ្យចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ដែល *"នាំគ្រោះថ្នាក់ដល់ប្រជាជនយើង"*[4995]។

១២៣២. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **អៀង ធីរិទ្ធ** បានផ្តល់យុត្តិកម្ម និងគាំទ្រចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៨០ គាត់បានពន្យល់អំពីការ *"មិនសប្បាយចិត្ត"* របស់ប្រជាជនដែលត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយសារគ្មាននរណាពន្យល់ប្រាប់ពួកគេអំពី *"នយោបាយ"* ហើយថានោះគ្រាន់តែ *"ជាការបណ្តោះអាសន្ន ហើយបន្ទាប់ពីយើងមានហូបគ្រប់គ្រាន់ ពួកគេនឹងបានត្រឡប់មកបន្តការងារចាស់របស់គេ"*[4996]។

<u>ដំណាក់កាលទី២</u>

១២៣៣. **អៀង ធីរិទ្ធ** បាននិយាយថា គាត់បានចុះទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៦[4997]។ ការចុះទស្សនកិច្ចនេះកើតឡើងក្រោយពេល ឬ ក្នុងពេលផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល (ឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និងបូព៌ា ទៅភូមិភាគឧត្តរ និងពាយ័ព្យ។ ក្នុងអំឡុងពេលចុះទៅពិនិត្យនោះ **អៀង ធីរិទ្ធ** ទំនងជាបានដឹងថា ប្រជាជនជាច្រើនត្រូវបានផ្លាស់ទីលំនៅនៅពាសពេញប្រទេស។

<u>ដំណាក់កាលទី៣</u>

១២៣៤. ការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលនេះ មានជាប់ពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគបូព៌ា ដែលបានកើតឡើងដោយសារការភ័យខ្លាចការបង្កប់ខ្លួនរបស់វៀតណាមនៅក្នុងជួរ ប.ក.ក ក្នុងភូមិភាគបូព៌ា ដើម្បីរៀបចំរដ្ឋប្រហារ។ តួនាទីរបស់ អៀង ធីរិទ្ធិ ទាក់ទងនឹងបញ្ហានេះមានរៀបរាប់លំអិតខាងក្រោម។ ជាពិសេស ក្នុងអំឡុងពេលដែល **អៀង ធីរិទ្ធ** នៅជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ប្រជាជនមួយចំនួនត្រូវបានផ្លាស់ទីលំនៅតាមរយៈក្រសួងរបស់គាត់។ ចាប់ពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ ប្រជាជនមកពីភូមិភាគបូព៌ា ដែលជាបុគ្គលិកក្រសួងរបស់គាត់ ត្រូវបានបញ្ជូនចេញ[4998]។ អ្នកទាំងនោះត្រូវបានជំនួសដោយកម្មករមកពីខេត្តកំពង់ឆ្នាំង[4999] ឬ ស្រែអំបិល[5000]។

## សហករណ៍ និងការដ្ឋាន

១២៣៥. តាមរយៈតួនាទីនានារបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា **អៀង ធីរិទ្ធ** បានចូលរួមក្នុងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាននានា។

### ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ

១២៣៦. **អៀង ធីរិទ្ធ** បានចូលរួមរៀបចំធ្វើផែនការគោលនយោបាយនេះ តាមរយៈតួនាទីរបស់គាត់នៅក្នុងគណៈរដ្ឋមន្ត្រី[5001] និងក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច[5002]។

១២៣៧. ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានចូលរួមការប្រជុំគណៈរដ្ឋមន្ត្រីដែលរៀបចំធ្វើផែនការគោលនយោបាយនេះ និងការចេញសេចក្តីណែនាំដើម្បីសម្រេចឱ្យបានគោលនយោបាយនោះ។ ក្នុងកិច្ចប្រជុំមួយក្នុងចំណោមកិច្ចប្រជុំទាំងនេះ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានបង្ហាញពីសភាពការណ៍បដិវត្តន៍ **អៀង ធីរិទ្ធ** បានបញ្ចេញមតិថា *"យល់ស្របតាមមតិអង្គការទាំងស្រុង"*[5003]។ **អៀង ធីរិទ្ធ** ក៏បានរាយការណ៍ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រសួងគាត់ និងសេចក្តីត្រូវការដើម្បីសម្រេចឱ្យបានគោលដៅ *"៣តោន១ហិកតា"* [5004]។ គាត់បានរាយការណ៍ពីកង្វះបទពិសោធន៍ និងការបណ្តុះបណ្តាលបុគ្គលិកពេទ្យ កង្វះបុគ្គលិក និងបញ្ហាផ្សេងទៀត ដែលទាក់ទិននឹងកង្វះខាតផ្នែកបច្ចេកទេស[5005]។ **អៀង ធីរិទ្ធ** ក៏បាននិយាយថា គាត់ជឿថាអង្គការអាច *"ជួយដោះស្រាយបានដើម្បីបំរើចលនាទូទាំងប្រទេស"* ដែលថាត្រូវរៀបចំវគ្គបណ្តុះបណ្តាល *"ពិសេសខាងពេទ្យ"* ដែល *"បងប្អូនខំដោយជ្រួតជ្រាប ពីភារកិច្ចរបស់ខ្លួន ដើម្បី ផ្សារភ្ជាប់ និងចលនា៣តោន* [ក្នុង១ហិកតា]*"* ហើយថា ក្រសួង *"ជាមួយអ្នកបច្ចេកទេសចិន ក៏បានជិតស្និត រៀនសូត្រ ពីគេតាមអង្គការណែនាំ"* ដើម្បីគោលបំណងនៃការបណ្តុះបណ្តាល ដូចដែលបានណែនាំដោយអង្គការ[5006]។

១២៣៨. ភារកិច្ចរបស់ក្រសួងសង្គមកិច្ចទាក់ទិននឹងគោលនយោបាយនេះ ក៏ត្រូវបានពិភាក្សាផងដែរ នៅឯកិច្ចប្រជុំមួយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដែលមានការចូលរួមពី ប៉ុល ពត, នួន ជា និង **ខៀវ សំផន**។ នៅឯកិច្ចប្រជុំនោះ **អៀង ធីរិទ្ធ** និងកម្មាភិបាលជាថ្នាក់ដឹកនាំមួយចំនួននៅក្នុងក្រសួងរបស់គាត់បានរាយការណ៍អំពីសកម្មភាពរបស់ក្រសួង និងផ្នែកនានារបស់ក្រសួង រួមទាំងការផលិត

និងការចែកចាយថ្នាំពេទ្យ និងការស្រាវជ្រាវពីការព្យាបាលជម្ងឺផ្សេងៗ។ បន្ទាប់មក ប៉ុល ពត និង នួន ជា បានណែនាំពីរបៀបដោះស្រាយបញ្ហានានា ដែលទាក់ទិននឹងជីវភាពរស់នៅរបស់ប្រជាជន និងការបណ្ដុះបណ្ដាលបុគ្គលិកជាដើម[5007]។

**១២៣៩.** ប្រព័ន្ធសហករណ៍ និងការដ្ឋានមានសរសេរនៅក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្ដកម្ពុជា[5008] ដែល **អៀង ធីរិទ្ធ** អាចបានអាន និងចែកចាយនៅក្នុងក្រសួងរបស់គាត់[5009]។

## ការគាំទ្រគោលនយោបាយនេះ

**១២៤០.** ជាមួយនឹងតួនាទីនានារបស់គាត់ **អៀង ធីរិទ្ធ** ទំនងជាបានចូលរួមសមាជថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ដែលនៅពេលនោះ សភាតំណាងប្រជាជនបានអះអាងជាថ្មីអំពីគោលនយោបាយនេះ[5010]។

**១២៤១.** ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ **អៀង ធីរិទ្ធ** បានអះអាងថា *"ថ្នាំពេទ្យទំនើប ថ្នាំបុរាណ ថ្នាំបង្ការ ថ្នាំពេទ្យដែលមិនធ្លាប់ផលិតពីមុន"* ត្រូវបានផលិតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន *"ថ្នាំបង្ការ ២០ មុខ"* នៅមន្ទីរពិសោធន៍ជ្រោយចង្វា ហើយថា ថ្នាំពេទ្យត្រូវបានបញ្ជូនជាទៀងទាត់ទៅឲ្យប្រជាជននៅទូទាំងប្រទេស តែការចែកចាយត្រូវបានបញ្ឈប់ដោយកម្មាភិបាលមូលដ្ឋាន[5011]។ **អៀង ធីរិទ្ធ** ក៏បានទទួលស្គាល់ផងដែរអំពីចំណុចខ្សោយនៅក្នុងគោលនយោបាយនេះ តាមរយៈការសម្ភាសន៍មួយជាមួយអ្នកសារព័ត៌មានម្នាក់ក្នុងឆ្នាំ ១៩៨០ ដែលគាត់បានដឹងថា វាជាការខុសឆ្គងក្នុងការអនុវត្តន៍គោលនយោបាយជ្រុលនិយម ស្ដីពីជំហរខ្លួនទីពឹងខ្លួន និងក្នុងការបដិសេធជំនួយអន្តរជាតិ[5012]។

## ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះ

**១២៤២.** **អៀង ធីរិទ្ធ** ត្រូវបានជូនដំណឹងអំពីការអនុវត្តន៍គោលនយោបាយនេះ តាមរយៈតួនាទី ស្ថានភាពគ្រួសារ និងទំនាក់ទំនងរបស់គាត់ជាមួយមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាផ្សេងទៀត។ ឧទាហរណ៍ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៧ គាត់បានចូលរួមពិធីជប់លៀងមួយ ដើម្បីទទួលគណៈប្រតិភូពីភូមា ដែលនៅពេលនោះ **អៀង សារី** បានថ្លែងសុន្ទរកថាគួសបញ្ជាក់ថា ក្នុងអំឡុងពេល ៨ ខែចុងក្រោយនេះ ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍បានពុះពារយ៉ាងខ្លាំងក្លា និងលំបាកលំបិន ដើម្បី

បង្កើនការបង្កបង្កើនផល[5013]។

១២៤៣. **អៀង ធីរិទ្ធ** បានធ្វើដំណើរដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជា ដើម្បីពិនិត្យមើលសហករណ៍ និងការដ្ឋានទាំងឡាយ។ ឧទាហរណ៍ គាត់បានធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៦។ គាត់បានទទួលស្គាល់ថា ក្នុងអំឡុងពេលនៃការធ្វើទស្សនកិច្ចនោះ គាត់បានកត់សម្គាល់ពីស្ថានភាពរស់នៅ និងការងារនៅតាមវាលស្រែ។ នៅពេលសួរអំពីការធ្វើដំណើរទស្សនកិច្ចនេះ **អៀង ធីរិទ្ធ** បាននិយាយនៅឆ្នាំ១៩៨០ ថា *"ខ្ញុំបានធ្វើដំណើរដើម្បីពិនិត្យមើលស្ថានភាពប្រជាជន ហើយក្នុងកាលនោះ នៅពេលដែលខ្ញុំបានមកដល់ក្រុងភ្នំពេញ ខ្ញុំបានរាយការណ៍ជូនថ្នាក់ដឹកនាំរបស់យើងថា មានរឿងចម្លែកខ្លះក្នុងខេត្តមួយចំនួន ឧទាហរណ៍ នៅខេត្តបាត់ដំបង (...) នៅពេលនោះ ខ្ញុំបានប្រាប់មេដឹកនាំរបស់ខ្ញុំថា មានអ្វីមួយខុសក្នុងខេត្តនោះ (...) ខ្ញុំបានឃើញមនុស្សទាំងអស់នៅទីនោះស្ថិតនៅវាលស្រែកណ្ដាលវាល គ្មានអ្វីទាំងអស់នៅកណ្ដាលថ្ងៃដែលក្ដៅខ្លាំង។ ខ្ញុំបានឃើញប្រជាជនជាច្រើនមានជម្ងឺរាគ និងគ្រុនចាញ់ ហើយក៏បានរាយការណ៍ជូនគាត់"*[5014]។

១២៤៤. **អៀង ធីរិទ្ធ** ក៏បានធ្វើដំណើរទូទាំងប្រទេសនៅក្នុងខែមេសា ឆ្នាំ១៩៧៧ ផងដែរ។ គាត់បានអមដំណើរគណៈប្រតិភូឡាវទៅធ្វើទស្សនកិច្ចនៅតំបន់មួយចំនួនក្នុងប្រទេស ដូចជា សៀមរាប ភូមិភាគកណ្ដាល កំពង់ចាម ភូមិភាគបូព៌ា និងជាពិសេស ទំនប់ ១-មករា ផងដែរ[5015]។ សាក្សីមួយរូបអះអាងថា **អៀង ធីរិទ្ធ** បានចុះទៅពិនិត្យទំនប់ ១-មករា ហើយអ្នកដែលទៅទទួលបដិសណ្ឋារកិច្ច **អៀង ធីរិទ្ធ** បានទទួលអាហារ និងសម្លៀកបំពាក់[5016]។ នៅពេលនោះ អៀង ធីរិទ្ធ ធ្វើទស្សនកិច្ចផងដែរនៅក្នុងមន្ទីរពេទ្យមួយ ដែលនៅទីនោះគេបានប្រាប់គាត់អំពីកង្វះខាតថ្នាំពេទ្យ[5017]។

១២៤៥. **អៀង ធីរិទ្ធ** ទំនងជាបានដឹងអំពីការដ្ឋានការងារដទៃទៀត។ យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ១៩៧៨ មនុស្សជាច្រើន ត្រូវបានបញ្ជូនមកពីខេត្តកំពង់ឆ្នាំង[5018] និងស្រែអំបិល[5019] ដើម្បីជំនួសអ្នកដែលត្រូវបានបញ្ជូនចេញពីមន្ទីរ ក-២ និងមន្ទីរពេទ្យនានា។

១២៤៦. ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដែលទទួលខុសត្រូវលើការផលិត ផ្គត់ផ្គង់ និងចែកចាយថ្នាំពេទ្យ **អៀង ធីរិទ្ធ** បានដឹងពីបញ្ហាផ្នែកសុខាភិបាលធ្ងន់ធ្ងរ[5020] ដែលកើតឡើងនៅទូទាំងប្រទេស រួមទាំងការណ៍ដែលថា ថ្នាំពេទ្យជាថ្នាំបុរាណ និងជាថ្នាំសាកល្បងពិសោធន៍[5021] និងជាថ្នាំដែលមិនមានប្រសិទ្ធភាពទាល់តែសោះ ឬ ក៏មានគុណភាពអន់[5022] ហើយត្រូវបានគ្រប់គ្រងដោយបុគ្គលិក


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១...។

00605671



ពេទ្យដែលមិនមានលក្ខណៈសម្បត្តិ[5023]។ ទោះបីជា **អៀង ធីរិទ្ធ** បានលើកបញ្ហាពាក់ព័ន្ធនៅក្នុងការប្រជុំនានាជាមួយ ប៉ុល ពត, នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗទៀតក៏ដោយ ក៏ក្រសួងរបស់គាត់[5024] នៅតែបន្តអនុវត្តគោលនយោបាយរបស់បក្ស។

**មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស**

**១២៤៧.** តាមរយៈតួនាទីជាច្រើនរបស់ខ្លួន ក្នុងជួរថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា **អៀង ធីរិទ្ធ** បានចូលរួមនៅក្នុងការអប់រំកែប្រែ *"សមាសភាពអាក្រក់"* និងសម្លាប់ *"ខ្មាំង"* ទាំងខាងក្នុង និងខាងក្រៅជួរបក្ស។

<u>ការចូលរួមក្នុងការបង្កើតគោលនយោបាយនេះ</u>

**១២៤៨.** **អៀង ធីរិទ្ធ** បានចូលរួមក្នុងការបង្កើតគោលនយោបាយនេះ តាមរយៈតួនាទីរបស់គាត់ក្នុងគណៈរដ្ឋមន្ត្រី[5025] និងក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច[5026]។ **អៀង ធីរិទ្ធ** បានចូលរួមការប្រជុំគណៈរដ្ឋមន្ត្រី ដែលរៀបចំផែនការគោលនយោបាយនេះ និងបានចេញសេចក្តីណែនាំដើម្បីសម្រេចគោលនយោបាយរួមនេះ។ ក្នុងកិច្ចប្រជុំមួយក្នុងចំណោមកិច្ចប្រជុំទាំងនេះ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៧៦ បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានបង្ហាញពីសភាពការណ៍បដិវត្តន៍ **អៀង ធីរិទ្ធ** បានបញ្ចេញមតិ *"យល់ស្របតាមមតិអង្គការទាំងស្រុង"* [5027]។ នៅឯកិច្ចប្រជុំនោះ គាត់ក៏បានប្រកាសផងដែរអំពីបុគ្គលិកដែលបម្រើការនៅក្នុងក្រសួងរបស់គាត់ថា *"បានអប់រំបំផុសបងប្អូន មួយខែម្តង។ ពេលប្រជុំមាន មតិទាំងអស់គ្នា មហាជន ប៉ា[ន] ទិទៀន។ (...) ពង្រឹង នយោបាយ និងសតិអារម្មណ៍"*[5028]។

**១២៤៩.** នៅឯកិច្ចប្រជុំមួយស្តីពីសុខាភិបាល និងសង្គមកិច្ច នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដែលចូលរួមដោយ ប៉ុល ពត, នួន ជា និង **ខៀវ សំផន** គោលនយោបាយនេះត្រូវបានពិភាក្សា ហើយ **អៀង ធីរិទ្ធ** និងកម្មាភិបាលថ្នាក់ដឹកនាំក្នុងក្រសួងរបស់គាត់បានរាយការណ៍អំពីរបៀបដែល *"បក្សបំពាក់បំប៉នជាប់"*[5029] និងបានផ្តល់ជាយោបល់ថា គួរឲ្យមានការឃោសនាបន្ថែមទៀត ជា ដំណោះស្រាយចំពោះបញ្ហាដែលកំពុងកើតមាន[5030]។

**១២៥០.** លើសពីនេះទៀត នៅខែកញ្ញា ឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ** បានចូលរួមសន្និបាតដ៏ធំមួយនៅក្នុងទីក្រុង

ភ្នំពេញ ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់ ប.ក.ក ដែលនៅពេលនោះ ប៉ុល ពត បានប្រកាសដល់អ្នកចូលរួមរាប់រយនាក់ថា កងទ័ព និងមូលដ្ឋាន មិនមានសិទ្ធិចាប់មនុស្សទៀតឡើយ។ ចាប់ពីពេលនោះមក ពួកគេមានតែសិទ្ធិសួរចម្លើយមនុស្ស ហើយរាយការណ៍ទៅមជ្ឈិមបក្ស[5031]។ សន្និបាតនេះត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដើម្បីផ្សព្វផ្សាយអំពីសេចក្ដីសម្រេចរបស់គណៈមជ្ឈិមខែមិថុនា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា *"សេចក្ដីណែនាំ របស់ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពី គោលនយោបាយ របស់បក្ស ចំពោះ អ្នកភាន់ច្រឡំ ចូល សេ អ៊ី អា ឬធ្វើភ្នាក់ងារ យួន ឬចូល កា សេ បេ ប្រឆាំងបក្ស បដិវត្ត ប្រជាជន និង កម្ពុជាប្រជាធិបតេយ្យ"* ។ សេចក្ដីសម្រេចនេះ ហាក់ដូចជារៀបរាប់អំពីការកសាងខ្លួនឡើងវិញ ចំពោះអ្នកដែលបានចូល សេ.អ៊ី.អា., កា.ហ្សេ.បេ និងវៀតណាម មុនខែកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែ បានដាក់បញ្ញាឱ្យបក្ស និងប្រជាជនកម្ពុជា កម្ចាត់ខ្សែបណ្ដាញ ដែលបានបន្តប្រឆាំងនឹងបក្សចាប់ពីខែកក្កដា ឆ្នាំ១៩៧៨ តទៅ[5032]។

## ការគាំទ្រគោលនយោបាយនេះ

**១២៥១.** នៅខែកក្កដា ឆ្នាំ១៩៧៥ គោលនយោបាយនេះត្រូវបានពិភាក្សានៅក្នុងការជួបជុំដ៏ធំមួយរបស់បក្ស[5033] ដែល **អៀង ធីរិទ្ធ** បានចូលរួម និងដែល *"សមមិត្តប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស"* បានប្រកាសថា កងទ័ពបដិវត្តន៍ត្រូវតែការពារប្រទេសប្រឆាំងនឹង *"ខ្មាំងខាងក្នុង"* និង *"បន្កកំទេច"* [5034]។

**១២៥២.** ជាមួយនឹងតួនាទីរបស់គាត់ **អៀង ធីរិទ្ធ** ពិតជាបានចូលរួមសមាជរបស់សភាតំណាងប្រជាជននៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ដែលពេលនោះ មានការលើកឡើងអំពីភាពចាំបាច់ក្នុងការរក្សា *"ការប្រុងប្រយ័ត្នបដិវត្តឱ្យខ្ពស់ជានិច្ច"*[5035]។

## ការបោសសម្អាតនៅភូមិភាគបូព៌ា

**១២៥៣.** ក្នុងឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ** បានចូលរួមក្នុងការបញ្ជូនចេញបុគ្គលិកក្រសួងសង្គមកិច្ចដែលជាអតីតអ្នកបូព៌ា។ អ្នកទាំងនោះមួយចំនួនត្រូវបានបញ្ជូនទៅជំរំកែប្រែ ឬការដ្ឋាន[5036]។ **អៀង ធីរិទ្ធ** បានបញ្ជាអោយមានការបញ្ជូនសមាជិកទាំងនេះ ជាពិសេសទៅមន្ទីរពេទ្យ ព-៤ [ក្រោយមក ព-



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៦ ឬមន្ទីរពេទ្យ ៦-មករា] និងនៅ ផ-២[5037]។

**១២៥៤.** [លុប] (ស្រី) ដែលបានធ្វើជាប្រធានមន្ទីរពេទ្យ ព-៤ បានរយៈពេលបីខែ នៅដើមឆ្នាំ១៩៧៨ បាននិយាយថា ការដកបុគ្គលិកដែលមកភូមិភាគបូព៌ា ចេញពីមន្ទីរពេទ្យរបស់គាត់ ត្រូវបានធ្វើឡើងតាមបញ្ជារបស់ថ្នាក់លើ គឺ **អៀង ធីរិទ្ធ** ចំពោះករណីនេះ *"បន្ទាប់ពីមានការចោទប្រកាន់ថា សោ ភឹម ក្បត់។ ជួនកាល អៀង ធីរិទ្ធ បានប្រាប់ខ្ញុំដោយផ្ទាល់ពីបញ្ហានេះ"*[5038]។ សាក្សីរូបនេះបន្ថែមថា *"ខ្ញុំមិនដឹងថា អៀង ធីរិទ្ធ ទទួលបញ្ជាមកពីណាទេ ប៉ុន្តែគាត់ប្រាប់ខ្ញុំ និងអង្គភាពក្រោមបង្គាប់ឱ្យធ្វើដូច្នោះ ហើយព្រមទាំងបានប្រាប់ខ្ញុំថា មេខាងបូព៌ាក្បត់"*[5039]។ តាមការអះអាងរបស់ [លុប] គេមិនដែលបានឃើញមនុស្សទាំងនេះទៀតទេ ហើយពួកគេប្រហែលជាត្រូវបានសម្លាប់[5040]។

**១២៥៥.** សាក្សីនានានិយាយថា នៅផ-២ បុគ្គលិកចំនួនរាប់រយនាក់ត្រូវបានបញ្ជូនចេញ និងជំនួសជាបន្តបន្ទាប់នៅមុន និងក្នុងអំឡុងឆ្នាំ១៩៧៨ ដោយសារតែពួកគេជាប់ពាក់ព័ន្ធជាមួយនឹង **សោ ភឹម** ពាក់ព័ន្ធជាមួយនឹងពួកវៀតណាម ឬភូមិភាគបូព៌ា[5041]។ [លុប] ជាអតីតសមាជិកគណៈផ-២ និយាយថា *"ក្នុងរយៈនោះល្ងាចមួយ មានទូកមកជាច្រើន ដើម្បីមកទទួលយកអ្នកធ្វើការចាស់ទៅកន្លែងផ្សេង រួចហើយដាក់ជំនួសដោយអ្នកថ្មីវិញ"*[5042]។ [លុប] ដែលត្រូវបានបញ្ជូនមកជាមួយមនុស្សរាប់រយនាក់ទៀតនោះ ដើម្បីមកជំនួសបុគ្គលិកដែលដកចេញពីផ-២ នាដើមឆ្នាំ១៩៧៨ បញ្ជាក់ថា *"បុគ្គលិកចាស់ៗទាំងអស់ ដែលមានគ្នាប្រហែលមួយរយនាក់ ភាគច្រើនគឺអ្នកមកពីភូមិភាគបូព៌ា ត្រូវបានបញ្ជូនចេញតាមទូក"*[5043]។

**១២៥៦.** [លុប] ជាអតីតប្រធាន ផ-២ តែងតាំងដោយ **អៀង ធីរិទ្ធ** ក្នុងឆ្នាំ១៩៧៦ បានអះអាងថា **អៀង ធីរិទ្ធ** បានចេញបញ្ជាឱ្យបញ្ជូនចេញនូវបុគ្គលិកពីផ-២[5044]។ [លុប] ពន្យល់ថា *"ពេលខ្លះបន្ទាប់ពីកិច្ចប្រជុំ [ប្រចាំខែ] នៅមន្ទីរសង្គមកិច្ច អៀង ធីរិទ្ធ បានឱ្យបញ្ជីឈ្មោះអ្នកដែលត្រូវដកចេញមកឱ្យខ្ញុំ ឬពេលខ្លះនិរសាមកពីក្រសួងសង្គមកិច្ចបានយកបញ្ជីឈ្មោះអ្នកដែលត្រូវដកចេញយកមកឱ្យខ្ញុំ បន្ទាប់មកខ្ញុំក៏ប្រាប់អ្នក ដែលមានឈ្មោះក្នុងបញ្ជីនោះឱ្យទៅក្រសួងសង្គមកិច្ច ហើយអ្នកទាំងនោះពុំដែលឃើញត្រឡប់មកវិញទេ"*[5045]។

**១២៥៧.** [លុប] ក៏រៀបរាប់ផងដែរថា នៅចុងឆ្នាំ១៩៧៧នោះ **អៀង ធីរិទ្ធ** បានផ្តល់ដំណឹងដល់គាត់ដោយផ្ទាល់ថា គាត់នឹងត្រូវបញ្ជូនចេញពីផ-២ ទៅកន្លែងផ្សេងទៀត។ ក្រោយពីនោះមក ទូក

00605674



មួយបានមកទទួលយកគាត់ ហើយគាត់ត្រូវបញ្ជូនទៅមន្ទីរ ក-៧ និងបានជួបជាមួយប្រពន្ធ និងកូនទាំងពីររបស់គាត់នៅទីនោះ។ បន្ទាប់មក [លុប] ព្រមទាំងក្រុមគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនទៅជំរំរៀនសូត្រមួយ[5046]។ នៅពេលត្រូវបានសាកសួរពីមូលហេតុដែលបណ្តាលឱ្យមានការបញ្ជូនចេញ និងបាត់ខ្លួនទាំងនេះ [លុប] និយាយថា មូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗទៀតនោះគឺ "*មកពីមនុស្សទាំងអស់នោះជាមនុស្សមកពីបូព៌ា ដែលត្រូវបានបង្អាត់បង្រៀនដោយពួកវៀតណាម*"[5047]។ [លុប] និយាយផងដែរថា "*រឿងនេះមិនមែនបានន័យថា អៀង ធីរិទ្ធ ជាអ្នកមានអំណាចសម្រេចធ្វើការដោះដូរអ្នកទាំងនេះទេ ប៉ុន្តែគាត់ គឺជាអ្នកអនុវត្តបញ្ជាមកពីថ្នាក់លើ*"[5048]។

១២៥៨.[លុប] ដែលត្រូវបានគេចាត់តាំងឱ្យទៅធ្វើការនៅ ផ-២ នាដើមឆ្នាំ១៩៧៨ ពន្យល់ថា ក្រោយពីគាត់បានទៅដល់ទីនោះអស់រយៈពេលមួយយប់ បុគ្គលិកដែលធ្វើការយូរនៅ ផ-២ ទាំងអស់ប្រមាណជា១០០នាក់ ដែលភាគច្រើនមកពីភូមិភាគបូព៌ា - ត្រូវគេបញ្ជូនចេញតាមទូក។ [លុប] ក៏លើកឡើងទៀតដែរថា មានម្តងនោះ[លុប]ដែលត្រូវជាកូនស្រីរបស់ **អៀង ធីរិទ្ធ** និងជាប្រធាន ផ-២ បានស្នើឱ្យគាត់នាំមនុស្សម្នាក់ ឈ្មោះ **វេត** ទៅមន្ទីរ ក-៧។ គាត់បានទទួលដំណឹងថា មន្ទីរ ក-៧ គឺជាទីតាំងទទួលអ្នកទោសមួយ មុនពេលត្រូវបញ្ជូនទៅកាន់កន្លែងផ្សេងៗទៀត។ ចំណុចនេះត្រូវបានអះអាងដោយ **វេត** ដែល [លុប] បានជួបម្តងទៀត ក្រោយពីរបបនោះបានបញ្ចប់។ **វេត** បានប្រាប់គាត់ថា បន្ទាប់ពីនៅមន្ទីរ ក-៧ បានពីរ ឬបីយប់ គាត់ត្រូវគេបញ្ជូនទៅព្រៃកក្តាម ដែលនៅទីនោះ គាត់ប៊ិះតែនឹងស្លាប់[5049]។

១២៥៩.ទីកន្លែងដែលមនុស្សទាំងនោះ ត្រូវគេបញ្ជូនទៅ រួមមាន ព្រៃកក្តាម[5050] ស្រែអំបិល[5051] វត្តជ័យឧត្តម[5052] និងជំរំលត់ដំមួយផ្សេងទៀតនៅក្រោមការគ្រប់គ្រងរបស់ **ប៉ង់** ជាប្រធានមន្ទីរ ស-៧១ ដែលជាទីកន្លែងសម្រាប់ទទួលយកអ្នកដែលត្រូវបានគេយល់ថាជា "ជនក្បត់"[5053]។

**<u>ការដឹងឮ និងការអនុវត្តន៍គោលនយោបាយនេះ</u>**

**<u>នៅទូទាំងប្រទេស</u>**

១២៦០.ទោះបីជាមិនមានភស្តុតាងបង្ហាញថា **អៀង ធីរិទ្ធ** បានចុះពិនិត្យមន្ទីរសន្តិសុខ ឬកន្លែងសម្លាប់មនុស្ស

នានាដោយផ្ទាល់ ក៏គាត់បានដឹងថា ខ្មាំងនៅក្នុងជួរ និងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានកំណត់អត្តសញ្ញាណ និងសម្លាប់ចោល តាមរយៈតួនាទីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច តាមរយៈការទាក់ទងរបស់គាត់ជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា, តាមការដឹងឮរបស់គាត់អំពីមន្ទីរ ស-២១, ទំនាក់ទំនងរបស់គាត់ជាមួយមន្ទីរ ស-២១ និងការចូលរួមប្រជុំរបស់គាត់ជាមួយលេខាភូមិភាគ លេខាតំបន់ និងកម្មាភិបាលយោធា។

**១២៦១.**នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៧ នៅពិធីជប់លៀងមួយដែលមានវត្តមាន **អៀង ធីរិទ្ធ** ចូលរួមផ្តល់កិត្តិយសដល់គណៈប្រតិភូមកពីប្រទេសភូមា **អៀង សារី** បានថ្លែងសុន្ទរកថាលើកឡើងអំពីគោលនយោបាយនេះ ដោយនិយាយថា "ក្នុងរយៈពេលប្រាំបីខែមុននេះ ប្រជាពលរដ្ឋកម្ពុជា និងកងទ័ពបដិវត្តន៍បាន វាយសម្រុកយ៉ាងសស្រាក់សស្រាំ (...) ការពារដោយជោគជ័យលើឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាពទឹកដីរបស់ជាតិយើង រួមទាំងផ្លែផ្ការបស់បដិវត្តន៍ និងការចាត់ចែងសមភាព និងយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋ តាមរយៈការកំទេចគ្រប់កលល្បិចរបស់ខ្មាំងគ្រប់ប្រភេទ" [5054]។

**១២៦២.**នៅពេលខុសៗគ្នា **អៀង ធីរិទ្ធ** បានទទួលស្គាល់ថា គាត់បានដឹងពីការសម្លាប់ខ្មាំង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងកិច្ចសម្ភាសន៍មួយក្នុងឆ្នាំ១៩៨០ **អៀង ធីរិទ្ធ** បានពន្យល់ថា ការចាប់ខ្លួន និងការសម្លាប់ **រស់ ញឹម** (លេខាភូមិភាគពាយ័ព្យ និងជាសមាជិកគណៈអចិន្ត្រៃយ៍) និងអត្តឃាតរបស់ **សោ ភឹម** (លេខាភូមិភាគបូព៌ា និងជាសមាជិកគណៈអចិន្ត្រៃយ៍) ក្នុងខែមិថុនា ឆ្នាំ១៩៧៨ បានកើតឡើងជាលទ្ធផលនៃរបាយការណ៍របស់ **អៀង ធីរិទ្ធ** អំពីស្ថានភាពនៅភូមិភាគពាយ័ព្យជូន **ប៉ុល ពត**។ ផ្តើមចេញពីរបាយការណ៍នេះ ការស្រាវជ្រាវមួយបានធ្វើឡើងដោយបានរកឃើញថា **សោ ភឹម** គឺជាភ្នាក់ងាររបស់វៀតណាម ហើយ **រស់ ញឹម** បានឃុបឃិតជាមួយនឹង **សោ ភឹម**[5055]។ នៅក្នុងការសម្ភាសន៍ដដែល **អៀង ធីរិទ្ធ** បាននិយាយថា *"ពួកភ្នាក់ងារបានលាក់ខ្លួននិងបង្កប់ខ្លួននៅក្នុងជួររបស់យើង ហើយគេមានតំណែងខ្ពស់*[5056]។ នៅក្នុងការសម្ភាសន៍មួយទៀតនៅក្នុងឆ្នាំ១៩៨១ ជាមួយនឹងអ្នកសារព័ត៌មានម្នាក់មកពីទស្សនាវដ្តីបារាំង Le Nouvel Observateur **អៀង ធីរិទ្ធ** បានទទួលស្គាល់នៅក្នុងអត្ថបទកាសែតថា មានការបំពារបំពាន ប៉ុន្តែថាវាកើតមាននៅគ្រប់បដិវត្តន៍ ហើយថា អាចមានការបោសសម្អាត ដែលមានគោលដៅចំពោះអ្នកដែលគេហៅថាជនក្បត់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ *"ប៉ុន្តែវាមិនមែនជាការប្រល័យពូជសាសន៍ឡើយ"*[5057]។

១២៦៣. យ៉ាងហោចណាស់ ចាប់តាំងពីខែតុលា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** បានដឹងពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលអំពាវនាវ និង “អប់រំកែប្រែ” ប្រជាជនកម្ពុជានៅឯបរទេសឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមរយៈតួនាទីផ្នែកការទូត[5058] ស្ថានភាពគ្រួសារ និងទំនាក់ទំនងរបស់គាត់ជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ជាពិសេសជាមួយស្វាមីគាត់ **អៀង សារី**។ **អៀង ធីរិទ្ធ** បានពិភាក្សាបញ្ហានេះជាមួយកម្មាភិបាលម្នាក់ ក្នុងចំណោមកម្មាភិបាលក្នុងក្រសួងរបស់គាត់[5059]។ អ្នកដែលវិលត្រឡប់មកប្រទេសវិញមួយចំនួនត្រូវបានបញ្ជូនឱ្យធ្វើការនៅក្រសួងសង្គមកិច្ច បន្ទាប់ពីបានរៀនសូត្រលត់ដំហើយ[5060]។

១២៦៤.**អៀង ធីរិទ្ធ** ក៏បានដឹងផងដែរពីការចាប់ខ្លួនទាហានវៀតណាម ដោយសារថា ចម្លើយសារភាពរបស់ពួកគេត្រូវបានថតជាសម្លេងសម្រាប់ការឃោសនា និងប្រកាសតាមវិទ្យុ[5061]។

<u>នៅក្រសួងសង្គមកិច្ច</u>

១២៦៥.**អៀង ធីរិទ្ធ** បានចូលរួមក្នុងការអនុវត្តន៍គោលនយោបាយនេះ ក្នុងក្រសួងរបស់គាត់។

១២៦៦.ការអប់រំកែប្រែ *“សមាសភាពអាក្រក់”* និងការសម្លាប់ *“ពួកខ្មាំង”* ត្រូវបានសរសេរនៅក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា[5062] ដែល **អៀង ធីរិទ្ធ** អាចបានអាន និងចែកចាយក្នុងក្រសួងរបស់គាត់[5063]។

១២៦៧.យោងតាមអត្ថបទដកស្រង់ចេញពីសៀវភៅកំណត់ហេតុមួយ ដែលចងក្រងនូវការប្រជុំនៅក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** អាចបាននិយាយនៅឯកិច្ចប្រជុំក្នុងមន្ទីរពេទ្យ១៧-មេសា ថា៖ *“សំណូមពររបស់បក្សយើងវាយខ្មាំងកំ* [កុំ] *ឱ្យងើបក្បាលឡើងវិញបាន”*[5064]។

១២៦៨.នៅក្នុងកិច្ចប្រជុំដែល **អៀង ធីរិទ្ធ** រៀបចំជាមួយប្រធានពេទ្យ និងរោងចក្រផលិតថ្នាំពេទ្យរបស់ក្រសួង គាត់បានណែនាំបុគ្គលិកឱ្យអនុវត្តគោលនយោបាយនេះ។ ឧទាហរណ៍ [លុប] ដែលជាអតីតប្រធានពេទ្យ១៧-មេសា រៀបរាប់ថា៖ *“គាត់ធ្លាប់បានណែនាំ ទី១- ឱ្យបងប្អូនមើលអ្នកជំងឺឱ្យបានជិតដល់ ទី២- សន្សំសំចៃថ្នាំពេទ្យកុំខ្ជះខ្ជាយ ទី៣- ធ្វើការងារត្រូវគោរពពេលវេលាឱ្យបានត្រឹមត្រូវ ទី៤- ត្រូវតាមដានសកម្មភាពរបស់ខ្មាំងក្នុងមន្ទីរពេទ្យ ត្រូវប្រុងប្រយ័ត្នខ្មាំងបំផ្លាញថ្នាំពេទ្យ ឃ្លាំង*

*ជាដើម*"[5065]។

១២៦៩.ស្រដៀងគ្នានេះដែរ នៅក្នុងកិច្ចប្រជុំធំៗ និងវគ្គបណ្តុះបណ្តាលនានា ដែល **អៀង ធីរិទ្ធ** បានរៀបចំជាមួយបុគ្គលិកពេទ្យពីក្រុងភ្នំពេញ និងពីបណ្តាខេត្តនានា គាត់បានផ្តល់ការណែនាំឱ្យអនុវត្តគោលនយោបាយនេះ។ យោងតាមសាក្សីម្នាក់ដែលធ្លាប់ចូលរួមក្នុងការប្រជុំមួយក្នុងចំណោមការប្រជុំទាំងនោះ **អៀង ធីរិទ្ធ** *"បានប្រកាសពីឈ្មោះអ្នកក្បត់និងណែនាំកុំឱ្យយកគំរូតាម"*[5066]។ ចំណុចនេះត្រូវបានបញ្ជាក់ដោយសាក្សីមួយចំនួនផ្សេងទៀត ដែលធ្លាប់ធ្វើការនៅក្រសួងសង្គមកិច្ច[5067]។ ឧទាហរណ៍ [លុប] ដែលធ្លាប់ធ្វើការនៅមន្ទីរ ក-២ និងធ្លាប់ចូលរួមប្រជុំ ដែលមាន **អៀង ធីរិទ្ធ** ធ្វើជាអធិបតី និយាយថា **អៀង ធីរិទ្ធ** បានលើកឡើងអំពី *"រឿងចាប់ខ្លួនមេធំៗ ដែលចោទថាក្បត់មានដូចជា ហ៊ូ យន់, ហ៊ូ នឹម និង កុយ ធួន ជាដើម"*[5068]។

១២៧០.ជាលទ្ធផល ក្នុងអំឡុងពេលដែល **អៀង ធីរិទ្ធ** ធ្វើជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច មានបុគ្គលិកជាច្រើននាក់នៅក្នុងក្រសួងត្រូវបានដាក់ទោស និង "នាំយកទៅ" ដោយសារមូលហេតុនយោបាយ [5069] វិន័យ[5070] ឬ "សីលធម៌" [5071]។

១២៧១. [លុប] ដែលធ្វើការជាគ្រូពេទ្យវះកាត់ជាមួយ **ជួន ជឿន** នៅពេទ្យ១៧-មេសា ត្រូវបានដាក់ទោសដោយមូលហេតុនយោបាយ។ [លុប] អះអាងថា គាត់ត្រូវបានគេចាប់ខ្លួនអំឡុងពេលដំណាលគ្នានឹង **ឡេង ស៊ីមហាក់** ហៅ **សី** (ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧)[5072]។ [លុប] ត្រូវបានចោទប្រកាន់ថា *"ជា សេ. អ៊ី. អា"* និងថា *"ជាខ្មាំងស៊ីរូងផ្ទៃក្នុងបក្ស"* ដោយបានដាក់ប៉ាំងកន្ត្រៃក្នុងពោះអ្នកជម្ងឺក្នុងពេលវះកាត់[5073]។ គាត់ត្រូវបានគេកោះហៅឱ្យទៅរៀនសូត្រ និងត្រូវគេដឹកតាមឡានដោយចងមុខ រួចបញ្ជូនទៅកន្លែងឃុំឃាំងដែលគាត់ស្គាល់ថាជា វត្តស្ដែង។ វត្តស្ដែងជាជំរំលត់ដំមួយផ្សេងទៀតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ ដែលជាប្រធានមន្ទីរ ស-៧១[5074]។ ពេលទៅដល់ គាត់ត្រូវបានគេផ្តល់ស្លាកដែលមានឈ្មោះ និងព័ត៌មានពិស្តារផ្ទាល់ខ្លួនរបស់គាត់ ព្រមទាំងថតរូបផង។ ក្នុងពេលដែលគាត់ជាប់ឃុំឃាំង គាត់ត្រូវបានគេដាក់ខ្នោះជើង និងទទួលរងការធ្វើទារុណកម្មជាប្រចាំ។ គេសួរចម្លើយគាត់ពី *"សកម្មភាពអ្វីខ្លះក្នុងការបំផ្លាញបក្សក្នុងមន្ទីរពេទ្យ"*[5075]។

១២៧២. វាទំនងជាថា ការដាក់ទោសដោយសារមូលហេតុ "សីលធម៌" មានលក្ខណៈតឹងរ៉ឹង

ជាពិសេសនៅក្នុងក្រសួងសង្គមកិច្ច។ សាក្សីមួយរូប ដែលធ្លាប់បានធ្វើការនៅមន្ទីរពេទ្យព-៦ និងមន្ទីរក-២[5076] បញ្ជាក់ថា *"គេហាមឃាត់មិនឱ្យពេទ្យ និងអ្នកជំងឺស្រឡាញ់គ្នាជាប្តីប្រពន្ធទេ បើគេដឹង គេយកបាញ់ចោលនៅនឹងមុខ។... ខ្ញុំឃើញមាន ពូ អៀន (យុទ្ធជន) និងនារី ស (ពេទ្យ) ស្រឡាញ់គ្នានៅក្នុងបន្ទប់ទឹក។ ពេលនោះ មានគេឃើញ ហើយក៏ចាប់ចងអ្នកទាំងពីរ រួចបាញ់សម្លាប់ចោលនៅទីនោះតែម្តង។ គេបានព្រមានថា "កុំឱ្យអ្នកដទៃយកគំរូតាម"*។ យ៉ាងហោចណាស់មានសាក្សីបួនរូប បញ្ជាក់ថា ប្រជាជនដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តខុសសីលធម៌ត្រូវបានចាប់ខ្លួន[5077]។

**<u>ទំនាក់ទំនងជាមួយមន្ទីរ ស-២១ តាមរយៈក្រសួងសង្គមកិច្ច</u>**

**១២៧៣.** ទោះបីជា **អៀង ធីរិទ្ធ** បានបដិសេធថា គាត់មិនបានស្គាល់ ឌុច ឬ មិនបានដឹងពីអត្ថិភាពនៃមន្ទីរ ស-២១[5078] ក៏ដោយ ក៏ **អៀង ធីរិទ្ធ** បានទទួលស្គាល់នាពេលថ្មីៗនេះថា គាត់បានដឹងអំពីបុគ្គលិកក្រសួងរបស់ខ្លួន ដែលត្រូវបានចាប់ខ្លួន ដឹកចេញតាមរថយន្ត និងសម្លាប់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[5079]។ មានភស្តុតាងដែលថា គាត់បានចូលរួមក្នុងការចាប់ខ្លួនបុគ្គលិកជាច្រើនពីក្រសួង រួមទាំងសហការីដែលជិតស្និទ្ធនឹងរូបគាត់មួយចំនួនផងដែរ[5080]។ អ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីសួរនិងយកចម្លើយសារភាព មុននឹងយកទៅសម្លាប់។ ទោះបីចម្លើយសារភាពមួយចំនួនត្រូវបានផ្ញើទៅឱ្យ **អៀង ធីរិទ្ធ**[5081] ក៏ដោយ តួនាទីច្បាស់លាស់របស់ **អៀង ធីរិទ្ធ** ទាក់ទិននឹងការសម្រេចចាប់ខ្លួន មិនច្បាស់លាស់ទេ។

**១២៧៤.** មនុស្សជាច្រើនបានបាត់ខ្លួនពីក្រសួងសង្គមកិច្ច ឬមន្ទីរពេទ្យ និងអង្គភាពនៅក្រោមចំណុះរបស់ក្រសួងនេះ ក្នុងពេលដែល **អៀង ធីរិទ្ធ** មានអំណាចលើក្រសួង។ នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ យ៉ាងហោចណាស់មានមនុស្ស ១១៦ នាក់ ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរ ស-២១[5082]។ ការចាប់ខ្លួនលើកទីមួយបានកើតឡើងនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៦[5083] ហើយនិងចុងក្រោយនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៨[5084] ដោយមានចំនួនមនុស្សត្រូវចាប់ខ្លួនច្រើនបំផុតនៅក្នុងឆ្នាំ១៩៧៨។

**១២៧៥.** ចំនួនមនុស្សដែលបានបាត់ខ្លួនពីមន្ទីរពេទ្យ១៧-មេសា មានចំនួនច្រើនជាងកន្លែងផ្សេងៗទៀត[5085]។ នេះគឺជាការអះអាងរបស់សាក្សីមួយចំនួន ដែលធ្លាប់បម្រើការងារនៅមន្ទីរពេទ្យនេះ[5086]។ ក្នុង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605679



ចំណោមនោះ [លុប] បានឃើញដោយផ្ទាល់នូវការចាប់ខ្លួនអតីតប្រធានមន្ទីរពេទ្យ១៧-មេសា ឈ្មោះ **ឡេង ស៊ីមហាក់** ហៅ **សី** ហើយត្រូវបញ្ជូនទៅមន្ទីរ ស-២១ ក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ ១៩៧៧[5087]។ សាក្សីកត់សម្គាល់ថា ក្រោយមក សមាជិកក្នុងក្រុមគ្រួសាររបស់ **ឡេង ស៊ីមហាក់** ហៅ **សី** និងបុគ្គលិកផ្សេងៗទៀតនៃមន្ទីរពេទ្យ១៧-មេសា ត្រូវចាប់ខ្លួនជាបន្តបន្ទាប់[5088]។ [លុប] [លុប] នៅចងចាំថា **អៀង ធីរិទ្ធ** បានប្រកាសថា **ឡេង ស៊ីមហាក់** ហៅ **សី** គឺជាជនក្បត់ នៅក្នុងអង្គប្រជុំមួយ[5089]។ [លុប] អ្នកដែលចូលមកកាន់តំណែងជាប្រធាននៅមន្ទីរពេទ្យ១៧-មេសា ជំនួស **ឡេង ស៊ីមហាក់** ហៅ **សី** បានបកស្រាយថា គាត់បានទទួលការចាត់តាំងពី **អៀង ធីរិទ្ធ**[5090] ហើយគាត់បានទទួលការណែនាំដោយផ្ទាល់ពី **អៀង ធីរិទ្ធ** ឱ្យស៊ើបពីសកម្មភាពរបស់ខ្មាំង និងជាពិសេសត្រូវតាមដានឱ្យបានជាប់ ព្រមទាំងរាយការណ៍ពីបុគ្គលិកជាសមាជិកទាំងឡាយណា ដែលត្រូវបុគ្គលឯទៀត *"ឆ្លើយដាក់"* ឬ *"ចោទប្រកាន់"*[5091]។

**១២៧៦.**ការចាប់ខ្លួនមនុស្សក្នុងទ្រង់ទ្រាយធំ ក៏បានកើតឡើងនៅមន្ទីរ ក-២ ផងដែរ។ អនុរបស់ **អៀង ធីរិទ្ធ** ឈ្មោះ **ស៊ីន ផលគុណ** ហៅ ស៊ូ ត្រូវចាប់ខ្លួននៅដើមឆ្នាំ១៩៧៨ រួចបញ្ជូនទៅមន្ទីរ ស-២១[5092]។ ការចាប់ខ្លួននេះ បានប្រព្រឹត្តទៅក្រោយពីមានការចាប់ខ្លួនមនុស្សជាច្រើននៅក្នុងមន្ទីរ ក-២ នៅតាមមន្ទីរពេទ្យនិងរោងចក្រផលិតឱសថនានារបស់ក្រសួងសង្គមកិច្ច[5093]។ [លុប] នៅចាំថា ដូចគ្នានឹងករណីរបស់ **ឡេង ស៊ីមហាក់** ហៅ **សី** ដែរ **អៀង ធីរិទ្ធ** បានកោះហៅអង្គប្រជុំមួយ ដើម្បីប្រកាសថា ស៊ីន ផលគុណ ហៅ ស៊ូ គឺជាជនក្បត់[5094]។ [លុប] ជាអតីតអ្នកបើកបររថយន្តរបស់ **អៀង ធីរិទ្ធ** ក៏បានរំឭកផងដែរថា *"[អៀង ធីរិទ្ធ] ហៅបុគ្គលិកក្រសួងសង្គមកិច្ចទៅប្រជុំ ដោយប្រាប់ថា អ្នកទាំងពីរនាក់* [ស៊ូ និង ប៉ក់] *នេះក្បត់។ ព្រោះមានសារភាពពីក-៣ អានឱ្យ ស្តាប់"*[5095]។ តាមរយៈការអះអាងរបស់ [លុប] **អៀង ធីរិទ្ធ** នៅបាននិយាយទៀតថា *"យើងទាំងអស់ត្រូវធ្វើការឱ្យប្រយ័ត្នប្រយែង កុំឱ្យខុសដូចអ្នកទាំងពីរនោះ"*[5096]។

**១២៧៧.** នៅពេលត្រូវបានសាកសួរឱ្យនិយាយពីបញ្ជីឈ្មោះអ្នកទោស ដែលមានបង្ហាញពីឈ្មោះសមាជិកបុគ្គលិកមកពីក្រសួងសង្គមកិច្ច ឌុច បកស្រាយថា ការចាប់ខ្លួនមនុស្សទាំងនេះ គឺស្របគ្នាទៅនឹងការចាប់ខ្លួនមនុស្សជាច្រើនដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ហើយ ឌុច រៀបរាប់ពីដំណើរនៃប្រព័ន្ធនោះ *"កម្មាភិបាលសំខាន់ៗមួយចំនួនត្រូវបានចាប់ខ្លួនរួចហើយ គឺជាករណីឧទាហរណ៍ របស់ ស៊ីន ផលគុណ ហៅ ស៊ូ ដែលជាអនុប្រធានរបស់អៀង ធីរិទ្ធ ឬ ម៉ុក សំអុល ហៅ ហុង (ដែលជាប្រធាននៃអង្គភាពជម្ងឺគ្រុនចាញ់)។*

*អ្នកទាំងអស់នេះ ត្រូវបានសួរចម្លើយដោយមានធ្វើទារុណកម្ម ហើយបានឆ្លើយដាក់អ្នកផ្សេងទៀតដែលជាហេតុនាំឱ្យមានការចាប់ខ្លួនជាទ្រង់ទ្រាយធំ។ ការចាប់ខ្លួនទាំងនេះមិនមានហេតុផលសំអាងអ្វីផ្សេងទៀតនោះទេ ហើយ ក៏មិនមានការផ្ទៀងផ្ទាត់ជាមុនដែរ”*[5097]។

**១២៧៨.ឌុច** ពន្យល់ថា សម្រាប់អង្គភាពពិសេស មានការសម្រេចចាប់ខ្លួនដោយវិធីពីរយ៉ាងគឺ៖ ម្យ៉ាង **សុន សេន** ឬ **នួន ជា** ជាអ្នកធ្វើចំណារលើមនុស្សដែលគេឆ្លើយដាក់ ក្នុងចម្លើយសារភាព បន្ទាប់មកគឺកោះហៅប្រធានអង្គភាពនោះ (ដូចជា **អៀង ធីរិទ្ធ** ចំពោះក្រសួងសង្គមកិច្ច) ដើម្បីធ្វើការសម្រេច។ ម្យ៉ាងទៀត ប្រសិនបើមានបញ្ហាណាមួយកើតឡើងក្នុងអង្គភាព ប្រធានអង្គភាពនោះ (សម្រាប់ក្រសួងសង្គមកិច្ចគឺ **អៀង ធីរិទ្ធ**) នឹងរាយការណ៍ជូនថ្នាក់លើ ដែលនឹងសម្រេចអំពីការចាប់ខ្លួន[5098]។

**១២៧៩.ឌុច** ក៏ផ្តល់ព័ត៌មានស្តីពីរបៀបដឹកជញ្ជូនមនុស្សទៅកាន់មន្ទីរ ស-២១ ផងដែរ។ តាមការអះអាងរបស់ **ឌុច** បុគ្គលិកមន្ទីរ ស-២១ បានប្រមូលមនុស្សដែលត្រូវបានចាប់ខ្លួននៅតាមបណ្តាអង្គភាពដែលរក្សាមនុស្សទាំងនោះ រហូតដល់ឆ្នាំ១៩៧៧។ ប៉ុន្តែ នៅក្រោយឆ្នាំ១៩៧៧ អង្គភាពដែលពាក់ព័ន្ធទាំងនោះ ត្រូវទទួលបន្ទុកក្នុងការដឹកជញ្ជូនមនុស្សទៅកាន់មន្ទីរ ស-២១ វិញម្តង[5099]។ ពាក់ព័ន្ធនឹងក្រសួងសង្គមកិច្ច **ឌុច** និយាយថា គឺឈ្មោះ **លីន** ដែលជាអនុលេខាគណៈមន្ទីរ ស-៧១ និងក្រោយមកជាប្រធានមន្ទីរ ៨៧០[5100] ជាអ្នក “ពិនិត្យមើល” លើការចាប់ខ្លួន។ **ឌុច** បានប្រមូលអ្នកទោសពីក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល ដោយអនុវត្តទៅតាមបញ្ជារបស់ ប៉ុល ពត ផ្ទាល់ និងផ្តល់ដំណឹងដល់ **ឌុច** នៅពេលអ្នកទោស ធ្វើដំណើរទៅដល់[5101]។ **ឌុច** ពន្យល់ថា “*ពេលខ្លះ គេបាននាំអ្នកទោសមកតែមួយនាក់ប៉ុណ្ណោះ ដូចជាករណីរបស់ ម៉ុកសំអុល ហើយ ពេលខ្លះ នាំមក ២នាក់ក្នុងពេលតែមួយ*”[5102]។

**១២៨០.**សាក្សី [លុប] បាននិយាយថា មានមនុស្សដែលត្រូវបានគេបញ្ជូនទៅមន្ទីរ ក-៧ ដែលជាមន្ទីរនីរសារ។ គាត់ពន្យល់ថា **អៀង ធីរិទ្ធ** បានប្រាប់គាត់ឱ្យបើកឡានជូន **ស៊ីន ផលគុណ** ហៅ **ស៊ូ** ដែលជាអនុរបស់ **អៀង ធីរិទ្ធ** និងប្រធានមន្ទីរ ធ-១ ឈ្មោះ [លុប] ភេទស្រី ទៅកាន់មន្ទីរនោះ។ អ្នកបើកបររបស់ពួកគេក៏ត្រូវបញ្ជូនទៅកាន់មន្ទីរ ក-៧ ផងដែរ[5103]។

**១២៨១.**ដូចបានពន្យល់ខាងលើ **ឌុច** យល់ថា ក្រសួងសង្គមកិច្ចរបស់ **អៀង ធីរិទ្ធ** និងក្រសួងសុខាភិបាលត្រូវបានពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់ជាងក្រសួងផ្សេងទៀត[5104]។ **ឌុច** ក៏និយាយផងដែរថា

លីន *"បានលួកលាន់ការងាររបស់ អៀង ធីរិទ្ធ ដោយសារគាត់សំអាងលើការគាំទ្រពី ប៉ុល ពត"*[5105]។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមដោយ សាក្សី [លុប] ដែលធ្លាប់ស្នាក់នៅមន្ទីរ ក-២ និយាយថា *"ខ្ញុំយល់ថា គ្មានអ្នកណាក្រៅពីតានួន ជា ទេ ជាអ្នកសម្រេចចាប់ខ្លួននេះ(...) [អៀង ធីរិទ្ធ] មិនមានអំណាចចាប់មនុស្សទេ"*[5106]។

**១២៨២.** [លុប] និយាយថា *"មនុស្សបាត់ខ្លួនជាហូរហែ ដោយគេប្រាប់ថា ហៅទៅរៀនសូត្រ"*[5107]។ យោងតាម [លុប], **អៀង ធីរិទ្ធ** មានសិទ្ធ *"...ដក (បោសសម្អាត) ... និងតាមដានបុគ្គលិកមន្ទីរពេទ្យដើម្បីរកខ្មាំងស៊ីរូងផ្ទៃក្នុង"* [5108]។ ម្យ៉ាងវិញទៀត នៅពេលសួរអំពីការចាប់ខ្លួននៅមន្ទីរ ក-២ [លុប] និយាយថា *"ពេលនោះ ខ្ញុំមិនដឹងថា យាយភា ដឹងពីរឿងចាប់ខ្លួនអ្នកពីរនេះឬអត់ទេ ប៉ុន្តែខ្ញុំបានឃើញទឹកមុខរបស់គាត់ភ័យដែរ។ មានការ...ស្តីបន្ទោស យាយភា... គាត់មិនមានពាក្យអ្វីតបទេ និយាយមិនចេញ"*[5109]។

**១២៨៣.** ខណៈដែល **ឌុច** បំភ្លឺថា គាត់មិនមានទំនាក់ទំនងផ្ទាល់ជាមួយក្រសួងសង្គមកិច្ចក៏ដោយ[5110] ក៏មានចម្លើយសារភាពមួយចំនួនដែលភ្ជាប់ **អៀង ធីរិទ្ធ** ដោយផ្ទាល់ទៅមន្ទីរ ស-២១។ នៅលើចម្លើយសារភាពរបស់ **ម៉ុក សំអុល** ដែលជាអតីតប្រធានពេទ្យកម្ចាត់ជម្ងឺគ្រុនចាញ់ មានចំណារថា *"ខាងសង្គមកិច្ចដោះស្រាយអស់"*[5111] ដែលបញ្ជាក់ថា ក្រសួងសង្គមកិច្ចពាក់ព័ន្ធនឹងការចាប់ខ្លួននេះ[5112]។

**១២៨៤.** ចម្លើយសារភាពរបស់ [លុប] ជាអតីតបុគ្គលិកនៅ ផ-៤/មន្ទីរខុយម៉ិច គេឃើញមានចំណារឈ្មោះ *"ភា"* នៅខាងឆ្វេងផ្នែកខាងលើក្នុងទំព័រទី១[5113]។ នៅពេលសួរអំពីចំណារឈ្មោះ *"ភា"* នៅលើ ចម្លើយសារភាពនោះ **ឌុច** លើកឡើងថា កន្លែងហ្នឹងមានន័យថា *"ចម្លើយសារភាពនេះ ត្រូវបានផ្ញើរទៅឱ្យ* [ឲ្យ] *អៀង ធីរិទ្ធ"*[5114]។ [លុប] [លុប]។ [លុប] ដែលជាសហការីជិតស្និទ្ធរបស់ **អៀង ធីរិទ្ធ** និយាយថា **អៀង ធីរិទ្ធ** បានអានសម្រង់ចម្លើយសារភាពរបស់ប្តីគាត់ឲ្យគាត់ស្តាប់[5115]។

**១២៨៥.** ក្នុងករណីខ្លះ **អៀង ធីរិទ្ធ** រារាំង ឬ យ៉ាងហោចណាស់ក៏ពន្យារការចាប់ខ្លួនអ្នកខ្លះ ដែលគាត់គិតថាមិនមែនជាជនក្បត់។ ឧទាហរណ៍ គាត់បានការពារអ្នកបើកឡានរបស់គាត់ឈ្មោះ [លុប][5116] និងប្អូនស្រីរបស់អ្នកបើកឡាននេះឈ្មោះ [លុប]។ យោងតាម [លុប], **អៀង ធីរិទ្ធ**

ជឿជាក់ថា *"មានអ្នកក្បត់ និងគោលការណ៍ចាប់ខ្លួនអ្នកក្បត់មែន។ ... អៀង ធីរិទ្ធ ប្រាកដជាជឿថាខ្ញុំមិនក្បត់បានជាមិនចាប់ខ្ញុំ។ ចំណែកស៊ូ និងអ្នកផ្សេងទៀត ដូចជាប៉ក់ គាត់ជឿថា ក្បត់ហើយបានជាពួកនេះត្រូវបានចាប់ខ្លួនហើយ"*[5117]។ [លុប] អះអាងថា គាត់ត្រូវតែបញ្ចុះបញ្ចូល **អៀង ធីរិទ្ធ** ឲ្យជឿថា គាត់មិនមែនជាជនក្បត់ឡើយ[5118]។

**១២៨៦.** [លុប] បានលើកឧទាហរណ៍មួយផ្សេងទៀតអំពីស្ថានភាពដែល **អៀង ធីរិទ្ធ** បានប្រើប្រាស់អំណាចធ្វើអន្តរាគមន៍របស់ខ្លួន។ [លុប] ពន្យល់ថា ស្វាមីគាត់ឈ្មោះ [លុប] ត្រូវបានគេសង្ស័យថាជាសមាជិករបស់ សេ.អ៊ី.អា តាំងពីដើមឆ្នាំ១៩៧៧[5119]។ [លុប] បានប្រាប់អំពីការនិយាយសន្ទនារបស់ខ្លួនជាមួយនឹង **ស៊ុន ផលគុណ** ហៅ **ស៊ូ** ថា *"ឲ្យទៅសាកសួរស្វាមីនាងខ្ញុំ ថាតើគាត់មានបានចូលរួមក្នុងចលនា CIA ឬទេ។ ហើយប្រសិនណាជាគាត់បានចូលរួមមែននោះ នឹងអាលគាត់ (លោកស្រី ស៊ូ) ចេញមុខធានា"* [5120]។ យោងតាម [លុប] អន្តរាគមន៍របស់ **អៀង ធីរិទ្ធ** បានពន្យារពេលចាប់ខ្លួន [លុប] មួយឆ្នាំ។ [លុប] ពន្យល់ថា ក្រោយពីគេចាប់ស្វាមីរបស់គាត់ **អៀង ធីរិទ្ធ** បានប្រាប់គាត់ថា *"បង [លុប] ប្រាកដជាត្រូវបានចាប់ខ្លួនជាមួយនឹងមនុស្សពីរនាក់ទៀត ដែលត្រឡប់មកពីស្រុកប្រទេសបារាំងជាមួយគាត់ដែរ ហើយថាគាត់ (អៀង ធីរិទ្ធ) ក៏បានជំទាស់ទៅលើការចាប់ខ្លួនស្វាមីរបស់នាងខ្ញុំដែរ... គាត់នឹងសុំ "បង" ដើម្បីសុំ ឲ្យដោះលែងបង [លុប] ចេញពីគុក និងបញ្ជូនគាត់ទៅមន្ទីរលត់ដំ"*[5121]។ ប៉ុន្តែចម្លើយសារភាពរបស់ [លុប] ដែលមានសល់នៅមន្ទីរ ស-២១ បានបង្ហាញថា [លុប] ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[5122]។ [លុប] ពន្យល់ផងដែរថា **អៀង ធីរិទ្ធ** បានការពារជីវិតរបស់គាត់ ដោយ **អៀង ធីរិទ្ធ** បានដាក់ទណ្ឌកម្មគាត់ដោយបញ្ជូនគាត់ទៅចំការអំពៅ ក្រោយពេលគេចោទគាត់ថាបានសមគំនិតជាមួយនឹង **ស៊ុន ផលគុណ** ហៅ **ស៊ូ**[5123]។

**១២៨៧.** វាទំនងជាថា **អៀង ធីរិទ្ធ** មិនអាចអន្តរាគមន៍គ្រប់ពេលទេ ដូចក្នុងករណីចាប់ខ្លួនប្រធានមន្ទីរពេទ្យព្រះកុសុមៈ ដែលគេរាយការណ៍ថា **អៀង ធីរិទ្ធ** បាននិយាយថា *"ម្នាក់នេះមិនសមក្បត់ទេ"* [5124]។

## ការប្រព្រឹត្តលើក្រុមមនុស្សជាក់លាក់នានា

**១២៨៨.** តាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុង ប.ក.ក **អៀង ធីរិទ្ធ** បានចូលរួមនៅក្នុងវិធានការនានាដែលកំណត់ជាគោលដៅចំពោះក្រុមមនុស្សជាក់លាក់មួយចំនួន។

## ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

១២៨៩.នៅពេលសួរអំពីរបៀបដែលបុគ្គលិកមន្ទីរពេទ្យ ១៧-មេសា ត្រូវបានជ្រើសរើសយកចេញ សាក្សីមួយរូបដែលបានធ្វើការនៅមន្ទីរពេទ្យនោះ ពីឆ្នាំ១៩៧៥ ពន្យល់ថា អ្នកដែលមាន "និន្នាការ" មិនត្រូវបានរើសយកទេ ដោយមិនគិតពីជំនាញរបស់ពួកគេ។ ចំពោះគាត់ ពាក្យនេះមានន័យថា ជាការជាប់ពាក់ព័ន្ធនឹងអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ។ គាត់ក៏ពន្យល់ដែរថា *"បើស្គាល់គឺពិបាកហើយ ពេលគឺត្រូវយកទៅលត់ដំ ឬបាត់ខ្លួនរហូត ឬយកទៅវៃចោល"*[5125] ។

## ការប្រព្រឹត្តលើជនជាតិវៀតណាម

១២៩០.**អៀង ធីរិទ្ធ** បានដឹងពីការប្រព្រឹត្តចំពោះជនជាតិវៀតណាម តាមរយៈតួនាទីផ្នែកការទូត ស្ថានភាពគ្រួសារ និងទំនាក់ទំនងរបស់គាត់ជាមួយថ្នាក់ដឹកនាំផ្សេងៗទៀតរបស់ ប.ក.ក និងតាមរយៈប្រព័ន្ធឃោសនារបស់បក្ស ដែលត្រូវបានផ្សព្វផ្សាយតាមវិទ្យុ និងភាពយន្ត។ ឧទាហរណ៍ សុន្ទរកថារបស់ **អៀង សារី** ជាបន្តបន្ទាប់ ដែលញុះញង់ឱ្យស្អប់ខ្ពើមជនជាតិវៀតណាមត្រូវបានចាក់ផ្សាយតាមវិទ្យុ[5126]។ ចម្លើយសារភាពរបស់ទាហានវៀតណាមដែលត្រូវចាប់ខ្លួន ត្រូវបានថតសំឡេង និងផ្សាយតាមវិទ្យុ ដើម្បីធ្វើការឃោសនាផ្សព្វផ្សាយផងដែរ[5127]។ លើសពីនេះទៀត នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ** បានចូលរួមការបញ្ចាំងភាពយន្តមួយ ដែលញុះញង់ឱ្យស្អប់ខ្ពើមទឹងវៀតណាម[5128]។

១២៩១.**អៀង ធីរិទ្ធ** ទំនងជាបានថ្លែងសុន្ទរកថាដោយខ្លួនឯងផ្ទាល់ ដែលបង្ហាញពីការញុះញង់ឱ្យស្អប់ខ្ពើមប្រឆាំងនឹងជនជាតិវៀតណាម។ នៅក្នុងការប្រជុំមួយនៅមន្ទីរពេទ្យ ១៧-មេសា មានសេចក្តីរាយការណ៍ឱ្យដឹងថា **អៀង ធីរិទ្ធ** បាននិយាយថា *"ស/ម យកល.ការណ៍* [សមមិត្តយកលក្ខការណ៍] *របស់បក្ស យកមកដាក់លើក្បាលគ្រប់ពេលរបស់មិត្ត អនុវត្តទៅ តើនៅខាងបក្ស ឬនៅខាងយួន"... "ខ្មាំងយួនក្រោយចាញ់ វាបានចូលមកបញ្ហារលើ* [បញ្ហាលើក]*ទីII. ប៉ុនប៉ងវាយប្រហារកម្ពុជាប្រជាធិបតេយ្យយើង. ពួកវាបានប្រមូល* [បង្រួម] *មកត្រឹមភូ/បូព៌ា នៅជិតយួន... បានកំទេចរដ្ឋប្រហារនេះបានទាំងស្រុង... លើខ្មាំងយួនឱ្យវាស្រងាកមែន... មន្ទីរពេទ្យប/វ* [បដិវត្ត] *យើងបានរួមចំណែកយ៉ាងណាដែរ បានរួមចំណែកវាយខ្មាំងរដ្ឋប្រហារ ដោយមហាជ័យប/វយើង។*


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605684



*...បានសំពងវាយប្រឆាំងខ្មាំងឃ្មួនណ្តានពាន-វាតទីលេបទឹកដី*[5129]។ សុន្ទរកថានេះត្រូវបានធ្វើឡើង នៅក្នុងបរិបទនៃការសម្លាប់រង្គាលប្រជាជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងនៅកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា ដូចមានបរិយាយលម្អិតនៅក្នុងផ្នែកទាក់ទងនឹងអង្គហេតុនៃដីកាដំណោះស្រាយនេះ។

**១២៩២.** ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **អៀង ធីរិទ្ធ** បានធ្វើសេចក្តីថ្លែងការណ៍ជាច្រើន ជាថ្មីទៀតប្រឆាំងជនជាតិវៀតណាម។ ឧទាហរណ៍ នៅឯសន្និសីទអន្តរជាតិដើម្បីសាមគ្គីភាពជាមួយកម្ពុជា នៅថ្ងៃទី ១៧-១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៩[5130] ឬនៅក្នុងបទសម្ភាសន៍ដែលគាត់បានផ្តល់នៅឆ្នាំ១៩៨០ **អៀង ធីរិទ្ធ** បាននិយាយថា គោលនយោបាយមានលក្ខណៈដាច់ខាត និងប្រទូស្តរាយភាគច្រើនចេញមកពីការគំរាមកំហែងរបស់វៀតណាម[5131]។

## ការរៀបអាពាហ៍ពិពាហ៍

**១២៩៣.** តាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុង ប.ក.ក. **អៀង ធីរិទ្ធ** បានចូលរួមចំណែកក្នុងការចេញបទបញ្ញត្តិរៀបអាពាហ៍ពិពាហ៍។

**១២៩៤.** ប្រព័ន្ធរៀបអាពាហ៍ពិពាហ៍ដែលរៀបចំដោយបក្ស ត្រូវបានសរសេរនៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក[5132] ដែល **អៀង ធីរិទ្ធ** អាចបានអាន និងចែកចាយនៅក្នុងក្រសួងរបស់គាត់[5133]។

**១២៩៥.** **អៀង ធីរិទ្ធ** បានរៀបចំអាពាហ៍ពិពាហ៍ឲ្យបុគ្គលិកក្រសួងរបស់គាត់៖ អតីតកម្មាភិបាលថ្នាក់ខ្ពស់នៃមន្ទីរ ក-២ មួយរូប [លុប] បាននិយាយថា *"អៀង ធីរិទ្ធ បានសារភាពប្រាប់ខ្ញុំថាគាត់ទុកខ្ញុំសម្រាប់បុរសម្នាក់ទៀត គឺបុរសម្នាក់ដែលធ្វើការជាមួយប្តីរបស់គាត់ អៀង សារី"*[5134] និងនៅក្នុងបទសម្ភាសន៍មួយផ្សេងទៀត ថា *"គាត់បានប្រាប់នាងខ្ញុំទៀតថា ពីដំបូង គាត់មិនចង់ឲ្យនាងខ្ញុំរៀបការជាមួយ* [លុប] *ទេ គឺគាត់ចង់ឲ្យនាងខ្ញុំរៀបការជាមួយបុរសម្នាក់ដែលធ្វើការជាមួយប្តីរបស់គាត់ ជាជនជាតិខ្មែរលើ"*[5135]។

១២៥៦.យ៉ាងហោចណាស់ ចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ **អៀង ធីរិទ្ធ** បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និងវៀតណាម។

១២៥៧.**អៀង ធីរិទ្ធ** បានដឹងអំពីស្ថានភាពជម្លោះ តាមរយៈតួនាទីផ្នែកការទូតរបស់គាត់ តាមរយៈស្ថានភាពគ្រួសារ និងការពាក់ព័ន្ធនានារបស់គាត់ជាមួយនឹងមេដឹកនាំផ្សេងទៀតនៃ ប.ក.ក[5136]។ **អៀង ធីរិទ្ធ** បានទទួលការចម្លងជូនយ៉ាងហោចណាស់ ទូរលេខមួយច្បាប់ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលរាយការណ៍ពីស្ថានការណ៍ជម្លោះនៅតំបន់២៣ ការផ្លាស់ទីលំនៅប្រជាជនចេញពីបណ្តាទីក្រុងធំៗស្ថិតនៅតាមព្រំដែន និងស្ថានការណ៍ថ្នាំសង្កូវ[5137]។ ស្ថានការណ៍ការពារប្រទេសនោះ ត្រូវបានលើកយកមកពិភាក្សានៅក្នុងបណ្តាអង្គប្រជុំ ដែលគាត់បានចូលរួមនៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨[5138] ហើយក៏មានការនិយាយអំពីជម្លោះប្រដាប់អាវុធនេះនៅក្នុងការផ្សាយវិទ្យុផងដែរ[5139]។

១២៥៨.**អៀង ធីរិទ្ធ** បានអះអាងថា គាត់បានដឹងជាប្រចាំអំពីអត្ថិភាពនៃជម្លោះនេះ រហូតដល់ចុងបញ្ចប់នៃរបប នៅក្នុងបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានមួយរូប ក្នុងឆ្នាំ១៩៨០[5140]។

# ជំពូក ២ - ច្បាប់ដែលត្រូវអនុវត្ត

## ផ្នែកទី ១- យុត្តាធិការរបស់ អ.វ.ត.ក

១២៥៩.ក្នុងអំឡុងពេលនៃដំណើរការស៊ើបសួរ មានបញ្ហាជាច្រើនបានចោទឡើងទាក់ទងនឹងច្បាប់ដែលត្រូវអនុវត្តដែលបញ្ហាទាំងនោះពាក់ព័ន្ធទាំងជាមួយនឹងការកំណត់យកនិយមន័យនៃ "បទល្មើស" និង "ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ" ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[5141]។ ដោយយោងទៅលើសំអាងដែលមានរៀបរាប់ខាងក្រោមនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទាំងបទល្មើស ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកំណត់នៅក្នុងផ្នែកនេះនៃដីកាដំណោះស្រាយ ស្របទៅនឹងគោលការណ៍នីត្យានុកូលភាព ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605686



១៣០០.ជាក់ស្តែង អនុលោមតាមកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក. អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងដោយច្បាប់ ក្នុងទម្រង់ជាស្ថាប័នយុត្តាធិការដែលឋិតនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា ដើម្បីធ្វើការជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើដែលបានប្រព្រឹត្តឡើងនៅក្នុងសម័យកាលចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដែលជាឧក្រិដ្ឋកម្ម និងការបំពារបំពានធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា លើវិធាន និងទំនៀមទម្លាប់នៃច្បាប់មនុស្សធម៌អន្តរជាតិ ក៏ដូចជាលើអនុសញ្ញាអន្តរជាតិនានាដែលកម្ពុជាបានផ្តល់សច្ចាប័ន[5142] ។

១៣០១. បញ្ហាដែលថា តើ អ.វ.ត.ក. ជាស្ថាប័នយុត្តាធិការជាតិ ឬអន្តរជាតិ មិនមានបង្កើតជាផលវិបាកអ្វីចំពោះ សមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះនោះទេ[5143] ដរាបណាគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង/ nullum crimen sine lege* ត្រូវបានគោរព[5144] ។

១៣០២. អនុលោមតាមគោលការណ៍នេះ ដែលមានចែងនៅក្នុងមាត្រា ៣៣(២)(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលយោងទៅដល់មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិឬច្បាប់អន្តរជាតិនៅខណៈពេលប្រព្រឹត្តនោះឡើយ[5145] ។ ដូច្នេះ ដើម្បីអាចឲ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេលដែលអំពើនោះកើតឡើងនោះទេ[5146] នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ ឬដោយតុណ្ហីភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិដែលអនុវត្តនៅក្នុងប្រទេសកម្ពុជានៅខណៈពេលដែលអំពើនោះបានកើតឡើងផងដែរ[5147]។ ប្រភពនៃច្បាប់អន្តរជាតិដែលអនុវត្តនោះ រួមមានច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិ ក៏ដូចជាគោលការណ៍ទូទៅនៃនីតិដែលត្រូវបានទទួលស្គាល់ដោយសហគមន៍នៃបណ្តាប្រជាជាតិនានាផងដែរ[5148]។ ជាងនេះទៀត ច្បាប់ទាំងនេះត្រូវតែមានការផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ នៅខណៈពេលដែលអង្គហេតុបានកើតឡើង ហើយជនជាប់ចោទត្រូវឋិតក្នុងសភាពដែលអាចព្យាករជាមុនថា ពួកគេអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ពួកគេ នៅក្នុងបញ្ហានេះ ចរិតលក្ខណៈសាហាវយង់ឃ្នងនៃអំពើអាចត្រូវ

00605687



បានយកមកពិចារណា[5149] ។

១៣០៣. គោលការណ៍ទាំងអស់ ដែលបានរៀបរាប់ខាងលើនេះ ត្រូវអនុវត្តផងដែរចំពោះទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌផ្សេងៗទៀត[5150] ។

១៣០៤.ពាក់ព័ន្ធនឹងបញ្ហានៃភាពដែលអាចអនុវត្តដោយផ្ទាល់នៃច្បាប់អន្តរជាតិ នៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវរំលឹកឡើងវិញថា មាត្រា១ និងមាត្រា២ និងមាត្រា២៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក. បានដាក់បញ្ចូលក្នុងច្បាប់កម្ពុជានូវការរំលោភបំពានច្បាប់អន្តរជាតិមួយចំនួន ដែលត្រូវឋិតនៅក្រោមយុត្តាធិការ របស់ អ.វ.ត.ក (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះ ប្រដាប់អាវុធ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការ ការពារជាអន្តរជាតិ[5151]) ក៏ដូចជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវអនុវត្ត (ដោយបញ្ចូលផងដែរនូវរបបទោស បញ្ញត្តិ ដែលអនុលោមតាមគោលការណ៍ *មិនមានទោសប្រសិនបើគ្មានច្បាប់ចែង/nulla poena sine lege*[5152]) ។ ដោយយោងទៅលើបទប្បញ្ញត្តិទាំងនេះ បញ្ហាដែលចោទឡើងថា តើច្បាប់អន្តរជាតិអាច ឬមិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជានឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. នោះឡើយ[5153] ។

១៣០៥.ម្យ៉ាងវិញទៀត បទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដែលចែងអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ[5154] គឺមានអនុភាពគតិយុត្តចាប់បង្ខំតម្រូវឲ្យកម្ពុជាត្រូវតែគោរពតាមដូចមានបកស្រាយខាងក្រោមនេះ[5155] ក្នុងន័យនេះ បទប្បញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាបានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដែលអាចឲ្យជនត្រូវចោទទទួលបានព័ត៌មាន ក្នុងឋានៈដែលខ្លួនជាសមាជិកនៃថ្នាក់ដឹកនាំកម្ពុជា ។

១៣០៦.ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ ការកំណត់ថាអំពើនេះជាបទល្មើសដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ ដល់ជនត្រូវចោទ[5156] តាមរយៈការជំនុំជម្រះ នានាដែលបានធ្វើឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ នៅទីក្រុងណ្យូរ៉ែម

00605688



ប៉ើក និងតូក្ស ជាដើម[5157] ។

១៣០៧. ក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក. ក៏មានទម្រង់នៃការទទួលខុសត្រូវមួយចំនួនត្រូវបានទទួលស្គាល់ផងដែរនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដូចមានបញ្ជាក់ខាងក្រោមនេះ[5158] ។ ហេតុដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ជនត្រូវចោទ។ ហើយចំពោះទម្រង់នៃការទទួលខុសត្រូវដែលនៅសេសសល់វិញ ដូចជា សហឧក្រិដ្ឋកម្មរួម (JCE) ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាក៏ត្រូវបានទទួលស្គាល់ផងដែរដោយច្បាប់អន្តរជាតិ ឆ្លងតាមរយៈការជំនុំជម្រះ នានាដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានចាត់ទុកថា បានផ្សព្វផ្សាយទូលំទូលាយ និងគ្រប់គ្រាន់ដល់ ជនត្រូវចោទ[5159] ។

១៣០៨.ជាមួយនឹងគោលការណ៍ទាំងនេះ ចាំបាច់ត្រូវកត់សម្គាល់ថា គោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង/ nullum crimen sine lege* មិនរារាំងដល់សហចៅក្រមស៊ើបអង្កេតក្នុងការបកស្រាយបទប្បញ្ញត្តិ ដែលទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការរបស់ខ្លួនឡើយ[5160] ហើយប្រសិនបើចាំបាច់អាចយោងទៅដល់យុត្តិសាស្ត្រ របស់តុលាការអន្តរជាតិផ្សេងៗទៀត[5161]។ ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋនីមួយៗ នឹងមានបកស្រាយលម្អិតនៅក្នុងដីកាដំណោះស្រាយនេះ ត្រង់ផ្នែកស្តីអំពីការកំណត់ប្រភេទបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ។

១៣០៩.កំណត់សម្គាល់អំពីច្បាប់ដែលត្រូវអនុវត្តខាងលើនេះ ដែលចាំបាច់ដល់ការកំណត់ប្រភេទបទល្មើសលើអង្គហេតុដែលបានរៀបរាប់មកនេះ និងចាំបាច់ដល់ការកំណត់ទម្រង់នៃការទទួលខុសត្រូវដែលសមស្រប ដោយអនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង គឺមានលក្ខណៈគ្រាន់តែជាកំណត់សម្គាល់បឋមតែប៉ុណ្ណោះ គឺវាមិនប៉ះពាល់ដល់សិទ្ធិក្នុងលើកឡើងនូវបញ្ហានានាពាក់ព័ន្ធនឹង សមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ក្រោមទម្រង់ជាអញ្ញត្រកម្មមុនអង្គសេចក្តីនៅមុខអង្គជំនុំជម្រះសាលាដំបូង នោះឡើយ ដោយអនុលោមតាមវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ។

# ផ្នែក ទី ២- និយមន័យនៃឧក្រិដ្ឋកម្ម

## ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

១៣១០. នៅពេលដែលប្រទេសកម្ពុជាចូលក្នុង "សហភាពបារាំង" ក្នុងឆ្នាំ១៩៤៩ ប្រទេសកម្ពុជាបានទទួលនូវស្វ័យភាពអធិបតេយ្យគ្រប់គ្រាន់ ក្នុងការចូលជាសមាជិកនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[5162]។ អង្គការសហប្រជាជាតិបានទទួលយកការផ្តល់សច្ចាប័នចូលជាសមាជិករបស់កម្ពុជា ហើយក៏មិនមានការជំទាស់លើទិដ្ឋភាពគតិយុត្តណាមួយផងដែរ។ អនុសញ្ញានេះបានទទួលនូវការផ្តល់សច្ចាប័នចូលជាសមាជិកចំនួន ២០ ដែលចាំបាច់ដល់ការចូលជាធរមាននៅក្នុងឆ្នាំ១៩៥១[5163]។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង[5164] ។

១៣១១. គួរកត់សម្គាល់ថា នៅក្នុងអត្ថបទច្បាប់នានាដែលពាក់ព័ន្ធនឹង អ.វ.ត.ក. មានអត្ថបទខ្លះនៃការឲ្យនិយមន័យអំពីឧក្រិដ្ឋកម្មនេះ បានទុកលទ្ធភាពឲ្យមានការបកស្រាយថា ចំនួននៃបទល្មើសជាក់លាក់ នៃឧក្រិដ្ឋកម្មនេះ មិនកម្រិតត្រឹមអ្វីដែលមានរៀបរាប់ក្នុងនិយមន័យនោះទេ[5165] ។ ដូច្នេះ ដើម្បីបង្ការការរំលោភបំពានលើគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង/ nullum crimen sine lege* ដោយផ្អែកលើមាត្រា ៩ នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក. និងមាត្រា៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលមានខ្លឹមសារថា៖ *"អង្គជំនុំជម្រះមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨"* សហចៅក្រមស៊ើបអង្កេតសម្រេចទទួលយកនិយមន័យជាអន្តរជាតិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ[5166] ។

១៣១២. យោងតាមការបកស្រាយមកខាងលើ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម ដោយមានចេតនាជាក់លាក់[5167] ដើម្បីបំផ្លាញ[5168] ទាំងស្រុង ឬដោយផ្នែក[5169] ទៅលើក្រុមជាតិ[5170] ជាតិពន្ធុ[5171] ពូជសាសន៍[5172] ឬសាសនា[5173] ត្រឹមប៉ុណ្ណឹង[5174] ដូចជា៖ អំពើមនុស្សឃាតលើសមាជិកក្រុម[5175] ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពរាងកាយ[5176] ឬផ្លូវចិត្ត[5177]នៃសមាជិកក្រុម ការដាក់ដោយចេតនានូវក្រុមមនុស្សនៅក្រោមលក្ខខណ្ឌរស់នៅលំបាក[5178] ដែលនាំឲ្យមានការបំផ្លាញសុខភាពរាងកាយទាំងស្រុង ឬ

ដោយផ្ទែក[5179] វិធានការដែលរារាំងដល់ការមានគភ៌របស់សមាជិកក្រុម[5180] ឬការជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត[5181] ។

## ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៣១៣. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង[5182] ។

១៣១៤. អនុលោមតាមគោលការណ៍ *មិនមានបទល្មើសប្រសិនបើគ្មានច្បាប់ចែង/nullum crimen sine lege* ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តែងឡើងតាមរយៈការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម នៅក្នុងក្របខណ្ឌនៃការវាយប្រហារ[5183]ជាទូទៅ ឬជាប្រព័ន្ធ[5184] ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល[5185] ដូចជា៖ ការធ្វើមនុស្សឃាត[5186] ការសម្លាប់រង្គាល[5187] ការធ្វើឱ្យទៅជាទាសករ[5188] ការនិរទេស[5189] ការដាក់ក្នុងមន្ទីរឃុំឃាំង[5190] ការធ្វើទារុណកម្ម[5191] ការរំលោភលើផ្លូវភេទ[5192] ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា[5193] និងរួមទាំងអំពើអមនុស្សធម៌ផ្សេងទៀត[5194] ដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំ[5195] អំពើហិង្សាផ្លូវភេទ[5196] ការបាត់ខ្លួនដោយបង្ខំ[5197] និងការជម្លៀសប្រជាជនដោយបង្ខំ[5198] ។

១៣១៥. គួរកត់សម្គាល់ថា ចំពោះនិទ្ទេស *"មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"* ដែលសរសេរជា "ធាតុផ្សំរួម" នៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និទ្ទេសនេះមិនអាចត្រូវបានបកស្រាយថា បានបន្ថែមធាតុផ្សំបទល្មើសទៅក្នុងនិយមន័យនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ[5199]៖ និទ្ទេសនេះវាគ្រាន់តែជាការកំហិតមួយដែលបង្កើតឡើងដោយច្បាប់ ចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. តែប៉ុណ្ណោះ[5200] ។ ការបង្កើតឡើងនូវលក្ខខណ្ឌបន្ថែមនេះ បានធ្វើឱ្យនិយមន័យនៃឧក្រិដ្ឋកម្មនេះមានលក្ខណៈតឹងរឹងជាងមុន (ដូច្នេះវាជាប្រយោជន៍ដល់ជនត្រូវចោទ) ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេចទទួលយកនិយមន័យដែលមានលក្ខណៈតឹងរឹង ដែលផ្តល់ដោយមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១...។

## គ.ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩

**១៣១៦.** "ការបំពារបំពានធ្ងន់ធ្ងរ" លើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានចាត់ជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង[5201] ។ អនុសញ្ញាទាំងនេះបានចូលជាធរមាននៅថ្ងៃទី២១ ខែតុលា ឆ្នាំ ១៩៥០ ។ ប្រទេសកម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨ ក្នុងឋានៈជារដ្ឋអធិបតេយ្យ ហើយមិនមានការជំទាស់លើទិដ្ឋភាពគតិយុត្តណាមួយទាក់ទងនឹងការចូលជាសមាជិកនេះឡើយ ។

**១៣១៧.** ធាតុផ្សំនៃឧក្រិដ្ឋកម្មបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ស្តែងឡើងតាមរយៈការប្រព្រឹត្តអំពើណាមួយ ឬការខកខានមិនបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោមនេះ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ[5202] ប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលទទួលបានការការពារក្រោមបទប្បញ្ញត្តិនៃអនុសញ្ញានេះ[5203] ដូចជា៖ ការធ្វើមនុស្សឃាតដោយចេតនា[5204] ការធ្វើទារុណកម្ម[5205] ឬការធ្វើបាបដោយអមនុស្សធម៌[5206] ការបង្កដោយចេតនាឲ្យមានការឈឺចាប់ខ្លាំង ឬឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព[5207] ការបំផ្លាញ ឬធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធា និងធ្វើឡើងដោយខុសច្បាប់ និងរំលោភបំពាន[5208] ការបង្ខំឲ្យអ្នកទោសសង្គ្រាម ឬជនស៊ីវិលធ្វើការនៅក្នុងកងកម្លាំងសត្រូវ[5209] ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់[5210] ការនិរទេស ឬការជម្លៀសចេញដោយខុសច្បាប់[5211] ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[5212] ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង[5213] ។

## ផ្នែកទី ៣. ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

**១៣១៨.** ទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលមានរៀបរាប់នៅក្នុងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សុទ្ធតែត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជា ក្នុងពេលដែលអង្គហេតុបានកើតឡើង[5214]។ អនុលោមតាមមាត្រានេះ ជនសង្ស័យណាមួយដែលបានប្រព្រឹត្ត[5215] (រួមបញ្ចូលផងដែរនូវការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម/JCE[5216]៖ JCEI ឬ JCEII[5217]) បញ្ជាឲ្យប្រព្រឹត្ត[5218] ញុះញង់ឲ្យប្រព្រឹត្ត[5219] រៀបចំផែនការ[5220] ឬសមគំនិតដោយ

ការជួយ ឬជម្រុញ[5221]ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ។

១៣១៩. មាត្រា ២៩ (ថ្មី) ក៏បានចែងផងដែរថា ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលឋិតនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. ដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់ នៅពេលដែលថ្នាក់លើបានដឹង ឬមានហេតុផលដែលត្រូវដឹងថា ថ្នាក់ក្រោមបានប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយក្នុងចំណោមនោះ និងនៅក្នុងក្របខណ្ឌនៃការអនុវត្តអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពលើអ្នកក្រោមបង្គាប់ ថ្នាក់លើមិនបានចាត់វិធានការចាំបាច់ និងសមរម្យ ដើម្បីរារាំង ឬបង្ក្រាបការប្រព្រឹត្តអំពើទាំងនោះ[5222]។ ទម្រង់នៃការទទួលខុសត្រូវនេះ ក៏អនុវត្តផងដែរចំពោះថ្នាក់លើក្នុងស្ថាប័នស៊ីវិល ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយថ្នាក់ក្រោមបង្គាប់របស់ខ្លួន[5223] ។

## ផ្នែកទី ៤. សញ្ញាណនៃភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់

១៣២០. ក្នុងអំឡុងពេលនៃការសម្រេចអំពីចំណាត់ការបន្តនៃការស៊ើបសួរ ចាំបាច់ត្រូវធ្វើការបញ្ជាក់អំពី "កម្រិតនៃភស្តុតាង" ដែលតម្រូវនៅក្នុងការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ។

១៣២១. ទាំងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. និងច្បាប់កម្ពុជា មានបញ្ញត្តិយោងទៅដល់សញ្ញាណនៃពាក្យថា *"ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់[5224]"* ប៉ុន្តែមិនមានការឲ្យនិយមន័យច្បាស់លាស់ណាមួយចំពោះខ្លឹមសារនៃពាក្យនេះនោះឡើយ។ ដោយហេតុថា មិនមានយុត្តិសាស្ត្ររបស់តុលាការកម្ពុជាទាក់ទងនឹងសញ្ញាណនេះ សហចៅក្រមស៊ើបអង្កេតត្រូវយោងទៅលើយុត្តិសាស្ត្ររបស់តុលាការបារាំង (ច្បាប់កម្ពុជាមានឫសគល់ដូចគ្នានឹងច្បាប់បារាំង) ក៏ដូចជាទៅលើទ្រឹស្តីច្បាប់[5225] និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ ដោយអនុលោមតាមវិធាន ២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក. មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ព្រមទាំងមាត្រា ១២ នៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៦ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិជាមួយនឹងព្រះរាជាណាចក្រកម្ពុជា ។

១៣២២. ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងក៏មានបញ្ញត្តិយោងទៅដល់សញ្ញាណនៃពាក្យថា *"ភស្តុតាងដាក់*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១...។

*បន្ទុកគ្រប់គ្រាន់*[5226]" នេះផងដែរ ប៉ុន្តែក៏នៅមិនមានការផ្តល់និយមន័យឱ្យបានច្បាស់លាស់ដដែល ។ យុត្តិសាស្ត្ររបស់តុលាការបារាំងក៏ដូចគ្នា គឺមិនបានផ្តល់និយមន័យឱ្យសញ្ញាណមួយនេះនោះឡើយ[5227]៖ នៅក្នុងការអនុវត្តជាក់ស្តែង ការវាយតម្លៃអំពីអត្ថិភាពនៃភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ គឺឋិតនៅក្នុង "ការវាយតម្លៃជាឥស្សរចិត្ត" របស់យុត្តាធិការស៊ើបសួរ (យុត្តាធិការនេះមិនត្រូវបានតម្រូវឱ្យប្រើប្រាស់ នូវលក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយ ក្នុងការវាយតម្លៃអំពីអត្ថិភាពនៃភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នេះនោះទេ) ហើយតុលាការកំពូលបារាំងមិនមានអំណាចវិនិច្ឆ័យលើការវាយតម្លៃ ដែលធ្វើឡើងដោយយុត្តាធិការស៊ើបសួរនោះឡើយ[5228] ។

១៣២៣. ទោះបីជានៅក្នុងច្បាប់បារាំង មានការផ្តល់នូវអំណាចឆន្ទានុសិទ្ធិដ៏សំខាន់នេះទៅឱ្យយុត្តាធិការស៊ើបសួរក៏ដោយ ក៏ទ្រឹស្តីច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការបានផ្តល់ជាពន្លឺខ្លះៗទាក់ទងនឹងការប៉ាន់ប្រមាណអំពីកម្រិតនៃភស្តុតាងដែលតម្រូវនៅក្នុងការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ នោះផងដែរ។ នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទនោះទេ (អង្គជំនុំជម្រះសាលាដំបូង គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នេះ)[5229] ប៉ុន្តែចាំបាច់ត្រូវមានការបង្ហាញអំពី "*ភាវនីយភាព*" នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា) ។ ហេតុដូច្នេះ ការវាយតម្លៃអំពីភស្តុតាងដាក់បន្ទុកនៅក្នុងដំណាក់កាលនេះ មានលក្ខណៈខុសពីសញ្ញាណនៃ "ជំនឿស៊ប់" របស់ចៅក្រមនៅក្នុងដំណាក់កាលជំនុំជម្រះ[5230] ប៉ុន្តែភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់ (ភស្តុតាងដែលត្រូវយកជាបានការរហូតដល់មានភស្តុតាងផ្ទុយ = Force Probante) [5231] ។

១៣២៤. យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC បានបង្ហាញឱ្យឃើញនូវទស្សនទានស្រដៀងគ្នានេះ ចំពោះលក្ខណៈវិនិច្ឆ័យដែលត្រូវប្រកាន់យកនៅក្នុងការទទួលយកបទចោទប្រកាន់នៅក្នុងដំណាក់កាលមុនអង្គសេចក្តី៖ ចាប់តាំងពីសេចក្តីសម្រេចនៅក្នុងរឿងក្តី Lubanga មក តុលាការព្រហ្មទណ្ឌអន្តរជាតិបានអនុម័តយកជំហរតែមួយថា៖ "*បន្ទុកនៃភស្តុតាងដែលអយ្យការត្រូវបំពេញ គឺត្រូវស្វែងរកភស្តុតាងណាដែលមានលក្ខណៈពិត និងជាក់ស្តែង ដែលបង្ហាញអំពីទិសដៅមួយច្បាស់លាស់នៅក្នុងការវិភាគដើម្បីនឹងធ្វើការចោទប្រកាន់អំពីបទល្មើសណាមួយ*[5232]" ។

១៣២៥. លក្ខន្តិកៈ និងវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី (ICTY)


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

និងរ៉ាន់ដា (ICTR) បានកំណត់ថា៖ *"ត្រូវមានភស្តុតាងគ្រប់គ្រាន់ដែលផ្តល់ជាមូលដ្ឋាននាំឱ្យជឿថា ជនសង្ស័យបានប្រព្រឹត្តបទល្មើស[5233]"* ។ យោងតាមយុត្តិសាស្ត្ររបស់ ICTY *"ភស្តុតាងបឋម [...] គឺជាភស្តុតាងដែលគួរឱ្យជឿជាក់ ដែល (ប្រសិនបើមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី) នឹងអាចក្លាយជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីវិនិច្ឆ័យជនត្រូវចោទលើបទចោទប្រកាន់ដែលមាន[5234]"* ។ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការ ICTR *"ពាក្យថា មូលដ្ឋានសមស្រប អាចបកស្រាយថា ជាអង្គហេតុ និងកាលៈទេសៈដែលអាចនាំឱ្យបុគ្គលម្នាក់ដែលមានការគិតគ្រប់ជ្រុងជ្រោយ និងមានហេតុផលជឿជាក់ថា ជនសង្ស័យបានប្រព្រឹត្តឧក្រិដ្ឋកម្ម"។ ដើម្បីបង្ហាញអំពីអត្ថិភាពនៃហេតុផលសមរម្យ ត្រូវបង្ហាញអំពីអង្គហេតុដែលនាំឱ្យមានការសង្ស័យច្បាស់លាស់ថា ជនសង្ស័យមានពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសនោះ[5235]"* ។

**១៣២៦.** ដូច្នេះការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញនូវទស្សនទានជារួមមួយអំពីបញ្ហានេះ នៅក្នុងយុត្តិសាស្ត្ររបស់យុត្តាធិការជាតិ និងអន្តរជាតិដែលបានលើកឡើងខាងលើ។ សហចៅក្រម-ស៊ើបអង្កេតនឹងគោរពតាមគោលការណ៍របស់យុត្តាធិការទាំងនេះ នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពគ្រប់គ្រាន់នៃភស្តុតាងបានដាក់បន្ទុកដែលពាក់ព័ន្ធនឹងជនត្រូវចោទ ដោយពិនិត្យមើលទាំងលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក និងដោយពិចារណាអំពីភាពជាប់ពាក់ព័ន្ធ និងភាពស្របច្បាប់នៃភស្តុតាងទាំងនោះផងដែរ។

# ជំពូក ៣. ការកំណត់ប្រភេទបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ

## ផ្នែកទី ១- យុត្តាធិការលើបុគ្គល

**១៣២៧.** ការស៊ើបសួរបង្ហាញថា **នួន ជា អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** គឺជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលដែលស្ថិតនៅក្រោមយុត្តាធិការតាមពេលវេលានៃ អ.វ.ត.ក ដោយសារអំណាចឋានានុក្រមជាក់ស្តែង និងតាមច្បាប់ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "តួនាទីរបស់ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៣២៨. ម្យ៉ាងទៀត ឬដោយឆ្លាស់គ្នា អាស្រ័យដោយការចូលរួមជាបុគ្គលរបស់អ្នកទាំងនេះនៅក្នុងការអនុវត្តផែនការរួមរបស់ ប.ក.ក តាមមធ្យោបាយឧក្រិដ្ឋ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម ជនត្រូវចោទនីមួយៗត្រូវបានចាត់ចូលក្នុងប្រភេទជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងអំពើបំពារបំពារយ៉ាងធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

## ផ្នែកទី ២- ការលើកលែងទោស ការអនុគ្រោះទោស គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*Ne bis in idem*)

១៣២៩. នាពេលសម្រេចឃុំខ្លួនបណ្តោះអាសន្ន **អៀង សារី** នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា ព្រះរាជក្រឹត្យដែលទាក់ទងនឹងបញ្ហានេះ[5236] មិនអាចលើកយកមកសម្រាប់ធ្វើការជំទាស់នៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះការចោទប្រកាន់ទាក់ទងនឹងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ នាថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ការលើកលែងទោសដែលបានធ្វើឡើងចំពោះ **អៀង សារី** តាមរយៈព្រះរាជក្រិត្យនោះគ្របដណ្តប់តែទៅលើការចោទប្រកាន់ទាំងឡាយណាដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ប៉ុណ្ណោះ[5237] និងថា អានុភាពនៃព្រះរាជក្រិត្យលើកលែងទោស បន្ទាប់ពីមានការផ្តន្ទាទោសនូវ "*បន ប៉ុល ពត និង អៀង សារី*" នាឆ្នាំ១៩៧៩ បានកម្រិតត្រឹមតែទោសប៉ុណ្ណោះ ដោយមិនបានលើកឡើងនូវបញ្ហាណាមួយទាក់ទងនឹងសាលក្រមផ្តន្ទាទោសផ្ទាល់នោះឡើយ[5238]។ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានថា "*មិនមានការអនុគ្រោះ ឬ ការលើកលែងទោសណាមួយនាពេលបច្ចុប្បន្នដែលអាចបង្កជាឧបសគ្គចំពោះការចោទប្រកាន់ទាំងឡាយណាដែលធ្វើឡើងនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នូវបទឧក្រិដ្ឋអន្តរជាតិដែលបានដាក់បន្ទុកលើ អៀង សារីឡើយ*"[5239]។ ដោយសំអាងទៅលើគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*Ne bis in idem*) សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា "*ហាក់ដូចជាមិនមានអ្វីដែលជំទាស់ដល់ការចោទប្រកាន់ទាំងឡាយដែលបានធ្វើឡើងទៅលើ អៀង សារី ចំពោះអង្គហេតុដែលបានកាត់ទោសនាឆ្នាំ១៩៧៩ ដែលស្ថិតនៅក្រោមការកំណត់ប្រភេទបទល្មើសអន្តរជាតិផ្សេងក្រៅពីបទល្មើសប្រល័យពូជសាសន៍ឡើយ*" [5240]។

១៣៣០. ទាក់ទិនទៅនឹងបណ្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ព្រះរាជក្រឹត្យមិនអាចលើកយកមកសម្រាប់ធ្វើការជំទាស់នៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ចំពោះទិដ្ឋភាពទាក់ទងនឹងច្បាប់ឆ្នាំ១៩៩៤[5241]។ ទាក់ទងទៅនឹងព្រះរាជប្រទានទោស អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា *"នៅក្នុងដំណាក់កាលនេះនៃនីតិវិធី វាពុំមែនជាករណី ជាក់ស្តែងទេដែលថា រឿងក្តី និងសាលក្រមកំណត់ពិរុទ្ធភាពដែលបានធ្វើក្នុងឆ្នាំ១៩៧៩ បានរាំងស្ទះ សេចក្តីប្រកាសពិរុទ្ធភាពនៅចំពោះមុខ អ.វ.ត.ក.។ ចំណុចដែលត្រូវយកទៅពិចារណានឹងមានរូបរាង ក្នុងករណីបញ្ជូនជនត្រូវចោទទៅជម្រះ ដែលជាដំណាក់កាលដែលភស្តុតាងដាក់បន្ទុកពិតប្រាកដ និងអង្គហេតុនានា ដែលភស្តុតាងដាក់បន្ទុកនោះបានផ្អែកទៅលើត្រូវបានគេស្គាល់"*[5242]។ បន្ទាប់ពីមានការឃុំខ្លួនបណ្តោះអាសន្ន មេធាវីការពារ **អៀង សារី** បានដាក់នូវកំណត់សម្គាល់របស់ខ្លួនលើប្រធានបទនេះ[5243]។

១៣៣១. ចំពោះបញ្ហានេះ សហចៅក្រមស៊ើបអង្កេតអាចត្រឹមតែអះអាងបន្ថែមទៅលើការវិភាគជាបឋមរបស់ខ្លួនប៉ុណ្ណោះ។ ដូចនេះ ការលើកលែងទោសគឺមិនមានផលប៉ះពាល់ឡើយ ដោយហេតុថា វិសាលភាពនៃការលើកលែងទោសនេះ គឺបានកម្រិតត្រឹមការចោទប្រកាន់នៅក្នុងក្របខ័ណ្ឌនៃច្បាប់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤។ ដូចគ្នាដែរ បើទោះជាយើងសន្មតថា ការអនុគ្រោះទោសអាចត្រូវបានយកមកសំអាងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក៏វិធានការនេះមិនមានផលប៉ះពាល់លើការចោទប្រកាន់នានាឡើយ ទោះបីជាមានការកំណត់ប្រភេទបទល្មើសណាមួយក៏ដោយ។ នៅចុងបញ្ចប់ យើងមិនអាចបញ្ជាក់បានទេថា សាលក្រមនាឆ្នាំ១៩៧៩ហាមឃាត់មិនឲ្យមានការចោទប្រកាន់ថ្មីទៀតចំពោះ **អៀង សារី** ដោយអនុវត្តនូវគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ។

១៣៣២. នៅក្នុងដំណាក់កាលនេះនៃនីតិវិធី បន្ទាប់ពីមានការវិភាគយ៉ាងពិស្តារទៅលើភស្តុតាងទាក់ទងនឹងរឿងក្តីនាឆ្នាំ១៩៧៩ ជាពិសេសកិច្ចចោទប្រកាន់ ក្រឹត្យ-ច្បាប់ លេខ១ និង សាលក្រមសហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា ដោយមូលហេតុមកពីមានការខ្វះខាតទាក់ទងនៅនឹងនីតិវិធីនេះ ដើម្បីស្របតាមគោលការណ៍នៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ នៅមានភាពស្រពិចស្រពិលទាក់ទងមួយផ្នែកទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់នាឆ្នាំ១៩៧៩ និងមួយផ្នែកទៀតទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសដែលមានចំណងជើងថា "ប្រល័យពូជសាសន៍" និងចុងបញ្ចប់ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវដែលតាមរយៈនេះ "បន ប៉ុល ពត និង អៀង សារី" ត្រូវបាន

គេផ្តន្ទាទោស។ ម្យ៉ាងវិញទៀត ជាការសំខាន់ដែលត្រូវរំលឹកឡើងវិញថា នៅក្នុងសាលក្រមចេញថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ក្នុងសំណុំរឿងរបស់ ឌុច ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា *"ប្រព័ន្ធតុលាការកម្ពុជា គឺមានភាពទន់ខ្សោយ និង មានកម្រិតនៅឡើយនៅចន្លោះឆ្នាំ១៩៧៩ និង ១៩៩៣"*[5244] រហូតដល់ *"មិនអាចដំណើរការទៅបានល្អនៅចន្លោះឆ្នាំ១៩៧៩ និង ១៩៨២"* [5245]។ ដូច្នេះ គេមិនអាចបានចាត់ទុកថា ការចោទប្រកាន់សព្វថ្ងៃនេះដូចគ្នាទៅនឹងការចោទប្រកាន់ដែលធ្វើឡើងនាឆ្នាំ ១៩៧៩ ឡើយ ។

១៣៣៣. ដោយយោងទៅតាមធាតុទាំងអស់នេះ ដោយសន្មតថាអង្គហេតុដែលបានកាត់សេចក្តីនាឆ្នាំ១៩៧៩ បានបញ្ចូលមួយផ្នែក ឬ ទាំងស្រុងក្នុងអង្គហេតុបច្ចុប្បន្នដែលបានធ្វើការចោទប្រកាន់ចំពោះ **អៀង សារី** សហចៅក្រមស៊ើបអង្កេតយល់ឃើញថា បញ្ហាដែលចោទឡើងថាតើសាលក្រមនាឆ្នាំ១៩៧៩ នៅតែមានសុពលភាព និង អាចលើកយកមកធ្វើជាសំអាងនៅក្នុងការជំទាស់ទៅនឹងដំណើរការក្តីថ្មីទាក់ទងនឹងបទប្រល័យពូជសាសន៍ចំពោះ អៀង សារី ឬទេនោះ គឺជាយុត្តិកម្មមួយដែលនាំទៅរកការពិភាក្សាដេញដោលជាសាធារណ: និង ចំពោះមុខ នៅអង្គជំនុំជម្រះសាលាដំបូង ដែលមានតែការពិភាក្សាប្រភេទនេះទេ ដែលអនុញ្ញាតអោយជនត្រូវចោទ សហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណី អាចបង្ហាញនូវអំណះអំណាងរបស់ខ្លួនដោយពេញលេញ។

១៣៣៤. ហេតុដូច្នេះហើយ អៀង សារី នឹងត្រូវបានបញ្ជូនទៅកាត់ក្តីលើអង្គហេតុទាំងមូលដែលត្រូវបានធ្វើឡើងចំពោះរូបគាត់នាពេលបច្ចុប្បន្ននេះ។

## ផ្នែកទី ៣. បទល្មើសប្រល័យពូជសាសន៍

១៣៣៥. ដោយយោងលើអង្គហេតុដែលមានរៀបរាប់នៅក្នុងផ្នែកស្តីអំពីការប្រព្រឹត្តចំពោះជនជាតិចាម និង វៀតណាម នៃដីកាដំណោះស្រាយនេះ មានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើសប្រល័យពូជសាសន៍ (ជាក់ស្តែង ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយតែម្តង)[5246]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605698



### ក. បទល្មើសប្រល័យពូជសាសន៍ ក្រោមឧក្រិដ្ឋថា ការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិចាម

១៣៣៦. ចំពោះ*ធាតុសត្យានុម័ត* បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិចាម (ជាក្រុមជនជាតិភាគតិច និង សាសនាជាក់លាក់មួយដែលកំណត់ខ្លួនឯងថាជាក្រុមនេះ និង ត្រូវបានកំណត់អត្តសញ្ញាណថាជាក្រុមនេះផងដែរដោយប្រជាជនផ្សេងទៀតនៅក្នុងសង្គម) ត្រូវបានសម្លាប់តាមវិធីសាស្ត្រមួយ។

១៣៣៧. វិធីសាស្ត្រប្រតិបត្តិការចំបងរួមមាន ការកំណត់អត្តសញ្ញាណ កំណត់មុខសញ្ញា ប្រមូលផ្តុំ និងសម្លាប់បុគ្គលដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជនជាតិចាម ហើយទង្វើទាំងនេះបានធ្វើឡើងដោយមានការគិតទុកជាមុន និងមានលក្ខណៈជាប្រព័ន្ធ។ វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រនានាដែលត្រូវបានប្រើប្រាស់ញឹកញាប់គឺការចាប់ខ្លួន ឬ ការប្រមូលប្រជាជនចាមទាំងអស់នៅក្នុងតំបន់មួយជាក់លាក់ដើម្បីយកទៅសម្លាប់ជាក្រុមនៅទីកន្លែងសម្លាប់មនុស្ស។ ជនរងគ្រោះត្រូវបានគេកំណត់ជាមុខសញ្ញាដោយសារសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមជនជាតិចាម ៖ ជាទូទៅជនរងគ្រោះមិនត្រូវបានឃុំឃាំង ឬ សួរចម្លើយដើម្បីទទួលបានចម្លើយសារភាពឡើយ ប៉ុន្តែផ្ទុយទៅវិញពួកគេត្រូវបានសម្លាប់ភ្លាមៗ និងជាញឹកញាប់គឺក្រោយពេលដែលពួកគេត្រូវបានសួរដើម្បីបញ្ជាក់ថា ពួកគេជាជនជាតិចាម។

១៣៣៨. ចំពោះ*ធាតុអត្តនោម័ត*[5247] ចារីមានចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែកនូវក្រុមជនជាតិចាមដោយសារពួកគេជាក្រុមហ្នឹងតែម្តង។ ការសម្លាប់ត្រូវបានធ្វើឡើងនៅក្នុងបរិបទមួយដោយមានការប្រកាសជាសាធារណៈដែលរៀបរាប់ពីគោលដៅនៃការបំផ្លិចបំផ្លាញខាងរូបរាងកាយទៅលើក្រុម៖ ជនជាតិចាមត្រូវបានគេកំណត់មុខសញ្ញា និង សម្លាប់ជាលក្ខណៈប្រព័ន្ធ និង ដោយមានវិធីសាស្ត្រជាក់លាក់ ដោយសារសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមជនជាតិចាម ខណៈដែលអ្នកដែលមិនមែនជនជាតិចាមត្រូវបានគេដកចេញយ៉ាងច្បាស់ និងជាពិសេសពីការវាយប្រហារទាំងនេះ។

១៣៣៩. មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចូលរួមចំណែកក្នុងចេតនាបំផ្លាញ ទាំងស្រុង ឬ មួយផ្នែក ទៅលើក្រុមជនជាតិចាមដោយសារពួកគេជាក្រុមហ្នឹងតែម្តង។ ផែនការបំផ្លិចបំផ្លាញជនជាតិចាមជាក្រុមត្រូវបានសម្រេចដោយបក្ស។ គេបានចេញបញ្ជាទៅកម្មាភិបាលថ្នាក់ស្រុកឲ្យ

កំណត់អត្តសញ្ញាណ និង កំណត់មុខសញ្ញាសមាជិកក្រុមនេះ និង សម្លាប់ពួកគេទាំងអស់។

១៣៤០. លក្ខណៈជាប្រព័ន្ធ ទំហំ វិធីសាស្ត្រប្រតិបត្តិការ និងសមកាលកម្មនៃការសម្លាប់ដែលធ្វើចំពោះក្រុមជនជាតិចាមនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល (ឧត្តរចាស់) គឺជាធាតុផ្សំដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា អំពើប្រល័យពូជសាសន៍ត្រូវបានសម្រេច និងសម្របសម្រួល ដោយមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងក្របខ័ណ្ឌនៃផែនការរួម។ ការណ៍ដែលថា ការសម្លាប់ត្រូវបានធ្វើឡើង មិនត្រឹមតែនៅក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និង បូព៌ាប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានធ្វើនៅតាមភូមិភាគផ្សេងៗទៀតក្នុងពេលជាមួយគ្នា បង្ហាញអោយឃើញថា នេះមិនមែនជាអំពើល្មើសដែលបានប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាត្ត និងតាមបែបមិនទៀងដោយកម្មាភិបាលមូលដ្ឋាននោះទេ ប៉ុន្តែផ្ទុយមកវិញ អំពើល្មើសទាំងនេះត្រូវបានរៀបចំឡើងដោយមេដឹកនាំបក្ស។

១៣៤១. ចេតនារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការបំផ្លិចបំផ្លាញក្រុមជនជាតិចាមអាចត្រូវបានគេសន្និដ្ឋានដោយការណ៍ដែលថា អំពើប្រល័យពូជសាសន៍លើជនជាតិចាមបានកើតឡើងនៅក្នុងបរិបទនៃអំពើធ្វើទុក្ខបុកម្នេញប្រឆាំងជនជាតិចាមដែលចេះតែកើនឡើង និងជាអំពើដែលត្រូវបានសម្របសម្រួលដោយបក្សកុម្មុយនីស្តកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានដាក់អោយអនុវត្តនូវផែនការថ្នាក់ជាតិក្នុងការលុបបំបាត់វប្បធម៌ចាម ប្រពៃណី និង ភាសារបស់ពួកគេ ហើយបានរៀបចំការជម្លៀសដោយបង្ខំនូវសហគមន៍ជនជាតិចាមដើម្បីបំបែកពួកគេ។

១៣៤២. ទោះបីជា កម្រិតនៃចំនួនជនរងគ្រោះដើម្បីកំណត់ថាមានបទល្មើសប្រល័យពូជសាសន៍មិនត្រូវបានគេទាមទារក៏ដោយ ក៏ភស្តុតាងនៃសំណុំរឿងទាំងមូលបានបង្ហាញថា សមាមាត្រនៃស្ថិតិប្រជាជនចាមដែលត្រូវបានសម្លាប់អំឡុងពេលនៃទង្វើបំផ្លិចបំផ្លាញដែលផ្តោតលើក្រុមជនជាតិចាមបញ្ជាក់យ៉ាងច្បាស់អំពីចេតនាក្នុងការបំផ្លាញក្រុមនេះទាំងស្រុង ឬ មួយផ្នែក ៖ យោងទៅតាមរបាយការណ៍របស់អ្នកបច្ចេកទេសផ្នែកប្រជាសាស្ត្រ ៣៦%នៃក្រុមជនជាតិចាមនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើប្រៀបធៀបនឹងអត្រាមធ្យមនៃការស្លាប់របស់ប្រជាជនខ្មែរដែលមាន ១៨,៧%។

## ខ. បទល្មើសប្រល័យពូជសាសន៍ ក្រោមទម្រង់ជា ការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាម

១៣៤៣. ចំពោះ*ធាតុសត្យានុម័ត* បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិវៀតណាម (ក្រុមជនជាតិភាគតិច និងជនជាតិជាក់លាក់ ដែលត្រូវបានចាត់ទុកដូចជាក្រុមពូជសាសន៍មួយដោយបក្សកុម្មុយនីស្តកម្ពុជា) ត្រូវបានសម្លាប់ដោយមានវិធីសាស្ត្រជាក់លាក់។

១៣៤៤.វិធីសាស្ត្រប្រតិបត្តិការចំបង រួមមាន ការកំណត់អត្តសញ្ញាណ កំណត់មុខសញ្ញា ប្រមូលផ្តុំ និងសម្លាប់បុគ្គលដោយសារតែសមាជិកភាពរបស់ពួកគេទៅនឹងក្រុមជនជាតិវៀតណាម និងទង្វើទាំងនេះបានធ្វើឡើងដោយមានការគិតទុកជាមុន និងជាប្រព័ន្ធ។ ជារឿយៗ ប្រជាជនវៀតណាមត្រូវបានគេកំណត់អត្តសញ្ញាណតាមរយៈការប្រើប្រាស់បញ្ជីស្ថិតិ ដែលបានរៀបចំទុកជាមុន ឬ បញ្ជីចុះឈ្មោះដែលចាត់ ចំណាត់ថ្នាក់ថា បុគ្គលទាំងនេះជាប្រជាជនវៀតណាម ហើយជាញឹកញាប់ ចារីបានចាត់នូវវិធានការណ៍នានា ដើម្បីធានាថា ជនរងគ្រោះទាំងនោះជាប្រជាជនវៀតណាមមុននឹងសម្លាប់ពួកគេ។

១៣៤៥.ចំពោះ*ធាតុអត្តនោម័ត*[5248] ចារីមានចេតនាបំផ្លិចបំផ្លាញ ទាំងស្រុង រឺមួយផ្នែក នូវក្រុមជនជាតិវៀតណាម ដោយសារពួកគេជាក្រុមហ្នឹងតែម្តង។ ការសំលាប់ត្រូវបានធ្វើឡើងនៅក្នុងបរិបទមួយដោយមានការប្រកាសជាសាធារណៈ ដែលរៀបរាប់ពីគោលដៅក្នុងការបំផ្លិចបំផ្លាញលើរូបរាងកាយទៅលើក្រុម។ ដូចជា ចារីបានអនុវត្តដូចជាវិធីសាស្ត្រជាក់លាក់មួយដើម្បីបំផ្លិចបំផ្លាញក្រុមដោយការ អនុវត្តនូវទ្រឹស្តីដែលថាចំណងបុត្តភាពមានដើមកំណើតពីសែស្រឡាយខាងម្តាយ។ ជនជាតិវៀតណាម ត្រូវបានគេកំណត់មុខសញ្ញា និងសម្លាប់ជាប្រព័ន្ធ និងតាមវិធីសាស្ត្រជាក់លាក់ ដោយសារសមាជិកភាពរបស់គេទៅនឹងក្រុមជនជាតិវៀតណាម ខណៈដែលអ្នកដែលមិនមែនជាជនជាតិវៀតណាមត្រូវបានដកចេញយ៉ាងច្បាស់លាស់ជាពិសេសពីការវាយប្រហារទាំងនេះ។

១៣៤៦.មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចូលរួមចំណែកក្នុងចេតនាបំផ្លាញ ទាំងស្រុង ឬ មួយផ្នែកទៅលើក្រុមជនជាតិវៀតណាមដោយសារពួកគេជាក្រុមហ្នឹងតែម្តង។ មានឯកសារមួយ ដែលអំពាវនាវចំៗអោយមានការសម្លាប់ប្រជាជនវៀតណាម ដែលនៅមានវត្តមានក្នុងប្រទេសកម្ពុជាត្រូវបាន បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលត្រូវបានចែកចាយនៅក្នុងបក្ស។ គោលនយោបាយក្នុងការបំផ្លិចបំផ្លាញក្រុមជនជាតិវៀតណាមនេះ ត្រូវបានធ្វើឡើងនៅក្នុងវគ្គសិក្សាបណ្តុះបណ្តាលនានា ដូចដែលមានមានបញ្ជាក់ក្នុងកំណត់ដៃដែលសរសេរដោយកម្មាភិបាល

ព្រមទាំងសក្ខីកម្មរបស់សាក្សីផងដែរ។ បន្ថែមលើសពីនេះ ឯកសារនៃការប្រាស្រ័យទាក់ទងមួយចំនួនរវាងភូមិភាគ និង មជ្ឈិម ដែលបានចង្អុលបង្ហាញថា នួន ជា និង អៀង សារី ជាអ្នកទទួល គឺទាក់ទងទៅនឹងការដាក់ឱ្យអនុវត្តនូវគោលនយោបាយនេះ និងបានបង្ហាញអំពីអត្ថិភាពនៃរបាយការណ៍ស្តីពីការសម្លាប់ប្រជាជនវៀតណាមផងដែរ។

**១៣៨៧.** លក្ខណៈជាប្រព័ន្ធ ទំហំ វិធីសាស្ត្រប្រតិបត្តិការចំបង និង សមកាលកម្មនៃការសម្លាប់ប្រជាជនវៀតណាម គឺជាធាតុផ្សំដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា អំពើប្រល័យពូជសាសន៍ត្រូវបានសម្រេច និងសម្របសម្រួល ដោយមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងក្របខ័ណ្ឌនៃផែនការរួម។ ការណ៍ដែលថា ការសម្លាប់ត្រូវបានធ្វើឡើង មិនត្រឹមតែនៅក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និង បូព៌ាប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានធ្វើនៅតាមភូមិភាគផ្សេងៗទៀតក្នុងពេលជាមួយគ្នា បង្ហាញអោយឃើញថា នេះមិនមែនជាអំពើល្មើសដែលបានប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាត្ត និងតាមបែបមិនទៀងដោយកម្មាភិបាលមូលដ្ឋាននោះទេ។

**១៣៨៨.** ចេតនារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការបំផ្លិចបំផ្លាញក្រុមជនជាតិវៀតណាម អាចត្រូវបានគេសន្និដ្ឋានដោយការណ៍ដែលថា អំពើប្រល័យពូជសាសន៍ត្រូវបានកើតឡើងនៅក្នុងបរិបទមួយនៃការនិរទេស ការធ្វើទុក្ខបុកម្នេញ ការញុះញុងដើម្បីអោយមានការស្អប់ខ្ពើម និងការឃោសនាអំពីសង្គ្រាមប្រឆាំងប្រជាជនវៀតណាម ដែលអំពើទាំងនេះចេះតែកើនឡើង ហើយជាអំពើដែលបានសម្រេចដោយមេដឹកនាំទាំងនោះ។

**១៣៨៩.** ទោះបីជា កម្រិតចំនួននៃជនរងគ្រោះមិនត្រូវបានគេទាមទារនៅក្នុងការកំណត់នូវបទល្មើសប្រល័យពូជសាសន៍ក៏ដោយក៏ភស្តុតាងនៃសំណុំរឿងទាំងមូលបានបង្ហាញថា សមាមាត្រនៃស្ថិតិប្រជាជនវៀតណាម ដែលត្រូវបានសម្លាប់បញ្ជាក់យ៉ាងច្បាស់អំពីចេតនាក្នុងការបំផ្លាញក្រុមនេះទាំងស្រុង ឬមួយផ្នែក ៖ យោងទៅតាមរបាយការណ៍របស់អ្នកបច្ចេកទេសផ្នែកប្រជាសាស្ត្រ ប្រជាជនវៀតណាមទាំងអស់ដែលនៅមានវត្តមានក្នុងប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យទំនងជាត្រូវបានសម្លាប់។

# ផ្នែកទី ៤- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

## ក. ធាតុផ្សំដែលជា "ធាតុផ្សំរួម"

### អត្ថិភាពនៃការវាយប្រហារ

១៣៥០.យោងតាមអង្គហេតុដូចបានរៀបរាប់នៅក្នុងផ្នែកនៃដីកាដំណោះស្រាយស្តីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" និងផ្នែកស្តីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" គោលនយោបាយដែលអនុវត្តដោយកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ បង្កើតបានជាការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ[5249] ប្រឆាំងទៅលើប្រជាជនស៊ីវិលទាំងអស់នៃប្រទេសកម្ពុជា[5250] ដោយសារមូលហេតុនយោបាយជាចម្បង និងក្នុងបរិបទមួយចំនួន ដោយសារមូលហេតុជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[5251]។ បទល្មើសជាក់លាក់ ដែលនឹងរៀបរាប់ដូចតទៅនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារនេះ[5252] ជាហេតុធ្វើឱ្យធាតុផ្សំដែលជា "ធាតុផ្សំរួម" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនា អំឡុងពេលនៃការកកើតអង្គហេតុ[5253] ត្រូវបានបំពេញ។

១៣៥១. ចំពោះធាតុសត្យានុម័ត ការវាយប្រហារនេះរួមមានជា ការទាមទារឱ្យមានការគ្រប់គ្រងផ្តាច់ការមួយទៅលើប្រជាជនកម្ពុជាទាំងមូល[5254] ដោយអនុវត្តតាមផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាសំដៅសម្រេចឱ្យបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅប្រទេសកម្ពុជា និងបោសសម្អាតខ្មាំងខាងក្នុង និង ខ្មាំងខាងក្រៅ ។

### លក្ខណៈជាទូទៅ ឬ ជាប្រព័ន្ធ

១៣៥២. ការវាយប្រហារត្រូវបានគ្រោងទុក និងអនុវត្តក្នុងលក្ខណៈរីករាលដាលធំឡើងជាលំដាប់នៅក្នុងតំបន់ ស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧២-៧៣មក។ ការវាយប្រហារបានរីករាលដាលទូទាំងប្រទេសកម្ពុជា ចាប់តាំងពីពេលដែលបក្សឡើងកាន់អំណាចនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក ហើយបានបន្តអនុវត្តយ៉ាងហោចណាស់ ក្នុងអំឡុងពេលដែលស្ថិតនៅក្រោម យុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១។

00605703



១៣៥៣. បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់មធ្យោបាយប្រាំប្រភេទធំៗ ដើម្បីដាក់ឱ្យអនុវត្តផែនការបដិវត្តន៍របស់ខ្លួន៖ ការជម្លៀសប្រជាជនជាច្រើនដងពីទីប្រជុំជនទៅជនបទ និងពីជនបទមួយទៅជនបទមួយទៀត, ការបង្កើត និងការទាញយកប្រយោជន៍ពីបណ្តាញសហករណ៍ និងការដ្ឋាននៅទូទាំងប្រទេស, ការអប់រំកែប្រែ “សមាសភាពមិនល្អ” និង ការកម្ទេច “ខ្មាំង” ទាំងនៅក្នុង និងនៅក្រៅបក្ស, ការប្រព្រឹត្តចំពោះក្រុមមនុស្សជាក់លាក់ ជាពិសេសគឺជនជាតិចាម វៀតណាម ពុទ្ធសាសនិក និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ, ព្រមទាំងការដាក់ចេញនូវបទបញ្ញាអំពីការរៀបអាពាហ៍ពិពាហ៍។

១៣៥៤.ការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំ ដែលធ្វើឡើងម្តងហើយម្តងទៀត នៅទូទាំងប្រទេស ជាពិសេស នៅក្នុងដំណាក់កាលធំៗទាំងបីដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹង បានធ្វើឡើងចំពោះជនស៊ីវិលជាច្រើន ដែលពួកគេបានទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយនិងផ្លូវចិត្ត និងបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងក្របខ័ណ្ឌដែលថា ការជម្លៀសទាំងនេះធ្វើឡើងដោយបង្ខំ គម្រាមកំហែង ឬការប្រើអំពើហិង្សាលើរូបកាយ។

១៣៥៥.ការតម្រូវជាទូទៅឱ្យរស់នៅជាសមូហភាពនិងការធ្វើការងារដោយបង្ខំនៅក្នុងសហករណ៍ “កងចល័ត” និងការដ្ឋានធ្វើការងារ បណ្តាល ឬបង្កឱ្យមានការរំលោភជាប្រព័ន្ធទៅលើសិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ប្រជាជនកម្ពុជា៖ ដូចជា ការបង្ខំឱ្យរស់នៅក្នុងសហករណ៍បណ្តាលឱ្យមានការដកហូតទ្រព្យសម្បត្តិទាំងអស់ ហើយជនរងគ្រោះត្រូវបានតម្រូវឱ្យធ្វើការងារយ៉ាប់យ៉ឺនក្នុងស្ថានភាពលំបាក ទាំងផ្នែកសុខភាព ម្ហូបអាហារ វេជ្ជសាស្ត្រ និងការស្នាក់នៅ ដោយពួកគេគ្មានសិទ្ធិទទួលផលពីការងារ របស់ខ្លួនឡើយ។ នៅក្នុងក្របខ័ណ្ឌនៃការប៉ុនប៉ងកែប្រែប្រជាជន ការរៀបអាពាហ៍ពិពាហ៍ដោយ បង្ខំត្រូវបានរៀបចំឡើង ដោយបញ្ហាជីវិត និងបញ្ហាសីលធម៌បានក្លាយជាបញ្ហារួម (សាធារណៈ) និងត្រូវបានដឹកនាំដោយ “វិធីសាស្ត្រគ្រប់គ្រង” ដែលទាមទារឱ្យមានការចាប់បង្ខំ។

១៣៥៦.ទន្ទឹមនឹងនេះ បក្សកុម្មុយនីស្តកម្ពុជាបានប៉ុនប៉ងលុបបំបាត់ចោលទាំងស្រុងនូវប្រភពតវ៉ាទាំងអស់ដែលអាចមាន តាមរយៈការបោសសម្អាតជនទាំងឡាយណាដែលត្រូវបានសង្ស័យថាប្រឆាំង ឬអាចប្រឆាំងនឹងបក្ស និងផែនការរួមរបស់បក្ស។ ការបង្ខំឱ្យរស់នៅក្នុងសហករណ៍ជួយសម្រួលដល់ការកំណត់អត្តសញ្ញាណជនសង្ស័យ ហើយកម្មវិធីតាមដាន (ដោយពួកឈ្លប) ត្រូវបានបង្កើតឡើង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

នៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃរបបនេះ។ គោលនយោបាយនេះបណ្តាលឲ្យកើតមានអំពើហិង្សាក្នុងទ្រង់ទ្រាយធំនានា។

១៣៥៧. បើទោះបីជា អត្ថិភាពនៃផែនការមនោគមវិជ្ជាមិនត្រូវបានចាត់ទុកថា ជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ការដាក់ឲ្យអនុវត្តតាមមធ្យោបាយឧក្រិដ្ឋដោយអាជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យនូវផែនការដែលត្រូវបានអនុម័តនៅក្នុងករណីនេះ បានបង្ហាញអំពីលក្ខណៈទូទៅ និងជាប្រព័ន្ធនៃការវាយប្រហារ។ ជាពិសេស ការជំនួសរចនាសម្ព័ន្ធសេដ្ឋកិច្ច រដ្ឋបាល និងនយោបាយនៅកម្ពុជា ដោយអំណាចបដិវត្តន៍ ដូចមានកំណត់ជាអាទិ៍នៅក្នុងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ និងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា បានអនុញ្ញាតឲ្យបក្សប្រើប្រាស់គ្រប់ធនធានទាំងអស់របស់រដ្ឋ ដើម្បីបង្ខំឲ្យប្រជាជនទាំងអស់ ក្រោមការគ្រប់គ្រងរបស់ខ្លួនអនុវត្តតាមផែនការដែលខ្លួនដាក់ចេញ ដោយពឹងផ្អែកលើ ឋានានុក្រមមជ្ឈការរបស់បក្ស លើរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ និងលើកងទ័ព និងកងសន្តិសុខ[5255]។

១៣៥៨.គោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានបោះបង់ចោលដោយ ប.ក.ក ដោយជំនួសមកវិញនូវការអនុវត្តប្រព័ន្ធគ្រប់គ្រងនយោបាយដែលមានលក្ខណៈមជ្ឈការខ្ពស់បំផុត សំដៅកំណត់អត្តសញ្ញាណសមាសភាពដែលអាចបង្ក "វិទ្ធង្សនា" សំដៅបង្ក្រាបសមាសភាពទាំងនេះមុននឹងពួកគេអាច "បង្កគ្រោះថ្នាក់" ដល់បដិវត្ត ដោយចាប់ខ្លួនពួកគេដើម្បីអប់រំ ឬ កម្ទេចចោលនៅក្នុងករណីដែលពួកគេត្រូវបានចាត់ទុករួចទៅហើយថា បានប្រឆាំងនឹងបដិវត្ត។ ដោយផ្អែកលើការស្រាវជ្រាវមិនច្បាស់លាស់ មួយដែលកំណត់យក "ហានិភ័យកម្រិតសូន្យ" គោលនយោបាយនេះត្រូវតែរីករាលដាលដោយចៀសមិនរួច។ ជាក់ស្តែង ដំណើរការកំណត់អត្តសញ្ញាណខ្មាំង ដែលបានដាក់ឲ្យអនុវត្តនៅគ្រប់លំដាប់ថ្នាក់នៃប.ក.ក បានផ្អែកជាមូលដ្ឋានលើសញ្ញានៃភាពបង្កគ្រោះថ្នាក់មួយដែលមិនអាចផ្ទៀងផ្ទាត់បាន និងដែលភាគច្រើនកើតចេញពីការសារភាពដែលទទួលបានក្រោមការធ្វើទារុណកម្ម ដែលទីបំផុតដំណើរការកំណត់អត្តសញ្ញាណខ្មាំងនេះបានដំណើរការទៅមុខដោយខ្លួនឯង និងបានបង្វែរគោលដៅត្រឡប់ទៅរកអ្នកបង្កើតវាវិញ។ លក្ខណៈវិនិច្ឆ័យ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណខ្មាំងដែលអាចមាននៅក្នុងស្រទាប់ប្រជាជនបានរីវត្ត និងរីកធំទៅៗក្នុងអំឡុងពេលដែលស្ថិតនៅក្រោមការស៊ើបសួរ ដោយសារតែបរាជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ច និងការរីករាលដាលនៃជម្លោះប្រដាប់អាវុធជាអន្តរជាតិរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ការស្រាវជ្រាវរក "ខ្មាំង" ត្រូវបានធ្វើឡើងដោយស្ថាប័នទទួលបន្ទុកផ្នែកសន្តិសុខ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605705



ទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសកងសន្តិសុខ ដែលហៅថា "សន្តិបាល" ដែលគ្រប់គ្រងដោយបក្ស ដោយមិនមានគ្រោងទុកជាមុននូវយន្តការណាមួយដើម្បីជំទាស់នឹងនីត្យានុកូលភាពនៃការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ទោសឡើយ[5256]។

១៣៥៩.ដោយខុសស្រឡះពីភាពចៃដន្យដែលៗនៃទង្វើដែលត្រូវបានប្រព្រឹត្តឡើងស្រដៀងគ្នា និងនៅកន្លែងផ្សេងៗពីគ្នា ការវាយប្រហារត្រូវបានបង្កើត និងសម្របសម្រួលដោយថ្នាក់មជ្ឈិម ផ្អែកលើសេចក្តីណែនាំរបស់មេដឹកនាំ ដែលជាអ្នកគ្រប់គ្រងដោយផ្ទាល់នូវការដាក់ឱ្យអនុវត្តនេះ។ ជាក់ស្តែងអាជ្ញាធរមូលដ្ឋានមានសិទ្ធិទំនាក់ទំនងតែជាមួយថ្នាក់លើផ្ទាល់របស់ខ្លួន និងគណៈមជ្ឈិមប៉ុណ្ណោះ។ កម្មាភិបាលដែលត្រូវបានចាត់ទុកថា "ជនមានកំហុស" នៃគំនិតផ្តួចផ្តើមប្រឆាំងនឹងមាគ៌ានយោបាយរបស់បក្ស ក៏ត្រូវបានចាត់ទុកថាជាសត្រូវផងដែរ[5257]។

១៣៦០.ចរិតលក្ខណៈជាប្រព័ន្ធនេះស្តែងឡើងនៅក្នុងការអនុវត្តជាក់ស្តែង តាមរយៈការធ្វើឱ្យមានលក្ខណៈជាទូទៅនៃមធ្យោបាយដាក់ឱ្យអនុវត្ត ដោយតម្រូវឱ្យមានការរៀបចំផែនការថ្នាក់កណ្តាលក្នុងកម្រិតមួយខ្ពស់។ វិធីសាស្ត្រប្រតិបត្តិការជាចម្បងរួមមានជា វិធីសាស្ត្រហិង្សាជាបទដ្ឋានដែលកំណត់ពីថ្នាក់លើ និង តម្រូវឱ្យមានការធ្វើរបាយការណ៍ពីថ្នាក់ក្រោម ហើយអនុវត្តក្នុងទ្រង់ទ្រាយធំ (ដូចជាប្រព័ន្ធធ្វើទារុណកម្ម ដែលអនុវត្តនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ដើម្បីវែកមុខ និងកម្ទេច "ខ្មាំង") ដោយផ្អែកលើរចនាសម្ព័ន្ធរដ្ឋទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធនេះបានធ្វើឱ្យមនុស្សរាប់លាននាក់ បានក្លាយជាជនរងគ្រោះ ដែលមានចំនួនពី ១,៧ ទៅ ២,២លាននាក់ស្លាប់ ដែលក្នុងនោះប្រហែល ៨០០.០០០ នាក់ស្លាប់ដោយអំពើហិង្សា[5258]។ ក្រៅពីជនរងគ្រោះផ្ទាល់ ការបាត់ខ្លួនដោយបង្ខំដែលធ្វើឡើងជាប្រព័ន្ធដោយ អាជ្ញាធរដើម្បីលាក់បាំងការចាប់ខ្លួន បានធ្វើឱ្យឈឺចាប់ផងដែរដល់អ្នកដែលជាសាក្សីនៃអំពើនោះ ដោយសារតែការភ័យខ្លាច និងភាពមិនច្បាស់លាស់ដែលបណ្តាលមកពីបាត់ខ្លួនទាំងនេះ។

១៣៦១. យោងទៅលើធាតុផ្សំទាំងអស់នេះ ជាក់ស្តែង ការវាយប្រហារលើជនស៊ីវិលមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធ (ដោយរំឭកផងដែរថា លក្ខណៈវិនិច្ឆ័យតែមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់នេះ គឺមានភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ហើយ ដើម្បីកំណត់បានថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ធ្វើឡើងប្រឆាំងនឹងជនស៊ីវិល

១៣៦២. ប្រជាជនទាំងអស់នៃប្រទេសកម្ពុជាគឺជាគោលដៅនៃការវាយប្រហារ ដែលភាគច្រើនជាជនស៊ីវិល ដូចមានកំណត់នៅក្នុងច្បាប់មនុស្សធម៌ ទោះគេជាជនស៊ីវិលកម្ពុជា ឬជនបរទេសក៏ដោយ។

១៣៦៣. ទោះបីជា ក្រុមជនស៊ីវិលមួយចំនួននៅក្នុងស្រទាប់ប្រជាជន "ដែលជាលក្ខណៈនយោបាយត្រូវបានចាត់ទុកថាមិនគួរទុកចិត្ត" បើប្រៀបធៀបទៅនឹងអ្នកផ្សេងទៀត (ដូចជា "ប្រជាជនថ្មី" អតីតអ្នកមានបណ្ដាស័ក្តិស៊ីវិល និងយោធានៃរបបសាធារណៈខ្មែរ និងជនជាតិភាគតិច) ត្រូវបានគេប្រព្រឹត្តជាពិសេសក៏ដោយ (ដូចដែលមានបញ្ជាក់ខាងក្រោម) ក៏គោលដៅនៃការវាយប្រហារគឺធ្វើឡើងចំពោះប្រជាជនទាំងអស់។ ជាក់ស្ដែងសូម្បីតែបុគ្គលដែលមានឋានៈ "ពេញសិទ្ធិ" ដូចជាកសិករក៏ដោយ ក៏នៅតែជាកម្មវត្ថុនៃការដកហូតទ្រព្យសម្បត្តិ និងការរំលោភធ្ងន់ធ្ងរផ្សេងទៀតទៅលើសិទ្ធិរបស់ពួកគេ មុនខែមេសា ឆ្នាំ១៩៧៥ដែរ ហើយអ្នកទាំងនោះនៅបន្តជាជនរងគ្រោះនាពេលបន្ទាប់មកទៀត។

១៣៦៤.ម្យ៉ាងវិញទៀត សមាជិកនៃកងសន្តិសុខ និងកងទ័ពកម្ពុជា ក៏ស្ថិតនៅក្នុងចំណោមប្រជាជនដែលជាគោលដៅនៃការវាយប្រហារផងដែរ ដោយហេតុថា បក្សកុម្មុយនីស្តកម្ពុជាមិនធ្វើការបែងចែករវាងកងទ័ព និងជនស៊ីវិលនៅក្នុងការអនុវត្តគោលដៅកែប្រែសង្គម និងបោសសម្អាត "ខ្មាំង" របស់ខ្លួនឡើយ។ អតីតអ្នកមានបណ្ដាស័ក្តិ(ខ្ពស់) ជាជនស៊ីវិល និងយោធានៃរបបសាធារណៈរដ្ឋខ្មែរ (ព្រមទាំងអ្នកនៅក្រោមបង្គាប់ និងសមាជិកគ្រួសាររបស់ពួកគេ) ត្រូវបានកំណត់មុខសញ្ញា ពីព្រោះជនទាំងនេះត្រូវបានចាត់ទុកថា ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។ ជាញឹកញាប់ កងទ័ពត្រូវបានដកហូតអាវុធ មុននឹងត្រូវបានចាត់តាំងឲ្យទៅបំពេញសកម្មភាពមិនមែនយោធា ជាពិសេសនៅពេលបោសសម្អាត "សមាសភាពមិនល្អ" (ឧទាហរណ៍ គឺនៅពេលបញ្ជូនកងទ័ពពីភូមិភាគបូព៌ាទៅកាន់ការដ្ឋានប្រលានយន្តហោះកំពង់ឆ្នាំង) គឺមានន័យថា ពួកគេលែងចូលរួមនៅក្នុងកងកម្លាំងថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ ទៀតហើយ។ ទោះជាយ៉ាងណាក៏ដោយ ឲ្យតែគេបានបង្ហាញថាមានការវាយប្រហារសំដៅទៅលើជនស៊ីវិលកើតមានឡើង នោះច្បាប់អន្តរជាតិមិនបានទាមទារថាជនរងគ្រោះទាំងអស់ត្រូវតែជាជនស៊ីវិល នោះទេ។

00605707



ដោយមូលហេតុជាតិ (ជនជាតិ) នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា

១៣៦៥.មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តម្រូវថា ការវាយប្រហារត្រូវតែធ្វើឡើង *"ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"។* មាត្រានេះសំដៅតែទៅលើចារិតលក្ខណៈនៃការវាយប្រហារខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ ដោយមិនតម្រូវទេថា ចេតនារើសអើងជាក់លាក់គឺជាធាតុផ្សំនៃបទល្មើសជាក់លាក់នីមួយៗ។ មានតែបទល្មើសធ្វើទុក្ខបុកម្នេញប៉ុណ្ណោះដែលទាមទារឱ្យមានចេតនារើសអើងជាក់លាក់បែបនេះ។

១៣៦៦. ក្នុងករណីនេះ ការវាយប្រហារជាទូទៅផ្អែកជាសំខាន់ទៅលើមូលហេតុនយោបាយ[5259]។ ការដាក់ឱ្យ អនុវត្តការវាយប្រហារនេះតម្រូវឱ្យបែងចែកប្រជាជនជាក្រុមផ្សេងៗ ដែលការបែងចែក នេះកំណត់នូវ វិសាលភាពនៃសិទ្ធិរបស់ពួកគេ ដែលជាលទ្ធផល មានការបដិសេធចោលនូវសិទ្ធិ ទាំងនេះសម្រាប់ ប្រជាជនទាំងមូល ដោយជំនឿខាងនយោបាយ ឬសាសនា ត្រូវបានសន្មត់ថា ផ្ទុយនឹងគោលដៅមនោគមវិជ្ជារបស់បក្ស។

១៣៦៧. មុននឹងឡើងកាន់អំណាច បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចថា ក្រុមមនុស្សមួយចំនួន ដែល ត្រូវបានចាត់ទុកថា មិនអាចអប់រំកែប្រែបាន ត្រូវតែកម្ទេចចោល។ ប្រភេទក្រុមមនុស្សទាំងនេះ បានរីកធំឡើង ទៅតាមពេលវេលា។ ទន្ទឹមនឹងនេះ ជនទាំងឡាយណាដែលមិនគោរពតាមគោល នយោបាយរបស់របប ឬដែលត្រូវបានចាត់ទុកថាជាឧបសគ្គរាំងរាដល់ការអនុវត្តគោលនយោបាយ ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជា "ខ្មាំង" បើទោះបីជាតាមការពិត ពួកគេមិនបានប្រឆាំង ទៅនឹងរបបនោះក៏ដោយ។ រាល់សត្រូវពិតប្រាកដ ឬសត្រូវតាមការសន្មតទាំងអស់របស់បក្ស កុម្មុយនីស្តកម្ពុជា ត្រូវបានចាប់ខ្លួន អប់រំកែប្រែ ឬបោសសម្អាតនៅតាមមន្ទីរសន្តិសុខ និងការដ្ឋាន។

១៣៦៨. គោលបំណងចំបងនៃការជម្លៀសប្រជាជន គឺជាបញ្ហានយោបាយ។ នេះគឺជា ការសម្រិតសម្រាំងប្រជាជន ដែលត្រូវបានចាត់ទុកថា អាចប្រឆាំងនឹងគោលនយោបាយរបស់របប (ប្រជាជនថ្មី ក្នុងករណីនៃដំណាក់កាលទី១នៃការជម្លៀសប្រជាជន ប្រជាជនថ្មី និងពួកចាម សម្រាប់ដំណាក់កាលទីពីរ និងប្រជាជននៃភូមិភាគបូព៌ា ដែលជាប់ពាក់ព័ន្ធនឹងកម្មាភិបាលដែលត្រូវ បោសសម្អាត ក្នុងដំណាក់កាលទីបី) និងផ្តល់ឱ្យរបបនូវកម្លាំងពលកម្ម ដែលអាចប្រើប្រាស់បាន តាមតម្រូវការ សម្រាប់ផែនការសេដ្ឋកិច្ចធំៗ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ECCC * CETC

១៣៦៩.ទោះជាយ៉ាងណាក្តី ក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ ដោយមូលហេតុនយោបាយនេះ ក្រុមប្រជាជនស៊ីវិលជាក់លាក់មួយចំនួន គឺជាគោលដៅ ដោយមូលហេតុជាតិ ជាតិពន្ធុ ឬពូជសាសន៍ (ជាពិសេស ជនជាតិវៀតណាម និងចាម) ឬសាសនាផងដែរ (ពុទ្ធសាសនិក និងចាម)[5260] ទោះជាមូលហេតុពិតប្រាកដ ឬ តាមការសន្មត់ក៏ដោយ។ ជាក់ស្តែង ដូចបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" នៃដីកាដំណោះស្រាយនេះ ការដាក់ឱ្យអនុវត្តផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា តម្រូវឱ្យលុប បំបាត់ចោលសាសនា "ប្រតិកិរិយា" ទាំងអស់ រួមទាំងការជម្លៀស ការធ្វើទុក្ខបុកម្នេញ ឬការបំផ្លាញ ជនជាតិភាគតិច។

<u>ត្រូវបានប្រព្រឹត្ត "នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារ"</u>

១៣៧០. បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនឹងពិនិត្យខាងក្រោមនេះ ត្រូវបានប្រព្រឹត្ត *"ក្នុងក្របខ័ណ្ឌ"* នៃការវាយប្រហារ ក្នុងន័យថា អំពើទាំងនេះស្របគ្នាជាមួយនឹងការវាយប្រហារនេះ ហើយថា តាមរយៈចរិតលក្ខណៈនៃអំពើ គោលបំណងនៃអំពើ ប្រភេទនៃអំពើ ឬផលវិបាករបស់វា អំពើទាំងនេះពិតជាផ្នែកមួយនៃការវាយប្រហារ ហើយមិនមែនជាអំពើចៃដន្យសុទ្ធសាធឡើយ។ ក្នុងករណីនេះ ទោះបីជានៅពេលដែលអំពើជាលក្ខណៈបុគ្គលរបស់ចារីផ្ទាល់មិនមានភាព "ទូទៅឬជាប្រព័ន្ធ" ក៏ដោយ ក៏អំពើទាំងនេះស្ថិតនៅក្នុងបរិបទទូទៅនៃការវាយប្រហារ ហើយចារីបានដឹងអំពីបរិបទទូលាយនៃការវាយប្រហារ ទោះបីជាពួកគេមិនដឹងអំពីសេចក្តីលម្អិតក៏ដោយ។

១៣៧១. ចំពោះធាតុផ្សំអត្តនោម័ត ភស្តុតាងនៃសំណុំរឿងបង្ហាញថា លក្ខណៈទូទៅនៃការវាយប្រហារ ត្រូវបាន ដឹងឮដោយជនត្រូវចោទផង និងចារីប្រព្រឹត្តបទល្មើសផ្ទាល់ផង ដូចជាតាមរយៈការផ្សព្វផ្សាយ សេចក្តីណែនាំជាទៀងទាត់ដល់កម្មាភិបាលបក្ស និងបុគ្គលិកទទួលបន្ទុកអនុវត្តគោលនយោបាយ[5261]។ ដោយសារតែល័ក្ខខ័ណ្ឌតម្រូវនៃ "មូលហេតុរើសអើង" នៅក្នុងកថាខ័ណ្ឌដំបូង នៃមាត្រា ៥ នៃច្បាប់ស្តី ពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនតម្រូវឱ្យមានធាតុផ្សំអត្តនោម័តបន្ថែមណា មួយនោះទេ យើងមិនចាំបាច់ត្រូវបង្ហាញថា អំពើនេះត្រូវបានប្រព្រឹត្តក្នុងចេតនា ធ្វើឱ្យឈានទៅមុខនូវការវាយប្រហារ ឬមនោគមវិជ្ជា គោលនយោបាយ ឬផែនការជាដើមចមនៃការវាយប្រហារនោះឡើយ។

១៣៧២.ម្យ៉ាងវិញទៀត ទំនាក់ទំនងជាមួយនឹងការវាយប្រហារត្រូវបានផ្ទៀងផ្ទាត់ចំពោះបទល្មើស

00605709



ទីមួយៗនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានកំណត់យក នៅក្នុងដីកាដំណោះស្រាយនេះ រួមទាំងការដឹងឮអំពីទំនាក់ទំនងនេះ ដោយអ្នកប្រព្រឹត្តផ្ទាល់ និងមេដឹកនាំ ជាអាទិ៍ តាមរយៈបណ្តាញទំនាក់ទំនង វត្តមាននៅក្នុងកិច្ចប្រជុំ ឬការថ្លែងសុន្ទរកថាជាសាធារណៈ។

## ខ. បទល្មើសជាក់លាក់នីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ការធ្វើមនុស្សឃាត

១៣៧៣. មានធាតុផ្សំគ្រប់គ្រាន់ចំពោះបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពជាការធ្វើមនុស្សឃាត[5262]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបងទៅនឹងជនដែលត្រូវបានសម្លាប់នៅតាមកន្លែង សម្លាប់មនុស្សទាំងឡាយ ដូចជានៅ **ស្រុក១២ ស្ទឹងត្រូច ទួលពោធិជ្រៃ** និង**ជើងឯក**, នៅតាមមន្ទីរ សន្តិសុខនានា ដែលរួមមានមន្ទីរសន្តិសុខកោះខ្យង គោកក្ដួច ក្រាំងតាចាន់ នៅភូមិភាគឧត្តរ ភ្នំក្រោល **អូរកន្សែង** ព្រៃដំរីស្រុត ស-២១ សង់ **វត្តគិរីរម្យ វត្តធ្លក**។ ធាតុផ្សំនៃបទល្មើសមនុស្សឃាត ក៏ត្រូវ បានបំពេញផងដែរក្នុងដំណាក់កាលទី១ **និងទី៣**នៃការ**ផ្លាស់ទីលំនៅ**, នៅតាមការដ្ឋានដូចជា **ទំនប់១មករា** ព្រលានយន្តហោះកំពង់ឆ្នាំង ព្រៃស និងទំនប់ត្រពាំងថ្ម និងនៅក្នុងក្របខណ្ឌនៃការប្រព្រឹត្តចំពោះក្រុមពុទ្ធសាសនិកជន ជនជាតិវៀតណាម និងជនជាតិចាម។

១៣៧៤. ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័ត ការស្លាប់របស់ជនរងគ្រោះគឺជាលទ្ធផលនៃអំពើសកម្ម ឬអកម្មនៃចារី ដែលជាមូលហេតុចម្បងនៃការស្លាប់របស់ជនរងគ្រោះ។

១៣៧៥. មូលហេតុពិតប្រាកដនៃកកើតកន្លែងសម្លាប់មនុស្សដូចបានរៀបរាប់ខាងលើ គឺដើម្បីសម្រួលដល់ការ សម្លាប់រង្គាលទៅលើជនរងគ្រោះ ឱ្យចាកឆ្ងាយពីក្រសែភ្នែករបស់ប្រជាជន ស្របតាមគោលនយោបាយ "កម្ទេចខ្មាំង" របស់បក្សកុម្មុយនីស្តកម្ពុជា។ ជនរងគ្រោះទាំងនោះ ជាពិសេស ជនរងគ្រោះដែលជា អតីតទាហាន និងជាមន្ត្រីរដ្ឋការក្នុងសម័យ លន់ នល់ ត្រូវបានសម្លាប់នៅ**ទួលពោធិជ្រៃ**។ ជនរងគ្រោះដែលជាសមាជិកនៃ "ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសមកពីក្រុងកំពង់ឆ្នាំង និងភ្នំពេញ **ទៅកាន់កន្លែងសម្លាប់មនុស្ស ក្នុងស្រុក១២** និងអ្នកស្រុកទាំងឡាយដែលត្រូវបានរកឃើញថាមានជាប់ខ្សែ រយៈជាមួយលេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម ដែលត្រូវបានបោសសម្អាត ត្រូវបាននាំយកទៅ សម្លាប់នៅស្ទឹងត្រូច។

១៣៧៦. ទាក់ទងដល់**មន្ទីរសន្តិសុខនានា**នៅក្នុងរបបនោះ បុគ្គលិកមន្ទីរសន្តិសុខគឺជាអ្នកដែលបានបង្ក ដោយផ្ទាល់ឬដោយប្រយោលឲ្យមានការស្លាប់បាត់បង់ជីវិតដល់ជនជាប់ឃុំឃាំងយ៉ាងច្រើន សន្ធឹកសន្ធាប់។ ជាទូទៅ អ្នកទោសត្រូវបានគេសម្លាប់ដោយចេតនា តាមរយៈមធ្យោបាយច្រើនយ៉ាង ជាពិសេស ការសម្លាប់ភ្លាមៗនៅក្នុងមន្ទីរសន្តិសុខតែម្តង ឬក៏នៅក្បែរៗនោះ។ ក៏ប៉ុន្តែ មានអ្នកទោសជាច្រើនបានស្លាប់ដោយសារការធ្វើទារុណកម្ម និងការធ្វើបាបផ្សេងៗដែលប្រព្រឹត្ត មកលើពួកគេ។

១៣៧៧. ប្រសិនបើគោលដៅចម្បងនៃ**ការផ្លាស់ទីលំនៅប្រជាជន** និង**ការធ្វើការងារដោយបង្ខំ** ពុំមែនដើម្បី សម្លាប់មនុស្សដែលជាមុខសញ្ញាទេនោះ ក៏ភស្តុតាងនៃសំណុំរឿងបង្ហាញថា មនុស្ស ត្រូវបានសម្លាប់ដោយ កងទ័ពខ្មែរក្រហមនៅមុនពេល នៅក្នុងពេល ឬនៅពេលទៅដល់ នៃការផ្លាស់ទីលំនៅ ដំណាក់កាលទី១ និងទី៣។ ដោយឡែក ការតាមដានបុគ្គលម្នាក់ៗនៅតាម ការដ្ឋានធ្វើការងារនានា មានគោលដៅដើម្បីស្វែងរក "ខ្មាំង" ជាពិសេសអ្នក ដែលបដិសេធពុំព្រម ធ្វើការផ្លាស់ទី ឬអ្នកដែលគ្មានសមត្ថភាពក្នុងការបំពេញការងារដែលគេបានប្រគល់អោយ។ ជារឿយៗ ជនរងគ្រោះត្រូវបានសម្លាប់នៅនឹងកន្លែង (ទំនប់ត្រពាំងថ្ម) ឬត្រូវបានគេចាប់ខ្លួន បន្ទាប់ មកនាំយកទៅសម្លាប់នៅក្បែរៗ នោះ (ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង និងព្រៃស)។

១៣៧៨. អំពើមនុស្សឃាត ត្រូវបានប្រព្រឹត្តផងដែរក្នុងក្របខណ្ឌនៃការធ្វើបាបទៅលើក្រុមមនុស្ស ដែលជាពុទ្ធសាសនិក (ព្រះសង្ឃដែលបដិសេធពុំព្រមលាចាកសិក្ខាបទ) ទៅលើ**ជនជាតិវៀតណាម** (អ្នកដែលប្រឆាំងនឹងការនិរទេសកាលពីឆ្នាំ១៩៧៥-១៩៧៦)និង ទៅលើជនជាតិចាម (ទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខក្រូចឆ្មា និងនៅវត្តអូរត្រកួន)។ ក្នុងករណីប្រជាជនវៀតណាម និងប្រជាជនចាម ដែលត្រូវ បានកំណត់ជាបទល្មើសប្រល័យពូជសាសន៍ អំពើមនុស្សឃាតទាំងនេះ ដែលប្រព្រឹត្តទៅ លើក្រុមមនុស្សទាំងពីរក្រុមនេះ បានអនុវត្តជាទូទៅចាប់តាំងពីឆ្នាំ១៩៧៧ មក។

១៣៧៩. ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ចារីនៃអំពើសម្លាប់មនុស្សភាគច្រើនដែលបំពេញភារកិច្ច ក្រោម ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការប្រតិបត្តិនូវផែនការរួមសំដៅធានាការរក្សា សន្តិសុខ និង"កម្ទេចខ្មាំង" ពួកគេបានប្រព្រឹត្តដោយមានចេតនាសម្លាប់មនុស្សតែម្តង។ ទោះជា សន្មតថា នៅក្នុងករណីមួយចំនួននៃអំពើទារុណកម្ម ឬអំពើហិង្សា ដែលបានបណ្តាលឲ្យបាត់បង់

ជីវិតមនុស្ស ចារីគ្មាន ចេតនានឹងសម្លាប់មនុស្សក៏ដោយ ប៉ុន្តែយោងទៅលើស្ថានភាពនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពរាងកាយនៃជនរងគ្រោះ ចារីគួរតែដឹងជាមុនថា អំពើទារុណកម្ម ឬអំពើហិង្សាដែលប្រព្រឹត្តទៅលើជនរងគ្រោះ អាចសម្លាប់មនុស្សបាន។

១៣៨០.ករណីមនុស្សឃាតទាំងនេះ ដែលបានប្រព្រឹត្តដោយកម្មាភិបាល បុគ្គលិក ឬកងទ័ព និងកងសន្តិសុខនៃបក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយទាំងឡាយដែល ត្រូវបានប្រើប្រាស់ដើម្បីសម្រេចនូវគោលដៅរួមក្នុងការបោសសម្អាត "ខ្មាំង" ជាពិសេស តាមរយៈការដាក់ចេញនូវគោលនយោបាយរបស់គណៈមជ្ឈិម អនុម័តនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលសម្រេចអំពីការផ្ទេរអំណាចទៅគណៈភូមិភាគ និងតំបន់ស្វយ័តមួយចំនួនក្នុងការ "កម្ទេច" មនុស្សដែលស្ថិតនៅ "ក្រៅជួរបដិវត្តន៍"។ អំពើមនុស្សឃាតទាំងនេះ គឺជាផ្នែកមួយនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល ដែលចំណុចនេះ ចារី និងជនត្រូវចោទបានដឹងយ៉ាងច្បាស់។ នៅក្នុងរឿងក្តីនេះ ការប្រព្រឹត្តិរបស់ពួកគេនៅទូទាំងប្រទេស ដូចដែលសាក្សី និងដើមបណ្តឹង រដ្ឋប្បវេណីនានាបានរៀបរាប់ប្រាប់ (ទោះបីជា ការប្រព្រឹត្តទាំងនេះ នៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មទាំងនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្តីសម្រេច និងសម្របសម្រួលឲ្យមានការប្រព្រឹត្តិ ឧក្រិដ្ឋកម្មទាំងនេះ ក្នុងក្របខណ្ឌនៃផែនការរួម ។

**ការសម្លាប់រង្គាល**

១៣៨១. មានធាតុផ្សំគ្រប់គ្រាន់ចំពោះបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពជាការសម្លាប់រង្គាល[5263]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបងទៅនឹងជនដែលត្រូវបាន សម្លាប់ ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ នៅតាមទីកន្លែងសម្លាប់មនុស្សទាំងឡាយ ដែលរួមមាន **ជើងឯក កន្លែងសម្លាប់ មនុស្សក្នុងស្រុក១២ ស្ទឹងតូច និងទួលពោធិជ្រៃ**, នៅតាមមន្ទីរសន្តិសុខនានា ដែលរួមមានមន្ទីរសន្តិសុខ **កោះខ្យង គោកក្តួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត ស-២១ សង់ វត្តគិរីរម្យ វត្តធ្លក** និងនៅតាមការដ្ឋានធ្វើការងារដោយបង្ខំ ដូចជា **ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ព្រៃស ការដ្ឋានស្រែអំបិល ទំនប់ត្រពាំងថ្ម** និង**សហករណ៍ត្រាំកក់**។ ធាតុផ្សំនៃឧក្រិដ្ឋកម្មសម្លាប់រង្គាល ក៏ត្រូវបាន បំពេញផងដែរក្នុងដំណាក់កាលទី១ និងទី២ នៃការទីលំនៅប្រជាជន និងការប្រព្រឹត្តិទៅលើ **ក្រុមជនជាតិវៀតណាម និងជនជាតិចាម**។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៣៨២. ទាក់ទងដល់ធាតុផ្សំសត្យានុម័ត អំពើសកម្ម និងអកម្មរបស់ចារី ទោះបីជាអំពើនោះត្រូវបានប្រព្រឹត្តដោយផ្ទាល់ក្តីឬដោយប្រយោលក្តី បានបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតដល់មនុស្សជាច្រើននាក់ រួមទាំងការបង្កើតនូវលក្ខខណ្ឌជីវិតដ៏លំបាកលំបិន ដើម្បីឈានទៅរកការបំផ្លាញប្រជាជនមួយភាគ។ ទោះបីជាគេពុំមានតួលេខច្បាស់លាស់ដែលបញ្ជាក់អំពីចំនួននៃអ្នកស្លាប់ និងការកំណត់ អត្តសញ្ញាណនៃសាកសពទាំងឡាយរបស់ជនរងគ្រោះក៏ដោយ ក៏ភស្តុតាងនានានៃសំណុំរឿងមានលក្ខណៈ គ្រប់គ្រាន់អាចបញ្ជាក់អំពីការស្លាប់របស់មនុស្សដែលមានចំនួនដល់ទៅរាប់ម៉ឺននាក់។

១៣៨៣. ប្រសិនណាជាពុំមានចំនួនអប្បបរិមានៃជនរងគ្រោះ ដើម្បីធ្វើការកំណត់ប្រភេទបទល្មើសសម្លាប់រង្គាលទេនោះ ក្នុងករណីជាក់ស្តែងនីមួយៗដូចដែលបានរៀបរាប់ពីខាងលើ ដោយយោងទៅលើចំនួននៃអ្នកស្លាប់ដែលបានកំណត់នៅក្នុងឯកសារ ឬតាមរយៈសក្ខីកម្មនានា និងដែលបានបញ្ជាក់តាមរយៈ សាកសពដ៏ច្រើនសន្ធឹកសន្ធាប់ដែលគេបានរកឃើញនៅក្នុងរណ្តៅសពនានាក៏ដូចជាភស្តុតាងរឹងមាំ លម្អិតនានាខាងក្រោម អំពើដែលបានលើកឡើងនេះបានឈានដល់ទំហំធំគ្រប់គ្រាន់ និងមានចរិតលក្ខណៈជា សម្ងហភាព។

១៣៨៤.ទាក់ទងដល់**ទីកន្លែងសម្លាប់មនុស្ស** ដូចដែលត្រូវបានកត់សម្គាល់ឃើញនៅក្នុងក្របខណ្ឌនៃការកំណត់អំពីបទមនុស្សឃាតខាងលើ ហេតុផលផ្ទាល់នៃទីកន្លែងសម្លាប់មនុស្សនេះ គឺដើម្បីសម្រួលដល់ការសម្លាប់ជនរងគ្រោះក្នុងទ្រង់ទ្រាយធំ។

១៣៨៥.ទាក់ទងដល់**មន្ទីរសន្តិសុខ** ក៏ដូចជាព្រៃស ក្រៅអំពីអំពើមនុស្សឃាតជាលក្ខណៈបុគ្គល មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់អំពីការសម្លាប់ និងការស្លាប់បណ្តាលមកពីអំពើទារុណកម្ម និងអំពើហឹង្សាដទៃទៀត ដែលបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំ និងមានលក្ខណៈជាសម្ងហភាព។ ជាឧទាហរណ៍ ផ្អែកលើឯកសារនានា គេអាចសន្និដ្ឋានបានថាមានមនុស្សលើសពី ១២.០០០ នាក់ត្រូវបានសម្លាប់នៅ មន្ទីរ ស-២១ ហើយច្បាស់ណាស់ក៏មានមនុស្សលើសពី ១៥.០០០ នាក់ត្រូវបានសម្លាប់នៅក្រាំងតាចាន់ដែរ។

១៣៨៦. ទាក់ទងដល់ការប្រព្រឹត្តិទៅលើក្រុមជនជាតិ**វៀតណាម** ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៧ និងទៅ លើជនជាតិចាម ចាប់ផ្តើមតាំងពីដើមឆ្នាំ១៩៧៧ ការសម្លាប់សមាជិកនៃក្រុមមនុស្សទាំងនេះបានវិវត្តឈានដល់ទ្រង់ទ្រាយធំ និងជាសម្ងហភាព ដែលបង្កជាការសម្លាប់រង្គាល។ សម្រាប់


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ជនជាតិចាម ការសម្លាប់រង្គាលបានកើតឡើងជាពិសេសនៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងភូមិភាគបូព៌ា និងមន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងភូមិភាគកណ្តាល (ខត្តរចាស់)។

១៣៨៧. ដោយឡែក ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកស្តីអំពី "ទង្វើអមនុស្សធម៌ផ្សេងៗទៀត" និង "ការធ្វើទុក្ខបុកម្នេញ" មានមនុស្សជាច្រើននាក់បានស្លាប់ ដោយសារស្ថានភាពរស់នៅមានការលំបាកវេទនា នៅ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនលើកទី១ និងទី២ និងនៅតាមមន្ទីរសន្តិសុខទាំងនោះ។ មនុស្ស ទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ។ ដូចគ្នានេះដែរ ចំពោះអ្នកដែលធ្វើការនៅការដ្ឋានធ្វើការងារដោយបង្ខំ ពួកគេស្ថិតក្នុងស្ថានភាពរស់នៅ ដូចគ្នា មិនតែប៉ុណ្ណោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ថែមទៀតផង។

១៣៨៨. ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ដែលចាំបាច់សម្រាប់ការកំណត់បទល្មើសសម្លាប់រង្គាល ចារីនៃអំពើសកម្ម ឬអកម្ម ដែលនាំទៅរកការស្លាប់របស់មនុស្សនៅតាមកន្លែងសម្លាប់មនុស្ស ដូចដែលបានរៀបរាប់ខាងលើ មានចេតនា ដូចមេដឹកនាំនានានៃបក្សកុម្មុយនីស្តកម្ពុជាដែរ ក្នុងការសម្លាប់មនុស្សក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់។

១៣៨៩. ពាក់ព័ន្ធទៅនឹងការស្លាប់ ដែលបណ្តាលមកពីស្ថានភាពរស់នៅលំបាកវេទនា ដែលទទួលរងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន និងនៅក្នុងពេលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខ និងនៅតាមការដ្ឋាននានា ចារីផ្ទាល់បានប្រព្រឹត្តបទល្មើសដោយបានដឹងជាមុនថា ស្ថានភាពរស់នៅដែលពួកគេតម្រូវទៅលើជនរងគ្រោះនឹងបណ្តាលឱ្យជនរងគ្រោះទាំងនោះស្លាប់បាត់បង់ជីវិតក្នុងទ្រង់ទ្រាយធំ។ ដោយបានដឹងអំពីចំនួនអ្នកស្លាប់ ដែលបណ្តាលមកពីស្ថានភាពរស់នៅលំបាកវេទនាបែបនោះ ចារីនៅតែបន្តកំណត់ស្ថានភាពរស់នៅបែបនោះទៅលើជនរងគ្រោះដដែល។ ផ្អែកលើធាតុផ្សំអស់ទាំងនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការកំណត់បទល្មើសសម្លាប់រង្គាលមានធាតុផ្សំគ្រប់គ្រាន់ដែលអាចទទួលយកបាន។

១៣៩០. ករណីសម្លាប់រង្គាលទាំងនេះ ដែលភាគច្រើនបានប្រព្រឹត្តដោយកម្មាភិបាល បុគ្គលិក ឬកងទ័ព និងកងសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយទាំងឡាយដែលប្រើប្រាស់ដើម្បីសម្រេចនូវគោលដៅរួមក្នុងការបោសសម្អាត "ខ្មាំង"។ អំពើសម្លាប់រង្គាល

ទាំងនេះគឺជាផ្នែកមួយនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល ដែលចំណុចនេះជនល្មើស និងជនត្រូវចោទបានដឹងច្បាស់។ នៅក្នុងរឿងក្ដីនេះ ការប្រព្រឹត្តិរបស់ពួកគេនៅទូទាំងប្រទេស ដូចដែលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីនានាបានរៀបរាប់ប្រាប់ (ទោះបីជា ការប្រព្រឹត្តទាំងនេះនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មទាំងនេះ និងបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្ដីសម្រេច និងសម្របសម្រួល ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ក្នុងក្របខណ្ឌនៃផែនការរួម ។

## ការធ្វើឲ្យទៅជាទាសករ

**១៣៩១.** មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើឲ្យទៅជាទាសករ[5264]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបង នឹង**សហករណ៍ត្រាំកក់** និង**ការដ្ឋានធ្វើការងារដោយបង្ខំ នៅទំនប់ ១ មករា ព្រលានយន្តហោះកំពង់ឆ្នាំង ស-២៤ ការដ្ឋានស្រែអំបិល ទំនប់ត្រពាំងថ្ម**។ មានធាតុផ្សំគ្រប់គ្រាន់ផងដែរនៃការធ្វើឲ្យទៅជាទាសករ នៅ**មន្ទីរសន្តិសុខកោះខ្សែង គោកក្ដួច ក្រាំងតាចាន់ ភូមិភាគឧត្ដរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត** មន្ទីរ**ស-២១** សង់ **វត្តគិរីរម្យ និងវត្តផ្ទុក**។

**១៣៩២.** ចំពោះធាតុផ្សំសត្យានុម័ត បុគ្គលិកនៃសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខទាំងនេះ បានអនុវត្តការគ្រប់គ្រង និងអំណាចទាំងស្រុងដែលដូចគ្នានឹងសិទ្ធិកម្មសិទ្ធិ ទៅលើបុគ្គលដែលស្ថិតនៅទីនោះ ដោយមិនឲ្យបុគ្គលទាំងនោះមានលទ្ធភាពក្នុងការយល់ព្រមទទួលយកឡើយ។

**១៣៩៣.** ដោយអនុវត្តនូវផែនការបដិវត្តន៍នៃបក្សកុម្មុយនីស្តកម្ពុជាក្នុងការកសាងសង្គមនិយម និងក្នុងការកម្ទេចខ្មាំងផ្ទៃក្នុង និងខាងក្រៅ តាមរយៈការបង្កើតបណ្ដាញ សហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ ចាប់តាំងពីមុន ឆ្នាំ១៩៧៥ នៅក្នុងតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជា និងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រាល់ការសម្រេចស្ទើរតែទាំងអស់ទាក់ទងទៅនឹងមជ្ឈដ្ឋានផ្លូវកាយរបស់ជនរងគ្រោះ ត្រូវធ្វើឡើងដោយកម្មាភិបាលមូលដ្ឋាននៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការបន្តអនុវត្តនយោបាយរបស់បក្ស។ ជាដំបូងគឺចាប់ផ្ដើមឡើង ដោយការដកហូតទ្រព្យសម្បត្តិឯកជនមកធ្វើជាសម្បត្តិរួម និងការតម្រូវឲ្យរស់នៅតាមសហករណ៍ ដូចជានៅត្រាំកក់ជាដើម។ គ្រួសារទាំងអស់ត្រូវបានគេបំបែកចេញពីគ្នា ទៅតាម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

អាយុ សមត្ថភាពធ្វើការ និងសមត្ថភាពក្នុងការបង្កបង្កើនផល។ ការកាន់សាសនា ប្រពៃណីវប្បធម៌ និងសេរីភាពនៃការនិយាយស្តី ត្រូវបានហាមឃាត់។ ការជ្រើសរើសគូស្រករត្រូវបានគេបង្ខំ ហើយឪពុកម្តាយក៏មិនមានសិទ្ធិអប់រំកូនឡើយ។ មានការគ្រប់គ្រងទាំងស្រុងលើរបបអាហារ (ជាលក្ខណៈរួម) ប្រភេទនៃកន្លែងស្នាក់នៅ ការទទួលនូវការព្យាបាលជំងឺ និងការអនុញ្ញាតឱ្យធ្វើការដើរហើរ ទោះបីទៅជួបជុំគ្រួសារក៏ដោយ។ មានការត្រួតពិនិត្យផ្នែកផ្លូវចិត្តផងដែរ តាមរយៈការតាមដានយ៉ាងខ្ជាប់ខ្ជួន ពីសំណាក់ពួកឈ្លប ការប្រជុំស្វ័យទិតៀន និងការបាត់ខ្លួន ការដាក់ទណ្ឌកម្មយ៉ាងតឹងរឹងចំពោះរាល់ការប៉ុនប៉ងលួចរត់ និងការប្រើប្រាស់កម្លាំងបាយជាប្រចាំថ្ងៃ ការធ្វើទុក្ខទោសយ៉ាងព្រៃផ្សៃ ការគម្រាមកំហែង ឬក៏ការបង្ខំឱ្យគោរពតាមនយោបាយបក្ស។ មនុស្សជាច្រើនត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខ ដោយសារតែពួកគេបានរកអាហារបន្ថែម ឬមួយបានត្អូញត្អែរអំពីជីវភាពរស់នៅ។

១៣៩៤.ជាងនេះទៅទៀត នៅគ្រប់កន្លែងដែលបានរៀបរាប់ខាងលើ រួមមានទាំងមន្ទីរសន្តិសុខផង ជនរងគ្រោះត្រូវបង្ខំឱ្យធ្វើការងារដែលខ្លួនមិនចង់ធ្វើ ដោយគ្មានប្រាក់ខែ និង ដោយពួកគេមិនបានទទួលផលដោយផ្ទាល់ពីការងារនោះ។ កន្លែង ពេលវេលា និងម៉ោងធ្វើការ ត្រូវបានគេកំណត់។ ជនរងគ្រោះមិនមានសិទ្ធិបដិសេធមិនទទួលការងារដែលប្រគល់ឱ្យនោះទេ។ ការងារនេះ ជាមួយនឹងធាតុការគ្រប់គ្រងដែលបានរៀបរាប់ខាងលើ បានដកហូតពីជនរងគ្រោះ នូវអំណាចសម្រេចរបស់ខ្លួន និងបង្កើតបានជាការធ្វើឱ្យទៅជាទាសករ។

១៣៩៥.ចំពោះធាតុផ្សំអត្តនោម័ត ចារីដែលប្រព្រឹត្តក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការតម្រូវឱ្យអនុវត្តផែនការរួមរបស់បក្សក្នុងការកសាងលទ្ធិសង្គមនិយម មានចេតនាក្នុងការយកអាយុជីវិតរបស់ជនរងគ្រោះមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដោយអនុវត្តអំណាចទាំងអស់ដែលដូចគ្នានឹងសិទ្ធិកម្មសិទ្ធិ ទៅលើជនរងគ្រោះ។ ចេតនានេះអាចសន្និដ្ឋានចេញផងដែរ ពីកម្រិតនៃការត្រួតត្រាដោយបង្ខំ ដែលត្រូវបានអនុវត្ត ពីការដាក់ឱ្យអនុវត្តជាលក្ខណៈទូទៅនៅទូទាំងប្រទេស និងពីភាពធ្ងន់ធ្ងរនៃការដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនគោរពតាមគោលការណ៍។

១៣៩៦.ការដាក់ឱ្យទៅជាទាសភាពនេះ ដែលមួយផ្នែកធំរៀបចំឡើង ដោយកម្មាភិបាល បុគ្គលិក កងទ័ព កងសន្តិសុខ នៃបក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយ ដែលត្រូវបានប្រើប្រាស់ ដើម្បីឈានទៅដល់គោលដៅរួមក្នុងការកសាងសង្គមនិយម។ ការដាក់ឱ្យទៅជា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ទាសភាពនេះគឺជាផ្នែក មួយនៃការវាយប្រហារប្រជាជនស៊ីវិល ដែលចារី និងជនត្រូវចោទបានដឹង។ នៅក្នុងរឿងក្តីនេះ ការប្រព្រឹត្តនូវការធ្វើឱ្យទៅជាទាសករនៅទូទាំងប្រទេស ដូចដែលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីនានា បានរៀបរាប់ (ទោះបីជា ការប្រព្រឹត្តទាំងនេះនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មទាំងនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្តីសម្រេច និង សម្របសម្រួលឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ក្នុងក្របខណ្ឌនៃផែនការរួម ។

**ការនិរទេស**

**១៣៩៧.** មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការនិរទេស នៅខេត្ត **ព្រៃវែង ខេត្តស្វាយរៀង** និងសហករណ៍ស្រុកត្រាំកក់[5265] ។

**១៣៩៨.** ទាក់ទងនឹងធាតុផ្សំសត្យានុម័ត ជនជាតិវៀតណាមមួយភាគធំ ដែលរស់នៅប្រទេសកម្ពុជា ត្រូវបាន បង្ខំឱ្យចាកចេញពីទីលំនៅស្របច្បាប់របស់ខ្លួន និងឱ្យឆ្លងទៅព្រំដែនវៀតណាម។ ប្រជាជន ត្រូវបានបង្ខំឱ្យចាកចេញ ដោយការគម្រាមកំហែង ចាប់តាំងពីបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់ អំណាច។ ការធ្វើ ដូច្នេះបានប្រព្រឹត្តទៅរហូតដល់ឆ្នាំ១៩៧៦។ អ្នកដែលមិនបានចាកចេញទៅ ក្រោយមកត្រូវបានសម្លាប់។

**១៣៩៩.** គ្មានភស្តុតាងណាមួយ ដែលបញ្ជាក់ថា អ្នកដែលត្រូវបានផ្លាស់ទីលំនៅ មិនមានសិទ្ធិ ឬមិនត្រូវបាន អនុញ្ញាតិឱ្យរស់នៅកន្លែង ដែលពួកគេត្រូវបានផ្លាស់ទីលំនៅចេញនោះទេ។ គ្មានអ្វីបញ្ជាក់ថា “ការបោសសម្អាត” ជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា មានគោលដៅស្របច្បាប់ ដែល ទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិដូចជា បញ្ហាសន្តិសុខប្រជាជនឬភាពចាំបាច់ខាងផ្នែកយោធានោះ ទេ។

**១៤០០.** យោងតាមចំនួនជនរងគ្រោះ និងប្រភេទនៃការផ្លាស់ទីលំនៅ ដោយប្រើប្រាស់នូវអន្តរាគមពី អាជ្ញាធរ នៅគ្រប់តំបន់នៃប្រទេស ចារីនៃអំពើនិរទេសមានចេតនាបង្ខំឱ្យជនជាតិវៀតណាមចាកចេញ ពីប្រទេស។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៤០១.ការនិរទេសនេះ ដែលមួយផ្នែកធំរៀបចំឡើងដោយកម្មាភិបាល បុគ្គលិក កងទ័ព កងសន្តិសុខនៃបក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយ ដែលត្រូវបានប្រើប្រាស់ ដើម្បីសម្រេចគោលដៅរួមក្នុងការការពារប្រទេសពីខ្មាំងខាងក្នុង និងខាងក្រៅ។ ការនិរទេសនេះ គឺជាផ្នែកមួយនៃការ វាយប្រហារប្រជាជនស៊ីវិល ដែលចារី និងជនត្រូវចោទបានដឹង។ ការប្រព្រឹត្តនូវការនិរទេសនេះ នៅ ទូទាំងប្រទេសក្នុងអំឡុងពេលជាច្រើនខែ ដូចដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាបានរៀបរាប់ (ទោះជាការប្រព្រឹត្តនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្តីសម្រេច និងសម្របសម្រួលឲ្យមានការនិរទេសនេះ ក្នុងក្របខណ្ឌនៃផែនការរួម។

## ការដាក់ក្នុងមន្ទីរឃុំឃាំង

១៤០២.មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការឃុំឃាំង[5266]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបង នឹងមន្ទីរសន្តិសុខទាំងអស់ដែលស្ថិតក្រោមការស៊ើបសួរ ដូចជា **កោះខ្យង គោកក្ដួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត មន្ទីរ ស២១ សង់វត្តគិរីរម្យ និងវត្តធ្លក**។ ធាតុផ្សំនៃបទល្មើសការដាក់ក្នុងមន្ទីរឃុំឃាំងក៏ត្រូវរកឃើញផងដែរ នៅការដ្ឋាន **ព្រៃស និងសហករណ៍ត្រាំកក់** និងនៅក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តចំពោះចំពោះជនជាតិចាម។

១៤០៣.ចំពោះធាតុផ្សំសត្យានុម័ត ជនរងគ្រោះត្រូវបានដកហូតសេរីភាពយ៉ាងតឹងរ៉ឹង តាមទំនើងចិត្ត ដោយបំពានទៅលើសិទ្ធិនានាដែលមានចែងក្នុងនៅច្បាប់។

១៤០៤.អ្នកជាប់ឃុំរាប់ម៉ឺននាក់ក្នុងមន្ទីរសន្តិសុខត្រូវបានដាក់ឃុំឃាំងដោយចេតនា ដោយបំពាន និងដោយគ្មានមូលដ្ឋានគតិយុត្តិ។ ដូចបានរៀបរាប់នៅក្នុងផ្នែកស្តីពី"ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហ ឧក្រិដ្ឋកម្មរួម" បណ្តាញនៃមន្ទីរសន្តិសុខបានជំនួសប្រព័ន្ធយុត្តិធម៌ ដើម្បីជួយសម្រួលដល់ការឃុំឃាំង ដែលផ្អែកលើភាពបង្កគ្រោះថ្នាក់តាមការសន្មតចំពោះបុគ្គលនានា ទៅតាមការយល់ឃើញរបស់អាជ្ញាធររបស់ប.ក.ក។ ការធ្វើបែបនេះបានរំលោភយ៉ាងជាក់ស្តែងទៅលើសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានសេរីភាព និងសុវត្ថិភាព ដែលផ្តល់ជូនដោយច្បាប់អន្តរជាតិ។ អាស្រ័យហេតុនេះ អ្នកទោសមិនបានទទួលការធានាណាមួយតាមនីតិវិធីច្បាប់ នៅចន្លោះថ្ងៃទី១៧ ខែមេសា

ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលអាចឱ្យអ្នកទាំងនោះដឹងអំពីមូលហេតុនៃការចាប់ខ្លួន ឬអាចជំទាស់នឹងការឃុំខ្លួន ឬការដាក់ទោសលើពួកគេ។

១៤០៥. ចំពោះសហករណ៍ និងការដ្ឋាននានា ការប៉ះពាល់ដល់សេរីភាពមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីកំណត់ថា ជាអំពើនៃការឃុំឃាំង។ នៅការដ្ឋានព្រៃស អ្នកជាប់ឃុំត្រូវបានបិទសិទ្ធិសេរីភាព និងឃាម កាមយ៉ាងតឹងរ៉ឹង ទាំងពេលធ្វើការ និងពេលយប់ ជាពិសេស "អ្នកជាសមាសភាពមិនល្អ" ពីព្រោះអ្នកទាំងនោះត្រូវបានដាក់ខ្នោះនៅពេលយប់។ នៅសហករណ៍ត្រាំកក់ ឈ្លបឃុំចាប់ឃុំខ្លួន និងសួរចម្លើយមនុស្សនៅក្នុងមន្ទីរឃុំឃាំង ដែលស្ថិតក្រោមឱវាទកងឈ្លបឃុំ។

១៤០៦. ចំពោះធាតុផ្សំអត្តនោម័ត ចារីបានប្រព្រឹត្តដោយចេតនាក្នុងការដកហូតសេរីភាព របស់អ្នកទោសតាមទំនើងចិត្តរបស់ខ្លួន។

១៤០៧. ករណីនៃការឃុំឃាំងទាំងនេះ ដែលត្រូវបានធ្វើឡើងមួយផ្នែកធំដោយកម្មាភិបាល បុគ្គលិក ឬកងទ័ព និងកងសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយនានាដែលប្រើប្រាស់ដើម្បីសម្រេចគោលដៅរួមសំដៅបោសសម្អាត "ខ្មាំង" ជនជាតិវៀតណាមនិងជនជាតិចាម។ ការឃុំឃាំងគឺជា ផ្នែកមួយនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលដែលចារី និងជនត្រូវចោទបានដឹង។ ការប្រព្រឹត្តិនូវការឃុំឃាំងនៅទូទាំងប្រទេស ដូចដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាបានរៀបរាប់ប្រាប់ (ទោះបីជាការប្រព្រឹត្តនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្តីសម្រេច និងសម្របសម្រួលដល់ការប្រព្រឹត្តទាំងនេះ ក្នុងក្របខណ្ឌនៃផែនការរួម។

**ការធ្វើទារុណកម្ម**

១៤០៨. មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទារុណកម្ម[5267]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបងនឹងអ្នកជាប់ឃុំ ដែលបានទទួលរងទារុណកម្ម នៅឯមន្ទីរសន្តិសុខ **កោះខ្យង គោកក្តួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល ព្រៃដំរីស្រុត មន្ទីរស-២១ សង់ និងវត្តធ្លក**។ មានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើស ធ្វើទារុណកម្ម ផងដែរនៅការដ្ឋានធ្វើការដោយបង្ខំ **ព្រៃស សហករណ៍ត្រាំកក់** និងក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តចំពោះ**ជនជាតិចាម**។

១៤០៩. ចំពោះធាតុផ្សំសត្យានុម័ត បុគ្គលិកមន្ទីរសន្តិសុខបានបង្កដោយចេតនាឱ្យមានទុក្ខវេទនា និងការឈឺចាប់ធ្ងន់ធ្ងរទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ក្នុងអំឡុងពេលសួរចម្លើយ ជាច្រើនលើកច្រើនសា តាមរយៈអំពើសកម្ម ឬអកម្មរបស់ខ្លួន។

១៤១០. ដោយពិចារណាទៅលើភស្តុតាងជាក់ស្តែង និងភស្តុតាងតាមការយល់ឃើញទាំងអស់នៃរឿងក្តី ការប្រព្រឹត្តចំពោះជនទាំងនេះមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីកំណត់ថា ជាការធ្វើទារុណកម្ម៖ វិធីដែលបានប្រើប្រាស់ រួមផ្សំនឹងលក្ខខណ្ឌអមនុស្សធម៌ និងបរិបទនៃភាពតក់ស្លុតដែលគ្របដណ្តប់នៅតាមមន្ទីរសន្តិសុខ បានបង្កឱ្យមានផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដែលជួនកាលបណ្តាលឱ្យមានការស្លាប់។ ការធ្វើទារុណកម្មត្រូវបានគិតទុកជាមុន និងដាក់ឱ្យអនុវត្តជាប្រព័ន្ធ ជាសមាសធាតុមួយដ៏សំខាន់នៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹង "សត្រូវ" ។ ការធ្វើទារុណកម្មមានទម្រង់ ជាអាទិ៍ ជាការវាយដំ ការឆក់ខ្សែភ្លើង ការធ្វើឱ្យថប់ដង្ហើមដោយច្រកក្បាលក្នុងថង់ប្លាស្ទិក ការធ្វើឱ្យថប់ដង្ហើមដោយប្រើទឹក ការចាក់ទម្លុះ និងដកក្រចកដៃក្រចកជើង ការចាក់ម្ជុលចូលក្នុងសាច់ក្រោមក្រចក ការអុជនឹងភ្លើងបារី ការបង្ខំឱ្យថ្វាយបង្គំរូបឆ្កែ ឬវត្ថុផ្សេងៗ ការបង្ខំឱ្យស៊ីលាមក ឬផឹកទឹកនោម ការគំរាមធ្វើទារុណកម្ម ឬសម្លាប់ដោយផ្ទាល់ ឬដោយប្រយោលចំពោះអ្នកជាប់ឃុំ ឬសមាជិកគ្រួសាររបស់ពួកគេ ការប្រើភាសាប្រមាថមើលងាយ ការជ្រមុជក្បាលអ្នកជាប់ឃុំទៅក្នុងទឹកពាង ឬការចងដៃអ្នកជាប់ឃុំទៅក្រោយ រួចព្យួរឡើងលើ។

១៤១១. ការធ្វើបាបដែលបានប្រព្រឹត្តមានគោលដៅជាសំខាន់ក្នុងការប្រមូលព័ត៌មាន និងទទួលបានចម្លើយសារភាពពាក់ព័ន្ធនឹង "សកម្មភាពក្បត់" របស់ជនរងគ្រោះ និងអត្តសញ្ញាណសមាជិកនៃ "បណ្តាញ" របស់ជនរងគ្រោះ ដើម្បីបន្តចាប់ខ្លួនសមាជិកទាំងនោះទៀត។

១៤១២. ម្យ៉ាងវិញទៀត ចារីនៃបទល្មើសទាំងនេះធ្វើសកម្មភាពក្នុងពេលបំពេញមុខងារជាផ្លូវការរបស់ខ្លួនដែលជាក់ស្តែង ពួកគេបានប្រព្រឹត្តអំពើទាំងនេះ ដោយបំពេញតួនាទីដែលត្រូវបានប្រគល់ជូន នៅក្នុងរចនាសម្ព័ន្ធបញ្ជាដែលត្រូវបានកំណត់យ៉ាងច្បាស់ ជាពិសេសរចនាសម្ព័ន្ធនៃផ្នែកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា។

១៤១៣. ទាក់ទងនឹងធាតុផ្សំអត្តនោម័ត អង្គហេតុនៃរឿងក្តីនេះបង្ហាញអំពីចេតនានៃអំពើសកម្ម ឬអកម្មដែលតាមរយៈអំពើទាំងនេះ បានបង្កឱ្យមានការឈឺចាប់ខ្លោចផ្សា និងទុក្ខវេទនាយ៉ាងខ្លាំង។

១៤១៤.ការធ្វើទារុណកម្មទាំងនេះ ដែលភាគច្រើនត្រូវបានប្រព្រឹត្តដោយកម្មាភិបាល និងបុគ្គលិកផ្នែកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោបាយនានាដែលគេប្រើដើម្បីសម្រេចគោលដៅរួមក្នុងការកម្ទេច "ខ្មាំង"។ ការធ្វើទារុណកម្មជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល ដែលចារី និងជនត្រូវចោទបានដឹង។ ការប្រព្រឹត្តនូវការធ្វើទារុណកម្មនៅតាមមន្ទីរសន្តិសុខនៅទូទាំងប្រទេស ដូចដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាបានរៀបរាប់ប្រាប់ (ទោះជា ការប្រព្រឹត្តនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាអ្នកដែលចេញសេចក្តីសម្រេច និងសម្របសម្រួលដល់ការប្រព្រឹត្តិនេះ ក្នុងក្របខណ្ឌនៃផែនការរួម។

## ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា

១៤១៥.មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[5268]។ ក្នុងករណីលម្អិតខាងក្រោមនេះ អំពើសកម្ម ឬអកម្មរបស់ចារី បានបង្កឱ្យមានការរើសអើងដោយពិតប្រាកដ ដែលជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានមួយឬច្រើន ដែលមានចែងនៅក្នុងច្បាប់ទំនៀមទំលាប់ ឬច្បាប់អន្តរជាតិ។ អំពើសកម្ម និងអកម្មទាំងអស់បានបង្ហាញអំពីភាពធ្ងន់ធ្ងរបំផុតមួយ។ បុគ្គលទាំងឡាយត្រូវបានចាត់ទុកជាមុខសញ្ញា ដោយសារពួកគេជាសមាជិកពិតប្រាកដ ឬដោយសន្មត របស់ក្រុមមនុស្សទាំងឡាយដែលត្រូវបានកំណត់ដោយអាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យផ្នែកនយោបាយ ពូជសាសន៍ និងសាសនា។

### ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ

១៤១៦.ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អង្គហេតុកើតមានស្ទើរតែនៅគ្រប់ទីកន្លែងទាំងអស់ដែលស្ថិតក្រោមការស៊ើបសួរ ដូចជា៖ នៅដំណាក់កាលទី១ ទី២ និងទី៣ នៃការផ្លាស់ទីលំនៅប្រជាជន, នៅការដ្ឋាន ឬជំរំធ្វើការដោយបង្ខំ ដូចជា **ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ព្រៃស ស្រែអំបិល សហករណ៍ត្រាំកក់** និង**ទំនប់ត្រពាំងថ្ម** នៅតាមមន្ទីរសន្តិសុខ ដូចជា **កោះខ្សែង គោកក្តួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត មន្ទីរ ស-២១ សង់**

00605721



វត្តគិរីរម្យ និងវត្តផ្លក និងនៅកន្លែងសម្លាប់មនុស្ស ដូចជា ជើងឯក កន្លែងសម្លាប់មនុស្សក្នុងស្រុក១២ ស្ទឹងតូច និងទួលពោធិ៍ជ្រៃ។

១៤១៧. អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណ "ខ្មាំង" ជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មតរបស់ក្រុមមនុស្សទាំងនោះ ឬដោយសារមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ មនុស្សប្រភេទខ្លះនៃក្រុមមនុស្សទាំងនេះ ដូចជាអតីតថ្នាក់ដឹកនាំស៊ីវិល និងយោធានៃរបបសាធារណៈរដ្ឋខ្មែរ ត្រូវបានរាប់បញ្ចូលក្នុងផែនការរួមនៃការកសាងលទ្ធិសង្គមនិយម។ ចំណែកឯភ្នាក់ងារតូចតាចនៃរបបចាស់ អ្នកខ្លះត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ដោយសារការគាំទ្ររបស់ខ្លួនដល់រដ្ឋាភិបាលចាស់ ហើយជាញឹកញាប់ ពួកគេត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខ ដូចជាមន្ទីរ ស-២១ ឬទួលពោធិ៍ជ្រៃ។ ប្រជាជនទាំងអស់ដែលស្ថិតនៅតាមទីប្រជុំជន នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ត្រូវបានចាត់ទុកជា "ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" និងបានស្ថិតនៅក្រោមការប្រព្រឹត្តិតឹងរ៉ឹងជាងប្រជាជនចាស់ ក្នុងគោលបំណងលត់ដំ ឬកំណត់អត្តសញ្ញាណ "ខ្មាំង" នៅក្នុងចំណោមពួកគេ។ បញ្ញវន្ត និស្សិត និងអ្នកការទូតដែលរស់នៅបរទេស ត្រូវបានហៅឲ្យត្រឡប់ចូលស្រុកវិញ ហើយនៅពេលមកដល់ ពួកគាត់ត្រូវបានបញ្ជូនទៅជំរំលត់ដំ ឬទៅមន្ទីរ ស-២១។ "ខ្មាំង"ប្រភេទនេះ កាន់តែមានច្រើនទៅៗ ទៅតាមពេលវេលា។ ម្យ៉ាងទៀត ការកំណត់មនុស្សដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ ដោយឈរលើមូលដ្ឋាននៃការបំបាត់រាល់បុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាជាក់ស្តែង គឺជាទម្រង់មួយនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ។

១៤១៨.នៅតាមសហករណ៍ និងការដ្ឋានធ្វើការដោយបង្ខំ ដូចនៅពេលផ្លាស់ទីលំនៅប្រជាជនដែរ ខ្មាំងពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេធ្វើបាបនិងដាក់ឲ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬទៅកម្ទេចចោលនៅតាមមន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្ស។

## ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា

១៤១៩.ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ពុទ្ធសាសនិក និង ជនជាតិចាម

គឺជាជនរងគ្រោះជាប្រព័ន្ធនៃអំពើធ្វើទុកបុកម្នេញនេះ ក្នុងកម្រិតធំធេង។ ពុទ្ធសាសនិក និងជនជាតិចាមត្រូវបានកំណត់មុខសញ្ញា ដោយសារមូលហេតុរើសអើង ដែលពួកគេមានសមាជិកភាពទៅនឹងក្រុមទាំងនោះ។ អំពើដែលរៀបរាប់ខាងក្រោមបង្កើតបានជាការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ក្រុមទាំងនោះ។

១៤២០.ធាតុផ្សំនៃឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើពួកចាម ត្រូវបានបំពេញ (សូមពិនិត្យមើល"ការប្រព្រឹត្តិមកលើពួកចាម" "ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល/ឧត្តរចាស់ ភូមិភាគនិរតី ភូមិភាគបូព៌ា និង ភូមិភាគបស្ចិម" និង "ការដ្ឋានទំនប់១មករា") បានកើតមានឡើងយ៉ាងហោចណាស់នៅទីតាំងពីរដែលស្ថិត នៅក្រោមការស៊ើបសួរ គឺមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា។ ការលុបបំបាត់ចោល នូវវប្បធម៌ ប្រពៃណី និងភាសា របស់ជនជាតិចាមកើតមានឡើងនៅថ្នាក់ជាតិ។ ប.ក.ក បានហាម ឃាត់ជនជាតិចាមប្រតិបត្តិសាសនាអ៊ីស្លាម ហាមរឹបអូសយក និងដុតចោលគម្ពីរគួរអាន បិទទ្វារនិង បំផ្លាញវិហារ ហើយជនជាតិចាមត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក។ មេសាសនា និង និស្សិតសាសនា ត្រូវបានចាប់ខ្លួន និង សម្លាប់។ ស្ត្រីជនជាតិចាម ត្រូវបានបង្ខំឲ្យកាត់សក់ និង ហាមមិនឲ្យរុំក្បាល។ សហគមន៍ជនជាតិចាម ត្រូវបានបំបែក ផ្លាស់ទីលំនៅដោយបង្ខំនៅទូទាំងប្រទេស និង ត្រូវបានបំបែក ឲ្យទៅរស់នៅក្នុងសហគមន៍នានា។

១៤២១.ទាក់ទងទៅនឹងពុទ្ធសាសនិក ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាបានកើតឡើងនៅគ្រប់តំបន់ទាំងអស់នៅកម្ពុជា ដូចជានៅតាមទីតាំង៖ **វត្តដំណាក់ត្រយឹង វត្តសំរោង វត្តគិរីរម្យ វត្តចំបក់ វត្តតាគត់ វត្តមេ វត្តធ្លក វត្តជ័យមង្គល វត្តអន្លង់វៀន និង សហករណ៍ស្រុកត្រាំកក់**។ ការគោរពព្រះពុទ្ធសាសនាត្រូវបានហាមឃាត់។ វត្តអារាម និងវិហារត្រូវបានកម្ទេចចោល ឬប្រើប្រាស់សម្រាប់អ្វីផ្សេង និងរូបសំណាកព្រះពុទ្ធក៏ត្រូវបានកម្ទេចផងដែរ។ ព្រះសង្ឃ និង ដូនជីទាំងអស់ត្រូវបានចាប់ផ្សឹក ហើយមានព្រះសង្ឃខ្លះត្រូវបានគម្រាមសម្លាប់ ឬ សម្លាប់ ប្រសិនបើមិនព្រមតាម។ អតីតព្រះសង្ឃមួយអង្គរៀបរាប់ថា គាត់ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។

## ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍

១៤២២.ប្រជាជនវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញ ពីព្រោះថាប.ក.ក ចាត់ទុកជនជាតិវៀតណាមថា ជា

00605723



ពូជសាសន៍ដទៃ ខុសពីពូជសាសន៍ខ្មែរ ដោយផ្អែកលើសែស្រឡាយខាងម្តាយ។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ កើតមានឡើងនៅខេត្តព្រៃវែង និងស្វាយរៀង ក៏ដូចជានៅតាមមន្ទីរសន្តិសុខ ក្រាំងតាចាន់ គោកក្ដួច និង អូរកន្សែង ស-២១ និងសហករណ៍ត្រាំកក់។ ជនជាតិវៀតណាមត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាដោយចេតនានិងជាលក្ខណៈប្រព័ន្ធ ដោយផ្អែកលើមូលដ្ឋាន "ពូជសាសន៍" របស់គេ។ នៅក្នុងករណីខ្លះ ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីទឹកដីកម្ពុជា និងបញ្ជូនទៅកាន់វៀតណាម។ នៅក្នុងករណីខ្លះទៀត ជនជាតិវៀតណាមត្រូវបានចាប់ខ្លួន ឃុំខ្លួន និងសម្លាប់។ ចាប់ពីខែមេសា ឆ្នាំ ១៩៧៧មក ជនជាតិវៀតណាមត្រូវបានគេប្រមូលផ្តុំ និងសម្លាប់ជាទ្រង់ទ្រាយធំ នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។ ជនជាតិវៀតណាមត្រូវបានគេកំណត់អត្តសញ្ញាណ ដោយការប្រើប្រាស់ បញ្ជីស្ថិតិ ដែលត្រូវបានរៀបចំ និង ចងក្រងជាមុន។ ជារឿយៗ ចារីតែងតែផ្ទៀងផ្ទាត់ថា ជនរងគ្រោះគឺពិតជាជនជាតិវៀតណាមសិនមុននឹងសម្លាប់។

១៤២៣. ទាក់ទងនឹងធាតុផ្សំអត្តនោម័ត ក្នុងរឿងក្តីនេះ ចេតនានៃការប្រព្រឹត្តិការរើសអើង ដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ស្តែងចេញពីបរិបទនៃការវាយប្រហារ និងកាលៈទេសៈដែលនៅជុំវិញការប្រព្រឹត្តិអំពើទាំងនេះ។

១៤២៤. ជាក់ស្តែង ទាក់ទងនឹងការធ្វើទុក្ខម្នេញផ្នែកនយោបាយ ភស្តុតាងជាច្រើនបង្ហាញថា ក្រុម "ខ្មាំង" ដូចជាប្រជាជនថ្មី និងភ្នាក់ងារនៃរបប លន់ នល់ គឺជាប្រភេទមនុស្សដែលត្រូវទទួលការប្រព្រឹត្តិខុសពីគេ។ តាមរយៈសេចក្តីប្រកាស និងការបោះពុម្ពផ្សាយជាផ្លូវការទាក់ទងនឹងក្រុមទាំងអស់នោះ ការប្រព្រឹត្តិ បែបនេះបញ្ជាក់ថា ចារីពិតជាមានចេតនាជាក់លាក់ក្នុងការធ្វើឲ្យប៉ះពាល់ដល់ជនរងគ្រោះ ដោយមូលហេតុជនរងគ្រោះជាសមាជិកនៃក្រុម "ខ្មាំង" ទាំងនេះ។ ជាឧទាហរណ៍ បុគ្គលទាំងឡាយ ដែលមជ្ឈិមបក្សចាត់ទុកថាជាអ្នកប្រឆាំងផ្នែកនយោបាយ ដែលជាញឹកញាប់ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ជាមួយសមាជិកគ្រួសារ ឬអ្នកជិតស្និទ្ធរបស់គេ ត្រូវបានគេចាត់ទុកថាជាខ្មាំងបម្រើឲ្យសហរដ្ឋអាមេរិក សាធារណរដ្ឋសង្គមនិយមសហភាពសូវៀត ឬប្រទេសវៀតណាម ដែលត្រូវតែ សម្លាប់ចោល។

១៤២៥. ការធ្វើទុក្ខបុកម្នេញទាំងនេះ ដែលភាគច្រើនត្រូវបានប្រព្រឹត្តដោយកម្មាភិបាល និងបុគ្គលិកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ឬអ្នកនៅក្រោមអំណាចរបស់ពួកគេ ជាក់ស្តែង គឺជាផ្នែកមួយនៃមធ្យោ

00605724



បាយដែលប្រើប្រាស់ដើម្បីសម្រេចគោលនយោបាយក្នុងការកម្ទេច "ខ្មាំង" ហើយក៏ជាវិធានការនានាសម្រាប់ប្រឆាំងនឹងក្រុមមនុស្សជាក់លាក់មួយចំនួនផងដែរ។ ដូច្នេះ ការធ្វើទុក្ខបុកម្នេញនេះជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល ដែលចារី និងជនត្រូវចោទបានដឹង។ នៅក្នុងរឿងក្តីនេះ ការប្រព្រឹត្តនូវការធ្វើទុក្ខបុកម្នេញនៅទូទាំងប្រទេស ដូចដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាបាន រៀបរាប់ប្រាប់ (ទោះជាការប្រព្រឹត្តនៅក្រៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការស៊ើបសួរក៏ដោយ) បានបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មនេះ និងបានបង្ហាញយ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដែលចេញសេចក្តីសម្រេច និងសម្របសម្រួលដល់ការប្រព្រឹត្តិនេះក្នុងក្របខណ្ឌនៃផែនការរួម។

**ការរំលោភផ្លូវភេទ**

__ការរំលោភផ្លូវភេទដែលប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ ការដ្ឋាន និងសហករណ៍__

**១៤២៦.**មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការរំលោភផ្លូវភេទ[5269] ត្រូវបានប្រព្រឹត្តឡើងនៅក្នុងកាលៈទេសៈផ្សេងៗ ជាអាទិ៍នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ **ភូមិភាគឧត្តរ ព្រៃដំរីស្រុត មន្ទីរស-២១ និងសង់ ព្រមទាំងនៅក្នុងសហករណ៍ត្រាំកក់។**

**១៤២៧.**ចំពោះទីតាំងនីមួយៗដូចបានរៀបរាប់ខាងលើចារីបានប្រព្រឹត្តដោយចេតនានូវការលុកលុយរាងកាយជាលក្ខណៈផ្លូវភេទទៅលើជនរងគ្រោះ តាមវិធីបង្ខំ ដោយគ្មានការព្រមព្រៀងគ្នាពីសំណាក់ជនរងគ្រោះ ដែលចារីបានដឹងច្បាស់ ហើយធាតុផ្សំជាបរិបទនៃការរំលោភផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញ។

**១៤២៨.**ផ្អែកតាមអង្គហេតុដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" នៃដីកាដំណោះស្រាយនេះ យើងឃើញថា ទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាផ្ទុយទៅនឹងទស្សនៈសមូហភាពរបស់ ប.ក.ក ហើយថា ជនដែលត្រូវបានចោទប្រកាន់ថា មានអំពើ "ខុសសីលធម៌)" ត្រូវបានចាត់ចូលប្រភេទ "សមាសភាពមិនល្អ" ឬ"ខ្មាំង" ដែលជារឿយៗ ត្រូវបានលត់ដំ ឬ សម្លាប់។ នៅក្នុងបរិបទនេះ កម្មាភិបាលនៃមន្ទីរសន្តិសុខ

ទាំងនេះដឹងថា ការរំលោភផ្លូវភេទគឺជាបទល្មើសដែលខ្លួនអាចទទួលរងទណ្ឌកម្ម ឧទាហរណ៍ដូចជា នៅមន្ទីរសន្តិសុខ ក្រាំងតាចាន់ជាដើម។ ជាញឹកញាប់ អ្នកដែលបានប្រព្រឹត្តអំពើរំលោភផ្លូវភេទ ត្រូវបានចាប់ខ្លួន នៅពេលថ្នាក់លើរបស់ពួកគេបានដឹងអំពីអំពើបទល្មើសនេះ ដូចជានៅមន្ទីរសន្តិសុខ សង់។ លើសពីនេះ ជួនកាលកម្មាភិបាល ប.ក.ក បានទទួលការណែនាំឱ្យស៊ើបអង្កេតលើករណី រំលោភផ្លូវភេទនៅតាមសន្តិសុខនានា ដូចជា នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ មានភស្តុតាងដែល បង្ហាញថាកម្មាភិបាលបានរាយការណ៍អំពីករណីរំលោភផ្លូវភេទជូនថ្នាក់លើរបស់ខ្លួន ដោយចារីទាំង នោះត្រូវបានចាត់ទុកថាជា "ជនក្បត់" ឬ "ខ្មាំង" ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី ជនត្រូវចោទ **នួន ជា** និង **អៀង សារី** និង នៅក្នុងផ្នែកស្តីអំពីសហករណ៍ស្រុកត្រាំកក់។

១៤២៩.ផ្អែកលើភស្តុតាងទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា គោលនយោបាយជាផ្លូវការ របស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្ម ដល់ចារី។ ពិតណាស់ ទោះបីជាគោលនយោបាយនេះមិនអាចឈានទៅដល់ ការរារាំងការរំលោភ ផ្លូវភេទក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្ម នានា ដែលត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់ឱ្យអនុវត្តនូវផែនការរួមឡើយ ។ ក៏ប៉ុន្តែ ករណីនេះខុសពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចដែលនឹងរៀបរាប់ ខាងក្រោម។

## ការរំលោភផ្លូវភេទដែលប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

១៤៣០.មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការរំលោភផ្លូវភេទ នៅក្នុង ក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ("សូមមើលផ្នែកស្តីពី "ការរៀបអាពាហ៍ពិពាហ៍)[5270]។

១៤៣១. ចំពោះធាតុផ្សំសត្យានុម័ត ដោយតម្រូវឱ្យរួមដំណេកក្រោយការរៀបអាពាហ៍ពិពាហ៍ដោយ បង្ខំ ចារីបាន ធ្វើឱ្យជនរងគ្រោះទទួលរងនូវការលុកលុយរាងកាយជាលក្ខណៈផ្លូវភេទ តាមវិធីបង្ខំ ដោយមិនមានការព្រមព្រៀងពីជនរងគ្រោះ។ ចំពោះធាតុផ្សំអត្តនោម័ត ចារីបានតម្រូវឱ្យមានការ លុកលុយរាងកាយជាលក្ខណៈផ្លូវភេទដោយចេតនា ហើយចារីបានដឹងពីកាលៈទេសៈបង្ខំ ឬ យ៉ាងហោចណាស់បានដឹង អំពីការមិនព្រមព្រៀងពីសំណាក់ជនរងគ្រោះ។ សហចៅក្រមស៊ើប អង្កេតកត់សម្គាល់ឃើញថា តាមលក្ខណៈនៃអំពើ និងផលវិបាកនៃអំពើជាពិសេស ដោយការ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

កំណត់មុខសញ្ញាជាសំខាន់ទៅលើបូរណភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ អង្គហេតុនៃការរំលោភផ្លូវភេទទាំងនេះគឺជាផ្នែកមួយនៃការវាយប្រហារប្រឆាំងលើជនស៊ីវិល។ ចារីបានដឹងថាមានការវាយប្រហារមួយលើជនស៊ីវិល ហើយអំពើរបស់ខ្លួនរួមចំណែកដល់ការវាយប្រហារនេះ។

១៤៣២. ទោះបីជា ឌុច រំលឹកអំពីឧទាហរណ៍នៃកម្មាភិបាលមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានដាក់ទណ្ឌកម្មពីបទបានបញ្ជាអ្នកនៅក្រោមបង្គាប់ឱ្យតាមដានប្ដីប្រពន្ធរៀបការ ដើម្បីឱ្យដឹងថាតើពួកគេរួមដំណេកជាមួយគ្នាដែរឬទេក៏ដោយ ក៏មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា នេះមិនមែនជាគោលការណ៍ទេ៖ ផ្ទុយទៅវិញ ការរួមដំណេកក្រោយអាពាហ៍ពិពាហ៍ ត្រូវបានឃ្លាំមើលជាប្រចាំ ដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ហើយប្ដីប្រពន្ធដែលមិនព្រមរួមដំណេកក្រោយអាពាហ៍ពិពាហ៍អាចត្រូវបានចាប់ខ្លួន។ ផ្អែកលើអង្គហេតុទាំងអស់នេះ ឧក្រិដ្ឋកម្មក្រោមទម្រង់ជាការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រើប្រាស់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីដាក់ឱ្យអនុវត្តផែនការរួម។

១៤៣៣. អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការបំពារបំពានផ្លូវភេទ[5271]។

## អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស

១៤៣៤.មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ផ្សេងៗទៀត[5272]។ អង្គហេតុទាំងនេះពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការប្រព្រឹត្តិទៅលើប្រជាជននៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ (ដំណាក់កាលទី១) និងការជម្លៀសប្រជាជនចេញអំពីភូមិភាគកណ្តាល (អតីតភូមិភាគឧត្តរ) ភូមិភាគបស្ចឹមនិងបូព៌ា (ដំណាក់កាលទី២), នៅតាមសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ព្រៃស ស្រែអំបិល និងទំនប់ត្រពាំងថ្ម ក៏ដូចជានៅតាមមន្ទីរសន្តិសុខកោះខ្យង គោកក្ដួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត ស-២១ និង សង់ ផងដែរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៤៣៥.ទាក់ទងដល់ធាតុផ្សំសត្យានុម័ត ការមិនផ្តល់ឲ្យប្រជាជននូវ អាហារគ្រប់គ្រាន់ ទីជម្រក ជំនួយវេជ្ជ-សាស្ត្រ លក្ខខណ្ឌអនាម័យអប្បរិមា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានធ្វើឲ្យជនរងគ្រោះ ទទួលរងនូវការឈឺចាប់ផ្នែកផ្លូវកាយ និងផ្លូវចិត្ត ការរងរបួស ព្រមទាំងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរជាមនុស្ស រហូតដល់កម្រិតមួយធ្ងន់ធ្ងរមានទំហំប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀតដែរ។

១៤៣៦.ការកំណត់អំពីលក្ខខណ្ឌរស់នៅបែបនេះ បានកើតឡើងនៅក្នុងដំណាក់កាលទី១ និងទី២ នៃ **ការផ្លាស់ទីលំនៅប្រជាជន**។ ប្រជាជនត្រូវបានបង្ខិតបង្ខំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ឲ្យធ្វើការចាកចេញពីលំនៅដ្ឋានរបស់ខ្លួនជាប្រញាប់ ដោយគ្មានឱកាសត្រៀមរៀបចំរបស់របរសម្ភារៈធ្វើដំណើរអ្វីឡើយ។ មនុស្សម្នាក់ៗមិនមានអាហារ និងទឹកទទួលទានគ្រប់គ្រាន់ឡើយនៅក្នុងដំណើរជម្លៀសចេញនោះ ដែលពួកគេត្រូវធ្វើដំណើរដោយថ្មើរជើង ឬតាមមធ្យោបាយដទៃទៀតដែលប្រើកម្លាំងកាយដ៏លំបាកលំបិន ព្រមទាំងស្ថិតក្នុងស្ថានភាពខ្វះអនាម័យទៀតផង។ ប្រសិនបើមានករណីដែលប្រជាជនដែលត្រូវបានជម្លៀសទទួលបាននូវជម្រកបណ្តោះអាសន្នក្នុងពេលផ្លាស់ទីលំនៅនោះ វាជាករណី លើកលែងប៉ុណ្ណោះ ពីព្រោះថា តាមធម្មតាប្រជាជនទាំងនោះត្រូវបានគេតម្រូវឲ្យសម្រាកនៅកណ្តាលវាលតែម្តង។ ក្នុងករណីភាគច្រើន ពុំមានជំនួយវេជ្ជសាស្ត្រណាមួយត្រូវបានផ្តល់ជូនប្រជាជនជម្លៀសនោះទេ បើទោះបីជាក្នុងចំណោមពួកគេ មានវត្តមានក្រុមមនុស្សដែលនឹងរងគ្រោះថ្នាក់ ដូចជាករណីអ្នកជំងឺ ទារក និងមនុស្សចាស់ជរាក៏ដោយ។ នៅក្នុងពេលជម្លៀសនោះ ដោយសារអំពើអមនុស្សធម៌នានាដែលពួកគេបានទទួលរង មានមនុស្សជាច្រើននាក់បានធ្លាក់ខ្លួនឈឺ ឬទទួលរងរបួស បាក់កម្លាំង ព្រមទាំងមានការតក់ស្លុតខាងផ្លូវចិត្ត ហើយអ្នកខ្លះបានស្លាប់បាត់បង់ជីវិតផងដែរ។

១៤៣៧. ការកំណត់អំពីលក្ខខណ្ឌរស់នៅបែបនេះ គឺជាវិធីសាស្ត្រដែលអនុវត្តដដែលៗនៅតាមការដ្ឋាន **ធ្វើការងារដោយបង្ខំ** និងនៅតាមសហករណ៍នានាដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា។ នៅតាមការដ្ឋានធ្វើការងារដោយបង្ខំទាំងឡាយ ដែលស្ថិតនៅក្រោមការស៊ើបសួរ អ្នកធ្វើការងារនៅទីនោះមិនត្រូវបានគេផ្តល់អាហារ និងជំនួយវេជ្ជសាស្ត្រ និងអនាម័យឡើយ។ នៅតាមការដ្ឋានធ្វើការងារដោយបង្ខំ ចំណីអាហារមានលក្ខណៈខ្វះខាត ទាំងបរិមាណ ទាំងគុណភាព ជាពិសេសដោយពិចារណាទៅលើលក្ខខណ្ឌការងារដែលបានដាក់ចំពោះអ្នកធ្វើការ។ អ្នកធ្វើការងារទាំងឡាយរស់នៅ និងសម្រាកនៅតាមជម្រករួមតោកយ៉ាក ដែលមានសភាពកខ្វក់ និង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605728



មានមនុស្សណែនតាន់តាប់។ ជាទូទៅ ពុំមានការចាត់ វិធានការទប់ស្កាត់ចំពោះជំងឺឆ្លងនានាទេ ហើយការព្យាបាលជំងឺទៀតសោត គឺធ្វើឡើងដោយ គ្រូពេទ្យដែលមិនបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ គ្មានថ្នាំសង្កូវ និងបរិក្ខាវេជ្ជសាស្ត្រគ្រប់គ្រាន់។ ជាលទ្ធផល ការព្យាបាលជំងឺមិនសូវមានប្រសិទ្ធភាពទេ ហើយមានពេលខ្លះបានធ្វើឱ្យអ្នកជំងឺកាន់តែឈឺធ្ងន់ឡើងថែមទៀត។ លើសពីនេះ អ្នកធ្វើការងារដែលធ្លាក់ខ្លួនឈឺតែងត្រូវបានបង្អត់អាហារ។ ពុំមានសេវាអនាម័យឡើយ ហើយបើមានក៏បណ្តោះអាសន្នដែរ។ ប្រជាជនដែលរស់នៅតាមការដ្ឋានធ្វើការងារដោយបង្ខំ និងនៅតាមសហករណ៍នានា បានទទួលរងនូវការឈឺចាប់រាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ដែលបណ្តាលមកពីអំពើអមនុស្សធម៌ទាំងនេះ។

១៨៣៨.ការកំណត់អំពីលក្ខខណ្ឌរស់នៅបែបនេះគឺជាចរិតលក្ខណៈរួមមួយនៃទង្វើដែលប្រព្រឹត្ត ទៅលើបុគ្គលជាប់ឃុំឃាំងនៅតាមមន្ទីរសន្តិសុខនានារបស់បក្សកុម្មុយនីស្តកម្ពុជា។ របបអាហាររបស់អ្នកជាប់ឃុំឃាំងមានលក្ខណៈស្តួចស្តើងបំផុត។ ពួកគេរស់នៅ និងសម្រាកនៅក្នុងបន្ទប់ឃុំឃាំងតូចៗ ដែលផ្ទុកចំនួនអ្នកទោសហួសចំណុះ។ អ្នកទោសមួយចំនួនត្រូវបានគេដាក់ខ្នោះដៃនិងខ្នោះជើងតភ្ជាប់គ្នាពីម្នាក់ទៅម្នាក់ទាំងយប់ទាំងថ្ងៃ។ មានអ្នកជាប់ឃុំឃាំងជាច្រើន ដែលធ្លាក់ក្នុងស្ថានភាពទ្រុឌទ្រោមដោយសារស្ថានភាពរស់នៅលំបាកវេទនា និងទទួលរងការធ្វើបាបពីសំណាក់កងសន្តិសុខ និងអ្នកសួរចម្លើយ បានធ្លាក់ខ្លួនឈឺ ហើយនៅពេលនោះទៀតសោត ពួកគេទទួលបានការព្យាបាលដែលមានលក្ខណៈពុំត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ពីសំណាក់បុគ្គលិកពេទ្យដែលមិនបានទទួលការបណ្តុះបណ្តាល និងដោយគ្មានឧបករណ៍ពេទ្យពិតប្រាកដ និងថ្នាំសង្កូវអ្វីឡើយ។ ដោយមានចេតនាការបំពាក់សេវាអនាម័យពុំមានលក្ខណៈគ្រប់គ្រាន់ឡើយ។ អ្នកទោសជាប់ឃុំឃាំងត្រូវបង្ខំឱ្យជុះ ឬនោមនៅទីកន្លែងដែលពួកគេដេកនិងរស់នៅ ដែលស្ថិតនៅជិតៗគ្នាពីម្នាក់ទៅម្នាក់ ដោយរួមទាំងអ្នកដែលកើតជំងឺឆ្លងផងដែរ ហើយមានលទ្ធភាពតិចតួច ឬគ្មានតែម្តង ក្នុងការលុបលាងខ្លួន បោកគក់សម្លៀកបំពាក់ ឬលាងសម្អាតបន្ទប់ឃុំឃាំងរបស់ខ្លួន។ ការប្រព្រឹត្តដូច្នេះបានធ្វើឱ្យបុគ្គលធ្លាក់ក្នុងស្ថានភាពសុខភាពខ្សោយ អត់ឃ្លាន និងភាពទ្រុឌទ្រោមផ្នែករាងកាយជាទូទៅ ក៏ដូចជាភាពឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ។ មានអ្នកខ្លះបានស្លាប់ដោយសារកត្តាទាំងអស់នេះផងដែរ។

១៨៣៩.ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ចារីបានដឹងអំពីស្ថានភាពនៃអង្គហេតុដែលបង្ហាញឱ្យឃើញពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួន។

១៤៤០. អំពើអមនុស្សធម៌ដទៃទៀត ដែលភាគច្រើនប្រព្រឹត្តដោយកម្មាភិបាល បុគ្គលិក ឬយោធានិងកងសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងឡាយដែលប្រើប្រាស់សម្រាប់សម្រេចនូវផែនការរួម ក្នុងកសាងរបបសង្គមនិយម កម្ទេច"ខ្មាំង" និងការពារបដិវត្តន៍ ដែលប្រការនេះបានឈានទៅរកការបង្កើតនូវបរិយាកាសភ័យខ្លាច និងបង្ខិតបង្ខំ។ តាមលក្ខណៈ និងផលវិបាករបស់វា អំពើអមនុស្សធម៌ទាំងនេះជាផ្នែកមួយនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល ដែលជនល្មើស និងជនត្រូវចោទទាំងឡាយបានដឹងច្បាស់។ អំពើនេះបានប្រព្រឹត្តក្នុងរូបភាពជាប្រព័ន្ធនៅទូទាំងប្រទេសកម្ពុជា ក្នុងសម័យកាលដែលស្ថិតក្រោមការស៊ើបសួរ ដូចដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបានរៀបរាប់ ដែលជាការបញ្ជាក់អំពីចរិតលក្ខណៈទូទៅនៃឧក្រិដ្ឋកម្ម និងជាការបញ្ជាក់យ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាអ្នកចេញសេចក្តីសម្រេច និងធ្វើការសម្របសម្រួលឲ្យមានការប្រព្រឹត្តិអំពើអមនុស្សធម៌ទាំងនេះក្នុងក្របខណ្ឌនៃការអនុវត្តន៍ផែនការរួម។

១៤៤១. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា មានការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងទៀតដែលជាប់ទាក់ទិននឹងអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ។

## អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

១៤៤២. សម្រាប់អង្គហេតុនីមួយៗ ដែលមានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "អាពាហ៍ពិពាហ៍" (នៅក្នុងផ្នែកស្តីអំពី "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម") សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានធាតុផ្សំគ្រប់គ្រាន់នៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា ជាពិសេស នៅតាមទីតាំង ដូចជា **ទំនប់មួយមករា ទំនប់ត្រពាំងថ្ម សហករណ៍ត្រាំកក់ មន្ទីរសន្តិសុខគោកក្ដួច និងនៅក្នុងបរិបទនៃការប្រព្រឹត្តចំពោះពុទ្ធសាសនិក**[5273]។

១៤៤៣. ចំពោះធាតុផ្សំសត្យានុម័ត ជនរងគ្រោះបានទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្ត


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ឬការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្សក្នុងកម្រិតមួយធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែរ។ ជាក់ស្ដែង ជនរងគ្រោះត្រូវបានបង្ខំឱ្យរួមសមគ្គសង្វាស។

១៤៤៤. ចំពោះធាតុផ្សំអត្តនោម័ត ចារីបានដឹងអំពីកាលៈទេសៈអង្គហេតុ ដែលបង្ហាញឱ្យឃើញពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួន។

១៤៤៥. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា តាមលក្ខណៈ និងផលវិបាកនៃអំពើ និងជាពិសេសដោយការកំណត់មុខសញ្ញាជាសំខាន់ទៅលើបូរណភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ អង្គហេតុនៃការរំលោភបំពានខាងផ្លូវភេទទាំងនេះ គឺជាផ្នែកមួយនៃការវាយប្រហារលើជនស៊ីវិល ។ ចារីដឹងថា មានការវាយប្រហារលើជនស៊ីវិល ហើយថា អំពើរបស់ខ្លួនរួមចំណែកក្នុងការវាយប្រហារនេះ។

១៤៤៦. ផែនការរួមសំដៅ ឬរាប់បញ្ចូល ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជា "អំពើអមនុស្សធម៌ផ្សេងទៀត" តាមវិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការដាក់ឱ្យអនុវត្តផែនការរួមពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានជួយសម្រួលតាមរយៈទំនាក់ទំនងប្ដីប្រពន្ធដែលតម្រូវដល់ជនរងគ្រោះដោយចារីដែលជាកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈជាប្រព័ន្ធ និងបង្កើតបានជាផ្នែកមួយនៃផែនការរួម ដែលត្រូវបានអនុវត្តនៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៦។ លក្ខណៈជាទូទៅនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស បានបង្ហាញយ៉ាងច្បាស់ថា អំពើនេះត្រូវបានសម្រេច និងសម្របសម្រួលដោយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងក្របខ័ណ្ឌនៃផែនការរួម។ ចំពោះវិធីសាស្ត្រប្រតិបត្តិការចំបង សាក្សីនានានៃតំបន់ផ្សេងៗបានបញ្ជាក់ថា តំណាងបក្សកុម្មុយនីស្ដកម្ពុជាផ្គូផ្គងអ្នកដែលមានលក្ខណៈសម្បត្តិស្រដៀងគ្នា។ លក្ខណៈពិសេសនៃវិធីសាស្ត្រនេះ និងភស្តុតាងនៃការអនុវត្តតាមកន្លែងផ្សេងៗ បង្ហាញអំពីអត្ថិភាពនៃផែនការរួមមួយ ដែលត្រូវបានតាក់តែងឡើងនៅថ្នាក់កំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការអនុវត្តទូទៅមួយទៀត ដែលបញ្ជាក់ថាការរៀបអាពាហ៍ពិពាហ៍បានប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃផែនការរួម គឺការណ៍ដែលថា ជាទូទៅ ការរៀបអាពាហ៍ពិពាហ៍ជាច្រើនត្រូវបានរៀបចំ ក្នុងពេលជាមួយគ្នា ដែលក្នុងពិធីម្ដងមានពី២០ ទៅ ៦០គូ។

១៤៤៧. ក្នុងករណីភាគច្រើននៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានការគំរាមកំហែងសម្លាប់ មានការប្រើអំពើហិង្សា ឬមានការសម្លាប់ ក្នុងករណីបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍។ សាក្សីជាច្រើនបានបញ្ជាក់ថា ដោយសារពួកគេភ័យខ្លាចពេក ពួកគេមិនហ៊ានជំទាស់នោះឡើយ។ ពិធីត្រូវបានរៀបចំឡើង ដោយគ្មានការចូលរួមតាមលក្ខណៈប្រពៃណីពីសំណាក់ឪពុកម្ដាយរបស់កូនកម្លោះ-កូនក្រមុំ។ មិនមានការគោរពតាមពិធីប្រពៃណីឡើយ។ ក្នុងករណីខ្លះ អនាគតសហព័ទ្ធណាមួយអាចសុំការអនុញ្ញាតរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលខ្លួនស្គាល់ ប៉ុន្តែ ករណីនេះមិនអាចផ្លាស់ប្ដូរការណ៍ដែលថា ការដាក់កំហិត ឬការបង្ខំត្រូវបានធ្វើឡើងទៅលើបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណផងដែរ។ សាក្សីមួយចំនួនអះអាងថា ពួកគេត្រូវបានបង្ខំឱ្យរួមដំណេក ដែលចំណុចនេះស៊ីសង្វាក់ទៅនឹងអត្ថិភាពនៃផែនការរួម ដែលបង្កើតឡើងដោយមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយតាមរយៈនេះ ការរៀបអាពាហ៍ពិពាហ៍ជាការចាំបាច់ដើម្បីបង្កើនចំនួនប្រជាជន។

## អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ

១៤៤៨. មានធាតុផ្សំគ្រប់គ្រាន់នៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបង្កឡើងតាមរយៈអំពើអមនុស្សធម៌ផ្សេងទៀតដោយការជម្លៀសដោយបង្ខំ[5274]។ អង្គហេតុទាំងនេះទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជនពីទីក្រុងភ្នំពេញ បន្ទាប់ពីការចូលមកដល់នៃកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី ១៧ មេសា ១៩៧៥ (ដំណាក់កាលទី១) ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្ដាល (ឧត្តរចាស់) រួមទាំងពីភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ាក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ពីការជម្លៀសចេញពីភ្នំពេញ និងរហូតដល់ឆ្នាំ១៩៧៦ និង ១៩៧៧ (ដំណាក់កាលទី២) និងការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា ពីចុងឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨ (ដំណាក់កាលទី៣)។

១៤៤៩. ចំពោះធាតុសត្យានុម័ត ជនរងគ្រោះបានទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្ត ឬការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលមានកម្រិតធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។ ជាក់ស្ដែង ជនរងគ្រោះត្រូវបានបង្ខំឱ្យចាកចេញពីទីលំនៅស្របច្បាប់របស់ខ្លួន ដោយគ្មានមូលហេតុដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ។

១៤៥០. មានការប្រើប្រាស់ការបង្ខំនៅក្នុងការផ្លាស់ទីលំនៅប្រជាជន ដែលត្រូវបានបង្ខិតបង្ខំតាមរយៈការគំរាមកំហែង អំពើហិង្សាលើរូបរាងកាយ ឬតាមរយៈការបញ្ជាដែលពួកគេមានអារម្មណ៍ថាអាចនឹងនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរប្រសិនបើមិនអនុវត្តតាម។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៤៥១. មិនមានភស្តុតាងដែលបង្ហាញថា ប្រជាជនមិនមានកម្មសិទ្ធិស្របច្បាប់ក្នុងការតាំងនៅទីលំនៅ នៅកន្លែងដែលពួកគេត្រូវបានជម្លៀសចេញនោះទេ។

១៤៥២. នៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរ មេធាវីរបស់ជនត្រូវចោទបានលើកឡើងអំពីយុត្តិកម្មនានា ដើម្បីជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ដែលពាក់ព័ន្ធទៅនឹងស្ថានភាពទូទៅនៅកម្ពុជានាសម័យកាលនោះ (តម្រូវការម្ហូបអាហារ និងថ្នាំពេទ្យ សន្តិសុខ ។ល។)[5275]។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មិនមានមូលហេតុណាមួយដែលត្រូវបានលើកឡើងដោយជនត្រូវចោទ និងក៏មិនមានមូលហេតុផ្សេង ទៀតដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់អន្តរជាតិ ដែលអាចផ្តល់យុត្តិកម្មដល់ការជម្លៀសប្រជាជននេះ ឡើយ។

**<u>អវត្តមាននៃមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ</u>**

**<u>សន្តិសុខរបស់ប្រជាជន</u>**

១៤៥៣. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី១ ការផ្លាស់ទីលំនៅរបស់ប្រជាជនទាំងមូលចេញពីទីក្រុងភ្នំពេញមិនអាចត្រូវបានផ្តល់ជាយុត្តិកម្មដោយបញ្ហាសន្តិសុខរបស់ប្រជាជន ក្នុងការឆ្លើយតបនឹងការ ភ័យខ្លាច ដែលចោទឡើងអំពីយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិកឡើយ។ នៅពេលវេលាច្បាស់លាស់ដែលកងទ័ពបក្សកុម្មុយនីស្តកម្ពុជាយកបញ្ហាទម្លាក់គ្រាប់នេះ ជាមូលហេតុនៃការជម្លៀសប្រជាជន ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងបានមកតាំងទីលំនៅរបស់ខ្លួននៅទីក្រុងភ្នំពេញ ដែលនេះបង្ហាញថា ពួកគេមិនមានការភ័យខ្លាចអំពីការទម្លាក់គ្រាប់បែកឡើយ។ លើសពីនេះទៀត យុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកប្រឆាំងនឹងកម្ពុជាបានបញ្ចប់ចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ មកម្ល៉េះ។

១៤៥៤. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ និងទី៣ យុត្តិកម្មបែបនេះមិនអាចទទួលយកបានឡើយ។ ជាក់ស្តែង សាក្សីមួយចំនួនបានអះអាងថា ការជម្លៀសដោយបង្ខំដំណាក់កាលទី៣ គឺជាលទ្ធផលនៃជម្លោះជាមួយប្រទេសវៀតណាមក៏ដោយ ក៏បញ្ហានេះគ្រាន់តែជាបញ្ហាបន្ទាប់បន្សំតែប៉ុណ្ណោះ៖ ភាពចាំបាច់នៃការធានាសន្តិសុខរបស់ប្រជាជនតែម្យ៉ាង មិនបានផ្តល់យុត្តិកម្មចំពោះការជម្លៀសនេះឡើយ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ភាពចាំបាច់ផ្នែកយោធា

១៤៥៥. មិនមានភស្តុតាងដែលបង្ហាញថា ការផ្លាស់ទីលំនៅប្រជាជនចេញពីភ្នំពេញមានការពាក់ព័ន្ធនឹងភាពចាំបាច់ផ្នែកយោធានោះទេ។ ទោះបីជាកងទ័ពបក្សកុម្មុយនីស្តកម្ពុជាដែលជម្លៀសប្រជាជនចេញពីទីក្រុង ពេលខ្លះបាននិយាយយោងទៅដល់ការប្រយុទ្ធជាមួយនឹងកងកម្លាំងលន់ នល់ ដែលនៅសេសសល់ក្នុងទីក្រុងក៏ដោយ ប៉ុន្តែមិនមានការប្រយុទ្ធជាទ្រង់ទ្រាយធំ ឬប្រតិបត្តិការផ្នែកយោធាបានកើតឡើងក្នុងទីក្រុងភ្នំពេញបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឡើយ។ ហេតុផលដូចគ្នានេះត្រូវយកមកអនុវត្តចំពោះតម្រូវការដែលត្រូវបានលើកឡើង ក្នុងការស្វែងរក និងចាប់ខ្លួនភ្នាក់ងារសេ.អ៊ី.អា ឬដើម្បីអនុវត្តកិច្ចខិតខំប្រឹងប្រែងបោសសម្អាតសារធាតុមិនទាន់ផ្ទុះ និងគ្រាប់មីន។

១៤៥៦. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ មិនមានសាក្សីណាបានលើកឡើងអំពីភាពចាំបាច់ផ្នែកយោធាថា ជាយុត្តិកម្មនៃការផ្លាស់ទីលំនៅប្រជាជនឡើយ ហើយយុត្តិកម្មនេះក៏មិនឃើញមាននៅក្នុងភស្តុតាងក្នុងសំណុំរឿងដែរ។

១៤៥៧. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី៣ ដូចបានរៀបរាប់ខាងលើ សាក្សីមួយចំនួនលើកឡើងអំពីការជម្លៀសប្រជាជនចេញពីទីតាំងប្រយុទ្ធគ្នាជាមួយនឹងប្រទេសវៀតណាម។ ទោះជាយ៉ាងណាក៏ដោយភាពតឹងតែងនៃជម្លោះនោះមិនមានលក្ខណៈគ្រប់គ្រាន់ ក្នុងការផ្ដល់យុត្តិកម្មចំពោះវិសាលភាព (ទំហំ) នៃការផ្លាស់ទីលំនៅប្រជាជននេះឡើយ។

កង្វះម្ហូបអាហារ

១៤៥៨. ទោះបីជាយុត្តិកម្មនេះត្រូវបានអនុញ្ញាតនៅក្នុងច្បាប់អន្តរជាតិក៏ដោយ មិនមានភស្តុតាងណាមួយដែលអាចបង្ហាញថាការផ្លាស់ទីលំនៅប្រជាជនមានភាពចាំបាច់ដើម្បីជៀសវាងបញ្ហាកង្វះម្ហូបអាហារឡើយ។

១៤៥៩. ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ទោះបីជាការផលិត ការចែកចាយ និងការផ្គត់ផ្គង់ចំណីអាហារត្រូវបានរាំងស្ទះដោយជម្លោះក៏ដោយ ក៏ការបញ្ជូនចំណីអាហារនៅតែអាចត្រូវបានធ្វើឡើងតាមរយៈផ្លូវទន្លេ ផ្លូវថ្នល់ ឬតាមផ្លូវអាកាសដែរ។ ម្យ៉ាងវិញទៀត ព្រឹត្តិការណ៍បន្តបន្ទាប់បានបង្ហាញថា កង្វះម្ហូបអាហារមិនមែនជាកង្វល់របស់អ្នកដែលរៀបចំការផ្លាស់ទីលំនៅ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១។

00605734



ប្រជាជនទេ៖ ជាទូទៅប្រជាជនក្រុងភ្នំពេញមិនត្រូវបានផ្តល់ម្ហូបអាហារក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅនោះទេ ហើយអាហារត្រូវបានគេចែកចាយដោយមានកំណត់ ឬគ្មានសោះតែម្តង នៅតាមទីកន្លែងដែលជាគោលដៅមកដល់ និងមានការតម្រូវឲ្យប្រជាជនរកចំណីអាហារដោយខ្លួនឯង ទោះបីជាពួកគេភាគច្រើនគឺជាអ្នកទីក្រុងដែលមិនស៊ាំទៅនឹងការងារកសិកម្មក៏ដោយ។ ទាក់ទិនទៅនឹងការអះអាង ដែលថារបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធជំនួយបរទេសដើម្បីចៀសវាងការជ្រៀតជ្រែកចូលក្នុងនយោបាយផ្ទៃក្នុងរបស់ខ្លួននោះ គួររំលឹកថា មិនមានយុត្តិកម្មតាមផ្លូវច្បាប់ណាមួយអាចត្រូវបានលើកឡើង នៅពេលដែលស្ថានភាពនោះកើតចេញពីកាលៈទេសៈដែលបង្កើតឡើងដោយខ្លួនឯងនោះទេ។

១៤៦០. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ និងទី៣ ទោះបីជាសាក្សីនានានិយាយថាចំណីអាហារ និងភាពសំបូរបែបនៃដីមានជីជាតិ គឺជាមូលហេតុមួយដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានលើកឡើងដើម្បីផ្លាស់ទីលំនៅប្រជាជនក៏ដោយ ប៉ុន្តែការប្រៀបធៀបស្ថានភាពនៅទីកន្លែងចាកចេញ និងទីកន្លែងទៅដល់មិនមានតម្រុយបញ្ជាក់ថា មានការគោរពនូវលក្ខខណ្ឌចាំបាច់សម្រាប់ការផ្លាស់ទីលំនៅប្រជាជននៅក្នុងបរិបទជាក់លាក់ទាំងនោះឡើយ។

<u>ការថែទាំផ្នែកវេជ្ជសាស្ត្រ</u>

១៤៦១. ទោះបីជាយុត្តិកម្មនេះត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិក៏ដោយ មិនមានភស្តុតាងដើម្បីគាំទ្រដល់ទ្រឹស្តីដែលថា ការផ្លាស់ទីលំនៅប្រជាជនត្រូវបានផ្តល់យុត្តិកម្មដោយកង្វះការថែទាំ ឬការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រឡើយ។ ទាក់ទងនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី១ ទោះបីជាការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រត្រូវបានកាត់បន្ថយក្នុងទីក្រុងភ្នំពេញ ក្នុងអំឡុងពេលមានជម្លោះក៏ដោយ ក៏ភស្តុតាងបញ្ជាក់ថា ទាំងរយៈពេលមុន និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញនៅតែជាទីកន្លែងដែលមានការបំពាក់ផ្នែកវេជ្ជសាស្ត្រប្រសើរជាងទីកន្លែងផ្សេងៗទៀតនៅក្នុងប្រទេសដែរ។

១៤៦២. ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ និងទី៣ មិនមានសាក្សីណាបានលើកឡើងអំពីភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រថា ជាយុត្តិកម្មមួយសម្រាប់ការផ្លាស់កន្លែងប្រជាជននោះទេ ហើយក៏មិនមានភស្តុតាងណាមួយអាចស៊ីសង្វាក់ទៅនឹងយុត្តិកម្មនេះដែរ។

<u>ការបង្កើតសង្គមជនបទ</u>



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៤៦៣.គោលនយោបាយដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការបង្កើតសង្គមមួយ ដែលផ្អែកលើផលិតកម្មកសិកម្មជនបទមិនបង្កើតបានជាមូលហេតុមួយនៅក្រោមច្បាប់អន្តរជាតិ ដែលអនុញ្ញាតឲ្យមានការផ្លាស់ទីលំនៅប្រជាជនឡើយ។

## ភស្តុតាងនៃ "ការត្រឡប់វិញ"

១៤៦៤.ពាក់ព័ន្ធទៅនឹងការទាមទារឲ្យមានការ "ត្រឡប់វិញ" របស់ជនរងគ្រោះ ទោះបីជាមានយុត្តិកម្មតាមផ្លូវ ច្បាប់សម្រាប់ដំណាក់កាលនានានៃការផ្លាស់ទីលំនៅ ដែលបានរៀបរាប់ខាងលើក៏ដោយ អង្គហេតុទាំងមូលបានគូសបញ្ជាក់ថា អ្នកដែលត្រូវបានផ្លាស់ទីលំនៅស្ទើរតែទាំងអស់អាចត្រឡប់ទៅផ្ទះរបស់ខ្លួនវិញបន្ទាប់ពីការដួលរលំនៃរបបនេះតែប៉ុណ្ណោះ។

១៤៦៥.ចំពោះធាតុអត្តនោម័ត ចារីនៃការជម្លៀសដោយបង្ខំទាំងបីដំណាក់កាល បានយល់ច្បាស់អំពីស្ថានភាពអង្គហេតុ ដែលបានបង្ហាញឲ្យឃើញពីភាពធ្ងន់ធ្ងរនៃអំពើ ដូចជាការឈឺចាប់ដែលកើតឡើងដោយអំពើហឹង្សា និងការគំរាមកំហែងនានា ការផ្លាស់ទីលំនៅដែលធ្វើឡើងក្នុងភាពប្រញាប់ប្រញាល់ កង្វះការចាត់ចែង និងការសម្របសម្រួល ដើម្បីធានាថា សមាជិកគ្រួសារមិនបែកគ្នា និងការណ៍ដែលថា ប្រជាជនមិនត្រូវបានផ្តល់ឲ្យជាទូទៅនូវចំណីអាហារ ទីជម្រក និងការគាំពារឡើយ។ ការឈឺចាប់នេះ បានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ និងពេលមកដល់។

១៤៦៦.ការជម្លៀសដោយបង្ខំលើប្រជាជនទាំងបីដំណាក់កាល ទោះជាតាមលក្ខណៈនៃអំពើ ឬតាមផលវិបាកនៃអំពើក៏ដោយ គឺជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល។ ចារីបានដឹងអំពីអត្ថិភាពនៃការវាយប្រហារនេះ ហើយថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនេះផងដែរ។

១៤៦៧.ផែនការរួមបានរួមបញ្ចូលការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបង្កឡើងដោយការជម្លៀសប្រជាជនដោយបង្ខំ។ ការអនុវត្តនូវផែនការរួមក្នុងការដាក់ឲ្យដំណើរការការដ្ឋាន និងសហករណ៍ ត្រូវបានសម្រួលដោយបក្សកុម្មុយនីស្តកម្ពុជាតាមរយៈការដាក់ប្រជាជននៅក្រោមអំណាចទាំងស្រុងដោយកំណត់ទីតាំងដាក់លាក់របស់ប្រជាជននៅក្បែរទីកន្លែងដែលប្រជាជនត្រូវបានបញ្ជូនឲ្យធ្វើការ។ ភស្តុតាងមួយចំនួនបង្ហាញថា ការជម្លៀសដោយបង្ខំកើតមានឡើងជាប្រព័ន្ធ និងបង្កើតបានជាផ្នែកមួយនៃផែនការរួម។ ចរិតលក្ខណៈទូទៅនៃការជម្លៀសដោយបង្ខំនៅតាមទីតាំងផ្សេងៗគ្នានៅទូទាំងប្រទេសបង្ហាញយ៉ាងច្បាស់ថា ការជម្លៀសដោយបង្ខំទាំងនេះត្រូវបានសម្រេច និងសម្របសម្រួលដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជា

00605736



ប្រជាធិបតេយ្យ។

១៤៦៨. វិធីសាស្ត្រប្រតិបត្តិការចម្បង រួមមានការមិនគិតគូរអំពីតម្រូវការរបស់ជនដែលងាយរងគ្រោះនៅក្នុងការជម្លៀសដោយបង្ខំក្នុងដំណាក់កាលនីមួយៗ៖ ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ រួមមានមនុស្សគ្រប់អាយុទាំងអស់ និងទាំងពីរភេទ។ អ្នកដែលត្រូវបានគេជម្លៀសត្រូវបានគេកំណត់អត្តសញ្ញាណថា ជាអ្នកដែលល្មើស ឬអាចនឹងល្មើសទៅនឹងគោលនយោបាយនៃផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងករណីនៃការជម្លៀសដោយបង្ខំដំណាក់កាលទី១ ប្រជាជនភ្នំពេញត្រូវបានផ្តល់អត្តសញ្ញាណថា ជាប្រជាជន "ប្រជាជនថ្មី" ហើយការណ៍ដែលថាប្រជាជនប្រភេទនេះបានរស់នៅទីក្រុង ត្រូវបានគេចាត់ទុកថា មិនត្រូវគ្នាទៅនឹងផែនការរួមក្នុងការកសាងលទ្ធិសង្គមនិយមមួយ តាមរយៈការអភិវឌ្ឍន៍វិស័យកសិកម្ម។ ប្រជាជនមកពីទីក្រុងក៏ត្រូវបានជាប់សង្ស័យថាអាចមានការពាក់ព័ន្ធជាមួយនឹងរបបលន់ នល់ផងដែរ។ ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ "ប្រជាជនថ្មី" ក៏ត្រូវបានកំណត់ជាមុខសញ្ញាផងដែរ ដូចគ្នានឹងប្រជាជនដែលពាក់ព័ន្ធនឹងរបបលន់ នល់ ខ្មែរក្រោម ជនជាតិចិន និងជនជាតិចាម ជាពិសេសជនជាតិចាមបន្ទាប់ពីការបះបោរនៅចុងឆ្នាំ១៩៧៥។ ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី៣ ការជម្លៀសនេះកំណត់មុខសញ្ញាយកប្រជាជននៅតាមតំបន់ដែលត្រូវបានបោសសម្អាត ហើយជនរងគ្រោះត្រូវបានគេចាត់ទុកថា ជាអ្នកមានភក្តីភាពទៅនឹងមន្ត្រីដែលត្រូវបានបោសសម្អាត ឬទៅនឹងវៀតណាម ដោយត្រូវបានសង្ស័យថាជាសមាសភាពអាក្រក់ ឬជនក្បត់ ជាអ្នកគាំទ្ររបបលន់ នល់ ជា"ប្រជាជនថ្មី" ព្រះសង្ឃ ចាម និងប្រជាជនជាប់ខ្សែស្រឡាយចិនឬវៀតណាម។ វិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជន ដែលត្រូវបានអនុវត្តនៅក្នុងក្របខណ្ឌនៃផែនការរួម ត្រូវបានបង្ហាញផងដែរដោយអង្គហេតុដែលថា នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនដែលត្រូវបានជម្លៀសមិនត្រូវបានឲ្យត្រឡប់ទៅលំនៅដ្ឋានដើមដែលពួកគេត្រូវបានជម្លៀសចេញពីដំបូងនោះទេ។

១៤៦៩. ការជម្លៀសទាំងបីដំណាក់កាលត្រូវបានអនុវត្តដោយកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា កងឈ្លបឬកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដោយមានការប្រើប្រាស់នូវការបង្ខំ។ ការជម្លៀសត្រូវបានអនុវត្តជាមួយនឹងការជូនដំណឹងក្នុងរយៈពេលដ៏ខ្លី ដោយមិនបានផ្តល់ពេលឲ្យអ្នកដែលត្រូវជម្លៀសទៅនោះមានការរៀបចំធ្វើដំណើរឲ្យបានសមរម្យឡើយ។ នៅអំឡុងពេលនៃការជម្លៀសដោយបង្ខំដំណាក់កាលទី១ ប្រជាជនត្រូវបានរំពឹងថាមានមធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន ប៉ុន្តែប្រជាជនភាគច្រើនបានធ្វើដំណើរដោយថ្មើរជើង។ នៅក្នុងការជម្លៀសដោយបង្ខំ ដំណាក់កាលទី២ និងទី៣ជាទូទៅ បក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ការដឹកជញ្ជូនឲ្យ ប៉ុន្តែគឺដើម្បីដាក់បម្រាមដើរហើរចំពោះអ្នក

ត្រូវបានជម្លៀសប៉ុណ្ណោះ ហើយអ្នកដែលត្រូវបានជម្លៀសមិនត្រូវបានផ្ដល់ឱ្យនូវការផ្គត់ផ្គង់ និង ការឧបត្ថម្ភគ្រប់គ្រាន់ ដែលបង្កឱ្យមានការរងការឈឺចាប់ និងស្លាប់ក្នុងចំណោមប្រជាជនទាំងនោះ។

## អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ

១៤៧០. មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបង្កឡើងតាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទំរង់នៃការបាត់ខ្លួនដោយបង្ខំ[5276]។ អង្គហេតុទាំងនេះពាក់ព័ន្ធជាចំបងទៅនឹងជនដែលបានបាត់ខ្លួននៅតាមមន្ទីរសន្តិសុខនានា ដែលរួមមានមន្ទីរសន្តិសុខកោះខ្សែង គោកក្ដួច ក្រាំងតាចាន់ ភូមិភាគឧត្ដរ ភ្នំក្រោល ព្រៃដំរីស្រុត សង់ និងវត្តគិរីរម្យ។ មានធាតុផ្សំគ្រប់គ្រាន់ផងដែរនៃការបាត់ខ្លួនដោយបង្ខំនៅតាមការដ្ឋានធ្វើការងារដោយបង្ខំ ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ស្រែអំបិល ទំនប់ត្រពាំងថ្ម និងសហករណ៍ត្រាំកក់។ ដូចគ្នាផងដែរ មានការបាត់ខ្លួនដោយបង្ខំ នៅក្នុងក្របខណ្ឌនៃការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងនៅក្នុងក្របខណ្ឌនៃការជម្លៀសដោយបង្ខំ (ដំណាក់កាលទី២ និងទី៣)។

១៤៧១. ចំពោះធាតុសត្យានុម័ត ជនរងគ្រោះបានទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរផ្នែកស្មារតី រឺ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដោយមូលហេតុ មួយចំណែកទាក់ទងនឹងការចាប់ខ្លួន ការឃុំខ្លួន ឬ ការចាប់ពង្រត់នូវសាច់ញាតិរបស់ពួកគេ ឬអ្នកដទៃ ក្នុងលក្ខខណ្ឌដែលពួកគេគ្មានការគាំពារផ្នែកច្បាប់ និងមួយចំណែកទៀត ទាក់ទងនឹងការបដិសេធក្នុងការប្រគល់ ឬ ក៏ផ្ដល់ឱ្យពួកគេនូវព័ត៌មានអំពីជោគវាសនាឬទីកន្លែងឃុំខ្លួនរបស់បុគ្គលទាំងនោះ។ ចារីបានប្រព្រឹត្តដោយមានការអនុញ្ញាត និង ការគាំទ្រអំពីរដ្ឋ ឬពី "*អង្គការ*"។

១៤៧២. វិធីសាស្ត្រប្រតិបត្តិការចំបងរួមមានជាការដាក់អោយអនុវត្តដោយអាជ្ញាធររបបកម្ពុជាប្រជាធិបតេយ្យ នូវវិធានការមួយដែលមានគោលបំណងលាក់បាំងអំពីជោគវាសនារបស់បុគ្គលដែលបាត់ខ្លួន ដោយធ្វើអោយប្រាកដថា មិនមានសាក្សីណាម្នាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងបុគ្គលនោះឡើយ ឧទាហរណ៍ ដូចជា ការចាប់ពង្រត់ជនរងគ្រោះនៅពេលយប់ដើម្បីកុំឱ្យអ្នកដទៃទៀតបានដឹងអំពីពេលវេលា ឬ អំពីរបៀបដែលជនរងគ្រោះបាត់ខ្លួន ឬ ដោយការប្រើប្រាស់នូវឧឃោសនសព្ទដើម្បីកុំអោយលឺសំលេង នៅពេលសម្លាប់មនុស្ស។

១៤៧៣. មិនមានសាក្សីណាម្នាក់អាចបង្ហាញ ថាមានប្រព័ន្ធនៃការចុះបញ្ជីណាមួយ ឬ ការតំកល់ទុកនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលបាត់ខ្លួនដែលអាចប្រើប្រាស់បានជាសាធារណៈ ឬការគោរពការគាំពារផ្នែកនីតិវិធីណាមួយផ្សេងទៀតនៅអំឡុងពេលនៃការចាប់ខ្លួន ការចាប់ពង្រត់ ឬ នៅអំឡុងពេលឃុំឃាំង បុគ្គលដែលបាត់ខ្លួននោះ ហើយសូម្បីតែគ្រួសាររបស់បុគ្គលដែលបាត់ខ្លួនក៏មិនបានដឹងអំពីអ្វីដែលនឹងកើតមានឡើងចំពោះពួកគេបន្ទាប់ពីនោះដែរ។

១៤៧៤.ក្រៅពីការបដិសេធមិនព្រមផ្តល់ព័ត៌មាន កម្មាភិបាលបានផ្តល់នូវហេតុផលផ្សេងៗដែលមានការបំភ័ន្តយ៉ាងច្បាស់ ដើម្បីផ្តល់យុត្តិកម្មអំពីអវត្តមានរបស់បុគ្គលដែលបាត់ខ្លួន ឧទាហរណ៍ដូចជាការពន្យល់ថាបុគ្គលទាំងនោះ “ត្រូវបានគេបញ្ជូនទៅជួបអង្គការ” “ត្រូវបានគេបញ្ជូនអោយទៅប្រជុំ” ឬ“បញ្ជូនអោយទៅក្រសួងការបរទេសដើម្បីធ្វើជាអ្នកការទូត” ឬត្រូវបានយក “ទៅរៀនសូត្រ” ឬ ទៅ “អប់រំកែប្រែ”។

១៤៧៥.ចំពោះធាតុអត្តនោម័ត ចារីបានយល់ច្បាស់អំពីស្ថានភាពអង្គហេតុដែលបង្ហាញឲ្យឃើញពីភាពធ្ងន់ធ្ងរនៃអំពើរបស់ពួកគេ ហើយមានភស្តុតាងដែលបង្ហាញផងដែរអំពីវិធានការណ៍ ដែលមានចេតនាគិតទុកជាមុនត្រូវបានអនុវត្ត ដើម្បីលាក់បាំងនូវជោគវាសនារបស់បុគ្គលបាត់ខ្លួនដែលភាគច្រើនទំនងជាត្រូវបានសម្លាប់ នាពេលបន្ទាប់។

១៤៧៦.ការប្រព្រឹត្តទាំងនេះបានឈានដល់កំរិតធ្ងន់ធ្ងរមួយដែលស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។ កម្មាភិបាលខ្មែរក្រហមបានគំរាមកំហែងដល់បុគ្គល ដែលបានធ្វើការសាកសួរ ឬបានដឹងនូវព័ត៌មាន រហូតទាល់តែពួកគេមានភាពភ័យខ្លាចខ្លាំងមិនហ៊ានសួរដេញដោល។ បរិបទនៃភាពមិនច្បាស់លាស់និង ការភ័យខ្លាចដែលបណ្តាលមកពីការបាត់ខ្លួនបានជួយសម្រួលដល់ការចាប់ខ្លួនផ្សេងៗទៀត។

១៤៧៧.ករណីបាត់ខ្លួនដោយបង្ខំទាំងនេះ តាមលក្ខណៈជាទូទៅ និង ជាប្រព័ន្ធនៃអំពើ គឺជាផ្នែកមួយនៃការវាយប្រហារលើប្រជាពលរដ្ឋស៊ីវិល ដែលចារីបានដឹងអំពីការវាយប្រហារនេះ។ លើសពីនេះទៅទៀត មានសាក្សីជាច្រើនបានរៀបរាប់អំពីករណីស្រដៀងគ្នានៃការបាត់ខ្លួនដោយបង្ខំនៅតាមទីកន្លែងផ្សេងៗ ដែល មិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបសួរ ដែលនេះជាការបញ្ជាក់នូវលក្ខណៈជាទូទៅនៃការបាត់ខ្លួន ដោយបង្ខំ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

១៤៧៨.ការបាត់ខ្លួនដោយបង្ខំបង្កើតបានជាផ្នែកមួយនៃមធ្យោបាយ ដែលបានប្រើប្រាស់ដើម្បីសម្រេចបាននូវផែនការរួមក្នុងការធ្វើការកម្ទេច "ខ្មាំង" ៖ លក្ខណៈជាប្រព័ន្ធនៃការបាត់ខ្លួនដោយបង្ខំ ព្រមទាំងការប្រព្រឹត្តអំពើទាំងនេះដែលមានលក្ខណៈជាទូទៅនៅទូទាំងប្រទេស ចង្អុលបង្ហាញអោយឃើញកាន់តែច្បាស់ថា ការបាត់ខ្លួនទាំងនេះត្រូវបានសម្រេច និងសម្របសម្រួល ដោយមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងក្របខ័ណ្ឌនៃផែនការរួម។

## ផ្នែកទី៥- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

១៤៧៩.មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខអូរកន្សែង និងនៅពេលកងទ័ពបដិវត្តន៍កម្ពុជាចូលលុកលុយក្នុងទឹកដីវៀតណាម។

### ក- ធាតុផ្សំដែលជា "ធាតុផ្សំរួម"

<u>អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ</u>

១៤៨០.ដូចបានបញ្ជាក់នៅក្នុងផ្នែកស្តីអំពី "ជំលោះប្រដាប់អាវុធ" ក្នុងអំឡុងពេលយ៉ាងហោចណាស់ចន្លោះពីខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ជម្លោះប្រដាប់អាវុធបានកើតមានឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយជម្លោះនេះមានលក្ខណៈជាអន្តរជាតិ[5277]។

<u>បុគ្គលដែលត្រូវទទួលបានការការពារ</u>

១៤៨១.សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ជនដែលស្ថិតនៅក្នុងប្រភេទនៃ "បុគ្គលដែលត្រូវទទួលបានការការពារ" នៅក្នុងអំឡុងជម្លោះអន្តរជាតិរវាងរដ្ឋទាំងពីរ មានដូចតទៅ៖

ក. សមាជិកកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ (កងទ័ពបដិវត្តន៍កម្ពុជា) ដែលត្រូវទទួលបានការការពារក្នុងឋានៈជាឈ្លើយសឹក តាមមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ទី៣។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ខ. ពលរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលស្ថិតនៅក្រោមកណ្ដាប់ដៃរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ (កងទ័ពបដិវត្តន៍កម្ពុជា) ដែលត្រូវទទួលបានការការពារក្នុងឋានៈជាជនស៊ីវិល តាមមាត្រា៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ទី៤។

១៤៨២.ម្យ៉ាងវិញទៀត ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនបានសម្រេចលើបញ្ហាដែលថា តើសញ្ញាណនៃ "ទំនាក់ទំនងភក្តីភាព"[5278] ស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនាសម័យកាលជម្លោះប្រដាប់អាវុធអន្តរជាតិដែរឬទេក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ចំពោះជនត្រូវចោទ សញ្ញាណនេះអាចយល់បាន និងអាចព្យាករណ៍បានក្នុងលក្ខណៈមិនគ្រប់គ្រាន់ឡើយ (ប្រសិនបើសញ្ញាណ នេះត្រូវបានទទួលស្គាល់) ដើម្បីគោរពទៅតាមគោលការណ៍ដែលថា *គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ ដំណោះស្រាយនេះត្រូវបានតម្រូវ ដោយហេតុថា សញ្ញាណនេះទើបតែត្រូវបានប្រកាសជាផ្លូវការនៅក្នុងយុត្តិសាស្ត្រនាចុងទសវត្សរ៍ឆ្នាំ១៩៩០ តែប៉ុណ្ណោះ និងនៅក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុងបន្ទាប់ពីការរំលាយរដ្ឋមួយដែលមានស្រាប់ពីមុនមក ក៏ដូចជាក្នុងក្របខ័ណ្ឌនៃការបង្កើតរដ្ឋថ្មីៗ និងមិនមែនក្នុងក្របខ័ណ្ឌនៃជម្លោះរវាងរដ្ឋ និងរដ្ឋ ដែលជាកម្មវត្ថុចម្បងនៃអនុសញ្ញាទីក្រុងហ្សឺណែវក្នុងពេលតាក់តែងអនុសញ្ញានោះទេ។

<u>ទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធអន្តរជាតិ និងឧក្រិដ្ឋកម្ម</u>

១៤៨៣. រាល់ឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានវិភាគនៅទីនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអរិភាពរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយអត្ថិភាពនៃជម្លោះប្រដាប់អាវុធបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដោយចារី[5279]។

១៤៨៤. នៅមន្ទីរសន្តិសុខស-២១ ជនរងគ្រោះទាំងអស់គឺជាឈ្លើយសឹកវៀតណាម ឬជាជនស៊ីវិលវៀតណាម ដែលត្រូវបានចាប់ខ្លួនដោយកងទ័ពបដិវត្តន៍កម្ពុជា នៅក្នុងអំឡុងពេលអរិភាពទាក់ទងនឹងជម្លោះ។ ជាទូទៅ អ្នកដែលក្លាយជាអ្នកទោសត្រូវបានបញ្ជូនពីសមរភូមិ ពីព្រំដែនវៀតណាមទៅកាន់មន្ទីរសន្តិសុខស-២១ ដើម្បីឲ្យបុគ្គលិកមន្ទីរស-២១ សួរចម្លើយអំពីព័ត៌មានយោធា ក៏ដូចជា (ប្រសិនបើជាជនស៊ីវិល) អំពីការណ៍ដែលត្រូវបានចោទថា ជាគិញវៀតណាម និងដើម្បីតម្រូវការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងអំឡុងជម្លោះទាំងមូល ឈ្លើយសឹក ឬជនស៊ីវិលវៀតណាមរាប់រយនាក់ ត្រូវបាននាំទៅមន្ទីរស-២១ ដើម្បីសួរចម្លើយ និងសម្លាប់ចោល។ ចំនួនច្រើន

00605741



បំផុតគឺនៅចន្លោះឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨ ក្នុងអំឡុងពេលវាយប្រយុទ្ធគ្នាដ៏ខ្លាំងក្លារវាងរដ្ឋទាំងពីរ។

១៤៨៥. ជនរងគ្រោះជាជនជាតិចារ៉ាយនៅមន្ទីរសន្តិសុខអូរកន្សែង គឺជាជនស៊ីវិលវៀតណាម ដែល ក្រោយពីមានការវាយប្រយុទ្ធគ្នារវាងរដ្ឋទាំងពីរ ត្រូវបាននាំពីទឹកដីវៀតណាមមកទឹកដីកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីនោះ ពួកគេត្រូវបានចាប់ខ្លួនដោយកងពលធំ៨០១ នៃកងកម្លាំងរបស់កងទ័ពបដិវត្តន៍កម្ពុជា និងបញ្ជូនមកអូរកន្សែង ហើយត្រូវសម្លាប់ចោល ដោយសារពួកគេមាន ជាប់ទាក់ទងជាមួយទាហានវៀតណាមនៅក្នុងជម្លោះរវាងរដ្ឋទាំងពីរ។

១៤៨៦. នៅពេលកងទ័ពបដិវត្តន៍កម្ពុជាចូលលុកលុយក្នុងទឹកដីវៀតណាម ជនស៊ីវិលត្រូវបានសម្លាប់ដោយកងទ័ពតាមការអនុវត្តបញ្ជា។ ការលុកលុយនេះធ្វើឡើងដោយកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការសម្រេចគោលបំណងយោធា សម្រាប់តម្រូវការនៃជម្លោះប្រដាប់អាវុធប្រឆាំងនឹងវៀតណាម។

<u>ការដឹងឮរបស់ចារី</u>

១៤៨៧. នៅគ្រប់ពេលទាំងអស់ ចារីនៃឧក្រិដ្ឋកម្មបានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ[5280] និងដឹងអំពីកាលៈទេសៈនៃអង្គហេតុដែលបង្ហាញឲ្យឃើញពីស្ថានភាពនៃការការពាររបស់ជនរងគ្រោះ[5281]។

១៤៨៨. នៅមន្ទីរសន្តិសុខស-២១ ជាទូទៅ អ្នកទោសវៀតណាមត្រូវបានចាប់ខ្លួននៅក្នុង ឬនៅជិតសមរភូមិតាមបណ្តោយព្រំដែនជាមួយវៀតណាម។ ពួកគេត្រូវបានដឹកពីកន្លែងចាប់ខ្លួនទៅកាន់មន្ទីរស-២១ ដើម្បីសួរចម្លើយអំពីព័ត៌មានយោធាពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងសម្រាប់តម្រូវការឃោសនាប្រឆាំងនឹងវៀតណាមដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ នៅក្នុងរបាយការណ៍របស់មន្ទីរស-២១ អ្នកទោសវៀតណាមត្រូវបានចាត់ចូលក្នុងប្រភេទជា "ទាហានវៀតណាម" ឬ "ជនស៊ីវិលវៀតណាម" ឬចាត់ទុកថា ជា "គិញវៀតណាម"។

១៤៨៩. នៅមន្ទីរសន្តិសុខអូរកន្សែង ជនរងគ្រោះត្រូវបានចាប់ខ្លួននៅព្រំដែនវៀតណាមដោយកងពលប្រយុទ្ធនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលចូលរួមក្នុងជម្លោះប្រដាប់អាវុធជាមួយកងកម្លាំងវៀតណាមនៅក្នុង

តំបន់នេះ។ ម្យ៉ាងវិញទៀត នៅពេលពួកចារ៉ាយត្រូវបានចាប់ខ្លួន ពួកគេបានប្រកាសប្រាប់កងកម្លាំងនៃកងទ័ពបដិវត្តន៍កម្ពុជាដោយខ្លួនឯងថា ពួកគេជាជនជាតិវៀតណាម និងជាជនស៊ីវិល។

១៤៩០. ជាចុងក្រោយ នៅពេលកងទ័ពបដិវត្តន៍កម្ពុជាចូលលុកលុយក្នុងទឹកដីវៀតណាម ចារីនៃការវាយប្រហារលើជនស៊ីវិលបានដឹងឮយ៉ាងច្បាស់ថា ពួកគេស្ថិតនៅលើទឹកដីនេះដើម្បីបំពេញប្រតិបត្តិការយោធាប្រឆាំងនឹងកងកម្លាំងវៀតណាម នៅក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ហើយថាជនស៊ីវិលដែលត្រូវបានសម្លាប់ក្នុងឋានៈជាពលរដ្ឋវៀតណាម គឺជាបុគ្គលដែលត្រូវទទួលបានការការពារ។

**ខ-បទល្មើសជាក់លាក់នីមួយៗនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ**

**អំពើមនុស្សឃាតដោយចេតនា**

**មន្ទីរសន្តិសុខ ស-២១**

១៤៩១. ឈ្លើយសឹក និងជនស៊ីវិលវៀតណាម ត្រូវបានសម្លាប់ដោយចេតនានៅមន្ទីរ ស-២១ ដោយបុគ្គលិកមន្ទីរសន្តិសុខ ដែលបានធ្វើការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដោយផ្ទាល់ និងជាប្រព័ន្ធទៅលើអ្នកជាប់ឃុំទាំងអស់[5282]។

១៤៩២. លើសពីនេះទៀត ការស្លាប់របស់ឈ្លើយសឹក និងជនស៊ីវិលវៀតណាមមួយចំនួន ជាប្រយោលបណ្តាលមកពីវិធីសាស្ត្រសួរចម្លើយដែលបានប្រើប្រាស់ និងលក្ខខណ្ឌទូទៅដែលអនុវត្តចំពោះអ្នកជាប់ឃុំ ដោយមានការយល់ដឹងសមហេតុផលថា បុគ្គលដែលត្រូវទទួលបានការការពារអាចនឹងស្លាប់បាន។

១៤៩៣. ចំពោះធាតុផ្សំអត្តនោម័ត អំពើមនុស្សឃាតទៅលើបុគ្គលដែលត្រូវទទួលបានការការពារត្រូវ បានប្រព្រឹត្តដោយបុគ្គលិកមន្ទីរស-២១ ដោយចេតនា ឬដោយការធ្វេសប្រហែស។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605743



<u>មន្ទីរសន្តិសុខអូរកន្សែង</u>

១៨៩៤. អ្នកជាប់ឃុំជាជនជាតិចារ៉ាយនៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានសម្លាប់ដោយចេតនា ដោយបុគ្គលិកមន្ទីរសន្តិសុខ និងបុគ្គលិកតំបន់ និងកងវរៈសេនាតូច៨០៣ ដែលបានធ្វើការសម្លាប់ក្រៅប្រព័ន្ធតុលាការដោយផ្ទាល់ និងជាប្រព័ន្ធទៅលើអ្នកជាប់ឃុំទាំងអស់ រួមទាំងស្ត្រី និងកុមារផងដែរ។

១៨៩៥. ចំពោះធាតុផ្សំអត្តនោម័ត អំពើមនុស្សឃាតទៅលើបុគ្គលដែលត្រូវទទួលបានការការពារទាំងនេះត្រូវបានប្រព្រឹត្តដោយចេតនា។

<u>ការលុកលុយរបស់កងទ័ពបដិវត្តន៍កម្ពុជាទៅក្នុងទឹកដីវៀតណាម</u>

១៨៩៦. ក្នុងអំឡុងពេលកងកម្លាំងនៃកម្ពុជាប្រជាធិបតេយ្យចូលលុកលុយទៅក្នុងទឹកដីវៀតណាម ជនស៊ីវិលវៀតណាមត្រូវបានកំណត់ជាគោលដៅនៃការសម្លាប់ដោយចេតនា ដោយទាហាននៃកងទ័ពបដិវត្តន៍កម្ពុជាដែលបានទទួលបញ្ជាច្បាស់លាស់អំពីបញ្ហានេះ។ ម្យ៉ាងវិញទៀត មានការបញ្ជាឲ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ដែលបានជួបប្រទះ ដោយមិនឲ្យជនណាម្នាក់រួចខ្លួនឡើយ សូម្បីតែអ្នកចុះចាញ់ក៏ដោយ។

១៨៩៧. ចំពោះធាតុផ្សំអត្តនោម័ត អំពើមនុស្សឃាតទៅលើបុគ្គលដែលត្រូវទទួលបានការការពារទាំងនេះត្រូវបានប្រព្រឹត្តដោយចេតនាដោយកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ។

**ការធ្វើទារុណកម្ម**

<u>មន្ទីរសន្តិសុខស-២១</u>

១៨៩៨. អ្នកជាប់ឃុំជនជាតិវៀតណាមនៅមន្ទីរស-២១ទាំងឈ្លើយសឹកនិងជនស៊ីវិលត្រូវបានធ្វើទារុណកម្ម[5283]។ វិធីសាស្ត្រសួរចម្លើយត្រូវបានអនុវត្តដោយបុគ្គលិកមន្ទីរស-២១ ដោយបង្កឲ្យមានការឈឺចាប់ដល់ផ្លូវកាយ ឬផ្លូវចិត្ត ឬការរងទុក្ខធ្ងន់ធ្ងរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

១៤៩៩. ការឈឺចាប់ ឬការរងទុក្ខទាំងនេះត្រូវបានធ្វើឡើង ក្នុងគោលបំណងជាក់លាក់ដើម្បីទទួលបានព័ត៌មានពីអ្នកទោស (ជាចម្បងពាក់ព័ន្ធនឹងព័ត៌មានយោធា) ឬចម្លើយសារភាព (ជាចម្បងក្នុងគោលដៅនៃការឃោសនាជាសាធារណៈ)។ បុគ្គលិកមន្ទីរស-២១ បានបំពេញមុខងារជាផ្លូវការស្របតាមគោលនយោបាយដែលត្រូវបានកំណត់យ៉ាងច្បាស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលមានបំណងទាញយកចម្លើយសារភាព។

១៥០០. ចំពោះធាតុផ្សំអត្តនោម័ត អំពើបង្កការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរ ក្នុងគោលបំណងដូចបានរៀបរាប់ខាងលើ ត្រូវបានប្រព្រឹត្តដោយបុគ្គលិកមន្ទីរស-២១ ដោយចេតនា។

**ការធ្វើបាបដោយអមនុស្សធម៌**

**<u>មន្ទីរសន្តិសុខស-២១</u>**

១៥០១. តាមរយៈលក្ខខណ្ឌដែលអនុវត្តចំពោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ បុគ្គលិកមន្ទីរស-២១ បានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ប្រឆាំងនឹងបុគ្គលដែលត្រូវទទួលបានការការពារ ដែលបានបង្កការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្ត ការងទុក្ខ ឬការរងរបួស ស្មើនឹងការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើតបានជាធាតុផ្សំនៃការធ្វើបាបដោយអមនុស្សធម៌[5284]។

១៥០២. លក្ខខណ្ឌទាំងនេះរួមបញ្ចូលទាំងលក្ខខណ្ឌទូទៅនៃការឃុំខ្លួនបុគ្គលដែលត្រូវទទួលបានការការពារ ជាអាទិ៍ លក្ខខណ្ឌដាក់មនុស្សហួសចំណុះ និងកង្វះការបំពាក់ឧបករណ៍អនាម័យសមស្រប កង្វះថ្នាំសង្កូវ ម្ហូបអាហារ ឬសម្លៀកបំពាក់ ដែលជាអំពើបង្កការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្ត ឬការរងរបួសធ្ងន់ធ្ងរ និងការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរជាមនុស្សរបស់បុគ្គលដែលត្រូវទទួលបានការការពារ។ លក្ខខណ្ឌអស់ទាំងនេះ ទោះជាក្នុងលក្ខណៈជាបុគ្គលក្តី ឬជាសមូហភាពក្តី បានបន្ទាបបន្ថោក ធ្វើឱ្យអាប់ឱនកិត្តិយស និងធ្វើឱ្យបាត់បង់ភាពជាមនុស្សដល់ជនជាប់ឃុំឃាំងដែលត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ។

១៥០៣. ចំពោះធាតុផ្សំអត្តនោម័ត អំពើធ្វើបាបដោយអមនុស្សធម៌ត្រូវបានប្រព្រឹត្តដោយបុគ្គលិកមន្ទីរ ស-២១ ដោយចេតនា ឬដោយការធ្វេសប្រហែស។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

00605745



## ការបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសស្នាមធ្ងន់ធ្ងរដល់រូបកាយ ឬ សុខភាព

**មន្ទីរសន្តិសុខ ស-២១**

១៥០៤. តាមរយៈលក្ខខណ្ឌនានាដែលបានអនុវត្តទៅលើជនជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ បុគ្គលិកនៃមន្ទីរនេះបានប្រព្រឹត្តមកលើជនដែលត្រូវទទួលបានការការពារ ដោយអំពើសកម្ម ឬអកម្ម ដែលបានបង្កជាការឈឺចាប់ខាងរាងកាយ ឬការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ ឬបានបង្កនូវរបួសស្នាមធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាពរបស់ជនទាំងនោះ[5285]។

១៥០៥. លក្ខខណ្ឌទាំងអស់នេះបានរួមបញ្ចូលទាំងលក្ខខណ្ឌទូទៅនៃការឃុំខ្លួនជនដែលទទួលបានការការពារ ដែលរួមមានការឃុំខ្លួនមនុស្សលើសចំណុះ និងការមិនមានបំពាក់ឧបករណ៍អនាម័យឲ្យបានត្រឹមត្រូវ និងការមិនបានផ្តល់នូវការព្យាបាលជំងឺ ម្ហូបអាហារ ឬសម្លៀកបំពាក់ ទាំងអស់នេះបានបង្កជាការឈឺចាប់ធ្ងន់ធ្ងរ ឬបានបង្កនូវរបួសស្នាមធ្ងន់ធ្ងរដល់បូរណភាពរាងកាយ ឬសុខភាព។ លក្ខខណ្ឌអស់ទាំងនេះ ទោះជាក្នុងលក្ខណៈជាបុគ្គលក្តី ឬជាសមូហភាពក្តី បានបន្ទាបបន្ថោក ធ្វើឲ្យអាប់ឱនកិត្តិយស និងធ្វើឲ្យបាត់បង់ភាពជាមនុស្សដល់ជនជាប់ឃុំឃាំងដែលត្រូវបានដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ។

១៥០៦. ទាក់ទងដល់ធាតុផ្សំអត្តនោម័ត អំពើដែលបង្កជាការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសស្នាមធ្ងន់ធ្ងរ ត្រូវបានប្រព្រឹត្តដោយចេតនា ឬដោយធ្វេសប្រហែស ពីសំណាក់បុគ្គលិកនៃមន្ទីរស-២១។

## ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងទៀងទាត់

**មន្ទីរសន្តិសុខ ស-២១**

១៥០៧. តាមរយៈនីតិវិធីនានាដែលអនុវត្តទៅលើជនជាប់ឃុំនៅមន្ទីរសន្តិសុខស-២១ បុគ្គលិករបស់មន្ទីរនេះបានដកហូតពីឈ្លើយសឹក និងជនស៊ីវិលវៀតណាម នូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការធានាផ្នែកតុលាការផ្សេងៗទៀត ជាពិសេសការធានាទាំងឡាយដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទី៣ និង៤ ឆ្នាំ១៩៤៩[5286]។

១៥០៨. ឈ្លើយសឹក និងជនស៊ីវិលវៀតណាមទាំងឡាយដែលត្រូវបានចាប់ខ្លួន ត្រូវបានគេប្រព្រឹត្តដូចគ្នាទៅនឹងជនជាប់ឃុំទាំងឡាយនៅមន្ទីរស-២១ ដែរ។ ពួកគេត្រូវបានធ្វើទារុណកម្មក្នុងពេលសួរចម្លើយ ត្រូវបានបង្ខិតឱ្យផ្តល់ចម្លើយសារភាព និងបន្ទាប់មកត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការ។ នៅគ្រប់ពេលទាំងអស់ ជនដែលត្រូវទទួលបានការការពារទាំងនោះមិនត្រូវបានកំណត់ជាផ្លូវការថា ជាប់ពិរុទ្ធភាពក្នុងបទល្មើសណាមួយទេ។ ជនទាំងនោះក៏ពុំត្រូវបានបញ្ជូនទៅជំនុំជម្រះនៅតុលាការ និងទាំងពុំដែលបានទទួលនូវការប្រកាសសាលក្រមដែលវិនិច្ឆ័យទៅលើអំពើរបស់ខ្លួនឡើយ។

១៥០៩. ជាពិសេស តាមរយៈនីតិវិធីទាំងឡាយដែលបានអនុវត្តមកលើខ្លួន ជនដែលទទួលបានការការពារទាំងនោះ ត្រូវបានគេដកហូតនូវ៖

- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការមួយឯករាជ្យ និងអនាគតិ។
- សិទ្ធិទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័សអំពីបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់។
- សិទ្ធិ និងមធ្យោបាយការពារខ្លួនតាមផ្លូវតុលាការ។
- ការការពារខ្លួនទល់នឹងការដាក់ទណ្ឌកម្មជាសមូហភាព
- សច្ចធារណ៍នៃនិរទោស
- សិទ្ធិធ្វើឧបាស្រ័យ និងសិទ្ធិមិនត្រូវទទួលបានការផ្តន្ទាទោសដោយគ្មានការប្រកាសសាលក្រមដោយតុលាការដែលមានសមត្ថកិច្ច។

១៥១០. ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ការដកហូតនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងទៀងទាត់ ត្រូវបានប្រព្រឹត្តដោយចេតនា ឬដោយធ្វេសប្រហែស ពីសំណាក់បុគ្គលិកនៃមន្ទីរស-២១។

__មន្ទីរសន្តិសុខ អូរកន្សែង__

១៥១១. តាមរយៈនីតិវិធីនានាដែលអនុវត្តទៅលើជនជាប់ឃុំចារ៉ាយដែលត្រូវបានចាប់ខ្លួន បុគ្គលិកនៃមន្ទីរសន្តិសុខអូរកន្សែង បានដកហូតពីជនស៊ីវិលទាំងនេះ នូវសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងត្រឹមត្រូវ និងការធានាផ្នែកតុលាការផ្សេងទៀត ជាពិសេសការធានាដែលមានចែងនៅក្នុងអនុសញ្ញាក្រុងហ្សឺណែវទី៤ ឆ្នាំ១៩៤៩។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605747



១៥១២.នៅគ្រប់ពេលទាំងអស់ ជនស៊ីវិលចាវ៉ាយទាំងនេះមិនត្រូវបានកំណត់ជាផ្លូវការថា ជាប់ពិរុទ្ធភាព ក្នុងបទល្មើសណាមួយទេ ហើយពុំត្រូវបានបញ្ជូនទៅជំនុំជម្រះនៅតុលាការណាមួយឡើយ ព្រមទាំងពុំបានទទួលនូវការប្រកាសសាលក្រមដែលវិនិច្ឆ័យទៅលើអំពើរបស់ខ្លួនដែរ។ នៅពេលដែលបុគ្គលិកមន្ទីរសន្តិសុខអូរកន្សែងបានទទួលការណែនាំពីគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជនដែលត្រូវទទួលបានការការពារទាំងនេះត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការ។

១៥១៣. ជាពិសេស តាមរយៈនីតិវិធីទាំងឡាយដែលបានអនុវត្តមកលើខ្លួន ជនដែលទទួលបានការការពារទាំងនោះត្រូវបានគេដកហូតនូវ៖

- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការមួយឯករាជ្យ និងអនាគតិ។
- សិទ្ធិទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័សអំពីបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់។
- សិទ្ធិ និងមធ្យោបាយការពារខ្លួនតាមផ្លូវតុលាការ។
- ការការពារខ្លួនទល់នឹងការដាក់ទណ្ឌកម្មជាសមូហភាព
- សច្ចធារណ៍នៃនិរទោស
- សិទ្ធិធ្វើឧបាស្រ័យ និងសិទ្ធិមិនត្រូវទទួលបានការផ្តន្ទាទោសដោយគ្មានការប្រកាសសាលក្រមដោយតុលាការដែលមានសមត្ថកិច្ច។

១៥១៤.ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ការដកហូតនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងទៀងទាត់ ត្រូវបានប្រព្រឹត្តដោយចេតនា ឬដោយធ្វេសប្រហែស ពីសំណាក់បុគ្គលិកនៃមន្ទីរសន្តិសុខ អូរកន្សែង។

**ការនិរទេសជនស៊ីវិលដោយខុសច្បាប់**

**<u>មន្ទីរសន្តិសុខ ស-២១</u>**

១៥១៥.ជនស៊ីវិលវៀតណាមជាច្រើននាក់ដែលចាប់បានដោយកងទ័ពបក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងពេលនៃការលុកលុយផ្នែកយោធាចូលក្នុងប្រទេសវៀតណាម ត្រូវបាននិរទេសដោយខុសច្បាប់[5287]ពីទឹកដីនៃប្រទេសនេះមកកាន់ទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីនោះពួកគេត្រូវបានឃុំឃាំងក្នុងមន្ទីរ សន្តិសុខ ស-២១ ដើម្បីទុកសួរចម្លើយ ហើយបន្ទាប់មកត្រូវបានសម្លាប់ចោល។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១៕

១៥១៦.មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ការនិរទេសជនស៊ីវិលដែលត្រូវទទួលបានការការពារទាំងនេះ មានហេតុផលដើម្បីរក្សាសន្តិសុខដល់ប្រជាជន ឬដោយសារមានហេតុផលខាងយោធាដាច់ខាតណាមួយឡើយ។ ផ្ទុយទៅវិញ ការនិរទេសនេះគឺបានធ្វើឡើងដោយអនុវត្តតាមគោលនយោបាយជាក់លាក់របស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទិនទៅនឹងការបញ្ជូនជនស៊ីវិលវៀតណាមទៅកាន់មន្ទីរ ស-២១។

១៥១៧.ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ការនិរទេសប្រជាជនជនស៊ីវិលដោយខុសច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយចេតនា។

**ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់**

**<u>មន្ទីរសន្តិសុខ ស-២១</u>**

១៥១៨.ជនស៊ីវិលវៀតណាមត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ ស-២១ ដែលមិនមានភស្តុតាងណាមួយអាចបញ្ជាក់ថា ការឃុំខ្លួននេះត្រូវបានធ្វើឡើងដោយមានហេតុផលសមស្រប ឬមានមូលដ្ឋានច្បាប់ត្រឹមត្រូវនោះឡើយ[5288]។ ម្យ៉ាងទៀត ការឃុំខ្លួនជនដែលត្រូវទទួលបានការការពារទាំងនេះ ត្រូវបានធ្វើដោយគ្មាននីតិវិធានការការពារតាមផ្លូវនីតិវិធី និងអង្គសេចក្តី ដែលជនទាំងនោះត្រូវមានសិទ្ធិទទួលបាន ដោយផ្អែកលើបទបញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវទី៤ ទេ។

១៥១៩.ទាក់ទងដល់ធាតុផ្សំអត្តនោម័ត ការឃុំខ្លួនដោយខុសច្បាប់នូវជនដែលត្រូវទទួលបានការការពារទាំងនេះ ត្រូវបានប្រព្រឹត្តដោយចេតនា ឬដោយធ្វេសប្រហែស ពីសំណាក់បុគ្គលិកនៃ មន្ទីរស-២១។

១៥២០.ជាទីបញ្ចប់ រាល់បទល្មើសជាក់លាក់ទាំងឡាយ ដូចបានរៀបរាប់ខាងលើ ដែលបានប្រព្រឹត្តនៅទីកន្លែងខាងលើ ត្រូវបានប្រព្រឹត្តដោយអនុវត្តតាមគោលនយោបាយដែលបានកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជា ដែលបានសម្រេច និងដែលបានសម្របសម្រួលដោយមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជានៅក្នុងក្របខណ្ឌនៃផែនការរួម។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

## ផ្នែកទី៦- ការកំណត់ប្រភេទនៃទម្រង់នៃការទទួលខុសត្រូវ

### ក- សហឧក្រិដ្ឋកម្មរួម

១៥២១.ដូចដែលបានបង្ហាញជូនក្នុងផ្នែកស្តីអំពីច្បាប់ដែលត្រូវអនុវត្តនៃដីកាដំណោះស្រាយនេះ នៅក្នុងនីតិអន្តរជាតិ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលជា "ការប្រព្រឹត្ត" ។ ធាតុផ្សំសត្យានុម័តនៃសហឧក្រិដ្ឋកម្មរួមសំដៅទៅលើអង្គហេតុដែលក្នុងនោះជនត្រូវចោទបានចូលរួម ឬរួមចំណែក ជាមួយនឹងបុគ្គលច្រើននាក់ ក្នុងការធ្វើឱ្យសម្រេចនូវផែនការរួមមួយ រួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ ធាតុផ្សំអត្តនោម័តនៃសហឧក្រិដ្ឋកម្មរួមទម្រង់បឋមសំដៅទៅលើចេតនារួមគ្នាក្នុងការចូលរួម ឬ រួមចំណែកដល់ការអនុវត្តផែនការរួម។

១៥២២.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមរយៈសហឧក្រិដ្ឋកម្មរួមមិនតម្រូវឱ្យមានជាចាំបាច់នូវការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដោយផ្ទាល់នោះទេ ប៉ុន្តែអាចធ្វើឡើងក្រោមទម្រង់នៃការជួយ ឬការចូលរួមចំណែកដល់ការធ្វើឱ្យសម្រេចនូវផែនការរួម ឬគោលនយោបាយខ្លះនៃផែនការរួមដែលរួមមានជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ។ ប្រសិនបើ ការរួមចំណែកដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនត្រូវបានចាត់ទុកថាជាធាតុផ្សំចាំបាច់ឬសំខាន់ក៏ដោយ ក៏យ៉ាងហោចណាស់គេត្រូវបង្ហាញឱ្យឃើញផងដែរថា ការរួមចំណែកនោះមានអត្ថន័យជាសំខាន់ដល់ឧក្រិដ្ឋកម្មដែលជនត្រូវចោទត្រូវទទួលខុសត្រូវ[5289]។

១៥២៣. ទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម អនុវត្តចំពោះផែនការមួយ ដែលសំដៅដល់ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព្រៃផ្សៃ និងអយុត្តិធម៌មួយ ដែលត្រូវបានរៀបចំ ដោយអាជ្ញាធរនានានៅទូទាំងប្រទេស នៅក្នុងកម្រិតមួយដែលគ្រប់ធាតុផ្សំចាំបាច់នានាត្រូវបានបំពេញស្របតាមលក្ខខណ្ឌវិនិច្ឆ័យទាំងឡាយដែលបានលើកឡើងនៅក្នុងផ្នែកស្តីពីសញ្ញាណនៃភស្តុតាងគ្រប់គ្រាន់នៃដីកាដំណោះស្រាយនេះ[5290]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605750



# ការទទួលខុសត្រូវព្រហ្មទណ្ឌក្រោមទម្រង់នៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម

១៥២៤.ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យគឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយម ឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[5291]។

១៥២៥.ដើម្បីសម្រេចបានផែនការរួមនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានកំណត់យកគោលនយោបាយ ៥ យ៉ាងដូចមានរៀបរាប់ខាងក្រោម ដែលការដាក់ឱ្យអនុវត្តនូវគោលនយោបាយទាំង៥ នេះដែលការអនុវត្តរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនេះ[5292] ៖

(១). ការផ្លាស់ទីលំនៅប្រជាជនជាច្រើនដង ពីទីប្រជុំជនទៅជនបទ និងពីជនបទមួយទៅជនបទមួយទៀត ៖

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(គ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និង ការជម្លៀសដោយបង្ខំ )

(២). ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋាននានា ៖

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឱ្យទៅជាទាសករ

(ឃ)ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)

**(៣). ការអប់រំកែប្រែ "*សមាសភាពមិនល្អ*" និង ការកម្ទេច "*ខ្មាំង*" ទាំងនៅក្នុង និង នៅក្រៅបក្ស៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឱ្យទៅជាទាសករ

(ឃ)ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

(ខ) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬ ឲ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព

(ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**(៤). ការចេញនូវវិធានការណ៍ចំពោះក្រុមមនុស្សជាក់លាក់ ជាពិសេសជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលមានជាអាទិ៍ មន្ត្រី ទាហាន និង គ្រួសាររបស់ពួកគេ) ៖**

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ ៖

(ក) ជនជាតិចាម

(ខ) ជនជាតិវៀតណាម

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការនិរទេស

(ឃ)ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ញ) អំពើអមនុស្សធម៌ផ្សេងៗទៀត ដោយការបាត់ខ្លួនដោយបង្ខំ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

**(៥). ការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍៖**

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន៖

(ក) ការរំលោភលើផ្លូវភេទ

(ខ) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

**១៥២៦.** បន្ទាប់ពីបានចូលកាន់អំណាចលើទឹកដីទូទាំងប្រទេសរួចហើយ ឧក្រិដ្ឋម្មទាំងនេះកាន់តែមានទំហំធំ និងមានភាពធ្ងន់ធ្ងរឡើង នៅពេលដែលមេដឹកនាំ ប.ក.ក បានខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីអោយបានសម្រេចបាននូវផែនការបដិវត្តន៍របស់ខ្លួន ដោយធ្វើការកែតម្រូវទៅលើអ្វីដែលខ្លួនសន្មតថាជាការខ្វះខាត។

**១៥២៧.** ទាក់ទងដល់គោលនយោបាយប្រឆាំងនឹងជនជាតិចាម និង ជនជាតិវៀតណាម ផែនការក្នុងការកម្ទេចក្រុមមនុស្សអស់ទាំងនេះបានកើតមានឡើងចាប់តាំងពីខែមេសា ឆ្នាំ ១៩៧៧ ចំពោះជនជាតិវៀតណាម និង ចាប់តាំងពីដើមឆ្នាំ ១៩៧៧ ចំពោះជនជាតិចាម។ បន្ទាប់ពីនោះមក សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីការណ៍ដែលថា ការធ្វើឱ្យបានសម្រេចនូវផែនការរួមត្រូវបានពន្លាតផងដែរដល់ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ទៅលើក្រុមមនុស្សដែលទទួលបានការការពារទាំងនេះ។ ការដែលថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមទទួលយកការបង្កើនមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមធ្យោបាយនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យបានសម្រេចនូវផែនការរួម មានន័យថា សមាជិកទាំងនោះមានចេតនាក្នុងការ ធ្វើឱ្យបានសម្រេចនូវផែនការនោះតាមរយៈអំពើប្រល័យពូជសាសន៍[5293]។

**១៥២៨.** សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ផែនការរួមនេះបានលេចចេញជារូបរាងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម្លេះ ហើយបានបន្តអត្ថិភាពរបស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល

យ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ គោលនយោបាយទាំង៥ ត្រូវបានដាក់ឱ្យអនុវត្ត នាមុនសម័យកាលដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែលនេះបង្ហាញថា ជនត្រូវចោទមានចេតនារួចទៅហើយតាំងតែពីមុនឆ្នាំ១៩៧៥ ក្នុងការធ្វើឱ្យសម្រេចនូវផែនការរួម និង បង្កើតនូវមាគ៌ាដឹកនាំមួយ ដែលចេតនានេះបានបន្តនៅក្នុងសម័យកាលដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.[5294]។

**១៩២៩.** សមាជិកនៃផែនការរួម រួមមានយ៉ាងហោចណាស់ សមាជិកនៃគណៈអចិន្ត្រៃយ៍ ដូចជា **នួន ជា** និង **អៀង សារី**, សមាជិកគណៈមជ្ឈិម ដូចជា **ខៀវ សំផន**, រដ្ឋមន្ត្រីនានា ដូចជា **អៀង ធីរិទ្ធ**, លេខាភូមិភាគ និង លេខាតំបន់ស្វយ័ត និង ថ្នាក់ដឹកនាំកងពលយោធារបស់មជ្ឈិម ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពីរចនាសម្ព័ន្ធរបស់បក្សកម្មុយនីស្តកម្ពុជា នៃដីកាដំណោះស្រាយនេះ។

**១៩៣០.** ការរួមចំណែករបស់ជនត្រូវចោទនៅក្នុងសហឧក្រិដ្ឋកម្មរួមមិនកម្រិតត្រឹមការបង្កើតបក្សកុម្មុយនីស្តកម្ពុជា រដ្ឋបាលគ្រប់គ្រងរបស់បក្ស និង រចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្ស ប៉ុណ្ណោះទេ ប៉ុន្តែ ដូចដែលបានរៀបរាប់ខាងក្រោម ជនត្រូវចោទបានរួមចំណែកយ៉ាងសកម្មដល់ការពង្រីកផែនការរួម តាមមធ្យោបាយផ្សេងៗជាច្រើន ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[5295]។

**១៩៣១.** ទាក់ទិនទៅនឹងការចូលរួម និង ការរួមចំណែក របស់ជនត្រូវចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម និង ចេតនារបស់ជនត្រូវចោទនៅក្នុងការបន្តសម្រេចឱ្យបាននូវផែនការរួម សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទាក់ទិនទៅនឹង ៖

**នួន ជា**

**១៩៣២.** មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "តួនាទីរបស់ជនត្រូវចោទ" និង "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" បានបង្ហាញថា **នួន ជា** គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **នួន ជា** បានចូលរួម ឬរួមចំណែក ក្នុងការបង្កើត ការដាក់ឱ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួម ដែលរួមមាន ជាការប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **នួន ជា** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជា អនុលេខាបក្ស សមាជិកគណៈកម្មាធិការយោធានៃគណៈមជ្ឈិម និងសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលជាស្ថាប័ន

មានសិទ្ធិចេញសេចក្ដីសម្រេចខ្ពស់បំផុតរបស់ប្រទេស និងនៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹងពីមជ្ឈិមទៅកាន់ថ្នាក់មូលដ្ឋាន ដែលបានដាក់ឱ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្ស ដែលនៅក្នុងកិច្ចប្រជុំនោះ មានការសម្រេចអំពីមាគ៌ានយោបាយ និងបានចូលរួមនៅក្នុងការតាក់តែងឯកសារផ្លូវការនានា។ ក្នុងការធានាការគ្រប់គ្រងមន្ទីរស-២១ និងសន្តិសុខផ្ទៃក្នុងនៅក្នុងប្រទេស នួន ជា មានការទទួលខុសត្រូវជាចំបងនៅក្នុងការដាក់ឱ្យអនុវត្តមាគ៌ានយោបាយ ដោយការផ្ដល់ការណែនាំ និងការទទួលសេចក្ដីរាយការណ៍ពីថ្នាក់ក្រោមរបស់គាត់។ នួន ជា បានពន្យល់ បានគាំទ្រ និងបានជំរុញជាសាធារណៈ ដល់គោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងការឃោសនារបស់ ប.ក.ក តាមរយៈសុន្ទរកថាដែលគាត់បានធ្វើ តាមរយៈការដឹកនាំវគ្គសិក្សានយោបាយធំៗ នានា និងតាមរយៈការចុះទៅពិនិត្យដោយផ្ទាល់តាមបណ្ដាខេត្តនានា។

១៥៣៣. ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឱ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋកម្មរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ នួន ជា អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាព សកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។

**អៀង សារី**

១៥៣៤.មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្ដីអំពី "តួនាទីរបស់ជនត្រូវចោទ" និង "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" បានបង្ហាញថា **អៀង សារី** គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **អៀង សារី** បានចូលរួម ឬ រួមចំណែក ក្នុងការបង្កើតការដាក់ឱ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួម ដែលរួមមាន ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **អៀង សារី** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជា ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលជាស្ថាប័នមានសិទ្ធិចេញសេចក្ដីសម្រេចខ្ពស់បំផុតរបស់ប្រទេស និងនៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹងពីមជ្ឈិមទៅកាន់ថ្នាក់មូលដ្ឋាន ដែលបានដាក់ឱ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ **អៀង សារី** បានចូលរួមនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្ស ដែលនៅក្នុងកិច្ចប្រជុំនោះ មាគ៌ានយោបាយត្រូវបានសម្រេច និងផ្សព្វផ្សាយ។ **អៀង សារី** បានចូលរួមនៅក្នុងការសម្រេចអំពីបញ្ហាសន្តិសុខផ្ទៃក្នុង បានបញ្ជូន

00605756



សេចក្តីណែនាំទៅកាន់ថ្នាក់ក្រោមរបស់គាត់ និងបានទទួលសេចក្តីរាយការណ៍ពីថ្នាក់ក្រោមរបស់គាត់មកវិញ។ **អៀង សារី** បានគាំទ្រជាសាធារណៈ ដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងសុន្ទរកថា ឬកិច្ចសម្ភាសន៍នានា ហើយបានចុះទៅពិនិត្យដោយផ្ទាល់តាមបណ្តាខេត្តនានា។ ក្នុងនាមជាឧបនាយករដ្ឋមន្ត្រី **អៀង សារី** ទទួលបន្ទុកផងដែរនៅក្រសួងការបរទេស ស្ថានទូតទាំងអស់នៅបរទេស និងទទួលបន្ទុកការផ្សព្វផ្សាយគោលនយោបាយរបស់ ប.ក.ក។ នៅក្នុងក្របខណ្ឌនៃមុខងាររបស់គាត់ គាត់ផ្តល់យោបល់ដល់គណៈអចិន្ត្រៃយ៍អំពីកិច្ចការបរទេស បានពន្យល់ និងបានគាំទ្រគោលនយោបាយរបស់ ប.ក.ក នៅក្នុងពេលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនានា និងដំណើរទស្សនកិច្ចទៅបរទេស ដូចជាទៅអង្គការសហប្រជាជាតិជាដើម។ គាត់គ្រប់គ្រងបញ្ហាសន្តិសុខផ្ទៃក្នុង និងដឹកនាំវគ្គបំពាក់បំប៉នយោបាយនៅក្នុងក្រសួងរបស់គាត់ ហើយគាត់បានហៅបញ្ញវ័ន្ត និងមន្ត្រីឲ្យមកកម្ពុជាវិញ និងបានគ្រប់គ្រងមន្ទីរអប់រំរៀនសូត្រមួយចំនួននៅភ្នំពេញ។

**១៩៣៥.**ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឲ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ **អៀង សារី** អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាពសកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។

**ខៀវ សំផន**

**១៩៣៦.**មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "តួនាទីរបស់ជនត្រូវចោទ" និង "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" បានបង្ហាញថា **ខៀវ សំផន** គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **ខៀវ សំផន** បានចូលរួម ឬ រួមចំណែក ក្នុងការបង្កើតការដាក់ឲ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួម ដែលរួមមាន ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **ខៀវ សំផន** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជាសមាជិកនៃគណៈមជ្ឈិម និងការចូលរួមជាទៀងទាត់របស់គាត់នៅក្នុងការងាររបស់គណៈអចិន្ត្រៃយ៍ ដែលជាស្ថាប័នមានសិទ្ធិចេញសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រទេស និងនៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹងពីមជ្ឈិមទៅកាន់ថ្នាក់មូលដ្ឋាន ដែលបានដាក់ឲ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ **ខៀវ សំផន** បានចូលរួមនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់បំផុតរបស់បក្ស ដែលនៅក្នុងកិច្ចប្រជុំនោះ មាន

ការសម្រេច និងផ្សព្វផ្សាយអំពីមាគ៌ានយោបាយ និងបានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយកម្មាភិបាលភូមិភាគ តំបន់ និងស្រុក។ គាត់បានធ្វើការនៅក្នុងមន្ទីរនយោបាយ៨៧០ ដែលក្នុងនោះការដែលដាក់ឲ្យអនុវត្តផែនការរួមត្រូវបានត្រួតពិនិត្យ ហើយគាត់ក៏បានចុះទៅពិនិត្យដោយផ្ទាល់ទៅតាមខេត្តនានាផងដែរ។ **ខៀវ សំផន** បានគាំទ្រ និងផ្សព្វផ្សាយផែនការរួម នៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈសុន្ទរកថា និងកម្មវិធីផ្សាយវិទ្យុរបស់គាត់ តាមរយៈបទបង្ហាញដែលគាត់បានធ្វើនៅក្នុងកិច្ចប្រជុំសំខាន់ៗរបស់បក្ស និងនៅក្នុងវគ្គសិក្សា និងបំពាក់បំប៉ននយោបាយនានា និង ដំណើរទស្សនៈកិច្ចរបស់គាត់ទៅបរទេសក្នុងនាមជាសមាជិកគណៈប្រតិភូរបស់ ប.ក.ក។

**១៥៣៧.** ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឲ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋកម្មរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ **ខៀវ សំផន** អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាពសកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។

**អៀង ធីរិទ្ធ**

**១៥៣៨.**មានភស្តុតាងដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីអំពី "តួនាទីរបស់ជនត្រូវចោទ" និង "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" បានបង្ហាញថា **អៀង ធីរិទ្ធ**គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ **អៀង ធីរិទ្ធ** បានចូលរួម ឬ រួមចំណែក ក្នុងការបង្កើតការដាក់ឲ្យដំណើរការ និងបានត្រួតពិនិត្យការអនុវត្តផែនការរួមដែលរួមមាន ជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមុន និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **អៀង ធីរិទ្ធ** បានអនុវត្តនូវអំណាចក្នុងតួនាទីរបស់ខ្លួនជារដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច នៅក្នុងការគោរពខ្សែសង្វាក់នៃការបញ្ជាដ៏តឹងរឹង ពីមជ្ឈិមទៅថ្នាក់មូលដ្ឋាន ដែលបានដាក់ឲ្យអនុវត្តដោយបក្ស។ នៅក្នុងតួនាទីទាំងនេះ **អៀង ធីរិទ្ធ** បានចូលរួមនៅក្នុងកិច្ចប្រជុំនានារបស់គណៈមជ្ឈិម កិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី កិច្ចប្រជុំនៅក-១ និងក-៣ និងការជួបជុំធំៗរបស់បក្ស ដែលក្នុងនោះ មានការបង្កើត និងផ្សព្វផ្សាយ គោលនយោបាយរបស់បក្ស។ **អៀង ធីរិទ្ធ** ទទួលបន្ទុកការផ្សព្វផ្សាយ និងការដាក់ឲ្យអនុវត្តនូវគោលនយោបាយទាំងនេះ ជាពិសេស នៅក្នុងក្រសួងរបស់គាត់។ គាត់បានគាំទ្រ និងពន្យល់អំពីគោលនយោបាយទាំងនេះជា សាធារណៈ នៅក្នុងសុន្ទរកថា និងកិច្ចសម្ភាសន៍នានារបស់គាត់ នៅក្នុងវគ្គបំពាក់បំប៉ននយោបាយ ដែលគាត់បានធ្វើនៅទីក្រុងភ្នំពេញ ឬនៅក្នុងក្របខណ្ឌនៃដំណើរចុះទៅពិនិត្យនៅតាមខេត្តនានា។ គាត់បានដាក់ឲ្យដំណើរការនូវគោលនយោបាយទាំងនេះនៅទូទាំងប្រទេសក្នុងវិស័យសុខាភិបាល និងសង្គមកិច្ច

និងនៅក្នុងក្រសួងរបស់គាត់ក្នុងវិស័យសន្តិសុខ។

១៩៣៩.ដូចដែលបានរៀបរាប់ខាងលើ ការដាក់ឱ្យអនុវត្តផែនការរួមនៃសហឧក្រិដ្ឋកម្មរួម រួមមានជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ចេតនាឧក្រិដ្ឋរបស់ **អៀង ធីរិទ្ធ** អាចទាញសន្និដ្ឋានចេញពីសំដី ពីសកម្មភាពសកម្ម ឬពីសកម្មភាពអកម្ម របស់គាត់។

**សេចក្តីសន្និដ្ឋានអំពី "សហឧក្រិដ្ឋកម្មរួម"**

១៩៤០. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង ជនត្រូវចោទ នួន ជា **អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនេះ ក្នុងឋានៈរបស់ខ្លួន ជាសមាជិកសហឧក្រិដ្ឋកម្មរួម និងដោយការចូលរួមចំណែករបស់ខ្លួននៅក្នុងផែនរួម ដូចដែលបានរៀបរាប់នៅខាងលើ។ ម៉្យាងវិញទៀត ជនត្រូវចោទមិនត្រឹមតែរួមចំណែកជាមួយនឹងសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម ក្នុងចេតនា ដែលថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅក្នុងក្របខណ្ឌនៃការសម្រេចឱ្យបាននូវផែនការរួមប៉ុណ្ណោះទេ ប៉ុន្តែ ជនត្រូវចោទក៏ជាមនុស្សដ៏សំខាន់ ដើម្បីឱ្យផែនការរួមដំណើរការផងដែរ។[5296]

១៩៤១.ដោយយោងទៅលើអង្គហេតុនានានៃរឿងក្តីនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទម្រង់ជាប្រព័ន្ធ (ទម្រង់ទីពីរ) នៃសហឧក្រិដ្ឋកម្មរួម មិនត្រូវបានទទួលយកឡើយ ហើយសហឧក្រិដ្ឋកម្មរួមទម្រង់បឋម (ទម្រង់ទីមួយ) អាចកំណត់យ៉ាងពេញលេញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ។

១៩៤២.ដោយបន្ថែម ឬ ដោយឆ្លាស់គ្នា ទម្រង់មួយ ឬទម្រង់ច្រើនទៀតនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានរៀបរាប់នៅក្រោមនេះអនុវត្តចំពោះអង្គហេតុនៃរឿងក្តីនេះផងដែរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

## ខ- ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ

១៥៤៣.សម្រាប់បទឧក្រិដ្ឋនីមួយៗដែលបានពិនិត្យខាងក្រោមនេះ សហចៅក្រមស៊ើបអង្កេតនឹងវិភាគលម្អិតទៅលើប្រភេទនៃការរួមចំណែករបស់ជនត្រូវចោទទាំងបួន និងចេតនារបស់ជនត្រូវចោទទាំងនេះចំពោះទម្រង់នៃការទទួលខុសត្រូវដែលរួមមាន ការរៀបចំផែនការ, ការញុះញង់ឲ្យមានការប្រព្រឹត្ត, ការសមគំនិតដោយការជួយ និង ជម្រុញ, ការបញ្ជា, ការទទួលខុសត្រូវរបស់ថ្នាក់លើ។

### ការរៀបចំផែនការ

១៥៤៤.នឹងត្រូវបានចាត់ទុកថា មានការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ការរៀបចំផែនការ នៅពេលដែលបុគ្គល ម្នាក់ ឬច្រើននាក់បានគូសវាសនូវផែនការសកម្មភាពឧក្រិដ្ឋ ដែលបង្កជាឧក្រិដ្ឋកម្មមួយ ឬច្រើន។ សកម្មភាពនេះត្រូវតែជាមូលហេតុដែលនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ហើយជននោះត្រូវតែបានប្រព្រឹត្តដោយចេតនា ឬយល់ច្បាស់ អំពីលទ្ធភាពពិតប្រាកដ ដែលថាឧក្រិដ្ឋកម្ម អាចត្រូវបាន ប្រព្រឹត្តនៅក្នុងអំឡុងនៃការប្រតិបត្តិ ឬការដាក់ឲ្យប្រតិបត្តិនូវផែនការនេះ[5297]។

១៥៤៥.ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី និងខៀវ សំផន** ថា បានរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត ៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ដ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ឋ). អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។

**១៥៤៦.** ចំពោះ អៀង ធីរិទ្ធ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំង

នឹងជនត្រូវចោទនេះថា បានរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត ៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក). ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្ដីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។

## ការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម

១៥៤៧.នឹងត្រូវបានចាត់ទុកថាមានការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម នៅពេលដែលបុគ្គលម្នាក់បានជម្រុញ ទោះជាតាមរយៈអំពើសកម្មក្ដី ឬអកម្មក្ដី ដល់បុគ្គលម្នាក់ទៀតឲ្យប្រព្រឹត្ត ឧក្រិដ្ឋកម្មមួយ ឬច្រើនទៀត។ អំពើសកម្ម ឬអកម្មទាំងនេះត្រូវតែជាមូលហេតុនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ហើយបុគ្គលនោះត្រូវតែមានចេតនា ឬការយល់ច្បាស់អំពីលទ្ធភាពពិតប្រាកដដែលថា ឧក្រិដ្ឋកម្មអាចត្រូវបានប្រព្រឹត្តនៅពេលដែលមានការដាក់ឲ្យអនុវត្ត ដែលកើតចេញពីការញុះញង់ណាមួយនោះ[5298]។

១៥៤៨.ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្ដីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង**ខៀវ សំផន** ថា បានញុះញង់អ្នកដទៃទៀតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ខាងក្រោមនេះ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត ៖** បទល្មើសដែលមានចែងនិងផ្ដន្ទាទោសដោយមាត្រា៤ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្ដន្ទាទោស ដោយមាត្រា៦ មាត្រា ២៩ (ថ្មី) និងមាត្រា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឱ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ដ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ឋ). អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។

**១៥៤៥.** ចំពោះ **អៀង ធីរិទ្ធ** ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី

"ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទនេះថា បានញុះញង់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមាន ប្រល័យពូជសាសន៍លើ៖

(ក). ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជា ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។

**ការជួយ និងជម្រុញ**

១៥៥០. នឹងអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ការជួយ និងជម្រុញដល់ការប្រព្រឹត្តបទល្មើស នៅពេលដែលបុគ្គលម្នាក់បានផ្តល់នូវជំនួយខាងសម្ភារៈ ឬការគាំទ្រខាងផ្លូវចិត្ត ទោះជាតាមរយៈអំពើសកម្មក្តី ឬអកម្មក្តី ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយមានចេតនា ឬមានការយល់ច្បាស់ អំពីលទ្ធភាពពិតប្រាកដដែលថាឧក្រិដ្ឋកម្មនេះអាចត្រូវបានប្រព្រឹត្ត។ អំពើសកម្ម ឬអកម្មទាំងនេះត្រូវតែមានឥទ្ធិពលជាសំខាន់ទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្មពីសំណាក់ចារី នៅមុនពេល ក្នុងពេល និងក្រោយពេលការប្រព្រឹត្តិបទល្មើស[5299]។

១៥៥១. ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី និងខៀវ សំផន** ថា បានសមគំនិតតាមរយៈការជួយ និងជម្រុញ ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ខាងក្រោមនេះ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** ៖ បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែងនឹងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ដ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ឋ). អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605767



១៥៥២.ចំពោះ **អៀង ធីរិទ្ធ** ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី “ជនត្រូវចោទ” នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទនេះ ថាបានសមគំនិតតាមរយៈការជួយ និងជម្រុញដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដូចតទៅ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត ៖** បទល្មើសដែលមានចែងនឹងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក). ជនជាតិវៀតណាម

**អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែងនិងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្ដីថ្លៃថ្នូរជា មនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។

**ការបញ្ជា**

**១៥៥៣.** នឹងអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបញ្ជា នៅពេលណាបុគ្គលម្នាក់ស្ថិតក្នុងឋានៈជាមេកើយ បានចេញ ឬបញ្ជូនដោយជាក់ច្បាស់ ឬដោយតណ្ហីភាព នូវបញ្ជាឲ្យមានការប្រព្រឹត្តបទល្មើស ដោយមានចេតនា ឬមានការយល់ច្បាស់អំពីលទ្ធភាពពិតប្រាកដដែលថា ឧក្រិដ្ឋកម្មអាចត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការអនុវត្តបញ្ជាដែលបានចេញ។ បញ្ជានេះត្រូវតែជាមូលហេតុដែលនាំឲ្យមានការ ប្រព្រឹត្តឧក្រិដ្ឋកម្ម[5300]។

**១៥៥៤.** ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្ដីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី និងខៀវ សំផន** ថា បានចេញបញ្ជាដល់អ្នកក្រោមបង្គាប់របស់ខ្លួន (កងទ័ពបដិវត្តកម្ពុជា សមាជិកគណៈភូមិភាគ គណៈតំបន់ និង គណៈស្រុក កងឈ្លប និង កម្មាភិបាលមូលដ្ឋាន បុគ្គលិកនៃមន្ទីរសន្តិសុខ ប្រធានកង ឬ អ្នកគ្រប់គ្រងការដ្ឋាន និង សហករណ៍) ដែលទង្វើនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចមានរៀបរាប់ខាងក្រោមនេះ ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** ៖ បទល្មើសដែលមានចែង និងផ្ដន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក រួមមាន ប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

00605769



(ខ) ៖ ជនជាតិវៀតណាម

**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ដ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ថ). អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។

១៥៥៥. ចំពោះ **អៀង ធីរិទ្ធ** ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទនេះថា បានចេញបញ្ជា(ជាពិសេសក្នុងវិស័យសុខាភិបាល) ដល់អ្នកក្រោមបង្គាប់របស់ខ្លួននៅក្នុងក្រសួងសង្គមកិច្ច ដែលទង្វើនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចមានរៀបរាប់ខាងក្រោមនេះ៖

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សនិង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ខ). ការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(គ).ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍លើជនជាតិវៀតណាម

១៥៥៦. ផ្ទុយទៅវិញ ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានលើកឡើងនៅក្នុងផ្នែក "ជនត្រូវចោទ" "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" និង"ការកំណត់ប្រភេទបទល្មើស" នៃដីកាដំណោះស្រាយនេះ និងដោយផ្អែកលើកិច្ចស៊ើបសួរស្តីពីស្ថានភាពនៃអង្គហេតុ ដែលបានប្តឹងមកសហចៅក្រមស៊ើបអង្កេត មិនមានមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង **អៀង ធីរិទ្ធ** ថាបានចេញបញ្ជា (ជាពិសេសក្នុងវិស័យសុខាភិបាល) ទៅកាន់ចារីនៃឧក្រិដ្ឋកម្មដូចខាងក្រោមនេះ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** បទល្មើសដែលបានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក. ជាអាទិ៍អំពើប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១ ។

**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឱ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ញ). អំពើអមនុស្សធម៌ផ្សេងៗទៀតនៃការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ

## ការទទួលខុសត្រូវរបស់ថ្នាក់លើ

**១៥៩៧.** ការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលជាលទ្ធផលនៃការខកខានករណីកិច្ចក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬក្នុងការដាក់ទោសចារីដែលបានប្រព្រឹត្ត

ឧក្រិដ្ឋកម្ម។ ជាផលវិបាក ជនត្រូវចោទមិនអាចត្រូវបានបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ (ដោយប្រយោល) នេះ ផង និងដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវដោយផ្ទាល់ផងនោះឡើយ (ដែលរួមមាន ប្រព្រឹត្ត, រៀបចំផែនការ, ញុះញង់, ជួយ និងជម្រុញ, បញ្ជា)[5301]។

១៥៩៨. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ថ្នាក់លើអនុវត្តទៅលើថ្នាក់លើទាំងផ្នែកយោធា ទាំងផ្នែកស៊ីវិល ហើយការលើកឡើងអំពីឋានានុក្រមជាផ្លូវការពុំចាំបាច់ឡើយ ក្នុងការចាត់ទុកបុគ្គលណាម្នាក់ថាជាអ្នក ទទួលខុសត្រូវក្នុងឋានៈជាថ្នាក់លើនោះ[5302]។ម្យ៉ាងទៀត សម្រាប់បទល្មើសតែមួយដូចគ្នាអាចមាន ថ្នាក់លើច្រើននាក់ (ដែលមានឋានៈខុសៗគ្នា) ដែលត្រូវទទួលខុសត្រូវចំពោះការដែលមិនបាន បំពេញកាតព្វកិច្ចក្នុងការទប់ស្កាត់ ឬដាក់ទោសការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ថ្នាក់ក្រោមខ្លួន នៅពេលណាដែលលក្ខខណ្ឌនៃ "អំណាចជាក់ស្តែង" ត្រូវបានបំពេញនោះ[5303]។

១៥៩៩. ដោយឆ្លាស់គ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដូចបានរៀបរាប់ខាងលើ និងដោយផ្អែកលើ មូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង**ខៀវ សំផន** ថា ជាអ្នកទទួលខុសក្នុងនាមជាថ្នាក់លើ ដោយហេតុផលថា ពួកគេមានអំណាចជាក់ស្តែងលើអ្នកក្រោមបង្គាប់របស់គេ (កងទ័ពបដិវត្តកម្ពុជា សមាជិកគណៈភូមិភាគ គណៈតំបន់ និង គណៈស្រុក កងឈ្លប និង កម្មាភិបាលមូលដ្ឋាន បុគ្គលិកនៃមន្ទីរសន្តិសុខ ប្រធានកង ឬ អ្នកគ្រប់គ្រងការដ្ឋាននិងសហករណ៍) ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចមានរៀបរាប់ខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖** បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និង

មាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖** បទល្មើសដែលមានចែងនឹងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឱ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

(ញ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ដ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ឋ). អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជា ការប៉ះពាល់ដល់ភាពសេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ)។

**១៥៦០.នួន ជា អៀង សារី និង ខៀវ សំផន** បានដឹង ឬមានហេតុផលដែលអាចដឹងថា នឹងមានការប្រព្រឹត្តិ

បទល្មើសដូចខាងក្រោមពីសំណាក់ថ្នាក់ក្រោមរបស់ខ្លួន ហើយពួកគេខកខានក្នុងការបំពេញកាតព្វកិច្ចចាត់វិធានការចាំបាច់ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ។ ម្យ៉ាងទៀត **នួន ជា** **អៀង សារី** **និង ខៀវ សំផន** បានដឹង ឬមានហេតុផលនឹងអាចដឹងបានថាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តដោយថ្នាក់ក្រោមរបស់ខ្លួន ហើយពួកគេខកខានក្នុងការបំពេញកាតព្វកិច្ចផ្តន្ទាទោសចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។

**១៥៦១.**ចំពោះ **អៀង ធីរិទ្ធ** ដោយឆ្លាស់គ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដូចបានរៀបរាប់ខាងលើ និងដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកា ដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថា មានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទនេះ ថាជាអ្នកទទួលខុសក្នុងនាមជាថ្នាក់លើ ដោយហេតុផលថា ជនត្រូវចោទមានអំណាចជាក់ស្តែង (ជា ពិសេសក្នុងវិស័យសុខាភិបាល) លើអ្នកក្រោមបង្គាប់របស់ខ្លួននៅក្រសួងសង្គមកិច្ច ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៖** បទល្មើសដែលមានចែងនឹងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក).អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ការប៉ះពាល់ដល់ភាពថ្លៃថ្នូរជាមនុស្ស និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(ខ). ការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

(គ). ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម

**១៥៦២.អៀង ធីរិទ្ធិ** បានដឹង ឬមានហេតុផលដែលដឹងថា ពិតជាអាចមានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ហើយខ្លួនបានខកខាននូវកាតព្វកិច្ចក្នុងការចាត់វិធានការចាំបាច់នានា ដើម្បីបង្ការឧក្រិដ្ឋកម្មទាំងនេះ។ ម៉្យាងទៀត **អៀង ធីរិទ្ធិ** បានដឹង ឬ មានហេតុផលដែលដឹងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តយ៉ាងជាក់ស្តែង ដោយអ្នកក្រោមបង្គាប់របស់ខ្លួន ហើយខ្លួនបានខកខាននូវកាតព្វកិច្ចក្នុងការដាក់ទោសចារីទាំងនោះ។

**១៥៦៣.**ផ្ទុយទៅវិញ ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានលើកឡើងនៅក្នុងផ្នែក "ជនត្រូវចោទ" "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" នៃដីកាដំណោះស្រាយនេះ និងដោយផ្អែកលើលទ្ធផល

នៃការស៊ើបសួរលើស្ថានភាពនៃអង្គហេតុដែលបានប្តឹងមកសហចៅក្រមស៊ើបអង្កេត មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង **អៀង ធីរិទ្ធ** ថា បានអនុវត្តនូវអំណាចគ្រប់គ្រងជាក់ស្តែងទៅលើចារីនៃឧក្រិដ្ឋកម្ម និង ជាផលវិបាក មិនទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ នូវឧក្រិដ្ឋកម្មដូចខាងក្រោមនេះ៖

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាត** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា ២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន ប្រល័យពូជសាសន៍លើ៖

(ក) ៖ ជនជាតិចាម

(ខ) ៖ ជនជាតិវៀតណាម

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** ៖ បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់

(ង). ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច). ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ៖ បទល្មើសដែលមានចែងនឹងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឱ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

(ច). ការធ្វើទារុណកម្ម

(ឆ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

(ជ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើជនជាតិចាម

(ឈ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាលើពុទ្ធសាសនិក

(ញ). អំពើអមនុស្សធម៌ផ្សេងៗទៀតនៃការជម្លៀសដោយបង្ខំ និង ការបាត់ខ្លួនដោយបង្ខំ។

## ផ្នែកទី ៧- បទល្មើសដែលមានចែង និងផ្តន្ទាទោស ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

**១៥៦៤.** នៅក្នុងដីកាដំណោះស្រាយចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ចំពោះសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច (០០១/១៨-០៧-២០០៧-អ.វ.ត.ក.-ក.ស.ច.ស.) សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា អង្គហេតុមួយចំនួនក្នុងចំណោមអង្គហេតុ ដែលបង្ហាញឡើងតាមរយៈការស៊ើបសួរ (ជាក់ស្តែង អំពើមនុស្សឃាត និងអំពើទារុណកម្ម) អាចត្រូវបានកំណត់ជាបទល្មើសច្រើនប្រភេទ ដោយហេតុថា អង្គហេតុទាំងនោះ អាចជាឧក្រិដ្ឋកម្មដែលត្រូវបានផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ផង និងជាឧក្រិដ្ឋកម្មអន្តរជាតិផង[5304]។ សហចៅក្រមស៊ើបអង្កេតក៏កត់សម្គាល់ផងដែរថា ការចោទប្រកាន់ដែលត្រូវធ្វើដោយយោងទៅលើបទបញ្ញត្តិច្បាប់ក្នុងស្រុករបស់កម្ពុជា បានបង្កើតនូវបញ្ហាលំបាកផ្នែក គតិយុត្តជាច្រើន ដូចដែលបានស្តែងឡើងតាមរយៈបញ្ហានិតិវិធីដែលបានកើតមានជាបន្តបន្ទាប់។ ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃកិច្ចការតុលាការ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាជាការប្រសើរដែលអង្គហេតុទាំងនោះ ត្រូវកំណត់ជាបទល្មើសក្នុងចំណាត់ថ្នាក់ ដែលមានកំរិតខ្ពស់ជាងគេតែប៉ុណ្ណោះ ដែលនៅក្នុងករណីនេះគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

**១៥៦៥.** សហព្រះរាជអាជ្ញាបានធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយនេះ ដោយបានលើកឡើងថា៖

*-"គ្មានឋានានុក្រមរវាងបទល្មើស ហើយនិងបទល្មើសនោះទេនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ហើយគេក៏មិនអាចនិយាយថា បទមនុស្សឃាត និងការធ្វើទារុណកម្មដែលបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាបទល្មើសដែលមានលក្ខណៈ "ស្រាលជាង" បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវបានដែរ"*[6305] ។

00605777



-*"បទល្មើសនានាក្រោមច្បាប់ជាតិ មិនអាចដាក់បញ្ចូលទៅក្រោមបទល្មើសនានាក្រោមច្បាប់អន្តរជាតិបានទេ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ពីព្រោះបទល្មើសនីមួយៗក្រោមច្បាប់ជាតិ គឺតម្រូវឱ្យមានធាតុផ្សំជាក់ស្តែងណាមួយ ដែលមិនមាននៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ។ ហើយបញ្ច្រាស់មកវិញ បទល្មើសនីមួយៗក្រោមច្បាប់អន្តរជាតិ ក៏តម្រូវឱ្យមានធាតុផ្សំជាក់ស្តែងណាមួយ ដែលមិន មាននៅក្នុងបទល្មើសក្រោមច្បាប់ជាតិនោះដែរ"*[5306] ។

-*"ដោយមានការខកខានមិនបានធ្វើការចោទប្រកាន់អំពីបទល្មើសតាមច្បាប់ជាតិនោះ សហចៅក្រមស៊ើបអង្កេតបានបង្កើតជាហានិភ័យ ដែលមិនមានការចាំបាច់មួយដែលមានសក្តានុពលថា ឧុចអាចនឹងត្រូវបានលើកលែងការចោទប្រកាន់ទាំងស្រុងនៅក្នុងពេលជំនុំជម្រះក្តី"*[5307] ។

**១៥៦៦.** នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានសម្រេចថា អំពើទារុណកម្ម និងអំពើមនុស្សឃាតគិតទុកជាមុន ដែលមានបញ្ញត្តនៅក្រោមច្បាប់ជាតិ *"មិនត្រូវរួម បញ្ចូលនៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ"*[5308] នោះឡើយ។ ដោយហេតុថា សញ្ញាណនៃការកំណត់បទល្មើសច្រើនលើអង្គហេតុតែមួយ មិនមានកំណត់នៅក្នុងច្បាប់កម្ពុជា និងក៏មិនមានលើកឡើងនៅក្នុងវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានស្វែងរកបទដ្ឋានណែនាំ ដែលបានបង្កើតនៅកម្រិតអន្តរជាតិ(ដែលសហចៅក្រមស៊ើបអង្កេតមាននិន្នាការផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការបារាំងច្រើនជាង ដោយសារច្បាប់កម្ពុជាមានប្រភពឬសគល់ដូចគ្នាទៅនឹងច្បាប់បារាំង) និងបានយោងទៅដល់យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពិសេស ដែលបានទទួលស្គាល់ថា៖ *"នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ អន្តរជាតិ គេអនុញ្ញាតឱ្យបញ្ចូលបទចោទខុសៗគ្នាចំពោះអំពើតែមួយនៅក្នុងដីកាបញ្ជូនទៅជម្រះ*[5309]"។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះក៏បានសម្រេចធ្វើការដាក់បញ្ចូលបន្ថែមទៅក្នុងដីកាបញ្ជូនទៅ ជំនុំជម្រះ នូវបទល្មើសទារុណកម្ម បទល្មើសមនុស្សឃាត ដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[5310] ។

**១៥៦៧.** នៅពេលបើកសវនាការ ក្រុមមេធាវីការពារក្តីបានលើកឡើងអំពីអញ្ញត្រកម្មមុនអង្គសេចក្តីមួយនៅមុខអង្គជំនុំជម្រះសាលាដំបូងដែលទាក់ទងនឹងការរលត់បណ្តឹងអាជ្ញាចំពោះបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដោយបានលើកឡើងថា មាត្រា១០៩នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានចែងអំពីអាជ្ញាយុកាល ១០ឆ្នាំ នៃបណ្តឹងអាជ្ញាចំពោះបទល្មើសទាំងនេះ ហើយថិរវេលានៃអាជ្ញាយុកាលនេះមិនត្រូវបានកាត់ផ្តាច់ ឬបង្អង់នោះឡើយ ដោយវាត្រូវរលត់នៅថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៨៩[5311] ។

00605778



១៥៦៨. អង្គជំនុំជម្រះសាលាដំបូងបានវិនិច្ឆ័យថា នៅក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ប្រទេសកម្ពុជា មិនមានប្រព័ន្ធតុលាការណាមួយដែលដំណើរការក្នុងចន្លោះឆ្នាំនោះទេ ជាហេតុធ្វើឲ្យការស៊ើបសួរ ឬការចោទប្រកាន់នៅក្នុងរយៈពេលនោះមិនអាចប្រព្រឹត្តទៅបាន ហេតុដូច្នេះចិរវេលានៃ អាជ្ញាយុកាលចំពោះបទល្មើសទាំងនេះក៏មិនបានចាប់ផ្តើមគិតនៅក្នុងរយៈពេលនោះដែរ[5312]។ ផ្ទុយទៅវិញ ចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះសាលាដំបូងមិនបានមានមតិឯកភាពគ្នាលើបញ្ហា ដែលពាក់ព័ន្ធនឹងការកាត់ផ្តាច់ឬការបង្អង់ថេរៈវេលានៃអាជ្ញាយុកាលក្នុងចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៩៣ នោះឡើយ ដោយសារមានមតិផ្សេងៗគ្នាលើបញ្ហានេះ ។

១៥៦៩. ចៅក្រមកម្ពុជាយល់ឃើញថា ទោះបីជានៅរយៈពេលនោះ មានការរៀបចំការជំនុំជម្រះនៅមុខ តុលាការកម្ពុជាលើសំណុំរឿងមួយចំនួនក៏ដោយ *("ចាប់តាំងពីឆ្នាំ ១៩៨២")* ក៏សមត្ថភាពដំណើរការ នៃប្រព័ន្ធតុលាការរបស់កម្ពុជាមានការខ្វះខាតច្រើនណាស់នាពេលនោះ ដោយសារតែ ការបំផ្លិចបំផ្លាញទាំងស្រុងដែលធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ចៅក្រមកម្ពុជាសន្និដ្ឋាន ថា *"ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ ប្រព័ន្ធតុលាការនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា មិនមានដំណើរការទាល់តែសោះ និងបានដំណើរការតែក្នុងទ្រង់ទ្រាយមួយមានកម្រិតបំផុតនៅក្នុង អំឡុងឆ្នាំក្រោយៗមក"*[5313]។ អាស្រ័យហេតុនេះ ចៅក្រមកម្ពុជាបានសម្រេចថា ចិរវេលានៃ អាជ្ញាយុកាលចំពោះបទល្មើសក្នុងក្រមឆ្នាំ១៩៥៦ចាប់ផ្តើមគិតយ៉ាងឆាប់បំផុតចាប់ពីពេលដែលមាន ការបង្កើតព្រះរាជាណាចក្រកម្ពុជា គឺរាប់ចាប់តាំងពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដូច្នេះ អាជ្ញាយុកាលមិនទាន់ ផុតរលត់នៅឡើយទេ។ ជាងនេះទៀត ចៅក្រមកម្ពុជាបានកត់សម្គាល់ លើសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញដែលបានបញ្ជាក់ក្នុងខ្លឹមសារសំខាន់ថា ការបន្តចិរវេលា នៃអាជ្ញាយុកាល ដូចមានចែងក្នុងមាត្រា៣(ថ្មី)នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. គឺស្របទៅ នឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣[5314] ហើយចៅក្រមកម្ពុជាក៏បានលើកឡើងទៀតថា *"ចៅក្រមកម្ពុជា មិនមានសមត្ថកិច្ចពិនិត្យអំពីភាពត្រឹមត្រូវនៃសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះ ទេ"*[5315] ។

១៥៧០. ចៅក្រមអន្តរជាតិបានទទួលស្គាល់ថា ប្រព័ន្ធតុលាការកម្ពុជាពិតជា *"មានលក្ខណៈទន់ខ្សោយខ្លាំង និងដំណើរការដោយមិនមានលក្ខណៈពេញលេញ"* នៅចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ នោះ ប៉ុន្តែ វាមិនទាន់ដល់ចំណុចដែលថា *"ការចោទប្រកាន់ឬការស៊ើបសួរណាមួយមិនអាចនឹងធ្វើបាន*

00605779



*នោះឡើយ"*[5316]។ ចៅក្រមអន្តរជាតិបានបន្ថែមទៀតថា *"ទោះបីជាការប្រកាសនូវរដ្ឋធម្មនុញ្ញនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ជាកាលបរិច្ឆេទនៃការបង្កើតព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏វាមិនមានភស្តុតាងច្បាស់លាស់បង្ហាញឲ្យឃើញថា ការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញបានស្តារនូវប្រព័ន្ធយុត្តិធម៌កម្ពុជាឲ្យមានសមត្ថភាពដោយសត្យានុម័ត ដើម្បីស៊ើបសួរ ឬចោទប្រកាន់នោះទេ ឬបានលុបបំបាត់នូវភាពទន់ខ្សោយដែលមានលក្ខណៈជាប្រព័ន្ធ ដែលគេសង្កេតឃើញមានពីមុនៗ ដែលភាគច្រើននៃបញ្ហាទាំងនោះ បន្តមានឬសឆ្នាំ១៩៩៣ ទៅទៀត"*[5317] ។ ម្យ៉ាងវិញទៀត ចៅក្រមអន្តរជាតិយល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញ *"មិនបានលើកឡើងឲ្យច្បាស់ថា មាត្រា៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មានចេតនាផ្តល់នូវការព្យួរឲ្យមានប្រតិសកម្មចំពោះចិរវេលានៃអាជ្ញាយុកាលដែលយកមកអនុវត្ត ឬបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ បន្ទាប់ពីការផុតរលត់ចិរវេលានៃអាជ្ញាយុកាលនោះទេ"* ហើយ *"ក្រុមប្រឹក្សាធម្មនុញ្ញគ្រាន់តែកត់សម្គាល់ថា មាត្រា៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. ប៉ះពាល់ដល់គោលការណ៍ "ជាមូលដ្ឋាន" នៃអប្រតិសកម្មភាពនៃច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែមិនបានធ្វើការសម្រេចបន្ថែមទៀតចំពោះផលប៉ះពាល់នៃគោលការណ៍នេះទេ"*[5318] ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិមិនអាចសន្និដ្ឋានបានថា ចិរវេលានៃអាជ្ញាយុកាលដែលអនុវត្តចំពោះបទល្មើសជាតិត្រូវបានបង្អង់នៅចន្លោះឆ្នាំ១៩៧៩ និង១៩៩៣ នោះទេ និងបានសម្រេចថា ការចោទប្រកាន់មិនអាចនឹងធ្វើទៅបានទៀតឡើយ គិតត្រឹមថ្ងៃដែលប្រកាសឲ្យប្រើមាត្រា៣ និងមាត្រា៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. គឺនៅក្នុងឆ្នាំ ២០០១ និង ២០០៤ ។

**១៥៧១.** ដោយហេតុថា មិនមានការទទួលបាននូវសម្លេងភាគច្រើនលើសលប់ ដូច្នេះមិនមានការសម្រេចបែបណាមួយដោយអង្គជំនុំជម្រះសាលាដំបូងលើពិរុទ្ធភាពរបស់ជនជាប់ចោទ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានចែង និងផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះទេ[5319] ។

**១៥៧២.** ចៅក្រមអង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានថា *"ដោយសារតែមានភាពត្រួតគ្នារវាងធាតុផ្សំនៃបទឧក្រិដ្ឋជាតិ និងបទឧក្រិដ្ឋអន្តរជាតិ ការរកឃើញនេះមិនមានផលប៉ះពាល់ដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងរបស់ជនជាប់ចោទ ឬការផ្តន្ទាទោសជាចុងក្រោយនោះទេ"*[5320] ។

**១៥៧៣.** គឺនៅក្នុងស្ថានភាពនេះហើយ ដែលនៅក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាបានស្នើឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង

ក្រោមអំពើរំលោភបំពានលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ *"រួមមាន ការធ្វើមនុស្សឃាត (មាត្រា ៥០១ មាត្រា ៥០៣ និងមាត្រា ៥០៦) និងការធ្វើទារុណកម្ម (មាត្រា ៥០០)"*[5321] ។

**១៥៧៤.** ឆ្លងតាមការបកស្រាយមកខាងលើ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតកំពុងប្រឈមនឹងបញ្ហានីតិវិធីមួយដែលមិនអាចដោះស្រាយបាន ដែលបញ្ហានេះមានជាប់ពាក់ព័ន្ធមួយផ្នែកទៅនឹងរចនាសម្ព័ន្ធចម្រុះរបស់ អ.វ.ត.ក. ។ សហចៅក្រមស៊ើបអង្កេតបានព្យាយាមតាក់តែងនូវគោលជំហររួមមួយស្តីអំពីបញ្ហានៃការកំណត់បទល្មើសត្រួតគ្នាចំពោះអង្គហេតុតែមួយ និងបញ្ហាអាជ្ញាយុកាលចំពោះបទល្មើសជាតិ ក៏ដូចជាអំពីវិសាលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ប៉ុន្តែការងារនេះមិនទទួលបានលទ្ធផលនោះឡើយ។ ដោយថិតក្នុងស្ថានភាពលំបាកបែបនេះ និងដើម្បីជៀសវាងភាពទ័លច្រកនានា ដោយមិនចាំបាច់ឱ្យមានការប្រើប្រាស់នីតិវិធីនៃការដោះស្រាយការខ្វែងយោបល់ដែលអាចនឹងប៉ះពាល់ដល់ដំណើរការតុលាការទាំងមូល និងដោយពិចារណាទៅលើកាតព្វកិច្ចរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេចមួយក្នុងថិរៈវេលាសមស្រប ដូចមានចែងក្នុងវិធាន ២១ (៤) រួមទាំងការទន្ទឹងរង់ចាំអស់រយៈពេលជាយូររបស់ជនរងគ្រោះដែលចង់បាននូវការស៊ើបសួរមួយដែលប្រព្រឹត្តទៅនៅក្នុងថិរវេលាមួយសមស្រប សហចៅក្រមស៊ើបអង្កេតបានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនៃនីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទាំងនោះ ។

**១៥៧៥.** សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញផងដែរថាទោះបីជាដីកាសន្និដ្ឋានស្ថាពរទាំងពីរភាសាបានធ្វើការវិភាគនៅក្នុងផ្នែកស្តីពីច្បាប់ដែលត្រូវអនុវត្ត[5322] អំពីបទល្មើសទាំងបី ការវាយប្រហារលើសាសនា មនុស្សឃាត និង ទារុណកម្ម ក៏ដោយ ក៏អត្ថបទជាភាសាអង់គ្លេសរបស់ដីកាសន្និដ្ឋានស្ថាពរនេះ (ដែលមានបញ្ជាក់យ៉ាងច្បាស់ថាជាអត្ថបទក្នុងភាសាដើម) មិនបានធ្វើការចោទប្រកាន់លើបទល្មើសវាយប្រហារលើសាសនាទេនៅក្នុងផ្នែកនៃសេចក្តីសម្រេចបញ្ចប់ ដែលនេះខុសទៅនឹងអត្ថបទជាភាសាខ្មែរ ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មិនមានការយល់ឃើញណាមួយ ដែលត្រូវធ្វើការបែងចែករវាងបទល្មើសទាំងបីនេះ នោះឡើយ។

**១៥៧៦.** អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១ ។

វាយប្រហារលើសាសនា ដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្ដន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

# ជំពូក ៤ - បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ

## ផ្នែកទី ១- នួន ជា

**១៩៧៧.** អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង ក្រោមបទចោទប្រកាន់នៃអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើសាសនា ដែលជាឧក្រិដ្ឋកម្មដែលមានចែង និងផ្ដន្ទាទោសដោយក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។នួន ជា កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង[5323]។ នៅពេលចូលខ្លួនដំបូង នួន ជា បានឆ្លើយប្រាប់ថា ឈ្មោះកំណើតរបស់គាត់គឺ **ឡៅ គឹមលន** ដោយបញ្ជាក់ថាឈ្មោះនេះ *"ឈប់ប្រើយូរហើយ"*។[5324] នួន ជា គឺជាកូនទីបីក្នុងចំណោមបងប្អូនចំនួន ប្រាំបួននាក់។ ឪពុកគាត់មានឈ្មោះថា **ឡៅ លឹវ** ជាសែស្រឡាយចិន (ជនជាតិហាន) ប្រកបរបរទិញលក់ពោតនៅខេត្តបាត់ដំបង។ ម្ដាយគាត់ឈ្មោះ **ដុស ពាញ** ជាជាងកាត់ដេរ។ ម្ដាយគាត់ក៏មានដើមកំណើតកូនកាត់ចិនផងដែរ ប៉ុន្តែ នួន ជា ត្រូវបានចិញ្ចឹមបីបាច់ នៅក្នុងគ្រួសារចម្រុះវប្បធម៌ដែលនិយាយភាសាខ្មែរ[5325]។

**១៩៧៨.** នួន ជា បានរៀបការជាមួយ **លី គឹមសេង** និងមានកូនបីនាក់ ថែមទាំងមានកូនចិញ្ចឹមម្នាក់ផងដែរ។

**១៩៧៩.** បន្ទាប់ពីបានទទួលសញ្ញាបត្របឋមសិក្សា នួន ជា បានបន្តការសិក្សាថ្នាក់មធ្យមនៅខេត្តបាត់ដំបង។ ការសិក្សានេះត្រូវបានផ្អាកនៅក្នុងសម័យសង្គ្រាមលោកលើកទីពីរ នៅឆ្នាំ១៩៤១ នៅពេលខេត្តបាត់ដំបងស្ថិតនៅក្រោមការកាន់កាប់របស់ប្រទេសថៃ ដែលជាសម្ព័ន្ធមិត្តរបស់ជប៉ុន ។ ដូចនេះ នួន ជា បានសិក្សាភាសាថៃ បន្ទាប់មកបានធ្វើដំណើរទៅទីក្រុងបាំងកក[5326] ដែលនៅទីនោះ គាត់បានរស់នៅជាមួយនឹងព្រះសង្ឃខ្មែរជាច្រើនអង្គ នៅក្នុងវត្តមួយ[5327]។ នួន ជា បានសិក្សាមុខវិជ្ជាច្បាប់ (មិនបានចប់ទេ) នៅសកលវិទ្យាល័យធម្មសាស្ត្រ (Thammasat) នាទីក្រុងបាងកក ដោយប្រើឈ្មោះថា **រុងឡឺត ឡាវឌី**[5328] (Runglert Laodi) និងបានធ្វើការងារក្រៅម៉ោង ក្នុងតួនាទីជាស្មៀន

00605782



ដោយដំបូងនៅក្រសួងហិរញ្ញវត្ថុ បន្ទាប់មកនៅក្រសួងការបរទេសរបស់ថៃ ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៩ មុនគាត់ចូលមកក្នុងប្រទេសកម្ពុជាវិញនាឆ្នាំ១៩៥០ ជាពេលដែលគាត់ចូលប្រឡូកនៅក្នុងសកម្មភាពបដិវត្តន៍[5329]។

១៩៨០. សកម្មភាពនយោបាយរបស់ **នួន ជា** រហូតដល់ឆ្នាំ១៩៧៩ នឹងត្រូវរៀបរាប់នៅក្នុងផ្នែកទាក់ទងនឹងជនត្រូវចោទនៃដីកាដោះស្រាយនេះ។

១៩៨១. នៅពេលកងទ័ពវៀតណាមមកដល់នៅខែមករា ឆ្នាំ១៩៧៩ **នួន ជា** និង **ប៉ុល ពត** បានជួបជុំជាមួយ **អៀង សារី** និង **ខៀវ សំផន** នៅក្នុងខេត្តពោធិសាត់[5330]។ នៅពេលប្រជុំគណៈមជ្ឈិម នាខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៩ **នួន ជា** បានជំរុញឱ្យ **ប៉ុល ពត** បន្តនៅជាលេខាបក្ស[5331]។ បន្ទាប់មកទៀត **នួន ជា** បានធ្វើដំណើរនៅក្នុងប្រទសកម្ពុជា[5332] ដើម្បីបែងចែកសម្ភារសឹកឱ្យកម្មាភិបាល និងកងទ័ព[5333]។ នៅខែធ្នូ ឆ្នាំ១៩៧៩ គណៈអចិន្ត្រៃយ៍របស់សភាតំណាងប្រជាជនបានសម្រេចជាឯកច្ឆន្ទរក្សាតួនាទីរបស់គាត់ជាប្រធានសភាដដែល[5334]។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ **នួន ជា** បានរៀបចំសន្និសីទជាមួយ **ខៀវ សំផន** ដែលនៅក្នុងសន្និសីទនោះ គាត់បានសម្រេចបង្កើតរណសិរ្សរួបរួមមួយ ជាមួយនឹងរណសិរ្សរំដោះជាតិប្រជាជនខ្មែរ និងអ្នករាជានិយម[5335] ដើម្បីប្រឆាំងនឹងវៀតណាម។ ក្រោយមក ក្នុងនាមសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ **នួន ជា** និង **ខៀវ សំផន** បានផ្សព្វផ្សាយសារាចរណែនាំផ្សេងៗ ដែលអំពាវនាវឱ្យកងទ័ព, ប្រជាជន និងជនរួមជាតិទាំងអស់ដែលនៅក្រៅប្រទេស ឱ្យបន្តការតស៊ូដើម្បីមាតុភូមិ ប្រឆាំងនឹងវៀតណាម[5336]។ នៅខែតុលា ឆ្នាំ១៩៨១ **នួន ជា** ជាប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ចូលរួមសន្និសីទសភាអាស៊ី ធ្វើនៅទីក្រុងប៉េកាំង[5337]។ បន្ទាប់ពីការរំលាយបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការ នាចុងឆ្នាំ១៩៨៣ ឬនាដើមឆ្នាំ១៩៨៤ **នួន ជា** បានចូលរួមវគ្គអប់រំនយោបាយ នៅតំបន់សំឡូត ដែលនៅក្នុងវគ្គសិក្សានយោបាយនោះ គាត់បានប្រកាសថា "របបសង្គមនិយមកុម្មុយនីស្តមិនមែនជាគោលដៅរបស់យើងនោះទេ វាគ្រាន់តែជាមធ្យោបាយសម្រាប់ស្នេហាជាតិនិយមតែប៉ុណ្ណោះ"[5338]។

១៩៨២. **នួន ជា** ជាមួយនឹង **ខៀវ សំផន** បានចុះចូលជាមួយរដ្ឋាភិបាលទីក្រុងភ្នំពេញ នៅខែធ្នូ ឆ្នាំ១៩៩៨ ជាងប្រាំមួយខែក្រោយពីការស្លាប់របស់ **ប៉ុល ពត**[5339]។ នៅពេលចាប់ខ្លួនគាត់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ **នួន ជា** រស់នៅជាមួយប្រពន្ធរបស់គាត់ នៅភូមិផ្សារព្រហ្ម ស្រុកប៉ៃលិន[5340]។

១៩៨៣.បន្ទាប់ពីបានប្រកាសបដិសេធអង្គហេតុដែលបានចោទប្រកាន់ទាំងអស់ និងថាចង់ *"បំភ្លឺឲ្យពិភពលោកដឹងការពិត"* នៅពេលចូលខ្លួនដំបូង និងនៅពេលសួរដេញដោលបឋមដើម្បីធ្វើការឃុំខ្លួនរបស់គាត់ **នួន ជា** មិនបានធ្វើសេចក្តីប្រកាសជាខ្លឹមសារណាមួយទេ ដោយគ្រាន់តែលើកឡើងជាបឋមអំពីសុខភាពរបស់គាត់ប៉ុណ្ណោះ[5341]។ **នួន ជា** ក៏បានជ្រើសរើសអនុវត្ត "សិទ្ធិនៅស្ងៀមមិនឆ្លើយ" ផងដែរ[5342]។

១៩៨៤.**នួន ជា** បានបដិសេធការជួបជាមួយអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដែលទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់អំពីលទ្ធភាពរបស់គាត់ក្នុងការទទួលយកការជំនុំជម្រះ។ ដូច្នេះ អ្នកជំនាញធ្វើការសង្កេតថា សំណុំឯកសារពេទ្យរបស់ **នួន ជា** មិនបង្ហាញអំពីប្រវត្តិនៃបញ្ហាផ្លូវចិត្តពីអតីតកាលឡើយ[5343]។

## ផ្នែកទី២- អៀង សារី ហៅ វ៉ាន់

១៩៨៥.**អៀង សារី** (ឈ្មោះកំណើត **គីម ត្រឹង**) កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ខេត្តត្រាវិញ វៀតណាមខាងត្បូង (កូសាំងស៊ីន)។ ក្នុងពេលបង្ហាញខ្លួនលើកដំបូង[5344] **អៀង សារី** និយាយថា គាត់បានប្តូរស្ថានភាពអត្រានុកូលដ្ឋាន ដើម្បីទទួលបានសំបុត្រកំណើតខ្មែរ និងដើម្បីអាចប្រឡងចូលរៀនវិទ្យាល័យព្រះស៊ីសុវត្ថិ។ ដូច្នេះ ជាផ្លូវការ **អៀង សារី** កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ នៅភូមិបារាយណ៍ ខេត្តព្រៃវែង ប្រទេសកម្ពុជា។

១៩៨៦.ឪពុករបស់ **អៀង សារី** ឈ្មោះ **គីម រៀម** ជាខ្មែរកម្ពុជាក្រោម និងម្តាយឈ្មោះ **ត្រឹង ធិឡើយ** ជាកូនកាត់ចិន-វៀតណាម។ នៅពេលឪពុកគាត់ស្លាប់ ដែលពេលនោះគាត់នៅក្មេងនៅឡើយ **អៀង សារី** បានមករស់នៅជាមួយសាច់ញាតិ ក្នុងខេត្តព្រៃវែង ប្រទេសកម្ពុជា[5345]។ ដូច្នេះ គាត់បានប្តូរឈ្មោះពី **គីម ត្រឹង** ទៅជា **អៀង សារី**[5346]។

១៩៨៧.នៅពេលមកដល់ភ្នំពេញនៅដើមទសវត្សរ៍ឆ្នាំ១៩៤០ **អៀង សារី** បានបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ[5347] (ជាទីកន្លែងដែលគាត់បានស្គាល់អនាគតភរិយារបស់គាត់ឈ្មោះ **អៀង ធីរិទ្ធ** ដែលជាសិស្សក្នុងវិទ្យាល័យជាមួយគ្នា)[5348]។ មុនពេលចាកចេញទៅប្រទេសបារាំង[5349] (គាត់ទទួលបានអាហារូបករណ៍ដើម្បីទៅសិក្សានៅទីនោះ) **អៀង សារី** បានភ្ជាប់ពាក្យជាមួយ **អៀង ធីរិទ្ធ** ហើយបានរៀបការជាមួយគ្នា នៅទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៥៣។ អ្នកទាំងពីរមានកូនបួននាក់ (ស្រីបី



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605784



ប្រុសមួយ)[5350]។

១៩៨៨. ក្រោយពេលត្រឡប់មកភ្នំពេញវិញនៅឆ្នាំ១៩៥៧[5351] **អៀង សារី** បានធ្វើជាសាស្ត្រាចារ្យប្រវត្តិវិទ្យា និងភូមិវិទ្យា នៅអនុវិទ្យាល័យឯកជនឈ្មោះ កម្ពុជបុត្រ[5352] រហូតដល់ពេលគាត់ចូលលាក់ខ្លួនក្នុងឆ្នាំ១៩៦៣[5353]។

១៩៨៩. សកម្មភាពនយោបាយរបស់ **អៀង សារី** រហូតដល់ឆ្នាំ១៩៧៩ ត្រូវបានវិភាគនៅក្នុងផ្នែកទាក់ទងនឹងជនត្រូវចោទ នៃដីកាដំណោះស្រាយនេះ។

១៩៩០. នៅដើមឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា **អៀង សារី** បានភៀសខ្លួនទៅប្រទេសថៃ ហើយបានជួបជាមួយ ប៉ុល ពត និង **នួន ជា** នៅជិតខេត្តពោធិសាត់។ បន្ទាប់មក មានការសម្រេចបញ្ជូន **អៀង សារី** ទៅប្រទេសចិន ដើម្បីចរចាសុំជំនួយ[5354]។

១៩៩១. នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ **អៀង សារី** ត្រូវបានតុលាការបដិវត្តន៍ប្រជាជនភ្នំពេញ ជំនុំជម្រះកំបាំងមុខ រួមជាមួយ ប៉ុល ពត ពីបទ "ប្រល័យពូជសាសន៍" ហើយផ្តន្ទាទោសប្រហារជីវិត និងដកហូតទ្រព្យសម្បត្តិ[5355]។

១៩៩២. **អៀង សារី** បានបន្តតួនាទីជាផ្លូវការក្នុងរដ្ឋាភិបាលនិរទេស ដោយតំណាងរដ្ឋាភិបាលនេះ នៅក្រៅប្រទេស ជាពិសេសនៅអង្គការសហប្រជាជាតិ[5356] និងត្រូវបានស្គាល់តាមរយៈសារព័ត៌មានបរទេស ថាជាប្រមុខដឹកនាំម្នាក់នៃរបបខ្មែរក្រហម[5357]។ ក្នុងឆ្នាំ១៩៨២ នៅពេលបង្កើតរដ្ឋាភិបាលចម្រុះ[5358] ដែលក្រៅពីសមាសភាពខ្មែរក្រហម មានការចូលរួមពីក្រុមអ្នកនិយមសម្តេចស៊ីហានុ និង សុន សេន **អៀង សារី** បានផ្ទេរក្រសួងការបរទេសទៅឲ្យ **ខៀវ សំផន**។

១៩៩៣. ក្នុងតួនាទីជាអ្នកទទួលខុសត្រូវលើគណៈកម្មាធិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរដ្ឋាភិបាលចម្រុះ[5359] **អៀង សារី** បានដើរតួនាទីដាច់មុខជាអ្នកទាក់ទងតែមួយគត់ជាមួយអាជ្ញាធរចិន ពាក់ព័ន្ធនឹងបញ្ហាជំនួយយោធា និងហិរញ្ញវត្ថុ ដែលផ្តល់ដោយរដ្ឋាភិបាលក្រុងប៉េកាំង ដល់ខ្មែរក្រហម[5360]។

១៩៩៤. ក្រោយមក ឥទ្ធិពលរបស់ **អៀង សារី** នៅក្នុងចលនានេះបានថយចុះបន្តបន្ទាប់ ដោយគាត់ត្រូវបាន

ដកហូតការទទួលខុសត្រូវជាច្រើន។ ក្នុងខែសីហា ឆ្នាំ១៩៩៦ ការបែកបាក់បានកើតឡើង ហើយ **អៀង សារី** បានចុះចូលជាមួយរដ្ឋាភិបាល ព្រមជាមួយនឹងក្រុមអ្នកគាំទ្រគាត់ជាច្រើនពាន់នាក់។ តាមរយៈព្រះរាជក្រឹត្យ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ **អៀង សារី** ត្រូវបានលើកលែងទោស ពីការផ្តន្ទាទោសក្នុងឆ្នាំ១៩៧៩ និងទទួលបានផងដែរនូវការលើកលែងចេញពីច្បាប់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ (ច្បាប់ស្តីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" អោយនៅក្រៅច្បាប់)[5361]។

**១៩៩៥.** ក្នុងឆ្នាំ១៩៩៧ **អៀង សារី** បានបង្កើតគណបក្សមួយដែលមានឈ្មោះថា ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ដើម្បីចូលរួមក្នុងការបោះឆ្នោតក្នុងឆ្នាំ១៩៩៨ ក៏ប៉ុន្តែបានបញ្ឈប់ទៅវិញ[5362]។

**១៩៩៦.** រហូតដល់ពេលបានចាប់ខ្លួន **អៀង សារី** បានរស់នៅក្នុងទីក្រុងភ្នំពេញ និងប៉ៃលិន ជាមួយភរិយារបស់គាត់[5363]។

**១៩៩៧.** ក្នុងបរិបទនៃការធ្វើកោសល្យវិច័យចិត្តសាស្ត្រ ដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត អ្នកជំនាញបានប្រាស្រ័យទាក់ទងជាមួយ **អៀង សារី**។ អ្នកជំនាញបានសន្និដ្ឋានថា **អៀង សារី** គ្មានបញ្ហាផ្លូវចិត្តនោះទេ[5364] ដោយបានលើកឡើងថា៖ [លុប]

[លុប]

[លុប] *តាមការពិនិត្យ យើងខ្ញុំមិនជឿថា បញ្ហានេះនឹងធ្វើឱ្យលោក អៀង សារី មានសភាពចុះខ្សោយរហូតមិនអាចមានលទ្ធភាពប្រឈមមុខនឹងការជំនុំជម្រះក្តីបាននោះឡើយ។"*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

# ផ្នែកទី ៣- ខៀវ សំផន

១៥៩៨. **ខៀវ សំផន** ហៅ "ហែម"[5365] ឬ "ខាង"[5366] ឬ "ណាន"[5367] កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង[5368]។ ឪពុករបស់គាត់ឈ្មោះ **ខៀវ ឡុង** និងម្តាយរបស់គាត់ឈ្មោះ **លី គង់**[5369]។ ឪពុករបស់ **ខៀវ សំផន** ជាមន្ត្រីរាជការ រីឯម្តាយដែលមានដើមកំណើតជាជនជាតិចិន បានប្រកបរបរជាអ្នកលក់បន្លែ បន្ទាប់ពីមរណភាពរបស់ស្វាមីគាត់នៅឆ្នាំ១៩៤៧[5370]។

១៥៩៩. នៅឆ្នាំ១៩៥៣ **ខៀវ សំផន** បានទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសបារាំង[5371]។ នៅឆ្នាំ១៩៥៩ **ខៀវ សំផន** បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត ក្រោមចំណងជើងថា "សេដ្ឋកិច្ចប្រទេសកម្ពុជា និងការអភិវឌ្ឍន៍បែបឧស្សាហកម្ម"[5372]។ ពេលនៅទីក្រុងប៉ារីស **ខៀវ សំផន** បានចាប់ផ្តើមចូលរួមជាសកម្មជននយោបាយ[5373]។

១៦០០. នៅឆ្នាំ១៩៦២ បន្ទាប់ពីបានត្រលប់មកកម្ពុជាវិញ **ខៀវ សំផន** បានជាប់ឆ្នោតជាតំណាងរាស្ត្រនៅខេត្តកណ្តាល ហើយត្រូវបានតែងតាំងជារដ្ឋលេខាធិការទទួលបន្ទុកការងារពាណិជ្ជកម្ម[5374]។ បន្ទាប់ពីពេលរដ្ឋាភិបាលជួបអស្ថេរភាព ក្នុងខែមេសា ឆ្នាំ១៩៦៧ **ខៀវ សំផន** ត្រូវបានចោទប្រកាន់ដោយតុលាការយោធា និងប្រឈមមុខនឹងការចាប់ខ្លួន។ ហេតុការណ៍នេះ បានជំរុញឲ្យគាត់គេចខ្លួនពីទីក្រុងភ្នំពេញនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧[5375]។ គាត់បានគេចខ្លួនទៅរស់នៅជាមួយតាម៉ុក[5376] ក្នុងភូមិជៀងតុង ខេត្តកំពង់ស្ពឺ ជាកន្លែងដែលគាត់រស់នៅរហូតដល់ឆ្នាំ១៩៧០[5377]។

១៦០១. សកម្មភាពនយោបាយរបស់ **ខៀវ សំផន** រហូតដល់ឆ្នាំ ១៩៧៩ ត្រូវបានវិភាគនៅក្នុងផ្នែកពាក់ព័ន្ធនឹងបុគ្គលដែលដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ នៅក្នុងដីកាដំណោះស្រាយនេះ។

១៦០២. បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ, ការភៀសខ្លួនរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា, និងការរុលទៅមុខរបស់កងទ័ពវៀតណាម **ខៀវ សំផន** បានបន្តគាំទ្រសកម្មភាពនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដោយគាត់រស់នៅប្រទេសកម្ពុជាជាមួយ ប៉ុល ពត ហើយបានជួយដឹកនាំការងារជម្លោះជាមួយវៀតណាម[5378]។ ការចូលរួមរបស់ ខៀវ សំផន ស្តែងឡើងតាមសកម្មភាពនានា ដូចជា៖ ការចុះពិនិត្យ និងការបែងចែកផ្គត់ផ្គង់ដល់កងទ័ព និងតំណាងកម្ពុជាប្រជាធិបតេយ្យក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ[5379]។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ នាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ និងជាប្រធានបណ្តោះអាសន្ននៃរណសិរ្សស្នេហាជាតិប្រជាធិបតេយ្យ **ខៀវ សំផន** បានចូលរួមក្នុងការបង្កើតសម្ព័ន្ធភាពជាមួយនឹងក្រុមចលនាតស៊ូផ្សេងៗ

00605787



ដូចជា រណសិរ្សរំដោះប្រជាជនខ្មែរ និងក្រុមរាជានិយម[5380]។ ជាមួយនឹងការបង្កើតរដ្ឋាភិបាលចម្រុះរបស់កម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៨២ **ខៀវ សំផន** បានក្លាយជាអនុប្រធានទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ[5381]។ រវាងឆ្នាំ១៩៧៩-១៩៨៦ **ខៀវ សំផន** បានបំពេញបេសកកម្មការទូតនានា និងបានតំណាងកម្ពុជានៅអង្គការសហប្រជាជាតិ[5382]។ នៅខែសីហា ឆ្នាំ១៩៨៥ នៅពេលដែលមានការសម្រេចបង្កើតគណបក្សកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** ត្រូវបានតែងតាំងជាប្រធាន។ នៅក្នុងឆ្នាំ១៩៨៩ ក្នុងឋានៈជាតំណាងកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានចូលរួមក្នុងសន្និសីទអន្តរជាតិទីក្រុងប៉ារីស ហើយនៅឆ្នាំ១៩៩១ គាត់បានមានវត្តមាននៅក្នុងពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមជាមួយនឹង សុន សេន[5383]។ ដូច្នេះ **ខៀវ សំផន** បានធ្វើដំណើរទស្សនកិច្ចផ្លូវការមួយមកទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៩១ ដែលនៅពេលនោះ គាត់ត្រូវបានវាយប្រហារដោយបាតុករមួយក្រុម[5384]។ **ខៀវ សំផន** នៅតែបានរក្សាសម្ព័ន្ធភាពនយោបាយជាមួយ ប៉ុល ពត រហូតដល់មានការចាប់ ប៉ុល ពត ក្នុងឆ្នាំ១៩៩៧[5385]ដោយពួកខ្មែរក្រហម ។ ទោះបីជា **ខៀវ សំផន** បានបដិសេធទូទៅចំពោះរាល់ការពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មនានាដែលប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ **ខៀវ សំផន** បានទទួលស្គាល់នៅក្នុងខែមេសា ឆ្នាំ១៩៨៦ ថា ខ្មែរក្រហម *"បានធ្វើខុស"*[5386]។

**១៦០៣.ខៀវ សំផន** បានរស់នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ រហូតដល់គាត់បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹង **នួន ជា** នៅខែធ្នូ ឆ្នាំ១៩៩៨។ **ខៀវ សំផន** បានរស់នៅទីក្រុងប៉ៃលិន។

**១៦០៤.ខៀវ សំផន** មិនចង់ជួបអ្នកជំនាញផ្នែកចិត្តសាស្ត្រ ដែលទទួលបន្ទុកពិនិត្យ និងផ្ដល់យោបល់លើសម្បទារបស់គាត់ក្នុងការទទួលយកការជំនុំជម្រះ ដោយបញ្ជាក់ថា គាត់មិនមានបញ្ហាផ្លូវចិត្តនោះទេ ហើយគាត់មិនព្រមទទួលយកការពិនិត្យឡើយ។ ដូច្នេះ អ្នកជំនាញបានធ្វើការបញ្ជាក់ថា សំណុំឯកសារពេទ្យរបស់ **ខៀវ សំផន** មិនបង្ហាញអំពីប្រវត្តិនៃបញ្ហាផ្លូវចិត្តពីអតីតកាលឡើយ[5387]។

# ផ្នែកទី ៤- អៀង ធីរិទ្ធ

១៦០៥. ខៀវ ធីរិទ្ធ ឈ្មោះក្រោយអាពាហ៍ពិពាហ៍ **អៀង ធីរិទ្ធ** ហៅ ភា[5388] កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅទីក្រុងភ្នំពេញ[5389]។ ឪពុករបស់គាត់ឈ្មោះ ខៀវ អុន ជាអតីតចៅក្រមនៅខេត្តបាត់ដំបង និង ម្តាយរបស់គាត់ឈ្មោះ អ៊ុក ប៉ុន មានកូនប្រាំនាក់ កូនស្រីបួននាក់ និងកូនប្រុសម្នាក់ ហើយធីរិទ្ធ គឺជាកូនពៅ[5390]។ **អៀង ធីរិទ្ធ** បានរៀបការជាមួយ **អៀង សារី** នៅឆ្នាំ១៩៥៣ ហើយពួកគាត់ មានកូនបួននាក់ កូនស្រីបីនាក់ និងកូនប្រុសម្នាក់[5391]។

១៦០៦. បន្ទាប់ពីទទួលបានសញ្ញាប័ត្រទុតិយភូមិនៅវិទ្យាល័យស៊ីសុវត្ថិ ទីក្រុងភ្នំពេញ (ដែល សុន សេន ជាគ្រូបង្រៀននៅទីនោះ ហើយនៅទីនោះ **អៀង ធីរិទ្ធ** បានស្គាល់អនាគតស្វាមីគាត់ **អៀង សារី** ដែលជាសិស្សរៀននៅសាលានោះដែរ) **អៀង ធីរិទ្ធ** បានទទួលអាហារូបករណ៍ ដើម្បីទៅបន្ត ការសិក្សានៅទីក្រុងប៉ារីស។ **អៀង ធីរិទ្ធ** បានចាកចេញទៅទីក្រុងប៉ារីសនៅឆ្នាំ១៩៥២ ជាមួយនឹង បងស្រីរបស់គាត់ ខៀវ ប៉ុណ្ណារី (ដែលបានរៀបការជាមួយ សាឡុត ស ហៅ ប៉ុល ពត នៅឆ្នាំ ១៩៥៦)។ **អៀង សារី** បានទៅដល់ទីក្រុងប៉ារីសមុនគាត់ គឺនៅឆ្នាំ១៩៥១ ហើយបន្ទាប់មក ពួកគាត់ក៏បានរៀបការជាមួយគ្នានៅទីក្រុងប៉ារីស។ **អៀង ធីរិទ្ធ** ទទួលបានសញ្ញាប័ត្រខាង អក្សរសាស្ត្រអង់គ្លេស ពីសាកលវិទ្យាល័យ Sorbonne[5392]។

១៦០៧. ពេលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៧ **អៀង ធីរិទ្ធ** បានធ្វើការងារជាគ្រូបង្រៀន មួយរយៈដំបូងនៅសាលាឯកជនមួយ ហើយបន្ទាប់មក នៅវិទ្យាល័យព្រះស៊ីសុវត្ថិ មុននឹងចូលរួម ទាំងស្រុងទៅក្នុងសកម្មភាពបដិវត្តន៍ ចាប់ពីឆ្នាំ១៩៦៥។

១៦០៨. **អៀង ធីរិទ្ធ** បានពន្យល់ប្រាប់ថា ដោយសារការចូលរួមបដិវត្តន៍នេះ និងការរត់ចូលព្រៃរបស់គាត់ គាត់ខានបានជួបកូនរបស់គាត់ អស់រយៈពេលដប់ឆ្នាំ។ កូនទាំងនេះ គាត់បានប្រគល់ទៅឱ្យជីដូន ពួកគេ មើលថែទាំ រហូតដល់រដ្ឋប្រហារឆ្នាំ១៩៧០ ជាថ្ងៃដែលពួកគេបានរត់ចូលព្រៃម៉ាគីដែរ[5393]។

១៦០៩. សកម្មភាពនយោបាយរបស់ **អៀង ធីរិទ្ធ** រហូតដល់ឆ្នាំ១៩៧៩ ត្រូវបានវិភាគនៅក្នុងផ្នែកទាក់ទង នឹងជនត្រូវចោទនៅក្នុងដីកាដំណោះស្រាយនេះ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

**១៦១០.**បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ **អៀង ធីរិទ្ធ** នៅតែជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច តាមការសម្រេចជាថ្មីដោយសមាជសភាតំណាងប្រជាជនកម្ពុជា នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩[5394] ហើយបានបន្តកាន់តួនាទីនេះ យ៉ាងហោចណាស់រហូតដល់ខែឧសភា ឆ្នាំ១៩៨២[5395]។ នៅខែកញ្ញា ឆ្នាំ១៩៨២ **អៀង ធីរិទ្ធ** ជាអគ្គលេខាធិការក្រសួងការបរទេសនៃរដ្ឋាភិបាលសម្ព័ន្ធភាពកម្ពុជាប្រជាធិបតេយ្យ[5396] ហើយកាន់តួនាទីនេះ យ៉ាងហោចណាស់រហូតដល់ចុងខែសីហា ឆ្នាំ១៩៨៥[5397]។ ក្នុងតួនាទីនេះ **អៀង ធីរិទ្ធ** បានចូលរួមនៅក្នុងសន្និសីទអន្តរជាតិជាច្រើន ដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជា[5398] ជាពិសេសនៅអង្គការសហប្រជាជាតិ[5399]។ **អៀង ធីរិទ្ធ** ក៏បានជួបជាមួយគណៈប្រតិភូបរទេសជាច្រើនផងដែរ[5400] ដើម្បីពិភាក្សាអំពីការបង្កើតរដ្ឋាភិបាលសម្ព័ន្ធភាពកម្ពុជាប្រជាធិបតេយ្យ[5401]។ **អៀង ធីរិទ្ធ** ក៏បានជួបជាមួយអ្នកសារពត៌មានបរទេសមួយចំនួនផងដែរ[5402]។ នៅក្នុងសន្និសីទទាំងនោះ ឬនៅក្នុងការសម្ភាសន៍របស់គាត់ជាមួយអ្នកសារពត៌មាន **អៀង ធីរិទ្ធ** បានថ្កោលទោសការកាន់កាប់របស់វៀតណាម និងបានតស៊ូមតិឲ្យមានការវិលមកវិញរបស់បក្សកុម្មុយនីស្តកម្ពុជា[5403]។

**១៦១១.អៀង ធីរិទ្ធ** បានបន្តនៅជាមួយខ្មែរក្រហម រហូតដល់ថ្ងៃដែលស្វាមីគាត់ **អៀង សារី** ចុះចូលនឹងរដ្ឋាភិបាលកម្ពុជា និងទទួលបាននូវការលើកលែងទោស និងការអនុគ្រោះទោសពីព្រះមហាក្សត្រនៅឆ្នាំ១៩៩៦។ បន្ទាប់មក ពួកគាត់បានមករស់នៅជាមួយគ្នា នៅផ្ទះកូនស្រីៗរបស់គាត់នៅទីក្រុងភ្នំពេញ រហូតដល់ថ្ងៃដែលគេចាប់ខ្លួនពួកគាត់ នៅខែវិច្ឆិកា ឆ្នាំ២០០៧។

**១៦១២.**នៅក្នុងក្របខណ្ឌនៃការធ្វើកោសល្យវិច័យចិត្តសាស្ត្រ ដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត អ្នកជំនាញបានប្រាស្រ័យទាក់ទងអស់ពេលយ៉ាងយូរជាមួយ **អៀង ធីរិទ្ធ**។ អ្នកជំនាញបានធ្វើការសន្និដ្ឋានថា **អៀង ធីរិទ្ធ** មិនមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរនោះទេ ដោយលើកឡើងដូច្នេះថា[5404]៖

[លុប]



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

# [លុប]

## ជំពូក ៥- សេចក្តីសម្រេចបញ្ចប់

១៦១៣. អាស្រ័យហេតុនេះ កិច្ចស៊ើបសួរបានបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ តាមរយៈអំពើ សកម្ម និងអំពើអកម្ម នៅទីក្រុងភ្នំពេញ នៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយចូលទឹកដីវៀតណាម ក្នុងរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានប្រព្រឹត្ត (ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម), រៀបចំផែនការ, ញុះញង់ឲ្យប្រព្រឹត្ត, បញ្ជាឲ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដូចខាងក្រោម, បានជួយ និងជម្រុញដល់អ្នកចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ នូវ៖

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន៖**

(ក). ការធ្វើមនុស្សឃាត

(ខ). ការសម្លាប់រង្គាល

(គ). ការធ្វើឲ្យទៅជាទាសករ

(ឃ). ការនិរទេស

(ង). ការដាក់ក្នុងមន្ទីរឃុំឃាំង

(ច). ការធ្វើទារុណកម្ម

(ឆ). ការរំលោភលើផ្លូវភេទ

(ឆ). ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា

(ជ). អំពើអមនុស្សធម៌ផ្សេងៗទៀត

បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00605791



**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុម ចាម និងវៀតណាម**

បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ រួមមាន៖**

(ក). ការធ្វើមនុស្សឃាតដោយចេតនា

(ខ). ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ). ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ). ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង). ការនិរទេស និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

**ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ រួមមាន៖**

(ក)ការធ្វើមនុស្សឃាត

(ខ)ការធ្វើទារុណកម្ម

(គ) ការវាយប្រហារលើសាសនា

បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៣ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក., មាត្រា២០៩ មាត្រា២១០ មាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ ដល់ មាត្រា៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១៕

# ជំពូក ៦- ការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន

បានឃើញវិធាន ៦៣ វិធាន ៦៤ វិធាន ៦៦ វិធាន ៦៨ និង វិធាន ៨២ នៃវិធានផ្ទៃក្នុង

បានឃើញសំណើសុំដោះលែងឱ្យនៅក្រៅឃុំ ធ្វើឡើងដោយមេធាវីការពារក្ដី នួន ជា ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ២០១០ (C65- សំណើសុំដោះលែងឱ្យនៅក្រៅឃុំ)។

បានឃើញការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០១០ (C65/2)

## ផ្នែកទី១- អំពីសំណើសុំនៅក្រៅឃុំរបស់ នួន ជា

### ក. ការរំលឹកឡើងវិញពីនីតិវិធី

១៦១៤.នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ មេធាវីការពារក្ដី នួន ជា បានដាក់សំណើសុំដោះលែងកូនក្ដីរបស់ខ្លួនឱ្យនៅក្រៅឃុំ ដោយអះអាងថា៖

- *"ការឃុំខ្លួនបណ្ដោះអាសន្នយ៉ាងជាពិសេសចំពោះថិរវេលាដែលបានចំណាយនៅក្នុងមន្ទីរឃុំឃាំង 'នៅរង់ចាំសាលក្រមស្ថាពរ' ហើយរយៈពេលឃុំខ្លួនបណ្ដោះអាសន្នត្រូវបញ្ចប់ទៅវិញបន្ទាប់ពីការផ្ដន្ទាទោស ការសម្រេចឱ្យរួចផុតពីការចោទប្រកាន់ ការសម្រេចជាស្ថាពរទៅលើបណ្ដឹងសារទុក្ខ ឬការដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន"*[5405]
- *"រយៈពេលកំណត់ជាអតិបរមាសម្រាប់ឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ដែលអនុញ្ញាតដោយច្បាប់កម្ពុជា គឺមានរយៈពេលបីឆ្នាំ"*[5406]
- *"រាល់ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នដោយ ក.ស.ច.ស រាប់បញ្ចូលទាំងរយៈពេលបួនខែ ដែលអនុញ្ញាតដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង ត្រូវតែគិតបញ្ចូលជាមួយរយៈពេលបីឆ្នាំ"*[5407] ។

១៦១៥.អាស្រ័យដោយហេតុផលទាំងអស់នេះ មេធាវីការពារក្ដី ស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបញ្ចប់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ការឃុំខ្លួនបណ្តោះអាសន្ន នួន ជា នៅពេលផុតថិរវេលាបីឆ្នាំ គឺនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១០។

១៦១៦.សហព្រះរាជអាជ្ញា ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំដោះលែងឱ្យនៅក្រៅឃុំ ធ្វើឡើងដោយមេធាវីការពារក្តី នួន ជា ដោយសំអាងថា៖ *"ច្បាប់ធរមានដែលគ្រប់គ្រងលើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន គឺមាននៅក្នុងវិធានផ្ទៃក្នុង"*។ *"វិធានផ្ទៃក្នុងមិនបានចែងពី រយៈពេលអតិបរិមាបីឆ្នាំនៃការឃុំខ្លួនបណ្តោះអាសន្ន ថាអនុវត្តបានទាំងនៅលើការស៊ើបសួរ និងកិច្ចដំណើរការនីតិវិធីសវនាការទេ (...)* និងថា *"ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទក្នុងរយៈពេលយូរជាងបីឆ្នាំ មិនរំលោភបទដ្ឋានយុត្តិធម៌អន្តរជាតិទេ ដោយសារភាពស្មុគស្មាញនៃសំណុំរឿង ភាពធ្ងន់ធ្ងរនៃបទចោទ និងវិរិយភាពរបស់តុលាការក្នុងពេលបច្ចុប្បន្ននេះ"*[5408]។ ហេតុនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ៖ *"ពាក្យសុំរបស់ជនត្រូវចោទដែលបានស្នើសុំឱ្យដោះលែងជាបណ្តោះអាសន្ន គួរតែត្រូវបានបដិសេធចោល និងថាអនុលោមតាមវិធាន ៦៨ សហចៅក្រមស៊ើបអង្កេតគួរបន្តឃុំខ្លួនជនត្រូវចោទរូបនេះ ព្រមទាំងជនដទៃទៀតដែលអាចនឹងត្រូវបញ្ជូនទៅជម្រះនៅក្នុងដីកាដំណោះស្រាយ រហូតដល់ពេលជនទាំងនេះអាចត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង"*[5409]។

## ខ. សំអាងហេតុនៃសេចក្តីសម្រេច

១៦១៧.វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន[5410] ដែលមានលក្ខណៈដូចគ្នាទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[5411] ដោយក្រមនេះមានអានុភាពលើច្បាប់មុនដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន[5412] ដែលជាច្បាប់ត្រូវបានយោងដោយមេធាវីការពារក្តី[5413]។

១៦១៨.ផ្ទុយពីអ្វីដែលបានអះអាង វិធានផ្ទៃក្នុងមិនបានចែងពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នតែសម្រាប់រយៈពេល បី(៣) ឆ្នាំ ដូចដែលមេធាវីការពារក្តី បានលើកឡើងទេ។

១៦១៩.ទោះបីជាវិធាន៦៣(៦) ចែងថា នៅក្នុងអំឡុងពេលនៃការស៊ើបសួរ ការឃុំខ្លួនបណ្តោះអាសន្នមិនមានថិរវេលាលើសពីមួយឆ្នាំ និងអាចពន្យារពេលបានតែពីរដងក៏ដោយ ក៏វិធាននេះសំដៅតែថិរវេលាដែលគិតចាប់ពីពេលបើក រហូតដល់បិទការស៊ើបសួរប៉ុណ្ណោះ។ នៅពេលណាដែល

ការស៊ើបសួរត្រូវបានបញ្ចប់តាមរយៈការចេញដីកាដំណោះស្រាយ ការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់ លើកលែងតែក្នុងក្របខ័ណ្ឌនៃវិធាន៦៨ និងក្នុងករណីដែលជនជាប់ចោទត្រូវបាននាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបួនខែ នោះជនជាប់ចោទនៅតែបន្តជាប់ឃុំដដែល ដែលករណីនេះនឹងស្ថិតនៅក្រោមបទប្បញ្ញត្តិវិធាន ៨២ នៃវិធានផ្ទៃក្នុង។

១៦២០.ជាចុងក្រោយ ដូចដែលមេធាវីការពារក្តីបានទទួលស្គាល់[5414] គឺថា បទដ្ឋានអន្តរជាតិទាក់ទិននឹងថិរវេលាអតិបរិមានៃការឃុំខ្លួនមុនពេលជំនុំជម្រះ អនុញ្ញាតឲ្យមានរយៈពេលលើសពីការកំណត់ដោយវិធានផ្ទៃក្នុង ដោយសារតែគិតពីកាលៈទេសៈជាមូលហេតុនៃការឃុំខ្លួន និងជាពិសេសពីភាពស្មុគស្មាញនៃសំណុំរឿង[5415]។ ដូច្នេះ ថិរវេលានេះមិនបានរំលោភបទដ្ឋានអន្តរជាតិទាំងនេះទេ ផ្ទុយទៅវិញ វាធានាបាននូវការការពារយ៉ាងល្អចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងថិរវេលាមួយសមស្រប។

១៦២១.ដោយផ្អែកទៅលើកត្តាទាំងអស់នេះ ជាការច្បាស់ណាស់ថា វិធានផ្ទៃក្នុងអនុញ្ញាតឲ្យនៅតែបន្តការឃុំខ្លួនជនជាប់ចោទ នួន ជា ទៀតបាន។ ដូច្នេះ ពាក្យសុំដោះលែងនៅក្រៅឃុំត្រូវបានបដិសេធចោល។

**ផ្នែកទី ២- អំពីការរក្សាការឃុំខ្លួនបណ្តោះអាសន្ន ជនជាប់ចោទ**

**១៦២២.យល់ឃើញថា** ដោយផ្អែកលើបទចោទដែលមាននៅក្នុងដីកានេះ ក្នុងការផ្តល់យុត្តិកម្មដល់ការបញ្ជូន **នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន** ទៅអង្គជំនុំជម្រះ លក្ខខណ្ឌដែលបានកំណត់ដោយវិធាន ៦៣(៣) (ក) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ។

**១៦២៣. យល់ឃើញថា** ទាក់ទិននឹងលក្ខខណ្ឌដែលតម្រូវដោយវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង សំអាងហេតុនៃដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន នួន ជា ចុងក្រោយបង្អស់ (ដែលមិនត្រូវបានប្តឹងឧទ្ធរណ៍)[5416] ហើយសាលដីកាចុងក្រោយរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចលើបណ្តឹង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ខ្ទួរណ៍របស់ **អៀង សារី**[5417], **អៀង ធីរិទ្ធ**[5418] និង **ខៀវ សំផន**[5419] នៅតែរក្សាតំលៃរបស់ខ្លួនដដែល ហើយចំនុចថ្មីដែលមានតែមួយគត់គឺ ការចោទប្រកាន់ទៅលើអ្នកទាំងនោះ ដែលនេះរឹតតែធ្វើសំអាងហេតុដែលមាននៅក្នុងដីកាកន្លងមកកាន់តែមានលក្ខណៈរឹងមាំ និងធ្វើឲ្យការឃុំខ្លួនរឹតតែមានភាពចាំបាច់ជាងពេលណាៗទាំងអស់។

**១៦២៤.ហេតុនេះ យល់ឃើញថា** ការបន្តការឃុំខ្លួនជនជាប់ចោទរហូតដល់ពេលនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ដោយអនុវត្តតាមវិធាន ៦៨ នៃវិធានផ្ទៃក្នុង គឺជាការចាំបាច់ដើម្បី៖

- ទាក់ទងនឹង **នួន ជា** ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ, បង្ការកុំឲ្យមានហានិភ័យ ដែលជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្តុតាង ប្រសិនបើពួកគេ ត្រូវបានដោះលែងឲ្យមានសេរីភាព;
- ទាក់ទងនឹង **អៀង សារី** ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ;
- ទាក់ទងនឹង **អៀង ធីរិទ្ធ** ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ, បង្ការកុំឲ្យមានហានិភ័យ ដែលជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្តុតាង ប្រសិនបើពួកគេ ត្រូវបានដោះលែងឲ្យមានសេរីភាព;
- ទាក់ទងនឹង **ខៀវ សំផន** ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ, បង្ការកុំឲ្យមានហានិភ័យ ដែលជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្តុតាង ប្រសិនបើពួកគេ ត្រូវបានដោះលែងឲ្យមានសេរីភាព;

# ហេតុដូច្នេះ

បានឃើញវិធាន ៦៤ វិធាន៦៧ និងវិធាន ៦៨ នៃវិធានផ្ទៃក្នុង

សម្រេច ដាក់ឲ្យជាប់ចោទ ៖

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

សម្រេចបញ្ជូន ជនជាប់ចោទទាំងនេះទៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីវិនិច្ឆ័យទោសតាមច្បាប់

បដិសេធ ពាក្យសុំដោះលែងនៅក្រៅឃុំរបស់ នួន ជា និង

សម្រេច រក្សាឲ្យនៅជាប់ឃុំបណ្ដោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខអង្គជំនុំជម្រះសាលាដំបូង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**co-juges d'instruction**

យូ ប៊ុនឡេង

**Marcel LEMONDE**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។